ជេម ក្លាវែល

# អគ្គមហាសេនា

# SHŌGUN



ប្រែសម្រួលដោយ ៖ ខៀវ កាញ្ញារីទ្ធ

និង ខៀវ ធេព រស្មី

១

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

៣៣៧:១៧២

ជេម ក្លាវែល

# អគ្គមហាសេនា



## SHŌGUN

ប្រែសម្រួលដោយ : ខៀវ កាញារីទ្ធ

និង ខៀវ ធេព រង្សី

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

១

១០០២/០៣

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថាអ្នកបកប្រែ

សៀវភៅនេះ ជាវណ្ណកម្មមួយដ៏ល្បីល្បាញរបស់លោក *ជេម ក្លាវែល* ។ លោក បានដាក់ប្រលោមនេះក្នុងយុគសម័យ នៃការប្រកួតប្រជែងមហាអំនាចបស្ចិមប្រទេស ក្នុងការទន្ទ្រានយកប្រទេសនានានៅអាព្រិច អាមេរិច និងអាស៊ីធ្វើជាចំនុះរបស់ខ្លួន ហើយដែលជាកត្តាដ៏សំខាន់មួយធ្វើអោយប្រទេសមហាអំនាចទាំងនោះ ប្រែក្លាយជាប្រទេសសំបូររុងរឿងរហូតសព្វថ្ងៃ ។ អ្វីដែលធ្វើអោយខ្ញុំបាទសំរេចយកប្រលោមលោកនេះមកបកប្រែ នៅពេលក្រៅម៉ោងធ្វើការអស់រយៈពេលប្រាំឆ្នាំនេះ គឺការបុកទង្គិចរវាងអារ្យធម៌ពីរ ហើយដែលជាកត្តាមួយយ៉ាងសំខាន់ក្នុងការរស់រានមានជីវិត រឺ ការរលំរលាយ នៃប្រជាជាតិមួយនៅក្នុងប្រវត្តិសាស្ត្រ ។ សមត្ថភាពបំប្លែងការបុកទង្គិចអោយទៅជា កំលាំងជំរុញស្របតាមទំនោរពិភពលោក ទន្ទឹមនឹងរក្សាបាននូវសារធាតុរបស់ខ្លួនមានលក្ខណៈគំនត់ជាទីបំផុតដល់អត្ថិភាពនៃប្រជាជាតិនិមួយៗ ហើយនេះគឺជាលក្ខណសម្បត្តិដ៏សំខាន់ នៃអ្នកដឹកនាំប្រទេស យុទ្ធវិទូ និងបញ្ញជនគ្រប់ៗរូប ។

ខ្ញុំបាទយល់ឃើញថា កត្តាមួយក្នុងកត្តាជាច្រើននៃសោកនាដកម្មរបស់ខ្មែរយើង គឺមោទនភាពហួសហេតុទៅលើអតីតកាលដ៏រុងរឿងរបស់ខ្លួន ។ ភាពរុងរឿងនៃអតីតកាលគឺជាស៊ីម៉ង់ផ្សារផែនឯកភាពជាតិ ជាគ្រឹះនៃស្មារតីស្នេហាជាតិ ស្នេហាមាតុភូមិ ប៉ុន្តែមោទនភាពហួសហេតុរបស់ខ្មែរយើងច្រើនធ្វើអោយខ្មែរងាកចេញពីការពិត នៃបច្ចុប្បន្នភាព ហើយតែងត្រូវបានប្រើជាលេសសំរាលដល់អសមត្ថភាពរបស់ខ្លួនក្នុងការប្រឈមមុខនឹងការទាមទារនៃយុគសម័យ ។ ដោយមោទនភាពហួសហេតុទៅលើអតីតកាលនេះហើយ ទើបខ្មែររមែងស្អប់ជនជាតិថៃ និងវៀតណាមដែលជាជនជាតិធ្វើអោយមហាចក្រភពខ្មែររលំរលាយ ប៉ុន្តែខ្មែរយើងមិនដែល ឬមិនប៉ានពិចារណាអោយបានស៊ីជំរៅលើពាក្យថា " ហេតុអ្វី ? "នោះឡើយ ។ ព្រោះតែយើងគេចពីពាក្យពីរម៉ាត់នេះហើយ ទើបយើងមើលមិនឃើញបាន នូវចំនុចខ្សោយរបស់យើង ក៏ដូចជាមើលមិនឃើញពីចំនុចខ្លាំង របស់សត្រូវរបស់ខ្លួន ។

ខ្ញុំបាទសង្ឃឹមថា ប្រលោមលោកនេះនឹង អាចជាមិត្ត ដ៏មានប្រយោជន៍មួយជួយលំហែអស់លោកនៅពេលទំនេរបាន ។

**ខៀវ ភាញ្ញារិទ្ធ**



www.budinst.gov.kh www.elibraryofcambodia.org

# លំនាំដើម

វាយោបក់បោកឥតឈប់ឈរត្របាក់ខាំសព្វសពាង្គកាយរបស់គេ ។ បើសិនជាពួកគេ មិនបានទៅដល់ដីគោកក្នុងពេលថ្ងៃនេះទេ គេដឹងច្បាស់ណាស់ថា ពួកគេច្បាស់ជានឹងត្រូវស្លាប់ អស់ជាមិនខាន ។ គេគិតនៅក្នុងចិត្តថា ដំណើរជើងនេះ យើងមានការខូចខាតធ្ងន់ហួស ហើយ អីលូវនេះ អញបានក្លាយខ្លួនជាអ្នកបញ្ជាការនៃកងនាវាខ្មោចមួយទៅវិញ ។ ក្នុងសំពៅប្រាំនៅ សល់តែមួយ ក្នុងកងនាវិក ៧០០នាក់ នៅសល់តែ២៨នាក់តែប៉ុណ្ណោះ ហើយក្នុងនេះទៀតមាន តែ១០នាក់ ដែលនៅដើរបាន ។ អ្នកឯទៀត រួមទាំងមេបញ្ជាការផង កំពុងតែត្រដរខ្យល់ទាំង អស់ ។ គ្មានអ្វីទទួលទានទាំងអស់ ហើយរឹតតែគ្មានអ្វីផឹកទៀតផង ក្រៅតែពីទឹកខ្មោះ១ និង មានក្លិនដ៏អាក្រក់នោះ ។

គេមានឈ្មោះថា *ជន ប្លាក់ជន* ។ គេនៅតែម្នាក់ឯងលើជាន់ខាងលើនៃសំពៅ រួមជា មួយនឹងអ្នកសង្កេតសមុទ្រម្នាក់ឈ្មោះ *សាឡូម៉ុង* ហៅអាតំលង់ ដែលកំពុងតែជ្រកក្នុងជំរក របស់ ខ្លួន និងដែលខំបើកភ្នែកសំលឹងមើលជើងមេឃសព្វទិសទីនោះ ។

ខ្យល់បក់មួយរឹបយ៉ាងខ្លាំង ហើយសំពៅ ក៏ចាប់ផ្ទៀង។ *ប្លាក់ជន* ស្រវាច្បាមតោងខ្លួន ទៅនឹងភ្នាក់ដៃកៅអី ដែលគេវាយភ្ជាប់ទៅនឹងក្តារសំពៅដែលនៅជិតចង្កូតនាផ្នែកកន្សៃសំពៅ រហូតដល់សំពៅវិលមកកាន់សភាពដើមវិញ ក្នុងស្នូរសង្វៀតនៃតួសំពៅទាំងមូល ។ សំពៅនេះ ឈ្មោះ *អេរ៉ាស់* ដែលមានចំណុះ ២៦០តោណូ[១] ជាសំពៅជំនួញប្រើដងក្តោង ៣ មកពី *រ៉ូតែដាំ*[២] និងប្រដាប់ដោយកាណុង ២០ដើមទៀតផង ។ជាសំពៅតែមួយដែលនៅសល់ ក្នុង ចំនោម កងប្រតិបត្តិការទីមួយ ដែលត្រូវបានបញ្ជូនពីហូឡង់ ដើម្បីទៅបង្ក្រាបសត្រូវនៅឯពិភព ថ្មី[៣] សំពៅនេះ ស្ថិតក្នុងសំពៅហូឡង់ ដំបូង១គេ ដែលបានទំលាយអាថិកំបាំង នៃច្រកសមុទ្រ

---

*(១)- ឯកតាអន្តរជាតិសំរាប់វាស់ចំណុះនាវា ។ ក្នុងមួយតោណូមានទំហំ ២៨៣ ម៉ែតគូប ។ ( កំនត់អ្នកបក ប្រែ-ក.អ.ប. ) ។*

*(២)- ឈ្មោះទីក្រុង កំពង់ផែមួយ នៃប្រទេសហូឡង់( ក.អ.ប ) ។*

*(៣)- ឈ្មោះដែលនៅសម័យនោះទ្វីបអឺរ៉ុប ហៅទ្វីបអាមេរិច ( ក.អ.ប. ) ។*



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ាសេឡង់*[៤] ។ នៅលើសំពៅមាននាវិក៤៩៦នាក់ ហើយសុទ្ធតែជាអ្នកស្ម័គ្រចិត្តទាំងអស់ ។ ពួកគេសុទ្ធតែមានសញ្ជាតិហូឡង់ ហើយមានតែ ៣នាក់ដែលមានសញ្ជាតិ អង់គ្លេស : អ្នកបើកបរ ២នាក់ និងបញ្ជាការម្នាក់ ។ ទិសដៅរបស់ពួកគេគឺកំទេចអោយម៉ត់នូវ រាល់ទីតាំងកាន់កាប់របស់ពួកអេស្ប៉ាញ និងប៉កទុយកាល់នៅក្នុងពិភពថ្មី ចាត់តាំងដាក់កន្លែង ពាណិជ្ជកម្ម ស្វែងរកនៅក្នុងមហាសមុទ្រប៉ាស៊ីភិច នូវកោះថ្មី១ទៀត ដែលអាចធ្វើជាមូលដ្ឋានអចិន្ត្រៃយ៍បាន និងកាន់កាប់ដែនដីនានា ក្នុងនាមប្រទេសហូឡង់ ។ ហើយក្នុងរយៈពេលបីឆ្នាំពួកគេនឹងវិលទៅកាន់មាតុប្រទេសវិញ ។

ប្រទេសហូឡង់ ដែលប្រកាន់និកាយប្រូតេស្តង់ បានធ្វើសង្គ្រាមអស់រយៈកាល ៤០ឆ្នាំមកហើយ ដើម្បីរំដោះខ្លួនចេញពីនឹមនៃម្ចាស់ដ៏សំអប់របស់ខ្លួន គឺប្រទេសអេស្ប៉ាញ ដែលកាន់និកាយកាតូលិច ។ សម្ព័ន្ធមិត្តតែមួយរបស់ប្រទេសហូឡង់ គឺប្រទេសអង់គ្លេស ដែលជាប្រទេសមុនគេបង្អស់ ក្នុងចំនោមប្រទេសកាន់គ្រិស្តសាសនា ដែលបានផ្តាច់ខ្លួនចេញពីរង្វង់*ប៉ាប*[៥] នៃទីក្រុងរ៉ូម ហើយដែលបានធ្វើសង្គ្រាមប្រឆាំងអេស្ប៉ាញជាង ២០ឆ្នាំមកហើយ១បានរួមដៃជាចំហជាមួយហូឡង់ជាង ១០ឆ្នាំមកហើយផងដែរ ។

ខ្យល់កាន់តែត្រជាក់ សំពៅក៏កាន់តែហក់ទៅមុខ ។ គេបានទំលាក់ក្តោងសំខាន់១អស់ហើយ នៅសល់តែក្តោងតូច១សំរាប់ប្រើនៅពេលមេឃមិនល្អតែប៉ុណ្ណោះ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏រលក និងព្យុះនៅតែរុញសំពៅអោយហក់ទៅជើងមេឃ ដ៏ខ្មៅងងឹតនេះដែរ ។

ប្លាក់ថន គិតថា តំបន់នេះរឹតតែសំបូរដោយព្យុះ ដោយផ្ទាំងថ្ម និងបាតរាក់១ជាច្រើនទៀតជាមិនខាន ។ ម្យ៉ាងទៀតគេមិនដែលបើកកាត់កន្លែងនេះផង ។ ប៉ុន្តែមិនអីទេ ។ ម៉ាជីវិតអញ១តែងប្រយុទ្ធទល់នឹងសមុទ្រ ហើយអញតែងឈ្នះរហូត ។ លើកនេះអញនឹងឈ្នះទៀត ។

---

*(៤) - ច្រកសមុទ្រដែលស្ថិតនៅរវាងចន្លោះត្បូងបំផុតនៃទ្វីបអាមេរិច និងប្រជុំ កោះ ដីអគ្គី (Tierra Del Fuego ) ហើយដែល ហ្វែណង់ដឺម៉ាសែឡង់ សញ្ជាតិប៉កទុយកាល់ រកឃើញដើម្បីឆ្លងពីមហាសមុទ្រអាត្លង់ទិចចូលមហាសមុទ្រ ប៉ាស៊ីភិច ( ក.អ.ប ) ។*

*(៥) - សម្តេច សង្ឃរាជនៃគ្រិស្តសាសនា ដែលត្រួតលើគ្រិស្តសាសនិកទូទាំងពិភពលោក ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

*ក្លាក់ថន* ជាជនជាតិអង់គ្លេសដំបូងបង្អស់ ដែលបានឆ្លងច្រកសមុទ្រម៉ាសេឡង់ ។ ពិតណាស់ជាជនជាតិអង់គ្លេសដំបូងបង្អស់ ។ ហើយក៏ជាអ្នកដំបូងបង្អស់ដែរ ដែលបានបើកសំពៅទៅលើសាគរអាស៊ីនេះ ។ នេះបើមិនរាប់ពីពួកខិលខូចប៉ុកទុយកាល់ និងពួកពាលអេស្ប៉ាញប៉ុន្មានក្បាល ដែលនៅតែនឹកថា ខ្លួនជាម្ចាស់ពិភពលោកតទៅទៀតនោះចេញ ។ ជាជនជាតិអង់គ្លេសដំបូង បង្អស់លើដែនទឹកនេះ ......

ជាអ្នកដំបូងច្រើនបែប ។ ពិតជាអីចឹងមែន។ ហើយក៏មានមនុស្សស្លាប់មិនតិចទេដើម្បីឈានរកឋានៈនេះ ។ គេស្រូបខ្យល់ហើយហិតក្លិនមើល ប៉ុន្តែគ្មានស្នាមអ្វីដែលបញ្ជាក់ថា មានដីគោកសោះ ។ គេសំលឹងរាវរកមហាសាគរ ប៉ុន្តែគេគ្មានឃើញអ្វីក្រៅពីកំហឹងនិងភាពដាសនោះសោះ ។ គ្មានសារ៉ាយ គ្មានពណ៌ថ្លា ដែលបញ្ជាក់ថាមាន ខ្សាច់នៅជិតផ្ទៃទឹកបន្តិចបន្តួចណាសោះ ។ គេឃើញមានចុងផ្កាំងថ្មមួយ លេចចេញពីផ្ទៃទឹកនៅស្តាំដៃសំពៅនាទីឆ្ងាយ ប៉ុន្តែវាមិនអាចអោយគេសំគាល់យល់បានអ្វីទាំងអស់ ។ ជាងមួយខែមកហើយដែលថ្មប៉ប្រះផ្ទៃទឹកទាំងនេះ ធ្វើអោយគេមានអារម្មណ៍ប្រុងប្រយ័ត្ន តែក៏គ្មានដីគោកឯណាដែរ ។ មហាសមុទ្រនេះគ្មានទីបញ្ចប់សោះតែម្តងឬអី ? -គេគិតនៅក្នុង ចិត្ត ។ បានអីចឹង ! អ្នែងត្រូវរ៉ិករ៉ិនសំរាប់អីចឹងហើយតើ នោះគឺបើកកាត់សមុទ្រ ដែលមិន ធ្លាប់ស្គាល់ស្វែងយល់អោយស្គាល់ ហើយត្រលប់ទៅប្រទេសវិញ ។ ពីនេះទៅដល់ ផ្ទះយើងត្រូវស៊ីពេលប៉ុន្មានថ្ងៃអីចេះ ? មួយឆ្នាំ ១១ខែនិង២ថ្ងៃ ។ កំពង់សំចតនៅស៊ីលី ស្ថិតនៅឆ្ងាយពីកន្លែងនេះ ១៣៣ថ្ងៃទៅហើយ គឺនៅពីម្ខាងទៀតនៃមហាសមុទ្រ ដែល គេហៅថា ប៉ាស៊ីភិចនេះហើយដែលលោក *ម៉ាស៊េឡង់* បានឆ្លងកាត់មុនគេបង្អស់ កាលពី ៨០ឆ្នាំមុននេះ[៦] ។

---

*(៦) - លោក ម៉ាស៊េឡង់ បានឆ្លងកាត់ពីមហាសមុទ្រ អាត្លង់ទិច មកមហាសមុទ្រ ប៉ាស៊ីភិច នៅឆ្នាំ ១៥២០ ហើយលោកឆ្លងកាត់មហាសមុទ្រប៉ាស៊ីភិចនេះ ដើម្បីវិលទៅអឺរ៉ុបវិញ ប៉ុន្តែលោកត្រូវ ជនជាតិ ភីលីពីន សំលាប់នៅឆ្នាំ ១៥២១ នៅលើកោះ ភីលីពីននោះ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ាក់ថង់* មានតំលានយ៉ាងខ្លាំង ។ មាត់និងខ្លួនប្រាណរបស់គេត្រូវស្កប៊ុត [៧] រុករាន ទន្ទ្រានយ៉ាងធ្ងន់ធ្ងរ ។ គេបង្ខំចិត្តផ្ទៀងផ្ទាត់ឡើងវិញនូវផ្លូវបើកបររបស់សំពៅ អាស្រ័យដោយ ដែកឈាន និងអាស្រ័យដោយការប្រមាណពីទីតាំងប្រហាក់ប្រហែលរបស់ពួកគេ ។ នៅពេល ដែលបំរាប់ ត្រូវគេកត់ចូលក្នុងសៀវភៅប្រចាំនាវាហើយនោះ គេប្រហែលជាមានសន្តិសុខ ខ្លះនៅលើជ្រុងមួយនៃមហាសមុទ្រនេះ ។ បើសិនជាគេមានសន្តិសុខ នាវាគេក៏អឺចឹងដែរ ។ ដល់អឺចឹងទៅ ទាំងគេ ទាំងសំពៅប្រហែលជាអាចស្វែងស្គាល់ពីប្រជុំកោះជប៉ុន រឺអែលដូរ៉ាដូ [៨] របស់ស្តេចគ្រិស្តសាសនិក *វ៉ែប្រស្គីជន* ដែលរឿងព្រេងបាននិយាយថា នៅភាគខាងជើង កាតៃ [៩] ទោះជាគេមិនដឹងថា កាតៃនោះនៅឯណាក៏ដោយ ។ ពេលណាអញបានចំនែក ទ្រព្យសម្បត្តិ ធនធានទាំងប៉ុន្មានរបស់អញហើយ អញនឹងជិះសំពៅត់រង់ទៅស្រុកអញវិញ ក្នុងឋានៈជាអ្នក សំពៅអង់គ្លេសដំបូងគេបង្អស់ ដែលបានដើរជុំវិញពិភពលោក ហើយអញឈប់ដើរចោល មាតុភូមិអញទៀតហើយ -ឈប់រហូតតែម្តង ខ្ញុំសុំស្បថដោយយកជីវិតកូនប្រុសជា បន្ទាល់ ។

តំហុកខ្យល់ធ្វើអោយគេអាក់ខាន ក្នុងការរវើរវាយ ទន្ទឹមនឹងទប់គេកុំអោយលង់លក់ ក្នុងដំណេក ។ ដេកលក់គឺពិតជាចំកួតពេញទី ។ បើអ្នែងដេក លក់ អ្នែងគ្មានផ្លូវភ្ញាក់វិញទេ - គេគិតក្នុងចិត្ត ។ គេពត់ខ្លួនដើម្បីបន្ធូរសាច់ដុំខ្នង ដ៏ស្ពឹកស្រពន់ រួចគេក៏ទាញរឹតបន្តឹងអាវក្រៅ របស់គេ ។ *ម៉ាក់ថង់* មើលឃើញថា ក្តោងត្រូវរៀបចំស្រេចបាច់ ចង្កូតសំពៅ ក៏ត្រូវចងរឹតយ៉ាង ណែន ឯអ្នកមើលផ្លូវ ក៏នៅប្រចាំការនៅកន្លែងខ្លួនផងដែរ ។ គេក៏អង្គុយចុះ ហើយក៏តាំង សង្រួងបួងសួងដើម្បី អោយបានទៅដល់ដីគោក ។

---

*(៧ )-Scorbut ជំងឺដែលបណ្តាលមកពីកង្វះវីតាមីនសេ ពិសេសនៅសម័យនោះនាវិកនៅ ពេលធ្វើ ដំណើរឆ្ងាយ ហូបតែម្ហូបក្រៀមក្រោះ ( ក.អ.ប ) ។*

*(៨ ) - សុវណ្ណភូមិ ( ក.អ.ប )*

*(៩ ) - ឈ្មោះដែលគេហៅប្រទេសចិន កាលពីដើម* ( CATHAY )



www.budinst.gov.kh www.elibraryofcambodia.org

" បងតែកុង ចុះទៅក្រោមទៅ ។ ទុកខ្ញុំជំនួសម្តង បើបងមិនយល់ទាស់ទេ " អនុសេនីយ៍ទោជំនួយការ *ហ៊ិនឌ្រិចស្មិច* ឡើងជណ្តើរទាំងលំបាក ។ មុខរបស់ *ហ៊ិនឌ្រិច* ឡើងពណ៌ប្រផេះ ព្រោះការនឿយហត់ ភ្នែកឡើងហើមនិងល្អក់ ចំនែកឯស្បែកគេវិញ ឡើងក្រហមដុំៗ ជាំពេញខ្លួន ។ គេប្រឹងគ្រវែងខ្លួន ហើយផ្អែកខ្លួនទាំងដុលទៅលើបន្ទប់សំពៅ ដើម្បីសំរួលខ្លួន ។ ឱព្រះអើយព្រះ ! ថ្ងៃដែលអញចេញពីហូឡង់ គឺជាថ្ងៃចង្រៃរលត់រលាយតែម្ដង ។

- អ្នកជំនួយការទីមួយនៅឯណា *ហ៊ិនឌ្រិច* ?

- នៅលើគ្រែ។ វាដើបលែងរួចតែរហូតហ្នឹង ឬបើងើបរួចទាល់តែដល់ពេលជួបយមរាជហើយ ។

- រួចចុះលោកមេបញ្ជាការ ?

*ហ៊ិនឌ្រិច* ស្តោះទឹកមាត់

-គាត់ទារផឹក ទារហូប ។ខ្ញុំប្រាប់គាត់ថា ចាំខ្ញុំរ៉ូទីមាន់ក្រៀវអោយមួយហើយចាំខ្ញុំលើកជូនគាត់លើថាសប្រាក់ថែមទាំងកូញាក់មួយដបទៀតដើម្បីអោយគាត់ស្រួលលេប ។ កូនមី......!

- នែ៎ ! អោយថ្នមសំដីបន្តិចទៅអ្នា !

- បាទខ្ញុំឈប់ឡូឡាហើយបង ។ តែលោកមេបញ្ជាការ គឺចំជាមនុស្សឡប់មែនទែនតែម្តង មើលទៅយើងស្លាប់តែទាំងអស់គ្នា ដោយសារតែគាត់ហ្នឹងតែម្ដង - យុវបុរសគ្រវែងខ្លួនម្ដងទៀត ហើយក៏ផ្ដើមក្អួតវែកៗបណ្តោយ - ឱព្រះអើយព្រះ ។ ខ្ញុំសូមអង្វរសូមជួយខ្ញុំផង។

- នែ៎ ! ឯងចុះទៅវិញចុះ ហើយចាំភ្លឺសឹមឡើងមកណា៎ !

*ហ៊ិនឌ្រិច* ដាក់បង្គុយលើកៅអីទាំងត្រដាបត្រដួស

- នៅខាងក្រោមថុំតែក្លិនងាប់ទេ ។ បើស្រួលទុកខ្ញុំជំនួសម្តងវិញទៅ ។ អីលូវយើងទៅតាមទិសណាហ្នឹង ?

- តាមទិសដែលខ្យល់បក់ហ្នឹងណា៎ ?

- រួចចុះឯណាឆ្នេរ ដែលបងបានសន្យានោះ ? រួចចុះប្រទេសជប៉ុននោះនៅឯណា ? នៅឯណាទៅអ្នាស ?



www.budinst.gov.kh www.elibraryofcambodia.org

- នៅពីមុខត្រង់ណឹង !

- ម្ដងណា ក៏ចេះតែថា ត្រង់ទៅមុខៗ ! វិបល់យក៍ ! មានអ្នកណាណែនាំអោយបើកសំពៅមិនដឹងកោះត្រើយយ៉ាងនេះ ? ធ្វើរណេះយើងគួរតែដល់ផ្ទះយើងវិញស៊ីណែនពោះ មិនមែនមកដើររកភ្លើងយក្សអ៊ីចឹងទេ ។

- អីលូវចុះក្រោមវិញទៅ ! បើនៅ ឈប់មាត់ !

*ហ៊ិនទ្រ៊ិច* បែរមុខ ដ៏មូម៉ងរបស់ខ្លួនចេញពីមនុស្សពុកមាត់ស្រមូម និងដែលមានមាឌដ៏ធំនេះ ។ តើយើងនៅទីណាណឹង ? នេះសំនួរដែលគេប៉ងសួរ ។ តើអញមិនអាចអានសៀវភៅសំងាត់ប្រចាំនាវានោះ គាក់តូចទេអ្ហី ? តែ*ហ៊ិនទ្រ៊ិច* ក៏ដឹងដែរថា គេមិនត្រូវលើកសំនួរបែបនេះដល់អ្នកបើកសំពៅឡើយ ពិសេសទៅទៀតចំពោះមនុស្សនេះ ។ ឱ ! បើសិនជាអញមានសុខភាពល្អដូចកាលពីពេលចេញមកពីហូឡង់អីអ្ហា៎ អញច្បាស់ជាមិនបាច់រួញរាទេ ។ អញច្បាស់ជាវ៉ៃបែកអាភ្នែកខៀវប្រផេះរបស់ឯ្អងហើយ ។ អញច្បាស់ជាជាន់កំទេចអាស្នាមញញឹមបែបចំអករបស់ឯ្អង ធ្វើវាអោយទាល់តែលែងមាននៅលើផ្ទៃមុខឯ្អង ហើយជាន់ឯ្អងអោយលិចដល់ឋាននរក ។ នេះបានសមមុខឯ្អង ។ ពេលណុងអញ នឹងក្លាយជាប្រធានបើកបរសំពៅហើយដល់អ៊ីចឹងទៅ មិនមែនជនបរទេសទៀតទេ គឺច្បាស់ជាជនជាតិហូឡង់ហើយ ដែលនឹងបើកសំពៅនេះ ហើយយើងក្លាប់បានការណ៍សំងាត់នានាជាមិនខាន ។ ព្រោះបើគិតៗទៅទោះជាយ៉ាងណាក៏ពួកអញ ច្បាស់ជាត្រូវច្បាំងជាមួយពួកឯងមិនលែងទេ ពួកអង់គ្លេសឯងនេះ ។ យើងសំលឹងមើលគោលដៅតែមួយ នោះគឺធ្វើម្ចាស់លើសមុទ្រក្លាប់រាល់ផ្លូវពាណិជ្ជកម្មត្រួតត្រាពិភពថ្មីរីតកអេស្ប៉ាញ ។ រួច *ហ៊ិនទ្រ៊ិច* រអ៊ូឡើង : " ជប៉ុននេះ ប្រហែលជាមិនដែលមានទេមើលទៅ ។ ប្រហែលជារឿងព្រេងប៉ុណ្ណឹងទេមើលទៅ " ។

- ជប៉ុន ពិតជាមានមែន ។ វានៅចន្លោះអង្សាទី ៣០ និងទី ៤០ នៃខ្សែរយៈទទឹងភាគខាងជើង ។ អីលូវនេះ ឬមួយឯងបិទមាត់ ឬមួយឯងចុះទៅខាងក្រោម ។

*ហ៊ិនទ្រ៊ិច* និយាយរអ៊ូរ៉ូ : " យមរាជកំពុងក្រវែលនៅខាងក្រោមបង " រួចក៏សំលឹងមើលត្រង់ទៅមុខ ។



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ផន* ប្តូរទិសរបស់សំពៅ ។ គេមានការយ៉ាប់យ៉ឺនខ្លាំងនៅថ្ងៃនេះ ។ អ្នែងមានសំនាងជាងគេហើយអាវ៉ា -គេគិតនៅក្នុងចិត្ត -អ្នែងមានសំនាងជាងអា *ហ៊ែនទ្រិច* ។ ទេ និយាយមែនទែនទៅ មិនមែនមានសំនាងជាងនោះទេ ។ តាមពិតទៅ គឺអ្នែងចេះគិតគូរជាង គេ ។ អ្នែងចេះសំចៃផ្លែឈើក្នុងពេល ដែលអ្នកឯទៀតវាត់ខ្នក ទោះជាអ្នែងណែនាំយ៉ាងណាក្តី នោះ ។ ស្តុប៊ិតរបស់អ្នែងនៅក្នុងគីរិតទាបនៅឡើយ ។ អ្នកឯទៀតតែងធ្លាក់ឈាម រាកអាច់ ភ្នែកស្លី និងមានធ្មេញសណ្តក រឺក៏ធ្លាក់ជ្រុះតែម្តង ។ ចុះហេតុអី ក៏មនុស្សមិនចង់ រៀនសូត្រ សោះអ៊ីចឹង ?

ប្លាក់ផន ដឹងខ្លួនថាទាំងអស់គ្នា រាប់ទាំងមេបញ្ជាការសំពៅផង សុទ្ធតែខ្លាចគេ ហើយ មានភាគច្រើនផងដែលស្អប់គេ ។ តែអារឿងនេះគឺជារឿងធម្មតាទេ ព្រោះថាអ្នកបើកបរគឺជា ម្ចាស់តែមួយគត់នៅលើសមុទ្រ ។ គឺមានតែគេទេដែលមានសិទ្ធិសំរេចថា ត្រូវបើកសំពៅទៅ តាមផ្លូវណា មានតែគេទេដែលបញ្ជាសំពៅ មានតែគេទេដែលនាំសំពៅពីផែមួយទៅផែមួយ ។

ដំណើរម្តង១គឺជាការផ្សងព្រេងដ៏គ្រោះថ្នាក់ ពីព្រោះផែនទីសមុទ្រដែលមានទាំង ប៉ុន្មាន គឺជារបស់អត់ប្រយោជន៍ ព្រោះវាមានលក្ខណៈលំ១ សើ១តែប៉ុណ្ណោះ ។ ម្យ៉ាងទៀតគេ គ្មានមធ្យោបាយអ្វីនឹងវាស់ខ្សែបណ្តោយផែនទីផង ។

បុរសជរា *អាលបានកាភ៊ុក* ដែលជាគ្រូរបស់ *ប្លាក់ផន* រមែងតែងនិយាយប្រាប់គេថា: រកអោយឃើញនូវមធ្យោបាយ ដើម្បីគំនត់បានខ្សែរយៈបណ្តោយផែនដី ហើយឯងនឹងក្លាយ ទៅជាមនុស្សមានជាងគេបំផុតនៅលើផែនដីនេះ ។ បើឯងដោះបញ្ហាអាថិកំបាំងនេះបាន ព្រះ មហាក្សត្រិយានីយើង -សូមព្រះជួយប្រសិទ្ធពរព្រះនាង -នឹងអោយឯងមួយម៉ឺនលីវ (១០) និងអាណាខេត្តមួយ ។ ពួកអាកំហូចប៊កទុយកាល់នឹងអោយឯងច្រើនជាងនេះទៅទៀត : មាស មួយសំពៅ ឯពួកពាលអេស្ប៉ាញវិញ នឹងអោយឯងជាង ២០ ! ជាធម្មតាចេញឆ្ងាយពីច្រាំងគឺឯង វង្វេងអ៊ីចឹងអាទូន ។ លោក *កាភ៊ុក* ទៅស្ងៀមស្ងាត់ ។ រួចលោកងក់ក្បាលផ្ងក់ផ្អើកយ៉ាង

---

*( ១០ ) -លុយរបស់អង់គ្លេស ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

កំសត់ទទឹមនឹងសំលឹងទៅកាន់ *ភ្លាក់ថន* ដូចសព្ទមួយដង ។ អានួន ឯងនឹងវង្វេងលើកលែងតែ....

- លើកលែងតែមាន កាកណោ !

*ភ្លាក់ថន* ស្រែកឡើងយ៉ាងរីករាយដោយដឹងថា ខ្លួនគេបានរៀនសូត្រយ៉ាងច្បាស់ពីមេរៀននេះ ។ កាលនោះ *ភ្លាក់ថន* មានអាយុ ១៣ឆ្នាំ ហើយគេបានចូលមកហាត់រៀន ជាមួយលោក *កាកំដុក* បានមួយឆ្នាំហើយ ។ លោក *កាកំដុក* ជាអ្នកបើកបរនាវាផង ជាជាងធ្វើនាវាផង ហើយលោកបានជំនួសឪពុករបស់ *ភ្លាក់ថន* ក្រោយពីឪពុក *ភ្លាក់ថន* ស្លាប់បាត់ទៅ ។ លោក *កាកំដុក* មិនដែលវាយធ្វើបាប *ភ្លាក់ថន* ទេតែផ្ទុយទៅវិញដូចជាចំពោះក្មេង១ឯទៀតដែរ លោកបានបង្រៀនដល់គេនូវរាល់ចំនេះ និងល្បិចនានាក្នុងការសាងសង់នាវា និងជីវិតអាថិកំបាំង នៃសមុទ្រសាគរ ។

កាកណោ គឺជាកូនសៀវភៅដែលនិយាយលំអិតពីការសង្កេតនានា របស់អ្នកបើកសំពៅម្នាក់ ដែលធ្លាប់មកដល់ទីនេះ ដូចជាចំនុចដែលវាស់ដោយដែកឈានរវាងផៃ នឹងជ្រោយច្រកសមុទ្រ រី ជ្រោយខ្ពស់ ដែកសណ្តូន ពណ៌ទឹក និងប្រភេទបាតសមុទ្រ ។ តើយ៉ាងម៉េចគេទៅដល់កន្លែងនោះ និងយ៉ាងម៉េចគេត្រលប់មកវិញបាន : តើគេត្រូវឆ្លងកាត់ប៉ុន្មានថ្ងៃ ប្រភេទខ្យល់ពេលណាវាបក់ បក់មកពីទិសណា ប្រភពនិងទិសនៃចរន្តទឹក រដូវខ្យល់ព្យុះ រីរដូវដែលមានខ្យល់អំនោយផល កន្លែងដែលអាចជួសជុលសំពៅ កន្លែងណាដែលត្រូវទំលាក់យុថ្កា កន្លែងណាមានសត្រូវ កន្លែងណាដែលសំពៅគៀង ថ្មប៉ប្រះទឹក ទឹកជោរនាច កំពង់ផៃ និយាយរួមត្រូវពតិមានចាំបាច់ទាំងអស់ ដើម្បីដំណើរប្រកបដោយភាពសុខសាន្តមួយ ។

ពួកអង់គ្លេស ពួកហូឡង់ និងពួកបារាំង សុទ្ធតែមានសៀវភៅការងារនៅលើសំពៅនិមួយ១របស់ខ្លួន ប៉ុន្តែសៀវភៅទាំងនោះ និយាយទាក់ទិនតែពីដែនសមុទ្រ របស់ប្រទេសនិមួយ១តែប៉ុណ្ណោះ ។ ផ្ទៃសមុទ្រផ្សេងគ្មានអ្នកណាស្គាល់ក្រៅតែពីនាយនាវាប៉កទុយកាល់ និងអេស្ប៉ាញប៉ុណ្ណោះ ។ សៀវភៅដែលប្រាប់ពីច្រកផ្លូវ ទៅកាន់ពិភពថ្មី រីដែលបើកទំលាយពីអាថិកំបាំងនៃច្រកសមុទ្រ ម៉ាស៊ែឡង់ រី ជ្រោយសង្ឃឹម (១១) ដែលជារបកគំហើញរបស់ប៉កទុយកាល់ទាំងពីរ ហើយដែលជាច្រកនាំទៅដល់ទ្វីបអាស៊ីនោះ ត្រូវគេរក្សាទុកដាក់យ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

គត់មត់ ដូចជាទ្រព្យមហាសាល របស់ប្រទេសជាតិ ហើយទាំងសត្រូវអង់គ្លេស និង ហូឡង់សុទ្ធតែស្រក់ទឹកមាត់ចង់បានដូចៗគ្នា ។ ប៉ុន្តែសៀវភៅមានតំលៃទៅបានក៏អាស្រ័យទៅនឹងតំលៃរបស់អ្នកបើកដែលបានកត់ត្រាវា ទៅនឹងតំលៃស្បៀនដែលចំលងវា ទៅនឹងអ្នកដែលបានបោះពុម្ពវាវិទៅនឹងអ្នកអក្សរសាស្ត្រដែលបានបកប្រែវា ថ្វីត្បិតតែអ្នកជំពូកទីពីរខាងក្រោយនេះ ស្ថិតនៅក្នុងចំនោមអ្នកដែលកំរមានឱកាសបានស្គាល់វាក្តី ។ កូនសៀវភៅ អាចមានការភ័ន្តច្រលំដោយចេតនាដោយហេតុនេះ អ្នកបើកសំពៅមិនច្បាស់ថាស្គាល់អស់នោះទេគឺទាល់តែទៅដោយខ្លួនឯងថែមទៀត ។ យ៉ាងហោចណាស់ទៅស្គាល់កន្លែងមួយជើងសិនដែរ ។ នៅលើសមុទ្រ អ្នកបើកបរគឺជាស្តេចតែមួយអង្គ ជាអ្នកនាំផ្លូវតែម្នាក់ និងជាអាជ្ញាកណ្តាលខ្ពស់បំផុតរវាងសំពៅនឹងក្រុមនាវិក ។ ពីខាងកន្សែអ្នកបើកចេញបញ្ជាតែម្នាក់ឯងគត់ ។

*ប្លាក់ថន* តែងនិយាយនឹងខ្លួនឯងថា ស្ថានភាពនេះ ប្រៀបដូចជាស្រាញៀនអីចឹង ។ តែធ្លាប់ភ្លក់វាម្តងហើយគេមិនអាចបំភ្លេចវាបានទេ ។ គេច្បាស់ជារកវាទៀត រករហូតតែម្តង។ ហើយប្រការនេះហើយ ដែលជួយឯងអោយត្រដរស់បានក្នុងពេលដែលអ្នកឯទៀតស្លាប់បាត់បង់ជីវិតនេះ ។

*ប្លាក់ថន* ងើបចេញពីកៅអី ហើយទៅបន្ទោរបង់តាមប្រហោងគែមសំពៅ ។ នៅក្បែរបន្ទប់អ្នកបើក ជីខ្សាច់បានធ្លាក់អស់ក្នុងផ្នែកដបម្ខាងទៀតហើយ (១២) ។ គេលើកដបជីខ្សាច់ត្រលប់វា ហើយវាយជួងបន្លឺសំលេងឡើង ។

- អ្ហែងច្បាស់ជាមិនដេកលក់មែនអ្ហឺ *ហ៊ិនទ្រិច* ?

---

*(១១) - ជ្រោយផ្នែកខាងត្បូងនៃទ្វីបអាព្រិច ហើយដែលរកឃើញដោយលោក បាកតូឡូម៉ឺឌី យ៉ាស់នៅឆ្នាំ ១៤៨៧ ( ក.អ.ប ) ជាភាសាបារាំងគេហៅថា* Cap de Bonne Esperance *ជាភាសាអង់គ្លេស* Cape of Good Hope.

*( ១២ ) ក្នុងសម័យនោះ ដោយគ្មាននាឡិកា គេធ្វើដបមាត់តូចពីរ ផ្ទាប់ទល់មុខគ្នា ។ នៅម្ខាងគេដាក់ជីខ្សាច់ គេកំណត់ម៉ោងពេលនេះ អាស្រ័យរយៈពេលដែលជីខ្សាច់ ហូរពីដបម្ខាង ចូលម្ខាងទៀតអស់ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

- មិនអីទេ មើលទៅ

- ចាំខ្ញុំ ទៅហៅអ្នកណាម្នាក់មកបួរអ្នកមើលផ្លូវ ។ មើលវាផង ។ អោយវាឈរមុខខ្យល់អីចឹងហើយ កុំអោយវាទៅសំកុកបាំងខ្យល់ណាំ ។ ខ្យល់បក់អីចឹងអោយវាស្វាងមិនងុយដេកផង ។

*ប្លាក់ថន* ដណ្តឹងសួរខ្លួនឯងមួយសន្ទុះដែរ ថាតើគួរទៅរោងសំភក ហើយបន្ថយក្តោងដើម្បីបង្អង់ល្បឿនសំពៅនាវេលាយប់នេះ រឺយ៉ាងណា រួចគេក៏សំរេចថាទុកដូចដដែលអីចឹង ។ គេបើកក្តារដែលនៅឯក្បាលសំពៅ ហើយចុះទៅកន្លែងពួកនាវិក ដែលមានទំហំមួយទទឹងសំពៅនោះ ។ នៅទីនេះមានគ្រែ និងអង្រឹងសំរាប់មនុស្ស ១២០នាក់ ។ កំដៅបានមករួបរឹតខ្លួនគេហើយ *ប្លាក់ថន* ធូរទ្រូងបន្តិច ព្រោះកំដៅនេះធ្វើអោយគេអាចបំភ្លេចនូវក្លិនអសោចន៍ ដែលច្រាលពីបាតសំពៅមកនោះ ។ មនុស្សជាង ២០នាក់ ដែលមានវត្តមាននៅក្នុងបន្ទប់នេះ ឥតមានកំរើកខ្លួនអ្វីបន្តិចណាសោះឡើយ ។

- *មែតស៊ីតែ* ឡើងទៅលើ !

*ប្លាក់ថន* និយាយជាភាសាហូឡង់ គឺជាភាសាដែលគេចេះនិយាយយ៉ាងស្ទាត់ រួមទាំងភាសាប៉ក់ទុយកាល់ អេស្ប៉ាញ និងឡាតាំងផងដែរ ។

- ខ្ញុំជិតងាប់ហើយ

បុរសរាងតូចមុខឆ្អឹង ឆ្លើយតបទន្ទឹមនឹងខំខ្សៀនខ្លួនទៅក្នុងដំណេក ។

- ខ្ញុំឈឺណាំ ! បងមិនឃើញទេអ្ហី ? ស្តុប៊ុតដកធ្មេញខ្ញុំអស់រលីងទៅហើយ ។ឱ ! ព្រះអើយព្រះ ! ជួយពួកខ្ញុំផង មើលទៅពួកយើងខ្ញុំស្លាប់អស់គ្មានសល់ម្នាក់ទេ ! នែ៎ ! បើកុំតែបងឯង កុំអីពួកយើងត្រលប់ទៅដល់ស្រុកវិញបាត់ទៅហើយ ! ខ្ញុំជាអ្នកជំនួញណាំ ! មិនមែនអ្នកដើរសំពៅទេ ។ ខ្ញុំមិនមែននៅក្នុងក្រុមនាវិកទេ ...... ហៅអ្នកណាផ្សេងទៀតទៅ ទុះ ! ដូចជាអា *យ៉ូហាន់* អាអីនោះ -*មែតស៊ីតែ* លាន់សំរែកឡើងនៅពេលដែល *ប្លាក់ថន* ទាញខ្លួនចេញពីដំណេកហើយ បោះយ៉ាងអស់ទំហឹងសំដៅទៅទ្វារ ។ ឈាមហូរពេញមាត់ *មែតស៊ីតែ* តែនៅពេលដែលជើងរបស់ *ប្លាក់ថន* ទាត់ត្រូវឆ្អឹងជំនីគេមួយផ្ទូងថែមទៀតនោះទើប



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ែតស៊ីតែ* ស្ទាងមែនទែនតែម្តង ។

-ភ្លេងឡើងទៅខាងលើ ហើយនៅទីណុងរហូតដល់ពេលដាច់ខ្យល់ងាប់ រឺមួយរហូតដល់ពេលសំពៅដល់ច្រាំងណាំ !

*ម៉ែតស៊ីតែ* បើកទ្វារ ហើយរត់ចេញបាត់យ៉ាងលឿនដូចផ្លេកបន្ទោរ ។

*ប្លាក់ថន* សំលឹងមើលអ្នកឯទៀត១ ក៏សំលឹងមើលមកគេវិញ ។

- យ៉ាងម៉េចហើយ *យ៉ូហាន់វិញ* ?

- មិនអីទេបងតែកុង ខ្ញុំប្រហែលទប់ទល់បាន

*យ៉ូហាន់វិញ* មានអាយុ៤៣ឆ្នាំ ។ គាត់ជាប្រធានកាណុងផង ជាអនុប្រធានផ្នែកក្តោងផង ។ជាមនុស្សមានវ័យចំនាស់ជាងគេនៅលើសំពៅ មានក្បាលទំពែក និងមាត់គ្រហុប *យ៉ូហាន់* មានសំបុរដូចជាដើមស្រល់ ប៉ុន្តែក៏មានថាមពលដូចជាដើមស្រល់ផងដែរ ។៦ឆ្នាំមុននេះ *យ៉ូហាន់* រួមជាមួយ *ប្លាក់ថន* នៅក្នុងការរុករកច្រកអីសានមួយដោយគ្មានបានផលអ្វីទាំងអស់ ។ ទាំងពីរនាក់ស្គាល់គ្នាទៅវិញទៅមកយ៉ាងច្បាស់ណាស់ ។

- មនុស្សភាគច្រើន ស្លាប់បាត់ទៅហើយនៅពេលមានអាយុដូចឯងនេះ ។ ឯងស៊ីដាច់ពួកយើងតែទាំងអស់ហើ៎ង !

*ប្លាក់ថន* មានអាយុ៣៦ឆ្នាំ ។ *វិញ* ញញឹមតបយ៉ាងស្រងូតស្រងាត់ :

- នេះគឺគុណបុណ្យកូញាក់ណាំ ! ថែមបានគុណបុណ្យស្រី និងការសូត្រធម៌រាល់ថ្ងៃរបស់ខ្ញុំទៀត - គ្មានអ្នកណាផ្ទុះសំនើចទេ ។ អ្នកណាម្នាក់ចង្អុលទៅគ្រែមួយទៀតដោយពោលពាក្យឡើង :

- បងតែកុង ប្រធានក្តោងស្លាប់ហើយ !

- យកសពឡើងទៅលើ ហើយចំអាសទឹក និងបិទភ្នែកគាត់ផង ! ទំ ! ឯងមួយ ! ឯងមួយ ! ទៅ ! -ម្តងនេះអ្នកមានខ្លួនធើបយ៉ាងរហ័ស ។ ពួកគេនាំគ្នាអូសសពចេញក្រៅបន្ទប់បាត់ទៅ ។

- *វិញ* ដល់ពេលជិតភ្លឺ ឯងឡើងទៅបញ្ជាសំពៅម្តងណាំ ! *គីនសែល*ឯងទៅមើលផ្លូវ



www.budinst.gov.kh www.elibraryofcambodia.org

នៅឯក្បាលសំពៅលើទេ ?

- បាទ

*ប្លាក់ថន* ឡើងទៅជាន់ខាងលើវិញ ។ គេឃើញថា *ហិនឌ្រិច* នៅតែបើកភ្នែកក្រលោតនៅឡើយ ហើយអ្វីៗក៏នៅរៀបរយដដែល ។ *សាឡូម៉ុងដែលទើបត្រូវគេមកដូរវេនដើរជិត *ប្លាក់ថន* ក្នុងដំណើរទ្រេតទ្រោត មើលទៅដូចជាខ្មោចច្រើនជាងមនុស្ស ។ ភ្នែករបស់ *សាឡូម៉ុង* ឡើងក្រហម និងហើមប៉ោងព្រោះខ្យល់បក់បោក ។ *ប្លាក់ថន* ដើរតាមបណ្តោយសំពៅ ហើយចុះតាមជណ្តើរកន្សៃនៃសំពៅសំដៅទៅបន្ទប់ធំ ។

បន្ទប់ធំនេះ ជាសេនាធិការដ្ឋានរបស់បញ្ជាការផង ជាឃ្លាំងគ្រាប់ផង ។ បន្ទប់របស់ *ប្លាក់ថន* ស្ថិតនៅចំហៀងខាងស្តាំសំពៅ ឯបន្ទប់ខាងឆ្វេង គឺជាបន្ទប់របស់នាយទាហានបីនាក់នោះគឺ *ពាតួសវ៉ាន់ណិត* ដែលជាមេឈ្មួញដ៏ធំ *ហិនឌ្រិច* អនុសេនីយ៍ទោជំនួយការ និងយុវជនម្នាក់ឈ្មោះ *ត្រូក* ។ តាមពិតពួកគេទាំងបីកំពុងត្រូវជំងឺរុករាន យ៉ាងខ្លាំងណាស់ទៅហើយ ។

*ប្លាក់ថន* ដើរចូលបន្ទប់ធំ ប៉ុន្តែ *ស្ទីលប៉ែកកេន* ជាមេបញ្ជាការកំពុងដេកស្ងួកស្ងីង ដឹងខ្លួនបន្តិច មិនដឹងខ្លួនបន្តិចនៅលើគ្រែរបស់ខ្លួន ។ ជាមនុស្សមានមុខក្រហមជាប់ និងដុះក្បាលពោះស្តួយផងនោះ អីលូវនេះគាត់នៅសល់តែឆ្អឹងរឃើងតែប៉ុណ្ណោះ ។ ស្បែកពោះគាត់អីលូវនេះធ្លាក់រយាក ។

*ប្លាក់ថន* ដកយកផង់ទឹកពីថតតុសំងាត់មួយ ហើយជួយមេបញ្ជាការនាវាអោយក្រេបទឹក ។

- អរគុណ -ស្ទីលប៉ែកកេននិយាយខ្សាវៗ -ជីគោកនៅឯណាទៅ ? ជីគោកនៅឯណាទៅ ?

*ប្លាក់ថន* ឆ្លើយតបដោយទាំងលែងជឿខ្លួនឯងថែមទៀតទៅហើយ :

- នៅពីមុខត្រង់ !

រួចគេដាក់ផង់ទឹកនៅក្បែរនោះ ហើយគេដើរចេញពីបន្ទប់ដោយចិត្តមួម៉ង ហើយចិត្តស្អប់បញ្ជាការគេនេះ បានងើបរើឡើងវិញម្តងទៀតជាថ្មី ។



www.budinst.gov.kh www.elibraryofcambodia.org

កាលពីមួយឆ្នាំមុននេះ ពួកគេបានមកដល់ដីអគ្គី ។ ពេលនោះខ្យល់អំនោយផលណាស់ ដើម្បីចោះទំលាយអាថ៌កំបាំងនៃច្រកសមុទ្រ ម៉ាសែឡង់ តែបញ្ជាការនេះឯងបានបញ្ជាអោយគេឡើងគោក ដើម្បីស្វែងរកមាស និងកំនប់ទៅវិញ ។

- តែលោកមេបញ្ជាការ ម៉េចក៏មិនមើល ? ទៅរកកំនប់ឯណាកណ្តាលវាលរហោស្ថានយ៉ាងនេះនោះ ?

- រឿងព្រេងបាននិយាយថា កន្លែងនេះសំបូរមាសណាស់ ។ ម៉្យាងទៀតយើងអាចកាន់ កាប់ដែនដីនេះក្នុងនាមប្រទេសហូឡង់ ដ៏ជាញជ័យបានដែរតើ !

- ជាង ៥០ឆ្នាំហើយ ដែលពួកអេស្ប៉ាញទាំងវ៉ូងមកទីនេះ !

- វាអាចអីចឹងមែន ប៉ុន្តែពួកវាមិនដែលមកដល់ចុងខាងត្បូង បានឆ្ងាយយ៉ាងនេះដែរលោកតៃកុង !

- នៅខ្សែរយៈទទឹងខាងនេះ រដូវគឺផ្ទុយពីយើង ហើយខែឧសភា មិថុនា កក្កដា និងសីហា គឺជារដូវរងាទៅវិញទេ ។ កូនសៀវភៅបានបញ្ជាក់ហើយថា ពេលនេះគឺជាកំនត់ណាស់ក្នុងការឆ្លងកាត់ច្រកសមុទ្រនេះ ព្រោះខ្យល់នឹងប្តូរទិសក្នុងពេលប៉ុន្មានអាទិត្យទៀតនេះ តែហួសពីនេះយើងត្រូវទ្រាំនៅកន្លែងនេះ និងទ្រាំទ្ររដូវរងារាប់ខែហើយ ។

- អីលូវនៅសល់ប៉ុន្មានអាទិត្យទៀតលោកតៃកុង ?

- កូនសៀវភៅ ដាក់ថា៨អាទិត្យ ប៉ុន្តែរដូវមួយទៅរដូវមួយ មានការប្រែប្រួលណាំ !

- បើអីចឹងយើងចុះរុករក២អាទិត្យចុះ ព្រោះពេលក៏នៅសល់ច្រើនណាស់ដែរ មិនថាអីចឹង ? ម៉្យាងទៀតបើឆ្លងមិនរួច យើងបែរក្បាលឡើងទៅទិសខាងជើង ដើរប្លន់ក្រុងពីរបីទៅ (១៣) រួចគ្នាទៅហើយមិនថាអីចឹងអស់លោក ?

- តែលោកមេបញ្ជាការ គឺអីលូវនេះហើយដែលយើងត្រូវឆ្លងកាត់ច្រកផ្លូវនេះ ។ នៅ

---

*( ១៣ ) - ក្នុងសម័យនោះការប្លន់ក្រុង រឺសំពៅរបស់ប្រទេសដែលជាគូសត្រូវនឹងប្រទេសខ្លួន មិនចាត់ថាជាឧក្រិដ្ឋកម្ម រឺអសីលធម៌ទេ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងមហាសមុទ្រប៉ាស៊ីភិច. ពួកអេស្ប៉ាញមានសំពៅតែបន្តិចបន្តួចប៉ុណ្ណោះ ចំនែកឯនៅទីនេះ វិញពួកវាមាននាវាល្បាតច្រើនណាស់ ។ បើយើងបន្តដំណើររបស់យើងគឺនៅពេលនេះឯង ។

តែមេបញ្ជាការមិនព្រមតាមមតិរបស់ *ប្លាក់ថន* សោះ ហើយបែរជាទាមទារអោយបញ្ជាការឯទៀតបោះឆ្នោតសំរេច ។ ឯអ្នកបើកសំពៅទាំង ៣នាក់ ដែលម្នាក់ជាអង់គ្លេស ២នាក់ទៀតជាហូឡង់នោះ គេឥតអោយរួមមតិសំរេចសោះទេ ។ មិនតែប៉ុណ្ណោះមេបញ្ជាការនេះនៅបានដឹកនាំកំលាំងចុះរុករកដោយគ្មានបានផល នៅឯដីគោកដោយខ្លួនឯងផ្ទាល់ថែមទៀត ។ នៅឆ្នាំនោះ ខ្យល់បានប្តូរទិសរហ័សណាស់ ។ពួកគេទាំងអស់គ្នា ក៏ត្រូវនៅតាំងស្ងៀមមួយរដូវរងា ព្រោះមេបញ្ជាការមិនហ៊ានបែរក្បាលទៅទិសខាងជើងវិញ ដោយខ្លាចនាវាចរណ៍អេស្ប៉ាញ ។ អស់ជាង ៤ខែទើបពួកគេអាចបន្ត ដំណើរទៅមុខទៀតបាន ។ ក្នុងរយៈពេល៤ខែនេះ មនុស្ស ១៥៦នាក់ត្រូវស្លាប់ដោយដាច់ពោះ ដោយរងា និងដោយរាកមួល ។ ពួកគេស៊ីរហូតដល់ខ្សែព្រ័ត្រ ។ បន្ទាប់មកខ្យល់ព្យុះដ៏គួរអោយស្ញើមនៅតាមច្រកសមុទ្រនោះ បានកំទេចកងសំពៅទាំងប៉ុន្មានបង្ហើយទៅ ។ *អេហ៊ាស់* គឺជាសំពៅតែមួយគត់ ដែលបានមកជួបមុខនឹងឆ្នេរប្រទេសស៊ីលី ។ ពួកគេរង់ចាំអ្នកឯទៀតអស់រយៈពេលមួយខែដែរ តែដោយត្រូវពួកអេស្ប៉ាញឡោមព័ទ្ធនោះ ពួកគេ ក៏បើកសំពៅចេញទាំងគ្មានដឹងទិសតំបន់អ្វី ព្រោះកំនត់របស់កូនសៀវភៅបញ្ចប់ត្រឹមប្រទេសស៊ីលីនេះឯង ។

*ប្លាក់ថន* ដើរតាមរបៀងបន្ទប់ ហើយបើកបន្ទប់របស់ខ្លួន ។ ពេលចូលហើយគេបិទទ្វារវិញយ៉ាងមធ្យ័ត ។ បន្ទប់នេះទាបតូច តែមានការរៀបចំយ៉ាងស្អាតបាត ។ ដើម្បីដើរទៅអង្គុយនៅនឹងតុរបស់ខ្លួន *ប្លាក់ថន* ត្រូវអោនក្បាលដើម្បីកុំអោយទង្គិចនឹងរនូត ។ គេបើកថតតុហើយលូកយកយ៉ាងថ្នម១ នូវផ្លែប៉ោមចុងក្រោយបង្អស់ ដែលគេបានថែរក្សាយ៉ាងម៉ត់ចត់តាំងពីកោះសាន់តាម៉ារីយ៉ា ឯនាយសមុទ្រនៃប្រទេសស៊ីលីនោះមកម្ល៉េះ ។ ផ្លែប៉ោមនេះតូច ហើយមានស្នាមជាំពេញផង ។ កន្លែងដែលជាំខ្លាំង មានផ្សិតតូច១ដុះពេញទៅហើយ ។ *ប្លាក់ថន* ពុះផ្លែប៉ោមមួយជ្រុង ។ នៅខាងក្នុងមានដង្កូវខ្លះ១ទៅហើយ តែគេទំពារវាជាមួយផ្លែប៉ោមតែម្តងដោយខំដាក់ជំនឿទៅលើពាក្យនិយាយត១គ្នា របស់អ្នកដើរសមុទ្រដែលថាដង្កូវនេះ ក៏មាន



www.budinst.gov.kh www.elibraryofcambodia.org

ប្រសិទ្ធភាពដូចជាផ្លែឈើដែរ ក្នុងការទប់ទល់នឹងស្កប៊ុត ពិសេសពេលសាច់វាប៉ះនឹងអញ្ចាញធ្មេញ វាការពារធ្មេញមិនអោយសណ្តកជ្រុះបាន ។ គេទំពារផ្លែប៉ោមយ៉ាងថ្នម១ ព្រោះធ្មេញគេពោរពេញដោយការឈឺចាប់ រីឯអញ្ចាញធ្មេញគេឡើងសង្កៀរដូចគេបកស្បែកយ៉ាងដូចនោះដែរ ។ បន្ទាប់មកគេហូបមួយជ្រុងទៀតទើបផឹកទឹកពីរបីក្អឹក ។ ទឹកចុំក្លិនម្ជិះ១ ។ គេខំខ្ចប់ផ្លែប៉ោមហើយរុញចូលទៅក្នុងថតតុ និងបិទវាវិញ ។

កណ្តុរមួយបោលលឿនស្ទើរ ។ នៅលើក្តារក្រាលកន្លាតរត់ពាសពេញ ។

- អញហត់ណាស់ ! អញហត់សំបើមណាស់តែម្តង !

*ប្លាក់ថន* ចោលភ្នែកសំលឹងមួយភ្លែតទៅគ្រែដំណេករបស់ខ្លួន ។ ពូកដែលមានរាងតូចទ្រវែងនេះហាក់ដូចបោះដៃមករកគេអ៊ីចឹង ។

- អញហត់សំបើមណាស់តែម្តង !

គំនិតទ្រមក់របស់គេហាក់ដូចជាខំផ្គុំត្រចៀករបស់គេ : ដេកមួយម៉ោងអីទៅ រឺយ៉ាងហោចណាស់ ១០នាទីអីទៅ រួចហើយច្បាស់ជាមានកំលាំងបានមួយអាទិត្យទៀតអីដែរ ។ប៉ុន្មានថ្ងៃចុងក្រោយ អ្នែងបានដេកតែប៉ុន្មានម៉ោងទេ ហើយភាគច្រើនដេកនៅតែពីខាងលើ ហាលវងាទៀត ។ អ្នែងត្រូវតែដេក ។ ដេកទៅ អ្នកឯទៀតគេទុកចិត្តលើអ្នែងហើយ ............

- ទេ ! អញចាំស្អែកបានដេក

*ប្លាក់ថន* និយាយខ្លាំង១ទៅកាន់ខ្លួនឯង ។ គេបង្ខំដៃគេអោយបើកហិប ហើយយកកូនសៀវភៅចេញមក ។ គេបានកត់សំគាល់យ៉ាងរីករាយថា កូនសៀវភៅមួយទៀត ដែលសរសេរជាភាសាប៉ាកទុយកាល់នោះ នៅតែស្ថិតនៅក្នុងសន្តិសុខ និងក្នុងជំរកដ៏មាំទាំរបស់វាដដែល ។ គេចាប់យកស្លាបក្ខានស្អាតមួយ ហើយចាប់ផ្តើមសរសេរ :

" ២១ មេសា ឆ្នាំ ១៦០០ ។ យាមទីប្រាំ ។ មេឃចាប់ផ្តើមងងឹតជិតយប់ ។ ថ្ងៃទី ១៣៣ បន្ទាប់ពីកោះ សាន់តាម៉ារីយ៉ាប្រទេសស៊ីលី ។ ខ្សែរយៈទទឹង ឧត្តរ ២១អង្សា ។ សមុទ្រ នៅតែរលកខ្លាំង ។ ខ្យល់ខ្លាំង ។ នាវារៀបចំតាមស្ថានភាពចំពោះមុខនេះ ។ សមុទ្រពណ៌ស្លេល្អក់ឃើញបាត ។ សំពៅបើកក្នុងលក្ខណៈអំនោយផលតាមផ្លូវ ២៧០ អង្សា ។



www.budinst.gov.kh www.elibraryofcambodia.org

បត់តាមទិសខាងជើង រួចពាយ័ព្យ ។ ល្បឿនល្បឿនប្រហែល ២យោជន៍ ក្នុង១យោជន៍ ៣ ម៉ៃយ[១៤] ។ មានថ្មប៉ប្រះទឹកធំ១ រាងជាត្រីកោណមើលឃើញក្នុងចំងាយប្រហែលកន្លះម៉ោង នៅទិសខាង ជើង-ពាយ័ព្យ កន្លះយោជន៍ពីផ្នែកខាងស្ដាំនាវា[១៥] ។

មនុស្ស ៣នាក់បានស្លាប់ កាលពីយប់មិញដោយ ស្កប៊ុត : *យូរីស* អ្នកកាន់ក្ដោង *រ៉ីស* អ្នកកាន់កាណុង និង *ដឹហាន* អ្នកជំនួយការ ។ ក្រោយពីបង្សុកូលរួចហើយ១ដោយលោកមេបញ្ជាការនៅមានជំងឺនៅឡើយ ខ្ញុំបានទំលាក់សពចុះសមុទ្រដោយគ្មានស្លប់រុំ ព្រោះគ្មានអ្នកណាដេរស្លប់ឡើយ ។ នៅថ្ងៃនេះ *វិចក្កូវ*ប្រធានក្ដោងបានទទួលមរណភាព ។

ខ្ញុំមិនបានមានពេលសង្កេតមើលព្រះអាទិត្យនៅពេលថ្ងៃត្រង់ឡើយ ។ ប៉ុន្តែខ្ញុំគិតថា យើងច្បាស់ជានៅចំផ្លូវហើយ១យើងនឹងទៅដល់ជប៉ុន ក្នុងពេលឆាប់១នេះ ................" ។

ឆាប់១នេះ តែតើអង្កាលទៅ ? *ប្លាក់ផុន* សួរសំនួរទៅចង្កៀងដែលយោលតេកតោក១ តាមកំលាំងមុជងើបនៃសំពៅ ហើយដែលគេព្យួរនៅលើក្បាលគេនោះ ។ តើធ្វើយ៉ាងម៉េចអាចគូសវាស់ផែនទីសមុទ្រនេះបាន ? វាច្បាស់ជាមានមធ្យោបាយអីមួយមិនខាន ។ នេះជាសំដីទីលានដងហើយ ដែលគេនិយាយទៅកាន់ខ្លួនឯង ។ តើធ្វើម្ដេច អាចកំនត់ខ្សែរយៈបណ្ដោយបាននោះ ? វាច្បាស់ជាមានមធ្យោបាយមួយមិនខាន ។ តើធ្វើម៉េចអាចថែរក្សាបន្លែបង្កាយូរបាន ? រួចអីទៅអាស្កប៊ុតនោះ ? .

- គេគិតថា វាជាជំងឺរាករូសសមុទ្រណាំ !

នេះជាសំដីរបស់លោកតា *អាល់បានកាវ៉ាដុក*ដែលជាមនុស្សប្រកបដោយសប្បុរសធម៌ មានពុកមាត់ល្បាយអាចំខ្លា និង ដ៏ស្រមូមនោះ ។

ចុះហេតុអីក៏គេមិនស្ងោរបន្លែ ហើយទុកវាអីចឹងទៅ ?

---

*(១៤) - ក្នុងមួយម៉ៃយ៍សមុទ្រ មាន១៦០៩ម៉ែត ( ក.អ.ប ) ។*

*(១៥) - គេចាត់ឆ្វេង ស្ដាំនាវា ដោយបែរមុខទៅរកទិស ដែលនាវាបើកទៅមុខ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

- ឈឺងាប់ហើយអាវ៉ា ! មិនទាន់មានអ្នកណារកឃើញមធ្យោបាយទុកវាអោយបានយូរទៅឡើយទេ ។

-លឺថា *ប្រង់ស៊ីសវ្រេក* (១៦) គិតចេញដំណើរទៀតហើយ

- ទេអាវ៉ា ស្តែងទៅជាមួយគេមិនទាន់បានទេ

- ខ្ញុំអាយុជិត ១៤ឆ្នាំហើយហ្នឹង ! ចុះម៉េចអ៊ំអោយអា*ទីម* និងអា *វ៉ាត* ទៅជាមួយគេឯងបាន ។ លោក *វ្រេក* គាត់ត្រូវការអ្នករៀនសាកបើកសំពៅដែរតើ ។

- អា*ទីម* អា*វ៉ាត* អាយុ ១៦ឆ្នាំហើយ ។ ស្តែងវិញទើបបាន ១៣ឆ្នាំបន្តិចបន្តួចប៉ុណ្ណឹង?

- គេថាគាត់នឹងសាកល្បងឆ្លងកាត់ច្រកសមុទ្រ ម៉ាសែឡង់ រួចគាត់នឹងបើកសៀវតាមឆ្នេរបហូតដល់កន្លែង ដែលគ្មានមនុស្សទៅដល់ គឺទៅដល់ កាលីភ័រនី ដើម្បីរកច្រកសមុទ្រអានីញ៉ាន ដែលភ្ជាប់ប៉ាស៊ីភិចទៅអាត្លង់ទិច អោយទាល់តែឃើញ ។ គេថាគាត់នឹងបើកសំពៅចេញ ពី កាលីភ័រនីត្រង់ទៅដីថ្មី (១៧) និយាយរួមគឺច្រកពាយ័ព្យ ។

- អានេះរឿងគេនិទានត។គ្នាទេ ។ មិនទាន់មានអ្នកណាមួយបង្ហាញថារឿងច្រកពាយ័ព្យនេះមានពិតមែន រឺអត់ផង ។

- គាត់ច្បាស់ជាធ្វើរឿងនេះ ។ អីលូវនេះគាត់ជាឧត្តមនាវីទៅហើយ។នេះជានាវាអង់គ្លេសទីមួយដែលនឹងឆ្លងកាត់ច្រកសមុទ្រ ម៉ាសែឡង់ ហើយដែលនឹងជានាវា ទី ១ ដែលបានឆ្លងទៅដល់ ប៉ាស៊ីភិច ។ ឪកាសដ៏ល្អយ៉ាងនេះ ខ្ញុំមិនងាយបានជួបប្រទះទេលោកអ៊ី ។

- តង់តែជួបទេ ។ ម្យ៉ាងទៀត *វ្រេក* មិនងាយនឹងទំលាយអាថិកំបាំងច្រកសមុទ្រ ម៉ាសែឡង់ បានជាដាច់ខាត លើកលែងតែលួចបានកូនសៀវភៅមួយ រឺក៏អាចចាប់បានតៃកុងសំ

---

*( ១៦ ) - អ្នកដើរសំពៅ ដ៏ល្បីល្បាញសញ្ជាតិអង់គ្លេសក្នុងសម័យនោះ ( ១៥៤០-១៥៩៦ ) ។*

*( ១៧ ) - កោះដ៏ធំមួយ ( ១១២ ២៩៩គីឡូម៉ែតការ៉េ ) ដែលស្ថិតនៅភាគអីសាន នៃប្រទេសកាណាដា ចំពោមទន្លេ សាន់ឡូរ៉ង់ ជាភាសាអង់គ្លេស New Foundland ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

ពៅប៉កទុយកាល់ណាម្នាក់ ។ អ្អែងមិនលឺអីតែងនិយាយប្រាប់អ្អែងរឿយៗទេអ្ហីថា តែកុងត្រូវចេះ អត់ធ្មត់ ។ រៀនអត់ធ្មត់អាវ៉ា ! អ្អែងនៅមាន ..........

- អីខ្ញុំសូមអង្វរ !

- ទេ !

- ហេតុអី ?

- ពីព្រោះ *វ្រេក* ត្រូវធ្វើដំណើរ ២ ទៅ ៣ ឆ្នាំ រឺអាចយូរជាងនេះទៅទៀត ។ អ្នកខ្សោយមួយ ក្មេងៗមួយ ស៊ីមិនគ្រប់គ្រាន់ហើយរកតែទឹកផឹក ក៏សឹងតែគ្មានផង ។ ក្នុងសំពៅ ៥ហ្លុង មានតែសំពៅ *វ្រេក*ទេ ដែលនឹងវិលត្រលប់មកវិញ ។ អ្អែងទប់ទល់មិនរួច ទេអាវ៉ា !

- បើអីចឹង ខ្ញុំទៅធ្វើការលើសំពៅគាត់ទៅ ! ខ្ញុំខ្លាំងស្រាប់គាត់ច្បាស់ជាយកខ្ញុំ ។

- នែ៎ស្តាប់អញ ! អញធ្លាប់នៅជាមួយអា *វ្រេក* នៅលើសំពៅ *យូឌីត* ។ នោះជាសំពៅចំនុះហាសិបតោណូ នៅឯ*សានជូន* *មូអ៊ីលូឡា* ក្នុងពេលដែលយើងវាយបំបែកការហ៊ុមព័ទ្ធ របស់ ពួកអាត្មាតអេស្ប៉ាញ ដើម្បីចេញផុតពីកំពង់ផែ ។ កាលនោះឧត្តមនាវី *ហកគីន* នៅលើសំពៅ ឈ្មោះ *មីនីញ៉ុន* ។ យើងរកស៊ីជួញទាសករ ពីប្រទេសគីនេ មកសមុទ្រអង់ទី ប៉ុន្តែយើងអត់បានសុំច្បាប់ពួកវាៗ ក៏បោក *ហកគីន* បញ្ឆោតវ៉ុងសំពៅយើង អោយចូលអន្ទាក់ពួកវាតែម្តង ។ ពួកវាមានសំពៅធំៗ ១៣ ឯយើងវិញ យើងមានតែ ៦គ្រឿងតែប៉ុណ្ណោះឯង ។ យើងបាញ់លិចសំពៅវា ៣ វាបាញ់ពន្លិចយើង វិញអស់ សំពៅ *សាឡូវ អង់សែល*មួយ *កាភាវែល*មួយ និង*យេស៊ូលូបិច*មួយ ។ អើនេះដោយសារ *វ្រេក* គេរំដោះ ពួកអញអោយបានមកស្រុក វិញណឹងណាំ ! តែអ្អែងដឹងថា នៅសល់មនុស្សនៅលើសំពៅប៉ុន្មាននាក់ទេ ដើម្បីនិយាយ រឿងនេះ ? ១១ នាក់គត់ ។ ឯលោក *ហកគីន* នៅសល់ ១៥ នាក់ ។ សល់តែប៉ុណ្ណឹង ក្នុងចំនោម ជើងដើរសមុទ្រ ៤០៨ នាក់ ! អញប្រាប់ឯងអាវ៉ា *វ្រេក* ជាមនុស្សគ្មានចេះអាណិតអាសូរអីទេ ។ វាចង់បានតែមាស វាចង់បានតែកិត្តិស័ព្ទតែសំរាប់ខ្លួនវាម្នាក់ប៉ុណ្ណោះ ។មានមនុស្សស្លាប់មិនតិចទេដែលគ្រាន់ធ្វើជាភស្តុតាងនៃចរិតនេះ ។

- ខ្ញុំមិនស្តាប់ទេ ខ្ញុំនឹងទៅជា ......



www.budinst.gov.kh www.elibraryofcambodia.org

- ទេ ! ឯងត្រូវហាត់រៀនចំនួន ១២ឆ្នាំ ។ ឥឡូវនេះនៅសល់ ១០ឆ្នាំ ទៀតរួចពីយើង អ្នែងចង់ទៅណាទៅចុះ ។ តែមុនដល់ពេលនោះ គឺឆ្នាំ ១៩៨៨ អ្នែងត្រូវរៀនធ្វើសំពៅ និងរៀនបញ្ជាសំពៅ ។ អ្នែងត្រូវស្តាប់បង្គាប់កញ្ចាស់ *អាលបានកាភ៍ដុក* ដែលជាគ្រូជាងឈើ ជាតែកុង និង ជាសមាជិកសមាគម *ទ្រីនីទីហ្វូវ* (១៨) នេះ ។ បើមិនអីចឹងទេ អ្នែងអត់បានសញ្ញាប័ត្រទេវ៉ឺ ហើយបើកាលណាអ្នែងអត់មានសញ្ញាប័ត្រហើយ អ្នែងមិនអាចបើកនាវាណាបាននៅលើដែនទឹកអង់គ្លេសទេ ! អ្នែងមិនអាចបើកនាវាអង់គ្លេសណាមួយនៅលើសមុទ្រណាមួយបានទេ ព្រោះនេះជាច្បាប់របស់ព្រះមហាក្សត្រជាទីស្រលាញ់របស់យើង *ព្រះបាទ ហង់រី* និងសូមព្រះអង្គបានសោយសុខក្នុងសុគតិភព ព្រោះនេះគឺជាច្បាប់របស់ មិមេសំធឹង *ម៉ារីទុដ័រ* (១៩) សូមអោយវានៅតែក្នុងឋាននរក ព្រោះនេះគឺជាច្បាប់របស់ព្រះរាជាយើង សូមព្រះអង្គនៅសោយរាជ្យអស់យូរអង្វែង ហើយនេះគឺជាច្បាប់អង់គ្លេស ដែលជាច្បាប់ល្អប្រសើរជាងគេបំ ផុតមកដល់ពេលនេះ ។

*ច្ចាក់ចន* នៅនឹកឃើញពីកំហឹង និងសំអប់ដែលគេបានជះទៅលើគ្រូរបស់គេ ទៅលើសមាគម *ទ្រីនីទីហ្វូវ* ទៅលើភាពពាក់កណ្តាលទាសភាពក្នុង ១២ឆ្នាំនេះ ហើយដែលគេដឹងច្បាស់ថា បើអត់ពីអ្វី១នេះទេគេក៏ច្បាស់ជាមិនអាចទទួលនូវអ្វីតែមួយ ដែលគេស្រមៃចង់បាននោះឡើយ ។ គេកាន់តែស្អប់ *អាល់បានកាភ៍ដុក* ថែមទៀតនៅពេលដែល *រ៉ូដ្រិក* បានឈានដល់កិត្តិស័ព្ទអមត : នៅពេលដែលបានវិលមកប្រទេសអង់គ្លេសក្នុងពេល ៣ ឆ្នាំក្រោយ នៅលើសំពៅចំនុះ ១០០ តោណូរបស់ខ្លួន ដែលមាន

---

*(១៨)-(Trinity House): សមាគមដែលទទួលអោយសញ្ញាប័ត្រ និងដាក់ពោង ផ្សេង១ជាសញ្ញាសំគាល់សំរាប់ចរាចរណ៍ផ្លូវទឹក នៅតាមឆ្នេរជុំវិញប្រទេសអង់គ្លេស (ក.អ.ប) ។*

*(១៩)- ម៉ារីទុដ័រ (១៥១៦-១៥៥៨) មហាក្សត្រិយានីអង់គ្លេស ដែលបាន បង្ក្រាបយ៉ាងឃោរឃៅពួកនិកាយប្រូតេស្តង់ រហូតដល់មាន រហស្សនាមថា " ម៉ារីឈាមជោក " (ក.អ.ប) ។*



www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះហៅថា " *កូលដែលហាញ* " នេះ ។ ជានាវា អង់គ្លេសទី១ ដែលបានធ្វើដំណើរព័ទ្ធជុំវិញពិភពលោក ហើយដោយនាំយកមកវិញនូវទ្រព្យធនដ៏សំបើម មិនដែលមានអ្នកណាប្រមូលបានតាមបណ្តោយឆ្នេរទាំងនោះ : ទ្រព្យតំលៃជាលីវ ជាង មួយលានគន្លះ ជាមាស ជាប្រាក់ ជាគ្រឿងទេស និងគ្រឿងអលង្ការ ផ្សេងៗ ។ ទោះបីជាក្នុង សំពៅ៥ សំពៅ៤ត្រូវបាត់បង់ក្តី ទោះបីជាក្នុងនាវិក១០នាក់ មាន៨នាក់ស្លាប់ក្តី ទោះបីជាអា*ទិម* អា*វិត* ត្រូវបាត់ខ្លួនក្តី ទោះបីមានតែកុង ប៉កទុយកាល់ បានជួយ *ដ្រេក* ក្នុងការ ឆ្លងកាត់ច្រកសមុទ្រ *ម៉ាស៊ែឡង់* ដើម្បី ចូលទៅកាន់ មហាសាគរ ប៉ាស៊ីភិចក្តី ក៏ទាំងអស់នេះ មិនបាន បន្ថយតំនុំរបស់ *ឆ្លាក់ថន* ឡើយ ។ ថ្វីត្បិតតែ *ដ្រេក* បានព្យួរកមេបញ្ជាការម្នាក់ថ្វីត្បិតតែ *ដ្រេក* បានផ្សឹកអ្នកអោយចមិ *វ៉្លេតឆី* និង មិនអាចរកឃើញច្រកផ្លូវពាយ័ព្យនោះក្តី ក៏ទាំង អស់នេះ មិនបានប៉ះពាល់ និង ប្រលាក់ប្រលូសដល់ភាពចិញ្ចាចចិញ្ចែង នៃការស្ញើចសរសើរទូទាំងប្រទេសដែរ ។ ព្រះមហាក្សត្រយានី បានរំលែកចែកទ្រព្យរបស់ *ដ្រេក* ពាក់កណ្តាល និងបានលើកតំកើង *ដ្រេក* អោយទៅជាអភិជន ។ ពួកអភិជន និង ពួកឈ្មួញ ដែលបានដាក់វិនិយោគក្នុងការស្វែង រកលាភនេះបានទទួលចំណេញ ៣០០ ភាគរយ ហើយពួកគេខំសំពះអង្វរករ *ដ្រេក* អោយពួក គេជាអ្នកទទួលចេញលុយ នៅដំណើរលើកក្រោយទៀត ។ អ្នកដើរសមុទ្រទាំងអស់សុទ្ធតែចង់ ដើរជាមួយ *ដ្រេក* ព្រោះ*ដ្រេក* ចេះប្រមូលទ្រព្យ ព្រោះ*ដ្រេក* វិលត្រលប់មកកន្លែងដោយសុខសាន្ត ហើយដល់អីចឹងទៅ អ្នកដែលមានសំនាងបាន នៅរស់រានមានជីវិត គ្រាន់តែភាគនៃទ្រព្យ ដែលគេចែកនេះ ក៏អាចដេកស៊ីចាយ ធ្វើមានបានមួយអាយុសបាត់ទៅហើយ ។

ពេលនោះអញច្បាស់ជាទ្រោលរួច -*ឆ្លាក់ថន* និយាយតិច ៗ ។ ច្បាស់ណាស់អញពិតជាទ្រោលរួចហើយភាគ នៃសម្បត្តិមហាសាល ដែលគេចែកអោយអញនោះ ច្បាស់ជាគ្រប់គ្រាន់ ល្មម..........

- ប្រយ័ត្ន ! ថ្មនៅពីខាងមុខ !

សំរែកនេះ ជ្រាបចូលតាម សរសៃ សាច់ឈាមរបស់ *ឆ្លាក់ថន* ច្រើនជាងចូល



www.budinst.gov.kh www.elibraryofcambodia.org

តាមត្រចៀកទៅទៀត ។ រួចជាថ្មីម្តងទៀតសំរែកស្ទើរបែកក្រដាសត្រចៀកដែលរសាត់តាមខ្យល់បក់មកនោះលាន់លឺឡើង ។

*ភ្លាក់ផន* ស្ទុះចេញពីបន្ទប់ឡើងដណ្តើរចេញទៅខាងកន្សៃ ។ បេះដូងគេលោតឌឹបឌាក់ស្ទើរធ្លាយដើមទ្រូង បំពង់ករបស់គេឡើងស្ងួតខះ ។ យប់ងងឹតស្លុបងភ្លៀងធ្លាក់ដូចគេចាក់ទឹក ។ មួយភ្លែតនោះគេមានអារម្មណ៍សប្បាយរីករាយនៅក្នុងចិត្តដោយគិតថា ថង់ក្រណាត់ទាំងឡាយដែលគេនាំគ្នាធ្វើដើម្បីត្រងទឹកភ្លៀងនោះនឹងពេញហៀរជាមិនខាន ។ រួចគេបែរខ្នងបញ្ច្រាសខ្យល់វិញ ។

រំពេចនោះ *ភ្លាក់ផន* ឃើញ *ហិនឡើច* ឡើងស្រលាំងកាំងដូចខ្មោចងាប់ព្រោះការភ័យខ្លាច ។ *រ៉ែមតស៊ីត* អ្នកមើលផ្លូវសំពៅដែលនៅក្រញោន១ ឯក្បាលសំពៅនោះស្រែកឡូឡា ហើយចង្អុលទៅខាងមុខឥតដាច់ ។ *ភ្លាក់ផន* ក៏សម្លឹងទៅខាងមុខឯនាយសំពៅនោះដែរ ។

ថ្មប៉ប្រះទឹកនៅប្រហែលជា ២០០ម៉ែតពីសំពៅ ។ គឺជាជុំថ្មខ្មៅស្មុងប្រៀបដូចជាក្រញាំដ៏សាហាវ ហើយដែលបោកផ្ទប់ដោយទឹករលកបែកផ្កាត្រែង ។ ជុំថ្មតូច១ទៀត នៅព័ទ្ធជុំវិញសំពៅទៅហើយ ។ ខ្យល់បក់កួចយកតំណក់ទឹកបោកផ្ទប់ទៅលើសំពៅ ។ ខ្សែក្តោងផងសំពៅទីមួយដាច់លាន់ភឹង ឯដងទទឹងសម្រាប់ផ្តក់ក្តោងកណ្តាលក៏ត្រូវខ្យល់កួចទៅបាត់ទៀត ។ ដងក្តោងត្រូវខ្យល់កួចឡើងរញ្ជួយ ប៉ុន្តែនៅរឹងម៉ឹងនៅឡើយ ។ សមុទ្រកំពុងតែអូសប្រទាញសំពៅទៅកាន់ទីមរណៈហើយ ។

- ទាំងអស់គ្នាឡើងមកលើ !

*ភ្លាក់ផន* ស្រែកអស់ទំហឹង ព្រមទាំងអង្រួនកណ្តឹងយ៉ាងរន្ថាន់និងយ៉ាងអស់កំលាំងដៃ ។ សំលេងទាំងនេះហាក់កន្ត្រាក់ *ហិនឡើច* អោយចេញផុតពីភាពស្រលាំងកាំងរបស់ខ្លួន ។ គេស្រែកជាភាសាហូឡង់ ឡើង :

-យើងងាប់ហើយ ! ឱព្រះអើយព្រះ ! ជួយពួកយើងខ្ញុំផង !

- ហៅទាំងអស់គ្នាអោយឡើងមកខាងលើអោយឆាប់ ! ពួកអាបំបង់បាយ ! អ្នែងដេកលក់អ្នែង ! ពួកអ្នែងដេកលក់ទាំងពីរនាក់ណឹង !



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* រុញ *ហិនទ្រិច* សំដៅទៅជណ្ដើរដែលនៅក្បាលសំពៅ រួចគេដកគន្លឹះចង្កូតសំពៅហើយប្រឹងអស់ពីសរសៃសាច់ដុំដើម្បីសាកកាច់សំពៅអោយបត់ទៅខាងឆ្វេងវិញ ។ សំពៅទាំងមូលឡើងញ័រទទ្រើត ។ ក្រោមកំលាំងខ្យល់បក់ក្បាលសំពៅចាប់ផ្ដើមផ្ទៀងតួរអោយស្មើបក្នុងល្បឿនមួយដ៏លឿនស្លេវ ។ មួយស្របក់មកខ្យល់និងរលកចាប់វាយផ្ទប់សំពៅពីចំហៀងម្ដង ។ ក្ដោងជំនួយឡើងប៉ោងតឹង ហាក់ខំប្រឹងជួយទប់ទំងន់ទាំងមូលរបស់សំពៅខ្សែក្ដោងលាន់សម្លេងស្រ៊ីប។ ក្បាលសំពៅហាក់មុជលិចចុះបង្ហាញអោយឃើញសមុទ្រហាក់ដូចជាចង់គ្របពីខាងក្រោយសំពៅមក ។

អីលូវនេះសំពៅបើកតាមបណ្ដោយផ្ទាំងថ្មហើយ ។ ស្រាប់តែមួយរំពេចនោះ *ប្លាក់ថន* ក្រលេកប្រទះឃើញរលកដ៏ធំមួយកំពុងតែបោកមករកសំពៅ ។គេស្រែកប្រាប់ពួកគ្នាគេទាំងអស់ដែលទើបមកពីបន្ទប់ពួកនាវិកដើម្បីអោយប្រុងប្រយ័ត្នខ្លួន រួចខ្លួនគេផ្ទាល់ក៏ក្ដាប់តោងខ្លួននឹងចង្កូតយ៉ាងណែនតែម្ដង ។

រលកបោកគ្របលើសំពៅធ្វើអោយតួនាវាផ្ទៀងទៅម្ខាង ។ *ប្លាក់ថន* គិតថា សំពៅប្រហែលជានឹងលិចមិនខាន ប៉ុន្តែបន្តិចមកសំពៅហាក់ងើបមកវិញដោយរលាស់ទឹកចេញពីខ្លួនដូចឆ្កែរលាស់ទឹក ។

*ប្លាក់ថន* កត់សំគាល់ឃើញសាកសពប្រធានក្ដោង ដែលគេបានលើកយកដាក់នៅខាងលើសំពៅដើម្បីទំលាក់ក្នុងសមុទ្រពេលស្អែកនោះត្រូវទឹករលកកួចយកទៅបាត់ទៅហើយ ។រលកទីពីរដែលធំជាងមុន ខ្លាំងជាងមុននោះចាប់ផ្ដើមបោកមកទៀតហើយ ។ ទឹករលកបោកផ្ទប់ *ប្លាក់ថន* ហើយកួចលើកគេហើបផុតពីក្ដារ ធ្វើអោយគេប្រឹងទធាក់ទប់ខ្លួនទាំងដង្ហក់ ។ រលកសមុទ្រមួយទៀតបោកមកលើសំពៅដោយសម្លេងខ្ទរខ្ទារដូចផ្គរ ។ *ប្លាក់ថន* ទើបលូកដៃចូលក្នុងកាំចង្កូតដើម្បីទប់ខ្លួនទឹករលកមកដល់ល្មម ។ *ហិនទ្រិច* ត្រូវទឹកបោកខ្ទាតចេញពីសំពៅទៅខាងឆ្វេងប្រហែល ៥០ម៉ែត រួចទើបកួចមកជិតសំពៅវិញ បន្ទាប់មករលកដ៏ធំមួយទៀតបានកួចគេផ្ទោងពីលើសំពៅទៅគប់ខ្ទេចឆ្អឹងនឹងផ្ទាំងថ្មមួយ ។

សំពៅជ្រមុជក្បាលទៅក្នុងសមុទ្រដោយប្រឹងជំនះរលករកច្រកចេញ ។ ខ្សែក្ដោងមួយ



www.budinst.gov.kh www.elibraryofcambodia.org

ក៏ដាច់ថែមទៀត ។ រ៉ក និង គៅឡាក់ ចាប់ផ្តើមរញ្ជួយច្របូកច្របល់ ហើយក៏រមូលចូលគ្នាតែម្តង ។ *វិញ* និងនាវិកម្នាក់ឡើងមកខាងកន្សៃ ហើយនាំគ្នាជួយកាច់ចង្កូតសំពៅជាមួយនឹង *ប្លាក់ថន* ។ ឥឡូវនេះថ្ពាំងថ្មនៅជិតនឹងតួខាងស្តាំរបស់សំពៅទៅហើយ ។ ថ្ពាំងថ្មដែលនៅប៉ប្រះៗ ទឹកឯទៀតលេចឡើងស្កុងៗនៅពីមុខនិងពីឆ្វេងសំពៅថែមទៀត ។

- *វិញ* ដំឡើងក្តោងឆាប់ ! នៃវ៉ីយ ! ដំឡើងក្តោងមុខ !

*វិញ* និងនាវិកខាងក្តោងពីរនាក់ប្រវេប្រវាឡើងលើដងក្តោងខាងមុខយ៉ាងលំបាក ចំនែកអ្នកឯទៀតដែលនៅខាងក្រោមប្រឹងទាញខ្សែយ៉ាងអស់ទំហឹង ដើម្បីជួយអ្នកដែលនៅខាងលើ ។

- ប្រយ័ត្នខាងមុខ !

*ប្លាក់ថន* ស្រែកឡើង ។ រលកបោកគ្របសំពៅម្តងទៀតដោយឆក់យកនាវិកម្នាក់ទៅជាមួយ និងដោយយកសពរបស់ប្រធានក្តោងមកដាក់លើសំពៅជំនួសវិញ ។

ក្បាលសំពៅងើបផុសឡើង ហើយជ្រមុជចុះម្តងទៀត ។ *វិញ* និងក្រុមក្តោងរបស់គេខំប្រឹងខ្មីតដើម្បីដំឡើងក្តោង ។ បន្តិចក្រោយមកក្តោងរលាស់ព្នកឹងដូចជាស្នូរកាំភ្លើងធំអាស្រ័យដោយកំលាំងខ្យល់ដែលបោកផ្ទប់ទៅលើ ។ សំពៅក៏ស្ទុះហក់ទៅមុខវិញ ។ *វិញ* និងកូនក្រុមរបស់គេនៅយោលតែកពោកលើដងក្តោង ។ នៅខាងក្រោមគេគឺជាទឹកសមុទ្រ ។

- ថ្ម ! ថ្មនៅចំពីមុខ ! -*វិញ* ស្រែកឡើង ។

*ប្លាក់ថន* ដែលនៅកាន់ចង្កូតបង្វិលទៅស្តាំភ្លាម ។ សំពៅនៅទ្រឹងបន្តិច ហើយក៏ងាកដោយអោយស្នូរលឺក្រាក ។ នោះគឺថ្មដែលនៅប៉ប្រះនឹងចំហៀងសំពៅ ប៉ុន្តែដោយនេះជាការប៉ះទន្ទិចពីចំហៀងនោះ ទើបថ្មត្រូវរបេះទៅ ឯតួសំពៅគ្មានការខូចខាតអ្វី ធ្វើអោយ *ប្លាក់ថន* និងក្រុមរបស់គេបានធូរទ្រូងបន្តិច ។

សំលឹងមើលទៅថ្ពាំងថ្មនោះ *ប្លាក់ថន* ឃើញមានចន្លោះមួយគេក៏កាច់ក្បាលសំពៅតំរង់ទៅតាមនោះ ។ ខ្យល់បក់កាន់តែខ្លាំងឡើង ឯសមុទ្រក៏កាន់តែកញ្ជ្រោលជាងមុន ។ ខ្យល់បក់មួយវិញធ្វើអោយសំពៅងាកក្បាល និងធ្វើអោយគេបញ្ចោសំពៅលែងបានមួយភ្លែត ។ គេនាំគ្នា



www.budinst.gov.kh www.elibraryofcambodia.org

ទប់សំពៅនិងកាច់វាតំរង់ទៅរកច្រកចេញវិញដដែល ប៉ុន្តែសំពៅនៅតែឃ្លេងឃ្លោង ហើយវេម្តង ទៅនេះ ម្តងទៅនោះ ។ ទឹកសមុទ្រជោរជន់ពេញលើសំពៅនិងហូរធ្លាក់ចុះដល់បន្ទប់ពួកនាវិក ដោយសង្កត់មនុស្សម្នាក់ស្លាប់ថ្ងាច់នឹងជញ្ជាំង ។ ទាំងខាងលើសំពៅ ទាំងបាតក្រោមសំពៅទឹក ហូរជោរជន់តែម្តង ។

- ទាំងអស់គ្នាទៅសប់បូមទឹកចេញ !

*ក្លាក់ថន* ស្រែកឡើង ហើយគេក៏ឃើញមនុស្សពីរនាក់ចុះទៅក្រោមភ្លាម ។

តំនក់ទឹកភ្លៀងវាត់បក់បោកទៅលើមុខរបស់គេ ។ ការឈឺចាប់ធ្វើអោយភ្នែកគេ ឡើងស្រវាំង ។ ពន្លឺនៅក្នុងតូបនិងភ្លើងកន្សែសំរាប់សំគាល់នាវារលត់បាត់តាំងពីយូរយារណាស់ មកហើយ ។ ខ្យល់មួយវិបទៀតបានបង្វែរសំពៅអោយឃ្លាតឆ្ងាយពីគោលដៅ ។ អ្នកកាច់ចង្កូត រអិលដួលទៅលើក្តារធ្វើអោយគេមិនអាចបញ្ជាសំពៅបានមួយរយៈទៀត ។ ពេលដែលអ្នកកាច់ ចង្កូតប្រឹងងើបឡើងទាំងជេរប្រទេចផ្តាសា នោះ ដៃចង្កូតបានវាត់មកត្រូវក្បាលគេផាំង ហើយ គេក៏ដួលចុះលែងដឹងខ្លួនក្រោមគ្រោះគំរាមកំហែងនៃរលកសមុទ្រ ដែលបោកមកលើសំពៅ ។ *ក្លាក់ថន* ចាប់លើកអ្នកកាច់ចង្កូតឡើង ហើយគ្រាហ៍គេជាប់រហូតដល់ពេលដែលរលកបោកផុត ទៅ ទើបគេដឹងថា អ្នកកាច់ចង្កូតនោះដាច់ខ្យល់ស្លាប់បាត់ទៅហើយ ។ គេទំលាក់សាកសពទៅ លើកៅអី ហើយរលកបន្ទាប់មកទៀតក៏កួចយកសាកសពនោះទៅបាត់ទៅ ។

ចន្លោះចេញនៅបញ្ឈិតទិសខ្យល់បក់ តែទោះជា*ក្លាក់ថន*ប្រឹងយ៉ាងណាក៏សំពៅ មិន ឡើងទៅបានសោះ ។ គេខំសំលឹងទាំងអស់សង្ឃឹមរកមើលចន្លោះផ្សេងទៀត ថ្វីត្បិតតែគេដឹង ច្បាស់ថា គ្មានចន្លោះណាផ្សេងទៀតក៏ដោយ ។ គេក៏សំរេចដាក់សំពៅរត់បញ្ច្រាសខ្យល់ដើម្បី យកល្បឿនមួយរយៈ រួចទើបគេកាច់យ៉ាងរហ័សរត់បណ្តោយខ្យល់វិញ ។ សំពៅ*អេរ៉ាក់*ក៏ឡើង សន្ទុះមៗ តំរង់ទៅរកចន្លោះចេញ ។

តួសំពៅដែលត្រូវកោសដោយតែមថ្ម អោយស្នូរសង្កៀតលៃលានប្រៀបដូចជាសំរែក ដ៏ឈឺចាប់មួយ ។ នៅលើសំពៅគ្រប់ៗគ្នាស្រមៃឃើញតួសំពៅដែលធ្វើពីដើមសែននេះ បែក រយះ រយាយ ហើយទឹកសមុទ្រសំរុកចូលតតុក ។ សំពៅចាប់រញ្ជួយ ហើយគ្មានអ្នកណាអាចបញ្ជាវា



www.budinst.gov.kh www.elibraryofcambodia.org

បានទៀតទេ ។

*ប្លាក់ផន* ស្រែករកជំនួយ ប៉ុន្តែគ្មានអ្នកណាម្នាក់សួរសំរែករបស់គេឡើយ ។ គេបញ្ជា សំពៅតែម្នាក់ឯងតតាំងតទល់នឹងមហាសាគរ ។ នៅក្នុងខួរក្បាលរបស់គេដែលកាន់តែតពីក ទៅនោះ គេដណ្ដឹងសួរខ្លួនគេថា តើដោយហេតុអ្វីបានជាចង្វូតកខ្សែសំពៅទ្រាំបានយូរម្ល៉េះ ។

នៅក្នុងចន្លោះចេញជំចង្កៀតនេះ សមុទ្របានប្រែក្លាយទៅជាឋាននរកតែម្ដង ។ ខ្យល់ កួចទឹកបញ្ចូលតាមច្រកនេះ ឯផ្ទាំងថ្មទប់ទឹកនេះ ។ រលកទឹកធំបក់បោកបំបែកខ្លួនទៅលើផ្ទាំងថ្ម រួចហក់ទៅបោកខ្លួនលើនាវា រួចទើបប្រខាំបំបែកគ្នាជាមួយរលកឯទៀត ។ គ្រប់ទិសគេឃើញ តែរលកបោកបែកផ្កាត្រែងក្នុងកំហឹងមួយដ៏គួរអោយខ្លាច ។ នាវាវិលវល់ទៅទាំងទទឹងខ្លួន ។

-អាកូនមីចោលម្រាយព្យុះឈប់ប៉ះសំពៅអញទៅ !

*ប្លាក់ផន* ស្រែកឡើងក្នុងកំហឹងពុះពោរ ។ ដៃចង្កូតរេ ហើយបោកត្រវែង *ប្លាក់ផន* ទៅ ឆ្ងាយ ។ នៅលើជាន់លើនៃសំពៅសំលេងស្រើប១ ដ៏គួរអោយត្រជាក់ឆ្អឹងខ្នងបានលាន់លឺឡើង ។ ក្បាលសំពៅទៅបុកនឹងថ្មមួយ ហើយបាក់ស្រ៊ុប ។ ដងក្ដោងកណ្ដាលបាក់លាន់លឺប្រស់ ។ មនុស្សម្នាទាំងឡាយកន្ត្រាក់ពូថៅស្ទុះទៅរកខ្សែយិតខ្សែយោងក្ដោងកណ្ដាល ហើយកាប់ បណ្ដាច់ព្រលែងដងក្ដោងអោយធ្លាក់ទៅក្នុងសមុទ្រ ។ បុរសម្នាក់ដែលរំលូនខ្លួនរើមិនរួចពី ខ្សែយិតខ្សែយោង នឹងក្ដោងសំពៅនោះក៏ត្រូវប្រទាញធ្លាក់ក្នុងសមុទ្រផងដែរ ។ តើអ្នកណាអាច ធ្វើអ្វីកើត ។ គេបានត្រឹមតែសំលឹងមើលបុរសនោះលិចអណ្ដែត១តាមបណ្ដោយសំពៅតែ ប៉ុណ្ណោះ ។ រួចបន្តិចមកខ្លួនបុរសនោះក៏លិចបាត់លែងឃើញតែម្ដង ។

*វិញ* និងអ្នកឯទៀតបែរខ្លួនមកក្រោយ ។ ពួកគេឃើញ *ប្លាក់ផន* ឈរនៅឯកខ្សែ ហើយជំនះនឹងព្យុះសង្ឃរាប្រៀបដូចជាខ្មោចចូល ។ ពួកគេនាំគ្នាធ្វើសញ្ញាបូជាព្រះ ហើយសូត្រ ធម៌កាន់តែញាប់ឡើងទៀត ។ អ្នកខ្លះទៀតទ្រហោយំដោយការភ័យខ្លាច ។ ទាំងអស់គ្នាគ្មាន អ្នកណាចង់ស្លាប់ទេ ។

ចន្លោះដើមទីវាងទូលាយបន្តិច តែបន្ទាប់មកវាចេះតែរួញតូចទៅ១គួរអោយព្រួយ បារម្ភ ហើយថ្មហាក់កាន់តែធំនិងកាន់តែខ្ពស់ពីទឹកហាក់ដូចចង់គ្រប់សង្កត់ពួកគេយ៉ាងដូច្នោះ



www.budinst.gov.kh www.elibraryofcambodia.org

ដែរ ។ ចរន្តទឹកហូរបោកផ្ទាំងថ្មម្ខាងខាងនេះ ម្តងខាងនោះ ដោយអូសទាញទាំងសំពៅទៅជាមួយផង រួចបន្ទាប់មកវាទាញសំពៅអោយទៅទាំងទទឹងខ្លួនម្តងទៀត សំដៅទៅរកមហន្តរាយ ។

*ប្លាក់ថន* ឈប់ជេរព្យុះ ហើយគេបង្ខិលដៃចង្កូតទាញសំពៅអោយងាកទៅឆ្វេង ។ សាច់ដុំរបស់គេឡើងរឹង ព្រោះតែការខំប្រឹងប្រែងហួសហេតុ ។ ចង្កូតកន្ត្រៃលែងស្គាល់សំពៅឯសមុទ្រក៏រឹតតែលែងស្គាល់សំពៅទៅទៀត ។

*ប្លាក់ថន* ដកដង្ហើមទាំងដង្ហក់ កំលាំងរបស់គេក៏កាន់តែថមថយទៅៗ :

- អោយនឹងន ! មីកូនអន្សត្តិរិយជួយអញផង !

កំលាំងទឹកកាន់តែខ្លាំងឡើងៗ ឯ*ប្លាក់ថន* មានអារម្មណ៍ថា បេះដូងគេដោលស្ទើរធ្លាយទៅហើយ ។ ទោះជាយ៉ាងនេះក្តីគេនៅតែបន្តតស៊ូទប់ទល់នឹងសំពាធទឹកសមុទ្រដដែល ។ គេខំប្រឹងសំលឹងមើលអ្វីៗអោយបានច្បាស់ ប៉ុន្តែភ្នែករបស់គេកាន់តែស្រវាំងទៅៗហើយ បន្ទាប់មកអ្វីៗចាប់ផ្តើមវិលតែម្តង ។ ពណ៌នានាប្រែជាច្របូកច្របល់ល្អក់ខ្វល់ទៅហើយ ។ សំពៅពិតជារលត់រលាយពេលនេះហើយ ។ គឺនៅក្នុងខណៈនោះហើយដែលបាតសំពៅប៉ះបាតភក់ ។ ក្រោមទំងន់នៃការទង្គិចនេះ សំពៅក៏បែរក្បាលវិញ ហើយចង្កូតក៏ចាប់ទឹកបញ្ជាសំពៅបាន ។ ខ្យល់ហើយនិងចរន្តទឹកក៏បានពួតដៃគ្នា ដើម្បីជួយសង្គ្រោះសំពៅបន្ថែមទៀត ។ ការរួមគ្នានៃថែដន្យទាំងនេះបានរុញសំពៅទៅតាមបណ្តោយខ្យល់ ហើយឆ្លងផុតចន្លោះថ្មនេះ ដើម្បីទៅដល់ទីកន្លែងជាជំរកដ៏សុខសាន្តបាន ។ នោះគឺនៅក្នុងឆកសមុទ្រមួយ ។ គឺនៅម្ខាងទៀត ។

☆ ☆
☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ១

*ប្លាក់ថន* ភ្ញាក់ឡើងយ៉ាងក្រញេង ។ ដំបូងគេនឹកស្មានថាគេយល់សប្តិដោយហេតុគេនៅលើដីគោក ប៉ុន្តែគេឥតស្គាល់បន្ទប់ដែលគេស្នាក់នៅនេះបន្តិចបន្តួចណាសោះ ។ បន្ទប់នេះតូចទេ តែត្រូវគេរៀបចំស្អាតបាតណាស់ ។ នៅលើក្តារមានកំរាលក្រណាត់យ៉ាងទន់ល្មើយ ។ ខ្លួនគេដេកនៅលើភួយមួយយ៉ាងក្រាស់ ។ ពិតានធ្វើពីដើមសែនលាបវ៉ែនី ។ ជញ្ជាំងធ្វើពីផ្ទាំងក្តាររាងបួនជ្រុងស្មើ ដែលតាមពិតទៅគឺជាស៊ុមឈើសែន ហើយដែលគេពាសក្រដាសប៉ុយពីលើ ដើម្បីបន្ទន់និងបំបែកពន្លឺនេះ កុំអោយចាំងពេក ។ នៅលើក្បាល ដំណេករបស់គេមានថាសមួយដែលមានម្ហូបប៉ុន្មានចានចង្កឹះ ។ ចានមួយមានញាំបន្លែត្រជាក់ ។ *ប្លាក់ថន* ត្របាក់លេបតែម្តងដោយមិនទាំងបានយកចិត្តទុកដាក់ណាស់ណាដល់ជាតិគ្រឿងរបស់វាផង ។ ចានមួយទៀតមានស្ងោរត្រី គេលើកហុតសូម្បីតែមួយតំនក់ក៏គ្មានសល់នៅក្នុងចានឡើយ ។ នៅចានមួយចុងក្រោយគេគឺជាបបរមិនដឹងជាធ្វើពីស្រូវសាលី ឬ ពីអក ( orge ) ទេ គេលើកវាបង្ហើយយ៉ាងរហ័សដោយប្រើម្រាមកាយបញ្ចូលមាត់ ។ ទឹកដែលនៅក្នុងបំពង់មួយមានរាងដ៏គួរអោយចំលែកនោះ មានកំដៅក្តៅ ហើយមានរសជាតិដ៏ចំលែក គឺរាងចត់បន្តិចប៉ុន្តែឆ្ងាញ់ ។

*ប្លាក់ថន* កត់សំគាល់រូបព្រះឆ្លាក់នៅកន្លែងនមស្ការមួយ ។

ផ្ទះនេះបើមិនជារបស់អ្នកប៉ុកទុយកាល់ ក៏ជារបស់អ្នកអេស្ប៉ាញដែរ *ប្លាក់ថន* គិតនៅក្នុងចិត្តទាំងភ្ញាក់ផ្អើល ។ តើនេះជាប្រទេសជប៉ុន ឬ កាតៃ ?

ផ្ទាំងក្តារមួយបានរអិលទៅម្ខាង ។ ស្ត្រីម្នាក់ក្នុងវ័យពាក់កណ្តាលមនុស្ស រាងធាត់ មុខមូលនៅលុតជង្គង់ក្បែរមាត់ទ្វារ ។ នាងអោនក្បាលហើយញញឹម ។ស្បែកនាងសំបុរស្រអែមភ្នែករបស់នាងមានពណ៌ខ្មៅនិងតឹង សក់សំបុរខ្មោតដ៏វែងរបស់នាងត្រូវបានបួងដោយប៉ិនប្រសប់ ។ នាងពាក់អាវបំពង់វែងមួយធ្វើអំពីសូត ពណ៌ប្រផេះ ហើយនឹងក្រណាត់ពណ៌ ក្រមៅមួយបន្ទះធំនៅជុំវិញចង្កេះ ។

*- កូស៊ូជីនសាម៉ា កូតីប៊ុន វ៉ា អិកាកា តិស៊ូកា ?* -នារីនោះបន្លឺមកកាន់ *ប្លាក់ថន* ។សំលឹងមើលនាងដោយស្រលាំងកាំង ។នារីនោះនិយាយឃ្លានោះដដែលម្តងទៀត ។*ប្លាក់ថន*សួរទៅវិញ :

- ណឹងស្រុកជប៉ុនអ្ហី ? ជប៉ុន ឬ កាតៃ ?



www.budinst.gov.kh www.elibraryofcambodia.org

នារីនេះសំលឹងមើលមុខ *ភ្ជាក់ផ្អន* ផ្ទាំង ព្រោះមិនយល់ពីអ្វីដែល *ភ្ជាក់ផ្អន* និយាយរួច នាងនិយាយពីរបីម៉ាត់ទៀត ។ មកដល់ពេលនេះទើប *ភ្ជាក់ផ្អន* ដឹងថា គេនៅអាក្រាតខ្លួនទទេ ។ គេរកសំលៀកបំពាក់គេតែរកមិនឃើញសោះ ។ គេក៏ធ្វើកាយវិការប្រាប់ទៅនារីនោះថា គេចង់បានខោអាវមកស្លៀកពាក់ បន្ទាប់មកគេចង្អុលថាន ។ នារីនោះក៏យល់ភ្លាមថា ពោះរបស់គេនៅឃ្លាននៅឡើយ ។

នាងញញឹម ហើយអោនក្បាល បន្ទាប់មកនាងទាញទ្វារបិទទៅវិញ ។

*ភ្ជាក់ផ្អន* ប្រាសខ្លួនដេកទៅវិញដោយការហេវហត់ ។

អចលភាពនិងភាពរបឹងនៃក្តារធ្វើអោយគេរិលរវល់ស្មារតី ។ គេខិតខំប្រមូលស្មារតីរបស់គេឡើងវិញ ។ អញចាំបានថា ទំលាក់យុថ្កាជាមួយ *វិញ* នេះបើតាមអញចាំគឺជាមួយអា*វិញ* ណឹងហើយ ។ យើងនៅក្នុងឈូងសមុទ្រមួយ ហើយសំពៅបាននៅកៀងនឹងបាតសមុទ្រ ។ យើងបានលឺសំលេងរលកសមុទ្រដែលបោកផ្ទប់ឆ្នេរ ហើយនៅទីនោះមានពន្លឺភ្លើងរួចហើយ អញចុះទៅក្នុងបន្ទប់រួចងងឹតឈឹងតែម្តង ។ អញដូចជាគ្មានចាំអ្វីទាំងអស់ ។ រួចក្នុងភាពងងឹតនេះអញដូចជាបានឃើញពន្លឺនិងលឺសំលេងនិយាយគ្នាយ៉ាងចំលែក ។ អញបាននិយាយជាភាសាអង់គ្លេសរួចជាភាសាប៉ុកទុយកាល់ ។ មានអ្នកស្រុកម្នាក់ចេះនិយាយភាសាប៉ុកទុយកាល់បន្តិចបន្តួច ។ វាជាជនជាតិប៉ុកទុយកាល់ រឺក៏អ៊ីអ៊ីចេះ ?ទេ តាមស្មានប្រហែលជាអ្នកស្រុកអ្នកភូមិនៅទីនេះទេ ។ អញមានបានសួរគេថា ពួកអញនៅកន្លែងណាទេ ?អញមិនចាំសោះតែម្តង ។ រួចយើងពារផ្ទាំងថ្មម្តងទៀត រួចរលកបោកគ្របលើពួកយើង ហើយអញធ្លាក់ទៅក្នុងសមុទ្រ ។ ពេលនោះអញលង់ទឹក ហើយទឹកក្រជាក់រឹងថ្គាម ។ ទេ ! ទឹកក្តៅឧណ្ហៗទេ ព្រោះពេលនោះទឹកសមុទ្រហាក់ដូចជាគ្រែសូតមួយដែលមានកំរាស់ ២ម៉ែតអ៊ីចឹង ។ ប្រហែលពួកគេជួយស្រង់អញឡើងគោកហើយយកអញមកទីនេះហើយ ។

- ប្រហែលជាកន្ទេលហ្នឹងទេ ដែលធ្វើអោយអញកក់ក្តៅនិងស្រឹមតែម្តង ព្រោះអញមានទាន់ដែលបានដេកលើសូតម្តងណា ។

*ភ្ជាក់ផ្អន* និយាយនឹងខ្លួនឯង រួចដោយការហេវហត់គេក៏លង់លក់ក្នុងដំណេកម្តងទៀតទៅ ។

ពេលគេភ្ញាក់ឡើងម្តងទៀតគេឃើញថា មានគេលើកម្ហូបមកជាថ្មី ហើយសំលៀក



www.budinst.gov.kh www.elibraryofcambodia.org

បំពាក់របស់គេត្រូវបានបត់ទុកដាក់យ៉ាងស្អាតបាត នៅក្បែរខ្លួនគេជាស្រេច ។ សំលៀកបំពាក់នេះត្រូវបានគេបោកគក់ អ៊ុត និងដេរប៉ះយ៉ាងម៉ត់ចត់ដោយដៃដ៏ប៉ិនប្រសប់ ។

ប៉ុន្តែកាំបិតរបស់គេបាត់ទៅហើយ កូនសោក៏អ៊ីចឹង ។

អញត្រូវតែរកកាំបិតមួយអោយបាន ហើយអោយឆាប់បំផុត *ប្លាក់ថន* គិតនៅក្នុងចិត្តរឺកាំភ្លើងខ្លីមួយក៏បាន ។

ក្រសែភ្នែកគេសំលឹងទៅចំរូបព្រះឆ្កាង ។ ថ្វីត្បិតតែគេខ្លាច ប៉ុន្តែអារម្មណ៍រំភើបរបស់គេក៏ចេះតែមានចំឡើង១ដែរ ។ ក្នុងមួយជីវិតរបស់គេ១ បានលឺតែកុងសំពៅ រឺអ្នកដើរសមុទ្រនិយាយរឿងព្រេងស្តីពីសម្បត្តិមហាសាលដ៏សំបើមអស្ចារ្យ នៃចក្រភពសំងាត់របស់ពួកប៉ិកទុយកាល់នៅបូព៌ាទិស ស្តីពីរបៀបដែលពួកប៉ិកទុយកាល់បញ្ចុះបញ្ចូលអ្នកស្រុកអោយកាន់សាសនាកាតូលិច ដើម្បីងាយស្រួលត្រួតត្រាពួកនោះ នៅក្នុងទាសភាព ស្តីពីចក្រភពនេះ ដែលមានថ្លៃថោកដូចដែកស្និត និងដែលមរកតកណ្តៀង ទទឹម ពេជ្រសំបូរដូចក្រួសនៅលើឆ្នេរអ៊ីចឹង ។

អ៊ីចឹងហើយ បើរឿងសាសនាកាតូលិចមានមែន អារឿងអី១ទៀតក៏ច្បាស់ជារឿងពិតដូចគ្នាហ្នឹង ។ អារឿងទ្រព្យសម្បត្តិមហាសាលច្បាស់ជាមានពិត ។ តែអញរកអាវុធកាន់តែឆាប់ពេលណា អញបានឡើងទៅលើសំពៅឈរពីក្រោយកាណុងឆាប់ពេលណានោះគឺល្អកាលនោះ ។ *ប្លាក់ថន* ស្រស់ស្រូបយ៉ាងប្រញាប់ប្រញាល់ ហើយគេស្លៀកពាក់ខោអាវជាក្រោយ ។ នៅពេលគេក្រោកឈរខ្លួនប្រាណគេញ័រទទ្រើត ។ គឺដូច ជារាល់ពេលអ៊ីចឹងដែរ តែពេលណាគេចុះដីគោកខ្លួនគេប្រៀបដូចជាត្រីចេញពីទឹកអ៊ីចឹង ។ ជើងរបស់គេនៅទទេ ។ គេដើរតំរង់ទៅទ្វារ ។ គេនៅវាងផេងផោងនៅឡើយ ដោយហេតុនេះ ដើម្បីទប់ខ្លួនគេក៏ច្រត់ដៃទៅលើផ្ទាំងក្តារស្តើង១ទាំងនោះ ។ ក្រោមទំងន់របស់ *ប្លាក់ថន* ក្រដាសរហែករយះរយាយមួយរំពេច ។ ពេលដែលគេងើបឈរឡើងវិញនេះ គេឃើញនារីនោះនៅអង្គុយលុតជង្គង់នៅរបៀងផ្ទះ ហើយសំលឹងមើលគេផ្ទាំង ក្នុងទឹកមុខស្លន់ស្លោ ។

-សូមទោស! *ប្លាក់ថន* និយាយឡើង ។ ការភ្ញាក់ផ្អើលរបស់គេធ្វើអោយគេរសាប់រសល់ នៅក្នុងចិត្តយ៉ាងខ្លាំង ។ វាហាក់ដូចជាសុខភាពនៃបន្ទប់នេះត្រូវបានគេធ្វើអោយប្រលាក់ប្រលូសអ៊ីចឹង ។



www.budinst.gov.kh www.elibraryofcambodia.org

-ស្បែកជើងខ្ញុំនៅឯណា? -ស្ត្រីនោះសំលឹងមើលចំភ្នែករបស់ *ប្លាក់ថុន* ដោយមិនដឹងថាត្រូវធ្វើយ៉ាងម៉េច ។ *ប្លាក់ថុន* ធ្វើសញ្ញាសួរនាងម្តង ។ នាងក៏ស្ទុះទៅដល់ចុងរបៀងលុតជង្គង់ចុះរុញផ្ទាំងក្តារមួយ ហើយធ្វើសញ្ញាមករក *ប្លាក់ថុន* ។ សំលេងជជែកគ្នានៅជិតបង្កើយ ។ គេលឺស្នូររលកទឹកដែលបោកខ្លួននៅលើឆ្នេរ ។ គេឆ្លងទ្វារ ហើយក៏ប្រទះឃើញបន្ទប់មួយស្ទើរតែទទេ ស្អាត ។ នៅជាប់នឹងបន្ទប់នេះ មានរានហាលមួយ ។ រានហាលមានជណ្តើរមួយដែលនាំចុះទៅដល់សួនច្បារមួយព័ទ្ធដោយជញ្ជាំងដ៏ខ្ពស់ ។ ស្ត្រីចំនាស់ពីរនាក់ កូនក្មេង ៣នាក់ ស្លៀកពាក់រ៉ូបពណ៌ក្រហមជាំ ហើយនិងបុរសចាស់ម្នាក់កាន់រនាស់នៅដៃកំពុងឈរនៅក្បែរច្រកចូល ។ ពួកគេអោនក្បាលចុះយ៉ាងម៉ត់ចត់ ហើយស្ថិតនៅក្នុងស្ថានភាពបែបនេះទៅ ។

*ប្លាក់ថុន* បានកត់សំគាល់យ៉ាងភ្ញាក់ផ្អើលនូវប្រការ ដែលតាចាស់ស្ទើរតែនៅអាក្រាតខ្លួនទទេ លើកលែងតែកូនកន្ទបយ៉ាងតូចមួយដែលនៅរឹណ្ឌចង្កេះគាត់នោះ ។

ដោយមិនដឹងនិយាយពីអីផងនោះ *ប្លាក់ថុន* ក៏និយាយឡើង :

- សួស្តី !

ទាំងអស់គ្នានៅស្ងៀមឥតកំរើកដដែល ។

ដល់អីចឹងទៅ *ប្លាក់ថុន* ក៏ទៅជាស្រលាំងកាំងដែរ ។ គេសំលឹងផ្ទាំងទៅអ្នកទាំងនោះរួចហើយគេខំប្រឹងគោរពតាមរបៀបអ្នកទាំងនោះទាំងឆ្គង ។ ពួកគេទាំងអស់ ក៏ងើបត្រង់ខ្លួនវិញ ហើយញញឹមពព្រាយដាក់ *ប្លាក់ថុន* ។ តាចាស់អោនក្បាលគោរពម្តងទៀត ហើយក៏ទៅធ្វើសួនរបស់គាត់បន្តទៀតទៅ ។ ពួកក្មេង១ទាំគ្នាសំលឹងមើល *ប្លាក់ថុន* មួយសន្ទុះ ក៏នាំគ្នារត់ចេញទាំងសំនើចក្អាកក្អាយ ។ នារីចំនាស់ទាំងពីរនាំគ្នាចូលទៅក្នុងបាត់ទៅ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏ *ប្លាក់ថុន* មានអារម្មណ៍ថា មានគេកំពុងតែលបឃ្លាំមើលខ្លួនដែរ ។

គេក្រលេកឃើញស្បែកជើងរបស់គេនៅជើងជណ្តើរ ។ គ្រាន់តែគេហៀបនឹងយកស្បែកជើងមកពាក់ នារីដែលនៅឯបន្ទប់គេនោះមកលុតជង្គង់ក្បែរនោះភ្លាម ហើយជួយពាក់ស្បែកជើងអោយគេ ។

- អរគុណ !

*ប្លាក់ថុន* និយាយទៅកាន់នាង ។ គេគិតមួយសន្ទុះរួចចង្អុលខ្លួនឯងដោយនិយាយថា :

- *ប្លាក់ថុន ! ប្លាក់ថុន !*



www.budinst.gov.kh www.elibraryofcambodia.org

រួចគេចង្អុលទៅនារីនោះវិញដោយសួរថា :

- នាងឈ្មោះអ្វី ?

នាងសំលឹងមើលគេដោយងឿងឆ្ងល់ ។ គេក៏និយាយម្តងទៀតដោយយឺតៗជាងមុន :

- *ប្លាក់ថុន !* - រួចគេចង្អុលទៅរូបនាងជាថ្មី ។

- នាងឈ្មោះអី ?

នាងជ្រួញចិញ្ចើមបន្តិច រួចហើយហាក់ដូចជាយល់សំនួរ ។ នាងយកម្រាមដៃចង្អុលខ្លួននាងហើយនិយាយ :

- *អូណា ! អូណា !*

សែនពេញចិត្តនឹងខ្លួនឯង ដូចជាការសប្បាយពេញចិត្តរបស់នារីនោះដែរ *ប្លាក់ថុន* និយាយបន្តតាម :

- *អូណា ! អូណា !*

នារីនោះក៏ងក់ក្បាលទាំងរីករាយ

- *អូណា ! អូណា !*

សួនដែលនៅទីនេះមិនដូចគ្នាបន្តិចណាសោះទៅនឹង សួនទាំងឡាយដែលគេធ្លាប់ឃើញ : មានទឹកធ្លាក់តូចមួយ ប្រលាយទឹកហូរ ស្ពានតូចមួយ មានផ្លូវចាក់ក្រួសយ៉ាងស្អាត មានដុំថ្ម មានផ្កា មានគុម្ពោត-*ប្លាក់ថុន* គិតថា នេះគឺជាសួនមួយដែលបានគេថែទាំយ៉ាងម៉ត់ចត់យ៉ាងម៉ត់ចត់មែនទែនតែម្តង ។

- អស្ចារ្យណាស់ !-*ប្លាក់ថុន* លាន់មាត់ជាភាសាអង់គ្លេស (Incredible) ។

-អិនតេរីបេល ? -នារី *អូណា* ប្រឹងនិយាយព្រាប់

- អត់អីទេ !

*ប្លាក់ថុន* ឆ្លើយតប ។ ដោយមិនដឹងថាត្រូវធ្វើអ្វីនោះ គេក៏ធ្វើសញ្ញាអោយនាងដកថយចេញ ។ នាងអោនក្បាលគោរព យ៉ាងសុភាព ហើយថយខ្លួនចេញយ៉ាងគោរព ។

*ប្លាក់ថុន* ដាក់ខ្លួនអង្គុយក្រោមពន្លឺព្រះអាទិត្យ ។ គេមានអារម្មណ៍ប៉ក់ល្ងើយ ។



www.budinst.gov.kh www.elibraryofcambodia.org

គេសំលឹងទៅតាចាស់ ដែលកំពុងជិះស្មានៅក្នុងសួនគ្មានស្មៅនេះ ។ គួរអោយឆ្ងល់ដែរតើពួកអញឯទៀតនៅឯណា ?មេបញ្ហាការនៅរស់ឬទេ? អញចាំបានថា នៅពេលអញភ្ញាក់ដឹងខ្លួនអញបានទទួលទានអាហារហើយអញដេកទៅវិញទៀត ។ មួបដែលអញស៊ីយ៉ាប់ដូចសប្តិរបស់អញអ៊ីចឹង ។ ក្មេងរត់ប្រដេញគ្នាមកក្បែរគេដោយសំរែកខ្សែវខ្សារ។ *ក្លាក់ថន* ខ្មាសជំនួសក្មេង ១ ចំពោះភាពអាក្រាតរបស់តាចាស់នោះ ពីព្រោះនៅពេលដែលគាត់អោន រឺ ឈ្នោកនោះស៊ី ១ ក៏លេចចេញទាំងអស់ដែរ។ គេសែនភ្ញាក់ផ្អើលនៅពេលដែលគេសង្កេតឃើញថាក្មេង១គ្មានយកចិត្តទុកដាក់ដល់ប្រការនេះសោះទេ។ គេសំលឹងមើលឃើញដំបូលថ្មផ្នួនិងស្បូវនៃផ្ទះនានា ដែលនៅម្ខាងរបងហើយនៅឆ្ងាយពីនេះគឺជាភ្នំមួយដ៏ស្ដឹមស្ដៃ។ នៅលើអាកាសវាយោបក់បញ្ជូនពពកអណ្តែតគ្រឿន១។ ហ្វូងឃ្មុំកំពុងហិចហើរក្រេបលំអងផ្កា។ នេះគឺជាថ្ងៃដ៏អស្ចារ្យនៃនិទាឃរដូវ។ ថ្វីត្បិតតែខ្លួនគេទាមទារការសំរាកទៀតក្តី ក៏ *ក្លាក់ថន* សំរេចងើបឡើងហើយដើរសំដៅទៅរកច្រកចេញនៃសួនច្បារដែរ។ អ្នកធ្វើសួនញញឹមដាក់ *ក្លាក់ថន* អោនគោរពគេហើយរត់ទៅបើកទ្វារអោយ អោនគោរពម្តងទៀត រួចទើបបិទទ្វារទៅវិញនៅពេលដែល *ក្លាក់ថន* ចេញផុត ។

ភូមិនេះបែរមុខទៅខាងកើត ហើយសង់ព័ទ្ធកំពង់ផែជាស្នែងក្របី ។ ផ្ទះប្រហែលជាង ២០០ខ្នង សង់តាមរបៀបមួយដែលគេ មិនដែលធ្លាប់ឃើញសោះ នៅបណ្តាក់គ្នាតាមជំរាលជើងភ្នំរហូតដល់ឆ្នេរសមុទ្រ។ នៅឯទួលខ្ពស់គេបានធ្វើស្រែជាថ្នាក់ ១ ហើយនិងមានផ្លូវដីជាច្រើន ដែលឆ្ពោះទៅជើងក៏មានទៅត្បូងក៏មាន ។ ឆ្នេរសមុទ្រមានក្រាលថ្មហើយអ៊ូនាវាមួយស្ថិតនៅកាត់កែងនឹង មាត់សមុទ្រនោះ ។ នេះជាឈូងសមុទ្រដ៏ស្ងប់ស្ងាត់និងដ៏ជាទីទុកចិត្ត ។ ទំនប់រលកធ្វើពីថ្មមួយលយចូលទៅក្នុងសមុទ្រ ។ នៅទីនោះមានមនុស្សប្រុសស្រីកំពុងធ្វើត្រីធ្វើសំណាញ់ ។ នៅផ្នែក ខាងជើងកំពង់ផែ គេកំពុងសាងសង់នាវាដ៏មានរាងចំលែកមួយ ។ នៅឯនាយសមុទ្រមានកោះជាច្រើននៅខាងកើតនិងខាងត្បូង ។ ថ្មប៉ប្រះទឹកប្រហែលជានៅម្តុំនោះ រឺនាយនោះបន្តិចក្នុងលំហសមុទ្រនោះហើយ ។

នៅក្នុងឈូងសមុទ្រមាននាវាចំលែកនោះជាច្រើន ហើយភាគច្រើនជានាវានេសាទ ។ នាវាខ្លះមានក្តោងចំតែមួយ ខ្លះទៀតជាទូកអុំ ។ អ្នកអុំទូកអុំឈរ ហើយអុំបុករលក ។ របៀប



www.budinst.gov.kh www.elibraryofcambodia.org

ដែលគេអុំនោះគឺ ខុកប្លែកពីរបៀបអុំរបស់*ប្លាក់ថន* ណាស់ ។ នាវាមួយចំនួនកំពុងបើកចេញពីផែ ខ្លះទៀតកំពុងសំដៅទៅកាន់អ៊ូធ្វើពីឈើនោះ ។ នៅហាសិបម៉ែត្រពីច្រាំងអេរ៉ាសបោះយុថ្កានៅនឹងមួយកន្លែង ។

អ្នកណារៀបចំទុកដាក់សំពៅនេះហ្ន៎ ? *ប្លាក់ថន* ដណ្ដឹងសួរខ្លួនឯង ។ នៅជាប់នឹងអេរ៉ាសមាននាវាមួយទៀតនៅអែបជាប់ ហើយគេឃើញមានអ្នកភូមិមួយចំនួនកំពុងឈរនៅលើសំពៅ ប៉ុន្តែគេឥតឃើញមនុស្សនៅក្នុងក្រុមរបស់គេឡើយ ។ រួចចុះពួកនោះទៅឯណាអស់ទៅហើយអ៊ីចេះ ?

*ប្លាក់ថន* ចោលភ្នែកពិនិត្យមើលភូមិមួយគ្រូស ហើយគេកត់សំគាល់ឃើញថា មានមនុស្សជាច្រើនកំពុងតែសង្កេតមើលគេ ។ ពេលដែលគេសំលឹងចំអ្នកទាំងនោះៗ លំអោនខ្លួនភ្លាម ។ ដោយរសាប់រសល់គេក៏លំឱនខ្លួនតបទៅវិញ ។ អ្នកភូមិ អ្នកស្រុកដើរទៅដើរមកឈប់រ៉ែរ៉តថ្លៃឬគោរពគ្នាទៅវិញទៅមក ទំនងហាក់ដូចជាពួកគេភ្លេចវត្តមានរបស់*ប្លាក់ថន* អស់រលីង ។ ពួកគេប្រៀបដូចជាមេអំបៅចំរុះពណ៌មួយហ្វូងអ៊ីចឹង ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដីក៏នៅពេលដែលគេដើរតំរង់ទៅរកឆ្នេរនោះប្លាក់ថនមានអារម្មណ៍ថា មានក្រសែភ្នែកមនុស្សកំពុងតាមឃ្លាំមើលគេនៅតាមគ្រប់បង្អួច និង នៅតាមច្រកចន្លោះទ្វារដដែល ។

ដើរបណ្ដើរគេដណ្ដឹងសួរខ្លួនឯងបណ្ដើរ ។ តើពួកនេះមានអ្វីដែលធ្វើអោយពួកគេចំលែកម្ល៉េះនោះ ? មិនមែនគ្រាន់តែមកពីខោអាវ មិនមកពីអាកប្បកិរិយានោះទេ ! រួចបន្តិចមកគេក៏យល់ភ្លាម ។ អ្វីដែលចំលែកនោះគឺ ពួកនេះគ្មានអាវុធនៅជាប់នឹងខ្លួនទេ ! គ្មានដាវ គ្មានកាំភ្លើង ។ ហេតុអ្វីបានជាអ៊ីចឹងហ្ន៎ ?

ហាងទានាដែលពោរពេញដោយទំនិញចំលែក ៗ និងកញ្ជេរព្រោងព្រាតនោះនៅអមតាមមាត់ផ្លូវ ។ អ្នកលក់និងអ្នកទិញអង្គុយចោងហោងរឹលុតជង្គង់នៅលើរានឈើ ។ ភាគច្រើនពាក់ស្បែកជើងឈើ ខ្លះមានបាតក្រាស់ឃ្មឹកតែម្ដង ។ ស្បែកជើងនេះមានខ្សែដែលគេពាក់ចូលចន្លោះមេជើងនិងម្រាមជើងទាំងពីរ ។ ទាំងអស់គ្នារមែងទុកស្បែកជើងនៅមាត់ទ្វារផ្ទះ ។

ពេលដែលគេឃើញអ្នកប្រដៅសាសនានោះ ប្លាក់ថនមានអារម្មណ៍ដឹងថា ការភ័យ



www.budinst.gov.kh www.elibraryofcambodia.org

ខ្លាចបានមករូបរីតពោះគេ រួចឡើងមកដល់ចុងដង្ហើមគេមួយរំពេច ។ សង្ឃនេះបើមិនជាជនជាតិប៉កទុយកាល់ ក៏ជាជាតិអេស្ប៉ាញដែរ ។ ថ្វីត្បិតតែស្បង់របស់សង្ឃនេះពណ៌ស្លាទុំក្តីក៏គេមិនអាច ច្រឡំបានដែរ ព្រោះមានសញ្ញាអង្កាំនិងព្រះឆ្កាងដែលព្យួរនៅនឹងចង្កេះគេនោះ ។ ស្បង់របស់សង្ឃនេះមានប្រលាក់ដុំ ៗ ហើយស្បែកជើងបែបអឺរ៉ុបរបស់គេនោះប្រលាក់សុទ្ធតែភក់ ។ មនុស្សនេះកំពុងតែសំលឹងមើលទៅសំពៅអេរ៉ាសដែរ ។ *ភ្លាក់ថន* មានអារម្មណ៍ដឹងថា សង្ឃនេះស្គាល់ពីប្រភពអង់គ្លេសឬហូឡង់របស់សំពៅនេះហើយ ។ នេះជាសំពៅចុនក្រោយបំផុតនៅលើផ្ទៃសមុទ្រ ។ មានល្បឿនលឿនជាងគេ រហ័សជាងគេ ។ នេះជាសំពៅជំនួញពិតមែន តែក៏ជាសំពៅប្រយុទ្ធផងដែរហើយដែលគេបានសាងសង់តាមគំរូសំពៅកកស៊ែ (២២) អង់គ្លេសដែលធ្លាប់បានធ្វើព្យុះ ធ្វើផ្គរយ៉ាងសំបើមនៅក្នុងសមុទ្រអង់ទីនោះ ។ អ្នកភូមិ១០នាក់ដើរហែហមសង្ឃនេះ ។ ពួកទាំងនោះមានសំបុរត្នោត ភ្នែកខ្មៅ ហើយក្នុងចំណោមអ្នកទាំងនោះមានម្នាក់ស្លៀកពាក់ដូចជាសង្ឃនោះដែរ ប៉ុន្តែពាក់ស្បែកជើងក្រណាត់និងចង់ខ្សែ ។ អ្នកខ្លះទៀតពាក់រ៉ូបមានពណ៌ចំរុះនិងមានខោរលុងស៊ុលឃុល រីវ័ណ្ឌតែក្រណាត់មួយផ្ទាំងតែប៉ុណ្ណោះ ។ អ្នកទាំងអស់នោះគ្មានអាវុធទេ ។

*ភ្លាក់ថន*បង្ហាក់មេធាយទៅហើយទាន់នៅមានពេល ប៉ុន្តែគេគ្មានកំលាំងអ្វីនៅក្នុងខ្លួនសោះ ។ ម្យ៉ាងទៀតគេក៏គ្មានកន្លែងណា ដើម្បីលាក់ខ្លួនបំពួនអាត្មាផង ។ មានុរបស់គេពណ៌ភ្នែករបស់គេ ធ្វើអោយគេស្ថិតនៅជាមនុស្សចំលែកក្នុងពិភពនេះតែម្តង ។ គេក៏ផ្អែកខ្លួនទៅនឹងជញ្ជាំង ។

- ឯងជាអ្នកណា ?

---

*(២២) នៅក្នុងសម័យពីសតវត្សទី១៦ ពួកប្រទេសនានាបានអនុញ្ញាតអោយពលរដ្ឋខ្លួនដើរទូកតាមសមុទ្រ ដើម្បីតាមប្លន់ និងកំទេចនាវារបស់ប្រទេសជាសត្រូវរបស់ខ្លួនបាន ពួកនេះនិយមប្រើនាវាចុនលឿន ដែលគេហៅថា កកស៊ែ ហើយក្រោយមកគេក៏ហៅទាំងពួកដែលប្រកបការងារនេះថាពួកកកស៊ែតែម្តង ( ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

សង្ឃនោះសួរទៅកាន់ *ប្លាក់ថន* ជាភាសាប៉ក់ទុយកាល់ ។ សង្ឃនេះមានរាងធាត់ស្មៀចសំបុរស្រអែម មានអាយុប្រហែល២៥ឆ្នាំ និងមានពុកចង្កាយ៉ាងវែង ។

- ឯងជាអ្នកណា ?

*ប្លាក់ថន* សួរវិញដោយសំលឹងមើលសង្ឃនោះយ៉ាងមុត ។

- នេះគឺជានាវាកកស៊ែហូឡង់ ។ ឯងប្រាកដជាពួកទមិឡហូឡង់នោះហើយ ។ ពួកឯងគឺជាពួកចោរសមុទ្រ ។ ឱ ! សូមព្រះជួយប្រណីពួកឯងផងចុះ !

- ពួកយើងមិនមែនជាចោរសមុទ្រទេ ។ យើងគឺជាឈ្មួញដែលសុំតែសុខតែប៉ុណ្ណោះ លើកលែងតែជាមួយសត្រូវយើង ។ ខ្ញុំគឺជាតៃកុងសំពៅនេះ ។ រួចអ្នកឯងវិញអ្នកឯងជាអ្នក ណា ?

- បុព្វជិតសេបាស្ស ។ អ្នកឯងធ្វើម៉េចបានមកដល់ទីនេះ ? អ្នាសធ្វើម៉េច ?

-យើងត្រូវខ្យល់បក់រុញមកទើរនឹងច្រាំងនេះ ។ កន្លែងនេះជាកន្លែងអី ? ស្រុកជប៉ុនហើយហ្នឹងអ្វី ?

- អើ ! ជប៉ុនហើយ ។ នីប៉ុង !

សង្ឃនេះឆ្លើយទាំងធុញទ្រាន់ រួចគេក៏បែរទៅរកមនុស្សម្នាក់ ។ មនុស្សនេះមានចំនាស់ជាងអ្នកឯទៀតហើយមានរាងទាបស្តើង មានដៃម៉ាំនិងបាតដៃឡើងក្រិន។ គេកោរលលាដ៍ក្បាល ហើយសក់របស់គេ ដែលមានពណ៌ល្បាយអាច់ខ្លាដូចជាចិញ្ចើមរបស់គេដែរនោះ ត្រូវបានចងជាសក់សេះយ៉ាងស្អាត ។ សង្ឃនោះនិយាយទៅកាន់មនុស្សនេះដោយមានលក្ខណៈរួញរា និងជាភាសាជប៉ុន ហើយចង្អុលទៅប្លាក់ថន ។ អ្នកទាំងអស់នៅទីនោះហាក់ដូចជាភ័យជ្រួលច្របល់ ហើយបុរសម្នាក់ធ្វើសញ្ញាកាកបាទ ដែលជាសញ្ញាការពារខ្លួននោះ ។

- អោយតែពួកហូឡង់គឺសុទ្ធតែជាពួកទមិឡពួកបះបោរ និងពួកចោរសមុទ្រតែទាំងអស់ហ្នឹង ។ ឯងឈ្មោះអី ?

- កន្លែងហ្នឹងជាដីអាណានិគមប៉ក់ទុយកាល់អ្វី ?

ក្រសែភ្នែករបស់សង្ឃបានសំដែងភាពគំនាច ហើយក្រហមស្មើរស្រក់ឈាម ។



www.budinst.gov.kh www.elibraryofcambodia.org

- ប្រធានភូមិបាននិយាយថា គេបានជូនដំណឹងពីឯងដល់អាជ្ញាធរហើយ ។ បាបកម្មទាំងប៉ុន្មានរបស់ឯងនឹងធ្វើអោយឯងរលត់រលាយហើយអ្នក!រួចពួកសំពៅឯទៀតទៅណាអស់ហើយ ?

- ខ្ញុំមិនដឹងដែរ ។នៅលើសំពៅក៏មិនដឹង ។ ប្រហែលនៅលើសំពៅហើយមើលទៅ ។ សង្ឃនោះក៏ចាប់ផ្ដើមសួរប្រធានក្រុមនោះម្ដងទៀត ។ប្រធានក្រុមឆ្លើយតបដោយចង្អុលទៅចុងម្ខាងភូមិ និងដោយនិយាយពន្យល់យ៉ាងយូរ ។ រួចចប់សព្វគ្រប់ហើយសង្ឃនោះក៏ងាកមករក *ប្លាក់ថន*វិញ :

-នៅទីនេះគេឆ្កាងពួកឧក្រិដ្ឋជនណាំ លោកតែកុង ។ លោកច្បាស់ជានឹងស្លាប់តែហោងហើយ ។ *វ៉េមីញ៉ូ* នឹងមកទីនេះជាមួយនឹងពួក *សាមូរ៉ៃ* របស់គេ ។ ឱ ! សូមព្រះប្រណីសន្ដោសដល់ពួកឯងផងចុះ !

-ស្អីទៅ *វ៉េមីញ៉ូ* ហ្នឹង !

-គឺស្ដេចត្រាញ់ណាំ!គឺគេត្រួតខេត្តហ្នឹងទាំងមូលណាំ!រួចម៉េចបានជាឯងមកដល់ទីនេះ?

- រួចស្អីទៅ *សាមូរ៉ៃ* នោះ ?

- គឺជាយុទ្ធជន ជាកងទ័ព ជាអ្នកនៅក្នុងត្រកូលអ្នកច្បាំង-សង្ឃនោះកាន់តែមួម៉ៅឡើង១-រួចម៉េចបានជាឯងមកដល់កន្លែងនេះបាន ?

- ខ្ញុំស្ដាប់សំនៀងអ្នែងមិនបានសោះ ។ អ្នកឯងជាពិអេស្ប៉ាញអ្វី ?- *ប្លាក់ថន*និយាយដើម្បីធ្វើអោយសង្ឃនោះឆេះដុំ ។

- អញប៉ុកទុយកាល់-សង្ឃនោះនិយាយទាំងឆេះដុំគឺគេបានត្របាក់នុយរបស់ *ប្លាក់ថន* ហើយ-អញនិយាយប្រាប់ហើយតើ!អញឈ្មោះសេបាស្ស អញមកពីប៉ុកទុយកាល់ ។ រួចឯងរៀននិយាយប៉ុកទុយកាល់នៅឯណាបានជាច្បាស់ម្ល៉េះ ?

-តែក្រែង ប៉ុកទុយកាល់និងអេស្ប៉ាញតែមួយទេអ្វី? អ្នកឯងមានស្ដេចតែមួយទេតើ!-*ប្លាក់ថន* ដុតបន្ថែម ។

- យើងគឺជាប្រទេសឯករាជ្យ ។ យើងជាប្រជាជនខុសគ្នា ហើយខុសគ្នាតាំងតែពីដើមរៀងមក ។ យើងមានទង់ជាតិផ្ទាល់របស់យើងណាំ ! ដីយើងកាន់កាប់នៅឯនាយសមុទ្រក៏ផ្សេង



www.budinst.gov.kh www.elibraryofcambodia.org

ពីអេស្ប៉ាញដែរ ។ មែនណាំ ! ផ្សេងគ្នាវ៉ឺយ ! ស្តេចភីលីប ពេលកាន់កាប់ប្រទេសយើងក៏ទ្រង់យល់ព្រមដែរ - សង្ឃសេបាស្ទៀងប់កាពនីងនររបស់ខ្លួនលែងបាន ម្រាមដៃលោកឡើងញ័រទទ្រើត-២០ឆ្នាំមុននេះស្តេចនេះបានឈ្លានពានប៉័កទុយកាល់ ! ទាហាន អាស្តេចផ្តាច់ការអេស្ប៉ាញកូនមេនរក ខុច [២៣] អាល់វ៉ាបានបង្ក្រាបស្តេចពិតប្រាកដរបស់ពួកយើង ។ អីលូវព្រះរាជបុត្ររបស់ស្តេចភីលីបសោយរាជ្យលើនគរយើងមែន តែមិនមែនស្តេចពិតប្រាកដរបស់ពួកយើងទេ ។ ព្រះរាជាយើងនឹងឡើងសោយរាជ្យវិញជាមិនខាន ។

រួចសង្ឃសេបាស្ទៀនិយាយបន្ថែមទៀតក្នុងសំលេងដ៏សាហាវ

- ហើយអ្នែងក៏ដឹងថា ប្រការនេះគឺជាប្រការពិតដែរ ។ អ្វីដែលអាខ្មោចកាច់អាល់វ៉ានេះបានធ្វើដល់ប្រទេសអ្នែងក៏វ៉ាបានធ្វើតែដូចគ្នាហ្នឹងដែរនៅប្រទេសអញ ។

- កុហកស្មោះ ! អាអាល់វ៉ាវ៉ាជាមេរោគនៅហូឡង់មែន ប៉ុន្តែវ៉ាមិនដែលកាន់កាប់ហូឡង់បានទេណាំ ! ហូឡង់តាំងពីដើមរៀងមកជាប្រទេសឯករាជ្យ ហើយទៅថ្ងៃមុខក៏នៅតែឯករាជ្យអីចឹង ! តែនៅប៉័កទុយកាល់គ្រាន់តែអាល់វ៉ាវៃបាក់មួយកងទ័ពតូចសោះ ម៉ាប្រទេសសុំចាញ់តែម្រ៉ង ។ ពួកឯងនេះប្រមាត់តូចណាស់ ។ ពួកឯងចង់ទាត់ពួកអេស្ប៉ាញចេញពីស្រុកធ្វើរណាក៏បានដែរ អោយតែពួកឯងចង់ ។ តែមើលទៅពួកឯងនៅតែរួញក្បាលដូចអណ្តើករហូតហ្នឹង ។ ពួកឯងសុទ្ធតែពួកញី ។ ខ្លាំងណាស់បានត្រឹមតែយកមនុស្សស្លូតត្រង់ទៅដុតទាំងរស់ក្នុងនាមព្រះតែប៉ុណ្ណឹង ។

សង្ឃសេបាស្ទៀតបទាំងញ័រមាត់ទទ្រើតដោយកំហឹង :

- ឪ ! សូមអោយអ្នែងឆេះរោលរាលនៅក្នុងនរកអវចីទៅចុះ ! មារវជ្រែកបន្លំខ្លួនយ៉ាងណាក៏គង់តែផ្ចាញ់ព្រះមិនបានផង ។ ហើយពួកទមិឡឯងអស់នេះក៏គង់តែរលត់រលាយទេព្រោះព្រះដាក់បណ្តាសាពួកឯងរួចហើយ !

នៅចំពោះពាក្យបណ្តាសាទាំងនេះ ចង់វីមិនចង់*ញាក់ផង* ស្រៀវឆ្អឹងខ្នងដែរ ។

---

*(២៣) ហ៊ាន:ខ្ពស់បំផុតនៅអឺរ៉ុប បន្ទាប់ពីព្រះអង្គម្ចាស់មក ( ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

- ពួកសង្ឃមិនមែនមានបញ្ញាញាណព្រះទេ ហើយសំដីលោកឯងក៏មិនមែនសំដីព្រះដែរ ។ ពួកយើងរំដោះខ្លួនចេញពីទីមងំថោកទាបរបស់ពួកឯងហើយ ១ យើងនឹងស្ថិតនៅក្នុងសេរីភាពនេះរហូត ។

កាលពីប៉ុន្មានសែសិបឆ្នាំមុននេះម៉ារីទុដ័រឈាមជោកនោះ បានឡើងសោយរាជ្យលើប្រទេសអង់គ្លេសជាមួយនឹងស្វាមីខ្លួន ដែលជាស្តេចប្រទេសអេស្ប៉ាញព្រះនាមភីលីប ទី២ និងដែលគេប្រសិទ្ធនាមថា ភីលីបមហាកំនាច ។ ម៉ារីទុដ័រ ដែលជាបុត្រីព្រះបាទហង់រី ទី៨ នេះជាមនុស្សរឹងប៉ឺងសាសនាហួស ដោយហេតុនេះព្រះនាងបានលើកតំកើងពួកសង្ឃកាតូលិចឡើងវិញបានចាត់តាំងតុលាការសាសនា(២៤) ដើម្បីកាត់ទោសមនុស្សទាំងអស់ណាដែលគេចាត់ទុកថាដើរខុសគន្លងមាគ៌ាព្រះ ដែលជាប្រការមួយធ្វើអោយប្រទេសអង់គ្លេសស្ថិតនៅក្រោមការជិះជាន់របស់បរទេសទៅវិញ ។ ព្រះមហាក្សត្រយានីទុដ័រ បានធ្វើមិនដឹងមិនលឺនូវការសំរេចនានា និងបំបែបំរួលជាប្រវត្តិ ដែលព្រះបិតាព្រះនាងបានប្រកាន់យកក្នុងទំនាក់ទំនងជាមួយព្រះសង្ឃរាជនៅរ៉ូម ហើយព្រះនាងបានប្រឆាំងនឹងឆន្ទៈរបស់ប្រជារាស្ត្រព្រះនាងទៅវិញ ។ ក្នុងរយៈពេល ៥ឆ្នាំ នៃការសោយរាជ្យរបស់ព្រះនាង គំនុំគុំគួន ភាពភ័យខ្លាច និងឈាមហូរដាបពោះដីរបានចាប់ហែកព្រះរាជាណាចក្រអោយរយះរយាយខ្ទេចខ្ទី ។ ពេលដែលម៉ារីទុដ័រសោយទីវង្គតទៅព្រះនាង *អេលីសាបែត* អោយឡើងសោយរាជ្យបន្តនៅក្នុងព្រះជន្មាយុ ២៤ព្រះវស្សា ។

ពេលរំលឹកដល់ព្រះនាងអេលីសាបែត *ភ្លាក់ផង* មានអារម្មណ៍ស្ងើចសរសើរ និងការគោរពស្រលាញ់ដូចម្តាយចំពោះព្រះមហាក្សត្រីយានីនេះ ។ ក្នុងរយៈពេល៤០ឆ្នាំ ព្រះនាងបានពុះពារជំនះពិភពលោកទាំងមូល ។ ទីបំផុតព្រះនាងទទួលបានជ័យជំនះលើពួកប៉ាប លើចក្រភពសាសនារ៉ូម លើប្រទេសបារាំងនិងអេស្ប៉ាញ ដែលរួមគ្នាប្រឆាំងប្រទេសអង់គ្លេស ។ ទោះជាត្រូវ

---

*(២៤) ចាប់តាំងពីសតវត្សរ៍ទី១៣ (១២៣១) ដើម្បីទប់នឹងទំនោរផ្សេងៗនៅក្នុងនិកាយកាតូលិច គេបានបង្កើតតុលាការសាសនា (Inquisition) ដើម្បីផ្តន្ទាទោសអ្នកណាដែលគេចាត់ថា អនុវត្តផ្ទុយពីមាគ៌ារបស់ព្រះ ។ ទណ្ឌកម្មដែលគេតែងអនុវត្តគឺដុតទាំងរស់ និងដាក់គុកអស់មួយជីវិត ។ ការអនុវត្តន៍ របៀបផ្តាច់ការក្នុងសាសនានេះមានរហូតដល់សតវត្សទី១៦ ( ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

គេប្រកាសបណ្តេញចេញពីកពគ្រិស្តសាសនា ទោះត្រូវគេប្រមាថមាក់ងាយ គេជេរប្រទេច ផ្តាសា ព្រះនាងសំរេចជោគជ័យក្នុងការដឹកនាំប្រទេសអង់គ្លេសអោយបានទៅដល់ទីដៅដោយគ្មានខូចខាត ដោយមានឯករាជ្យនិងប្រកបដោយវឌ្ឍនភាព ។

-ពួកយើងមានសេរីភាពហើយ-*ប្លាក់ថន* ពោលបន្តទៅកាន់សង្ឃសេបាស្ទ-ពួកអ្នកឯងរលត់រលាយបាត់ហើយ ។ យើង!យើងមានសាលារៀនរបស់យើង មានសៀវភៅរបស់យើង មានប៊ីប[២៥] របស់យើង មានវិហាររបស់យើង ចំនែកពួកឯង ពួកអេស្ប៉ាញដូចតែគ្នាហ្នឹង គឺជាពួកកាកសំរាម ។ ពួកឯងជាសង្ឃនេះក៏ដូចតែគ្នាហ្នឹង គឺពួកគោរពរូបចំលាក់តែប៉ុណ្ណឹង !

សង្ឃសេបាស្ទលើករូបឆ្លាង ហើយរុញទៅមុខដូចជាខែល :

-ឱព្រះយេស៊ូជាម្ចាស់អើយ ! សូមការពារពួកយើងខ្ញុំអោយផុតពីបិសាចនេះផង ! អញមិនមែនសញ្ជាតិអេស្ប៉ាញទេ អញប្រាប់អ្ហែងហើយតើ ! អញសញ្ជាតិប៉័កទុយកាល់ ។ ហើយអញមិនមែនជាសង្ឃទេ អញជាបព្វជិតនៅក្នុងសមាគមយេស៊ូ[២៦] ។

-អូ ! អីចឹងឯងនៅក្នុងក្រុមពួកយេស៊ុីតហ្នឹងទេ !

-ហ្នឹងហើយ ! សូមព្រះជាម្ចាស់ប្រោសព្រលឹងអ្ហែងផងចុះ !

-ហ្នឹងហើយ ! សូមព្រះជាម្ចាស់ប្រោសព្រលឹងអ្ហែងផងចុះ !

បព្វជិតសេបាស្ទចេញបញ្ជាប៉ុន្មានម៉ាត់យ៉ាងគំបុត ១ ជាភាសាជប៉ុន រួចពួកអ្នកទាំងនោះហក់មករក*ប្លាក់ថន*ភ្លាមមួយរំពេច ។ *ប្លាក់ថន* ទល់ខ្នងទៅនឹងជញ្ជាំង ហើយដាល់មួយដៃយ៉ាងអស់ទំហឹងទៅលើបុរសម្នាក់ ប៉ុន្តែដោយអ្នកឯទៀតមានចំនួនច្រើនពេកនោះ គេក៏ត្រូវអ្នកទាំងនោះសង្កត់ជាប់ស្ទើរដាច់ដង្ហើម ។

- *ណាទីកូតូ ដា ?*

---

*(២៥) សៀវភៅគម្ពីរធម៌របស់គ្រិស្តសាសនា ( ក.អ.ប)*

*(២៦) អង្គការសាសនាមួយក្រុមបង្កើតឡើងនៅរង្វង់ឆ្នាំ១៥៤០ ដែលសង្កត់ធ្ងន់លើការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់នូវវិន័យគ្រិស្តសាសនា ( ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

ការប្រគាយប្រគប់គ្នាបានឈប់ភ្លាមមួយរំពេច ។

យុវជននោះនៅឈរចំងាយ១០ជំហានពីកន្លែងកើតហេតុ ។ គេស្លៀកខោពាក់ស្បែកជើងសង្រែកនិងតីមីល្ហូស្តើងមួយ ។ កាំបិត២នៅក្នុងស្រោមត្រូវបានសៀតទៅនឹងចង្កេះ ។ ក្នុងកាំបិតទាំងពីរនេះមានកាំបិតមួយរាងដូចជាកាំបិតស្នៀត កាំបិតមួយទៀតជាដាវមុខមួយសំរាប់កាន់ដៃពីររាងវែង ហើយកោងបន្តិច ។ ដៃស្តាំរបស់យុវជននោះដាក់លើដងកាំបិតទីពីរនេះ ។

*-ណានីកូតូ ដា ?-* យុវជននោះសួរម្តងទៀត ហើយដោយគ្មានអ្នកណាឆ្លើយតបគេក៏ស្រែកសន្ធាប់ឡើងភ្លាម *-ណានីកូតូ ដា ?*

ពួកជប៉ុនដែលនៅទីនេះទាំងប៉ុន្មានលុតជង្គង់ស្រុប ក្បាលអោនដល់ដី ។ មានតែបព្ជិតនោះម្នាក់ទេដែលនៅឈរ ។ សេចក្តីស្ញប់ស្ញែងអោនខ្លួនគោរព រួចទើបនិយាយទាំងរួញរា ។ យុវបុរសនោះនិយាយកាត់បព្ជិតទាំងអាការៈប្រមាថមាក់ងាយ ហើយចង្អុលទៅប្រធានភូមិ :

*-មូរ៉ា !*

*មូរ៉ា* និយាយយ៉ាងញាប់ឆ្អេវដោយនៅតែរក្សាក្បាលអោនជាប់ ។ គេលើកដៃចង្អុល *ប្លាក់ថន* យ៉ាងញឹកញាប់ចង្អុលសំពៅនិងចង្អុលបព្ជិតពីរដង ។ នៅលើផ្លូវគ្មានអ្វីកំរើកទាំងអស់ ។ នៅពេលដែលប្រធានភូមិនិយាយពន្យល់ចប់ហើយ យុវបុរសប្រដាប់អាវុធនោះ សួរបញ្ជាក់ថែមទៀតក្នុងលក្ខណៈយ៉ាងក្រអឺតក្រទម ហើយមូរ៉ាក៏ឆ្លើយតបទៅវិញយ៉ាងគោរព ។ រួចហើយទើបយុវជននោះនិយាយពីរបីមាត់ជាមួយប្រធានភូមិ និងដោយមានកាយវិការប្រមាថមាក់ងាយចង្អុលមកបព្ជិតនិង *ប្លាក់ថន* ថែមទៀតផង ។ បុរសសក់ប្រផេះនោះក៏បកប្រែជាពាក្យសាមញ្ញ ហើយបព្ជិតនេះមុខឡើងក្រហមងាំងតែម្តង ។

យុវបុរសមានអាវុធនេះនៅក្មេងជាង និងទាបត្រឹម ក *ប្លាក់ថន* ។ គេមានមុខស្អាតនិងមានអុជ ១បន្តិច ។ គេសំលឹងមើលអ្នកចំនួលថ្មីឥតដាក់ភ្នែក :

*- អូនូស៊ី អ៊ិតៃ ដូកូ កាវ៉ាគីតាណូ ដា ? ដូកូណូ គូនីណូ ម៉ូណូដា ?*

បព្ជិតបកប្រែអោយ *ប្លាក់ថន* ទាំងរសាប់រសល់ :

*-កាស៊ីគី អូមី- សាន* សួរថាអ្លែងមកពីណា ហើយអ្លែងសាសន៍អី ?

-លោក *អូមី-សាន* ជា *ដៃមីញ៉ូ* អ្លេស ?



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* សួរតបទៅវិញ ។ នៅក្នុងចិត្តរបស់គេក៏មានការរន្ធត់ញាប់ញ័រដែរ ទោះជាគេខំប្រឹងទប់យ៉ាងណាក្តី ព្រោះតែគេឃើញអាវុធដែលបុរសនោះ មានជាប់នឹងខ្លួននោះ ។

-ទេ ! គេគឺជា*សាមូរ៉ៃ* ។ ជា*សាមូរ៉ៃ* ដែលទទួលខុសត្រូវលើភូមិនេះ ។ ត្រកូលគេឈ្មោះ *កាស៊ុគិ* ឈ្មោះគេគឺ *អូមី* ។ នៅស្រុកនេះគេដាក់ត្រកូលមុនឈ្មោះគេផ្ទាល់ " *សាន* "មានន័យថា" លោក" ។ អ្នកត្រូវភ្ជាប់ពាក្យនេះជាមួយឈ្មោះរបស់គេគ្រប់គ្នា ដើម្បីបង្ហាញនូវការគោរព ។ អ្នកត្រូវរៀនមានសុជីវធម៌ ហើយចេះដឹងទំនៀមទំលាប់អោយបានរហ័សកាលណាល្អកាលហ្នឹង ។ ពួកគេស្អប់ណាស់មនុស្សគ្មានការអប់រំ- រួចបព្វជិតសេបាស្ទ្យបន្ថឹងសំលេង - នែ ! ឆាប់ឆ្លើយភ្លាមទៅ !

- ខ្ញុំមកពីអាំស្ទែដាំ ខ្ញុំសញ្ជាតិអង់គ្លេស ។

បព្វជិតសេបាស្ទ្យ ដូចធ្លាក់ពីលើមេឃតែម្តង ។ គាត់ងាកទៅបក : " អង់គ្លេស " ទៅ *សាមូរ៉ៃ* រួចចាប់ផ្តើមពន្យល់ ។ ប៉ុន្តែ *អូមី-សាន* និយាយយ៉ាងញាប់ស្មេរកាត់សំដីបព្វជិតនោះ ។

-*អូមី-សាន* សួរថា អ្នកជាមេអ្វី ? ប្រធានភូមិបាននិយាយថា មានតែពួកទមិឡនៅរស់តែប៉ុន្មាននាក់ទេ ហើយភាគច្រើនឈឺទៀតផង ។ អ្នកមានមេបញ្ជាការទេ ?

- ខ្ញុំគឺជាមេគេ ។

*ប្លាក់ថន* ឆ្លើយតប ។ តាមពិតគេដឹងច្បាស់ថា នៅពេលជាន់ដីគោកគេគ្មានតួនាទីអ្វីទៀតទេ តែទោះជានៅលើដីគោកក៏នៅលើសមុទ្រ ទោះជា ជារីមានជំងឺក៏មេបញ្ជាការ *ស្ពីលប៊ែកេន* គ្មានសមត្ថភាពនឹងបញ្ជាបានឡើយ ។

*សាមូរ៉ៃ* និយាយប៉ុន្មានម៉ាត់បន្ថែមទៀត ។

- *អូមី-សាន* និយាយថា អ្នកអាចដើរលេងនៅក្នុងភូមិនេះបាន ។ គឺអ្នកចង់ទៅកន្លែងណាក៏ទៅចុះ រហូតដល់ពេលលោកម្ចាស់របស់គាត់មក ។ នេះគឺព្រោះអ្នកជាមេគេ ។ លោកម្ចាស់របស់គាត់គឺ *ដៃមីញ៉ូ* នឹងកំនត់ពីវាសនារបស់អ្នក ។ ប៉ុន្តែក្នុងចន្លោះពេលនេះអ្នកអាចរស់នៅដូចជាភ្ញៀវនៅក្នុងផ្ទះរបស់ប្រធានភូមិនេះ ហើយអ្នកចង់ទៅណាទៅចុះម៉ាសេរី ។



www.budinst.gov.kh www.elibraryofcambodia.org

តែហាមផ្តាច់មិនអោយចេញពីភូមិដាច់ខាតទោះក្នុងមូលហេតុអីក៏ដោយ ។ ឯក្រុមរបស់អ្អែង ត្រូវឃាត់ខ្លួននៅមួយកន្លែង ហើយគ្មានសិទ្ធិចេញដើរទេ ។ ម៉េចអ្អែងយល់ហើយនៅ ?

- យល់ហើយ ។ ចុះពួកខ្ញុំនៅឯណា ?

បញ្ជិតសេបាស្សលើកដៃចង្អុលវាសទៅមុំផ្ទះដែលនៅក្បែរផែមួយ ។ តាមមើលទៅ បញ្ជិតនេះខកចិត្តខ្លាំងនឹងអារម្មណ៍ ហើយនឹងភាពមិនដាច់ស្រេចរបស់ *អូមី* :

- នៅទីនោះ ! អីលូវប្រឹងឆ្លៀតសប្បាយសេរីភាពអ្អែងអោយហើយទៅអាមេចោរ សមុទ្រ ! ព្រោយអ្អែងនឹងអោយអ្អែងរលាយខ្លួនហើយអ្នា !

*អូមី* បែរនិយាយមកកាន់ *ប្លាក់ថន* ផ្ទាល់តែម្តង :

- *វ៉ាការីម៉ាស៊ូកា* ?

- គាត់សួរថា អ្អែងយល់ទេ ?

- " បាទ " ភាសាជប៉ុនថាម៉េច ?

តែសេបាស្សងាកទៅឆ្លើយប្រាប់ *សាមូរ៉ៃ* វិញ :

- *វ៉ាការីម៉ាស៊ូ*

*អូមី* ក្នុងរឹកពាររឹងឆ្អែធ្វើសញ្ញាអោយអ្នកផងងាកចេញពីផ្លូវដើររបស់ខ្លួន ។ អ្នកទាំងអស់លំអោនខ្លួនយ៉ាងទាប លើកលែងតែមនុស្សម្នាក់គត់នៅឈរត្រង់ មិនព្រមលំអោនខ្លួនដូចអ្នកឯទៀតឡើយ ។

ផ្លែដាវវាសឡើងជារាងដងធ្នូជះពន្លឺប្រាក់ឆ្វាច ហើយនៅក្នុងស្នូរកាត់ខ្យល់ និងក្នុងល្បឿនមួយដ៏អស្ចារ្យបានកាត់ក្បាលបុរសនោះប៉េង ។ ឈាមក៏ចាប់ហូរចេញកខក់ប្រៀបដូចជាចំពួយទឹកទៅលើដី ។ ខ្លួនបុរសនោះទធាក់ត្រដរខ្យល់មួយស្របក់ទើបលែងកំរើក ។ បញ្ជិតសេបាស្សថយក្រោកទៅក្រោយដោយសភាវគតិ ប៉ុន្តែអ្នកឯទៀតដែលនៅលើផ្លូវនេះគ្មានកំរើកអ្វីទាំងអស់ ។ ក្បាលពួកគេនៅតែអោនជាប់ដដែល ។ ចំនែកឯ *ប្លាក់ថន* វិញភាពស្រលាំងកាំងបានធ្វើអោយគេនៅថ្មឹងដូចជារូបចំលាក់តែម្តង ។ *អូមី* យកជើងជាន់លើសាកសពបែបវាហ៊ី ។

" *អ៊ីគីណាសៃ* " គេនិយាយបណ្តេញអ្នកទៀតអោយដើរចេញ ។



www.budinst.gov.kh www.elibraryofcambodia.org

ក្រុមមនុស្សដែលនៅទល់មុខអូមីទាំងប៉ុន្មានលុតជង្គង់ក្រាបគោរព រួចនាំគ្នាដើរចេញពីទីនេះអស់រលីង ។ នៅលើដងផ្លូវគ្មានមនុស្សមួយគ្រាប់ណាទៀតឡើយ នៅក្នុងហាងក៏អ៊ីចឹងដែរ ។

បព្វជិតសេចាស្សូចោលភ្នែកសំលឹងមើលសាកសព ហើយធ្វើសញ្ញាកាកបាទពីលើដោយសូត្រធម៌បន្តិច ។ រួចហើយគាត់ងាកទៅរកសាមូរ៉ៃនោះ ហើយសំលឹងមើលចំភ្នែកយុវបុរសនោះដោយគ្មានញញើត ។

" *អូតឹលកាសែ !* " ចុងដាវភ្លឺចិញ្ចាចនៅលើសាកសពនៅឡើយ ។

ក្នុងរយៈពេលមួយសន្ទុះធំទើបបព្វជិតនេះបែរខ្លួន ហើយដើរចេញពីទីកន្លែងនេះយ៉ាងថ្លៃថ្នូរ ។ អូមីតាមសំលឹងមើលបព្វជិតយ៉ាងពិនិត្យពិច័យ រួចទើបចោលភ្នែកមួយខ្ទាប់ទៅរកប្លាក់ថន ។ ក៏ចាប់ដើរថយក្រោយ លុះបានឆ្ងាយល្មមហើយគេក៏បត់ទៅតាមផ្លូវមួយទៀតយ៉ាងរហ័ស ។

*អូមី* ផ្ទុះសំនើចយ៉ាងខ្លាំងខ្លារ ។ ផ្លូវថ្នល់ស្ងាត់គ្មានមនុស្សម្នាក់ ។ នៅពេលគេឈប់សើចគេក៏ចាប់យកដាវដោយដៃទាំងពីរ ហើយចាប់ផ្តើមកាប់សាកសពជាកំនាត់ ៗ ដោយមានរបៀបរៀបរយ ។

*ប្លាក់ថន* ឡើងជិះលើទូកមួយដែលគេរកបានដោយងាយស្រួល ។ គេឃើញមនុស្សមួយចំនួនកំពុងឈរនៅលើសំពៅអេរ៉ាស់ ។ ពួកគេគឺជាពួកសាមូរ៉ៃ ។ អ្នកខ្លះមានពាក់អាវក្រោះឯអ្នកខ្លះទៀតពាក់គីម៉ូណូចម្លែកតា ប៉ុន្តែទាំងអស់គ្នាសុទ្ធតែមានកាំបិតទាំង ២នេះ ។ របៀបសិតសក់របស់ពួកគេដូចគ្នាទាំងអស់ គឺលលាដ៍ក្បាលខាងលើត្រងោល ហើយសក់ដែលលាបប្រេងរលោងនោះត្រូវបួងទៅក្រោយបត់ជាពីរគន្ទាក់ ។ គឺមានតែពួកសាមូរ៉ៃទេ ដែលមានសិទ្ធិ និងកាតព្វកិច្ចសិតសក់របៀបនេះ ។ ហើយគឺមានតែពួកនេះទេ ដែលមានសិទ្ធិនិងកាតព្វកិច្ចកាន់កាំបិតទាំងពីរនេះ ។ ពួកគេឈរតំរៀបតាមគែមសំពៅ ហើយតាមសង្កេតមើល *ប្លាក់ថន* ។

មកដល់សំពៅហើយ *ប្លាក់ថន* ឡើងតាមជណ្តើរដែលនៅចំហៀងសំពៅទៅជាន់ខាងលើទាំងក្នុងចិត្តព្រួយបារម្ភ ។ សាមូរ៉ៃម្នាក់ ដែលមានសំលៀកបំពាក់ល្អស្អាតជាងអ្នកឯទៀត



www.budinst.gov.kh www.elibraryofcambodia.org

បានដើរមកជិត *ប្លាក់ថន* ហើយលំអោនខ្លួនដាក់គេ ។ *ប្លាក់ថន* ដែលចាំស្ទាត់នូវមេរៀនរបស់ខ្លួន ហើយនោះក៏លំអោនខ្លួនតបវិញ ។ ទឹកមុខរបស់អ្នកនៅលើសំពៅទាំងប៉ុន្មានក៏ប្រែទៅជាស្រស់ស្រាយភ្លាម ។ ចំពោះប្លាក់ថន គេនៅតែរញ្ជួយចិត្តនៅឡើយចំពោះភាពដ៏គួរអោយតក់ស្លុតនៃឃាតកម្មទាំងនៅកណ្តាលផ្លូវអំបាញ់មិញនេះ ។ ភាពញញឹមនៃពួកសាមូរ៉ៃទាំងនេះក៏មិនអាចបំបាត់បាននូវចិត្តរអើលរបស់គេនៅឡើយដែរ ។ គេដើរតំរង់ទៅជណ្តើរប្រុងចុះទៅជាន់ក្រោមសំពៅ ស្រាប់តែគេឈប់ងិក់តែម្តង ។ នៅនឹងមាត់ជណ្តើរមានក្រនាត់ស្លូតពណ៌ក្រហមមួយផ្ទាំងនៅរាំងផ្លូវ ហើយនៅជិតនោះមានក្តារមួយបន្ទះពេញដោយសញ្ញាក្រវេមក្រវាម ថែមទៀតផង។ *ប្លាក់ថន* នៅរេរា ហើយងាកទៅសំលឹងទ្វារមួយទៀត ។ ទ្វារនោះក៏ត្រូវរាំងដោយក្រណាត់ស្លូតបែបគ្នាដែរ ហើយថែមទាំងមានបន្ទះក្តារដូចគ្នានេះវាយភ្ជាប់ទៅនឹងសន្លឹកទ្វារទៀតផង ។

*ប្លាក់ថន* លូកដៃបំរុងដកផ្ទាំងក្រណាត់ចេញ ...

- *ហ្វូតេ អុកេ* !

*សាមូរ៉ៃ* ដែលនិយាយឡើងនេះគ្រវីក្បាលជាសញ្ញាហាមឃាត់ ។ ភាពញញឹមអំបាញ់មិញនេះលែងមានទៀតហើយ ។

- តែនេះជាសំពៅខ្ញុំណាំ ! ខ្ញុំចង់...

នៅពេលឃើញកាំបិត *ប្លាក់ថន* មិនអាចលាក់ការភ័យខ្លាចរបស់ខ្លួនបានទេ ។ អញត្រូវតែចុះទៅក្រោម-គេគិតនៅក្នុងចិត្ត-អញត្រូវតែយកកូនសៀវភៅអោយបាន។ ទាំងកូនសៀវភៅអញទាំងកូនសៀវភៅសំងាត់ ។ ឱ ! ព្រះអើយលោតែអ្នកណាឃើញកូនសៀវភៅទាំងនេះ ហើយយកទៅអោយបព្វជិតវីពួកជប៉ុននោះ គឺច្បាស់ជាអន្តរធានទាំងអស់គ្នាហើយ ។ គ្រប់តុលាការមួយក្រោមមេឃលើដីនេះ លើកលែងតែតុលាការអង់គ្លេស និងហូឡង់ចេញ ពេលមានភស្តុតាងនេះច្បាស់ជាកាត់ទោសពួកយើងពីបទប្លន់លើសមុទ្រ ជាមិនខានទេ ។ កូនសៀវភៅអញមានកត់តាំងពីថ្ងៃខែទីកន្លែង និង ចំនួនទ្រព្យសម្បត្តិ ដែលជណ្តើមបាន កត់ទាំងចំនួនអ្នកស្លាប់ នៅកន្លែងចូលចតទាំង ៣ កន្លែងនៅអាមេរិច និង កន្លែងចតនៅអាព្រិច អេស្ប៉ាញ ចំនួនព្រះវិហារ ដែលបានប្លន់ និង ពីរបៀប ដែលយើងបានដុតក្រុង និង សំពៅនានា ។ ហើយបើនិយាយពីកូនសៀវភៅប៉កទុយកាល់



www.budinst.gov.kh www.elibraryofcambodia.org

វិញអាហ្នឹង គឺធានាថាច្បាស់ជាងាប់មុនព្រឹក ព្រោះលួចគេស្មោះ ។ ពិតមែនថា បានលួចទិញកូនសៀវភៅពីជនជាតិប៉កទុយកាល់ម្នាក់ ប៉ុន្តែតាមច្បាប់ប៉កទុយកាល់ជនបរទេសណាដែលគេចាប់បានដោយមានកូនសៀវភៅពួកគេនោះ គឺត្រូវសំលាប់ចោលភ្លាមមួយរំពេច កុំថាឡើយដល់ទៅបើកច្រកសមុទ្រម៉ាស៊េឡង់ ។ បើសិនជាគេរកឃើញកូនសៀវភៅសំងាត់នៅលើសំពៅខ្លាំងវិញ គឺគេត្រូវសំលាប់នាវិកទាំងអស់ចោល ហើយសំពៅក៏ត្រូវដុតចោលថែមទៀត ។

- *ណាទណ្ដូយ៉ូដា?* -សាមូរ៉ៃម្នាក់សួរ ។

- លោកចេះនិយាយភាសាប៉កទុយកាល់ទេ . ?

*ប្លាក់ថន* សួរជាភាសាប៉កទុយកាល់ ។ បុរសនោះញាក់ស្មា :

- *វ៉ាការីម៉ាសេន* !

បុរសម្នាក់ទៀតដើរមកជិត ហើយនិយាយទៅកាន់មេក្រុមរបស់ខ្លួនយ៉ាងគោរព ។ បុរសជាមេងក់ក្បាល :

- លោកមិត្តប៉កទុយកាល់ ?

បុរសនេះសួរ *ប្លាក់ថន* ជាភាសាប៉កទុយកាល់ តែលាយសំនៀងជប៉ុនយ៉ាងខ្លាំង ។ បន្ទាប់មកគេបើកអាវគីម៉ូណូ ហើយបង្ហាញ *ប្លាក់ថន* នូវរូបព្រះឆ្លាងធ្វើអំពីឈើមួយ ដែលគេពាក់នៅនឹង ក រួចគេចង្អុលខ្លួនគេ :

- គ្រិស្តសាសនិក !

រួចចង្អុលទៅ *ប្លាក់ថន* :

- គ្រិស្តសាសនិក *កា*?

*ប្លាក់ថន* អេះអុញបន្តិច រួចងក់ក្បាល :

-គ្រិស្តសាសនិក

- ប៉កទុយកាល់ ?

- អង់គ្លេស

បុរសនោះក៏ងាកទៅជជែកជាមួយមេរបស់ខ្លួន រួចញាក់ស្មា ហើយពួកគេក៏បែរមករក



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថង* វិញ :

- ប៉ុកទុយកាល់ ?

ដោយខ្វិលប្រកែកច្រើន *ប្លាក់ថង* ងក់ក្បាល :

- ពូកម៉ាកខ្ញុំ ! នៅឯណា ?

បុរសនោះចង្អុលទៅចុងខាងកើតភូមិ :

- ពូកម៉ាក !

- នេះជាសំពៅខ្ញុំ ។ ខ្ញុំចង់ចុះទៅក្រោម ។

ដើម្បីអោយពួកនេះកាន់តែយល់គេធ្វើ កាយវិការពន្យល់បន្ថែម ពួកគេយល់ភ្លាម ។

- *អ្ហ៊ា ! សូតិស្វ៊ ! គីនជ៊ី* ! -ពួកគេឆ្លើយយ៉ាងម៉ឺងម៉ាត់ ដោយចង្អុលបង្ហាញផ្ទាំងក្តារផង ។ នៅលើទឹកមុខរបស់ពួកគេហាក់ដូចជាមានការរីករាយម្យ៉ាង ។ វាជាការច្បាស់ណាស់ គេមិនមានសិទ្ធិចុះទៅជាន់ក្រោមបានទេ ។ *គីនជ៊ី* ប្រហែលមានន័យថា " ហាម " ហើយមើលទៅ *ប្លាក់ថង* គិតទាំងមួហ្មងនៅក្នុងចិត្ត ។ តែណ្ហើយកុំខ្វល់ ! *ប្លាក់ថង* ក៏លូកដៃចាប់គន្លឹះ ហើយបង្ហើបទ្វារឡើង ។

- *គីនជ៊ី* !

អ្នកណាម្នាក់ចាប់គេកន្ត្រាក់អោយបែរក្រោយវិញ ។ សាមូយរ៉ៃពីរនាក់នៅឈរទល់មុខគេ ។ ដាវរបស់គេត្រូវហូតចេញពាក់កណ្តាលទៅហើយ ។ អ្នកទាំងពីរនេះនៅឈរយ៉ាងស្ងៀមស្ងាត់ រង់ចាំការសំរេចចិត្តរបស់ *ប្លាក់ថង* ។ អ្នកឯទៀតដែលឈរនៅលើសំពៅនេះសំលឹងមើលព្រឹត្តិការណ៍នេះដោយនឹងធឹង គ្មានបង្ហាញភាពរញ្ជួយចិត្តណាបន្តិចសោះឡើយ ។ *ប្លាក់ថង* ដឹងខ្លួនយ៉ាងច្បាស់ណាស់ថា គេគ្មានជំរើសអ្វីក្រៅពីដកថយនោះទេ ។ គេញាក់ស្មា ហើយដើរចេញពីទ្វារនោះទៅពិនិត្យមើលខ្សែក្តោង និងភាគខាងលើនៃនាវាទាំងមូល ។ ក្តោងដំទក់ខ្ទុកខ្ទីត្រូវបានគេទំលាក់ចុះ ហើយផ្នែកខ្លះត្រូវគេស្រាវចង ។ រួចសព្វគ្រប់ហើយគេក៏បែរខ្លួនសំដៅទៅដណ្តើរចំហៀង ដើម្បីចុះទូកស្រាប់តែគេឈប់ង៉ក់មួយរំពេច ។ គេបែកញើសត្រជាក់ពេញខ្លួនភ្លាមនៅពេលដែលគេឃើញទឹកមុខជាអរិភាព របស់ពួកសាមូរ៉ៃទាំងនេះ ។ គេ



www.budinst.gov.kh www.elibraryofcambodia.org

គិតនៅក្នុងចិត្តថា ឱ ! អញអើយអញ ! ម៉េចក៏វាភ្លើយ៉ាងហ្នឹង ! គេក៏លំអោនខ្លួនគោរព ហើយអរិភាពទាំងឡាយបានរលាយបាត់ដូចគេខាប បែរជំនួសវិញដោយស្នាមញញឹម ។ គេចុះជណ្តើរ តែគេនៅតែមិនទាន់បាត់ត្រជាក់ខ្លួននៅឡើយទេ ។ ឥឡូវនេះគេស្តប់ទាំងសព្វទាំងគ្រប់នៅក្នុងស្រុកជប៉ុននេះ ហើយគេបន់សូមអោយតែពួកគេបានឡើងមកលើសំពៅវិញទេ ដើម្បីអាលនឹងបើកសំពៅចេញទៅលំហសមុទ្រវិញ ។

***

- ចុមយក្ស ! បងតែកុងគិតអីចឹងខុសហើយ- វិញ និយាយឡើង- អោយតែចេះទ្រាំស៊ីអាចម៍តែអីគេហ្នឹង ដែលពួកវាអោយឈ្មោះថា ម្ហូបហ្នឹងទៅ គ្មានកន្លែងណាអស្ចារ្យជាងស្រុកនេះទេ ។ គ្រាន់តែ ៣ថ្ងៃហ្នឹងខ្ញុំបានស្រីពីរនាក់ទៅហើយ ។ រួចពួកស្រី ១នេះស្លូតដូចកូនទន្សាយអីចឹង ប្រាប់អោយធ្វើអីធ្វើតាមភ្លាម ។

- អើមែនហ្នឹ ! ប៉ុន្តែគ្មានអាណាធ្វើកើតទេ បើគ្មានសាច់ គ្មានកូញាក់អីចឹងនោះ ។ ហើយបើធ្វើកើតក៏គ្មានទ្រោលបានយូរដែរ ។ អញបាក់បៀហើយនេះ ហើយហ្នឹងអញដេកជាមួយស្រីតែម្តងផង ។

*វ៉ែមស៊្វើតែ* ឆ្លើយតប ។ មុខគេឡើងស្លឹត

-ពួកអាឆ្កែស្បែកលឿងនេះគ្មានយល់សោះ ថា គេត្រូវការសាច់ គេត្រូវការប៊ីយែរ គេត្រូវការទំប៉ុងទេអ្វី ! ហើយពិសេសកូញាក់រីយ៉ាងហោចណាស់អោយតែបានស្រាចុះ ។

- គ្មានអីយ៉ាប់ជាងនេះទេព្រះអើយព្រះ !

- អញដូរនគរអញទាំងមូលអោយតែបានស្រាម៉ាតក់មកលោក !

*បាតូសវ៉ាន់ណេច* មានទឹកមុខធ្ងន់ពាប់ ។ គេដើរមកជិត *ប្លាក់ថន* ហើយសំលឹងមើលអ្នកបើកសំពៅរបស់គេនេះ ។ *បាតូសវ៉ាន់ណេច* ម្ញឹបភ្នែកហើយគេបាត់វិនតាចុងក្រោយរបស់គេនៅពេលព្យុះនោះម្ល៉េះ ។ គេជាឈ្មួញជាអ្នកកាន់លុយ និងជាតំនាងក្រុមហ៊ុនហូឡង់ប្រចាំផ្នែកបូព៌ាឥណ្ឌា ដែលជាក្រុមហ៊ុនទទួលបាវងំណើរនេះ គេនិយាយបន្តទៀត :

- យើងបានដល់ដីគោករស់រានមានជីវិតហើយ តែនៅមិនទាន់បានដាក់មួយតយពីរ



www.budinst.gov.kh www.elibraryofcambodia.org

សោះយ៉ាប់អស្ចារ្យតែម្ដង ! បងតែកុងមានបានស្រាផឹកទេ ?

-អត់ទេ ! -*ប្លក់ថន* មិនចូលចិត្តអោយអ្នកណាឈរកៀកខ្លួនទេ ប៉ុន្តែដោយបាតួសជាមិត្តភក្តិ ហើយម៉្យបស៊ើរខ្ទាក់ទៅហើយនោះ ទើបគេមិនក់រើកខ្លួនឡើយ-បានតែទឹកក្ដៅលាយជាមួយស្មៅអីទេ ! មានតែស្មៅហ្នឹង !

- ពួកអានេះគ្មានយល់អីតិចតួចណាថា គេត្រូវការស្រាទេអ្ហ៎ ! គ្មានអីផឹកសោះអីចឹង ! មានឡើងទឹកក្ដៅជាមួយស្មៅ ។ ឱ ព្រះអើយព្រះ ! ជួយខ្ញុំផង ! បែបម៉ាប្រទេសហ្នឹងគ្មានស្រាផឹកទេអ្ហ៎ ?- បាតួសខំញោចចិញ្ចើម -បងតែកុង ! ជួយពួកខ្ញុំម្ដងទៅ សុំបងជួយសុំស្រាពីពួកនេះអោយពួកខ្ញុំផងបានទេ ?

មុននេះបន្តិច *ប្លក់ថន* បានរកឃើញផ្ទះដែលពួកនាវិករបស់គេស្នាក់នៅ ។

*សាមូរ៉ៃ* ម្នាក់ដែលនៅយាមទីនេះបានបណ្ដោយអោយគេចូលក្នុងផ្ទះ ប៉ុន្តែនាវិករបស់គេបានបញ្ជាក់ប្រាប់គេថា ពួកគេគ្មានសិទ្ធិចេញទៅសួនច្បារទេ ។ ផ្ទះនេះមានបន្ទប់ច្រើនដូចជាផ្ទះដែលគេស្នាក់នៅដែរ គ្រាន់តែបន្ទប់នៅទីនេះធំជាងគេតែប៉ុណ្ណោះ ។ នាវិករបស់គេ ១១នាក់នៅរស់រានមានជីវិត ឯអ្នកស្លាប់ឯទៀតបានត្រូវពួកជប៉ុនលើកយកទៅកប់អស់ហើយ ។ បន្លែស្រស់ដែលគេបានផ្ដល់អោយយ៉ាងបរិបូណ៌នោះ បានចាប់ផ្ដើមបន្ថយការទន្ទ្រានលុកលុយរបស់ស្កប៊ុតហើយ ។ ក្រៅតែពីពីរនាក់ចេញអ្នកឯទៀតចាប់ផ្ដើមជាសះស្បើយយ៉ាងរហ័ស ។ អ្នកទាំងពីរដែលនៅដាបនោះគឺ បណ្ដាលមកពីការរាកមួលដ៏ខ្លាំងក្លា ហើយគេនៅតែបត់ជើងចេញឈាមនៅឡើយ ។ វិញ្ញបានជួយព្យាបាលគេដែរ ប៉ុន្តែដូចជាគ្មានបានធូរស្បើយបន្តិចណាសោះ ហើយវិញ្ញគិតថា អ្នកទាំងពីរប្រហែលជាផុតដង្ហើមនៅពេលព្រលប់នេះហើយ ។ លោកមេបញ្ជាការស្ថិតនៅបន្ទប់មួយផ្សេងទៀត ហើយនៅតែមានជំងឺដាបនៅឡើយ ។

ចុងភៅឈ្មោះ *សុង* ដែលមានមាឌទាបក្រអាញនោះនិយាយបណ្ដើរ សើចបណ្ដើរ :

- ដូចអាយ៉ូហាយ និយាយអីចឹងនៅកន្លែងនេះស្រួលម្យ៉ាងដែរ លើកលែងតែរឿង ស៊ីនិងខ្វះស្រាតែប៉ុណ្ណឹងឯង ។ ហើយអ្នកស្រុកនេះក៏ស្រួល កុំតែពាក់ស្បែកជើងចូលផ្ទះ ។ ពួកអាស្បែកលឿងនេះតែឃើញគេមិនដោះស្បែកជើងវាពុលជ្រូកភ្លាមតែម្ដង ។


www.budinst.gov.kh www.elibraryofcambodia.org

-នែ់ស្តាប់ខ្ញុំណា!- *ប្លក់ថន* និយាយ -មានបព្វជិតម្នាក់នៅទីនេះដែរ ។ វាជាយេស៊ុត ។

- រំបល់យក៏ !

ការជជែកគ្នាវែវអំបាញ់មិញបានចប់ភ្លាមនៅពេលដែល *ប្លក់ថន* និយាយប្រាប់ពួកគេពីបព្វជិតនិងពីការកាត់ក្បាលមនុស្សនោះ ។

- រួចថីបានវាកាត់ក្បាលគេបងតែកុង ?

- អញមិនដឹងដែរ ។

ភាពភ័យខ្លាចបានចូលមកសណ្ឋិតនៅក្នុងបន្ទប់វិញម្តង ។ សាឡូម៉ុង អាត់លង់ សំលឹងសង្កេតមើល *ប្លក់ថន* ដោយធ្វើមាត់ម្ខប ១ឡើងបែកពពុះទឹកមាត់ ។

ដើម្បីឆ្លើយតបទៅនឹងសំនួរយ៉ាងស្ងៀមស្ងាត់របស់បុរសតម្លង់នេះ *ប្លក់ថន* ងាកទៅឆ្លើយយ៉ាងស្រួល :

- អត់ទេសាឡូម៉ុង ខ្ញុំអត់ច្រលំទេ ! វាប្រាប់ថា វាជាយេស៊ុតមែនណា !

- វាជាយេស៊ុត វាជាខ្មោចអីក៏ដោយ ក៏វានៅតែប៉ុណ្ណឹង ។ យកល្អត្រូវវិលទៅសំពៅវិញ - *វិញ* និយាយ ។

- យើងស្រេចទេវតាកំនត់ហើយ- *យ៉ាន់ទូវ៉ែត* និយាយឡើង ។*យ៉ាន់* ជាយុវឈ្មួញផ្សងព្រេងម្នាក់ដែលមានថ្ពាសទូលាយ ភ្នែកតូច ច្រមុះតូចច្រលឹង - សូមព្រះលោកជួយយើងអោយចៀសផុតពីពួកកូនចៅបិសាចទាំងនេះផង ។

វិញក៏បែរមកសួរ *ប្លក់ថន* វិញម្តង :

- រួចពួកប៉កទុយកាល់ ? បងមានឃើញពួកប៉កទុយកាល់នៅម្តុំហ្នឹងទេ ?

- ទេ គ្មានឃើញស្រមោលមួយទេ ។

- បន្តិចទៀតច្បាស់ជាពួកវាមកពេញទឹកពេញដីមិនខានទេ តែពេលណាវាដឹងថាគេចាប់យើងបាននោះ- *វ៉ែស្ស៊ីវ៉ែត* និយាយសំរាប់លឺទាំងអស់គ្នា ។ យុវជនជំទង់ម្នាក់ឈ្មោះគ្រួកថ្ងូរឡើងរហ៊ឹស ។ *គិនវ៉ែលេ* និយាយតបដោយល្បឿនអណ្តាតផ្ទៃម ១លើបបូរមាត់ដ៏ស្ងួតរបស់ខ្លួនផង :

-ពិតហើយ ។ មានបព្វជិតម្នាក់ គឺវាមានច្រើននាក់ ។ ហើយពួកអាកូនមីចោរកុង



www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

គិស្តា ឌ័រ[២៧] ក៏មិននៅឆ្ងាយប៉ុន្មានដែរ ។

-ច្បាស់ជាអីចឹងហើយ-*វិភូ* និយាយបន្ថែមទាំងរសាប់រសល់ -ពួកនោះដូចជាតែអីចឹង។

- តែក្រែងយើងនៅស្រុកជប៉ុនអ្ហីបងតែកុង ? ក្រែងគេប្រាប់បងតែកុងថាអីចឹងអ្វី ?

-*វ៉ាន់ណិច* សួរ ។

- អើមែនណា ។ រួចវាម៉េច ?

*វ៉ាន់ណិច* ខិតមកជិត *ប្លាក់ថុន* ហើយបន្ទាបសំលេង :

- បើមានពួកបព្វជិត អ្នកស្រុកមួយចំនួនប្រហែលជាកាតូលិចហើយ ។ បើអីចឹងអារឿងមួយទៀតនោះ ក៏ប្រហែលជាពិតដែរហើយមើលទៅ ។ គឺអារឿងទ្រព្យសម្បត្តិមហាសាល រឿងមាស ប្រាក់ ត្បូងពេជ្រនោះណា ! បងតែកុងមានបានឃើញមាសទេ ? មាសក៏ដោយ ត្បូងក៏ដោយ ! -ទាំងអស់គ្នាដូចឡើងឋានសួគ៌ទាំងភ្នែកស្រស់មួយភ្លែតអីចឹង ។ *ប្លាក់ថុន* សញ្ជឹងគិតមួយស្របក់ទើបឆ្លើយតប :

- ទេ ខ្ញុំដូចជាមិនឃើញទេ ។ ហ្អឹងហើយបើតាមខ្ញុំចាំគឺគ្មានឃើញទេ ។ គ្មានឃើញខ្សែក គ្មានឃើញគុជ គ្មានឃើញកងដៃអីតិចតួចណាទេ ។ តែស្តាប់ខ្ញុំណា ! ខ្ញុំចង់ប្រាប់ពួកឯងរឿងមួយផ្សេងទៀត ។ គឺខ្ញុំបានឡើងទៅលើសំពៅ អេរ៉ាស់ នោះហើយ ប៉ុន្តែគេបានវាយត្រាភ្ជិតវាហើយ - រួច *ប្លាក់ថុន* ក៏និយាយពីរឿងដែលកើតមានឡើងទាំងប៉ុន្មាន ដែលធ្វើអោយកង្វល់បារម្ភរបស់ពួកនោះកាន់តែធំឡើង ៗ ។

- ពួកយើងគង់តែព្រះជួយទេ-*យ៉ាន់វ៉ាពេ* និយាយដោយទុកចិត្ត-ព្រះគង់តែជួយយើងផុតពីពួកមារទាំងនោះ ដូចព្រះអង្គបានសន្យាអីចឹង ។ គ្មានរឿងអីខ្លាចទេ ។

*ប្លាក់ថុន* បន្ត :

- ខ្ញុំដឹងច្បាស់ថា *អូមី សាន* ស្អប់បព្វជិតនោះណាស់ ។ មើលតែរបៀបវានិយាយជា

---

*(២៧)Conquistadors : ឈ្មោះដែលគេប្រសិទ្ធិនាមអោយពួកអ្នកជុំងព្រេងអេស្ប៉ាញ ដែលទៅទន្ទ្រានទ្វីបអាមេរិច ( ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

មួយបព្វជិតនេះ មើលតែរបៀបវាក្តៅក្រហាយនោះ គឺច្បាស់ក្រលៃតតែម្តង ។ រួចខ្ញុំឆ្ងល់ដែរថា ហេតុអ្វីបានជាបព្វជិតនេះមិនមានស្បង់ដូចគេដូចឯង ហើយបែរជាប្រើស្បង់ពណ៌ស្វាទុំទៅវិញ ហ្នំ ? ខ្ញុំមិនដែលឃើញស្បង់របៀបនេះសោះ ។ នេះប្រហែលជាអំនាចរបស់បព្វជិតនេះមិនធំធេងណាស់ណាទេមើលទៅ ។ បើអ៊ីចឹងមែនរឿងនេះអាចជួយសំរួលយើងបានច្រើន ។

- តើយើងត្រូវធ្វើយ៉ាងម៉េចបងតែកុង ? -*គីនសែល* សួរ ។

- អត់ធ្មត់សិន ។ ត្រូវចាំមេពួកគេ គឺ *ដៃម៉ីញ៉ូ* មកសិន ។ គាត់នោះនឹងអោយយើងចាកចេញទៅជាមិនខាន ។ ព្រោះមិនដឹងជាពួកគេទុកយើងធ្វើម៉ាំធ្វើអីទេ ហើយយើងក៏គ្មានប៉ះពាល់អីគេដែរ ។ ម្យ៉ាងទៀតយើងមានទំនិញ ដើម្បីចែចូវជាមួយដែរ ។ ពួកយើងមិនមែនចោរសមុទ្រទេ អ៊ីចឹងគ្មានអីត្រូវព្រួយបារម្ភទេ ។

*វ៉ាន់ណិច* និយាយបន្ទរឡើង ដើម្បីកម្លាចិត្តខ្លួនឯងជាងកម្លាអ្នកឯទៀតផងនោះ :

- ពិតជាអ៊ីចឹង ។ បងប្រធានថាអំបាញ់មិញហើយថា អ្នកស្រុកទាំងនេះមិនមែនសុទ្ធតែពួកកាតូលិចឯណា ។ ពិតជាអ៊ីចឹងហើយ ។ ល្អដែរដែលអាសាមូរ៉ៃនោះស្អប់បព្វជិត មិនស្រួលអ៊ីចឹង ? ឥឡូវនេះធ្វើម៉េចប្រយ័ត្នប្រយែងពួក*សាមូរ៉ៃ* រួចធ្វើម៉េចយកអាវុធយើងបានមកវិញ អាហ្នឹងហើយរឿងដែលត្រូវធ្វើនោះ ។ រួចហើយតែមាប់ប្រិចភ្នែក យើងច្បាស់ជាទៅដល់សំពៅវិញភ្លាម ។

- រួចចុះធ្វើម៉េចទៅបើលោតែ អា*ដៃម៉ីញ៉ូ* ហ្នឹងវាជាកាតូលិចដែរ ?

- បងតែកុងរឿងអាកាន់ដាវនោះណា ? រួចពីកាត់ក្បាលគេហើយវាកាត់គេជាកង់ ១ ទៀតមែនអ្ហី ?

-មែន !

- ព្រះជាម្ចាស់អើយ !អានេះសុទ្ធតែជាពួកព្រៃតែម្រង់! ឬក៏ជាពួកឆ្កួតឡប់សតិហើយ ។

*គីនសែល* គឺជាយុវជនបុរសរាងស្គាតបាតម្នាក់ ដែលមានដៃខ្វិ ១ និងមានជង្គង់សេកយ៉ាងច្បាស់ ។ ស្តប៊ុតបានធ្វើអោយគេគ្រហុបធ្វេញអស់ទៅហើយ ។ គេសួរបន្តទៅទៀត :

- រួចក្រោយពីអានោះកាត់ក្បាលហើយ អ្នកឯទៀតដើរចេញទៅ ? ចេញអត់និយាយ



www.budinst.gov.kh www.elibraryofcambodia.org

ម៉ាម៉ាត់ម៉ាកអីសោះ ?

- ហ្នឹងហើយ ។

-វិបល់យក៍ ! សំលាប់មនុស្សគ្មានអីការពារអីចឹង ? បែបហ្នឹង ? រួចហេតុអីបានជាវាធ្វើអីចឹង ? ហេតុអីបានជាវាសំលាប់គេនោះ ?

- ខ្ញុំឥតដឹងដែរ *គីនវែល* ។ តែតាំងពីកើតមកមិនដែលឃើញអីក៏របស់យ៉ាងនេះទេ ។ ដាវនៅក្នុងស្រោមសោះ រួចតែម៉ាប់ប្រិចភ្នែកអ្លែងឃើញក្បាលរមៀលតុក ១ នៅនឹងដីបាត់ទៅហើយ ។

- ឱ !ព្រះអើយព្រះ !- *វ៉ាន់ណេិច* និយាយរអ៊ូ ១- បើយើងមិនបានឡើងទៅលើសំពៅវិញទេ... យីអាកូនមីចោរខ្យល់ព្យុះនេះដល់អស់វ៉ែនតាអីចឹងទៅអញវង្វេងវង្វាន់អស់ហើយ ។

- សូមព្រះជាម្ចាស់ផ្ដន្ទាទោសពួកទមិឡ និង ពួកអាមេបាបអស់នេះទៅលោក ។ សូមអោយវាទៅឆេះរលាយឯនរកអវចិចុះ ។

- ខ្ញុំបន់អោយតែអីចឹងដែរទេ *វ៉ាំព* ។

*ប្លាក់ថន* ឆ្លើយតបដោយសំលេងយ៉ាងនឹង ។ គេមានអារម្មណ៍ថា ការភ័យខ្លាចបណ្ដាសាព្រះបានមកសណ្ឋិតនៅក្នុងពេញបន្ទប់នេះ ។ គេមានការហេវហត់ និង ងោកងុយយ៉ាងខ្លាំង ។

- វាច្បាស់ជាអីចឹងហើយបងតៃកុង ។ បាទច្បាស់ជាអីចឹង ។ ខ្ញុំបួងសួងសូមបងមើលឃើញសច្ចធម៌របស់ផ្លូវធម៌នេះ និង សូមបងដឹងច្បាស់នៅក្នុងខ្លួនថា ពួកយើងមកដល់កន្លែងនេះគឺដោយហេតុតែរូបបងហ្នឹងណា !

- ស្អី ?- *ប្លាក់ថន* គំហកក្នុងអាកប្បកិរិយាសំលុត ។

- ហេតុអីបានជាបងបញ្ចុះបញ្ចូលលោកមេបញ្ជាការ អោយបើកមកជប៉ុនធ្វើអី ? អារឿងហ្នឹងអត់មាននៅក្នុងបញ្ជាឯណា ? ពួកយើងគ្រាន់តែធ្វើអោយភពថ្មីភ្លូកទឹកភ្លូកដីតែប៉ុណ្ណឹង ។ ពួកយើងត្រូវបង្កសង្គ្រាមនៅក្នុងតំបន់ខ្ទាំង ហើយយើងត្រូវវិលចូលផ្ទះវិញទេតើ ។

- ពួកយើងត្រូវសំពៅអេស្ប៉ាញព័ទ្ធពីខាងជើងផង ពីខាងត្បូងផង ហេតុនេះគ្មានផ្លូវ



www.budinst.gov.kh www.elibraryofcambodia.org

ជ្រើសទេ ។ ពួកអ្នែងមិនចាំទេអ្ហី ? ឬមួយពួកអ្នែងវង្វេងវង្វាន់អស់ហើយអ្ហី ? កាលនោះច្រករស់មានតែមួយគត់ គឺចេញតាមលិចហ្នឹងណា៎ !

- ខ្ញុំគ្មានឃើញសំពៅខ្មាំងមួយណាទេ ។ ម៉ាចំនោមយើងគ្មានអ្នកណាបានឃើញទេ ។

- បានហើយ ! បានហើយ ! អាយ៉ាន -*វ៉ាន់ណិច* លូកមាត់-បងតែកុងគាត់សំរេចយកច្រកចេញដែលល្អបំផុតហើយ ។ ម្យ៉ាងទៀតសំពៅខ្មាំងពិតជាមាននៅទីហ្នុងមែនផង ។

- អើ ! វាច្បាស់ជារឿងពិតមែន ។ សំពៅមិត្តនៅរាប់ពាន់យោជន៍ ហើយយើងនៅក្នុងដែនទឹកខ្មាំង !- *វិញ* ស្តោះទឹកមាត់មួយឆ្វាច់រួចបន្ត-នេះគឺរឿងពិត ។ ហើយការពិតយើងបានបោះឆ្នោតសំរេចហើយ ទាំងអស់គ្នាបានឯកភាពគ្នាថា ត្រូវមកតាមនេះណា៎ !

- អញអត់ឯកភាពទេ

*សុង* បន្ថែម :

- ខ្ញុំវិញអត់មានអ្នកណាសួរខ្ញុំផងហ្នឹង !

- ឱ ! ព្រះអើយព្រះ !

- នែ៎ ! អោយនឹងនរឡើង *យ៉ូហាន់* !- *វ៉ាន់ណិច* និយាយឡើងដើម្បីបន្ធូរបរិយាកាស -ពួកយើង គឺជាអ្នកទីមួយដែលបានមកដល់ជប៉ុន ។ អ្នែងនឹកឃើញពីរឿងគេនិយាយដំណាលគ្នាអស់នោះដែរទេ ? យើងនឹងក្លាយទៅជាអ្នកមានបើសិនណាជាយើងមិនធ្វើផ្ដេសផ្ដាសទេនោះ ។ យើងមានទំនិញ ឯនៅទីនេះមានមាស ។ វាច្បាស់ជាមានមាសនៅស្រុកនេះ ។ ម្យ៉ាងទៀតអ្នែងចង់យកទំនិញយើងទៅលក់ឯណាវិញ ? ទោះយ៉ាងម៉េចយ៉ាងម៉ាច្បាស់ជាមិនមែនទៅលក់នៅឯភពថ្មីទេ ។ កាលនោះពួកអេស្ប៉ាញកំពុងតែតាមរកយើង ហើយពួកវាដឹងថាយើងនៅម៉្លុំ សាន់តាមារីយ៉ា ។ អ៊ីចឹងហើយទើបយើងត្រូវចេញពីដែនទឹកស៊ីលី ហើយអានេះគឺជាច្រកតែមួយគត់និងក៏ជាគំនិតល្អផងដែរ ។ ដូរទំនិញយើងជាមួយគ្រឿងទេស ជាមួយមាស ជាមួយប្រាក់មើល ! អ្នែងចង់យ៉ាងម៉េចទៀត ? អ្នែងប៉ាន់រឿងចំនេញវិញមើលអ្ហា ! រាប់ពាន់ដង ហើយហ្នឹងយ៉ាងសាមញ្ញផង ។ អ្នែងធ្លាប់ដឹងពីសម្បុកសម្បត្តិស្រុកជប៉ុន និងស្រុកកាតៃហើយតើ ! អ្នកណាក៏គេនិយាយរឿងហ្នឹងដែរ ។ យើងទាំងអស់គ្នាសុទ្ធតែលឺដែរ ។ រួចយើងចេញមកនេះក៏មិន



www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីរឿងហ្នឹង ? ពួកយើងច្បាស់ជាក្លាយទៅជាអ្នកមានមិនខាន ពួកអ្អែងចាំតែមើលចុះ !

- ពួកយើងច្បាស់ជាស្លាប់តែទាំងអស់គ្នាហ្នឹង ។ ស្លាប់ដូចពួកអ្នកឯទៀតអីចឹង ។ យើងមកនេះមកចំស្រុកសាតង់ (២៨) តែម្តង ។

*វិញ* ឆ្លើយតបយ៉ាងកំនាច :

- បិទមាត់ទៅរា *វ៉ែរ* ! បងតៃកុងគាត់បានធើអីដែលត្រូវធើហើយ ។ អ្នកឯទៀតងាប់មិនមែនកំហុសគាត់ឯណា ! គាត់គ្មានកំហុសទេ ។ ក្នុងដំណើរបែបនេះ តែងតែមានអ្នកងាប់អីចឹងហើយ ។

កូនក្រមុំនៅក្នុងក្អែករបស់ *វ៉ែរ* ប្រែជារូមតូច :

- ពិតហើយ ! សូមព្រលឹងរបស់ពួកគេបានសោយសុខក្នុងសុគតិភពចុះ ! ក្នុងចំនោមអ្នកស្លាប់នេះមានបងអញដែរណា !

*ប្លាក់ថុន* សំលឹងចំកែវក្អែករបស់ *យ៉ានវ៉ូរ៉ែ* ។ គេដណ្តឹងសួរនៅក្នុងចិត្តគេ ថាតើគេពិតជាបើកសំពៅមកទិសខាងលិចនេះ ដើម្បីគេចពីសំពៅខ្មាំង រឺមួយក៏ដើម្បីក្លាយខ្លួនជាតៃកុងអង់គ្លេសដំបូងគេបង្អស់ដែលបានធ្វើដំណើរជុំវិញពិភពលោក ?

*យ៉ានវ៉ូរ៉ែ* និយាយទាំងចំអកបន្ថែមទៀត :

- អ្នកទាំងអស់ហ្នឹងស្លាប់ដោយហេតុតែមហិច្ឆតារបស់បងមែនទេ ? ព្រះនឹងផ្តន្ទាបងមិនខានទេ !

- ឥឡូវនេះអ្អែងបិទមាត់ទៅ !

*ប្លាក់ថុន* និយាយទៅកាន់ *យ៉ាន* ដោយទឹងនរតែយ៉ាងដាច់ណាត់ ។ *យ៉ានវ៉ូរ៉ែ* នៅតែសំលក់សំលឹងគេប្រកបដោយទឹកមុខជាសត្រូវ ប៉ុន្តែគេលែងបន្តសំដីទៀតហើយ ។

- អីលូវនេះតើត្រូវធ្វើយ៉ាងម៉េចបងតៃកុង ?

---

(២៨ ) - *នៅក្នុងគម្ពីរប៊ីប សាតង់គឺជាមេបិសាចដែលតែងប្រឆាំងនឹងព្រះយេស៊ូ ប្រៀបដូចជានៅក្នុងពុទ្ធសាសនាមានមារគោមព្រៃកដូចនោះដែរ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

- រង់ចាំ ។ ស្ដារកំលាំងយើងឡើងវិញ ។ មេពួកវាជិតមកហើយ ដល់ពេលនោះយើងនឹងដឹងថាម៉េចៗ ហើយ ។

វិញសំលឹងមើលទៅសាមូរ៉ៃដែលអង្គុយចោងហោងគ្មានកំរើកនៅក្បែរច្រកចូល :

-បងឯងមើលអាល្បែងនោះមើល ។ វានៅអង្គុយកន្ទែងហ្អងរាប់ម៉ោងរួចគ្មានកំរើកម៉ាតឹកណា គ្មាននិយាយម៉ាម៉ាត់ណាសោះ ។ តែខ្វះច្រមុះក៏វាមិនខ្វះផង ។

*គីនស៊ែល* និយាយយ៉ាងនឹងនរ :

- បងតែកុងវានៅតែម្នាក់ឯងតើ ឯយើងវិញមានដប់នាក់ណា !

- ខ្ញុំបានគិតរឿងហ្នឹងដែរ ប៉ុន្តែពួកយើងនៅដាបណាស់ ។ ពួកយើងត្រូវការមិនតិចជាងម៉ាអាទិត្យទេ ដើម្បីព្យាបាលស្នប៉ុត-*ពាក់ផន* តបដោយរសាប់រសល់-ហើយនៅលើសំពៅមានពួកវាច្រើនហួសថែមទៀតផង ។ ខ្ញុំមិនប្រថុយលេងជាមួយពួកនេះ ដោយអត់កាំបិត រឺកាំភ្លើងទេ ។ ពេលយប់មានគេយាមពួកអ្វែងទេ ?

- មានបង ! ម៉ាយប់មានបីទៅបួនវេន ។ នែ៎ ! មានអ្នកណាដែលឃើញអ្នកយាមដេកលក់ទេ ? -វ៉ាន់ណិចសួរ ។

ទាំងអស់គ្នាគ្រវីក្បាល ។ *យ៉ានូរ៉ែត* និយាយឡើង :

- យប់នេះយើងអាចឡើងទៅលើសំពៅវិញបាន ។ បើសិនជាព្រះជួយយើង យើងអាចកំទេចពួកអាទមិឡអស់នេះ និងដណ្តើមយកសំពៅយើងមកវិញផង ។

- អ្វែងដូចពុលក្ដចអីចេះ ! អ្វែងមិនឮបងតែកុងនិយាយប្រាប់ថាយ៉ាងម៉េចទេ អ្វី ? *វិញ* និយាយទាំងមូហ្មង ហើយស្ដោះទឹកមាត់ដោយការខ្ពើមរអើម។ ភ្នែករបស់ *យ៉ានូរ៉ែត* កាន់តែរូមតូចទៅទៀត :

- គិតតែបួងសួងអោយព្រះស្រោចស្រង់ព្រលឹងអ្វែងទៅអា *យ៉ូហានវិញ* ។ អ្វែងជិតដល់ថ្ងៃអន្សាហើយអា !

រួច *យ៉ាន* ក៏ដើរចេញទៅអង្គុយនៅឯរានហាលបាត់ទៅ។ យុវជន *ត្រុក* ក៏និយាយឡើងទាំងសំលេងញ័រៗ :



www.budinst.gov.kh www.elibraryofcambodia.org

- *រ៉ាក់* និយាយត្រូវហើយ ។ គឺការលោភលន់ហ្នឹងណាដែលអូសទាញយើងមកដល់កន្លែងហ្នឹង ។ នេះគឺព្រះលោកផ្ដន្ទាទោសហើយបើ.........

-អ្អែងឈប់និយាយទៅបានទេ ?

យុវជន *ត្រូក* កំរើកចុះកំរើកឡើង :

- បាទបងតែកុង ។ អោយខ្ញុំសូមទោស តែអារឿងហ្នឹងវាអីចឹង ។

*ម៉ាក់ស៊ីមីល្យ៉ានត្រូក* គឺជានាវិកក្មេងជាងគេបំផុតនៅលើសំពៅ ។ វាមានអាយុមិនទាន់ដល់ ១៦ឆ្នាំ ស្រួលបួលផង ។ វាមកជាមួយគេព្រោះឪពុកវាគឺជាបញ្ជាការនៃសំពៅមួយក្នុងក្រុមសំពៅទាំងអស់នេះ ហើយម្យ៉ាងទៀតព្រោះវាចង់ស្វះស្វែងរកលាភផងដែរ ។ ប៉ុន្តែវាបានឃើញឪពុកវាស្លាប់យ៉ាងវេទនានៅក្នុងពេលដែលពួកគេឡើងប្លន់ ទីក្រុងសាន់តា ម៉ាក់ដីលេណា របស់ពួកអេស្ប៉ាញនៅអាកសង់ទីន ។ ការប្លន់នោះធ្វើអោយគេប្រមូលទ្រព្យសម្បត្តិបានយ៉ាងច្រើន ហើយត្រូកបានឃើញថា អ្វីទៅជាការចាប់រំលោភនោះ ។ ខ្លួនវាផ្ទាល់ក៏បានសាកដែរ ហើយវាក៏ស្អប់ខ្លួនវាទន្ទឹមនឹងការធុញទ្រាន់ក្នុងការកាប់សំលាប់ ធុញទ្រាន់នឹងក្លិនឈាមដ៏ឆ្អេះឆ្អាប ។ ក្រោយ១មកទៀត វាបានឃើញមិត្តភក្ដិរបស់វាស្លាប់ជាបន្តបន្ទាប់ វាបានឃើញសំពៅ ៥ ថយមកនៅត្រឹមតែមួយ ហើយឥលូវនេះវាមានអារម្មណ៍ថា វាជាអ្នកមានអាយុចាស់ជាងគេទៅវិញ ។

- សូមទោស ! អោយខ្ញុំសូមទោស ! - *ត្រូក* និយាយ ។

- យើងមកដល់ដីគោកនេះប៉ុន្មានពេលហើយ *ពាតូស* ? - *ប្លាក់ថន* សួរ ។

វ៉ាន់ឈិចដើរមកអង្គុយចោងហោងក្បែរ *ប្លាក់ថន* :

- មកដល់ថ្ងៃនេះ បានបីថ្ងៃហើយ ។ អាពេលមកដល់ខ្ញុំក៏ចាំស្រពេចស្រពិលដែរទេ ។ ពេលខ្ញុំដឹងខ្លួនមានពួកអាមនុស្សព្រៃនេះពេញសំពៅទៅហើយ តែពួកវាគួរសមនិងរាក់ទាក់ទេ។ ពួកវាបានអោយយើងស៊ីចុកនិងផឹកទឹកក្ដៅ ជញ្ជូនខ្មោចនិងទំលាក់យុថ្កាចុះ ។ ខ្ញុំមិនសូវចាំអស់ដែរទេ តែដូចជាពួកវាសណ្ដោងយើងទៅដល់កន្លែងឈប់សំពៅមួយ ដែលមានសន្តិសុខកាលហ្នុងបងតែកុងរវើរវាយទៅហើយ ពេលដែលគេសែងបងទៅដីគោកនោះ។ ពួកយើងទារ



www.budinst.gov.kh www.elibraryofcambodia.org

ទុកបងដែរតែពួកវាមិនព្រម ។ មានអាម្នាក់នោះចេះនិយាយភាសាប៊កទុយកាល់លប៉ុន្មានម៉ាត់ដែរ អាមួយដែលមានសក់ល្បាយអាច់ខ្លានោះហើយ មើលទៅ វាបែបជាមេគេផង ។ វាអត់ចេះពាក្យ " មេតែកុង " ទេ តែវាចេះពាក្យ " បញ្ជាការ " ហើយវាថា វាចង់អោយ " បញ្ជាការ " សំរាកនៅដោយឡែក ។ វាថាកុំអោយពួកយើងខ្វល់មានគេថែទាំបងក៏ដូចជាគេថែទាំពួកយើងដែរ ។ ហើយគេនាំពួកយើងរហូតមកដល់ផ្ទះនេះ ។ ជិតម៉ាផ្លូវដែលមកទីនេះ ពួកវាបីពួកយើងទេបង ។ ពួកវាប្រាប់យើងថា កុំអោយយើងចេញទៅណារហូតដល់បញ្ជាការពួកវាមក ។ ពួកយើងមិនចង់អោយគេយកបងទៅកន្លែងផ្សេងដែរ តែងដឹងធ្វើយ៉ាងម៉េច ? រួចបងមានស្ទូវរកស្រាកូញាក់ឬស្រាអី១ ពីប្រធានភូមិទេបង ?

*វ៉ាន់លើច* លិទ្ធបបូរមាត់ រួចនិយាយបន្ថែម :

- អើដល់និយាយអីចឹងខ្ញុំលឺវានិយាយពីដេមីញ៉ូដែរ ។ ពេលដែលដេមីញ៉ូអីហ្នឹងមកតើវាទៅជាយ៉ាងណាទៅអីចេះ ?

- នែ ! មានអ្នកណាមានកាំបិត រឺ មានកាំភ្លើងមួយដើមទេរឺ ?

- គ្មានទេ ! -*វ៉ាន់លើច* និយាយទាំងអេះក្បាលពេញទៅដោយចៃធ្វើបែបវាហ៊ី -ពួកវាដោះខោអាវយើងយកទៅបោក ហើយដកយកអាវុធយើងទាំងអស់ ។ កាលហ្នុងខ្ញុំគិតមិនដល់ដែរ ។ ពួកវាយកទាំងកូនសោ យកទាំងកាំភ្លើងខ្ញុំ។ សោខ្ញុំម៉ាចង្កោម ! តាំងពីសោទូដែកសោហីបនិងសោឃ្លាំងគ្រាប់ ។

- កុំខ្វល់អីអារឿងហ្នឹង ។ នៅលើសំពៅគេបិទជាប់អស់ហើយ ។

- ខ្ញុំមិនចូលចិត្តទាល់តែសោះ អារឿងអត់មានសោនៅនឹងខ្លួននេះ ។ អានេះនាំមូម៉ៅតើ ! ចង្រៃវាយក៏ ! មានកូញាក់មួយកែវអីបែបស្រួលហ្នឹងរឺបើមិនអីចឹងទេ បានតែបីយែរមួយកែវក៏អស់ចិត្តដែរ ។

- ឱព្រះអើយព្រះ ! អូ! អាសាម៉ារី កាត់មនុស្សជាកង់១មែនអ្វី?- សុងនិយាយឡើងមិនសំដៅឆ្ពោះទៅរកអ្នកណាមួយឡើយ ។

-‑ព្រះអើយ ! បិទមាត់ខ្លះទៅអ្ហា ! ហើយគេហៅ " *សាមូរ៉ៃ* មិនមែន *សាមារី* ទេ ។



www.budinst.gov.kh www.elibraryofcambodia.org

អ្នែងរញ៉េរញ៉ៃមែនទែនតែម្តង ! -គីនសែលឆ្លើយតប ។

*វិញ* បន្ទរ :

- អញបន់កុំអោយតែអាកូនមីចោរបព្វជិតនោះមកទីនេះទេ !

*វ៉ាន់លើច* ឆ្លើយតបដោយខំប្រឹងធ្វើជានៅតែទុកចិត្តដដែល :

- ព្រះជួយយើងអោយបានសុខហើយ ។ ពេលដែលមីញ៉ូមកដល់គេនឹងលែងពួកយើង ហើយនឹងប្រគល់សំពៅនិងកាំភ្លើងអី១ ហ្នឹងមកយើងវិញជាមិនខានទេ ។ ពួកអ្នែងចាំតែមើលទៅ ។ យើងនឹងលក់អីវ៉ៃអីវ៉ាន់យើងដាច់តែទាំងអស់ហ្នឹង ហើយយើងនឹងត្រលប់ទៅវិញដោយសុខសាន្ត និងក្លាយជាអ្នកមានហើយ១ ពិសេសយើងនឹងជាជនជាតិហូឡង់ទីមួយហើយ ដែលបានធ្វើដំណើរព័ទ្ធជុំវិញពិភពលោក ។ ពួកអាកាតូលិចទៅចុះនរកឯណាចុះទៅ ឯយើងគឺសុំមួយចានហើយ ។

-មិនមែនអីចឹងទេវ៉ុយ !-*វិញ* តប-ពួកអាកាតូលិចនេះគ្រាន់តែលឺអញញាក់សាច់បាត់ទៅហើយអ្នា ! ប្រឹងទប់យ៉ាងម៉េចក៏មិនកើតដែរ រឿងអាពួកកុងពីស្តាឌ័រនោះ ។ បងតែកុង ! បងគិតថាពួកវាមានច្រើនទេនៅកន្លែងនេះ ?

- ខ្ញុំមិនដឹងដែរ តែខ្ញុំគិតប្រហែលជាមានច្រើនមែនហើយ ។ ខ្ញុំបន់អោយតែមានពួកទ័ពយើងមកដល់ទីនេះទេ ។

*វិញ* គ្រញ៉ែងខ្លួន :

- អ្អើយ ! យ៉ាងហោចណាស់ក៏យើងនៅរស់ឡើយដែរ ។

*ម៉ែស៊ូរ៉ៃ* និយាយត :

- ប្រហែលជាពួកយើងនោះ ត្រលប់ទៅស្រុកវិញហើយក៏មិនដឹង ។ ពួកនេះអាចវិលចេញតាមច្រកម៉ាសេឡង់វិញពេលដែលយើងប៉ះព្យុះនោះ ។

-ខ្ញុំសង្ឃឹមថាអ្នែងគិតត្រូវចុះ-*ក្លាក់ថុន* តប-តែខ្ញុំគិតថាពួកគេនោះច្បាស់ជាអន្តរាយហើយ ។

*វិញ* ញាក់ស្មា :



www.budinst.gov.kh www.elibraryofcambodia.org

- យ៉ាងហោចណាស់ក៏ពួកយើងនៅរស់នៅឡើយដែរ ។

- ខ្ញុំគិតទៅក៏យើងមិនមែនគ្រាន់បើជាងគេប៉ុន្មានទេ នៅជាមួយពួកកាតូលិច និងពួកព្រៃដែលមានចរិតប្រកាច់យក៏យ៉ាងនេះនុះ !

-អោយវាចង្រៃស្រលះទៅ អាថ្ងៃអញចេញពីហូឡង់នោះ-*ពីតែស៊ូន* និយាយ-អោយវាចង្រៃអោយអស់ទៅអាស្រាបរំលយក៏នោះ ។ បើកុំតែអញស្រវឹងបន្តក់ទឹកទេនោះ កុំអីអញច្បាស់ជានៅតែអាំស្ងែដាំដេកអោបយាយកញ្ចាស់របស់អញរំភើយទៅហើយ ។

- អ្ហែងប្រទេចអីប្រទេចទៅអ្ហា ! តែកុំប្រទេចស្រារ៉ឺយ ! អានេះវាជាអ្នកធ្វើអោយជីវិតត្រចះត្រចង់ណាំ !

*វិញ* និយាយទាំងបើកភ្នែកក្រលៃតក្រលោត :

- អីលូវនេះយើងដូចជាប់ជង់កណ្តាលអណ្តូង ហើយទឹកចេះតែឡើងលឿនឡើង១អីចឹង ។

- កាលនោះខ្ញុំស្មានថា ពួកយើងគ្មានសំនាងបានដល់ដីគោកបន្តិចណាទេ -*រ៉ែមស៊ូតែ* រំលឹករឿងពួកគេឡើងវិញ គេមានមុខដូចជាសំពោចអីចង ទាស់តែគេជាសំពោចអត់ធ្មេញតែប៉ុណ្ណោះ -គ្មានសោះហើយ ។ ហើយគ្មាននឹកថា បានមកដល់ជប៉ុននេះបន្តិចបន្តួចណាទេ។ យីពួកអាកូនមីចោរកាតូលិចនេះ ។ មើលទៅយើងគ្មានសំនាងបានមានជីវិតចេញផុតពីនេះទេ ! បើបានកាំភ្លើងទៅវាគួរបន្តិច ! របស់វាយក៏ ! ឱសូមទោសបងតែកុងខ្ញុំអត់ចង់ថាអីអោយបងឯងទេ -*រ៉ែមស៊ូតែ* និយាយសូមទោសយ៉ាងលឿន នៅពេលដែលគេឃើញ *ប្លាក់ថន* សំលឹងមើល គេហើយគេបញ្ជាក់បន្ថែម :

- ខ្ញុំគ្រាន់តែចង់និយាយថា យើងស័យស្បៀវណាស់តែប៉ុណ្ណឹងទេ !

បន្តិចក្រោយមកអ្នកបំរើបានលើកម្ហូបអាហារមកអោយពួកគេជាថ្មីម្តងទៀត ។ ម្ហូបគឺមានតែធុនដដែល១ : បន្លែស្រស់និងបន្លែស្រុសលាយទឹកខ្មេះបន្តិច១ សំលត្រី និងបបរអង្ករសាលីរអង្ករស្រងៃតែប៉ុណ្ណឹង ។ ពួកគេច្រានចេញម្ហូបត្រីនៅដែលគេកាត់ជាកង់តូច១នោះហើយសួរគេរកសាច់និងស្រា ប៉ុន្តែគ្មានអ្នកណាយល់ថាពួកគេចង់បានអីទេ។ នាពេលព្រលប់ *ប្លាក់ថន* ក៏



www.budinst.gov.kh www.elibraryofcambodia.org

ចេញពីក្រុមរបស់គេមកវិញដោយនឿយណាយនឹងការភ័យខ្លាចគំនុំគុំគួន និងពាក្យចំអកចំអួង របស់ក្រុមគេជាពន់ពេក ។ គេប្រាប់ពួកក្រុមគេថា គេនឹងត្រលប់មកវិញពេលព្រលឹមស្រាង១ ។

នៅតាមច្រកផ្លូវដ៏ចង្អៀត ហាងទំនិញនានាមានអ្នកចូលទិញលែនណាន់តាន់តាប់ ។ *ប្លាក់ថន* ដើរមួយសន្ទុះទើបរកឃើញផ្លូវ និងផ្ទះដែលគេស្នាក់នៅ។ ស្នាមឈាមដែលប្រឡាក់នៅលើដីត្រូវគេបោសចេញ ហើយសាកសពនោះក៏ត្រូវគេយកចេញទៅបាត់ហើយដែរ ធ្វើអោយ *ប្លាក់ថន* មានអារម្មណ៍ដូចថា អ្វីៗដែលគេបានឃើញនោះ គ្រាន់តែជាការយល់សប្តិតែប៉ុណ្ណោះអីចឹង។ នៅពេលដែលគេលើកដៃប្រុងទៅបើកទ្វារក៏របើកភ្លាម ។ តាមចាស់ធ្វើសួនដែលនៅវិណ្ណកខ្ទបមួយផ្ទាំងទោះបីជាធាតុអាកាសចុះត្រជាក់ហើយក្តីនោះ ញញឹមដាក់ *ប្លាក់ថន* និងលំអោនខ្លួនគោរព "*កូនចៅនាំ*"។

- សួស្តី !

*ប្លាក់ថន* ឆ្លើយតបដោយស្វ័យប្រវត្តិ ហើយឡើងជណ្តើរពីរបីកាំទើបនឹកឃើញពីរឿងស្បែកជើងកវែងរបស់គេ ។ គេក៏ដោះវាចេញ ហើយដើរជើងទទេឆ្លងកាត់រានហាលចូលទៅក្នុង ប៉ុន្តែនៅតាមរបៀងផ្ទះនេះគេរកមិនឃើញបន្ទប់គេសោះ ។

- *អូណា ! -ប្លាក់ថន* ស្រែកហៅ ។

ស្រីចាស់ម្នាក់លេចមុខចេញមក :

- ហែ ?

- *អូណា* នៅឯណា ?

ស្រីចាស់នោះជ្រួញចិញ្ចើម ហើយចង្អុលខ្លួនគាត់ :

- *អូណា !*

- ឱព្រះអើយព្រះ *-ប្លាក់ថន* និយាយទាំងមួម៉ៅ -បន្ទប់ខ្ញុំនៅឯណាអ្នកស ? រួច អូណានៅឯណា ?

រួចគេរុញទ្វារមួយឃ្លាំងទៅម្ខាង ។ ជប៉ុនបួននាក់កំពុងអង្គុយទទួលទានអាហារនៅជុំវិញតុតឿមួយ ។ *ប្លាក់ថន* ស្គាល់បុរសម្នាក់ក្នុងចំនោមអ្នកទាំងបួននាក់ គឺបុរសសក់ល្បាយ



www.budinst.gov.kh www.elibraryofcambodia.org

អាច់ខ្លាជាប្រធានភូមិដែលគេជួបជាមួយគ្នានឹងបញ្ជិតនោះឯង ។ ពួកគេទាំងបួននាក់លំអោនខ្លួនដាក់ *ភ្លាក់ថន* ។

- អូ ! សូមទោស !

*ភ្លាក់ថន* ទាញទ្វារបិទទៅវិញ ហើយបន្តហៅរកទៅទៀត :

- *អូណា !*

ស្ត្រីចំនាស់នោះ សញ្ជឹងគិតមួយសន្ទុះទើបបក់ដៃហៅ *ភ្លាក់ថន* អោយទៅតាមខ្លួន ។ គេដើរតាមស្ត្រីនោះទៅតាមរបៀងថ្មីមួយទៀត។ ស្ត្រីនោះរុញទ្វារមួយទៅម្ខាងហើយ អាស្រ័យដោយរូបព្រះឆ្លាងនោះគេក៏ស្គាល់បន្ទប់របស់គេភ្លាម ។ ពួកកំរាលត្រូវគេរៀបចំឡើងវិញ យ៉ាងស្អាតបាតជាស្រេច ។ *ភ្លាក់ថន* មានអារម្មណ៍ចូរទ្រូងសន្ធឹក :

- អរគុណ ! ឥឡូវនេះជួយរកអូណាអោយខ្ញុំបន្តិចផង ។

ស្ត្រីចាស់ត្រលប់ខ្លួនដើរចេញទៅក្នុងដំណើរថ្នម១ ។ *ភ្លាក់ថន* ក៏អង្គុយចុះ ។ ក្បាលនិងខ្លួនប្រាណគេឈឺចុកចាប់គ្រប់កន្លែង ហើយគេសំឡឹងសព្វកន្លែងរកកៅអីមួយ ដើម្បីអង្គុយតែគេរកមិនឃើញសោះ ។ រួចចុះពួកនេះទុកកៅអីនៅឯណា ? ម្យ៉ាងទៀត តើធ្វើម៉េចឡើងទៅលើសំពៅវិញបាន និងធ្វើម៉េចបានកាំភ្លើងខ្លះអីចេះ ? ច្បាស់ជាមានផ្លូវដោះស្រាយបានជាមិនខានទេ ។

ស្នូរជើងថ្នម១ បានវិលត្រលប់មកវិញ ហើយនៅចំពោះមុខ *ភ្លាក់ថន* មាននារីបីរូបបានបង្ហាញរូបរាងឡើង គឺស្ត្រីចាស់ នារីម្នាក់មុខមូលនិងស្ត្រីវ័យមធ្យម កាលពីពេលព្រឹកនោះឯង ។ ស្ត្រីចាស់ចង្អុលទៅនារីក្មេងជាងគេដែលហាក់ដូចជាផ្អើល១នោះ :

- *អូណា !*

- ទេ !

*ភ្លាក់ថន* ស្ទុះងើបឡើងទាំងឆេះដុំ ហើយចង្អុលទៅនារីអាយុមធ្យមនោះ ។

- នេះនែអូណានោះ ! ឱព្រះអើយ ! នាងឯងមិនចាំឈ្មោះខ្លួនឯងទេអ្វី ?

អូណា ! ខ្ញុំឃ្លានណាស់ ។ តើមានអីអោយខ្ញុំទទួលទានទេ ?



www.budinst.gov.kh www.elibraryofcambodia.org

និយាយផង *ប្លាក់ថុន* យកដៃលុញពោះជាសញ្ញាថា ឃ្លានផង ។ នារីទាំងបីនាក់សំលឹងមើលមុខគ្នាឡិនឡង់ រួចនារីវ័យមធ្យមនោះញាក់ស្មាហើយនិយាយពាក្យប៉ុន្មានម៉ាត់ ដែលធ្វើអោយនារីទាំងពីរនាក់ទៀត សើចកាច់កកាច់ស្រង់ ។ បន្ទាប់មកនារីវ័យមធ្យមនោះដើរទៅរកកន្លែងដំណេក ហើយចាប់ផ្តើមដោះសំពត់អាវ ក្នុងពេលដែលនារីទាំងពីរនាក់ទៀត អង្គុយចោងហោងបើកភ្នែកធំៗរង់ចាំ ។

*ប្លាក់ថុន* កាន់តែមិងម៉ាំង :

- រួចនាងធ្វើអីហ្នឹង ?

- *អីស៊ីម៉ាំស៊ូ*

នារីនោះតប ហើយដោះអូប៊ីនិងបើកអាវគីម៉ូណូរបស់ខ្លួនឡើង ។ នាងមានដោះសំប៉ែត និងជ្រាយបំប្លែក ។ ក្បាលពោះនាងធំស្អែល ។

អាកប្បកិរិយានេះ បង្ហាញច្បាស់ណាស់ថា នារីនេះច្បាស់ជាដេកនៅកន្លែងនេះហើយ ។ *ប្លាក់ថុន* គ្រវីក្បាលញ៉េរតតាត់ ហើយចាប់ដៃនាងអោយងើបស្លៀកពាក់វិញ ។ គេទាំងពីរនាក់ចាប់ផ្តើមប្រកែកគ្នាផ្អារដៃ ផ្អារជើង ហើយនារីនោះចាប់ផ្តើមខឹងយកតែមែនទែនតែម្តង ។ នាងក៏ចាប់ផ្តើមដោះខោអាវ ហើយប៉ះវិលទៅកន្លែងដំណេកវិញទាំងស្រាតនទលក្ក ។

ការប្រកែកគ្នាស្រាប់តែចប់ឈឹង ហើយពួកគេក៏លំអោនខ្លួនទៅពេលដែលបុរសជាមេនោះចូលមក :

- *ណាន់ដា ? ណាន់ដា ?*

ស្ត្រីចំណាស់នោះក៏ចាប់ផ្តើមរៀបរាប់រឿងរ៉ាវជាហូរហែ ហើយបុរសនេះក៏ងាកមកសួរ *ប្លាក់ថុន* ទាំងងឿងឆ្ងល់និងជាភាសាប៉ែកទុយកាល់ប៉ៃឡាំៗដោយចង្អុលទៅនារីអាក្រាតនោះផង:

- លោកចង់បានស្រីហ្នឹង ?

-ទេ ! ទេ ! គ្មានទេ ! ខ្ញុំគ្រាន់តែចង់អោយនាង *អូណា* នេះ យកម្ហូបអោយខ្ញុំទទួលទានទេតើ ។

រួច *ប្លាក់ថុន* ចង្អុលទាំងរន្ធើនទៅលើនារីអាក្រាត :



www.budinst.gov.kh www.elibraryofcambodia.org

- នេះនាង *អូណា* នោះ !

-*អូណា* មានន័យថា " នារី "

រួចបុរសនោះ ចង្អុលទៅនារីទាំងបី :

- *អូណា អូណា អូណា* ។ លោកចង់បានអូណាអ្វី ?

*ប្លាក់ផន* គ្រវីក្បាលទាំងឡើយណាយ :

- ទេ ! ទេ ! អរគុណច្រើនហើយ ខ្ញុំច្រលំទេ អោយខ្ញុំសូមទោសណា ! រួចចុះនារីនេះឈ្មោះអីទៅ ?

- នាងហ្នឹង ? នាងឈ្មោះ *ហាគូ* ។ *ហាគូ* ! -បុរសនោះតប ។

- *ហាគូ ?*

- ហៃ ! *ហាគូ !*

-ខ្ញុំសូមទោស *ហាគូ - សាន* ។ ខ្ញុំស្មានថានាងឈ្មោះ *អូណា* ។

បុរសនោះក៏ពន្យល់រឿងរ៉ាវទៅហាគូ ហើយនាងហាក់ដូចជាមិនសប្បាយចិត្តសោះ ។ *ប្លាក់ផន* ឥតនិយាយស្តីពីមួយម៉ាត់សោះ ហើយពួកគេសំលឹងមើល *ប្លាក់ផន* ទាំងអស់គ្នា ។ នៅទីបញ្ចប់នៃការពន្យល់ពួកគេក៏នាំគ្នាយកដៃខ្ទប់មាត់សើចកក្អឹក ហើយចាកចេញពីបន្ទប់ទៅ ។ *ហាគូ* ងើបឡើងដើរចេញពីបន្ទប់ទាំងអាក្រាតដោយកាន់គីម៉ូណូនៅនឹងដៃ និងដោយមានទឹកមុខយ៉ាងថ្លៃថ្នូរបំផុត ។

- សូមអរគុណលោកច្រើនណាស់ !

*ប្លាក់ផន* និយាយទៅកាន់បុរសនោះ ។ នៅក្នុងចិត្តរបស់គេៗសែនមួម៉ៅមិនគួរគេពភ្លីពភ្លើយ៉ាងហ្នឹងសោះ ។

- ផ្ទះនេះ គឺជាផ្ទះខ្ញុំ ។ ខ្ញុំឈ្មោះ *មូរ៉ា* ។

- សូមគោរព *មូរ៉ា -សាន* ។ ខ្ញុំឈ្មោះ *ប្លាក់ផន* ។

- សូមទោសឈ្មោះអី ?

- *ប្លាក់ផន*



www.budinst.gov.kh www.elibraryofcambodia.org

- អ្ហ៎ ! បា - ឡាក់ - ផន

*ម្ងក៍* ប្រឹងហៅឈ្មោះ *ប្លាក់ផន* អោយបានត្រូវពីរបីដង តែទៅមិនរួចគេក៏ឈប់ប្រឹងតទៅទៀត តែគេខំសំលឹងមើលមុខបុរសមាឌយក្ស ដែលនៅពីមុខគេនេះ ។ នេះជាមនុស្សចុងស្រុក [២៩] ទីមួយដែលគេបានជួប ។ នេះមិននិយាយពីបព្វជិតសេបាស្ទ្យ និងបព្វជិតម្នាក់ ទៀតដែលគេបានជួបកាលពីប៉ុន្មានឆ្នាំមុននោះទេ ។ *ម្ងក៍* គិតថា ទោះជាយ៉ាងនេះក្តី ក៏បព្វជិតទាំងពីរនាក់ ដែលគេជួបនោះមានសក់ខ្មៅ ហើយកំពស់កំពចម្មតាទេ តែអាមនុស្សចុងស្រុកនេះខុសពីគេពីឯងតែម្តង ។ មាឌធំដូចយក្ស សក់លឿង ភ្នែកខៀវ ស្បែកស្លាំង កន្លែងណាត្រូវថ្ងៃឡើងក្រហម ។ ចំជាប្លែកអស្ចារ្យមែន ! ពីដើមរៀងមកអញតែងគិតថា មនុស្សទាំងអស់មានសក់ខ្មៅ ភ្នែកខ្មៅ ។ ម៉ាស្រុកនេះអ្នកណាក៏អីចឹង ! ពួកចិនក៏អីចឹង ! ហើយសំខាន់គឺចិននេះហើយ ព្រោះចិនមិនគឺជាពិភពលោកទាំងមូលអ្ហី ? [៣០] នេះកុំរាប់បញ្ចូលនគរចុងស្រុករបស់ពួកប៉ិកទុយកាល់ដែលនៅខាងជើងនោះ ។ គួរអោយឆ្ងល់ដែរ ហេតុអីបានជាបព្វជិតសេបាស្ទ្យស្អប់មនុស្សនេះម្ល៉េះ ? ឬ មួយអានេះជាអ្នកគោរពបូជាសាតង់ ? ដូចជាមិនមែនទេ ព្រោះថាបព្វជិតសេបាស្ទ្យគាត់ចេះបាលីដេញខ្មោចដែរតើ ។ អស្ចារ្យ ! អញមិនដែលឃើញបព្វជិតនេះនេះប្រលោតយ៉ាងនេះទេ ។ មិនដែលសោះតែម្តង ! អស្ចារ្យមែន ! រឺ មួយភ្នែកខៀវ និងសក់លឿងជាសញ្ញាសំគាល់របស់សាតង់ ?

*ម្ងក៍* សំលឹងមើលទៅ *ប្លាក់ផន* ហើយគេរំលឹកឡើងវិញពីពេលដែលគេខំសួរមនុស្សនេះទៅឯលើសំពៅ ។ រួចនៅពេលដែលបញ្ហាការនេះ សន្លប់លែងដឹងខ្លួន គេក៏បានសំរេចចិត្តនាំមនុស្សម្នាក់នេះមកសំរាកនៅក្នុងផ្ទះគេដោយគេយល់ថាបុរសនេះជាមេហេតុនេះត្រូវទទួលតាម

---

*( ២៩ ) - ជាធម្មតាជនជាតិចិន ជប៉ុន ហៅអ្នកដែលមានជាតិសាសន៍ខុសខ្លួនថា " អ្នកចុងស្រុក " ( ក.អ.ប ) ។*

*( ៣០ ) - ចិនហៅប្រទេសខ្លួនថា "ចុងកួក " មានន័យថា ប្រទេសនៅកណ្តាលគេ- មានន័យថា ចិននៅចំកណ្តាលពិភពលោក ឯប្រទេសឯទៀតជាប្រទេសចុងស្រុកតែប៉ុណ្ណោះ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

ឋានៈតួនាទីរបស់គេ ។

មកដល់ផ្ទះគេបានដោះខោអាវ *ភ្លាក់ផន* ហើយជូតសំអាតខ្លួនប្រាណរបស់គេ ។ ប៉ុន្តែ *ភ្លាក់ផន* នៅតែសន្លប់មិនដឹងខ្លួនទៀត ។ គ្រូពេទ្យបានទូន្មានកុំអោយយកបុរសនេះ ទៅដាក់ត្រាំទឹកនៅពេលបុរសនេះ មិនទាន់ដឹងខ្លួនអោយសោះ :

-*មូរ៉ា* អែងគួរចាំណាំ ! យើងមិនដឹងថា ពួកចុងស្រុកនេះជាមនុស្សយ៉ាងណាទេ ។ ជួនកាលយើងថែទាំពេក គ្នាបែរជាស្លាប់ទៅវិញក៏បាន ។ រួចគ្រាន់តែមើលក៏ដឹងដែរថា វានេះជាក់មែនទែនហើយ ។ ផ្លូវមានតែមួយទេ គឺយើងត្រូវតែអត់ធ្មត់សិនទៅ ។

*មូរ៉ា* សួរបន្ថែម :

- រួចចុះអារឿងចៃដែលនៅពេញក្បាលគាត់នោះ ?

- អោយវានៅសិនទៅ ។ តាមខ្ញុំដឹងពួកចុងស្រុកមួយណាក៏មានចៃដែរ ។ អីចឹងហើយ សូមទោសណាំ ! ខ្ញុំស្នើអោយអត់ធ្មត់ទៅ ។

-រួចចុះបើគ្រាន់តែកក់សក់បានទេ? -ប្រពន្ធ *មូរ៉ា* សួរ-ពួកយើងនឹងប្រយ័ត្នប្រយែងមិនអោយមានគ្រោះថ្នាក់ ហើយម្យ៉ាងទៀតអ្នកម៉ែអាចនឹងជួយណែនាំពួកខ្ញុំដែរ ។ បើបានធ្វើយ៉ាងនេះ មនុស្សចុងស្រុកនេះ ក៏បានស្អាត ហើយផ្ទះយើងក៏វាបានស្អាតតាមហ្នឹងដែរ ។

ម្ដាយ *មូរ៉ា* និយាយបន្ទរ :

- ម៉ែយល់ព្រម ។ កូនឯងកក់សក់វាទៅ !

ដោយទាំងមិនចាប់ភ្នែកខ្លួនឯងផង *មូរ៉ា* កំពុងតែសំលក់សំលឹងមើល *ភ្លាក់ផន* តាំងពីក្បាលដល់ចុងជើង ។ រួចគេនឹកឃើញពីប្រការដែលបព្វជិតបានប្រាប់គេពីពួកគោរពសាតង់ និងពួកចោរសមុទ្រទាំងនេះ ។ ឱ ! សូមព្រះអង្គជួយថែទាំកូនចៅកុំអោយពួកខ្មោចបិសាចអន្យតិរ្ថិយនេះបៀតបៀនបានអោយសោះលោក -*មូរ៉ា* បន់អួច១ នៅក្នុងពោះ -បើអញដឹងថាវាសៀមយ៉ាងនេះ អញមិនយកវាមកផ្ទះអញទេ ។ អីលូវនេះ អ្អែងឃើញទេ -*មូរ៉ា* បន្ទោសខ្លួនឯងនៅក្នុងចិត្ត- អ្អែងត្រូវបង្ខំចិត្តទទួលវាដូចភ្ញៀវពិសេស ទាល់តែ *អូមីសាន* សំរេចចិត្តថាយ៉ាងម៉េចផ្សេងទៀតវិញ ។ នេះចាត់ថា អ្អែងឆ្លាតដែរ ព្រោះចេះជូនដំណឹងទៅបព្វជិត និង *អូមី-*



www.budinst.gov.kh www.elibraryofcambodia.org

-*សាន* ភ្លាម១ ។ ឆ្លាតណាស់ ។ អ្នែងជាមេភូមិអ្នែងទទួលការពារភូមិ ហើយអ្នែងម្នាក់គត់ជាអ្នក ទទួលខុសត្រូវនៅទីនេះ ។

អើពិតហើយ ។ *អូមី - សាន* ច្បាស់ជាអោយអ្នែងទទួលខុសត្រូវពីរឿងមនុស្សងាប់ពីព្រឹក មិញនេះមិនខានទេ ពិសេសទទួលខុសត្រូវរឿងដែលអាមួយហ្នឹងបានព្រហើនដាក់គេហើយ ។

ហ៊ឺ ! គេបានណែនាំមិត្តភក្តិគេ គឺ *តាម៉ាសាគី* ដែលជាអ្នកនេសាទនេះ មិនដឹង ប៉ុន្មានសិបដងហើយទេ ។

- អ្នែងកុំឆ្កួតពេក *តាម៉ាសាគី* ! ឯងធ្វើអោយម៉ាភូមិខូចឈ្មោះ នែ់ ! កុំតឹងរ៉ឹងពេក ! *អូមី-សាន* គ្មានជំរើសអីក្រៅពីចំអកដាក់អ្នកកាន់គ្រិស្តសាសនាតែប៉ុណ្ណឹងទេ ។ ក្រែងអ្នែងដឹងថា ដៃមីញ៉ូយើងស្អប់ ពួកកាន់គ្រិស្តសាសនាដែរអ្ហ៎? រួចបើអីចឹងហើយតើ *អូមី-សាន* គាត់អាចធ្វើ អ្វីបាន ?

-គ្មានធ្វើអ្វីបានទេ ខ្ញុំឯកភាពហើយ *មូរ៉ា-សាន* ។ អោយខ្ញុំសូមទោសផង-*តាម៉ាសាគី* រមែងឆ្លើយតបយ៉ាងនេះ-តែអ្នកកាន់ពុទ្ធសាសនាត្រូវតែមានមេត្តាករុណាចមិជាងគេ *ទេ* ! តើ ពួកគេមិនជាអ្នកពុទ្ធសាសនានិកាយសិន (៣១) ទេអ្ហ៎ ?

ពុទ្ធសាសនានិកាយសិន គឺការពង្រឹង វិន័យខ្លួនដោយខ្លួនឯង ហើយជាសាសនាសង្កត់ ធ្ងន់លើការពឹងលើអាត្មាខ្លួន និងនៅលើសមាធិដើម្បីស្វែងរកផ្លូវញាណ ។ ពួក *សាមូរ៉ៃ* ភាគ ច្រើន១កាន់និកាយសិននេះ ព្រោះជានិកាយដែល ស៊ីគ្នាបំផុត សំរាប់អ្នកធ្វើសង្គ្រាមមិនខ្លាចស្លាប់ និងពោរពេញដោយមោទនភាពនេះ ។

-ពិតហើយ ពុទ្ធសាសនាប្រៀនប្រដៅអោយចេះប្រណីករុណា ។ប៉ុន្តែប៉ុន្មានសិបដង ហើយ ដែលខ្ញុំរំលឹកប្រាប់អ្នែងថា ពួករុតជាសាមូរ៉ៃ ហើយកន្លែងនេះ គឺតំបន់អ៊ីស៊ូមិនមែន គ្យូស៊ូទេ ហើយទោះបីកន្លែងនេះ ជាតំបន់គ្យូស៊ូ ក៏អ្នែងនៅតែជាអ្នកខុសដែរ ។ ខុសតែរហូតហ្នឹង *ទេ* ?

- មែនហើយ ។ អោយខ្ញុំសូមទោសផង ។ ខ្ញុំដឹងថាខ្លួនឯងខុសដែរ ។ តែមានពេលខ្លះ

---

*(៣១) និកាយពុទ្ធសាសនាមួយនៅជប៉ុន (Zen) (ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំខ្មាសខ្លួនឯងតែម្ដង ដែលសុខចិត្តបណ្ដោយអោយ *អូមី-សាន* ប្រមាថមាក់ងាយជំនឿបរិសុទ្ធរបស់ខ្ញុំអីចឹងនោះ ។

ឥឡូវនេះអ្នែងឃើញទេ *តាម៉ាសាគី* ។ អ្នែងស្លាប់ខ្លួនទទេ ព្រោះតែអ្នែងបានប្រមាថមើលងាយ *អូមី-សាន* ដោយមិនព្រមលំអោនខ្លួនគោរព មកពី *អូមី-សាន* និយាយថា " ពួកបព្ជិតសំអុយនៃសាសនាក្រៅ " តែប៉ុណ្ណោះ ។ ពិតហើយថា បព្ជិតនោះធុំក្លិនមែន ហើយសាសនាកាតូលិចជាសាសនាមកពីក្រៅមែន តែឱអាកំសត់ *តាម៉ាសាគី* អើយ ការពិតហ្នឹងវាមានទៅបានចិញ្ចឹមគ្រួសារអ្នែងអោយរស់អី ? ហើយវាក៏មិនអាចលុបភាពអសោចន៍នេះចេញពីភូមិយើងបានដែរទេ ។ ឱទេវតាអើយ សូមជួយប្រោសមិត្តសំលាញ់របស់ខ្ញុំនេះ និងសូមអោយវាបាននៅក្នុងសុគតិភពផងចុះ ។

*មូរ៉ា* ដឹងនៅក្នុងចិត្តថា គេច្បាស់ជាមានបញ្ហាច្រើនជាមួយ *អូមី-សាន* ។ តែបើមានរឿងតែជាមួយ *អូមី-សាន* ក៏មិនទាន់អាក្រក់ណាស់ណាទេ តែពេលនេះដែលយ៉ាប់បំផុតនោះ គឺដៃមីញ៉ូក៏មកដែរ ។

កង្វល់បារម្ភធំធេងរមែងមករឹតរូបគេ នៅពេលណាដែលមូរ៉ា នឹកពីអម្ចាស់របស់គេ គឺ *កាស៊ីគី យ៉ាប៊ូ* ដៃមីញ៉ូនៃតំបន់អ៊ីស៊ូ ហើយដែលត្រូវជាឪពុកមារបស់អូមីនេះ ។ *កាស៊ីគី យ៉ាប៊ូ* គឺជាមនុស្សសាហាវឃោរឃៅគ្មានគិតគូរពីរឿងកិត្តិយសអ្វីបន្តិចបន្តួចសោះទេ ហើយគាបសង្កត់ប្រជាជនគ្មានអាណិតអាសូរ ដើម្បីអោយគេបង់ផលនេសាទនិងភោគផលដំណាំនានា ទៅអោយខ្លួន ។ *មូរ៉ា* កំពុងដណ្ដឹងសួរខ្លួនឯងថា នៅពេលដែលសង្គ្រាមផ្ទុះឡើង តើ *យ៉ាប៊ូ* នឹងគាំទ្រខាងណា ? តើគាំទ្រលោកម្ចាស់អ៊ីស៊ីដូ ឬក៏លោកម្ចាស់ *តូរ៉ាណាកា* តែពួកយើង ល្ងិតល្ងោចនេះច្បាស់ជានៅចន្លោះកណ្ដាលមហាយក្សទាំងពីរមិនខាន ។

នៅទិសខាងជើង គឺជាលោកម្ចាស់ *តូរ៉ាណាកា* ជាមេទ័ពដ៏ខ្លាំងក្លាក្នុងសម័យនេះ និងជាស្ដេចត្រាញ់លើតំបន់ក្វាន់តូ លើខេត្តទាំង ៨ ជាដៃមីញ៉ូសំខាន់បំផុត នៅទិសនេះ ហើយជាមេទ័ពធំទិសខាងកើតផែមទៀត ។ នៅខាងលិចគឺលោកម្ចាស់អ៊ីស៊ីដូ ជាស្ដេចត្រាញ់វិមានអូសាកា ជាអ្នកទន្ទ្រានបង្ក្រាបកូរ៉េ ជាអ្នកថែរក្សាទាយាទ និងជាមេទ័ពធំទិសខាងលិច ។



www.budinst.gov.kh www.elibraryofcambodia.org

នៅខាងជើងគឺ *ភូវ៉ែកដូ* ជាមហាវិថីបណ្ដោយឆ្នេរ ដែលភ្ជាប់ទីក្រុងរបស់លោកម្ចាស់ *ភូរ៉ាណាកា* គឺទីក្រុងយេដូទៅនឹងទីក្រុងអូកាសា របស់លោកម្ចាស់អ៊ីស៊ីដូ មានចំងាយជាង ៣០០ ម៉ៃ[(៣២)] ហើយនៅលើកំណាត់ផ្លូវនេះ ហើយដែលកងទ័ពទាំងពីរខាងនឹងត្រូវប្រទះគ្នានោះ ។

តើអ្នកណានឹងមានជ័យជំនះ ?

គ្មានអ្នកណាទាំងអស់ ។

ពីព្រោះសង្គ្រាមនឹងឆាបឆេះចក្រភពជាថ្មីម្ដងទៀត សម្ព័ន្ធភាពនានា នឹងរលត់រលាយ ខេត្តនឹងប្រយុទ្ធទល់នឹងខេត្តរហូតដល់ភូមិប្រយុទ្ធទល់នឹងភូមិដូចតែរាល់ដងហ្នឹង ។ ឃើញស្ងប់តែ ១០ឆ្នាំចុងក្រោយហ្នឹងទេ ។ អស្ចារ្យណាស់ដែល ១០ឆ្នាំកន្លងនេះ គឺជាសម័យគ្មានសង្គ្រាម ដែលគេហៅថា សន្តិភាពនោះ បានកើតមាននៅក្នុងទូទាំងចក្រភព ។ ហើយនេះ គឺជាលើកទីមួយហើយ ក្នុងប្រវត្តិសាស្ត្រ ។

អញដូចជាចាប់ផ្ដើមស្រលាញ់សន្តិភាពហើយដែរនេះ -*ប្លូរ៉ា* គិតនៅក្នុងចិត្ត ។

តែឥឡូវនេះ អ្នកដែលបានកសាងសន្តិភាពនោះ បានស្លាប់បាត់ទៅហើយ ។ ទាហានដើមកំនើតអ្នកស្រែ ដែលបានក្លាយខ្លួនជា *សាមូរ៉ៃ* រួចទៅជាមេទ័ព រួចជាមេទ័ពធំ ហើយទីបំផុតក្លាយខ្លួនជា *តៃកូ* អម្ចាស់កំពូលអ្នកថែរក្សាជប៉ុននោះ បានស្លាប់បាត់តាំងពីឆ្នាំទៅម្ល៉េះ ហើយកូនប្រុសអាយុ ៧ឆ្នាំ របស់គាត់ នៅក្មេងហួសដើម្បីទទួលមហាអំនាចកំពូលរបស់គាត់បាន ។ ដល់អ៊ីចឹងទៅកូនរបស់លោកម្ចាស់ក៏ដូចជាពួកយើងនេះដែរ សុទ្ធតែនៅក្នុងក្រញាំដៃគេទាំងអស់គ្នាហ្នឹង ។ ក្នុងក្រញាំដៃពួកយក្ស ។សង្គ្រាមមិនអាចចៀសផុតទេ ។ ឥឡូវនេះ សូម្បីតែលោកម្ចាស់ *តៃកូ* ខ្លួនឯង ក៏មិនអាចការពារកូនជាទីស្រលាញ់ សន្តិវង្ស កេរមរតក និងចក្រភពរបស់ខ្លួនបានដែរ ។

មើលទៅរឿងរ៉ាវត្រូវតែអ៊ីចឹង ។ លោកម្ចាស់ *តៃកូ* បានពង្រាបទឹកដីកសាងសន្តិភាពបង្ខំអោយពួក *ដៃមីញ៉ូ* មួយប្រទេស ក្រាបនៅមុខខ្លួនដូចអ្នកស្រែ រៀបចំឡើងវិញនូវតួនាទី

---

(៣២) -មួយម៉ៃមានចំងាយ ១ ៦០៩ ម៉ែត ( ក.អ.ប )



www.budinst.gov.kh www.elibraryofcambodia.org

យសសក្តិ ដោយលើកអ្នកនេះ ទំលាក់អ្នកនោះ តាមទំនើងចិត្ត រួចហើយលោកក៏ស្លាប់ទៅ ។ លោកគឺយក្សក្នុងចំនោមមនុស្សកន្ទៀ។ តែវាក៏ម្យ៉ាងដែរ ដែលរាល់ការងារ និងភាពថ្កុំថ្កើងរបស់លោកស្លាប់ទៅជាមួយនឹងរូបលោកដែរនោះ ។ នេះមិនមែនជាមនុស្សទេ តែគឺជាលំអងផ្កាមួយដែលរសាត់តាមខ្យល់តែប៉ុណ្ណោះ។ គឺមានតែភ្នំ សមុទ្រ ហ្វូងតារា និងទឹកដីរបស់ព្រះនេះទេដែលពិត ហើយដែលនៅស្ថិតស្ថេរនោះ ។ យើងនៅចន្លោះគំនាប អានេះគឺច្បាស់ហើយ ។ *យ៉ាប៊ូ* ខ្លួនឯងនឹងសំរេចថា ពួកយើងនឹងនៅខាងណា អានេះគឺច្បាស់ហើយ ។ ភូមិនៅតែភូមិព្រោះវាលស្រែដ៏មានជីជាតិ ហើយសមុទ្រក៏សំបូរធនធាន អានេះគឺជាប្រការច្បាស់ចុងក្រោយ។

រួច*មូរ៉ា* ក៏ប្រមូលអារម្មណ៍ផ្តោតទៅលើមនុស្សចុងស្រុក ដែលនៅពីមុខខ្លួនវិញ ។ អ្នែងនេះ គឺជាបិសាចដែលមកយាយីពួកយើងតែម្តង ។ តាំងពីអ្វែងមកដល់ពេលណាគ្មានបានអីក្រៅតែពីរឿងមិនស្វាងតែម្តង ។ រួចហេតុអីបានជាអ្វែងមិនចូលភូមិណាផ្សេងទៅ ។

-បញ្ហាការ - *សាន* ត្រូវការ *អូណា* អ្វី ?

*មូរ៉ា* សួរទៅ *ក្លាក់ថន* ។ តាមសំនើរបស់គេក្រុមប្រឹក្សាភូមិបានរៀបចំស្រី ដើម្បីផ្តល់អោយពួកចុងស្រុកឯទៀត ម្យ៉ាងជាកិច្ចគួរសម ម្យ៉ាងទៀតដើម្បីកំដរពួកនេះរហូតដល់ពេលដែលពួកអាជ្ញាធរមកដល់ផង ។

- *អូណា* ?

*មូរ៉ា* សួរម្តងទៀតដោយគិតថា ពេលដែលមនុស្សចុងស្រុកនេះដើរបានហើយ គេមុខជាត្រូវការស្ត្រីខ្លួនមុនដេកជាមិនខាន ហើយម្យ៉ាងទៀតអ្វីៗ ក៏ត្រូវបានគេរៀបចំត្រៀមទុកជាស្រេចហើយដែរ ។

- អត់ទេ ! -អ្វីដែល *ក្លាក់ថន* ចង់គឺដេក ប៉ុន្តែដោយគេដឹងថា គេត្រូវការមនុស្សនេះទើបគេខំប្រឹងញញឹម ហើយចង្អុលទៅរូបព្រះឆ្កាង :

- គ្រិស្តសាសនិក ?

*មូរ៉ា* ងក់ក្បាល :

- គ្រិស្តសាសនិក



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំគ្រិស្តសាសនិក ។

- បញ្ជិតថាទេ ។ មិនមែនគ្រិស្តសាសនិកទេ ។

- ខ្ញុំគ្រិស្តសាសនិក ។ មិនមែនកាតូលិចទេ ។ តែគ្រិស្តសាសនិក ។

តែ *មូរ៉ា* មិនអាចយល់បានទេ ទោះជា *ភ្ញាក់ផន* ប្រឹងពន្យល់យ៉ាងណាក៏ដោយ ។

- ត្រូវការ *អូណា ?*

- អឺ......ឱមយ៉ូ -អង្គាល់មកដល់ ?

-ឱមយ៉ូ ? មិនយល់ទេ

- ឱមយ៉ូ អូ ! ខ្ញុំចង់ថា *ដៃមីញ៉ូ*

- អ្ហា ! *ដៃមីញ៉ូ* ! ហៃ ! *ដៃមីញ៉ូ ! ដៃមីញ៉ូ* នឹងមកពេលដែលត្រូវមក ។ ដេកទៅ ។ ដំបូងបង្អស់ស្អាតសិន សូមទោស !

- ថាម៉េច ?

- ស្អាត ។ សូមអញ្ជើញមុជទឹក ។

- ខ្ញុំមិនយល់ទេ ។

*មូរ៉ា* ឱតចូលជិត ហើយច្របាច់ច្រមុះដោយឆ្អើម :

- ស្អុយក្លិន ។ អាក្រក់ ។ ដូចពួកប៉ុកទុយកាល់ ។ មុជទឹក ។ ផ្ទះនេះស្អាត ។

- ខ្ញុំមុជទឹកពេលណាខ្ញុំចង់ ហើយគ្មានស្អុយក្លិនទេ ។

*ភ្ញាក់ផន* ចាប់ផ្ដើមឆេះដុំ

- អ្នកណាក៏ដឹងថា មុជទឹកវាគ្រោះថ្នាក់ដែរ ។ អ្អែងចង់អោយខ្ញុំហើមស្លួតងាប់ទៅអ្វី ? ស្មានថាខ្ញុំហ្នឹងមិនដឹងខ្យល់អ្វី ? អីលូវនេះ អញ្ជើញចេញ ហើយទុកអោយខ្ញុំដេកពួនផង ។

- មុជទឹក !

*មូរ៉ា* និយាយបញ្ចាទាំងមួហ្មង ដោយទើសចិត្តនឹងការបញ្ចេញភាពគ្រេវគ្រោធ របស់មនុស្សចុងស្រុកនេះ ។ បញ្ចេញភាពគ្រេវគ្រោធ គឺជាអាកប្បកិរិយាដ៏ថោកទាបបំផុត ។ នេះមិនគ្រាន់តែអ្នកចុងស្រុកនេះធុំក្លិនទេ ហើយធុំក្លិនមែនទែន ប៉ុន្តែតាមគេដឹង គឺម្នាក់នេះមិនទាន់



www.budinst.gov.kh www.elibraryofcambodia.org

បានមុជទឹកស្រួលបួល ៣ថ្ងៃហើយ។ ស្រីកំដរទោះជាអោយថ្លៃយ៉ាងណាក៏ច្បាស់ជាប្រកែកមិនព្រមរួមដំណេកជាមួយមនុស្សបែបហ្នឹងឡើយ ។ យីអើ ! ពួកអាបរទេសនេះ យ៉ាប់មែនទែនតែម្តង ។ គួរអោយឆ្ងល់ដែរ រួចទំលាប់រស់នៅពួកនេះ អីក៏គគ្រិចសំបើមម្ល៉េះ ? - *មូភី* គិតនៅក្នុងចិត្ត- ប៉ុន្តែអត់អីទេអ្នា !អញជាអ្នកទទួលមើលការខុសត្រូវលើអ្នែង។ អញបង្រៀនអ្នែងអោយចេះស្គាល់ច្បាប់ទំលាប់ ។ អ្នែងត្រូវមុជទឹកដូចមនុស្សម្នាឯទៀត ។

- មុជទឹក !

- ឥឡូវនេះ ចេញទៅក្រៅប្រយ័ត្នអញអង្គន់សាច់អ៊ី !-និយាយបណ្តើរ *ប្លាក់ថន* សំលឹងថ្ងៃរទៅ *មូភី* បណ្តើរ ឯដៃរបស់គេធ្វើសញ្ញាអោយ *មូភី* ចេញទៅក្រៅ ។

បរិយាកាសហាក់នៅទ្រឹងមួយរយ: ហើយបន្ទាប់មកបុរសជប៉ុន ៣នាក់ បានចូលមកក្នុងបន្ទប់ទន្ទឹមគ្នា នឹងនារី ៣នាក់ដែរ ។ *មូភី* ពន្យល់ម៉ាត់ៗ ពីបញ្ហាដែលកើតឡើង រួចហើយគេនិយាយយ៉ាងដាច់ណាត់ទៅ *ប្លាក់ថន* ម្តងទៀត ។

- សូមទោស ! មុជទឹក !

- ទៅក្រៅ !

*មូភី* ដើរតំរង់ចូលទៅតែម្នាក់ឯង។ *ប្លាក់ថន* លើកដៃដើម្បីរុញ *មូភី* ចេញតែគេមិនមែនមានបំនងចង់ធ្វើអោយមានរបួសទេ ។ រួចស្រាប់តែ *ប្លាក់ថន* ស្រែកយ៉ូយដោយការឈឺចាប់ ។ *មូភី* បានបុកបាតដៃកាប់ចំកែងដៃរបស់ *ប្លាក់ថន* ធ្វើអោយស្ពឹកស្រយង់មួយរំពេច ។ ដោយកំហឹងឡើងដល់កហើយ ។ *ប្លាក់ថន* ស្ទុះចូលទៅរក *មូភី* ទាំងកំរោល ។ តែរំពេចនោះ គេហាក់ឃើញថា បន្ទប់វិលពេញក្រសែភ្នែកគេហើយ ស្រាប់តែគេក្រាបស្ប៉ាបទៅលើក្តារ ។ ស្នៀតមួយដៃទៀត ធ្វើអោយគេកំរើកខ្លួនលែងរួចតែម្តង ។

- រំបល់......

គេចង់ក្រោកឈរឡើងវិញ តែជើងរបស់គេលែងស្តាប់បញ្ជារបស់គេហើយ ។ បន្ទាប់មក *មូភី* យកម្រាមដៃតូចៗ តែរឹងដូចដែករបស់គេសង្កត់យ៉ាងនឹងនរលើចំណុចជីពចរមួយនៅកញ្ចឹងករបស់ *ប្លាក់ថន* ។ ចំបាយឈឺចាប់ទ្រាំមិនបានមួយបានមកខ្ទាំ *ប្លាក់ថន*



www.budinst.gov.kh www.elibraryofcambodia.org

ជាប់ ។

-អីយ៉ូយព្រះអើយ......

- មុជទឹកទេ ? អញ្ជើញ !

- បាទ ! បាទ !

*ភ្លាក់ថន* ប្រឹងគ្រវរឆ្លើយទាំងឈឺចាប់ ។ ខ្លួនគេផ្ទាល់ក៏មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលខ្លួនគេមកចាញ់មនុស្សល្អិតតូចមួយយ៉ាងងាយៗ ហើយអីលូវនេះ មកដេកស្រប៉ាបៗ គ្មានកំរើកខ្លួន ដូចជាកូនក្មេងរង់ចាំគេមកអោរកយ៉ាងដូចនេះដែរ ។

ប៉ុន្មានឆ្នាំមុននេះ *ឆូភ៌* បានហាត់ស្នៀតគុនយូដូ និង ការ៉ាតេ ក៏ដូចជាបានហាត់ស្នៀតគុនដាវ និងលំពែងផងដែរ ។ កាលនោះគេជាទាហាន ហើយគេបានប្រយុទ្ធអោយ *ណាកាមូរ៉ា* ជាមេទ័ពអ្នកស្រែ ដែលក្រោយមកជាតៃកូនោះ។ តែពេលនោះ គឺមុនពេលដែល *ណាកាមូរ៉ា* មិនទាន់ឡើងជាតៃកូនៅឡើយទេ ។ គឺជាពេលដែលកសិករអាចក្លាយជា *សាមូរ៉ៃ* ។ ហើយ *សាមូរ៉ៃ* អាចក្លាយជាកសិករ ជាជាង រឺជាឈ្មួញដែលនៅថ្នាក់ទាប ហើយអាចក្លាយជាអ្នកធ្វើសឹកសង្គ្រាមបានវិញដដែល ។ ដូចជាចំណែកដែរ - *ឆូភ៌* គិតរវើរវាយ នៅពេលដែលគេសំលឹងមើល ដោយគ្មានយកចិត្តទុកដាក់ទៅរកយក្សដែលដួលស្តូកនៅមុខគេ - ចំណែកគ្រង់ដែលថាប្រការដែលអម្ចាស់តៃកូបានប្រកាន់យកដំបូងគេ នៅពេលដែលគាត់ក្តាប់អំនាចទាំងស្រុងហើយនោះ គឺការចេញបញ្ជាហាមកសិករមិនអោយធ្វើទាហានទៀត និងត្រូវប្រគល់អាវុធទាំងអស់ ។ អម្ចាស់តៃកូ បានហាមមិនអោយកសិករកាន់អាវុធជារៀងរហូត ហើយលោកបានចាត់តាំងឡើង នូវប្រព័ន្ធវណ្ណៈមួយដ៏រឹងត្អឹង ដែលគ្មានអ្នកណាប្រែប្រួលបាន ហើយដែលអីលូវនេះបានគ្របដណ្តប់លើជីវិតមនុស្សទាំងអស់ នៅក្នុងចក្រភពនេះ : *សាមូរ៉ៃ* នៅពីលើគេបង្អស់បន្ទាប់មកកសិករ រួចសិប្បករ រួចឈ្មួញ ចុះក្រោមទៀតមានសិល្បករ ពួកអ្នកងារ និង ពួកចោរហើយនៅបាតក្រោមបង្អស់ នៃសង្គមគឺពួក *អេតា* ជាពួកអមនុស្ស គឺពួកដែលរកស៊ីជាមួយសាកសព អ្នកសំលាប់ស្បែក អ្នកសំលាប់សត្វ ពេជ្ឈឃាត និងអ្នកគ្រៀវសត្វ ។ ពិតហើយ បើនិយាយពីពួកចុងស្រុកវិញ នៅក្រោមហៅមិនលើទេ នៅក្នុងរង្វាស់សង្គមនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

- សូមអភ័យទោសអោយខ្ញុំផង បញ្ជាការ-*សាន* !

*ម៉ូរ៉ា* លំអោនខ្លួនយ៉ាងទាបដោយគេខ្មាសជួសមនុស្សចុងស្រុក ដែលកំពុងតែថ្ងូរ ហ៊ឺសដូចក្មេងបៀមដៃ ដោយឥតគិតពីការថ្ងៃថ្ងូររបស់ខ្លួនសោះ ។ អញស្តាយណាស់ ប៉ុន្តែត្រូវតែធ្វើអីចឹង - *ម៉ូរ៉ា* នឹកគិតនៅក្នុងចិត្ត - អ្អែងបានធ្វើអោយអញទ្រាំលែងបានទោះជាអញដឹងថា អ្អែងជាមនុស្សចុងស្រុកក្តី ។ អ្អែងមាត់ឡូឡាដូចមនុស្សឡប់សតិរំខានម៉ែអញធ្វើអោយភាពស្ងប់ស្ងៀមរលាយបាត់ រំខានអ្នកបំរើ ហើយប្រពន្ធអញត្រូវដូរទ្វាមោសទ្វីកទៅហើយ ។ អញទ្រាំអធ្យាស្រ័យអារបៀបច្រលោងខាមរបស់អ្អែងតទៅទៀតមិនបានទេ ។ ហើយអញ ក៏មិនអាចអោយអ្អែងជំទាស់នឹងឆន្ទៈរបស់អញនៅក្នុងផ្ទះនេះបានទេ ។ នេះក៏ដើម្បីអោយអ្អែងល្អដែរ ។ រូបរឿងនេះក៏មិនជាអាក្រក់អីដែរ ព្រោះអាពួកចុងស្រុកឯងមិនដែល ចេះស្គាល់ថា បាក់មុខ បាក់មាត់យ៉ាងម៉េចផង ។ អើបើពួកបព្វជិតនោះផ្សេងវិញ ។ ពួកវានោះធុំអាក្រក់មែនតែគេមានមន្តរបស់ព្រះ អីចឹងគេមានមុខមាត់ធំ។ តែអ្អែងវិញ អ្អែងគឺជាមនុស្សកុហក ហើយជាចោរសមុទ្រ ។ គ្មានកិត្តិយស គ្មានមុខមាត់អីទាំងអស់ ។ គួរអោយឆ្ងល់មែន ។ អីចឹងហើយអួតខ្លួនថា ជាគ្រិស្តសាសនិកផង ។ តែស៊យហើយអាភ៌រឿងហ្នឹងមិនមែនជួយអ្អែងរួចទេ ។ *ដេមីញ៉ូ* យើងស្អប់ណាស់ គ្រិស្តសាសនា ហើយ នឹងពួកចុងស្រុកទាំងអស់ ហើយរាល់ថ្ងៃគាត់ធ្មេចភ្នែក ព្រោះតែគាត់ត្រូវបង្ខំចិត្តទេ ។ ចំនែកអ្អែងវិញ អ្អែងមិនមែនជាតិប័កទុយកាល់ ហើយក៏មិនមែនគ្រិស្តសាសនិកអីចឹងគ្មានច្បាប់អី ការពារអ្អែងទេនេ ? ហេតុនេះទោះអ្អែងជាមនុស្សត្រូវស្លាប់ រឺ ត្រូវកាត់អវៈយវៈក្តី ក៏យ៉ាងហោចណាស់អញមានភារកិច្ចអោយអ្អែងទទួលភ័ព្វវាសនាអ្អែងអោយស្អាតបាតដែរ ។

*ម៉ូរ៉ា* ជួយអ្នកឯទៀត សែង *ភ្ជាក់ផន* ដែលនៅល្ងាក់ល្ងើនៅឡើយនោះ កាត់តាមផ្ទះចេញមកសួនច្បារ ហើយដើរតាមរបៀងមានជំបូលមួយ ដែលគេរមែងមានមោទនភាពបំផុតនោះ ហើយទីបំផុត គេបានមកដល់កន្លែងមុជទឹក ។ នារី១ ប៉ុន្មាននាក់ដើរជាប់ប្រកិតពីក្រោយគេ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ២

- *ដៃមីញ៉ូ កាស៊ីគីយ៉ាប៊ូ* អម្ចាស់តំបន់អ៊ីស៊ូចង់ដឹងថា អ្នែងជាអ្នកណា មកពីណាមក ដល់កន្លែងនេះតាមណា ហើយការឆក់ប្លន់អីខ្លះ ដែលអ្នែងបានធ្វើ- បព្វជិតសេបាស្ទ្យសួរមកកាន់ *ភ្វាក់ថន* ។

- ខ្ញុំនិយាយឡើងរួយមាត់ទៅហើយ ថាខ្ញុំមិនមែនជាចោរសមុទ្រទេ !

ព្រឹកនេះមេឃស្រលះល្អ ហើយកក់ក្តៅស្រួលផង ។ *ភ្វាក់ថន* កំពុងតែលុតជង្គង់ពីមុខវេទិកាមួយដែលនៅចំកណ្តាលភូមិ ។ ក្បាលរបស់គេនៅឈឺនៅឡើយ ។ ត្រូវតែនឹងនរ ហើយព្រលែងខ្វរក្បាលអ្នែងអោយវាធ្វើការវ៉ិ-គេនិយាយទៅកាន់ខ្លួនគេ-អ្នែងកំពុងតថ្លៃអាយ៉ូសអ្នែងហើយ ។ អ្នែងគឺជាអ្នកនាំពាក្យដឹងតែប៉ុណ្ណឹងទៅ ។ *អាយេស្ទ៊ីក* ស្អប់ពួកយើង ហើយវាជាអ្នកបកប្រែតែមួយគត់ ដែលមាននៅទីនេះ ។ ពួកអ្នែងគ្មានមធ្យោបាយដឹងថា វាបកពន្លាត់យ៉ាងម៉េចទេ ។ បើច្បាស់ គឺច្បាស់ តែរឿងមួយគត់ គឺវាច្បាស់ជាមិនជួយអ្នែងទេ ។ *ភ្វាក់ថន* ហាក់ឮសំដីគ្រូគេ គឺតា *អាល់បានកាក់ដុក* និយាយមកកាន់គេអ៊ីចឹង : "ចិត្តអោយ ត្រជាក់អាវ៉ា ! ពេលដែលព្យុះកាន់តែខ្លាំង សមុទ្រកាន់តែរលក ពេលហ្នឹងហើយ ដែលអ្នែងត្រូវ ការចិត្តត្រជាក់ពិសេសពេលនេះតែម្តង ។ ចិត្តត្រជាក់ហ្នឹងហើយ ដែលជួយអ្នែងអោយរស់ ជួយកប៉ាល់អ្នែងអោយរួច- បើសិនណាអ្នែងជាតៃកុង ។ ត្រូវរក្សាចិត្តអោយត្រជាក់ ហើយរាល់ថ្ងៃត្រូវក្រេបយកទឹកដមរបស់វា ទោះជាអាក្រក់....." ។

ទឹកដមថ្ងៃនេះមហាល្វីងតែម្តង-*ភ្វាក់ថន* គិតទាំងជូរចត់-រួចម៉េចបានជាអញ្ជើលីសំលេងពាក្យរាល់បានច្បាស់ល្អម្ល៉េះ ?

គេក៏និយាយបន្តទៀតទៅបព្វជិតសេបាស្ទ្យ :

- ដំបូងបង្អស់ ជំរាបដៃមីញ៉ូថា យើងច្បាំងគ្នា ថាយើងគឺជាសត្រូវនឹងគ្នា ។ ប្រាប់គាត់ថា អង់គ្លេសនិងហូឡង់កំពុងច្បាំង នឹងអេស្ប៉ាញ និងប៉័កទុយកាល់ ។

- អញ្ជូទូន្មានអ្នែងម្តងទៀតអោយនិយាយងាយយល់ ហើយកុំសាកកាឡៃរឿងរ៉ាវអោយសោះ ។ ប្រទេសហូឡង់ វី សេឡង់ វី សហភាពខេត្ត ទោះជាតាមឈ្មោះអីដែលពួក



www.budinst.gov.kh www.elibraryofcambodia.org

អាហ្វូឡង់តគ្រិចអ្អែងហៅក្តី គឺជាខេត្តដ៏តូចមួយ ដែលបានបះបោរប្រឆាំងនឹងចក្រភពអេស្ប៉ាញ ហើយដែលខ្លួនជាចំនែកមួយនោះ ។ អ្អែងគឺជាមេពួកក្បត់ដែលកំពុងបះបោរប្រឆាំងនឹងរាជាស្របច្បាប់របស់ខ្លួន ។

- ប្រទេសអង់គ្លេសកំពុងច្បាំង ហើយប្រទេសហូឡង់ ត្រូវបានផ្លា.......*ប្លាក់ថន* ឈប់និយាយបន្តដោយថា បព្វជិតនោះឈប់ស្តាប់គេហើយៗកំពុងតែបកប្រែ ។

*ដៃមីញ៉ូ* ដែលនៅអង្គុយលើវេទិកានោះ មានរាងទាបក្រអាញ តែមុខពោរពេញដោយអំនាច ។ គេលុតជង្គង់អង្គុយយ៉ាងស្រួល ។ នៅក្បែរគេមានភូឈ្មួយ ៤នាក់ រួមទាំង *កាស៊ីគីអូមី* ដែលត្រូវជាក្មួយ និងជាអ្នកចំនុះផងនោះ ។ ពួកគេទាំងអស់គ្នា ពាក់គីម៉ូណូសូត ហើយនៅពីលើគីម៉ូណូមានថែមអាវក្រាស់ប៉ាក់មួយ ដែលត្រូវរឹបស្តួចនៅចង្កេះដោយក្រវាត់ធំ និងដែលមានស្មារឹងគ្រមាំងធំៗ ។ ទាំងអស់គ្នាសុទ្ធតែមានអាវុធ ដែលគេតែងកាន់វាជាប់នោះ ។

*មូរ៉ា* លុតជង្គង់ផ្ទាល់ទៅនឹងដីថ្លា ។ គេគឺជាអ្នកភូមិតែម្នាក់គត់ដែលមានវត្តមាននៅទីនេះ ។ អ្នកឈរមើលព្រឹត្តិការណ៍នេះផ្សេងទៀត គឺពួក*សាមូរ៉ៃ* ទាំងហាសិបនាក់ ដែលមកដល់ទីនេះ ជាមួយដៃមីញ៉ូនេះឯង ។ ពួកគេអង្គុយជាជួរយ៉ាងស្ងៀមស្ងាត់ និងយ៉ាងមានវិន័យ ។ ក្រុមនាវិកសំពៅនៅពីក្រោយ *ប្លាក់ថន* ហើយអង្គុយលុតជង្គង់ដូចជាគេដែរ ។ ឆ្មាំច្រើននាក់ នៅឈរយាមក្បែរៗនោះ ។ នៅពេលដែលគេទៅរកនោះ ពួកនាវិកត្រូវសែងទាំងមេបញ្ជាការមកជាមួយផង ថ្វីត្បិតតែជំងឺរបស់គាត់នៅធ្ងន់ធ្ងរនៅឡើយក្តី ។ គេបានអនុញ្ញាតអោយមេបញ្ជាការដេកផ្ទាល់នឹងដីក្នុងភាពរវើរវាយ ។ ពេលមកដល់មុខ *ដៃមីញ៉ូ* *ប្លាក់ថន* ក៏បានលំអោនខ្លួនដូចជាអ្នកឯទៀតទាំងអស់គ្នាដែរ ។ ប៉ុន្តែប៉ុណ្ណឹង គឺមិនគ្រប់គ្រាន់ទៀត ។ ពួក *សាមូរ៉ៃ* បានបង្ខំអោយពួកគេទាំងអស់លុតជង្គង់ចុះ ហើយជ្រមុជក្បាលពួកគេផ្ទុចទៅនឹងដីបីដូចជារបៀបគោរពរបស់ពួកកសិករដែរ ។ *ប្លាក់ថន* បានប្រឹងប្រកែកនឹងរបៀបគោរពនេះ ហើយគេបានស្រែកប្រាប់ទៅបព្វជិតអោយពន្យល់ប្រាប់ថា របៀបនេះ មិនមែនទំលាប់របស់ពួកគេទេ ហើយថា គេគឺជាមេនិងជាតំនាងរបស់ប្រទេសគេ ដោយហេតុថា ត្រូវទទួលគេតាមឋានៈតួនាទីរបស់គេ ។ ប៉ុន្តែដង លំពែងមួយបានបុកគេដួលទៅលើដី ។ ពួកនាវិកគេក៏ផ្តុំគ្នាភ្ញាម ដើម្បីតដៃវិញ ប៉ុន្តែ



www.budinst.gov.kh www.elibraryofcambodia.org

*ភ្លាក់ថន* ស្រែកប្រាប់អោយពួកគេនៅស្ងៀម និងលុតជង្គង់ចុះតាមបញ្ជា ។ ជាសំនាងដែរ ដោយក្រុមរបស់គេស្តាប់តាមបញ្ជារបស់គេ ។ *ដៃមីញ៉ូ* ស្រែកឡើងគ្រលរ១ ហើយបព្វជិតនោះ ក៏បកប្រែប្រាប់គេថា នេះគឺជាការព្រមានដល់គេអោយនិយាយរឿងពិត ហើយនិយាយជាប្រញាប់ ។ *ភ្លាក់ថន* ស្នើសុំកៅអី ប៉ុន្តែបព្វជិតនោះបានប្រាប់គេថា ពួកជប៉ុនមិនប្រើកៅអីទេហើយក្នុងមួយប្រទេសនេះ គ្មានកៅអីមួយឡើយ ។

នៅពេល *សេបាស្ទូ* និយាយទៅកាន់ដៃមីញ៉ូ *ភ្លាក់ថន* ខំប្រមូលអារម្មណ៍ទៅលើបព្វជិតនេះ ដើម្បីស្វែងរកចំនុចខ្សោយនៅក្នុងរនាំងការពារនេះ ។

ផ្ទៃមុខរបស់ *ដៃមីញ៉ូ* បង្ហាញឡើងនូវភាពក្រអឺតក្រទម និងកំនាចឃោរឃៅតែម្តង-*ភ្លាក់ថន* គិតនៅក្នុងចិត្ត ។ អានេះចំជាអាមនុស្សជ្ជូរជាតិមែន១ តែម្តង ភ្ញាល់ប៉ុន្មានក៏ភ្ញាល់ដែរ ។ តែភាសាជប៉ុនរបស់អាល្បងបព្វជិតហ្នឹងគ្រាន់បើដែរ រឺមួយក៏ដូចឆ្មាចូលត្រឡោកទេដឹង ? អុញនោះ ! *ដៃមីញ៉ូ* មួម៉ៅផង តឿនបង្ខំផង ។ ប្រហែលដៃមីញ៉ូសួរពាក្យផ្សេង ព្រោះមិនសូវច្បាស់ទេដឹង ? ប្រហែលហើយ មើលទៅ ។ ហេតុអ្វីបានជាយេស៊ូតនេះ ស្លៀកស្បង់ពណ៌ស្លាទុំអ៊ីចឹង ? តើ *ដៃមីញ៉ូ* ជាអ្នកកាតូលិចដែរ រឺក៏អត់អ៊ីចឹង ? តែមើលទំ ! បព្វជិតនោះ ធ្វើក្រុន១ បែកញើសជោកខ្លួន ហ្នឹងច្បាស់ជា *ដៃមីញ៉ូ* មិនមែន កាតូលិចទេ ។រឺ បើនិយាយតាមត្រង់ដៃមីញ៉ូប្រហែលជាមិនមែនកាតូលិចទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏កុំសង្ឃឹមថា វាអនុគ្រោះអោយអ្អែងអោយសោះ ។ បើអ៊ីចឹងតើធ្វើម៉េចបេះប្រើអាចោរជូជាតិនេះបានអ៊ីចឹង ? រួចតើធ្វើម៉េចអាចនិយាយផ្ទាល់ជាមួយវាបាន ? តើធ្វើម៉េចអាចកៀងបព្វជិតនេះអោយចូលស៊ីង ? ធ្វើយ៉ាងម៉េចអ៊ីចេះបញ្ចុះហាងឆេងវាបានទំ ? រកមធ្យោបាយយ៉ាងណាអ៊ីចេះ ? មើល ! គិតអោយរហ័សមើល ! អ្អែងដឹងរឿងពួកយេស៊ូតច្រើនដែរតើ....

- លោកម្ចាស់ដៃមីញ៉ូមានប្រសាសន៍ថា ប្រញាប់ឆ្លើយនឹងសំនួររបស់លោកអោយភ្លាម១ឡើង ។

- បាទ ! បាទ ! សូមទោស ! ខ្ញុំឈ្មោះជន *ភ្លាក់ថន* ។ ខ្ញុំមានសញ្ជាតិអង់គ្លេស ជាមេកែកុងនៅក្នុងកងនាវាចរណ៍ហូឡង់ ។ ផែដើមរបស់សំពៅយើងគឺអាំស្ទែដាំ ។



www.budinst.gov.kh www.elibraryofcambodia.org

- កងនាវាចរណ៍ ? កងនាវាចរណ៍ណា ? អ្អែងកុហក ។ គ្មានកងនាវាចរណ៍ឯណាទេ ។ រួចវា យ៉ាងម៉េច បានជាជាតិអង់គ្លេសមកធ្វើតែកុងកប៉ាល់ហូឡង់ទៅវិញ ?

- ម្តងមួយ១ទាន ។ ឥឡូវនេះបកតែចំលើយខ្ញុំអំបាញ់មិញសិនទៅ !

- ហេតុអីបានជាអ្អែង មកធ្វើជាតែកុងសំពៅកកស៊ែហូឡង់អីចឹង ? និយាយអោយឆាប់ឡើង !

*ប៉ាក់ថន* សំរេចប្រថុយលេងមួយចានទឹកមួយចានគោកម្តងហើយ ។ គេបន្លឹងសំលេងគេភ្លាម ហើយសំលេងរបស់គេលាន់ឡើងកណ្តាលភាពក្តៅស្រទន់ នាពេលព្រឹកព្រហាម :

- វិបល់យក៏ ! បកចម្លើយអញនិយាយអំបាញ់មិញសិនទៅ អាស្ប៉ានីញ៉ោក [៣៣] ! បកភ្លាមទៅ !

ការអៀនខ្មាសធ្វើអោយមុខបព្វជិតឡើងក្រហម :

- អញសញ្ជាតិប៉ែកទុយកាល់ ។ អញប្រាប់អ្អែងពេលមុនហើយតើ ។ អីលូវឆ្លើយសំនួរអញសិនមក ។

- អញមកទីនេះ ដើម្បីនិយាយជាមួយ *ដៃមីញ៉ូ* មិនមែនជាមួយអ្អែងទេ ។ បករឿងអញនិយាយអម្បាញ់មិញសិនទៅ ។ អាកូនអត់ពូជ !

*ប៉ាក់ថន* ឃើញមុខរបស់បព្វជិតកាន់តែក្រហម ដោយការរសាប់រសល់ ហើយគេមានអារម្មណ៍ថា ទាំងអស់នេះ មិនបានកន្លងផុតពីក្រសែភ្នែករបស់ដៃមីញ៉ូឡើយ ។ ប្រយ័ត្នប្រយែងអាវ៉ា - គេណែនាំខ្លួនគេ ។ បើអ្អែងធ្វើហួសហេតុពេក ពួកអាកូនមីចោរស្បែកលឿងនេះ នឹងហែកអ្អែងជាចំរៀកជាងហ្វូងត្រីឆ្លាមទៀតអ្ហា !

- ជំរាបទៅលោកម្ចាស់ *ដៃមីញ៉ូ* ភ្លាមទៅ !

រួច *ប៉ាក់ថន* អោនខ្លួនយ៉ាងគោរពទៅរកវេទិកា ។ គេបែកញើសត្រជាក់ខ្លួនពេលដែលគេដឹងថា គេលេងមួយចានទឹកមួយចានគោកយ៉ាងនេះ ។

---

(៣៣) *ពួកជនជាតិអេស្ប៉ាញ*



www.budinst.gov.kh www.elibraryofcambodia.org

បព្វជិតសេបាស្សូរមែងជឿជាក់ថា ការអប់រំដែលខ្លួនទទួលបានច្បាស់ជាធ្វើអោយខ្លួន មិនញញើតនឹងការជេរប្រមាថរបស់ចោរសមុទ្រនេះ ក៏ដូចជាតទប់បាននឹងបំនងបំបាក់គេ នៅមុខ *ដៃមីញ៉ូ* ដ៏ច្បាស់ក្រលែតនេះជាមិនខាន ។ តែនេះជាលើកទីមួយហើយ ដែលគេមានអារម្មណ៍ ថា គេមិនអាចម្ចាស់ការលើខ្លួនឯងបាន ហេតុនេះហើយ ទើបគេចាប់ស្ងួនស្លោតែម្តង ។ នៅពេល ដែលនិរសារបស់ *ទូរ៉ា* បាននាំដំណឹងពីសំពៅទេវិហាររបស់គេ ដែលនៅខេត្តជិតនេះមក បព្វជិត សេបាស្សូសែនខ្វល់ខ្វាយនៅក្នុងចិត្ត ។ នេះមិនអាចជាសំពៅហូឡង់ រឺអង់គ្លេសទេ ! ។ គេគិត ថា នៅក្នុងមហាសាគរប៉ាស៊ីភិច មិនដែលមានសំពៅពួកទមិឡឡើយ លើកលែងតែសំពៅ របស់អាមហាឧត្បាតជ្រេកតែម្តងនោះ ហើយបើកន្លែងនេះវិញ គឺមិនដែលសោះតែម្តង ។ ផ្លូវ ចេញចូលមកទីនេះ គឺសំងាត់ណាស់ ហើយមានគេយាមទៀត ។ តែទោះជាយ៉ាងនេះក្តី ក៏បព្វ ជិតសេបាស្សូមុននឹងចេញដំណើរមកទីនេះ បានបញ្ជូនព្រាបនាំសារយ៉ាងលឿនមួយទៅ អ្នកដឹក នាំខាងលើរបស់ខ្លួននៅឯអូសាកា ដោយសង្ឃឹមថា គេនឹងបានពិគ្រោះជាមួយអ្នកដឹកនាំខ្លួនសិន ព្រោះគេដឹងថា គេនៅក្មេង ហើយរយៈពេលមកជប៉ុនទើបតែបាន ២ឆ្នាំ ហេតុនេះគេនៅមិន ទាន់ស្គាល់អស់ពីប្រទេសនេះ ម្យ៉ាងទៀតគេមិនទាន់បានបំបួសពេញសិទ្ធិ និងដឹងខ្លួនថា គេគ្មាន សមត្ថភាពដោះស្រាយរឿងសំខាន់ និងបន្ទាន់យ៉ាងនេះបានទេ ។ ពេលគេធ្វើដំណើរមក *អាន់ជីរ៉ូ* នេះ គេបានបួងសួងបន់ស្រន់ សូមអោយដំណឹងនោះជាការមិនពិតទៅចុះ ។ តែសំពៅដែលនៅ ទីនេះ ជាសំពៅហូឡង់ ឯតែកុងជាអង់គ្លេសទៅទៀត ។

រំពេចនោះ បព្វជិតសេបាស្សូ លឺ *ដៃមីញ៉ូ* និយាយមកកាន់គេ :

- បព្វជិត ! បកអោយខ្ញុំស្តាប់មើល អាចោរសមុទ្រនេះ វានិយាយរឿងអី ?

ឱព្រះមាតាអើយ ! សូមជួយខ្ញុំផង ។ ធ្វើកុំអោយខ្ញុំចាញ់ច្រាបមុខ *ដៃមីញ៉ូ* អោយ សោះ ហើយសូមអោយខ្ញុំរកពាក្យពេចន៍អោយឃើញ ។ ម្យ៉ាងទៀតសូមអោយខ្ញុំសំរេចនាំ *ដៃមីញ៉ូ* ដើរតាមផ្លូវធម៌ព្រះផងចុះ ។

បព្វជិតសេបាស្សូខំប្រមូលស្មារតី ហើយចាប់ផ្តើមនិយាយដោយទុកចិត្តខ្លួនឯងជាងមុន ។ *ប្លាក់ថន* ស្តាប់ដោយប្រុងប្រយ័ត្ន ដោយខំប្រឹងចាប់យកពាក្យ និង ន័យរបស់វា ។



www.budinst.gov.kh www.elibraryofcambodia.org

គេ លឺ សេបាស្ស៊ូប្រើពាក្យ " ប្រទេសអង់គ្លេស " និង " *ពួកថ់ន* " ហើយបព្វជិតនេះ ចង្អុលទៅសំពៅដែលបោះយុថ្កាយោលយោកយ៉ាងសង្ហានៅឯកំពង់ផែ ។

- អ្នកឯងធ្វើម៉េចបានមកដល់ទីនេះបាន ? - បព្វជិតសួរ ។

- មកតាមច្រកសមុទ្រម៉ាសេឡង់ ។ ចំងាយពីនេះ មានមួយរយសាមសិបប្រាំមួយថ្ងៃ ។ សូមជំរាបទៅលោកម្ចាស់ *ដេមីញ៉ូ*.....

- អ្អែងកុហក ។ ច្រកម៉ាសេឡង់ គឺជាច្រកសំងាត់ ។អ្អែងមកតាមអាព្រិច និង ឥណ្ឌាទេ ។ យកល្អអ្អែងត្រូវនិយាយរឿងពិតទៅ ។ នៅទីនេះ គេធ្វើទារុណកម្មដើម្បីសួរចំលើយណាំ !

- ច្រកនេះ វាសំងាត់កាលពីមុន ។ ប៉ុកទុយកាល់ម្នាក់លក់កូនសៀវភៅមកអោយយើង ។ ជាសញ្ជាតិអ្អែងហ្នឹងណាំ ដែលលក់ពួកអ្អែង ដើម្បីមាសបន្តិចបន្តួចនោះ ។ ពួកអ្អែងចោកទាបតែអីចឹង ។ អីលូវនេះ សំពៅចំបាំងអង់គ្លេស និងសំពៅចំបាំងហូឡង់ទាំងអស់ ស្គាល់ផ្លូវចូលមកប៉ាស៊ីភិចតែទាំងអស់ហ្នឹង ។ រូចអញប្រាប់ហើយថា នេះគឺជាកងនាវាចរណ៍ គឺសំពៅប្រយុទ្ធអង់គ្លេសចំនួន ២០គ្រឿង ហើយមាំគ្រឿងមាន ៦០កាណុង កំពុងវៃម៉ានីលហើយ ។ ចក្រភពរបស់អ្អែងដល់ថ្ងៃអន្សាហើយ ។

-អ្អែងកុហក !

អើអញកុហកមែន ! *ពួកថ់ន* គិតក្នុងចិត្ត ។ តែអ្អែងធ្វើម៉េចដឹងថា អញកុហកបាន ។ ទាល់តែអ្អែងទៅម៉ានីល ។

-កងនាវាចរណ៍នេះ នឹងតាមកំទេចនាវាចរណ៍ពួកអ្អែង ហើយអាណានិគមរបស់ពួកអ្អែងត្រូវតែរលាយអីចឹង ។ ប៉ុន្មានអាទិត្យទៀត កងនាវាចរណ៍ហូឡង់ និងមកដល់ទីនេះដែរ ។ អាស្មោកគ្រោកអេស្ប៉ាញ ប៉កទុយកាល់ត្រូវតែបោលចូលក្រោលវិញហើយអ្អាំ !

- ឱព្រះអើយ ព្រះ សូមដាក់បណ្តាសាអាមាត់សំអុយនេះផងទៅចុះ !

*ដេមីញ៉ូ* គំហកកាត់ពួកគេទាំងមូម៉ៅ ។ បព្វជិតសេបាស្ស៊ូក៏ចាប់និយាយញាប់ជាងមុនក្នុងសំលេងតឹងជាងមុន ។ *ពួកថ់ន* លឺគេប្រើពាក្យ " ម៉ាសេឡង់ " និង " ម៉ានីល " ប៉ុន្តែគេយល់ថា *ដេមីញ៉ូ* និងភូឈួយរបស់គេទាំងប៉ុន្មាននាក់នេះ បែបមិនសូវយល់ច្បាស់ប៉ុន្មានទេ ។



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៉ូ* ធុញទ្រាន់នឹងការសួរចំលើយបែបនេះណាស់ ។ គេសំលឹងមើលទៅកំពង់ផែ មើលទៅសំពៅដែលតាមលងអារម្មណ៍គេជាប់ តាំងពីទទួលបានសាររបស់អូមីម្ល៉េះ ហើយគេរំមែងដណ្ដឹងសួរថា ប្រហែលជារបស់នេះទេដឹង ដែលគេតែងបន់ស្រន់ សូមអោយព្រះបញ្ជូនក្ដីសង្ឃឹមមួយមកអោយគេនោះ ?

- អ្អែងមានបានទៅពិនិត្យអីវ៉ែអីវ៉ាន់ហើយរឺនៅ *អូមី-សាន ?*

នេះជាសំនួរ ដែល *យ៉ាប៉ូ* បានសួរពេលព្រឹកមិញនេះ នៅពេលគេមកដល់ភ្លាម ទាំងខ្លួនប្រាណនៅប្រលាក់អក់ស្រមក និងពោរពេញដោយការហត់នឿយនោះ ។

- អត់ទេលោកម្ចាស់ ! ខ្ញុំបាទគិតថា ល្អបំផុតគឺភ្ជិតសំពៅ ហើយរង់ចាំលោកម្ចាស់អញ្ជើញមកផ្ទាល់ខ្លួនតែម្តង តែសំពៅនេះ ពេញដោយកែសនិងកញ្ចប់ ។ ខ្ញុំបាទគិតថា ធ្វើអីចឹងវាត្រឹមត្រូវជាង ។ នេះគឺជាសោរបស់ពួកវា ។ ខ្ញុំបាទបានដកហូតទុកទាន ។

- ល្អ !

*យ៉ាប៉ូ* បានធ្វើដំណើរមកតាំងពីយេដូ ជាទីក្រុងរបស់ *តូរ៉ាណាកា* ដែលនៅចំងាយរាប់ពាន់ម៉ៃពីនេះ ។ គេបានចេញដំណើរយ៉ាងប្រញាប់ប្រញាល់ជាសំងាត់ ហើយដោយយ៉ាងប្រថុយស្បែកជាទីបំផុត ។ គឺជាការសំខាន់ណាស់ ដែលគេត្រូវរូតរះត្រលប់ទៅវិញ ។ ការធ្វើដំណើរត្រូវស៊ីពេលពីរថ្ងៃ នៅលើផ្លូវដ៏យ៉ាប់យ៉ឺន ហើយគេត្រូវថែមទាំងឆ្លងស្ទឹង ដែលមានទឹកកំពុងជន់ជោរថែមទៀត ។ ជួនកាលគេត្រូវប្រើសេះ ជួនកាលគេត្រូវប្រើស្នែង ។

- អញត្រូវទៅមើលសំពៅភ្លាម

- លោកម្ចាស់គួរទៅមើលពួកបរទេសសិនទៅ - *អូមី* និយាយទៅលោកម្ចាស់គេបណ្ដើរសើចបណ្ដើរ -ពួកអាអស់នេះ អស់យ៉ាងហើយ ។ ពួកវាភាគច្រើនសុទ្ធតែមានភ្នែកខៀវដូចភ្នែកឆ្មាអីចឹង ។ ហើយសក់ពួកវាពណ៌មាសថែមទៀត ។ តែស្អីដែលអស្ចារ្យមែនទែននោះគឺពួកវាជាចោរសមុទ្រណាលោកម្ចាស់.....

រួច *អូមី* ក៏បាននិយាយពីរឿងបព្វជិត ហើយនឹងអ្វីៗដែលបព្វជិតនោះនិយាយពីពួកកកស៊ែ ។ គេក៏បាននិយាយពីសំដី ដែលកកស៊ែតប និងអ្វីដែលបានកើតឡើងបន្ថែមទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៊ូ* មានអារម្មណ៍ថា ចិត្តចង់ដឹងកាន់តែឡើងមួយជាបី ។

*យ៉ាប៊ូ* ខំរំងាប់អារម្មណ៍ជ្រួលចង់ទៅមើលសំពៅនោះ ហើយគេក៏ទៅមុជទឹកផ្លាស់ប្តូរខោអាវ និង បន្ទាប់មកទើបគេចេញបញ្ជាអោយនាំពួកចុងស្រុក ទាំងប៉ុន្មានមកអោយគេ ។

- នែបព្វជិត !- *យ៉ាប៊ូ* និយាយយ៉ាងតឹងសំលេង ដោយគេពិបាកយល់ភាសាជប៉ុនដូចឆ្មាចូលព្រៃលោករបស់សេបាស្ទ-ហេតុអ្វីបានជាអាចោរសមុទ្រនេះវាខឹងជាមួយលោកឯងម្ល៉េះ ?

- វាជាបិសាច ។ វាជាចោរសមុទ្រ ។ វាគោរពខ្មោចព្រាយបិសាច ។

*យ៉ាប៊ូ* អោនទៅរក *អូមី* ដែលលុតជង្គង់នៅខាងឆ្វេងដៃរបស់ខ្លួន :

-ក្មួយឯងយល់ថា វាចង់និយាយពីអ្វីទេ ? វានិយាយកុហកមែនអ្វី ? រួចក្មួយឯងយល់យ៉ាងណាដែរ ?

- ខ្ញុំបាទមិនដឹងដែរ លោកម្ចាស់ ។ អ្នកណាទៅដឹងថា ពួកចុងស្រុកវាជឿអី ? ខ្ញុំគិតថា បព្វជិតយល់ថា ពួកចោរសមុទ្រជាពួកគោរពព្រាយបិសាច ។ ពិតមែន តាមពិត ទៅគ្មានន័យអីទាំងអស់ហ្នឹង ។

*យ៉ាប៊ូ* ងាកទៅរកបព្វជិតវិញម្តង ។ គេស្អប់បព្វជិតនេះណាស់ ។ គេបន់អោយតែបានឆ្កាងបព្វជិតនេះភ្លាម១អីលូវនេះ ហើយនិងរំលាយគ្រិស្តសាសនាអោយចេញផុតពីតំបន់ដែលគេគ្រួតត្រានេះ ជារៀងរហូតតែម្តង ។ ប៉ុន្តែគេមិនអាចធ្វើអ្វីចឹងទៅបានឡើយ ។ ថ្វីត្បិតតែរូបគេ និង *ដៃមីញ៉ូ* ឯទៀតទាំងអស់ មានអំនាចពេញលេញ នៅក្នុងតំបន់របស់ខ្លួនក្តី ពួកគេក៏ត្រូវតែគោរពអំនាចកំពូលនៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ដែលជាក្រុមមេទ័ពកាន់អំនាចបច្ចុប្បន្ន ហើយដែលអម្ចាស់តៃកូបានផ្ទេរសិទ្ធិអំនាចរបស់លោកទៅអោយ ក្នុងពេលដែលកូនរបស់គាត់មិនទាន់ពេញវ័យ ។ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនេះទៀតសោតក៏ត្រូវគោរពតាមបញ្ញត្តិរបស់អម្ចាស់ *តៃកូ* ដែលបានសំរេចឡើង នៅក្នុងពេលដែលលោកនៅកាន់អំនាច ហើយដែលឥឡូវនេះ នៅតែមានប្រសិទ្ធភាពក្នុងការអនុវត្តន៍នៅឡើយ ។ នៅក្នុងចំនោមបញ្ញត្តិទាំងនេះ មានបញ្ញត្តិមួយដែលត្រូវបានអនុម័តកាលពីប៉ុន្មានឆ្នាំមុននេះ ជាមួយពួកចុងស្រុកប៉ែកទុយកាល់ដែលបានកំនត់ចាត់ទុកពួកនេះ ជាមនុស្សដែលទទួលបានការគាំពារ ហើយក្នុងគិតសមស្របសាសនារបស់ពួក



www.budinst.gov.kh www.elibraryofcambodia.org

នេះ ត្រូវបានយល់ព្រមអោយមាន ឯពួកបព្វជិតទទួលបានការអនុញ្ញាតអោយផ្សព្វផ្សាយធម៌ និងបំបួសមនុស្ស ។

- នែបព្វជិត ! រូចអាចោរសមុទ្រនេះ និយាយថាម៉េចទៀត ? រូចវានិយាយស្អី អោយអែង ? ឆាប់ឡើងមើល ! ដាច់អណ្តាតហើយទេអ្វី ?

- អាចោរសមុទ្រនិយាយរឿងអាក្រក់ ។ អាក្រក់ ។ ថាមានពួកចោរកំពុងធ្វើចំបាំងសំពៅនេះច្រើនទៀត- ច្រើន១ ។

- មានន័យថាម៉េច " ធ្វើចំបាំងសំពៅ " ហ្នឹង ?

- សូមទោសលោកម្ចាស់ ។ ខ្ញុំអត់យល់ ។

- " ចំបាំងសំពៅ " អត់មានន័យទេ

- អូអីចឹងទេ ! អាចោរសមុទ្រថា មានសំពៅចំបាំងច្រើនទៀត នៅឯម៉ានីលប្រទេសភីលីពីនទាន ។

- *អូទី- សាន* ! អែ្នងយល់ថា វាចង់និយាយពីរឿងអីហ្នឹង ?

- អត់ទេលោកម្ចាស់ ! សំលេងវានិយាយស្តាប់មិនយល់ទេទាន ។ ឆ្លាមួលត្រលោកសុទ្ធតែម្តងទាន ។ ក្រែងវាថាមានសំពៅពួកចោរសមុទ្រច្រើនទៀតនៅទិសខាងកើតប្រទេសជប៉ុននេះទេដឹង ?

- នែបព្វជិត ! សំពៅពួកចោរសមុទ្រទាំងនោះ នៅឯនាយសមុទ្រហ្នឹងអ្វី ? នៅទិសខាងកើតហ្នឹងមែនទេ ?

- បាទលោកម្ចាស់ ។ តែខ្ញុំគិតថា វានិយាយកុហកទេ ។ វាថានៅម៉ានីល ។

- ខ្ញុំស្តាប់មិនយល់ទេ ។ ម៉ានីលនៅឯណា ?

- បាទនៅខាងកើត ។ ធ្វើដំណើរច្រើនថ្ងៃ ។

- អោយតែមានសំពៅចោរសមុទ្រណាមួយ មកដល់ទីនេះអញនឹងស្វាគមន៍អោយឆ្អែតម្តង ចង់ម៉ានីលហ្នឹងនៅក្រហែងមេឃណាក៏ដោយ ។

- សូមទោសលោកម្ចាស់ខ្ញុំស្តាប់មិនឈប់ទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- អ្ហាស ! មិនអីទេ !

*យ៉ាប៊ូ* ឆ្លើយតប ។ ខន្តីរបស់គេបានដល់ចុងបញ្ចប់ហើយ ។ គេបានសំរេចជាស្រេចថា ពួកបរទេសទាំងនេះ ត្រូវតែសំលាប់ចោល ។ គេជញ្ជាក់មាត់ជាស្រេចចំពោះប្រការនេះ ។ ជាការពិតហើយ ពួកនេះមិនត្រូវបានរាប់ចូលក្នុងបញ្ញត្តិរបស់អម្ចាស់ *តៃកូ* ដែលបញ្ជាក់ច្បាស់ថា " ពួកចុងស្រុកប៉កទុយកាល់ " តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ទោះជាយ៉ាងណាក្តី ក៏ពួកគេជាចោរសមុទ្រតែប៉ុណ្ណោះ ។ តាំងពីណាពីណីមក យ៉ាប៊ូ ស្អប់ពួកចុងស្រុកនេះណាស់ តាំងពីក្លិនអសោចិ៍ ភាពកខ្វក់ ទំលាប់ស៊ីចុកគួរអោយខ្ពើម សាសនាចំកួតលេលា ភាពក្រអឺតក្រទមរហូតដល់រឹកពារគួរអោយស្អប់ខ្ពើមរបស់ពួកគេ ។ លើសពីនេះទៅទៀត គេក៏ដូចជា *ដៃមីញ៉ូ* ទាំងអស់គ្នាដែរ គេសែនខ្មាសដែលពួកនេះ ជាន់ឈ្លីទឹកដីរបស់ព្រះយ៉ាងនេះ ។ ស្ថានភាពសង្គ្រាមរវាងប្រទេសចិន នឹងជប៉ុនបានកើតមានឡើងរាប់សតវត្សរ៍មកហើយ ។ ចិនមិនអនុញ្ញាតអោយមានពាណិជកម្មរវាងប្រទេសទាំងពីរនេះឡើយ ។ តែក្រណាត់សូត្រចិន គឺសំខាន់ ដើម្បីកាត់ចេញជាអាវវែងដ៏ក្តៅ និងដ៏ត្រជាក់នៃអាវជប៉ុនសំរាប់រដូវក្តៅ ។ ជាច្រើនតំនមកហើយ គឺមានតែក្រណាត់មួយចំនួនតូចប៉ុណ្ណោះដែលបានរត់ពន្ធឆ្លងរួចសំនាញ់ហាមឃាត់មកដល់ជប៉ុន ហើយក្នុងថ្លៃដ៏សែនខ្ពស់កប់ពពក ។ តែកាលពីប្រហែល ៦០ឆ្នាំមុននេះ ពួកចុងស្រុកបានមកដល់ជាលើកទីមួយ ។ អធិរាជចិនដែលនៅប៉េកាំងបានយល់ព្រមអោយមូលដ្ឋានអចិន្ត្រៃយ៍ដ៏តូចមួយនៅឯម៉ាកាវ នៅភាគខាងត្បូងប្រទេសចិនដល់ពួកវា ហើយព្រះអង្គបានយល់ព្រមដូរជាមួយគ្រឿងប្រាក់ ។ ជប៉ុនមានរ៉ែប្រាក់ដ៏សំបូរហូរហៀរ ។ តែក្នុងមួយរយៈពេលយ៉ាងខ្លីពាណិជ្ជកម្មមានសកម្មភាពខ្លាំងក្លាមែនទែន ។ ពួកប៉កទុយកាល់ដែលជាកូកជេក្នុងរឿងនេះ ក៏មានបានយ៉ាងសំបើម ។ ដល់អីចឹងទៅពួកបព្វជិតប៉កទុយកាល់ដែលភាគច្រើនជាពួកយេស៊ូតនោះ ក៏ក្លាយជាមានតួនាទីមួយយ៉ាងសំខាន់ក្នុងពាណិជ្ជកម្មនេះ ។ មានតែពួកបព្វជិតនេះទេ ដែលចេះនិយាយភាសាចិន និង ជប៉ុន ដោយហេតុនេះហើយ ទើបមានតែពួកបព្វជិតនោះទេ ដែលអាចជួយចរចា និងជួយបកប្រែបាន ។ ពេលដែលការដូរញដូរកាន់តែរីកចំរើនពួក បព្វជិតក៏កាន់តែសំខាន់ឡើង ។ អីលូវនេះ របរដូរញដូររៀងរាល់ឆ្នាំនេះផុលផុសមែនទែនហើយ សំរួលដល់ជីវិត



www.budinst.gov.kh www.elibraryofcambodia.org

រស់នៅរបស់ពួក *សាមូរ៉ៃ* គ្រប់ៗគ្នា ។ ព្រោះហេតុនេះ ពួកបព្វជិតត្រូវគេអនុគ្រោះសាសនា របស់គេក៏ត្រូវបានអនុគ្រោះ ព្រោះបើមិនអ៊ីចឹងទេ ពួកចុងស្រុកទាំងនេះ ចុះសំពៅចេញទៅវិញ ហើយការជួញដូរច្បាស់ជាចប់តែម្តង ។

មកដល់បច្ចុប្បន្ននេះ មាន *វ៉ៃមីញ៉ូ* ច្រើនគួរសមដែលជាគ្រិស្តសាសនិក ហើយអ្នកធម្មតាដែលបានទទួលយកសាសនានេះ មានរហូតដល់រាប់សែនទៅហើយ ។ ពួកនេះភាគច្រើនៗ នៅតំបន់ក្យូស៊ូ ដែលជាកោះខាងត្បូងជិតជាងគេបំផុត ទៅនឹងប្រទេសចិន ហើយដែលមានកំពង់ផែរបស់ពួក ប៉ុកទុយកាល់ មួយនៅណាកាសាគីនោះ ។ ពិតមែនតែយើងត្រូវអនុគ្រោះពួកបព្វជិតនិងពួកប៉ុកទុយកាល់-*យ៉ាប៊ូ* គិតនៅក្នុងចិត្ត-តែយើងគ្មានចាំអនុគ្រោះពួកចុងស្រុកចំនួលថ្មីទាំងនេះទេ ។ ចិត្តរំភើបរត់សស្រិបពេញខ្លួនប្រាណគេ ។ អីលូវនេះ គេមានឱកាសបំពេញការចង់ដឹងរបស់គេដែលថា តើពួកចុងស្រុកទាំងនេះ ស្លាប់របៀបម៉េច បើគេធ្វើទារុណកម្មទៅលើនោះ ។ គេមានមនុស្សដប់មួយនាក់ នៅក្នុងកណ្តាប់ដៃរបស់គេ ។ នេះគឺការសាកល្បងដប់មួយបែប ជាពិសោធន៍ដប់មួយធី ។ គេមិនដែលផល្គឹងសួរខ្លួនគេទេថា ហេតុអ្វីបានជាភាពព្រងវខ្យល់របស់អ្នកឯទៀត ធ្វើអោយគេសប្បាយចិត្តនោះ ។ គេដឹងតែម្យ៉ាង គឺថាទិដ្ឋភាពនេះ ធ្វើអោយគេសប្បាយរីករាយហើយ នេះគឺគ្រប់គ្រាន់ក្នុងការស្វែងរក និងសប្បាយចំពោះភាពព្រងវខ្យល់របស់មនុស្សនោះ ។

*យ៉ាប៊ូ* និយាយឡើង :

- សំពៅនេះ ជាសំពៅក្រៅ មិនមែនជារបស់ប៉ុកទុយកាល់ ហើយជាសំពៅចោរសមុទ្រ ។ ត្រូវតែរឹបអូសយកទាំងសំពៅ ទាំងរបស់របរដែលមាននៅក្នុងសំពៅ ។ ពួកចោរសមុទ្រទាំងអស់ ត្រូវកាត់ទោសអោយយកជាបន្ទាន់ទៅ......

មាត់របស់ *យ៉ាប៊ូ* នៅចំហាឆ្ងងដោយភាពស្រលាំងកាំង នៅពេលដែលគេឃើញមេក្រុមចោរសមុទ្រស្ទុះទៅរកបព្វជិត ហើយកន្ត្រាក់យករូបឆ្កាងឈើពីចង្កេះមក កាច់ខ្ទេចខ្ទីរួចទើបបោះចោលទៅលើដី រួចហើយបុរសនេះ ក៏ស្រែកនិយាយអ្វីយ៉ាងខ្លាំង ។ នៅពេលដែលពួកអ្នកយាមហក់ទៅដោយយារដាវយ៉ាងខ្ពស់ តំរង់រកគេនោះ បុរសនោះក៏លុតជង្គង់យ៉ាងរហ័ស



www.budinst.gov.kh www.elibraryofcambodia.org

ហើយលំអោនខ្លួនយ៉ាងទាបទៅរក *យ៉ាប៊ូ* ។

- ឈប់សិន ! កុំសំលាប់វា !

*យ៉ាប៊ូ* សែនភាន់ភាំងដោយមិនដែលមាននរណាព្រហើន ហ៊ានមានកាយវិការច្រឡោមខាមបែបនេះ នៅចំពោះមុខខ្លួនឡើយ ។

- យី ! ពួកអាចុងស្រុកទាំងនេះ ស្មានមិនត្រូវតែម្តង !

- ពិតមែនហើយលោកម្ចាស់ !

*អូមី* ឆ្លើយតប ។ នៅក្នុងខួរក្បាលរបស់គេ១ កំពុងគិតពីផលវិបាកនៃទង្វើនេះ ។

បព្វជិតនៅតែអង្គុយលុតជង្គង់ដដែល ។ ភ្នែករបស់គេសំលឹងជាប់ទៅរូបឆ្លាក់ ដែលបែកបាក់នោះ ។ ទាំងអស់គ្នា សំលឹងមើលបព្វជិតដែលលូកដៃទាំងញ័រទទ្រើតទៅរកឈើពិសិដ្ឋដែលត្រូវគេប្រមាថនេះ ។ បព្វជិតនិយាយទៅរកចោរសមុទ្រក្នុងសំលេងយ៉ាងទាប ស៊ីងថាយ៉ាងថ្នមផង ។ ភ្នែករបស់បព្វជិតបិទជិតឈឹង ហើយបបូរមាត់កំរើកយឺត១ ចំណែកឯមេពួកចោរសមុទ្រវិញ សំលឹងមើលកាយវិការទាំងនេះ ដោយគ្មានចិត្តរំភើបញ្ញាប់ញ័រអ្វីទាំងអស់ ។

*យ៉ាប៊ូ* និយាយ :

- *អូមី -សាន* ។ ដំបូងខ្ញុំចង់ទៅសំពៅសិន ។ បន្ទាប់មកចាំយើងចាប់ផ្តើម ។

រួចសំលេងគេក្លាយជាយឺត១ ក្នុងពេលដែលគេស្រមៃគិតដល់ការសប្បាយ ដែលគេបានត្រៀមរៀបចំទុកនោះ :

- ខ្ញុំចង់ចាប់ផ្តើមពីអាមួយដែលមានសក់ក្រហម ដែលនៅចុងគេបំផុតនោះ គឺអាមួយរាងទាបនោះ ឃើញទេ ?

*អូមី* ឈ្ងោកទៅជិត ហើយបន្ទាបសំលេង :

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំបាទទាន ។ ប៉ុន្តែរឿងបែបនេះ មិនដែលកើតមានសោះហើយ លោកម្ចាស់ ។ គឺមិនដែលមានតាំងពីពួកប៉ុកទុយកាល់មកដល់កន្លែងនេះម្ល៉េះ ។ មិនគឺព្រះឆ្លាងនេះ ហើយដែលជានិមិត្តរូបពិសិដ្ឋរបស់ពួកវានោះ ? មិនពួកវាជានិច្ចកាល គោរពបព្វជិតពួកវា ? ពួកវាតែងតែលុតជង្គង់មុខ បព្វជិត វាជាចំហទេតើ ? ដូចតែពួកគ្រិស្តសាសនិក



www.budinst.gov.kh www.elibraryofcambodia.org

ផងប៉ុនយើងដែរ តើមែនទេ ? មិនគឺពួកបច្ចជិតទាំងហ្នឹងហើយ ដែលមានអំនាចទាំងស្រុងលើពួកវានោះ ?

- កុំបាច់វាងច្រើន និយាយមើលក្អែងមានគំនិតយ៉ាងម៉េច ?

- ពួកយើងទាំងអស់គ្នា សុទ្ធតែស្អប់ពួកបកិទុយកាល់ទាន ។ លើកលែងតែពួកយើងដែលជាគ្រិស្តសាសនិកចេញទេ ? អ៊ីចឹងហើយ មើលទៅពួកអាចុងស្រុកទាំងនេះ នៅរស់ប្រហែលជាមានផលប្រយោជន៍ដល់យើងច្រើនជាងស្លាប់ ។

- មានប្រយោជន៍យ៉ាងម៉េច ?

- ពីព្រោះពួកវាខុសគេ ។ ពួកវាប្រឆាំងពួកគ្រិស្តសាសនិក ! មនុស្សវាងវៃប្រហែលអាចរកឃើញវិធីមួយ ដើម្បីប្រើចិត្តសំអប់ វិចិត្តមិនជំនឿរបស់ពួកវា ដើម្បីបំរើយើងបានណាលោកម្ចាស់ ។ ពួកវាគឺជាកម្មសិទ្ធិរបស់លោកម្ចាស់ សំរាប់លោកម្ចាស់ប្រើតាមចិត្តចង់របស់លោកម្ចាស់ ។

ពិតមែនហើយ ។ ហើយអញចង់អោយពួកវាភ្លក់ទារុណកម្ម-*យ៉ាប៉ូ* គិតនៅក្នុងចិត្ត ។ ប៉ុន្តែមែនវ៉ី ! អារឿងហ្នឹងអញចង់សប្បាយនៅពេលណាក៏បានដែរ ។ ត្រូវស្តាប់ *អូមី* ដែរ ។ វាជាទីប្រឹក្សាមួយយ៉ាងល្អ ។ តែពេលនេះ គួរទុកចិត្តវាទេ ? តើវាមានមូលហេតុសំងាត់អីមួយទេ អ្វីបានជាវានិយាយអ៊ីចឹង ។ ត្រូវគិតពិចារណា ។

- *អ៊ិកាវ៉ា ស៊ីគីយូ* គឺជាគ្រិស្តសាសនិកលោកម្ចាស់ - ក្មួយ *យ៉ាប៉ូ* និយាយបន្តដោយលើកឡើងពីសត្រូវដែលគេស្អប់ ហើយដែលត្រូវជាសាច់ញាតិ និងជាសម្ព័ន្ធមិត្តរបស់ *អ៊ិស៊ីដូ* និងដែលមានតំបន់ជាប់នឹងភាគខាងលិច នៃតំបន់របស់គេនោះ - មិនគឺ បច្ចជិតគ្រិចនេះ មានកន្លែង សំនាក់របស់វានៅទីនោះអ្វីលោកម្ចាស់ ? អាចអាពួកចុងស្រុកទាំងនេះ អាចជួយលោកម្ចាស់រកឃើញវិធីដែលអាចអោយលោកម្ចាស់ក្តាប់ខេត្ត របស់អ៊ីកាវ៉ាទាំងមូលបានណា ! រួចអាចទាំងខេត្តរបស់អ៊ីស៊ីដូទៀតផង រួចជូនកាលទាំងតំបន់របស់លោកម្ចាស់ *តូរ៉ាណាកា* ទៀតផងទាន ។

*អូមី* និយាយបន្ថែមពាក្យចុងក្រោយនេះយ៉ាងថ្នមៗ ។



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៊ូ* តាមដានទឹកមុខរបស់អូមី ដើម្បីស្វែងឈោងរកអ្វីដែលនៅពីក្រោយ ទឹកមុខនេះ ។ រួចបន្ទាប់មកគេបានរវើកទៅរកសំពៅវិញម្តង ។ អីលូវនេះគេគ្មានការសង្ស័យអ្វីទៀតឡើយ សំពៅនេះ គឺពិតជាព្រះបញ្ជូនអោយគេមែនហើយ ។ ពិតជាបញ្ជូនមកអោយគេមែន ។ តែបញ្ជូនមកជាអំនោយ រឺជាបណ្តាសា ?

គេសំរេចលើកដាក់ទៅម្ខាង នូវចំនួលចិត្តផ្ទាល់ខ្លួនគេ ដើម្បីគិតគូរពីសន្តិសុខ របស់ក្រុមគេវិញម្តង ។

- យល់ព្រមហើយ ។តែដំបូងបង្អស់ ត្រូវបំបាក់ពួកចោរសមុទ្រទាំងនេះសិន ។ បង្រៀនពួកវាអោយចេះច្បាប់ ចេះទំលាប់ ពិសេសអាមួយនោះ ។

☆ ☆ ☆

- ឱព្រះយេស៊ូអើយ ! -វិញផ្ទូរ

- ពួកយើងគួរស្ងួត្រចមិទៅ - *ភ៌ន់ណេិច* និយាយ ។

- យើងទើបស្ងួត្រអំចាញ់មិញហើយហ្នឹង ។

- ស្ងួព្រម្តងទៀតទៅវាកាន់តែល្អថែមទៀតទៅហើយ ។ ឱព្រះដ៏មានឫទ្ធិអើយអោយខ្ញុំព្រះអង្គបានស្រោម៉ាចឹបមកលោក ។

ពួកគេត្រូវញាត់បញ្ចូលទៅក្នុងអន្លង់ដ៏ជ្រៅមួយ ។ នេះជាអន្លង់មួយក្នុងចំនោមអន្លង់នានាជាច្រើន ដែលអ្នកនេសាទតែងស្តុកត្រីហាលរបស់គេ ។ ពួក *សាមូរ៉ៃ* បានកៀងប្រមូលពួកគេពីកន្លែងប្រជុំដូចជាហ្វូងសត្វ ហើយដាក់ជណ្តើរអោយពួកគេចុះ រួចចាក់សោឃុំពួកគេនៅក្រោមដីនេះបណ្តោយ ។ អន្លង់នេះ បណ្តោយប្រហែល ៥ម៉ែត ១ទឹង ៣ម៉ែត និង ជំរៅ ៤ម៉ែត ។ នៅក្រោមជើង និងជុំវិញពួកគេ គឺជាដីសុទ្ធ ។ ដំបូល គឺជាក្តារគ្របដោយដីកំរាស់ប្រហែលមួយហត្ថ ។ ច្រកមួយដែលបិទបើកដោយក្តារបន្ទះ សំរាប់អោយគេចេញចូលអន្លង់នេះបាន ។

- កុំជាន់ជើងអាស្វា !

- ថ្លង់ណាស់អាអាច់ ! -*ពីតែស៊ីន* តប - អ្ហេ ! អា *វិញ* ! ខិតបន្តិចមើលអ្ហា ! យីអាក្រហុបនេះ ! រួចអ្ហែងយកកន្លែងអីក៏ច្រើនជាងគេម្ល៉េះ ?



www.budinst.gov.kh www.elibraryofcambodia.org

- អញ្ជើរខិតទៅណា ក៏មិនរួចដែរ អាពីថៃស៊ូន បើវាណែនដូចកន្ទុំទៅហើយនោះ ។

- គឺមេបញ្ជាការទេ គាត់យកកន្លែងអស់រលីងហើយហ្នឹង ។ រុញគាត់បន្តិចមើល ! ជាស់គាត់តែម្តងទៅ - *ម៉ែស៊ូតែ* និយាយ ។

- នែ ! វាយ៉ាងម៉េចហ្នឹង ? កុំរំខានអញណា ! អញឈឺណាំ ! អញត្រូវការទំរេតខ្លួន អញអង្គុយមិនកើតទេ ! រួចចុះពួកយើងនៅកន្លែងណាហ្នឹង ?

- នែ ! កុំរំខានគាត់ , មិនឃើញគាត់ឈឺទេអ្ហី ? មកម៉ែស៊ូតែស្តាប់អញអាភឿន ។

វិញទាញកន្ត្រាក់ ម៉ែស៊ូតែទាំងកំហឹង ហើយរុញគេផ្ទប់ទៅនឹងជញ្ជាំង ។ អន្លង់ដ៏តូចចង្អៀតនេះ មិនអាចអោយពួកគេទំរេតខ្លួនបានទាំងអស់គ្នាឡើយ គ្រាន់តែអង្គុយអោយបានទាំងអស់ ដោយស្រួលក៏មិនបានផង ។ លោកមេបញ្ជាការប៉ូលូសស្តីលបែគីន ដេកស្តូកស្តឹងនៅចំពីក្រោមក្តារឃ្នុប ដែលជាកន្លែងមានខ្យល់ចេញចូលស្រួលល្អ ជាងគេបំផុតនោះ ។ អាវក្រៅរបស់លោកត្រូវគេមូរជាដុំ ដើម្បីធ្វើជាកំនើយក្បាលរបស់លោក ។ *ភ្លាក់ថុន* ឈរផ្អែកទៅនឹងក្បែរម្ខាង ភ្នែកគេសំលឹងទៅរកបន្ទះឃ្នុបនោះ ។ អ្នកឯទៀតប្រឹងឈរឆ្ងាយពីគេ តាមដែលអាចធ្វើបាន ព្រោះម្នាក់ៗ សុទ្ធតែធ្លាប់ភ្លក់ហើយថា នៅក្រោមភាពស្ងៀមស្ងាត់ខាងក្រៅនេះ គឺជាភ្នំភ្លើងមួយដែលកំពុងពុះគគ្រុក ។

ពេលត្រូវរុញផ្ទប់ជញ្ជាំង *ម៉ែស៊ូតែ* អត់លែងបាន ។ គេក៏ងាកមកដាល់ចំមុខវិញ :

-កុំរំខានអញណាំ ! បើថាមិនស្តាប់ទេ ប្រយ័ត្នទៅស្រុកខ្មោច ! លឺទេអាកូនអត់ពូជ ?

*វិញ* ស្ទុះហក់ទៅរកម៉ែស៊ូតែ តែ *ភ្លាក់ថុន* ច្បាមចាប់អ្នកទាំងពីរជាប់ ហើយរុញក្បាលពួកគេបោកផ្ទប់ជញ្ជាំង :

- ពួកអ្ហែងទាំងអស់គ្នា ស្ងាត់មាត់លឺទេ ?

គេនិយាយយ៉ាងនឹងនរ ។ ទាំងអស់នៅស្ងៀមតាមពាក្យបញ្ជារបស់គេ ។

- ពួកយើងត្រូវចែកវេនម្តងម្នាក់ ។ មួយក្រុមដេក មួយក្រុមអង្គុយ មួយក្រុមទៀតឈរហើយយាម ។ *ស្តីលបែគីន* ដេករហូតដល់គាត់បានស្រួលខ្លួនឡើងវិញ ។ ជ្រុងម្ខាងនេះសំរាប់បត់ដៃបត់ជើង ។



www.budinst.gov.kh www.elibraryofcambodia.org

រួច *ប្លាក់ថន* ចាប់ផ្ដើមបែងចែកក្រុម ។ បរិយាកាសមានលក្ខណៈប្រសើរជាងមុន នៅពេលណាដែលមនុស្សត្រូវបានរៀបចំជាក្រុមហើយ ។

*ប្លាក់ថន* គិតនៅក្នុងចិត្តគេថា គេត្រូវតែចេញអោយផុតពីកន្លែងនេះអោយបានឆាប់រហ័ស ។ នៅកាន់តែយូរពេលណាពួកគេនឹងកាន់តែចុះខ្សោយពេលនោះ ។ ត្រូវតែសំរុកចេញនៅពេលណាដែលពួកគេវាទំលាក់ជណ្ដើរចុះ ដើម្បីយកម្ហូប រឺ ទឹកមកអោយពួកយើង ។ វាអាចយប់នេះ រឺ យប់ស្អែក ។ រួចហេតុអី បានជាពួកវាយកយើងមកដាក់នៅទីនេះ ? ពួកយើងមិនមែនជាគ្រោះតំរាមកំហែងសំរាប់ពួកវាទេ ។ ពួកយើងអាចជួយលោកម្ចាស់ *វ៉េមីញ៉ូ* បាន ។ តើគាត់យល់រឿងហ្នឹងទេ ? ព្រឹកមិញអញមានផ្លូវតែមួយគត់ ដើម្បីបង្ហាញអោយគាត់ដឹងថា បព្វជិតគឺជាសត្រូវនឹងយើងយ៉ាងពិតប្រាកដនោះ ។ តើ *វ៉េមីញ៉ូ* យល់រឿងទេ ? បើបព្វជិតសេបាស្សូ គឺលោកយល់បំនងនៃទង្វើពីព្រឹកមិញនេះច្បាស់ណាស់ ។

- ព្រះជាម្ចាស់ប្រហែលជាអាចត្រាប្រណីពីរឿងអ្នែង ប្រមាថចេស្ដាព្រះអង្គបាន -បព្វជិតសេបាស្សូ និយាយទៅកាន់ *ប្លាក់ថន* យ៉ាងនឹងនរ -ប៉ុន្តែអញនឹងមិននៅស្ងៀមទេ រហូតទាល់តែអ្នែង និងបិសាចរបស់អ្នែងត្រូវកំទេចអស់ ទើបអញបិទភ្នែកជិត ។

ញើសហូរស្រក់តក់ៗ តាមថ្ពាល់ និងចង្ការរបស់ *ប្លាក់ថន* ។ គេវាសដៃជូតដោយគ្មានចាប់អារម្មណ៍អ្វីទាំងអស់ ។ ត្រចៀករបស់គេត្រងត្រាប់សំលេងក្នុងអន្លង់ដូចជាពីកាល ដែលគេដេកយល់សប្តិ រឺ មិនមានភារកិច្ចយាមនៅលើសំពៅយ៉ាងដូចនោះដែរ ។ មិនយកចិត្តទុកដាក់តែប្រយ័ត្នល្មមនឹងដឹងក្លិនគ្រោះថ្នាក់មុនពេលដែលវាមកដល់បាន ។

ពួកយើងត្រូវតែសំរុកចេញ ហើយវាយដណ្ដើមយកសំពៅមកវិញ ។ តើធ្វើរហ្នឹងភេលីស៊ីទីនាងធ្វើអ្វីទំ ? រួចចុះកូនរបស់អញ ? ឥឡូវនេះ *ទុឌ័រ* អាយុ ៧ឆ្នាំហើយៗ *លីស្បេត*...មើល ! យើងនៅចំងាយមួយឆ្នាំ ដប់មួយខែ ៦ថ្ងៃពីរអាំស្ទែដាំ បូក ៣៦ថ្ងៃ ត្រៀមស្បៀង និងចេញពីឆាថាំ មកទីនេះ បូកនិងដប់មួយថ្ងៃដែលនាងមានកំនើតមុនពេលចេញសំពៅទៀត។ អឺ !ហ្នឹងហើយ ! អាយុកូនស្រីអញ គឺប៉ុណ្ណឹង ។ មើលទៅនៅឯផ្ទះបែបស្រួលបួលទេ ។ ភេលីស៊ីទីជាអ្នកធ្វើម្ហូប ថែទាំ បោកខោអាវ និងប្រលែងលេងជាមួយកូន ។ ហើយវានឹងរីងប៉ឹងមាំមួន



www.budinst.gov.kh www.elibraryofcambodia.org

និងគ្មានខ្លាចអ្វីទាំងអស់ ដូចម៉ែវាមិនខាន ។ពេលទៅដល់ផ្ទះវិញ នឹងសប្បាយយ៉ាងណាទេ បាននាំគ្នាដើរលេងតាមមាត់សមុទ្រតាមព្រៃដ៏គួរជាទីរីករាយនិងដ៏សែនល្អនៃប្រទេសអង់គ្លេសនោះ ។

ច្រើនឆ្នាំមកហើយ ដែល *ប្លាក់ថន* ទំលាប់ខ្លួនគិតពីអ្នកទាំងអស់ ដែលគេស្រលាញ់និងនឹកដល់នោះ ប្រៀបបីដូចជាតួអង្គនៅក្នុងរឿងមួយដែលមិនចេះចប់យ៉ាងដូចនោះដែរ ។ បើមិនយ៉ាងដូចនោះទេ គេមិនអាចទ្រាំទ្រទំងន់ នៃគំលាតឆ្ងាយពីគ្នាយ៉ាងនេះបានទេ ។ ក្នុងដប់មួយឆ្នាំ នៃជីវិតរៀបការរបស់គេ *ប្លាក់ថន* អាចរាប់ចំនួនថ្ងៃដែលគេបាននៅផ្ទះនោះ លើម្រាមដៃទាំងដប់បាន ។ គេបាននៅផ្ទះតិចណាស់ តិចពេក ។

- នេះគឺជាជីវិតដ៏សែនលំបាកចំពោះនារី *ភេលីស៊ីទី* អូន !

នេះជាសំដី ដែលគេបាននិយាយមុនពេលរៀបការ ។ នាងតបទៅរកគេវិញ :

- ចំពោះនារីជីវិត គឺជាការលំបាកហើយ ។

កាលនោះ នាងអាយុបាន ១៧ឆ្នាំ....

ត្រចៀករបស់គេប្រាប់គេអោយប្រុងប្រយ័ត្ន ។

*វិញ* និង *ពីវ៉េស៊ិន* ដែលជាមិត្តភក្តិស្និទ្ធស្នាលនឹងគ្នានោះ កំពុងជជែកគ្នាយ៉ាងរាហី ។ *កាំងលិច* ដូចជាអ្នកឯទៀតដែរ សំលឹងផ្ទាំងទៅមុខដោយគ្មានឃើញអ្វីទាំងអស់ ។ *ស្ទីលវ៉េបិគីន* នៅតែបើកភ្នែកនៅឡើយ ហើយ *ប្លាក់ថន* គិតថា មនុស្សនោះ តាមពិតទៅខ្លាំងជាងរូបភាពដែលគេបង្ហាញអោយអ្នកឯទៀតឃើញនោះឆ្ងាយណាស់ ។

នៅពេលដែលស្នូរជើងលាន់លឺ នៅពីលើក្បែរឃ្លុបនោះ ហើយ ភាពស្ងៀមស្ងាត់បានកើតមានមួយរំពេច នៅក្នុងអន្លង់ ។ ស្នូរជើងរលត់បាត់ទៅវិញ ។ សំលេងល្វើយៗ ក្នុងភាពចំលែកនិងកញ្ជក់បានលាន់លឺឡើង ។ *ប្លាក់ថន* គិតថា គេស្គាល់សំលេងរបស់ *សាមូរ៉ៃ* ម្នាក់នោះ។ ឈ្មោះអីអីចេះ ? *អូមីសាន* អ្ហ ? ហ្នឹងហើយឈ្មោះ *អូមី-សាន* អីចឹងហើយ ។ ប៉ុន្តែខ្លួនគេក៏មិនទាន់ច្បាស់ថា នេះពិតជា *អូមី-សាន* មកដែរ ។ បន្តិចក្រោយមកស្នូរនិយាយក៏ស្ងាត់បាត់ហើយស្នូរជើងក៏ដើរចេញទៅវិញ ។

- មើលទៅវាអោយស៊ីចុករី ក៏អត់ទេបងតែគុង ? -សុងស្នូរ ។


www.budinst.gov.kh www.elibraryofcambodia.org

- វាអោយ

-ធ្វើម៉េចបានជីកហ្ន៎ ! បីខែយេរត្រជាក់មួយកែវអីមកលោកអើយ-*ពីរីតេស៊ូន*និយាយ ។

- ឈប់និយាយទៅអ្នា ! -*វិញ*តប ។

*ភ្លាក់ថ្ងន* ដឹងថា អាវគេជោកទៅដោយញើស ទន្ទឹមនោះក្លិនអសោចន៍នៃទឹកខ្លែងបានហ៊ុមព័ទ្ធខ្លួនប្រាណគេជុំជិត ។ ហ៊ី ! បើបានមុជទឹកស្រួលខ្លួនម្ល៉េះទេ ។ ពេលពិតដល់នេះ គេញញឹមដោយនឹកឃើញពេលមុជទឹកនៅផ្ទះមូភា ។

ពេលនោះ *មូភា* និងអ្នកឯទៀតបានសែងរូបគេទៅដល់បន្ទប់មួយ ដែលមានកំដៅឧណ្ហ១ហើយពួកនោះបានដាក់រូបគេនៅលើកៅអីថ្មមួយ ។ ដៃជើងគេពេលនោះ នៅស្ពឹកស្រយង់នៅឡើយ ។ នារីទាំង ៣ ក្រោមការណែនាំរបស់យាយម្ដាយមូភា បានចាប់ផ្ដើមដោះសំលៀកបំពាក់របស់គេ ។ នៅរាល់ពេលដែល *ភ្លាក់ថ្ងន* ខំរើបំរះ បុរសម្នាក់បានចុចជីពចររបស់គេអោយស្ពឹកស្រយង់មួយរំពេច ។ គេមិនមែនខ្មាសអៀន ព្រោះតែភាពអាក្រាតនៅចំពោះមុខនារីនោះទេ ប៉ុន្តែគេធ្លាប់ដោះខោអាវដោយលាក់កំបាំងតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត គេមិនចូលចិត្តអោយ អ្នកណាផ្សេងមកដោះខោអាវអោយគេទេ ពិសេសពួកអ្នកស្រុកអត់អារ្យធម៌អស់នេះ ។ មួយវិញទៀតប្រការដែលអ្នកឯទៀតមកដោះខោអាវអោយគេ ប្រៀបដូចជាខ្លួនគេជាកូនក្មេងមិនទាន់ដឹងក្ដី មកមុជទឹកដុសលាងខ្លួនប្រាណប្រៀបដូចគេជាទារកនោះធ្វើអោយគេទ្រាំមិនបានឡើយ ។

បន្ទាប់មកគេបានយក *ភ្លាក់ថ្ងន* អោយទៅត្រាំទឹកដ៏ក្ដៅដែលធ្វើអោយគេទ្រាំមិនបានយូរឡើយ ។ រួចគេយក *ភ្លាក់ថ្ងន* ទៅដាក់ផ្ដេកលើកៅអីថ្មម្ដងទៀត ហើយនារីម្នាក់ក៏តាំងជូតសំងួតខ្លួនប្រាណរបស់គេ រហូតដល់ពេលដែលបុរសខ្វាក់ភ្នែកម្នាក់មកដល់ ។ តាំងពីតូចរហូតដល់ធំប៉ុណ្ណេះ *ភ្លាក់ថ្ងន* មិនដែលស្គាល់យ៉ាងម៉េចហៅថា ចាប់សរសៃនោះទេ ។ ដោយហេតុនេះនៅពេលដំបូងគេខំប្រឹងទប់នឹងម្រាមដៃដែលសសុលលូកខ្ទេះគេនោះ រួចយ៉ាងឆាប់រហ័ស ឥទ្ធិពលនៃម្រាមដៃបានធ្វើអោយគេចុះចាញ់ ហើយគេចាប់ផ្ដើមស្រមុកខ្ញុំ១ ដូចឆ្មាតែម្ដង ក្នុងពេលដែលម្រាមដៃបន្តឈ្លីបន្ធូរសរសៃ សំរួលឈាមនិងសាច់ដុំអោយបានដើរស្រួលវិញនោះ ។

បន្ទាប់មកគេជួយយក *ភ្លាក់ថ្ងន* ទៅដំណេក ។ ខ្លួនប្រាណគេឡើងទន់ល្មើយ ហើយគេ



www.budinst.gov.kh www.elibraryofcambodia.org

មានអារម្មណ៍ដូចជាយល់សប្តិបន្តិច ដូចមែនទែនបន្តិច ។ បន្ទាប់មកនារីម្នាក់បានមកដល់ដើម្បីរួមដំណេកជាមួយ ។ នាងនៅកំដរគេយ៉ាងអត់ធ្មត់រហូតដល់ពេល *ប្លាក់ថន* ភ្ញាក់ពីដំណេកមានកំលាំងកំហែងឡើងវិញ ដើម្បីរួមរក្សជាមួយនាង ។

គេឥតបានសួរឈ្មោះនាងឡើយ ។ ដោយហេតុនេះ បានជាដល់ពេលព្រឹកឡើង នៅពេលដែល *មូរ៉ា* មកដាស់គេទាំងស្លន់ស្លោ និងទាំងបារម្ភអោយងើបពីដំណេកនោះ នាងបានចេញបាត់ទៅហើយ ។

*ប្លាក់ថន* ដកដង្ហើមធំ ។ ជីវិតមនុស្សចំជាអស្ចារ្យមែន ។

នៅក្នុងអន្លង់ ស្តិលប៊ែគីនចាប់ផ្តើមរករឿងទាស់ជាមួយគេឯង ជាថ្មីម្តងទៀតហើយ ។ *មែស៊ូរ៉ែ* អោបក្បាលថ្ងូរហ៊ឹសមិនមែនដោយការឈឺចាប់នោះទេ តែដោយការភ័យខ្លាច ។ យុវជនត្រូកជិតបាក់មែនទែនហើយ ។

*យ៉ានូរ៉ែ* និយាយ :

- ទៅប្រកាច់ប្រកិនងាប់ឯណាអោយអស់ទៅ !

*ភ៉ាន់ណិច* និយាយទៅកាន់ *ប្លាក់ថន* ទាំងប្រយ័ត្នប្រយែងនូវអ្វីៗ ដែលអ្នកផងគិតនៅតែក្នុងពោះ :

- ខ្ញុំនិយាយនេះ គ្មានបំនងមើលងាយបងតែកុំងទេ ។ តាមពិតបងមិនគួរប៉ះពាល់បព្វជិតនោះមុខពួកអាកូនមីចោរស្បែកលឿងនោះទេ ។ បើសិនជាបងមិនប៉ះពាល់បព្វជិតនោះយើងក៏មិនមែននៅកន្លែងគគ្រិចបែបនេះដែរ ។ បញ្ហាសំខាន់ដែលបងត្រូវធ្វើ គឺថាបើអាលោកម្ចាស់រំបល់យក់នោះ ដើរមកជិតយើងៗ អោនក្បាលអោយដល់ដីទៅ ពួកអាឯទៀតៗវាឡើងស្ងួតដូចកូនចៀមទៅហើយ ។

និយាយចប់ *ភ៉ាន់ណិច* គិតថា *ប្លាក់ថន* នឹងមានប្រតិកម្ម ។ ក្នុងពេលនិយាយនេះ គេមិនខិតចូលទៅជិត *ប្លាក់ថន* ឡើយ ។ តែផ្ទុយទៅវិញ *ប្លាក់ថន* ឥតមានតបតសូម្បីតែមួយម៉ាត់ក៏គ្មានផង ។ គេបែរខ្នង ហើយសំលឹងមើលទៅឃ្លុបក្លារទៅវិញ ហាក់ដូចជាគ្មានអ្នកណានិយាយស្តីអ្វីប៉ះពាល់ដល់គេអីចឹង ។ ក្នុងសភាពបែបនេះ ម្នាក់ៗ មានអារម្មណ៍រសាប់រសល់ជាទីបំផុត ។



www.budinst.gov.kh www.elibraryofcambodia.org

*ប៉ូល្លូសស្តីលប៉ែតីន* ច្រត់កែងដៃបន្ទើបខ្លួនយ៉ាងលំបាក :

- អ្នែងកំពុងនិយាយរឿងអីហ្នឹង *ពាក្លូស* ?

*ភ៉ាន់ណែច* ដើរទៅជិតមេបញ្ជាការ ហើយនិយាយប្រាប់ពីរឿង បព្វជិត រឿងព្រះឆ្លាង រួចបន្ទាប់មកកើតរឿងអីទៀត ហើយហេតុអ្វីបានជាពួកគេមកនៅក្នុងអន្លង់នេះ រួចស្ដីលប៉ែតីនក៏និយាយទៅកាន់ *ប្លាក់ថន* :

- មែនហើយអារឿងនេះ គ្រោះថ្នាក់ណាស់តែកុង ! ខ្ញុំក៏យល់ថា ធ្វើនេះខុសដែរ...... អោយទឹកខ្ញុំបន្តិច ។ អីលូវនេះ អាយេស៊ុតទាំងនេះ វាច្បាស់ជាមិនអោយយើងសុខទេ ។

- បងឯងមិនកាច់កវាបណ្ដោយទៅ ។ ទោះយ៉ាងម៉េចយ៉ាងម៉ាក៏ពួកយេស៊ុតនេះ វាមិនទុកអោយយើងសុខដែរ -*យ៉ានរ៉ូវ៉េត* និយាយ-ពួកវានេះគគ្រិចដូចតែចៃដៃរហ្នឹង ។ ឥឡូវនេះព្រះដាក់ទោសពួកយើងហើយ បានជាពួកយើងមកនៅក្នុងអន្លង់សំអុយហ្នឹងនោះ !

- កុំតែផ្ដាស *រ៉ូវ៉េត* - *ស្ដីលប៉ែតីន* តប - យើងមកកន្លែងនេះព្រោះ.......

- ព្រោះព្រះផ្ដន្ទាទោសណាំ ! យើងគួរដុតវិហារទាំងអស់ នៅសាន់ពាម៉ាក់ដៃឡាណា មិនមែនដុតតែពីរអីចឹងទេ ។

*ស្ដីលប៉ែតីន* លើកដៃទន្ទុយយ៉ាងខ្សោយ :

- ពួកទ័ពអេស្ប៉ាញវាផ្ដុំកំលាំងគ្នា ហើយយើងមានគ្នាតិច ។មួយតដប់ប្រាំមិនមែនធម្មតាទេ ។ អោយទឹកផឹកបន្តិចមើល ។ យើងប្រមូលយកខ្មៅចម៉ាទីក្រុង ហើយដាក់ពួកវាឡើងកំពិតច្រមុះទៅហើយ ។ បើយើងនៅយូរទៀត ពួកយើងច្បាស់ជាស្លាប់ខ្មោចគ្មានសល់ម្នាក់ទេនេះចេះ...

-ចុះទៅខ្វល់អីបើយើងធ្វើការដើម្បីព្រះនោះ? អីលូវនេះយើងធ្វើអោយព្រះខកចិត្ត ហើយ ។

-ពួកយើងមកដល់ទីនេះ ក៏ប្រហែលដើម្បីបំពេញកិច្ចការថ្វាយព្រះដែរក៏មិនដឹង- *ភ៉ាន់ណែច* និយាយដើម្បីលួង *រ៉ូវ៉េត* ។ *រ៉ូវ៉េត* ថ្វីត្បិតតែជាមនុស្សចិត្តក្ដៅ តែវាងវៃក្នុងជំនួញ ទន្ទឹមនេះ គេគឺជាកូនប្រុសរបស់អ្នកដៃហ៊ុនរកស៊ីជាមួយ *ភ៉ាន់ណែច* ផង-យើងអាចពន្យល់អ្នកស្រុកទាំងនេះអោយយល់ថា ពួកប៉ាបបាននាំពួកគេដើរខុសផ្លូវហើយៗ ជួនកាលយើងអាចនាំគេអោយងាកមករកផ្លូវធម៌ត្រឹមត្រូវបានវិញណា ។



www.budinst.gov.kh www.elibraryofcambodia.org

- ពិតជាត្រឹមត្រូវ- ស្ដីលប៉ៃតិនបន្ទរតាម ។ ថ្វីត្បិតតែគេនៅខ្សោយតែកំលាំងរបស់គេកំពុងតែរើប១ វិញហើយ - ខ្ញុំគិតថា តែកុងគួរតែពិគ្រោះជាមួយបាតួសសិន ព្រោះយ៉ាងម៉េចយ៉ាងម៉ា គេជាប្រធានលើឈ្លូញទាំងអស់នៅលើសំពៅនេះ ។ អារឿងនិយាយជាមួយពួកមនុស្សព្រៃគាត់ពូកែណាស់ ។ រួចចុះឯណាទឹកដែលខ្ញុំសួររកនោះ ?

- អត់មានទឹកទេប៉ូលូស - ភាពអស់សង្ឃឹមរបស់វ៉ាន់ណិចចេះតែរីកធំឡើង- ពួកវាអត់អោយបាយ អត់អោយទឹកយើងតាក់តិចណាទេ ។ តែថ្វមួយគ្រាន់តែបាញ់នោមក៏គ្មានផង ។

- អ៊ីចឹងសុំគេទៅ ! រួចសុំទឹកផង ! រំបល់យក៍ ស្រេកទឹកខះកចង់ស្លាប់ទៅហើយ ! នែ ! អានេះ ! សុំទឹកគេទៅ !

- ខ្ញុំ ? -*វិញ* សួរ ។

- អើអ្អែងហ្នឹងណា !

*វិញ* ចោលភ្នែកសំលឹងមើលទៅ *ប្លាក់ថន* ប៉ុន្តែ *ប្លាក់ថន* នៅតែសំលឹងជាប់ទៅឃ្លុបក្ដារនោះ ។ ដោយហេតុនេះ វិញ ក៏ដើរទៅឈរពីក្រោយឃ្លុប ហើយតាំងជំទាលឡើង :

- អ្ហ៎ ! អាណានៅលើនោះវ៉ុ ! អោយទឹកផឹកផង ! អោយម្ហូប អោយទឹកផង !

ខាងលើស្ងាត់ច្រៀប ។ *វិញ* ស្រែកជំទាលម្ដងទៀត ។ ស្ងាត់ច្រៀបដដែល ។ ម្ដងមួយ១ អ្នកឯទៀតជួយបំពងសំរែករបស់វិញ ។ មានតែ ប្លាក់ថន ម្នាក់គត់ដែលនៅតែឈរស្ងៀមស្ងាត់ដដែល ។ បន្តិចក្រោយមកការភ័យខ្លាច និងភាពរអើមចំពោះអន្លង់បិទជិតនេះ បានលេចចេញតាមសំរែករបស់ពួកគេ ដែលប្រែពីសំរែកមនុស្សទៅជាសំរែករបស់ចចកទៅវិញ ។

ឃ្លុបរបើកឡើង ហើយបង្ហាញរូបរាងរបស់ *អូមី* ដែលកំពុងសំលឹងចុះមកក្រោម ។ នៅក្បែរគេមាន *មូកា* ហើយនិងបព្វជិត ។

- ទឹក ! ម្ហូប ! លោកអើយលោក ! អោយពួកយើងចេញក្រៅ !

បន្តិចក្រោយមក ពួកគេក៏ចាប់ជំទាលគោកកាកឡើងវិញដដែល ។

*អូមី* និយាយប៉ុន្មានម៉ាត់ទៅ *មូកា* ងក់ក្បាល ហើយដើរចេញទៅ ។ បន្តិចក្រោយមក *មូកា* ត្រឡប់មកវិញជាមួយអ្នកទេសាទម្នាក់ ។ អ្នកទាំង ២សែងធុងមួយធំមកជាមួយផង ។



www.budinst.gov.kh www.elibraryofcambodia.org

មកដល់មាត់អន្លង់ពួកគេក៏ចាក់ផ្តឹងធុងចូលក្នុងអន្លង់តែម្តង ។ នោះគឺជាត្រីវល្វយកខ្វក់ជាមួយនឹងទឹកសមុទ្រដែលហូរស្រោចក្បាលអ្នកទោសទាំងអស់ ។

អ្នកនៅក្នុងអន្លង់ រត់ជ្រួលច្របល់គេចអោយប្រញាប់ ។ ប៉ុន្តែគ្មានអ្នកណាគេចរួចបានទាំងអស់គ្នាទេ ។ ស្តីលប៉ៃគីនឈ្លក់ទឹកវិះតែលង់ងាប់ ។ អ្នកខ្លះរអិលជើងដួល ហើយត្រូវគេជាន់ពីលើ ។ *ភ្លាក់ថន* ឥតមានកំរើកចេញពីជ្រុងជញ្ជាំងរបស់ខ្លួនឡើយ ។ គេសំឡឹងផ្ទៃរទៅ *អូមី* ហើយគេដឹងថា គេកំពុងតែស្អប់មនុស្សនេះហើយ ។

បន្ទាប់មក *អូមី* ចាប់ផ្តើមនិយាយ ។ នៅក្នុងអន្លង់ភាពស្ងាត់ស្ងៀមដែលបណ្តាលមកពីកំលាចបានកើតមានឡើងរំខានម្តងៗ ដោយសំលេងក្អកនិងចង្អោររបស់ *ស្តីលប៉ៃគីន* ។ នៅពេលដែល *អូមី* និយាយចប់ បព្វជិតដើរមកជិតប្រហោងឃ្លុប ហើយចាប់ផ្តើមបកប្រែ :

- នេះ គឺជាបញ្ជារបស់លោកម្ចាស់ *កាស៊ីគី អូមី* : ពួកអ្នែងទាំងអស់ត្រូវប្រកាន់ វិកពាអោយបានសមរម្យជាមនុស្សម្នានឹងគេ ។ ពួកអ្នែងឈប់ឡូឡាទៀត ។ បើពួកអ្នែងនៅតែធ្វើអោយលឺសំលេងទៀត លើកក្រោយគេនឹងចាក់ត្រីស្អុយនេះ ប្រាំមួយធុងចូលអន្លង់នេះ ។ រួចបន្តមកទៀតដប់ រួចម្តែ ។ ក្នុងមួយថ្ងៃពួកអ្នែងទទួលទឹក និងម្ហូបពីរដង ។ ពេលណាពួកអ្នែងចេះច្បាប់ ចេះទំលាប់ហើយ ពួកអ្នែងនឹងបានអនុញ្ញាតអោយឡើងមកកន្លែងមនុស្សម្នានឹងគេហើយ ។ លោកម្ចាស់ *យ៉ាប៊ូ* មានសន្តានចិត្តល្អលើកលែងទោសអោយពួកអ្នែងទាំងអស់គ្នាហើយ អោយតែពួកអ្នែងបំរើលោកម្ចាស់ដោយស្មោះត្រង់ ។ លោកលើកលែងជីវិតអោយទាំងអស់គ្នាលើកលែងតែម្នាក់ ។ ក្នុងចំនោមពួកអ្នែងទាំងអស់ ត្រូវមានម្នាក់ស្លាប់ ។ ស្លាប់ពេលព្រលប់នេះ ។ ពួកអ្នែងត្រូវជ្រើសរើសទៅ ថាអ្នកណាត្រូវស្លាប់នោះ ។ តែអ្នែងនេះ-សេបាស្សូចង្អុលទៅ *ភ្លាក់ថន* - អ្នែងអត់ត្រូវរាប់បញ្ចូលជាអ្នកដែលត្រូវរើសទេ ។

រួចបព្វជិតសេបាស្សូលំអោនខ្លួនទាំងឆ្គងគោរព *សាមូរ៉ៃ* ហើយថយទៅក្រោយវិញ ។

*អូមី* ចោលភ្នែកសំលឹងចុះក្រោម ។ ភ្នែករបស់គេបានជួបប្រទះនឹងភ្នែករបស់ *ភ្លាក់ថន* ហើយភ្លាមនោះ គេទទួលអារម្មណ៍នូវគំនុំដែលមាននៅក្នុងក្រសែភ្នែកនេះ ។ ចង់បំបាក់មនុស្សនេះ ត្រូវស៊ីពេលយូរហើយ-គេគិតក្នុងចិត្ត ។ តែមិនបញ្ហាទេ ។ ពេលវេលានៅសល់ច្រើននៅឡើយ ។

ឃ្លុបត្រូវគេទំលាក់មកវិញក្រាំង ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៣

*យ៉ាប៊ូ* ដេកស្ងៀម ត្រាំខ្លួននៅក្នុងទឹកក្ដៅ ។ ជាងពេលណាទាំងអស់ក្នុងមួយជីវិតគេ ពេលនេះគេរីករាយបំផុត និងមានទំនុកចិត្តខ្លួនឯងជាទីបំផុត ។ សំពៅបានបង្ហាញនូវធនធានរបស់វា ហើយជាធនធានដែលផ្ដល់ដល់គេនូវអំនាចមួយដែលពីពេលមុន ទោះជាគេយល់សប្តិក៏មិនដែលឃើញដែរនោះ ។

- ខ្ញុំចង់អោយសាងអីវ៉ាន់ទាំងអស់ ចេញពីសំពៅនៅថ្ងៃស្អែកនេះ-*យ៉ាប៊ូ* ចេញបញ្ជា- វុំមួស្តេ [៣៤] ទាំងអស់ឡើងវិញ ហើយលាក់ទាំងអស់ហ្នឹងក្រោមបាវក្រោម សំនាញ់ទៅ ។

មួស្តេប្រាំរយ !-គេគិតទាំងរំភើប ។ ថែមទាំងរំសេវ និងគ្រាប់ទៀត គឺលើសពីលោកម្ចាស់ *ភូរ៉ាណាកា* មាននៅក្នុងខេត្តទាំងប្រាំបីទៅទៀត។ រួចនៅមានកាណុងម្លៃ គ្រាប់ប្រាំពាន់ និងរំសេវគ្រប់គ្រាន់ទាំងអស់នេះ គឺជាផលិតផលថ្នាក់លេខ១ ដែលមកត្រង់ពីអឺរ៉ុបថែម ទៀត ។

- *អូរ៉ា* អ្នែងត្រូវរកមនុស្សសំរាប់ដឹកជញ្ជូន ។ *អ៊ីកូរ៉ូស៊ី -សាន* ខ្ញុំចង់អោយគេដឹកអាវុធទាំងអស់នេះ រួមទាំងកាណុងផងយកទៅវិមានខ្ញុំនៅឯស៊ីម៉ាជាសំងាត់ ។ ត្រូវធ្វើដំណើរពេលយប់ ហើយអ្នែងត្រូវទទួលខុសត្រូវលីទេ ?

- ប្របាទម្ចាស់ !

ពួកគេកំពុងឈរនៅក្នុងបន្ទប់ធំនៃសំពៅ ហើយម្នាក់ៗសំលឹងមើល *យ៉ាប៊ូ* ផ្ទាំង ។ពួកគេទាំងអស់នោះ មាន*អ៊ីកូរ៉ូស៊ី* ជាបុរសមាឌធំ ភ្នែកម្ខាងជាអ្នកមើលការលើអ្នកបំរើទាំងឡាយ*ស៊ូគីម៉ូតូ* ជាប្រធានភស្តុភារ អ្នកភូមិដប់នាក់ទៀត ដែលកំពុងបែកញើសគយៀវក្នុងការគាស់កែស ផ្សេងៗក្រោមបញ្ជារបស់ *អូរ៉ា* ហើយនិង *សាមូរ៉ៃ* ដែលជាអង្គរក្សរបស់គេ ។ *យ៉ាប៊ូ* ដឹងថា ពួកអ្នកទាំងនេះ មិនអាចយល់បានទេ ថាហេតុអ្វីបានជាគេរីកច្រើមប្រមាត់យ៉ាងនេះ ហើយពួកនេះរឹតតែមិនយល់បានទៀតពីភាពចាំបាច់ នៃការលាក់ការណ៍នេះ ។ អីចឹងល្អហើយ -គេគិតនៅក្នុងចិត្ត ។

---

(៣៤) *កាំភ្លើងបុរាណដែលប្រើឈ្នួន ។*



www.budinst.gov.kh www.elibraryofcambodia.org

នៅឆ្នាំ ១៩៤២ ពេលដែលពួកប៉ុកទុយកាល់ មកដល់ប្រទេសជប៉ុនជាលើកទីមួយនោះ ពួកនេះ បាននាំចូលមូស្កេ និងរំសេវសំរាប់បាញ់ ។ ក្នុងអំលុងពេលតែដប់ប្រាំខែប៉ុណ្ណោះ ជប៉ុនចាប់ផ្តើមផលិតរបស់ទាំងនេះ ។ គុណភាពរបស់ទាំងនេះ មិនស្មើដល់ផលិតផលដូចគ្នាដែលផលិតនៅអឺរ៉ុបនោះឡើយ តែនេះមិនជាការសំខាន់ទេ ពីព្រោះកាំភ្លើងត្រូវគេចាត់ថា គ្រាន់តែជារបស់មួយប្លែក ហើយគេច្រើនប្រើសំរាប់បរបាញ់សត្វ តែប៉ុណ្ណោះ ។ ក្នុងការបរបាញ់នេះទៀតសោតគេរមែងចាត់ថាព្រួញច្រើនត្រង់ជាងផង ។ម្យ៉ាងទៀតអ្វីដែលសំខាន់ គឺថាសង្គ្រាមជប៉ុន មានលក្ខណៈជាទំលាប់មួយនោះ គឺការប្រយុទ្ធប្រកៀកគ្នាមួយតមួយ ហើយក្នុងនោះដាវត្រូវគេចាត់ទុកជាអាវុធមួយដ៏ថ្លៃថ្នូរបំផុត ។ បំរើបំរាស់កាំភ្លើងត្រូវគេចាត់ទុកដូចជាអំពើកំសាកញី ថោកទាប ហើយផ្ទុយនឹងបញ្ញត្តិរបស់*សាមូរ៉ៃ* ដែលមានឈ្មោះថា *ប៊ូស៊ីដូ* ( វិន័យអ្នកធ្វើសឹក ) ដែលតំរូវអោយ*សាមូរ៉ៃ* ធ្វើការប្រយុទ្ធក្នុងកិត្តិយស រស់នៅក្នុងកិត្តិយស និង ស្លាប់ទៅក្នុងកិត្តិយស ត្រូវមានភក្តីភាពដាច់ខាត ដោយគ្មានសំនួរដោយគ្មានប្រែប្រួលចំពោះអម្ចាស់របស់ខ្លួន ត្រូវមិនចេះខ្លាចស្លាប់ ហើយជូនកាលស្វែងរកស្លាប់ដើម្បីបំរើអម្ចាស់របស់ខ្លួនថែមទៀតផង ទទឹមនោះ*សាមូរ៉ៃ* ត្រូវមានមោទនភាពចំពោះឈ្មោះរបស់ខ្លួន ហើយត្រូវថែរក្សាយ៉ាងណា ដើម្បីកុំអោយឈ្មោះរបស់ខ្លួនប្រលាក់ប្រឡូសឡើយ ។

ច្រើនឆ្នាំមកហើយ ដែល *យ៉ាប៉ូ* លើកឡើងនូវទ្រឹស្តីមួយជាសំងាត់ ។ អស់រយៈពេលយ៉ាងយូរមក-គេគិតនៅក្នុងចិត្តយ៉ាងរំភើប-ឥឡូវនេះអ្វែងអាចអនុវត្តវា និង ផ្សព្វផ្សាយវាបានហើយ ។ នោះគឺ *សាមូរ៉ៃ* ដ៏ជំរើស ៥០០នាក់ ប្រដាប់ដោយមូស្កេ តែរឹករឹនជាអង្គភាពមួយ ដែលនឹងនាំមុខកងទ័ពធម្មតា ៥០០០នាក់ គាំទ្រដោយកាណុង ២០ដើម ដែលប្រើជាពិសេសដោយក្រុមពួកពិសេស ហើយដែលនឹងទទួលការរឹករឹនជាអង្គភាពតែមួយ ។ យុទ្ធសាស្ត្រថ្មីសំរាប់យុគសម័យថ្មី ! នៅក្នុងសង្គ្រាមខាងមុខកាំភ្លើង នឹងមានតួនាទីគំនត់ហើយ ។

ប៉ុន្តែចុះរឿងវិន័យ *ប៊ូស៊ីដូ*? ព្រលឹងបុព្វបុរសរបស់ *យ៉ាប៉ូ* តែងតែសួរសំនួរនេះដល់គេ ។

គ្មានចំលើយអ្វីទាំងអស់ ។



www.budinst.gov.kh www.elibraryofcambodia.org

ពេលមុន ១ សូម្បីតែដេកយល់សប្ដិ ក៏គេមិនដែលនឹកឃើញថា គេនឹងរកបានកាំភ្លើង ៥០០ដើមសោះឡើយ ។ តែពេលនេះគេបែរជាបានវាដោយគ្មានអស់ ១កាក់សោះឡើយ ហើយមានតែគេមួយគត់ដែលចេះប្រើវា ។ ប៉ុន្តែតើប្រើកាំភ្លើងនេះដើម្បីអ្នកណាហ្ន៎ ? *តូវ៉ាណាកា* រឺ *អ៊ីស៊ីដូ*? រឺមួយគេគួររង់ចាំ... ហើយក្រែងខ្លួនគេអាចមានលទ្ធភាពទៅជាអ្នកឈ្នះក៏មិនដឹង ?

- *អ៊ីតូវ៉ាស៊ី-សាន* ! អ្នែងត្រូវធ្វើដំណើរពេលយប់ ហើយពង្រឹងសន្តិសុខអោយខ្លាំងមែនទែនណា !

- ប្របាទម្ចាស់ !

- *មូរ៉ា* ! រឿងនេះត្រូវរក្សាសំងាត់បំផុតណា ! បើមិនអ៊ីចឹងទេ ភូមិនេះទាំងមូលនឹងត្រូវទៅជាផេះលឹទេ ?

- ទុកចិត្តចុះលោកម្ចាស់ ។ ខ្ញុំសូមធានាភូមិខ្ញុំ ។ ខ្ញុំមិនធានារឿងធ្វើដំណើរ និងរឿងភូមិឯទៀតទេ ព្រោះអ្នកណាដឹងថា ពួកយកការណ៍នៅឯណាខ្លះ ?ប៉ុន្តែរឿងពួកយើងនេះ គឺគ្មានលេចម៉ាចិបណាឡើយ ។

បន្ទាប់មកពួកគេទៅឃ្លាំងសំពៅ ដែល *យ៉ាប៊ូ* គិតថា នៅកន្លែងនោះពួកចោរសមុទ្រពិតជាតំកល់ជ័យភណ្ឌរបស់ពួកវាទាំងអស់ហើយ ។ ពិតដូចជាគេគិតមែន : មានថាសមាសថាសប្រាក់ ពែង កែវ កង ពេជ្រ ត្បូង មាស ក្រណាត់នៅពោរពាស ។

- យកមាស និងប្រាក់ផែជាដុំ ហើយយកវាទៅទុកនៅក្នុងឃ្លាំងទៅ ! -*ស៊ូគីម៉ូតូ* និយាយ ។ *ស៊ូគីម៉ូតូ* អាយុប្រហែល ៤០ ស្គាតបាត មានរបៀប ហើយគេមិនមែនជា*សាមូរ៉ៃ*ទេ ។ ប៉ុន្មានឆ្នាំមុននេះគេគឺជាសង្ឃ ដែលបានហាត់គុន ហើយលោកម្ចាស់តៃកូ បានមកកំទេចវត្តរបស់គេ នៅក្នុងយុទ្ធនាការកំទេចវត្តហាត់គុនទាំងប៉ុន្មាន ដែលប្រកែកមិនព្រមទទួលស្គាល់អំនាចរបស់លោក ។ *ស៊ូគីម៉ូតូ* បានសូកគេ គេចខ្លួនផុតពីមរណភាពនេះ ហើយក៏បានក្លាយខ្លួនទៅជាអ្នកលីសែង និងយូរបន្តិចមកក៏បានទៅជាឈ្មួញអង្ករកំប៉ុកកំប៉ុកម្នាក់ ។ គេបានចូលមកបំរើ *យ៉ាប៊ូ* កាលពីដប់ឆ្នាំមុននេះ ហើយអឺលូវនេះគេក៏បានក្លាយខ្លួនទៅជាមនុស្សចាំបាច់បំផុត ។



www.budinst.gov.kh www.elibraryofcambodia.org

- ចំនែកអារឿងក្រណាត់ សរសៃមាស និងត្បូងនេះ អាចមានតំលៃ ។ បើលោកម្ចាស់យល់ព្រម ខ្ញុំបាទនឹងចាត់ចែងវេចខ្ចប់វា ហើយបញ្ជូនវាទៅ *ណាកាសាគី* ជាមួយនឹងរបស់របរឯទៀត ដែលខ្ញុំបាទប្រមែប្រមូលបាន ។ អាចពួកអាចុងស្រុកអោយថ្លៃដែរអារបស់គំប៉ិកគំប៉ុកអស់ហ្នឹងនោះ ។

កំពង់ផែ*ណាកាសាគី* ដែលនៅឯជ្រោយខាងត្បូងនៃកោះខាងត្បូងឈ្មោះ *គ្យូស្យូ* គឺជាឃ្លាំង និងទីផ្សារស្របច្បាប់របស់ពួកប៉ីកទុយកាល់ ។

-ល្អ រួចចុះរបស់ ១ ខាងនោះ ?

- មានសុទ្ធតែខោអាវក្រាស់លោកម្ចាស់ ។ យើងប្រើវាក៏មិនកើតដែរ អឺចឹងហើយវាឥតមានតំលៃអ្វីដែរ ។ ប៉ុន្តែអានេះប្រហែលជាលោកម្ចាស់ពេញចិត្តហើយ -*ស៊ូគីម៉ូតូ* ឈោងដៃទៅបើកប្រអប់មួយ ។

នៅក្នុងប្រអប់មានកាស់ប្រាក់ ២រយពាន់ ។ គឺជាប្រាក់ខ្ទប្លុងរបស់អេស្ប៉ាញ ។ ប្រភេទចុនលេខ ១ ។

*យ៉ាប៊ូ* ពត់ខ្លួននៅក្នុងទឹក ។ គេយកកន្សែងស តូចមួយមកជូតញើសចេញពីមុខ និង ករបស់ខ្លួន បន្ទាប់មកគេក៏ជ្រមុជខ្លួនទៅក្នុងទឹកក្តៅដ៏ក្រអូបនេះ ។ គេគិតថា បើសិនជាកាលពីរបីថ្ងៃមុននេះ មានគ្រូទាយណាទាយប្រាប់គេថា រឿងរ៉ាវទាំងនេះនឹងកើតមានឡើងនោះ គេច្បាស់ជាយកគ្រូនោះទៅកាត់អណ្តាតចោល ព្រោះតែគេចាត់ទុកថា គ្រូនោះនិយាយភរហួសជំរពិតប្រាកដ ។

បីថ្ងៃមុននេះ គេកំពុងតែនៅឯទីក្រុង*យេដូ* ទីក្រុងរបស់លោកម្ចាស់ *តូរ៉ាណាកា* ។ អ្នកនាំសាររបស់*អូមី* បានទៅដល់នាពេលព្រលប់ ។ ជាការច្បាស់ណាស់ដែលថា គេត្រូវមកផែកឆែរសំពៅជាបន្ទាន់ ប៉ុន្តែលោកម្ចាស់ *តូរ៉ាណាកា* រវល់នៅអូសាកានៅឡើយ ដើម្បីធ្វើការតទល់ចុងក្រោយនឹងលោកម្ចាស់ឧត្តមសេនីយ៍ *អ៊ីស៊ីដូ* ។ ក្នុងអំលុងអវត្តមានយ៉ាងនេះ លោកម្ចាស់*តូរ៉ាណាកា* បានអញ្ជើញ *យ៉ាប៊ូ* និង *ជៃមីញ៉ូ* ដែលនៅជិត ១ ហើយដែលគាំទ្រលោកនោះអោយមករង់ចាំរហូតដល់ពេលលោកត្រលប់មកវិញ ។ នេះជាការអញ្ជើញដែលមិនទទួល



www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

ការប្រកែក ។ ប្រកែក គឺនាំមកនូវមហន្តរាយដល់ខ្លួនជាមិនខាន ។ *យ៉ាប៊ូ* ដឹងខ្លួនច្បាស់ណាស់ថា ខ្លួនគេនិងពួក *វ៉េមីញ៉ូ* ឯករាជ្យឯទៀតក៏ដូចជាក្រុមគ្រួសារពួកគេផងដែរ គឺជាអ្នកការពារបន្ថែម ទៅលើសន្តិសុខរបស់លោកម្ចាស់ *តូរ៉ាណាកា* ។ តាមពិតទៅថ្វីត្បិតតែគេមិនបានប្រើពាក្យនេះក្តី ក៏ពួកគេ គឺជាចំនាប់ខ្មាំង រហូតដល់ពេលណា ដែលលោកម្ចាស់ *តូរ៉ាណាកា* វិលត្រលប់មកវិញ ដោយសុវត្ថិភាពពីវិមានដ៏រឹងមាំនៅអូសាកាជាទីកន្លែងដែលអ្នកទាំងពីរជួបគ្នានោះ ។ *តូរ៉ាណាកា* គឺជាប្រធាននៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ដែលអម្ចាស់តៃកូ បានចាត់តាំងឡើងមុនពេលលោកចូលមរណភាព ដើម្បីគ្រប់គ្រងចក្រភព ក្នុងរយៈពេលដែលកូនរបស់លោកឈ្មោះ *យ៉ែយ៉ុន* មិនទាន់ពេញវ័យ ។ សព្វថ្ងៃកូនអម្ចាស់ តៃកូ មានវ័យទើបបាន ៧ឆ្នាំប៉ុណ្ណោះ ។ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ មានសមាជិកប្រាំរូប ដែលជា *វ៉េមីញ៉ូ* ដ៏កំពូល ១ ប៉ុន្តែអ្នកដែលមានអំនាចពិតប្រាកដ មានតែពីរនាក់ទេ គឺ *តូរ៉ាណាកា* និង *អ៊ីស៊ីដូ* ។

*យ៉ាប៊ូ* បានថ្លឹងថ្លែងយ៉ាងល្អិតល្អន់នូវរាល់ហេតុផល ដើម្បីទៅ *អាន់ជីរ៉ូ* ទាំងគ្រោះថ្នាក់ដែលអាចកើតមានឡើង ទាំងមូលហេតុដែលត្រូវស្នាក់នៅ ។ បន្ទាប់មកគេបានចាត់អោយទៅហៅភរិយានិងប្រពន្ធចុងរបស់គេមកជួប ។ បុរសអាចមានប្រពន្ធចុងច្រើនតែប្រពន្ធដើមអាចមានតែម្នាក់គត់ ។

-ក្មួយរបស់បងទើបផ្ញើសារសំងាត់មួយប្រាប់បងថា មានសំពៅពួកចុងស្រុកមួយបានចូលផែនៅ *អាន់ជីរ៉ូ* ហើយ ។

-សំពៅខ្មៅមួយហ៊ើងរឺបង ?

ប្រពន្ធរបស់គេសួរយ៉ាងរហ័ន ។ សំពៅខ្មៅ គឺជាក្រុមសំពៅធំ ១ និងពោរពេញដោយគ្រឿងទំនិញដែលតែងបើកទៅបើកមក តាមជំនោរខ្យល់មូសុង រវាង *ណាកាសាគី* និងម៉ាកាវនោះ ។

- មិនមែនទេ ។ ប៉ុន្តែអាសំពៅនេះក៏អាចសំបូរធនធានណាស់ដែរ ។ បងចាកចេញដំណើរអីលូវនេះ ។ បើគេសួរ អូនឯងប្រាប់គេថាបងមានជំងឺ ហើយមិនត្រូវរំខានបងឡើយទោះជាមានការអ្វីក៏ដោយ ។ ប្រាំថ្ងៃទៀតបងនឹងត្រលប់មកវិញហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

ប្រពន្ធរបស់គេទូន្មាន :

- រឿងនេះដូចមានគ្រោះថ្នាក់ពេកហើយ ។ លោកម្ចាស់ *តូរ៉ាណាកា* បានបញ្ជាជាពិសេសអោយពួកយើងស្នាក់នៅទីនេះ ។ ខ្ញុំគិតថា លោកម្ចាស់ច្បាស់ជាសំរេចធ្វើសម្បទានម្តងទៀតជាមួយលោកម្ចាស់ *អ៊ីស៊ីដូ* ជាមិនខាន ព្រោះគាត់មានឥទ្ធិពលខ្លាំងក្លា ដែលគេមិនត្រូវប្រឆាំងផងទេ ។ លោក ! យើងមិនអាចទុកចិត្តទាំងស្រុងថា អត់មានអ្នកណាម្នាក់អាចសង្ស័យពីរឿងនេះទេ ព្រោះអ្នកយកការណ៍មានគ្រប់ទីកន្លែងណឹង ។ បើសិនណាជាលោកម្ចាស់ *តូរ៉ាណាកា* ត្រលប់មកវិញ ហើយដឹងថា លោកប្រុសទៅបាត់នោះលោកម្ចាស់អាចយល់ច្រលំពីអវត្តមានរបស់លោកប្រុស ។ សត្រូវរបស់លោកប្រុសនឹងញុះញង់លោកម្ចាស់ *តូរ៉ាណាកា* អំពីរឿងលោកប្រុសជាមិនខាន ។

- ចាស់មែនហើយ - ប្រពន្ធចុងរបស់គេបន្ថែម-សូមលោកប្រុសអភ័យទោសដល់ខ្ញុំ ប៉ុន្តែលោកប្រុសគួរស្តាប់លោកស្រីម្ចាស់ ។ លោកស្រីម្ចាស់មានយោបល់ត្រឹមត្រូវ ។ លោកម្ចាស់ *តូរ៉ាណាកា* នឹងមិនជឿបានទេថា លោកម្ចាស់ហ៊ានមិនគោរពតាមបញ្ជារបស់លោកដោយគ្រាន់តែរឿងទៅមើលសំពៅពួកចុងស្រុកនោះ ។ សូមលោកម្ចាស់បញ្ជូនអ្នកណាផ្សេងទៀតទៅ ។

- តែនេះមិនមែនជាសំពៅរបស់ពួកចុងស្រុកធម្មតានោះទេ ។ វាមិនមែនជារបស់ពួកប៉ាកទុយកាល់ទេ ។ ស្តាប់បងវិញ ។ *អូមី* វាបាននិយាយថា សំពៅនេះមកពីប្រទេសផ្សេង ។ ពួកទាំងនោះនិយាយភាសាសំលេងខុសគ្នា ហើយពួកវាមានភ្នែកខៀវ និងសក់ពណ៌មាសណាំ !

- *អូមី-សាន* ឆ្កួតហ្នឹង ។ រឺបើមិននេះទេ វាផឹកសាកេច្រើនពេកតែប៉ុណ្ណឹង ប្រពន្ធគេឆ្លើយ ។

- រឿងសំខាន់យ៉ាងនេះ ទាំងអូន ទាំងវាអត់ត្រូវលេងសើចទេ !

ប្រពន្ធរបស់គេលំអោនខ្លួន និងសូមអភ័យទោស ហើយបញ្ជាក់ថា គឺជាការ ត្រឹមត្រូវណាស់ ដែលគេបានកែតំរូវនាងនោះ ប៉ុន្តែនាងប្រាប់ថា ពាក្យនាងនិយាយអំបាញ់មិញនេះមិនមែនជាការចំអកអោយនោះទេ ។ នាងគឺជានារីម្នាក់មានឧស្តែង រាងទាប ហើយអាយុបងគេដប់



www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំ ។ កន្លងមកនេះនាងបានផ្ដល់កូនអោយគេជាទៀងរាល់ឆ្នាំអស់រយៈពេលប្រាំបីឆ្នាំ ក្នុងនោះកូនប្រុសប្រាំបានត្រូវនាងផ្ដល់កំនើតអោយ ។ ក្នុងកូនប្រុសទាំងប្រាំនាក់បានក្លាយជាអ្នកធ្វើសឹកហើយបានទទួលមរណភាពយ៉ាងអង់អាចក្លាហាននៅក្នុងសង្គ្រាមប្រឆាំងប្រទេសចិន ។ កូនទីបួនបានក្លាយជាលោកសង្ឃ ហើយកូនពៅដែលអីលូវនេះមានអាយុ ១៩ឆ្នាំ ហើយនោះ គឺជាកូនសំអប់បំផុត ។

អ្នកស្រី*យូរីកូ* ប្រពន្ធរបស់គេ គឺជានារីតែម្នាក់គត់ដែលគេខ្លាច ជានារីតែម្នាក់គត់ដែលគេគោរព-លើកលែងតែម្ដាយគេ ដែលចូលមរណភាពទៅហើយនោះ-ហើយរាល់ថ្ងៃនាងមើលកិច្ចការផ្ទះយ៉ាងប៉ិនប្រសប់ ។

- សូមលោកប្រុសអភ័យទោសអោយខ្ញុំម្ដងទៀតផង ។ តើ*អូមី-សាន* មានរ៉ាយរ៉ាប់ពីមុខទំនិញដែលមាននៅក្នុងសំពៅទេ ?

- ទេ *យូរីកូ-សាន* ។ វាឥតបានពិនិត្យទេ ។ វានិយាយថា វាបានប្រថាប់ត្រាបិទសំពៅតែម្ដង ព្រោះរឿងនេះខុសពីធម្មតា ។ តាំងពីដើមមកមិនដែលមានសំពៅណាផ្សេងពីសំពៅប៉ិកទុយកាល់ទេ ? *អូមី* និយាយថា សំពៅនោះជាសំពៅចំបាំងផងដែរ ។ វាមានកាណុងម្ភៃនៅលើខ្លួនវា ។

- អ៊ីចឹងផង ? បើអ៊ីចឹងត្រូវតែអ្នកណាម្នាក់ទៅមើលភ្លាមទៅ ។

- ខ្ញុំទៅខ្លួនឯងតែម្ដង ។

- សូមលោកប្រុសគិតម្ដងទៀតទៅ ។ បញ្ជូន *មីស៊ូណូ* ទៅបានហើយ ។ បងរបស់លោកប្រុសជាមនុស្សវាងវៃ ហើយមានគំនិតចាស់ទុំផង ។ ខ្ញុំសូមអង្វរលោកប្រុសសូមកុំទៅអី ។

- *មីស៊ូណូ* ជាមនុស្សទន់ខ្សោយ ហើយក៏មិនគួរទុកចិត្តទេ !

- បើអ៊ីចឹងអោយគាត់ធ្វើសិបពូគូ អោយរួចស្រេចតែម្ដងទៅ !-នាងនិយាយតបយ៉ាងកំបុត ។ *សិបពូគូ* ដែលជូនកាលគេហៅថា *ហារ៉ាគីរី* គឺជាអត្តឃាតតាមក្បួនខ្នាតមួយតាមរយៈការវះពោះខ្លួនឯង ហើយដែលជាមធ្យោបាយតែមួយគត់សំរាប់*សាមូរ៉ៃ* ដើម្បីលុបលាងអំពើអាម៉ាស់ បាបកម្ម រឺកំហុសដោយកិត្តិយសនោះ ។ *សិបពូគូ* គឺជាសិទ្ធិផ្ដាច់មុខសំរាប់វណ្ណៈ*សាមូរ៉ៃ*



www.budinst.gov.kh www.elibraryofcambodia.org

តែប៉ុណ្ណោះ ។ *សាមូរ៉ៃ* ទាំងអស់ ទាំងនារីក៏ដូចជាទាំងបុរសសុទ្ធតែទទួលបាននូវការអប់រំបែប នេះតាំងពីកុមារភាពមកម៉្លេះ រីដើម្បីបំពេញការងារនេះ រីដើម្បីចូលរួមក្នុងពិធីនេះក្នុងឋានៈជាជំនួយការ ។ នារីធ្វើសិបពុគូ ដោយគ្រាន់តែចាក់កាំបិតទំលាយដើមទ្រូងខ្លួនតែប៉ុណ្ណោះ ។

- ចាំបន្តិចទៀត មិនមែនពេលនេះទេ -*យ៉ាំប៉ូ* ឆ្លើយទៅប្រពន្ធ ។

- បើអីចឹងបញ្ជូន *ស៊ូគិម៉ូតូ* ទៅ ។ គេជាមនុស្សទុកចិត្តបានដែរតើ ។

- បើសិនជាលោកម្ចាស់ *តូរ៉ាណាកា* មិនបញ្ជាថា ទាំងប្រពន្ធដើម ទាំងប្រពន្ធចុងត្រូវទៅទីនេះទាំងអស់គ្នាទេនោះ បងនឹងអោយអូនទៅវិញ ។ ប៉ុន្តែនេះ គឺប្រថុយប្រថានខ្លាំងណាស់ ។ បងត្រូវតែទៅ ព្រោះបងគ្មានជំរើសណាផ្សេងទៀតទេ ។ *យូរីកូ-សាន* អូនបានប្រាប់បងហើយថា ឃ្លាំងទ្រព្យយើងនៅទទេគ្រហត ហើយអូនថា ពួកអាបុលប្រាក់ចង្រៃយក៏ទាំងនោះវាលែងអោយយើងខ្ចីលុយវាទៀត ។ *ស៊ូគិម៉ូតូ* បានប្រាប់ថា ពន្ធដែលយើងយកពីពួកកសិករនោះគឺ វាដល់កំរិតកំពូលទៅហើយ ។ បងត្រូវការសេះ អាវុធ ដាវ លំពែង និង*សាមូរ៉ៃ* បន្ថែមទៀត ។ សំពៅនេះអាចផ្តល់នូវមធ្យោបាយ ដើម្បីដោះស្រាយបញ្ហាទាំងនេះបានផងក៏មិនដឹង ។

- បញ្ជារបស់លោកម្ចាស់ *តូរ៉ាណាកា* គឺច្បាស់ណាស់លោកប្រុស ។ បើសិនជាគាត់ត្រលប់មកវិញ ហើយដឹង...

- ដឹងហើយ ។ បើសិនជាគាត់ត្រលប់មកវិញ ។ បងនៅតែគិតថា គាត់កំពុងចូលក្នុងអន្ទាក់ហើយ ។ គ្រាន់តែនៅជុំវិញ និង ក្នុងវិមាន *អូសាកា* ម៉ាកន្លែងណឹងលោកម្ចាស់ *អ៊ីស៊ីដូ* មាន*សាមូរ៉ៃ* ប្រាំបីពាន់នាក់ទៅហើយ ។ លោកម្ចាស់ *តូរ៉ាណាកា* ចំជាឆ្កួតមែន ដែលហ៊ានទៅកន្លែងនោះដោយយកកំលាំងទៅតែប៉ុន្មាននាក់យ៉ាងនេះ ។

- លោកម្ចាស់ *តូរ៉ាណាកា* មានការឈ្លាសវៃណាស់ ដោយហេតុនេះគាត់ មិនប្រថុយស្បែកទទេ ៗនោះទេ-ប្រពន្ធ *យ៉ាំប៉ូ* តបយ៉ាងទុកចិត្ត ។

- បើសិនជាបងជា *អ៊ីស៊ីដូ* វិញ ហើយបាន *តូរ៉ាណាកា* នៅក្នុងកណ្តាប់ដៃហើយនោះ បងនឹងសំលាប់គាត់នេះចោលភ្លាម ។



www.budinst.gov.kh www.elibraryofcambodia.org

- ចាស់-*យូរិកូ* តប- ប៉ុន្តែម្តាយរបស់ទាយាទនៃអម្ចាស់ តែកូ នៅជាចំនាប់ខ្ទាំងនៅយេដូរង់ចាំការវិលត្រលប់របស់លោកម្ចាស់ *តូរ៉ាណាកា* នៅឡើយ ។ លោកមេទ័ព *អ៊ីស៊ីដូ* ពិតជាមិនហ៊ានប៉ះពាល់លោកម្ចាស់ *តូរ៉ាណាកា* ឡើយ ដរាបណាលោកស្រីមិនត្រលប់ទៅអូសាកាវិញនោះ ។

- បងនឹងសំលាប់គាត់ ។ រឿងលោកស្រី *អូជីបា* ស្លាប់រស់មិនមែនជាការសំខាន់ទេ ។ ទាយាទរបស់អម្ចាស់មានសន្តិសុខនៅអូសាកាហើយ ។ បើ *តូរ៉ាណាកា* ស្លាប់ការបន្តមរតកគឺគ្មានបញ្ហាទេ ។ *តូរ៉ាណាកា* គឺជាគ្រោះតំរាមកំហែងតែមួយគត់ ចំពោះទាយាទអម្ចាស់ និងជាមនុស្សតែមួយគត់ ដែលអាចប្រើក្រុមប្រឹក្សាអាជ្ញានុសិទ្ធិដណ្តើមយកអំនាចអម្ចាស់ *តៃកូ* និងសំលាប់កូនរបស់អម្ចាស់បាននោះ ។

- សូមលោកអភ័យទោសអោយខ្ញុំចុះ ។ ប៉ុន្តែក៏អាចថា លោកមេទ័ព *អ៊ីស៊ីដូ* អាចបញ្ចុះបញ្ចូលសមាជិកបីនាក់ទៀតនៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ហើយបដិសេធលោកម្ចាស់ *តូរ៉ាណាកា* ទៅ នេះមិនគឺលោកម្ចាស់ *តូរ៉ាណាកា* ត្រូវចប់ទើរី ?- ប្រពន្ធចុងរបស់ *យ៉ាប៊ូ* លូកមាត់ ។

- ពិតហើយនាង ! បើ *អ៊ីស៊ីដូ* អាចធ្វើបានមែននោះគាត់នឹងធ្វើបាត់ទៅហើយ ។ ប៉ុន្តែខ្ញុំគិតថា គាត់មិនអាចធ្វើបាន រឺថាគាត់មិនទាន់អាចធ្វើបាននៅឡើយ ។ *តូរ៉ាណាកា* ក៏អីចឹងដែរ ។ អម្ចាស់ *តៃកូ* ជ្រើសរើសសមាជិកក្រុមប្រឹក្សាយ៉ាងឈ្លាសវៃបំផុត ។ ពួកគេទាំងប្រាំនាក់ស្អប់ខ្ពើមគ្នាយ៉ាងខ្លាំងរហូតដល់ពួកគេមិនអាចឈានទៅសំរេចអ្វីទាំងអស់ ។ អីចឹងទៅការដឹកនាំជាឯកច្ឆន្ទមានន័យថា គ្មានអ្នកណាអាចកែប្រែអ្វីទាំងអស់រហូតដល់ *យ៉ែមុ៉ន* ឡើងកាន់អំនាចតែម្តង ។

នៅមុនពេលឡើងកាន់អំនាច មហា *ដៃមីញ៉ូ* ទាំងប្រាំបានធ្វើការស្បថស្បែជាសាធារណៈថា ខ្លួននឹងនៅតែស្មោះត្រង់ជានិច្ច ចំពោះអម្ចាស់ *តៃកូ* ដែលជិតផុតដង្ហើមនោះក៏ដូចជាចំពោះកូនប្រុស និងមាតាអម្ចាស់ *តៃកូ*ផងដែរ ។ ពួកគេក៏បានធ្វើការសច្ចាមុខវត្ថុស័ក្តិសិទ្ធិនិងជាសាធារណៈផងដែរថា នៅក្នុងក្រុមប្រឹក្សានេះពួកគេនឹងធ្វើការដឹកនាំជាឯកច្ឆន្ទ ហើយប្តេជ្ញាថានឹងប្រគល់អំនាចទាំងអស់អោយ *យ៉ែមុ៉ន* វិញនៅក្នុងថ្ងៃខួបកំនើតទីដប់ប្រាំរបស់គេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ប៉ុន្តែលោកម្ចាស់អាចមានថ្ងៃណាមួយ សមាជិកក្រុមប្រឹក្សាទាំងបួនអាចរួមគ្នាប្រឆាំងមួយបាន តាមរយៈការខ្លាច តាមរយៈការច្រណែនឬមហិច្ឆតា*ទេ* ? ដល់អ៊ីចឹងទាំងបួននោះអាចបង្វែរបញ្ជាអម្ចាស់ *តៃកូ* ដើម្បីធ្វើសង្គ្រាម*ទេ*?

- មែនហើយ តែនោះគឺគ្រាន់តែជាសង្គ្រាមដ៏តូចតែប៉ុណ្ណោះ ។ អ្នកឯកោតែងតែបរាជ័យជានិច្ច ។ ទឹកដីរបស់គេនឹងត្រូវអ្នកឈ្នះបែងចែកគ្នា ហើយពួកគេនឹងរើសអ្នកទីប្រាំម្នាក់ទៀត ហើយយូរបន្តិចទៅនឹងមានបួនទល់មួយទៀត ហើយអ្នកឯកោនឹងត្រូវកំទេច ទឹកដីគេត្រូវបែងចែកទៀត គឺអ្វី ៗ ដូចដែលអម្ចាស់ តៃកូ បានគ្រោងទុកអ៊ីចឹង ។ បញ្ហាតែមួយរបស់បងគឺថា តើអ្នកណាជាអ្នកឯកោក្នុងពេលនេះ ? ជា *អ៊ីស៊ីដូ* ឬជា *តូរ៉ាណាកា*?

- *តូរ៉ាណាកា* នឹងឯកោ ។

- ហេតុអ្វី ?

- អ្នកឯទៀតខ្លាចគាត់ពេក ពីព្រោះទាំងអស់គ្នាដឹងថា គាត់ចង់ជាសំងាត់ក្លាយខ្លួនទៅជាស្ញូគុន ថ្វីត្បិតតែគាត់ប្រកែកថា មិនចង់យ៉ាងណាក្តី ។

SHOGUN គឺជាតំណែងដ៏ខ្ពស់កំពូលដែលមនុស្សធម្មតាអាចឈានឈោងដល់ ។ *ស្ញូគុន* មានន័យថា អគ្គមហាសេនា ។ នេះជាតំណែងមានតែមួយគត់សំរាប់ *ដៃមីញ៉ូ* តែ ម្នាក់ក្នុងចំនោម *ដៃមីញ៉ូ* ទូទាំងប្រទេស ហើយតំណែងនេះ គឺមានតែព្រះអធិរាជដែលគង់នៅ ដាច់ពីគេឯងជាមួយព្រះរាជវង្សានុវង្សនៅឯក្យូតូនោះទេ ដែលជាអ្នកប្រទាននោះ ។

ទទួលតំណែងជា ស្ញូគុន គឺមានន័យថា ក្តាប់អំនាចកំពូល នោះគឺត្រា និង រាជបញ្ជារបស់ព្រះចៅអធិរាជ ។ *ស្ញូគុន* គ្រប់គ្រងប្រទេសក្នុងនាមព្រះចៅ ។ អំនាចទាំងអស់ចេញមកពីព្រះចៅអធិរាជ ព្រោះព្រះអង្គជាអំបូរផ្ទាល់របស់ព្រះ ។ ដោយហេតុនោះ *ដៃមីញ៉ូ* ណាក៏ដោយអោយតែហ៊ានជំទាស់នឹង *ស្ញូគុន* គឺត្រូវចាត់ទុកជាស្វ័យប្រវត្តិថា ប្រឆាំងនឹងព្រះរាជបល្ល័ង្កដោយហេតុនេះត្រូវទំលាក់ចេញពីមុខតំណែង ហើយទឹកដីរបស់គេនឹងត្រូវរឹបអូស ។

ព្រះចៅអធិរាជត្រូវបានគេគោរពដូចជាព្រះ ពីព្រោះព្រះអង្គជាព្រះញាតិវង្សផ្ទាល់នៃព្រះទេពធីតាព្រះអាទិត្យព្រះនាម *អាម៉ាត់តេរ៉ាស៊ូអូមីកាមី* ដែលជាព្រះរាជបុត្រីម្នាក់ ក្នុងចំនោមបុត្រា



www.budinst.gov.kh www.elibraryofcambodia.org

បុត្រីនៃព្រះអាទិទេព *អ៊ីសណាគីអ៊ីសាណាមី* អ្នកដែលជប់ទឹកដីជប៉ុនចេញពីនភាល័យ ។ តាមទេវបញ្ញត្តិ ព្រះចៅអធិរាជ គឺជាម្ចាស់លើដីទូទាំងនគរ ហើយបញ្ជារបស់ព្រះអង្គត្រូវតែគោរពតាមដោយគ្មានប្រកែកជំទាស់អ្វីទាំងអស់ ។ ប៉ុន្តែនៅក្នុងការជាក់ស្តែង ជាងប្រាំមួយរយឆ្នាំមកនេះអំនាចពិតប្រាកដរមែងនៅពីក្រោយរាជបល្ល័ង្កទៅវិញទេ ។

កាលពីប្រាំមួយរយឆ្នាំមុននេះ ត្រកូលពីរក្នុងចំនោមត្រកូលប្រជែងគ្នាទាំងបី នៃក្រសែ *សាមូរ៉ៃ* គឺ *មីណូរ៉ាក៉ា តូជីម៉ូតូ* និង *តាកាស៊ីមា* បានគាំទ្រអ្នកដែលប្រកួតគ្នា ដើម្បីឡើង សោយរាជ្យ ហើយដែលបានធ្វើអោយប្រទេសជាតិធ្លាក់ចុះក្នុងសង្គ្រាមផ្ទៃក្នុងមួយ ។ ហុកសិបឆ្នាំ ក្រោយមក ត្រកូល *មីណូរ៉ាក៉ា* បានឈ្នះលើត្រកូល *តាកាស៊ីមា* ។ ក្នុងរយៈពេលជំលោះនេះត្រកូល *តូជីម៉ូតូ* បានស្ថិតនៅជាអព្យាក្រិត ហើយសំងំរង់ចាំពេលវេលារបស់ខ្លួន ។

តាំងពីពេលនោះមក ដើម្បីរក្សាអោយបានណែននៅក្នុងដៃនូវអំនាចរបស់ខ្លួន *ស្ហូគុន មីណូរ៉ាក៉ា* បានបង្ក្រាបប្រទេសទាំងមូល ហើយប្រកាសថា តួតំនែង *ស្ហូគុន* គឺជាកេរដំនែលសំរាប់តែត្រកូល *មីណូរ៉ាក៉ា* តែប៉ុណ្ណោះ ។ ក្រៅពីនេះពួកគេនៅបានប្រឹងប្រែងរៀបការកូនស្រីពួកគេជាមួយក្រសែព្រះចៅអធិរាជថែមទៀត ។ ព្រះចៅអធិរាជ និងក្រុមបរិពារត្រូវបានគង់ និងស្ថិតនៅតែក្នុងរាជវាំង នៅតំបន់ចង្អៀតមួយនៃទីក្រុងក្យូតូ ហើយជាញឹកញាប់នៅក្នុងភាពខ្វះខាតថែមទៀតផង ។ សកម្មភាពរបស់ព្រះចៅអធិរាជ និងបរិពារជាសំខាន់គឺគោរពទំនៀមស៊ីនតូ ដែលជាសាសនារបស់ប្រទេសជប៉ុន ហើយនិងធ្វើសកម្មភាពផ្នែកសតិបញ្ញាខ្លះ ៗ ដូចជាឆ្លាក់អក្សរ គូររូប រៀនទស្សនវិជ្ជា និងសរសេរកំនាព្យជាដើម ។

ព្រះរាជវាំងងាយស្រួលនឹងក្តាប់ណាស់ ព្រោះថ្វីត្បិតតែព្រះចៅអធិរាជ ជាម្ចាស់លើដីទាំងអស់ក្តី ប៉ុន្តែរាជវាំងគ្មានចំនូល ហើយក៏គ្មានសិទ្ធិយកពន្ធដែរ ។ ដោយហេតុនេះថ្វីត្បិតតែព្រះរាជវង្សានុវង្សនៃព្រះរាជវាំងមានឋានៈខ្ពស់ជាងពួក*សាមូរ៉ៃ* ទាំងអស់ក្តី ក៏ទាំងអស់គ្នារស់នៅអាស្រ័យដោយប្រាក់បំនាច់ដែលផ្តល់អោយតាមទំនើងចិត្តរបស់ *ស្ហូគុន* រឺដោយពួកក្រុមមេទ័ពដែលកាន់អំនាច រឺដោយ*ភ្ញានបាកូ* ប្រធានទីប្រឹក្សាស៊ីវិលតែប៉ុណ្ណោះ ។ ក្នុងចំនោមអ្នកទាំងនេះមានតិចណាស់ ដែលមានសន្តានចិត្តសប្បុរសនោះ ។ ព្រះចៅអធិរាជខ្លះត្រូវប្តូរព្រះហស្តលេខាជាមួយព្រះស្មោយផងក៏មាន ។ ជាច្រើនដងហើយ ដែលរាជវាំងខ្វះលុយ ដើម្បីធ្វើពិធី



www.budinst.gov.kh www.elibraryofcambodia.org

អភិសេកនោះ ។

ប៉ុន្តែនៅចំនេរក្រោយមកទៀត សូគុនត្រកូល *អ៊ីឈូកាំកា* បានបាត់បង់អំនាចរបស់ខ្លួននៅចំពោះមុខត្រកូល *តាកាស៊ីមារី ភូជីម៉ូតូ* វិញម្តង ។ ហើយនៅពេល ដែលសង្គ្រាមផ្ទៃក្នុងកាន់តែបន្តទៅទៀតដោយគ្មានថមថយអស់ច្រើនសតវត្សទៅទៀតនោះ ព្រះចៅអធិរាជក៏កាន់តែក្លាយខ្លួនជាមនុស្សរបស់ *ដៃមីញ៉ូ* ណាដែលមានកំលាំងកាន់កាប់ក្សត្តបាន ។ នៅពេលណាដែលអ្នកឈ្នះថ្មីទន្រ្ទានកាន់កាប់ក្សត្ត និងកាប់សំលាប់សូគុន ហើយនឹងក្រុមគ្រួសាររបស់គេហើយអ្នកនោះនឹងមកស្បថស្បែយ៉ាងសុភាពនៅចំពោះមុខព្រះចៅ ដែលគ្មានអំនាចអ្វីទាំងអស់នោះនូវភក្តីភាពរបស់ខ្លួន ហើយនឹងទូលសុំព្រះរាជាអោយផ្តល់តំនែង*សូគុន* ដែលនៅទំនេរនោះមកអោយគេ ។ រួចហើយដូចជាអ្នកមុនៗ ដែរ សូគុនថ្មីខិតខំពង្វាតអំនាចរបស់ខ្លួនពីក្សត្តទៅរហូតដល់ពេលណាមួយដែលខ្លួនត្រូវអ្នកណាម្នាក់ទៀតផ្តួលរំលំបាន ។ សូគុន ជាអ្នកសំរេចអោយព្រះចៅរៀបការជាមួយអ្នកណាដាក់រាជ្យរឺឡើងសោយរាជ្យនៅពេលណាតាមឆន្ទៈរបស់ខ្លួន។ ប៉ុន្តែមានប្រការតែមួយទេដែលគ្មានអ្នកណាហ៊ានកែប្រែ នោះគឺសន្តិវង្សព្រះចៅគ្មានអ្នកណារំលោភបាន ហើយក៏គ្មានអ្នកណាមានសិទ្ធិជ្រែករាជ្យបានឡើយ ។

ហេតុនេះសូគុន គឺជាអ្នកមានអំនាចកំពូល ។ រហូតដល់ពេលត្រូវគេផ្តួលរំលំ ។

មានពេលខ្លះតំនែង *សូគុន* គ្មានបានអ្នកណាម្នាក់ទទួលឡើយ ដោយហេតុថាចក្រភពត្រូវបែងចែកជាបក្សពួកតូច ៗ ។ ដូចជាក្នុងមួយរយឆ្នាំចុងក្រោយនេះគ្មាន *ដៃមីញ៉ូ* ណាម្នាក់មានអំនាចខ្លាំងក្លាគ្រប់គ្រាន់ ដើម្បីក្លាយខ្លួនជា*សូគុន* ឡើយ ។ កាលពីដប់ពីរឆ្នាំមុននេះលោកមេទ័ពកសិករនាម *ណាកាមូរ៉ា* ដណ្តើមបានអំនាចទាំងអស់ ហើយតែថែមទាំងទទួលអំនាចទាំងអស់ពីព្រះចៅបច្ចុប្បន្ននេះ គឺព្រះចៅគូនីចូ ទៀតផង ។ ប៉ុន្តែ *ណាកាមូរ៉ា* មិនអាចទទួលតំនែងជាសូគុនបានទេ ទោះជាគេប៉ុនប៉ងយ៉ាងណាក្តី ដោយហេតុថា *ណាកាមូរ៉ា* បានកើតក្នុងត្រកូលកសិករ ។ ដោយហេតុនេះ *ណាកាមូរ៉ា* ត្រូវតែសុខចិត្តទទួលឋានៈនាទីស៊ីវិលគឺ*ក្វានប៉ាគូ* ទៅ ហើយនៅពេលដែលគេសំរេចប្រគល់តំនែងនេះទៅអោយកូនរបស់ខ្លួន គេនៅតែរក្សាអំនាចដដែលនេះ ដោយបានទទួលគោរម្យងារជាតៃកូនេះ ។ តាមប្រពៃណីប្រវត្តិសាស្ត្រ អ្នកដែលអាច



www.budinst.gov.kh www.elibraryofcambodia.org

ទទួលតួនាទីសូគុន នេះបានមានតែក្រុមត្រកូលជាប់ស្រលាយព្រះមហាក្សត្រ ទាំងបីនេះទេ គឺត្រកូល *មីណូវ៉ា៉* *តាកាស៊ីមា* និង *កូជីម៉ូតូ* ។

*តូរ៉ាណាកា* គឺជាសែស្រលាយ *មីណូវ៉ា៉* ចំណែកឯ *យ៉ាប៊ូ* ជាប់សែស្រលាយបន្តិចបន្តួចទៅនឹងត្រកូល *តាកាស៊ីមា* ។

*យ៉ាប៊ូ* និយាយបន្ត :

-ជាការពិតហើយ *តូរ៉ាណាកា* ចង់បានតំនែងសូគុន មែន ។ ប៉ុន្តែគាត់នឹងមិនសំរេចបានទេ ។ សមាជិកក្រុមប្រឹក្សាឯទៀតស្អប់គាត់ផង ខ្លាចគាត់ផង ។ ពួកគេនឹងដកធ្មុងគាត់ដូចអម្ចាស់ តែកូ បានគ្រោងទុកអ៊ីចឹង ។

រួច *យ៉ាប៊ូ* អោនទៅរកប្រពន្ធខ្លួន ហើយសំលឹងមើលនាងយ៉ាងមុត :

- អ៊ីចឹងអូនថា *តូរ៉ាណាកា* នឹងចាញ់ *អ៊ីស៊ីដូ* អ្ហេស ?

- ចាស់ គាត់នឹងត្រូវគេឯកោ ។ ប៉ុន្តែនៅទីបំផុតខ្ញុំមិនគិតថា លោកម្ចាស់ *តូរ៉ាណាកា* ចាញ់ឡើយ ។ លោកប្រុស ! ខ្ញុំសូមអង្វរលោកប្រុស ! សូមកុំជំទាស់នឹងបញ្ជារបស់លោកម្ចាស់ *តូរ៉ាណាកា* និងសូមកុំចាកចេញពី *យេដូ* នេះដោយគ្រាន់តែដើម្បីទៅមើលសំពៅពួកចុងស្រុកនោះអោយសោះ ។ ទោះជារឿងនោះប្លែកចំលែកដូច *អូមី-សាន* បានប្រាប់យ៉ាងណាក្តី ។ សូមលោកប្រុសបញ្ជូន *ស៊ូគីម៉ូតូ* ទៅ *អាន់ជីរ៉* ទៅ ។

-រួចចុះបើសំពៅមានមាស មានប្រាក់ទៅវិញ តើអូនទុកចិត្ត *ស៊ូគីម៉ូតូ* រឺមេកងណាមួយរបស់យើងនេះទេ ?

- ចាស់ទេ-ប្រពន្ធ *យ៉ាប៊ូ* ឆ្លើយ ។

ដោយហេតុនេះហើយ ទើបនៅយប់នោះគេបានលបចេញជាសំងាត់ពីទីក្រុង *យេដូ* ដោយនាំមកតែមនុស្សហាសិបនាក់ប៉ុណ្ណោះ ។ ឥឡូវនេះគេមានទ្រព្យសម្បត្តិនិង មានអំនាចលើសពីការយល់សប្តិរបស់គេទៅទៀត ហើយឈ្លើយទាំងអស់នៅក្នុងកណ្តាប់ដៃរបស់គេ លើកលែងតែម្នាក់ដែលត្រូវស្លាប់យប់នេះតែម្តងប៉ុណ្ណោះ ។ ព្រលឹមស្រាង ១ ស្អែកគេនឹងវិលត្រលប់ទៅ *យេដូ* វិញ ប៉ុន្តែទាល់តែពេលព្រលប់ស្អែក ទើបមាសនិងកាំភ្លើងទាំងអស់ចាប់ផ្តើមចេញ



www.budinst.gov.kh www.elibraryofcambodia.org

ដំណើរជាសំងាត់របស់ខ្លួន ។

-កាំភ្លើង ! កាំភ្លើង !- *យ៉ាប៉ូ* គិតទាំងលោតកញ្ឆេងនៅក្នុងចិត្ត - កាំភ្លើងគួបផ្សំនឹងគំរោងផែនការនឹងផ្តល់អោយអញនូវអំនាច ដែលអាចធ្វើអោយ *អ៊ីស៊ីដូ រីតូរ៉ាណាកា* ឈ្នះបានស្រេចតែអ្នកណាមួយអញគាំទ្រ ។ រួចអញនឹងទៅជាសមាជិកទីប្រឹក្សាដើម្បីអង្គុយនៅ កន្លែងដែលទំនេរ *នេ ?* រួមមកទៀតអញនឹងក្លាយជាសមាជិកទីប្រឹក្សាដ៏មានអំនាចជាងគេ អីចឹងហើយមានអ្វីដែលថាអញមិនក្លាយខ្លួនទៅជា *ស្គុន* នោះ ។ អ្វី ១ ក៏អាចសំរេចបានតែទាំងអស់ហ្នឹងក្នុងពេលអីលូវនេះ ។

គេបណ្តែតខ្លួនយ៉ាងរីករាយនៅក្នុងទឹក ។ តើយកលុយពីរយពាន់កាសប្រាក់នេះទៅចាយអ្វីខ្លះអីចេះ ? អញអាចជូសជុលប៉មវិមានអញបាន ហើយអញទិញសេះ ពិសេសសំរាប់អូសកាណុង ។ អញនឹងពង្រីកបណ្តាញយកការណ៍របស់អញ ។ រួចចុះគិតយ៉ាងម៉េចរឿង *អ៊ីកាវ៉ា ស៊ីគីយូ ?* តើកាសប្រាក់មួយពាន់អាចជួលចុងភៅរបស់ *អ៊ីកាវ៉ា ស៊ីគីយូ* អោយបំពុលវាបានទេហ្ន៎ ? ច្បាស់ជាបាន ! តែប្រាំរយក៏បានដែរ ហើយបើរកចំមនុស្សតែមួយរយកាសនោះច្រើនពេកផង ។ ប៉ុន្តែរកអ្នកណាហ្ន៎ ?

កាំរស្មីព្រះអាទិត្យនាពេលរសៀលចាំងឆ្លុះចូលតាមបង្អួចតូចមួយ ដែលចោះនៅលើជញ្ជាំងថ្ម ។ ទឹកមុជមានកំដៅយ៉ាងខ្លាំង អាស្រ័យដោយកំលាំងភ្លើងអុសដែលគេដុតបំពក់ពីខាងក្រៅជញ្ជាំងថ្មនេះ ។ ផ្ទះនេះគឺជាផ្ទះរបស់ *អូមី* ។ ផ្ទះនេះសង់នៅលើកូនភ្នំតូចមួយដែលអាចអោយគេមើលឃើញភូមិទាំងអស់ ហើយនិងកំពង់ផែទៀតផង ។ សួនច្បារនៅក្នុងភូមិរបស់ *អូមី* ស្អាត ស្ងប់ស្ងាត់និងផ្លែផ្កាល្អណាស់ ។

ទ្វារបន្ទប់មុជទឹករបើកឡើង ។ បុរសកង្វាក់លំអោនខ្លួន :

- លោកម្ចាស់ *កាស៊ីគី អូមី-សាន* បញ្ជូនខ្ញុំបាទមកទាន ។ ខ្ញុំបាទឈ្មោះ *ស៊ូរ៉ី* ជាអ្នកធ្វើសវសែរបស់លោកម្ចាស់ *អូមី* ទាន !

បុរសនោះមាឌខ្ពស់ ស្គមត្រដឹត និងមានវ័យចំនាស់ទៅហើយ ។ ផ្ទៃមុខរបស់គេពេញទៅដោយភាពជ្រីវជ្រួញ ។

- ល្អ ។



www.budinst.gov.kh www.elibraryofcambodia.org

មួយជីវិតរបស់ខ្លួន *យ៉ាប៊ូ* ខ្លាចបំផុតរឿងដែលខ្លួនទៅជាមនុស្សខ្វាក់ ។ គេធ្លាប់ចាំរឿងគេបានយល់សប្តិថា គេបានដើរនៅក្នុងភាពអន្ធការ ថ្វីត្បិតតែអារម្មណ៍គេដឹងថា ពេលនោះព្រះអាទិត្យកំពុងចែងចាំងស្ទើរចិញ្ចាចចិញ្ចែងយ៉ាងណាក៏ដោយ ព្រោះពេលនោះនៅលើស្បែករបស់គេៗ បានទទួលកំដៅរបស់ព្រះអាទិត្យ ហើយគេក៏បានស្រែករហូតទាល់តែគេភ្ញាក់ដឹងខ្លួនទាំងញើសជោក ។

ប៉ុន្តែគេខ្លាចភាពកង្វាក់ពេលណា ការសប្បាយរបស់គេ ក៏កាន់តែមានច្រើនពេលនោះដែរ នៅពេលណាដែលមនុស្សខ្វាក់មកធ្វើសរសៃអោយគេ ។

*យ៉ាប៊ូ* សង្កេតឃើញថា នៅស្មៀតផ្កាខាងស្តាំរបស់មនុស្សនេះមានសំលាកយ៉ាងជ្រៅមួយ ។ នេះគឺស្នាមដាវតែម្តង-*យ៉ាប៊ូ* សញ្ជឹងគិត ។ តើមុខរបួសនេះវីដែលធ្វើអោយបុរសនេះខ្វាក់នោះ ? តើពីដើមវាធ្លាប់ជា*សាមូរ៉ៃ*? បើជា*សាមូរ៉ៃ* តើវាធ្វើការអោយអ្នកណា ? តើវាជាអ្នកយកការណ៍រឺក៏មិនមែន ?

*យ៉ាប៊ូ* ដឹងច្បាស់ណាស់ថា មុននឹងចូលមកដល់ទីនេះបាន ពួកអង្គរក្សរបស់គេបានឆែកឆេរបុរសខ្វាក់នេះ ដើម្បីរកអាវុធយ៉ាងម៉ត់ចត់ណាស់ ដោយហេតុនេះគេគ្មានខ្លាចថា បុរសនេះអាចមានលាក់អាវុធអ្វីបាននោះទេ ។ ម្យ៉ាងទៀតដាវដ៏វែង និង ដ៏ល្អរបស់គេនៅជិតដៃរបស់គេស្រាប់ ។ នេះគឺជាដាវបុរាណដែលកសាងដោយជាងដាវដែងឯក *មូរ៉ាសាម៉ា* ។ គេសំលឹងមើលបុរសខ្វាក់ដោះអាវគីម៉ូណូអំបោះរបស់ខ្លួនចេញ ហើយយកទៅព្យួរដោយមិនចាំបាច់រាវរកឡើយ ។ នៅលើទ្រូងមានសំលាកដែលបណ្តាលមកពីស្នាមដាវច្រើនទៀត ។ សៃដែលរុំព័ទ្ធគេជាខោស្លាប់ភ្លៅនោះស្អាតភ្លឹង ។ បុរសនោះលុតជង្គង់ចុះ ហើយនៅរង់ចាំយ៉ាងស្ងៀមស្ងាត់និងយ៉ាងអត់ធ្មត់ ។

ពេលរួចរាល់ហើយ *យ៉ាប៊ូ* ងើបចេញពីអាងទឹក ហើយទៅដេកនៅពីលើកៅអីថ្ម ។ បុរសចំនាស់ជូតសំងួតសាប៊ូយ៉ាងថ្នម ១ រួចបន្ទាប់ពីចាក់ប្រេងក្រអូបលើបាតដៃរបស់ខ្លួនហើយក៏ចាប់ផ្តើមឈ្លីក និង ខ្នងរបស់ *វ៉ៃមីតូ* ។

ភាពរោយស្រពន់ទាំងប៉ុន្មាន ចាប់ផ្តើមរលាយបាត់នៅពេលដែលម្រាមដៃដ៏ប៉ិនប្រសប់



www.budinst.gov.kh www.elibraryofcambodia.org

បានចាប់ផ្ដើមខ្ទេះកកាយសព្វខ្លួនប្រាណរបស់*យ៉ាប៊ូ* មក ។

- ល្អណាស់ ! ល្អណាស់ ! -*យ៉ាប៊ូ* និយាយសរសើរ ។

- សូមអរគុណ *យ៉ាប៊ូ-សាម៉ា-សាម៉ា* មានន័យថា " លោកម្ចាស់ " ជាពាក្យដែលអ្នកតូចត្រូវប្រើនៅពេលដែលនិយាយជាមួយអ្នកដែលមានឋានៈខ្ពស់ជាងខ្លួន ។

-អែងនៅបំរើ*អូមី- សាន* យូរហើយអ្ហី ?

- បីឆ្នាំហើយលោកម្ចាស់ ។ លោកម្ចាស់*អូមី* មានសន្ដានចិត្តល្អណាស់ចំពោះមនុស្សចាស់ជរា ។

- រួចចុះមុនហ្នឹង ?

-ខ្ញុំបាទដើរពនេចរពីភូមិមួយទៅភូមិមួយ ។ ពីរបីថ្ងៃនៅឯណោះ កន្លះឆ្នាំនៅឯណោះ ដូចជាមេអំបៅរដូវផ្ការីកអ៊ីចឹងដែរទាន ។

សំលេងរបស់ *ស៊ូរ៉ូ* ស្រទន់ប្រៀបបីដូចជាម្រាមដៃរបស់ខ្លួនអ៊ីចឹងដែរ ។ គេដឹងថា *ដៃមីក្វូ* ចង់អោយគេនិយាយ ដោយហេតុនេះគេរង់ចាំយ៉ាងស្ងប់ស្ងៀមនូវសំនួរដែល *ដៃមីក្វូ* នឹងសួរបន្តទៀត រួចគេនឹងចាប់និយាយបន្ត ។ ផ្នែកមួយនៃសិល្បៈរបស់គេគឺត្រូវដឹងថា អ្នកឯទៀតក៏ចង់បានអ្វីនិងនៅពេលណា ។ត្រចៀករបស់គេលឺម្យ៉ាង ប៉ុន្តែគឺម្រាមដៃរបស់គេទេដែលជាអ្នកប្រាប់ពីអ្វីដែលនៅជាអាថិកំបាំងនៅក្នុងខួរក្បាលរបស់បុរស រីនារីនោះ ។ ពេលនេះម្រាមដៃរបស់គេប្រាប់គេអោយប្រុងប្រយ័ត្នមនុស្សនេះ ។ ម្រាមដៃរបស់គេប្រាប់គេថា មនុស្សដែលគេកំពុងឈ្លីសរសៃនេះជាមនុស្សមានគ្រោះថ្នាក់ ជាមនុស្សឆាប់ម្ហូរចិត្ត ដូរគំនិត ស្ថិតក្នុងវ័យប្រហែលសែសិបឆ្នាំ ជាអ្នកជិះសេះដ៏ចំនាន និងជាអ្នកគុនដាវដ៏កំពូល ។ ប៉ុន្តែគេក៏ដឹងដែរថា ថ្លើមរបស់មនុស្សនេះកំពុងមានជំងឺ ហើយគេនឹងស្លាប់ក្នុងពេលពីរឆ្នាំទៀត ។ នេះរឺមួយមកពីស្រា រឺមួយមកពីថ្នាំកំរើកសរសៃច្រើនពេកហើយមើលទៅ ។

- លោកម្ចាស់អាយុប៉ុណ្ណឹងហើយនៅតែមាំទាំល្អណាស់ ។

- អែងក៏អ៊ីចឹងដែរ ។ អែងអាយុប៉ុន្មានហើយ ?

បុរសចំនាស់សើច ប៉ុន្តែម្រាមដៃរបស់គេឥតបញ្ឈប់ចលនាទេ :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំបាទជាមនុស្សចាស់ជាងគេក្នុងពិភពនេះ ។ ក្នុងពិភពរបស់ខ្ញុំបាទទាន ។ អ្នកដែលខ្ញុំបាទស្គាល់ទាំងប៉ុន្មានស្លាប់បាត់តាំងពីយូរយារណាស់មកហើយ ។ខ្ញុំបាទអាយុប្រហែលជាងប៉ែតសិបហើយលោកម្ចាស់ ។ តែរឿងអាយុនេះខ្ញុំបាទមិនសូវច្បាស់ដែរទេ ។ ខ្ញុំបាទធ្លាប់បំរើលោកម្ចាស់ *យ៉ូស៊ី ជីគីតាដា* ជាជីតារបស់លោកម្ចាស់ *តូរ៉ាណាកា* តាំងពីត្រកូលរបស់គាត់មានកម្មសិទ្ធិប្រហែលកូនភូមិតូចនេះម្ល៉េះ ។ ថ្ងៃដែលលោកម្ចាស់ *យ៉ូស៊ី ជីគីតាដា* ត្រូវគេធ្វើឃាតនោះខ្ញុំបាទក៏នៅបន្ទាយនោះដែរលោកម្ចាស់ ។

*យ៉ាប៊ូ* ប្រឹងរំងាប់ចិត្ត ដើម្បីរក្សាខ្លួនគេអោយនៅនឹងដូចធម្មតា ប៉ុន្តែខួរក្បាលរបស់គេចាប់កំរើកយ៉ាងរហ័ស ហើយគេចាប់ផ្តើមស្តាប់ដោយយកចិត្តទុកដាក់ជាងមុន ។

- ថ្ងៃនោះគឺជាថ្ងៃអាប់អួរបំផុត *យ៉ាប៊ូ-សាម៉ា* ។ ខ្ញុំបាទមិនចាំទេថា កាលនោះខ្ញុំបាទអាយុប៉ុន្មានទេ តែពេលនោះខ្ញុំបាទមិនទាន់បែកសំលេងផងទេ ។ ឃាតករគឺ *អូបាតាហ៊ីរ៉ូ* ជាកូនរបស់សម្ព័ន្ធមិត្តដ៏ខ្លាំងក្លារបស់គាត់ ។ ប្រហែលជាលោកម្ចាស់ធ្លាប់ដឹងរឿងនេះហើយ ។ កាលនោះ *អូបាតា ហ៊ីរ៉ូ* កាត់ក្បាលរបស់លោកម្ចាស់ជីគីតាដា ដាច់ត្រឹលតែមួយដាវគត់ ។ ដាវនោះធ្វើដោយត្រូដាវ *មូរ៉ាសាម៉ា* ។ ហើយចាប់ពីពេលនោះមកទើបគេមានជំនឿថា ដាវរបស់ជាងដែកមូរ៉ាសាម៉ាគឺតែងនាំស័យដល់បក្ខពួកក្រុម *យ៉ូស៊ី*។

តើវានិយាយរឿងនេះប្រាប់អញ មកពីអញមានដាវធ្វើដោយ *មូរ៉ាសាម៉ា* រឺក៏យ៉ាងម៉េច។ *យ៉ាប៊ូ* ដណ្តឹងសួរខ្លួនឯង ។ មនុស្សជាច្រើនដឹងថាអញមានដាវនេះមួយដែរ ។ រឺមួយក៏តាចាស់នេះនឹកឃើញថ្ងៃពិសេសបំផុតក្នុងជីវិតរបស់ខ្លួន ?

- តើជីតារបស់ *តូរ៉ាណាកា* រូបរាងយ៉ាងម៉េចទៅ ?

*យ៉ាប៊ូ* សួរទៅតាចាស់បែបវាហ៊ី ក្នុងបំនងស្ថាបស្ទង់ *ស៊ូរ៉ូ* ។

- ខ្ពស់ *យ៉ាប៊ូ-សាម៉ា* ។ ខ្ពស់ជាងលោកម្ចាស់ ហើយស្តើងជាងលោកម្ចាស់ ។ ពេលដែលគាត់ស្លាប់គាត់មានអាយុម្ភៃប្រាំឆ្នាំទាន-រួចសំលេងរបស់ *ស៊ូរ៉ូ* ហាក់ដូចជារំភើបជាងមុន-អូស ! *យ៉ាប៊ូ-សាម៉ា* ។ ពេលគាត់អាយុបានដប់ពីរឆ្នាំគាត់ក្លាយខ្លួនទៅជាអ្នកធ្វើសឹកបាត់ទៅហើយ ។ គាត់ក្លាយទៅជាលោកម្ចាស់យើងនៅអាយុដប់ប្រាំ ពេលដែលឪពុកគាត់ត្រូវស្លាប់ក្នុង



www.budinst.gov.kh www.elibraryofcambodia.org

ការប្រយុទ្ធមួយ ។ នៅពេលនោះលោកម្ចាស់ *គីជីតាដា* បានរៀបការរួចហើយ ១លោកមានកូនប្រុសមួយ ។ ស្តាយណាស់ដែលលោកម្ចាស់ *គីជីតាដា* ស្លាប់បាត់ទៅហើយ ។ *អូបាតាហ៊ីរ្ស* គឺជាមិត្តរបស់គាត់ផង ជាអ្នកចំនុះរបស់គាត់ផង ។ *អូបាតាហ៊ីរ្ស* កាលនោះអាយុទើបបានដប់ប្រាំពីរឆ្នាំប៉ុណ្ណឹង ប៉ុន្តែមានអ្នកណាចាក់ចុចគាត់ថា លោកម្ចាស់ *គីជីតាដា* មានគំរោងនឹងសំលាប់ឪពុកលោកប្រុស *អូបាតា* ក្នុងល្បិចកលពីក្រោយខ្នង ។ ក្រោយមកទើបគេដឹងថាទាំងអស់ណឹងសុទ្ធតែជាការកុហកទេ ប៉ុន្តែទោះជាយ៉ាងណាក៏លោកម្ចាស់ គីជីតាដា មិនអាចរស់រានមានជីវិតមកដឹកនាំយើងវិញបានដែរ ។ អ្នកប្រុសអូបាតា បានទៅលុតជង្គង់មុខលោកម្ចាស់ ហើយអោនគោរពបីដង ។ គាត់បាននិយាយថា គាត់បានបំពេញភារកិច្ចជាកូនកតញ្ញូចំពោះឪពុកខ្លួនរួចហើយ ១ ឥលូវគាត់ចង់លុបលាងកំហុស ដែលបណ្តាលមកពីគាត់ប្រមាថលើពួកយើង និងបក្ខពួកយើងដោយសុំធ្វើសិបពូគូ ។ ពួកយើងបានយល់ព្រម ។ ដំបូងគាត់លាងក្បាលលោកម្ចាស់ *ជីគីតាដា* ដោយផ្ទាល់ដៃគាត់ ហើយបន្ទាប់មកគាត់យកក្បាលនេះទៅកន្លែងសក្ការៈបូជា ។ បន្ទាប់មកទើបគាត់វះពោះគាត់ ហើយស្លាប់យ៉ាងអង់អាចសក្តិសមជាកូនប្រុសមែន ។ ពេលនោះមនុស្សម្នាក់នៅក្នុងក្រុមយើងបានទទួលធ្វើជាអ្នកជំនួយការដល់គាត់ ដើម្បីកាត់ក្បាលគាត់អោយដាច់តែមួយដាវតែប៉ុណ្ណោះ ។ ក្រោយមកទៀតឪពុកអ្នកប្រុស *អូបាតា* បានមកយកក្បាលកូនគាត់ហើយនឹងដាវរបស់ជាងឯក *មូរ៉ាសាម៉ា* នោះ ។ តាំងពីពេលនោះមកអ្វី ១ ក៏បានក្លាយទៅជាអាក្រក់បំផុតសំរាប់ពួកយើង ។ កូនប្រុសតែមួយគត់របស់លោកម្ចាស់ *គីជីតាដា* ត្រូវគេជំរិតយកទៅណាបាត់ ហើយបក្ខពួកយើងក៏បានចាប់ផ្តើមរង្គោះរង្គើ ។ នោះគឺ ...

-តាឯងកុហកហើយ ! តាឯងមិនដែលនៅទីនោះទេ !

*យ៉ាប៊ូ* ត្រលប់ផ្ងារខ្លួន ហើយសំលឹងមើលទៅតាចាស់ ដែលហាក់ដូចជានៅរឹងត្អឹតមួយរំពេច

- ដាវនោះត្រូវបាក់ ហើយត្រូវគេបំផ្លាញចោលក្រោយពី *អូបាតា* ស្លាប់ទៅនោះ

- អត់ទេ *យ៉ាប៊ូ-សាម៉ា* ។ នោះគឺជារឿងនិទានទេ ។ ខ្ញុំបាទបានឃើញឪពុករបស់អ្នកប្រុស *អូបាតា* ទៅដល់កន្លែង ហើយនឹងយកក្បាល ព្រមទាំងដាវនោះទៅវិញ ។ មានអ្នកហៅ



www.budinst.gov.kh www.elibraryofcambodia.org

បានបំផ្លាញរបស់ដ៏ល្អយ៉ាងនេះ ? បើបានបំផ្លាញគឺដូចជាប្រមាថព្រះរតនត្រ័យអីចឹង ។ ច្បាស់ណាស់ទាន ឪពុករបស់អ្នកប្រុស *អូបាតា* បានយកដាវនោះទៅវិញមែនទាន ។

- គេយកដាវនោះទៅធ្វើអ្វី ?

- អត់មានអ្នកណាដឹងទេទាន ។ អ្នកខ្លះថា គាត់យកដាវនោះទៅគ្រវែងចោលក្នុងសមុទ្រ ព្រោះគាត់ស្រលាញ់និងគោរពលោកម្ចាស់ *ជីគីតាដា* ដូចជាបងប្អូនបង្កើត ។ អ្នកខ្លះនិយាយថា គាត់បានកប់ដាវនោះ ហើយដាវនោះនៅវង់ចាំចៅរបស់លោកម្ចាស់ *ជីគីតាដា* គឺលោកម្ចាស់ *យ៉ូស៊ី តូរ៉ាណាកា*...

- ខ្លួនអែងផ្ទាល់អែងស្មានទៅមើលថា តើឪពុក *អូបាតា* ធ្វើយ៉ាងម៉េច ?

- បោះចោលក្នុងសមុទ្រទាន !

- អែងឃើញគាត់បោះចោលអ្វី ?

- អត់ទេទាន !

*យ៉ាប៊ូ* ផ្កាប់មុខឡើងវិញ ហើយម្រាមដៃក៏ចាប់ផ្តើមធ្វើការឡើងវិញដែរ ។ អារម្មណ៍ដែលដឹងថា មានអ្នកផ្សេងដឹងថា ដាវនោះមិនទាន់បាក់ធ្វើអោយគេនៅមិនសុខស្រួលសោះ ។ អ្អែងគួរសំលាប់*ស៊ូវ៉ូ*ចោលទៅ- គេគិតនៅក្នុងចិត្ត ។ ហេតុអី ? ព្រោះថាហេតុអីក៏មនុស្សគង្វាក់អាចស្គាល់ដាវនោះបាន ? ដាវនេះក៏ដូចជាដាវរបស់ជាងឯក *មូរ៉ាសាម៉ា* ឯទៀត ១ ដែរតើ ម្យ៉ាងទៀតទាំងដងដាវ ទាំងស្រោមដាវក្នុងប៉ុន្មានឆ្នាំកន្លងមកនេះត្រូវផ្លាស់ប្តូរជាច្រើនសា ។ គ្មានអ្នកណាមួយដឹងថាដាវរបស់អ្អែង គឺជាដាវនោះដែលបានប្តូរពីដៃមួយទៅដៃមួយ និង កាន់តែជាសំងាត់ឡើង ៗ នៅពេលដែលអំនាចរបស់ *តូរ៉ាណាកា* កាន់តែខ្លាំងក្លាឡើងនោះទេ ។ តែហេតុអីសំលាប់ *ស៊ូវ៉ូ* ? ប្រការដែលវានៅរស់អីចឹង រឹតតែធ្វើអោយរឿងរ៉ាវកាន់តែល្អមើលថែមទៀត ។ អ្អើយទុកអោយវារស់សិនចុះចង់សំលាប់វាធ្វើរណាក៏បានដែរ ។ ដល់ត្រូវសំលាប់ចាំសំលាប់នឹង ដាវហ្នឹងចុះ ។

គេគិតនៅក្នុងចិត្តថា នៅក្នុងពេលខាងមុខដ៏ឆាប់ ១ នេះគេនឹងមានអំនាចគ្រប់គ្រាន់ដើម្បីកាន់ដាវរបស់ *មូរ៉ាសាម៉ា* នេះនៅចំពោះមុខលោកម្ចាស់ *តូរ៉ាណាកា* ជាមិនខាន ។ ហើយប្រ



www.budinst.gov.kh www.elibraryofcambodia.org

ហែលដល់ថ្ងៃណាមួយអញនឹងនិទានប្រាប់គាត់ពីប្រវត្តិផ្ទៃដាវនេះជាមិនខាន ។

- រួចរឿងហ្នឹងវាយ៉ាងម៉េចទៀត ?

គេសួរទៅបុរសចំនាស់បន្ត ។

- កាលនោះគឺជាឆ្នាំមហាសិយស្បៀវ ។ ឆ្នាំនោះ គឺជាឆ្នាំមហារាំង ហើយដល់លោកម្ចាស់ ខ្ញុំបាទស្លាប់ទៅទៀត ខ្ញុំបាទក៏បានក្លាយទៅជា *រ៉ូនីន* ទៅ ។

*រ៉ូនីន* គឺជាយុទ្ធជនកសិករដែលគ្មានដី រឺដែលគ្មានម្ចាស់ ។ ជា*សាមូរ៉ៃ* ដែលបាត់បង់កិត្តិយសខ្លួន រឺដែលបាត់បង់ម្ចាស់ ហើយត្រូវបង្ខំចិត្តដើរពនេចរសព្វទិសទី រហូតដល់ពេលដែលមានអម្ចាស់ឯទៀតស្ម័គ្រទទួលអោយចូលបំរើខ្លួន ។ គឺជាការលំបាកបំផុតចំពោះ *រ៉ូនីន* ក្នុងការរកម្ចាស់ថ្មី ។ មួបរមែងខ្សត់ខ្សោយ បុរសសឹងតែទាំងអស់ជាយុទ្ធជន ហើយគេក៏រទុកចិត្តមនុស្សចំលែកណាស់ ។ ភាគច្រើននៃពួកចោរប្លន់ និង ពួកចោរសំពៅដែលនៅពាសពេញដីគោក និងតាមបណ្តោយឆ្នេរសមុទ្រនោះ គឺជាពួក *រ៉ូនីន* នេះឯង ។

- ឆ្នាំនោះសែនលំបាក ហើយតដល់ឆ្នាំមួយទៀត។ រួចបន្ទាប់មកខ្ញុំបានលឺគេនិយាយថានៅឯក្យូស៊ូ មានម្ហូបសំបូរហូរហៀរឥតខ្ចះ ម៉្លោះហើយខ្ញុំបាទក៏ចេញដំណើរទៅទិសខាងលិចនោះទៅ ។ នៅរដូវត្រជាក់ឆ្នាំនោះ ខ្ញុំបាទបានជួបនឹងវត្តមួយ ហើយគេក៏បានជួលខ្ញុំបាទជាឆ្មាំវត្តនោះទៅ ។ ខ្ញុំបាទប្រយុទ្ធ ដើម្បីលោកសង្ឃទាំងនោះជាងកន្លះឆ្នាំ ដើម្បីការពារវត្ត និង ស្រែវត្តកុំអោយចោរប្លន់បាន ។ វត្តនោះនៅជិតទីក្រុង *អូសាកា* ទេតែមានពួកចោរដេរដាសរោមជុំជិតដូចមូសតែម្តង ។ កាលនោះ គឺមុនពេលដែលអម្ចាស់ តៃកូ កាន់ទេចវត្តនោះ ។ ថ្ងៃមួយយើងធ្លាក់ក្នុងការហ៊ុមព័ទ្ធរបស់គេ ហើយគេបោះបង់ខ្ញុំបាទចោលដោយស្មានថា ខ្ញុំបាទស្លាប់ ។ ក្រោយមកពួកសង្ឃបានរកខ្ញុំបាទឃើញ ហើយជួយព្យាបាលរបួសខ្ញុំបាទទាល់តែជាសះស្បើយ ។ ប៉ុន្តែគេមិនអាចព្យាបាលភ្នែកខ្វាក់របស់ខ្ញុំបាទឡើយ ។

ម្រាមដៃរបស់*ស៊ូរ៉ៃ* វាកាន់តែកប់ជ្រៅទៅ ។ ។

- ពួកគេបានអោយខ្ញុំបាទទៅនៅជាមួយសង្ឃខ្វាក់មួយអង្គ ដែលបានបង្រៀនខ្ញុំបាទអោយចេះធ្វើសរសៃ និង ចេះប្រើដៃ ដើម្បីជំនួសភ្នែក ។ឥឡូវនេះខ្ញុំបាទគិតថា ម្រាមដៃរបស់ខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

បាទប្រាប់ខ្ញុំបាទច្រើនជាងកាលពីពេលខ្ញុំបាទមានភ្នែកភ្លឺទៅទៀត ។ របស់ចុងក្រោយ ដែលខ្ញុំបាទបានឃើញមុនពេលខ្ញុំបាទខ្វាក់ គឺរង្វះមាត់ដ៏ធំ និងធ្មេញដង្កូវស៊ីរបស់អាចោរនោះ និងផ្លែដាវដែលវាគំមក ហើយពេលដែលខ្ញុំបាទត្រូវដាវគេហើយនោះ ខ្ញុំបាទធុំក្លិនផ្កាក្រអូបឈ្ងុយ ។ ពេលនោះខ្ញុំបាទបែកអំពិលអំពែកព្រាត *យ៉ាប៊ូ-សាមាំ* ។ ខ្ញុំបាទគិតថា ប្រហែលជាខ្ញុំបាទឃើញនិពាន្ធហើយ ១ក្នុងមួយភ្លែតនោះ ខ្ញុំបាទហាក់ឃើញរង្វង់កត្រូវរបស់ព្រះសម្មាសម្ពុទ្ធតែម្តង ។ គិតទៅភាពកង្វាក់នេះ គឺជាសំនងដ៏តូចមួយចំពោះសំនាងដ៏ធំនេះ *រទ* ?

គ្មានលឺចំលើយតបឡើយ ។ *ស៊ូរ៉ូ* ក៏មិនគិតថានឹងមានចំលើយដែរ ។ *យ៉ាប៊ូ* កំពុងតែងោកងុយ ។ តើ *យ៉ាប៊ូ-សាម៉ា* ចូលចិត្តរឿងនិទានរបស់ខ្ញុំបាទទេ ? *ស៊ូរ៉ូ*សួរទាំងសប្បាយនៅក្នុងពោះ ។ រឿងទាំងអស់នេះសុទ្ធតែជារឿងពិត លើកលែងតែចំនុចមួយទេ ។ វត្តដែលខ្ញុំបាទនៅមិនមែននៅជិតក្រុង អូសាកាទេ ប៉ុន្តែនៅជាប់ព្រំប្រទល់ភាគខាងលិចនៃតំបន់របស់អ្នែងតែម្តង។ អ្នែងចង់ដឹងព្រះនាមរបស់សង្ឃនោះទេ ? ព្រះអង្គមានព្រះនាមស៊ូ ហើយត្រូវជាឪពុកមារបស់សត្រូវអ្នែងតែម្តង គឺជាឪពុកមារបស់ *អ៊ិកាវ៉ា ស៊ិតូយូ* ។

អញអាចកាច់បំបាក់ក អែងយ៉ាងចូរល្អុយ - *ស៊ូរ៉ូ* គិតនៅក្នុងចិត្ត ។ នេះដូចជាអញជួយ *អូម៉ី-សាន* អីចឹង ។ ភូមិទាំងមូលនេះក៏នឹងបានសុខ ។ ហើយម្យ៉ាងទៀតនេះក៏ដូចជាអញបានសងគុណម្ចាស់អញបានបន្តិចបន្តួចដែរ ។ តើអញគួរសំលាប់វាអីលូវ ? រឺចាំពេលក្រោយ ?

☆ ☆ ☆

*ស្ទីលប៉ែគីន* កាន់សរសៃចំបើងប្រកបដោយទឹកមុខមាំ :

- អីលូវអ្នកណាចាប់មុន ?

គ្មានអ្នកណាឆ្លើយតបឡើយ ។ *ភ្ញាក់ផន* ហាក់ដូចជាផ្អែកលក់នៅក្បែនជញ្ជាំង ។ ព្រះអាទិត្យជិតលិចហើយ ។ ភាពស្ងៀមស្ងាត់នេះធ្វើអោយ ស្ទីលប៉ែគីន រឹតតែមួម៉ៅថែមទៀត ។ គេបញ្ជាម្តងទៀត :



www.budinst.gov.kh www.elibraryofcambodia.org

- វាត្រូវតែមានអ្នកណាមកចាប់មុនគេ ។ មក ! នៅសល់ពេលតិចណាស់ហើយ !

ពួកគេបានទទួលម្ហូបនិងទឹកមួយធុង ហើយធុងមួយទៀតសំរាប់ពួកគេបត់ជើង ។ តែពួកគេគ្មានអ្វី ដើម្បីលុបលាងខ្លួនទេ ដើម្បីជំរះក្លិនដ៏អសោចដែលនៅជាប់នឹងខ្លួននោះឡើយ ។ ក្លិននេះនាំរុយមករោមពេញអន្លង់តែម្តង ។ ខ្យល់ដែលគេដកដង្ហើមពោរពេញដោយក្លិនគំរង់ ឯដីដែលគេជាន់ក៏បែកភក់កក្តិច ។ បុរសភាគច្រើននាំគ្នាដោះអាវនៅខ្លួនទទេ ហើយមានញើសស្រក់ដូចទឹក ។ ជាញើសបណ្តាលមកពីកំដៅផង ជាញើសបណ្តាលមកពីការភ័យខ្លាចផង ។

*ស្តីលវ៉ាបិតិន* សំលឹងមើលមុខពីមួយទៅមួយ រួចត្រលប់មកមើល *ប្លាក់ថន* វិញ :

- ហេតុអ្វី ១បានជាគេលើកលែងក្មេងម្នាស ? ហេតុអ្វី ?

*ប្លាក់ថន* បើកភ្នែកឡើង ។ ជាភ្នែកត្រជាក់ស្រេប :

- អញប្រាប់ជាលើកចុងក្រោយណា ! អញ-មិន-ដឹង-ទេ !

- មិនយុត្តិធម៌ទេ ! មិនយុត្តិធម៌សោះហើយ !

*ប្លាក់ថន* វិលត្រលប់ទៅរកភាពអណ្តែតអណ្តូងរបស់គេវិញ ។ វាអាចមានវិធីណាមួយ ដើម្បីចេញពីកន្លែងនេះ ។ វាត្រូវតែមានវិធីណាមួយ ដើម្បីទៅអោយដល់សំពៅវិញ ។ ពួកអាកូនអត់ពូជនេះវានឹងសំលាប់ពួកយើងតែទាំងអស់ហើង ។ ពេលកាន់តែខើចណាស់ទៅហើយ ។ ពួកវាលើកលែងអញ ក៏ព្រោះតែពួកវាមានគំរោងអាក្រក់អាក្រីណាមួយសំរាប់អញហើយ ។

កាលពីពេលដែលឃ្លុបត្រូវបិទទៅវិញនោះ អ្នកទាំងអស់បានសំលឹងមើល មកគេហើយ មានម្នាក់បាននិយាយឡើង :

- តើពួកយើងត្រូវធ្វើយ៉ាងម៉េច ?

- ខ្ញុំមិនដឹងដែរ-គេឆ្លើយតប ។

- រួចយ៉ាងម៉េចបានជាគេលើកលែងតែកុងអែងអីចឹង ?

- ខ្ញុំមិនដឹងដែរ ។

អ្នកណាម្នាក់និយាយរង៉ូវ ១ :



www.budinst.gov.kh www.elibraryofcambodia.org

- ឱព្រះអើយព្រះ ! សូមជួយពួកយើងខ្ញុំផង .

*ប្លាក់ថន* ចេញបញ្ជា :

-មើលបោសសំអាតកន្លែងនេះអោយស្អាតទៅមើល រួចលើកអាច់ទៅគរកន្លែងនោះមួយដុំទៅ ។

- អត់មានអំបោស អត់...

*- ប្រើដៃទៅណា៎ !*

ពួកគេធ្វើតាមបញ្ជា ហើយ *ប្លាក់ថន* ជួយសំអាតមេបញ្ជាការតាមលទ្ធភាព ដែលគេអាចធ្វើទៅបាន :

- មិនអីទេបងមេបញ្ជាការអ៊ី១នឹងបានស្រួលបួលអីលូវហ្នឹងហើយ !

- តើ...តើធ្វើម៉េចដើម្បីរើសអ្នកណាម្នាក់នោះ ? -*ស្ពីលប៉េតឺន* សួរ ។

- អត់រើសអ្នកណាទាំងអស់យើងវៃតទល់វ៉ា !

- វៃនឹងស្អី ?

- បងមេបញ្ជាការសុខចិត្តទៅស្លាប់ដូចចៀមអីចឹង ? បងឯងចង់អីចឹងអ្វី ?

-កុំផ្ដេសផ្ដាសពេក ពួកវាមិនមែនចង់បានខ្ញុំទេ ។មិនត្រឹមត្រូវទេ ដែលត្រូវយកខ្ញុំនោះ ។

- ហេតុអី ? -*វិញ* សួរ ។

- ព្រោះខ្ញុំជាមេបញ្ជាការណា៎ !

- សូមទោសលោក ! -*វិញ* តបយ៉ាងចំអក -តាមពិតលោកគួរតែស្ម័គ្រចិត្តទៅ ព្រោះជាតួនាទីរបស់លោកហើយដែលត្រូវស្ម័គ្រចិត្តទៅនោះ ។

-សំនើល្អណាស់ -*ពីតែស៊ូន* បន្ទរតាម-ខ្ញុំសូមឯកភាព ។

ទាំងអស់គ្នាឯកភាពភ្លាម ។ *ស្ពីលប៉េតឺន* ចាប់ផ្ដើមឡូឡានិងបញ្ជាឆ្វេងស្ដាំ ប៉ុន្តែគេគេប្រទះឃើញតែក្រសែភ្នែកឥតមេត្តា ដែលសំលឹងមើលមករូបគេតែប៉ុណ្ណោះ ។ ដោយហេតុនេះគេឈប់នៅស្ងៀម សំលឹងដី ក្នុងចិត្តពោរពេញដោយភាពឆ្អើម ។ រួចគេនិយាយម្ដងទៀត:

- ទេ ។ មិន...មិន...មិនជាការត្រឹមត្រូវទេ ដែលទាមទាររកអ្នកស្ម័គ្រចិត្តនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

យើង...យើង...យើងចាប់ឆ្នោតវិញ ។ អីលូវនេះយកសរសៃចំបើងមកចាប់ក្នុងសរសៃទាំងអស់ណុងមានមួយខ្លីជាងគេ ។ រួចស្រេចតែព្រះចុះជាអ្នកសំរេចលើដៃយើង...លើអាយុជីវិតយើង ។ តែកុងអ្អែងជាអ្នកកាន់ចំបើងណាំ !

- ខ្ញុំអត់ទេ ។ ខ្ញុំអត់រវីរវល់រឿងអីចឹងទេ ។ ខ្ញុំប្រាប់ហើយថា យើងប្រយុទ្ធ ។

- ពួកវានឹងសំលាប់យើងតែទាំងអស់គ្នាណុង ។ អ្អែងមិនលឺអា *សាមូរ៉ៃ* នោះនិយាយទេអ្ហី : គេលើកលែងជីវិតពួកយើងទាំងអស់ លើកលែងតែម្នាក់ទេ ដែលត្រូវស្លាប់ ។

*ស្តិលប៉ែគីន* យកដៃជូតញើសចេញពីថ្ងាស ធ្វើអោយរុយមួយរ៉ូងផ្អើលងូង រួចគេបន្ត :

-អោយទឹកអញបន្តិច ។ នែ៎ ! មានម្នាក់ស្លាប់វាគ្រាន់បើជាងស្លាប់ទាំងអស់គ្នាណាំ !

*វ៉ាន់ណិច* ជ្រមុជឃ្លោកទៅក្នុងធុង ហើយហុចទឹកទៅអោយ *ស្តិលប៉ែគីន* ដោយនិយាយថា :

- យើងមានគ្នាទាំងអស់ដប់នាក់រាប់ទាំងអ្អែងផង *ប៉ូលូស* ។ គត់គួលណាស់ ។

- ល្អ ? លើកលែងតែអ្អែងជាអ្នកទៅងាប់-*វិញ* សំលឹងទៅ *ប្លាក់ថន*-តើយើងអាចប្រយុទ្ធនឹងដាវណឹងបានអ្ហី ?

- បើមិនជាប៉ះចំអ្អែង តើអ្អែងសុខចិត្តដើរតត្រុកទៅរកអ្នកធ្វើទារុណកម្មអ្អែងទេ ?

- ខ្ញុំមិនដឹងដែរ ។

*វ៉ាន់ណិច* និយាយ :

- យើងចាប់ឆ្នោតទៅ ។ ស្រេចតែព្រះលោកសំរេចចុះ .

- យ៉ាប់តែព្រះតែម្តងហើយ-*ប្លាក់ថន* និយាយ-ចំជាឆ្កួតមែន ។ រឿងអីចឹងបន្ទោសព្រះដែរ ។

- តើអីចឹងធ្វើយ៉ាងម៉េចទេវិញ ?- ម្នាក់ទៀតស្រែកឡើង ។

-អត់ធើម៉េចទេ !

- ធើតាម *ប៉ូលូស* និយាយទៅ គាត់ជាមេបញ្ជាការ -*វ៉ាន់ណិច* និយាយ-យើងចាប់ឆ្នោតទៅ ។ នេះល្អសំរាប់ភាគច្រើនផង ។ ម៉ស ! បោះឆ្នោតទៅ ! មើលអ្នកណាគាំទ្រគំនិតនេះ?



www.budinst.gov.kh www.elibraryofcambodia.org

ទាំងអស់គ្នាយល់ព្រម លើកលែងតែ *វិញ* ។ *វិញ* និយាយពន្យល់ជំហរនេះ

- ខ្ញុំគាំទ្រគំនិតបងតែកុង ។ អារឿងចាប់ឆ្នោតប្រកាច់ប្រកិនចំកូតយក៏នោះខ្ញុំមិនគាំទ្រទេ !

ទីបំផុតពួកគេសំរេចបញ្ចុះបញ្ចូល វិញបាន ។ *យ៉ាន់ឌូរ៉ែ* ចាត់ចែងសូត្រធម៌ ។ រួចហើយ *ស្កីលប៊ែគីន* កាត់ចំបើងដប់សរសៃត្រឹម ១ត្អា ហើយទើបគេកាត់សរសៃចំបើងមួយអោយនៅខ្លីត្រឹមពាក់កណ្តាល ។

☆☆☆

*ស្កីលប៊ែគីន* សួរជាថ្មីម្តងទៀត :

- មើល ! អ្នកណាចង់ចាប់មុន ?

- រួចចុះយើងធ្វើម៉េចដឹងបានថា...ថាអ្នកចាប់ចំអាចំបើងខ្លីនោះ នឹងព្រមទៅ ? ធ្វើម៉េចយើងដឹងបាន ?-សំលេងមែស៊ូតែ បានក្លាយទៅជាសំលេងខ្មោចទៅហើយ ព្រោះតែការវន្ធតំញ្ញាប់ញ៉័រ ។

- អើមែន ! ធ្វើម៉េចអោយច្បាស់បាន ?-*ភ្លេក* បន្ទរ ។

- ងាយទេ -*យ៉ាន់ឌូរ៉ែ* ឆ្លើយ-អីលូវនាំគ្នាស្បថយកព្រះជាបន្ទាល់ ។ គឺថាយើងសុខ...សុខ...សុខចិត្តស្លាប់ដើម្បីអ្នកឯទៀត ។ តែប៉ុណ្ណឹងទៅវាចប់ហើយ ។ អ្នកដែលត្រូវធ្វើពលិកម្មនេះនឹងឡើងឋានសួគ៌ ។

ទាំងអស់គ្នាឯកភាព ។

- តសវិញ ! ធ្វើតាម *រ៉ែ* ប្រាប់ទៅ !

- អឺចឹងក៏បាន - បបូរមាត់វិញ ឡើងស្លូតខ្យោះ-បើ...បើ...បើសិនណាជាខ្ញុំ...ខ្ញុំសូមស្បថដោយយកព្រះជាបន្ទាល់ ថាខ្ញុំនឹងទៅតាមពួកគេ បើ... បើសិនណាជាខ្ញុំចាប់ចំចំបើងអាក្រក់។ សូមព្រះអង្គជាសាក្សី ។

ពួកគេក៏ធ្វើតាម *វិញ* ។ *មែស៊ូតែ* ស្លូតពេកទៅទាល់តែមានអ្នកចាំប្រាប់អោយថា



www.budinst.gov.kh www.elibraryofcambodia.org

តាម ។ រួចរាល់ហើយ *សុង* ជាអ្នកចាប់មុនគេ ។ *ពីតែស៊ួន* ចាប់បន្ទាប់ រួចដល់វេន *យ៉ានរ៉ូវែ* រួចដល់សាឡាម៉ុន និង *ភ្លុក* ។ *ស្ពិលប៊ែគីន* បាត់ដង្ហើមផុត ១ ព្រោះទាំងអស់គ្នាបានសំរេចថា គាត់មិនចាំបាច់ចាប់ទេ គឺត្រូវនៅក្រោយគេបង្អស់តែម្តង ដោយហេតុនេះពេលផុតម្នាក់ ១ *ស្ពិលប៊ែគីន* បាត់ដង្ហើមម្តង ១ដែរ ។

*គីនស៊ែល* ផុតទៀត ។ នៅសល់តែបួននាក់ទេ ។

*មែស្ទ័រ* យំសស្រិចសស្រាក់ ។ គេរុញ *វិញ* ទៅម្ខាង ហើយលូកដៃចាប់ចំបើងមួយសរសៃចេញមក ។ ស្រាប់តែគេសឹងមិនជឿខ្លួនឯង ព្រោះចំបើងនោះដូចគេដូចឯង ។

ដៃ *ស្ពិលប៊ែគីន* ដែលកាន់ចំបើងកាន់តែញ័រទទ្រើកមែនទែន រហូតដល់ *ភ្លុក* ត្រូវជួយកាន់ថែមទៀត ។ ឈាមកហូរចុះមកតាមជើងខោរបស់ *ស្ពិលប៊ែគីន* ដោយមិនដឹងខ្លួន ។

អញរើសយកអាមួយណាអឺចេះ? - *រ៉ាន់ណើច* ដណ្តឹងសួរខ្លួនឯងទាំងអស់សង្ឃឹម ឱព្រះអើយព្រះជួយខ្ញុំផង ! ភ្នែកម៉ូបរបស់គេមើលឃើញចំបើងព្រាល ១ តែប៉ុណ្ណោះ ។ ឱ ! បើសិនណាជាអញអាចមើលឃើញច្បាស់អញច្បាស់ជាឃើញគំរុយសំរាប់ចាប់ហើយនេះ ។ អាមួយណាអឺចេះ?

គេចាប់ចំបើងមួយ ហើយយកមកជិតភ្នែកគេ ដើម្បីដឹងពីលទ្ធផល ។ មិនមែនជាចំបើងខ្លីទេ ។

*វិញ* សំលឹងមើលម្រាមដៃគេ ដែលដកយកចំបើងមួយក្នុងចំនោមចំបើងទាំងពីរសរសៃដែលនៅសស់ ។ ចំបើងធ្លាក់ចុះទៅក្រោម ហើយទាំងអស់គ្នាបានឃើញថា នោះជាចំបើងខ្លីដ៏គួរអោយខ្លាចនោះឯង ។ *ស្ពិលប៊ែគីន* លាដៃចេញ ហើយដួលសន្លប់បណ្តោយ ។

ទាំងអស់គ្នាសំលឹងមើលទៅ *វិញ* ។ *វិញ* សំលឹងមើលពួកគេទាំងអស់សង្ឃឹមនិងដោយគ្មានឃើញអ្នកណាទាំងអស់ គេញាក់ស្មាបន្តិច ញញឹមបន្តិច ហើយបក់រុយយ៉ាងប៉ក់ល្បើយ រួចគេដាក់បង្គុយស្រ៊ុប ។ ទាំងអស់គ្នាវាតវង់ទុកកន្លែងអោយ *វិញ* ដោយគ្មានអ្នកណាហ៊ានចូលទៅជិតគេឡើយ ។

*ញាក់ថន* លុតជង្គង់ក្នុងកក់ក្បែរ *ស្ពិលប៊ែគីន* ។

- គាត់ស្លាប់រឺអត់ទេ ? - *រ៉ាន់ណើច* សួរដោយសំលេងខ្សាវ ១ ។



www.budinst.gov.kh www.elibraryofcambodia.org

វិញផ្ទុះសំនើចខ្លាំង ១ ដែលធ្វើអោយអ្នកផងរសាប់រសល់រកថាមិនត្រូវ ។

- គឺអញ អញដែលជា...ដែលជា...ដែលជាអ្នកត្រូវស្លាប់ ។ អញស្លាប់ហើយ !

-តាំងចិត្តអោយក្លាហាន*វិញ- យ៉ានូវ៉ែ* និយាយ-ព្រះនឹងប្រោសអ្លែងមិនខានទេ

-មែនហើយ-*ភាន់ណិច* បន្ទរ-កុំតក់ស្លុតអី ។

- អីលូវដូរចិត្តហើយមែនទេ ?

*វិញ* សំលឹងមើលមុខម្នាក់ម្តង ១ ប៉ុន្តែគ្មាន អ្នកណាហ៊ានទ្រាំទ្រនឹងក្រសែភ្នែករបស់ *វិញ* ទេ មានតែ *ប្លាក់ថន* ទេ ដែលមិនគេចចេញពីក្រសែភ្នែករបស់ *វិញ* ។

-យកទឹកអោយខ្ញុំបន្តិច *វិញ* - *ប្លាក់ថន* និយាយយ៉ាងស្ងប់ស្ងៀម-ទៅ ទៅយកទឹកអោយខ្ញុំបន្តិច ។

*វិញ* សំលឹងមើលទៅ*ប្លាក់ថន* រួចក៏ក្រោកទៅយកឃ្លោកដងទឹក ហើយហុចទៅ*ប្លាក់ថន*។

- ព្រះអើយព្រះ តើខ្ញុំត្រូវធ្វើយ៉ាងម៉េចទៅ ? - វិញពោលរង៉ូវ ១ ។

- ដំបូងបំផុតជួយខ្ញុំមើល *ប៉ូលូស* សិន ។ *វិញ* ! ធ្វើតាមខ្ញុំប្រាប់ទៅ ។ ម៉េចទៅគាត់ដឹងខ្លួនហើយរឺនៅ ?

វិញ ទុកភាពរន្ធត់គ្រដរខ្យល់របស់ខ្លួនដោយឡែក អាស្រ័យដោយភាពនឹងនរបស់ *ប្លាក់ថន* ។ ជីពចររបស់ *ស្ទីលប៉ែគីន* ខ្សោយណាស់ទៅហើយ ។ *វិញ* អោនស្តាប់បេះដូង បើកត្របកភ្នែក ហើយសំលឹងមើលពិនិត្យពិច័យមួយស្របក់ ។

- ខ្ញុំអត់ដឹងដែរបងតែកុង ។ ឱ ! ព្រះអើយព្រះ ! ខ្ញុំឡប់អស់ហើយដែរ ។ ខ្ញុំ...ខ្ញុំ...ខ្ញុំផ្អិតគំនិតមិនកើតសោះ...ជួយខ្ញុំ...

*វិញ* ឈប់និយាយដោយការហេវហត់ ។ គេក៏ផ្អែកខ្លួនទៅនឹងជញ្ជាំង ហើយចាប់ផ្តើមយំខ្សឹកខ្សួល ។

រំពេចនោះឃ្មុបរបើកឡើងឃ្វាំង ។

*រូប អូមី* ឈរបាំងផ្ទៃមេឃ គឺម៉ូណូរបស់គេត្រូវពន្លឺថ្ងៃលិចឡើងពណ៌ក្រហមដូចឈាម ។



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី ៤

*វិញ* ប្រឹងគំរើកជើងដើរ ប៉ុន្តែគេឥតគំរើកជើងរួចសោះ ។ គេធ្លាប់ប្រឈមមុខនឹងមច្ចុរាជ ជាច្រើនដងហើយ ក្នុងជីវិតរបស់គេប៉ុន្តែមិនមែនដូចពេលនេះទេ។ ពេលនេះគេប្រឈមមុខនឹងមច្ចុរាជ ដោយឥតមានលទ្ធភាពទប់អ្វីបានទាំងអស់ ។ គេជួបមច្ចុរាជ អាស្រ័យដោយចំបើងជាអ្នកកំនត់ ។ ហេតុអីបានជារូបអញទៅវិញ ? ខួរក្បាលរបស់គេស្រែកជំទាលឡើង ។ អញមានទៅអន់ជាងអ្នកណា មានតែគ្រាន់បើជាងមាំចំនួនធំនេះផង ។ ឱ ! ព្រះអើយព្រះ ! ហេតុអីបានជាតំរូវលើរូបខ្ញុំ ?

ជណ្តើរមួយត្រូវគេសំរូតចុះមកក្នុងអន្លង់ ។ *អូមី* បញ្ជាអោយមនុស្សម្នាក់ឡើងមកលើជាប្រញាប់ :

- *អ៊ីសូគី* !( ប្រញាប់ឡើង )

*ភ៉ាន់ណិច* និង *យ៉ាន់រ៉ូពៃ* ធ្មេចភ្នែកសូត្រធម៌យ៉ាងស្ងៀមស្ងាត់ ។ *ពីថៃស៊ូន* ឥតហ៊ានមើលទិដ្ឋភាពទាំងនេះឡើយ ។ *ប្លាក់ថន* នៅតែសំលឹងថ្ងៃទៅរក *អូមី* និង កូនចៅរបស់គេ ។

- *អ៊ីសូគី* ! -*អូមី* គំហកម្តងទៀត ។

*វិញ* ខំក្រោកឈរម្តងទៀត :

- មើលអ្នកណាជួយខ្ញុំបន្តិចមើល ។ ជួយខ្ញុំក្រោកឈរបន្តិច ។

ពីថៃស៊ូនដែលនៅជិតជាងគេអោនទៅចាប់ដៃរបស់ *វិញ* ហើយជួយគេអោយងើបឈរឡើង តែរំពេចនោះ *ប្លាក់ថន* ដើរទៅជិតជណ្តើរ ដោយឈរជ្រែងជើងយ៉ាងមាំនៅក្នុងភក់ ។

*ប្លាក់ថន* ស្រែកឡើងដោយប្រើពាក្យដែលគេចាំនៅលើសំពៅ ។ ភាពស្រលាំងកាំងបានកើតមានឡើងនៅក្នុងអន្លង់ទាំងមូល ។ ដៃរបស់ *អូមី* ក្តាប់យ៉ាងណែនលើដងដាវ ហើយដើរតំរង់ជណ្តើរ ។ ភ្លាមនោះ *ប្លាក់ថន* ចាប់ជណ្តើរអង្រួនយ៉ាងខ្លាំង ពន្យុះ *អូមី* អោយចុះក្រោម ។

- *គីនជីរ៉ូ* ! គេនិយាយម្តងទៀត ។

*អូមី* ឈប់នៅស្ងៀម ។



www.budinst.gov.kh www.elibraryofcambodia.org

- រួចចុះវាថីហ្នឹង ?

*ស្ទីលវ៉ប៊ីគីន* សួរទៅ *ភ្លាក់ថន* ទាំងញ័រចំប្រប់ដូចជាអ្នកឯទៀតទាំងអស់គ្នាដែរ ។

- ខ្ញុំប្រាប់វាថាមិនបានទេ ! គ្មានអ្នកណាម្នាក់ក្នុងក្រុមខ្ញុំដើរទៅស្លាប់ ដោយមិនប្រយុទ្ធនោះទេ ។

- តែ...តែ...យើងបានឯកភាពគ្នាហើយតើ

- ចុះខ្ញុំមានឯកភាពឯណា ?

- អ្អែងឆ្កួតហើយ !

- បានហើយ ! បានហើយ ! បងតែកុង !-*វិញ* និយាយខ្សាវ ១ -ខ្ញុំ...ខ្ញុំ...ពួកយើងឯកភាពគ្នាហើយ ១ នេះគឺត្រឹមត្រូវ ។ នេះជាចំនារព្រះហើយ ។ ខ្ញុំទៅហើយ ។ ដល់...

*វិញ* ដើរតតេះតតះរហូតដល់ជើងជណ្តើរ ប៉ុន្តែ *ភ្លាក់ថន* នៅឈរថ្នាំងមុខជណ្តើរប្រឈមមុខនឹង *អូមី* ដដែល ។

- អ្អែងមិនត្រូវចេញទៅដោយគ្មានការប្រយុទ្ធឡើយ ។ អ្នកណាក៏ដោយ ។

- តៃកុងចេញពីជណ្តើរទៅ ! ខ្ញុំបញ្ជាអោយអែងចេញពីណឹង !

*ស្ទីលវ៉ប៊ីគីន* ឈរយ៉ាងញ័រទទ្រើតនៅកន្លែតជញ្ជាំង ។ លោកស្រែកសន្ធាប់ម្តងទៀតយ៉ាងភ្លាត់សំលេង :

- តៃកុង !

ប៉ុន្តែ *ភ្លាក់ថន* មិនស្តាប់មេបញ្ជាការឡើយ គេនិយាយយ៉ាងខ្លី :

- ប្រុងប្រៀប !

*អូមី* ថយក្រោយពីរបីជំហាន ហើយចេញបញ្ជាមនុស្សរបស់គេ ។ វំពេចនោះ *សាមូរ៉ៃ* ម្នាក់ចុះតាមជណ្តើរ ។ រួចមានពីរនាក់ទៀតចុះតាមប្រកិតមកដែរ ។ ពួកគេដកដាវកាន់នៅដៃហើយជាស្រេច ។ *ភ្លាក់ថន* អង្រួនបង្វិលជណ្តើរហើយច្បាមចាប់ជាប់បុរស ដែលចុះមកមុនគេ ។ បុរសនេះវាត់ដាវសំដៅ *ភ្លាក់ថន* ប៉ុន្តែគេគេចផុត ហើយច្របាច់កបុរសនោះភ្លាម :

- ជួយអញផង ! មក ! ដើម្បីអាយុជីវិតពួកអ្អែងណឹងណាំ !



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* ដូរស្មៀតដើម្បីកន្ត្រាក់បុរសនោះអោយធ្លាក់ពីលើជណ្ដើរ នៅពេលដែលបុរសទីពីរចុះជិតមកដល់គេនោះ ។ *វិញ* ភ្ញាក់ខ្លួនពីភាពស្រពន់ ហើយហក់ទៅរក*សាមូរ៉ៃ* ម្នាក់ទៀតយ៉ាងក្រពុលមុខ ។ គេស្ទាត់ជាប់ផ្លែដាវ ដែលបំរុងនឹងកាត់ផ្ដាច់ កដៃរបស់ *ប្លាក់ថន* ហើយនៅពេលដែលដៃម្ខាងរបស់គេច្របាច់ជាប់ដៃ ដែលកាន់ដាវនោះ កណ្ដាប់ដៃម្ខាងទៀតរបស់គេក៏ដាល់ចំក្រលៀនរបស់ *សាមូរ៉ៃ* នោះផង ។ *សាមូរ៉ៃ* នោះក៏យារជើងទាត់ទាំងដដួក់ត្រូវ *វិញ* មួយជើង ប៉ុន្តែ *វិញ* ហាក់គ្មានដឹងការឈឺចាប់សោះឡើយ ។ គេហក់ឡើងជណ្ដើរហើយប្រតាយគ្នានឹងបុរសនោះ ដើម្បីដណ្ដើមយកដាវ ។ ក្រចករបស់ *វិញ* ខ្វាំខ្វារមុខរបស់ *សាមូរ៉ៃ* ប្រៀបដូចជាខ្លាមួយដ៏សាហាវ ។ ដោយកន្ទែងចង្កៀត *សាមូរ៉ៃ* ទាំងពីរនាក់ទៀតត្រូវ *ប្លាក់ថន* និង *វិញ* សង្គ្រប់ជាប់ តែបន្តិចមកទៀតត្រូវគេទាត់ចំមុខមួយជើង ហើយក៏ដួលប្រួសទៅ ។ *សាមូរ៉ៃ* ទីបីដែលនៅលើជណ្ដើរនៅឡើយនោះ ហៀបនឹងស្ទុះហក់ទៅរក *ប្លាក់ថន* ទៅហើយតែក៏ត្រូវពួកក្រុមនារីកទាំងអស់ស្ទុះហក់ព្រូទៅរកតែម្ដង ។

*ត្រូក*ចាប់ជើង *សាមូរ៉ៃ* ដែលនៅខាងក្រោមជាប់ ហើយយារដៃដ៏ធ្ងន់ដូចជាញញួររបស់គេដាល់ញាប់ស្មេចំកំភួនជើង ។គេឮសំលេងឆ្អឹងតូច១បាក់ប្រេស១ ។ ក្នុងស្ថានភាពនេះបុរសនេះខំប្រឹងគ្រវែងដាវរបស់ខ្លួនចេញទៅក្រៅអន្លង់ ដើម្បីចៀសវាងកុំអោយគេដណ្ដើមយកបានហើយក៏ដួលបះជើងច្រូងទៅក្នុងភក់ ។ *វិញ* និង *ពីធែស៊ូន* លោតទៅសង្គ្រប់ពីលើជាប់ ។ បុរសនេះវាយតវិញយ៉ាងចាស់ដៃ ។ *ប្លាក់ថន* ឆក់យកកាំបិតខ្លីរាងកោងបន្តិចរបស់ *សាមូរ៉ៃ* ដែលដេកដួលនៅទីនោះហើយស្ទុះឡើងតាមជណ្ដើរទៅខាងលើ ដោយមាន*ត្រូក យ៉ាន់រ៉ូវ៉ែ* និង *សាឡាម៉ុន* តាមប្រកិតពីក្រោយផង ។ *សាមូរ៉ៃ* ទាំងពីរនាក់ទៀត ដោយឃើញស្ថានភាពមិនអំនោយផលបានឡើងទៅលើមាត់អន្លង់យារដាវចាំកាប់ជាស្រេច ។ *ប្លាក់ថន* ដឹងច្បាស់ណាស់ថាកាំបិតរបស់គេមិនអាចទប់នឹងដាវទាំងនេះបានទេ ប៉ុន្តែទោះជាយ៉ាងនេះក្ដីគេនៅតែរុលទៅលើដែរ ។ អ្នកឯទៀតឡើងប្រកៀកពីខាងក្រោម ។ ពេលដែលក្បាលគេគេចចេញផុតពីអន្លង់បន្តិចដាវមួយកាប់វឹបជ្រិះក្បាលរបស់គេ ទន្ទឹមនោះជើងរបស់ *សាមូរ៉ៃ* ម្នាក់ ដែលគេមិនបានឃើញទាត់ត្រូវគេម៉ាំងធ្វើអោយគេធ្លាក់ទៅក្រោមប្រួស ។



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* ស្ទុះក្រោកឡើងវិញ ហើយស្ទុះទៅរកជណ្តើរវិញដោយខំងាកចេញពីរ៉ូង មនុស្ស ដែលកំពុងប្រវាយប្រតប់ជាមួយ*សាមូរ៉ៃ*ម្នាក់ ដែលនៅកប់កក់នោះ ។ *វិញ* វៃចំកញ្ចឹងក បុរសនោះមួយដៃធ្វើអោយគេសន្លប់បាត់មាត់ឈឹង ។ ទោះជាយ៉ាងនេះក្តី *វិញ* នៅតែវៃហើយ វៃទៀត រហូតដល់ *ប្លាក់ថន* ទាញគេចេញ ។

- កុំសំលាប់វា ! ត្រូវទុកវាជាឈ្លើយ !

គេស្រែកយ៉ាងអស់ទំហឹង ទន្ទឹមនោះគេខំហក់ឈោងកន្ទ្រាក់យកជណ្តើរចុះមកវិញ ប៉ុន្តែជណ្តើរត្រូវគេលើកខ្ពស់ផុតទៅហើយ ។ នៅមាត់ឃ្លុបពួក*សាមូរ៉ៃ* របស់ *អូមី* នៅរង់ចាំ យ៉ាងស្ងៀមស្ងាត់ ។

- ព្រះអើយព្រះ ! នៃតៃកុងឈប់ទៅ ! -*ស្តីលវ៉ែតិន* និយាយទាំងញ័ររន្ធត់- ពួកវា នឹងសំលាប់ ពួកយើងតែទាំងអស់ហ្នឹងទៀតហើយ ។ មើលអ្នកណាចាប់វាបន្តិចមើល !

*អូមី* ស្រែកអោយបញ្ជាម្តងទៀត ។ ម្តងទៀតដៃដ៏ខ្លាំង ១បានទប់មិនអោយ *ប្លាក់ថន* ប្រើជណ្តើរខ្ទាស់មាត់ឃ្លុបបានឡើយ ។

- ប្រយ័ត្នពួកយើង !- *ប្លាក់ថន* ស្រែក ។

រំពេចនោះ*សាមូរ៉ៃ* បីនាក់ប្រដាប់ដោយដាវវែង១ខ្លួន ហើយដែលស្លៀកពាក់តែខោ ស្ពាប់ភ្លៅនោះបានហក់ចុះមកយ៉ាងរហ័សរហួន ។ *សាមូរ៉ៃ*ពីរនាក់ ដែលចុះមកមុនគេបានស្ទុះដូច គេណាត់សំដៅទៅរក *ប្លាក់ថន* ដោយឥតគិតពីគ្រោះថ្នាក់ដល់អាយុជីវិតរបស់ខ្លួនឡើយ ។ កំលាំងរបស់បុរសទាំងពីរបានរុញផ្ទប់ *ប្លាក់ថន* ទៅនឹងជញ្ជាំងដោយឥតអោយគេមានលទ្ធភាព ប្រើកាំបិតខ្លីរបស់គេឡើយ ។ ក្នុងពេលនេះគេសែនស្រេកឃ្លានចង់ចេះស្នៀតរបស់មេភូមិ *មូរ៉ា* ក្នុងការប្រយុទ្ធខ្លួនទល់នឹងខ្លួនជាពន់ពេក ។ គេដឹងទាំងអស់សង្ឃឹមថា គេមិនអាចរស់បានយូរ ទៀតទេ ប៉ុន្តែគេប្រឹងរើយ៉ាងអស់ទំហឹង ហើយសំរេចរើរួចបានដៃម្ខាង ។ ដៃដ៏រឹងដូចថ្មមួយវាយ ចំក្បាលរបស់គេធ្វើអោយគេឡើងសឹតែម្តង ។ ដៃទីពីរធ្វើអោយគេបែកអំពិលអំពែកព្រាត តែទោះជាយ៉ាងនេះក្តី ក៏ *ប្លាក់ថន* នៅតែប្រឹងប្រវាយប្រតប់តទល់នឹងពួកទាំងពីរនេះយ៉ាងស៊ី សាច់ហុតឈាមជាទីបំផុត ។



www.budinst.gov.kh www.elibraryofcambodia.org

ឃើញយ៉ាងនេះ វិញ ស្មុះរឹងទៅច្របាច់ក*សាមូរ៉ៃ*ម្នាក់ តែភ្លាមនោះ*សាមូរ៉ៃ* ទីបីបាន ហក់ទំលាក់ខ្លួនមកពីលើទៀត ។ *ម៉ែស្ស៊ីតែ* ស្រែកយ៉ាងគ្រលួចនៅពេលដែលកាំបិតខ្វីបានចាក់ រយះដៃគេ ។ *វ៉ាន់ណេច* រេីប្រវេប្រវាំតែពាស ដើម្បីរកច្រកចេញ ឃើញយ៉ាងនេះ *ពីធែស៊ួន* ក៏ ស្រែកឡើង :

- ពុទ្ធោអើយ ! រ៉ៃពួកខាងនោះម៉េចបានជាមករ៉ៃអញវិញ ?-ប៉ុន្តែ*វ៉ាន់ណេច* ឥតបាន លឺ សំដីរបស់ *ពីធែស៊ួន* ទេព្រោះតែការញ័ររន្ធត់របស់ខ្លួន ។

*ភ្លាក់ថន* ស្រវ៉ាប៉ះបំពង់ក *សាមូរ៉ៃ* ម្នាក់ ប៉ុន្តែគេបន្លឹងរឹតបំពង់កមិនបានសោះ ព្រោះ គេរអិលនឹងញើស ហើយនឹងភក់ដែលប្រលាក់ពាសពេញនោះ ។ ទោះជាយ៉ាងនេះក្តីក៏ *ភ្លាក់ថន* ក្រោយឈរយ៉ាងរឹងមាំបានវិញហើយ ។ គេកំពុងតែបន្តឹងដៃបន្តិចម្តង ។ ទៅហើយ ស្រាប់តែ កណ្តាប់ដៃមួយបានវាត់មកប៉ះគេម៉ាំង ធ្វើអោយគេសន្លប់បាត់ស្មារតីទៅ ។ ម្តងនេះពួក*សាមូរ៉ៃ* បានទំនេរដៃក៏តាំងត្រីដារវត្ថារផ្លូវទៅរកជណ្តើរវិញ ។ ក្រុមនាវិកដែលអស់មេដឹកនាំហើយនោះ នាំគ្នាថយក្រោក ។ ចេញពីមុខផ្លែដាវដ៏គ្រោះថ្នាក់ទាំងបីនេះ ។ ប៉ុន្តែពួក*សាមូរ៉ៃ* ដែលអីលូវ នេះក្តាប់ស្ថានភាពក្នុងអន្លង់នេះជាប់ហើយនោះ ឥតមានប៉ុនប៉ងសំលាប់រឺធ្វើអោយរបួសអ្នកណា ឡើយ ប៉ុន្តែពួកគេគ្រាន់តែចង់បង្ខំអោយពួកនាវិក ដែលកំពុងតែដង្ហក់និង ញាប់ញ័រដូចកូនសត្វ ទាំងនេះអោយចេញឆ្ងាយពីជណ្តើរ ដែលនៅក្បែរនោះ*ភ្លាក់ថន*និង *សាមូរ៉ៃ* ម្នាក់ដេកសន្លប់ស្តូក ស្តឹងនៅឡើយ ។

*អូមី* ចុះមកក្នុងអន្លង់យ៉ាងក្រអឺតក្រទម ហើយច្បាមចាប់ អ្នកដែលនៅជិតដៃ ជាងគេ។ នោះគឺ *ពីធែស៊ួន* ។ *អូមី* រុញ *ពីធែស៊ួន* អោយឡើងជណ្តើរទាំងបង្ខំ ។ *ពីធែស៊ួន* ស្រែកភ្លាត់សំលេង ហើយប្រឹងរើចេញពីក្រញ៉ាំដៃរបស់ *អូមី* ប៉ុន្តែផ្លែដាវទីមួយបានវាត់ រយះកដៃរបស់គេ ឯផ្លែដាវទីពីរ ធ្វើអោយកំភួនដៃគេរយះហូរឈាមកក្លាក់តែម្តង ។ នាវិក កំសត់ត្រូវតែអូស ឡើងជណ្តើរ ដោយគ្មានអាណិតអាសូរ ទោះជាគេខំប្រឹងស្រែកស្ទើរបែក បំពង់កយ៉ាងណាក្តី ។

-ព្រះអើយជួយខ្ញុំផង !មិនមែនខ្ញុំទេដែលត្រូវទៅនោះ !មិនមែនខ្ញុំ ទេ !មិនមែនខ្ញុំទេ!



www.budinst.gov.kh www.elibraryofcambodia.org

*ពីតែស៊ីន* ខំទប់ខ្លួននឹងជណ្តើរផង ខំគេចចេញពីមុខកាំបិតដែលដោលពីក្រោមផង ។ បន្ទាប់ពីសំរែក" ជួយខ្ញុំផងព្រះអើយ " ជាចុងក្រោយនោះមករូបរាងកាយរបស់ *ពីតែស៊ីន* ត្រូវគេកន្ត្រាក់ផ្ដោងឡើងបាត់ស្រមោលទៅ ។

*អូមី* ឡើងជណ្តើរតាមក្រោយមួយ ១ ដោយឥតញញើតអារម្មណ៍អ្វីទាំងអស់ ។

*សាមូរ៉ៃ* ម្នាក់ដកខ្លួនឡើងទៅលើ ។ បន្ទាប់មកម្នាក់ទៀត ។ *សាមូរ៉ៃ* ទីបីអោនរើសយកកាំបិតខ្លី ដែល *ភ្លាក់ថន* បានប្រើនោះមកវិញ ហើយបែរខ្លួនចេញទាំងអាការៈមើលងាយរួចក៏សំដៅទៅឡើងជណ្តើរ ដោយរំលងរូបរាងកាយមិត្តរបស់គេ ដែលនៅដេកស្តូកស្តឹងនោះ ។

ជណ្តើរត្រូវគេហូតចេញវិញហើយ ។ ខ្យល់ មេឃ និង ពន្លឺក៏រលាយរលត់បាត់ទៅ ។ រនុកត្រូវគេរុញខ្ទាស់ឡើងវិញ ហើយរ៉ូងរុយក៏វិលត្រលប់មកវិញដែរ ។

ក្នុងមួយខណៈនោះគ្មានអ្នកណាម្នាក់កំរើកសោះឡើយ ។ *យ៉ាន់រូវ៉ែ* ត្រូវមួយកាំបិតស្រាលចំថ្ពាល់ *វ៉ែមស្ស៊ីរ៉ែ* មានឈាមហូរគគុកដូចអារកមាន់ អ្នកឯទៀតបាត់ព្រលឹងព្រលះអស់នៅឈរធ្មឹងតែម្តង ។ លើកលែងតែ*សាឡាម៉ុន* ម្នាក់គត់ ។ គេរាវពើមពើមទៅរក *ភ្លាក់ថន* ហើយទាញ *ភ្លាក់ថន* ចេញពី*សាមូរ៉ៃ* សន្លប់នោះ ដោយនិយាយត្រេល១ មិនដឹងជាចង់ថាអ្វី ប៉ុន្តែដៃគេចង្អុលទៅរកធុងទឹក ។ ត្រួកជ្រលក់ឃ្លោកទៅក្នុងធុង ហើយហុចទៅអោយ*សាឡាម៉ុន* និងជួយលើក *ភ្លាក់ថន* ដែលនៅតែសន្លប់បាត់មាត់បាត់ក នោះអោយងើបអង្គុយផ្អែកនឹងជញ្ជាំងឡើង ។ ទាំងពីរនាក់ចាប់ផ្តើមលាងភក់អោយជ្រះចេញពីមុខមាត់របស់ *ភ្លាក់ថន* ។

- ពេលដែលពួកអាកូនមីចោរទាំងនេះ...វា...វា...ពេលវាហែកធាក់គាត់នោះខ្ញុំលឺដូចជាកគាត់បន្តិច ស្មាគាត់បន្តិច បាក់លឺសូរប្រស-*ត្រួក* និយាយទាំងដង្ហក់ ១ដោយទ្រូងតែនៅឈឺអួលនៅឡើយ-អីលូវនេះគាត់លែងដឹងខ្លួនដូចជាដាច់ដង្ហើមហើយ ! ឱព្រះអើយព្រះ !

*សុង* ប្រឹងងើបឡើងទាំងលំបាក ហើយដើរវែកផ្លូវតំរង់មករក *ភ្លាក់ថន* ។ គេបង្វិលក្បាលតែកុងគេចុះឡើង ១ យ៉ាងថ្នម ១ រួចស្ទាបស្ទាទាំងពីរ :

- ដូចជាមិនអីទេ ។ ចាំគាត់ភ្ញាក់ឡើងចាំសួរនាំគាត់បន្ថែម ។

*វិញ* ចាប់ផ្តើមត្អូញត្អែរទាំងសោកសៅ :



www.budinst.gov.kh www.elibraryofcambodia.org

- ឱព្រះអើយព្រះ ! អា*ពីថែស៊ុន* អើយ ! ម៉េចបានអ្អែងស័យម្ល៉េះ...តែប៉ុណ្ណេះអញត្រូវបណ្ដាសាហើយ ! អញត្រូវបណ្ដាសាហើយ !

- បងអែងទៅហើយទេតើ តែបងតៃកុងទេដែលឃាត់បងនោះ ។ បងទៅដូចបងបានសន្យាហើយតើ ខ្ញុំក៏ឃើញដែរ ។ មែនណា៎ ខ្ញុំយកព្រះជាបន្ទាល់-*សុង* អង្រួន *វិញ* កុំអោយសោកសៅប៉ុន្តែ *វិញ* ឥតមានអារម្មណ៍នឹងទង្វើនេះឡើយ-ខ្ញុំឃើញបងទៅមែនណាបង *វិញ* ។

*សុង* ងាកទៅនិយាយជាមួយ *ស្ទីលវ៉ប៊ិតិន* បណ្ដើរ បក់ដៃញរុយបណ្ដើរ :

- មែនទេមេបញ្ជាការ ?

- អើអញឃើញហើយ ។ វាទៅមែន ។ *វិញ* ! ឈប់ទួញទៀតទៅអា្ហ ! អាតៃកុងទេនាំរឿងរ៉ាវនោះ ។ អោយទឹកអញបន្តិច ។

*យ៉ាន់ទ្វីវ៉ៃ* យកឃ្លោកដងទឹកមកផឹក ហើយនឹងលាងមុខរបួសនៅលើទ្រូងខ្លួនបណ្ដើរពោលបណ្ដើរ :

- *វិញ* គួរតែទៅសោះ ។ ព្រះបានសំរេចលើអ្អែងហើយ ។ អីលូវនេះព្រលឹងអ្អែងជាប់សម្បថហើយ ។ ឱសូមព្រះជួយប្រោសអ្អែងផងចុះ ។

- ថាអោយទឹកខ្ញុំផឹកបន្តិច - *ស្ទីលវ៉ប៊ិតិន* តួញម្ដងទៀត ។

*វ៉ាន់ណិច* យកឃ្លោកពី*យ៉ាន់ទ្វីវ៉ៃ* ហើយហុចទៅអោយ *ស្ទីលវ៉ប៊ិតិន* ហើយនិយាយបន្ទរយ៉ាងប៉ក់ល្បើយ :

-អារឿងនេះមិនមែនជាកំហុសរបស់ *វិញ* ទេ ។ *យ៉ាន* ! អ្អែងមិនចាំទេអ្វី ? កាលនោះ *វិញ* ទើបមិនរួច ហើយវាមានទាំងពឹងអោយអ្នកណាម្នាក់ជួយគ្រាហ៍វាឡើងផង កុំថាតែ *វិញ* សូម្បីតែអញដែលមិនមែនជាអ្នកទៅផងក៏អញនៅស្លុតធ្វើអ្វីមិនកើតផងពេលនោះ ។

- មិនមែនកំហុស*វិញ* ទេ-*ស្ទីលវ៉ប៊ិតិន* និយាយ-មិនមែនទេ មិនមែនមកពី *វិញ* ទេតីមកពីវា- អ្នកទាំងអស់គ្នាសំលឹងមើលទៅ*ពាក់ថន* -វានេះឡប់សតិហើយ ។

- ពួកអង់គ្លេសឡប់សតិតែទាំងអស់ គ្នាណើង- *សុង* និយាយ

- មើលដែលអ្នកណា ម្នាក់ស្គាល់អង់គ្លេសណាមួយដែលមិនឡប់ ? អេះស្បែកពួកវា



www.budinst.gov.kh www.elibraryofcambodia.org

តែបន្តិចបើមិនឃើញ មនុស្សឡប់ក៏ឃើញចោរសមុទ្រដែរ ។

- ពួកអាកូនមីចោរអស់នេះ-*គិញ្សែល* រអ៊ូរ ។

- ទេមិនមែនពួកវាសុទ្ធតែអញ្ចឹងទេ !-*វ៉ាន់ណិច* និយាយ-កុំភ្លេចថាគាត់ជាអ្នកការពារយើងណា ហើយ គាត់នាំយើងឆ្លងកាត់រាប់ពាន់យោជន៍មកហើយ !

- ការពារ ! អាច់អញនែ៎ ! កាលយើងចេញមកយើងមានគ្នាប្រាំរយនាក់ និងសំពៅប្រាំ ។ អីលូវយើងសល់ប៉ុន្មាន ? ប្រាំបួននាក់គត់ !

-រឿងសំពៅវង្វេងគ្នាជាកំហុសគាត់អី ? ព្យុះបោកបំផ្លាញពួកយើងជាកំហុសគាត់អី ?

- តែបើកុំតែគាត់ យើងប្រហែលនៅត្រឹមពិភពថ្មីតែប៉ុណ្ណឹង ។ តែគាត់ទេ គាត់ថាយើងអាចមកដល់ជប៉ុន ។ រួចអីលូវមើលទៅ ! មើលពួកយើងមើល ! វាយ៉ាប់ម៉េចហើយ ?

*វ៉ាន់ណិច* តបវិញទាំងធុញទ្រាន់ :

- ពួកយើងបានឯកភាពគ្នាសាកល្បងមកជប៉ុននេះ ។ យើងទាំងអស់គ្នាណុង ! យើងបោះឆ្នោតទេតើពេលនោះ ។

- វាអ៊ីចឹងមែនហើយ តែគាត់ជាអ្នកបញ្ចុះបញ្ចូលពួកយើងណា !

- ប្រយ័ត្ន !

*គីនស៊ែល* ចង្អុលទៅ*សាមូរ៉ៃ* ដែលកំពុងប្រែខ្លួនទាំងថ្ងូររហ៊ុំ ។ *សុង* ស្ទុះយ៉ាងរហ័សទៅជិតយារដៃដាល់ចំថ្គាមមួយដៃផាំង ។ បុរសនោះក៏សន្លប់បាត់មាត់ម្តងទៀតទៅ ។

- រំបល់យក៍ ! រួចពួកអាកូនមីចោរអស់នោះវាទុកអាឈើងមួយនៅកន្លែងនេះធ្វើអីវ៉ា? ពួកវាអាចយកគ្នាវាឡើងទៅវិញបានយ៉ាងងាយទេតើ ? មានអ្នកណាឃាត់ពួកវាបាន ?

- ក្រែងលោពួកវាស្មានថាអាមួយណឹងងាប់ហើយទេដឹង ?

- ខ្ញុំមិនដឹងដែរ ។ តែយ៉ាងម៉េចយ៉ាងម៉ាគួរតែមើលគ្នាសិនដែរ ។ យីធ្វើម៉េចបានប៊ីយែរត្រជាក់ផឹកទំ ?- *សុង* និយាយ ។

- *សុង* កុំរៃវាទៀតណា កុំអោយវាងាប់អោយសោះ ។ វាគឺជាឈ្លើយទុកធ្វើថ្នូរ ។

*គ្រូក* សំលឹងមើលទៅ *វិញ* ដែលនៅអង្គុយសោកសៅក្បែរជញ្ជាំង ក្នុងអារម្មណ៍ស្អប់



www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនឯង ដែលមិនបានគោរពតាមពាក្យសន្យារបស់ខ្លួន :

- សូមព្រះអង្គជួយតាមថែរក្សាពួកយើងខ្ញុំផង ។ តើវាធ្វើម៉េចខ្លះលើ *ពីចែស៊ុន* ? រួចចុះពួកវានឹងធ្វើអ្វីពួកយើង ?

- រឿងនេះខុសមកពីតៃកុងទេ-*យ៉ាទូរ៉ែ* និយាយ-តែគាត់ម្នាក់គត់ ។

*វ៉ាន់ណិច* សំលឹងមើល *ប្លាក់ថន* ទាំងអាណិតអាសូរ :

- វាគ្មានសំខាន់អីទៀតទេ រឿងណឹងនោះ អ្នកណាខុសអ្នកណាត្រូវក៏រឿងវាផុតទៅហើយមិនអីចឹង ?

*ម៉ែស៊្វីតែ* ចាប់ផ្ដើមធេងធោងដោយឈាមនៅតែហូរឥតដាច់ពីកំភួនដៃគេ :

- អញត្រូវរបួសហើយ អ្នកណាជួយអញបន្តិចទៅមើល !

*សាឡាម៉ុន* ចង់រឹតកួនកំព្រាដើម្បីឃាត់ឈាម ។ កំភួនដៃរបស់ *ម៉ែស៊្វីតែ* របេះយ៉ាងជ្រៅ ប៉ុន្តែសរសៃឈាមធំឥតមានដាច់ទេ ។ វ៉ូងរុយចាប់ផ្ដើមរោមមុខរបួសហើយ ។

- អារុយរបល់យក៍នេះវ៉ី ! ហើយអោយព្រះលោកអូសតៃកុងទៅនរកទៅលោក ! *ម៉ែស៊្វី តែ*អ៊ូរទាំ - គេព្រមព្រៀងរួចរាល់ហើយ តែលោកធ្វើបូក ចង់ជួយអា *វិញ* ! អីលូវឈាម *ពីចែស៊ុន* ត្រូវបូកលើតៃកុងណុងហើយ។ ពួកយើងច្បាស់ជានឹងរងទុក្ខ ដោយហេតុតែវាមិនខានទេ !

- បិទមាត់ទៅអ្នា បងតៃកុងថាគ្មាននាវិកមួយណារបស់គាត់...

នៅឯខាងលើស្ពូរជើងបានបន្លឺឡើង ។ ឃ្លុបរបើកឃ្លាំង ។ ពួកអ្នកភូមិក៏ចាប់ផ្ដើមចាក់ត្រីស្អុយលាយទឹកសមុទ្រទាំងធុង។ ចូលក្នុងអន្លង់រហូតដល់ត្រីស្អុយទាំងនេះ លិចអន្លង់បានប្រហែលមួយតឹកកន្លះទើបគេឈប់ ។

⋆⋆⋆

សំរែកបានលាន់លឺឡើងនៅពេលដែលព្រះច័ន្ទរះផុតចុងឈើហើយ ។ *យ៉ាប៊ូ* នៅលុតជង្គង់ក្នុងសួនច្បារ ក្នុងបរិវេណផ្ទះរបស់ *អូមី* ។ គេគ្មានញោចអារម្មណ៍អ្វីបន្តិចសោះ ។



www.budinst.gov.kh www.elibraryofcambodia.org

គេសំលឹងមើលពន្លឺខែតាមចន្លោះដើមឈើ ដែលមានផ្ការីកស្គុសស្គាយនិងសំលឹងមើលមែកឈើ ដែលតូសវាសពាសលើផ្ទៃអាកាសដ៏មានពន្លឺត្រជាក់ ។ ផ្កាមួយទងដាច់ ហើយធ្លាក់វិលខ្វាល់ចុះមកលើដី ។ *យ៉ាប៊ូ* គិតជាកំនាព្យមួយភ្លាម :

*សោភ័ណអមតៈមិនបាត់បង់*

*លើមែកត្រចង់គួរស្នេហា*

*ពេលធ្លាក់លើដីចាកវុក្ខា*

*សោភ័ណយ៉ាងណា នៅគង់វង្ស* ។

វាយោផ្ទុំទំលាក់បុប្ផាមួយទងទៀតពីលើដើមឈើ ដែលមានកំពស់ប្រហែលត្រឹមក្បាលមនុស្ស និង ដុះកណ្តាលថ្មដុះស្លែមួយចំនួនដែលគេរៀបចំយ៉ាងប៉ិនប្រសប់ មើលទៅហាក់ដូចជាផុសចេញពីដីពិត១ ។

*យ៉ាប៊ូ* ត្រូវប្រមូលផ្តុំឆន្ទៈ ទាំងអស់របស់ខ្លួន ដើម្បីអាចផ្តោតអារម្មណ៍ទៅលើដើមឈើ ទៅលើបុប្ផារីកស្គុសស្គាយ ទៅលើពួដអាកាសវេហាស៍ និងរាត្រីកាលដើម្បីទទួលការបបោសអង្អែលដ៏ស្រទន់របស់វាយោ ដើម្បីហិតក្លិនសមុទ្រ ដើម្បីតែងកាព្យ ទន្ទឹមនោះ ក៏ដើម្បីបណ្តែតអារម្មណ៍សប្បាយតាមសំរែកត្រដរខ្យល់ របស់អ្នកទោសរបស់ខ្លួនផងដែរ ។ គេរោយស្រពន់ខ្លួនយ៉ាងខ្លាំង ប៉ុន្តែឆន្ទៈយ៉ាងខ្លាំងក្លារបស់គេបានជួយអោយនៅទ្រាំទ្របានយ៉ាងស្ងៀមស្ងាត់យ៉ាងរឹងមាំ ។ ពេលគិតដល់នេះ គេមានកាមតណ្ហារញ្ជួលយ៉ាងខ្លាំងក្លា និងយ៉ាងចំលែកដែលគេមិនដែលជួបប្រទះសោះឡើយ ។

នៅក្នុងផ្ទះ ម្តាយរបស់ *អូមី* សួរខ្សឹប១ និងយ៉ាងភ័យខ្លាចទៅកាន់កូន :

- *អូមី-សាន* តើលោកម្ចាស់នៅអង្គុយកន្លែងហ្នឹងដល់ថ្មើរណាទៅកូន ?

- ខ្ញុំមិនដឹងដែរម៉ែ- *អូមី* ឆ្លើយ ។

- សំលេងស្រែករោទ៍នេះពិបាកទ្រាំណាស់ អង្កាល់ទៅទើបពួកគេឈប់ ?

- ខ្ញុំមិនដឹងដែរម៉ែ ។

ទាំងពីរនាក់អង្គុយនៅពីក្រោយរនាំង នៃបន្ទប់គម្ពីរ ។ បន្ទប់របស់ម្តាយ *អូមី* ដែលជា



www.budinst.gov.kh www.elibraryofcambodia.org

បន្ទប់ល្អស្អាតជាងគេនោះ ត្រូវបានរៀបចំអោយ *យ៉ាប៉ូ* សំរាក ។ បន្ទប់ទាំងពីរ បែរមុខទៅរកសួនច្បារដែល *អូមី* បានរៀបចំយ៉ាងមធ្យ័ត ។ តាមចន្លោះ....ពួកគេអាចមើលឃើញ *យ៉ាប៉ូ* អង្គុយយ៉ាងស្ងប់ស្ងាត់ ។ ស្រមោលដើមឈើផ្តិតជាប់នៅលើមុខរបស់គេ ឯពន្លឺព្រះច័ន្ទវិញរត់ប្រដេញគ្នានៅលើដងដាវរបស់គេ ។ *យ៉ាប៉ូ* ពាក់ហាវ៉ារី ( អាវក្រៅ ) ពណ៌ខ្មៅមួយជាន់ទៀត ពីលើគីម៉ូណូរបស់ខ្លួន ។

ម្តាយរបស់អូមីនិយាយបន្ទទាំងញ័រចំប្រប់ :

-ម៉ែចង់ទៅគេងហើយ តែម៉ែគេងមិនលក់ទេ ព្រោះតែឈឺសំរែកនេះ ។ អង្កាល់ទៅទើបចប់ ?

- ខ្ញុំមិនដឹងដែរ តែសូមម៉ែអត់ធ្មត់ទៅណាម៉ែ -*អូមី* និយាយថ្នម១ -វាជិតចប់ហើយ ។ ស្អែកព្រឹកលោកម្ចាស់ *យ៉ាប៉ូ* នឹងវិលត្រលប់ទៅ យេដូវិញហើយ ។ ទ្រាំបន្តិចទៅណាម៉ែ ។

មាត់និយាយយ៉ាងនេះ ប៉ុន្តែនៅក្នុងចិត្ត *អូមី* ដឹងច្បាស់ណាស់ថា ទារុណកម្ម នឹងប្រព្រឹត្តទៅពេញមួយយប់រហូតដល់ភ្លឺ ដូចដែលគេបានគ្រោងទុកអ៊ីចឹង ។

អូមី ប្រឹងប្រមូលសតិអារម្មណ៍តាមគំរូរបស់ *យ៉ាប៉ូ* ដែលអាចធ្វើកើតក្រោមសំរែកស្មួឈាមមួយរបស់មនុស្សនោះ ។ ប៉ុន្តែសំរែកដែលរោទ៍ឡើងជាថ្មីម្តងទៀតស្ទើរបែកក្រដាសត្រចៀកនោះ ធ្វើអោយគេភ្ញាក់ក្រញាង ហើយគិតថា គេមិនអាចធ្វើបានដូច *យ៉ាប៉ូ*ទេ ។ អញគ្មានអំនាច និងគ្មានសមត្ថភាពបញ្ញាដូចជាគាត់ទេ ។

រឺមួយ អានេះហើយជាអំនាច ? គេដណ្តឹងសួរខ្លួនគេ ។

*អូមី* អាចមើលឃើញច្បាស់មុខរបស់ *យ៉ាប៉ូ* ។ គេខំស្វែងយល់ពីទឹកមុខ ដ៏ចំលែករបស់ដៃមីញ៉ូ គេ : បបូរមាត់ក្រាស់ ញញឹមបន្តិចបែបចំអក ភ្នែករួងដែលទៅនឹងថ្កល់ មើលទៅហាក់ដូចជា *យ៉ាប៉ូ* ឡើងដល់ឋានសុខមួយខ្ពស់បំផុត ក្នុងដំណេករូមវ័ក្យស្នេហាអ៊ីចឹង ។ តើអាចមានបែបណើងកើតដែររឺ ?

នេះជាលើកទីមួយហើយ ដែល *អូមី* បានមានទំនាក់ទំនងយ៉ាងជិតបែបនេះ ជាមួយនឹពុកមារបស់គេដោយថា គេគឺជាសាច់ញាតិឆ្ងាយមួយរបស់ *យ៉ាប៉ូ* តែប៉ុណ្ណោះ ហើយទឹកដី *អាន់ជី*



www.budinst.gov.kh www.elibraryofcambodia.org

រី ដែលគេត្រួតត្រានេះ ជាតំបន់ក្រខ្សត់ និងគ្មានសារសំខាន់អ្វីផង ។ ឪពុករបស់ *អូមី* ឈ្មោះ *មីស៊ីណូ* មានបងប្អូនប្រាំមួយនាក់ ឯ*អូមី* ជាកូនពៅគេនៅក្នុងចំនោមកូនប្រុសទាំង ៣ របស់ *មីស៊ីណូ* ។*យ៉ាប៊ូ* ជាបងច្បងគេ និងជាអ្នកដឹកនាំត្រកូល *កាស៊ីក៏* ឯឪពុក *អូមី* ជាបងទីពីរតែប៉ុណ្ណោះ អីលូវនេះ *អូមី* មានអាយុម្ភៃឆ្នាំហើយ១គេមានកូនប្រុសមួយ ។

យាយចាស់ជាម្តាយចាប់ផ្តើមរអ៊ូ :

- រួចចុះមីប្រពន្ធអ្អែងទៅណាបាត់ហើយ ? អញចង់អោយវាមកឈ្លីខ្នង ឈ្លីស្មាអញបន្តិច ។

- វាទៅសួរសុខទុក្ខឪពុកវាហើយ ម៉ែមិនចាំទេអ្អេស ? ឪពុកក្មេកខ្ញុំឈឺធ្ងន់ណាស់ម៉ែ ។ អីលូវទុកអោយខ្ញុំឈ្លីជូនម៉ែចុះ ។

- មិនបាច់ទេ ។ ចាំបន្តិចទៀតអោយឈ្នួលម្នាក់មកឈ្លីអោយម៉ែ ក៏បានដែរ ។ ប្រពន្ធអ្អែងគ្មានចេះគិតគូរអីមែនតែម្រ៉ង ។ ចាំពីរ បីថ្ងៃទៀតចាំទៅមិនបានទេអ្អី ?អញខំមកលេងពួកអ្អែងតាំងពីយេដូមក ខំធ្វើដំណើរទាំងលំបាកលំបិនអស់ពីរអាទិត្យ ។ អញមកលេងមិនបានមួយអាទិត្យផង ប្រពន្ធវាចេញដំណើរទៅបាត់ ។ គ្រាន់តែចាំបន្តិចសិនមិនបាន ។ ប្រពន្ធអ្អែងគ្មានបានការអីទេ ។ ឪអ្អែងនេះច្រលំធ្ងន់តែម្រ៉ង ដែលអោយអ្អែងទៅការជាមួយស្រីបែបនេះ ។ តែអ្អែងគួរប្រាប់មីមិនបានការហើង អោយវាឈប់មករវីរវល់នឹងអ្អែងទៅ ។ គ្រាន់តែធ្វើសរសៃខ្នងអញក៏មិនស្រួលដែរ ។ បើអ្អែងមិនលែងវាទេ ក៏គួរតែសំពងវាអោយដឹងដៃម្តងដែរ ។ យីស ! វាជិទាលអីក៏ជិទាលម្លេះ ។ រួចម៉េចក៏វាក្រឈប់ម្លេះ ?

- វាឈប់អីលូវហើយ

- នែ៎ ! សំពងប្រពន្ធអ្អែងម្តងទៅ ។

- បាទម៉ែ ។

ពេលគិតដល់ *មីដូរី* ប្រពន្ធរបស់គេ បេះដូង *អូមី* លោតខុសប្រក្រតី ។ នាងមានរូបស្អាត រាងស្តើង ទន់ភ្លន់ រួសរាយ និងមានប្រាជ្ញាវាងវៃ ។ សំលេងនាងពីរោះ ហើយភ្លេងដែលនាង លេងមិនចាញ់អ្នកណាម្នាក់នៅ *អ៊ីស៊ូ* ឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

គេនៅចាំសំដី ដែលគេបាននិយាយទៅកាន់នាងនៅឡើយ :

- *មី ដូរី-សាន* អូនឯងត្រូវទៅក្នុងពេលឥឡូវនេះ ។

- *អូមី-សាន* ឪពុកខ្ញុំឥតមានជំងឺទេ ហើយភារកិច្ចរបស់ខ្ញុំ គឺនៅទីនេះ ដើម្បីបំរើម្ដាយរបស់បង *ទេ ?* ម្យ៉ាងទៀតបើលោកម្ចាស់ ដៃមីញ៉ូមកផ្ទះនេះ ក៏ត្រូវរៀបចំអោយបានស្រួលបួលដែរ ។ *អូមី-សាន* រឿងនេះសំខាន់ណាស់ ។ជាពេលដ៏សំខាន់បំផុតនៃការងារទាំងអស់របស់បង។ បើសិនជាលោកម្ចាស់ *យ៉ាប៉ូ* អារម្មណ៍ល្អនឹងបង គាត់អាចអោយបងកាន់កាប់តំបន់ណា ដែលល្អជាងនេះទៅទៀត ។ ព្រោះបងគួរតែកាន់កន្លែងល្អជាងនេះណា ។ បើសិនជាខ្ញុំមិនទៅ ហើយបើតែមានអីកើតឡើង ខ្ញុំមិនអាចប្រណីទោសខ្លួនខ្ញុំបានទេ ។ នេះជាលើកទីមួយហើយ ដែលបងមានឱកាសបង្ហាញសមត្ថភាពរបស់បង អ៊ីចឹងហើយត្រូវធ្វើយ៉ាងណាអោយបានជោគជ័យ ។ គាត់ត្រូវតែមក ។ខ្ញុំសូមអង្វរបងអោយខ្ញុំនៅទីនេះហើយ ព្រោះមានកិច្ចការច្រើនណាស់ដែលត្រូវធ្វើ ។

- ត្រូវហើយ *មីដូរី-សាន* ប៉ុន្តែបងអោយអូនចេញដំណើរ ! នៅទីនោះពីរថ្ងៃទៅរួចសឹមស្រួតមកផ្ទះវិញ ។

នាងបានអង្វរណាស់ដែរ ប៉ុន្តែគេនៅតែរក្សាសេចក្ដីសំរេចចិត្តរបស់គេដដែល ហើយនាងក៏បានចេញដំណើរទៅ ។ គេបានសំរេចចិត្តអោយនាងចេញដំណើរទៅឆ្ងាយពី *អាន់ជ្យ៉ូ* មុនពេលដែល *យ៉ាប៉ូ* ស្នាក់នៅក្នុងផ្ទះនេះ ។

បញ្ជូននាងទៅឆ្ងាយ មិនមែនគេខ្លាចថា ដៃមីញ៉ូរបស់គេ នឹងហ៊ានប៉ះពាល់នាងដោយទំនើងចិត្តនោះទេ ។ រឿងនេះមិនអាចកើតមានទេ ហើយបើសិនជាមានរឿងបែបនេះមែន គេក៏មានសិទ្ធិ មានកិត្តិយស និងមានភារកិច្ចតាមផ្លូវច្បាប់កំទេច ដៃមីញ៉ូដែរ ។ ទេមិនអាចមានរឿងយ៉ាងនេះទេ ប៉ុន្តែក្រោយពីបានរៀបការហើយនៅឯ យេដូ នោះមកគេបានកត់សំគាល់ថា ដៃមីញ៉ូរបស់គេហាក់ដូចជាតាមសំលឹងដោយយកចិត្តទុកដាក់លើរូបប្រពន្ធគេ ។ ដោយហេតុនេះ ពេលដែលលោកម្ចាស់គេមានវត្តមាននៅទីនេះ គេចង់បំបាត់ចោលនូវរាល់រូបភាពជាយថាហេតុ នៃរាល់ការថ្នាំងថ្នាក់ រីវង្វេសចិត្តរបស់ ដៃមីញ៉ូ របស់គេ ។ ប្រការសំខាន់គឺគេត្រូវទាក់ទាញអារម្មណ៍លោកម្ចាស់របស់គេតាមរយៈ នៃភក្ដីភាព សមត្ថភាពវិភាគ និងសតិរបស់គេ ។ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

លើចំនុចនេះ *អូមី* បានទទួលជោគជ័យលើសពីគេស្មាន ។ សំពៅគឺជាកំនប់ទ្រព្យ ឯពួកនាវិកក៏អស្ចារ្យទៀត ។ អ្វី១ គឺល្អឥតខ្ចោះ ។

- ខ្ញុំបានបួងសួងអោយជំនាងផ្ទះ *កាមី* មើលថែទាំបងហើយ -*មីដូរី* និយាយទៅកាន់ប្តីមុនពេលចេញដំណើរ -ហើយខ្ញុំបានអោយគេយកទេយ្យវត្ថុនានា ទៅប្រគេនព្រះសង្ឃនៅឯវត្តរួចហើយ ។ ខ្ញុំប្រាប់ *ស៊ូរី* អោយធ្វើយ៉ាងណាអោយល្អបំផុត ហើយខ្ញុំបានផ្ញើសារមួយទៅ *គីតូ-សាន* ហើយ ។ ហ៊ី *អូមី-សាន* សូមអោយខ្ញុំនៅទីនេះផងចុះ ។

ទឹកភ្នែកហូរជ្រែកផែនថ្ពាល់ លុបបំបាត់ម្សៅដែលនាងខំផាត់យ៉ាងផ្ចិតផ្ចង់នោះ ប៉ុន្តែ *អូមី* គ្រាន់តែញញឹម ហើយធ្វើសញ្ញាអោយនាងចេញដំណើរទៅ ។

គេមានការស្រងេះស្រងោចខ្លួនដែរ ពេលនៅម្នាក់ឯងយ៉ាងដូចនេះ ប៉ុន្តែគេ ក៏សប្បាយចិត្ត ដោយនាងចេញដំណើរនេះដែរ ។ បើសិនជានាងនៅទីនេះ សំរែកទាំងនេះ មិនដឹងជាធ្វើអោយនាងពិបាកចិត្តយ៉ាងណាទេ ។

ក្រោមជំនោរខ្យល់ ម្តាយរបស់ *អូមី* ថ្ងូរហ៊ឺស ហើយប្រឹងពត់ខ្លួនបន្តិចដើម្បីបន្ថយការឈឺចាប់នៅលើស្មារបស់ខ្លួន ។ នេះមកពីខ្យល់សមុទ្រហើយមើលទៅ គាត់គិតនៅក្នុងចិត្ត ប៉ុន្តែទោះជាយ៉ាងម៉េចយ៉ាងម៉ា ក៏វាគ្រាន់បើជាង *យេដូ* ដែរ ។ នៅ *យេដូ* ត្រពាំង បឹងបួរ ច្រើនពេក ហើយមូសច្រើនបួសដូចគេបាចអង្កាមទៅហើយ ។

ម្តាយរបស់ *អូមី* មើលឃើញស្រមោល *យ៉ាប៊ូ* ព្រាល១នៅឯសួនច្បារ ។ នៅក្នុងពោះរបស់យាយ១សែនស្អប់មនុស្សនេះ ហើយយាយបន់អោយតែមនុស្សនេះស្លាប់បាត់ទៅទេ ។ ពេលណាដែល *យ៉ាប៊ូ*ស្លាប់ ស្វាមីរបស់យាយគឺ *មីស៊ូណូ* នឹងបានក្លាយជា ដៃមីញ៉ូតំបន់ *អ៊ីស៊ូ* ហើយនឹងទៅជាអ្នកដឹកនាំក្រុមវិញម្តង ។ ដល់ពេលហ្នឹង ប្រហែលជាល្អអស្ចារ្យតែម្រ៉ង -យាយគិត ។ ពេលនោះទាំងសាច់ថ្លៃ ទាំងកូនចៅរបស់គេ នឹងក្លាយទៅជាអ្នកចំនុះយាយម្តង ហើយជាការច្បាស់ណាស់ ដែលពេលនោះ *មីស៊ូណូ-សាន* នឹងតែងតាំង *អូមី* ជាអ្នកទទួលស្នងត្រកូលជាមិនខាន ។

ការចុកចាប់បានរត់មួយឆាវ ឆាបរឹបដល់កញ្ចឹងកយាយ ។



www.budinst.gov.kh www.elibraryofcambodia.org

- ចាំខ្ញុំហៅ *គីតូ-សាន* នាងប៉ិនណាស់ណាំម៉ែ ! ។

*គីតូ-សាន* ជានារីអ្នកកំដរភ្ញៀវ ដែលគេហៅមកដើម្បីកំដរលោកម្ចាស់ *យ៉ាប៊ូ* នាពេលយប់នេះ ហើយដែលអីលូវនេះ កំពុងរង់ចាំយ៉ាងខន្តីបំផុត នៅឯបន្ទប់ម្ខាង ។

- ម៉ែមិនអីទេ គ្រាន់តែហត់បន្តិចបន្តួចតែប៉ុណ្ណឹង ។ តែអីចឹងក៏ល្អ អោយនាងមកធ្វើសរសៃអោយម៉ែបន្តិចទៅ ។

*អូមី*ឆ្លងទៅបន្ទប់ម្ខាងទៀត ។ ដំណេកត្រូវបានគេរៀបចំជាស្រេច ។ ពេលដែល *អូមី* និយាយប្រាប់នាងពីបំណងរបស់គេ *គីតូ* លំអោនខ្លួនគោរពយ៉ាងញញឹម ហើយនិយាយថ្នមៗថា នាងមានកិត្តិយសណាស់ ដែលបានយកចំនេះវិជ្ជាបន្តិចបន្តួចរបស់នាង មកបំរើនារីដ៏ខ្ពង់ខ្ពស់ជាងគេបំផុតក្នុងផ្ទះនេះ ។ ថ្ងៃនេះនាងមានភាពស្លេកស្លាំងជាងសព្វដង ។ *អូមី* យល់បានភ្លាមថា សំរែករោទ៍នេះបានជះឥទ្ធិពលមកលើនាងដែរ ។ កុមារម្នាក់ដែលនៅជិតនាងនោះ បានខិតខំលាក់បាំងការភ័យខ្លាចរបស់ខ្លួនយ៉ាងលំបាក ។

នៅពេលសំលេងស្រែករោទ៍បានលាន់លឺឡើង *អូមី* ត្រូវប្រឹងអស់ពីលទ្ធភាព ដើម្បីបញ្ចុះបញ្ចូល *គីតូ* អោយព្រមនៅ ។ នាងនិយាយអង្វរ *អូមី*:

- អោយខ្ញុំសូមទោសទៅចុះ *អូមី-សាន* ។ ខ្ញុំមិនអាចទ្រាំទ្របានទេ ។ វា....... វា..... វាគួរអោយរន្ធត់ណាស់ ។ អីចឹងហើយបានជាខ្ញុំសូមទោស សូមអនុញ្ញាតអោយខ្ញុំទៅវិញទៅ...... ខ្ញុំខំខ្ទប់ត្រចៀកហើយ តែសំលេងនៅតែរត់កាត់ដៃរបស់ខ្ញុំទៀត ។ ឱអ្នកកំសត់អើយ ! អីក៏វេទនាម្ល៉េះ ។

- *គីតូ-សាន* សូមនាងទ្រាំអត់ធ្មត់ទៅ ។ *យ៉ាប៊ូ-សាម៉ា* ជាអ្នកបញ្ជាទាំងអស់ ។ គ្មានអ្នកណាប៊ានជំទាស់អីបានទេ ។ បន្តិចទៀតចប់ហើយ ។

- ខ្ញុំទ្រាំមិនបានទេ *អូមី-សាន* ។ វាហួសពីខ្ញុំទ្រាំបានទៅទៀត ។

ជាទំនៀមទំលាប់មួយ ដែលគ្មានអ្នកណាអាចបំពានបាន គឺប្រាក់មិនអាចទិញនារីបានទេ បើសិនជានារីនោះ រឺថៅកែរបស់នារីនោះ មិនចង់ទទួលភ្ញៀវ ទោះជាភ្ញៀវនោះ ជាអ្នកណាក៏ដោយ ។ *គីតូ* គឺជានារីកំដរភ្ញៀវថ្នាក់លេខមួយ ជានារីដ៏ល្បីល្បាញបំផុតនៅ អ៊ីស៊ូ ហើយថ្វីត្បិត



www.budinst.gov.kh www.elibraryofcambodia.org

តែ *អូមី* ជឿជាក់ថានាង មិនអាចប្រៀបផ្ទឹមបានទៅនារីកំដរភ្ញៀវថ្នាក់លេខពីរ នៅយេដូ អូសាកា រឺ ក្យូតូគ្គី ក៏នៅទីនេះ *គីតូ* ជាកំពូលលើគេ ជានារីពិសេស ហើយប្រកបដោយមោទនភាព ។ ដោយហេតុនេះ ថ្វីត្បិតតែគេបានអោយលុយទៅម៉ែយ៉ែម *ក្យូកូ* នូវទឹកប្រាក់ប្រាំដង លើសតំលៃសព្វដងក្តី ក៏ *អូមី* មិនអាចច្បាស់ថា *គីតូ-សាន* នឹងយល់ព្រមនៅដែរ ។

អីលូវនេះគេសំលឹងមើលដៃដ៏ប៉ិនប្រសប់របស់នាង ដែលរត់នៅលើកញ្ចឹងករបស់ម្តាយគេ ។ *គីតូ* មានសំរស់ស្អាត មានមាឌតូចច្រលឹង និងមានសាច់រលោងឆ្អុះ ។ នៅក្នុងខ្លួននាង ពោរពេញទៅដោយថាមពលនៃជីវិត ។ ប៉ុន្តែ តើនារីដ៏ល្អស្អាតនេះ អាចរកឃើញការរីករាយម្តេចនឹងបានទៅនៅក្រោមសំរែកដ៏ឈឺចាប់យ៉ាងនេះ ? *អូមី* សញ្ជឹងគិតនៅក្នុងចិត្ត ។ គេចូលចិត្តសំលឹងមើល *គីតូ* ដោយបណ្តែតអារម្មណ៍ស្រមើស្រមៃគិតពីរូបកាយនាង ពីកំដៅដ៏ស្រទន់របស់នាង.....

រំពេចនោះ សំរែកបានរលត់ស្ងាត់បាត់ឈឹង !*អូមី* ផ្ទៀងត្រចៀកច្រហមាត់ប្រឹងត្រងត្រាប់ស្តាប់សូរស័ព្ទសំលេង ។ គេបានសង្កេត ឃើញ *គីតូ* បញ្ឈប់ចលនាម្រាមដៃរបស់នាង ឯម្តាយរបស់គេក៏នៅទ្រឹង ផ្ទៀងត្រចៀកស្តាប់ យ៉ាងយកចិត្តទុកដាក់ ដោយលែងថ្ងូរនឹងការឈឺចាប់របស់ខ្លួនទៀត ។ *អូមី* សំលឹងមើលទៅ *យ៉ាប៊ូ* តាមចន្លោះប្រដឹស ។ ដៃមិញ្ញូអង្គុយដូចជារូបចំលាក់ដដែល ។

នៅទីបំផុត *យ៉ាប៊ូ* ឧទានឡើង :

- *អូមី-សាន*

*អូមី-សាន* ក្រោកឡើងដើរចេញទៅវានហាលលំអោនខ្លួន :

- បាទលោកម្ចាស់ ។

-ទៅមើល តើមានអីកើតឡើងណឹង ?

*អូមី* លំអោនខ្លួនម្តងទៀត ទើបដើរកាត់សួនច្បារ ហើយធ្វើដំណើរលើផ្លូវរដិបរដុបមួយ ដែលរត់កាត់ភូមិ ចេញរហូតដល់ឆ្នេរមាត់សមុទ្រ ។ នៅជិតនឹងផែ *អូមី* ប្រទះឃើញមនុស្ស មួយក្រុមនៅជិតភ្នក់ភ្លើងមួយ ចំនែកឯនៅទីវាលទល់មុខនឹងឆ្នេរសមុទ្រ គេឃើញឆ្មាំប្ញនាក់ ដែលនៅអង្គុយយាមឃ្លប់អន្លង់នោះយ៉ាងមធ្យ័ត ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* កត់សំគាល់ផងដែរថា សំពៅពួកចុងស្រុកត្រូវបោះយុថ្កាយ៉ាងមាំទាំ ថែមទាំងមានចង្កៀងប្រេងដុតបំភ្លឺ ទាំងនៅលើ ទាំងនៅជុំវិញថែមទៀតផង ។ អ្នកភូមិមានទាំងបុរសទាំងនារី ទាំងកុមារ កំពុងរើអីវ៉ាន់ចេញពីសំពៅទៅដាក់លើទូកនេសាទតូចៗ ដែលកំពុងឆ្លងចុះឆ្លងឡើង ហើយដែលមើលពេលយប់ប្រៀបដូចជាវ៉ូងអំពិលអំពែកយ៉ាងដូចនោះឯង ។ នៅលើឆ្នេរខ្សាច់ អីវ៉ៃអីវ៉ាន់ត្រូវបានរៀបចំដាក់ជាគំនរដោយមានរបៀបរៀបរយ ។ កាណុងប្រាំពីរត្រូវរៀបជាស្រេចនៅលើឆ្នេរ ឯកាណុងទីប្រាំបីកំពុងត្រូវគេយោងដាក់លើឆ្នេរខ្សាច់ផងដែរ ។

*អូមី* ព្រឺខ្លួនឡើងស្បែកគីង្គក់ ថ្វីត្បិតតែគ្មានខ្យល់ធាតុត្រជាក់ក្តី ។ ជាធម្មតានៅក្នុងពេលបំពេញការងារ អ្នកភូមិរមែងនាំគ្នាច្រៀង ម្យ៉ាងដើម្បីផ្តល់កំលាំងគ្នា ម្យ៉ាងព្រោះសុភមង្គលរបស់ពួកគេ ។ ប៉ុន្តែយប់នេះភូមិមានសភាពស្ងប់ស្ងាត់ខុសពីប្រក្រតី ថ្វីត្បិតតែផ្ទះទាំងអស់មិនទាន់ចូលដំណេក ថ្វីត្បិតតែមនុស្សទាំងអស់ត្រូវបានគេឈ្នួរអោយមកបំពេញការងារក្តី ។ សូម្បីតែអ្នកជំងឺក៏ដោយ ក៏មិនអាចនៅស្ងៀមក្នុងផ្ទះបានដែរយប់នេះ ។ អ្នកភូមិទាំងអស់ញាប់ដៃញាប់ជើងជញ្ជូនអីវ៉ាន់យ៉ាងច្រវាត់ ។ ប៉ុន្តែស្ងាត់ឈឹង ។ សូម្បីតែឆ្កែ ក៏នៅស្ងាត់ស្ងៀម គ្មានព្រូសមួយរ៉ូសផង ។

តាំងពីដើមមក មិនដែលមានភាពបែបនេះទេ -*អូមី* ដើរបណ្តើរគិតបណ្តើរ ដៃគេក្តាប់ដងដាវយ៉ាងណែន ។ វាហាក់ដូចជាអ្នកតាថៃភូមិរត់ចោលពួកយើងបាត់អ៊ីចឹង ។

*មូរ៉ា* រត់មកជួប *អូមី* នៅពាក់កណ្តាលផ្លូវ ដោយគេទទួលដំណឹងពីការមកដល់របស់ *អូមី* តាំងពីពេលដែល *អូមី* បើកទ្វារសួនច្បារចេញមកក្រៅម្លេះ ។ គេលំអោនខ្លួនគោរព *អូមី* :

- រាត្រីសួស្តី *អូមី-សាន* ។ ដល់ថ្ងៃត្រង់អីវ៉ាន់នឹងសាងចេញអស់ហើយ ។
- អាចុងស្រុកងាប់ហើយរឺនៅ ?
- ខ្ញុំមិនដឹងដែរ ចាំខ្ញុំទៅមើលសិន ។
- តស់ទៅទាំងអស់គ្នាតែម្តងទៅ !

*មូរ៉ា* ដើរតាមពីក្រោយ *អូមី* យ៉ាងគោរព ។ ដោយមិនចូលចិត្តនឹងភាពស្ងប់ស្ងៀម *អូមី* ចាប់ផ្តើមសួរ :



www.budinst.gov.kh www.elibraryofcambodia.org

- អីចឹងដល់ថ្ងៃត្រង់រួចរាល់ហើយមែនទេ ?

- បាទទាន ។ អ្វីៗកំពុងដំណើរការល្អណាស់ ។

- រួចចុះអារឿងបិទបាំងរបស់ទាំងអស់នេះយ៉ាងម៉េចទៅហើយ ?

*មូរ៉ា* ចង្អុលទៅក្រុមមួយដែលមាននារីចាស់ៗ និងកុមារៗកំពុងអង្គុយត្បាញប្រជីសក្បែររោងសំនាញ់ ។ *ស៊ូរ៉ា* ក៏នៅក្នុងក្រុមនោះដែរ :

- យើងអាចដោះកាណុងចេញពីជើងទំរ ហើយរុំវាកុំអោយគេឃើញបាន ។ ក្នុងកាណុងមួយដើមយើងត្រូវការអ្នកសែងដប់នាក់ ។ *អ៊ីកូរ៉ាស៊ី-សាន* បានអោយគេទៅហៅអ្នកសែងបន្ថែមពីភូមិផ្សេងទៀតហើយ ។

- ល្អ !

- លោកម្ចាស់ ខ្ញុំខ្វល់ណាស់ពីរឿងធ្វើយ៉ាងម៉េចរក្សាការសំងាត់អោយបានទាន !

- *អ៊ីកូរ៉ាស៊ី-សាន* នឹងអោយពួកទាំងនោះ យល់ពីការចាំបាច់នៃបញ្ហានេះ *នេ* ?

- *អូមី-សាម៉ា* យើងត្រូវប្រើបាវអង្ករ ខ្សែ សំនាញ់ និងដើមបបុសទាំងអស់ ដែលយើងមាននៅក្នុងភូមិនេះហើយ ។

- រួចចុះវាយ៉ាងម៉េច ?

- បាទ ! ដល់រួចទៅធ្វើម៉េច ចាប់ត្រី និងទុកដាក់កោតផលបានទាន ?

- ពួកអ្នែងគង់តែរកឃើញផ្លូវដោះស្រាយទេ -សំលេង *អូមី* ប្រែក្លាយជាមុតៗ- រដូវនេះពន្ធត្រូវតំលើងពាក់កណ្តាលថែមទៀត ។ *យ៉ាប៊ូ-សាន* បានចេញបញ្ជាពីយប់មិញនេះ ។

- ពន្ធឆ្នាំនេះ និងពន្ធឆ្នាំក្រោយ យើងខ្ញុំបានបង់រួចរាល់ហើយទេតើលោកម្ចាស់ ។

- អភ័យឯកសិទ្ធិរបស់អ្នកស្រែមិនតឹ ចាប់ត្រី ច្រូតកាត់ ភ្ជួររាស់ និងបង់ពន្ធមែនទេ *មូរ៉ា* ?

*មូរ៉ា* ឆ្លើយតបយ៉ាងនឹងនរ !

- បាទមែនហើយលោកម្ចាស់ !

- មែភូមិដែលមិនអាចត្រួតត្រាភូមិឯងបានជារបស់អត់ប្រយោជន៍ *នេ* ?



www.budinst.gov.kh www.elibraryofcambodia.org

- បាទមែនហើយលោកម្ចាស់ !

- អាអ្នកភូមិម្នាក់ណុង ចំជាឆ្កួតមែន តែវាព្រហើនណាស់ដែរ ។ មានអាណាដូចវាអីចឹងទៀតទេ ?

- គ្មានទេលោកម្ចាស់ !

-យើងសង្ឃឹមថាគ្មានទៀតដែរ ។ អាកប្បកិរិយាព្រហើនមិនអាចអត់អោនអោយបានទេ ។ ត្រូវពិន័យគ្រួសារវាមួយគូគូ ជាត្រី រឺស្រូវ រឺជាភោគផល រឺជាអីៗទៀត ក៏បានដែរ ។ ពិន័យនេះត្រូវបង់អោយគ្រប់ក្នុងរយៈពេលបីខ្នើតណា !

- បាទលោកម្ចាស់ !

ទាំង *មូវ៉ា* ទាំង *អូមីសុទ្ធ* តែដឹងច្បាស់ថា ចំនួននេះគឺលើសពីលទ្ធភាពរបស់គ្រួសារហើយ ។ បងប្អូន *តាម៉ាសាគី* ទាំងបីនាក់ ហើយដែលអីលូវនេះនៅសល់តែពីរនាក់នោះ មាន តែទូកនេសាទមួយនិងដីស្រែកន្លះហិចតាប៉ុណ្ណោះ ដើម្បីចិញ្ចឹមប្រពន្ធ ហើយនិងកូនប្រុសបី កូន ស្រីបី ហើយនិងកូន *តាម៉ាសា* បីនាក់ប្រពន្ធមេម៉ាយពី *តាម៉ាសាគី* ម្នាក់ទៀត ។ ស្រូវមួយគូគូអាចចិញ្ចឹមគ្រួសារបានមួយឆ្នាំពោលគឺប្រហែល៣៥០ផោន ។នៅទូទាំងប្រទេសរាល់ចំនួននិងពន្ធដារត្រូវគិតជាគូគូ ។

*អូមី* សួរ :

- បើសិនជាយើងភ្លេចទំនៀមទំលាប់ តើដីព្រះនេះនឹងទៅជាយ៉ាងណា ?

- ពិតមែនហើយ *អូមី-សាន* ។

នៅក្នុងខួរក្បាល *មូវ៉ា* កំពុងគិតរកមធ្យោបាយយ៉ាងណា ដើម្បីរករបស់ពិន័យអោយបានមួយគូគូនោះ ព្រោះនៅពេលណាដែលគ្រួសារទទួលពិន័យ មិនអាចមានលទ្ធភាពបង់ទេនោះ គឺភូមិត្រូវទទួលសងជំនួស ។ ក្រៅពីហ្នឹងតើធ្វើម៉េច ដើម្បីរកបានបាវខ្សែ និងសំនាញ់បន្ថែមទៀត ? ព្រោះថាពេលដឹកជញ្ជូននេះនឹងមានដាច់ដោច ខូចខាតខ្លះជាមិនខាន ហើយក៏មានខ្លះនៅល្អអាចបន្តប្រើបានទៀតដែរ ។ ដោះស្រាយរឿងទាំងនេះ មើលទៅប្រហែលជាត្រូវខ្ចីលុយគេហើយ ។ មេភូមិជិតនេះ ធ្លាប់ជំពាក់គុណគេដែរ ប្រហែលជាគេអាចពឹងពាក់បាន ។ ឱមែនហើយ ! *តាម៉ាសាគី* មានកូនស្រីដ៏ល្អស្រស់ម្នាក់ អាយុប្រាំមួយឆ្នាំដែរតើ ប្រាំមួយឆ្នាំគឺជា



www.budinst.gov.kh www.elibraryofcambodia.org

អាយុល្អបំផុតសំរាប់លក់ក្មេង ។ ឯអ្នកទទួលជួញក្មេងល្បីល្បាញបំផុត ម៉ាតំបន់ *អ៊ីស៊ូ* នេះក៏គ្មានអ្នកណាក្រៅពីបងប្អូនជីដូនមួយ ម្ដាយមីងរបស់គេដែរ ។ គឺជាមេព្រាយដ៏គួរអោយស្អប់ខ្ពើម សំលឹងមើលឃើញតែលុយ និងទំពែកពាក់កណ្ដាល........

*មូរ៉ា* ដកដង្ហើមធំ ព្រោះគេដឹងថា នៅចំពោះមុខគេនឹងត្រូវធ្វើការចរចារជាច្រើនជាមិនខាន ។ តែអ្ហើយ ! អត់បញ្ហាទេ ! -គេគិតក្នុងចិត្ត ។ ហេងស៊យ ក្មេងស្រីនោះអាចបានថ្លៃដល់ពីរកូគូផងក៏មិនដឹង ព្រោះបើតាមរូបរាងក្មេងណុង មានតែលើសពីនេះផង ។ គេឆ្លើយតបទៅ *អូមី* :

- ខ្ញុំសូមទោសចំពោះអាកប្បកិរិយាមិនសមរម្យ របស់ *តាម៉ាសាគី* ហើយសូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ។

- នេះជាការព្រហើនរបស់ *តាម៉ាសាគី* ទេ មិនមែនរបស់អែងឯណា -*អូមី* ឆ្លើយតបយ៉ាងសុភាព ។

តែទាំងពីរនាក់ដឹងច្បាស់ថា នេះជាការទទួលខុសត្រូវរបស់ *មូរ៉ា* ហើយជាការល្អដែលមិនត្រូវមាន *តាម៉ាសាគី* ផ្សេងទៀតដែរ ។ ពេលនេះទាំងពីរនាក់ពេញចិត្តថ្លើម នឹងអ្វីដែលបានសំរេចរួចមកហើយនេះ ។ ការសូមទោសត្រូវបានធ្វើឡើង ហើយសំនូមពរនេះ ត្រូវបានទទួលទន្ទឹមនឹងត្រូវបានប្រកែកផង ។ពោលគឺកិត្តិយសរបស់ម្នាក់ៗ ត្រូវបានថែរក្សានៅគង់វង្សដដែល ។

ពួកគេបត់ចេញទៅកំពង់ផែ ហើយឈប់នៅទីនោះ ។ *អូមី* រួញរាបន្តិចទើបធ្វើសញ្ញាអោយ *មូរ៉ា* ចាកចេញ ។ មេភូមិលំអោនគោរព ហើយដើចេញទាំងចូរទ្រូងសទ្ទឹក ។

- វាស្លាប់ហើយអ្ហី *ស៊ូគីម៉ូតូ* ?

- បាទអត់ទេ *អូមី-សាន* ។ វាគ្រាន់តែសន្លប់ម្ដងទៀតតែប៉ុណ្ណឹង ។

*អូមី* ដើរទៅជិតថ្លាងដែក ដែលអ្នកភូមិប្រើសំរាប់ទុកចំរាញ់ខ្លាញ់ត្រីបាឡែន ដែលជូនកាលអ្នកភូមិចាប់បាន នៅក្នុងរដូវរងាងាឯលំហសមុទ្រ រី ក៏ដើម្បីចំរាញ់ការត្រី ដែលជាឧស្សាហកម្មរបស់ភូមិនោះ ។

មនុស្សចុងស្រុក ត្រូវគេដាក់ត្រាំលិចត្រឹមស្មានៅក្នុងទឹកពុះ ។ មុខរបស់គេឡើងក្រ



www.budinst.gov.kh www.elibraryofcambodia.org

ហមជាំ បប្តូរមាត់គេឡើងខើច ។

កាលពីព្រលប់ *អូមី* បានមកឈរមើល *ស៊ូគីម៉ូតូ* ដែលកំពុងណែនាំរៀបចំពិធី ក្នុងរីកពាដ៍ក្រអឺតក្រទម ។ មនុស្សចុងស្រុកត្រូវបានគេចងស្រាក់យ៉ាងមាំ ដោយដៃទាំងពីរត្រូវចងផ្តោបជង្គង់ បាតដៃប៉ះបាតជើង ហើយទំលាក់ចូលក្នុងទឹកត្រជាក់ ។ ក្នុងរយៈពេលនោះ បុរសចុងស្រុកសក់ក្រហម មាឌុល្អិត ដែល *យ៉ាប៊ូ* បានជ្រើសរើសយកនោះ ជូនស្រែកចចេចចចាច ជូនសើច ជូនយំ ។ បញ្ជិតកាតូលិច ក៏នៅទីកន្លែងនោះដែរ ហើយបានអោយធម៌ដល់អ្នកទទួលរងទារុណកម្មនោះ ។ រួចបន្ទាប់មកគេចាប់ផ្តើមបង្កាត់ភ្លើង ។ *យ៉ាប៊ូ* ឥតមានមុខនៅលើឆ្នេរទេ ប៉ុន្តែបញ្ជារបស់គេ គឺជាក់លាក់ ហើយទាំងអស់គ្នាបានអនុវត្តតាមដោយគ្មានល្បៀងមួយសរសៃសក់ឡើយ ។ អាចោរសមុទ្រនេះ ក៏ចាប់ផ្តើមស្រែករោទ៍ និងរើប្រកាច់ប្រកិន ។ រួចគេបានប្រឹងបោកទំលាយក្បាលនឹងគែមថ្នាង ទាល់តែបង្ខាំងអោយនៅស្ងៀមទើបឈប់ ។ បន្ទាប់មកបុរសនេះចាប់ផ្តើមអង្វរករ យំស្រែក សន្លប់ ភ្ញាក់ឡើងវិញ ហើយស្រែកយំជំទាលរហូតដល់ពេលដែលការឈឺចាប់មែនទែន ចាប់ផ្តើមទន្ទ្រានរូបរាងកាយរបស់គេ ។ *អូមី* សាកល្បងឈរមើលទិដ្ឋភាពនេះ ដូចគេមើលរុយមួយត្រដរខ្យល់យ៉ាងដូចនេះដែរ ប៉ុន្តែគេមិនអាចទ្រាំមើលបានយូរឡើយ ហើយគេត្រូវបង្ខំចិត្តចាកចេញពីទីនេះយ៉ាងរហ័ស ។ គេបានដឹងថាគេឥតមានចំនូលចិត្តអ្វីបន្តិចបន្តួចណាសោះក្នុងរឿងទារុណកម្មនេះ។ គេបានសន្និដ្ឋានថា ទង្វើនេះគ្មានអ្វីជាទីថ្លៃថ្នូរគួរជាទីមោទនៈសោះប៉ុន្តែទោះជាយ៉ាងនេះក្តីក៏គេមានការរីករាយសប្បាយក្នុងចិត្តម្យ៉ាងដែរ ព្រោះដោយគេមិនដែលឃើញការធ្វើទារុណកម្មពីមុនមក ទើបតែពេលនេះទេដែលគេបានដឹងពីចំនង់ចំនូលចិត្តពិតប្រាកដរបស់គេក្នុងរឿងនេះ។ វាគ្មានភាពថ្លៃថ្នូរទាំងចំពោះអ្នករងទារុណកម្ម ទាំងអ្នកធ្វើទារុណកម្ម។ ទង្វើនេះបានធ្វើអោយមរណភាពបាត់បង់នូវសេចក្តីថ្លៃថ្នូររបស់វា ហើយបើគ្មានសេចក្តីថ្លៃថ្នូរនេះ តើអ្វីទៅដែលជាចំនុចខ្ពស់បំផុតនៃជីវិតរបស់មនុស្សនោះ ?

យ៉ាងនឹងនរ *ស៊ូគីម៉ូតូ* យកឈើស្រួចមួយចាក់សាកជើងស្ទើរឆ្អិនទៅហើយ របស់ជនរងគ្រោះ ប្រៀបដូចជាគេចុចមើលថា តើត្រីដែលចំអិននោះ វាឆ្អិនហើយរឺនៅយ៉ាងដូចនោះដែរ រួចគេងាកមកនិយាយកាន់ *អូមី* :



www.budinst.gov.kh www.elibraryofcambodia.org

- បន្តិចទៀតវាដឹងខ្លួនវិញហើយ ។ អានេះពូកែទ្រាំគ្រាន់បើតែម្រ៉ង ។ មិននឹកស្មានថាពួកវាដូចយើងសោះរ៉ី ។ ឆ្ងល់ដែរមែនទេ ?

- អត់ឆ្ងល់ទេ -*អូមី* ឆ្លើយតបដោយចិត្តសំអប់ចំពោះបុរសដែលនៅពីមុខគេនេះ ។

ភ្លាមនោះ *ស៊ូគីម៉ូតូ* ត្រៀមអារម្មណ៍ប្រុងប្រយ័ត្នមួយរំពេច ហើយគេវិលត្រលប់ទៅប្រកាន់អាកប្បកិរិយា ញ៉ែប១ឡើងវិញ ។ គេលំអោនខ្លួនគោរព *អូមី*

- ខ្ញុំអត់ចង់និយាយថាម៉េចទេ *អូមី-សាន* ។ អត់មានអីទេ !

- ពិតជាអ៊ីចឹង ។ លោកម្ចាស់ *យ៉ាប៊ូ* និយាយថាលោកម្ចាស់សប្បាយចិត្តណាស់ ចំពោះកិច្ចការដែលលោកបានធ្វើនេះ ។ ព្រោះទាល់តែប្រសប់ណាស់ទើបចេះដុតភ្លើងម៉ាល្មម មិនក្ដៅហួស តែក៏មិនត្រជាក់ពេក ។

- លោកម្ចាស់ចិត្តល្អនឹងខ្ញុំណាស់ !

- អ្នកឯងធ្លាប់ដែលធ្វើការហ្នឹងពីដើមមកដែរអ្ហ៎ ?

- មិនមែនការណឹងទេ ប៉ុន្តែដោយសារលោកម្ចាស់ *យ៉ាប៊ូ* មានសគុណលើរូបខ្ញុំ ទើបខ្ញុំខំបំពេញបំនងរបស់គាត់ទៅ !

- លោកម្ចាស់ *យ៉ាប៊ូ* ចង់ដឹងថា តើវារស់បានប៉ុន្មានពេលទៀត ?

- បើប្រយ័ត្នប្រយែង វាអាចរស់ដល់ព្រឹកបាន ។

*អូមី* សំលឹងមើលថ្លាងយ៉ាងយកចិត្តទុកដាក់ រួចគេដើរតំរង់ទៅទីធ្លា ។ ពួក*សាមូរ៉ៃ*ដែលនៅយាមឃ្លុបទាំងប៉ុន្មាន ក្រោកឈរឡើង ហើយលំអោនកាយគោរព *អូមី* ។ បុរសម្នាក់ក្នុងចំនោមអ្នកទាំងអស់នោះ និយាយទៅកាន់ *អូមី* ទាំងសើចបណ្ដើរ ទាំងលើកដៃចង្អុលទៅឃ្លុបបណ្ដើរ :

- ខាងក្រោមនេះ នៅស្ងាត់ស្ងៀមល្អណាស់ទាន ។ ដំបូងពួកវាប្រកែកគ្នាដែរ បែបវាទាស់គ្នាមិនដឹង រួចលឺសូរដាល់តប់គ្នា ។ រួចបន្តិចទៀតលឺដូចពីរនាក់ រឺ បែបច្រើនជាងនេះផងក៏មិនដឹង ថ្ងូរអោយរហ៊ុសដូចកូនក្មេងទើបត្រូវមោងអ៊ីចឹង ។ អីលូវនេះស្ងាត់យូរក្រែលហើយទាន ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* ផ្ទៀងត្រចៀកស្តាប់ ។ គេលឺសំលេងទឹកក្លែកក្លក និងសំលេងខ្យល់បក់ខ្សៀវយ៉ាងស្រាល១ ។ យូរ១មានសំលេងថ្ងូរម្តង ។

- រួចចុះ *ម៉ាស៊ីជី* ?

*អូមី* សួរពីសាមូរ៉ៃម្នាក់ ដែលគេបញ្ជាអោយទុកចោលនៅក្នុងអន្លង់នោះ ។

- យើងខ្ញុំមិនដឹងដែរ *អូមី-សាន* ។ ប៉ុន្តែអត់លឺវាស្រែកហៅអីមួយម៉ាត់សោះ ។ ប្រហែលវាស្លាប់ហើយទាន ។

រួចចុះម៉េចបានជាអា *ម៉ាស៊ីជី* បំបង់បាយម្ល៉េះ -*អូមី* គិតនៅក្នុងចិត្ត ។ ចាញ់អ្នកណាមិនចាញ់ទៅចាញ់អាពួកមនុស្សអត់អាវុធ ហើយម៉ាចំនួនសុទ្ធតែមានជំងឺទៅទៀត ។ គួរអោយឆ្អែមមែន យកល្អវាគួរតែស្លាប់អីចឹងហើយ ។ គេចេញបញ្ជា :

- ស្អែកនេះ មិនត្រូវអោយទឹក អោយម្ហូបទេ ។ ដល់ថ្ងៃត្រង់ប្រមូលខ្មោចចេញមកលីទេ ? ហើយយកអាមេគេមកអោយខ្ញុំ ។ យកតែវាម្នាក់បានហើយ ។

- ប្របាទ *អូមី-សាន* ។

*អូមី* វិលមកកន្លែងភ្នក់ភ្លើង ហើយនៅរង់ចាំរហូតដល់ពេលមនុស្សចុងស្រុកបើកភ្នែក ។ ដល់ពេលនោះទើបគេគ្រលប់ទៅឯសួនច្បារ ដើម្បីរាយការណ៍ប្រាប់ *យ៉ាប៊ូ* ពីសំដីរបស់ *ស៊ូគីម៉ូតូ* ។ សំរែកឈឺចាប់ បានអណ្តែតខ្ទួនបន្តទៀតតាមជំនោរខ្យល់ ។

- តើអែងមានបានមើលភ្នែកអាចុងស្រុកនោះទេ ?

- បាទ *យ៉ាប៊ូ-សាន* ។

ពេលនេះ *អូមី* កំពុងអង្គុយពីក្រោយ *ដៃមីញ៉ូ* ឃ្លាតប្រហែលដប់ជំហាន ។ *យ៉ាប៊ូ* នៅតែអង្គុយធ្មឹងឥតកំរើកដដែល ។ ពន្លឺព្រះច័ន្ទ ចាំងឆ្លុះទៅលើគីម៉ូណូ និងដងដាវរបស់គេ ។

- តើ........ តើអែងឃើញអ្វីខ្លះនៅក្នុងភ្នែករបស់វា ?

- ឃើញឆ្កួត ។ ឃើញសារជាតិវិនភាពចំកួត ។ ខ្ញុំមិនដែលឃើញភ្នែករបៀបនេះទេ ។ ម្យ៉ាងទៀតនៅក្នុងភ្នែកវាក៏មានភាពរទូត់ញាប់ញ័រគ្មានព្រំដែនផងដែរ ។

- តែងកំនាព្យពីវាមួយទៅមើល !



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* ប្រឹងប្រើខួរក្បាលមួយស្របក់ រួចនៅពេលដែលគិតថាបានសមរម្យហើយ គេចាប់ផ្ដើមសូត្រឡើង :

*កែវភ្នែកក្រលោតញ័រចំប្រប់*

*ព្រោះដល់បញ្ចប់នៃជីវិត*

*ដល់ស្ថានទរគលាលោកា*

*ឈឺចាប់ខ្លោចផ្សាជាទំងន់* ។

សំរែកឈឺចាប់លាន់ឡើងខ្ទរជាថ្មី ។ គំលាតទឹកខ្នែងហាក់ដូចជាធ្វើអោយការឈឺចាប់នេះចាក់ជ្រៅទៅក្នុងប្រមាត់ សួតថែមទៀត ។

មួយសន្ទុះមក *យ៉ាប៊ូ* ចាប់ផ្ដើមសូត្រកំនាព្យតនឹង *អូមី*:

*បើអែងញាប់ញ័រនឹងវេទ្រា*

*វានាំទុក្ខាធ្ងន់ដល់ខ្លួន*

*ចិត្តថ្មដៃដែកប្រែក្រមួន*

*មិនចូនសក្តិសមជាម្ចាស់ឡើយ* ។

នៅក្នុងសោភ័ណភាព នៃរាត្រីកាល *អូមី* ត្រិះរិះយ៉ាងយូរអំពីអត្ថន័យ នៃកំនាព្យនេះ ។

☆

☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៥

សំរែកបានរលត់បាត់ នៅពេលដែលផ្ទៃមេឃចាប់ផ្ដើមមានពន្លឺព្រាល១ហើយនោះ ។ អីលូវនេះទាំងម្ដាយរបស់ *អូមី* ទាំង *យ៉ាប៊ូ* កំពុងលង់លក់ក្នុងដំណេក ។

ក្នុងពន្លឺល្ហះ១នៃពេលព្រឹកព្រហាម ទិដ្ឋភាពភូមិនៅតែមានចលនារស់រវើកដដែល ។ គេត្រូវសាងចេញពីសំពៅ នូវកាណុងបូនទៀត ព្រមជាមួយនឹងរំសេវហាសិបធុង និងគ្រាប់កាណុងជាងមួយពាន់គ្រាប់ផង ។

*គីតូ* នៅតែងស់ង៉ក្នុងកំរាលពូកនៅឡើយ ។ នាងសំលឹងមើលស្រមោលដែលកំពុងរវាំនៅលើជញ្ជាំង ។ ថ្វីត្បិតតែនាងមានការហត់នឿយលើសពីសព្វដងក្ដី ក៏នាងឥតបានគេងលង់លក់ផ្អែតដែរ សំលេងស្រមុករបស់យាយចាស់ ដែលនៅបន្ទប់ម្ខាងទៀតនោះ បានលុបដណ្ដប់ដង្ហើមស្រាល១ របស់ *ដៃមីញ៉ូ* ដែលកំពុងលង់លក់ ក្នុងដំណេកក្បែរនាង ។ នៅឯម្ខាងទៀត ក្មេងប្រុសម្នាក់គេងលក់យ៉ាងស្ងប់ស្ងាត់ ដោយយកដៃម្ខាងគងភ្នែក ដើម្បីបិទបាំងពន្លឺ ។

*យ៉ាប៊ូ* កំរើកខ្លួនបន្តិច ។ *គីតូ* ឈប់ដកដង្ហើមមួយភ្លែតក្នុងការរង់ចាំ ។ ប៉ុន្តែ *យ៉ា ប៊ូ* នៅលង់លក់យ៉ាងសុខស្រួលនៅឡើយក្នុងដំនេកខ្លួន ហើយប្រការនេះធ្វើអោយខ្លួននាងមានការរីករាយនៅក្នុងចិត្តច្រើន ព្រោះនាងដឹងថា បន្តិចទៀតនាងអាចចាកចេញពីទីនេះ ដោយមិនរំខានលោកម្ចាស់ឡើយ ។ នៅក្នុងពេលរង់ចាំយ៉ាងអត់ធ្មត់នេះ នាងខំនឹកពីការសប្បាយទាំងឡាយដែលនាងបានជួប ។ នាងនឹកឃើញសំដីរបស់គ្រូនាងដែលតែងអប់រំនាងថា :

- កូនឯងត្រូវចាំកុំភ្លេចអោយសោះថា គិតពីរឿងអាក្រក់ ជារឿងងាយបំផុតក្នុងពិភពលោកនេះ ។ បើយើងបណ្ដោយអារម្មណ៍វានឹងទាញឯងអោយធ្លាក់ចុះកាន់តែជ្រៅទៅ១ ក្នុងទុក្ខសោក ។ តែបើចង់គិតពីរឿងល្អនោះ គឺទាមទារការប្រឹងប្រែងមួយរបស់អន្ទះ ។ ហើយនេះគឺជាគោលបំនងនៃវិន័យ វីនៃការរីកបាត់នោះហើយ ។ ដោយហេតុនេះហើយកូនឯង ត្រូវបង្វិកសតិអារម្មណ៍ខ្លួនអោយយកចិត្តទុកដាក់លើក្លិនក្រអូប ដ៏ត្រជាក់ល្ហុយល្ហប់ ពីភាពទន់ល្មើយនៃក្រណាត់សូតនេះ ពីសំលេងភ្លៀងធ្លាក់រណ្ដំលើជញ្ជាំងសូជី ពីសោភ័ណភាពនៃការរៀបផ្កា ពីភាពស្ងប់ស្ងាត់នៃពេលព្រឹកព្រលឹម ។ យូរ១ទៅឯងមិនចាំបាច់ប្រឹងទេនៅក្នុងបញ្ហានេះ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

ពេលនោះឯងនឹងមានតំលៃសក្តិសមនឹងខ្លួនឯង សក្តិសមនឹងមុខរបរយើង ហើយឯងនឹងផ្តល់នូវកិត្តិយសយ៉ាងពោរពេញ ដល់ពិភពរបស់យើង គឺពិភពនៃសោភ័ណ ........

*គីគូ* នឹកគិតដល់ទឹកមុជ ដែលនាងនឹងត្រាំខ្លួនក្នុងពេលបន្តិចទៀតនេះ ដើម្បីលាងជំរះរាត្រីនេះចេញពីខ្លួនប្រាណនាង ហើយនឹងបន្ទាប់មកការជួយថែទាំរបស់ *ស៊ូរ៉ូ* ។ នាងនឹកគិតដល់សំនើចក្អាកក្អាយដែលនាងនឹងមានជាមួយនារីឯទៀត១ ហើយនឹង *ក្សូក្-សាន* ម៉ែយ៉ែម នៅពេលដែលគេខ្សឹបខ្សៀវប្រាប់គ្នាពីរឿងចចេចចចូច និងរឿងរ៉ាវផ្សេង១ទៀតនោះ ។

នៅពេលមុជទឹកហើយ នាងនឹងសំអាងសក់របស់នាង ហើយអាស្រ័យប្រាក់ដែលនាងបាននៅយប់នេះ នាងអាចកាត់សងបំនុលរបស់ *ក្សូក្-សាន* មួយចំនួនទៀតផ្ញើទៅអោយឪពុកនាងដែលជាអ្នកស្រែនៅឯស្រុក និងមួយចំនួនទៀតទុកសំរាប់ខ្លួននាង រួចនាងនឹងទៅជួបសង្សារនាង ដើម្បីធ្វើអោយរាត្រីនេះពោរពេញទៅដោយទឹកដមរបស់វាតែម្តង ។

គិតទៅជីវិតគួរជាទីរីករាយមែន ។

មែន ! ប៉ុន្តែទន្ទឹមនេះ គឺជាការលំបាកបំផុតដើម្បីបំភ្លេចសំរែកកាលពីយប់មិញនេះ បំភ្លេចមិនបានតែម្តង ។ អ្នកឯទៀតរួមទាំង *ក្សូក្-សាន* ផងមិនបានសប្បាយសោះទេ ។ ប៉ុន្តែល្ហើយកុំទៅខ្វល់ ! ស្អែកនេះយើងនឹងចាកចេញពី *អាន់ជីរ* ហើយនឹងត្រលប់ទៅផ្ទះដ៏គួរអោយស្រលាញ់របស់យើងនៅឯ *មីស៊ីម៉ា* វិញហើយ ។ហើយ *មីស៊ីម៉ា* គឺជាទីក្រុងធំបង្អស់ក្នុងតំបន់អ៊ីស៊ូនេះ ។

ស្តាយណាស់ដែលអ្នកស្រី *មីដ្ស៊ីរ* អោយគេទៅហៅអញមកនេះ ។

ប៉ុន្តែអ្ហើយ មានរឿងអីត្រូវស្តាយនោះ ? *គីគូ* ស្តីបន្ទោសខ្លួនឯង -គឺអ្ហែងគ្មានអ្វីត្រូវស្តាយទេ *នេ* ? គឺជាកិត្តិយសណាស់ទៅហើយ ដែលបានបំរើលោកម្ចាស់នោះ ។ បានកិត្តិយសនេះមិនតែនាងឯងអាចឡើងថ្លៃជាមួយ *ក្សូក្-សាន* បានទេអ្ហី ? នេះដូចជាបទពិសោធន៍មួយ ហើយចាប់ពីពេលនេះទៅ គេនឹងស្គាល់អ្ហែងក្នុងរហស្សនាមថ្មីមួយគឺ " ធីតាក្នុងរាត្រីសំរែក " ហើយលោតែមានសំនាង មានអ្នកណាសរសេរកំនាព្យពីអ្ហែង ហើយហេងស័យគេយកទៅច្រៀងផងក៏មិនដឹង ។ ឱ ! នោះគឺចំជាអស្ចារ្យតែម្តង ។ ពេលនោះកំនាន់អ្ហែងនឹងលោះឯង ហើយអ្ហែង



www.budinst.gov.kh www.elibraryofcambodia.org

នឹងមានកូន មានចៅ រស់នៅដោយសុខសាន្តទៀត ។

*គីតូ* ញញឹមស្រស់នៅពេលនឹកឃើញពីរឿងទាំងនេះ ។ នាងនឹកដល់រឿងនេះ ដែលនឹងក្លាយទៅជារឿងនិទានមួយ ដែលគេនិយាយដំណាលនៅក្នុងគ្រប់តែផ្ទះទូទាំង *អ៊ុស៊ូ* ស្ដីអំពីយប់នេះ ។ គេនឹងនិយាយអំពីលោកម្ចាស់ *ដៃមីញ៉ូ* ដែលនៅលុតជង្គង់ឥតញញោចសតិអារម្មណ៍អ្វីបន្តិចចំពោះសំរែកជំទាលរបស់មនុស្សត្រដរខ្យល់ ។ រួចចុះពេលចូលដំណេក លោកម្ចាស់ធ្វើយ៉ាងម៉េចខ្លះ ? ពួកគេចង់ដឹងទាំងសព្វទាំងគ្រប់ ។ រួចម៉េចបានជាមានក្មេងប្រុសនៅក្នុងបន្ទប់ជាមួយផង ? តើអ្នកនាង *គីតូ* ធើអី និយាយអី ហើយតើលោកម្ចាស់ *យ៉ាប៊ូ* ធើអី និយាយអី ? តើគាត់រួមដំណេកម្ដងរឺ ច្រើនដង ?.........

សំនួរនឹងមានរាប់ពាន់ ។ ប៉ុន្តែគឺជាសំនួរបញ្ឆិត និងជាចំលើយបញ្ចៀង ។ នេះគឺជាច្បាប់នៃពិភពសោភ័ណ ។ អ្វី១ត្រូវនៅជាសំងាត់បំផុត ។ គេមិនត្រូវនិយាយពីភ្ញៀវ ពីទំលាប់ភ្ញៀវ ពីគេអោយលុយ ប៉ុន្មាន១នោះទេ ។ ទាល់តែរក្សាការសំងាត់យ៉ាងនេះ ទើបអាចអោយភ្ញៀវទុកចិត្តបាន ។ បើមានអ្នកណានិយាយរឿងទាំងនេះនោះ គឺជារឿងរបស់គេ ប៉ុន្តែដាច់ខាតរឿងទាំងនេះ មិនត្រូវចេញពីសាមីនារីឡើយ ។ ជ្រួញចិញ្ចើមគ្រញែងស្នាយ៉ាងស្ទាក់ស្ទើរ ច្បូតសក់ទាំងនេះគឺអាចអនុញ្ញាតបាន ប៉ុន្តែនេះគឺគ្រប់គ្រាន់ហើយ បើសិនជានារីនោះ ជាអ្នកមានប្រាជ្ញា ។

នៅឯក្រៅ មេឃចាប់ផ្ដើមភ្លឺហើយ ។ គិតទៅមនុស្សប្រុសប្រៀបដូចជាកូនក្មេងអីចឹង -នាងគិតនៅក្នុងចិត្ត ។ ក្នុងចិត្តមនុស្សប្រុស គឺដូចជាពោរពេញដោយមោទនភាព ដ៏លេលាអីចឹង ។ លំបាក តឹងតែងមួយយប់ ដើម្បីគ្រាន់តែអ្វីជាស្រមោលភ្លឹបភ្លែត ហើយដែលគេស្មានថាជាការពិតមួយរយៈតែប៉ុណ្ណោះ ។ ប៉ុន្តែអ្វីទៅតណ្ហា ? នោះមិនគ្រាន់តែជាស្រមោលភ្លឹបភ្លែតនោះទេរឺ ?

ពេលដែលនាងយល់ថា ល្មមដល់ពេលហើយ *គីតូ* ទើបចេញពីដំណេកដ៏កក់ក្ដៅ រៀបគីម៉ូណូខ្លួនអោយមានសណ្ដាប់ធ្នាប់ឡើងវិញ ចងបន្ទឹងអូប៊ី សំរួលសក់ និងផាត់ម្សៅ ។

ក្មេងប្រុសនៅគេងលង់លក់នៅឡើយទេ ។ វាមានអាយុដប់ប្រាំឆ្នាំហើយ១ជាកូនរបស់អ្នកនេសាទនៅក្នុងភូមិនេះ ។ វាបានទៅហាត់រៀនជាមួយព្រះសង្ឃនៅក្នុងវត្តក្បែរនេះដែល



www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

ចេះគូររូបគំនូរផ្សេងៗដ៏ល្អ ។ វាជាក្មេងសំរាប់បំរើការសប្បាយរបស់អ្នកណាដែលមិនចង់ចិត្ត ស្វែងរកភាពសប្បាយជាមួយនារី ។ ប៉ុន្តែយប់មិញនេះ លោកម្ចាស់ *យ៉ាប៉ូ* បានសំរេចជ្រើសរើសរូបនាង........

នាងដើរចេញពីបន្ទប់ដោយគ្មានលឺស្នូរជើងមួយសីរបណាឡើយ ។

*សាមូរ៉ៃ* ឆ្មាំទ្វារលំអោនខ្លួនគោរពនាង ហើយនាងក៏លំអោនខ្លួនសងទៅគេវិញ ។ ពេលចេញផុតមាត់ទ្វារ ខ្លួននាងត្រូវជ្រមុជទៅក្នុងពន្លឺព្រះសុរិយា នាពេលព្រឹកព្រលឹមដ៏ត្រកាល ។ នារីអ្នកបំរើរបស់ *គីគូ* ទៅរង់ចាំនាងជាស្រេច ។

- អរុណសួស្តី *គីគូ-សាន* !

- អរុណសួស្តី

កំដៅព្រះអាទិត្យផ្តល់អារម្មណ៍សុខស្រួលម្ល៉េះទេ ទន្ទឹមនេះពន្លឺហាក់ជួយកំចាត់ចេញនូវរាត្រីកាលដែលកន្លងផុតទៅ ។ គ្មានអ្វីប្រសើរជាងមានជីវិតរស់រានទៅទេ -នាងគិតក្នុងចិត្ត ។

នាងសិកជើងទៅក្នុងទ្រនាប់ជើង ដំលោះឆ័ត្រពណ៌ក្រម៉ៅ ហើយដើរកាត់សួនច្បារតំរង់ចុះទៅភូមិសំដៅផ្ទះតែ ដែលជាផ្ទះសំនាក់បណ្តោះអាសន្នរបស់នាង ។ នារីអ្នកបំរើដើរតាមនាងប្រកិតពីក្រោយ ។

- អរុណសួស្តី *គីគូ-សាន* !

*មូរ៉ា* ស្វាគមន៍ *គីគូ* ដោយលំអោនខ្លួន ។ គេកំពុងអង្គុយសំរាកហូបតែនៅក្រោមរានហាលមុខផ្ទះរបស់គេ ។

- អរុណសួស្តី *មូរ៉ា-សាន* ។ អរុណសួស្តី *សៃតូ-សាន* ។ អីថ្ងៃនេះមានទឹកមុខស្រស់បស់ណាស់ -*គីគូ* តប ។

*សៃតូ*-គឺជាម្តាយរបស់ *មូរ៉ា* ។ គាត់រៀបចំតែសំរាប់កូនគាត់បណ្តើរឆ្លើយតបទៅ *គីគូ* បណ្តើរ :

- នាងសុខសប្បាយជាទេ ? អ្ហើយយប់មិញអស់យ៉ាងតែម្រ៉ង ! មក៏ចូលមក ញ៉ាំតែសិនមក ។ កូនឯងស្លាំងណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

- អរគុណអ៊ំ ! តែសូមអ៊ំអត់ទោសចុះ ព្រោះខ្ញុំប្រញាប់ស្រួតទៅផ្ទះ ។ អ៊ំហៅខ្ញុំនេះជាកិត្តិយសណាស់ ! ចាំលើកក្រោយអ៊ំ !

-តាមពិតប្រការដែលឯងយល់ព្រមមកនេះ បានផ្តល់កិត្តិយស ដល់ភូមិយើងទៅវិញទេណា ។

*គិតូ* ញញឹម ហើយធ្វើជាមិនសង្កេតឃើញភ្នែកសំលឹងពិនិត្យ របស់អ្នកទាំងពីរឡើយ ។ នាងលំអោនខ្លួនលាអ្នកទាំងពីរ ហើយបន្តដំណើរយ៉ាងនឹងនររបស់នាងបន្តទៅទៀត ។

☆ ☆ ☆

គំនរអុសត្រូវបានរៀបចំហើយស្រេច ។ អ្នកភូមិប្រាំនាក់ ក៏បានរៀបចំខ្លួនហើយជាស្រេចដែរ ។

កន្លែងនេះ ជាកន្លែងត្រកាលជាងគេបំផុតនៅក្នុងភូមិនេះ ។ ជាកន្លែងដែលមានខ្យល់អាកាសត្រសៀកបំផុតនៅរដូវក្តៅ ហើយជាកន្លែងដែលគេអាចមើលឃើញទេសភាពល្អបំផុតផងដែរ ។ នៅជិតនោះមានវិហារ ស៊ិនតូ របស់អ្នកភូមិមួយ និងរោងអ្នកតាប្រក់ស្បូវមួយសំរាប់ *កាមី* ។

ប៉ុន្មានម៉ោងក្រោយមក *អូមី* បានដើរមកដល់កន្លែងបូជាសពនេះ ។ *ស៊ូគីម៉ូតូ* និង សាមូរ៉ៃ ៤នាក់ ហែហមមកជាមួយគេ ។ នៅពេលដែល *អូមី* លំអោនខ្លួនចំពោះមុខគំនរអុសគោរពសពរលេះរលួយរុំក្នុងស្នប់ ដែលនៅពីលើអុសនោះ អ្នកឯទៀតក៏ធ្វើតាម *អូមី* ភ្លាម ។ គេគោរពមនុស្សចុងស្រុកនេះដែលបានស្លាប់ ដើម្បីមិត្តភក្តិឯទៀតរបស់ខ្លួនបានរស់រានមានជីវិត ។

ពេលដែល *អូមី* អោយសញ្ញា *ស៊ូគីម៉ូតូ* ក៏ដើរទៅឆូលភ្លើងគំនរអុស ។ *ស៊ូគីម៉ូតូ* បានទទូចសុំធ្វើការនេះ ហើយ *អូមី* បានសំរេចផ្តល់កិត្តិយសនេះទៅតាមសំនើ ។ នៅពេលដែលភ្លើងឆាបឆេះហើយ ពួកគេក៏នាំគ្នាចាកចេញពីទីនោះទៅ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

*ភ្លាក់ថន* ច្រលក់ពែងទៅក្នុងទឹក ហើយវាស់យ៉ាងម៉ត់ចត់នូវរបបទឹកដែលគេហុចទៅអោយ *សុង* ។ ដំបូង *សុង* លិទ្ធទឹកចិប១ដើម្បីអោយបានយូរ ។ ប៉ុន្តែសំរេករបស់គេខ្លាំងជាងបំនងទៅទៀត ។ គេក៏ក្រេបកែវអកទឹកក្តៅឧណ្ហ១នោះអស់មួយរំពេច រួចទើបគេនឹកស្តាយចំពោះទង្វើរបស់គេអំបាញ់មិញនេះ ។ គេដើរពពីមពពើមតំរង់ទៅកន្លែងរបស់គេវិញ ដែលនៅជាប់ជញ្ជាំង ដោយកន្លងអ្នកដែលដល់វេនទំរេតខ្លួននោះ ។ បាតអន្លង់ មានសុទ្ធតែភក់ ឯក្លិនអសោចិ៍ និងរំវិងរុយ គឺលែងពណ៌នាបាន ។ ពន្លឺព្រាល១ចាំងឆ្លុះតាមចន្លោះក្តារឃ្លុប ។

*វិញ* គឺជាអ្នកដល់វេនត្រូវបានទទួលទឹកផឹកម្តង ។ គេអង្គុយក្បែរចុងទល់មុខ នឹង *ភ្លាក់ថន* ដែលនៅពីម្ខាងទៀត ហើយសំលឹងមើលពែងរបស់ខ្លួនថ្ងាំង រួចទើបគេនិយាយខ្សាវ១ទាំងឡើយណាយ :

- អរគុណ !

- នែឆាប់បន្តិចមើល !

*យ៉ានទូរ៉ែ* តឿនឡើង ។ របួសនៅលើថ្ពាល់របស់គេ ចាប់ផ្តើមក្លាយហើយ ។ គេជាអ្នកចុងក្រោយបង្អស់ ដែលត្រូវទទួលទឹក ហើយប្រការដែលជិតដល់វេនខ្លួនឯងយ៉ាងនេះ ធ្វើអោយគេច្រាសច្រាលទ្រាំលែងបានតែម្តង ។

- ឆាប់ឡើង អា *វិញ* អ្នា ! អាណិតអញទៅ !

- សូមទោស ! នេះទឹក !

*វិញ* តបក្នុងសំដីប៉ក់ល្ងើយ និងដោយទាំងមិនរវល់ដេញរុយរោមមុខរោមមាត់របស់គេផង ។

- អ្ហែងឆ្កួតទេអី្ហ ? ផឹកទៅ ! នេះរបបអ្ហែងសំរាប់រហូតដល់ល្ងាចណា ។ ផឹកទៅ !

*យ៉ានទូរ៉ែ* រុញពែងទៅក្នុងដៃរបស់ *វិញ* តែ *វិញ* ឥតមានសំលឹងមើល *យ៉ាន* ឡើយ ។ គេផឹករបបគេហាក់ដូចគ្មានវិញ្ញាណ ហើយបន្ទាប់មកគេក៏នៅធ្មឹងដូចរូបចំលាក់ដដែល ។

*យ៉ាន* ទទួលពែងទឹករបស់ខ្លួនពីដៃ *ភ្លាក់ថន* គេបិទភ្នែកហើយស្ទឹងស្មាធភាវនាធម៌មួយសន្ទុះ ។ គេស្ថិតនៅក្នុងក្រុមដែលត្រូវវេនឈរ ដោយហេតុនេះគេឈឺជើងសឹងទ្រាំមិនបាន ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលដែលអ្នកទាំងអស់គ្នាបានទទួលរបបទឹករួចរាល់ហើយ *ភ្ញាក់ថន* ដួសទឹកយករបបរបស់គេជាចុងក្រោយ ។ គេក្រេបទឹករបស់គេយ៉ាងឆ្ងាញ់ត្រជាក់ចិត្ត ។ មាត់និងអណ្ដាតរបស់គេឡើងស្ងួតស្អិត និងពេញដោយធូលី ។ ខ្លួនប្រាណរបស់គេមានសុទ្ធតែភក់ ញើស និងរុយ ។ ដើមទ្រូង ខ្នង របស់គេនៅឈឺអួលនៅឡើយ ។

គេសំលឹងមើលទៅ សាមូរ៉ៃដែលត្រូវបោះបង់ចោលក្នុងអន្លង់ ។ បុរសនេះអង្គុយត្របោមក្បាលជង្គង់ក្បែរជញ្ជាំងចន្លោះ *សុង* និង *ភ្លុក* ។ តាំងពីដឹងខ្លួនពេលណាបុរសនេះ នៅស្ងៀមស្ងាត់ឥតកំរើក ក្នុងស្ថានភាពបែបនេះរហូត ។ គេសំលឹងមើលត្រង់ទៅមុខ ដោយក្រសែភ្នែកថ្មឹងដូចជាមនុស្សស្លាប់ ។ ក្រៅពីស្បែករុំជាខោស្នាប់ភ្លៅ ខ្លួនប្រាណគេនៅទទេស្អាត ។ ស្នាមជាំនៅពេញខ្លួនគេ ហើយនៅជុំវិញមានស្នាមកន្ទួលជាំ ។

ពេលដែល *ភ្ញាក់ថន*ភ្ញាក់ដឹងខ្លួនឡើងវិញនោះ នៅក្នុងអន្លង់ងងឹតស្លុងទៅហើយ សំរែករោទ៍បានលាន់ខ្ទរពេញអន្លង់ ធ្វើអោយគេគិតថា គេស្លាប់បាត់បង់ជីវិត ហើយមកដល់ទីឋាននរកហើយ ។ គេមានអារម្មណ៍ថា ខ្លួនគេត្រូវភក់ដ៏ស្អិត បឺតប្រទាញគេចុះទៅក្រោម ។ គេបានស្រែកនិងរើបំរះ ហើយដង្ហើមគេហាក់ដូចជាថប់។ ។ មួយសន្ទុះក្រោយមក ដែលប្រៀបបានមួយសតវត្សរ៍ចំពោះរូបគេ ទើប *ភ្ញាក់ថន* លឺសំលេងមួយពោលមកកាន់គេ :

- អត់អីទេបងតែកុង ។ បងឯងមិនទាន់ស្លាប់ទេ ។ រួចរាល់អស់ហើយភ្ញាក់ឡើង ! នែ៎ ! ភ្ញាក់ឡើង ! កន្លែងនេះមិនមែនឋាននរកទេ ! តែវាដូចតែគ្នាហ្នឹង ។ ឱព្រះអើយព្រះ ! ជួយពួកយើងផង ។

ពេលដែលគេដឹងខ្លួនមែនទែនហើយ ទើបអ្នកឯទៀតនិយាយប្រាប់គេពីរឿង *ពីតែស៊ូន* និងទឹកត្រីស្អុយ ។ បុរសម្នាក់ថ្ងូររហឹុសឡើង :

- ឱព្រះអង្គអើយព្រះអង្គ ! ជួយពួកយើងខ្ញុំអោយចេញរួចពីកន្លែងនេះផង !

- រួចចុះពួកវាធ្វើអីអា *ពីតែស៊ូន* ហ្នឹង ? វាធើអីហ្នឹង ? ឱព្រះអើយអញទ្រាំស្ដាប់វាស្រែកមិនបានទេ !

- ឱព្រះអង្គអើយអោយវា ស្លាប់ឆាប់ទៅ !



www.budinst.gov.kh www.elibraryofcambodia.org

- ឱព្រះអើយព្រះ កុំអោយលឺវាស្រែកទៀតលោក !

ស្ថានភាពអន្ទង់ និងសំរែក *ពីវែស៊ុន* បានបង្ខំអោយពួកគេពិចារណារូបពួកគេផ្ទាល់ ហើយម្នាក់ៗដឹងខ្លួនថា ពួកគេច្បាស់ជាមិនមានសំនាងគេចផុតពីអ្វី ដែលគេជឿថានឹងមកដល់រូបគេនៅពេលខាងមុខនេះឡើយ ។

នេះគឺជារាត្រីក្នុងអន្ទង់ ដែលគ្មានទីបញ្ចប់ ។

សំរែកបានរលត់ទៅជាមួយនឹងការលេចចេញ នៃពន្លឺព្រាលៗនាពេលព្រលឹម ពេលដែលពន្លឺជ្រែកចូលដល់បាតអន្ទង់ ទើបគេឃើញសាមូរ៉ៃនោះ ។

- រួចអាមួយនេះ គិតយ៉ាងម៉េចហ្នឹង ? -*វ៉ាន់ណិច* សួរ ។

- មិនដឹងដែរ ។ តែមើលទៅវាកំពុងតែញាក់សាច់ដូចតែយើងដែរហ្នឹង - *ប្លាក់ថន* ឆ្លើយតប ។ បេះដូងរបស់គេលោតស្ទើរធ្លាយតាមមាត់ ។

- សំខាន់ អោយតែវានៅអោយស្ងៀមទៅ ។

*គ្រូក* ចាប់ផ្តើមបាត់ស្មារតីហើយ ។ គេស្រែកជំទាលឡើងភ្លាត់សំលេង :

- ឱព្រះអើយព្រះអង្គ ! ជួយយកខ្ញុំចេញពីហ្នឹងផង ! ជួយផង !

*វ៉ាន់ណិច* ដែលនៅក្បែរនោះ ខំអង្រួន និងលួងលោម *គ្រូក* :

- អត់អីទេ *គ្រូក* ។ ព្រះនៅតាមថែរក្សាពួកយើងអីចឹង !

- នែ៎ ! មើលដៃអញទៅ ! -*វែស្ទ័រតែ* និយាយរង៉ូវៗ របួសគេចាប់ផ្តើមក្លាយហើយ ។

*ប្លាក់ថន* នៅឈរញ័រខ្លួនចំប្រប៉ៃនៅឡើយ ។ គេបន្លឺសំលេងឡើងដោយមិនសំដៅទៅរកអ្នកណាម្នាក់ទេ :

- ពីរបីថ្ងៃទៀតបើយើងចេញមិនរួចពីកន្លែងនេះទៀត ពួកយើងឡប់អស់មិនខានទេ។ *វ៉ាន់ណិច* និយាយបន្ទរ :

- អីលូវនេះជិតអស់ទឹកហើយហ្នឹង !

- អីលូវគិតទឹកផឹកទើបបាន ។ អីលូវនេះផឹកបន្តិច ថ្ងៃត្រង់បន្តិចទៀត ។ បើហេងអាចផឹកបានបីវេនដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

យី ! អារុយរបស់យក៏នេះ !

បន្ទាប់មកគេរកបានពែង ហើយចាប់ផ្ដើមចែករបប ។ អីលូវនេះគេកំពុងតែចិបទឹក ដែលជារបបរបស់គេដើម្បីអូសបន្ទាយភាពត្រេកត្រអាលនេះ ។

- រួចចុះ អាជប៉ុននេះគិតយ៉ាងម៉េចទៅ ?

*ស្ដីលវ៉េគីន* សួរទៅអ្នកផង ។ ក្នុងចំនោមអ្នកទាំងអស់គ្នាមានតែមេបញ្ជាការទេ ដែលនៅគ្រាន់បើជាងគេ ដោយកាលពីយប់គាត់បានយកភក់ចុកត្រចៀក ដើម្បីកុំអោយលឺសូរសំរែករបស់ *ពីតែស៊ីន* ។ ម្យ៉ាងទៀតដោយគាត់នៅសំរាកជិតធុងទឹកនេះ គាត់បានឆ្លៀតសំរន់សំរេករបស់គាត់យ៉ាងបរិបូរណ៍ ។

- មើលដោះស្រាយរឿងយ៉ាងម៉េច ? - *ស្ដីលវ៉េគីន* សួរម្ដងទៀត ។

- គួរអោយទឹកវាផឹកផងទៅ -*វ៉ាន់ណិច* និយាយ ។

- មិនបានទេ ! ម៉ាតំនក់ ក៏កុំអោយដែរ -*សុង* តប ។

រួចគេអនុម័ត ។ ហើយគេបានឯកភាពមិនអោយទឹកទៅ បុរសជប៉ុននោះឡើយ ។

- ខ្ញុំមិនឯកភាពទេ !- *ពួក់ថន* និយាយ ។

- អោយតែពួកយើងនិយាយអី បងឯងជិទាស់ភ្លាម -*យ៉ាន់រ៉ូវ៉េ* និយាយ -អានេះវាជាខ្មាំង ។ វាជាទមិឡ ............រួចវាវិះតែសំលាប់បងឯងស្លាប់ទៅទៀត ។

- អ្អែង កវិះតែធ្វើអោយខ្ញុំស្លាប់ដែរ ។ មិនដឹងប៉ុន្មានសិបដងហើយទេ ។ បើ *មូស្គ* ឯងនេះរំសេវ ស្រួលបួលនោះ ប្រហែលជាសន្ទះក្បាលខ្ញុំវារយះបាត់ទៅហើយ កាលពីនៅ *សាន់តាម៉ាន់ឌីលែណា* នោះ ។

- ខ្ញុំមានតំរង់បងឯងឯណា ។ ខ្ញុំតំរង់ពួកគោរពសាតង់សំអុយនោះទេតើ ។

- ពួកគេ ជាបព្វជិតគ្មានអាវុធទេ ។ ហើយម្យ៉ាងទៀតមានពេលគគោកតើ ។

- ថាខ្ញុំឥតមានតំរង់ដាក់បងឯងទេ !

- ខ្ញុំវិះតែស្លាប់ប៉ុន្មានដងហើយ ពីព្រោះតែអារឿងឆេវឆាវ អារឿងខូបង្កង និងអារឿងពភ្លីពភ្លើ ចោលពុទ្ធោឯងនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

- នែ ! បងឯងមិនមែនស្តេចទេ ហើយនេះក៏មិនមែនជាសំពៅដែរ ។ បងឯង ក៏មិនមែនជាអ្នក ............

- តែអ្នែង ត្រូវធ្វើតាមខ្ញុំថា !

*យ៉ានូវ៉ែត* ខំសំលឹងមើលពេញអន្លង់ ដើម្បីរកអ្នកគាំទ្រខ្លួន តែគ្មានសោះ ។

- បងឯងធ្វើម៉េចធ្វើទៅ -គេនិយាយទាំងប៉ក់ល្បើយ

- អើច្បាស់ជាធើហើយ ។

សាមូរ៉ៃនោះ ក៏ស្រេកទឹកដូចអ្នកឯទៀតដែរ ប៉ុន្តែនៅពេលដែល *ប្លាក់ថន* ហុចពែងទឹក គេបែរជាគ្រវីក្បាលប្រកែកទៅវិញ ។ *ប្លាក់ថន* ស្ទាក់ស្ទើរបន្តិច រួចទើបគេរុញពែងទៅដល់បបូរមាត់ហើមឃ្លើបរបស់ សាមូរ៉ៃនោះ ប៉ុន្តែបុរសនោះ គ្រវាសពែងនោះកំពប់ទឹកខ្ចាយ ព្រមទាំងនិយាយយ៉ាងមុត១ទៀតផង ។ *ប្លាក់ថន* ត្រៀមក្រោកដើម្បីទប់ការវាយលុកទីពីរទៀតប៉ុន្តែបុរសនោះ ឥតមានកំរើកទៀតឡើយ ។គេនៅអង្គុយធ្មឹងសំលឹងទៅមុខ ដោយឥតកំរើកដដែល ។

- វាឆ្កួតទេ ។ ពួកវាឆ្កួតតែទាំងអស់គ្នាហ្នឹង -*ស្ពិលប៊ែគីន* និយាយ ។

- វាមិនផឹកក៏រឹតតែល្អ ។ វាកាន់តែសល់ទឹកសំរាប់ពួកយើងផង -*យ៉ានូវ៉ែត* និយាយ ។

- ទុកវាទៅងាប់ចុះនរកឯណាចុះទៅ ។

- នែ អ្នែងឈ្មោះអី ? អ្នាស ? -ប្លាក់ថន សាកល្បងសួរបុរសនោះ ពីរដង តែហាក់ដូចជាសាមូរ៉ៃនោះមិនលឺសំនួរ របស់គេសោះតែម្តង ។

រួចចុះវាគិតអីអីល្ងង់ហ្នឹង -*ប្លាក់ថន* ដណ្តឹងសួរនៅក្នុងចិត្ត ។ ហេតុអីបានជាវាមិនព្រមទទួលទឹក រួចហេតុអីបានជាគេទុកវាចោលនៅកន្លែងនេះ ? រឺមួយ *អូទី* ច្រលំ ? ដូចជាមិនមែនទេ ។ រឺវាមានផែនការអី ? ក៏ដូចជាមិនមែនដែរ ។ អាចយកវាសំរាប់ធ្វើជាឈ្នាន់ចេញទៅលើបានទេ ? ប្រហែលជាមិនបានទេ ។ អ្វី១ក៏សុទ្ធតែមិនច្បាស់តែទាំងអស់ លើកលែងតែរឿងមួយទេដែលច្បាស់ គឺថាពួកយើងនឹងត្រូវនៅទីនេះ រហូតដល់ពេលដែលពួកវាអនុញ្ញាតអោយយើងចេញតែប៉ុណ្ណោះ ។ ហើយបើពួកវាព្រមអោយយើងចេញ តើនឹងអាចមានរឿងអ្វីបន្តទៀត ? រួចអា *គីចែស្ទីន* វាទៅជាយ៉ាងណាហើយ ?



www.budinst.gov.kh www.elibraryofcambodia.org

កំដៅកាន់តែក្ដៅ រុយក្នុងអន្លង់ ក៏កាន់តែច្រើនដែរ ។

ឱព្រះអើយព្រះ ! អញបន់អោយតែបានទំរេត អោយបានទៅមុជទឹកដូចកាលនោះទៀត ។ ម្ដងនេះពួកវាមិនបាច់សែងអញទេ ។ មកដល់អីលូវនេះ បានអញដឹងថា មុជទឹកនោះវាមានសារសំខាន់យ៉ាងណា ។ រួចតាខ្វាក់ម្រាមដៃដែកនោះ ក៏អីចឹងដែរ ។ អញពឹងគាត់ធ្វើសរសៃពីរម៉ោង គឺស្រួលតែម្ដង ។

អីលូវនេះគឺខាតបង់រលត់រលាយហើយ ។ អស់ទាំងសំពៅ អស់ទាំងមនុស្ស អស់ទាំងកំលាំង ហើយបានមកដល់ត្រឹមណឹង ! បរាជ័យទាំងស្រុងហើយនេះ ! មិនមែនទាំងស្រុងទេ តែស្ទើរ តែទាំងស្រុងប៉ុណ្ណោះ ព្រោះគ្នាយើងខ្លះនៅរស់នៅឡើយដែរ ។

- បងតៃកុង ! បងតៃកុង ! -*វ៉ាន់ណេច* អង្រួន *ប្លាក់ថន* -បងឯងលក់មួយរឹងហើយ ។ គឺរឿងវា ។ វាអោនគោរពបងឯងជាងម៉ានាទីហើយណា ។

និយាយបណ្ដើរ *វ៉ាន់ណេច* ចង្អុលទៅបុរសជប៉ុនដែលនៅលុតជង្គង់ និងអោនក្បាលគោរពនៅពីមុខគេនោះ ។

*ប្លាក់ថន* ញីភ្នែកបណ្ដេញការងឿយហត់ចេញ ហើយក្រោយពីការប្រមូលស្មារតីបន្តិចមកគេក៏អោនក្បាលគោរពសងទៅវិញ ។

- *ហៃ* -គេសួរយ៉ាងកំបុត ដោយប្រើពាក្យជប៉ុន ដែលគេចាំថា មានន័យថា " បាទ " នោះ ។

សាមូរ៉ៃដោះយកក្រណាត់ខ្សែក្រវាត់ គឺម៉ូណូ រហែករបស់ខ្លួន យកមកគុំទៅជុំវិញក ។ បន្ទាប់មកគេហុចចុងក្រណាត់ម្ខាងទៅ *ប្លាក់ថន* និងម្ខាងទៀតទៅ *សុង* ហើយអោនក្បាលគោរពម្ដងទៀត និងធ្វើសញ្ញាអោយទាញវាអោយតឹង ។ ក្នុងរយៈពេលនេះ គេនៅតែលុតជង្គង់ដដែល ។

- អានេះវាខ្លាចយើងរឹតកវាហើយមើលទៅ -*សុង* និយាយ ។

- ព្រះអើយ ! នេះគឺវាចង់អោយយើងធ្វើអីចឹងហើយ ។

*ប្លាក់ថន* ទំលាក់ជាយក្រណាត់ ហើយគ្រវីក្បាល ។

- *គីន ជីរ* ! - គេឆ្លើយជាភាសាជប៉ុន ថែមទាំងគិតថា ពាក្យនេះមាន ប្រយោជន៍



www.budinst.gov.kh www.elibraryofcambodia.org

មែន ។

តើអ្នែងអាចនិយាយយ៉ាងម៉េចទៅកាន់មនុស្សម្នាក់ដែលមិនចេះភាសាអ្នែងថាសំលាប់ខ្លួន សំលាប់មនុស្សគ្មានអាវុធ គឺផ្ទុយនឹងក្រឹត្យវិន័យរបស់អ្នែង ហើយអ្នែងក៏មិនមែនជាពេជ្ឈឃាត ហើយការសំលាប់ខ្លួនគឺព្រះប្រោសមិនរួចទេនោះ ?

*សាមូរ៉ៃ* អង្វរម្តងទៀត ប៉ុន្តែ *ប្លាក់ថន* គ្រវីក្បាលម្តងទៀត :

- *គីន ជីរ៉ូ*

បុរសនេះ សំលឹងមើលជុំវិញខ្លួនទាំងអស់សង្ឃឹម ។ រួចគេស្ទុះក្រោកឡើង ហើយដើរតំរង់ទៅចុងបន្ទោរបង់ ហើយក៏តាំងជ្រមុជក្បាលដើម្បីសំលាប់ខ្លួន ។ *យ៉ាន់ទូរ៉ែព* និង *សុង* ស្ទុះទៅទាញបុរសនេះចេញវិញយ៉ាងរហ័ស ។ បុរសនេះ រើបណ្តើរ ឈ្លក់ដង្ហក់បណ្តើរ ។

- ទុកអោយវាទៅចុះ !-*ប្លាក់ថន* បញ្ជា ។ ទាំងអស់គ្នាធ្វើតាម ។*ប្លាក់ថន* ចង្អុលទៅចុងបន្ទោរបង់ -*សាមូរ៉ៃ*បើអ្នែងចង់ស្លាប់របៀបណឹងអ្នែងធើចុះ ។

*សាមូរ៉ៃ* រកចង្អោរ ប៉ុន្តែគេទប់បាន ។ គេសំលឹងទៅក្នុងចុងគគ្រិចនោះ ហើយគេដឹងថាគេមិនអាចមានកំលាំងគ្រប់គ្រាន់ នឹងជ្រមុជក្បាលរហូតដល់ដាច់ដង្ហើមបានទេ ។ គេដើរទៅកាន់កន្លែងគេទៅជញ្ជាំងវិញ ទាំងទឹកមុខដ៏កំសត់ក្រៃលែង ។

*ប្លាក់ថន* ជូសទឹកប្រហែលកន្លះពែង រួចក្រោកឈរឡើងទាំងអវៈយវៈធ្ងន់ពាប់ ហើយដើរតំរង់ទៅរកបុរសនោះ ។ គេហុចពែងទៅ *សាមូរ៉ៃ* ប៉ុន្តែបុរសនេះធ្វើជាមិនឃើញពែងនោះឡើយ ។

- អញឆ្ងល់ដែរ វាទ្រាំបានប៉ុន្មានទៀត ?- *ប្លាក់ថន* ឧទានឡើង ។

- តែរហូតណឹង -*យ៉ាន់ទូរ៉ែព* និយាយ -ពួកវាសត្វទេតើ ។ ពួកវាមិនមែនមនុស្សទេ ។ *គីញ៉សែល* លួកមាត់ :

- រួចចុះវាទុកពួកយើងនៅកន្លែងណឹងប៉ុន្មានពេលទៅ ?

- ប៉ុន្មានពេល ស្រេចតែវានឹកឃើញ ។

- ពួកយើងទាល់តែស្តាប់តាមវា -*វ៉ាន់ណេិច* និយាយ -ទាល់តែស្តាប់តាមវា បើយើង



www.budinst.gov.kh www.elibraryofcambodia.org

ចង់រស់ ហើយនឹងចេញពីអន្លង់នរកនេះ ។ មិនអ៊ីចឹងអ្អេសបងតៃកុង ?

- មែន -*ប្លាក់ថុន* ឆ្លើយបណ្តើរ សង្កេតមើលថ្ងៃបណ្តើរ -ថ្ងៃត្រង់ហើយ។ដល់ពេលដូរវេន អង្គុយម្តងហើយ ។

*ស្ទីលប៊ែគីន មែស៊្វីតៃ* និង*សុង* ចាប់ផ្តើមតូញត្អែរ ប៉ុន្តែ *ប្លាក់ថុន* សន្ទាប់អោយរហូតដល់ពួកគេត្រូវងើបឈរ ។ នៅពេលដែលអ្វីៗត្រូវបានរៀបចំស្រួលបួលហើយ *ប្លាក់ថុន* ក៏ប្រាសខ្លួនដេក យ៉ាងសែនសុខ ។ ក្លិនអាសោច៍ វិរុយ គឺលែងនិយាយ ប៉ុន្តែការសប្បាយរីករាយចំពោះប្រការ ដែលបានទំរេតមួយបណ្តោយខ្លួននេះ វាធំលើសលប់ ។

តើពួកគេធ្វើអី *ភីចែស៊ីន* អ៊ីចេះ ? គេសួរខ្លួនគេ នៅពេលដែលគេមានអារម្មណ៍ថាភាពនឿយហត់បានលេបត្របាក់គេហើយនោះ ។ ឱព្រះអើយព្រះ ! ជួយពួកយើងខ្ញុំ អោយបានចេញផុតពីនេះផង ។ ខ្ញុំខ្លាចណាស់ ។

នៅឯលើ មានសូរជើងលាន់លឺឡើង រួចឃ្លុបក្តារក៏របើកយ៉ាំង ។ បព្វជិតនោះ ឈរនៅក្បែរឃ្លុប និងដោយមានពួក សាមូរ៉ៃ នៅឈរអមខ្លួនផង ។ បព្វជិតនោះ និយាយឡើង :

- តៃកុង ។ ឯងត្រូវឡើងមកលើ ។ ហើយឡើងមកតែម្នាក់ឯងគត់ !

☆

☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៦

ក្រសែភ្នែកទាំងអស់ នៅក្នុងអន្លង់ បានបាញ់ផ្ចោតទៅរក *ប្លាក់ថន* តែម្នាក់គត់ ។

- តើពួកវាចង់ធ្វើអីខ្ញុំ ?

- យើងមិនដឹងទេ -បព្វជិត *សេបាស្ទ* តបយ៉ាងធ្ងន់ពាប់ -ប៉ុន្តែអែងត្រូវឡើងមកលើតែម្នាក់ឯងភ្លាម ។

*ប្លាក់ថន* ដឹងខ្លួនថា គេគ្មានជំរើសអ្វីទេ ប៉ុន្តែគេមិនចង់ចេញពីជញ្ជាំងការពារ ដ៏ល្អរបស់គេនោះទេ ។ គេខំប្រមូលកំលាំងគេឡើងវិញ ។

- រួចពួកវាណឹង វាធ្វើអី *ពីថែស្ទ័ន* ?

បព្វជិតនិយាយដំណើររឿងប្រាប់ *ប្លាក់ថន* ។ បកបន្តសំរាប់អ្នកមិនចេះភាសាប៊កទុយកាល់ ។ ក្នុងកណ្តាលភាពស្ងប់ស្ងាត់ ដ៏គួរអោយព្រឺព្រួចនេះ *វ៉ាន់ណេច* ឧទានឡើង :

- សូមព្រះជាម្ចាស់ប្រោសប្រណីវាផង ។ ហ៊ឺ ! អាកំសត់អើយ !

- ខ្ញុំស្តាយណាស់ ប៉ុន្តែខ្ញុំក៏មិនអាចធ្វើអ្វីបានដែរ -បព្វជិតនិយាយទាំងក្រៀមក្រំ-ខ្ញុំគិតថា វាលែងស្គាល់ខ្ញុំ ក៏ដូចជាលែងស្គាល់អ្នកណាទៀតទាំងអស់ដែរ នៅពេលដែលពួកនោះដាក់វាចូលក្នុងទឹក ។ សតិវិញ្ញាណវាចេញបាត់រួចទៅហើយ ។ ខ្ញុំបានអោយធមិវា ហើយបានបង្សុកូលអោយវាហើយ ។ សូមព្រះជួយប្រោសវាផងទៅចុះ ។ -បព្វជិត *សេបាស្ទ* ធ្វើសញ្ញាខ្វែងពីលើឃុប -ខ្ញុំសូមអង្វរករពួកឯង សូមលះបង់ផ្លូវខុស ហើយវិលមករកផ្លូវត្រូវវិញទៅ ។ អីលូវនេះតៃកុងឯងឡើងមក !

*ត្រូក* ស្រែកវ៉ាសឡើង :

- កុំទៅចោលពួកយើង បងតៃកុង !

*វិញ* ដើរទាំងទ្រេតទ្រោតទៅជណ្តើរ ហើយចាប់ផ្តើមឡើងទៅលើ :

- ពួកវាយកខ្ញុំចុះ តែមិនត្រូវយកបងតៃកុងទេ ។ គឺខ្ញុំមិនមែនគាត់ទេ ។ ប្រាប់ពួកណឹងទៅថា ..........

សំដី *ត្រូក* ឈប់អាក់ក្នុងបំពង់ក ជើងគេនៅឆ្កឹងលើកាំជណ្តើរ ។ លំពែងវែងមួយនៅ



www.budinst.gov.kh www.elibraryofcambodia.org

សល់តែប៉ុន្មានតឹកពីបេះដូងរបស់គេតែប៉ុណ្ណោះ ។ *វិញ* សាកល្បងច្បាមចាប់ជងល់ពែងនោះដែរ ប៉ុន្តែ *សាមូរ៉ៃ* ដែលកាន់លំពែងនេះ ត្រៀមខ្លួនហើយ១បើសិនជា *វិញ* មិនលោតចុះក្រោមទាន់ទេ លំពែងច្បាស់ជាដោតដើមទ្រូងគេបាត់ទៅហើយ ។

*សាមូរ៉ៃ* ដែលកាន់លំពែងនេះ តំរង់ចុងមករក *ប្លាក់ថន* ហើយសំលុតគេអោយឡើង ជណ្ដើរ ។ ប៉ុន្តែ *ប្លាក់ថន* នៅតែមិនទាន់កំរើកនៅឡើយ ។ ឃើញយ៉ាងនេះ *សាមូរ៉ៃ*ម្នាក់ រុញស្ដ មានសុទ្ធតែឃ្មៀងចុះមកសំដៅថ្គក់ *ប្លាក់ថន* ឡើងពីអន្លង់ ។

ក្នុងពេលនោះ គ្មានអ្នកណាធ្វើចលនាអ្វីដើម្បីជួយ *ប្លាក់ថន* ឡើយ លើកលែងតែ *សាមូរ៉ៃ* នៅក្នុងអន្លង់នោះ ។ បុរសនេះច្បាមចាប់ស្មយ៉ាងរហ័ស ហើយនិយាយកំបុត១ទៅ បុរសដែលនៅខាងលើ ។ បុរសនៅខាងលើអេះអុញបន្តិច រួចសំលឹងមើល *ប្លាក់ថន* ហើយនិយាយ មកកាន់រូបគេ ។

- វានិយាយថាម៉េច ?- *ប្លាក់ថន* សួរ ។

បព្វជិតតប

- នេះជាសុភាសិតជប៉ុន ដែលមានន័យថា " វាសនាមនុស្ស គឺជាវាសនាមនុស្ស ឯ ជីវិតគ្រាន់តែជារូបភាពបន្ទំតែប៉ុណ្ណោះ " ។

*ប្លាក់ថន* ងក់ក្បាលដាក់ *សាមូរ៉ៃ* ហើយដើរតំរង់ទៅជណ្ដើរដោយគ្មានងាកក្រោយបន្តិច ឡើយ ។ គេចាប់ផ្ដើមឈានឡើងកាំជណ្ដើរម្ដងមួយ១ ។ នៅពេលដែលគេចេញមកប៉ះទាំង តំហុក នឹងពន្លឺថ្ងៃ ភ្នែកគេឡើងស្រវាំងព្រិល ជង្គង់ញ័រទទ្រើក ហើយគេក៏ដួលស្ប៉ាបទៅលើដី ខ្សាច់នោះទៅ ។

*អូមី* ឈរនៅម្ខាងគេ ។ បព្វជិត និង *មូភ៊ា* ឈរនៅក្បែរ *សាមូរ៉ៃ* ទាំងបួន ។ នៅឯទី ឆ្ងាយ អ្នកភូមិប៉ុន្មាននាក់ នាំគ្នាសំលឹងមើលទិដ្ឋភាពទាំងនេះបានបន្តិច ហើយក៏ចាកចេញបាត់ ទៅ ។

គ្មានអ្នកណាជួយ *ប្លាក់ថន* ឡើយ ។

ឱព្រះអើយព្រះ សូមជួយផ្ដល់កំលាំងពលំដល់ខ្ញុំម្ចាស់ផង -*ប្លាក់ថន* ភាវនានៅក្នុង



www.budinst.gov.kh www.elibraryofcambodia.org

ពោះ ។ អញត្រូវតែក្រោកឈរ ហើយត្រូវធ្វើដូចជាខ្លាំងក្លា ។ ពួកវាគោរពតែប៉ុណ្ណឹងទេ ។ ត្រូវតែខ្លាំង ។ ត្រូវតែមិនចេះខ្លាច ។ ព្រះអង្គអើយជួយខ្ញុំផង ។

គេខាំធ្មេញប្រឹងច្រត់ទៅលើដី ហើយងើបឈរឡើង ។ គេនៅចេងចោងបន្តិច ។

- រួចអ្អែងត្រូវការអញយកមករបស់យក៏អី ? -*ភ្លាក់ថុន* និយាយសំដៅទៅរក*អូមី* ផ្ទាល់ រួចទើបគេបែរមកនិយាយជាមួយបព្វជិតម្តង -ប្រាប់អាកូនមីអត់ពូជនេះថា ខ្ញុំគឺដៃមីញ៉ូ នៅក្នុងស្រុកខ្ញុំ ហើយធ្វើបែបនេះសមរម្យវីទេ ? ប្រាប់វាថាយើងគ្មានជំលោះអីជាមួយវាទេ ។ ប្រាប់ វាអោយលែងពួកយើង បើមិនអីចឹងទេច្បាស់ជាចង្រៃធំមិនខានទេ ។ ប្រាប់វាណា ! ថាខ្ញុំគឺជា *ដៃមីញ៉ូ* ! របល់យក៏នេះ ! ប្រាប់វាទៅ !

យប់មិញនេះ គឺជាពេលវេលា ដ៏សែនយ៉ាប់យ៉ឺនវេទនាបំផុតសំរាប់*សេបាស្ស* ។ប៉ុន្តែនៅក្នុងពេលស្ងឹងស្ងាធ៌ គេមានអារម្មណ៍ពីវត្តមានរបស់ព្រះជាម្ចាស់ ហើយគេក៏មានអារម្មណ៍ស្រលះស្ងប់ស្ងាត់មួយ ដែលគេមិនធ្លាប់ជួបប្រទះសោះក្នុងជីវិតរបស់គេ ។ អីលូវនេះគេដឹងថា គេអាចជាឧបករណ៍របស់ព្រះ តទល់នឹងពួកទមិឡទាំងនេះ ព្រោះខ្លួនតើងមាំ អាចការពារនឹងបាបកម្មនេះ អាចតទល់នឹងល្បិចកលរបស់អាចោរសមុទ្រនេះ ។ ទោះជាយ៉ាងនេះក្តី ក៏បព្វជិត *សេបាស្ស* ដឹងខ្លួនថា យប់មិញនេះគឺជាការរៀបចំមួយ ជាផ្លូវបត់មួយសំរាប់របលោក ។

- បកប្រាប់វាទៅ !

បព្វជិតនិយាយជាភាសាជប៉ុន :

- ចោរសមុទ្រនេះ និយាយថា គេគឺជាលោកម្ចាស់នៅក្នុងស្រុករបស់គេ ។

ពេល*អូមី* តបចប់ សេបាស្ស ងាកមុខបកអោយ *ភ្លាក់ថុន* :

- *អូមី -សាន* និយាយថា គាត់មិនខ្វល់ទេ ទោះជាអ្នកឯងជាស្តេចនៅក្នុងប្រទេសរបស់អ្នកឯងក្តី ។ នៅកន្លែងនេះ អ្នកឯងរស់ទៅតាមឆន្ទៈរបស់លោកម្ចាស់ *យ៉ាប៊ូ* ។ ទាំងអ្នកឯង ទាំងក្រុមរបស់អ្នកឯងទាំងអស់ ។

- ប្រាប់វាទៅ ថាវាដូចជាតំរង់អីចឹង ។

- នែ៎ ! ប្រយ័ត្នកុំជេរគាត់ណា !



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* ចាប់ផ្តើមនិយាយបន្តទៀត ។

- *អូមី-សាន* និយាយថា គេនឹងនាំឯងទៅមុជទឹក ទៅហូប និងផឹកទឹក ។ បើឯងស្រួលបួលគេមិនដាក់ឯងចូលក្នុងអន្លង់វិញទេ ។

- រួចចុះពួកខ្ញុំ ?

បព្វជិតបន្តសំនួរទៅ *អូមី* ។

- ពួកនោះនៅក្រោមដីណឹងហើយ ។

- អីចឹង ប្រាប់វាអោយទៅប្រកាច់ងាប់ឯណាងាប់ទៅ !

*ប្លាក់ថន* ត្រលប់ខ្លួនដើរសំដៅទៅរកជណ្តើរ ដើម្បីចុះទៅក្រោមវិញ ។ សាមូរ៉ៃ ពីរនាក់ស្ទុះចេញមកឃាត់គេ ហើយថ្វីត្បិតតែ *ប្លាក់ថន* ខំតដៃយ៉ាងណាក៏ពួកនេះ បង្ក្រាបគេបានយ៉ាងងាយដែរ ។

*អូមី* និយាយទៅកាន់បព្វជិត រួចទៅកាន់មនុស្សរបស់គេ។ ពួកនេះលែង *ប្លាក់ថន* ភ្លាមដែលធ្វើអោយគេរិះដួលទៅលើដី ។

- *អូមី -សាន* និយាយថា បើឯងមិនស្រួលបួលទេ គេនឹងយកកូនក្រុមអ្នកឯងម្នាក់ឡើងមកលើ ។ នៅទីនេះទឹក អុសមិនខ្វះទេ ។

បើអញយល់ព្រមអីលូវនេះ ពួកវានឹងដឹងពីមធ្យោបាយត្រួតត្រាអញ ហើយអញនឹងនៅក្រោមអំនាចវាម៉ាអាយុ៉ស ។ តែអានេះអត់ការទេ ព្រោះអីលូវនេះអញនៅក្រោមអំនាចពួកវាទៅហើយនោះ ហើយនៅទីបញ្ចប់អញគង់តែធ្វើតាមបញ្ជាពួកវាតែទាំងអស់ណឹង ។ *អាវ៉ាន់ណិច* និយាយត្រូវដែរ គឺអញមិនត្រូវធ្វើអីផ្តេសផ្តាសទេ ។

- តើវាចង់អោយខ្ញុំធ្វើអី ? រួចចុះពាក្យ " ស្រួលបួល" នេះមានន័យថាម៉េច ?

- *អូមី -សាន* និយាយថា គឺថាត្រូវគោរពតាមបញ្ជា។ ត្រូវធ្វើតាមសំដីដែលគេប្រាប់។ បើគេអោយស៊ីអាចម៍ ក៏ត្រូវតែស៊ីដែរ ។

- ប្រាប់វាថាអោយទៅប្រកាច់ង្ងាប់ឯណាបាត់ទៅ ។ប្រាប់វាថាទុកអោយខ្ញុំបាញ់នោមច្រាសវា ហើយនឹង ច្រាសនោមស្រុកវា ហើយនឹង *ដៃមីញ៉ូ* វានេះ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំទូន្មានឯង អោយធ្វើអ្វីតាមដែល..............

- បកប្រាប់វា ពីសំដីខ្ញុំទៅបានហើយ ! យីព្រះអើយ !

- ល្អ ! តែខ្ញុំប្រាប់ឯងហើយណាតែកុង !

*អូមី* ស្តាប់បំនកប្រែរបស់ បព្វជិត ។ កណ្តាប់ដៃ ដែលក្តាប់ដងដាវ ឡើងប្រែជាពណ៌ស្លាំង ។ មនុស្សរបស់ *អូមី* ទាំងប៉ុន្មានបង្ហាញកាយវិការរសាប់រសល់ ហើយក្រសែភ្នែករបស់ពួកគេ ប្រៀបដូចជាដាវដែលកំពុងអង្គន់សាច់ *ប្លាក់ថន* អីចឹង ។

បន្ទាប់មក *អូមី* ចេញបញ្ជាមួយយ៉ាងនឹងនរ ។

រំពេចនោះ សាមូរ៉ៃពីរនាក់ ក៏ស្ទុះចុះទៅក្នុងអន្លង់ ហើយទាញ *គ្រូក* ចេញមកក្រៅ ។ ពួកគេអូសក្មេងនេះសំដៅទៅថ្លាង ។ នៅពេលដែលអ្នកខ្លះចងគ្រៀក *គ្រូក* អ្នកឯទៀតក៏ជញ្ជូនអុសនឹងទឹកមករៀបចំ ។ រួចរាល់ហើយពួកគេលើកក្មេងដែលភ័យរហូតស្លុត និយាយលែងចេញនេះ ដាក់ទៅក្នុងថ្លាង ហើយចាប់ផ្តើមបង្កាត់ភ្លើងឡើង ។

*ប្លាក់ថន* សំលឹងមើលក្មេងដែលប្រឹងហាមាត់ស្រែក ដោយឥតចេញសូរបន្តិចសោះ ។ នៅលើផ្ទៃមុខរបស់គេ គឺការភ័យស្លុតឥតគណនា ។ ចំពោះពួកនេះ ជីវិតគ្មានតំលៃបន្តិចណាសោះតែម្តង -គេគិតនៅក្នុងចិត្ត ។ ឱព្រះអើយព្រះ បញ្ជូនពួកនេះ អោយទៅនរកទាំងអស់ទៅ ។ រួចនេះគឺច្បាស់ជាវាស្ងោរអា *គ្រូក* ទាល់តែស្លាប់មិនខានទេ ។

ផ្សែងចាប់ផ្តើមហុយថ្លោលពីលើភ្នែរខ្សាច់ ។ រំងសត្វរំពេហើរស្រែកចេចចាច ជុំវិញទូកនេសាទ ។ អង្កត់អុសមួយដែលឆេះធ្លាក់ចេញពីគុកភ្លើង ត្រូវសាមូរ៉ៃរើសបញ្ចូលវិញ ។

- ប្រាប់វាអោយឈប់ទៅ -*ប្លាក់ថន* និយាយ -ប្រាប់វាអោយឈប់ទៅ !

- *អូមី-សាន* និយាយថា អ្នកឯងយល់ព្រមស្រួលបួលហើយ ?

- យល់ព្រម !

- គាត់ថាឯង យល់ព្រមគោរពតាមបញ្ជាទាំងអស់អ្វី ?

- អីដែលខ្ញុំធ្វើបាន ខ្ញុំយល់ព្រម !

*អូមី* និយាយបន្ត ។ បព្វជិត *សេបាស្ស* សួរសំនួរមួយ *អូមី* ងក់ក្បាល ។



www.budinst.gov.kh www.elibraryofcambodia.org

- គាត់ចង់អោយឯងឆ្លើយផ្ទាល់នឹងគាត់ ។ ពាក្យ " បាទ " ជាភាសាជប៉ុន ថា " ហៃ " ។ អីលូវនេះ គាត់សួរថា ព្រមគោរពតាមបញ្ជាទាំងអស់ហើយអ្ហឺ ?

- អីដែលខ្ញុំធ្វើបាន ហៃ !

អណ្តាតភ្លើងចាប់ផ្តើមកំដៅទឹកហើយ ។ សរវៃកគួរអោយស្រៀវឆ្អឹងខ្នងបានធ្លាយចេញពីមាត់របស់ *ភ្លុក*។ អណ្តាតភ្លើង លិទ្ធតូចថ្លាងភ្លែម១។ អុសត្រូវបានគេញាត់បន្ថែមទៅក្នុងគុក។

- *អូមី -សាន* និយាយថា ក្រាបចុះភ្លាម !

*ប្លាក់ថន* ធ្វើតាមបញ្ជា ។

- *អូមី-សាន* និយាយថា គាត់ឥតបានប្រមាថរូបឯងសោះ ហើយក៏គ្មាន ហេតុអីដែលឯងត្រូវប្រមាថគាត់ដែរ ។ ប៉ុន្តែ ដោយឯងជាពួកចុងស្រុក ហើយគ្មានដឹងអីសោះនោះ ទើបគេមិនសំលាប់ឯង ។ តែឯងត្រូវរៀនអោយមានច្បាប់ទំលាប់ ។ យល់ទេ ?

- បាទ !

គាត់ចង់អោយឯង ឆ្លើយផ្ទាល់នឹងគាត់ ។

*ភ្លុក* ស្រែកថ្ងូរឡើងគ្រលួច រួចវាក៏សន្លប់ទៅ ។ សាមូរ៉ៃម្នាក់លើកទាញក្បាល *ភ្លុក* អោយចេញផុតពីទឹក ។

*ប្លាក់ថន* សំលឹងមើល *អូមី* ។ អ្អែងត្រូវចាំណាំ -គេនិយាយទៅកាន់ខ្លួនគេ -អ្អែងត្រូវចាំថា ជីវិតក្មេងនោះនៅក្នុងដៃអ្អែងតែម្នាក់គត់ ។ ហើយជីវិតក្រុមនាវិកទាំងអស់ ក៏នៅក្នុងដៃអ្អែងដែរ ។

- អ្អែងយល់ហើយវឺនៅ ?

- ហៃ !

*ប្លាក់ថន* ឃើញ *អូមី* លើកអាវគីម៉ូណូរបស់គេ ហើយប្រុងប្រៀបបន្ទោរបង់ទឹកម៉ូតលើរូបគេ ។ គេគិតថា ច្បាស់ជា *អូមី* បាញ់នោមច្រាសមុខគេជាមិនខាន ។ តែ *អូមី* នោមដាក់លើខ្នងគេសោះ ។ សូមព្រះអង្គជួយចងចាំ -*ប្លាក់ថន* ស្បថទៅក្នុងចិត្ត -អញនឹងចងចាំថ្ងៃនេះជានិច្ច ហើយទោះបីជាដោយរបៀបណាក៏ដោយ នៅទីកន្លែងណាក៏ដោយ អា*អូមី* ត្រូវសងតំនុំនេះ។



www.budinst.gov.kh www.elibraryofcambodia.org

*សេបាស្ទ* និយាយ :

-*អូមី-សាន* និយាយថា គឺជាបែបបទអាក្រក់ណាស់ដែលនិយាយថា ចង់បាញ់នោមដាក់គេនោះ ។ អាក្រក់មែនទែន ។ ជាបែបបទអាក្រក់ផង ល្ងីល្ងើផង ដែលនិយាយថា អែងនឹងបាញ់នោមដាក់គេដោយដៃគ្មានអាវុធនោះ ។ វារឹតតែជាបែបបទអាក្រក់ និងល្ងីល្ងើណាស់ទៅទៀតដែលនិយាយថា អែងនឹងបាញ់នោមដាក់គេ ពេលដែលដៃអែងគ្មានអាវុធ គ្មានអំនាចហើយ ពេលដែលអែងមិនបានត្រៀមខ្លួន សុខចិត្តអោយមិត្តភក្តិអែង គ្រួសារអែង រឺអ្នកណាមួយ ទៀត នោះ ស្លាប់មុនអែង ។

*ប្លាក់ថន* ឥតនិយាយអ្វីទាំងអស់ ។ ភ្នែកគេសំលឹងមើល *អូមី* ឥតដាក់ ។

*អូមី* និយាយបន្ត :

- *វ៉ាកាវី ម៉ាស៊ូកា* ?

- គាត់ថាអែងយល់ទេ ?

- ហៃ !

- *អូគីរ៉ូ*

- គាត់ថា អែងក្រោកឡើង !

*ប្លាក់ថន* ក្រោកឡើង ។ ក្បាលរបស់គេឈឺខ្ទោក១ តែគេនៅតែបន្តសំលឹងចំមុខ *អូមី*។ *អូមី* សំលឹងតបនឹង *ប្លាក់ថន*វិញ ។

- អែងត្រូវទៅតាម *មូរ៉ា* ហើយធ្វើតាមបញ្ជារបស់គាត់ ។

*ប្លាក់ថន* នៅស្ងៀមឥតឆ្លើយតប ។

- *វ៉ាកាវី ម៉ាស៊ូកា* ?

*អូមី* សួរយ៉ាងកំបុត១ ។

- ហៃ

*ប្លាក់ថន* លួចប្រមាណចំងាយ រវាងគេ នឹង *អូមី* ។ ដៃគេហាក់មានអារម្មណ៍កំពុងច្របាច់ក និងច្បាមមុខ *អូមី* បាត់ទៅហើយ ។ គេបន់ស្រន់ថ្កូន១ សូមអោយគេរហ័ស និងមាន



www.budinst.gov.kh www.elibraryofcambodia.org

កំលាំងគ្រប់គ្រាន់ដើម្បីខ្ទេះភ្នែកទាំងពីររបស់ *អូមី* មុនពេលដែលពួកអ្នកដទៃទៀតកាប់ផ្តាច់គេចេញនោះ ។

- រួចចុះក្មេងនេះគិតយ៉ាងម៉េច ? -គេសួរ ។

បព្វជិត និយាយយ៉ាងញាប់រន្ថើនទៅ *អូមី* ។

*អូមី* សំលឹងមើលទៅថ្លាង ។ ទឹកមិនទាន់ក្តៅឧណ្ហៗផងទេ ។ ក្មេងនោះសន្លប់មែន តែមិនមានរលាកអីដែរ ។ គេចេញបញ្ជា :

- យកវាចេញមកចុះ ហើយបើម៉េចៗហៅពេទ្យមកមើលវាផង ។

កូនចៅរបស់គេ អនុវត្តតាមបញ្ជាភ្លាម ។ *អូមី* ឃើញ *ពួក់ថន* ដើរទៅរក *ក្លេក* ហើយផ្ទៀងត្រចៀកស្តាប់បេះដូងរបស់វា ។

*អូមី* និយាយទៅកាន់បព្វជិត :

- ប្រាប់អាមេណឹងថា អាក្មេងនេះអាចនៅក្រៅអន្លង់បាន ។ បើសិនជាអាមេវាស្រួលបួល និងអាក្មេងប្រុសនេះវាស្រួលបួល ស្អែកនេះ អាចុងស្រុកម្នាក់ទៀត អាចចេញពីអន្លង់បាន ។ រួចស្អែកម្នាក់ទៀត ។ រឺមួយអាចច្រើនជាងម្នាក់ផង ។ នេះប្រហែលទេ ។ អារឿងនេះស្រេចតែបែបបទ របស់អាអ្នកឡើងមកមុនទេ ។ តែអ្អែង -*អូមី* សំលឹងចំមុខ *ពួក់ថន* -អ្អែង ជាអ្នកទទួលខុសត្រូវ លើរាល់ការបំពានវិន័យរឺបញ្ញត្តិទាំងអស់ ទោះជាតូចក្តី ធំក្តី។ អ្អែងយល់ទេ ?

ក្រោយពីបព្វជិត បកសំដីមក *អូមី* លឺមនុស្សចុងស្រុកនេះឆ្លើយថា " បាទ " ហើយគេឃើញថាកំហឹងស្ទើរស្រក់ឈាម បានរលាយបាត់ចេញពីក្រសែភ្នែករបស់គេ ។ ប៉ុន្តែគំនុំនៅមាននៅឡើយ ។ ចំជាឆ្កួតមែន -*អូមី* គិតនៅក្នុងចិត្ត -ហើយថែមទាំងល្ងង់ថែមទៀត ដែលធ្វើអោយគេមើលធ្លុះចិត្តខ្លួនឯងយ៉ាងនេះ ។ ឆ្ងល់ដែរ តើវាមានប្រតិកម្មយ៉ាងម៉េចណេះ បើអញលេងសើចជាមួយវាខ្លាំងជាងនេះបន្តិចទៀត ឧទាហរណ៍ដូចជា អញថា អញប្រែក្រលាស់ពាក្យសន្យារបស់អញវិញជាដើមនោះ ?

- បព្វជិត *សេបាស្ទ្យ* និយាយអីចឹងប្រាប់ឈ្មោះវាម្តងទៀតមើល ! និយាយយឺតៗ ។

*អូមី លឺ សេបាស្ទ្យ* និយាយឈ្មោះ *ពួក់ថន* ពីរបីដងតែគេនៅតែមិនអាចចាំបាន ។ គេ



www.budinst.gov.kh www.elibraryofcambodia.org

ក៏ ងាកទៅរកកូនចៅគេម្នាក់ :

- មើលក្អែងសាកហៅឈ្មោះវាលមើល !

.- ទៅមិនរួចទេ *អូមី-សាន*

- បព្វជិតប្រាប់គេថា ចាប់ពីថ្ងៃនេះទៅ គេមានឈ្មោះថា *អានជីន* ប្រែថាតៃកុងណា ! បើថ្ងៃក្រោយគេមានស្លាដៃ នោះគេនឹងហៅថា *អាន់ជីន-សាន* ។ ពន្យល់ប្រាប់គេផងថា ភាសាយើងគ្មានសំនៀងហៅឈ្មោះគេអោយចំទេ -*អូមី* បន្លឹងសំលេង -បញ្ជាក់ប្រាប់អោយច្បាស់ថា នេះមិនមែនមានន័យថា គេប្រមាថមើលងាយទេ ។ សូមលា *អាន់ជីន* ! លាម៉ារយៈសិន ។

ទាំងអស់គ្នាអោនខ្លួនគោរព *អូមី* ។ គេអោនខ្លួនគោរពតបវិញយ៉ាងគួរសម ហើយក៏ដើរចេញទៅ ។ នៅពេលដែលគេដើរចេញបានឆ្ងាយបន្តិច ហើយច្បាស់នៅក្នុងចិត្តថា គ្មានអ្នកណាមើលគេឃើញ ហើយគេក៏ញញឹមស្ញាញតែម្ដង ។ គេមិននឹកស្មានសោះថា កាច់បានអាមេពុកចុងស្រុកយ៉ាងនេះសោះ គេក៏សែនពេញចិត្តនឹងខ្លួនគេ ដែលចេះរកវិធីត្រួតត្រាអាមេ នេះបាន ហើយក៏ដូចជាពួក អាកូនចៅនោះផងដែរ ។

គិតទៅពួកអាចុងស្រុកនេះ អស្ចារ្យមែនតែម្ដង ។ ប៉ុន្តែបើ *អានជីន* ចេះនិយាយភាសាយើង កាន់តែឆាប់កាលណា កាន់តែល្អកាលនោះ ។ នៅពេលនោះយើងនឹងដឹងថា តើត្រូវធ្វើយ៉ាងម៉េច ដើម្បីកំទេចចោល ពួកចុងស្រុកជាគ្រិស្តសាសនិកទាំងអស់តែម្ដង និងជាវៀងរហូត ។

☆ ☆ ☆

- ហេតុអីបានជាអែង មិនបាញ់នោមដាក់មុខវា ? -*យ៉ាប៊ូ* សួរ ។

- ដំបូងខ្ញុំបាទ គិតបាញ់នោមដាក់មុខវាដែរលោកម្ចាស់ ។ ប៉ុន្តែអាតៃកុងនេះជាសត្វមិនទាន់ផ្សាំងបាន ហេតុនេះគ្រោះថ្នាក់ណាស់ ។ ចំពោះជាតិសាសន៍យើង ប៉ះពាល់មុខរបស់មនុស្ស គឺជាការប្រមាថមាក់ងាយបំផុត *ទេ* ? ដោយហេតុនេះហើយ បានជាខ្ញុំគិតថា បើខ្ញុំបាទ បាញ់នោមដាក់មុខវា១ អាចបាត់ម្ចាស់ការលើខ្លួនវា ព្រោះនេះគឺជាការប្រមាថហួសហេតុ ។ ហេតុនេះ ទើបខ្ញុំបាទបាញ់នោមដាក់ខ្លួនវាទៅ ព្រោះខ្ញុំគិតថា ប៉ុណ្ណឹងគ្រប់គ្រាន់ណាស់ទៅហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

អ្នកទាំងពីរអង្គុយជជែកគ្នាលើ ម៉ក់សូតនៅរានហាលនៃផ្ទះរបស់ *អូមី* ។ ម្ដាយរបស់ *អូមី* ជាអ្នកបំរើតែ យ៉ាងប៉ិនប្រសប់ ។

- ខ្ញុំស្ងើចឯងហើយ *អូមី-សាន -យ៉ាហ្គូ* និយាយ -ការវិភាគរបស់ឯងគឺអស្ចារ្យ ការរៀបផែនការ និងការចាត់ចែងរបស់ឯង គឺវិសេសវិសាលតែម្ដង ។

- លោកម្ចាស់សរសើរខ្ញុំបាទពេកហើយទាន ។ ខ្ញុំគួរតែប្រឹងប្រែងខ្លាំងជាងនេះទៀតទើបត្រូវ ។

- តើឯងរៀនពីណាមកដើម្បីយល់បានច្រើនពីចិត្តគំនិតរបស់ពួកអាចុងស្រុកទាំង នេះ?

- នៅពេលដែលខ្ញុំបាទអាយុ ដប់បួនឆ្នាំ ខ្ញុំមានឧបជ្ឈាយ៍ ជាសង្ឃម្នាក់ឈ្មោះ *ជីរ៉ូ* ។ មុនជាសង្ឃ គាត់បានធ្វើជាបព្វជិតគ្រិស្តសាសនា រឺថាគាត់រៀបធ្វើជាបព្វជិតគ្រិស្តសាសនាតែ ក្រោយមកគាត់ដឹងថាគាត់ល្ងើពេកថ្វាសមែន ។ ខ្ញុំបាទនៅចាំរឿងមួយដែលគាត់តែងនិយាយប្រាប់ខ្ញុំបាទ ។ គាត់ថា គ្រិស្តសាសនាជាសាសនាមានចំនុចខ្សោយច្រើនណាស់ ពីព្រោះសាសនានេះ និយាយថាព្រះរបស់គេគឺ *យេស៊ូ* បានប្រដៅថា មនុស្សទាំងអស់ ត្រូវ "ស្រលាញ់គ្នាទៅវិញទៅ មក " តែព្រះគេណឹងអត់មានប្រដៅអំពីរឿងកិត្តិយស ពីរឿង កាតព្វកិច្ចអីទេ និយាយតែពីរឿងស្រលាញ់មួយមុខគត់ ។ រួចព្រះគេថា ជីវិតពិសិដ្ឋណាស់ គឺគេហាមមិនអោយសំលាប់មនុស្សផងគ្នាទេ ។ ហើយនៅមានអារឿងចំកួត១ អីចឹង ច្រើនទៀត ។ ពួកអាចុងស្រុកមកដល់នេះនិយាយថា វាជាគ្រិស្តសាសនិកដែរ ទោះជាបព្វជិតនោះថា មិនមែនក្ដី ។ ដោយហេតុនេះហើយខ្ញុំបាទ ស្វែងយល់ពីរឿសគល់ទំនាស់គ្នា ហើយខ្ញុំបាទគិតថា អានេះដូចតែរឿងអ្នកកាន់និកាយពុទ្ធសាសនា ខុសគ្នា ស្អប់គ្នា អីចឹង ។ ខ្ញុំបាទគិតថា បើសិនជាយើងសំលាប់ រឺសំលុតកូនចៅវាម្នាក់ពីរទៅ យើងច្បាស់ជាក្ដាប់ មេវាបានហើយ ។

*អូមី* ដឹងថាកិច្ចសន្ទនានេះមានគ្រោះថ្នាក់ណាស់ ពីព្រោះតែអារឿងទារុណកម្ម និងមរណភាព ដ៏ព្រឺព្រួចកន្លងមកនេះ គេហាក់ដូចជាលឺសូរការព្រមាន ដ៏ស្ងាត់ស្ងៀមរបស់ម្ដាយគេដែលនៅអង្គុយឯម្ខាងទៀតនោះ ។

- លោកម្ចាស់អញ្ជើញតែ ទៀតទេ ? -ម្ដាយ *អូមី* សួរ ។



www.budinst.gov.kh www.elibraryofcambodia.org

-អរគុណ !-*យ៉ាប៊ូ* ឆ្លើយតប -តែនេះឆ្ងាញ់ណាស់ ។

-អរគុណណាស់លោកម្ចាស់ ។ នៃ *អូមី-សាន* ! តើឯងច្បាស់ជាកាច់បំបាក់មនុស្សចុងស្រុកនោះបានរហូតហើយអ្វី ? -ម្ដាយ *អូមី* បង្វែរកិច្ចសន្ទនា -យកល្អឯងគួរជំរាបលោកម្ចាស់ថាមនុស្សនោះវាបាក់រហូត រឺក៏បាក់បណ្ដោះអាសន្ន ។

*អូមី* អេះអុញ :

- បណ្ដោះអាសន្នទេ ។ ប៉ុន្តែខ្ញុំបាទគិតថា វាគួររៀនភាសាយើងអោយបានរហ័ស ។ រហ័សពេលណាល្អពេលណឹង ។ រឿងនេះសំខាន់ណាស់ សំរាប់លោកម្ចាស់ ។ លោកម្ចាស់ច្បាស់ជានឹងត្រូវសំលាប់ពួកវាម្នាក់ពីរហើយ ដើម្បីក្ដាប់វា និងកូនចៅវា ។ ទន្ទឹមនេះ វាត្រូវរៀនអោយចេះរបៀបរបបរបស់យើង ។ នៅពេលណាដែលលោកម្ចាស់អាចនិយាយជាមួយវាបានលោកម្ចាស់ អាចប្រើចំនេះរបស់ វាបានហើយ ។ បើសិន ជាបព្វជិតនោះ វានិយាយ រឿងនេះពិតមែន គឺថាតែកុងនេះបើកសំពៅ ជាងមួយម៉ឺនលី ទើបមកដល់ទីនេះ គឺមិនមែនធម្មតាទេ ។

- អែងក៏មិនមែនធម្មតាដែរ -*យ៉ាប៊ូ* សើច -អាសត្វអស់នេះ ខ្ញុំប្រគល់អោយអែងហើយ ។ *អូមី-សាន* អ្នកផ្សាំងមនុស្ស ។

- បាទខ្ញុំចេះតែខំប្រឹងហើយទាន -*អូមី* សើចបន្ទរតាម ។

សម្បត្តិអែង ត្រូវតំលើងពីប្រាំរយ កូគូទៅបីពាន់កូគូ ។ ដីអែងត្រូវពង្រីកដល់រង្វង់ម្ភៃលី ។

មួយលី មានចំងាយប្រហែលមួយម៉ែ ។ *យ៉ាប៊ូ* បន្តទៀត :

- ជាសក្ខីភាពនៃការ រាប់អានរបស់ខ្ញុំ ពេលខ្ញុំត្រលប់ទៅយេដ្ឌូវិញ ខ្ញុំនឹងចាត់ចែងផ្ញើអោយអែងសេះពីរ គឺម៉ូណូសូតម៉្តែ អាវក្រោះមួយប្រដាប់ ដាវពីរ ហើយនឹងអាវុធគ្រប់គ្រាន់សំរាប់ សាមូរ៉ៃ មួយរយនាក់ ដែលអែងត្រូវរើសបន្ថែម ។ នៅពេលដែលសង្គ្រាមផ្ទុះឡើង អែងត្រូវមកកួមកំលាំងនឹងខ្ញុំភ្លាម ដើម្បីធ្វើជា *ហាតាម៉ូតូ* ។

*យ៉ាប៊ូ* មានអារម្មណ៍ទូលាយណាស់នៅពេលនេះ ។ *ហាតាម៉ូតូ* គឺជា អង្គរក្សផ្ទាល់ ហើយដែលមានសិទ្ធិកាន់អាវុធនៅចំពោះមុខអម្ចាស់របស់ខ្លួន ។ គេសែនពេញចិត្តនឹង *អូមី*



www.budinst.gov.kh www.elibraryofcambodia.org

ហើយដូចជាមានអារម្មណ៍រំភើប ហាក់កើតឡើងម្តងទៀត ។ ពីយប់មិញគេសំរាកលក់យ៉ាងស្កប់ស្កល់ ។ ពេលដែលគេភ្ញាក់ឡើង *យ៉ាប៊ូ* ឃើញថាខ្លួននៅតែម្នាក់ឯងដូចគេប៉ង ព្រោះគេឥតបានប្រាប់នារីក្មេងៗនោះអោយនៅចាំគេឡើយ ។ គេបានហូបតែបន្តិច ហើយបន្ទាប់មកបបរវូចមុជទឹក និងអោយ *ស៊ូរ៉ូ* ធ្វើសរសៃ ។ គេគិតថា នេះជាការពិសោធន៍មួយដ៏ល្អ ។ អញមិនដែលមានអារម្មណ៍នៅផ្ទាល់នឹងធម្មជាតិ នឹងដើមឈើ ភ្នំ ដី រីក៏ស្គាល់បដឹង ពីភាពដ៏កំសត់ នៃជីវិតដូចពេលនេះទេ ។ គឺសំរែកនោះហើយដែលធ្វើអោយអ្វីៗ ទៅជាសុក្រិត្យទាំងអស់ ។

- *អូមិ-សាន* នៅក្នុងសួនច្បារខ្ញុំ ឯ *មីស៊ីម៉ា* មានថ្មមួយដុំ ។ ខ្ញុំចង់អោយអែងទទួលយក ដើម្បីរំលឹកពីអ្វីដែលកើតឡើងពីយប់ ដ៏អស្ចារ្យ និងពីសំនាងដ៏ល្អរបស់យើងនេះ ។ ខ្ញុំនឹងធ្វើថ្ម នេះជាមួយនឹងរបស់របរឯទៀតនោះ ។ ថ្មនោះមកពី *ត្សូស៊ូ* ។ ខ្ញុំហៅថ្មនោះថា " ថ្មរង់ចាំ " ព្រោះពេលដែលប្រទះឃើញវា គឺជាពេលដែលខ្ញុំរង់ចាំបញ្ជារបស់អម្ចាស់ *រ៉ៃតូ* ដើម្បីវាយលុក ។ រឿងនេះកើតឡើងកាលពីដប់ប្រាំឆ្នាំមុន ។ កាលនោះខ្ញុំនៅក្នុងទ័ពរបស់គាត់ ដែលដើរពង្រាបពួកបះបោរនោះ ។

- លោកម្ចាស់ផ្តល់កិត្តិយស អោយខ្ញុំបាទពេកហើយ !

- នែ៎ ម៉េចមិនយកវាមកដាក់នៅសួនអែង ហើយអោយឈ្មោះថ្មីទៅ ? អែងអាចអោយឈ្មោះនេះជា " ថ្មនៃសន្តិភាពរបស់ពួកចុងស្រុក " ក៏បាន ដើម្បីរំលឹកពីយប់គន្លងទៅ និងការរង់ចាំនិញ្ញនរបស់វា ។

- ប្រហែលជាខ្ញុំបាទអោយឈ្មោះថា " ថ្មសុភមង្គល " វិញដើម្បីទាំងខ្ញុំបាទ ទាំងកូនចៅស្រែករក្រោយរបស់ខ្ញុំបាទ អាចរំលឹកបានពីកិត្តិយស ដែលលោកម្ចាស់បានផ្តល់ដល់ខ្ញុំបាទ ត្រូវទេលោកម្ចា ?

- ទេ ។ យកល្អហៅវាថា " អ្នកចុងស្រុករង់ចាំ " ។ ណឹងហើយ ឈ្មោះនេះខ្ញុំពេញចិត្តណាស់ ។ ឈ្មោះនេះនឹងធ្វើអោយខ្ញុំ និងវាកាន់តែចូលជិតគ្នាថែមទៀត ។ វារង់ចាំដូចខ្ញុំរង់ចាំដែរ ។ ខ្ញុំរស់ វាស្លាប់ -*យ៉ាប៊ូ* និយាយបណ្តើរ សំលឹងមើលសួនច្បារដោយអាការៈ រិះគិតបណ្តើរ -ល្អ ! "អ្នកចុងស្រុករង់ចាំ" ខ្ញុំពេញចិត្តឈ្មោះនេះ ។ នៅលើថ្មនោះមួយចំហៀងមានស្នាមចំណែកមួយ



www.budinst.gov.kh www.elibraryofcambodia.org

ចំនួន ដែលធ្វើអោយខ្ញុំនឹកឃើញពីតំនក់ទឹកភ្លែក ហើយក៏មានផ្កាពណ៌ខៀវ លាយនឹងសាច់ថ្ម ក្លាតក្រហមព្រឿងៗ ដែលធ្វើអោយខ្ញុំនឹកឃើញពីសាច់មនុស្ស និងភាពស្រងេះស្រងោចផងដែរ ។ -យ៉ាប៉ូ ដកដង្ហើមធំ រួចពោលបន្ថែម -គឺជាការល្អមួយ ដែលមនុស្សចេះយកថ្មមកដាក់នៅក្នុងសួនច្បារ ហើយអោយឈ្មោះវាបាន ។ គិតទៅ អាចុងស្រុកនោះទ្រាំរស់បានយូរផង *ទេ* ? ប្រហែលជាជាតិក្រោយ វាអាចកើតជាជប៉ុនបានហើយ ពីព្រោះវាឈឺចាប់ណាស់ដែរ ។ បើអ៊ីចឹងគឺពិតជាអស្ចារ្យហើយ ។ អាចមានថ្ងៃណាមួយកូនចៅគេ អាចឃើញថ្មរបស់គេ ហើយពួកគេច្បាស់ជាសប្បាយចិត្តហើយ ។

*អូមី* អរគុណយ៉ាងញាប់មាត់ផង ប្រកែកចំពោះកិត្តយស ដែលគេយល់ឃើញថាគេមិនសក្តិសមនឹងទទួលនេះផង ។ *យ៉ាប៉ូ* ក៏ដឹងដែរថាសប្បុរសធម៌របស់លោក ក៏មិនហួស ព្រំដែនដែរ ។ លោកអាច បង្ហាញសប្បុរសធម៌លោកច្រើនជាងនេះទៅទៀត ប៉ុន្តែលោកនៅចងចាំពាក្យស្លោកបុរាណមួយ :

" *ពេលណាក៏អែងអាចពង្រីកដែនអំនាចអោយគេបានដែរ តែបើបន្ថយវិញ គឺអែងបង្កើតភាពជាសត្រូវ ។ ហើយ នឹងការក្បត់ទៀត* " ។

- *អូតូ-សាន- យ៉ាប៉ូ* ហៅម្តាយ *អូមី* ដោយផ្តល់នាមជាឧត្តមមាតា -ប្អូនខ្ញុំ គួរតែប្រាប់ខ្ញុំពីយូរយារណាស់ហើយ ពីមហាគុណសម្បត្តិរបស់កូនពៅរបស់គាត់ ។ បើធ្វើអ៊ីចឹងប្រហែលជា *អូមី-សាន* ឡើងមានមុខ មានមាត់ពីណាពីណើមកបាត់ទៅហើយ ។ ប្អូនខ្ញុំវាទុយមុយ តក់មឹក់ ពេកតែម្រ៉ង ។

- ប្តីខ្ញុំគោរពលោកម្ចាស់ណាស់ ដោយហេតុនេះ ទើបគាត់មិនហ៊ានរំខានលោកម្ចាស់ -ម្តាយ *អូមី* ឆ្លើយតប នឹងការរិះគន់ជាប្រយោលនេះ -ខ្ញុំអរគុណណាស់ដោយកូនខ្ញុំបាន មានឱកាសបំរើលោកម្ចាស់ ហើយបានលោកម្ចាស់ពេញចិត្តនឹងវា ។ កូនខ្ញុំវាគ្រាន់តែបំពេញភារកិច្ចរបស់វា តែប៉ុណ្ណោះទេលោកម្ចាស់ ។ នេះជាភារកិច្ចរបស់យើងខ្ញុំ ទាំង *មីស៊ូហ្គូ-សាន* និងទាំងពួកយើងខ្ញុំទាំងអស់គ្នានេះ ដែលត្រូវបំរើលោកម្ចាស់នោះ ។

ស្គួរជើងសេះបានលាន់លឺឡើងតាមជំរាលផ្លូវ ។ *អ៊ីកូរ៉ាស៊ី* អង្គរក្សរបស់ *យ៉ាប៉ូ* ដើរកាត់



www.budinst.gov.kh www.elibraryofcambodia.org

សួន សំដៅមករក *យ៉ាប៊ូ* ។

- អ្វី១រួចរាល់អស់ហើយលោកម្ចាស់ ។ បើសិនជាលោកម្ចាស់ចង់វិលត្រលប់ទៅ យេដូ អោយបានរហ័ស យើងគួរចាកចេញអីលូវនេះ ។

- ល្អ ! *អូមី-សាន* អែង និងក្រុមរបស់អែង ត្រូវចេញដំណើរជាមួយក្បួនអីវ៉ាន់ ហើយជួយ *អ៊ីកូរ៉ាស៊ី-សាន* ដឹកអីវ៉ាន់ទាំងនេះ អោយទៅដល់វិមានដោយសុវត្ថិភាពណា ! *-យ៉ាប៊ូ* ឃើញទឹកមុខ *អូមី* ប្រែជាស្រពោនមួយភ្លែតយ៉ាងរហ័ស-មាន រឿងអី ?

- ខ្ញុំបាទគិតពីពួកចុងស្រុកទាន !

- ដាក់អ្នកយាមខ្លះទៅមើលវាទៅ ។ ធ្វើមជាមួយក្បួនអីវ៉ាន់ ពួកវាគ្មានសារសំខាន់ ប៉ុន្មានទេ អែងចង់ចាត់ការយ៉ាងម៉េច ក៏ស្រេចតែអែង ។ ដាក់វាទៅក្នុងអន្លង់វិញ ក៏តាមតែចិត្ត អែង ។ នៅពេលដែលអែងអោយពួកវានិយាយបានហើយ អែងអោយដំណឹងខ្ញុំភ្លាមណា ! ។

-បាទលោកម្ចាស់ ! - *អូមី* តប - ខ្ញុំបាទ ទុកសាមូរ៉ៃដប់នាក់ ហើយនិងផ្ដែផ្កាំ *មួរ៉ា* ថែមទៀត ។ ក្នុងបួនប្រាំថ្ងៃនេះវា ច្បាស់ជាគ្មានហេតុការណ៍អាក្រក់អីកើតទេ ។ ចុះសំពៅនេះ លោកម្ចាស់ប្រុងធ្វើអី ?

- ទុកវាអោយនៅកន្លែងនេះចុះ ។ អែងជាអ្នកទទួលខុសត្រូវណា ។ *ស៊ូគីម៉ូតូ* បានផ្ញើ សំបុត្រទៅម៉ូយគេ នៅឯ *ណាកាសាគី* ដើម្បីលក់វាទៅអោយពួក ប៉័កទុយកាល់ ហើយនាំពួក ប៉័កទុយកាល់មកយកវាទៅចុះ ។

*អូមី* អេះអុញ :

- ប្រហែលជាលោកម្ចាស់ គួរទុកសំពៅនេះវិញលោកម្ចាស់ ។ ហើយគួរអោយពួកចុង ស្រុកបង្រីកបង្ហាត់ពួកយើងអោយចេះបើកវាវិញ ។

*យ៉ាប៊ូ* សើចចំអក :

- រួចចុះអោយខ្ញុំ ត្រូវការយកសំពៅពួកចុងស្រុកនេះយកទៅធ្វើអី ? អោយខ្ញុំទៅ ធ្វើជាពួកឈ្មួញគគ្រិចទាំងនោះ អីចឹងអ្វី ?

- អត់ទេលោកម្ចាស់ ! អត់ទេ !-*អូមី* តបយ៉ាងរហ័ស -ខ្ញុំបាទគ្រាន់តែគិតថា *ស៊ូគីម៉ូតូ*



www.budinst.gov.kh www.elibraryofcambodia.org

អាចរកមធ្យោបាយប្រើប្រាស់សំពៅនេះបាន តែប៉ុណ្ណោះទាន ។

- ខ្ញុំយកសំពៅជំនួញនេះទៅធ្វើអី ?

- បព្វជិតនោះ ថាសំពៅនេះ ជាសំពៅចំបាំងលោកម្ចាស់ ។ បព្វជិតនោះ ហាក់ដូចជាខ្លាចសំពៅនេះណាស់ ។ ពេលដែលសង្គ្រាមផ្ទុះឡើង សំពៅចំបាំងអាច..........

- សង្គ្រាមយើងនឹងធ្វើឡើងនៅលើដី ។ សមុទ្រសំរាប់ពួកឈ្មួញ ។ ពួកអាអស់នេះសុទ្ធតែជាពួកចងការប្រាក់ ពួកចោរសមុទ្រ និងពួកចាប់ត្រីសំគិះតែប៉ុណ្ណឹង ។

រួច *យ៉ាប៊ូ* ក៏ក្រោកឡើង ហើយចាប់ផ្តើមចុះជណ្តើរតំរង់ទៅរកច្រកទ្វារ នៃសួនច្បារដែលនៅទីនោះ សាមូរ៉ៃម្នាក់កំពុងកាន់បង្ហៀរសេះ រង់ចាំគេហើយជាស្រេច ។ គេឈប់មួយភ្លែតហើយសំលឹងមើលទៅឯលំហសមុទ្រ ។

ជើងរបស់គេឡើងទន់មួយរំពេច ។

*អូមី* សំលឹងមើលតាមក្រសែភ្នែករបស់ ឪពុកមាគេ ។

នាវាមួយកំពុងតែបត់តាមជ្រោយសមុទ្រតំរង់មក ។ នេះគឺជាប្រភេទទូកធំមួយ ដែលមានដងចែវដ៏ច្រើន ។ ជាប្រភេទនាវា ដ៏លឿនជាងគេនៅតាមបណ្តោយឆ្នេរសមុទ្រជប៉ុននេះព្រោះវាមិនចំនុះខ្យល់ មិនចំនុះចរន្តទឹក ។ នៅលើកំពូលនៃសរសរក្តោង ទង់មួយបក់ រវិច ។ ទង់នេះមានសញ្ញារបស់ *តូរ៉ាណាកា* ។

☆

☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៧

*តូដាហ៊ីរ៉ូម៉ាត់ស៊ី* ស្តេចគ្រាញ់លើខេត្ត *សាកាមី* និង *កូស៊ូកេ* ជាមេទ័ព និងជា ទីប្រឹក្សាដ៏ទុកចិត្តបំផុតរបស់ *តូរ៉ាណាកា* និងជាអគ្គមេបញ្ជាការលើកងទ័ពរបស់ *តូរ៉ាណាកា*ទាំងមូល បានចុះតាមជណ្តើរនាវាមកលើផែតែម្នាក់ឯង។ ប្រៀបជាមួយជនជាតិជប៉ុនធម្មតា លោកជាមនុស្សមាឌធំដំបង ក្នុងកំពស់មួយម៉ែតប៉ែតសិប ជាប្រភេទគោឡើងកម្មយ ដែលមានថ្គាមខ្លាហើយដែលអាយុហុកសិបប្រាំពីរឆ្នាំនេះ មិនបានប៉ះពាល់កំលាំងពលំរបស់លោក បន្តិចបន្តួចណាសោះ ។គីម៉ូណូទ័ពរបស់លោកធ្វើអំពីសូតពណ៌ប្រផេះ ហើយគ្មានគ្រឿងលំអអ្វីទាំងអស់ ក្រៅតែពីរូបសញ្ញារបស់ *តូរ៉ាណាកា*ទាំងប្រាំតែប៉ុណ្ណោះ។ នោះគឺជារូបដើមរីស្សីបីដើមមូរចូលគ្នា។ លោកពាក់អាវក្រោះមួយ ។ ដៃរបស់លោកត្រូវបានការពារដោយបន្ទះដែកថែប ។ នៅនឹងចង្កេះរបស់លោកមានតែកាំបិតខ្លីមួយតែប៉ុណ្ណោះ ចំនែកឯកាំបិតមួយទៀតដែលជាកាំបិតសំរាប់សំលាប់នោះត្រូវបានលោកកាន់នៅនឹងដៃ ត្រៀមដកចេញពីស្រោមជាប់ ដើម្បីសំលាប់មួយរំពេចនៅពេលណាដែលលោកត្រូវការការពារអម្ចាស់របស់លោក ។ នេះគឺជាទំលាប់របស់លោកតាំងពីលោកមានអាយុ ដប់ប្រាំឆ្នាំម្លេះ ។

គ្មានអ្នកណាម្នាក់ សូម្បីតែអម្ចាស់ *តៃគូ* ក្តីក៏មិនអាចអោយលោកប្តូរទំលាប់នេះបានដែរ ។

កាលពីឆ្នាំទៅ នៅពេលដែលអម្ចាស់ *តៃគូ* ស្លាប់ទៅ *ហ៊ីរ៉ូម៉ាត់ស៊ី* បានចំនុះខ្លួនទៅ នឹង *តូរ៉ាណាកា* ។ *តូរ៉ាណាកា* បានអោយខេត្តពីរ ក្នុងខេត្តទាំងប្រាំបី របស់ខ្លួនទៅ *ហ៊ីរ៉ូម៉ាត់ស៊ី* ត្រួតត្រា។ នោះគឺជាខេត្ត *សាកាមី* និង *កូស៊ូកេ* ។ មិនតែប៉ុណ្ណោះលោកបានទទួលពី *តូរ៉ាណាកា* ជារៀងរាល់ឆ្នាំនូវសម្បត្តិជាប្រាំរយពាន់កូគូ ហើយលោកមានសិទ្ធិរក្សាទំលាប់ របស់លោកដដែល ។ *ហ៊ីរ៉ូម៉ាត់ស៊ី* ជាអ្នកជំនាញបំផុត ក្នុងរឿងសំលាប់មនុស្ស ។ អ្នកស្រុក អ្នកភូមិទាំងអស់ ទាំងប្រុស ទាំងស្រី ទាំងកុមារ កំពុងលុតជង្គង់ ជាជួរអោនក្បាលយ៉ាងទាបនៅតាមបណ្តោយឆ្នេរសមុទ្រ ។ នៅពីមុខអ្នកទាំងនេះ គឺជាជួរដ៏មានរបៀបរៀបរយរបស់ពួក សាមូរ៉ៃ។ នៅមុខគេបង្អស់ គឺ *យ៉ាប៊ូ* និង ភូឈួយទាំងប៉ុន្មានរបស់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org

បើសិន *យ៉ាប៊ូ* ជានារី រឺជាបុរសទន់ខ្សោយវិញ គេប្រហែលជាតក់ស្លុត បោចសក់ ទ្រហោយំមិនខាន ។ព្រោះរឿងទាំងឡាយវាចៃដន់ហួសពេក ។ វត្តមានរបស់ *ក្ងួដាហ៊ីរ៉ូម៉ាត់ស៊ី* ដ៏ល្បីល្បាញនៅទីនេះ ក្នុងថ្ងៃនេះ មានន័យថា មានអ្នកណាម្នាក់បានក្បត់ខ្លួនគេហើយ ។ អ្នកក្បត់នេះអាចជាអ្នកផ្ទះគេ ដែលនៅ *យេដូ* រឺក៏អ្នកដែលនៅ *អាន់ជ៉ីរ* នេះដែលអាចជា *អូមី* រឺមនុស្សណាម្នាក់របស់ *អូមី* រឺអ្នកភូមិណាម្នាក់នៅទីនេះ ។ អីលូវនេះខ្លួនគេត្រូវជាន់កែងជាប់ពីរឿងមិនគោរពវិន័យតែម្តង ។ ពួកអ្នកប្រឆាំងរបស់គេបានឆ្លៀតឱកាសយកប្រៀប ក្នុងពេលដែលគេផ្ចោតការយកចិត្តទុកដាក់របស់គេទៅលើសំពៅនេះ ។

*យ៉ាប៊ូ* លុតជង្គង់ចុះ អោនក្បាលគោរព ។ សាមូរ៉ៃឯទៀតធ្វើតាម *យ៉ាប៊ូ* ភ្លាម ។ នៅក្នុងពោះរបស់គេ *យ៉ាប៊ូ* ជេរប្រទេចទាំងនាវា ទាំងអ្នកដែលបញ្ជាវា ។

- អូ ! *យ៉ាប៊ូ-សាម៉ា* ទេតើ !

សំលេង *ហ៊ីរ៉ូម៉ាត់ស៊ី* លាន់លឺឡើង ។ *យ៉ាប៊ូ* ឃើញ *ហ៊ីរ៉ូម៉ាត់ស៊ី* លុតជង្គង់នៅលើម៉ក់ដែលគេបានរៀបចំទុកជូនជាមុន ហើយអោនគោរពតបមកវិញ ។ ប៉ុន្តែជំរៅនៃការគោរពនេះ គឺមានភាពសើៗតែប៉ុណ្ណោះ ហើយ *ហ៊ីរ៉ូម៉ាត់ស៊ី* ឥតរង់ចាំរូបគេអោនគោរពតបម្តងទៀតឡើយ ដោយហេតុនេះគេដឹងច្បាស់ថា រូបគេកំពុងស្ថិតនៅក្នុងស្ថានភាព ដ៏គ្រោះថ្នាក់បំផុត ។ អ្នកផងគេធ្លាប់ហៅ *ហ៊ីរ៉ូម៉ាត់ស៊ី* ពីក្រោយខ្នងថា " កណ្តាប់ដៃដែក " ហើយគឺមានតែ *តូរ៉ាណាកា* និងទីប្រឹក្សា ទាំងបីទេដែលអាចប្រើទង់ *តូរ៉ាណាកា* បាន។ តែហេតុអីបានជាចាំបាច់ប្រើមេទ័ព ដ៏សំខាន់ម្នាក់មកតាមអញ្ជូលយពី *យេដូ* យ៉ាងនេះ ។

*យ៉ាប៊ូ* បន្លឺសំលេង :

- *ហ៊ីរ៉ូ-ម៉ាត់ស៊ី-សាម៉ា* ! លោកម្ចាស់អញ្ជើញមកដល់ភូមិដ៏កំសត់របស់ខ្ញុំបាទ យ៉ាងនេះគឺជាការផ្តល់កិត្តិយស យ៉ាងធំធេងមកដល់ខ្ញុំបាទណាស់ ។

- លោកម្ចាស់បញ្ជាអោយខ្ញុំមកទីនេះ !

អ្នកណា ក៏ល្បីល្បាញថា *ហ៊ីរ៉ូម៉ាត់ស៊ី* ជាមនុស្សត្រង់ណាស់ ។ លោកមិនមានល្បិចកិច្ចកលអ្វីទាំងអស់ ក្រៅតែពីភាពស្មោះត្រង់ ស្លាប់រស់ជាមួយម្ចាស់លោក តែប៉ុណ្ណោះ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំបាទមានកិត្តិយសណាស់ ហើយរីករាយថែមទៀតផង -*យ៉ាហ៊ូ*ឆ្លើយតប -ខ្ញុំបាទ ស្រូតពី *យេដូ* មកពីព្រោះតែរឿងសំពៅពួកចុងស្រុកនេះឯង ។

- លោកម្ចាស់ *តូរ៉ាណាកា* បានអញ្ជើញ ដៃមីញ្ញទាំងអស់ដែលជាមិត្ត អោយនៅរង់ចាំលោកម្ចាស់នៅឯ *យេដូ* រហូតដល់ពេលដែលលោកម្ចាស់ត្រលប់មកពី *អូសាកា* វិញ ។

- តើលោកម្ចាស់យ៉ាងម៉េចទៅហើយ ? ខ្ញុំបាទសង្ឃឹមថា លោកម្ចាស់ប្រហែលជាមិនអីទេមើលទៅ !

- លោកម្ចាស់វិលត្រលប់មកវិមានលោកម្ចាស់នៅ *យេដូ* ដោយសុខសាន្តកាន់តែឆាប់ពេលណាកាន់តែល្អពេលហ្នឹង ។ យើងបើកការប្រយុទ្ធជាមួយ *អ៊ីស៊ីដូ* កាន់តែរហ័សពេលណាយើងនឹងកាន់តែឆាប់បញ្ជូនទ័ពយើង វាយលុក *អូសាកា* កំទេចវាទៅជាផេះពេលហ្នុង ។

ថ្ពាមរបស់ *ហ៊ីរ៉ូម៉ាត់ស៊ឺ* កាន់តែឡើងក្រហម នៅពេលដែលលោកកាន់តែខ្វល់ខ្វាយពីសុខទុក្ខ របស់លោកម្ចាស់របស់លោក ។លោកមិនចូលចិត្តចេញឆ្ងាយ ពីលោកម្ចាស់របស់លោកសោះឡើយ ។ អម្ចាស់ *តែតូ* បានកសាងវិមាន *អូសាកា* គឺដើម្បីគ្មានអ្នកណាចូលចុះ ។ នេះគឺជាវិមានដ៏ធំបំផុតនៅក្នុងចក្រភព ដែលមានប៉ម និងគូទឹកប្រទាក់គ្នា មានវិមានតូចធំ ច្រើន និងស្ពានខ្វែងខ្វាត់ ហើយទីទូលាយល្មមដាក់ទាហានបាន ប្រាំបីម៉ឺននាក់បង្កប់ខ្លួនក្នុងកំផែងនេះ ។ ហើយនៅជុំវិញកំផែងវិមាន និងក្នុងទីក្រុង ដ៏មានមនុស្សកុះករ នៅមានទ័ព ដ៏មានវិន័យ និងដ៏មានប្រដាប់អាវុធគ្រប់គ្រាន់ច្រើនទៀត ដែលសុទ្ធតែស្មោះត្រង់ នឹងទាយាទ *យែម៉ុន* ។ *ហ៊ីរ៉ូ*សន្ទូទៀត :

-ខ្ញុំបាទជំរាបលោកម្ចាស់ប៉ុន្មានសិបដងហើយតើ ថាកុំទៅឆោតដើរចូលក្នុងកណ្តាប់ដៃ *អ៊ីស៊ីដូ* នេះបានចំជាលេលាតែម្តងហើយ !

- ប៉ុន្តែលោកម្ចាស់ *តូរ៉ាណាកា* ត្រូវតែអញ្ជើញទៅ *ទេ* ? លោកម្ចាស់គ្មានជំរើសទេក្នុងរឿងនេះ ។

អម្ចាស់ *តែតូ* បានចេញបញ្ជាអោយក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ដែលទទួលគ្រប់គ្រងចក្រភពក្នុងនាមរបស់ *យែទម៉ុន* យ៉ាងតិចប្រជុំពីរដងក្នុងមួយឆ្នាំ។ រយៈពេលប្រជុំគឺដប់ថ្ងៃ ហើយជា



www.budinst.gov.kh www.elibraryofcambodia.org

និច្ចកាលធ្វើនៅក្នុងប៉មនៃវិមាន *អូសាកា* ។សមាជិកដែលចូលប្រជុំអាចយកអ្នកហែហមតាមខ្លួនចូលក្នុងវិមាន យ៉ាងច្រើនបំផុត ប្រាំរយនាក់ប៉ុណ្ណោះ ។ មិនតែប៉ុណ្ណោះ *ដៃមីញ៉ូ* ទាំងអស់ក៏ត្រូវមានកាតព្វកិច្ចនាំគ្រួសារខ្លួន ចូលវិមាន *អូសាកា* មួយឆ្នាំពីរដងដែរ ដើម្បីគោរពទាយាទ ។ ដោយហេតុនេះទាំងអស់គ្នា ត្រូវតែស្ដាប់យ៉ាងណែន និងគ្មានអ្វីអាចទប់បានឡើយ ។ *យ៉ាប៊ូ* បន្ត :

- ការប្រជុំនេះ ត្រូវបានកំនត់ហើយស្រេចទៅហើយ *នេ* ? បើលោកម្ចាស់មិនទៅនេះត្រូវចាត់ថាជាអំពើក្បត់ *នេ* ?

- ក្បត់នឹងអ្នកណា ?-មុខ *ហ៊ីរ៉ូ-ម៉ាត់ស៊ឹ* កាន់តែក្រហមឡើងថែមទៀត -*អ៊ីស៊ីដូ* ខិតខំឯកោលោកម្ចាស់យើងណា ។ ស្ដាប់ណា ! បើសិនជា *អ៊ីស៊ីដូ*នៅក្នុងកណ្ដាប់ដៃខ្ញុំ ដូចជាលោកម្ចាស់*តូរ៉ាណាកា* នៅក្នុងកណ្ដាប់ដៃវាពេលនេះ ខ្ញុំគ្មានរួញរាគិតតូចណាទេ ទោះជាមានរឿងយ៉ាងម៉េចទៅទៀតក៏ដោយ ។ ក្បាលរបស់វាច្បាស់ជាដាច់ចេញពីស្មាតាំងពីយូរយារណាស់បាត់ទៅហើយៗព្រលឹងវា បែបត្រៀមកើតម្ដងទៀតទៅហើយ ។

និយាយបណ្ដើរ ដៃឆ្វេងរបស់លោកមេទ័ពបង្វិលដោយឥតដឹងខ្លួននូវស្រោមដាវស់ទឹករបស់ខ្លួន ចំនែកឯដៃស្ដាំ ដ៏គំរិន ដាក់នៅស្មៀមនៅលើពោះ ។ លោកសំលឹងមើលសំពៅហើយសួរឡើង :

- កាណុងនៅឯណា ?

- ខ្ញុំបាទយកវាដាក់នៅលើគោកហើយ ដើម្បីបញ្ជាសន្តិសុខ ។ តើ *តូរ៉ាណាកា-សាម៉ា* នឹងធ្វើសម្បទានទៀតជាមួយ *អ៊ីស៊ីដូ* រឺអី ?

- ពេលខ្ញុំចេញពី អូសាកា អ្វីៗនៅស្ងាត់ស្ងៀមទេ ។ ក្រុមប្រឹក្សានឹងចាប់ផ្ដើមការងារបីថ្ងៃទៀត ។

- តើនឹងមានការប្រឈមមុខគ្នាទេលើកនេះ ?

- ខ្ញុំបទំអោយតែបូសធ្លាយមុខទេ ។ តែធ្វើម៉េច ខ្ញុំដឹងចិត្តលោកម្ចាស់ ? បើលោកចង់ធ្វើសម្បទាន លោកនឹងធ្វើសម្បទាន -*ហ៊ីរ៉ូ-ម៉ាត់ស៊ឹ* សំលឹងមើល *យ៉ាប៊ូ* -លោកម្ចាស់បានបញ្ជាអោយ *ដៃមីញ៉ូ* ទាំងអស់ដែលជាសម្ព័ន្ធមិត្ត អោយរង់ចាំលោកម្ចាស់នៅឯ *យេដូ* រហូតដល់ពេល



www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់ត្រលប់មកវិញ ។ កន្លែងនេះមិនមែនជា *យេដូ* ទេណា !

- ខ្ញុំបាទដឹងហើយលោកម្ចាស់ ។ ប៉ុន្តែខ្ញុំបាទមានអារម្មណ៍គិតថា សំពៅនេះអាចមានប្រយោជន៍ដល់បុព្វហេតុរបស់យើង ដោយហេតុនេះហើយទើបត្រូវពិនិត្យជាបន្ទាន់ ។

- មិនចាំបាច់ទេ *យ៉ាប៊ូ-សាន* ។ លោកគួរមានទំនុកចិត្តជាងនេះ ។ គ្មានរឿងអ្វីដែលកើតឡើង ដោយលោកម្ចាស់យើងមិនដឹងនោះទេ ។ លោកម្ចាស់ច្បាស់ជានឹងបញ្ជូនអ្នកណាម្នាក់មកអង្កេតរឿងនេះជាមិនខាន ។ ចៃដន្យខ្ញុំត្រូវលោកម្ចាស់ចាត់តាំងមកទីនេះ ។ លោកមកដល់កន្លែងនេះប៉ុន្មានថ្ងៃហើយ ?

- មួយថ្ងៃមួយយប់

- អ៊ីចឹងលោកធ្វើដំណើរមកពី យេដូ តែពីថ្ងៃមកដល់ទីនេះរឺ ?

- បាទ ។

- លោកមកដល់រហ័សមែន ។ គួរតែសរសើរលោកហើយ ។

ដើម្បីចំនេញពេលផង *យ៉ាប៊ូ* ក៏ចាប់ផ្តើមរ៉ាយរ៉ាប់ប្រាប់ *ហ៊្សិរ-ម៉ាត់ស៊ុ* ពីដំណើររូតរះយ៉ាងបង្ខំរបស់ខ្លួន ប៉ុន្តែខួរក្បាលរបស់គេផ្តោតទៅលើបញ្ហាសំខាន់ៗរបស់ផ្សេងទៀត ។ អ្នកណាជាអ្នកយកការណ៍ ? ហេតុអ្វីបានជា *តូរ៉ាណាកា* បានទទួលពត៌មានពីសំពៅនេះ យ៉ាងរហ័សដូចគេដែរអ៊ីចឹង ? ហើយតើអ្នកណាប្រាប់ *តូរ៉ាណាកា* ថាគេចាកចេញពី *យេដូ* ? អីលូវនេះគេធ្វើយ៉ាងម៉េចដើម្បីទប់ទល់នឹងស្ថានភាពនេះផង ទប់ទល់នឹង *ហ៊្សិរ-ម៉ាត់ស៊ុ* ដែលនៅទល់មុខនឹងគេនេះផងនោះ ?

*ហ៊្សិរ-ម៉ាត់ស៊ុ* ស្តាប់ *យ៉ាប៊ូ* និយាយចប់ ទើបនិយាយមុតៗថា :

- លោកម្ចាស់ *តូរ៉ាណាកា* សំរេចរឹបអូសសំពៅ ហើយនឹងអីវ៉ាន់ទាំងអស់ដែលមាននៅលើសំពៅនេះ ។

ភាពស្ងៀមស្ងាត់ដ៏ព្រឺព្រួចបានគ្របដណ្តប់ពេញទីឆ្នេរ ។ ទីនេះគឺជា *អ៊ីស៊ូ* ពោលគឺជាដែនអំនាចរបស់ *យ៉ាប៊ូ* អ៊ីចឹងហើយ *តូរ៉ាណាកា* គ្មានសិទ្ធិអ្វីនៅទីនេះទេ ហើយ *ហ៊្សិរ-ម៉ាត់ស៊ុ* ក៏គ្មានសិទ្ធិបញ្ជាអ្វីនៅទីនេះផងដែរ ។ ដៃរបស់ *យ៉ាប៊ូ* ក្តាប់ដងដាវរបស់គេយ៉ាងណែន ។ *ហ៊្សិរ-*



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ាត់ស៊ី* អង្គុយរង់ចាំក្នុងសភាពស្ងាត់ស្ងៀមយ៉ាងធម្មតា ។ គេបានធ្វើអ្វីៗគ្មានខុសមួយសរសៃសក់ ពីបញ្ជារបស់ *តូរ៉ាណាកា* ឡើយ ។ ហើយគេត្រៀមខ្លួនជាស្រេច ។

សំលាប់ រឺត្រូវគេសំលាប់ ។ នេះជារឿងដែលគ្មានអ្នកណាចៀសផុតទេ ។

*យ៉ាប៊ូ* វិញក៏ដឹងខ្លួនយ៉ាងច្បាស់ដែរថា ពេលនេះគេត្រូវតែសំរេចចិត្តអោយបានដាច់ស្រេច ។ គ្មានរឿងរង់ចាំទៀតទេ ។ បើសិនជាគេប្រកែកមិនព្រមប្រគល់សំពៅ គេត្រូវតែសំលាប់ *ហ៊្សឺ-ម៉ាត់ស៊ី* កណ្តាប់ដៃដែក ព្រោះបុរសនេះមិនព្រមត្រលប់ទៅវិញ ដោយដៃទទេទេ។ នៅលើទូកធំប្រហែល ជាមានពួក *សាមូរ៉ៃ* ជើងឆើតពីររយនាក់ប៉ុណ្ណោះ ។ ពួកនោះក៏ត្រូវតែស្លាប់ទាំងអស់ដែរ ។ គេអាចហៅពួកទាំងនេះឡើងគោក ហើយល្បួងលួងលោមពួកវា ។ ក្នុងរយៈពេលតែប៉ុន្មានម៉ោង គេអាចប្រមូល *សាមូរ៉ៃ* គ្រប់គ្រាន់ពី *អាន់ជិរ៉ូ* ដើម្បីបង្ក្រាបពួកនេះព្រោះខ្លួនគេ គឺពូកែស៊ីដាច់ខាងសិល្បៈពួនស្ទាក់នោះ ប៉ុន្តែបើធ្វើអីចឹងដូចជាបង្ខំ *តូរ៉ាណាកា* អោយបញ្ជាទ័ពមកវ៉ៃ *អ៊ីស៊ូ* ជាមិនខាន ។ អ្ហែងត្រូវគេត្របាក់ តែមួយគ្រឹបទេអ្ហា ! -*យ៉ាប៊ូ*និយាយក្នុងចិត្ត -លើកលែងតែ *អ៊ីស៊ីដូ* មកជួយអ្ហែង ។តើហេតុអីបានជា *អ៊ីស៊ីដូ* មកជួយអែង បើអា *អ៊ីកាវ៉ា ជីគីយ៉ូ* ជាសត្រូវនឹងអ្ហែងនោះជាប់សាច់ញាតិនឹង*អ៊ីស៊ីដូ* ហើយកំពុងតែស្រក់ទឹកមាត់ចង់បាន *អ៊ីស៊ូ* សំរាប់ខ្លួនវាដែរនោះ ។ សំលាប់ *ហ៊្សឺ-ម៉ាត់ស៊ី* នឹងជាការចាប់ផ្តើមសង្គ្រាមពីព្រោះដោយថានេះ ជាបញ្ហាកិត្តិយស *តូរ៉ាណាកា* ត្រូវបង្ខំចិត្តវ៉ៃលុកមកលើអែង ដល់អីចឹងទៅ *អ៊ីស៊ីដូ* ច្បាស់ជាក់រីកដែរហើយ ទីបំផុត *អ៊ីស៊ូ* នឹងក្លាយទៅជាសមរភូមិដំបូងគេជាមិនខាន ។

រួចចុះកាំភ្លើងទាំងអស់របស់អញ នឹងទៅជាយ៉ាងណា ? កាំភ្លើងនឹងផែនការដ៏ល្អរបស់អញៗនឹងបាត់សំនាងមួយពាន់ឆ្នាំមានម្តងនេះ បើសិនជាអញប្រគល់កាំភ្លើងទាំងនេះទៅអោយ *តូរ៉ាណាកា* ។

ដៃរបស់គេ នៅតែស្ថិតលើដាវរបស់ជាងដែឯក *មូរ៉ាសាម៉ា* ។ គេមានអារម្មណ៍ថា ចរន្តឈាមកំពុងរត់កាត់ផ្ទៃដាវគេសស្រិប ហើយនៅក្នុងខ្លួនគេ សំរែកមួយបានប្រាប់គេអោយចាប់ផ្តើម ។ គេបានច្រានចោលនូវប្រការដែលគួរលាក់បាំងមិននិយាយពីរឿង មូស្កេ ។ បើសិនជាមានគេក្បត់លួចរាយការណ៍ពីរឿងសំពៅទៅហើយ គឺវាច្បាស់ជាគេ នឹងរាយការណ៍ផងដែរ ពីមុខ



www.budinst.gov.kh www.elibraryofcambodia.org

របស់របរ ដែលមាននៅលើសំពៅនោះហើយ ។ ប៉ុន្តែតើ *តូរ៉ាណាកា* ទទួលដំណឹងយ៉ាងលឿននេះតាមរបៀបណា ? ចំលើយមានតែមួយ គឺតាមព្រាបនាំសារ !តើព្រាបនាំសារពី *យេដូ* រឺពីទីនេះ? តើអ្នកណាមានព្រាបនាំសារ ? ហេតុអីក៏អញគ្មានព្រាបនាំសារដូចនេះ ? អានេះគឺជារឿងកំហុសរបស់ *ស៊ូគីម៉ូតូ* តែម្តង វាគួរតែគិតគូរពីរឿងនេះទើបត្រូវ ។

អីលូវនេះ សំរេចចិត្តម្តែងទៅមើល ! ច្បាំងរឺអត់ ?

តែសំរេចចិត្តដកថយ ។

- លោកម្ចាស់ *តូរ៉ាណាកា* មិនអាចរឹបអូសសំពៅនេះបានទេ ព្រោះវាជាជំនូនជូនលោកម្ចាស់ *តូរ៉ាណាកា* រួចទៅហើយនោះ ។ ខ្ញុំបាទអោយគេសរសេរលិខិតមួយជំរាបលោកម្ចាស់រួចទៅហើយ មិនថាអីចឹង *ស៊ូគីម៉ូតូ* ?

- ប្របាទ ! ពិតមែនហើយ !

- ពិតណាស់ បើសិនជាលោកម្ចាស់ *តូរ៉ាណាកា* ចាត់ថាសំពៅនេះជាផលនៃការរឹបអូសនោះ ក៏ស្រេចតែលោក ។ ប៉ុន្តែនេះគឺជាជំនូន -*យ៉ាប៊ូ* សែនរីករាយនៅពេលដែលគេលើសំលេងរបស់គេលាន់ឡើងដូចធម្មតា -លោកម្ចាស់ប្រហែលជារីករាយនឹង របស់នេះ ។

- ក្នុងនាមលោកម្ចាស់ ខ្ញុំសូមអរគុណលោក ។

ជាថ្មីម្តងទៀត *ហ៊ីរ៉ូ-ម៉ាត់ស៊ី* លួចស្ងើចការវិភាគរបស់ *តូរ៉ាណាកា* ។ លោកម្ចាស់បានព្យាកររឿងទាំងនេះហើយជាស្រេច ហើយលោកបានព្យាករថា នឹងគ្មានការប្រយុទ្ធគ្នាទេ ។ ពេលនោះ ខ្លួនគេបានតបវិញ :

- ខ្ញុំបាទមិនជឿទេលោកម្ចាស់ ! គ្មាន *ដៃមីញ៉ូ*ណាមួយ ឈរអោបដៃអោយគេរំលោភសិទ្ធិខ្លួនយ៉ាងនេះទេ ។ *យ៉ាប៊ូ* រឹតតែច្បាស់ទៅទៀត ។ ខ្ញុំក៏ទ្រាំមិនបានដែរ ។ តែលោកម្ចាស់ខ្លួនឯងក៏ទ្រាំមិនបានដែរ ។

- តែលោកត្រូវអនុវត្តបញ្ជាខ្ញុំ ហើយលោកត្រូវរាយការណ៍ពីរឿងសំពៅនេះ ដល់ខ្ញុំ ។ សំខាន់ត្រូវកៀង *យ៉ាប៊ូ* ណា ។ ខ្ញុំត្រូវការហិង្សា និងល្បិចកិច្ចកលរបស់វា ។ វាជាអ្នកទប់ទល់នឹង *អ៊ីកាវ៉ា ជីគីយ៉ូ* ហើយការពារឆ្អឹងជំនីរបស់ខ្ញុំ ។



www.budinst.gov.kh www.elibraryofcambodia.org

អីលូវនេះនៅលើឆ្នេរខ្សាច់ស្រោចស្រពដោយពន្លឺព្រះសុរិយា *ហ្ស៊ី-ម៉ាត់ស៊ី* បង្ខំចិត្តគោរពយ៉ាងគួរសម ប៉ុន្តែនៅក្នុងចិត្តលោកសែនស្អប់នឹងការចូលរួម ឃុបឃិតរបស់ខ្លួនលោកផ្ទាល់នេះជាពន់ពេក ។

- លោកម្ចាស់ *តូរ៉ាណាកា* ពិតជានឹងរីករាយចំពោះសប្បុរសធម៌របស់លោកនេះ ។

យ៉ាប៉ូ សំលឹងពិនិត្យទឹកមុខរបស់ *ហ្ស៊ី-ម៉ាត់ស៊ី* យ៉ាងម៉ត់ចត់ ។

- សំពៅនេះមិនមែនជារបស់ពួកប៉ុកទុយកាល់ទេ ។

- ត្រូវហើយ ។ យើងលឺគេថាអ៊ីចឹងដែរ ។

- នេះជាសំពៅពួកចោរសមុទ្រ !

*យ៉ាប៉ូ* ឃើញភ្នែករបស់ លោកមេទ័ពធ្វើព្រិម :

- ហ៊ឺស ?

ពេលដែលគេនិយាយដំណើរដើមទងតាមអ្វីដែលបព្វជិតបាននិយាយនោះ *យ៉ាប៉ូ* គិតនៅក្នុងចិត្តថា ដំណឹងដែលលោកមេទ័ពបានទទួល គឺដូចគ្នានឹងដំណឹងដែលអញបានដែរនេះគឺមិនមានន័យថា *តូរ៉ាណាកា* បានទទួលពត៌មានដើមដូចតែអញដែររឺអី ? តែបើអ្វែង ដឹងថាសំពៅមានអីខ្លះនោះ អ្នកអោយការណ៍មានតែ *អូមី* រឺជា សាមូរ៉ៃរបស់វាណាម្នាក់ រឺក៏អ្នកភូមិណាម្នាក់តែប៉ុណ្ណោះ ។

- នៅក្នុងសំពៅ មានខោអាវហូរហៀរ មានទ្រព្យសម្បត្តិខ្លះ មានមូស្កេ រំសេវ និងគ្រាប់ ។

*ហ្ស៊ី-ម៉ាត់ស៊ី* អេះអុញបន្តិចរួចសួរឡើង :

- ខោអាវធ្វើពីសូតចិនអ្វី ?

- ទេ *ហ្ស៊ី-ម៉ាត់ស៊ី-សាន* ។

អីលូវនេះគេប្រើពាក្យ " *សាន* " ជំនួស " *សាម៉ា* " វិញម្តង ។ ពួកគេសុទ្ធតែជា *ដៃមីញ៉ូ* ដូចគ្នាទេតើ ។ គេមានអារម្មណ៍ថា មានសន្តិសុខគ្រប់គ្រាន់ល្មមនឹងប្រើពាក្យគួរសមល្មម ។ តែសែនរីករាយ ដោយឃើញថា បុរសចាស់នេះ មិនបានកត់សំគាល់នូវបំលាស់ប្តូរពាក្យនេះ



www.budinst.gov.kh www.elibraryofcambodia.org

ឡើយ ។ អញតីជា *វ៉េមីញ៉ូ* ទៅ *អ៊ីស៊ូ* ណា !

- ខោអាវនេះមិនដែលឃើញទេ *-យ៉ាប៊ូ* បន្ត -ខោអាវក្រាស់ៗប្រើមិនកើតទេសំរាប់ពួកយើងនោះ ។ របស់ដែលសំខាន់នោះ ខ្ញុំសាងឡើងគោករួចអស់ហើយ ។

- ល្អ ។ ស្មើជញ្ជូនដាក់ទូកខ្ញុំទាំងអស់ទៅ !

- ថាម៉េច ? *-យ៉ាប៊ូ* មានអារម្មណ៍ដូចពោះគេស្ទើរផ្ទុះឡើង ។

- ទាំងអស់ ហើយអីលូវណឹង !

- អីលូវណឹង ?

- បាទ ! ខ្ញុំស្ដាយណាស់ តែលោកគួរដឹងហើយថា ខ្ញុំចង់ត្រលប់ទៅ *អូសាកា* វិញកាន់តែឆាប់កាលណាល្អកាលនោះ ។

- បាទ ។ តែ......តែ......តែតើមានកន្លែងគ្រប់គ្រាន់ដាក់អីវ៉ាន់ទេ ?

- ជញ្ជូនកាណុងទៅដាក់លើសំពៅ ពួកចុងស្រុកវិញ ហើយភ្ជិតអាច់ល័ខ .........ទៅបីថ្ងៃទៀត នឹងមាននាវាគេមកអូសវាទៅ *យេដូ* ហើយ ។ ចំនែកអារឿងមូស្កេ រំសេវ និងគ្រាប់យកវា..........

*ប៊្លែ-ម៉ាត់ស៊ី* ឈប់ស្ងៀមកណ្ដាលទី ដោយទើបដឹងថា លោកកំពុងតែផុងខ្លួនក្នុងអន្ទាក់ដែល *យ៉ាប៊ូ* បានដាក់នោះ ។ លោករំលឹកសំដី ដែល *តូរ៉ាណាកា* និយាយប្រាប់លោកមុនពេលចេញដំណើរ :

- កន្លែងលើទូក មានល្មមតែសំរាប់ដាក់មូស្កេទាំងប្រាំរយ រំសេវ និងខ្ទប្លុងប្រាក់ចំនួនពីររយពាន់តែប៉ុណ្ណោះ ។ទុកកាណុងនៅលើសំពៅ និងខោអាវក្នុងរមូរវាទៅ ។ទុកអោយ *យ៉ាប៊ូ* ជាអ្នកនិយាយ តែលោកជាអ្នកបញ្ជាវា កុំទុកអោយវាមានពេលគិតទាន់ ។ តែជាមួយវា កុំមួម៉ៅ កុំរហ័ន ។ខ្ញុំត្រូវការវា តែខ្ញុំក៏ត្រូវការសំពៅ ហើយនឹងកាំភ្លើងទាំងអស់ណឹង ។ លោកត្រូវប្រយ័ត្នអន្ទាក់វា ដែលធ្វើអោយលោកជ្រុលមាត់ និយាយប្រាប់វាថា យើងដឹងច្បាស់ពីចំនួនពិតប្រាកដនៃរបស់របរនៅក្នុងសំពៅនោះ ។ វាមិនត្រូវដឹងថា អ្នករាយការណ៍ជាអ្នកណាមួយទេណា !

*ប៊្លែ-ម៉ាត់ស៊ី* ជេរប្រទេចខ្លួនឯង ដែលដើរល្បិចដ៏ចាំបាច់នេះមិនកើត ។ លោកនិយាយ



www.budinst.gov.kh www.elibraryofcambodia.org

ពង្វាង :

- លោកប្រាប់ខ្ញុំមើលថា តើត្រូវការកន្លែងប៉ុន្មាន ? ហើយមានរបស់របរអីខ្លះ ? កាំភ្លើងមានប៉ុន្មាន ? វិសេវប៉ុន្មាន ? គ្រាប់ប៉ុន្មាន ? រួចចុះប្រាក់នោះជាដុំ រឺជាកាស ?

- *ស៊ូតីម៉ូតូ* !

- ប្របាទ ! *សាប៊ូ-សាម៉ា*

- យកបញ្ជីរបស់របរមក ! - អញចាត់ការអ្វែងពេលក្រោយ *យ៉ាប៊ូ* គិតនៅក្នុងចិត្ត ។

*ស៊ូតីម៉ូតូ* ប្រញាប់ចេញទៅភ្លាម ។

- លោកប្រហែលជាហត់នឿយហើយ *ហ៊ុីរ៉ូ-ម៉ាត់ស៊ឺ-សាន* ។ អញ្ជើញតែអ្វី ? កន្លែងសំរាកក៏រៀបចំរួចរាល់ហើយដែរ សំរាប់លោកសំរាក ។ កន្លែងមុជទឹកមិនសូវបានសមរម្យក៏ប៉ុន្តែយ៉ាងហោចណាស់ ក៏អាចអោយលោកបានត្រជាក់ខ្លួនបន្តិចបន្តួចដែរ ។

- អរគុណ ។ លោកគិតគួរបានសព្វគ្រប់ណាស់ ។ តែ និង ទឹកពិតជាល្អមែន ។ ចាំលើកក្រោយ ។ ដំបូងបង្អស់ សូមលោករ៉ាយរ៉ាប់ប្រាប់ខ្ញុំបន្តិចមើលថា តើមានរឿងអីកើតឡើង តាំងពីសំពៅណើងមកដល់នោះ ។

*យ៉ាប៊ូ* និយាយរឿងរ៉ាវទាំងអស់ លើកលែងតែរឿងនារីអ្នកកំដរភ្ញៀវ ដែលគេចាត់ទុកថា មិនមែនជារឿងសំខាន់នោះ ។ តាមបញ្ជា *យ៉ាប៊ូ អូមី* ក៏និទានពីរឿងរ៉ាវទាំងឡាយដែលគេឃើញ លើកលែងតែរឿងសន្ទនារបស់គេ ជាមួយ*យ៉ាប៊ូ*នោះ ហើយ *មូរ៉ា* ក៏និយាយរ៉ាយរ៉ាប់ពីព្រឹត្តិការណ៍ដែលគេបានជួបផងដែរ លើកលែងតែរឿងមុជទឹកតែប៉ុណ្ណោះ ។

*ហ៊ុីរ៉ូ-ម៉ាត់ស៊ឺ* សំលឹងមើលផ្សែងដែលនៅឆេះហុយ១ពីភ្នក់ភ្លើងនៅឡើយ ។

តើពួក ចោរសមុទ្រនៅសល់ប៉ុន្មាននាក់ទៀត ?

*អូមី* ឆ្លើយ :

- នៅសល់ដប់នាក់លោកម្ចាស់ ។ រាប់ទាំងមេពួកវាផង ។

- តើមេពួកវានៅឯណា ?

- នៅផ្ទះ *មូរ៉ា* ទាន ។



www.budinst.gov.kh www.elibraryofcambodia.org

- តើវាមានធ្វើអ្វីខ្លះ ? នៅពេលវាចេញពីអន្លង់ភ្លាម តើវាធ្វើអ្វី ?

- វាទៅកន្លែងមុជទឹកភ្លាមលោកម្ចាស់ -មូរ៉ាឆ្លើយតបយ៉ាងលឿន -អិលូវវាដេកដូចងាប់អ៊ីចឹងទាន ។

- មុជទឹកលើកនេះ អ្អែងឥតចាំបាច់សែងវាទេអ្អី ?

- អត់ទេទាន ។

- វារៀនបានរហ័សណាស់ដែរទេតើ !

រួច *ហ្ស៊ី-ម៉ាត់ស៊ី* ងាកសំលឹងមើលទៅ *អូមី* :

- អែងគិតថាអាចអប់រំវា អោយចូលចំនុំចំនោមគេចុះអ្អី ?

- ប្របាទ ! មិនច្បាស់ទេ *ហ្ស៊ី-ម៉ាត់ស៊ី-សាម៉ា*

- តើអែង អាចលាងជ្រះទឹកនោមសត្វវអែង អោយស្អាតចេញពីខ្លួនអែងបានទេ ?

- អត់ទេលោកម្ចាស់ !

- ខ្ញុំក៏អ៊ីចឹងដែរ ។ មិនជ្រះដាច់ខាត ។ ពួកចុងស្រុកអស់នេះគួរអោយចំលែកមែនតែម្រ៉ង ។

រួច *ហ្ស៊ី-ម៉ាត់ស៊ី* ទាញអារម្មណ៍របស់លោក មកផ្តោតលើសំពៅវិញម្តង :

- អ្នកណាជាអ្នកចាត់ចែងជញ្ជូនអីវ៉ាន់ដាក់ទូក ?

- *អូមី-សាន* ក្មួយខ្ញុំ ។

- ល្អ ! *អូមី-សាន* ខ្ញុំចង់ចេញដំណើរមុនព្រលប់នេះ ។ នាយទូក ខ្ញុំនឹងជួយអែងអោយកាន់តែរហ័សថែមទៀត ។ ក្នុងបីធូបណាំ !

- ប្របាទម្ចាស់ !

- *យ៉ាប៊ូ-សាន*ម៉េចក៏លោកមិនទៅ *អូសាកា* ជាមួយខ្ញុំតែម្តងទៅ ? -*ហ្ស៊ី-ម៉ាត់ស៊ី* និយាយបាក់ដូចជាគំនិតនេះ ទើបរត់កាត់ខួរក្បាលលោកអំបាញ់មិញអ៊ីចឹង-លោកម្ចាស់ *តូរ៉ាណាកា* ពិតជារីករាយណាស់ ដែលបានទទួលរបស់ទាំងនេះ ពីដៃរបស់លោកនោះ ។ អញ្ជើញលោក ! នៅលើទូកសល់កន្លែងទេ ។



www.budinst.gov.kh www.elibraryofcambodia.org

តាមការណែនាំរបស់ *តូរ៉ាណាកា* *ហ៊ិរូ-ម៉ាត់ស៊ី* ទុកអោយ *យ៉ាប៊ូ* ប្រកែកមួយស្របក់ ហើយ ទើបលោកចាប់និយាយបន្ត :

- ខ្ញុំសូមលោកអញ្ជើញទៅកុំខាន ។ ក្នុងនាមលោកម្ចាស់ *តូរ៉ាណាកា* ខ្ញុំសូមស្នើលោកអញ្ជើញទៅជាមួយខ្ញុំ យ៉ាងទទូចតែម្តង ។ សប្បុរសធម៌របស់លោកត្រូវតែទទួលបានរង្វាន់ទើបត្រឹមត្រូវ ។

យកក្បាលអញ និងដីអញជារង្វាន់ណឹងអ្វី ? *យ៉ាប៊ូ* សួរនៅក្នុងចិត្តយ៉ាងជូរចត់ ដោយគេដឹងច្បាស់ថា គេគ្មានជំរើសអ្វីក្រៅពីទៅតាមការអញ្ជើញនេះឡើយ :

- សូមអរគុណ ។ នេះគឺជាកិត្តិយសណាស់សំរាប់ខ្ញុំ ។

-ល្អ ។ អ្វីៗរៀបរយអស់ហើយអីចឹង -កណ្តាប់ដៃដែកពោលទាំងបង្ហាញភាពធូរទ្រូងយ៉ាងច្បាស់ក្រលែត -អីលូវយកតែមក រួចទៅមុជទឹក ។

*យ៉ាប៊ូ* នាំផ្លូវ *ហ៊ិរូ-ម៉ាត់ស៊ី* យ៉ាងគួរសម ដើរឡើងជំរាលភ្នំទៅផ្ទះរបស់ *អូមី* ។ មេទ័ពមុជទឹក ជូតសំអាតខ្លួន បន្ទាប់មកទៅទំរេតនៅបន្ទប់ចំហុយថែមទៀត ។ ក្រោយមក ម្រាមដៃរបស់តាចាស់ *ស៊ូរី* ធ្វើអោយលោកមានអារម្មណ៍កើតឡើងជាថ្មីម្តងទៀតតែម្តង ។

អស់រយៈពេលបីធូបមក ទ្វាររបើកឡើង ។ អង្គរក្សផ្ទាល់ ជាអ្នកដឹងជាងគេទាំងអស់ពីម៉ោង ពេលត្រូវចូលក្នុងបន្ទប់ ដោយមិនបាច់មានបញ្ជាហៅ ។ *ហ៊ិរូ-ម៉ាត់ស៊ី* ក្រោកហើយជាស្រេច ។ នៅក្បែរខ្លួនលោកដាវដែលហូតចេញពីស្រោមពាក់កណ្តាល ក៏ត្រៀមខ្លួនជាស្រេចដើម្បីផ្តាច់ជីវិតផងដែរ ។

- *យ៉ាប៊ូ-សាម៉ា* នៅរង់ចាំលោកម្ចាស់នៅឯក្រៅ ។ គាត់និយាយថា ទូកផ្ទុកអីវ៉ាន់រួចរាល់ ហើយទាន ។

- ល្អណាស់ ។

*ហ៊ិរូ-ម៉ាត់ស៊ី* ដើរចេញទៅរានហាល :

- មនុស្សរបស់លោក របស់របហូនមែន *យ៉ាប៊ូ-សាន* ។

- នេះបានក្រុមរបស់លោកជួយផងទេ *ហ៊ិរូ-ម៉ាត់ស៊ី-សាន* ។ មនុស្សរបស់លោក



www.budinst.gov.kh www.elibraryofcambodia.org

លើសពីរហ័សរហួនទៅទៀត ។

ពិតហើយៗ ថ្ងៃក្ដៅយ៉ាងនេះពួកវាត្រូវតែលឿនអីចឹងហើយ -*ហ៊ូ-ម៉ាត់ស៊ី* គិតនៅក្នុងចិត្ត ។ រួចទើបលោកពោលឡើង :

- តើគេមានយកអាមេពួកចោរសមុទ្រ ទៅទូកខ្ញុំហើយរឺនៅ ?

- ថាម៉េច ?

- លោកមានសន្ដានចិត្តល្អ ប្រគល់ទាំងសំពៅ ទាំងរបស់របរក្នុងសំពៅទៅជូនលោកម្ចាស់ អីចឹងហើយពួកនាវិកសំពៅ ក៏ជារបស់ក្នុងសំពៅដែរ ។ ដោយហេតុនេះហើយទើប ខ្ញុំនាំអាមេវាទៅ *អូសាកា* ។ លោកម្ចាស់ *តូរ៉ាណាកា* ចង់ឃើញវា ។ ចំពោះអ្នកឯទៀត លោកចង់ធ្វើម៉េចស្រេចតែលោក ។ ប៉ុន្តែសូមជំរាបថា នៅពេលអវត្តមានរបស់លោកៗត្រូវប្រាប់កូនចៅរបស់លោកទាំងអស់ អោយចាំច្បាស់ថា ពួកចុងស្រុកទាំងនោះ គឺជាកម្មសិទ្ធិរបស់លោកម្ចាស់ខ្ញុំ ដោយហេតុនេះ ត្រូវធ្វើយ៉ាងណាអោយពួកវានៅគ្រប់ទាំងប្រាំបួននាក់ មានសុខភាពល្អ នៅមានជីវិត ហើយមានវត្តមាននៅទីនេះ ពេលណាលោកម្ចាស់ខ្ញុំ ត្រូវការពួកវា ។

*យ៉ាប៊ូ* ដើរយ៉ាងលឿនសំដៅ ទំនប់រលកជាកន្លែងដែលគេគិតថា *អូមី* នឹងនៅទីនោះ ។

មុនពេលដែល *ហ៊ូ-ម៉ាត់ស៊ី* ជាប់ត្រាំទឹក គេបានដើរឡើងតាមជំរាលភ្នំ ដោយដើរក្បែរកន្លែងបូជាសពរបស់ *ពីតែស៊ូន* ។ គេអោនក្បាលគោរពកន្លែងនោះមួយភ្លែតទើបបន្ដដំណើរទៅទៀត តាមបណ្ដោយចំការស្រូវសាលី និងដំណាំហូបផ្លែ ដែលធ្វើជាថ្នាក់ៗតាមជំរាលនោះរហូតដល់វាលមួយដែលនៅទីខ្ពស់ពីភូមិ ។ រោងអ្នកតាមួយ ត្រូវបានគេសង់នៅទីកន្លែងនេះ ។ ដើមឈើចំនាស់មួយ បានព្រាចម្លប់ និងភាពសុខសាន្ត ដ៏ត្រជាក់ចិត្ត ។ *យ៉ាប៊ូ* មកទីនេះ ដើម្បីរំសាយកំហឹងរបស់គេផង ដើម្បីត្រិះរិះពិចារណាផង ។ គេមិនហ៊ានទៅជិតសំពៅ រឺ *អូមី* រឺកូនចៅរបស់គេឡើយ ព្រោះគេដឹងថា គេនឹងបញ្ជាអោយមួយចំនួនធំ បើថា មិនទាំងអស់ផ្ដាក់អោយ ធ្វើ *សិបពូគូ* ដែលជាការខាតបង់យ៉ាងធ្ងន់ធ្ងរ រឺពុំនោះសោត គេនឹងអោយសំលាប់ខ្មៅមនុស្សមួយភូមិនេះ ដែលជាអំពើដ៏លេលាបំផុត ព្រោះថា គឺមានតែអ្នកស្រែទេ ដែលចាប់ត្រី និងធ្វើ ស្រែ សំរាប់ចិញ្ចឹម សាមូរ៉ៃនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលដែលគេអង្គុយឆេះដុំ ហើយនិងសង់គិតនោះ ព្រះអាទិត្យបានជ្រេ ទៅទិសខាងលិច ហើយបានកំចាត់ចេញនូវរាល់ផ្សែងអ័ព្ទលើសមុទ្រទាំងឡាយ ។ ដុំពពកដែលពីមុន នេះបានគ្របដណ្តប់បាំងបិទជួរភ្នំ ដែលនៅឯទីឆ្ងាយនោះក៏ត្រូវបានបំបែកចេញ ហើយ *យ៉ាប៊ូ* អាចក្រលេកឃើញកំពូលភ្នំ គ្រប់ដណ្តប់ទៅដោយព្រិលនោះ ពោរពេញទៅដោយសំរស់មួយគួរជាទីស្រលាញ់ ។ ទិដ្ឋភាពទាំងនេះធ្វើអោយគេ អាចជំរះចិត្តមួម៉ងបាន ហើយគេក៏បន្ថយកំហឹង និងចាប់ផ្តើមប្រើខួរក្បាលដើម្បីពិចារណាវិញម្តង ។

ចាត់តាំងអ្នកយកការណ៍ ដើម្បីរកអោយឃើញអ្នកយកការណ៍ *-យ៉ាប៊ូ* និយាយនៅក្នុងចិត្តរបស់ខ្លួន ។ អ្វីៗដែល *ហ្ស៊ី-ម៉ាត់ស៊ី* និយាយឥតមានបង្ហាញអោយដឹងថា តើអំពើក្បត់មកពីភូមិនេះ រឺមកពី *យេដូ* សោះឡើយ ។ នៅឯ *អូសាកា* អែងមានពួកម៉ាកច្រើន ដែលសុទ្ធតែជាអ្នកមានអំនាច ហើយលោកម្ចាស់ *អ៊ីស៊ីដូ* ក៏ស្ថិតនៅក្នុងចំនោមនេះដែរ ។ អាចមានអ្នកណាម្នាក់ក្នុងចំនោមអ្នកទាំងនោះ ភាវរកមុខអាក្បត់នេះឃើញ ។ តើត្រូវបញ្ជូនលិខិតសំងាត់ទៅប្រពន្ធអ្អែងភ្លាម បើសិនជាអ្នកយកការណ៍នៅទីនោះ រឺយ៉ាងណា ? រួចចុះ *អូមី* វាយ៉ាងម៉េចដែរ ? ប្រគល់ភារកិច្ចអោយវាភាវរកមុខអាអ្នកយកការណ៍នៅទីនេះ រឺយ៉ាងម៉េច រឺមួយក៏វាជាអ្នកយកការណ៍ ? មិនប្រាកដទេ តែក៏មិនមែនថាមិនអាចនោះដែរ ។ មើលទៅអាចថាអារឿង ក្បត់នេះ ចាប់ផ្តើមពី *យេដូ* មកទេ ។ អានេះជារឿងពេលវេលា តែប៉ុណ្ណោះ ។ បើសិនណាជា *តូរ៉ាណាកា* ដឹងដំណឹងភ្លាមពីការមកដល់នៃសំពៅនេះ ច្បាស់ជា *ហ្ស៊ី-ម៉ាត់ស៊ី* ជាអ្នកមកដល់ទីកន្លែងនេះ មុនគេទៅហើយ ។ តែអ្អែង ក៏មានអ្នកយកការណ៍នៅ *យេដូ* ដែរ ទុកអោយពួកវានោះ វាបញ្ចេញស្នាដៃរបស់វាទៅចុះ ។

រួចចុះអារឿងពួកចុងស្រុកទាំងនោះ តើគិតយ៉ាងម៉េច ? អីលូវនេះវាគឺជាផលតែមួយដែលអ្អែងទទួលបានពីសំពៅនេះ ។ តើអាចប្រើវាធ្វើអីបានអីចេះ ? អូមែន ! អា *អូមី* វាមិនបានប្រាប់អ្អែងម្តងហើយ ? អ្អែងអាចប្រើចំនេះដឹងផ្នែកសមុទ្រ និងសំពៅរបស់វាដើម្បីតថ្លៃជាមួយ *តូរ៉ាណាកា* ដូរយកអាវុធបានដែរតើ ?

នៅមានលទ្ធភាពមួយទៀត នោះគឺដាក់ខ្លួនទាំងស្រុងចំនុះ *តូរ៉ាណាកា* ។ អ្អែង



www.budinst.gov.kh www.elibraryofcambodia.org

ប្រគល់ផែនការទៅអោយ *តូរ៉ាណាកា* ហើយសុំគេធ្វើជាអ្នកដឹកនាំកងកាំភ្លើង ដើម្បីកិត្តិយស របស់គាត់ ។ តែអ្នកចំនុះគេ មិនត្រូវសង្ឃឹមថា លោកម្ចាស់ខ្លួននឹងផ្តល់រង្វាន់ ចំពោះស្នាដៃ ខ្លួន រឺ ធ្វើដឹង ធ្វើលឺចំពោះស្នាដៃទាំងនេះឡើយ ។ បំរើ គឺជាកាតព្វកិច្ច កាតព្វកិច្ចគឺជា *សាមូរ៉ៃ* *សាមូរ៉ៃ* គឺអមតភាព ។ អាណឹងគឺជារឿងមួយល្អបំផុត *យ៉ាប៊ូ* គិតនៅក្នុងចិត្ត ប៉ុន្តែតើអញអាច ក្លាយជាអ្នកអណ្តាប់[៣៥] របស់ *តូរ៉ាណាកា* បានពិតប្រាកដទេ ? រឺមួយក៏ចំនុះ *អ៊ីស៊ីដូ* ?

ទេ មិនអាចទៅជាអ៊ីចឹងបានទេ ។ ជាសម្ព័ន្ធមិត្តបាន ជាអ្នកចំនុះគឺទេ !

ល្អ ! គិតយូរៗទៅ ពួកអាចុងស្រុកទាំងនេះ គឺជាជ័យភណ្ឌមួយយ៉ាងល្អ ។ គិតទៅ *អូមី* មានមតិត្រូវមែន ។

ពេលនោះ គេដូចជាមានអារម្មណ៍ធូរស្រាលជាងមុន ដោយហេតុនេះនៅពេល ដែល នីរសារមកប្រាប់គេថា ទូកត្រូវបានផ្ទុកអស់ហើយនោះ គេក៏បានរូតរះទៅជូនដំណឹងដល់ *ហ្សី- ម៉ាក់ស៊ី* ភ្លាម ។ អីលូវនេះគេទើបដឹងខ្លួនថា សូម្បីតែពួកចុងស្រុកទាំងនេះ ក៏គេបានបាត់បង់អស់ រលីងហើយដែរ ។

ពេលគេទៅដល់ទំនប់រលក ចិត្តរបស់គេពុះហុយហើយជាស្រេច ។

- *អូមី-សាន* !

- បាទ *យ៉ាប៊ូ-សាម៉ា* !

- ទៅយកអាមេពួកចុងស្រុកមកទីនេះ ។ ខ្ញុំយកវាទៅ *អូសាកា* ។ ចំពោះពួកអាអ្នក ឯទៀត ពេលខ្ញុំមិននៅ ត្រូវថែទាំវាអោយបានល្អ ។ ខ្ញុំចង់អោយពួកវាមានសុខភាពល្អ ហើយ ចូលចំនុំចំនោមគេចុះផង ។ បើត្រូវប្រើអន្លង់ ក៏ប្រើទៅ ។

តាំងពីទូកចំមកដល់ ខួរក្បាលរបស់ *អូមី* ច្របូកច្របល់ចាក់ស្រេះ ទន្ទឹមនោះគេ សែនបារម្ភចំពោះសន្តិសុខរបស់ *យ៉ាប៊ូ* ។

- លោកម្ចាស់ សូមអោយខ្ញុំបាទទៅជាមួយលោកម្ចាស់ផង ។ ខ្ញុំអាចជួយជាជំនួយដល់ លោកម្ចាស់បានណាំ !

---

(៣៥) : អ្នកដែលជាបរិពារ ( Vassal ) ក.អ.ប.



www.budinst.gov.kh www.elibraryofcambodia.org

-ទេ ! អ៊ីលូវនេះ ខ្ញុំចង់អោយអែងមើលថែទាំពួកអាចុងស្រុកទាំងនេះចុះ ។

- ខ្ញុំសូមអង្វរលោកម្ចាស់ ។ ទោះតិចក្ដី ទោះច្រើនក្ដី យ៉ាងហោចណាស់ក៏សូមអោយខ្ញុំ បានសងគុណលោកម្ចាស់ផង ។

- មិនចាំបាច់ទេ !

*យ៉ាប៊ូ* ឆ្លើយតបទាំងសំលេងមួយ ហួសពីការគួរសមធម្មតាទៅទៀត ។ គេនឹកឃើញថា គេបានតំលើងប្រាក់បៀវត្សរ៍របស់ *អូមី* ហើយនឹងពង្រីកដែនដីត្រួតត្រារបស់គេ អាស្រ័យប្រាក់ និងកាំភ្លើងដែលគេរឹបអូសយកពីសំពៅ ។ ប៉ុន្តែរបស់ទាំងអស់នោះ អ៊ីលូវរលាយសាបសូន្យទៅហើយ ។ តែនៅពេលឃើញយុវជននេះបង្ហាញនូវក្ដីកង្វល់របស់ខ្លួននោះ គេក៏មាន ចំហាយក្ដៅជាអចេតនាមួយមកនៅក្នុងអារម្មណ៍របស់គេ ។ មានអ្នកចំនុះ ដូចនេះអញអាចសាងចក្រភពមួយបាន -គេគិតនៅក្នុងចិត្ត ។ នៅពេលណាអញបានកាំភ្លើងអញមកវិញ *អូមី* នឹងទទួលដីកនាំមួយកងឯកភាពហើយ ។

-នៅពេលដែលសង្គ្រាមចាប់ផ្ដើមហើយ ខ្ញុំនឹងមានការងារដ៏សំខាន់មួយ សំរាប់អែង *អូមី-សាន* ។ អ៊ីលូវនេះអែងទៅយកអាចុងស្រុកនោះមក ។

*អូមី* យកអ្នកការពារបួននាក់ទៅជាមួយគេ ហើយនិង *មូរ៉ា* សំរាប់បកប្រែផង ។

☆ ☆ ☆

*ប្លាក់ថន* ត្រូវគេអង្រួនអោយភ្ញាក់ឡើងទាំងសើងមម៉ើង ។ ជិតមួយនាទីបានកន្លងទៅ ទំរាំគេភ្ញាក់ដឹងខ្លួនស្រួលបួល ។ នៅពេលដែលអ័ព្ទនៃសុបិនបានរលត់រលាយទៅ គេឃើញ *អូមី* ឈរសំលឹងមករកគេ ។

*សាមូរ៉ៃ* ម្នាក់ ទាញភួយចេញពីខ្លួនគេ ម្នាក់ទៀតអង្រួនគេអោយភ្ញាក់ដឹងខ្លួន ពីរនាក់ទៀតកាន់រំពាត់ឫស្សី ។ *មូរ៉ា* មានខ្សែមួយចុងកន្ទុយនៅដៃ ។

*មូរ៉ា* លុតជង្គង់ចុះ និងអោនក្បាលគោរព :



www.budinst.gov.kh www.elibraryofcambodia.org

- *កូនីជីវ៉ា* -សូស្តី ។

- *កូនីជីវ៉ា* !

ថ្វីត្បិតតែគេនៅអាក្រាតក្តី ក៏ *ប្លាក់ថន* ប្រញាប់ប្រញាល់ងើបលុតជង្គង់ និងលំអោន ះការពរិញយ៉ាងគួរសមដែរ ។

នេះគឺជាការគួរសម -*ប្លាក់ថន* និយាយទៅកាន់ខ្លួនឯងនៅក្នុងចិត្ត ។ នេះជាទំនៀមទំលាប់របស់ពួកគេ ហើយអោនខ្លួនគោរព គឺជាសុជីវធម៌របស់គេ ដូចនេះមិនមែនជាការអាម៉ាស់ទេដែលអ្នែងធ្វើតាមនេះ ។ អារឿងអាក្រាតពួកគេមិនរវីរវល់ទេ ហើយតាមទំនៀមទំលាប់ពួកនេះ អារឿងអាក្រាតមិនមែនជារឿងអាម៉ាស់នោះទេ ។

- *អាន់ជីន* សូមអញ្ជើញស្បែកពាក់ខោអាវ ។

*អាន់ជីន* ? អូ !អញទឹកឃើញហើយ ។ បព្ជិតបាននិយាយថា ពួកវាមិនអាចហៅឈ្មោះអញត្រូវ អ៊ីចឹងហើយទើបពួកវា អោយឈ្មោះនេះមកអញ ហើយបើកាលណាអញធ្វើល្អគេនឹងហៅអញថា *អាន់ជីន-សាន* - លោកតែកុង ។

កុំមើលអា *អូមី* -*ប្លាក់ថន* ប្រាប់ខ្លួនឯងនៅក្នុងចិត្ត។ កុំអាលសិន ។ កុំអាលរំលឹកពីទីធ្លាកូមិ ពី*អូមី*ពី*ត្រូក* ពី *ពីថែស៊ូន* ។ ដោះស្រាយរឿងម្តងមួយៗ ។ នេះជារឿងអ្នែងត្រូវធ្វើ ។

នេះជាការងារដែលអ្នែងបានស្បថចំពោះមុខព្រះ ។ ការសងសឹក នឹងនៅក្នុងកណ្តាប់ដៃអញ ។

*ប្លាក់ថន* បានឃើញខោអាវ របស់គេត្រូវបានបោកគក់សំអាតសាជាថ្មីម្តងទៀត ហើយនៅក្នុងចិត្តគេលួចជូនពរ យ៉ាងក្រាស់ក្រែលដល់អ្នកដែលបានបោកគក់ ខោអាវអោយគេនេះ ។ នៅឯបន្ទប់ទឹកគេបានដោះខោអាវគេចោល ប្រៀបដូចជាខោអាវមនុស្សគំលង់មួយ ហើយគេបានអោយអ្នកឯទៀតដុសខ្លងគេបីដងជាមួយនឹងថ្មស្អោត ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី គេនៅតែមានអារម្មណ៍ ពីភាពក្របាយនៃទឹកនោមនៅឡើយ ។

*ប្លាក់ថន* បង្វែរភ្នែកចេញពី *មូរ៉ា* ហើយសំលឹងទៅ *អូមី* ។ គេមានអារម្មណ៍រីករាយយ៉ាងគំនាច ដោយគេដឹងថា សត្រូវរបស់គេនៅរស់រានមានជីវិតនៅឡើយ ហើយនៅក្បែរខ្លួនគេ



www.budinst.gov.kh www.elibraryofcambodia.org

ថែមទៀត ។

គេលំអោនខ្លួន ហើយនិយាយឡើងនៅក្នុងស្ថានភាពនេះ :

- *គូនីជីវ៉ា អូមី-សាន*

មិនត្រូវខ្មាសអៀន ក្នុងការនិយាយភាសាពួកវា គ្មានខ្មាសអៀនក្នុងការនិយាយពាក្យ "សួស្តី" ក្នុងការលំអោនខ្លួនគោរពមុនតាមទំនៀមទំលាប់របស់ពួកវាឡើយ ។

*អូមី* លំអោនខ្លួនតបវិញ ។

*ប្លាក់ថន* កត់សំគាល់ថា ការលំអោនខ្លួនរបស់ *អូមី* មិនបានទាបស្មើនឹងគេឡើយ ប៉ុន្តែគេចាត់ថាគ្រប់គ្រាន់នៅពេលនេះទៅចុះ ។

- *គូនីជីវ៉ា អាន់ជីន -អូមី* តប ។

សំលេងមានភាពគួរសម តែក៏មិនចូនដល់កំរិតគួរសមរបស់វានៅឡើយដែរ ។

- *អាន់ជីន-សាន* !

ប្លាក់ថន បន្ថែមពាក្យ ដោយសំលឹងមើលចំក្រសែភ្នែករបស់ *អូមី* ។ ក្នុងមួយរយៈនោះឆន្ទៈរបស់បុរសទាំងពីរ បានប៉ះទង្គិចគ្នាយ៉ាងគំហុក ។

- *គូនីជីវ៉ា អាន់ជីន-សាន* !

នៅទីបំផុត *អូមី* ព្រមនិយាយឡើងដោយមានលាយទាំងស្នាមញញឹមមួយភ្លែតផង ។

*ប្លាក់ថន* ស្លៀកពាក់ខោអាវយ៉ាងប្រញាប់ប្រញាល់ ។

*ប្លាក់ថន*ស្លៀកខោស៊ុលឃុលមួយ ពាក់ស្រោមជើង និងអាវ ហើយថែមអាវក្រៅមួយជាន់ពីលើទៀត ។ សក់ក្បាលដ៏វែងរបស់គេ ត្រូវបានចងជាកន្ទុយសេះ ហើយពុកមាត់របស់គេត្រូវបានកាត់ដោយមានរបៀបរៀបរយ អាស្រ័យកន្ត្រៃដែលគេបានខ្ចីពីជាងកាត់សក់មក ។

- *ហៃ អូមី-សាន* ?

*ប្លាក់ថន* សួរទៅ *អូមី* នៅពេលដែលគេស្លៀកពាក់រួច ។ គេមានអារម្មណ៍ស្រួលបួលជាងមុន តែគេនៅតែប្រយ័ត្នខ្លួនជាប់ ហើយស្តាយដោយគេមិនចេះភាសា បានច្រើនជាងពាក្យប៉ុន្មានម៉ាត់នេះ ។



www.budinst.gov.kh www.elibraryofcambodia.org

- សូមទោស ដៃ ! - *មូរ៉ា* ពោលឡើង ។

ដោយគេមិនយល់ថា *មូរ៉ា* ចង់និយាយពីអ្វីនោះ *ប្លាក់ថន* ក៏ធ្វើជាសញ្ញាប្រាប់ទៅ *មូរ៉ា* វិញ ។ *មូរ៉ា* ហុចដៃខ្លួនឯងទៅមុខ ហើយធ្វើសញ្ញាចងផ្ដោបគ្នា ។

- សូមទោស ដៃ !

- ទេ !

*ប្លាក់ថន* និយាយពាក្យនេះត្រង់ទៅរក *អូមី* ដោយទាំងគ្រវីក្បាលផង រួចគេនិយាយភាសាអង់គ្លេស បន្តទៀត :

- មិនចាំបាច់ទេ ។ មិនចាំបាច់ទាល់តែសោះ ។ ខ្ញុំបានសន្យាហើយៗនេះគឺគ្រប់គ្រាន់ - គេខំថ្លមស័ដីគេ អោយមានភាពសុភាពជាទីបំផុត រួចទើបគេបន្ថែមយ៉ាងកំបុត ដោយធ្វើត្រាប់តាម *អូមី* :

- *វ៉ាការីម៉ាស៊ូកា អូមី-សាន* ? លោកយល់ទេ ?

*អូមី* សើចរួចពោលឡើង :

- ហៃ *អាន់ជីន-សាន វ៉ាការីម៉ាស៊ូ* !

បន្ទាប់មកគេបែរខ្នង ហើយចាកចេញទៅ ។ អ្នកឯទៀតតាមសំលឹង *អូមី* ទាំងភ្ញាក់ផ្អើល ។ *ប្លាក់ថន* ដើរតាម *អូមី* ក្រោមពន្លឺថ្ងៃ ។ ស្បែកជើងកវែងរបស់គេ ត្រូវបាន ជូតសំអាតហើយស្រេច ហើយនៅមុនពេលដែលគេពាក់វានោះ អ្នកបំរើ " *អាណា* " បានមកលុតជង្គង់ជួយពាក់ស្បែកជើងអោយគេភ្លាម ។

- អរគុណ *ហាតូ-សាន* !

*ប្លាក់ថន* និយាយទៅកាន់នាង ដោយគេទើបរំលឹកចាំពីឈ្មោះពិតប្រាកដរបស់នាង ។ តែគេកំពុងតែខំរកពាក្យអ្វី ដែលអាចនិយាយថា " អរគុណ " មិនបានសោះ ។

រួចគេដើរតំរង់ទៅរកទ្វារចេញ ដោយមាន *អូមី* ជាអ្នកនាំមុខ ។

អញតាមអ្អែងជាប់ហើយអាកូនមី ......ឈប់សិន ! អ្អែងចាំពាក្យសន្យារបស់អ្អែងទេ ? ហេតុអីចាំបាច់ជេរវាធ្វើអី ? វាឥតបានជេរអ្អែងទេ ។ ការជេរបញ្ចោរគឺ សំរាប់អ្នកទន់ខ្សោយ



www.budinst.gov.kh www.elibraryofcambodia.org

អ្នកល្ងិល្ងើទេតើមិនអីចឹង ?

ដោះស្រាយរឿងម្ដងមួយ ។អីលូវនេះអែងតាមវាជាប់ តែប៉ុណ្ណោះគឺគ្រប់គ្រាន់ហើយ ។ អែងដឹងរឿងនេះច្បាស់ណាស់ ហើយវាក៏ដឹងរឿងនេះច្បាស់ណាស់ដែរ ។ ហើយ *អូមី* ខ្លួនវាក៏ដឹងច្បាស់ណាស់ថា វាមិនត្រូវធ្វើការភាន់ច្រលំអ្វីឡើយ ។

*សាមូរ៉ៃ* ទាំងប្អូនអម *ភ្លាក់ថន* ជាប់នៅពេលដែលគេចុះជំរាលភ្នំមក ។ *មូភ៊ា* ដើរពីក្រោយ ពួកគេប្រហែលដប់ជំហាន ។ *អូមី* ដើរពីមុខ ។ នៅកន្លែងនេះគេមិនទាន់មើលឃើញកំពង់ផែនៅឡើយទេ ។

អាពួកនេះយកអញទៅញាត់អន្លង់វិញទេដឹង ? *ភ្លាក់ថន* ដណ្ដឹងសួរនៅក្នុងចិត្ត ។ ហេតុអីបានជាពួកវាចង់ចងដៃអញ ? តើអា *អូមី* វានិយាយពីម្សិលមិញ....ឱ ! ព្រះអើយព្រះ ! ទើបតែពីម្សិលមិញសោះ ........... វាថា " បើអែងស្រួលបួល អែងអាចនៅក្រៅអន្លង់បាន តែបើអត់ទេ មនុស្សម្នាក់ទៀត នឹងត្រូវអូសចេញពី............តើវាប្រុងធ្វើអីចឹងអ្វី ? តើអញបានធ្វើស្រួលបួល រឺក៏អត់អីចេះ ? រួចចុះអា *ភ្លូក* វាយ៉ាងម៉េចទៅហើយ ? អាទូចណឹងវានៅរស់ទេ នៅពេលដែលពួកអាអំបែងក្បាលទាំងនោះ យកវាចេញពីថ្លាងទៅដាក់នៅផ្ទះ ដែលវាស្នាក់នៅពីដំបូងទីនោះ ។

ថ្ងៃនេះ *ភ្លាក់ថន* មានកំលាំងកំហែងស្រួលបួលជាងមុន ។ ទឹក ការសំរាក និងម្ហូបស្រស់ៗ បានស្ដារកំលាំងរបស់គេឡើងវិញហើយ ។ គេដឹងខ្លួនថា បើគេចេះប្រយ័ត្នប្រយែង ហើយអាចដេក និងទទួលទានគ្រប់គ្រាន់ ក្នុងរយៈពេលតែមួយខែប៉ុណ្ណោះ គេអាចរត់ និងហែលទឹកបានមួយម៉ៃ ហើយអាចបញ្ជាសំពៅចំបាំងឡើងវិញ និងអាចបើកវាមួយជុំផែនដីបានដូចដើមហើយ ។

តែកុំរវាលគិតអារឿងនេះ ថ្ងៃនេះធ្វើម៉េចរក្សាកំលាំងអ្នែងអោយបានល្អទៅ មួយខែមិនមែនជាយូរប៉ុន្មានទេ មិនអីចឹង ?

ដំណើរចុះភ្នំ និងដើរកាត់ភូមិនេះ ធ្វើអោយគេហេវហត់ជាខ្លាំង ។ គិតទៅអ្នែងខ្សោយជាងស្មានទៅទៀត...... ទេ អ្នែងខ្លាំងជាងអ្នែងស្មានទៅវិញទេ -គេខំបញ្ជាចិត្តរបស់គេ............



www.budinst.gov.kh www.elibraryofcambodia.org

ដងក្តោងសំពៅ *អេវ៉ាស* លេចចេញលើដំបូលក្បឿង របស់ផ្ទះអ្នកភូមិ ។ បេះដូង របស់ *ប្លាក់ថន* លោតញាប់រន្ថើន ជាងមុនទៅទៀត ។ នៅពីមុខរបស់គេផ្លូវបត់កោងតាមជើងភ្នំ ហើយមកបញ្ចប់នៅត្រង់ទីធ្លាភូមិ ។ គ្រែស្នែងមួយដែលមានវាំងននបាំងជិត នៅឈប់ស្ងៀម ក្រោមកំដៅថ្ងៃ ។ អ្នកសែងបួននាក់ ដែលស្លៀកខោស្លាប់ភ្លៅមួយនោះ នៅអង្គុយចោងហោង អ៊ិះធ្មេញធ្វើវាហ៊ី ។ ពេលដែលពួកគេក្រលេកឃើញ *អូមី* ពួកគេស្ទុះក្រោកឡើងយ៉ាងប្រញាប់ ហើយអោនក្បាលគោរព *អូមី* យ៉ាងស្វាហាប់ ។

*អូមី* ងក់ក្បាលបន្តិចតែប៉ុណ្ណោះ នៅពេលដែលគេដើរជិតអ្នកទាំងនោះ ប៉ុន្តែខណៈនោះ យុវតីម្នាក់បានដើរចេញពីទ្វារតូចមួយ ហើយដើរសំដៅទៅគ្រែស្នែង ធ្វើអោយ *អូមី* ឈប់ទ្រឹងមួយរំពេច ។

*ប្លាក់ថន* ហាក់ដូចបាត់ដង្ហើម ហើយគេក៏ឈប់ទ្រឹងភ្លាមដែរ ។

នារីអ្នកបំរើដ៏ក្មេងម្នាក់ស្ទុះចេញមកតំលោះឆត្រពណ៌បៃតងមួយ ដើម្បីបាំងកំដៅថ្ងៃដល់យុវតីអំបាញ់មិញនេះ ។ *អូមី* អោនខ្លួន ហើយនារីនោះ ក៏លំអោនសងវិញ ។ បន្ទាប់មកអ្នកទាំងពីរនាក់ ក៏ជជែកគ្នាយ៉ាងសប្បាយ ។ ភាពក្រអឺតក្រទមរបស់ *អូមី* បានរលាយបាត់អស់ហើយ ។

យុវតីនោះ ពាក់គីម៉ូណូពណ៌ផ្កាឈូកស្រាល និងមានអូប៊ីទឹកមាសមួយជុំព័ទ្ធនៅចង្កេះ ។ នាងពាក់ស្បែកជើងសង្រែក ដែលមានខ្សែទឹកមាសដែរ ។ ប្លាក់ថន ឃើញនាងគួរអោយភ្ញាក់ផ្អើល រូបគេមួយភ្លែតដែរ ។ ច្បាស់ណាស់ថា នាង និង *អូមី* កំពុងជជែកគ្នាពីរឿងរបស់គេហើយ ។ គេមិនដឹងថា តើត្រូវមានអាកប្បកិរិយាបែបណា ហើយត្រូវធ្វើយ៉ាងដូចម្តេច ដោយហេតុនេះហើយគេឥតធ្វើអ្វីទាំងអស់ ក្រៅពីរង់ចាំយ៉ាងអត់ធ្មត់ និងសំលឹងមើលយ៉ាងគ្រេកគ្រអាល នូវសំរស់របស់នារីនេះតែប៉ុណ្ណោះ ។ គេដណ្តឹងសួរខ្លួនឯងថា តើ *អូមី* និងនារីនោះជាគូសង្សានឹងគ្នា រឺក៏នាងជាប្រពន្ធ *អូមី* ។

*អូមី* សួរសំនួរមួយដល់នាង១ឆ្លើយតបបណ្តើរ បក់ផ្លិតដែលជះពន្លឺរេរាំក្រោមពន្លឺថ្ងៃបណ្តើរ ។ សំនើចរបស់នាងពិរោះរណ្តំ ប្រៀបដូចជាសំលេងភ្លេងស្នេហ៍ គួរអោយទាក់ចិត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

*អូទី* ញញឹមពព្រាយ បន្ទាប់មកគេបែរខ្លួន ហើយបន្តដំណើរទៅទៀត ។ គេបានក្លាយខ្លួន ជាសាមូរ៉ៃវិញហើយ ។

*ប្លាក់ថន* បន្តដំណើរតាម *អូទី* ទៅទៀត ។ យុវនារីតាមសំលឹងមើលគេឥតដាក់ភ្នែក ។ ពេលគេដើរជិតនាង ប្លាក់ថន ក៏បន្លឺឡើង :

- *កូនីជីវ៉ា*

នារីនោះឆ្លើយតប :

- *កូនីជីវ៉ា អាន់ជីន-សាន* !

សំលេងនាង គួរអោយរំជួយដល់បេះដូង ។ នាងមានកំពស់ប្រហែលមួយម៉ែតកន្លះប៉ុណ្ណោះ ប៉ុន្តែសំរស់នាង គឺស៊ីផ្តាច់តែម្តង ។

ពេលដែលគេដើរដល់ផ្លូវបត់ទៅហើយ ក្លិនពិដោររបស់នារីនៅតាមជាប់ច្រមុះគេនៅឡើយ ។ នៅពេលនោះហើយដែលគេប្រទះឃើញឃ្លុប ឃើញ*អេរ៉ាស* ហើយនឹងទូកធំ ។ រូបភាពយុវនារីរលាយបាត់ឈឹងពីអារម្មណ៍របស់គេ ។

រួចម៉េចបានជានៅលើសំពៅទទេស្អាតយ៉ាងនេះ ? រួចចុះកាណុងទាំងអស់ទៅណាទៅ? រួចចុះអាទូកចែវនេះវាមកធ្វើអី ? តើមានរឿងអីនៅក្នុងឃ្លុបនោះ ?

ដោះរឿងម្តងមួយ១ ។

ដំបូងសំពៅ *អេរ៉ាស* ។ បង្គោលក្តោងមុខត្រូវព្យុះវាយបាក់ ។ តែនេះមិនសំខាន់ទេ-គេគិតនៅក្នុងចិត្ត ។ យើងអាចបើកវាចេញទៅលំហសមុទ្រយ៉ាងងាយ ។ យើងអាចលើកយុថ្កា ហើយខ្យល់ពេលល្ងាច និងទឹក ជំនោរសមុទ្រ អាចរុញសំពៅយើងចេញដោយស្រួល ។ យើងនឹងជុំសជុលសំពៅនៅឯចុងកោះនោះ ។ តាមច៉ាន់មើលយើងត្រូវការកន្លះថ្ងៃទេ ដើម្បីជួសជុលក្តោង ។ នៅពេលរួចរាល់ហើយកាលណា យើងបង្ហូតក្តោង ដាក់មេប្រិបតែម្តង ។ យកល្អមិនបាច់ទំលាក់យុថ្កាទេ ។ ប៉ុន្តែតើកងជើងសំពៅឯណាទៅ ? អ្នែងតែម្នាក់ឯងធ្វើម៉េចបញ្ជាសំពៅបាន ?

រួចចុះអាទូកធំនេះមកពីណាគេ ? រួចហេតុអីបានជាមកដល់ទីនេះ ? នៅឯលើផៃ *ប្លាក់*



www.budinst.gov.kh www.elibraryofcambodia.org

*ថន* ឃើញពួក *សាមូរ៉ៃ* និងពួកនាវិកខ្លាប់ ។ ទូកនេះមានដងចែវហុកសិប -ម្ភៃ សាមសិប-ហើយមានលក្ខណៈថៃទាំយ៉ាងស្អាត ។ ដងចែវត្រូវបានដាក់ចុះយ៉ាងស្មើ មើលទៅហាក់ដូចជា ប្រុងចេញដំណើរភ្លាម១យ៉ាងដូច្នោះដែរ ។ ទិដ្ឋភាពនេះធ្វើអោយ *ប្លាក់ថន* ស្រៀវឆ្អឹងខ្នង ជាសភាវគតិ ។ ទូកចែវដែលគេបានជួបប្រទះជាចុងក្រោយ គឺកាលពីឆ្នាំមុន នៅឯឆ្នេរមាស (៣៥ ស្ទួន) នោះគឺជាទូកចែវរបស់ ពួកឈ្មួញសមុទ្រ ប៊ិកទុយកាល់ ដ៏មានម្នាក់ ។ នាវានេះបានរត់ចេញ ពីសំពៅគេ ដោយរត់បញ្ច្រាសខ្យល់ ។ សំពៅ *អេរ៉ាស* ពេលនោះ មិនអាចដេញទាន់ មិនអាចចាប់បាន ហើយសូម្បីតែបាញ់ពន្លិច ក៏មិនបានផង ។

ប្លាក់ថន ស្គាល់ឆ្នេរសមុទ្រតំបន់អាព្រិចខាងជើងយ៉ាងច្បាស់ដូចបាតដៃ ។ ជាងដប់ឆ្នាំមកហើយ ដែលគេបើកបរសំពៅសំរាប់ក្រុមហ៊ុនឈ្មួញ *បាបារី* (៣៦) នៅទីក្រុងឡុង ។ នេះគឺក្រុមហ៊ុនមួយ ដែលគ្រប់គ្រងនាវាជំនួញប្រដាប់អាវុធ ដើម្បីគេចការហ៊ុមព័ទ្ធរបស់ អេស្ប៉ាញ ហើយនិងរកស៊ីតាមឆ្នេរ *បាបារី* ។ គេបានបើកបរសំពៅគ្រប់ទិសទី តាមឆ្នេរអាព្រិចខាងជើង ។ កាលនោះសមុទ្រ *មេឌីទែរ៉ាណេ* គឺមហាគ្រោះថ្នាក់សំរាប់នាវាហូឡង់ ។ នៅទីនោះនាវាអេស្ប៉ាញ និងប៊ិកទុយកាល់ ដែលជាសត្រូវមានច្រើនកុះករ ហើយដែលកាន់តែអាក្រក់ទៅទៀតគឺចក្រភព *អូតូម៉ាន់* (៣៧) ដែល បើកទូកចែវ និងនាវាចំបាំងរបស់ខ្លួន កកូរកកាយផ្ទៃសមុទ្រនោះ ។

របររកស៊ីនេះបានធ្វើអោយគេ កាក់កបគ្រាន់បើ ហើយគេបានទិញសំពៅរបស់គេផ្ទាល់

---

*(៣៥ស្ទួន) (Gold Coast) ឆ្នេរសមុទ្រទ្វីបអាព្រិច ដែលបច្ចុប្បន្នជាភាគមួយនៃប្រទេសកាណា Ghana- ( ក.អ.ប ) ។*

*(៣៦ ) តំបន់មួយដែលលាតសន្ធឹងពី ម៉ារ៉ុក អាល់សេរី ទុយនេស៊ី រហូតដល់ ទ្រីប៉ូលី ហើយជាមជ្ឈមណ្ឌលនៃចោរសមុទ្រ ( ក.អ.ប ) ។*

*( ៣៧ ) ចក្រភព តួគី ក្នុងសម័យដើម ដែលបន្តតំណសន្តិវង្សអូស្មាន់ ( ក.អ.ប ) ។*



www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនមួយដើម្បីរកស៊ីខ្លួនឯង ។ ប៉ុន្តែសំពៅគេត្រូវលិច ហើយគេបានបាត់បង់អ្វីៗទាំងអស់ដែលគេមាន ។ កាលនោះសំពៅរបស់គេជួបប្រទះនឹងទូកចែវ តួគី ក្នុងពេលដែលគេនៅត្រង់តំបន់ស្ងប់ខ្យល់នៃកោះ *សាកដែញ* (៣៨) ។ ការប្រយុទ្ធមានសភាពស៊ីសាច់ហុតឈាម តាំងពីពេលព្រឹករហូតដល់ពេលព្រលប់ ។ ពេលនោះឆ្លាល់ទូករបស់ពួកតួគី បុកត្រូវកន្សៃសំពៅរបស់គេ ហើយតែក្នុងមួយស្របក់ប៉ុណ្ណោះ ពួកគេត្រូវចាញ់ប្រៀបភ្លាម ។ គេនៅចាំនឹងត្រចៀកនៅឡើយ នូវសំរែក " អាឡាឡាឡាឡាឡា " របស់ពួកសត្រូវនៅពេលដែល ពួកនេះបាក់ចូលមកសំពៅរបស់គេ ។ ពួកនោះប្រដាប់ទៅដោយដាវ និងមួស្កេ ។ គេបានផ្ដុំមនុស្សទាំងអស់ ហើយរុញការវាយលុកលើកទីមួយអោយថយក្រោយបាន តែនៅលើកទីពីរ ពួកខ្មាំងមានចំនួនច្រើនលើសលប់ ទើបគេបញ្ជាអោយដុតឃ្លាំងគ្រាប់របស់សំពៅ ព្រោះគេគិតថា សុខចិត្តស្លាប់ប្រសើរជាជាងត្រូវគេចាប់ទាំងរស់ យកទៅធ្វើជាទាសករចែវទូក ដែលជាវាសនា របស់អ្នកដើរសមុទ្រភាគច្រើន ដែលត្រូវគេចាប់បាននោះ ។

នៅពេលដែលឃ្លាំងគ្រាប់ផ្ទុះឡើង បាតសំពៅរបស់គេ ត្រូវរយះខ្ទេចខ្ទី ហើយទូករបស់ខ្មាំងក៏ត្រូវខូចខាតមួយភាគដែរ ។ ក្នុងពេលជ្រួលច្របល់នោះ គេបានហែលទៅរកទូកសង្គ្រោះតូចមួយ ហើយរត់រួចជាមួយពួកនាវិកគេបួននាក់ទៀត ។ *ព្លាក់ថន* នៅចាំសំរែកសុំអោយជួយរបស់នាវិកសំពៅគេ ដែលមិនអាចហែលមករកគេបាន ។ ប៉ុន្តែគេមិនអាចជួយអ្នកទាំងនោះបានទេ ហើយគេគ្មានវាសនាអ្វីក្រៅពីស្លាប់ រឺក្លាយទៅជាអ្នកចែវទូកនោះឡើយ ។ គេនិងនាវិកសំពៅទាំងបួននាក់ ជាអ្នកដែលមានសំនាងជាងគេនៅថ្ងៃនោះ ។ ពួកគេបានមកដល់ក្រុង *កាគ្លីយ៉ារី* នៃកោះ *សាកដែញ* ហើយបន្ទាប់មកពួកគេបានត្រលប់ទៅផ្ទះវិញ ដោយគ្មានមួយកាក់សោះនៅនឹងហោប៉ៅ ។

រឿងនេះ បានកន្លងទៅប្រាំបីឆ្នាំទៅហើយ ។ នេះជារឿងដែលកើតឡើងទន្ទឹមនឹងជំងឺប៉េស បានរាតត្បាតទីក្រុងឡុងម្ដងទៀតដែរ ។ ប្អូនប្រុសពៅ និងគ្រួសាររបស់គេត្រូវស្លាប់គ្មាន

---

(៣៨) Sadinia កោះមួយនៃប្រទេសអ៊ីតាលី ក្នុងសមុទ្រ មេឌីទែរ៉ាណេ ( ក.អ.ប ) ។



www.budinst.gov.kh www.elibraryofcambodia.org

សល់ ។ កូនច្បងរបស់គេ ក៏ត្រូវបាត់បង់ជីវិត ក្នុងគ្រានោះដែរ ។ ជំងឺប៉េស បាន រលាយបាត់ទៅវិញ ហើយគេរកបានសំពៅមួយទៀត យ៉ាងងាយដើម្បីចេញស្ដារទ្រព្យឡើង វិញ ។ ដំបូងគេធ្វើការអោយក្រុមហ៊ុន *បាគរី* នៃទីក្រុងឡុង បន្ទាប់មកគេទៅម៉្គុំឥណ្ឌា ខាងលិចដើម្បីតាមកំទេចពួក អេស្ប៉ាញ ។ ក្រោយពីគេមានបានបន្តិចហើយ គេបានធ្វើការ អោយជនជាតិ ហូឡង់ម្នាក់ឈ្មោះ *ភាវ៉ាម៉ាន់* ដើម្បីធ្វើដំណើរជាលើកទីពីរស្វែងរកច្រក អីសាន ដ៏ល្បីល្បាញដូច រឿងនិទាន ដើម្បីទៅ *កាតៃ* និងកោះគ្រឿងទេសនៅ អាស៊ី ហើយដែល គេដំណាលថា ច្រកនេះ ស្ថិតនៅក្នុងសមុទ្រទឹកកក ភាគខាងជើងនៃប្រទេស រុស្ស៊ី ។ ពួក គេរុករកអស់ជាងពីរឆ្នាំ រហូតដល់ *ភាវ៉ាម៉ាន់* ហើយនិងនាវិកជាង ប៉ែបសិបភាគរយត្រូវ ស្លាប់បាត់បង់ជីវិត នៅក្នុងសមុទ្រ ទឹកកកនោះទៅ ។ *ហ្វាក់ថន* ក៏បានសំរេចនាំអ្នកនៅសល់ ទាំងប៉ុន្មាន ត្រលប់មកស្រុកវិញ ។ លុះបីឆ្នាំមុននេះ ក្រុមហ៊ុន ទើបបង្កើតថ្មី ឈ្មោះ ក្រុមហ៊ុន បូព៌ាឥណ្ឌារបស់ហូឡង់ បានមកទាក់ទងគេ ដើម្បីដឹកនាំដំណើរទៅកាន់ ពិភពថ្មី ។ ពួក គេបានលួចខ្សឹបប្រាប់ *ហ្វាក់ថន* ថា ពួកគេបានចំនាយប្រាក់ជាច្រើន ដើម្បីទិញកូនសៀវភៅ សំងាត់របស់ពួគ ប៉ក់ទុយកាល់ ដែលបានប្រាប់ពីអាថិកំបាំង នៃច្រកសមុទ្រ *ម៉ាសេឡង់* ហើយ ពួកគេចង់ដឹងថា ពតិមាននេះជាការពិតរឺអត់ ។ ជាការពិតពួកនេះ ចង់ប្រើជនជាតិហូឡង់ ដូចគ្នាច្រើនជាង ប៉ុន្តែសមត្ថភាពរបស់អ្នកទាំងនោះមិន អាចផ្ទឹមបានជាមួយនឹងជនជាតិ អង់គ្លេស ដែលទទួលការរឹកហាត់ពីសមាគមផ្គាច់មុខ *ទ្រីនីទីហូស* ឡើយ ហើយតំលៃ ដ៏សំបើម នៃកូនសៀវភៅនេះ បង្ខំអោយពួកគេត្រូវតែប្រថុយចាក់លើ *ហ្វាក់ថន* នេះឯង ។ ហើយនេះក៏ មិនមែនជាចៃដន់ដែរ ។ *ហ្វាក់ថន* គឺជាជំរើស ដ៏សុក្រិតមួយ ។ គេជាអ្នកបើកសំពៅកាន់ និកាយប្រូតេស្តង់ដ៏ឆ្នើមជាងគេ ដែលនៅមានជីវិត ។ ម្ដាយគេសញ្ជាតិហូឡង់ ហើយគេនិយាយ ភាសាហូឡង់ យ៉ាងស្ទាត់ទៀតផង ។

នៅពេលគេស្នើ *ហ្វាក់ថន* បានទទួលយល់ព្រមយ៉ាងរីករាយ ។ តំលៃដែលគេបានឯក ភាពគ្នា គឺដប់ប្រាំភាគរយ នៃប្រាក់ចំនេញ ហើយដូចជាសព្វដង គេបានស្បថស្បែថា នៅតែមាន ស្វាមីភក្តិចំពោះក្រុមហ៊ុន និងធានានាំសំពៅត្រលប់មកស្រុកវិញ នៅពេលចប់បេសកកម្មហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

ច្បាស់ជាអីចឹង ។ អញនឹងនាំ *អេវ៉ាស* ទៅដល់ស្រុកវិញជាមិនខាន ។ យកទាំងស្ត្រីនៅ យកទាំងអ្នកដែលព្រះទុកជីវិតអោយនៅទាំងប៉ុន្មាន ។

អីលូវនេះពួកគេ កំពុងដើរកាត់ទីធ្លា ហើយ *ប្លាក់ថន* ក៏ដកភ្នែកគេចេញពីទូកធំនេះ ។ គេប្រទះឃើញ *សាមូរ៉ៃ* បីនាក់កំពុងនៅយាមឃ្លុប ។ ពួកគេកំពុងទទួលទានអាហារ ដោយចង្កឹះឈើ ដែល *ប្លាក់ថន* បានឃើញគេប្រើប្រាស់ ជាច្រើនដងមកហើយ ៗ ដែលខ្លួនគេរៀនប្រើមិនកើតនោះ ។

- *អូមី-សាន*

*ប្លាក់ថន* ធ្វើសញ្ញាប្រាប់ *អូមី* ថាគេចង់ទៅឃ្លុបមាត់អន្លង់ គ្រាន់តែស្រែកអោយដំណឹងទៅមិត្តភក្តិ របស់គេតែប៉ុណ្ណោះ ។ គេប្រាប់ថា សុំតែមួយភ្លែតទេ ។ ប៉ុន្តែ *អូមី* គ្រវីក្បាលនិយាយប៉ុន្មានម៉ាត់ តែ *ប្លាក់ថន* ស្តាប់មិនបានថា គេចង់និយាយពីអ្វីសោះ រួចគេក៏បន្តដំណើរទៅមុខទៀត កាត់ទីធ្លារហូតទៅដល់ទំនប់រលក ។ *ប្លាក់ថន* ដើរតាមតគ្រុក ដោយឥតប្រកែកប្រណាំងអីទាំងអស់ ។

ដោះស្រាយរឿងម្តងមួយ១ ! ត្រូវចេះអត់ធ្មត់ !

នៅពេលគេមកដល់ទំនប់រលកហើយ ទើប *អូមី* បែរក្រោយ ហើយស្រែកបញ្ជាទៅឆ្មាំឃ្លុប ។ ប្លាក់ថនឃើញពួកឆ្មាំបើកឃ្លុបឡើង ហើយអោនសំលឹងទៅក្រោម ។ *សាមូរ៉ៃ* ម្នាក់ធ្វើសញ្ញាទៅពួកអ្នកភូមិ អោយគេយកជណ្តើរ និងទឹកមួយធុង ទៅអោយខ្លួន ហើយយូរចុះទៅក្រោម ។ បន្តិចក្រោយមក គេយូរធុងទទេមួយ ព្រមទាំងធុងបន្ទោរបង់ ឡើងមកវិញ ។

ឃើញទេ ? អោយតែអ្ហែងចេះអត់ធ្មត់ ហើយទទួលលេងល្បែងរបស់ពួកវា អ្ហែងអាចជួយ ក្រុមរបស់អ្ហែងបាន គេគិតទាំងពេញចិត្តនឹងខ្លួនឯង ។

*សាមូរ៉ៃ* មួយក្រុមបានមកផ្តុំគ្នា ជារង្វង់ក្បែរទូកធំ ។ មនុស្សមាឌធំម្នាក់នៅឈរដាច់ពីគេពីឯង ។ គ្រាន់តែឃើញអាការៈគោរពរបស់ *ដៃមីញ៉ូ យ៉ាប៊ូ* និង អាការៈដែលអ្នកផងខ្វែងដៃខ្វែងជើងបំពេញ រាល់កំនត់សំគាល់ របស់បុរសចាស់ម្នាក់នេះ *ប្លាក់ថន* ដឹងមួយរំពេច ពីសារសំខាន់ នៃបុរសចាស់នេះ ។ តើតាណឹងជាស្តេច របស់ពួកវាទេដឹង ? គេដណ្តឹងសួរខ្លួនឯង ។



www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

*អូមី* លុតជង្គង់ចុះ យ៉ាងសុភាពបំផុត ។ បុរសចាស់ លំអោនខ្លួនបន្តិច ហើយចោលភ្នែកសំលឹងមករក *ប្លាក់ថន* ។

ដោយប្រឹងអាចុនស្រស់បំផុត ប្លាក់ថនលុតជង្គត់ចុះដោយដាក់បាតដៃទាំងទ្វេទៅលើដីខ្សាច់នៃទំបន់រលកដូចជា *អូមី* ហើយគេអោនក្បាលយ៉ាងទាបដូចជា *អូមី* ដែរ គេបន្លឺសំលេងយ៉ាងសុភាព :

- *កូនីជីវ៉ា សាយ៉ា* !

គេឃើញបុរសចាស់អោនបន្តិចជាថ្មីម្តងទៀត .

ពេលនេះគឺកិច្ចសន្ទនាគ្នារវាង *យ៉ាប៊ូ* បុរសចាស់និង *អូមី* រួច *យ៉ាប៊ូ* និយាយទៅកាន់ *មូរ៉ា* ។ *មូរ៉ា* ចង្អុលទៅទូកធំ :

- *អាន់ជីន-សាន* សូមអញ្ជើញទៅនោះ ។

- ហេតុអ្វី ?

- ទៅ ! អីលូវណឹង ! ទៅ !

*ប្លាក់ថន* មានអារម្មណ៍ដូចជាព្រលឹងព្រលះគេរត់ចេញអស់ ។ *អូមី* ចេញបញ្ជាដោយចង្អុលទៅទូកធំ :

-*អ៊ីស្វូគិ* !

- ទេ ! ខ្ញុំមិនខ្ចីទៅឡើង...

*អូមី* ចេញបញ្ជាមួយរ៉ាស ។ *សាមូរ៉ៃ*បួននាក់ហក់សង្រ្គប់ *ប្លាក់ថន* ហើយក្របួចដៃជាប់ ។ *មូរ៉ា* ដកយកខ្សែ ហើយចាប់ផ្តើមចងដៃគេទៅក្រោយ ។ *ប្លាក់ថន* ស្រែកជំទាលឡើង :

- អាកូនមីចោរ ! អញមិនខ្ចីឡើងអាទូកចោលម្រាយអ្នែងនេះទេ !

- ព្រះមាតាម្ចាស់អើយ ! នែ ! លែងគេទៅ ! យីពួកអាស្វាស៊ីអាច់នេះ លែងអាកូនអត់ពូជនេះទៅ ! *គីនជ៉ី* នេ ? ក្រែងវាជាតែកុងអ្វី ! ជា *អាន់ជីន កា* ?

*ប្លាក់ថន* ស្ទើរតែមិនជឿត្រចៀករបស់គេឡើយ ។ ពាក្យជេរប្រទេច ជាប៉ុកទុយកាល់ នេះ បានលាន់លឺពីលើទូកធំនោះមក ។ បន្ទាប់មក គេឃើញបុរសម្នាក់ចុះជណ្តើរមក ។



www.budinst.gov.kh www.elibraryofcambodia.org

បុរសនេះ មានមាឌដូចជាគេដែរ ហើយអាយុទៀតសោតក៏ស្របាលនឹងគេ ខុសតែបុរសនេះមានសក់ខ្មៅ ភ្នែកខ្មៅ ហើយស្បែកពាក់យ៉ាងខ្ចីខ្ចាជានាវិក ។ ដាវសោបមួយនៅម្ខាងខ្លួនគេ ហើយនៅចង្កេះរបស់គេ មានកាំភ្លើងខ្លីពីរបីថែមទៀតផង ។ គេពាក់មួកជាមេបញ្ជាការនាវាជំនួញ ។

-អ្នែងជាតៃកុងមែនរឺ ? ជាតៃកុងរបស់ពួកហូឡង់មែនទេ ?

- បាទ !

- ល្អ ! ល្អ ! ខ្ញុំឈ្មោះ *វ៉ាស្កូ រ៉ូឌ្រិច* ជាតៃកុងទូកនេះ !

រួចបុរសនេះងាកទៅរកបុរសចាស់ ហើយនិយាយលាយជប៉ុនខ្លះ ប៉កទុយកាល់ ខ្លះ ។ គេហៅបុរសចាស់ម្ដង *ស្វា-សាម៉ា* ម្ដង *តូដា-សាម៉ា* ប៉ុន្តែគេកាច់សំនៀងតាមភាសារបស់គេអោយលឺសូរទៅជា*សរ៉ាម-សាមអ៊ែ*ទៅវិញ ។ គេដកកាំភ្លើងខ្លីរបស់គេភ្ជង់ *ប្លាក់ថន* យ៉ាងសាហាវឃោរឃៅពីរដងរួចគេញាត់ទៅចង្កេះគេវិញទាំងពីរដង ។ ភាសាជប៉ុនរបស់គេលាយច្របល់ដោយភាសាប៉កទុយកាល់គំរាំងថៃត ដែលមានតែអ្នកដើរសមុទ្រជើងចាស់ទេ ដែលស្ដាប់យល់បាននោះ ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ី* ចេញបញ្ជាយ៉ាងកំបុត ហើយពួក*សាមូរ៉ៃ* ក៏លែង *ប្លាក់ថន* វិញ

*មូរ៉ា* ក៏ស្រាយចំនងចេញពីដៃ *ប្លាក់ថន* ។

- អើបើអីចឹងទៅវាស្រួលជាង ។ នែ ស្ដាប់ខ្ញុំតៃកុង អាតាប៊ិនេះដូចជាស្ដេចអីចឹង ។ ខ្ញុំប្រាប់វាថា ខ្ញុំទទួលខុសត្រូវលើរូបអ្នែង ហើយខ្ញុំប្រាប់វាថា ខ្ញុំនឹងបាញ់បែកក្បាលអ្នែងយ៉ាងរហ័សដូចខ្ញុំរហ័សផឹកជាមួយអ្នែងអីចឹង ។

*រ៉ូឌ្រិច* លំអោនខ្លួនគោរព *ហ៊ីរ៉ូ-ម៉ាត់ស៊ី* បណ្ដើរ និយាយបណ្ដើរទៅកាន់ *ប្លាក់ថន* :

- នែ ! អោនគោរពអាកូនមីចោរ-*សាម៉ា* ហ៊ឹងទៅ !

*ប្លាក់ថន* ធ្វើតាមទាំងអារម្មណ៍វវើរវាយដូចក្នុងយល់សប្ដិ ។

- យី អ្នែងធ្វើដូចពួកអាជប៉ុនតយនេះមែនតែម្រ៉ង-*រ៉ូឌ្រិច* និយាយទៅកាន់ *ប្លាក់ថន* ទាំងចំអក-អ្នែងពិតជាតៃកុងមែនអ្ហី ?



www.budinst.gov.kh www.elibraryofcambodia.org

- មែន !

- រយៈទទឹងបង្គួយ ?

- សែសិបប្រាំបួនអង្សាហាសិបមួយនាទីខាងជើង ហើយប្រយ័ត្នថ្មបំប្រេះមាត់ទឹកនៅត្បូង-ត្បូង-លិច ។

- អ្អែងពិតជាតៃកុងមែន សាធុ សាធុ-*រ៉ូវ៉េរិច* ចាប់អង្រួនដៃ *ប្លាក់ថន* យ៉ាងរំភើប-តោះឡើងលើទូក ។ ខ្ញុំមានគ្រឿងស៊ីចុកនៅលើនោះ ។ ខ្ញុំនៅមានកូញាក់ ស្រា និង ស្រាវ៉ូមកំដៅពោះ ។តៃកុងទាំងអស់ត្រូវចេះស្រលាញ់គ្នា ព្រោះពួកយើងជាមេអាសន្នរោគនៅលើផែនដីនេះមិនថាអីចឹង ? អនុមោទនា !

- ត្រូវហើយ ! -*ប្លាក់ថន* ឆ្លើយតបយ៉ាងខ្សាវ ។

- ពេលខ្ញុំលឺថា ត្រូវយកតៃកុងម្នាក់ត្រលប់ទៅជាមួយយើងវិញ ខ្ញុំថាចំម៉ាច់តែម្តង ។ ច្រើនឆ្នាំហើយដែលខ្ញុំមិនបានព្រោកប្រាជ្ញ ជាមួយតៃកុងមែនទែននោះ។ តោះឡើងទូករួចម៉េចបានជាអ្អែងជ្រៀតចូលតាមច្រកម៉ាឡាការួច? រួចម៉េចបានជាអ្អែងគេចរួចពីកងល្បាតប្រចាំមហាសមុទ្រឥណ្ឌាបាន ? អ្អែងលួចកូនសៀវភៅអ្នកណាគេរឺ ?

- អ្អែងនាំខ្ញុំទៅទីណាហ្នឹង ?

- ទៅអូសាកា ។ លោកម្ចាស់កំពុងចង់ជួបអ្អែងណាំ !

ជាថ្មីម្តងទៀតព្រលឹងព្រលះទាំងប៉ុន្មានរត់ចេញពីខ្លួន *ប្លាក់ថន* ទៀត :

- អ្នកណាគេ ?

- *តូរ៉ាណាកា* ! ស្តេចត្រាញ់លើខេត្តទាំងប្រាំបីចោលម្រាយវាហ្នឹង ! វាគឺជាមេ *ដៃមីញ៉ូ* នៅជប៉ុន ! *ដៃមីញ៉ូ* ដូចជាស្តេចរឺ ក៏ដូចម្ចាស់សក្តិភូមិអីចឹង តែវាគ្រាន់បើជាងផង ។ ពួកវាសុទ្ធតែពួកផ្តាច់ការតែទាំងអស់ហ្នឹង ។

- តើគេចង់បានអីពីខ្ញុំ ?

-ខ្ញុំមិនដឹងដែរ តែនេះគឺជាដើមហេតុនៃវត្តមាន របស់ពួកយើងនៅទីនេះ ។ បើកាលណា *តូរ៉ាណាកា* ចង់ជួបអ្អែងហើយគាត់នឹងជួបអ្អែង ។ គេថាមានពួកអាងាប់ភ្លែកតឹងណើងរាប់



www.budinst.gov.kh www.elibraryofcambodia.org

ហាននាក់ ដែលសុខចិត្តស្លាប់ ដើម្បីកិតអាច់អោយវា បើសិនណាជាវាចង់ណាំ... អ្នកបកប្រែនិយាយប្រាប់ខ្ញុំថា " *តូរ៉ាណាកា* ចង់អោយលោកយកតែកុងមកទីនេះ " ។ យកទាំងតែកុងយកទាំងរបស់របរក្នុងសំពៅ ។ យកតា *ហ្ស៊ី-មាត់ស៊ី* ទៅជាមួយផង ដើម្បីពិនិត្យសំពៅអីចឹងតាម ខ្ញុំដឹង គឺទាំងសំពៅ ទាំងរបស់របរក្នុងសំពៅត្រូវតែរឹបអូសយកតែទាំងអស់ហ្នឹង ។

- រឹបអូស ?

- ប្រហែលពាក្យមាត់ចាបមាត់ព្រាបទេក៏មិនដឹង ។ ពួកអាជប៉ុនតយនេះជូនរឹបអូសដៃម្ខាង ហុចទៅវិញដៃម្ខាងក៏មានដែរ រឺជួនកាលវានិយាយថា វាមិនដែលមានបញ្ហាអីផង ។ ពិបាកយល់មែនអាកូនមីចោរអត់ពូជអស់នេះ ។

*ប្លាក់ថន* ចាប់អារម្មណ៍ថា ក្រសៃភ្នែករបស់ *ហ្ស៊ី-មាត់ស៊ី* កំពុងពិនិត្យសង្កេតមើលជំរៅនៃចិត្តរបស់គេ ។ គេខំលាក់ភាពញ័ររបស់គេនៅក្នុងចិត្ត ។ *រ៉ូឌ្រិច* សំលឹងតាមក្រសៃភ្នែករបស់គេ ។

- មែនហើយ វានៅលែងស្ងៀមហើយ ។និយាយប៉ុណ្ណឹងល្មមហើយ ។ តោះឡើងទូក ។ រួចគេបែរខ្លងត្រលប់ទៅទូក ប៉ុន្តែ *ប្លាក់ថន* ឃាត់គេ ។

- រួចចុះពួកខ្ញុំគិតយ៉ាងម៉េច ?

- អ្នកាស ?

*ប្លាក់ថន* និយាយប្រាប់ *រ៉ូឌ្រិច* យ៉ាងសង្ខេបពីរឿងអន្ទង់ ។ *រ៉ូឌ្រិច* ក៏សួរទៅ *អូមី* ជាភាសាជប៉ុនដូចឆ្នាចូលត្រលោក រួចគេនិយាយមកប្រាប់ *ប្លាក់ថន* វិញ :

- វានិយាយថា ពួកទាំងនោះមិនអីទេ ។ នែ ! ស្ដាប់ខ្ញុំណាំ ! រឿងនេះទាំងអ្ហែង ទាំងខ្ញុំគ្មានធ្វើអ្វីកើតទេ ។ អ្ហែងគ្មានធ្វើអ្វីក្រៅពីរង់ចាំតែប៉ុណ្ណោះ ។ ជាមួយពួកអាតយអស់នេះគេថា ម៉េចក៏មិនព្រមដែរ ។ ពួកអាអស់នេះមានមុខប្រាំមួយ បេះដូងបីឯណោះ ។

និយាយផង *រ៉ូឌ្រិច* លំអោនខ្លួនគោរព *ហ្ស៊ី-មាត់ស៊ី* របៀបពួកមន្ត្រីអីរ៉ុប រួចហើយគេពោលបន្តទៅ *ប្លាក់ថន* :

- យើងធ្វើរបៀបនេះនែនៅជប៉ុន ។ ធ្វើដូចពួកយើងនៅវាំងព្រះចៅ *ភីលីបទីពីរ*



www.budinst.gov.kh www.elibraryofcambodia.org

អីចឹង ។ ឱ ! សូមអាស្តេចអេស្ប៉ាញរបស់យក៏នេះឆាប់ចូលមឈូសអោយឆាប់ទៅ !

គេនាំមុខ *ប្លាក់ថន* ឡើងទៅលើទូក ។ *ប្លាក់ថន* សែនងឿងឆ្ងល់ដោយឃើញថា នៅលើទូកនេះគ្មានទាសករ គ្មានច្រវាក់អីទាំងអស់ ។

- រួចកើតអីហ្នឹង ? អ្នែងឈឺអ្វី ? - *វ៉ុឡ្វើច* សួរ ។

-ទេ ! ខ្ញុំគិតថា នេះជាទូកទាសករ ។

- នៅជប៉ុនគ្មានទាសករទេ ។ ទោះជានៅក្នុងអណ្តូងរ៉ែក្តី ។ យីពូកវានេះបានចំជាលេលាមែនហើយ ។ ខ្ញុំមិនដែលឃើញពួកណាឡប់សតិដូចពួកនេះទេ ហើយនេះខ្ញុំធ្លាប់ដើរព័ទ្ធផែនដីបីជុំរួចហើយ ។ ពួកជើងថែវទាំងនេះសុទ្ធតែជាសាមូរ៉ៃទាំងអស់ ។ ពួកវាជាទាហាននៃកងទ័ពផ្ទាល់របស់អាកញ្ជាស់ក្បាលអាច់នោះណា ។ ហើយខ្ញុំប្រាប់អ្នែងណា គ្មានទាសករណាចែវល្អជាងពួកនេះទេ ហើយរឹតតែគ្មានទាហានណាប្រយុទ្ធល្អជាងពួកវានេះដែរ-*វ៉ុឡ្វើច*សើច-ពួកវាដាក់តែក្តិតអង្គុយចុះហើយវ៉ៃតែម្តង ។ ខ្ញុំសាករុញពួកវាអោយចែវលឿនជាងមុន ដោយខ្ញុំចង់ឃើញពួកវាលេចអាច់នៅនឹងកន្លែងតែម្រ៉ង ពួកអាអស់នេះអត់ញោចអត់ងើបពីកៅអីសោះតែម្រ៉ង ។ គិតមើលពួកយើងមកត្រង់តាំងពី អូសាកាមក...ជាងបីរយម៉ៃក្នុងសែសិបម៉ោង ។ មក៏!ចុះក្រោមជាមួយខ្ញុំ ។ យើងចេញដំណើរអីលូវនេះហើយ ។ អ្នែងច្បាស់ថាអត់អីហើយអ្វី ?

- បាទ ! បាទ ! ខ្ញុំគិតថាបែបមិនអីទេមើលទៅ ។

*ប្លាក់ថន* បែរភ្នែកសំលឹងមើលសំពៅ *អេរ៉ាស* ដែលនៅប្រហែលជាមួយរយម៉ែតពីនេះ ។

- តែកុងតើគ្មានផ្លូវឡើងទៅលើសំពៅនោះបានទេអ្វី ? ពួកនេះព្រមអោយខ្ញុំឡើងទេ រួចខ្ញុំអត់មានខោអាវតិចតួចណាសោះ ។ ម្យ៉ាងទៀតពួកវាភ្ញិតល័ក្ខតាំងពីសំពៅមកដល់ភ្លាមម្លេះ ។ ជួយខ្ញុំផង !

*វ៉ុឡ្វើច* ពិនិត្យមើលសំពៅ

- អ្នែងបាត់ដងក្តោងមុខពីអង្កាល់ណា ?



www.budinst.gov.kh www.elibraryofcambodia.org

- មុនដល់ដីគោកបន្តិច

- មានដងបន្ទាស់នៅលើសំពៅទេ ?

- មាន

- ផែដើមរបស់សំពៅនៅឯណា ?

- រ៉ូទែដាំ ។

- គេសាងវានៅកន្លែងណុងអ្វី ?

- ណឹងហើយ !

- ខ្ញុំធ្លាប់ទៅកន្លែងណុងដែរ ។ សំពៅអ្អែងរាងល្អណាស់ ។ ធុនថ្មីថែមទៀត ។ ខ្ញុំមិនដែលឃើញសំពៅធុននេះពីមុនទេ ។ ម៉ែអ្អើយ ! សំពៅនេះបែបលឿនណាស់ លឿនអស់ពីចិត្តតែម្ដង ។ អាធុននេះពិបាកលេបហើយ ។

*រូច រ៉ូទ្រិច* សំលឹងមើល *ប្លាក់ថន* :

- តើអ្អែងអាចប្រមែប្រមូលអីវ៉ាន់អ្អែងអោយរហ័សបានទេ ?

*រ៉ូទ្រិច* ចាប់កែវខ្យាច់កន្លះម៉ោងផ្កាប់ដាក់ជាថ្មី ។

- រហ័ស !

*ប្លាក់ថន* ខំទប់កំសួលនៃក្ដីសង្ស័យ កុំអោយលេចចេញតាមមុខបាន ។

- ត្រូវមានលក្ខខណ្ឌមួយណាតែកុង ។ គ្មានអាវុធទាំងនៅក្នុងដៃអាវ ទាំងនៅកន្លែងណាទាំងអស់ ។ អ្អែងសន្យាក្នុងនាមជាតែកុងម្នាក់ណាំ ! ខ្ញុំបានប្រាប់ពួកអាស្វាអស់នោះហើយថា ខ្ញុំទទួលខុសត្រូវលើរូបអ្អែងណាំ !

- យល់ព្រម !

*ប្លាក់ថន* ឆ្លើយបណ្ដើរ សំលឹងមើលដីខ្សាច់ដែលហូរធ្លាក់ទៅដបក្រោមយ៉ាងស្ងាត់ស្ងៀមបណ្ដើរ ។

- នែ ! ខ្ញុំនឹងបាញ់បំបែកក្បាលអ្អែងចោលភ្លាម ទោះអ្អែងជាតែកុង រឺមិនមែនតែកុងក៏ដោយ អោយតែអ្អែងហ៊ានលេងល្បិចជាមួយខ្ញុំ ហើយខ្ញុំនឹងអារកអ្អែងភ្លាមអោយតែអ្អែងរត់



www.budinst.gov.kh www.elibraryofcambodia.org

គេច លីហើយរឺនៅ ?

- ខ្ញុំសូមសន្យាជាមួយអ្អែង ។ ក្នុងឋានៈយើងជាតៃកុងដូចគ្នា .

*រ៉ូឡឺច* ញញឹមហើយទះខ្នង *ប្លាក់ថន* យ៉ាងស្និទ្ធស្នាល :

- ខ្ញុំដូចជាចាប់ផ្តើមចូលចិត្តអ្អែងហើយនេះ *អ៊ិញគីលីស* !

- ម៉េចបានអ្អែងដឹងថា ខ្ញុំជាអង់គ្លេស ?

ជាការពិតដែល *ប្លាក់ថន* ត្រូវសួរសំនួរនេះ ពីព្រោះគេដឹងថា ភាសា ប៉កទុយកាល់របស់គេ គឺឥតខ្ចោះ ហើយអ្វីដែលគេនិយាយ ក៏មិនបានមានលក្ខណៈអ្វី ដែលធ្វើអោយសំគាល់បានថា គេមិនមែនជាជនជាតិហូឡង់ដែរ ?

*រ៉ូឡឺច* សើចចំពោះសំនួរនេះ

- ខ្ញុំជាគ្រូទាយណា ! ក្រែងតៃកុងណាក៏ចេះទាយដែរអ្វី ? មិនថាអីចឹង ?

-អែងបាននិយាយជាមួយបព្វជិតនោះរឺ ? *សេបាស្ទូ* និយាយប្រាប់អែងមែនទេ?

- ខ្ញុំមិននិយាយជាមួយពួកបព្វជិតទេ លើកលែងតែចៀសមិនផុត ។ ម៉ាអាទិត្យជួបសូត្រធម៌ម្តងនោះ គឺវាមហាគ្រប់គ្រាន់ណាស់ទៅហើយ ចំពោះមនុស្សនោះ ។

និយាយរួច *រ៉ូឡឺច* ដើរទៅអើតនៅឯតែមទូក :

- *សំរាម-សាម៉ា អ៊ីគីម៉ាស្ទ-កា ?*

-*អ៊ីគីម៉ាស្ទ រ៉ូឡឺច-សាន ! អ៊ីម៉ា !*

- ចំអាអ៊ីម៉ានេះតែម្រ៉ង !

ពោលបណ្តើរ *រ៉ូឡឺច* សំលឹងទៅកាន់ *ប្លាក់ថន* ទាំងក្នុងអាការៈរិះគិតបណ្តើរ ។

- *អ៊ីម៉ា* មានន័យថា " អីលូវនេះ " រឺ " ភ្លាម " ។ យើងត្រូវចេញដំណើរអីលូវនេះភ្លាម *អ៊ិញគីលីស* ។

ដីខ្សាច់បានធ្លាក់ជាកូនគំនរតូចមួយជាស្រេចទៅហើយនៅឯបាក្រោម ។

- សូមឯងជួយស្នើគាត់សាកមើល ថាតើខ្ញុំសូមឡើងលើសំពៅខ្ញុំបានទេ ?

- ទេ *អ៊ិញគីលីស* ខ្ញុំមិនស្នើអារឿងចំកួតឡប់នេះទេ !



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងមួយខណៈនោះ *ប្លាក់ថន* ហាក់ដូចជាខ្លួនគេគ្មានឆ្អឹងឆ្អែង គ្មានឈាម គ្មានសាច់អ្វីទាំងអស់ ។ ហើយគេក៏មានអារម្មណ៍ថា គេចាស់ជរាជ្រុលណាស់ទៅហើយផងដែរ ។ គេសំលឹងមើល *រ៉ូឡ្រិច* ដើរទៅកន្សៀទូកហើយនិយាយជាមួយនាវិកម្នាក់រាងស្គាតបាតដែលឈរនៅទីនោះ ។

- នែ មេបញ្ជាការ-*សាន* ! *អ៊ីតឺមាំយូ* ? អោយពួក *សាមូរ៉ៃ* ឡើងទូក *អ៊ីម៉ា* ! *អ៊ីម៉ា ភាការីម៉ាស៊ូកា* ?

- *ហៃ អាន់ជីន-សាន* !

ជាបន្ទាន់នោះ *រ៉ូឡ្រិច* អង្រួនកណ្តឹងទូកយ៉ាងខ្លាំង ១ ចំនួនប្រាំមួយដង ។ ឯមេបញ្ជាការក៏ចាប់ផ្តើមស្រែកចេញបញ្ជាអោយនាវិក និង *សាមូរ៉ៃ* ដែលនៅលើទូកនិងនៅលើផែ ។ នាវិកទាំងប៉ុន្មានចាប់ផ្តើមប្រញាប់ប្រញាល់រៀបចំចេញដំណើរ ហើយនៅក្នុងស្ថានភាពប្រញឹកដ៏មានវិន័យនេះ *រ៉ូឡ្រិច* អូសដៃ *ប្លាក់ថន* ដើរយ៉ាងនឹងនរសំដៅទៅតែមស្តាំទូក ដែលនៅម្ខាងផែនោះ ។

- មានទូកតូចមួយនៅជាប់ទូក *អ៊ិញ្ជីលីស* ។ កុំចែវលឿនពេក កុំមើលអីទាំងអស់ ហើយក៏កុំស្តាប់អ្នកណាក្រៅតែពីខ្ញុំ ។ បើខ្ញុំប្រាប់ឯងថាអោយត្រលប់ក្រោយត្រូវត្រលប់មកវិញជាប្រញាប់ណាំ !

*ប្លាក់ថន* ឡើងរំលងតែមទូកចុះជណ្តើរចំហៀងទូក ហើយចុះទៅកូនទូកតូចមួយ ។ គេលឺសំលេងពោរពេញដោយកំហឹងនៅពីក្រោយខ្នងគេ ហើយរោមគេឡើងបះក្រញាង ដោយគេឃើញសាមូរ៉ៃជាច្រើននាក់នៅលើសំពៅ ខ្លះកាន់ព្រួញ និង ធ្នូ ខ្លះកាន់មូស្កេ ។

សំលេងរបស់ *រ៉ូឡ្រិច* លាន់លឺគ្របលើសំលេងអ្នកឯទៀត ។

- មេបញ្ជាការ-*សាន* កុំបារម្ភរឿងវ៉ា ។ ខ្ញុំជាអ្នកទទួលខុសត្រូវ ។ ខ្ញុំ *អារ៉ូឡ្រិច -សាន* ! *អ៊ីជី* បាន *អាន់ជីន-សាន* របស់យក៏ ! *ភាការីម៉ាស៊ូកា* ?

*ប្លាក់ថន* ចុះទៅដល់ទូកហើយ ទើបគេឃើញថា ទូកនេះ ឥតមានច្រវ៉ា ដូចដែលគេធ្លាប់ប្រើឡើយ ។ អញមិនចេះចែវដូចពួកវាទេ គេគិតនៅក្នុងចិត្ត ។ ទូកនេះគិតទៅដូចជាអត់ប្រយោជន៍តែដដែល ។ បើហែលឃើញថាឆ្ងាយណាស់ ។ រឺមួយក៏មិនឆ្ងាយប៉ុន្មានទេ ?

គេរួញរា ហើយគេប្រមាណចំងាយ រវាងគេនឹងសំពៅ ។ បើសិនជាគេមាន



www.budinst.gov.kh www.elibraryofcambodia.org

កំលាំងពលំពេញលេញនោះ គេឥតស្ទាក់ស្ទើរបន្តិចណាឡើយ ។ តែចុះអីលូវនេះ ?

ស្នូរជើងចុះជណ្តើរបានលាន់លឺឡើងពីក្រោយខ្នងរបស់គេ ហើយគេខំប្រឹងអស់កំលាំងចិត្តរបស់គេ ដើម្បីទប់ខ្លួនមិនងាកក្រោយ ។

សំលេង *រ៉ូឡិច* បានលាន់ឡើងយ៉ាងប្រញាប់ប្រញាល់ :

- នែ ទៅអង្គុយខាងណោះទៅ ! ប្រញាប់ឡើង !

*ព្លាក់ថន* ធ្វើតាមសំដី ហើយ*រ៉ូឡិច* ក៏លោតចុះទូកយ៉ាងប៉ិនប្រសប់ ។ បន្ទាប់មកគេស្រវាចាប់ដងចែវ ហើយខាល់ទឹកនាំទូកឃ្លាតចេញពីកេគ្រាយ៉ាងរហ័ស ។ គេចែវឈរនៅកណ្តាលទូកដូចជាពួកជប៉ុនពិត ១ ។ ខ្នងរបស់គេបែរទៅរកទូកធំ ។

-យើងអោយដល់កន្លែងនោះទៅ-*រ៉ូឡិច* និយាយផង ចង្អុលទៅសំពៅ *អេរ៉ាស* ផង-នៅកន្លែងណុងក៏មានពួក *សាមូរ៉ៃ* ដែរ ។ អ្នែងចាំប្រាប់ខ្ញុំពេលណាវាតំរង់ធ្នូមករកពួកយើងណាំ *អ៊ិញ្ជីលីស* ។ សង្កេតមើលពួកវាអោយមែនទែនណាំ អីលូវនេះពួកវាកំពុងធ្វើអ្វី ?

-មេបញ្ជាការកំពុងខឹងសំបើមណាស់ ។ អ្នែងច្បាស់ថា គ្មានរឿងអីទេអ្ហី ?

- បើពេលទឹកជោរហើយយើងមិនទៅនោះ ទើបអាកញ្ចាស់សំរាមនោះឆេះ រួចពួកខ្មាន់ ធ្នូវាកំពុងធើអី ?

- អត់ធ្វើអីទេ ។ ពួកវាកំពុងស្តាប់មេបញ្ជាការនោះ ។ ពួកវាហាក់អេះ អុញ ។ អូ ! អត់ទេ ! មានអាមួយនោះដកធ្នូចេញពីបំពង់ហើយ ។

*រ៉ូឡិច* រៀបចំបញ្ឈប់ទូកភ្លាម :

- ព្រះអើយព្រះ ! ពួកអាអស់នេះបាញ់ត្រង់ណាស់ កុំប្រថុយស្បែក ! ព្រួញនៅតែតំរង់មកដដែលទេអ្ហី ?

- ណឹងហើយ ។ ទេ ឈប់សិន ។ មេបញ្ជាការកំពុង...មានអ្នកដើរទៅរកគាត់តាមខ្ញុំស្មានគឺជានាវិកម្នាក់ ។ ដូចជាគេសួរគាត់រឿងសំពៅ ។ មេបញ្ជាការសំលឹងមកពួកយើង ។ អីលូវនេះគាត់និយាយអីទេប្រាប់អាអ្នកតំរង់ធ្នូមកយើង ។ អាគាត់នោះដាក់ធ្នូវាចុះហើយ ។ អានាវិកមួយនោះកំពុងបង្ហាញស្អីទេទៅលើទូកនោះដល់បញ្ជាការ ។



www.budinst.gov.kh www.elibraryofcambodia.org

*វ៉ាត្រិច* លួចចោលភ្នែកមួយខ្ទាប់តាមក្រោមក្បៀក ហើយដកដង្ហើមធូរជាងមុន ។

- គេនោះគឺជានាយទាហាន ។ យ៉ាងហោចណាស់ក៏ពួកវាត្រូវចំនាយពេលកន្លះម៉ោងដែរ ដើម្បីចាត់ចែងពួកចៃវអោយអង្គុយត្រឹមត្រូវ ។

*ភ្ញាក់ថន* អង្គុយរង់ចាំយ៉ាងស្ងាត់ស្ងៀម ។ ចំងាយរវាងទូកទាំងពីរចេះតែធំឡើង ៗ ។

- មេបញ្ជាការតាមសំលឹងមើលពួកយើង ។ ទេ អឺលូវនេះពួកយើងផុតភ័យហើយ ។ មេបញ្ជាការដើរចេញបាត់ហើយ ៗ នៅតែ *សាមូរ៉ៃ* ម្នាក់ទេ ដែលនៅឃ្លាំមើលយើង ។

- ស្រេចតែវាទៅ !

*វ៉ាត្រិច* មានទឹកមុខធូរស្រាលជាងមុន ប៉ុន្តែគេឥតបង្អង់ច្រវ៉ា ហើយក៏មិនងាកក្រោយដែរ ។ គេពោលបន្ត:

- ខ្ញុំមិនចូលចិត្តបែរខ្នងដាក់ពួកសាមូរ៉ៃទេ ពិសេសពេលពួកវាមានអាវុធតែម្តង ។ ម្យ៉ាងទៀតខ្ញុំក៏មិនដែលឃើញពួកកូនមីចោរអស់នេះ អត់មានអាវុធនៅនឹងដៃសោះឡើយ ។ ពួកអាអស់នេះបានចំជាកូនមីចោរមែន ។

- ហេតុអី ?

- ពួកវាចូលចិត្តសំលាប់ណាស់ *អ៊ិញ្ជីលីស* ។ ទំលាប់ពួកវាពេលចូលដេកក៏នៅតែមានដាវជាប់នឹងខ្លួនដែរ ។ ប្រទេសនេះគឺ ជាប្រទេសមួយឧត្តុង្គឧត្តមណាស់ ប៉ុន្តែពួកសាមូរ៉ៃមានគ្រោះថ្នាក់ដូចពស់វែកអ៊ីចឹង !

- ហេតុអី ?

- ខ្ញុំក៏មិនដឹងថា ហេតុអីដែរ *អ៊ិញ្ជីលីស* ! ប៉ុន្តែពួកវាគឺអ៊ីចឹង-*វ៉ាត្រិច* ឆ្លើយតបយ៉ាងរីករាយដោយគេទើបបាននិយាយជាមួយមនុស្សម្នាក់ទៀតដែលមានពូជអំបូរដូចខ្លួន -ពិតណាស់ពួកអាអស់នេះខុសប្លែកពីយើង ។ ពួកវាមានអារម្មណ៍ពីរឿងឈឺចាប់ ពីរឿងត្រជាក់ខុសពីយើង ។ តែបើពួកសាមូរ៉ៃវិញ គឺអាក្រក់អាក្រីតែម្រ៉ង ។ ពួកវាគ្មានខ្លាចអីទាំងអស់ ។ បើនិយាយពីរឿងស្លាប់វិញ វារឹតតែលែងខ្លាចសោះតែម្តង ។ រួចហេតុអី ? ក្រែងតែព្រះបានដឹងតែអាណឹងគឺជាការពិតអ៊ីចឹង ។ បើសិនជាមេវាថា " សំលាប់ " វាសំលាប់ភ្លាម បើមេវាថា



www.budinst.gov.kh www.elibraryofcambodia.org

"ងាប់" ពួកវាស្ទុះហក់ដកដាវ ហើយវះពោះខ្មោក ។ គឺថាពួកវាសំលាប់ និង ងាប់ផុយដូចយើង បាញ់ នោមអីចឹង ។ នារី*សាមូរ៉ៃ*ក៏អីចឹង ។ ពួកវាហ៊ានសំលាប់ឥតញញើតដៃទេ ដើម្បីការពារលោក ម្ចាស់របស់ពួកវា ។ លោកម្ចាស់នេះគឺជាពាក្យពួកវាហៅប្ដីវាហើយ ។ ហើយប្ដីវាប្រាប់វាអោយងាប់វាទទួលងាប់ភ្លាម ។ ពួកស្រីវាសំលាប់ខ្លួនដោយចាក់បំពង់ក ។ នៅស្រុកនេះ *សាមូរ៉ៃ* អាច បញ្ជាអោយប្រពន្ធវាសំលាប់ខ្លួនបាន ហើយតាមច្បាប់ប្រពន្ធវាត្រូវតែធ្វើតាម ។ តែស្រី ១ វាជាប្រភេទមួយដោយឡែក ម៉ាក្រោមមេឃលើដី គ្មានអ្នកណាដូចពួកនេះទេ តែអាពួកប្រុស ១ វិញ...ពួក *សាមូរ៉ៃ* គឺជាសត្វល្អនអ្ហែងដឹងទេ *អ៊ិញគីលិស* ? រឿងធានាបំផុតគឺត្រូវចាត់ពួកវាដូច ជាសត្វអសិរពិសអីចឹង ។ ម៉េចទៅអ្ហែងស្រួលបួលទេអ្អី ?

- បាទមិនអីទេ អរគុណ ។ អីលូវនេះគ្រាន់តែនៅខ្សោយ តែមិនអីទេ ។

- រួចយ៉ាងម៉េចដំណើរអ្ហែង ?

- យ៉ាប់ ! ចុះរឿងពួកវា .....ពួក*សាមូរ៉ៃ*នោះណា ! ... តើគេធ្វើម៉េចក្លាយទៅជា*សាមូរ៉ៃ*? តើពួកគេគ្រាន់តែកាន់ដាវពីរ និងកាត់សក់ប៉ុណ្ណឹងទៅចប់ហើយរឺយ៉ាងម៉េច ?

- អ្ហែងត្រូវកើតឡើងក្នុងត្រកូល*សាមូរ៉ៃ* ។ តែអានេះក៏វាមានគ្រប់ឋានៈផងដែរ រាប់តាំងពី *ដៃមីញ៉ូ* ដែលនៅលើកំពូលអាច់នេះ រហូតមកដល់ *សាមូរ៉ៃ* បេប ដែលនៅក្រោមគេបំផុត ។ អានេះគឺរត់តាមពូជ ដូចនៅស្រុកយើងអីចឹង វាមានអ្នកស្រែ វាមានអភិជន វាមានស្ដេច។ ពីមុនអ្នកស្រែក៏អាចក្លាយជាទាហាន ១ ក្លាយជាអ្នកស្រែបាន ។ អ្នកស្រែទាហានខ្លះក៏អាចឡើយឋានៈខ្ពស់បំផុតផងដែរ ដូចជា *តៃកូ* ជាដើម ។

- អ្នកណាគេ *តៃកូ* ណឹង ?

- ជាមហាមេផ្ដាច់ការ ជាអ្នកត្រួតត្រាជប៉ុន ជាមហាឃាតករលើគ្រប់ជំនាន់ ។ ចាំថ្ងៃណាមួយខ្ញុំនឹងនិយាយរ៉ាយរ៉ាប់ប្រាប់អ្ហែងពីរឿងនេះ ។ វាស្លាប់ពីឆ្នាំទៅ ហើយអីលូវនេះកំពុងលោតក្នុងខ្ទះយមរាជហើយ-*រ៉ូឌ្រិច* ស្ពោះទឹកមាត់ឆ្វេយ-តែអីលូវនេះ ទាល់តែកើតក្នុងត្រកូល *សាមូរ៉ៃ* ទើបអ្ហែងអាចក្លាយខ្លួនជា *សាមូរ៉ៃ* បាន ។ អីលូវនេះ គឺរឿងពូជពង្សវង្សត្រកូលហើយ *អ៊ិញគីលិស* ។ ឱ ! នេះអ្ហែងអត់ដឹងថា នៅទីនេះគេគោរពណាស់ អារឿងពូជ



www.budinst.gov.kh www.elibraryofcambodia.org

អារឿងខ្មែរ អារឿងឋានៈនេះ ។ អ្អែងឃើញ *អូមី* អោនគោរពអាប្រែត *យ៉ាប៊ូ* យ៉ាងម៉េច ហើយឃើញរបៀប ដែលអាពីរនាក់ណឹងគោរពអាកញ្ជាស់ *សំរាម-សាមាំ* យ៉ាងម៉េចទេ ? *សាមូរ៉ៃ* មកពីពាក្យជប៉ុនថា " បំរើ " ។ ប៉ុន្តែទោះជាមានលើមានក្រោមក្តី ក៏ពួកវាទាំងអស់គ្នាជា *សាមូរ៉ៃ* ស្មើ ១ គ្នា និងមានអភ័យឯកសិទ្ធិពិសេសរបស់ *សាមូរ៉ៃ* ដូច១ គ្នា ។ រួចចុះនៅលើទូកយ៉ាងម៉េចហើយ ?

- មេបញ្ជាការកំពុងជជែកគ្នាជាមួយ*សាមូរ៉ៃ* ម្នាក់ទៀត ហើយចង្អុលមកពួកយើង ។ រួចចុះពួក *សាមូរ៉ៃ* មានអីពិសេសទៅ ?

- នៅទីនេះ *សាមូរ៉ៃ* គ្រប់គ្រងអ្វី ១ ទាំងអស់ ធ្វើម្ចាស់លើអ្វី ១ ទាំងអស់ ។ ពួកវាមានក្រឹត្យក្រមកិត្តិយស និងមានបញ្ញត្តិផ្ទាល់របស់ពួកវា ។ តើអ្អែងស្មានថា នេះជាការក្រអឺតក្រទមអ្វី ? អ្អែងមិនទាន់ដឹងទៅឡើយទេ អាថ្នាក់ទាបបំផុតរបស់ *សាមូរ៉ៃ* ក៏អាចសំលាប់យ៉ាងស្របច្បាប់អ្នកមិនមែនជា *សាមូរ៉ៃ* ប្រុស ស្រី ក្មេងណាក៏បានតែទាំងអស់ណឹង ទោះជាមានរឺអត់ហេតុអីក៏ដោយ ។ ជូនកាលគ្រាន់តែចង់សាកដាវរំបល់យក៏វាហ្នឹង ក៏វាអាចសំលាប់បានដែររួចនេះខ្ញុំធ្លាប់ឃើញផ្ទាល់នឹងភ្នែកហើយ ។ រួចដាវពួកវាគឺល្អដាច់ម៉ាក្រោមមេឃលើដីមែន ។ ល្អជាងដែកថែបក្រុងដាម៉ាសទៅទៀត ។ រួចពួកអារំបល់យក៏ណុងធើអីហើយអីលូវនេះ ?

- ពួកវាគ្រាន់តែតាមមើលពួកយើងតែប៉ុណ្ណឹង ។ អាមួយនោះស្ពាយធ្នូមកវិញហើយ ។ ខ្ញុំស្អប់ពួកអាកូនមីចោរទាំងនេះជាងអាពួកអេស្ប៉ាញទៅទៀត ។

*វ៉ូរ្មិច* ផ្ទុះសំនើច :

- បើអាពួកនោះដឹងមើលទៅវាក្របែលទាំងខ្ញុំទៀត ។ តែបើអ្អែងចង់មានឆាប់ អ្អែងត្រូវតែធ្វើការជាមួយពួកវា ពីព្រោះពួកវាមានអ្វី ១ទាំងអស់ ។ នែ ! អ្អែងច្បាស់ថា អ្អែងស្រួលបួលទេអ្វី ?

- អត់អីទេ ។ អរគុណច្រើន ។ អ្អែងថាម៉េចអំបាញ់មិញ ? ថាពួក *សាមូរ៉ៃ* មានអ្វី ១ ទាំងអស់មែន ?

- ណឹងហើយ ។ ម៉ាប្រទេសនេះត្រូវបែងចែកជាវណ្ណៈដូចនៅឥណ្ឌាអីចឹង ។ *សាមូរ៉ៃ*



www.budinst.gov.kh www.elibraryofcambodia.org

នៅលើគេបំផុតបន្ទាប់មកកសិករ ។ មានតែកសិករទេទើបមានសិទ្ធិកាន់កាប់ដី តែ *សាមូរ៉ៃ* កាន់កាប់ផលទាំងអស់ ពិសេសស្រូវដែលជាដំណាំសំខាន់បំផុតនោះ ។ រួចទើប *សាមូរ៉ៃ* ចែកផលអោយទៅកសិករវិញ ។ មានតែ *សាមូរ៉ៃ* ទេ ដែលមានសិទ្ធិកាន់អាវុធ ។ ក្រៅពី*សាមូរ៉ៃ* ដូចគ្នា អ្នកណាផ្សេងអោយតែហ៊ានប៉ះពាល់ *សាមូរ៉ៃ* នោះត្រូវចាត់ថា ជាការបះបោរ ត្រូវទទួលទោសប្រហារជីវិតភ្លាម ។ ហើយបើអ្នកណាឃើញការប៉ះពារនេះ ហើយមិនរាយការណ៍ទេក៏ត្រូវមានទោសដល់ស្លាប់ដែរ ហើយប្រពន្ធកូនក៏ត្រូវប្រហារជីវិតដែរ។ ខ្ញុំធ្លាប់ឃើញកូនក្មេងត្រូវគេចិញ្ច្រាំដូចផ្លែកអីចឹង-*រ៉ូឌ្រិច* ស្ដោះទឹកមាត់ឆ្វេយទៅក្នុងសមុទ្រ- ទោះជាយ៉ាងនេះក្ដីបើអែងយល់ការពីរបីរឿងវិញ ស្រុកនេះគឺពិតជាឋានសួគ៌លោកិយហើយ ។

*រ៉ូឌ្រិច* ក្រវាសភ្នែកមួយភ្លែតទៅក្រោយ ដើម្បីច្បាស់ក្នុងចិត្ត រួចគេងាកមកនិយាយជាមួយ *ប្លាក់ថន* បន្តទៀត :

- ម៉េច *អ៊ិញគីលីស* គ្មានអីប្រសើរជាងជិះទូកលេងជុំវិញផែនអីចឹងទេមែនទេ ?

*ប្លាក់ថន* សើច ។ ក្លិនអំបិលសមុទ្រ សំលេងចេចចាចនៃសត្វរំពេ ដែលហើរច្រវាត់ពីលើក្បាល អារម្មណ៍នៃសេរីភាព និងអារម្មណ៍ដែលគិតថា ខ្លួនបានមកដល់ទីដៅ បន្ទាប់ពីដំណើរមួយដ៏សែនឆ្ងាយនោះមក បានធ្វើអោយគេដូចកើតជាថ្មីម្ដងទៀត ។

- ខ្ញុំគិតថា អែងក៏មិនទៅជួយខ្ញុំយកសំពៅ *អេរ៉ាស* វិញទេមែនទេ ?

- ពួក*អ៊ិញគីលីស* អែងគ្រប់គ្នាយ៉ាប់តែអារឿងណឹងតែម្ដង ។ គ្មានចេះអត់ធ្មត់អីបន្តិចណាសោះ ។ ស្ដាប់ខ្ញុំណាំ នៅទីនេះអែងកុំសុំអីពីពួកជប៉ុនអោយសោះទាំងពួក*សាមូរ៉ៃ* ទាំងអ្នកណាទៀតក៏តែអីចឹង ។ បើអែងសុំពួកវានឹងអេះអុញ ហើយច្បាស់ជាទៅសុំសេចក្ដីសំរេចពីថ្នាក់លើហើយ ។ នៅទីនេះ អែងបើត្រូវធើ អែងធើទៅ ។ ប៉ុន្តែនិយាយអោយហើយរឿយ-សំនើ របស់ *រ៉ូឌ្រិច* លាន់ខ្ទរតាមផ្ទៃសមុទ្រ- ជួនកាលបើអែងធើចំកន្លែងខុស អែងដាច់ក្បាលតែអីចឹង ។

- អែងចែវទូកបែបហ្នឹងបានល្អណាស់ ។ អែងដឹងទេ ពេលអែងចុះទូកខ្ញុំកំពុងតែគិតថា តើខ្ញុំចែវយ៉ាងម៉េចនឹងកើតទៅ ។



www.budinst.gov.kh www.elibraryofcambodia.org

-អ្អែងស្មានថា ខ្ញុំទុកអ្អែងអោយទៅម្នាក់អ្អែងកើតអ្វី ? និយាយអីចឹងអ្អែងឈ្មោះអីទៅ?

-*ប្លាក់ថន* ។ ជន *ប្លាក់ថន* ។

- *អ៊ិញគីលីស* ! អ្អែងធ្លាប់ទៅភាគខាងជើងទេ ? ទៅជើងបំផុតណា ?

- ខ្ញុំធ្លាប់ទៅជាមួយលោក *គាវែមាន់* ដោយសំពៅ *អែវឡេប* កាលពីប្រាំបីឆ្នាំមុន ។ កាលនោះ គឺជាដំណើរទីពីរ របស់គាត់ ដើម្បីរកច្រកសមុទ្រអីសានណា ។ ហេតុអី ?

- ខ្ញុំចូលចិត្តស្ដាប់រឿងហ្នឹងណាស់ ហើយចង់ស្គាល់កន្លែងណាទៀត ដែលអ្អែងធ្លាប់ទៅ ។ រួចចុះអ្អែងគិតថា គេអាចរកច្រកសមុទ្រហ្នុងឃើញទេ? ផ្លូវខាងជើងដើម្បីមកកាន់អាស៊ី ? អាស៊ីខាងលិច រឺខាងកើត ?

- ហ្នឹងហើយ ។ ពួកអ្អែងនិងពួកអេស្ប៉ាញនាំគ្នាខ្ទប់ផ្លូវខាងត្បូងទៅហើយ ហេតុនេះពួកយើងត្រូវតែខំរកផ្លូវថ្មីទៀត ។ ហើយពួកយើងច្បាស់ជារកឃើញ ។ បើមិនពួកយើងក៏ពួកហូឡង់ដែរ ។ ហេតុអី ?

- អ្អែងធ្លាប់បើកតាមឆ្នេរសមុទ្រ *បាបារី* ទេ ?

- ធ្លាប់ ! ហេតុអី ?

- អ្អែងធ្លាប់ស្គាល់ទីក្រុង *ទ្រីប៉ូលី*ទេ ?

- តែកុងភាគច្រើនសុទ្ធតែស្គាល់ហើយ ។ ហេតុអី ?

- ខ្ញុំដូចជាធ្លាប់ឃើញអ្អែងម្ដង ។ ហ្នឹងហើយ ពិតជានៅ *ទ្រីប៉ូលី* ហ្នឹងហើយ ។ កាលនោះមានគេបង្ហាញអ្អែងប្រាប់ខ្ញុំ ។គេថាហ្នុងហើយជាតែកុង *អ៊ិញគីលីស* ដ៏ល្បីល្បាញ ដែលបានដើរជាមួយអ្នករុករកហូឡង់ *គាវែមាន់* ទៅសមុទ្រទឹកកក ហើយក៏ជាអ្នកធ្លាប់ដើរសំពៅជាមួយ *រវេក* នោះ ។ កាលនោះអ្អែង អាយុប៉ុន្មាន ឆ្នាំហើយ ?

- ម្ភៃបួន ។ រួចចុះអ្អែងទៅធ្វើអីនៅឯ *ទ្រីប៉ូលី* ?

-កាលនោះខ្ញុំបើកកកសែអង់គ្លេស ។ សំពៅខ្ញុំត្រូវអាចោរសមុទ្រ *បាបារីម៉ូរ* ប្លន់យកទៅតំបន់ *គាភាអ៊ីប* ហើយក្រោយពីប្លន់រួច វាដុតចោលមិត្ត រួចហើយវាហៅខ្ញុំអោយបើកសំពៅអោយវា ព្រោះតែកុងវាមិនស្គាល់ផ្លូវ ដើម្បីស្ទាក់សំពៅដឹកមាសប្រចាំឆ្នាំ របស់ពួកអេស្ប៉ាញ



www.budinst.gov.kh www.elibraryofcambodia.org

ត្រង់កោះ *កាណារី* រួចវាគ្រោងទៅ *ទ្រីប៉ូលី* ហើយអោយម្ហូបអាហារហូបចុកគ្រប់គ្រាន់ ។ ខ្ញុំបានឆ្លើយថា " មានអី ? តែទាល់តែដាក់លក្ខខណ្ឌថា មិនប្លន់សំពៅប៉ុកទុយកាល់ ព្រមដាក់ខ្ញុំចុះនៅជិត *លីស្បោន*[៣៥] និងកុំលួចកូនសៀវភៅខ្ញុំ " ។ កាលនោះជជែកតថ្លៃគ្នាយូរណាស់ ទីបំផុតយើងបានស្បថជាមួយគ្នា ដោយយកព្រះជាបន្ទាល់ថា នឹងគោរពតាមលក្ខខណ្ឌរៀង ៗ ខ្លួន ។ កាលនោះធ្វើដំណើរបានស្រួលបួល ហើយយើងប្លន់បានសំពៅជំនួញអេស្ប៉ាញប៉ុន្មានគ្រឿងដែរ ។ នៅពេលដែលសំពៅជិតមកដល់លីស្បោន *ហង់រី ម៉ូរ៉េ* ស្នើខ្ញុំអោយនៅបន្តបើកសំពៅតទៅទៀត ដោយសន្យាថា អោយលុយខ្ញុំយ៉ាងច្រើន តែខ្ញុំមិនព្រម ហើយវាក៏រក្សាសំដីវា ដោយដាក់ខ្ញុំឡើងគោក និងប្រគល់កូនសៀវភៅមកខ្ញុំវិញ ។ តែវាចំលងរួចបាត់ទៅហើយអាកូនសៀវភៅនេះ ។ មិនតែប៉ុណ្ណឹងវាអោយទាំងភាគហ៊ុននៃទ្រព្យសម្បត្តិ ដែលយើងប្លន់បាននោះមកអោយខ្ញុំទៀត ។ *អ៊ិញគ្លីស* ឯងដែលដើរសំពៅជាមួយ *ហង់រី ម៉ូរ៉េ* ទេ ?

- ទេ ! ព្រះមហាក្សត្រិយានីទើបលើកងារៈគេជាមហាសេនា កាលពីប៉ុន្មានឆ្នាំមុននេះ ។ ឯខ្ញុំៗមិនដែលដើរសំពៅណាមួយរបស់គាត់ទេ ។ ខ្ញុំអរណាស់ដែលគាត់កាន់ពាក្យជាមួយឯងនោះ ។

-កាលនោះគឺជាលើកទីពីរហើយ ដែលខ្ញុំបើកសំពៅអោយពួកខមិឡ ។ កាលពីលើកទីមួយមិនសូវបានហេងអីចឹងទេ ។

- មែន ?

*រ៉ូឌ្រិច* លើកដងចែវ ហើយកូនទូកក៏មកអែបយ៉ាងស្រួលនៅក្បែរនឹងសំពៅ *អេរ៉ាស* គេចាប់ស្រវាជណ្តើរខ្សែនៅចំហៀងសំពៅ ហើយនិយាយទៅកាន់ *ប្លាក់ថន* :

- ឡើងទទួលខ្ញុំមក តែទុកអោយខ្ញុំជាអ្នកនិយាយ ។

នៅពេលដែល *រ៉ូឌ្រិច* ចងទូកភ្ជាប់នឹងសំពៅ *ប្លាក់ថន* ក៏ចាប់ផ្តើមឡើងទៅលើសំពៅ ។ ប៉ុន្តែ *រ៉ូឌ្រិច* ជាអ្នកទៅដល់លើសំពៅមុន ។ *រ៉ូឌ្រិច* ក៏លំអោនខ្លួនគោរពតាមបែបអ្នករាំងអឺរ៉ុប

---

*(៣៥) រដ្ឋធានីប្រទេសប៉ុកទុយកាល់ (ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

ហើយពោលឡើង ៖

- *កាទីជីវ៉ា* ចំពោះពួកអាស៊ុស្មៅ-សាម៉ាទាំងអស់

*សាមូរ៉ៃ* បួននាក់នៅឈរលើសំពៅនោះ ។ *ប្លាក់ថន* ចំនាំមុខ*សាមូរ៉ៃ*ម្នាក់ដែលធ្លាប់យាមឃ្លប ។ ទាំងបួននាក់អោនគោរពបុរសបក់ទុយកាល់ទាំងរឹងឆ្អឹត ។ *ប្លាក់ថន* ខំរៀបរកពាម *រ៉ូឡិច* ទាំងឆ្គង ដោយគេមានចំនួលចិត្តលំអោនខ្លួនត្រឹមត្រូវតាមបែបជប៉ុនវិញ ។

*រ៉ូឡិច* ដើរតំរង់ទៅរកជណ្តើរចុះទៅបន្ទប់ធំ ។ អាច់ល័ខ ត្រូវបិតភ្ជាប់នៅលើទ្វារ ។ *សាមូរ៉ៃ* ម្នាក់ស្ទុះមកឃាត់ *រ៉ូឡិច* ៖

- *តិនជីរ៉ូ កូមេនណាសៃ*-ហាមឃាត់ សូមអភ័យទោស !

- *តិនជីរ៉ូ* ? អាច់អញនែ !-*រ៉ូឡិច* ឆ្លើយតបដោយបង្ហាញអាការៈឥតញញើតអ្វីទាំងអស់-អញគឺ*រ៉ូឡិច-សាន* ជាអាន់ជីនរបស់*តូដាហ៊ីរ៉ូ-ម៉ាត់ស៊ី-សាម៉ា* ។ ត្រានេះ-គេចង្អុលទៅត្រាដែលប្រថាប់នៅលើអក្សរក្រវេមក្រវាមមួយផ្ទាំង-*តូដាហ៊ីរ៉ូ-ម៉ាត់ស៊ី-សាម៉ាកា* ?

- *អ៊ីយេ* សាមូរ៉ៃ នោះគ្រវីក្បាល-*កាស៊ីគី-យ៉ាប៊ូ-សាម៉ា*

-*អ៊ីយេ- រ៉ូឡិច* តប-*កាស៊ីគី-យ៉ាប៊ូ-សាម៉ា* ? អញគឺធ្វើការអោយ *តូដាហ៊ីរ៉ូ -ម៉ាត់ស៊ី-សាម៉ា* ។ គាត់ជាស្តេចធំជាងម្ចាស់កំប៉ិកកំប៉ុករបស់ពួកអ្នែង ហើយ*សំរាម-សាម៉ា* នេះគឺធ្វើការជូន *តាក៏ណាកា-សាម៉ា* ដែលជាកូនទីចោរ-សាម៉ាធំជាងគេបំផុតម៉ាក្នុងលោកនេះ ។ *នេ* ?

ដៃរបស់ *រ៉ូឡិច* ម្ខាងកន្ត្រាក់ត្រាចេញ ឯដៃម្ខាងទៀតកាន់កាំភ្លើងខ្លីរបស់គេ ។ ដាវក៏ត្រូវដកចេញពាក់កណ្តាលមកហើយដែរ ។ *រ៉ូឡិច* និយាយយ៉ាងនឹងនរទៅ *ប្លាក់ថន* ។

-អ្នែងត្រៀមលោតទឹកចោលសំពៅលីទេ ? - ហើយគេងាកទៅនិយាយយ៉ាងក្រៃលោត១ ទៅរក*សាមូរ៉ៃ* នោះ ៖

- *តូក៏ណាកា-សាម៉ា* ?

ដៃឆ្វេងរបស់*រ៉ូឡិច* ចង្អុលទៅទង់ដែលកំពុងបក់រវិចនៅលើដងក្តោងទូករបស់គេ ៖

- *វ៉ាការី ម៉ាស៊ូ កា*?

*សាមូរ៉ៃ*នោះអេះអុញ ប៉ុន្តែដាវរបស់គេត្រៀមកាប់ជាស្រេចទៅហើយ ។ *ប្លាក់ថន*



www.budinst.gov.kh www.elibraryofcambodia.org

សំលឹងមើលកន្លែងលោតហើយជាស្រេច ។

- *តូរ៉ាណាកា-សាមា* !

រួចហើយ *រ៉ូត្រិច* ធាក់ទ្វារក្តាំង ។ គន្លឹះទ្វាររបូត ហើយទ្វារក៏របើកឃ្វាំង ។

- *វ៉ាកាវី មាំស៊ូ កា*

- *វ៉ាកាវី មាំស៊ូ អាន់ជីន-សាន*

*សាមូរ៉ៃ* នោះរុញដាវទៅក្នុងស្រោមវិញយ៉ាងរហ័ស ហើយលំអោនខ្លួនសូមទោស ហើយសូមទោសទៀត ។ *រ៉ូត្រិច* និយាយឡើងទាំងសំលេងខ្មោច :

- អើអ៊ីចឹងទៅវាស្រួលបន្តិច ។

រួចគេនាំ *ប្លាក់ថន* ចុះទៅខាងក្រោម ។

នៅពេលដែលគេចុះដល់ក្រោមហើយ *ប្លាក់ថន* និយាយឡើង :

-ព្រះជាម្ចាស់អើយព្រលឹងព្រលះអើយមកវិញ ។នែ*រ៉ូត្រិច* រួចរាល់លើកអ្អែងធ្វើរបៀបហ្នឹងអ្វី?

*រ៉ូត្រិច* ជូតញើសថ្ងាសបណ្តើរ ឆ្លើយបណ្តើរ :

- ម្តងម្កាលទេ ! ហើយអ៊ីចឹងក្តី ក៏ខ្ញុំតែងតែបន់កុំអោយកើតមានទៀតដែរ ។

*ប្លាក់ថន* ផ្អែកខ្លួនទៅនឹងជញ្ជាំងក្ការសំពៅ :

- ខ្ញុំវិញ ដូចគេទាត់ត្រូវចំពោះទឹកមួយជើងអ៊ីចឹង ។

- ផ្លូវដោះស្រាយមានតែម៉ាបែបហ្នឹង ។ អ្អែងត្រូវធ្វើដូចម្តេចអ៊ីចឹង ។ អ៊ីចឹងក្តីក៏អ្អែងមិនដឹងថា វានឹងទៅជាយ៉ាងណាដែរ ជាមួយពួកសាមូរ៉ៃអស់នេះ ។ ពួកវានេះគ្រោះថ្នាក់មិនខុសអីពីពួកបព្វជិតប្រកាច់យក៏ ដែលកាន់ទៀនអង្គុយលើធុងម្សៅទេ !

- អំបាញ់មិញអែងនិយាយប្រាប់ពួកនេះថាម៉េច ?

- *តូដាហ៊ីរ៉ូ-មាត់ស៊ី* ជាទីប្រឹក្សាធំជាងគេរបស់ *តូរ៉ាណាកា* ។ វាជា *ដៃមីញ៉ូធំ* ជាងអាមួយក្នុងស្រុក ។ អ៊ីចឹងហើយបានជាពួកវាយល់ព្រមអោយយើងចុះមកណាំ

- តើ *តូរ៉ាណាកា* យ៉ាងម៉េចដែរ ?

*រ៉ូត្រិច* ដាក់បង្គុយលើកាំជណ្តើរ ដកស្បែកជើងកវែងរបស់ខ្លួន ហើយរឹតកជើងរបស់ខ្លួនបណ្តើរ និយាយបណ្តើរ :



www.budinst.gov.kh www.elibraryofcambodia.org

- អានេះរឿងវែងឆ្ងាយណាស់ *អ៊ីញគីលីស* ។ យីស ! អញរិះតែបាក់ជើងដោយសារតែទ្វារចង្រៃវាយក័នេះតែម្រ៉ង ។

- ទ្វារមិនទាំងចាក់សោផង អ្អែងគ្រាន់តែមួលគន្លឹះបើកបានទៅហើយ ។

- ខ្ញុំដឹងហើយ ។ តែបើករបៀបណឹងមិនសំលុតស្មារតីពួកអានៅខាងលើអស់នោះទេ។ ឱ ព្រះអើយព្រះ ! អ្អែងត្រូវរៀនសូត្រច្រើនណាស់ !

- អ្អែងជួយបង្រៀនខ្ញុំផងបានទេ ?

*រ៉ូន៊ិច* ពាក់ស្បែកជើងឡើងវិញ រួចឆ្លើយតប :

- ស្រេចតែកាលៈទេសៈទេអារឿងណឹង !

- កាលៈទេសៈយ៉ាងម៉េច ?

- ចាំតែមើលទៅ ! កន្លងមកខ្ញុំនិយាយតែរហូតហើយ ប៉ុន្តែអាណឹងវាត្រូវតែអ៊ីចឹង ។ ខ្ញុំអាច អ្អែងមិនអាច ។ បន្តិចទៀតដល់វេនអ្អែងម្តងហើយ ។ អីលូវនេះបន្ទប់អ្អែងណាមួយ ?

*ប្លាក់ថន* សំលឹងសង្កេត*រ៉ូន៊ិច* មួយរយៈ ។ នៅទីនេះក្លិនខ្មោះបានគ្របដណ្តប់គ្រប់ទីកន្លែង។

- អរគុណអ្អែងច្រើនណាស់ ដែលបាននាំខ្ញុំមកសំពៅនេះ ។

*ប្លាក់ថន* ដើរនាំមុខ សំដៅបន្ទប់នៅកន្សៀសំពៅ ។ ទ្វាររបស់គេឥតចាក់សោទេ ។ បន្ទប់ត្រូវគេរុះរើ ហើយអ្វីដែលអាចជញ្ជូនបានត្រូវគេជញ្ជូនចេញអស់ ។ គ្មានសៀវភៅ គ្មានប្រដាប់ប្រដា គ្មានខោអាវ គ្មានស្លាបក្លាន់សរាប់សរសេរទៀតឡើយ ។ ហឹបរបស់គេក៏បើកចំហដែរ ។ ហើយគ្មានអ្វីទាំងអស់នៅក្នុងនោះ ។

ខ្លួនញ័រចំប្រប់ដោយកំហឹង *ប្លាក់ថន* ដើរចូលបន្ទប់ធំ ដោយមាន *រ៉ូន៊ិច* តាមសំលឹងមើលគេជាប់ ។សូម្បីតែថតសំងាត់ក៏ត្រូវគេរកឃើញនិង ប្រមូលរបស់របរនៅក្នុងនោះអស់ដែរ។

- វាប្រមូលយកអស់គ្មានសល់អីទេ ។ ពួកអាប្រកាច់យក៏អស់នេះ ។

- រួចចុះអ្អែងសង្ស័យថា នៅសល់អី ?

- ខ្ញុំមិនដឹងដែរ ។ ខ្ញុំគិតថា គេប្រថាប់ភ្ជិតយ៉ាងនេះ...

*ប្លាក់ថន* ដើរទៅបន្ទប់ទូដែក ។ ទទេឡូត ។ ឃ្លាំងក៏យ៉ាងដូចនោះដែរ ។ រមូរបាល់



www.budinst.gov.kh www.elibraryofcambodia.org

មានតែខោអាវខ្សៀនតែប៉ុណ្ណោះ ។ គេដើរត្រលប់មកបន្ទប់គេ ហើយបិទហឹបគេលឺសូរគ្រាំង ។

- ពួកអាតយអស់នេះ អោយវារលត់រលាយទៅលោក !

*រ៉ូន្ទ្រិច* សូរឡើង :

- វានៅឯណា ?

- ស្អី ?

- កូនសៀវភៅអ្អែងណាំ ។ ឯណាកូនសៀវភៅអ្អែង ?

*ញ្ញក់ផន* សំលក់ *រ៉ូន្ទ្រិច* ។

- មិនដែលតែកុងណាខ្វល់ខ្វាយរឿងខោអាវទេ ។ អ្អែងមកនេះក៏ដើម្បីកូនសៀវភៅដែរ ។ មែនទេ ?

- មែនហើយ ។

- រួចអីចឹងម៉េចអ្អែងធ្វើមុខដូចជាភ្ញាក់ផ្អើលម្ល៉េះ ? ស្មានថា ខ្ញុំជូនអ្អែងមកកន្លែងនេះដើម្បីអី ? ស្មានថាខ្ញុំមកជួយអ្អែងជញ្ជូនសម្បុកសម្បត្តិអាជ័យអ្អី ? បើសិនជាអ្អែងមានសល់ខោអាវក៏វាសឹកសល់តែកទៅហើយ ។ អ្អែងគង់តែត្រូវការអាថ្មីទៀតទេ សំរាប់អ្អែងមួយ ខ្ញុំមានដល់ទៅសល់ឯណោះ ។ តែកូនសៀវភៅវានៅឯណា ?

- បាត់ហើយ ។ ពីមុនវានៅក្នុងហិបខ្ញុំនេះ ។

- នែ ! *អ៊ិញ្ញគីលីស* ! ខ្ញុំមិនមែនចង់លួចវាទេ ។ ខ្ញុំគ្រាន់តែចង់អានវា ។ ហើយបើចាំបាច់ខ្ញុំនឹងចំលងវា ។ ខ្ញុំនឹងថ្នាក់ថ្នមវាដូចជារបស់ខ្ញុំអីចឹង ហើយសូមអ្អែងកុំបារម្ភអោយសោះ -*រ៉ូន្ទ្រិច* បន្ទឹងសំលេង - ខ្ញុំសូមអង្វរអ្អែង *អ៊ិញ្ញគីលីស* យើងនៅសល់ពេលតិចណាស់ ។

- ខ្ញុំមិនដឹងទៅរកឯណាទេ ។ វាបាត់ហើយ ។ មុននេះវានៅក្នុងហឹបខ្ញុំណុង ។

-អ្អែងច្បាស់ជាមិនមែនទុកកូនសៀវភៅនៅក្នុងហឹបណឹងទេ ពិសេសពេលចូលមកកំពង់ផែបរទេសនោះ ។ អ្អែងច្បាស់ជាមិនភ្លេចទេទូវច្បាប់ទីមួយរបស់អ្នកតែកុងនោះ គឺលាក់កូនសៀវភៅអោយបានម៉ត់ចត់ ហើយទុកតែអាក្លែងក្លាយទេអោយនៅកណ្តាលវាលនោះ ។ នែ! ឆាប់ឡើង !



www.budinst.gov.kh www.elibraryofcambodia.org

- គេលួចយកវាទៅបាត់ហើយ !

- ខ្ញុំមិនជឿអ្អែងទេ ។ តែខ្ញុំសូមសារភាពថា អ្អែងលាក់កូនសៀវភៅនេះបានល្អមែនទែន ។ ខ្ញុំមករកវាជាងពីរម៉ោងតែអោយតែឃើញស្នាមចុះកួតអីបន្តិចក៏គ្មានដែរ ។

- អ្អែងថាម៉េច ?

- រួចអ្អែងដូចជាភ្ញាក់សំបើមម្ល៉េះ *អ៊ីញូគីលីស* ? អ្អែងអីក៏ទ្រើកម្ល៉េះ ? ធម្មតាទេ ខ្ញុំមកពីអូសាកាមកដល់ទីនេះគឺ ដើម្បីតែកូនសៀវភៅអ្អែងហ្នឹងណា !

- អីចឹងអ្អែងឡើងសំពៅនេះម្តងហើយ ?

*វ៉ុន្រ្ទិច* ឆ្លើយតបទាំងធុញទ្រាន់ :

- ឱ ព្រះអើយព្រះ បាទទាន ខ្ញុំបានឡើងសំពៅនេះពីរបីម៉ោងមុនហ្នឹងជាមួយ *ហ៊្សី-ម៉ាត់ស៊ី* ។ គាត់ចង់ដើរមើលសំពៅនេះ ។ គាត់បានបំបែកប្រថាប់ត្រា ហើយដល់ពេលគាត់ចេញទៅវិញ បាន *អាដែមីញ៉ូ* ម្ចាស់ស្រុកនេះភ្ជិតវាទៅវិញ ។

រួចគេបន្ថែម :

- អោយឆាប់ឡើងទៅ ! ឱ ព្រះអើយព្រះ ! នែ ខ្សាច់ជិតធ្លាក់អស់ហើយ !

- គេលួចយកវាទៅណាបាត់ហើយ !

រួច *ប្លាក់ថន* ក៏ចាប់ផ្តើមរ៉ាយរាប់ពីពេលគេមកដល់តើយ៉ាងណា ហើយនឹងពេលដែលគេភ្ញាក់ឡើងនៅឯដីគោក ។ រួចហើយគេទាត់ហឹបគេមួយជើងប៉ុងឡើងរមៀលទៅកណ្តាលបន្ទប់ដោយក្រេវក្រោធនឹងពួកដែលមកលួចប្លន់សំពៅគេនេះ ។

- ពួកវាលួចកូនសៀវភៅបាត់ហើយ ! ទាំងផែនទី ! ទាំងកូនសៀវភៅ ! កន្លែងខ្លះខ្ញុំមានចំលងទុកនៅប្រទេសអង់គ្លេស ប៉ុន្តែកូនសៀវភៅដែលកត់ត្រាដំណើរជើងនេះត្រូវគេលួចយកបាត់ ហើយនឹង...

*ប្លាក់ថន* បញ្ចប់សំដីទ្រឹង *វ៉ុន្រ្ទិច*បន្តឡើង :

- ហើយនិងកូនសៀវភៅប៉កទុយកាល់មែនទេ ? និយាយទៅ *អ៊ិញូគីលីស* វាត្រូវតែជារបស់ប៉កទុយកាល់ ។



www.budinst.gov.kh www.elibraryofcambodia.org

- ណុងហើយ អាកូនសៀវភៅប៊ិកទុយកាល់ក៏បាត់ដែរ !

នឹងនរឡើងអាប្រកាច់- *ប្លាក់ផង* គិតនៅក្នុងចិត្ត ។ កូនសៀវភៅបាត់គឺជា ទីបញ្ចប់ហើយ ។ អ្នកណាយកវាទំ ? ពួកជប៉ុនអ្វី ? រឺមួយក៏ពួកវាប្រគល់ទៅបព្វជិតនោះ ? គ្មានកូនសៀវភៅ គ្មានផែនទី អ្ហែងមិនអាចបើកសំពៅទៅស្រុកវិញបានទេ ។ មិនបានទាល់តែសោះ... តែដូចជាមិនពិតទេ ។ អ្ហែងនៅតែអាចបើកសំពៅទៅស្រុកវិញបានតែអ៊ីចឹង អោយតែអ្ហែងប្រយ័ត្នប្រយែងនិងហេងច្រើនទៅ កុំល្ងើពកថ្វាសពេក ! អ្ហែងនៅម៉ាចំហៀងពិភពលោកក្នុងកណ្តាប់ដៃខ្មាំង ហើយអ្ហែងគ្មានទាំងកូនសៀវភៅ គ្មានទាំងផែនទីទៅទៀត ។ ឱ ព្រះអង្គអើយជួយខ្ញុំផង !

*រ៉ូឌ្រិច* នៅតែសំលឹង *ប្លាក់ថន* មិនដាក់ភ្នែក ។ នៅទីបំផុតគេបន្លឺឡើង :

- ខ្ញុំសូមរួមសោកស្តាយជាមួយអ្ហែងផង ខ្ញុំដឹងថាតើអ្ហែងមានអារម្មណ៍យ៉ាងណាហើយ ។ ខ្ញុំក៏ធ្លាប់មានរឿងអ៊ីចឹងដែរ ។ អាចោរនោះជា *អ៊ិញគ្លីស* ដូចអ្ហែងដែរ ។ សូមអោយតែសំពៅវាលិច ហើយអោយវាទៅចុះនរកប្រាំបួនជាន់ទៅចុះ ។ មក៏ ! ទៅទូកយើងវិញ ។

ঌঌঌ

*អូមី* និង អ្នកឯទៀតឈរនៅលើទំនប់រលក រហូតដល់ពេលដែលទូកព័ទ្ធតាមជ្រោយហើយរលាយបាត់ទៅ ។ នៅឯខាងលិច ព្រះអាទិត្យហៀបលិចបានជាត់ផ្ទៃមេឃអោយមានពណ៌ក្រហមជាំ ចំនែកនៅខាងកើត ស្បៃរាត្រីបានគ្របដណ្តប់ទាំងទៅលើសមុទ្រ ទាំងទៅលើផ្ទៃមេឃទៅហើយ ។

- *អូរ៉ា* ! យកកាណុងទៅដាក់លើសំពៅវិញស៊ីពេលប៉ុន្មាន ?

- បើធ្វើពេញមួយយប់នេះផង គឺដល់ថ្ងៃត្រង់ស្អែក *អូមី-សាន* ។ បើយើងធ្វើពីព្រលឹមស្រាង ៗ យើងអាចបញ្ចប់មុនព្រលប់ ។ យកល្អគួរធ្វើពេលមានពន្លឺថ្ងៃវិញ ព្រោះវាសន្តិសុខជាង ។

- ធើទាំងយប់ណឹងទៅ ។ អីលូវទៅប្រាប់បព្វជិតនោះអោយទៅកន្លែងអន្លង់ !



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* ចោលភ្នែកសំលឹងមើល *អ៊ិគូរ៉ាស៊ី* ភូលយួយសំខាន់របស់ *យ៉ាប៊ូ* ដែលនៅតែឈរសំលឹងទៅជ្រោយឯនាយប្រកបដោយទឹកមុខតឹងតែង ។

-*អ៊ិគូរ៉ាស៊ី-សាន* ខ្ញុំសូមស្វាគមន៍លោកសំរាកនៅទីនេះ ។ ផ្ទះរបស់ខ្ញុំក្រីក្រទេ តែយើងខ្ញុំនឹងខិតខំធ្វើយ៉ាងណាអោយលោកបានសុខស្រួលជាទីបំផុត ។

- អរគុណ -បុរសចំនាស់ឆ្លើយតបដោយឥតបែរខ្លងមករក *អូមី* ឡើយ-តែលោកម្ចាស់យើងបានប្រាប់ថា ត្រូវតែត្រលប់ទៅ *យេដូ* ជាបន្ទាន់ ហេតុនេះហើយបានជាខ្ញុំត្រូវត្រលប់ទៅជាបន្ទាន់នោះ ។ ហ៊ឺ ! ខ្ញុំចង់តែបាននៅលើទូកនោះទេ ។

- មែនហើយ ។

- ខ្ញុំមិនចូលចិត្តសោះដែល *យ៉ាប៊ូ-សាម៉ា* ឡើងទូកដោយមានកូនចៅតែពីរនាក់អ៊ីចឹងនោះ ។ ខ្ញុំមិនចូលចិត្តសោះតែម្តង ។

- មែនហើយ ។

*អ៊ិគូរ៉ាស៊ី* ចង្អុលសំពៅ :

- អានេះជាសំពៅបិសាច ! ទ្រព្យសម្បត្តិម៉ាត់នរ រួចស្រាប់តែរលីងឆេញ ។

- មិនមែនទេអ្ហ ? លោកម្ចាស់ *តូរ៉ាណាកា* អាចនឹងសប្បាយចិត្តចំពោះជំនូន ដែលលោកម្ចាស់ *យ៉ាប៊ូ* បានធ្វើចំពោះលោកដែរណា ។

- អាម៉ៅស្វិតនេះសព្វថ្ងៃវារវល់តែរឿងបុណ្យសក្តិវាស្ទើរឆ្កួតទៅហើយនោះ វាច្បាស់ជាគ្មានបានចាប់អារម្មណ៍ថា វាប្លន់លុយកាក់ពីលោកម្ចាស់យើងអស់ប៉ុន្មានទេ ។ រួចអែងគិតអីហ្នឹង ?

- ខ្ញុំគិតថា លោកនិយាយបែបហ្នឹង ដោយសារតែលោកខ្វល់ពីរឿងសន្តិសុខរបស់លោកម្ចាស់ *យ៉ាប៊ូ* ពេកទេមើលទៅ ។

-អែងនិយាយត្រូវណាស់ ។ ខ្ញុំគ្មានបំនងប្រមាថកាតទានអីទេ ។ អែងជាមនុស្សឆ្លាតហើយមានប្រយោជន៍ច្រើន ចំពោះលោកម្ចាស់យើង ។ ហើយប្រហែលជាអែងយល់ត្រូវពី *តូរ៉ាណាកា* ផងដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

*អ៊ីកូរ៉ាស៊ី*និយាយបណ្តើរគិតបណ្តើរ ។ សប្បាយនឹងទ្រព្យសម្បត្តិរបស់អ្អែងទៅអាភ្លើ! អញស្គាល់លោកម្ចាស់អញច្បាស់ជាងអ្អែងឆ្ងាយណាស់ ហើយផែនដីដែលគេបង្កើត អោយអ្អែងនេះមិនមែនជាល្អសំរាប់អ្អែងណាស់ណាទេ ។ អ្អែងឡើងបានទាល់តែមានសំពៅ លុយ និងសព្វាវុធទាំងអស់ជាផ្ទូរ តែអីលូវនេះអារបស់ទាំងនេះវារលត់រលាយបាត់ទៅហើយ ។ ហើយព្រោះតែអ្អែងហ្នឹង បានជាលោកម្ចាស់អញមានរឿង ។ អ្អែង ធ្វើសារហើយៗអ្អែងនិយាយថា " ទៅជួបពួកអាចុងស្រុកជាមុនសិន " ។ គឺអ្អែងជន្លេញម្ចាស់អញតែម្តង ។ តាមគួរយើងគួរចាកចេញដំណើរតាំងពីម្សិលមិញម្ល៉េះ ។ មែន ! បើចេញដំណើរពីម្សិលមិញ លោកម្ចាស់អញច្បាស់ជារួចខ្លួនសុខសាន្ត ហើយបានទាំងលុយ បានទាំងអាវុធទៀត ។ តើអ្អែងជាអាក្បត់ រឺយ៉ាងណា ? តើអ្អែងធ្វើនេះដើម្បីអ្អែងផ្ទាល់ រឺដើម្បីឪអ្អែង រឺដើម្បីខ្មាំង ? រឺដើម្បី*តូរ៉ាណាកា* ? តែអត់បញ្ហាទេអ្នាំជឿអញចុះអា*អូមី* ! អាក្មេងមិនទាន់ជ្រុះពន្លៃពីក្បាល ! ទាំងអ្អែង ទាំងពូជអំបូរ ត្រកូល *កាស៊ីគី* អ្អែង អត់ឈរជាន់ដីបានយូរទៀតទេ ។ អញគួរនិយាយប្រាប់អ្អែងត្រង់ៗតែម្តង តែបើអីចឹង អញមានតែសំលាប់អ្អែងបណ្តោយ ។ រួចបើធ្វើអីចឹងទៅម្ចាស់អញច្បាស់ជាលែងទុកចិត្តអញហើយ ។ លោកម្ចាស់នឹងកំនត់ពេលវេលា មិនមែន អញទេ ។

បុរសចំនាស់បន្ទឹបន្ត :

- អរគុណណាស់ចំពោះបដិសណ្ឋារកិច្ចរបស់អែង *អូមី-សាន* ។ ចាំលើកក្រោយជួបគ្នាទៀត អីលូវនេះខ្ញុំសូមលាសិនហើយ ។

- អោយខ្ញុំសូមពឹងរឿងមួយផងបានទេ ? សូមលោកសួរសុខទុក្ខឪពុករបស់ខ្ញុំជំនួសខ្ញុំផង ។ ខ្ញុំសូមអរគុណយ៉ាងច្រើន ។

-ខ្ញុំសប្បាយចិត្តនឹងធ្វើការងារនេះណាស់ ។ ឪពុកអែង គឺជាមនុស្សល្អណាស់ ។ ម្យ៉ាងទៀតខ្ញុំភ្លេចអោយឈឹង ។ ខ្ញុំភ្លេចអបអរពីរឿងអែង បានដីថែមទៀតនេះ ។

- លោកម្ចាស់គួរសមពេកហើយ ។

- ខ្ញុំសូមអរគុណម្តងទៀតណា *អូមី-សាន* !

*អ៊ីកូរ៉ាស៊ី* លើកដៃលា យ៉ាងស្និទ្ធស្នាល ហើយធ្វើសញ្ញាទៅកូនចៅរបស់ខ្លួន រួចទើប



www.budinst.gov.kh www.elibraryofcambodia.org

នាំកងសេះចេញពីទីភូមិទៅមុន ។

*អូមី* ដើរសំដៅទៅអន្លង់ ។ បព្វជិតនោះ នៅរង់ចាំក្បែរអន្លង់ជាស្រេច ។ *អូមី* មើលដឹងថា បុរសនេះ កំពុងតែឆេះដុំហើយៗគេសង្ឃឹមថា បព្វជិតនេះនឹងធ្វើអ្វីផ្តេសផ្តាស នៅចំពោះមុខអ្នកផង ដើម្បីគេអាចមានលេសអោយបព្វជិតនេះស៊ីខ្សែតីម្តង ។

- បព្វជិតប្រាប់ទៅពួកចុងស្រុក អោយឡើងមកម្តងម្នាក់ៗ ។ ប្រាប់ពួកវាថា លោកម្ចាស់ *យ៉ាប៊ូ* បាននិយាយថា ពួកវាអាចរស់នៅក្នុងចំនោមមនុស្សវិញបានហើយ -*អូមី* និយាយដោយរកពាក្យសាមញ្ញៗ -តែបើពួកវាប៉ះពារវិន័យតែបន្តិច ពីរនាក់ត្រូវចុះអន្លង់វិញ ។ ពួកវាត្រូវអោយស្រួលបួល ហើយត្រូវស្តាប់បញ្ជាទាំងអស់ ។ យល់ទេ ?

- បាទយល់ !

*អូមី* បញ្ជាអោយបព្វជិតថាតាមខ្លួនម្តងទៀត ។ នៅពេលដែលគេឃើញថាបុរសនេះនិយាយបានត្រឹមត្រូវហើយ ទើបគេអោយនិយាយទៅកាន់អ្នកក្នុងអន្លង់ ។

មនុស្សទាំងអស់ឡើងមកលើអន្លង់ម្តងមួយៗ ។ ទាំងអស់ភ្ញាក់ផ្អើលប្រាប់ ។ មានអ្នកខ្លះទាល់តែគេជួយ ។ បុរសម្នាក់បែបឈឺចុកចាប់ណាស់ ព្រោះគេស្រែកជំទាលនៅពេលណាដែលមានអ្នកណាប៉ះដៃគេ ។

- ទាំងអស់ត្រូវមាន ប្រាំបួននាក់ណា៎ !

បព្វជិត *សេពាស្សូ* ឆ្លើយតប :

- អាមួយនោះស្លាប់បាត់ទៅហើយ ។ ខ្មោចវានៅក្នុងអន្លង់នោះ ។

*អូមី*សញ្ជឹងគិតមួយសន្ទុះ

- *អូរ៉ា*ចាត់ចែងបូជាសព ហើយទុកធាតុគេជាមួយពួកចុងស្រុកប៉ុន្មាននាក់ទៀតទៅ ។ យកពួកអស់នេះទៅដាក់ផ្ទះមុននោះចុះ ។ អោយត្រី និងបន្លែទៅពួកវាស៊ីចុកអោយបរិបូរណ៍ ។ បបរ និងផ្លែឈើក៏អីចឹងដែរ ។ នាំពួកអាអស់នេះទៅមុជទឹកផង ។ ពួកវាស្អុយណាស់ ។ នែបព្វជិត ប្រាប់ពួកវាថា បើពួកវាស្រួលបួល ហើយគោរពតាមបញ្ជា ម្ហូបចេះតែមានជាប់ហើយ ។

*អូមី*នៅសំលឹង និងស្តាប់យ៉ាងយកចិត្តទុកដាក់ ។ គេឃើញពួកចុងស្រុកទាំងអស់



www.budinst.gov.kh www.elibraryofcambodia.org

មានប្រតិកម្មយ៉ាងដឹងគុណ ។ គេគិតនៅក្នុងចិត្តទាំងប្រមាថទៅលើពួកទាំងស់នេះថា ចំជាល្ងីល្ងើពកថ្ងាសមែនពួកនេះ ។ អញបង្អត់វាពីរថ្ងៃ ហើយអីលូវនេះ អញអោយទានបន្តិចបន្តួចវាត្រង់កន្ទុយ ។ ពេលនេះ បើអញអោយវាស៊ីអាចម៌ ក៏វាស៊ីដែរ ។

គេបន្លឺឡើង :

- *ម្ភ៉ា* បង្រៀនពួកវាអោយចេះលំអោនខ្លួនត្រឹមត្រូវ ហើយនាំវាទៅអោយឆ្ងាយចុះ ។

រួចគេងាកទៅរកបព្វជិត :

- យ៉ាងម៉េចដែរ ?

- ខ្ញុំទៅហើយ ។ ទៅផ្ទះខ្ញុំ ។ ចេញពី *អាន់ជីរ៉ូ* ។

- យកល្អលោកឯងចេញហើយកុំត្រលប់មកវិញអោយសោះ ទាំងលោកឯង ទាំងពួកបព្វជិតដូចលោកឯង ។ រីមួយក៏ពេលក្រោយមានពួកលោកឯងណាម្នាក់នឹងមកដែនដីខ្ញុំនេះ ពីព្រោះមានអ្នកស្រែ និងអ្នកចំនុះកាន់គ្រិស្តសាសនា របស់ខ្ញុំកំពុងរៀបចំផែនការក្បត់ផង ។

*អូមី* និយាយដោយប្រើការគំរាមកំហែងមិនចំពោះ និងកលល្បិចជាប្រពៃណី ដែលពួក *សាមូរ៉ៃ* ប្រឆាំងគ្រិស្តសាសនា បានប្រើដើម្បីរាំងស្កាត់ ការរីកសាយនៃសាសនាបរទេសនៅក្នុងដែនដីដែលគេត្រួតត្រា ព្រោះថា បើពួកបព្វជិតបរទេសបានទទួលការការពារ គ្រិស្តសាសនិកសញ្ជាតិជប៉ុន មិនមានច្បាប់ណាការពារឡើយ ដោយហេតុនេះ ផ្លាក " *ក្បត់* " ជារនាំងទប់ស្កាត់មួយដ៏មានប្រសិទ្ធភាព ។

- គ្រិស្តសាសនិកជប៉ុនល្អ ។ ជានិច្ច ។ អណ្តាប់ក៏ល្អ ។ មិនដែលមានគំនិតអាក្រក់ ទេ ។ មិនដែល ។

- ខ្ញុំសប្បាយចិត្តណាស់ដោយបានលឺសំដីនេះ ។ កុំភ្លេចថា ដែនដីរបស់ខ្ញុំលាតបន្ថែមម្តុំលីទៀតទៅគ្រប់ទិស ។ លោកឯងយល់ទេ ?

- យល់ ។ បាទយល់ ។ ខ្ញុំយល់ច្បាស់ណាស់ !

*អូមី* សំលឹងមើលបព្វជិតលំអោនខ្លួនហើយទើបគេដើរចេញទៅ ។ ទោះជាបព្វជិត រឺពួកចុងស្រុកក៏ដោយ ក៏ត្រូវតែចេះរបៀបរបបនេះដែរ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

ម្ដាយ *អូមី* បន្លឺឡើង ៖

- អែងចំជាល្អមែន *គីតូ-សាន* ពិសេសអែងចេះគិតគួរខ្ពស់មែន ។ មិនអីទេអោយវាសំរាកចុះ ។

- អ៊ីចឹងក៏បាន ។ សូមលោកស្រីអភ័យទោសដល់នាងខ្ញុំ ដែលមករំខានលោកស្រីបែបនេះ តែនាងខ្ញុំគិតថា ត្រូវមកសួរយោបល់លោកស្រីទើបល្អជាង ។ និយាយអ៊ីចឹង *មីដូរី-សាន* តើការធ្វើដំណើរតាមផ្លូវ របស់អ្នកស្រីមិនសូវយ៉ាប់ណាស់ណាទេមើលទៅ ។

- ហ៊ឺ ! យ៉ាប់មែនទែន *-មីដូរី* ឆ្លើយតប -បានមកដល់ផ្ទះវិញខ្ញុំសប្បាយចិត្តដល់ហើយ ។ ខ្ញុំស្អប់ណាស់ទៅចោលផ្ទះនោះ ។ តើប្ដីខ្ញុំស្រួលបួលទេ ?

- ចាស៎ ! ស្រួលបួលទេ ! យប់មិញគាត់សើចច្រើនណាស់ មើលទៅប្រហែលជាគាត់សប្បាយចិត្តហើយមើលទៅ ។ គាត់ពិសាបានច្រើនណាស់ ហើយអីលូវនេះស្រមុកខ្ញុរហើយ ។

- អ្នកម៉ែ បានប្រាប់ខ្ញុំពីរឿងរ៉ាវដ៏គួរអោយបរសក់ ពេលដែលខ្ញុំមិននៅផ្ទះនេះខ្លះៗដែរ ហើយ ..........!

សំលេងពោរពេញដោយកំហឹង និងពិសរបស់យាយចាស់បន្លឺឡើង ៖

- អែងមិនគួរទៅសោះ ។ នៅឯនេះគេត្រូវការអែង ។ រីមួយអែងមិនគួរនៅទីនេះទេ។ ប្រហែលអែងគួរទៅអោយឆ្ងាយពីទីនេះជារៀងរហូតទៅវិញ ។ ព្រោះត្រលប់មកវិញស្រួលមិនស្រួល នាំទាំងចង្រៃឧបទ្រពចូលផ្ទះផងក៏មិនដឹង ។

*ដូមីរី* ឆ្លើយតបយ៉ាងអត់ធ្មត់ ៖

- មិនអាចជាអ៊ីចឹងទេម៉ែ ។ ជឿខ្ញុំចុះ ។ ខ្ញុំសុខចិត្តសំលាប់ខ្លួនចោល ជាជាងនាំរឿងអាស្រូវអោយមកប្រលាក់ប្រលូសកេរ្តិ៍ឈ្មោះ ដ៏ល្អរបស់អ្នកម៉ែ ។ សូមអ្នកម៉ែអភ័យទោសផងដែលខ្ញុំមិនបាននៅផ្ទះ ។ ខ្ញុំស្ដាយណាស់ ។

- តាំងពីអាសំពៅបិសាចនេះ មកដល់កាលណា ឃើញតែមានរឿងជាប់តែម្ដង ។ អាហឹងហើយ *កាមិច* ង្រៃនោះ។ អាគ្រក់ទាល់តែមែនទែន ។ រួចពេលកំពុងតែប្រញ៉ឹក ពេលគេកំពុងត្រូវការ អែងនៅឯណា ? ណ៎ ! នៅឯ *មីស៊ុីម៉ា* ស៊ីចុកបុកទំពារផឹកស្រាសាកេធ្វើព្រងើយទៅវិញ។



www.budinst.gov.kh www.elibraryofcambodia.org

- អ្នកម៉ែ ឪពុកខ្ញុំស្លាប់ ។ ស្លាប់មុនខ្ញុំទៅដល់មួយថ្ងៃម្លេះ ។

- ហ៊ឹស ! អែងគ្មានទាំងទៅអើតមើលខ្មោចឪអែងផងទេ ។ បើអែងចេញជារៀងរហូតពីផ្ទះយើងកាន់តែឆាប់ពេលណា កាន់តែល្អពេលនោះ ។ នែ៎ ! ម៉េចមិនយកតែមក ។ ផ្ទះមានភ្ញៀវ ហើយ នាងឯងគ្មានចាំច្បាប់ ចាំទំលាប់ទទួលភ្ញៀវអីសោះតែម្រ៉ង ។

- ពេលនាងមកដល់នោះ ខ្ញុំប្រាប់អ្នកបំរើអោយយកមកភ្លាមមិន............

- អីល្ងូវនេះ វាមិនឃើញមកភ្លាមដូចមាត់អែង !

ទ្វាររបើកឡើង ។ នារីអ្នកបំរើម្នាក់លើកថាសតែ និងនំផ្អែមចូលមក ។ *មីជូរី* ចាក់តែបំរើម្តាយក្មេកនាង ដែលកំពុងជេរប្រទេចអ្នកបំរើបណ្តើរ ទំពារនំឃ្មុម១បណ្តើរ ។ រួចយាយចាស់នេះងាកមកនិយាយទៅកាន់ *គីតូ* :

- សូមនាងកុំប្រកាន់មីស្រីបំរើនេះណា *គីតូ-សាន* ។ ទីកតែគ្មានជាតិគ្មានចូវអីទាំងអស់ ។ គ្មានជាតិសោះតែម្រ៉ង ! រួចក្តៅឆេះអណ្តាត ! ក្នុងផ្ទះណឹង មានតែរបៀបអីចឹង !

ក្រោយពីផ្តុំអោយត្រជាក់មួយស្របក់ *មីជូរី* ហុចតែមួយចានទៀតទៅម្តាយក្មេកខ្លួន :

- អ្នកម៉ែយកចាននេះវិញ ។

យាយចាស់ទទួលតែទាំងបង្ខំចិត្ត :

- តើម៉េចក៏ចាំបាច់ចាំពីរដង ?

*មីជូរី* ងាកទៅសួរ *គីតូ* ម្តង :

- តើនាងយល់យ៉ាងម៉េចដែរ ពីរឿងទាំងអស់ណឹង ? រឿងសំពៅលោកម្ចាស់ *យ៉ាប៊ូ* និង *តូដាហ៊្គីរូ-ម៉ាត់ស៊ុ-សាម៉ា* ណឹង ?

- ខ្ញុំមិនដឹងគិតថាម៉េចទេ ។ ដូចពួកចុងស្រុកអីចឹង អ្នកណាទៅដឹងបាន ? ពួកវាចំជាចំលែកអស្ចារ្យតែម្តង ដែលគាត់មកទទឹមពេលនឹងលោកម្ចាស់ *យ៉ាប៊ូ* យ៉ាងនេះ មែនទេ ? តែជារួម សូមអធ្យាស្រ័យចុះ នាងខ្ញុំសូមត្រលប់ទៅវិញហើយ ។

- អូ ! កុំអាលអី *គីតូ-សាន* ។

យាយចាស់និយាយកាត់ផ្ទួង :



www.budinst.gov.kh www.elibraryofcambodia.org

- អីលូវអែងឃើញហើយ *មីដូរី-សាន* ។ ភ្ញៀវគេមិនសប្បាយចិត្ត ហើយទឹកតែយ៉ាប់ មែនទែនតែម្ដង ។

- អត់ទេ ទឹកតែប៉ុណ្ណឹងល្មមចំពោះខ្ញុំហើយ ។ មែនណា ។ តែសូមលោកស្រីអធ្យាស្រ័យ មកពីខ្ញុំហាត់នឿយណាស់ទៅហើយ១ស្អែក ខ្ញុំត្រូវចេញដំណើរផង ។

ក្រោយពីនិយាយបញ្ចើចបញ្ចើរយាយចាស់មួយសន្ទុះមក *គីគូ* ក៏លាត្រឡប់ផ្ទះត្រលប់មកវិញ ។ *មីដូរី* ជូន *គីគូ* ដើរកាត់រានហាល និងសួនច្បារ ។

- *គីគូ-សាន* នាងចេះគិតល្អណាស់ ។ នាងចំជាល្អមែន ។ សូមអរគុណ ។

*គីគូ* ចោលភ្នែកសំលឹងទៅក្រោយមើលផ្ទះមួយខ្ទាច់ ហើយគ្រវីក្បាលខ្លួន :

- តើគាត់តែអ៊ីចឹងរាល់ពេលអ្វី ?

- បើថ្មីៗពីមុន១មកនោះ យប់ណឹងគាត់គួរសមហើយ ។ បើសិនជាគ្មាន *អូមី* និងកូនប្រុសខ្ញុំទេ ខ្ញុំសូមស្បថថា ឃើញដានជើងកន្លែងណា ក៏ចូកចោលដែរ ហើយខ្ញុំទៅបួសជាដូនជីវិញល្អជាង ។ តែអីលូវនេះមានប្ដី មានកូនទៅហើយធ្វើម៉េច ? សំនាងដែរដែលម្ដាយក្មេកខ្ញុំ គាត់ចូលចិត្ត *យេដូ* ហើយគាត់មិនចង់ចេញពីក្រុងនោះយូរទេ -*មីដូរី* ញញឹមទាំងក្រៀមក្រោះ- សំខាន់ត្រូវធ្វើត ធ្វើថ្លង់ទៅ នាងដឹងវិធីនេះ -នាងដកដង្ហើមធំ រូបសំរស់នេះកាន់តែលេចធ្លោថែមទៀតនៅក្រោមពន្លឺខែ -តែអារឿងនេះមិនមែនជារឿងសំខាន់ទេ ។ សូមនាងនិយាយប្រាប់ខ្ញុំទៅមើលថា តាំងពីខ្ញុំចេញទៅ តើមានរឿងអ្វីខ្លះ ?

ហើយនេះក៏ជាហេតុសំខាន់ ដែល *គូគី* ធ្វើដំណើរមកផ្ទះនេះដែរ ព្រោះនាងដឹងថាទាំងម្ដាយ ទាំងប្រពន្ធគ្មានអ្នកណាហ៊ានរំខានដំណេក *អូមី* នោះទេ ។ នាងមកទីនេះដើម្បីប្រាប់ *មីដូរី* នូវរឿងរ៉ាវគ្រប់បែបយ៉ាង ដើម្បី *មីដូរី* អាចរក្សាបាន *កាស៊ីគី អូមី* ។ នាងនិយាយប្រាប់ *មីដូរី* នូវអ្វី១ទាំងអស់ ដែលនាងបានដឹង ។ នាងនិយាយប្រាប់ទាំងពាក្យចចេចចចូចឯនេះ ឯនោះដែលនាងបានលឺ រឺបានដឹង ហើយនឹងអ្វី១ទាំងអស់ដែល *អូមី* បាននិយាយប្រាប់នាងទាំងការសង្ស័យ ការភ័យខ្លាច ទាំងផែនការរបស់គេ ។ និយាយរួមអ្វី១ទាំងអស់ ដែលបានកើតឡើង លើកលែងតែរាត្រីដែលកន្លងផុតទៅនេះ ។ មិនមែននាងលាក់ទេ តែនាងយល់ថា រឿងនេះមិនមែន



www.budinst.gov.kh www.elibraryofcambodia.org

ជារឿងសំខាន់សំរាប់ *មីដូរី* ទេ ។

- *គីគូ-សាន* ខ្ញុំបារម្ភចំពោះប្ដីខ្ញុំណាស់ !

- អ្នកស្រី ! មតិដែលគាត់លើកឡើងគឺវាងវៃណាស់ ។ ខ្ញុំគិតថា អ្វីៗដែលគាត់បានធ្វើគឺត្រឹមត្រូវ ។ លោកម្ចាស់ *យ៉ាហ៊ូ* មិនមែនចេះតែដៃទូលាយនោះទេ ហើយបីពាន់ *កូកូ* មិនមែនធម្មតាទេ ។

- តែលោកម្ចាស់ *តូរ៉ាណាកា* យកសំពៅ និងលុយអស់ទៅហើយ !

- មែន តែនៅពេលដែលលោកម្ចាស់ *យ៉ាហ៊ូ* បានប្រគល់សំពៅជូនជាជំនួន នេះគឺពិតជាល្បិចដ៏អស្ចារ្យមែន ។ ហើយក៏ដោយសារ *អូមី* ដែរ ដែលលើកគំនិតនេះឡើង ។ ហើយនេះគឺជាការបង់ថ្លៃមួយគ្រប់គ្រាន់ហើយ *នេ ?* គេត្រូវតែទទួលស្គាល់ *អូមី-សាន* ថាជាអណ្ដាប់ម្នាក់ដ៏អស្ចារ្យ ។

*គីគូ* និយាយពង្វាងចុះពង្វាងឡើងជុំវិញការពិត ។ តាមពិតទៅនាងដឹងថា *អូមី*កំពុងស្ថិតនៅមាត់ជ្រោះគ្រោះថ្នាក់មួយ ដ៏ធំធេង ។ ហើយរាប់ទាំងគ្រួសារគេទាំងមូល ។ អ្វីដែលត្រូវមកដល់គង់តែមកដល់ -នាងគិតនៅក្នុងចិត្ត ។ ប៉ុន្តែជួយស្រាយចិញ្ចើមនារីដ៏ល្អ គួរជាទីស្រលាញ់នេះក៏មិនខូចខាតអ្វីដែរ ។

- ចាស់ ខ្ញុំក៏គិតអីចឹងដែរ -*មីដូរី* ឆ្លើយតប ។ នាងស្រវាអោប *គីគូ*ទាំងទឹកភ្នែកអរគុណ ។ នាងល្អណាស់ *គីគូ-សាន* ។

នៅឆ្នាំនេះ *មីដូរី* អាយុដប់ប្រាំពីរឆ្នាំហើយ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៨

- តែអែងយល់យ៉ាងម៉េចដែរ *អ៊ិញគីលីស* ?

- បើតាមខ្ញុំគឺមានព្យុះហើយ ។

- អង្កាល់ ?

- មុនព្រលប់

អីលូវនេះពេលជិតថ្ងៃត្រង់ទៅហើយ១ពួកគេ កំពុងឈរនៅឯកន្សៃទូក ។ នេះជាថ្ងៃទីពីរ នៃការធ្វើដំណើរលើសមុទ្ររបស់ពួកគេ ។

- បើសិនជាទូកនេះ ជាទូករបស់អែង តើអែងធ្វើយ៉ាងម៉េច ?

- តើទីដៅយើងនៅចំងាយប៉ុន្មានទៀត ? - *ប្លាក់ថន* សួរ ។

- ក្រោយព្រលប់ដល់ហើយ ។

- ពីនេះទៅដីគោកចំងាយប៉ុន្មាន ?

- បួនទៅប្រាំម៉ោង *អ៊ិញគីលីស* ។ ទេបើរវល់តែទៅជ្រកព្យុះ គឺយើងត្រូវខាតកន្លះថ្ងៃហើយអារឿងនេះ មិនអាចយឺតយ៉ាវបានទេ ។ មើលតើអែងគិតធ្វើយ៉ាងម៉េច ?

*ប្លាក់ថន*ចាប់ផ្ដើមពិចារណាមួយសន្ទុះ ។នៅយប់ទីមួយទូកបានរត់ចុះទៅខាងត្បូងជ្រោយ *អ៊ិស៊ូ* អាស្រ័យដោយក្ដោងធំ ។ នៅពេលដែលគេបានមកដល់ភាគខាងត្បូងបំផុត នៃជ្រោយ *អ៊ិស៊ូ* ហើយ *វ៉ូឌ្រិច* បានបត់សំពៅទៅតាមនីរតីទិស ហើយបានចេញពីតំបន់ដ៏សុខសាន្ត បណ្ដោយឆ្មេរទៅឯលំហសមុទ្រត្រង់ទៅជ្រោយ *ស៊ីនតូ*ដែលនៅចំងាយពីររយម៉ៃល៍ពីនោះទៅវិញ ។

*វ៉ូឌ្រិច* បាននិយាយពន្យល់ប្រាប់ប្លាក់ថនថា :

- ជាមួយទូកបែបនេះ ល្អបំផុតគឺបើកសៀរឆ្នេរ ។ នេះវាសន្តិសុខជាង ។ ប៉ុន្តែវាស៊ីពេលយូរ ហើយពេលវេលាសំខាន់ណាស់ ។ *តូរ៉ាណាកា* បញ្ជាអោយខ្ញុំដឹកលោកសំរាមនេះ ទៅ *អាន់ជីរ៉ូ* និងជូនមកវិញយ៉ាងរហ័សបំផុត ។ បើសិនធ្វើការនេះរហ័ស គេអោយរង្វាន់ដល់ខ្ញុំ ។ តាមពិតទៅតែកុងពួកវា ក៏អាចធ្វើបានដែរលើដំណើរផ្លូវជិតយ៉ាងនេះ ប៉ុន្តែដល់ *ដៃមីញ៉ូ* សំខាន់ដូចអាសំរាមនេះអីចឹង ពួកវាមិនហ៊ានបើកឆ្ងាយពីឆ្នេរទេ ។ ពួកវាមិនមែនអ្នកដើរសមុទ្រទេ ពួក



www.budinst.gov.kh www.elibraryofcambodia.org

អាតយអស់នេះ ។ ពួកវាអាចជាមេចោរ ជាយុទ្ធជនពូកែ តែមិនមែនអ្នកដើរមហាសមុទ្រទេ ។ តាប៉ិ *វ៉ែក្ក* ចេញទាំងច្បាប់កំនត់អោយទូកសមុទ្រជប៉ុនប៉ុន្មានគ្រឿងនោះ ត្រូវតែមានតៃកុង ប៉ិកទុយកាល់ទៀតផង ។ ច្បាប់នេះនៅតែជាធរមាននៅឡើយ ។

- ម៉េចបានជាគាត់ចេញច្បាប់អីចឹង ?

*រ៉ូឌ្រិច* ញាក់ស្មា :

- ប្រហែលជាមានអ្នកណាអោយយោបល់នេះទៅគាត់ ក៏មិនដឹង ។

- អ្នកណា ?

*រ៉ូឌ្រិច* មិនឆ្លើយនឹងសំនួរនេះទេ គេសួរទៅ *ប្លាក់ថន* វិញ :

-កូនសៀវភៅរបស់អែងដែលបាត់នោះ ........អាកូនសៀវភៅប៉ិកទុយកាល់នោះ ជារបស់អ្នកណា ?

- ខ្ញុំមិនដឹងដែរ ។ នៅលើសៀវភៅនោះគ្មានឈ្មោះ គ្មានហត្ថលេខាអីទាំងអស់ ។

- អែងបានវាពីណាមក ?

- ពីថៅកែធំ នៃក្រុមហ៊ុន បូពាំឥណ្ឌារបស់ហូឡង់ ។

-គាត់បានសៀវភៅនេះពីណា ?

*ប្លាក់ថន* ញាក់ស្មា ។

សំនើចរបស់ *រ៉ូឌ្រិច* គ្មានភាពកំប្លុកកំប្លែងឡើយ :

- ណ្ហើយ ខ្ញុំក៏មិនដែលគិតថាអែងនឹងប្រាប់ខ្ញុំដែរ ។ តែអាណាដែលលួចកូនសៀវភៅនេះ ខ្ញុំបន់អោយវាទៅរលត់រលាយនៅឋាននរក អោយរហូត ។

- អែងធ្វើការអោយតាប៉ិ *តូរ៉ាណាកា* អីគេហើងអ្ហ ?

- ទេ មេបញ្ជាការខ្ញុំ និងខ្ញុំទៅលេង *អូសាកា* ទេ ។ តែនេះជាការធ្វើសគុណ របស់មេបញ្ជាការខ្ញុំ ចំពោះ *តូរ៉ាណាកា* តែប៉ុណ្ណោះ ។ មេបញ្ជាការខ្ញុំ ចាត់អោយខ្ញុំមកនេះបណ្តោយទៅ ។ តាមពិត ខ្ញុំជាតៃកុងសំពៅ ......- *រ៉ូឌ្រិច* ឈប់ទ្រឹង -ខ្ញុំរិះតែភ្លេចថា អែងជាសត្រូវ *អ៊ិញគីលីស*។

- ប៉ិកទុយកាល់ និងអង់គ្លេសធ្លាប់ជាសម្ព័ន្ធមិត្តនឹងគ្នា រាប់សតវត្សរ៍ហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- តែអីលូវនេះយើង មិនមែនទៀតទេ ។ នែ ចុះទៅក្រោមទៅ *អ៊ិញគីលីស* ។ អែង ឡើយហត់ណាស់ ។ ខ្ញុំក៏អីចឹងដែរ ហើយមនុស្សដែលហត់ឡើយ ងាយភាន់ច្រលំណាស់ ។ សំរាកហើយសឹមឡើងមកលើវិញ ។

*ប្លាក់ថន* ក៏ចុះទៅសំរាកនៅក្នុងបន្ទប់របស់តៃគុង ។ កូនសៀវភៅរបស់ *រ៉ូឌ្រិច* ស្ថិតនៅលើហិប ដែលវាយភ្ជាប់ទៅនឹងជញ្ជាំង ប្រៀបដូចជាកៅអីតៃគុង នៅកន្លែងកាច់ចង្កូតយ៉ាងនោះដែរ ។ កូនសៀវភៅមានក្របស្បែកដែលសឹកបន្តិចទៅហើយ តែ *ប្លាក់ថន* ឥតបើកវាទេ ។

- ហេតុអីបានជាអែង ទុកកូនសៀវភៅនៅទីនេះ ?

- បើសិនជាខ្ញុំមិនទុកនៅកន្លែងនេះ អែងច្បាស់ជារុករកវា ។ តែបើខ្ញុំទុកវាកន្លែងនេះ អែងនឹងមិនហ៊ានប៉ះពាល់ ហើយក៏មិនហ៊ានបើកមើលដោយគ្មានការអនុញ្ញាតឡើយ ។ អែងជាតៃគុង មិនមែនជាចោរ រឺទាហានទេ ។

- ខ្ញុំនឹងមើលវា ។ បើអែងវិញ អែងក៏ច្បាស់ជាធើអីចឹងដែរ ។

- មិនត្រូវលួចមើលទេអ៊ិញគីលីស ។ តៃគុងណាក៏ដោយ ក៏មិនត្រូវធ្វើយ៉ាងដូច្នេះទេ ។ ទោះជាខ្ញុំ ក៏មិនធ្វើអីចឹងដែរ ។

*ប្លាក់ថន* សំលឹងមើលកូនសៀវភៅមួយសន្ទុះ រួចក៏បិទភ្នែកទៅ ។ ក្នុងពេលពេញមួយថ្ងៃ និងជិតមួយយប់ គេដេកលង់លក់ឥតកំរើកខ្លួន ។ ដូចជាសព្វដងដែរ គេភ្ញាក់ដឹងខ្លួនឡើង នៅមុនពេលព្រលឹម ។ គេប្រើពេលមួយសន្ទុះ ដើម្បីទំលាប់ខ្លួននឹងចលនារបស់ទូក ហើយនឹងស្នូរស្គរដែលបញ្ជាអោយដងចែវ ចលនាបានឯកភាពគ្នា ។ គេដេកកើយដៃយ៉ាងសុខសាន្តនៅក្នុងភាពងងឹត ។ គេនឹកគិតទៅដល់សំពៅរបស់គេ ហើយគេផាត់ចោលចេញនូវកង្វល់អំពីថាតើ ពីពេលគេទៅដល់ដីគោកឯ *អូសាកា* ហើយនឹងមានរឿងរ៉ាវអ្វីខ្លះនោះ ។ដោះរឿងមួយម្តង១ ។ គិតពី *រេលីស៊ីទី* និង *ទុយដ័រ* ឯផ្ទះវិញ ។ ទេកុំអាលគិតពេលនេះ ។ គិតថាមកដល់ពេលនេះ អែងចំជាមានសំនាងហើយ១បើសិនជា ពួកប៉កទុយកាល់ឯទៀតដូចជា *រ៉ូឌ្រិច* នេះ អែងច្បាស់ជានឹងមានសំពៅត្រលប់ទៅស្រុកវិញហើយ ពួកតៃគុងមិនមែនជាសត្រូវនឹងគ្នាទេ ។តែកុំអាលអរអាវ៉ា ។កុំភ្លេចថា អែងជាជាតិអង់គ្លេសជាពួកទមិឡជាអ្នកប្រឆាំងគ្រិស្តសាសនា ។ពួកកាតូលិចត្រួតត្រាពិភពនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

ពួកវាបានត្រួតត្រាពិភពនេះ ។អីលូវនេះពួកយើងនិងពួកហូឡង់នឹងកំទេចពួកវាម្តង ហើយ ។

បន្ទាប់មក គេឡើងទៅខាងលើទូក ។ *វ៉ុន្រ៊ិច* កំពុងអង្គុយនៅលើកៅអីរបស់គេ ។ ភ្នែកគេឡើងក្រហមដោយភាពងងុយ ។ នាវិកជប៉ុនពីរនាក់ កំពុងកាន់ចង្កូតនៅជិតគេ ។

- ខ្ញុំមើលផ្លូវជំនួសអែងអ្វី ?

- អែងយ៉ាងម៉េចហើយ *អ៊ីញគីលីស* ?

- ស្រួលបួលហើយ ។ ខ្ញុំមើលផ្លូវជំនួសអែងអ្វី ?

*ប្លាក់ថន* ឃើញ *វ៉ុន្រ៊ិច* សំលឹងបាន់សមត្ថភាពរបស់គេ :

- មិនអីទេ ។ បើខ្យល់ដូរទិស រឺបើមានការអីកើតឡើង ខ្ញុំដាស់អែងភ្លាម ។

- អរគុណហើយ *អ៊ីញគីលីស* ។ មែនហើយ ខ្ញុំសំរាកមួយភ្លែតសិន ។ ទៅតាមទិសណឹងរហូតទៅ ។ ពេលខ្សាច់ហូរធ្លាក់មកក្រោមអស់ កាច់បូនអង្សាទៅខាងលិច ហើយនៅពេលដែលអស់ខ្សាច់ម្តងទៀត កាច់ទៅលិចប្រាំមួយអង្សាទៀត ។ អែងត្រូវបង្ហាញទិសថ្មីនេះ ប្រាប់អ្នកកាច់ចង្កូត ដោយគូសនឹងដែកឈាន ។ *វ៉ាការីម៉ាស៊ូកា* ?

- *វ៉ៃ* ! -*ប្លាក់ថន* សើច -បូនអង្សាទៅលិច ។ ចុះទៅក្រោមចុះតែកុង គ្រែអែងចំជាអែមមែន ។

តែ *វ៉ាស្ហូវ៉ុន្រ៊ិច* ឥតចុះទៅក្រោមទេ ។ គេទាញអាវក្រៅរបស់គេអោយជិតស្រួលបួល ហើយរំកៀកខ្លួន យ៉ាងស៊ប់ក្នុងកៅអីរបស់ខ្លួន ។ មុនពេលខ្សាច់ជិតអស់គេភ្ញាក់ឡើងមួយភ្លែត ដើម្បីផ្ទៀងផ្ទាត់ទិសរបស់ទូក រួចក៏ដេកលក់បន្តទៅទៀត ។ នៅពេលដែលខ្យល់ដូរទិស គេភ្ញាក់ឡើងម្តងទៀត ប៉ុន្តែនៅពេលដែលគេឃើញថាគ្មានគ្រោះថ្នាក់អ្វីទេមក គេក៏លង់លក់ទៅវិញទៅ ។

នៅពេលព្រឹកព្រលឹម *ហ៊ីរ៉ូ-ម៉ាត់ស៊ី* និង *យ៉ាប៉ូ* -បានឡើងមកខាងលើទូក ។ *ប្លាក់ថន* ឃើញអ្នកទាំងពីរមានទឹកមុខភ្ញាក់ផ្អើល ដោយឃើញរូបគេជាអ្នកបញ្ជាសំពៅ ឯ *វ៉ុន្រ៊ិច* នៅដេកលក់ជិតគេទេវិញ ។ អ្នកទាំងពីរនាក់ឥតនិយាយស្តីអ្វីទៅកាន់ *ប្លាក់ថន* ទេ តែគេបន្តជជែកគ្នាមួយសន្ទុះរួច ក៏ចុះទៅខាងក្រោមវិញ ។



www.budinst.gov.kh www.elibraryofcambodia.org

ពេលជិតថ្ងៃត្រង់ *រ៉ូត្រិច* ភ្ញាក់ឡើង ហើយបញ្ជាទូកអោយបត់ទៅតាមទិសអីសាន ។ គេស្ទង់ខ្យល់យ៉ាងមធ្យ័ត ។ ទាំង *រ៉ូត្រិច* ទាំង *ភ្លាក់ថន* នាំគ្នាពិនិត្យមើលទឹកសមុទ្រ មើលមេឃ និងមើលដុំពពក ។

*រ៉ូត្រិច* សួរ *ភ្លាក់ថន* ម្តងទៀត

- បើសិនទូកនេះជារបស់អែងវិញ តើអែងធ្វើយ៉ាងម៉េច ?

- ខ្ញុំនឹងបែរក្បាលទៅរកឆ្នេរហើយ បើខ្ញុំដឹងថាឆ្នេរនៅខាងណានោះ ។ ទៅចំនុចជិតបំផុត ។ ទូកនេះទ្រាំទឹកមិនបានច្រើនទេ ហើយព្យុះជិតមកដល់ហើយ ។ យ៉ាងយូរបួនម៉ោងទៀតតែប៉ុណ្ណោះ ។

*រ៉ូត្រិច* និយាយរង្វើរ :

- មើលទៅមិនមែន *កៃភូន* ទេ !

- ថាម៉េច ?

- *កៃភូន* ! ជាព្យុះកំបុតត្បូងណាំ ។ តែរដូវនេះ មិនមែនជារដូវខ្យល់ព្យុះទេ ។

- អង្កាល់ទៅអីចឹង ?

- មិនទាន់ដល់ពេលទេ ។ តែនេះក៏ជាព្យុះធំមួយដែរ អីចឹងហើយបានជាខ្ញុំសួរមតិរបស់អែង ហើយខ្ញុំបែរក្បាលទៅតាមទិសពាយ័ព្យវិញហើយ ។

នៅពេលដែល *ភ្លាក់ថន* គូសតំរង់ទិសថ្មី និងពេលដែលអ្នកកាន់ចង្កូតតំរង់ទូកតាមនោះ *រ៉ូត្រិច* ចេញទៅឈរនៅឯបង្កាន់ដៃ ហើយស្រែកប្រាប់មេបញ្ជាការ :

- *អ៊ីស្ទូតិ* មេបញ្ជាការ-*សាន* ។ *វ៉ាការីម៉ាស៊ូកា* ?

- *អ៊ីស៊ូតិ* *ហៃ* !

- ស្តីណឹង ? អោយលឿនមែនទេ ?

*រ៉ូត្រិច* បិទភ្នែកព្រឹម១ដោយការរីករាយ :

-ចេះនិយាយភាសាពួកអាតយនេះខ្លះ ក៏មិនអីដែរ មែនទេ ?មែនហើយ *អ៊ិញ្ជូតិលិស* ។ *អ៊ីស៊ូតិ* មានន័យថា លឿនឡើង ។ នៅស្រុកនេះ ចេះបួនដប់ម៉ាត់រស់ហើយ ។ តែអោយតែចេះ



www.budinst.gov.kh www.elibraryofcambodia.org

ពាក្យត្រូវប្រើ ហើយចំពេលដែលពួកវាស្រួលបួលចិត្តផង ។ ខ្ញុំចុះទៅក្រោមហើយ ។ ខ្ញុំទៅរកអីស៊ីបន្តិច ។

- អែងធ្វើម្ហូបខ្លួនអែងអ្វី ?

- នៅប្រទេសជប៉ុន មនុស្សដែលមានអារ្យធម៌ ត្រូវចេះធ្វើម្ហូប រឺចេះបង្ហាត់ពួកអាស្នាអស់នេះអោយចេះធ្វើម្ហូបដែរ បើមិនចង់ងាប់ដាច់ពោះស្លាប់ទេនោះ ។ ពួកវានេះស៊ីតែត្រីឆៅបន្លែឆៅ ជ្រក់ជាមួយទឹកខ្ទះឡម១តែប៉ុណ្ណឹង ។

រួច *រ៉ូត្រិច* ក៏ចុះទៅក្រោម ។ គេដាក់គន្លឹះទ្វារ រួចហើយគេចាប់ផ្តើមពិនិត្យយ៉ាងម៉ត់ចត់ គន្លឹះសោរហឹបរបស់គេ ។ សក់មួយសរសៃដែលគេដាក់យ៉ាងប្រុងប្រយ័ត្ននៅកន្លែងដដែលនៅឡើយ ។ សក់មួយសរសៃទៀតដែលគ្មានអ្នកណាមើលឃើញក្រៅពីរូបគេ ហើយដែលគេដាក់លើក្របកូនសៀវភៅនោះ ក៏នៅដដែលគ្មានអ្នកណាប៉ះពាល់ឡើយ ។

ក្នុងលោកនេះ ត្រូវតែប្រុងប្រយ័ត្ន កុំប្រហែសអោយសោះ -*រ៉ូត្រិច* គិតនៅក្នុងចិត្ត។ តើនឹងមានប្រការប៉ះពាល់អីទេ បើវាដឹងថាអ្អែងជាតែកុងសំពៅ*លាវដែលត្រាតូ* ដែលជាសំពៅធំខ្មៅ មកពី*ម៉ាកាវ*ក្នុងឆ្នាំនេះ ? ប្រហែលដែរ ។ ព្រោះដល់អីចឹងអែងត្រូវប្រាប់វាថា នេះជាសំពៅមួយក្នុងចំនោមសំពៅធំជាងគេ មានជាងគេនៅក្នុងលោកនេះ ។ មិនមែនធម្មតាទេ ទំងន់មួយរយតោណូនោះ។ ព្រោះអែងអាចថ្លោយនិយាយប្រាប់វាពីទំនិញ ដែលនៅលើសំពៅប្រាប់អំពីជំនួញ ពី*ម៉ាកាវ* និងពីរឿងអី១ទៀតដែលជារឿងមហាសំងាត់ ។ ព្រោះយើងកំពុងតែច្បាំងជាមួយ អង់គ្លេស និងហូឡង់ ។

*រ៉ូត្រិច* ចាក់សោបើកហឹប ហើយយកកូនសៀវភៅផ្ទាល់របស់គេ មកពិនិត្យចំនុចមួយចំនួន ទាក់ទងដល់ចំនុចណាដែលនៅជិតបំផុត ហើយភ្នែកគេក៏ប្រទះឃើញ កញ្ចប់បិទភ្ជិតអាច់ល័ក្ខមួយ ដែលបព្វជិត *សេបាស្ទួ* បានប្រគល់មកអោយគេនៅមុនពេលគេហៀបចេញពី*អាន់ជីរ៉ូ* បន្តិច ។

តិចលោតែកញ្ចប់នេះ គឺកូនសៀវភៅរបស់តៃកុងអង់គ្លេសនោះទៅ ? គេដណ្តឹងសួរនៅក្នុងចិត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

គេប៉ាន់ទំងន់កញ្ចប់ ហើយសំលឹងមើលត្រាភិតរបស់យេស៊ិត ។ គេខំទប់ចិត្តមិនបំបែក អាច់ល័ក្ខដើម្បីមើលអោយច្បាស់ថា តើកញ្ចប់នេះមានអ្វីខ្លះនោះ ។ *ប្លាក់ថុន* បាននិយាយប្រាប់ គេថា កងនាវាហូឡង់ បានមកដល់ទីនេះ ដោយឆ្លងកាត់ច្រកសមុទ្រ *ម៉ារស៊ើឡង់* តែប៉ុណ្ណឹង ។ អា*អ៊ិញគីលីស* នេះសួរច្រើន ប៉ុន្តែចង់ដឹងការណ៍អ្វីពីវាវិញដូចជាអួសឬស៊ីបញ្ច្រាសចុង ។ គិតទៅ វាជាមនុស្ស វៃ ឆ្លាត ហើយប្រកបដោយគ្រោះថ្នាក់ណាស់ទៀតផង ។

តើជាកូនសៀវភៅរបស់វា រឺក៏មិនមែន ? បើសិនជាមែន តើមានប្រយោជន៍អីសំរាប់ គណៈបព្វជិតនោះ ?

គេគ្រវៀងខ្លួន នៅពេលដែលគេគិតទៅដល់និកាយសាសនា និងតុលាការសាសនា ។វា មានបព្វជិតល្អវាមានបព្វជិតអាក្រក់ ហើយភាគច្រើនអាក្រក់ ។តែទោះជាយ៉ាងណាក៏ពួកនេះនៅ តែជាបព្វជិតដដែល ។ វិហារត្រូវតែមានបព្វជិត ហើយបើគ្មានពួកនេះ ដើម្បីធ្វើជា អ្នកកណ្តាល អោយយើងទេ យើងនឹងត្រូវវង្វេងវង្វាន់ក្នុង *ពិភពសាតង់* នេះជាមិនខាន ។ ឱព្រះ អើយព្រះអង្គ យ៉ាងម៉េចយ៉ាងម៉ា ជួយស្រោចស្រង់ខ្ញុំអោយរួចពីពួកបិសាច និងពីពួកបព្វជិតទាំងនេះផង ។

កាលពីនៅកំពង់ផែ *អាន់ជិរ* ក្នុងពេលដែល *រ៉ូត្រិច* កំពុងស្ថិតនៅក្នុងបន្ទប់មួយ ជា មួយ *ប្លាក់ថុន* នោះ បព្វជិតសេបាស្ទ្យូបានបើកទ្វារចូលមក ។ អ្នកទាំងពីរទើបស្រស់ស្រូបហើយ១ សំនល់ទាំងប៉ុន្មាននៅក្នុងចានឈើរបស់ពួកគេនៅឡើយ ។

ពេលឃើញទិដ្ឋភាពបែបនេះ បព្វជិត *សេបាស្ទ្យូ* សួរឡើង :

- អែងទទួលទាន ជាមួយពួកទមិឡអីចឹង?គ្រោះថ្នាក់ណាស់ដែលទទួលទានរួមជា មួយពួកវានោះ ពួកវាដូចមេរោគអីចឹង តើវាមានប្រាប់អែងថាវា ជាចោរសមុទ្រទេ ?

- មានចិត្តទូលាយជាមួយខ្មាំងគឺជាករណីយកិច្ចរបស់គ្រិស្តសាសនិកព្រះតេជគុណ ។ ពេលដែលខ្ញុំនៅក្នុងកណ្តាប់ដៃពួកវា១ធ្វើល្អជាមួយខ្ញុំ ។ អីលូវនេះ ខ្ញុំគ្រាន់តែសងសប្បុរសធមិនេះ ទៅវិញទេតើ ។

រួច *រ៉ូត្រិច*ក៏លុតជង្គង់ចុះ និងអោនថើបរូបព្រះឆ្កាងរបស់បព្វជិត*សេបាស្ទ្យូ* ។ ចប់សព្វ គ្រប់ហើយ គេងើបឈរឡើងចាក់ស្រាប្រគេនទៅបព្វជិតនេះ ជាមួយនឹងសំដីថា :



www.budinst.gov.kh www.elibraryofcambodia.org

- តើព្រះតេជគុណមានការអ្វី ?

- ខ្ញុំចង់ដោយសារសំពៅនេះ ទៅអូសាកាផង ។

- អ៊ីចឹងចាំខ្ញុំសួរពួកវាសិន ។

*រ៉ូទ្រិច* ក៏ចេញទៅទាក់ទងជាមួយមេបញ្ជាការ ហើយសំនើនេះក៏ត្រូវគេបញ្ជូនពីមួយទៅមួយ រហូតដល់ *តូដាហ្គី-ម៉ាត់ស៊ុ*១ក៏បានតបវិញថា លោកម្ចាស់ *តូរ៉ាណាកា* ឥតបាននិយាយពីរឿង នាំបព្វជិតបរទេសពី *អានជីរ៉ូ* ឡើយ ដោយហេតុនេះលោកមានការសោកស្តាយណាស់ ដែលគេមិនអាចទទួលបព្វជិត *សេបាស្ទ្យូ* អោយដោយសាបាន ។

អ៊ីចឹងទៅបព្វជិត *សេបាស្ទ្យូ* ក៏ស្នើឡើងចង់និយាយតែពីរនាក់ជាមួយ *រ៉ូទ្រិច* ហើយសុំអោយ *ភ្នាក់ងារ* ឡើងទៅខាងលើទូក ។ ពេលនៅស្ងាត់តែពីរនាក់ហើយ បព្វជិត*សេបាស្ទ្យូ* ក៏ហុតកញ្ចប់បិទត្រានេះចេញមក :

- ខ្ញុំស្នើអែង ប្រគល់របស់នេះទៅព្រះសង្ឃរាជផង ។

- ខ្ញុំមិនដឹងទេថាតើលោកនៅ*អូសាកា* ទៀតរឺអត់ ។ហើយខ្ញុំមិនដឹងជាទៅ*ណាកាសាគី*ភ្លាមក៏មិនដឹង ។ អានេះអាស្រ័យមេបញ្ជាការខ្ញុំ ដែលទៅមុនខ្ញុំនោះ មានទុកបញ្ជាយ៉ាងណាសំរាប់ខ្ញុំ តែប៉ុណ្ណោះ ។

- អ៊ីចឹង ប្រគល់អាណឹងទៅព្រះតេជគុណ *អាល់វីតូ* ទៅ ។ តែសំខាន់គឺយ៉ាងណាយ៉ាងណាក្តី ត្រូវតែប្រគល់វាអោយទៅដល់ដៃព្រះតេជគុណ *អាល់វីតូ* ផ្ទាល់ណា ។

- ទុកចិត្តចុះ ។

- កូនអែងសូត្រធម៌ចុងក្រោយបំផុតពីអង្កាល់ ?

- កាលពីថ្ងៃអាទិត្យ ព្រះតេជគុណ ។

- អែងចង់អោយខ្ញុំ អោយធម៌ទេ ?

- បាទ ! អរគុណណាស់ ។

*រ៉ូទ្រិច* អរណាស់ដែលបព្វជិត *សេបាស្ទ្យូ* បានស្នើមតិនេះ ដោយហេតុថា ដោយជីវិតរបស់គេធ្វើនឹងសមុទ្រយ៉ាងនេះ គេរមែងមានអារម្មណ៍ស្ងប់ជាងនៅពេលសូត្រធម៌រួចម្តងៗ ។



www.budinst.gov.kh www.elibraryofcambodia.org

អីលូវនេះនៅក្នុងបន្ទប់របស់គេ *រ៉ូឌ្រិច*អង្គុយសំលឹងមើលកញ្ចប់ទាំងចិត្តកន្ទះរា ។ ហេតុអីបានជាត្រូវប្រគល់ទៅព្រះតេជគុណ *អាលវីតូ* ? ព្រះតេជគុណ *ម៉ាកតាំង អាលវីតូ*គឺជាអ្នកចរចាដ៏សំខាន់ក្នុងរឿងពាណិជ្ជកម្ម ហើយក៏ជាអ្នកបកប្រែផ្ទាល់របស់អម្ចាស់ *វ៉ែកូ* ជាច្រើនឆ្នាំ ដោយហេតុនេះលោកជាមនុស្ស មានចំនងស្និទ្ធស្នាលជាមួយ *ដៃមីញ៉ូ* គ្រាត់ៗជាច្រើន ។ លោកតែងធ្វើដំណើរចុះឡើង រវាង*ណាកាសាគី* និង*អូសាកា* ហើយលោកស្ថិតនៅក្នុងចំនោមមនុស្សដ៏កំរ និងជាជនជាតិអឺរ៉ុបតែម្នាក់គត់ ដែលអាចជួប *វ៉ែកូ* នៅពេលណាក៏បាន ។ ព្រះតេជគុណ *អាលវីតូ* ជាមនុស្ស ដ៏មហាឈ្លាសវៃ ។ លោកនិយាយភាសាជប៉ុនយ៉ាងស្ទាត់ ហើយលោកស្គាល់ពីជនជាតិជប៉ុន ប្រពៃណីជប៉ុន ជាងមនុស្សណាៗទាំងអស់នៅអាស៊ី ។ អីលូវនេះ លោកជាជនជាតិប៉័កទុយកាល់ ដ៏មានឥទ្ធិពលបំផុត ក្នុងទំនាក់ទំនងជាមួយក្រុមប្រឹក្សាអាជ្ញាធរសិទ្ធិ និងជាពិសេសជាមួយ *អ៊ីស៊ីដូ* និង *តូរ៉ាណាកា* ។

ទាល់តែពួក*យេស៊ូត* ទើបអាចបញ្ចូលមនុស្ស អោយឈានទៅដល់ឋានៈបែបនេះបាន - *រ៉ូឌ្រិច* គិតនៅក្នុងចិត្តទាំងការភ័យខ្លាច ។ បើសិនជាគ្មានសមាគមព្រះយេស៊ូទេ ប្រហែលជាគ្មានអ្នកណាអាចឃាត់ពួកទមិឡបានឡើយ ហើយប្រហែលជាប៉័កទុយកាល់ និងអេស្ប៉ាញក្លាយទៅជាប្រូតេស្តង់បាត់ទៅហើយ ។

រួចវាយ៉ាងម៉េចអែង បានជាអែងគិតតែពីរឿងពួកបព្វជិតនេះអីចឹង ? -*រ៉ូឌ្រិច* ដណ្ដើងសួរខ្លួនឯងយ៉ាងលឺៗ -អែងដឹងហើយថា ពេលណាអែងគិតពីរឿងពួកនេះ អែងមួម៉ៅហើយ អីចឹងមែន តែម៉េចចាំបាច់ធ្វើរបស់នេះទៅព្រះតេជគុណ *អាលវីតូ* ធើអី ? បើសិនជាក្នុងកញ្ចប់នេះមានកូនសៀវភៅមែន តើកូនសៀវភៅនេះ សំរាប់ប្រគល់អោយទៅ *ដៃមីញ៉ូ* គ្រិស្តសាសនិកណាម្នាក់ វី យ៉ាងម៉េច ? វីមួយក៏សំរាប់ *អ៊ីស៊ូដូ* វី *តូរ៉ាណាកា* ? វីមួយក៏សំរាប់មេបញ្ជាការអញ ? វីមួយក៏ កូនសៀវភៅនេះត្រូវបញ្ជូនទៅទីក្រុងរ៉ូម អោយពួក *ស្ប៉ាញ៉ូល* ? ម៉េចបានជាយកទៅអោយព្រះតេជគុណ *អាលវីតូ* ទៅវិញ ? បព្វជិត *សេបាស្ទ្យូ* អាចប្រាប់ថា អោយយកទៅអោយ *យេស៊ូត*ណាមួយក៏បានដែរតើ ។

រួចហេតុអី បានជា *តូរ៉ាណាកា* ចង់ជួប *អ៊ិញ៉ូគីលីស* នេះ ?



www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងចិត្តអញ១ដឹងថា អញគួរតែសំលាប់ *ត្រាក់ថុន* ។ វាជាសត្រូវ វាជាទមិឡ ។ តែវាមានអីមួយសំខាន់ជាងនេះទៅទៀត ។ អញមានអារម្មណ៍ថា *អ៊ិញគីលិស* នេះ គឺជាគ្រោះថ្នាក់សំរាប់ពួកយើងទាំងអស់គ្នា។ ម៉េចបានជាអញគិតអ៊ីចឹងទៅវិញ ? វាជាតែកុងទេតើ។ ជាតែកុងដ៏អស្ចារ្យមួយ។ ជាមនុស្សរឹងមាំមានប្រាជ្ញាឈ្លាសវៃ ជាមនុស្សល្អ។ លើចំនុចទាំងនេះគ្មានអ្វីគួរអោយព្រួយបារម្ភទេ ។ បើអ៊ីចឹងហេតុអីក៏អញខ្លាចវា ? វាជាបិសាចអ្វី ? អញចូលចិត្តវា តែអញមានអារម្មណ៍ថា បើអញសំលាប់វាបានកាន់តែឆាប់ពេលណាកាន់តែល្អពេលនោះ ។ មិនមែនសំលាប់ដោយសារកំហឹងទេ។គឺគ្រាន់តែដើម្បីការពារពួកយើង?ប៉ុន្តែហេតុអី ?អញខ្លាចវាណាស់...

តើត្រូវធ្វើយ៉ាងម៉េចអីចេះ ? ទុករឿងនេះស្រេចតែវាសនាចាត់ចែងទៅចុះ រឺយ៉ាងម៉េច ? ព្យុះជិតមកដល់ហើយ១នេះជាមហាព្យុះផង ។

- ឱព្រះអង្គអើយ ផ្តន្ទាទោសខ្ញុំចុះ ហេតុអីបានជាខ្ញុំមិនចេះសំរេចការអីអោយវាបានងាយសោះអ៊ីចឹង ?

☆ ☆ ☆

ព្យុះបានមកដល់នៅមុនពេលព្រលប់ក្នុងពេល ដែលពួកគេនៅឯលំហសមុទ្រនៅឡើយ។ ឆ្ងាយនៅប្រហែលជាដប់ម៉ៃយ៍ទៀត។ ជ្រោយដែលគេតំរង់ទូកទៅនោះ គឺជាកន្លែងមួយសន្តិសុខតែនៅសែនឆ្ងាយនៅឡើយពីក្រសែភ្នែករបស់គេ ។ ជាកន្លែងដែលគ្មានថ្មាំងថ្មប៉ប្រះទឹកគ្មានផ្ទុកខ្សាច់ឡើយ ។ ប៉ុន្តែដប់ម៉ៃយ៍ គឺដប់ម៉ៃយ៍ហើយ១សមុទ្រកាន់តែរំពើកខ្លាំងឡើង១អាស្រ័យដោយកំលាំងខ្យល់ ។

ព្យុះបក់បោកមកពីទិសអីសាន មកចំខាងស្តាំទូក ហើយវិលវល់ម្តងពីកើត ម្តងពីជើង។ សមុទ្រឡើងពណ៌ស្លេ ។ ដោយគេតំរង់ទូកទៅទិសពាយ័ព្យនោះ រលករត់បុកទូកគេយ៉ាងគំហុកតែម្តង ធ្វើអោយទូកឃ្លេងឃ្លោង យ៉ាងគួរអោយបារម្ភ ។ ទូកនេះមានបាតរាក់ ហើយធ្វើសំរាប់យកល្បឿន និងរត់នៅលើទឹកស្ងប់ ដោយហេតុនេះទោះបីជាអ្នកចែវមានវិន័យ និងប៉ិនប្រសប់យ៉ាងណាក្តី ក៏ពួកគេមានការលំបាកប្រើច្រវាកាប់ទឹកអោយបានឯកភាពគ្នា និងអោយពេញកំលាំងបានដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- នែ៎ កាច់ទូកឡើងបញ្ច្រាសខ្យល់វិញ -*ភ្ជាក់ថន* ស្រែក ។

- ដឹងហើយ តែចាំបន្តិចទៀតសិន -*វ៉ូទ្រិច* ស្រែកតប ។

អ្នកទាំងពីរសុទ្ធតែដឹងថា បើគេចាក់ទូកបណ្តោយខ្យល់ គេមិនអាចចេញដល់ទីដៅរបស់គេបានទេ ដោយហេតុថា រលកហើយនឹងខ្យល់ពិតជាជំរុញទូក អោយកាន់តែឃ្លាតឆ្ងាយនិងកាន់តែរហ័សថែមទៀតពីច្រាំង ។ ទិសខាងត្បូង គឺជាកន្លែងមហាអន្ធការ ។ ពីនេះចេញទៅភាគខាងត្បូងរាប់ពាន់ម៉ៃល៍ គ្មានដីមួយដុំណាទេ ។

អ្នកទាំងពីរ សុទ្ធតែចងខ្លួនភ្ជាប់ទៅនឹងជញ្ជាំង ដើម្បីទប់នឹងភាពឃ្លេងឃ្លោងរបស់ទូក។ ក្នុងពេលនេះ ទឹកមិនទាន់សាចចូលទូកច្រើននៅឡើយទេ ប៉ុន្តែទូកផ្ទុកអីវ៉ាន់ច្រើន ដោយហេតុនេះ វាលិចជ្រៅក្នុងទឹកលើសពីធម្មតា។ នៅក្នុងពេលព្យុះមិនទាន់មកដល់ *វ៉ូទ្រិច*បានរៀបចំចាត់ចែងសព្វគ្រប់ជាស្រេច ។ ឃ្លុបទាំងអស់ ត្រូវបានបិទយ៉ាងជិត ហើយមនុស្សម្នាទាំងអស់ត្រូវបានប្រកាសអាសន្នជាមុន ។ *ហ្ស៊ីរ-ម៉ាត់ស៊ី* នឹង *យ៉ាប៊ូ* បានប្រាប់គេថា ពួកគេទាំងពីរនាក់នៅខាងក្រោមតែមួយសន្ទុះទេ រួចពួកគេនឹងឡើងមកខាងលើទូកវិញហើយ ។ *វ៉ូទ្រិច* ញាក់ស្មាហើយបានពន្យល់យ៉ាងច្បាស់ថា ឡើងមកខាងលើទូក នៅពេលមានព្យុះរបៀបនេះ គឺគ្រោះថ្នាក់បំផុត ។ ប៉ុន្តែ *វ៉ូទ្រិច* ជឿថា អ្នកទាំងពីរមិនយល់ឡើយ ។

- រួចពួកវាពីរនាក់ណឹងប្រុងធ្វើអី ? -*ភ្ជាក់ថន* សួរទៅ *វ៉ូទ្រិច* ។

- អ្នកណាទៅដឹង *អ៊ិញគីលីស* ? តែមានរឿងមួយដែលអែងត្រូវតែច្បាស់អោយហើយទៅ គឺថាពួកវាមិនយំសោកព្រោះរឿងខ្លាចទេ ។

នៅលើទូក អ្នកចែវប្រឹងឡើងខ្ទីត ។ជាធម្មតាក្នុងដងចែវមួយមានមនុស្សពីរនាក់ ។ប៉ុន្តែនៅពេលនេះដើម្បីបញ្ចោសន្តិសុខ បញ្ចោបង្កើនល្បឿន និងអោយបានខ្លាំង *វ៉ូទ្រិច* បានដាក់មនុស្សបីនាក់ក្នុងដងចែវមួយ ។ អ្នកចែវមួយចំនួនទៀត នៅរង់ចាំវេនខ្លួននៅខាងក្រោម ។ នៅឯក្បាលទូក ប្រធានដងចែវ ដែលជាមនុស្សពោរពេញដោយបទពិសោធន៍ បានទូងស្គររង្វើលជាងមុនទៅតាមសង្វាក់ទឹករលកសមុទ្រ ។ ទូកនៅតែជ្រែកទឹកទៅមុខជានិច្ច ថ្វីត្បិតតែតួវាកាន់តែឃ្លេងឃ្លោងនិងកាន់តែពិបាកយកចង្កូតយ៉ាងណាក្តី ។ បន្ទាប់មកទៀតផ្ទៃសមុទ្រកាន់តែបោកបក់ធ្វើ



www.budinst.gov.kh www.elibraryofcambodia.org

អោយប្រធានដងចែវ មិនអាចវាយសង្វាក់អោយស្របបានទៀតឡើយ ។

- ប្រយ័ត្នខាងមុខ !

ទាំង *ប្លាក់ថន* ទាំង *រ៉ូទ្រិច* ស្រែកឡើងក្នុងសំលេងតែមួយ ។ ទូកឃ្លេងឃ្លោងគួរអោយស្ញើប ធ្វើអោយច្រវ៉ាជាងម្ភៃកាប់ប៉ះតែខ្យល់ទទេ ។ ភាពជ្រួលច្របល់បានកើតមានឡើងមួយរំពេច ។ តំហុកទឹកទីមួយ បានស្រោចគ្របពីលើទូក ធ្វើអោយចំហៀងប៉ែកខាងឆ្វេងទទឹកជោក ។ ទាំងអស់គ្នា មានអារម្មណ៍ដូចលិចស្រិបចុះទៅក្នុងសមុទ្រ ។

- អែងទៅក្បាលទូក - *រ៉ូទ្រិច* បញ្ជា -ប្រាប់ពួកវាអោយលើកដងចែវម្ខាង១ពាក់កណ្តាលឡើង ! ឆាប់ឡើង ! ព្រះអើយ !

*ប្លាក់ថន* ដឹងថា បើគ្មានខ្សែការពារទេ គេអាចត្រូវទឹកគួចយកយ៉ាងងាយ ។ ប៉ុន្តែទន្ទឹមនេះ គេក៏ដឹងដែរថា បើមិនលើកដងចែវឡើងទេ ពួកគេគ្មានផ្លូវណាចេញផុតទេ ។

គេដោះខ្សែចេញ ហើយដើរប្រតោងតែមនៅលើក្តាររអិលព្រិល សំដៅទៅក្បាលទូក ។ រំពេចនោះទូករេក្បាលរិប ហើយ *ប្លាក់ថន* ត្រូវបោកទៅក្បាលទូក ។ មនុស្សម្នាក់ត្រូវទឹកកួចយកទៅបាត់ ។ *ប្លាក់ថន* ក៏មានអារម្មណ៍ថា ខ្លួនគេត្រូវទឹកស្រូបទៅជាមួយដែរ ។ គេស្រវ៉ាចាប់តែមទូកជាប់ ។ សរសៃដៃគេស្ទើរដាច់ចេញពីគ្នា ប៉ុន្តែគេខ្ទាំតែមទូកយ៉ាងជាប់មុឹង ។ បន្ទាប់មកដៃគេមួយទៀត ស្រវ៉ាចាប់បានបង្គោលមួយ ហើយគេខំទាក់ខ្លួនឡើងមកលើទូកវិញទាំងឈ្លក់ទឹកកខក់ ។ ពេលជើងរបស់គេជាន់ប៉ះក្តារទូកវិញហើយ គេរលាក់ទឹកបណ្តើរ អរគុណព្រះបណ្តើរ ទន្ទឹមនេះគេគិតនៅក្នុងចិត្តថា ជីវិតទីប្រាំពីររបស់គេ បានរលាយបាត់ទៅហើយ ។ ព្រោះគេនៅចាំសំដីតា *អាល់បាទការ៉ាដុក* ដែលតែងប្រដៅថា តៃកុងដែលពូកែត្រូវតែដូចជាឆ្មាអីចឹង ខុសគ្នាត្រង់តែថា ឆ្មាមានជីវិតតែប្រាំបួន ឯតៃកុងមានជីវិតដប់តែប៉ុណ្ណោះ ។

បុរសម្នាក់នៅដេកស្តឹកក្បែរជើងរបស់ *ប្លាក់ថន* ។ គេស្រវ៉ាចាប់បុរសនេះជាប់ ហើយលុះត្រាតែឃើញផុតគ្រោះថ្នាក់ ទើបគេលែងដៃអោយបុរសនោះទៅកន្លែងរបស់ខ្លួនវិញ ។ គេងាកក្រលេកទៅមើល *រ៉ូទ្រិច* ដែលនៅឯកន្សែបណ្តើរ ក្នុងពោះគេប្រទេចផ្តាសា *រ៉ូទ្រិច* ដែលបណ្តោយអោយចង្កូតរបូតចេញពីដៃនោះបណ្តើរ ។ *រ៉ូទ្រិច* គ្រវីដៃជាសញ្ញាមករកគេ ហើយស្រែក



www.budinst.gov.kh www.elibraryofcambodia.org

ប្រាប់គេពីរឿងមួយ ប៉ុន្តែសំរែកគេត្រូវសំលេងរលក ដែលបក់មកជាមួយនោះគ្របបាត់ទៅ ។ *ភ្ជាក់ផន* បានឃើញថា ទូកបានដូរទិសហើយៗអីលូវនេះគេរត់បណ្តោយខ្យល់ម្តង ។ ដោយហេតុនេះគេយល់ថា ការរទូកអំបាញ់មិញនេះ មិនមែនជាការចៃដន់ទេ ។ ល្អដែលវាដូរទិសនេះ *ភ្ជាក់ផន* គិតនៅក្នុងចិត្ត -តែអាកូនអត់ពូជនេះ គួរតែប្រាប់អញមួយម៉ាត់ជាមុនសិនអីទៅចុះ ។ រឿងងាប់មិនខ្លាចទេ តែអញមិនចូលចិត្តងាប់ទទេៗអីចឹងទេ ៗ ។

គេលើកដៃសងទេវិញ ហើយគេចាប់ផ្តើមការងាររបស់គេ ។ អ្នកចែវទាំងអស់នៅឃរស្ងៀម លើកលែងតែអ្នកកាន់ដងចែវទាំងពីរនៅខាងមុខ ដែលខំរាទូកអោយនៅរត់តាមបណ្តោយខ្យល់ដដែលតែប៉ុណ្ណោះ ។ ដោយប្រើដៃ និងសំរែករបស់ខ្លួន *ភ្ជាក់ផន* បញ្ជាអោយគេលើកដងចែវពាក់កណ្តាល បន្ថែមមនុស្សជាទ្វេទៅដងចែវដែលកំពុងធ្វើសកម្មភាព រួចទើបគេរៃទៅកន្ធែវិញ ។ ពួកបុរសទាំងនេះ នៅយ៉ាងស្ងៀមស្ងាត់គ្មានបង្ហាញនូវការព្រួយបារម្ភអ្វីទាំងអស់ ហើយថ្វីត្បិតតែក្នុងចំនោមពួកគេមានអ្នកខ្លះមិនស្រួលខ្លួន ព្រោះពុលរលកយ៉ាងណាក្តីក៏ពួកគេនៅអង្គុយរង់ចាំបញ្ជាដោយគ្មានជ្រួលច្របល់អ្វីទាំងអស់ ។

ឆ្នេរសមុទ្រនៅជិតបង្កើយ តែវាហាក់ដូចជាស្ថិតនៅរាប់លានយោជន៍អីចឹង ។ នៅពីខាងអីសាន មេឃងងឹតស្លុប ។ តំនក់ទឹកភ្លៀងវាយវាត់នៅលើមុខមាត់របស់ពួកគេ ហើយកំលាំងខ្យល់ ក៏បក់កាន់តែខ្លាំងឡើងៗ ។ បើសិនជាគេនៅលើសំពៅអេរ៉ាសវិញ ភ្ជាក់ផនគ្មានអ្វីបារម្ភសោះឡើយ ។ គេអាចទៅដល់កន្លែងជំរក រឺបត់ក្បាលត្រលប់ក្រោយយ៉ាងស្រួល ។ សំពៅរបស់គេសាងសង់ឡើង សំរាប់ទប់ទល់នឹងគ្រប់អាកាសធាតុ ។ ចំនែកទូកនេះវិញអត់សោះតែម្តង ។

- គិតយ៉ាងម៉េចទៅ *អ៊ីញគីលើស* ?

- ទោះជាអញប្រាប់អែងយ៉ាងម៉េចក៏គង់តែអែង ធើតាមតែចិត្តអែងដែរ - *ភ្ជាក់ផន* ស្រែកប្រជែងនឹងខ្យល់ -តែបើទឹកនៅតែសាចចូល អាទូកនេះលិចលឿនជាងដុំថ្មទៅទៀត ។ រួចមួយទៀត ពេលណាដែលខ្ញុំចូលទៅក្បាលទូក ប្រាប់ខ្ញុំផងថាអែងកាច់ក្បាលទូក ។ បើល្អបត់ទូកទាន់ពេលខ្ញុំនៅមានខ្សែការពារក្រែងលោ បានដល់ដីគោកទាំងពីរនាក់ ។



www.budinst.gov.kh www.elibraryofcambodia.org

-នេះគឺជារឿងទេវតាអ្នកសំរេចទេ *អ៊ិញគីលីស*។អំបាញ់មិញគឺរលកទឹកវាវាយបង្វែរទូកទេ។

- ខ្ញុំរិះតែធ្លាក់ទៅក្នុងទឹក ។

- ខ្ញុំឃើញហើយ ។

*ព្លាក់ថន* សំលឹងប្រមាណមើលទិសទូក :

- បើនៅតែតាមទិសណើង យើងមិនអាចដល់ច្រាំងបានទេ ។ យើងនឹងផុតជ្រោយប្រហែលមួយទៅពីរម៉ៃយ៍ ។

- ខ្ញុំបើកតាមទិសណើងសិន ។ រួចនៅពេលណាត្រូវការសឹមបត់ក្បាលទៅរកច្រាំងវិញ ។ អែងចេះហែលទឹកទេ ?

- ចេះ !

- ល្អ ។ ខ្ញុំមិនដែលរៀនហែលទឹកទេ ព្រោះអារឿងនេះគ្រោះថ្នាក់ណាស់ ។ ខ្ញុំគិតថាបើលង់អោយវាលង់រហ័សតែម្តង គ្រាន់បើជាងលង់ងាប់យឺត -*រ៉ូប៊ែច* គ្រញែងខ្លួន ជាសភាវតតិ - ឱព្រះអើយព្រះ យ៉ាងណា១កុំអោយខ្ញុំយកសមុទ្រធ្វើជាផ្នូរអោយសោះ យប់នេះអាកូនមីចោរសំពៅនិងអារូបអញនេះ ត្រូវតែដល់ច្រាំង ។ វាត្រូវតែទៅដល់ ។ ខ្ញុំដឹងស្រេចទៅហើយថា បើសិនជាយើងបត់ ហើយរត់បញ្ច្រាសខ្យល់នោះ យើងច្បាស់ជាលិចមិនខាន ព្រោះទូកយើងដឹកធ្ងន់ពេក ។

- សំរាលទូកទៅ ។ គ្រវាត់អីវ៉ៃអីវ៉ាន់ចោលទៅក្នុងសមុទ្រទៅ ។

-ស្តេចសំរាមច្បាស់ជាមិនព្រមដាច់ខាត ។ គាត់ត្រូវតែទៅដល់ជាមួយអីវ៉ាន់ បើមិនអីចឹងទេគាត់ មិនបាច់ទៅដល់វិញល្អជាង ។

- សាកសួរគាត់ទៅមើល ។

- ព្រះអើយ អែងថ្លង់ទេអ្ហី ? ខ្ញុំប្រាប់អែងហើយតើអែងដឹងច្បាស់ណាស់ថា វាមិនព្រមទេ ។

*រ៉ូប៊ែច* ខិតទៅជិតអ្នកកាន់ចង្កូត ដើម្បីផ្ទៀងផ្ទាត់អោយច្បាស់ថា អ្នកទាំងនេះពិតជាយល់ថា ពួកគេនៅតែបើកបណ្តោយខ្យល់តទៅទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

- មើលពួកវាអោយមែនទែន *អ៊ុញគីលីស* អែងទទួលធើតែកុងម្តង ។

*រួចរ៉ូឡិច* ដោះខ្សែការពារចេញ ហើយក៏ចុះជណ្តើរទៅផ្នែកកណ្តាលនៃទូកដោយជើងយ៉ាងរឹងមាំឥតញាប់ញ័រ ។ អ្នកចែវទាំងប៉ុន្មានសំលឹងមើលគេឥតដាក់ភ្នែក នៅពេលដែលគេនិយាយពន្យល់ដោយសំដីផង ដោយកាយវិការផង ជាមួយនឹងមេបញ្ជាការអំពីផែនការរបស់គេ ។ *ហ៊ីរ៉ូ-ម៉ាត់ស៊ុ* និង *យ៉ាប៊ូ* បានឡើងមកលើទូកដែរ ។ មេបញ្ជាការ-*សាន* ក៏ពន្យល់អ្នកទាំងពីរបន្ត ។ អ្នកទាំងពីរនាក់នេះ មុខឡើងស្លាំង ប៉ុន្តែនៅតែនឹងនរ និងមិនក្អួតចង្អោរអីទាំងអស់ ។ ពួកគេសំលឹងទៅច្រាំងកាត់ស្បៃភ្លៀងញាក់ស្មា ហើយក៏ចុះទៅខាងក្រោមវិញទៅ ។

*ប្លាក់ថន* សំលឹងមើលរកកន្លែងសំរាប់ជ្រកព្យុះ ដោយដឹងច្បាស់ថា ផែនការនេះ គឺមហាគ្រោះថ្នាក់ ។ គេត្រូវរង់ចាំពេលឆ្លងកាត់ជ្រោយហើយ ទើបចាក់ងាកក្បាលទូកទទឹងខ្យល់បត់ទៅទិសអីសានវិញ ហើយសាប់ច្រវាចែវយកងាប់រស់តែម្តង ។ អារឿងក្តោងមិនបាច់សង្ឃឹម ទេ ។ ច្រាំងខាងត្បូងពោរពេញទៅដោយថ្ម និងថ្មប៉ប្រះទឹក បើគេរើសពេលមិនត្រូវទេ ទូកនឹងបោកផ្ទប់ច្រាំង ហើយលិចបាត់ជាមិនខាន ។

- *អ៊ុញគីលីស* ទៅក្បាលទូក !

*រ៉ូឡិច* ធ្វើសញ្ញាមករកគេ ។ *ប្លាក់ថន*ដើរតំរង់ទៅក្បាលទូក ។ *រ៉ូឡិច*តំស្រេក សួរគេបន្ត :

- ប្រើក្តោងទៅវិយ៉ាងម៉េច ?

- ទេ វាខាតច្រើនជាងជួយ ។

- អីចឹង អែងទៅក្បាលទូកហើយ ។ បើសិនជាមេបញ្ជាការឈប់ទូងស្គរ រឺមួយគាត់ធ្លាក់ទឹក អែងជំនួសគាត់ ។ យល់ព្រម ?

- ខ្ញុំមិនដែលបើកទូករបៀបនេះទេ ហើយក៏ខ្ញុំមិនដែលប្រើដងចែវដែរ ។ ប៉ុន្តែចាំខ្ញុំសាកមើល ។

*រ៉ូឡិច* ចោលភ្នែកសំលឹងមើលទៅច្រាំង ដែលម្តងឃើញ ម្តងបាត់ក្នុងរនាំងទឹកភ្លៀង ។ បន្តិចទៀត គឺជាដំណាក់កាលចុងក្រោយហើយ ។ សមុទ្រកាន់តែរំជួយខ្លាំងឡើងបែកផ្កាត្រែងទៅហើយ ។ ចែវទូកតំរង់ទៅឆ្នេរ ហាក់ដូចជាទៅមិនរួចសោះតែម្តង ។ អារឿងនេះ ចំជារឿង



www.budinst.gov.kh www.elibraryofcambodia.org

ប្រកាច់ប្រកិនមែនទែនហើយ -គេគិតនៅក្នុងចិត្ត ។ រួចរំពេចនោះ គេស្តោះមួយខ្ទាច់ ហើយក៏សំរេចចិត្តភ្លាម :

- ទៅកន្សែងទៅ *អ៊ិញគីលីស* អែងកាច់ចង្កូត ។ ពេលខ្ញុំអោយសញ្ញាអែងចាក់ទៅទិសលិច ជើង លិច យល់ទេ ?

- យល់ ។

- កុំរួញរាអីទាំងអស់ អែងដាក់ទូកអោយចំទិសណឹង ហើយចាំមើលខ្ញុំ ។ សញ្ញានេះមានន័យថា អែបឆ្វេងអោយខ្លាំង អានេះអែបស្តាំខ្លាំង ហើយអានេះគឺ ទៅមុខត្រង់ ។

- ល្អ ។

- តែ នែ វំបល់យក៏ ! អែងចាំមើលសញ្ញាខ្ញុំ និងចាំស្តាប់បញ្ជាខ្ញុំណា ?

*វ៉ូទ្រិច* ដឹងថា គេមិនអាចយកសើ្បងបានទៀតទេ :

- អីលូវនេះខ្ញុំត្រូវទុកចិត្តអែងហើយ *អ៊ិញគីលីស* ហើយអារឿងហ្នឹងធើអោយខ្ញុំមូម៉ៅមែនទែន ដែលខ្ញុំទុកចិត្តអែងនេះ ។

*វ៉ូទ្រិច* ឈប់និយាយដោយគេឃើញថា *ប្លាក់ថន* កំពុងតែមើលធ្លុះបេះដូងរបស់គេទៅហើយ ។ គេដើរចេញបន្តិច រួចប្តូរចិត្តវិញ ហើយបន្លឺឡើង :

- នែ ល្បងចោរសមុទ្រដ៏កោង ទៅចុះ សូមព្រះជួយអែងវ៉ី !

*ប្លាក់ថន* ងាកមកដោយញញឹម

- អែងក៏អីចឹងដែរ ល្បងអេស្ប៉ាញ !

- ងាប់ចោលម្រាយវាអោយអស់ទៅ អាពួកអេស្ប៉ាញ ហើយជយោប៊កទុយកាល់ !

- ត្រង់ទៅមុខ !

☆ ☆ ☆

សំពៅបានអែបចូលច្រាំងហើយ ។ ប៉ុន្តែដោយគ្មានរូប *វ៉ូទ្រិច* ។ គេត្រូវទឹកបោកធ្លាក់ទៅក្នុងសមុទ្រ ព្រោះខ្សែការពាររបស់គេ បានដាច់បាត់ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលសំពៅបានទៅជិតដល់ទីសុខហើយ ស្រាប់តែរលកធំមួយមកពីទិសខាងជើង បានវាយគ្របលើទូក ហើយរុញវាត់រង់ទៅរកឆ្នេរសមុទ្រ ដែលពោរពេញទៅដោយផ្ទាំងថ្ម ។ នៅលើទូកទឹកដក់ល្អក់ល្អាច ហើយមេបញ្ជាការជប៉ុន ត្រូវទឹកកួចយកទៅបាត់មុននេះបន្តិច ។

ពេលរលកធំដកខ្លួនចេញបន្តិច *ប្លាក់ថន* ក្រលេកមើល *រ៉ូឡិច* ខំងើបចេញពីទឹក ដោយខំក្រេវក្រវេវក្រវាសវិលមករកសំពៅវិញ ។ កំលាំងរលកបានរុញទូកទៅភាគខាងត្បូងនៃឆ្នេរ ដែលមានសុទ្ធតែផ្ទាំងថ្មនោះ ។ នៅពេលដែលទូកហៀបពារលើផ្ទាំងថ្ម ទាំងអស់គ្នាដឹងថា ជាពេលចុងក្រោយហើយ ។

នៅពេលដែលឃើញ *រ៉ូឡិច* ត្រូវទឹកកួចតាមបណ្តោយទូកនោះ *ប្លាក់ថន* ក៏ស្រវាយកពោងឈើមួយបោះទៅអោយគេ ។ *រ៉ូឡិច* ក៏ស្រវាឈោងចាប់យកពោងនោះដែរប៉ុន្តែទឹកបានវាយខ្ទុនគេអោយចេញឆ្ងាយទៅវិញ ។ ច្រវ៉ាមួយផើតទៅធ្លាក់ក្បែរខ្លួនគេ ហើយគេក៏ស្រវាចាប់យកភ្លាម ។ ភ្លៀងនៅបន្តធ្លាក់ខ្ទោក១ ហើយគំហើញចុងក្រោយរបស់ *ប្លាក់ថន* គឺដៃ ដែលតោងច្រវ៉ាបាក់ និងនៅពីមុខគេគឺរលកដែលកំពុងតែសន្ធាប់មក ។ ខ្លួនគេអាចហក់ចុះទៅ ក្នុងសមុទ្រហែលទៅដល់ *រ៉ូឡិច* ហើយប្រហែលជាអាចជួយស្រោចស្រង់គេបាន ។ ប៉ុន្តែករណីកិច្ចទីមួយរបស់គេ គឺសំដៅទៅនាវា ហើយករណីកិច្ចចុងក្រោយរបស់គេ ក៏សំរាប់នាវាដែរ ។ អីលូវនេះនាវារបស់គេកំពុងមានគ្រោះថ្នាក់ហើយ ។

ដោយហេតុនេះ គេខាំមាត់ បែរខ្នងចេញពី *រ៉ូឡិច* ទៅ ។

រលកបានវាយផើតអ្នកចែវអស់ប៉ុន្មាននាក់ទៀត ។ មនុស្សមួយចំនួនទៀត ស្ទុះស្ទាញមកបំពេញកន្លែងដែលនៅទំនេរភ្លាម ។ នាយកងម្នាក់កន្ត្រាក់ដោះខ្សែការពារចេញ ហើយស្ទុះឡើងយ៉ាងអង់អាចទៅក្បាលទូក ដើម្បីវាយសង្វាក់ដងចែវ ។ អ្នកចែវទាំងប៉ុន្មាន ក៏ខំប្រឹងស្តាររបៀបរៀបរយឡើងវិញដែរ ។

- អ៊ី ស៊ូតីតីតីតីតីតី !

*ប្លាក់ថន* ស្រែកឡើងស៊ើបែកបំពង់ក នូវពាក្យដែលគេទើបចាំថ្មីៗនេះ ។ គេយកទំងន់គេទាំងអស់ទៅសង្កត់លើដៃចង្កូត ដើម្បីអោយទូកទៅតាមបណ្តោយខ្យល់វិញ រួចគេទៅ



www.budinst.gov.kh www.elibraryofcambodia.org

ដល់តែមបន្ទប់ដើម្បីអោយសង្វាក់ មួយ-ពីរ មួយ-ពីរ ដើម្បីជំរុញទឹកចិត្តអ្នកចែវ :

- ប្រឹងឡើងពួកអាកូនមីចោលម្រ៉ាយ ចែចែចែចែចែវ !

ទូកហៀបតែនឹងពារលើថ្មទៅហើយ ។ ច្រវាកាប់ទឹកយ៉ាងវន្ទាន់ ប៉ុន្តែទូកនៅតែទៅមុខមិនរួច ។ ផ្ទុយទៅវិញកំលាំងខ្យល់ និងកំលាំងរលក បានច្រានទូកបន្តិចម្តងៗអោយទៅក្រោយ ។

- ប្រឹងថែមទៀតឡើង ពួកអាកូនមីចោលម្រ៉ាយ !

*ប្លាក់ថន* ស្រែកឡើងម្តងទៀត ដោយទះដៃជាសង្វាក់បន្ទរ ។ ទូកចាប់ផ្តើមឃ្លាតចេញបន្តិចម្តងៗពីផ្ទាំងថ្ម ។ *ប្លាក់ថន* តំរង់ចង្កូតទៅដីគោកដោយឡើងបញ្ច្រាសខ្យល់ ។ បន្តិចក្រោយមកពួកគេបានមកដល់កន្លែងដែលស្ងប់ស្ងាត់ជាងគេ ។ ខ្យល់នៅតែបក់បោក ប៉ុន្តែទឹកកន្លែងដែលគេមកដល់នេះ មានផ្ទាំងថ្មបាំងយ៉ាងល្អ ។ ព្យុះនៅតែមាន ប៉ុន្តែវានៅឯលំហសមុទ្រឯណោះ ។

- ទំលាក់យុថ្កាស្តាំ

គ្មានអ្នកណាយល់ពីសំដីរបស់គេទេ ប៉ុន្តែអ្នកដើរទូកទាំងអស់យល់ថា គេចង់ធ្វើអ្វីហើយ ។ ពួកគេស្ទុះស្ទារធ្វើតាមបញ្ជា ។ យុថ្កា ក៏ត្រូវបានទំលាក់ប្រូងទៅក្នុងទឹក ។ *ប្លាក់ថន* ព្រលែងអោយទូករសាត់បន្តិច ដើម្បីសាកបាតសមុទ្រ រួចទើបគេចេញបញ្ជាជាថ្មី ។

- ទំលាក់យុថ្កាដៃ !

នៅពេលដែលទូកមានសន្តិសុខគ្រប់គ្រាន់ហើយ ទើបគេងាកសំលឹងមើលទៅខាងក្រោយវិញ ។

នៅក្នុងស្បែនៃតំនក់ទឹកភ្លៀង គេអាចមើលឃើញឆ្នេរព្រាលៗ ។ គេប៉ាន់សមុទ្រ និងវិភាគពីលទ្ធភាពនានាដែលគេមាន ។

កូនសៀវភៅរបស់ *វ៉ូឡើច* នៅបន្ទប់ក្រោមនៅឡើយទេ -គេគិតនៅក្នុងចិត្តទាំងហៅហត់ ។ អញអាចបញ្ជាទូកទៅដល់ *អូសាកា* បាន ។ ក៏អាចបញ្ជាទូកទៅ *អាន់ជិរ៉ូ* វិញក៏បាន ។ តែជាការត្រឹមត្រូវទេ ដែលអញមិនធ្វើតាមបញ្ជាវា ? ទេ អញមិនបានជំទាស់ នឹងបញ្ជារបស់ *វ៉ូឡើច* ទេ ។



www.budinst.gov.kh www.elibraryofcambodia.org

ពេលនេះអញនៅលើកន្សែងទូកតែម្នាក់ឯង ។

-កាច់ទៅត្បូង !-*រ៉ូត្រិច* ស្រែកយ៉ាងអស់សំលេង នៅពេលដែលឃើញថា ទូកត្រូវខ្យល់ និងរលករុញទៅរកថ្នាំងថ្ម ។ - កាច់ទូកបត់តាមបណ្តោយខ្យល់វិញ !

-ទេ ! -*ប្លាក់ថន* ស្រែកតបវិញ ដោយគេដឹងថា ផ្លូវរស់តែមួយរបស់ពួកគេ គឺរកកន្លែងជ្រក ខ្យល់តែប៉ុណ្ណោះ តែបើបែរក្បាលចេញទៅលំហសមុទ្រ តាមបញ្ជា *រ៉ូត្រិច* នោះពួកគេច្បាស់ជា អាសន្នធំហើយ ។ - យើងអាចចែវដល់ឆ្នេរបាន !

- ចង្រៃយក៏ ! អែងចង់អោយងាប់ទាំងអស់គ្នាហើយអ្ហី ?

ប៉ុន្តែអញឥតមានចង់អោយអ្នកណាងាប់ទេ -ប្លាក់ថនគិតនៅក្នុងចិត្ត ។*រ៉ូត្រិច* អែងដឹងណាស់ ហើយអញក៏ដឹងណាស់ដែរថា នេះជាភារកិច្ចទទួលខុសត្រូវរបស់អញក្នុងការសំរេចចិត្តនេះ បើសិនជានៅសល់ពេលដើម្បីសំរេចចិត្ត ។ អីលូវនេះឃើញអញថាត្រូវទេ ? ទូកបានរួចផុតគ្រោះ ។ ហើយអាហ៊ឹងហើយជារឿងសំខាន់បំផុតនោះ ...............

គេធ្វើសញ្ញាទៅមេកង ។ បុរសនោះស្ទុះមកយ៉ាងលឿនពីខាងក្បាលទូក ។ អ្នកកាច់ចង្កូតទាំងពីរនាក់នៅដួលស្តូកនៅឡើយ ។ ដៃ និងជើង របស់គេស្ទើរបែកចេញពីខ្លួនទៅហើយ ។ អ្នកចែវទូកប្រៀបដូចជាសាកសពទៅហើយ ។ ពួកគេក្រាបស្តូកពីលើច្រវារបស់ពួកគេ ។ អ្នកខ្លះទៀតក៏ឡើងពីក្រោមទាំងទ្រេតទ្រោត ដើម្បីមកជួយ ។ *ហ៊្វី-ម៉ាក់ស៊ី* និង *យ៉ាប៊ូ* ដោយល្ងាក់ល្ងើខ្លាំងពេក ក៏ត្រូវគេជួយគ្រាហ៍ឡើងមកលើដែរ ប៉ុន្តែ នៅពេលដែលគេមកដល់លើទូកពេលណាគេក៏ឈរត្រង់ខ្លួនភ្លាម ។

- *ហៃ អាន់ជីន-សាន ?*

នាយកងសួរទៅកាន់ *ប្លាក់ថន* ។ គេជាបុរសវ័យកណ្តាល ។ ធ្មេញរបស់គេនៅស្អុះនិងរឹងមាំនៅឡើយ ។ គេមានមុខធំ ហើយពណ៌ស្រអែម ។ នៅលើថ្ពាល់របស់គេ មានស្នាមជាំមួយដុំ ដែលបណ្តាលមកពីរលកសមុទ្របោកគេផ្ទប់ទៅនឹងគែមទូក ។

- អែងធ្វើបានល្អណាស់



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* និយាយទៅកាន់បុរសនេះ ដោយឥតខ្ចីខ្វល់ថា បុរសនេះស្តាប់យល់សំដីរបស់គេរឺក៏អត់ទេ ។ គេគ្រាន់តែដឹងថា សំលេងនិយាយ និងកាយវិការញញឹមរបស់គេល្មមនឹងអោយបុរសនេះយល់បានហើយ ។

- មែនណា ! ល្អណាស់ ! អីលូវនេះអែងជាមេបញ្ជាការ-*សាន* ហើយ ។ *វ៉ាកាវីម៉ាស៊ូ ?* អែងណឹងណាមេបញ្ជាការ-*សាន* ។

បុរសនោះ សំលឹងមើល *ប្លាក់ថន* ទាំងចំហមាត់ធ្លុង រួចគេក៏លំអោនខ្លួនយ៉ាងទាបដើម្បីបិទបាំងភាពភ្ញាក់ផ្អើលរបស់គេផង បាំងទឹកចិត្តរីករាយរបស់គេផង ។

- *វ៉ាកាវីម៉ាស៊ូ អាន់ជីន-សាន វ៉ៃ ! អារីកាតូ កូសាយម៉ាស៊ីតា*

*ប្លាក់ថន* បន្ត :

- ស្តាប់ខ្ញុំណា៎ មេបញ្ជាការ-*សាន* យកម្ហូបនិងទឹកចែកចាយដល់មនុស្សម្នាទាំងអស់គ្នានេះ ។ យកម្ហូបក្តៅណា៎ ! ។ យប់នេះយើងនៅទីនេះហើយ ។

*ប្លាក់ថន* និយាយផង ធ្វើកាយវិការផង ។ មេបញ្ជាការថ្មីយល់ភ្លាម ។ គេក៏ត្រលប់ងាកទៅស្រែកចេញបញ្ជាយ៉ាងក្លៀវក្លា ក្នុងអំនាចថ្មីរបស់ខ្លួន ។ នាវិកទាំងអស់រត់ខ្វេងដៃ ខ្វេងជើងដើម្បីអនុវត្តតាមបញ្ជារបស់គេ ។ ពោរពេញដោយមោទនភាព លោកមេបញ្ជាការថ្មីងាកទៅមើលបន្ទប់តៃកុងម្តងទៀត ។ តើធ្វើម៉េច អញចេះនិយាយភាសាពួកចុងស្រុកនេះបានណា៎ - គេគិតនៅក្នុងចិត្តយ៉ាងរីករាយ ។ បើអញចេះ អញនឹងអរគុណអែង *អាន់ជីន-សាន* ។ អរគុណដែលអែងបានសង្គ្រោះទូកអោយផុតគ្រោះថ្នាក់ ហើយជាមួយនឹងទូកនេះ គឺជាជីវិតរបស់លោកម្ចាស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* របស់យើង ។ វេទមន្តរបស់អែង បានធ្វើអោយពួកយើងទាំងអស់គ្នាមានកំលាំងពលំថ្មីប្រិសតែម្តង ។ គ្មានវេទមន្តអែងទេ ប្រហែលពួកយើងក្លាយជាចំនីត្រីបាត់ទៅហើយ ។ អែងជាចោរសមុទ្រមែន តែអែងក៏ជាអ្នកដើរសមុទ្រដ៏ជំនាញបំផុតដែរ ហើយនៅពេលដែលអែងជាតៃកុង អញនឹងធ្វើតាមអែងរហូតដល់ពេលអញអស់ជីវិត ។ តាមពិតទៅអញមិនសក្តិសមជាមេបញ្ជាការទេ តែអញនឹងប្រឹងប្រែងអោយសក្តិសមនឹងទំនុកចិត្តអែង ។

គេសួរទៅ *ប្លាក់ថន* :



www.budinst.gov.kh www.elibraryofcambodia.org

- លោកចង់អោយខ្ញុំធ្វើអ្វីទៀតទេ ?

*ប្លាក់ថន* សំលឹងមើលទៅក្រៅ ។ សមុទ្រទ្រឹងពណ៌ខ្មៅស្ងប់ ។ គេសំលឹងសំគាល់ចំនុចសំខាន់ៗ ហើយនៅពេលដែលគេច្បាស់ក្នុងចិត្តថា យុថ្កាជាប់ល្អ និងសមុទ្រនៅកន្លែងនេះ បានស្ងប់ល្អហើយ គេនិយាយឡើង :

- ទំលាក់ទូកចុះ ហើយយកអ្នកពូកែចែវម្នាក់ផង ។

ជាថ្មីម្តងទៀត គេធ្វើដៃជើង អមជាមួយសំដីរបស់គេផង ទើបមេបញ្ជាការនេះអាចយល់បាន ។

ទូកត្រូវបានទំលាក់ចុះមួយរំពេច ។

*ប្លាក់ថន* ដើរតំរង់ទៅគែមទូក ហើយគេហៀបនឹងរំលងគែមទូកទៅហើយ ស្រាប់តែសំលេងមួយបានបញ្ឈប់គេភ្លាម ។ គេងាកមករកប្រភពសំលេង ។ នោះគឺ *ហ្សិរ-ម៉ាក់ស៊ី* ។ *យ៉ាប៊ូ* នៅឈរក្បែរនោះដែរ ។

បុរសចំនាស់មាន ក និងស្មាឡើងជាំ ប៉ុន្តែគេនៅតែកាន់ដាវវែងរបស់ខ្លួនដដែល ។ *យ៉ាប៊ូ* មានឈាមហូរចេញពីច្រមុះ មុខឡើងហើមស្គរ គឺម៉្លូប្រលាក់ប្រលូសខ្ទេចខ្ទី ។ គេខំឃាត់ឈាមច្រមុះ នឹងក្រណាត់មួយផ្ទាំង ។ ទាំងពីរនាក់នៅយ៉ាងនឹងនរ ហាក់គ្មានចាប់អារម្មណ៍នឹងរបួស រីខ្យល់ដែលកំពុងតែបក់បោកនេះឡើយ ។

*ប្លាក់ថន* លំអោនខ្លួនយ៉ាងគោរព :

- *រ៉ៃហ តូដាសាម៉ា* ?

បុរសចំនាស់ និយាយយ៉ាងគំហកម្តងទៀត ហើយលើកដាវចង្អុលទៅចំនោតច្រាំងផងគ្រវីក្បាលផង ។

- *រ៉ូឌ្រិច-សាន* នៅទីនោះ

*ប្លាក់ថន* លើកដៃចង្អុលទៅច្រាំងខាងត្បូង ហើយនិយាយបន្ត :

- ខ្ញុំទៅរកមើលសិន ។



www.budinst.gov.kh www.elibraryofcambodia.org

- *អ៊ី យេ* !

*ហ៊ិរ៉ូ-ម៉ាត់ស៊ី* គ្រវីក្បាលជាសញ្ញាថាទេ ហើយក៏ចាប់និយាយម្តងទៀត យ៉ាងវែង ។ ច្បាស់ណាស់គេមិនអនុញ្ញាតអោយឡើងច្រាំង ពីព្រោះមានគ្រោះថ្នាក់ ។

- ខ្ញុំគឺជា *អាន់ជីន-សាន* នៃអាទូកចោលម្រ៉ាយនេះ ហើយបើខ្ញុំចង់ឡើងគោក គឺខ្ញុំឡើងហើយ ។

*ធ្លាក់ថន* រក្សាស៊ីយ៉ាងគួរសមដែរ ប៉ុន្តែសំលេងរបស់គេដាច់ណាត់ជាងមុន ។ ទាំងអស់គ្នា យល់បានយ៉ាងច្បាស់ថា តើ *ធ្លាក់ថន* និយាយពីអ្វី ។

- ខ្ញុំដឹងថា កូនទូកនេះ កាត់រលកសមុទ្រនេះមិនបានទេ ។ *វ៉ែហ* ! តែខ្ញុំត្រូវឡើងគោកត្រង់នេះ ពិសេសកន្លែងម្តុំនោះ លោកមានឃើញទេ *តួដា ហ៊ិរ៉ូ-ម៉ាត់ស៊ី សាម៉ា* ? ជិតកូនថ្មម្តុំនោះ។ ខ្ញុំចង់ដើរមួយជុំនោះសាកមើល ។ ខ្ញុំមិនរហ័សចង់ឆាប់ងាប់ទេ ហើយខ្ញុំចង់រត់ទៅណាក៏មិនរួចដែរ ។ ខ្ញុំចង់រកខ្មោច *រ៉ូឌ្រិច-សាន* តែប៉ុណ្ណឹង ។

និយាយរួច គេលើកជើងរំលងគែមទូកភ្លាម ។ ដាវក៏ចាប់កំរើកនៅក្នុងស្រោម ដែរ ។ *ធ្លាក់ថន* ក៏ឈប់នៅទ្រឹង ប៉ុន្តែគេនៅតែសំលឹងចំកែវភ្នែករបស់ *ហ៊ិរ៉ូ-ម៉ាត់ស៊ី* ឥតដាក់ ។ ទឹកមុខរបស់គេ នៅតែបង្ហាញនូវការប្តេជ្ញាចិត្តដដែល ។

ពេលនេះ *ហ៊ិរ៉ូ-ម៉ាត់ស៊ី* កំពុងស្ថិតនៅក្នុងជំរើស ដ៏ទាល់ច្រកមួយ ។ លោកយល់ពីបំនងប្រាថ្នា របស់ចោរសមុទ្រនេះ ដែលចង់ស្វែងរកសាកសព *រ៉ូឌ្រិច-សាន* ប៉ុន្តែគឺជាការគ្រោះថ្នាក់ ដែលនាំគ្នាឡើងគោកនៅទីនេះ ហើយលោកម្ចាស់ *តូរ៉ាណាកា* បានចេញបញ្ជាអោយនាំមនុស្សចុងស្រុកនេះ ទៅដល់ *អូសាកា* ដោយសុវត្ថិភាព ។ ប៉ុន្តែទន្ទឹមនេះ វាជាការច្បាស់ណាស់ដែលបុរសនេះមានបំនងចុះទៅដីគោកនោះ ។

លោកបានឃើញបុរសនោះ នៅក្នុងពេលព្យុះ ពេលដែលគេឈរយ៉ាងត្រដែតលើកន្លែងបញ្ជា ប្រៀបបីដូចជាអារក្សសមុទ្រ ដែលគ្មានខ្លាចអ្វីទាំងអស់ ។ បុរសនេះហាក់ដូចជាផ្នែកមួយនៃសមុទ្រ និងជាផ្នែកមួយនៃព្យុះសង្ឃរា ។ ពេលនោះលោកបានគិតយ៉ាងសាហាវថា ប្រការល្អបំផុតគឺត្រូវនាំមនុស្សនេះ ហើយនឹងពួកចុងស្រុកទាំងអស់ដែលដូចមនុស្សនេះអោយទៅនៅ



www.budinst.gov.kh www.elibraryofcambodia.org

លើដីគោក ដែលជាកន្លែងយើង អាចតទល់ជាមួយពួកវាបាន ។ ប៉ុន្តែនៅលើសមុទ្រវិញ ពួកយើងស្ថិតនៅក្នុងកណ្តាប់ដៃពួកវាហើយ ។

លោកក៏ឃើញផងដែរថា ចោរសមុទ្រនេះ កំពុងតែអន្ទះអន្ទែងនៅមិនសុខហើយ ។ពួកអាអស់នេះច្រលើសបើសមែនទែន -លោកគិតនៅក្នុងចិត្ត -តែទោះជាអ៊ីចឹងក្តី អញក៏ត្រូវតែអរគុណអែងដែរ ។ គ្រប់គ្នាបាននិយាយថា គឺមានតែអែងម្នាក់គត់ ដែលនាំទូកចូលចតបាននេះហើយថា *វ៉ូឡើច* ស្លន់ទាល់តែមែនទែន ហើយបែរជា ចង់បត់ក្បាលទៅលំហសមុទ្រវិញ ។ តែនេះកុំតែបានអែងនៅចេសបត់ទូកទៅរកច្រាំង កុំអីលិចលង់ងាប់ទាំងអស់គ្នានៅឯលំហសមុទ្រទៅហើយ ។ ហើយបើយ៉ាងនេះមែន អញពិតជាមិនបានគោរពតាមបញ្ជាលោកម្ចាស់អញហើយ ។ រាល់សរសៃសរស្លូងរបស់លោក ឡើងឈឺចុកចាប់គ្រប់កន្លែង ឯស្បែករបស់លោកឡើងរោលពេញពាស ។ ខ្លួនប្រាណរបស់លោកទាំងមូល ត្រូវភាពនឿយហត់រុករានទន្ទ្រាន ព្រោះតែលោកខំរៀប រឹកពារនឹងធឹង នៅចំពោះមុខកូនចៅរបស់លោកគឺ *យ៉ាប៊ូ* ចំពោះមុខពួកនាវិកនិងថែមទាំងចំពោះ មុខមនុស្សចុងស្រុកនេះទៀតផង ។ ឱព្រះអង្គអើយ ខ្ញុំសែនហេវហត់ម្ល៉េះទេ ។ សុំតែបានត្រាំទឹក ត្រាំហើយត្រាំទៀត ហើយសំរាកពេញមួយថ្ងៃតែម្រ៉ង អោយអស់អាវឿងឈឺចុកចាប់នេះ ។ សុំ តែម៉ាថ្ងៃទេ ។ ទេអ្ហើយ ឈប់តំអូញអ្ហា ! អញធ្លាប់លំបាកវេទនា ប្រហែលហុកសិបឆ្នាំហើយ ។ ចំពោះកូនប្រុស ដើមទ្រូងប្រាំហត្ថ តើមានអ្វីដែលត្រូវពោលថាវេទនានោះ ? នេះជាអភ័យឯកសិទ្ធិទេតើ ។ ចេះលាក់ការឈឺចាប់ ការលំបាកវេទនា គឺជាខ្នាតវាស់កូនប្រុស ។ អែងគួរអរគុណព្រះ ដែលព្រះអង្គអោយមានជីវិតរស់នៅដើម្បីការពារលោកម្ចាស់យើង ។ តាមពិតទៅ បើសិនជាត្រូវងាប់ អែងមិនដឹងជាងាប់ប៉ុន្មានរយដងហើយទេ ។ សូមអរគុណព្រះអង្គហើយ ។

តែអញស្អប់សមុទ្រ អញស្អប់ត្រជាក់ អញស្អប់ការឈឺចាប់អីម្ល៉េះទេ ។

- ឈប់នៅកន្លែងហ្នឹងហើយ *អាន់ជីន-សាន* ។

*ប៊្លូ-ម៉ាត់ស៊ី* និយាយផង លើកដាវទាំងស្រោមចង្អុលផង ដើម្បីអោយកាន់តែច្បាស់ ។ លោកសែនសប្បាយ ពេលដែលលោកឃើញពន្លឺភ្លើង ដ៏ត្រជាក់ស្រេង ដែលរត់ចេញពីក្រសែភ្នែក



www.budinst.gov.kh www.elibraryofcambodia.org

របស់បុរសនេះ ។ នៅពេលដែលលោកដឹងថា *ធ្លាក់ថន* យល់ពីបញ្ហារបស់ខ្លួនហើយ លោកក៏ចោលភ្នែកសំលឹងទៅមេកង :

- តើយើងនៅកន្លែងណាហ្នឹង ? តំបន់នេះជាដែនដីរបស់អ្នកណា ?

- ខ្ញុំបាទ មិនដឹងដែរលោកម្ចាស់ ។ តាមខ្ញុំស្មាន កន្លែងនេះប្រហែលជាម្តុំ១ខេត្ត *អ៊ីសេ* ហើយ ។ យើងគួរចាត់មនុស្សឡើងគោកទៅភូមិជិត១នេះសាកមើលទាន ។

- អែងអាចបញ្ជាទូកដល់ *អូសាកា* បានទេ ?

- ប្របាទបើបើកយឺត១ដោយប្រយ័ត្នប្រយែងស្មៀវ១ឆ្នេរ ចេះតែទៅដល់ហើយទាន។ ខ្ញុំបាទមិនស្គាល់តំបន់នេះទេ អីចឹងហើយបើធានាសន្តិសុខ ខ្ញុំបាទមិនធានាទេទាន ។ ខ្ញុំបាទគ្មានបទពិសោធន៏ទេ ហើយនៅលើទូកនេះ ក៏គ្មានអ្នកណាមានដែរ ។ ក្រៅតែពីតៃកុងនេះចេញទាន។ បើសិនជាខ្ញុំបាទត្រូវសំរេច ខ្ញុំបាទស្នើលោកម្ចាស់ទៅតាមដីគោកវិញហើយ ។ ខ្ញុំបាទអាចទៅរកសេះ រីកៅអីស្នែងសំរាប់លោកម្ចាស់ទាន ។

*ហ្សិ-ម៉ាត់ស៊ុ* គ្រវីក្បាលទាំងកំហឹង ។ ទៅតាមដីគោក ត្រូវស៊ីពេលយូរណាស់ ព្រោះភ្នំក៏ច្រើន ឯផ្លូវក៏មានតិច។ ទន្ទឹមនេះពួកលោកត្រូវឆ្លងកាត់ដែនដីជាច្រើននៃពួកសម្ព័ន្ធមិត្ត *អ៊ីស៊ីដូ* ដែលជាគូសត្រូវថែមទៀត ។ បន្ថែមពីលើគ្រោះថ្នាក់ទាំងនេះ នៅមានវ៉ូងចោររាប់មិនអស់ដែលនៅតាមច្រកភ្នំនានាថែមទៀត ។ មានន័យថា លោកត្រូវយកមនុស្សទាំងអស់ របស់លោកទៅតាមខ្លួន ។ ពិសេសគេអាចកំចាត់កំចាយពួកចោរហារយទាំងនោះបាន តែលោកច្បាស់ជាមិនអាចកំចាត់រកច្រកចេញបានទេ បើសិនជា *អ៊ីស៊ីដូ* រឹសម្ព័ន្ធមិត្តរបស់វាសំរេចរាំងផ្លូវនោះ ។ ទាំងនេះ នឹងធ្វើអោយលោកកាន់តែយឺតយូរណាស់ទៅទៀត ហើយបញ្ហាដែលលោកម្ចាស់បានទទួលគឺ ត្រូវនាំអីរ៉ៃអីវ៉ាន់មនុស្សចុងស្រុក និង *យ៉ាប៊ូ* អោយបានទៅដល់ទីដៅយ៉ាងឆាប់បំផុត និងយ៉ាងសុវត្ថិភាពបំផុត ។

- បើយើងបើកស្មៀវតាមឆ្នេរ តើស៊ីពេលប៉ុន្មានទៅ ?

-ខ្ញុំបាទមិនដឹងដែរលោកម្ចាស់ ។ ប្រហែលបួន រឺប្រាំថ្ងៃ រឺប្រហែលលើសពីហ្នឹងទៀតក៏មិនដឹង ។ ខ្ញុំបាទមិនសូវច្បាស់ដែរទេទាន ។ ខ្ញុំបាទមិនមែនមេបញ្ជាការផងទាន ។ សូមលោក



www.budinst.gov.kh www.elibraryofcambodia.org

ម្ចាស់អភ័យទោសផង ។

អ៊ីចឹងមានន័យថា អញត្រូវតែពឹងផ្អែកលើអាចុងស្រុកនេះហើយ *-ហ្ស៊ី-ម៉ាត់ស៊ី* គិតនៅក្នុងចិត្ត - បើមិនចង់អោយវាឡើងគោក អញត្រូវតែចងវា ។ រួចបើចងវា តើវាងាយអ៊ីនឹងសហការជាមួយ ?

- តើយើងត្រូវនៅទីនេះប៉ុន្មានពេល ?

- តែកុងថាមួយយប់ទាន ។

- ផុតមួយយប់ណឹងអស់ព្យុះហើយអ៊ីចឹង ?

- ប្រហែលហើយលោកម្ចាស់ ប៉ុន្តែគ្មានអ្នកណាដឹងច្បាស់ដែរទេ ។

*ហ្ស៊ី-ម៉ាត់ស៊ី* សំលឹងមើលច្រាំងដែលចោទដូចជញ្ជាំងភ្នំ រួចមើលតែកុង ។ លោកនៅរួញរានៅឡើយ ។

- តើខ្ញុំ អាចស្នើរឿងមួយបានទេ *ហ្ស៊ី-ម៉ាត់ស៊ី-សាន* ? *-យ៉ាប៊ូ* បន្លឺសំលេង ។

- បាន១អញ្ជើញ ។

- បើយើងគង់តែត្រូវការតែកុងនេះទេ ហេតុអីមិនអនុញ្ញាតអោយវាឡើងគោកទៅ? ប៉ុន្តែយើងអោយពួកយើងទៅតាមការពារវា ហើយវាត្រូវតែមកទូកវិញមុនព្រលប់ ។ អារឿងឡើងគោកនេះ ខ្ញុំគិតថា បើលោកទៅផ្ទាល់ខ្លួន គឺអាចជាគ្រោះថ្នាក់ណាស់ ។ ហើយបើមានរឿងអីកើតឡើងដល់លោក ខ្ញុំក៏មិនអត់អោនអោយខ្លួនខ្ញុំដែរ ។ នៅពេលដែលព្យុះស្ងប់ហើយ លោកនៅលើទូកនេះមានសន្តិសុខជាង ហើយលោកអាចទៅដល់ *អូសាកា* យ៉ាងរហ័សទៀតផង មិនអ៊ីចឹង ? យ៉ាងយូរល្ងាចស្អែកដល់បាត់ទៅហើយ ។

*ហ្ស៊ី-ម៉ាត់ស៊ី* ងក់ក្បាលយល់ព្រមទាំងបង្ខំចិត្ត :

- ល្អ !

រួចគេធ្វើសញ្ញាទៅ សាមូរ៉ៃម្នាក់ :

- *តាកាតាស៊ី-សាន* យកមនុស្សប្រាំមួយនាក់ ហើយទៅជាមួយតែកុង ។ បើរកខ្មោចប៉ុកទុយកាល់នោះឃើញយកមក តែបើរោមចិញ្ចើមតែម៉ាសរសៃរបស់អាចុងស្រុកនេះត្រូវជ្រុះ



www.budinst.gov.kh www.elibraryofcambodia.org

អែង និងក្រុមរបស់អែងទាំងអស់ត្រូវធ្វើ *សិបពូតូ* ជាបន្ទាន់ ។

- ប្របាទ ម្ចាស់ ។

- ហើយចាប់មនុស្សពីរនាក់ ទៅភូមិជិតៗនេះ ស៊ើបសួរមើលថា តើយើងនៅកន្លែងណាពិតប្រាកដ ? ហើយដែនដីនេះ ជារបស់អ្នកណា ?

- ប្របាទម្ចាស់ ។

- បើសិនជាលោកអនុញ្ញាត-*យ៉ាប៊ូ* និយាយ-ខ្ញុំសូមដឹកនាំក្រុមឡើងគោកចុះ ។ បើយើងទៅដល់ *អូសាកា* ដោយគ្មានអាចុងស្រុកនេះទេ ខ្ញុំមិនអាចទ្រាំទ្រអាម៉ាស់នេះបានទេ ក្រៅតែពីសំលាប់ខ្លួនឯងចោលតែប៉ុណ្ណោះ ។ សូមលោកទុកអោយខ្ញុំមានកិត្តិយស ទទួលបំពេញបញ្ជារបស់លោកទៅចុះ ។

*ហ៊ីរ៉ូ- មាត់ស៊ុ* ងក់ក្បាលយល់ព្រម ។ ប៉ុន្តែនៅក្នុងចិត្ត លោកសែនភ្ញាក់ផ្អើល ចំពោះប្រការដែល *យ៉ាប៊ូ* ស្ម័គ្រប្រថុយប្រថានយ៉ាងនេះ ។

នៅពេលដែល *ប្លាក់ថន* ដឹងថា *យ៉ាប៊ូ* នឹងឡើងគោកជាមួយគេនោះ ជីពចររបស់គេលោតលឿនជាងប្រក្រតី ។ អញអត់ភ្លេចទេរឿង *ពីតែស៊ូន* កូនក្រុមអញ អន្ទង់ សំរែកអា*អូមី* និងអ្វីៗឯទៀត ។ ថៃជីវិតអែងអោយស្រួល អាកូនមីចោរម្រាយ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៩

ពួកគេបានទៅដល់ដីគោកយ៉ាងរហ័ស ។ *ប្លាក់ថន* មានបំណងនាំមុខក្រុមនេះ ប៉ុន្តែ *យ៉ាប៊ូ* បានស្ទុះទៅមុខក្នុងជំហានយ៉ាងវែងៗ ធ្វើអោយអ្នកឯទៀត តាមស្ទើរតែមិនទាន់ ។ *សាមួរ៉ៃ* ទាំងប្រាំមួយនាក់ទៀត តាមឃ្លាំមើល *ប្លាក់ថន* យ៉ាងជាប់ ។ អញ្ចឹងមិនដឹងរត់ទៅកន្លែងណាទេអាចំកួត -*ប្លាក់ថន* ជេរប្រទេចផ្តាសាទៅក្នុងពោះ ដោយគេភាន់ច្រលំពីកង្វល់របស់ពួកទាំងនេះ ។ ភ្នែករបស់គេសង្កេតមើលឈូងសមុទ្រ ដើម្បីកត់សំគាល់បាតសមុទ្រ ផ្ទុកខ្សាច់ និងថ្មប៉ប្រះទឹកនានា និងចំណាំចំនុចសំខាន់ៗឯទៀត ។ ខួរក្បាលរបស់គេកត់ត្រារាល់ការសង្កេតទាំងនេះ ទុកយ៉ាងម៉ត់ចត់ ដើម្បីថ្ងៃក្រោយគេអាចសរសេរឡើងវិញ នៅក្នុងកូនសៀវភៅរបស់គេបាន ។

ពួកគេបានចុះលើឆ្នេរមានសុទ្ធតែក្រួសមួយ រួចបន្ទាប់មកគេនាំគ្នាឡើងចំនោតថ្មដែលសើមដោយទឹកសមុទ្រមួយខ្ពស់ល្មម ទើបបានទៅដល់ផ្លូវលំមួយដែលសៀរតាមបណ្តោយចំនោតច្រាំងនេះ ។ ផ្លូវនេះ រត់បត់បែនតាមជ្រោយនេះ ឆ្ពោះទៅទិសខាងត្បូង ។ ភ្លៀងបានរាំងហើយ ប៉ុន្តែខ្យល់នៅតែបក់បោកនៅឡើយ ។ នៅពេលដែល គេកាន់តែខិតទៅជិតដល់ក្បាលជ្រោយ រលកសមុទ្រដែលរត់មកបោកថ្មប៉ថ្មនៅឯក្រោមនោះ កាន់តែមានកំពស់ខ្ពស់ឡើងៗ ហើយបាចទឹកសំពោង ។ មិនយូរប៉ុន្មានពួកគេទទឹកជោកសព្វសាច់ ។

ថ្វីត្បិតតែ *ប្លាក់ថន* រងាឡើងរណ្តំផ្ចាមយ៉ាងណាក្តី ក៏ *យ៉ាប៊ូ* និង *សាមួរ៉ៃ* ទាំងប្រាំមួយនាក់ទៀត ដែលពាក់តែគីម៉ូណូយ៉ាងស្តើងនោះ ហាក់គ្មានអារម្មណ៍អ្វីពីសំណើម រឺ ពីភាពត្រជាក់អ្វីទាំងអស់ ។ ពួកអស់នេះ ប្រហែលដូចជា *រ៉ូឌ្រិច* វានិយាយមែនហើយ -*ប្លាក់ថន* គិតនៅក្នុងចិត្ត ។ ការភ័យខ្លាចបានវិលត្រលប់មកវិញម្តងទៀត ។ ពួកអាតយអស់នេះ មិនមែនដូចពួកយើងទេ ។ ពួកវាគ្មានអារម្មណ៍អ្វីពីរឿងត្រជាក់ ពីរឿងឃ្លាន ពីរឿងអត់ រឺ មួយពីរបួសអីៗដូចយើងទេ ។ ពួកវាដូចសត្វអីចឹង បើធៀបជាមួយពួកយើង ។ សរសៃពួកវាស្អិតតែម្រ៉ង ។

នៅពីក្រោមជើងគេ គឺជាចំនោតច្រាំងក្នុងកំពស់ប្រហែលមួយរយហាសិបម៉ែត ។ នៅជើងចំនោត គឺជាឆ្នេរមួយដែលមានទទឹងប្រហែលដប់ប្រាំម៉ែត ។ នៅជុំវិញក្បាលជ្រោយ



www.budinst.gov.kh www.elibraryofcambodia.org

នេះ មានសុទ្ធតែភ្នំ ហើយគ្មានផ្ទះ រឺ ខ្ទមណាមួយឡើយ ។ តាមពិតស្ថានភាពនេះ គ្មានអ្វីគួរអោយងឿងឆ្ងល់ទេ ដោយថា នៅគ្រប់ទីកន្លែងគ្មានដី សំរាប់ការដាំដុះបន្តិចបន្តួចណាសោះឡើយ ។ ឆ្នេរសមុទ្រសុទ្ធតែក្រួស រួចបន្ទាប់មក គឺជាចំនោតថ្មហើយ និងក្រានីតតែប៉ុណ្ណោះ ។ មានដើមឈើប៉ុន្មានដើមដុះតាមចំនោតភ្នំខ្ពស់ៗនោះដែរ ។

ផ្លូវបានបត់តាមក្បាលជ្រោយនេះ ។ *ធ្លាក់ថន* ខំចំកោងខ្នងទប់ខ្យល់ ហើយដើរទៅមុខយ៉ាងលំបាក ។ គេសំគាល់ឃើញថា ជើងរបស់ *យ៉ាំងប៊ូ* មានសាច់ដុំរឹងមាំ ហើយខ្លាំងណាស់។ រអិលជើងទៅអាកូនមីចោរម្រ៉ាយ ! រអិលទៅ ! -គេគិតនៅក្នុងចិត្ត - រអិលជើងធ្លាក់ទៅបោកលើថ្មនៅឯក្រោមនេះទៅណោក បើធ្លាក់តើអ្លែងស្រែករឺទេ ? រឺ ទាល់តែស៊ីបានអោយអ្លែងស្រែកនោះ ?

គេខំដកភ្នែករបស់គេចេញពី *យ៉ាំប៊ូ* ហើយងាកទៅសំលឹងរកមើលតាមឆ្នេរសមុទ្រវិញ ។ គេពិនិត្យមើលគ្រប់រូង គ្រប់រង្វះថ្ម ។ ខ្យល់ដែលពោរពេញទៅដោយចំហាយទឹកបានវាយបក់បោកមកលើគេឡើងចេញទឹកភ្នែករហាម ។ រលកសមុទ្ររត់មកបោកខ្លួនបែកផ្កាព្រែងនៅលើផ្ទាំងថ្ម ហើយដកខ្លួនទៅវិញទាំងបែកពពុះសក្បុស ។ *ធ្លាក់ថន* ដឹងថា គេមានសង្ឃឹមតិចណាស់ នឹងរកឃើញ *រ៉ូទ្រិច* នោះ។ នៅទីនេះមានរង្វះថ្មច្រើនរាប់មិនអស់ ដែលគេមិនអាចរុករកពិនិត្យមើលបានសព្វគ្រប់ឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏គេត្រូវតែឡើងគោក ស្វះស្វែងប្រឹងរក *រ៉ូទ្រិច* ដែរ។ យ៉ាងហោចណាស់ក៏ត្រូវសាកល្បងដែរ ដើម្បី *រ៉ូទ្រិច* ។ គ្រប់តែតែកុងទាំងអស់នៅពេលសូត្រធម៌រមែងបន់ស្រន់អោយខ្លួនបានស្លាប់នៅលើដីគោក និងបានកប់នៅដីគោកហើយ ។ ទាំងអស់គ្នាតែងធ្លាប់បានឃើញ មិនដឹងជាប៉ុន្មានសិបដងមកហើយទេ នូវសាកសពដែលហើមស្ពឹងអណ្តែតតាមទឹកសមុទ្រ សាកសពដែលត្រីស៊ីស៊ើរអស់ រឺសាកសពដែលត្រូវក្តាមស៊ីសុសសាច់ ដោយហេតុនេះ ស្លាប់ និងកប់នៅលើដីគោក គឺរមែងជាបំនងចុងក្រោយបំផុតរបស់ពួកគេហើយ ។

ពួកគេដើរវង់តាមក្បាលជ្រោយ ហើយក៏ឈប់យ៉ាងធូរទ្រូងនៅកន្លែងបាំងខ្យល់មួយ។ ពួកគេមិនចាំបាច់ទៅឆ្ងាយទៀតទេ ។ បើសិនមិនឃើញខ្មោចនៅតាមបណ្តោយខ្យល់



www.budinst.gov.kh www.elibraryofcambodia.org

មកដល់ត្រឹមនេះទេ បានន័យថា ខ្មោចវាចាំងនៅកន្លែងណាមួយ រីមួយក៏ត្រូវត្រីធំណាត្របាក់លេប រីមួយក៏អណ្តែតចេញទៅលំហសមុទ្របាត់ទៅហើយ ។ នៅកន្លះម៉ែត្រពីកន្លែងរបស់ពួកគេនេះ មានភូមិអ្នកនេសាទដ៏តូចមួយ ដែលសាងសង់ឡើងនៅលើឆ្នេរខ្សាច់សក្បុស ។ *យ៉ាប៊ូ* ធ្វើសញ្ញាទៅ *សាមូរ៉ៃ* ពីរនាក់ ។ ពួកគេលំអោនខ្លួន ហើយក៏រត់សំដៅទៅភូមិភ្លាមមួយរំពេច ។ ក្រោយពីចោលភ្នែកពិនិត្យកន្លែងមួយគ្រួសទៀតមក *យ៉ាប៊ូ* ក៏យកដៃជូតតំនក់ទឹកភ្លៀងចេញពីមុខ សំលឹងមើលមុខ *ប្លាក់ថន* ហើយធ្វើសញ្ញាត្រលប់ទៅវិញ ។ *ប្លាក់ថន* ងក់ក្បាល ហើយពួកគេក៏ចេញដំណើរដោយមាន *យ៉ាប៊ូ* នាំមុខ *សាមូរ៉ៃ* ទាំងប៉ុន្មានតាមឃ្លាំមើល *ប្លាក់ថន* ដដែល ។ ជាថ្មីម្តងទៀត *ប្លាក់ថន* គិតថា ពួកនេះចំជាល្ងើពកថ្ងាសមែន ។

ហើយនៅពាក់កណ្តាលផ្លូវ ពួកគេក៏ប្រទះឃើញ *រ៉ូឌ្រិច* ។

ខ្លួនរបស់ *រ៉ូឌ្រិច* ត្រូវជាប់នៅក្រហែងថ្ម ចំចន្លោះផ្ទាំងថ្មធំពីរដែលនៅផុតពីរលក ។ ប៉ុន្តែពាក់កណ្តាលរបស់ខ្លួនគេ នៅក្នុងទឹកនៅឡើយ ។ ដៃម្ខាងរបស់គេបោះទៅមុខឯដៃម្ខាងទៀតនៅច្បាមជាប់ច្រវាបាក់ ដែលកំពុងផែលផាលតាមរលកទឹក ។ គឺចលនានៃច្រវានេះ ហើយដែលបានទាក់ទាញភ្នែករបស់ *ប្លាក់ថន* នៅក្នុងពេលដែលគេចំកោងខ្លួនដើរបញ្ច្រាសខ្យល់តាមពីក្រោយ *យ៉ាប៊ូ* នោះ ។

ផ្លូវដែលចុះទៅក្រោមបាន គឺមានតែតាមចំនោតច្រាំងថ្មនេះ តែប៉ុណ្ណោះ ។ ច្រាំងមានកំពស់ប្រហែលដប់ប្រាំម៉ែត្រតែប៉ុណ្ណោះ ប៉ុន្តែនេះជាចំនោតត្រង់ ហើយស្ទើរពុំគ្មានកន្លែងដាក់ជើងឡើយ ។

រួចទឹកជោរឡើងដល់ត្រឹមណាទៅ ? *ប្លាក់ថន* ដណ្តឹងសួរនៅក្នុងចិត្ត ។ ទឹកជំនោរសមុទ្រកំពុងតែឡើងមកហើយ ។ បន្តិចទៀតទឹកសមុទ្រនឹងកួចយក *រ៉ូឌ្រិច* ទៅឯលំហសមុទ្រវិញហើយ ។ ពុទ្ធោអើយ ! ចុះតាមចំនោតនេះមិនមែនលេងចេងទេ គឺប្រាកដជាគ្រោះថ្នាក់សំបើមណាស់ ។ ធ្វើយ៉ាងម៉េចអីចេះ ?

គេដើរទៅដល់មាត់ច្រាំង ។ រំពេចនោះ *យ៉ាប៊ូ* ដើរតាមភ្លាមដោយគ្រវីក្បាលជាសញ្ញាហាមឃាត់ ។ *សាមូរ៉ៃ* ទៀតក៏ព័ទ្ធ *ប្លាក់ថន* ជុំជិត ។



www.budinst.gov.kh www.elibraryofcambodia.org

គេបន្លឺសំលេងឡើងទាំងម្វម៉ៅ :

- ឱព្រះអើយព្រះ ខ្ញុំគ្រាន់តែចង់មើលអោយច្បាស់ទេតើ មិនមែនខ្ញុំចង់រត់គេចនោះទេ ។ រួចបើខ្ញុំរត់អោយខ្ញុំរត់ទៅកន្លែងប្រកាច់យកំណា ?

គេថយក្រោយបន្តិច ហើយសំលឹងចុះទៅក្រោម ។ ទាំងអស់គ្នាសំលឹងតាមក្រសែភ្នែករបស់ *ប្លាក់ថន* ហើយចាប់ផ្តើមជជែកគ្នាវ៉ែ ដោយ *យ៉ាប៊ូ* ជាអ្នកនិយាយច្រើនជាងគេ ។

ដូចជាមិនកើតទេ - *ប្លាក់ថន* សំរេចនៅក្នុងចិត្ត ។ ដូចជាគ្រោះថ្នាក់ពេកតែម្តងចាំព្រលឹមមកម្តងទៀត ដោយយកខ្សែមកផង ។ បើវានៅកន្លែងណឹង គឺវានៅណឹង រួចចាំកប់វានៅនឹងឆ្នេរនេះ បណ្តោយទៅ ។ គេក៏បែរខ្លួនត្រលប់ក្រោយទាំងបង្ខំចិត្ត ។ រំពេចនោះ មាត់ច្រាំងក៏របេះ ហើយខ្លួនគេក៏រអិលទៅទាំងជំហរ ។ ភ្លាម១នោះដែរ *យ៉ាប៊ូ* និង *សាមូរ៉េ* ទាំងប៉ុន្មានច្បាមគេជាប់ ហើយទាញគេទៅក្រោយយ៉ាងរហ័ស ។ នៅគ្រានោះ ហើយដែលគេទើបយល់បានថា អ្នកដែលមកតាមគេនេះ មិនមែនភ័យខ្លាចគេដាក់មេធាយទេ តែពួកគេខ្វាយខ្វល់ពីសន្តិសុខរបស់គេសោះ ។ ពួកនេះ មកការពារអញទេតើ ។

ហេតុអីបានជាពួកនេះបារម្ភពីសន្តិសុខរបស់អញអីចឹង ? មកពី *ភូក៉ា .... ភូក៉ា ភូក៉ា* អីអីចេះ ? អូ មែនហើយ *ភូក៉ាណាកា* ! មកពីគាត់ណឹងមែនទេ ? អ្ហា ជាអីចឹងក៏បាន ប៉ុន្តែក៏អាចថាមកពីគ្មានអ្នកណាអាចបញ្ជាទូកបានទៀតទេក៏មិនដឹង ។ បែបមកពីអីចឹងទេដឹង បានជាពួកវាយល់ព្រមអោយអញឡើងគោកនេះ ? ប្រហែលដែរ បើអីចឹងមែន មានន័យថា អញមានអំនាចនៅលើទូកនេះ មានអំនាចទៅលើ *ដេមីញ៉ូ* កញ្ចាស់ និងអាកូនមីចោរម្រាយនេះហើយ ។ តែតើអញប្រើអំនាចអញនេះ យ៉ាងម៉េចអីចេះ ?

គេបន្ទូរឥរិយាបថ អរគុណអ្នកឯទៀត ហើយសំលឹងចុះទៅក្រោម :

- យើងចុះទៅយកវា *យ៉ាប៊ូ-សាន* ។ *វ៉ែហ* ? ផ្លូវមានតែមួយទេ គឺរបៀបនេះ ។ យើងចុះតាមចំនោតច្រាំង ខ្ញុំនឹងចុះទៅយកវាឡើងមក ។ ខ្ញុំ *អាន់ជីន-សាន*

ជាថ្មីម្តងទៀត *ប្លាក់ថន* ដើរតំរង់ទៅមាត់ច្រាំងធ្វើដូចជាប្រុងចុះទៅក្រោមមែន១ ។ អ្នកឯទៀត ក៏ស្ទុះមកឃាត់ *ប្លាក់ថន* ម្តងទៀត ។ គេនិយាយឡើងដោយធ្វើហាក់ដូចជាព្រួយ



www.budinst.gov.kh www.elibraryofcambodia.org

បារម្ភណាស់អីចឹង :

- យើងត្រូវយកសព *វ៉ូគ្រិច* ឡើងមក ។ មើលហ្ន៎ ! មេឃកាន់តែងងឹតហើយ

- *អ៊ុយេ អាន់ជីន-សាន -យ៉ាប៊ូ* ឆ្លើយតប ។

*ប្លាក់ថន* សំលឹងមើលទៅ *យ៉ាប៊ូ* :

- បើលោកមិនចង់អោយខ្ញុំចុះទេ *យ៉ាប៊ូ-សាន* សូមលោកចាត់មនុស្សម្នាក់អោយចុះទៅ ។ រឺមួយខ្លួនលោកឯងចុះតែម្រ៉ងទៅ លោកឯងណឹងណា៎ !

ខ្យល់វាយវាត់មកលើពួកគេ ហើយបញ្ចេញស្នូរគ្រលួចនៅពេលដែលវាបុកចំនោតច្រាំង។ *ប្លាក់ថន* ឃើញ *យ៉ាប៊ូ* អោនសំលឹងទៅក្រោមប្រមាណចំនោតច្រាំង ហើយសំលឹងមើលពន្លឺថ្ងៃ ។ គេដឹងថា *យ៉ាប៊ូ* កំពុងគ្រវាត់ផ្សែសន្ទូចគេហើយ ។ អ្អែងចូលអន្ទាក់អញហើយ អាកូនមី ចោលម្រ៉ាយ ។ អំនួតអ្អែងវាអូសអ្អែងចូលអន្ទាក់ហើយ ។ អ្អែងតែបានចុះតាមច្រាំងនេះ អ្អែងច្បាស់ជាធ្ងន់ខ្លួនហើយ ។ តែអញសូមអង្វរអ្អែង សូមអ្អែងមេត្តាកុំងាប់អី គ្រាន់តែបាក់ជើង រឺ បែកក្អែកគោលអីបានហើយ រួចចាំលង់ទឹកងាប់ទៅចុះ ។

*សាមូរ៉ៃ* ម្នាក់ចាប់ផ្តើមចុះទៅក្រោម ប៉ុន្តែ *យ៉ាប៊ូ* បញ្ជាអោយបុរសនេះ ថយទៅក្រោយវិញ ។ រួចគេនិយាយឡើង :

- ត្រលប់ទៅទូកយកខ្សែមកវិញជាប្រញាប់ !

បុរសម្នាក់រត់ចេញទៅវីង ។

*យ៉ាប៊ូ* ដោះខ្សែស្បែកជើង ហូតដាវចេញពីចង្កេះ ហើយគ្របវាយ៉ាងម៉ត់ចត់ :

- ពួកអ្អែងយាមដាវខ្ញុំ ហើយនិងយាមអាចុងស្រុកនេះ ។ បើមានហេតុការណ៍ អីកើតឡើង ដល់ដាវនេះក្តី ដល់អាចុងស្រុកនេះក្តី ខ្ញុំវះពោះពួកអ្អែងហើយណា៎ ។

*តាកាតាស៊ី* និយាយឡើង :

- សូមលោកម្ចាស់ *យ៉ាប៊ូ - សាម៉ា* អោយខ្ញុំបាទចុះទៅជំនួសវិញទាន ។ បើសិនជាលោកម្ចាស់មានរបួស រឺបាត់បង់ជីវិតនោះខ្ញុំនឹង......

-បើសិនជាខ្ញុំទៅមិនរួច អែងស្មានថាអែងអាចទៅរួចអ្វី ?



www.budinst.gov.kh www.elibraryofcambodia.org

- មិនរួចទេទាន ច្បាស់ជាមិនរួច ។

- ល្អ !

- បើអីចឹង សូមលោកម្ចាស់រង់ចាំគេយកខ្សែមកសិនទៅលោកម្ចាស់ បើសិនជាមានហេតុការណ៍អីប៉ះពាល់ដល់លោកម្ចាស់ ខ្ញុំបាទមិនប្រណីទោសដល់ខ្លួនខ្ញុំបាទទេទាន ។

ហេតុអីក៏មិនរង់ចាំខ្សែសិនទៅ ? *យ៉ាប៊ូ* ដណ្ដឹងសួរនៅក្នុងចិត្ត ។ រង់ចាំខ្សែ គឺពិតជាប្រការត្រឹមត្រូវ ។ ប៉ុន្តែនេះ មិនជាការឈ្លាសវៃនោះទេ ។ គេចោលភ្នែកសំលឹងទៅ *ភ្លាក់ផន* មួយខ្ទាប់ ហើយងក់ក្បាលបន្តិច ។ គេដឹងថា *ភ្លាក់ផន* កំពុងតែសាកល្បងកូនចិត្តរបស់គេហើយៗ គេក៏បានដឹងជាមុនដែរថា រឿងបែបនេះ ច្បាស់ជាមានកើតឡើងហើយ ។ ទន្ទឹមនេះគេបានសង្ឃឹមថា រឿងបែបនេះ នឹងកើតមានឡើងជាមិនខាន ។ ហេតុនេះហើយ បានជាអញស្ម័គ្រចិត្តបំពេញបេសកកម្មនេះ *អាន់ជីន-សាន*-គេនិយាយនៅក្នុងពោះដោយទឹកចិត្តសប្បាយផងអស់សំនើចផង ។ អែងនៅស្មើរក្មេងណាស់ *អូមី* វានិយាយត្រូវមែន ។

*យ៉ាប៊ូ* ដោះ គីម៉ូណូទទឹករបស់ខ្លួនចេញ ដោយទុកតែក្រណាត់ស្ទាប់ភ្លៅតែប៉ុណ្ណោះ ។ គេដើរទៅមាត់ច្រាំង ហើយយកជើងស្ទង់ដី ។ គេមិនដោះស្បែកជើងក្រណាត់ *តាប៊ី* ចេញទេ ។ គេគិតថា ពាក់វាជាប់នឹងជើងល្អជាងដោះចេញ ។ ឆន្ទៈរបស់គេ និងខ្លួនប្រាណរបស់គេដែលបានឆ្លងកាត់ការរឹកហាត់មួយជីវិត *សាមូរ៉ៃ* របស់គេនោះ បានឈ្នះលើភាពគ្រជាក់ផុតដល់ឆ្អឹងនេះបាន ។ *តាប៊ី* នឹងអោយខ្ញុំផ្ទុបានជាប់ល្អជាងក្នុងមួយរយៈដែរ ។ ចុះច្រាំងនេះ មិនមែនជាការងាយទេ ។ អែងត្រូវប្រើអស់កំលាំងកាយ និងការប៉ិនប្រសប់ទាំងអស់ ដែលអែងមាន បើអែងចង់ចុះទៅដល់ក្រោម ដោយនៅមានជីវិតរស់នៅនោះ ។ តែតើគួរប្រថុយទេ ?

នៅក្នុងពេលព្យុះ និងនៅពេលដែលទូកកំពុងជ្រែករលកសំដៅរកច្រាំងនោះ គេបានឡើងមកលើ ហើយទៅអង្គុយនៅកន្លែងចែវដោយមិនអោយ *ភ្លាក់ផន* ឃើញឡើយ ។ គេចែវទូកយ៉ាងរីករាយ ដោយគេបានបញ្ចេញកំលាំងរបស់គេតាមដងចែវ ទន្ទឹមនោះគេ ក៏មិនចូលចិត្តភាពរញ៉េរញ៉ៃនៅខាងក្រោម និងភាពពុលរលករបស់គេផង ។ គេបានសំរេចចិត្តស្នាប់នៅកន្លែងមានខ្យល់ដកដង្ហើមធូរទ្រូង ជាជាងស្លាប់នៅកន្លែងថប់ខ្យល់ ដូចខាងក្រោមនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងពេលដែលគេរួមកំលាំងថែវជាមួយអ្នកឯទៀត ក្នុងអាកាសធាតុដ៏ត្រជាក់នោះ គេបានសង្កេត *ក្វាក់ថុន* ជាប់ ។ គេបានឃើញយ៉ាងច្បាស់ថា នៅលើសមុទ្រទាំងទូក ទាំងអ្នកទាំងអស់នៅលើទូក ត្រូវធ្វើវាសនាខ្លួនលើមនុស្សតែពីរនាក់នេះគត់ ។ ក្នុងពេលនេះពួកតៃកុងស្ថិតនៅដូចត្រីក្នុងទឹក ហើយគេរត់ចុះឡើងនៅលើក្តារទូកដែលឃ្លេងឃ្លោងយ៉ាងខ្លាំងនេះ បែបវាហើ មិនខុសអ្វីពីខ្លួនគេ *យ៉ាប៊ូ* កំពុងជិះសេះដែលផាយពេញទំហឹងយ៉ាងដូច្នោះដែរ ។ គ្មានជប៉ុនណាម្នាក់នៅលើទូកនេះ អាចប្រជែងមនុស្សពីរនាក់នេះបានទេ ។ ទាំងលើការប៉ិនប្រសប់ ទាំងលើចំនេះដឹង ទាំងលើទឹកចិត្តក្លាហានអង់អាច ។ បន្តិចម្តង១ ការយល់ដឹងនេះ បានក្លាយជាទស្សនៈក៏មហិមាមួយនៅក្នុងខួរក្បាលរបស់យ៉ាប៊ូ នោះគឺជាសំពៅទំនើបរបស់ពួកចុងស្រុកផ្ទុកដោយពួក *សាមូរ៉ៃ* បើកបរដោយ *សាមូរ៉ៃ* បញ្ជាដោយ *សាមូរ៉ៃ* កាន់ក្តោងដោយពួក *សាមូរ៉ៃ* ។ ជាពួក *សាមូរ៉ៃ* របស់គេ ។

បើសិនណាជាពីពេលចាប់ផ្តើម អញមានសំពៅពួកចុងស្រុកតែបីគ្រឿងនោះ អញនឹងអាចក្តាប់បានយ៉ាងងាយផ្លូវសមុទ្រ រវាង *យេដូ* និង *អូសាកា* ។ អញដាក់បញ្ជាការដ្ឋានអញនៅ *អ៊ីស៊ូ* ហើយអញអាចបើក រឺបិទនាវាចរណ៍ទាំងអស់បានយ៉ាងធូរណ្តុយ ។ ដល់អ៊ីចឹងអញក្តាប់ស្រូវ ក្តាប់សូតចេញចូលដូចបើកបិទបាតដៃអញអ៊ីចឹង ។ ពេលនោះអញចង់ធ្វើជាអាជ្ញាកណ្តាលរវាង *អ៊ីស៊ីដូ* និង *តូរ៉ាណាកា* ក៏បាន រឺ យ៉ាងហោចណាស់ក៏ជាមេតុល្យភាពរវាងអ្នកទាំងពីរនាក់នេះដែរ ។

គ្មាន *ដៃមីញ៉ូ* ណាម្នាក់ធ្លាប់ត្រួតត្រាសមុទ្រទេ ។

គ្មាន *ដៃមីញ៉ូ* ណាម្នាក់មានសំពៅ មានតៃកុងទេ ។

លើកលែងតែអញ ។

អញមានសំពៅ រឺក៏ថា អញមានសំពៅកាលពីពេលមុននេះ ហើយអីលូវនេះ អញត្រៀវតែយកសំពៅនេះមកវិញ បើសិនជាអញចេះប្រើប្រាជ្ញារបស់អញ ។ អញមានតៃកុងដែលនឹងទៅជាអ្នកបង្វឹកបង្ហាត់ពួកតៃកុងឯទៀត បើសិនណាអញធ្វើយ៉ាងម៉េចអោយវាឃ្លាតពី *តូរ៉ាណាកា* និងធ្វើយ៉ាងម៉េចបង្ក្រាបវាបាននោះ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលណាអាមនុស្សចុងស្រុកនេះ សុខចិត្តសុខកាយចំនុះអញហើយ វានឹងជួយបង្ហាត់ពូកអញ ហើយវានឹងជួយធ្វើសំពៅអោយអញជាមិនខាន ។

តែធ្វើយ៉ាងម៉េចអោយវាព្រមចំនុះអញដោយពិតប្រាកដនោះ ? អន្ទង់មិនអាចបំបាក់ស្មារតីវាបានទេ ។

ដំបូងធ្វើយ៉ាងណា ផ្ដាច់វាអោយនៅតែម្នាក់ឯង ហើយអោយវានៅតែជាមួយរូបយើងម្នាក់ផ្ទាល់ ។ នេះមិនគឺជាមតិ *អូមី* អ្វី ? បន្ទាប់មកបង្រៀនវាអោយស្គាល់របៀបរបបនិងអោយចេះនិយាយភាសាជប៉ុន ។ ត្រូវមែន អូមីចំជាឆ្លាតមែន ។ សឹងតែថា វាឆ្លាតហួសពេកផង ។ តែល្មើយរឿង *អូមី* ចាំគិតនៅពេលក្រោយទៀត ។ អីលូវនេះ រឿងសំខាន់ គឺរឿងអាតែកុងនេះ ។ តើធ្វើម៉េចបង្ក្រាបវាបានហ្ន៎ ?

អានេះ ជាគ្រិស្តសាសនិក ។ តើ *អូមី* និយាយយ៉ាងម៉េចពីរឿងពួកនេះ? "ពួកវាគោរពជីវិត "ព្រះធំរបស់វាគឺ *យេស៊ូ* បានប្រៀនប្រដៅអោយចេះស្រលាញ់គ្នាទៅវិញទៅមក និងចេះគោរពជីវិត " ។ បើអញអាចជួយសង្គ្រោះជីវិតវានោះ គឺជាការល្អ ។ ប៉ុន្តែធ្វើម៉េចអាចពត់វាបាន ?

ដោយលង់លក់ទៅក្នុងគំនិតរំភើបទាំងនេះ *យ៉ាប៊ូ* ឥតបានរវល់សង្កេតទិសរបស់ទូក រឺស្ថានភាពរបស់សមុទ្រឡើយ ។ នៅពេលដែលរលកវាយគ្របលើទូកនោះ គេឃើញ *ក្វាក់ចិន* ត្រូវផ្ទាំងទឹកគ្របជុំជិត ប៉ុន្តែគេឥតឃើញបុរសនេះ ពក់ស្លុតបន្តិចណាសោះ ។ *យ៉ាប៊ូ* ស្រលាំងកាំងនៅក្នុងចិត្តជាខ្លាំង ។ ហេតុអីបានមនុស្សម្នាក់ដែលសុខចិត្តអោនក្បាលអោយគេបាញ់នោមដាក់ខ្លួង ដើម្បីគ្រាន់តែជួយបរិវារកំប៉ិកកំប៉ុកបែរជាអាចបំភ្លេចភាពអាម៉ាស មិនអាចលុបបាននេះ ហើយឈរជ្រែងជើងនៅកន្លែងបញ្ជាយ៉ាងសង្ហា ប្រយុទ្ធទប់នឹងគ្រោះថ្នាក់បីដូចជាវីរបុរសមួយ ដើម្បីជួយសត្រូវដដែលនេះយ៉ាងណឹង ? ហើយនៅពេលដែលមហារលកបោកកួចយកតែកុងប៉ិកទុយកាល់ ពេលដែលទូកហាក់ដូចជាអស់ផ្លូវកែហើយនោះ បុរសនេះ បែរជាធ្វើវាហី មិនតែប៉ុណ្ណោះចេះបំផុសកំលាំងអ្នកឯទៀត អោយចែវទូករួចផុតពីជុំផ្ចុំទៅវិញ ។

អញមើលទៅរកយល់វាមិនបានទេមើលទៅ -គេគិតនៅក្នុងចិត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

នៅមាត់ច្រាំង *យ៉ាប៉ូ* សំលឹងមើលក្រោយជាចុងក្រោយបង្អស់ ។ *អាន់ជីសាន* ! អញដឹងថា អ្នែងកំពុងគិតថា អញទៅងាប់ហើយ១ អ្នែងជាអ្នកបានជោគជ័យក្នុងការរុញអញចូលអន្ទាក់អ្នែង ។ អញដឹងថា ទោះជាយ៉ាងណាក៏អ្នែងមិនមែនចុះទៅក្រោម ដោយផ្ទាល់ខ្លួនអ្នែងដែរ ។ អញសង្កេតអ្នែងល្អិតល្អន់ណាស់ ។ អញធ្លាប់រស់ចាត់ចំក្នុងតំបន់ភ្នំ ហើយអ្នែងត្រូវដឹងថានៅប្រទេសជប៉ុនគេ រមែងឡើងភ្នំ ដើម្បីអំនួតខ្លួនផង ដើម្បីការកំសាន្តសប្បាយផង ។ ដោយហេតុនេះហើយ អីលូវអញកំពុងសាកនឹងខ្លួនអញ មិនមែនសាកនឹងអ្នែងនោះទេ ហើយសាកលើកំនត់របស់អញ មិនមែនលើកំនត់របស់អ្នែងទេ ។ អញនឹងចុះ ហើយបើអញស្លាប់អត់ការ ទេ ។ តែបើអញបានសំរេចវិញ អ្នែងជាកូនប្រុសអ្នែងត្រូវដឹងថា អញគ្រាន់បើជាងអ្នែង ហើយគ្រាន់បើនៅលើការកំនត់របស់អ្នែង ។ អ្នែងនឹងជំពាក់គុណអញថែមទៀត បើសិនជាអញយកខ្មោចឡើងមកបាននោះ ។

អ្នែងនឹងត្រូវទទួលចំនុះអញ *អាន់ជី -សាន* ។

*យ៉ាប៉ូ* សំរូតខ្លួនចុះតាមចំនោតទាំងយ៉ាងប៉ិនប្រសប់ ។ ពេលបានពាក់កណ្ដាលគេរអិលជើងធ្លាក់រូ ។ ប៉ុន្តែដៃឆ្វេងរបស់គេ ស្រវាចាប់ជាប់ដង្កៀល្បាស់មួយដែលបញ្ឈប់ការធ្លាក់របស់គេ ហើយក្នុងខណៈនោះ ខ្លួនគេស្ថិតនៅតែលតោល រវាងស្លាប់នឹងរស់ ។ ក្រញាំដៃរបស់គេខំប្រឹងខ្លាំងដី នៅពេលដែលគេដឹងថា គុម្ពល្បាស់ កំពុងតែរបូតចេញពីដៃរបស់គេហើយ ។ ជើងគេស្រវែស្រវារកក្រហែងថ្ម រឺ ពកថ្មអ្វីមួយ ដើម្បីជាន់ទប់ខ្លួន ។ នៅពេលដែលដៃឆ្វេងគេរបូតចេញពិគុម្ពល្បាស់ ជើងរបស់គេរាវប៉ះរង្វះថ្មមួយ ហើយគេក៏ខ្ទាំជើងនៅក្នុងនោះជាប់ទៅ ។ គេផ្ទិតខ្លួនទាំងអស់សង្ឃឹមទៅនឹងជញ្ជាំងថ្ម ហើយប្រវេសប្រវាសរកលំនឹង ដើម្បីទប់ខ្លួន រួចជើងគេក៏របូតឃ្លះតែម្ដង ។ ប៉ុន្តែនៅពេលទើបធ្លាក់បានបីបួនម៉ែត ដៃទាំងពីររបស់គេក៏ស្រវាចាប់គុម្ពល្បាស់មួយទៀតជាប់ ។ គុម្ពល្បាស់សណ្ដកឫសលាន់ភឹស ហើយគេក៏ធ្លាក់រំទៅលើឆ្នេរខ្សាច់ដែលនៅខាងក្រោមប្រហែលប្រាំមួយម៉ែត ។ គេធ្លាក់លើជើងរបស់គេប្រៀបដូចជាឆ្មា ហើយគេក៏ប្រមៀលខ្លួនជាច្រើនត្រលប់ទៀត ដើម្បីបន្ថយទន្ទាក់របស់គេ ។ រួចគេយកដៃដែលដាច់ឈាមរហាមនោះ អោបក្បាលជាប់ បង្ការក្រែងមានថ្មធ្លាក់មកតាមក្រោយ ។ ប៉ុន្តែគ្មានអ្វីធ្លាក់



www.budinst.gov.kh www.elibraryofcambodia.org

មកឡើយ ។ គេត្រវីក្បាល ដើម្បីប្រមែប្រមូលស្មារតី រួចហើយគេក្រោកឈរឡើង កជើងរបស់គេម្ខាងត្រេច ហើយការឈឺចាប់នៅក្នុងជើងរបស់គេនេះ បានឆក់កន្ត្រាក់សព្វសារពាង្គកាយ ធ្វើអោយគេបែកញើសច្រោកៗ ។ ម្រាមជើង និងក្រចកដៃរបស់គេបែកហូរឈាមកក្លាក់ ។

គ្មានការឈឺចាប់ទេ ។ អ្នែងមិនត្រូវឈឺចាប់ទេ ។ ឈរអោយត្រង់ខ្លួន ។ អាមនុស្សចុងស្រុកវាកំពុងមើលមកអ្នែង ។

តំនក់ទឹករលកដែលបែកខ្ចាយ បានបោកគ្របមកលើរូបគេ ។ អាកាសធាតុត្រជាក់បានបង្អន់ការឈឺចាប់បណ្ដាលមកពីមុខរបួសទាំងនេះ ។ គេដើរជ្រៀតចូលតាមចន្លោះដុំថ្មពោរពេញទៅដោយស្លែ ហើយរំកៀកខ្លួនតាមរង្វះថ្មចូលទៅជិត *រ៉ូត្រិច* ។

រំពេចនោះ *យ៉ាប៊ូ* ទើបបានដឹងថា បុរសនេះនៅរស់នៅឡើយ ។ ក្រោយពីពិនិត្យអោយបានច្បាស់ថា *រ៉ូត្រិច* នៅមានដង្ហើមទៅឡើយមែននោះ គេក៏អង្គុយចុះមួយសន្ទុះសិន ។ តើអញចង់បានវារស់ រឺងាប់អីចេះ .? វារស់ រឺ វាងាប់អាមួយណាល្អជាង ?

ក្ដាមមួយវារចេញពីក្រោមថ្ម ហើយចុះទៅក្នុងទឹកបាត់ទៅ ។ ទឹករលកបានមកបោកខ្លួននៅក្បែរជើងរបស់គេ ។ *យ៉ាប៊ូ* មានអារម្មណ៍ថា ជាតិអំបិលបានមកហែកខ្វាំរបួសគេអោយកាន់តែឈឺចាប់ថែមទៀត ។ តើអាមួយណាល្អជាងអីចេះ ?

គេក្រោកឡើងទាំងទ្រេតទ្រោត ហើយស្រែកទៅប្រាប់អ្នកនៅខាងលើ :

- *តាកាតាស៊ី -សាន* ពែកុងនេះនៅរស់នៅឡើយ ទៅទូកយកស្នែងនិងគ្រូពេទ្យម្នាក់ផងបើសិនជាមាន ។

សំដីរបស់ *តាកាតាស៊ី* លាន់មកវិញល្វើយៗដោយត្រូវសន្ធឹកខ្យល់លុប :

- បាទ ទាន !

រួច តាកាតាស៊ី ងាកផាំអ្នកឯទៀតមុននឹងគេរត់ចេញទៅ :

- មើលមនុស្សចុងស្រុកនេះ ? កុំអោយមានរឿងអីប៉ះពាល់ដល់គាត់អោយសោះ ។

*យ៉ាប៊ូ* សំលឹងមើលទៅទូកដែលត្រូវយុថ្កាទប់ជាប់នៅនឹងកន្លែង ។ *សាមូរ៉ៃ* ម្នាក់ដែលគេបានបញ្ជូនទៅរកខ្មែរនោះ បានទៅដល់កូនទូក ហើយចាប់ផ្ដើមចែវចេញហើយ ។ *យ៉ាប៊ូ*



www.budinst.gov.kh www.elibraryofcambodia.org

ញញឹមតែម្នាក់ឯង រួចងាកក្រោយសំលឹងឡើងទៅលើវិញម្ដង ។ *ភ្នាក់ផន* បានដើរមកដល់មាត់ច្រាំង ហើយស្រែកយ៉ាងរហ័សប្រាប់គេពីរឿងអ្វីមួយ ។

តើវាចង់និយាយពីរឿងអីហ្នឹង ? *យ៉ាប៊ូ* ផល្ដឹងសួរនៅក្នុងចិត្ត ។ គេឃើញបុរសនេះចង្អុលទៅសមុទ្រ ប៉ុន្តែគេគេមិនដឹងថា តើវាមានន័យយ៉ាងម៉េចនោះ ។ សមុទ្រនៅតែមានរលកបោកបក់ឡើង រញ្ជួយដូចមុនដដែលទេតើ ។ តែវាគ្មានអ្វីប្លែកសោះ ។

ទីបំផុតគេលែងខ្វល់នឹងប្រឹងយល់ថា តើ *ភ្នាក់ផន* ចង់និយាយពីអ្វី ហើយគេក៏បែរទៅពិនិត្យ *រ៉ូប៊ិច* ម្ដង ។ គេប្រឹងទាញបុរសនេះ យ៉ាងលំបាកពីកន្ទៀតថ្ម ហើយលើកដាក់នៅលើថ្មផុតពីទឹក ។ បុរសនេះ មានដង្ហើមកញ្ចក់១ ប៉ុន្តែបេះដូងរបស់គេនៅដើរល្អទេ ។ នៅលើខ្លួនគេមានរបួសជាច្រើន ។ ឆ្អឹងស្មងជើងរបស់គេលៀនចេញផ្លែតាមកំភួនជើងឆ្វេង ។ ស្មាស្ដាំរបស់គេហាក់ដូចជាសណ្ដកចេញពីគ្នា ។ *យ៉ាប៊ូ* ខំពិនិត្យក្រែងលោបុរសនេះ មានរបួសហូរឈាមកន្លែងណា ប៉ុន្តែគេឥតមានកន្លែងណាហូរឈាមឡើយ ។ គេគិតថា បើសិនជាបុរសនេះ មិនត្រូវរបួសគ្រឿងក្នុងធ្ងន់ធ្ងរទេនោះ គេអាចរស់បាន ។

*យ៉ាប៊ូ* ធ្លាប់ត្រូវរបួសរាប់មិនអស់ ហើយធ្លាប់ឃើញអ្នកស្លាប់ និងអ្នករបួសជាច្រើនដែលអាចអោយគេបានជំងឺបានខ្លះ ។ បើសិនជាគេអោយស្រា *សាកេ* និងថ្នាំរំសាយឈឺខ្លះ ដើម្បីធ្វើយ៉ាងណាអោយបុរសនេះ កើនកំដៅខ្លួនបាននោះ វានឹងអាចរស់បាន ។ វាអាចដើរមិនរួចមែន តែយ៉ាងហោចណាស់វាបានគង់ជីវិតដែរ ។ អញចង់អោយវារស់ អារឿងវាដើរបាន រឺមិនបាននោះ មិនមែនជាការសំខាន់ទេ ។ វាដើរមិនបានក៏អាចជាការល្អដែរ ព្រោះអញនឹងមានតែកុងបំរុងមួយដែរ ព្រោះថា អានេះវាជំពាក់គុណអញ ។ បើអាចោរសមុទ្រ វាមិនព្រមសហការ អញអាចប្រើអាមួយនេះ ។ តែតើអញគួរចូលគ្រិស្តសាសនាទេ ? បើអញចូលតើពួកវាទាំងពីរព្រមជួយអញទេ ?

បើសិនជា *អូមិ* វិញ តើវានឹងធ្វើយ៉ាងម៉េចហ្ន៎ ?

អាណឹងមួយពិតជាឈ្លាសវៃមែន ។ ពិតជាឈ្លាសវៃ ។ រឺក៏ឈ្លាសវៃហួស ? *អូមិ* វាយល់ច្រើនហួស ហើយរហ័សហួស ។ បើសិនជាវាឈ្លាសវៃយ៉ាងនេះ វាពិតជាមើលឃើញ



www.budinst.gov.kh www.elibraryofcambodia.org

ឆ្ងាយ វាពិតជាយល់ថា បើសិនជាអញរស់ទៅ គឺពិតជាឪវាហើយ ដែលជាអ្នកដឹកនាំត្រកូល ព្រោះអាកូនអញវានៅខ្ចះបទពិសោធន៍ណាស់ មិនអាចឈានឡើងបានទេ ពិសេសពេលដែលគ្មានរូបអញ ។ ហើយផុតពីរាជ្យអាឪទៅ ច្បាស់ជាអា *អូមី* ខ្លួនវាតែម្តង ដែលនឹងបន្តនាទីដឹកនាំនេះ ។ មិនថាអីចឹង ?

តើត្រូវដោះស្រាយរឿង *អូមី* នេះយ៉ាងណា ?

តើយ៉ាងម៉េចដែរ បើអញប្រគល់អូមីទៅអោយអាចុងស្រុក ?

បើធ្វើរបៀបហ្នឹង តើវាទៅជាយ៉ាងណាទៅវិញ ?

សំលេងជ្រួលច្របល់បានលាន់ពីមាត់ច្រាំងមកជាថ្មី។ នៅពេលនោះហើយដែល *យ៉ាប៊ូ* បានយល់ថា តើអាមនុស្សចុងស្រុកនោះ ចង់និយាយពីអ្វី ។ ទឹកជំនោរសមុទ្របានជោរឡើងយ៉ាងឆាប់រហ័ស ។ អីលូវនេះទឹកបានមកដល់ជុំថ្ម ដែលគេកំពុងអង្គុយនេះហើយ។ គេស្ទុះក្រោកឡើង ហើយខាំធ្មេញលាន់ក្រឹត ព្រោះការឈឺចាប់នៅកជើងរបស់គេ ។ ច្រកចេញទៅតាមឆ្នេរត្រូវទឹកសមុទ្រជន់លិចអស់ហើយ ។ គេកត់សំគាល់ថា តាមស្នាមនៅលើជញ្ជាំង ច្រាំងកំពស់ទឹកសមុទ្រនៅពេលជោរឡើង គឺផុតមួយជំហរមនុស្សទៅទៀត ។ គេចោលភ្នែកសំលឹងមើលទៅកូនទូកឃើញថា គេបានអុំជិតទៅដល់ទូកធំហើយ ។ នៅឯខាងលើច្រាំង *កាកាកាស៊ុ* កំពុងតែខ្ទឹតនៅឡើយ ។ គេដឹងថា ក្នុងស្ថានភាពនេះ ខ្សែមិនអាចមកដល់ទាន់ពេលវេលាឡើយ ។

ភ្នែករបស់គេសំលឹងមើលយ៉ាងរវាសរវៃកន្លែង ដែលគេកំពុងស្ថិតនៅ ។ គ្មានផ្លូវណាឡើយជញ្ជាំងថ្ម ក៏គ្មានរូង គ្មានរង្វះអ្វីទាំងអស់ ។ នៅឆ្ងាយពីច្រាំងមានដង្គុំឈើខ្លះ ដែលមានន័យថា មានទីឈរផុតពីទឹកបាន ប៉ុន្តែគេមិនអាចទៅដល់ទេ ព្រោះគេមិនចេះហែលទឹក ហើយក៏គ្មានអ្វីធ្វើជាក្បូនបានទៀត ។

អ្នកដែលឈរនៅខាងលើច្រាំង តាមសំលឹងមើល *យ៉ាប៊ូ* យ៉ាងអន្ទះសា ។ បុរសចុងស្រុកចង្អុលទៅដង្គុំឈើនៅឯនាយនោះ ហើយធ្វើជាសញ្ញាអោយហែលទឹកប៉ុន្តែ *យ៉ាប៊ូ* គ្រវីក្បាលតបទៅវិញ។ហើយគេក៏សំលឹងមើលកន្លែងជ្រកម្តងទៀត យ៉ាងប្រុងប្រយ័ត្ន។ គ្មានអ្វីទាំងអស់។

គ្មានច្រកណារត់រួចទេ គេគិតនៅក្នុងចិត្ត ។ អីលូវនេះដល់ពេលដែលត្រូវស្លាប់ហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

អ្នែងត្រូវត្រៀមខ្លួនស្លាប់ចុះ ។

នេះគឺជាវាសនា -គេគិតនៅក្នុងចិត្តបន្តទៅទៀត រួចហើយគេលែងគិតពីអ្វីទាំងអស់ក្រៅពីរៀបបង្គុយរបស់គេយ៉ាងស្រួលបួលនោះ ។ នេះជាថ្ងៃចុងក្រោយ សមុទ្រចុងក្រោយ ពន្លឺចុងក្រោយ ការសប្បាយចុងក្រោយ និងអ្វីៗ ជាចុងក្រោយ ។ សមុទ្រ មេឃ ភាពត្រជាក់ និងជាតិអំបិល របស់ទាំងអស់នេះ មានសំរស់ល្អអ្វីម្ល៉េះទេ ។ គេចាប់ផ្តើមនឹកគិតពីកំនាព្យចុងក្រោយ ដែលតាមប្រពៃណី គេគួរតែសរសេរឡើងនោះ ។ គេគិតថា គេមានសំនាងណាស់ព្រោះមុនស្លាប់គេមានពេលគ្រប់គ្រាន់ ដើម្បីត្រិះរិះយ៉ាងស្ងប់ស្ងៀម ។

*ប្លាក់ថន* ស្រែកយ៉ាងអស់សំលេងទៅកាន់ *យ៉ាប៊ូ* :

- នែស្តាប់អញអាកូនមីចោរម្រ៉ាយ រកមើលផ្លូវយណាឡើងទៅ រកមើលអោយសព្វទៅវាច្បាស់ជាមានមិនខានទេ ។

ពួក *សាមូរ៉ៃ* នាំគ្នាឈរពាំងផ្លូវ ហើយសំលឹងមើលទៅ *ប្លាក់ថន* ហាក់ដូចគេជាមនុស្សឆ្កួត ។ ចំពោះពួកគេវាជាការច្បាស់ណាស់ដែលថា គ្មានច្រកណាចេញបានទេ ហេតុនេះ *យ៉ាប៊ូ* ត្រូវរៀបចំខ្លួន ដើម្បីបិទភ្នែកស្លាប់យ៉ាងស្ងប់ស្ងៀម ហើយពួកគេក៏ប្រាកដជាធ្វើយ៉ាងដូចនេះដែរ បើសិនជាពួកគេស្ថិតនៅក្នុងករណីដូចគ្នានេះ ។ ហេតុនេះ ពួកគេក្តៅក្រហាយនឹង ប្លាក់ថន ដែលស្រែកឡូឡានេះណាស់ ។ *យ៉ាប៊ូ* ក៏យ៉ាងដូច្នេះដែរ ។

- តែពួកអែងមើលនោះ កន្លែងនោះដូចជាមានផ្លូវយចេញមែនទេ ?

បុរសម្នាក់ដើរទៅមាត់ច្រាំងអើតមើលទៅខាងក្រោម ហើយញាក់ស្មា ។ បន្ទាប់មកគេដើរមកជជែកជាមួយគ្នាគេវិញ ហើយពួកគេញាក់ស្មាធ្វើវាហ៊ី ។ នៅរាល់តែពេលដែល *ប្លាក់ថន* ដើរទៅជិតមាត់ច្រាំង ពួកគេបាំងផ្លូវភ្លាម ។ គេអាចរុញពួកនេះទំលាក់អោយស្លាប់យ៉ាងងាយ ហើយម្តងៗ គេរិះតែធ្វើយ៉ាងដូចនេះ ។ ប៉ុន្តែ *ប្លាក់ថន* យល់ពីចិត្តថ្លើមរបស់ពួកនេះ ក៏ដូចយល់បានពីបញ្ហារបស់ពួកគេដែរ ។ អ្នែងត្រូវតែជួយ *យ៉ាប៊ូ* បើសិនជាអ្នែងចង់ជួយ *រ៉ូឡើច* នោះ ។

- នែអាគយ អាប្រកាច់ អាកូនមីចោរ នែ *អាកាស៊ីគី យ៉ាប៊ូ* អាខូរបង្អង រួចក៏ប្រញ៉ាប់ចុះចាញ់ម្ល៉េះ ? មានតែអាមនុស្សកំសាកទេ ដែលចុះចាញ់នោះ អ្នែងជាកូនប្រុស រឺមួយមាន់



www.budinst.gov.kh www.elibraryofcambodia.org

ក្រចៀកស ?

ទោះជា ប្លាក់ថន ប្រឹងស្រែកស្ទើរបែកបំពង់កយ៉ាងណាក្តី ក៏ *យ៉ាប៊ូ* ឥតមានធ្វើដឹងធ្វើលឺអ្វីទាំងអស់ ។ គេនៅថ្ងឹងដូចជាដុំថ្ម ដែលគេកំពុងអង្គុយពីលើយ៉ាងដូចនោះដែរ ។

*ប្លាក់ថន* រើសយកដុំថ្មមួយដុំ ហើយចោលតំរង់ទៅ *យ៉ាប៊ូ* ។ ថ្មធ្លាក់ចុះក្នុងទឹកសមុទ្រ ប៉ុន្តែ *យ៉ាប៊ូ* នៅតែនៅថ្ងឹងដដែល ។ ពួក *សាមូរ៉ៃ* ស្រែកសន្ធាប់ដាក់ *ប្លាក់ថន* ទាំងកំហឹង ។ គេដឹងថា ពួកនេះ អាចសម្លាប់ ហើយចាប់គេចងបានគ្រប់ពេលវេលា ។ តែតើ ធ្វើម្តេចពួកនេះអាចចងគេបានបើពួកវាអត់ខ្សែ......

- ខ្សែ ! រកខ្សែមក ! នែ ពួកអ្អែងអាចធ្វើខ្សែបានទេ ?

ក្រសែភ្នែករបស់ *ប្លាក់ថន* បានវាសមកប៉ះនឹង *គីម៉ូណូ* របស់ *យ៉ាប៊ូ* ។ គេក៏ចាប់វាហែកជាចំរៀក ហើយសាកភាពទ្រាំទ្ររបស់វា ។ ក្រនាត់សូតនេះស្វិតណាស់ ។ គេក៏ដោះអាវរបស់គេចេញ ដើម្បីហែកបន្ត ទន្ទឹមនោះគេបញ្ជាទៅពួក *សាមូរ៉ៃ* :

- មកជួយគ្នាធ្វើខ្សែណា *រ៉ែហ* ?

ទាំងអស់គ្នាយល់ភ្លាមថា តើ *ប្លាក់ថន* ចង់ធ្វើអ្វី ។ ពួកគេដោះខ្សែក្រនាត់ក្រវាត់ចង្កេះ និងអាវ *គីម៉ូណូ* របស់ពួកគេ ហើយធ្វើតាមភ្លាម ។ *ប្លាក់ថន* ចាប់ផ្តើមចងចំរៀកក្រនាត់នឹងខ្សែក្រវាត់ចង្កេះបន្តគ្នា ជាខ្សែមួយវែងល្មម ។

រួមហើយ *ប្លាក់ថន* ក៏ក្រាបទៅលើដី ហើយលូនសំដៅទៅចំនោតច្រាំង ។ *សាមូរ៉ៃ* ពីរនាក់ ចាប់កជើងគេបង្ការមានគ្រោះថ្នាក់ ។ តាមពិតទៅគេមិនចាំបាច់ពួកនេះ ចាប់កជើងទេ ប៉ុន្តែគេបណ្តោយអោយពួកនេះ ធ្វើយ៉ាងនេះ ដើម្បីអោយពួកគេបានស្ងប់ចិត្ត ។

គេអើតក្បាលពីលើចំនោត រួចគេចាប់ផ្តើមសង្កេតទីកន្លែងដូចដែលគេសង្កេតមើលសមុទ្រយ៉ាងដូច្នោះដែរ ។ គឺមួយច្រៀកម្តង មួយច្រៀកម្តង ។

អស់មួយជុំ ។ គ្មានអ្វីទាំងអស់ ។

ម្តងទៀត ។

គ្មានអ្វីទាំងអស់ ។



www.budinst.gov.kh www.elibraryofcambodia.org

ម្តងទៀតសាកមើល ។

រួចចុះស្អីនោះ ? ស្អីដែលនៅពីលើស្នាមទឹកជំនោរនោះ ? ជារង្វះនៅលើជញ្ជាំងមែនទេ ? រឺក៏គ្រាន់តែជាស្រមោល ?

*ប្លាក់ថន* ជូរទឹកខ្មែងដើម្បីពិនិត្យសាជាថ្មី ។ ទឹកបានឡើងលិចថ្មដែល *យ៉ាប៊ូ* អង្គុយពីលើ ហើយនិងឆ្នេរជាប់នឹងចំនោតច្រាំងហើយ ។ ម្តងនេះ *ប្លាក់ថន* មើលឃើញច្បាស់ជាងមុន ។

- នោះហ្ន៎ ស្អីនោះ ?

*សាមូរ៉ៃ* ម្នាក់មកក្រាបសំលឹងមើលតាមដៃរបស់ *ប្លាក់ថន* តែគេមិនឃើញអ្វីសោះ ។

- នោះជាថ្នលយចេញមែនទេ ?

*ប្លាក់ថន* លាបាតដៃធ្វើជារាងថ្នលយ ហើយគេយកម្រាមដៃពីរជាសញ្ញាមនុស្សដាក់ពីលើរាងថ្នលយនេះ ហើយបន្ទាប់មកគេធ្វើរាងមនុស្សដែលកំពុងលីមនុស្សម្នាក់ទៀត ។

-ឆាប់ឡើង *អ៊ីស៊ូគី* !ពន្យល់ប្រាប់គាត់ទៅ ពន្យល់ប្រាប់ *កាស៊ី យ៉ាប៊ូ-សាម៉ា រ៉ាការីម៉ាស៊ូកា ?*

បុរសនោះក៏ក្រោកឡើង ហើយនិយាយញាប់ស្មេញទៅអ្នកឯទៀត ពួកគេអើតមើលទាំងអស់គ្នា ។ អីលូវនេះ ទាំងអស់គ្នា មើលឃើញថ្នលយនោះហើយ ។ ពួកគេទាំងអស់គ្នាចាប់ផ្តើមស្រែកប្រាប់ *យ៉ាប៊ូ* ។ តែ *យ៉ាប៊ូ* នៅធ្ងឹងឥតមានកំរើកអ្វីទាំងអស់ ។ គេនៅធ្ងឹងប្រៀបដូចជាដុំថ្ម ។ ពួកគេនៅបន្តស្រែក ហើយរួមទាំង *ប្លាក់ថន* ថែមទៀត ក៏ *យ៉ាប៊ូ* នៅស្ងៀមហាក់ដូចជាពួកគេឥតមានធ្វើអោយលឺសំលេងមួយប៉ិកណាអីចឹង ។

*សាមូរ៉ៃ* ម្នាក់ក៏ចាប់និយាយទៅកាន់អ្នកឯទៀត ។ ពួកគេក៏ងក់ក្បាល ហើយលំអោនខ្លួនគោរព ។ បុរសនោះគោរពសងវិញ ។ រួចរំពេចនោះ ក្រោយពីស្រែក " *បង់រ៉ៃ* " យ៉ាងខ្ទរមក គេក៏លោតចុះពីលើច្រាំងមកបោកនឹងថ្មស្លាប់មួយរំពេច ។ ព្រឹត្តិការណ៍នេះ ធ្វើអោយ *យ៉ាប៊ូ* ភ្ញាក់ពីភាពស្ពុងរបស់គេ១ ក៏ងាកខ្លួន ហើយក្រោកឈរឡើង ។

*សាមូរ៉ៃ* ម្នាក់ទៀតស្រែកផង ចង្អុលផង ប៉ុន្តែ *ប្លាក់ថន* គ្មានលឺ គ្មានឃើញអ្វីទាំងអស់ក្រៅតែពីសាកសពដែលនៅខាងក្រោយ ហើយដែលហៀបនឹងត្រូវទឹកសមុទ្រកួចយកទៅហើយ



www.budinst.gov.kh www.elibraryofcambodia.org

តែប៉ុណ្ណោះ ។ រួចចុះពួកអាអស់នេះ ជាមនុស្សបែបម៉េចណឹង ? គេដណ្ដើងសួរខ្លួនឯងទាំងអស់សង្ស័យ ។ តើនេះ ជាសេចក្ដីក្លាហាន រឺជាការចំកួតលេលា ?

រួចគេឃើញ *យ៉ាប៊ូ* ងើបឡើងទាំងទ្រេតទ្រោត *ប្លាក់ថន* គិតថា *យ៉ាប៊ូ* ច្បាស់ជាស៊ុះរត់ទៅរកកន្លែងសុខដោយចោលខ្មោច *រ៉ូឌ្រិច* ជាមិនខាន ។ ព្រោះបើអញវិញក៏អញប្រហែលជាធ្វើអីចឹងដែរមើលទៅ ។ មែនទេ ? ទេ អញក៏មិនដឹងដែរ ។ ប៉ុន្តែផ្ទុយពីការ គិតស្មានរបស់គេ *យ៉ាប៊ូ* បែរជាវារចុះពីលើថ្ម ហើយអូស *រ៉ូឌ្រិច* កាត់តាមទឹករហូតមកដល់ចំនោតច្រាំង ។ *យ៉ាប៊ូ* រកថ្មលយនោះឃើញតាមការចង្អុលប្រាប់ពីខាងលើហើយ ។ ថ្មលយនេះ មានទទឹងប្រហែលបីតឹកតែប៉ុណ្ណោះ ។ គេប្រឹងលើក *រ៉ូឌ្រិច* ទាំងលំបាកលំបិន ទៅដាក់លើថ្មលយនោះ ហើយគេវិះតែនឹងរបូតដៃធ្លាក់ *រ៉ូឌ្រិច* ទៅហើយ កុំតែគេរហ័សដៃច្បាមជាប់ ហើយរុញទៅដាក់វិញនោះ ។

ខ្សែរបស់ពួកគេនៅខ្លី ជាងប្រាំមួយម៉ែត្រទៀត ។ ពួក *សាមូរ៉ៃ* ដោះក្រវាត់រុំជាខោស្លាប់ភ្លៅរបស់គេចងបន្តទៀត ។ អីលូវនេះ បើ *យ៉ាប៊ូ* ឡើងឈរលើថ្មលយនេះ គេអាចតោងចាប់ចុងខ្សែបានហើយ ។

ពួកគេនាំគ្នា ស្រែកកម្លាចិត្ត *យ៉ាប៊ូ* ហើយនៅរង់ចាំ *យ៉ាប៊ូ* ឡើងមកតោងខ្សែ ។

ថ្វីត្បិតតែ *ប្លាក់ថន* មានគំនុំនឹង *យ៉ាប៊ូ* យ៉ាងណាក្ដី ក៏គេមិនអាចមិនកោតសរសើរសេចក្ដីក្លាហានរបស់បុរសនេះបានទេ ។ មិនដឹងជាប៉ុន្មានដងហើយទេ ដែលទឹកបានបោកលិចរូបគេ ។ *រ៉ូឌ្រិច* ត្រូវធ្លាក់ទៅក្នុងទឹកវិញពីរដង ប៉ុន្តែម្ដងណាក៏ដោយ ក៏ *យ៉ាប៊ូ* ច្បាមអូសគេមកវិញ ហើយប្រឹងលើកក្បាល *រ៉ូឌ្រិច* អោយងើបផុតពីទឹកក្នុងរយៈពេលយ៉ាងយូរ ។ *ប្លាក់ថន* ដឹងថាបើសិនជារូបគេវិញ គេព្រលែង *រ៉ូឌ្រិច* ចោលបាត់តាំងពីយូរមកហើយ ។ រួចចុះអ្ហែងម៉េចក៏ក្លាហានម្ល៉េះ *យ៉ាប៊ូ* ? តើអ្ហែងជាបិសាចទេដឹង ? រឺ ក៏ពួកអ្ហែងទាំងអស់គ្នាណឹងជាបិសាច ?

គ្រាន់តែរឿងចុះចំនោតច្រាំងថ្មនេះ ទាមទារសេចក្ដីក្លាហានដ៏អស្ចារ្យមួយទៅហើយ ។ ដំបូង *ប្លាក់ថន* គិតថា *យ៉ាប៊ូ* ហ៊ានចុះទៅនេះព្រោះតែមិនចង់បាក់ចិត្តតែប៉ុណ្ណោះ ។ ប៉ុន្តែក្រោយមកទើបគេឃើញថា *យ៉ាប៊ូ* កំពុងតែបញ្ចេញថ្វីដៃរបស់គេប្រកួតនឹងជញ្ជាំងថ្ម ហើយអាចនិយាយថា គេស្ទើរតែបានជ័យជំនះទាំងស្រុង បើសិនជាគេមិនរបូតដៃនៅពេលចុង



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយទេនោះ ។ គេបានទប់ទន្ទាក់របស់គេយ៉ាងប៉ិនប្រសប់ដូចអ្នកលេងសៀកអ៊ីចឹង ។ នៅពេលដែលដឹងថា គេគ្មានផ្លូវរស់ហើយ *យ៉ាប៊ូ* ក៏បានសុខចិត្តស្លាប់យ៉ាងថ្លៃថ្នូរ ។

ឱព្រះអង្គអើយ ខ្ញុំសូមសរសើរអាកូនមីចោរម្រ៉ាយនេះ។ ហើយខ្ញុំក៏ស្អប់វាណាស់ដែរ ។

ក្នុងរយៈពេលជិតមួយម៉ោង *យ៉ាប៊ូ* បានប្រយុទ្ធទល់នឹងសមុទ្រ តទល់នឹងរាងកាយរបស់គេដែលចេះតែខ្សោយទៅៗ ។ នៅពេលព្រលប់ *តាកាតាស៊ី* បានយកខ្សែមកផល់ ។ ពួកគេក៏ចងជាសង្រែក ហើយទំលាក់ចុះតាមចំនោតច្រាំងយ៉ាងប៉ិនប្រសប់ ។

*រ៉ូឡិច* ត្រូវគេទាញឡើងមកលើយ៉ាងរហ័ស។ *ប្លាក់ថន* ស្ទុះវឹងទៅរក *រ៉ូឡិច* ក្នុងបំនងពិនិត្យមើល តែបុរសជប៉ុនម្នាក់ដែលមានកាត់សក់ផ្កាថ្កូវបានលុតជង្គង់ចុះក្បែរនោះ មុនទៅទៀត ។ បុរសដែលប្រហែលជាគ្រូពេទ្យនេះ ពិនិត្យជើងរបួសរួច ហើយនៅពេលដែល *សាមូរ៉ៃ* ម្នាក់សង្កត់ស្មារបស់ *រ៉ូឡិច* នោះ គាត់ក៏សង្កត់យ៉ាងអស់ទំហឹងទៅលើជើងរបួស។ ឆ្អឹងក៏រត់ចូលកន្លែងដើមវិញ ។ បន្ទាប់ពីបានឈ្លីសពួកន្លែងរបួសមក គាត់ក៏យកថ្នាំមើមឈើនានាបិទមុខរបួសរៀនាត់ ហើយដាក់ព្រួលស្ដូបអបជើងនោះទៅ ។ បន្ទាប់មក *យ៉ាប៊ូ* ក៏ត្រូវគេនាំឡើងលើ ។

*វ៉េងមីញ៉ូ* នេះប្រកែកមិនព្រមទទួលការព្យាបាលអ្វីទាំងអស់ ។ គេធ្វើសញ្ញាអោយគ្រូពេទ្យវិលត្រលប់ទៅមើល *រ៉ូឡិច* វិញ រួចគេក៏អង្គុយចុះរង់ចាំនៅមួយកន្លែង ។

*ប្លាក់ថន* សំលឹងមើលបុរសនោះ ។ *យ៉ាប៊ូ* ក៏ហាក់ដឹងពីទំងន់នៃក្រសែភ្នែកនេះដែរទើបគេងើបមុខឡើង ។ ក្រសែភ្នែកអ្នកទាំងពីររត់ឆ្លងឆ្លើយគ្នា រួចនៅទីបំផុត *ប្លាក់ថន* ក៏និយាយឡើង ដោយលើកម្រាមដៃចង្អុលទៅ *រ៉ូឡិច* ផង :

- សូមអរគុណ អរគុណណាស់ *យ៉ាប៊ូ -សាន !*

ហើយគេលំអោនខ្លួនគោរព *យ៉ាប៊ូ* យ៉ាងស្មោះស្ម័គ្រ ។ អញ្ជើញសូមគោរពសេចក្ដីក្លាហានរបស់អ្លែងអាកូនចោរម្រ៉ាយ អាអាថ់ ។

*យ៉ាប៊ូ* អោនខ្លួនសងវិញយ៉ាងវ៉ាហ៊ី ។ តែនៅក្នុងចិត្តរបស់គេ គឺជាការញញឹមមួយយ៉ាងស្រស់ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ១០

ការធ្វើដំណើរពីខ្នែងជ្រកព្យុះរហូតដល់អូសាកា បានប្រព្រឹត្តទៅដោយគ្មានឧបទ្ទវហេតុអ្វីឡើយ ។ កំនត់នៅក្នុងកូនសៀវភៅ *រ៉ូត្រិច* គឺច្បាស់លាស់និងល្អិតល្អន់ ។ នៅយប់ទីមួយនោះ *រ៉ូត្រិច* បានដឹងខ្លួនឡើងវិញ ។ នៅគ្រាដំបូងគេស្មានតែគេស្លាប់បាត់ទៅហើយ ប៉ុន្តែការឈឺចាប់បានធ្វើអោយគេដឹងថា ខ្លួនគេនៅរស់នៅឡើយ ។

-ពួកគេបានតឆ្អឹង និងរុំជើងអែងរួចហើយ - *ប្លាក់ថន* និយាយ -ស្មាអែងក៏អ៊ីចឹងដែរ ។ ឆ្អឹងឡើងភ្លាត់ចេញពីគ្នា ។ ប៉ុន្តែទោះខ្ញុំអង្វរពួកវាយ៉ាងណា ក៏ពួកវាមិនចង់បង្ហូរឈាមអែងចេញទេ ។

- មិនអីទេ ចាំទៅដល់អូសាកា ពួក *យេស៊ូត* ធើបានហើយ ។

ភ្នែកដ៏ល្អក់របស់ *រ៉ូត្រិច* សំលឹង *ប្លាក់ថន* យ៉ាងមុត :

- រួចម៉េចបានជាខ្ញុំមកដល់ទូកនេះវិញ *អ៊ិញគីលិស* ? ខ្ញុំចាំត្រឹមតែធ្លាក់ទឹកតែ ប៉ុណ្ណឹងក្រៅពីនេះ អត់មានចាំអីបន្តិចណាសោះ ។

*ប្លាក់ថន* ក៏និយាយដំណើរដើមទងទាំងអស់ប្រាប់ *រ៉ូត្រិច* ។

- បើអ៊ីចឹង ខ្ញុំត្រូវជំពាក់គុណអែងធ្ងន់ណាស់ ។ វិបល់យក៏ !

-បើមើលពីកន្សែតីថាយើងអាចបុកទូកដល់ច្រាំងបាន តែបើមើលពីក្បាលទូកគំហើញអាចខុសពីរបីអង្សាដែរ ហើយរលកនោះ គឺវាបង្គ្រប់រឿងស័យសៀវនេះពៃម្លងទៅ ។

- អារឿងនេះ ខ្ញុំមិនទៅឈឺក្បាលទេ *អ៊ិញគីលិស* ។ អែងនៅឯកន្សែ អែងកាន់ចង្កូត យើងទាំងពីរនាក់ដឹងរឿងនេះច្បាស់លាស់ ។ ទេ អារឿងខ្ញុំដេរនេះ មិនមែនរឿងនេះទេ តែគឺរឿងដែលថា ជីវិតខ្ញុំវាត្រូវជំពាក់គុណអែងហើងណាំ ។ អ៊ីយ៉ូយ អាជើងចោរម្រ៉ាយនេះ !

តំនក់ទឹកភ្នែកបណ្តាលមកពីការឈឺចាប់ហូរស្រក់ចុះតក់ៗ ។ ប្លាក់ថន ហុចស្រាំ៉មួយផូទៅអោយ *រ៉ូត្រិច* ហើយគេនៅមើល *រ៉ូត្រិច* ពេញមួយយប់ ។ ព្យុះក៏បានស្ងប់ហើយដែរ ។ គ្រូពេទ្យជប៉ុន ក៏បានមកមើល *រ៉ូត្រិច* ជាច្រើនដង និងបានបង្ខំ *រ៉ូត្រិច* អោយផឹកទឹកថ្នាំដ៏ក្តៅ ដាក់កន្សែងក្តៅស្អុំថ្ងាស និងបើកបង្អួចទុកអោយខ្យល់ចូល ហើយនៅរាល់ពេលដែលគ្រូពេទ្យចេញ



www.budinst.gov.kh www.elibraryofcambodia.org

ផុត *ប្លាក់ថន* ក៏តែងតែទៅបិទបង្អួចវិញដែរ ព្រោះទំលាប់របស់គេរមែងចាត់ថា ខ្យល់ជាអ្នកនាំរោគ ហើយបន្ទប់កាន់តែបិទកាលណា សុខភាពមនុស្សកាន់តែល្អពេលនោះ ពិសេសចំពោះអ្នកដែលជុនជាបដូច *វ្រិទ្រិច* នេះ ។

ឃើញ *ប្លាក់ថន* ធ្វើយ៉ាងនេះ ជាញើកញយពេក នៅទីបំផុតគ្រូពេទ្យទ្រាំលែងបានក៏គំហកដាក់ *ប្លាក់ថន* ហើយទៅហៅ *សាមូរ៉ៃ* ម្នាក់អោយមកចាំយាមបង្អួចនេះ ។

នៅពេលព្រឹកព្រលឹម *ប្លាក់ថន* ឡើងទៅលើទូក ។ *ហ៊ីរ៉ូ - ម៉ាត់ស៊ី* និង *យ៉ាប៊ូ* កំពុងនៅទីនោះទាំងពីរនាក់ ។ *ប្លាក់ថន* អោនគោរពអ្នកទាំងពីរតាមបែបអឺរ៉ុប ។

អ្នកទាំងពីរគោរពតបវិញ ហើយ *ហ៊ីរ៉ូ -មាត់ស៊ី* និយាយឡើង :

- *អូសាកា ហៃ អាន់ជីន -សាន ?*

- *ហៃ អ៊ីស៊ូគី ហ៊ីរ៉ូ -ម៉ាត់ស៊ី សាម៉ា* ។ មេបញ្ជាការ *សាន* ស្រាវយុផ្តាឡើង !

- *ហៃ អាន់ជីន -សាន* ។

គេញញឹមដោយឥតបានគិតទុកជាមុនទៅរក *យ៉ាប៊ូ* ១ ក៏ញញឹមតបវិញ ហើយក៏ដើរចេញទៅទាំងប៉ុងខ្ញើក ។ នៅក្នុងខួរក្បាលរបស់ *យ៉ាប៊ូ* គេក៏ស្ងើចសរសើរ *ប្លាក់ថន* ណាស់ដែរ ។ អានេះចំជាអស្ចារ្យមែន ទោះវាជាបិសាច ជាឃាតកក្តី ។ ប៉ុន្តែខ្លួនអ្នែងមិនមែនជាឃាតកទេអ្វី ? ថាឃាតកក៏តែបាន ប៉ុន្តែវាខុសគ្នា ។

*ប្លាក់ថន* បញ្ជាសំពៅទៅដល់ *អូសាកា* យ៉ាងងាយ ។ ដំណើរផ្លូវបានស៊ីពេលអស់មួយថ្ងៃមួយយប់ ។ នៅព្រឹកព្រលឹមនៃថ្ងៃទីពីរ ទូកនៅច្រកចូលទៅ *អូសាកា* ជាស្រេច ។ តែកុងជំប៉ុនម្នាក់បានមកឡើងទូក ដើម្បីបញ្ជាទូកចូលកំពង់ផែ ដោយហេតុនេះ *ប្លាក់ថន* ក៏បានចុះដេកនៅខាងក្រោមទៅ ។

បន្តិចក្រោយមក មេបញ្ជាការបានចូលមកអង្រួន *ប្លាក់ថន* អោយភ្ញាក់ដឹងខ្លួន ហើយលំអោនខ្លួនគោរព និងធ្វើសញ្ញាប្រាប់ *ប្លាក់ថន* អោយត្រៀមខ្លួនជាស្រេច ដើម្បីចេញដំណើរទៅជាមួយ *ហ៊ីរ៉ូ -ម៉ាត់ស៊ី* ភ្លាម នៅពេលណាដែលទូកដល់ផែ ។

- *ភ៍ការីម៉ាស៊ូកា អាន់ជីន-សាន ?*



www.budinst.gov.kh www.elibraryofcambodia.org

- ហែ !

នៅពេលដែលបុរសនេះចេញផុត *ប្លាក់ថន* ក៏ពត់ខ្លួនយ៉ាងយូរ ។ គេរោយខ្លួនយ៉ាងខ្លាំង រួចគេក៏ប្រទះឃើញ *រ៉ូទ្រិច* ដែលកំពុងសំលឹងមើលមក :

- អែងយ៉ាងម៉េចហើយ ?

- ស្រួលបួលទេ *អ៊ិញ្ជូកិលីស* គ្រាន់តែជើងខ្ញុំក្តៅដូចឆេះ ក្បាលខ្ញុំឈឺស្ទើរបែកឈឺនោម ស្ទើរបែកមេជើង ហើយអណ្តាតខ្ញុំវាភ្លាវដូចស៊ីសាច់ជ្រូកអីចឹង ។

*ប្លាក់ថន* ហុចកន្ថោរទៅ *រ៉ូទ្រិច* បន្ទូរខ្លួន រួចគេក៏ចាក់ចោលតាមបង្អួចទៅ ។ គេចាក់ស្រាបំពេញថូមួយទៀត សំរាប់ *រ៉ូទ្រិច* ។

- អែងធ្វើអ្នកគ្រូពេទ្យសមដល់ហើយ នេះមកពីអែងមានធ្មើមខ្មៅតែម្រ៉ង ។

*រ៉ូទ្រិច* និយាយផង សើចកក្អឹកផង ។ សំនើចរបស់គេដែលលាន់ឡើងជាថ្មីនេះ បានបង្កបរិយាកាសដ៏ជាទីរីករាយមួយ ។ ភ្នែករបស់ *រ៉ូទ្រិច* វាសទៅមើលកូនសៀវភៅដែលបើកចំហនៅលើតុ រួចបន្ទាប់មកទៅហឹបរបស់គេ ។ ហឹបឥតមានចាក់សោឡើយ ។

- ខ្ញុំអោយសោទៅអែងអ្វី ?

- ទេ តែខ្ញុំយកពីខ្លួនអែង ព្រោះខ្ញុំត្រូវការកូនសៀវភៅមែនទែន ។ ខ្ញុំបានប្រាប់អែងម្តងហើយពីយប់ម្សិល ។

- អែងធ្វើនេះត្រឹមត្រូវហើយ ។ ខ្ញុំអត់ចាំថា អែងបានប្រាប់ខ្ញុំទេ តែអែងធើនេះ ត្រឹមត្រូវណាស់ ។ នែស្តាប់ខ្ញុំ *អ៊ិញ្ជូកិលីស* ពេលទៅដល់ *អូសាកា* អែងសួរសួរ *យេស៊ើត* ណាក៏បានដែរថា *វាស្កូរ៉ូទ្រិច* នៅឯណា ពួកគេនឹងជូនអែងមកជួបខ្ញុំហើយ ។ ទៅលេងនឹងខ្ញុំណា ហើយបើអែងចង់ខ្ញុំអោយអែងចំលងកូនសៀវភៅរបស់ខ្ញុំបាន ។

- អរគុណ តែខ្ញុំចំលងរួចហើយ ។ តែនិយាយស្រួលស្តាប់ គឺចំលងកន្លែងសំខាន់ៗ ហើយសល់ពីណឹងខ្ញុំអានយកចាំតែម្តង ។

- ម្រ៉ាយវានេះ ! -*រ៉ូទ្រិច* លាន់មាត់ជាភាសាអេស្ប៉ាញ ។

- ដូចតែម្រ៉ាយអែងដែរ !



www.budinst.gov.kh www.elibraryofcambodia.org

*រូច រ៉ូឡែង* និយាយជាភាសាបកទុយកាល់វិញ ៖

- និយាយភាសាអេស្ប៉ាញម្តង១ ចង់ចង្អោរតែម្រ៉ង ប៉ុន្តែអាភាសានេះសំបូរពាក្យ ល្បីផងជាងភាសាណា១ទាំងអស់ ។ នែ នៅក្នុងហឹបខ្ញុំមានកញ្ចប់មួយ អែងហុចអោយខ្ញុំបន្តិច ។

- អាកញ្ចប់មានបិទត្រាយេស៊ុតពីលើហ្នឹងអ្ហី ?

- ហ្នឹងហើយ ។

*ប្លាក់ថន* ហុចកញ្ចប់ទៅអោយ *រ៉ូឡែង* កាន់សំលឹងផ្ទៀងផ្ទង់ ហើយគេយកដៃទៅអង្អែលត្រាអាច់ល័ក្ខដែលនៅល្អស្អាតឥតមានប្រេះស្រាំបន្តិចណាឡើយ រូចគេហាក់ដូចជាប្តូរចិត្តគំនិតវិញ ។ គេក៏ដាក់វាទៅលើភួយដែលគេកំពុងដណ្តប់ ហើយផ្តេកក្បាលទៅវិញ ៖

- *អ៊ិញគីលីស* គិតទៅជីវិតចំលែកមែនទែនតែម្តង ។

- ហេតុអី ?

- អែងគិតមើល ខ្ញុំរស់មានជីវិត ម្យ៉ាងដោយសារព្រះជួយ ម្យ៉ាងទៀតដោយសារជំនួយរបស់ទមិឡម្នាក់ និងអាតយម្នាក់ទៅវិញ ។ អូនែ ! ប្រាប់អាស៊ីស្មៅហ្នឹងអោយចុះមកមុយភ្លែតផង ដើម្បីខ្ញុំអរគុណវា ។

- ចុះមកអីលូវហ្នឹង?

- ទេ បន្តិចទៀត ។

- បាន ។

- អារឿងកងសំពៅដែលអែងនិយាយថា កំពុងរ៉ៃ *ម៉ាទីល* នោះ តើជាការពិតអ្ហី ?

- កងសំពៅនឹងកំចាត់កំចាយចក្រភពអែងនៅអាស៊ីមិនខានទេ អែងចាំតែមើលចុះ ។

- មានកងសំពៅមែនអ្ហី ?

- មានមែនណាំ ។

- កងរបស់អែងមានសំពៅប៉ុន្មាន ?

- មានប្រាំ ។ ប៉ុន្មានទៀតនៅឯនាយសមុទ្រ ប្រហែលម៉ាអាទិត្យពីនេះ ។ ខ្ញុំមើល ផ្លូវនៅឯឆ្នេរសមុទ្រជប៉ុននេះមុន រូចទទួលគ្រោះថ្នាក់ទឹកព្យុះនេះ បណ្តោយទៅ ។



www.budinst.gov.kh www.elibraryofcambodia.org

- អែងប្រ៉ូទៀតហើយ *អ៊ិញ្ញូគីលីស* ។ តែខ្ញុំមិនទៅរស់ទេ ។ កាលគេចាប់ខ្ញុំបាន ខ្ញុំក៏តែប្រ៉ូគេដូចអែងអ៊ីចឹងដែរ ។ គ្មានសំពៅរឹកងសំពៅឯណាទៀតទេ ។

- អើ ចាំតែមើលទៅ !

- ច្បាស់ហើយ ។

*រ៉ូទ្រិច* ផឹកហើយផឹកទៀតយ៉ាងច្រើន ។

*ប្លាក់ថន* ពត់ខ្លួនបន្តិច ហើយដើរទៅបង្អួចដោយចង់បញ្ចប់កិច្ចសន្ទនានេះ ។ គេសំលឹងមើលឆ្នេរសមុទ្រ ហើយនិងទីក្រុង រួចនិយាយឡើង :

- ពីដើមខ្ញុំស្មានថា *ឡុង* ជាទីក្រុងធំជាងគេបំផុតនៅលើលោកនេះ តែឥលូវនេះ បើផ្ទឹមជាមួយ *អូសាកា* វាគ្រាន់តែជាទីប្រជុំជនតូចមួយសោះ ។

- អាក្រុងដូចនេះ មានប៉ុន្មានដណ្តប់ឯណោះ ។

*រ៉ូទ្រិច* ឆ្លើយតប ។ នៅក្នុងចិត្តគេក៏រីករាយនឹងបញ្ឈប់ល្បិចអាចោរ អាគិញ្ញដ៏គ្មានផលនេះដែរ ។ គេបន្តនិយាយ :

- *មីយ៉ាកូ* ដែលជារាជធានី រីដែលជូនកាលគេហៅថា *ក្យូតូ* នោះ គឺជាទីក្រុងធំជាងគេបំផុតនៅក្នុងចក្រភព ។ តាមគេនិយាយ គេថា *មីយ៉ាកូ* ធំជាង *អូសាកា* ពីរដងទៅទៀត ។ បន្ទាប់មកគឺ *យេដូ* ដែលជាទីក្រុងរបស់ *តូរ៉ាណាកា* ។ ខ្ញុំមិនដែលបានទៅ *យេដូ* ទេ ពួកបព្វជិតទាំងអស់ក៏មិនដែល ហើយក៏មិនដែលមានពួកប៉ិកទុយកាល់ណាបានទៅដល់ដែរ ។ *តូរ៉ាណាកា* មិនអនុញ្ញាតអោយបរទេសណាចេញចូលទេ ។ នោះជាទីក្រុងហាមឃាត់ ។ ហើយតាមពិតទៅកន្លែងណាក៏ដោយក៏ដូចជាកន្លែងណាដែរ- *រ៉ូទ្រិច* ផ្អែកខ្លួនទៅលើគ្រែវិញ មុខគេឡើងជ្រួញដោយការឈឺចាប់ -ជាផ្លូវការយើងអាចចេញចូលត្រឹមកំពង់ផែ *ណាកាសាគី* និង *ហ៊ីរ៉ាដូ* តែប៉ុណ្ណឹង មិនអាចដើរទៅកន្លែងណាបានទៀតទេ ។ តែពួកបព្វជិតយើងមិនខ្វីធ្វើដឹង ហើយដើរសព្វតែកន្លែងហ្នឹង ។ ឯពួកយើងអ្នកដើរសមុទ្រ និងឈ្មួញគ្មានសិទ្ធិដើរអ៊ីចឹងទេ លើកលែងតែមានលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ រឺពី *ដៃមីញ៉ូ* គ្រាក់១ ដូចជា *តូរ៉ាណាកា* ជាដើមអ៊ីចឹង ។ តែខុសពីកំពង់ផែ *ណាកាសាគី* និង *ហ៊ីរ៉ាដូ* *ដៃមីញ៉ូ* ណាក៏មានសិទ្ធិរឹបអូសយកសំពៅ



www.budinst.gov.kh www.elibraryofcambodia.org

អែងដែរ ដូច*តូរ៉ាណាកា*រីបអូសយកសំពៅអែងអីចឹង ។ នេះគឺជាច្បាប់របស់ពួកវា ។

- អីលូវនេះអែងចង់សាកអ្វី ?

- អត់អីទេ *អ៊ុញ្ចីលីស* ។ ជជែកគ្នាបានឆ្ងាយជាង វាមិនសូវឈឺ ។ ព្រះអើយព្រះឈឺក្បាលម្ល៉េះ ? គិតអីក៏មិនចេញដែរ ។ មក់ និយាយគ្នារហូតដល់ទូកចូលផែតែម្ដងទៅ ។ រួចមកលេងនឹងខ្ញុំវិញផង ។ ខ្ញុំមានរឿងច្រើនចង់ជជែកជាមួយអែង ។ អោយស្រាខ្ញុំបន្តិចទៀតផង ។ អរគុណ ។ អរគុណ អែងណាស់ *អ៊ុញ្ចីលីស* ។

-រួចហេតុអី បានជាពួកអែងមិនអាចទៅណាតាមចិត្តចង់បាន ?

-ថាម៉េច ? អូអារឿងនៅជប៉ុនហ្នឹងអ្វី ? នេះគឺមកពីតាប៉ិតែកូអីគេហ្នឹង ដែលនាំរឿងនោះ ។ ចាប់តាំងពីពួកយើងមកដល់ស្រុកនេះដំបូងបំផុតនៅឆ្នាំ ១៥៤២ មក ពួកយើងនិងពួកសង្ឃយើងដើរទៅណាម៉ាសេរី តែនៅពេលដែល*តៃកូ*ក្ដាប់អំណាចបានទាំងស្រុង ហើយវាក៏ចាប់ចេញបញ្ជាហាមឃាត់តែម្ដង ។ អីចឹងហើយបានជាអ្នកខ្លះគិតថា អាតាប៉ិ*តៃកូ* ហ្នឹងប្រហែលជាកូនជឹង*សាកង់* ទេក៏មិនដឹង ។ កាលពីដប់ឆ្នាំមុន វាចេញបញ្ជាប្រឆាំងនឹងការផ្សព្វផ្សាយសាសនាគ្រិស្ត ។ កាលណុងខ្ញុំមិនទាន់មកទេ ។ ខ្ញុំមកម្ដុំនេះទើបបានប្រាំពីរឆ្នាំទេ ។ ពួកបព្វជិត យើងថា មកពីលោកសង្ឃនៅទីនេះច្រនែនហើយមូលបង្កាច់គ្រិស្តសាសនៈ ។

*ប្លាក់ថន* ស្ដាប់យ៉ាងយកចិត្តទុកដាក់ ព្រោះគេស្រេកឃ្លានចង់ដឹងគ្រប់បែបយ៉ាងណាស់ ។

- កាលនោះ *តៃកូ* បញ្ជាអោយប្រមូលបព្វជិតទាំងអស់ ឡើងសំពៅបំរុងបញ្ជូនទៅម៉ាកាវហើយមានទាំងលិខិតហាមមិនអោយត្រលប់មកវិញទៀត បើមកត្រូវមានទោសដល់ស្លាប់ ។ រួចស្រាប់តែគេលែងពួកបព្វជិតនោះវិញ ហើយក៏គ្មានអ្នកណាប៉ះពាល់ទៀត ។ ខ្ញុំធ្លាប់ប្រាប់អែងហើយថា ពួកអាតយអស់នេះខ្មោចចេញខ្មោចចូលទេ ។ មែនណាដល់ពេលគេលែងពួកបព្វជិតហើយរឿងរ៉ាវក៏ល្អកល្អើនដូចពីមុនអីចឹង គ្រាន់តែចាប់ពីពេលនោះមកបព្វជិតភាគច្រើនបានទៅនៅឯ*គ្យូស្យូ* ដែលគេទាក់យើងច្រើនជាង ។ មិនដឹងថា ខ្ញុំប្រាប់អែងហើយរឺនៅទេ គឺប្រទេសជប៉ុនជាប្រទេសកោះ ។ វាមានកោះធំ១បីគឺ *គ្យូស្យូ ស៊ីកូកូ* និង *ហុងស្យូ* ក្រៅពីហ្នឹងមាន



www.budinst.gov.kh www.elibraryofcambodia.org

កោះតូចៗ រាប់ពាន់ទៀត ។ នៅឯទិសខាងជើងបំផុតមានកោះមួយទៀត ដែលអ្នកខ្លះហៅថា ដីគោកនោះគឺកោះ *ហុកកៃដូ* តែគឺមានតែពួកមនុស្សដុះរោមនៅទេ ។ ជប៉ុនក៏ជាប្រទេសមួយខ្មោចចេញខ្មោចចូលដែរ *អ៊ិញគឹលីស* ។ បញ្ញិត *អាលវីតូ* ប្រាប់ខ្ញុំថា ចាប់ពីពេលដែលពួកវាលែងបព្ជិតទាំងអស់រឿងរ៉ាវក៏ស្ងាត់ ហើយអ្វីៗក៏ទៅជាធម្មតា ដូចមិនដែលមានរឿងអីកើតឡើងអីចឹង ។ រួច *វៃតូ* ណឹងក៏រាក់ទាក់នឹងពួកយើងដដែល គ្រាន់តែមិនព្រមចូលសាសនាយើងសោះ ។ គាត់គំរបិទវិហារណាស់ហើយបណ្ដេញ *ដៃមីញ៉ូ* គ្រិស្តសាសនាតែពីរបីនាក់តែប៉ុណ្ណឹង ហើយណឹងគឺសំខាន់រឿងយកដីទេ។ តែអារឿង អនុវត្តសេចក្ដីសំរេចលើកមុនគឺអត់តែម្រ៉ង ។ រួចកាលពីរបីឆ្នាំមុននេះគាត់ចាប់ផ្ដើមឡប់ធាតុម្ដងទៀត ។ គាត់ចាប់ផ្ដើមធ្វើបាបបព្ជិតម៉្លេប្រាំមួយនាក់ ដោយយកទៅដោតឆ្កាងនៅ ឯ*ណាកាសាគី* ។ រួចអត់មានមូលហេតុអីទាំងអស់ ។ អាគាត់ណឹងសប្បាយនឹងធ្វើបាបគេតែម្រ៉ង ។ តែរួចពីធ្វើបាប អ្នកទាំងម៉្លេប្រាំមួយនាក់ស្លាប់មកគាត់លែងរវល់ទៀត ។ រួចក្រោយមកគាត់ក៏ស្លាប់ទៅ ។ មើលទៅអាគាត់ណឹងគេចមិនផុតពីឋាននរកទេ ។

- នៅស្រុកណឹងមានអ្នកចូលសាសនាកាតូលិចច្រើនទេ ?

ប៉ុន្តែ *រ៉ូឌ្រិច* ហាក់ដូចជាឥតបានលឺសំនួររបស់ *ប្លាក់ថន* ទេ ។ គេកំពុងលង់លក់នៅក្នុងភាពរវើរវាយរបស់គេ :

- ពួកអាតយនេះដូចជាសត្វអីចឹង ។ ខ្ញុំដែលនិយាយប្រាប់អែងពីរឿងបព្ជិត *អាលវីតូ* ហើយរឺនៅ ? លោកជាអ្នកបកប្រែ ។ ពួកអាតយហ្នឹងហៅលោកថា *ឈូតូ-សាន* បានន័យថា លោកថី បក ។ លោកជាអ្នកបកប្រែរបស់ *វៃតូ* ពីមុន ហើយអីលូវនេះលោកជាអ្នកបកប្រែផ្លូវការរបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ។ លោកចេះជប៉ុនច្បាស់ជាងជប៉ុនល្មម ១ ផង ហើយលោកស្គាល់ពួកនេះយ៉ាងច្បាស់ណាស់ ។ លោកបានប្រាប់ខ្ញុំថា នៅឯ *មីយ៉ាកូ* មានកូនភ្នំមួយកំពស់ជាងសាមសិបម៉ែត នោះគឺជាកន្លែងដែល *វៃតូ* យកស្លឹកត្រចៀក និងច្រមុះរបស់ពួកកូរ៉េ ដែលគេសំលាប់បាននៅពេលធ្វើសង្គ្រាមមកកប់នៅទីនោះ ។ កូរ៉េគឺជាផ្នែកមួយនៃដីគោក ហើយនៅខាងលិចកោះ *ត្សូស៊ី* ។ ហើយអារឿងភ្នំត្រចៀក និងច្រមុះនេះ គឺជាការពិតណាស់ ។ ម៉ែអ្ហើយ



www.budinst.gov.kh www.elibraryofcambodia.org

គ្មានអ្នកណាមេឃាតកជាង អាតាប៊ុ *វែគូ* នេះទេ ហើយពួកវានេះអាក្រក់អាក្រីដូច ១ គ្នាណឹង ។

*វ៉ុត្រិច* បិទភ្នែកឈប់និយាយ ថ្ងាសគេឡើងក្រហម ។

- អីលូវនេះមានអ្នកចូលសាសនាកាតូលិចច្រើនទេ ?

*ប្លាក់ថុន* សួរម្តងទៀត ដោយគេចង់ដឹងជាទីបំផុតថា តើនៅប្រទេសនេះគេមានសត្រូវប៉ុន្មាន ហើយគេស្ទុតចិត្តយ៉ាងខ្លាំងនៅពេលដែលគេលឺចំលើយរបស់ *វ៉ុត្រិច*:

-ជាងប៉ុន្មានសែននាក់ទៅហើយ ១ ចំនួននេះចេះតែកើនឡើងរៀងរាល់ឆ្នាំ ។ តាំងពី *វែគូ* ស្លាប់ទៅ ចំនួនអ្នកចូលសាសនាយើងកើនយ៉ាងលឿន ហើយអ្នកដែលលួចកាន់សាសនានេះពីមុននោះ អីលូវនេះគេទៅសូត្រធម៌ឯព្រះវិហារជាចំហតែម្តង ។ អ្នកនៅលើកោះ *ក្យូស៊្យូ* ភាគច្រើនជាកាតូលិចហើយនៅពេលនេះ ។ ភាគច្រើននៃ *វ៉េមីញ៉ូ* នៅ *ក្យូស៊្យូ* ជាកាតូលិចដែរ ។ *ណាកាសាគី* គឺជាទីក្រុងកាតូលិច ។ ពួក *យេស៊ុិត* ត្រួតត្រាទីក្រុងនេះហើយក្តាប់ពាណិជ្ជកម្មនៅទីនោះ ។ រាល់ការជួញដូរមែងឆ្លងកាត់ *ណាកាសាគី* ទាំងអស់ ។ យើងមានវិហារជាច្រើននៅ *ក្យូស៊្យូ* ប៉ុន្តែលើកោះធំនេះយើងទើបមានវិហារពីរបីទេ - ការចុកចាប់បង្ខំ *វ៉ុត្រិច* អោយឈប់និយាយមួយភ្លែត បន្ទាប់មកគេក៏បន្តទៀត - គ្រាន់តែនៅក្យូស៊្យូមានប្រជាជនប្រហែលបីទៅបួនលាននាក់ទៅហើយ ។ ពួកនោះនឹងទៅជាកាតូលិចទាំងអស់នៅពេលដ៏ខ្លីខាងមុខនេះ ។ ហើយម៉ាប៉ុន្មានកោះនេះមានពួកអាតយជាងម្ភៃលាននាក់ទៀត ....

-មិនគួរជឿទេ !

*ប្លាក់ថុន* បន្ទោសខ្លួនឯងនៅក្នុងចិត្ត ព្រោះតែបាននិយាយបង្អាក់ *វ៉ុត្រិច* ក្នុងពេលដែលគេត្រូវការពតិមានយ៉ាងសំខាន់ ១ យ៉ាងនេះ ។

- ខ្ញុំកុហកអែងបានការអី ? ដប់ឆ្នាំមុននេះគេបានធ្វើស្ថិតិម្តងហើយ ។ ព្រះតេជគុណ *អាល់វិតូ* បានប្រាប់ថា *វែគូ* ជាអ្នកបញ្ជាអោយធ្វើ ព្រោះអ៊ីចឹងហើយបានជាលោកដឹងពតិមាននេះ ។ ហើយលោកក៏គ្មានប្រយោជន៍អីនឹងកុហកដែរ ។ ប្រជាជននៅទីនេះមានលើសពីប្រជាជនម៉ាប៉ីកទុយកាល់ ម៉ាអង់គ្លេស ម៉ាអេស្ប៉ាញ ម៉ាហូឡង់ បូកបញ្ចូលគ្នាទៅទៀត ហើយ



www.budinst.gov.kh www.elibraryofcambodia.org

ទាល់តែថែមចក្រភពរ៉ូមពិសិដ្ឋ[៤០] ទៀតទើបបានស្មើខ្លះ ។

ឱ ! រំបល់យក់អើយ - *ប្លាក់ផន* គិតនៅក្នុងចិត្ត-ម៉ាប្រទេសអង់គ្លេសមានប្រជាជនតែបីលាននាក់តែប៉ុណ្ណោះ ហើយនេះរាប់ទាំងតំបន់អេកូសផង ។

បើប្រជាជនជប៉ុនមានច្រើនយ៉ាងណឹង តើត្រូវធ្វើយ៉ាងម៉េចអីចេះ ? បើពួកជប៉ុនមានគ្នាដល់ទៅម្ភៃលាននាក់មែន គឺមានន័យថា ពួកវាអាចស្លទិ៍ពច្រើនជាងប្រជាជនប្រទេសអង់គ្លេសទៅទៀតបើសិនណាជាពួកវាចង់មែន។ រួចបើពួកវាសាហាវឃោរឃៅដូចអាប៉ុន្មាននាក់ដែលអញជួបនេះ គឺគ្មានអ្នកណាឈ្នះពួកវាទេ ។ រួចបើពួកវាម៉ាចំនួនចូលនិកាយកាតូលិច ហើយពួកយេស៊ុិត នៅទីនោះកុះករចំនួនពួកវានឹងចេះតែកើនឡើងហើយ។ ហើយគ្មានអ្វីដាច់ខាតជាងពួកអាដាច់ខាតដែលទើបចូលសាសនាថ្មីៗនេះទេ ។ បើអីចឹងទៅអង់គ្លេស និង ហូឡង់គ្មាន ផ្លូវអីមកលូកជើងនៅអាស៊ីនេះទេមើលទៅ ។

ច្បាស់ជាគ្មានផ្លូវបន្តិចណាឡើយ ។

*វ៉ូត្រិច* និយាយបន្ត :

- បើអែងគិតថាប៉ុណ្ណឹងច្រើន ចាំអែងទៅដល់ស្រុកចិនបានដឹង ។ នៅស្រុកនោះមនុស្សមានស្បែកលឿង សក់ខ្មៅ ភ្នែកខ្មៅ ។ ហ៊ឺ *អ៊ិញគីលីស* ! អែងត្រូវរៀនសូត្រច្រើនណាស់ ។ ពីឆ្នាំទៅខ្ញុំទៅផ្សារណាត់សួតង *កង់តុង* ។ *កង់តុង* គឺជាទីក្រុងមួយ ដែលមានកំផែងព័ទ្ធជុំវិញនៅភាគខាងត្បូងស្រុកចិនតាមបណ្តោយទន្លេ គុជ ខាងជើង *ម៉ាកាវ* ដែលជាក្រុងរបស់យើង ។ ពួកចិនចូលចិត្តស៊ីឆ្កែណាស់ ហើយគ្រាន់តែម៉ាក្នុងកំផែងក្រុងមានមនុស្សជាងបីលាននាក់រស់នៅទៅហើយ ។ ពួកចិនមានចំនួនច្រើនជាងប្រជាជនពិភពលោកទាំងមូលនេះរួមគ្នាទៅទៀត ។ អាចប៉ុណ្ណឹង ។ រួច អែងគិតមើលទៅ ។

ការឈឺចាប់បានអង្រួនរូបរាងកាយរបស់*វ៉ូត្រិច* ហើយគេក៏ខំយកដៃសង្កត់ពោះជាប់ :

---

*(៤០) ចក្រភពបស្ចិមនិងកណ្តាលអឺរ៉ុប ដែលបង្កើតឡើងដោយស្តេចសាគឡឺម៉ាញនៅឆ្នាំ ៨០០គ.ស. ( Holy Roman Empire ) ( គ.អ.ប )*



www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

- មានកន្លែងណាហូរឈាមទេ ?

- អត់ទេ ។ ខ្ញុំពិនិត្យច្បាស់ណាស់ ។ អែងរបួសតែជើង និង ស្មាតែប៉ុណ្ណោះ ។ គ្រឿងក្រៅខាងក្នុងអត់អីទេ បើតាមខ្ញុំស្មាននោះ ។

- ជើងខ្ញុំយ៉ាងម៉េចដែរ ?

- ជើងអែងបានត្រាំទឹកសមុទ្រ ដោយហេតុនេះទាំងរបួស ទាំងឆ្អឹង ទាំងស្បែកវាស្អាតហើយ បែបមិនរលួយទេ ។

- អែងមានស្រោចស្រាដុតទេ ?

- អត់ទេ ពួកវាមិនព្រម ហើយបណ្ដេញខ្ញុំចេញ ។ តែគ្រូពេទ្យនោះដូចជាថ្លីកណាស់ដែរ ។ រួចចុះពួកវាឆាប់មករកអែងទេ ?

-តែពេលណាទូកចតផែហើយ ពួកណឹងច្បាស់ជាមករកខ្ញុំភ្លាម ។

-ល្អ ។ អំបាញ់មិញអែងនិយាយពីអីអ៊ីចេះ ?ពីរឿងស្រុកចិននិង ស្រុកកន្ដាំងមែន ទេ?

- ខ្ញុំនិយាយច្រើនពេកហើយ ។ យើងគង់តែមានពេលនិយាយពីពួកវាទេ ។

*ប្លូក់ថន* សំលឹងមើលដៃ*វ៉ូទ្រិច* ដែលព្រែះកញ្ចប់មានប្រថាប់ត្រាល័ក្ខនោះ ហើយគេដណ្ដឹងសួរនៅក្នុងចិត្តថា តើនៅក្នុងកញ្ចប់នេះមានរបស់អ្វីទៅ ។

- អែងកុំភ័យ ។ ជើងរបស់អែងនឹងបានស្រួលបួលវិញទេ ។ តែម៉ាអាទិត្យអ៊ីណឹងអែងគង់ដឹងមិនខានទេ ។

- អ៊ឺ !

- តាមខ្ញុំស្មានទៅប្រហែលវាមិនរលួយទេ ហើយគំនិតគិតគូររបស់អែងនៅតែល្អដដែល បានន័យថា ក្បាលអែងអត់មានប៉ះពាល់អីទេ ។ និយាយរួមគ្មានបញ្ហាអ្វីធ្ងន់ធ្ងរទេ *វ៉ូទ្រិច*។

- ខ្ញុំជំពាក់គុណអែងមែនទែនតែម្ដង ។ ពេលដែលខ្ញុំធ្លាក់ទៅក្នុងទឹក ស្ដីដែលខ្ញុំគិតគឺអារឿងក្លាមវារចេញពីប្រហោងភ្នែកខ្ញុំតែប៉ុណ្ណឹង ។ នេះជាលើកទីបី ហើយ ដែលខ្ញុំត្រូវទឹកបោកទំលាក់ពីលើសំពៅ ហើយម្ដងណាក៏សុខ្ខតែយ៉ាប់ដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំធ្លាប់លិចសំពៅប្អូនដង ។ ក្នុងនេះបីដងត្រូវលិចដោយពួកអេស្ប៉ាញ ។

ទ្វារបន្ទប់របើកឡើង ។ មេបញ្ជាការលំអោនខ្លួនគោរព ហើយធ្វើសញ្ញាអោយ *ប្លាក់ថន* ឡើងទៅខាងលើ ។

*ប្លាក់ថន* ក្រោកឡើង :

- *រ៉ែហ!*

រួចគេងាកទៅនិយាយយ៉ាងស្និទ្ធស្នាលជាមួយ *រ៉ុត្រិច* :

- អែងគ្មានជំពាក់អីខ្ញុំទេ *រ៉ុត្រិច* ។ នៅពេលដែលខ្ញុំអស់សង្ឃឹមអែងជាអ្នកជួយលួងលោមខ្ញុំនិងធ្វើអោយខ្ញុំមានសេចក្ដីសង្ឃឹមឡើងវិញ ហើយខ្ញុំត្រូវតែអរគុណអែងចំពោះរឿងនេះ ។ អីចឹងគ្មានគុណគ្មានស្រ័យអីទៀតទេ ។

- ថាអីចឹងក៏បានដែរ ប៉ុន្តែស្ដាប់ខ្ញុំណា *អ៊ិញគីលីស* ។ មានការពិតមួយចំនួន ដែលអែងត្រូវតែដឹងហើយទុកដូចជាការតបស្នងសងគុណរបស់ខ្ញុំចុះ ។ អែងកុំភ្លេចអោយសោះថា ពួកអាតយនេះមានមុខប្រាំមួយនិងបេះដូងបី ។ អានេះជាពាក្យទំនៀមរបស់ពួកវា ។ មនុស្សម្នាក់ៗមានបេះដូងក្លែងក្លាយមួយនៅក្នុងមាត់ ដែលទុកអោយគេឃើញគ្រប់គ្នា ។ បេះដូងមួយទៀតនៅក្នុងដើមទ្រូងសំរាប់មិត្តពិសេសនិងគ្រួសារ ឯអាបេះដូងពិតប្រាកដអាមែនទែន អាសំងាត់មែនទែន ដែលគ្មានអ្នកណាដឹងក្រៅតែសាម៉ីខ្លួននោះ គឺមិនដឹងលាក់នៅកន្លែងណាឡើយ ។ ពួកអាអស់នេះកុហក់ សូម្បីតែនឹកស្មានក៏មិនដល់ ហើយចូលចិត្តបាបកម្មរកព្រះប្រោសមិនរួច ។

- ហេតុអីបានជា *ភូរ៉ាណាកា* ចង់ជួបខ្ញុំ?

- ខ្ញុំមិនដឹងទេ ។ ខ្ញុំសូមស្បថ ថាខ្ញុំពិតជាមិនដឹងមែន ។ នែ បើអែងអាចដើរចុះឡើងបាន កុំភ្លេចមកលេងនឹងខ្ញុំណា ។

- មិនអីទេ ។ សូមអែងមានភ័ព្វល្អណា *ស្ប៉ានីញ៉ាក* ។

- រំបល់យក៏ សូមព្រះតាមថែអែង ។

*ប្លាក់ថន* ញញឹមជំនួសចំលើយតប រួចគេក៏ឡើងទៅខាងលើទូក ។ គេហាក់ដូចជាភាន់កាំងនឹងវិសាលភាពនៃទីក្រុង *អូសាកា* ភាពអ៊ូអររបស់ក្រុង ហើយនឹងវិមានដ៏ធំស្កឹមស្កៃ ដែល



www.budinst.gov.kh www.elibraryofcambodia.org

គ្របដណ្តប់ពីលើទីក្រុងនេះ ពិសេសគឺ ស៊េន ប្រហែលប្រាំពីរឺប្រាំបីជាន់ដ៏ខ្ពស់សន្ធឹម និងដ៏គួរជាទីគយគន់នោះឯង ។ ជញ្ជាំងស៊េននេះពណ៌ខៀវ ហើយក្បឿងមានពណ៌មាសភ្លឺផ្លេក ។ កន្លែងនោះគឺ ពិតជាកន្លែង *តួរ៉ាណាកា* ហើយគេគិតនៅក្នុងចិត្ត ។

គ្រែស្នែងមួយដែលបិទជិតនៅរង់ចាំ *ហ្វាក់ផន* ។ អ្នកសែងបានយកគេរហូតទៅដល់ផ្ទះធំមួយ ។ បន្ទាប់ពីមុជទឹកហើយ គេបានលើកម្ហូបត្រីស្មោរ ត្រីចំហុយ ត្រីឆៅ ហើយនិងបន្លែបន្តិចបន្តួច ព្រមទាំងតែក្តៅដូចសព្វដង ។ ប៉ុន្តែនៅពេលនេះគេមិនបំរើបបរទៀតទេ តែ គឺជាបាយម្តង ។ គេធ្លាប់បានឃើញបាយម្តង កាលពីនៅទីក្រុង *ណាប*[៤១] ។បាយនេះសស្គុស ប៉ុន្តែគេហាក់ដូចជាគ្មានរសជាតិអ្វីទាំងអស់ ។ ក្រពះគេស្រែកទាររកសាច់ រកនំប៉ុង ប៊ឺរ ពងមាន់ និងប៊ីយែរ ដែលគេខានស្គាល់រសជាតិយូរពេលណាស់មកហើយ ។

នៅវេលាស្អែកឡើងនារីអ្នកបំរើបានមកជួបនឹងគេ ។ សំលៀកបំពាក់ដែល *វ៉ុន្តិច* បានអោយគេនោះ ត្រូវបានបោកគក់ហើយជាស្រេច ។ នាងអង្គុយមើលគេស្លៀកពាក់ ហើយជួយអោយគេពាក់ស្រោមជើងក្រនាត់ថ្មីរបស់គេ ។ នៅឯភានុបាល ស្បែកជើងកវែងរបស់គេឥតឃើញមាននៅទីនោះទៀតឡើយ តែគឺជាស្បែកជើងសង្រែកថ្មីមួយគូទៅវិញ ។ នៅពេលដែល *ហ្វាក់ផន* ធ្វើសញ្ញាសួររកស្បែកជើងកវែងរបស់គេ នារីនេះគ្រវីក្បាល ហើយចង្អុលទៅស្បែកជើងសង្រែក រួចចង្អុលទៅគ្រែស្នែងនេះ ។ មេក្រុម *សាមូរ៉ៃ* ធ្វើសញ្ញាប្រាប់ *ហ្វាក់ផន* អោយរួសរាន់ចូលគ្រែស្នែង ។

គ្រាន់តែ *ហ្វាក់ផន* ចូលក្នុងគ្រែស្នែងហើយ ពួកគេក៏ចេញដំណើរភ្លាម ។ វាំងននគ្រែស្នែងត្រូវបានទាញបិទយ៉ាងជិត ។ ក្រោយពីធ្វើដំណើរយ៉ាងយូរមក ពួកគេក៏ដាក់គ្រែស្នែងចុះ ។

- អ្នែងកុំខ្លាច !

*ហ្វាក់ផន* និយាយលឺ ១ ដើម្បីកម្លាចិត្តខ្លួនឯង ហើយគេក៏ចេញពីគ្រែស្នែង ។

កំផែងថ្មដ៏ស្កឹមស្កៃ នៃវិមានបានស្ថិតនៅជ្រងោពីមុខរបស់គេ ។ នេះគឺជាកំផែងមួយ

---

(៤១) ទីក្រុងនៅភាគខាងត្បូងប្រទេសអ៊ីតាលី -Naples ( ក.អ.ប.)



www.budinst.gov.kh www.elibraryofcambodia.org

ដែលមានកំរាស់ជាងប្រាំបួនម៉ែត ការពារដោយកំពែងសារពើសូត ( Bastion ) និងសំណង់ការពារជាច្រើនរាប់មិនអស់ ។ ទ្វារដ៏ក្រាស់ មាំ និងពាសដោយដែកនោះត្រូវបានបើកឡើង ។ រនាំងដែកស្និតក៏ត្រូវគេលើកឡើងដែរ ។ ផុតពីទ្វារមានស្ពានឈើមួយទទឹងប្រហែលម្ភៃព្យាម និងបណ្ដោយប្រហែលពីររយ ដែលលូនកាត់ពីលើគូទឹកមួយ ។ នៅចុងស្ពានគឺជាស្ពានមួយដ៏ធំទៀត ដែលគេអាចលើកឡើងចុះបាន ហើយបន្ទាប់មក គឺជាទ្វារមួយទៀត ដែលនៅជាប់នឹងកំផែងទីពីរ ។ កំផែងនេះមានកំរាស់ដូចកំផែងទីមួយដែរ ។

នៅកន្លែងនេះ មានពួក*សាមូរ៉ៃ* រាប់រយនាក់ដើរខ្វាត់ខ្វែង ។ ទាំងអស់គ្នាពាក់អាវ*គីម៉ូណូ* ពណ៌ប្រផេះក្រមៅ ។ គ្រប់គ្នាមានសញ្ញាចំនួនប្រាំនៅលើអាវ គឺនៅលើដៃអាវម្ខាងមួយ លើដើមទ្រូងម្ខាងមួយ និង មួយទៀតចំកណ្ដាលខ្នង ។ សញ្ញានេះមានពណ៌ខៀវ ហើយមានរាងហាក់ដូចជាផ្កាមួយ រឺផ្កាជាច្រើនអីចឹង ។

- *អាន់ជីន-សាន* !

*ប៊្លែរ៉-មាត់ស៊ី* កំពុងអង្គុយយ៉ាងរឹងឆ្អឹតនៅលើគ្រែស្នែងមួយ ដែលរូតរនាំងចេញទាំងអស់ ។ មនុស្សបួននាក់កំពុងសែងគ្រែស្នែងនេះ ។ *គីម៉ូណូ* របស់លោកពណ៌ត្នោតក្រវាត់ចង្កេះលោកពណ៌ខ្មៅពោល គឺជាឯកសណ្ឋានដូចពួក*សាមូរ៉ៃ* ទាំងហាសិបនាក់ដែលកំពុងឈរនៅជុំវិញខ្លួនលោកយ៉ាងនោះដែរ ។ នៅលើគីម៉ូណូរបស់ពួកគេក៏មានសញ្ញាទាំងប្រាំនេះដែរ គ្រាន់តែសញ្ញានេះមានពណ៌ក្រហមឆិត ប្រៀបដូចជាសញ្ញាទង់ដែលដោតលើដងក្ដោងនៃទូករបស់*តូរ៉ាណាកា* យ៉ាងដូច្នោះដែរ ។ ពួក*សាមូរ៉ៃ* ក្រោយនេះកាន់លំពែងយ៉ាងវែង ដែលមានកូនទង់តូច ៗ នៅនឹងចុងទៀតផង ។

ភាពដ៏សៀមរបស់*ប៊្លែរ៉-ម៉ាត់ស៊ី* ធ្វើអោយ *ប្លាក់ថន* លំអោនខ្លួនជាស្វ័យប្រវត្តិ ។ បុរសចំនាស់លំអោនខ្លួនគោរពតបវិញយ៉ាងស្រាល ។ ដាវវែងរបស់លោកនៅតែស្ថិតលើពោះលោកនៅឡើយ ។ *ប៊្លែរ៉-ម៉ាត់ស៊ី* ធ្វើសញ្ញាអោយ *ប្លាក់ថន* ដើរតាមខ្លួន ។

មេកងដែលនៅប្រចាំការឯមាត់ទ្វារនោះដើរសំដៅមករកពួកគេ ។ គេអានយ៉ាងម៉ត់ចត់នូវលិខិតដែល *ប៊្លែរ៉-ម៉ាត់ស៊ី* ប្រគល់អោយរួចគេសំលឹងមើល *ប្លាក់ថន* មួយសន្ទុះទើបអនុញ្ញាត



www.budinst.gov.kh www.elibraryofcambodia.org

អោយគេឆ្លងកាត់ ។ ពួកអាវប្រផេះមួយក្រុមដើរតាមពីក្រោយពួកគេ ។

ពីផ្ទៃទឹកមកដល់ស្ពានមានកំពស់ប្រហែលជាងម្ភៃម៉ែត ។ គូទឹកនេះលាតសន្ធឹងចេញទៅម្ខាង១ ស្ពានប្រហែលជាបីរយម៉ែត ហើយបន្ទាប់មកទើបកុងតាមកំផែងបត់ទៅជើង។ ឱ ! ព្រះអើយព្រះ អោយស៊ីអញ្ចក៏អញមិនសប្បាយចិត្តនឹងឡើងវិមាននេះដែរ ។ ពួកអ្នកការពារខាងក្នុងវាសុខចិត្តអោយពួកការពារកំផែងក្រៅស្លាប់ រួចវាដុតតែស្ពាន ហើយច្បាស់ជាពួកវានៅអ៊ាំងអឺយនៅខាងក្នុងបាត់ទៅហើយ ។ ហើយកំផែងនីមួយ ១ ធ្វើឡើងពីថ្មទាំងផ្ទាំង ១ តែម្តង ។ ថ្មមួយដុំ ១ បីម៉ែតបួនជ្រុង ហើយត្រូវគេរំលីងយ៉ាងស្មើ ។ ជញ្ជាំងនេះរៀបចំឡើងដោយមិនបាច់ប្រើបាយអទេ ព្រោះថ្មវាមានទំងន់គ្រប់គ្រាន់នឹងទប់ខ្លួនវារួចហើយ ។ បើតាមប៉ាន់ថ្មមួយដុំ ១ ទំងន់យ៉ាងតិចហាសិបតោនដែរ ។ ប្រើកាណុងអ្វី ? បើកាណុងអាចបំបែកកំផែងក្រៅបាន តែពួកគេក៏មានកាំភ្លើងការពារដែលអាចបាញ់កំចាត់យើងដែរ ហើយម្យ៉ាងទៀតមិនងាយនឹងអូសវាឡើងទួលនេះទេ ។ ហើយបើអូសឡើងមកដល់ក៏គ្មានចំនុចខ្ពស់ដាក់តាំងកាំភ្លើង ដើម្បីបាញ់ផ្លោងចូលទៅក្នុងកំផែងនេះបានដែរ ។ បើសិនជាវាយបែកកំផែងក្រៅក៏ពួកអ្នកការពារនៅតែអាចសំលាប់អ្នកវាយលុកបានដដែល ព្រោះគេអាចបាញ់ចេញពីរន្ធតាមកំផែងនេះយ៉ាងឆ្ងាញ់ដៃ ។ តែបើវាយយកបានកំផែងក្រៅ តើធ្វើម៉េចវៃយកកំផែងក្នុងបាន ? កាំភ្លើងធំបានយ៉ាងច្រើនណាស់ត្រឹមបំផ្លាញសន្លឹកទ្វារតែប៉ុណ្ណឹង តែតើបានប្រយោជន៍អី ? រួចចុះឆ្លងគូទឹកនេះយ៉ាងម៉េចបើវាធំយ៉ាងហ្នឹង ? ប្រើមធ្យោបាយធម្មតាមិនកើតទេ ។ និយាយរួមបើមានទ័ពគ្រប់គ្រាន់ វិមាននេះគ្មានអ្នកវៃបំបែកបានទេ ។ តើនៅក្នុងវិមាននេះមានទាហានប៉ុន្មាននាក់អីចេះ ។ រួចចុះពួកអ្នកស្រុកប៉ុន្មាននាក់ដែលនឹងមកជ្រកនៅក្នុងវិមាននេះ ?

វិមាននេះធ្វើអោយប៉ុមទីក្រុងឡុង ប្រៀបបីដូចជាទ្រុងជ្រូក ហើយវាំងហាំគុនទាំងមូលបែបស្មើនឹងមួយជ្រុងវិមាននេះតែប៉ុណ្ណឹង ។

នៅឯខ្លោងទ្វារបន្ទាប់ គឺជាទីឆែកឆេរលិខិតឆ្លងដែនដូចលើកមុន ។ រួចក្បួនក៏បត់ទៅខាងឆ្វេងទៅតាមមហាវិថីមួយដែលអមទៅដោយសំណង់សឹកការពារដោយកំផែងទាបខ្ពស់។ បន្ទាប់មកផ្លូវក៏បែកចេញសាំញ៉ាំជាផ្លូវជណ្តើរខ្វែងខ្វាត់ ។ ក្បួនបានទៅដល់ទ្វារមួយទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

តែនែកលិខិតម្តងទៀត ។ រនាំងដែកមួយ ហើយនិងគូទឹកដ៏ធំមួយទៀត ។ រួចក្បួនក៏ដើរបត់ចុះឡើង ។ *ប្លាក់ថន* ដែលជាមនុស្សពូកែចាំបំផុត ហើយនិងជាអ្នកពូកែដឹងទិសបំផុតនោះក៏ត្រូវវង្វេងនៅក្នុងក្បួនព័ទ្ធនេះដែរ ។ ក្នុងមួយដំណើរនេះពួកអាវប្រផេះយ៉ាងច្រើនរាប់មិនអស់បានតាមសំលឹងមើលពួកគេពីលើប៉មពីលើសើន ពីលើកំផែងសារពើសួត និងពីលើបង្កាន់ដៃ ។ រួចនៅមានពួកអាវប្រផេះផ្សេងទៀត ដែលនៅឈរយាម រឺកំពុងហាត់ រឺកំពុងថែសេះ ។ ពោលគឺនៅគ្រប់កន្លែងមានសុទ្ធតែកងទ័ព ។ ទ័ពរាប់ពាន់នាក់ ។ ទាំងអស់គ្នាសុទ្ធតែប្រដាប់ទៅដោយអាវុធគ្រប់គ្រាន់ ហើយមានសំលៀកបំពាក់យ៉ាងស្អាតបាត ។

នៅក្នុងពោះ *ប្លាក់ថន* ដេរប្រទេចខ្លួនឯងរហូត ដែលល្ងីល្ងើពេកថ្វាសមិនចេះឈ្លេចស្ងួរ *រ៉ូត្រិច* អោយបានគ្រប់គ្រាន់ ។ ក្រៅពីពតិមានទាក់ទិននឹង *រ៉ែតកូ* ហើយនិងរឿងពួកចូលសាសនានោះ *រ៉ូត្រិច* ឥតមានឆ្លើយរឿងអីទៀតសោះ ។

អីលូវអ្នែងផ្តុំអារម្មណ៍សាកមើល រកមើលចំនុចសំគាល់ តើវិមាននេះមានអ្វីដែលជាពិសេសនោះ ? តើជាវិមានដ៏ធំជាងគេបំផុតដែលអ្នែងបានជួបអ្វី ? ទេ មិនមែនទេ តើស្អីទៅជាពិសេសនោះ ?

តើពួកអាវពណ៌ខ្មៅត្រូវគ្នានឹងពួកប្រផេះរឺអត់ ? ថាមិនត្រូវដែរ ព្រោះទឹកមុខពួកវាម៉ឹងម៉ាត់ដូច ១ គ្នា ។

*ប្លាក់ថន* សំលឹងមើលពួកទាំងនោះយ៉ាងយកចិត្តទុកដាក់ ហើយខំផ្តោតលើចំនុចសំអិតវិញម្តង ។ នៅខាងឆ្វេងដៃរបស់គេ គឺជាសួនច្បារចំរុះពណ៌មួយ ដែលត្រូវគេថែយ៉ាងយកចិត្តទុកដាក់ ហើយដែលមានស្ពានមួយតូចនិងជ្រោះតូចមួយហូរកាត់ផង ។ នៅពេលដែលគេកាន់តែខិតទៅជិតសើន ធំ ផ្លូវកាន់តែចង្អៀត កំពែងកាន់តែខិតចូលគ្នា ។ គ្មានប្រជាជនណាម្នាក់នៅលើផ្លូវនេះទេ ក្រៅតែពីអ្នកបំរើរាប់រយនាក់ ដែលដើរចុះឡើងហើយ...*គ្មានកាណុងមួយដើមសោះ* អានេះហើយជារឿងប្លែកនោះ ។

គ្មានឃើញកាណុងមួយដើមសោះ ។ គ្មានសោះតែម្តង ។

បើសិនជាអ្នែងមានអាវុធទំនើប ហើយអ្នកការពារគ្មានវិញ តើអ្នែងអាចបាញ់ រំលាយ



www.budinst.gov.kh www.elibraryofcambodia.org

កំផែងទ្វារ ផ្លោងគ្រាប់ចូលក្នុងវិមានបង្កជាអគ្គិភ័យ ហើយដណ្ដើមយកបានទេ ?

តែឆ្លងតួទឹកទីមួយរបៀបណា ?

មានអាវុធទំនើប អែងអាចធ្វើអោយអ្នកការពារ ដែលនៅខាងក្នុងមានការយ៉ាប់យ៉ឺន ប៉ុន្តែពួកវានឹងនៅតែទប់ទល់បាន បើសិនជាកងទ័ពមានការប្ដេជ្ញាចិត្ត និងមានទឹក ស្បៀង និងគ្រាប់គ្រប់គ្រាន់ ។

តើឆ្លងតួទឹករបៀបណា ? ដោយទូក ? រឺដោយក្បូនបន្ទើត *ស៊េន* ?

ខួរក្បាលគេកំពុងតែគូសវាសផែនការ ស្រាប់តែត្រែស្នែងឈប់ងំក់ ។ *ហ៊ីរ៉ូ-មាត់ស៊ឺ* ចុះទៅដី ។ ពួកគេនៅកន្លែងទាល់ដីចង្អៀតមួយ ។ នៅនឹងជញ្ជាំងកំផែងមានទ្វារឈើដ៏ក្រាស់ពាសដែកមួយ ។ ជញ្ជាំងនេះមានកំរាស់ប្រហែលប្រាំមួយម៉ែត ។ ខុសពីកន្លែងឯទៀត នៅត្រង់ទ្វារនេះពួកឆ្មាំទ្វារមានឯកសណ្ឋានពណ៌ត្នោត ។ ពួកគេបានសំដែងទឹកចិត្តរីករាយនៅពេលដែលគេឃើញ *ហ៊ីរ៉ូ-មាត់ស៊ឺ* នោះ ។

ពួកកងទ័ពអាវប្រផេះនាំគ្នាត្រលប់ទៅវិញ ។ *ប្លាក់ថន* បានកត់សំគាល់ក្រសែភ្នែកពោរពេញដោយអរិភាពរបស់ពួកត្នោត នៅពេលដែលគេសំលឹងមើលពួកប្រផេះនោះ ។

បើអ៊ីចឹងមានន័យថា ពួកគេជាសត្រូវនឹងគ្នាហើយ ។

ទ្វាររបើក ហើយ *ប្លាក់ថន* ក៏ដើរតាមបុរសចំនាស់ចូលទៅខាងក្នុងតែពីរនាក់ ។ *សាមូរ៉ៃ* ឯទៀតនៅរង់ចាំខាងក្រៅ ។

ទីធ្លាខាងក្នុងត្រូវយាមការពារដោយពួកឯកសណ្ឋានត្នោត ហើយក៏ដូចជានៅក្នុងសួនច្បារដែលនៅក្នុងបន្ទាប់ពីទីធ្លាខាងក្នុងនោះដែរ ។ ក្រោយពីឆ្លងកាត់សួនច្បារហើយពួកគេក៏ចូលដល់ក្នុងវិមាន ។ *ហ៊ីរ៉ូ-មាត់ស៊ឺ* ដោះស្បែកជើងរបស់ខ្លួនចេញ ។ *ប្លាក់ថន* ក៏ធ្វើតាមនោះដែរ ។

របៀងវិមានត្រូវបានក្រាលដោយ *តាតាមី* ពោលគឺជាកំរាលម្យ៉ាងដែលធ្វើអោយជើងមានអារម្មណ៍យ៉ាងសុខស្រួល ហើយដែលគេតែងក្រាលនៅគ្រប់ផ្ទះ លើកលែងតែផ្ទះអ្នកក្រីក្របំផុតប៉ុណ្ណោះ ។ *ប្លាក់ថន* បានកត់សំគាល់ឃើញថា *តាតាមី* ទាំងអស់មានទំហំប៉ុន ១គ្នា គឺបណ្ដោយប្រហែលមួយម៉ែតប្រាំបួនតឹក និងទទឹងជាងប្រាំបួនតឹក ។ ដូចជាឆ្ងល់ដែរ-*ប្លាក់ថន*



www.budinst.gov.kh www.elibraryofcambodia.org

គិតនៅក្នុងចិត្ត-អញមិនដែលឃើញ*ភាគាមី* មួយណាត្រូវគេចៀរ រឺបំព្រួញទំហំសោះ ។ បើអីចឹងមានន័យថា ផ្ទះនីមួយ១ រឺថាបន្ទប់នីមួយ១ ត្រូវតែសង់ឡើងសំរាប់ពេញគ្រប់ចំនួន*ភាគាមី*តែម្តង ។ ចំលែកម្ល៉េះដែរ ។

ពួកគេឡើងជណ្តើររាងតូចខ្សង ដែលជាជណ្តើរមួយអំនោយផលដល់អ្នកការពារជាងអ្នកវាយលុក ។ រួចគេដើរតាមរបៀង និងឡើងតាមជណ្តើរជាច្រើនទៀត ។ នៅគ្រប់ទីកន្លែងដែលគេដើរកាត់ មានសុទ្ធតែពួកអាវក្តោតនៅយាមល្បាតយ៉ាងម៉ត់ចត់ ។ *ប្លាក់ថន* បានមើលឃើញថា គេបានឈរនៅទីមួយយ៉ាងខ្ពស់លើសពីកំផែងទាំងបីនោះទៅទៀត ។ ទីក្រុង*អូសាកា* ហើយនឹងកំពង់ផែនៅឯខាងក្រោយយ៉ាងឆ្ងាយ មើលទៅប្រៀបដូចជាកំរាលព្រំមួយដ៏មានរូបចាក់យ៉ាងរស់រវើក និងយ៉ាងប្លែក ១ យ៉ាងនោះដែរ ។

ក្រោយពីបត់តាមរបៀងមួយទៀត គេទាំងពីរនាក់បានដើរមកដល់ទីបំផុត ។

*ប្លាក់ថន* ដឹងថា មាត់គេឡើងសាបអស់ហើយ ។ កុំខ្វល់ពេក-*ប្លាក់ថន* ប្តេជ្ញានៅក្នុងចិត្ត- អែងដឹងខ្លួនថា ត្រូវធ្វើអីហើយ ១ អ្អែងបានសំរេចចិត្តហើយតើ ។

ពួក*សាមូរ៉ៃ*ជាច្រើននៅកកកុញពីមុខទ្វារ ។ មេកងដ៏ក្មេងម្នាក់នៅពីមុខពួកនេះ ។ ទាំងអស់គ្នាសុទ្ធតែមានដៃស្តាំដាក់នៅលើដងដាវហើយជាស្រេច ។ ពួកគេសំលឹងមើលអ្នកទាំងពីរដែលចេះតែខិតចូលមករកពួកគេ ។

ពេលឃើញស្ថានភាពប្រុងប្រយ័ត្នរបស់ពួកនេះ *ហ្ស៊ី-ម៉ាត់ស៊ី* ហាក់ដូចជាបានធូរទ្រូងសន្ធឹក ។ឆ្មាំទាំងនេះត្រូវបានជ្រើសរើសដោយផ្ទាល់ដៃរបស់*ហ្ស៊ី-ម៉ាត់ស៊ី* ។ លោកស្ងប់វិមាននេះណាស់ហើយជាថ្មីម្តងទៀតលោកគិតថា គឺជាប្រការគ្រោះថ្នាក់បំផុតដែល*តូរ៉ាណាកា*បានសំរេចចិត្តចូលមកក្នុងវិមាននេះ ។ តាំងពីម៉្សិលមិញម្ល៉េះ គ្រាន់តែទូកចូលចតដល់ផែភ្លាមលោកបានប្រញាប់ប្រញាល់មកជួប *តូរ៉ាណាកា* ដើម្បីរាយការណ៍អំពីហេតុការណ៍ ដែលកើតឡើងផងនិងដើម្បីចង់ដឹងថា តើមានសភាពការណ៍អ្វីកើតឡើងគួរអោយសង្ស័យទេ នៅក្នុងអំលុងពេលអវត្តមានរបស់លោកផង ។ ប៉ុន្តែអ្វី ១ ហាក់ដូចជានៅធម្មតានៅឡើយ ថ្វីត្បិតតែអ្នកយកការណ៍របស់លោកបានផ្តល់ពត៌មាន ស្តីពីការផ្តុំទ័ពគួរអោយបារម្ភរបស់ពួកសត្រូវ



www.budinst.gov.kh www.elibraryofcambodia.org

នៅបូព៌ានិងឧត្តរទិស ហើយនឹងប្រការដែលសម្ព័ន្ធមិត្តដ៏សំខាន់ទាំងពីររបស់ *ភូរ៉ាណាកា* គឺ *អូណូស៊ី* និង *គីយ៉ាម៉ា* ដែលជាសមាជិកក្រុមប្រឹក្សាហើយក៏ជា *ដៃមីញ៉ូ* គ្រិស្តសាសនិកដ៏ខ្លាំងក្លាជាងគេនោះនឹងងាកទៅចូលដៃជាមួយ *អ៊ីស៊ីដូ* វិញក្តី ។ លោកបានផ្លាស់ប្តូរពួកការពារប្តូរពាក្យសំងាត់ ហើយនិងបានអង្វរ *ភូរ៉ាណាកា* ម្តងទៀតសូមអោយចាកចេញពី *អូសាកា* នេះប៉ុន្តែគ្មានបានផលអ្វីទាំង អស់ ។

នៅដប់ជំហានពីមេកង *ហ៊ូរី-ម៉ាត់ស៊ី* បញ្ឈប់ដំណើររបស់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ១១

*យ៉ូស៊ី-ណាកា* ដែលជាមេកងពួកអ្នកការពារនេះ ជាយុវបុរសអាយុដប់ប្រាំពីរឆ្នាំ ហើយដែលមានចរិតថោកទាបដ៏មានគ្រោះថ្នាក់ម្នាក់ ។

-ជំរាប់សួរលោក ។ សូមស្វាគមន៍ចំពោះការវិលត្រលប់របស់លោក

- អរគុណ ។ លោកម្ចាស់ *តូរ៉ាណាកា* នៅរង់ចាំខ្ញុំ ។

- បាទ ។

តាមពិតទោះជា *តូរ៉ាណាកា* មិនរង់ចាំក៏ដោយ ក៏*ណាកា* នៅតែអនុញ្ញាតអោយ *តូដា ហ៊្សិរ៉ូ-មាត់ស៊ី* ចូលទៅដែរ ព្រោះថាបុរសចំនាស់នេះជាមនុស្សម្នាក់ក្នុងចំនោមមនុស្សតែបីនាក់គត់នៅលើដីនេះ ដែលអាចចូលជួប *តូរ៉ាណាកា* ថ្មើរណាក៏បានថ្ងៃក៏ដូចយប់ ហើយដោយមិនចាំបាច់មានការណាត់ជួបជាមុនឡើយ ។

- ឆែកមនុស្សចុងស្រុកនេះទៅ !

*ណាកា* ចេញបញ្ជាទៅកូនក្រុមរបស់គេ ។ គេគឺជាកូនប្រុសទីប្រាំរបស់ *តូរ៉ាណាកា* ។ ម្តាយគេ គឺជាប្រពន្ធចុងម្នាក់ក្នុងចំនោមប្រពន្ធចុងទាំងឡាយរបស់ *តូរ៉ាណាកា* ប៉ុន្តែទោះជាយ៉ាងនោះក្តីក៏ *ណាកា* គោរពឪពុកគេណាស់ ។

*ប្លាក់ថន* នៅស្ងៀមអោយគេឆែកឆេរ ដោយគេយល់ថា តើពួកទាំងនោះមានបំនងចង់ធ្វើអ្វីហើយ ។ *សាមូរ៉ៃ* ទាំងពីរនាក់ដែលឆែកឆេរគេនោះ គឺពិតជាប៉ិនប្រសប់មែន ។ គ្មានរបស់អ្វីដែលអាចលាក់ផុតពីពួកគេនេះឡើយ ។

*ណាកា* ធ្វើសញ្ញាម្តងទៀត ។ ពួក*សាមូរ៉ៃ* ងាកទៅម្ខាងបើកផ្លូវអោយទៅទំនេរ ។ *ណាកា* ក៏បើកទ្វារដ៏ក្រាស់នោះដោយខ្លួនឯង ។

*ហ៊្សិរ៉ូ-មាត់ស៊ី* ដើរចូលសាលប្រជុំដ៏ធំល្វឹងល្វើយមួយ ។ គ្រាន់តែឈានហួសខ្លោងទ្វារបន្តិច លោកក៏លុតជង្គង់ចុះ ដាក់ដាវនិងកាំបិតខ្លីនៅពីមុខ ដាក់បាតដៃផ្ទាប់ទៅលើក្តារក្បៀរនោះ ហើយក៏នៅក្រាបចុះក្នុងស្ថានភាពបែបនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

*ណាកា* ដែលតាមឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នជាប់នោះ ធ្វើសញ្ញាអោយ *ប្លាក់ថន* ធ្វើតាម *ហ៊្វី-ម៉ាក់ស៊ី* ។

*ប្លាក់ថន* ដើរចូលទៅក្នុង ។ សាលនេះមានរាងបួនជ្រុងស្មើ ។ មួយជ្រុង ១ មានប្រវែងប្រហែលជិតសែសិបម៉ែត ហើយកំពស់មានប្រហែលដប់ម៉ែត ។ *ភាតាមី* ដែលក្រាលនៅទីនេះជា *ភាតាមី* ធុនលេខមួយ ហើយក្រាស់ឃ្មឹក ។ នៅឯជញ្ជាំងឯនាយ មានទ្វារចេញចូលពីរទៀត ដែលមានសុទ្ធតែអ្នកយាមឈរចាំអម ។ នៅមិនឆ្ងាយប៉ុន្មានពីក្តារកំនល់មួយ មានពួក *សាមូរ៉ៃ* ប្រហែលម្ភៃនាក់នៅអង្គុយពែនភ្លែនព័ទ្ធជុំវិញ ហើយបែរមុខទៅរកទ្វារដែល *ប្លាក់ថន* ទើបចូលមកនេះ ។

នៅពីលើក្តារកំនល់មានម៉ក់មួយ ។ *តូរ៉ាណាកា* កំពុងអង្គុយនៅពីលើនោះ ។ លោកកំពុងតែអោនព្យាបាលស្នាមបាក់របស់ស្មាំងមួយយ៉ាងប្រិតប្រៀង ហាក់បីដូចជាអ្នកឆ្លាក់ភ្នួកយ៉ាងនោះដែរ ។

គ្មានអ្នកណាម្នាក់នៅក្នុងសាលយកចិត្តទុកដាក់ដល់ *ហ៊្វី-ម៉ាក់ស៊ី* រឺ *ប្លាក់ថន* ដែលទើបចូលតាមក្រោយ ហើយមកឈប់នៅក្បែរមេទ័ពចំនាស់នេះឡើយ ។ ប៉ុន្តែផ្ទុយពី *ហ៊្វី-ម៉ាក់ស៊ី* *ប្លាក់ថន* ឥតបានលុតជង្គង់លំអោនខ្លួនគោរពតាមបែបជប៉ុនទេ គេលំអោនខ្លួនគោរពតាមបែបអឺរ៉ុបដូចដែល *រ៉ូឌ្រិច* បានធ្វើប្រាប់គេ រួចហើយគេក៏អង្គុយពែនភ្លែន ហើយសំលឹងជាប់ទៅរក *តូរ៉ាណាកា* ។

ក្រសែភ្នែកទាំងអស់បានបាញ់ស្រោចទៅ *ប្លាក់ថន* ។

នៅឯខ្លោងទ្វារ ដៃរបស់ *ណាកា* បានដាក់ទៅលើដាវហើយជាស្រេច ។ *ហ៊្វី-ម៉ាក់ស៊ី* ថ្វីត្បិតតែក្បាលនៅតែអោនជាប់ក្តី តែក៏ស្រវាយកដាវរបស់ខ្លួនហើយដែរ ។

*ប្លាក់ថន* មានអារម្មណ៍ដូចជានៅអាក្រាតខ្លួនទទេ ប៉ុន្តែគេបានតាំងចិត្តរួចជាស្រេចទៅហើយ ដោយហេតុនេះគេគ្មានអ្វីក្រៅពីរង់ចាំនោះទេ ។ *ប្លាក់ថន* នៅចាំសំដីរបស់ *រ៉ូឌ្រិច* ដែលប្រាប់គេថា " ជាមួយពួកអាតយអែងត្រូវចេះធើរីកដូចស្តេចអីចឹង ទើបបាន " ហើយថ្វីបើពេលនេះអ្វី ៗ មិនដូចស្តេចក្តី ក៏វាល្មមគ្រប់គ្រាន់ហើយដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* ងើបមុខឡើងយ៉ាងយឺត ១ ។

តំនក់ញើសចាប់ផ្ដើមលេចឡើងនៅលើសៀតថ្ងាររបស់ *ប្លាក់ថន* ដោយគេបានឃើញថា អ្វីដែល *រ៉ូទ្រិច* បាននិយាយពីរឿងពួក*សាមូរ៉ៃ* ត្រូវបានចំរាញ់ផ្ដុំនៅលើរូបមនុស្សម្នាក់នេះតត់ ។ ញើសធ្លាក់តក់ៗ កាត់តាមថ្ពាល់ ហើយរមៀលធ្លាក់ទៅតាមករបស់គេ ។ ប៉ុន្តែភ្នែករបស់គេឥតព្រិចឡើយ មុខរបស់គេក៏ឥតបង្ហាញអោយឃើញនូវអារម្មណ៍អ្វីទាំងអស់ ។ ហើយទឹកមុខរបស់ *តូរ៉ាណាកា* ក៏យ៉ាងដូច្នេះដែរ ។

*ប្លាក់ថន* មានអារម្មណ៍ថា ឥទ្ធិពលអំនាចរបស់បុរសនេះបានមកគ្របដណ្ដប់លើរូបគេហើយ ។ គេបង្ខំចិត្តរាប់ពីមួយរហូតដល់ប្រាំមួយ រួចលំអោនក្បាលគោរពជាថ្មីម្ដងទៀត ។ បន្ទាប់មកគេក៏ញញឹមយ៉ាងនឹងនរ និងយ៉ាងរាំហី ។

*តូរ៉ាណាកា* ចោលភ្នែកសំលឹងមើល *ប្លាក់ថន* មួយខ្ទាច់ ។ ទឹកមុខរបស់លោកនៅតែនៅថ្មឹងដដែល ។ បន្ទាប់មកលោកក៏អោនបន្តការងាររបស់លោកទៅទៀត ។ នៅក្នុងបន្ទប់គំនឹងនៅស្ងិតមាននៅឡើយ ។

ស្លាំងដែល*តូរ៉ាណាកា* កំពុងព្យាបាលនេះ ជាប្រភេទស្លាំងល្អ ហើយកំពុងតែបង្ហាញកំលាំងរបស់វា ។ *សាមូរ៉ៃ*ចាស់ម្នាក់ ដែលលុតជង្គង់នៅពីមុខ *តូរ៉ាណាកា* កំពុងទ្រស្លាំងនេះយ៉ាងថ្នមប្រៀបបីដូចជាគេកំពុងកាន់សរសៃកែវយ៉ាងដូច្នោះដែរ ។

*យ៉ូស៊ី តូរ៉ាណាកា* អម្ចាស់នៃតំបន់ក្វាន់តូ ដែលរួមបញ្ចូលខេត្តទាំងប្រាំបីជាមេនៃត្រកូល*យ៉ូស៊ី* ជាអគ្គបញ្ជាការនៃកងទ័ពបូព៌ាទិស និងជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ។ លោកមានរាងទាប ដុះពោះស្នើល ហើយមានច្រមុះធំ ។ ចិញ្ចើមរបស់លោកខ្មៅក្រាស់ឃ្មឹក ។ ពុកមាត់ និង ពុកចង្កាល្ហោលៗ របស់លោកមានពណ៌ល្បាយអាចខ្ចាបន្តិចទៅហើយ ។ អ្វី ១ដែលទាក់ទាញនៅលើមុខរបស់លោក គឺភ្នែកទាំងគូដ៏មុត ។ ថ្វីត្បិតតែមានអាយុហាសិបប្រាំឆ្នាំហើយក្តីក៏ *តូរ៉ាណាកា* នៅតែរឹងមាំមួននៅឡើយ ។ គីម៉ូណូដែលលោកពាក់នោះមានលក្ខណៈសាមញ្ញបំផុត ។ ក្រវាត់របស់លោកធ្វើពីអំបោះធម្មតា ប៉ុន្តែដាវរបស់លោកគឺ ជាដាវដ៏ល្អបំផុតនៅក្នុងលោកនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីព្យាបាលហើយ *តូរ៉ាណាកា* ក៏និយាយយ៉ាងថ្លម ១ទៅកាន់ស្ទាំង :

- នែ អីលូវរួចហើយ ។ អែងស្រួលបួលវិញហើយ ។

រួចលោកយកស្លាបមួយទៅត្រដុសអង្អែលលើស្ទាំង ១ គ្រញ៉ែងខ្លួន ហើយច្បូតរោមស្លាបរបស់ខ្លួនយ៉ាងរីករាយនៅលើដៃសាមូរ៉ៃចំនាស់នោះ ។ *តូរ៉ាណាកា* និយាយបន្ត :

- ម៉ាអាទិត្យទៀតវាហើរឡើងវិញបានហើយ ។

អ្នកកាន់ស្ទាំងលំអោនខ្លួនគោរព ហើយចេញទៅ ។

*តូរ៉ាណាកា* ក៏បង្វិលភ្នែកមករកអ្នកទាំងពីរ ដែលនៅឯមាត់ទ្វារវិញម្តង :

- សូមស្វាគមន៍កណ្តាប់ដៃដែក ។ ខ្ញុំសប្បាយចិត្តណាស់ដែលបានជួបលោក ។ រួចហើយ អ្នីអ្នកចុងស្រុកដ៏ល្បីល្បាញរបស់លោកនោះ ?

- ប្របាទ ម្ចាស់ !

រួច *ប៊្លែរ-មាក់ស៊ី* ក៏ខិតទៅជិត *តូរ៉ាណាកា* ដោយទុកដាវទាំងពីររបស់ខ្លួននៅ ឯមាត់ទ្វារតាមទំនៀមទំលាប់ប៉ុន្តែ*តូរ៉ាណាកា*នៅតែទទូចអោយលោកយកអាវុធទាំងនេះជាប់តាមខ្លួន

- ទេ ! ទេ ! ទេ ! យកមក ! បើលោកមិនមានអាវុធជាប់នឹងខ្លួន ខ្ញុំដូចជាមិនសូវស្រណុកចិត្តសោះ ។

*ប៊្លែរ-មាក់ស៊ី* ថ្លែងអំនរគុណចំពោះអម្ចាស់របស់ខ្លួន ។ ទោះជាមានការអនុញ្ញាតយ៉ាងនេះក្តី ក៏លោកនៅអង្គុយឃ្លាតឆ្ងាយពី *តូរ៉ាណាកា* ប្រហែលប្រាំម៉ែត្រដែរ ។ តាមទំនៀមទំលាប់គ្មានអ្នកមានអាវុធណាម្នាក់អាចចូលជិត *តូរ៉ាណាកា* ដោយនៅបានរស់រានមានជីវិតឡើយ ។ នៅជួរមុខនៃកងការពារ មាន*អ៊ូសាគី* ដែលជាចៅប្រសាស់នព្វរបស់ *ប៊្លែរ-មាក់ស៊ី* ។ ពេលមេទ័ពចំនាស់ងាកទៅងក់ក្បាលបន្តិចទៅខ្លួន *អ៊ូសាគី* លំអោនខ្លួនយ៉ាងទាប និងយ៉ាងរីករាយដោយបានមេទ័ពដ៏ធំនេះកត់សំគាល់ឃើញខ្លួន ។

*តូរ៉ាណាកា* សួរទៅ *ប៊្លែរ-មាក់ស៊ី* យ៉ាងយកចិត្តទុកដាក់ :

- យ៉ាងម៉េចទៅខ្លួនរបស់លោក ?

- ជាស្រួលបួលទេ លោកម្ចាស់ ។ តែខ្ញុំបាទសូមជំរាបលោកម្ចាស់ត្រង់ទៅចុះថា



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំបាទសប្បាយចិត្តណាស់បានឡើងគោកវិញនេះ ។

- ខ្ញុំលឺគេថា លោកទើបបានម៉ូយថ្មីមួយគ្រាន់តែអង្គុយនៅកន្លែងនេះមែនទេ ?

*ហ៊ូរ៉ូ-មាត់ស៊ី* ផុះសំនើចក្អាកក្អាយ :

- ខ្ញុំបាទគ្រាន់តែជំរាបលោកម្ចាស់ថា ពេលវេលាវាមិនអត់ប្រយោជន៍ទេទាន ។

*គូរ៉ាណាកា* សើចតាម :

- បើអ៊ីចឹងខ្ញុំត្រូវអោយរង្វាន់ទៅនារីនោះ ព្រោះថាសុខភាពរបស់លោកមានសារសំខាន់ណាស់ចំពោះខ្ញុំ ។ តើខ្ញុំសូមធ្វើជំនូនអរគុណរបស់ខ្ញុំទៅនាងបានទេ ?

- លោកម្ចាស់មានសន្តានចិត្តល្អណាស់ ។

រួច *ហ៊ូរ៉ូ-មាត់ស៊ី* ប្រែទឹកមុខជាម៉ាំទាំវិញម្តង :

- លោកម្ចាស់ដូចជាផ្តល់រង្វាន់ដល់ពួកយើងគ្រប់គ្នាអ៊ីចឹង បើសិនណាជាលោកម្ចាស់ចេញពីសំបុកពស់វែកនេះ ត្រលប់ទៅវិមានលោកម្ចាស់នៅឯយេដូ វិញនោះទាន ។ នៅយេដូអណ្តាប់លោកម្ចាស់ទាំងអស់អាចការពារលោកម្ចាស់បាន ចំនែកនៅទីនេះវិញពួកយើងខោលតែម្តង ។ *អ៊ីស៊ីដូ* វាចង់ធ្វើអីយើងថ្ងៃណា...ក៏តែ...

- ខ្ញុំចង់តែចេញពីទីនេះទេ នៅពេលណា ដែលក្រុមប្រឹក្សាអាជ្ញានុសិទ្ធិបញ្ចប់ការប្រជុំនោះ ។

រួច *គូរ៉ាណាកា* ក៏ងាកទៅបុរសប៉កទុយកាល់មុខឆ្អឹងម្នាក់ដែលអង្គុយយ៉ាង អត់ធ្មត់ក្រោយខ្លួននោះ :

- សូមមិត្តជួយបកប្រែអោយខ្ញុំបន្តិចបានទេ ?

- បាទ បានទាន ។

បព្វជិតដែលកោរត្រងោលនេះក៏ងើបដើរចេញមកខាងមុខ ហើយលុតជង្គង់បែបជប៉ុនយ៉ាងសមរម្យនៅជិតក្តារកំនល់ ។រាងកាយលោករាងឆ្អឹងដូចជាមុខរបស់លោកដែរ ។ ភ្នែករបស់បព្វជិតនេះខ្មៅគ្រីប ហើយថ្លាឆ្វង់ ។ ទឹកមុខរបស់លោកបង្ហាញនូវភាពស្ងប់យ៉ាងធំធេង ។ លោកពាក់អាវគីម៉ូណូរលុង ហើយនៅចង្កេះរបស់លោកមានសញ្ញាឆ្កាងមួយធ្វើពីមាស ។ លោក



www.budinst.gov.kh www.elibraryofcambodia.org

គោរព *ហ៊្សី-ម៉ាក់ស៊ី* ក្នុងភាពស្មើគ្នា រួចទើបសំលឹងទៅរក *ប្លាក់ថន* យ៉ាងសប្បាយរីករាយក្នុងចិត្ត:

- ខ្ញុំឈ្មោះ *ម៉ាតាំងអាលវីត្ត* នៃសហគមន៍ព្រះយេស៊ូ ។ លោកម្ចាស់ *តូរ៉ាណាកា* មានបំនងចង់អោយខ្ញុំបកជូនលោក ។

- ដំបូងជំរាបគាត់ថា យើងជាសត្រូវនឹងគ្នាហើយ...

- ដោះរឿងមួយម្តង ១ !

បព្វជិត *អាលវីត្ត* និយាយគាត់ *ប្លាក់ថន* យ៉ាងទន់ភ្លន់ រួចក៏បន្តទៀត :

- លោកចង់និយាយភាសាអី ? ភាសាប៉កទុយកាល់ អេស្ប៉ាញ វីឡាតាំង...នេះតាមចិត្តលោកជ្រើសរើសចុះ ។

មុនពេលដែលបព្វជិតដើរមកខាងមុខ *ប្លាក់ថន* ឥតបានឃើញរូបលោកឡើយ ដោយបាំងនឹងពួកសាមូរ៉ៃឯទៀតផង ។ ប៉ុន្តែដោយបាន *រ៉ូឌ្រិច* ប្រាប់គេជាមុននោះ *ប្លាក់ថន* បានរំពឹងជាមុនថា ច្បាស់ជានឹងជួបបព្វជិតនេះជាមិនខាន ។ ហើយពេលនេះគេកំពុងតែជេរប្រទេចទន្ទេរអ្វីដែលគេបានឃើញនៅពេលនេះ ។ នោះគឺជាភាពសង្ហាយ៉ាងបែបវ៉ាហី ហើយនិងឥទ្ធិពលយ៉ាងខ្លាំងក្លារបស់បុរសនេះ ។ *ប្លាក់ថន* បានគិតពីមុនមកថា បព្វជិត *អាលវីត្ត* ពិតជាមនុស្សមានវ័យចំនាស់ម្នាក់ជាមិនខាន ដោយយោលទៅលើមុខងារដ៏មានអំនាចរបស់លោក ហើយនិងយោលទៅលើរបៀបដែល *រ៉ូឌ្រិច* បាននិយាយពីលោក ។ ប៉ុន្តែពេលនេះគេឃើញថា បព្វជិត *អាលវីត្ត* មានអាយុប្រហាក់ប្រហែលនឹងគេប៉ុណ្ណោះ រឺយ៉ាងច្រើនណាស់អាយុលើសខ្លួនគេតែប៉ុន្មានឆ្នាំប៉ុណ្ណោះ ។

- ខ្ញុំនិយាយប៉កទុយកាល់ចុះ-*ប្លាក់ថន* តប ដោយសង្សឹមយ៉ាងស្ងួចស្ងើងថា ភាសានេះអាចអោយគេមានប្រៀបបន្តិចបន្តួច-ព្រះតេជគុណមានសញ្ជាតិប៉កទុយកាល់មែនទេ ?

- បាទ ខ្ញុំមានសំណាងកើតជាប៉កទុយកាល់មែន ។

- ព្រះតេជគុណនៅក្មេងជាងខ្ញុំស្មានទៅទៀត ។

- លោក *រ៉ូឌ្រិច* ចំជាល្អមែន ។ ខ្ញុំមិនសមនឹងកោតសរសើរបែបនេះទេ ។ តែគាត់និយាយពីលោកបានត្រឹមត្រូវល្អណាស់ ។ គាត់ថែមទាំងលើកពីសេចក្តីក្លាហានរបស់លោកថែម



www.budinst.gov.kh www.elibraryofcambodia.org

ទៀត ។

*ប្លាក់ថន* ឃើញបព្វជិត *អាលវីតូ* ងាកទៅនិយាយភាសាជប៉ុនយ៉ាងរអិល និងយ៉ាងរាក់ទាក់ជាមួយ *តូរ៉ាណាកា* ហើយប្រការនេះធ្វើអោយគេកាន់តែជ្រួលច្របល់ថែមទៀត ។ ក្នុងចំនោមមនុស្សទាំងអស់ ដែលនៅក្នុងសាលមានតែ *ហ្វ៊ីរូ-មារ៉ាត់ស៊ឺ* ទេដែលតាមស្តាប់ និងតាមសំលឹងមើលជាប់នូវកិច្ចសន្ទនានេះ ចំនែកឯអ្នកឯទៀតនៅធ្មឹងសំលឹងមើលទៅឯនាយឥតមានវីវរល់អ្វីឡើយ ។ បព្វជិត *អាលវីតូ* បន្លឺឡើង :

- អីលូវនេះយើងចាប់ផ្តើមណា មេបញ្ជាការ តៃកុង ។ សូមលោកយកចិត្តស្តាប់សំដីទាំងអស់ដែលលោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ ហើយកុំកាត់លោកអោយសោះ ។ ស្តាប់ហើយសឹមលោកឆ្លើយ ។ ចាប់ពីពេលនេះទៅ លោកនិយាយអីខ្ញុំនឹងបកភ្លាម ១ ឃ្លាម្តងៗតែម្តង ដោយហេតុនេះសូមលោកនិយាយស្តីដោយប្រុងប្រយ័ត្នអោយមែនទែន ។

- មានរឿងអីខ្លះណឹង ? ខ្ញុំអត់ទុកចិត្តព្រះតេជគុណទេ ។

ភ្លាម ១ នោះបព្វជិត *អាលវីតូ* ក៏បកទៅអោយ *តូរ៉ាណាកា* ដែលទំលាក់ទឹកមុខភ្លាម ១ មួយរំពេច ។

ប្រយ័ត្នប្រយែងអាវ៉ា- *ប្លាក់ថន* គិតនៅក្នុងចិត្ត វាកំពុងប្រលែងលេងជាមួយអែងដូចឆ្មាប្រលែងកណ្តុរហើយ ។ អីលូវនេះទោះវាបកក៏ដោយ វាពន្ធាត់ក៏ដោយសំខាន់អែងធ្វើយ៉ាងណាអោយ *តូរ៉ាណាកា* មានអារម្មណ៍ល្អជាមួយអែងបានហើយ ។ ព្រោះនេះគឺជាផ្លូវតែមួយគត់សំរាប់អែង ។

សំលេងរបស់បព្វជិតលាន់លឺម្តងទៀតយ៉ាងថ្លម ១ និងយ៉ាងទុកចិត្ត :

- សូមលោកទុកចិត្តចុះ ថាខ្ញុំនឹងបកប្រែសំដីដែលលោកនិយាយទាំងប៉ុន្មានអោយបានទាំងស្រុង តាមលទ្ធភាពរបស់ខ្ញុំ ។ ទីនេះជាកន្លែងរបស់លោកម្ចាស់ *តូរ៉ាណាកា* ។ ខ្ញុំជាអ្នកបកប្រែផ្លូវការសំរាប់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ សំរាប់លោកម្ចាស់ *តូរ៉ាណាកា* និងលោកម្ចាស់ *អ៊ីស៊ីដូ*។ លោកម្ចាស់ *តូរ៉ាណាកា* ទុកចិត្តខ្ញុំរាប់ឆ្នាំហើយ ។ ខ្ញុំអង្វរ សូមលោកឆ្លើយតែការពិត ពីព្រោះលោកម្ចាស់ *តូរ៉ាណាកា* ជាមនុស្សវាងវៃបំផុត ។ ម្យ៉ាងទៀតខ្ញុំសូមជំរាបលោកថា ខ្ញុំមិនមែនជា



www.budinst.gov.kh www.elibraryofcambodia.org

បព្វជិត*សេបាស្ទ* ដែលច្រនែនឫសហេតុ និយាយជប៉ុនដូចឆ្មាចូលត្រលោក ហើយដែលខ្វះបទពិសោធន៍ពីប្រទេសជប៉ុននោះទេ ។ វត្តមានរបស់លោកធ្វើអោយ*សេបាស្ទ* ភ្លេចអស់ពាក្យប្រៀនប្រដៅរបស់ព្រះ ហើយក៏បណ្តោយខ្លួនអោយធ្លាក់ក្នុងកំហឹងអតីតកាលទៅ ដោយហេតុថា ឪពុកម្តាយរបស់គេ បងប្អូនប្រុស ស្រីរបស់គេ បានត្រូវសំលាប់យ៉ាងសាហាវឃោរឃៅនៅហូឡង់ដោយពួកអស់លោក គឺកងទ័ពរបស់ព្រះអង្គម្ចាស់ទីក្រុង*អូរ៉េង* ។ ហេតុនេះខ្ញុំសូមលោកអធ្យាស្រ័យដល់គេផង ។

*អាលវីតូ* ញញឹមបន្តិច រួចបន្តទៀត :

- ពាក្យ " សត្រូវ " នេះជប៉ុនថា " *តេគី* " លោកអាចប្រើពាក្យនេះដោយខ្លួនលោកផ្ទាល់ក៏បាន ។ លោកគ្រាន់តែចង្អុលខ្ញុំហើយប្រើពាក្យនេះទៅ លោកម្ចាស់*តូរ៉ាណាកា* នឹងយល់ភ្លាម ។ ជាការពិតហើយ លោកមេបញ្ជាការ តែកុង *ប្លាក់ថន* ។ ខ្ញុំជាសត្រូវរបស់លោក ប៉ុន្តែខ្ញុំមិនមែនឃាតករបស់លោកទេ ។ រឿងឃាតកនេះ គឺលោកនឹងផ្គត់ផ្គង់ដោយខ្លួនលោកផ្ទាល់តែម្តង ។

*ប្លាក់ថន* ឃើញបព្វជិតនេះ ងាកទៅបកអោយ*តូរ៉ាណាកា* នូវអ្វីដែលគេបាននិយាយអំបាញ់មិញ ហើយគេលឺពាក្យ " *តេគី* " ជាច្រើនដង ។ គេងឿងសួរខ្លួនគេថា តើពាក្យនេះមានន័យថាសត្រូវមែនរឺអត់ ? ពិតជាមានន័យហ្នឹងមែនហើយ ។ បព្វជិតនេះមិនដូចអាមួយមុនទេ ។

- សូមទោស អីលូវនេះសូមលោកគិតថា គ្មានរូបខ្ញុំទៅចុះ *អាលវីតូ* ខ្ញុំគ្រាន់តែជាឧបករណ៍មួយ ដើម្បីអោយលោកម្ចាស់ *តូរ៉ាណាកា* យល់បានសំនួររបស់លោក ក៏ដូចជាដើម្បីយល់បានពីសំនួររបស់លោកម្ចាស់*តូរ៉ាណាកា* ផងដែរ ។

និយាយចប់ បព្វជិត*អាលវីតូ* រៀបចំអង្គុយខ្លួនស្រួលបួល ហើយងាកទៅគោរព*តូរ៉ាណាកា* យ៉ាងសមរម្យ ។ *តូរ៉ាណាកា* និយាយយ៉ាងកំបុត ១ ។ បព្វជិតនេះក៏ចាប់ផ្តើមបកទន្ទឹមគ្នាភ្លាមផងដែរ ។

- ហេតុអ្វីបានជាលោកជាសត្រូវនឹង*ស្ពូតូ-សាន* ដែលជាមិត្ត និងជាអ្នកបកប្រែរបស់ខ្ញុំ ហើយដែលមិនដែលចងសត្រូវជាមួយអ្នកណាម្នាក់សោះទៅវិញ ?



www.budinst.gov.kh www.elibraryofcambodia.org

រួចបព្វជិត *អាលវីតូ* ពន្យល់បន្ថែម :

- *ឈូតូ-សាន* គឺជាឈ្មោះ ដែលពួកជប៉ុនហៅខ្ញុំ ព្រោះគេហៅឈ្មោះខ្ញុំមែនទែនពិបាកពេក ។ *ឈូតូ* គឺជាពាក្យកាត់នៃពាក្យ *ឈូយ៉ាតូ* ដែលមានន័យថា បកប្រែ ។ អីលូវនេះសូមលោកឆ្លើយនឹងសំនួរចុះបាទ ។

-យើងជាសត្រូវនឹងគ្នា ពីព្រោះប្រទេសយើងទាំងពីរកំពុងច្បាំងគ្នា ។

- អីចឹង ? ប្រទេសរបស់លោកគឺជាប្រទេសអី ?

- អង់គ្លេស ។

- នៅឯណាទៅ ?

- នេះគឺជារាជាណាចក្រកោះមួយ នៅមួយពាន់ម៉ៃខាងជើងប្រទេសប៉កទុយកាល់ ។ ប្រទេសប៉កទុយកាល់ គឺជាផ្នែកមួយនៃឧបទ្វីបអឺរ៉ុប ។

- ប្រទេសលោកច្បាំងជាមួយប្រទេសប៉កទុយកាល់ប៉ុន្មានឆ្នាំហើយ ?

- តាំងពីប្រទេសប៉កទុយកាល់ក្លាយជាប្រទេសចំនុះប្រទេសអេស្ប៉ាញមក គឺនៅឆ្នាំ ១៥៨០ ពោលគឺកាលពីម្ភៃឆ្នាំមុនប្រទេសអេស្ប៉ាញបង្ក្រាបប្រទេសប៉កទុយកាល់បាន ។ តាមពិតទៅ ប្រទេសយើងខ្ញុំច្បាំងជាមួយប្រទេសអេស្ប៉ាញទេ ។ យើងខ្ញុំច្បាំងជាមួយប្រទេសអេស្ប៉ាញ ជាងសាមសិបឆ្នាំហើយ ។

*ប្លាក់ថន* សំគាល់នូវការភ្ញាក់ផ្អើលរបស់ *តូរ៉ាណាកា* ហើយនឹងសំនួរតាមក្រសែភ្នែករបស់លោកទៅរកបព្វជិត *អាលវីតូ* ប៉ុន្តែបុរសនេះសំលឹងយ៉ាងស្ងប់ស្ងៀមទៅឯទីឆ្ងាយ ។

- លោកថាប្រទេសប៉កទុយកាល់ជាភាគនៃប្រទេសអេស្ប៉ាញមែនទេ ?

- បាទមែន លោកម្ចាស់ *តូរ៉ាណាកា* ។ ជាប្រទេសចំនុះ ។ ប្រទេសអេស្ប៉ាញបានបង្ក្រាបយកប្រទេសប៉កទុយកាល់ ហើយអីលូវនេះប្រទេសទាំងពីរក្លាយជាប្រទេសតែមួយហើយនិងមានស្តេចតែមួយ ។ ប៉ុន្តែពិតមែនជាប្រទេសតែមួយក្តី ក៏ជនជាតិប៉កទុយកាល់ជាអ្នកចំនុះប្រទេសអេស្ប៉ាញនៅស្ទើរគ្រប់កន្លែងពិភពលោក ហើយមេដឹកនាំប្រទេសប៉កទុយកាល់ត្រូវគេចាត់ទុកដូចជាមនុស្សកំប៉ិកកំប៉ុកអីចឹងនៅក្នុងចក្រភពអេស្ប៉ាញ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងសាលមានភាពស្ងប់ស្ងៀមមួយរយៈពេលយ៉ាងយូរ ។ បន្ទាប់មក *ភូរ៉ាណាកា* ក៏ស៊ូរត្រង់ទៅបព្វជិតនេះ ។ បុរសនេះញញឹម ហើយក៏បកប្រែយ៉ាងប្រញាប់ ។

*ឆ្លាក់ថន* ក៏សួរឡើងយ៉ាងកំបុតកំបុយ :

- គាត់ថាម៉េច ?

បព្វជិត *អាលវីតូ* ឥតមានឆ្លើយតបនឹងសំនួររបស់ *ឆ្លាក់ថន* ទេ ប៉ុន្តែលោកបកសំនួរយ៉ាងភាវដូចដើម ។ *ភូរ៉ាណាកា* ក៏ងាកមកនិយាយជាមួយ *ឆ្លាក់ថន* ម្តង ។ សំដីរបស់លោកមុតស្រួច ហើយមានបង្កប់នូវភាពកំនាចឃោរឃៅទៀតផង :

- ខ្ញុំនិយាយអ្វី គ្មានទាក់ទងដល់លោកទេ ។ បើខ្ញុំចង់អោយលោកដឹងរឿងអ្វីខ្ញុំនឹងប្រាប់ហើយ ។

-ខ្ញុំសូមទោសលោកម្ចាស់ *ភូរ៉ាណាកា* ខ្ញុំមិនមែនចង់ធ្វើរកច្រលោមខាមអីចឹងទេ ។ ខ្ញុំគ្រាន់តែចង់ជំរាបលោកម្ចាស់ថា ពួកយើងខ្ញុំមកនេះក្នុងន័យសន្តិភាព...

- អីលូវនេះ លោកមិនចាំបាច់និយាយអីប្រាប់ខ្ញុំទេ សូមតែលោកបិទមាត់អោយឈឹងទៅ ចាំខ្ញុំសួរសឹមឆ្លើយ ។ លោកយល់ហើយរឺនៅ ?

- បាទ

មួយសូន្យ ! ខុសទទេ ! អែងត្រូវប្រយ័ត្នប្រយែងអោយមែនទែន ។ អែងមិនត្រូវមានការខុសឆ្គងទៀតទេ-គេនិយាយនៅក្នុងចិត្ត ។

- ហេតុអីបានជាលោកច្បាំងជាមួយអេស្ប៉ាញ និង ប្រទេសប៉កទុយកាល់ ?

-មួយផ្នែកពីព្រោះប្រទេសអេស្ប៉ាញមានបំនងចង់ត្រួតត្រាពិភពលោក ហើយពួកយើងជាអង់គ្លេស ហើយនិងហូឡង់ ដែលជាសម្ព័ន្ធមិត្តរបស់យើងខ្ញុំមិនព្រមចំនុះខ្លួន ។ មួយផ្នែកទៀតយើងច្បាំងគ្នាពីព្រោះរឿងសាសនា ។

- អ្នក សង្គ្រាមសាសនា ? សាសនារបស់លោកជាសាសនាអី ?

- ខ្ញុំជាគ្រិស្តសាសនិក ។ វិហាររបស់យើង ...

- ពួកប៉កទុយកាល់ និងពួកអេស្ប៉ាញ គឺជាគ្រិស្តសានិក ។ លោកបាននិយាយថា



www.budinst.gov.kh www.elibraryofcambodia.org

សាសនារបស់លោកផ្សេង តើសាសនារបស់លោកជាសាសនាអីទៅ ?

- គឺគ្រិស្តសាសនា ។ រឿងនេះមិនអាចពន្យល់គ្រួស ១ សើ ១ អោយយល់បានទេលោកម្ចាស់តូ *វ៉ាណាកា* ។ ទាំងពីរនេះ...

- គ្មានបញ្ហាអីដែលត្រូវបង្វែនោះទេលោកតៃកុង ។ សូមតែពន្យល់អោយច្បាស់មកបានហើយ ។ ខ្ញុំមានពេលយ៉ាងច្រើន ។ ខ្ញុំជាមនុស្សចេះអត់ធ្មត់ណាស់ ។ លោកជាមនុស្សមានកិរិតវប្បធម៌ មិនមែនជាអ្នកស្រែទេ ដោយហេតុនេះលោកចង់និយាយអោយងាយស្តាប់ រឺអួសបន្ទាយបានតាមចិត្តអោយតែច្បាស់ ។ បើលោកនិយាយចាកប្រធាន ខ្ញុំនឹងរំលឹកលោកអោយត្រលប់មករឿងដើមវិញ ។ លោកថាម៉េចអំបាញ់មិញ ?

- ខ្ញុំកាន់សាសនាគ្រិស្តដែរ ។ ក្នុងគ្រិស្តសាសនាមាននិកាយសំខាន់ពីរ គឺ *ប្រូតេស្តង់* និងកាតូលិច ។ ជនជាតិអង់គ្លេសភាគច្រើនកាន់ប្រូតេស្តង់ ។

- ព្រះមាតា និងព្រះកុមារតែមួយដែរអ្ហី ?

- អត់ទេលោកម្ចាស់ ។ មិនមែនរបៀបពួកកាតូលិចទេ ។

រួចចុះអាគាត់ហ្នឹងវាចង់ដឹងពីអីទៅអ៊ីចេះ ? *ឮក់ថន* ដណ្តឹងសួរនៅក្នុងចិត្ត ។ គាត់នេះកាតូលិចទេដឹង ? តើគួរឆ្លើយពីរឿងអីដែលគាត់ចង់ដឹង រឺឆ្លើយពីរឿងអីដែលអ្ហែងយល់ថាជាការពិត ? តើគាត់នេះប្រឆាំងគ្រិស្តសាសនារឺក៏អត់ ? ក្រែងអំបាញ់មិញគាត់ហៅអា*យេស៊ូត* ថា " មិត្តរបស់ខ្ញុំ" អ្ហី ? តើ*តូវ៉ាណាកា* ជាអ្នកមានសមានចិត្តនឹងសាសនាកាតូលិច រឺចង់កាន់សាសនាកាតូលិចអ៊ីចេះ ?

- តើលោកជឿថា *យេស៊ូ*ជាព្រះទេ ?

*ឮក់ថន* ឆ្លើយតបយ៉ាងប្រុងប្រយ័ត្ន :

- ខ្ញុំជឿថាមានព្រះ ។

- កុំពង្វាងសំនួរ ។ តើលោកជឿថា *យេស៊ូ* ជាព្រះរឺក៏អត់ ? មែនរឺអត់ ?

*ឮក់ថន* ដឹងយ៉ាងច្បាស់ណាស់ថា នៅគ្រប់តុលាការសាសនាកាតូលិច ទូទាំងពិភពលោកគេច្បាស់ជានឹងត្រូវកាត់ទោសពីរឿងបែកឆ្វេងជាមិនខាន ។ ហើយសូម្បីតែនៅតុលាការ



www.budinst.gov.kh www.elibraryofcambodia.org

*ប្រូតេស្តង់* ក៏មិនជាជាងគ្នាដែរ ។ ពីព្រោះការនៅអេះអុញមុខសំនួរបែបនេះ មានន័យថា សង្ស័យអំពីអត្ថិភាពរបស់ព្រះ ។ សង្ស័យក៏រាប់បញ្ចូលថាជាការបែកឆ្វេងមួយដែរ ។

តែមិនអាចឆ្លើយនឹងសំនួរស្តីពីរឿងព្រះ គ្រាន់តែតាមចំលើយ " មែន " " រឺ " អត់ " នោះទេ ។ រវាងពាក្យទាំងពីរម៉ាត់នេះមិនងាយបែងចែកអោយដាច់ជ្រះស្រលះឡើយ ។ គេអាចដឹងច្បាស់ពីរឿងព្រះបានតែ កាលណាគេស្លាប់ទៅហើយទេ ។ ពិតណាស់ខ្ញុំជឿថា *យេស៊ូ* ជាព្រះ តែរឿងនេះពិតរឺអត់ ខ្ញុំដឹងច្បាស់តែពេលណាខ្ញុំស្លាប់ទៅទេ ។

- ចុះហេតុអីបានជាពេលលោកទើបមកដល់ជប៉ុន លោកជាន់កំទេចរូបឆ្លាងរបស់បព្វជិតនោះ .?

*ប្លាក់ថន* ឥតបានគិតថា *តូរ៉ាណាកា* សួរសំនួរនេះមកតែសោះឡើយ ។ តើ *តូរ៉ាណាកា* ដឹងរឿងរ៉ាវទាំងអស់តាំងពីពេលអញ្ជូមកដល់ស្រុកនេះរឺយ៉ាងណាអីចេះ ?

- ខ្ញុំ...ខ្ញុំចង់បង្ហាញប្រាប់ *ដៃមីញ៉ូយ៉ាប៊ូ* ថា បុរស *យេស៊ុីត* គឺបព្វជិត *សេបាស្ទូ* ដែលជាអ្នកបកប្រែតែម្នាក់គត់នៅទីនោះជាសត្រូវរបស់ខ្ញុំ ។ ក្នុងគំនិតខ្ញុំៗគិតថាគេមិនត្រូវទុកចិត្តលោកទេ ពីព្រោះលោកមិនមែនសុទ្ធតែបកត្រឹមត្រូវទាំងអស់ ដូចព្រះតេជគុណ *អាល់វីតូ* ពេលនេះទេ ។ ដូចជាព្រះតេជគុណ *សេបាស្ទូ* ចោទពួកយើងថាជាចោរសមុទ្រជាដើម ។ ពួកយើងខ្ញុំមិនមែនជា ចោរសមុទ្រទេ យើងមកក្នុងនាមសន្តិភាពតែប៉ុណ្ណោះ ។

- អើ មែន ចោរសមុទ្រ ចាំបន្តិចយើងនិយាយពីរឿងចោរសមុទ្រណឹង ។ លោកនិយាយថា ពួកលោកទាំងពីរជាគ្រិស្តសាសនិក ពួកលោកទាំងពីរគោរពយេស៊ូជាព្រះគ្រិស្តមែនទេ ? តើខ្លឹមសាររបស់គ្រិស្តសាសនាមិនប្រដៅថា " ស្រលាញ់រាប់អានគ្នាទៅវិញទៅមក " មែនទេ ?

- ពិតហើយ ។

- បើអីចឹង ហេតុអីបានជាពួកលោកក្លាយជាសត្រូវនឹងគ្នាទៅកើត ?

- គឺរឿងជំនឿ រឺនិយាយអោយងាយស្តាប់ គឺការបកស្រាយចមិនុសគ្នា ។

- អ្ហា អីលូវដូចជាភ្លឺភ្លែកខ្លះ ។ អីចឹងពួកលោកច្បាំងគ្នា ពីព្រោះតែខ្វែងមតិពីរឿង



www.budinst.gov.kh www.elibraryofcambodia.org

ព្រះ និងមិនមែនព្រះមែនទេ ?

- បាទ ។

- ដូចជាសម្លមែនតែម្រេង គ្រាន់តែរឿងអីចឹងច្បាំងគ្នាដែរ ។

*ប្លាក់ថន* ឆ្លើយតបដោយសំលឹងមើលទៅបញ្ជិត *អាលវីតូ* ជាប់ :

- ខ្ញុំក៏យល់ស្របដែរ ។ ខ្ញុំឯកភាពយ៉ាងអស់ពីចិត្តពីថ្លើមរបស់ខ្ញុំ .

- កងនាវារបស់លោកមានប៉ុន្មាន ?

- មានប្រាំ ។

- លោកជាប្រធានខ្សែនាវាមែនទេ ?

- បាទ ។

- សំពៅឯទៀតនៅឯណា ?

- នៅឯលំហសមុទ្រទាន- *ប្លាក់ថន* បន្តឆ្លើយកុហកយ៉ាងប្រុងប្រយ័ត្ន ដោយគេគិតថា *តូរ៉ាណាកា* អាចប្រហែលជាត្រូវ *អាលវីតូ* ជួយអោយមតិក្នុងជំរើសសំនួរមួយចំនួនជាមិនខាន- យើងបែកគ្នាពេលព្យុះ ។ អីឡូវនេះពួកគេទៅដល់ណា ខ្ញុំក៏មិនដឹងដែរ ។

- សំពៅរបស់លោកជាសំពៅអង់គ្លេសមែនទេ ?

- ទេ លោកម្ចាស់ ។ ជាសំពៅហូឡង់ទាន ។

- ហេតុអីបានជាជនជាតិអង់គ្លេសមកបញ្ជាសំពៅហូឡង់ទៅវិញ ?

- រឿងនេះមិនមែនជារឿងចំលែកទេទាន ប្រទេសយើងទាំងពីរជាសម្ព័ន្ធមិត្តនឹងគ្នា ។ ដូចជាមានពេលខ្លះពួកប៉កទុយកាល់បើកសំពៅអេស្ប៉ាញ រឺបញ្ជាកងនាវាចរណ៍អេស្ប៉ាញអីចឹងដែរ ។ បើតាមខ្ញុំដឹងច្បាប់នៅស្រុកលោកម្ចាស់ក៏បានចែងអោយតែកុងប៉កទុយកាល់បើកសំពៅជប៉ុនឆ្លងកាត់ដែរតើ ។

- អីចឹងពួកហូឡង់អត់មានតែកុងទេអ្ហី ?

- មានច្រើនណាស់ទាន ។ តែធ្វើដំណើរផ្លូវឆ្ងាយយ៉ាងនេះ ពួកអង់គ្លេសមានបទពិសោធន៍ច្រើនជាង ។



www.budinst.gov.kh www.elibraryofcambodia.org

- ប៉ុន្តែហេតុអីក៏ជារូបលោក ? ហេតុអីបានជាពួកគេសំរេចយករូបលោកអោយនាំក្បួនសំពៅរបស់ពួកគេ ?

-នេះប្រហែលជាម្តាយខ្ញុំជាជនជាតិហូឡង់ ហើយខ្ញុំចេះនិយាយភាសាប៉កទុយកាល់ស្ទាត់ផង មានបទពិសោធន៏ច្រើនផង ។ ម្យ៉ាងទៀតនេះក៏ជាឱកាសមួយល្អសំរាប់ខ្ញុំផង ។

- ហេតុអី ?

- នេះជាឱកាសទីមួយ ដែលខ្ញុំអាចបើកបរសំពៅនៅលើផ្ទៃសមុទ្រនេះបាន ។ គ្មានសំពៅអង់គ្លេសណាមួយ មានបំនងមកដល់ទីឆ្ងាយបែបនេះទេ ។ នេះគឺជាឱកាសល្អបំផុត ដើម្បីធ្វើដំណើរព័ទ្ធផែនដី ។

-បើអីចឹងលោកបានស្ម័គ្រចិត្តចូលរួមក្នុងកងនាវានេះ ពីព្រោះតែរឿងសាសនានិង ដើម្បីច្បាំងប្រទេសអេស្ប៉ាញ និងប៉កទុយកាល់ ដែលជាសត្រូវរបស់លោកមែនទេ ?

- ខ្ញុំជាតែកុងទាន ។ នេះជាប្រការសំខាន់និងកំនត់បំផុត ។ នៅលើដែនសមុទ្រនេះមិនដែលមានវត្តមានជនជាតិអង់គ្លេស រឺហូឡង់ណាម្នាក់ឡើយ ។ ជាសំខាន់សំពៅយើងខ្ញុំជាសំពៅជំនួញទេ ថ្វីត្បិតតែយើងខ្ញុំមានសារអនុលោមអនុញ្ញាតអោយពួកយើងមានសិទ្ធិវាយប្រហារពួកសត្រូវរបស់យើងនៅឯពិភពថ្មីក្តី ។ យើងខ្ញុំមកជប៉ុននេះ ដើម្បីជួញដូរទេទាន ។

- ស្អីទៅជាសារអនុលោមនោះ ?

- គឺជាព្រះរាជអនុញ្ញាតជាផ្លូវការ របស់ព្រះរាជបល្ល័ង្ក រឺជាការអនុញ្ញាតតាមផ្លូវច្បាប់របស់រដ្ឋាភិបាល ដែលអាចអោយអ្នកកាន់សារនោះ មានសិទ្ធិវាយប្រហារសត្រូវប្រទេសខ្លួនបាន ។

- អ្ហា៎ រួចចុះបើអីលូវរបស់លោកនៅដីនេះ តើលោកមានផែនការច្បាំង និង លួចតែនៅទីនេះទេ ?

-ពេលមុនមកដល់ទីនេះយើងខ្ញុំក៏មិនដឹងថាយើងនឹងជួបស្ថានភាពបែបណានៅឡើយ



www.budinst.gov.kh www.elibraryofcambodia.org

ទេទាន ។ យើងខ្ញុំមកទីនេះ ក្នុងគោលបំនងជួញដូរតែមួយគត់ ។ យើងខ្ញុំដឹងតិចតួចមែន ទែន អំពីប្រទេសលោកម្ចាស់ សឹងតែស្មានថាជារឿងព្រេងផងទេ ។ ពួកប៉ុកទុយកាល់ និង អេស្ប៉ាញ បិទមាត់ជិតឈឹងពីតំបន់នេះ ។

- ឆ្លើយត្រង់នឹងសំនួរខ្ញុំមក ។ សត្រូវរបស់លោកនៅទីនេះ តើលោកមានផែនការវ៉ៃ ប្រហារពួកគេទេ ?

- បើគេវ៉ៃមកលើយើងខ្ញុំ ពិតជាយើងខ្ញុំនឹងវ៉ៃវិញ ។

*តូរ៉ាណាកា* ប្តូរបង្គុយទាំងមួម៉ៅ :

- រឿងដែលលោកឯងធ្វើនៅឯនាយសមុទ្រ រឺនៅប្រទេសរបស់លោក គឺជារឿង របស់លោក ។ តែនៅទីនេះច្បាប់មានតែមួយសំរាប់ទាំងអស់គ្នា ។ ហើយជនបរទេសដែលនៅ ទីនេះ ក៏អាស្រ័យដោយការអនុញ្ញាតរបស់ប្រទេសយើងដែរ ។ រាល់បាបកម្ម និងទំនាស់ជា សាធារណៈទាំងអស់ត្រូវប្រហារជីវិតចោលភ្លាម ។ ច្បាប់របស់យើងច្បាស់ណាស់ ហើយទាំង អស់គ្នាត្រូវតែគោរពតាម ។ តើលោកយល់ហើយរឺនៅ ?

- យល់ហើយលោកម្ចាស់ ។ យើងខ្ញុំមកទីនេះ ដើម្បីជួញដូរ ។ តើយើងអាចជជែក គ្នាពីរឿងរកស៊ីបានទេទាន ? ពួកយើងត្រូវការយកសំពៅឡើងអូ ហើយនិងជួសជុលវា ហើយ យើងទទួលចេញលុយ ។ ក្រៅពីនេះនៅមានបញ្ហា...

- ពេលណាខ្ញុំចង់ជជែកពីរឿងរកស៊ី រឺរឿងអីផ្សេងទៀតនោះ ខ្ញុំនឹងប្រាប់លោក ។ អីលូវនេះសូមតែលោកឆ្លើយនឹងសំនួររបស់ខ្ញុំតែប៉ុណ្ណឹងបានហើយ ។ អីចឹងលោកចូលរួម ក្នុងសង្រ្គាមនេះព្រោះតែរឿងរកស៊ី ព្រោះរឿងចំនេញតែប៉ុណ្ណោះ គឺមិនមែនមកពីករណីកិច្ច រឺភក្តីភាពឡើយមែនទេ ? លោកចូលរួមនេះដើម្បីលុយមែនទេ ?

- បាទ នេះជាទំនៀមទំលាប់របស់យើងខ្ញុំទាន ។ ធ្វើការដើម្បីលុយ និងដើម្បីទទួល បានមួយភាគនៃជ័យ...នៃការជួញដូរ ហើយនិងរបស់របររបស់ខ្មាំងទាំងប៉ុន្មាន ដែលយើងរឹប អូសបាន ។

- បើអីចឹងលោកជាអ្នកស៊ីឈ្នួលច្បាំងមែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- បើគិតពីរឿងដែលគេជួលខ្ញុំដឹកនាំកងសង្វែងនេះ អាចចាត់ថាខ្ញុំជាអ្នកស៊ីឈ្នួលច្បាំងក៏តែថាបាន ។

នៅពេលនេះ *ប្លាក់ថន* មានអារម្មណ៍ពីចំហាយអរិភាព ដែលភាយចេញពី *តូរ៉ាណាកា* មក ប៉ុន្តែគេមិនយល់ថា តើមកពីមូលហេតុអ្វីឡើយ ។ តើអញនិយាយណឹងខុសអ្វី ? អាបព្វជិតនេះវានិយាយហើយតើ ថាអញនឹងផ្គត់ផ្គង់ឃាតកសំរាប់ខ្លួនអញ ដោយខ្លួនអញផ្ទាល់តែម្តង ។ គេនិយាយម្តងទៀត :

- នេះគឺជាទំនៀមទំលាប់ជាប្រក្រតីនៅក្នុងប្រទេសយើងខ្ញុំ តូរ៉ាណាកា-សាម៉ា ។

*តូរ៉ាណាកា* ចាប់ផ្តើមពិភាក្សាជាមួយ *ហ៊ីរ៉ូ-មាត់ស៊ុ* ហើយអ្នកទាំងពីរផ្លាស់ប្តូរមតិផ្ទាមើលទៅក្នុងលក្ខណៈឯកភាពបំផុត ។ *ប្លាក់ថន* មានអារម្មណ៍ឃើញភាពប្រមាថមាក់ងាយ និង រអើមលេចចេញនៅលើមុខរបស់ពួកគេ ។ តើមកពីហេតុអីហ្នំ ? ច្បាស់ណាស់អាកប្បកិរិយារបស់ពួកគេវាទាក់ទិនទៅនឹងពាក្យ " អ្នកស៊ីឈ្នួលច្បាំង " នោះហើយ ? រួចចុះអារឿងណឹងវាមានទាស់ខុសអី ? អ្នកណាមួយធ្វើការមិនគិតកំរៃនោះ ? បើមិនយកកំរៃវាមិនក្រៀមផ្អោកងាប់បាត់ទៅហើយ ? ទោះជាបានកេរដីធ្លីយ៉ាងណាក៏ដោយក៏គេនៅ...

*តូរ៉ាណាកា* ក៏ងាកមកសួរ *ប្លាក់ថន* បន្តទៀត :

- លោកនិយាយថា លោកមកស្រុកនេះ ដើម្បីជួញដូរដោយសន្តិវិធីទេ ចុះហេតុអីក៏លោកមានមួស្កេ មានរំសេវ មានគ្រាប់ និងអាវុធយុទ្ធភណ្ឌច្រើនសំបើមម្ល៉េះ ?

- សត្រូវរបស់យើងខ្ញុំ គឺពួកអេស្ប៉ាញ និងប៉័កទុយកាល់ មានអានុភាពខ្លាំងក្លា ហើយមានកំលាំងក៏ច្រើន លោកម្ចាស់ *តូរ៉ាណាកា* ។ ហេតុនេះយើងខ្ញុំត្រូវការការពារខ្លួនហើយនិង...

- លោកចង់និយាយថា អាវុធទាំងអស់នេះសំរាប់តែការពារខ្លួនមែនទេ ?

- មិនមែនទេ ។ យើងប្រើវាមិនមែនគ្រាន់តែ ដើម្បីការពារខ្លួនប៉ុណ្ណោះទេ តែក៏ដើម្បីវាយប្រហារសត្រូវផងដែរ ។ ទន្ទឹមនេះយើងផលិតវាច្រើនណាស់ ដើម្បីជួញដូរ ហើយអាវុធដែលយើងផលិតនេះ គឺមានគុណភាពស៊ីដាច់គេនៅក្នុងលោកនេះ ។ ហេតុនេះទើបយើងខ្ញុំចង់ពិភាក្សាជាមួយលោកម្ចាស់អំពីការលក់ដូរអាវុធ រឺអំពីមុខទំនិញផ្សេង ១ ទៀតដែលយើងខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

ដីកមកនេះ ។

- យ៉ាងម៉េចទៅដែលហៅថាចោរសមុទ្រនោះ ?

- ជាពួកក្រៅច្បាប់ ។ ជាពួកដែលរំលោភនារី សំលាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិ ដើម្បីផលប្រយោជន៍ខ្លួនឯងតែប៉ុណ្ណោះ ។

- អាណឹងមិនដូចពួកស៊ុយស្លលច្បាំង ? ហើយណឹងមិនដូចលោកឯង ? លោកឯងជាចោរសមុទ្រ ហើយជាមេពួកចោរសមុទ្រផងមែនទេ ?

-ទេ លោកម្ចាស់ ។ ប្រការដែលខុសគ្នា គឺសំពៅរបស់ខ្ញុំបាទ មានសារអនុលោមរបស់អ្នកគ្រប់គ្រងស្របច្បាប់ប្រទេសហូឡង់ ដែលអនុញ្ញាតអោយយើងខ្ញុំធ្វើសឹកនៅលើផ្ទៃសមុទ្រ និង ទឹកទន្លេទាំងអស់ណា ដែលរហូតមកដល់អីលូវនេះត្រូវត្រួតត្រាដោយពួកសត្រូវរបស់យើងខ្ញុំ ហើយនិងស្វែងរកទីផ្សារ ដើម្បីផ្លាស់ប្តូរផលិតផលរបស់ប្រទេសយើងផង ។ ចំពោះពួកអេស្ប៉ាញ និងភាគច្រើននៃពួកប៉កទុយកាល់ វាពិតហើយដែលពួកនេះចាត់ថា យើងខ្ញុំជាពួកចោរសមុទ្រ និងជាពួកទមិឡនោះ ប៉ុន្តែខ្ញុំសូមនិយាយម្តងទៀត តាមពិតពួកយើងខ្ញុំមិនមែនជាចោរសមុទ្រទេ ។

បព្វជិត *អាលវីតូ* បកចប់ពេលណា ក៏និយាយយ៉ាងនឹងនរ តែយ៉ាងម៉ឺងម៉ាត់ទៅកាន់ *តូរ៉ាណាកា* ដោយផ្ទាល់ ។

*ប្លាក់ថន* លួចប្រទេចផ្កាសាតែក្នុងពោះ ។ ធ្វើម៉េចអញចេះនិយាយឆ្លើយឆ្លងបានដោយផ្ទាល់យ៉ាងនេះលោក ! *តូរ៉ាណាកា* ចោលភ្នែកមករក *ហ្សិរ-ម៉ាត់ស៊ី* ហើយមេទ័ពចំនាស់ក៏សួរប៉ុន្មានសំនួរទៅបុរសយេស៊ូតនេះ ។ *អាលវីតូ* ឆ្លើយតបយ៉ាងរហ័ស ។ បន្ទាប់មក *តូរ៉ាណាកា* ក៏ងាកមកសួរ *ប្លាក់ថន* ទៀត ប៉ុន្តែសំលេងរបស់លោកតឹងជាងមុន :

- *ឈូតូ-សាន* និយាយថា ប្រទេសហូឡង់នេះធ្លាប់ចំនុះប្រទេសអេស្ប៉ាញយូរមកហើយ ទើបតែរើខ្លួនរួចបានប៉ុន្មានឆ្នាំមុននេះទេ តើជាការពិតមែនរឺ ?

- ពិតហើយ ។

- និយាយអីចឹងមានន័យថា ប្រទេសហូឡង់ដែលជាសម្ព័ន្ធមិត្តរបស់លោកនោះ គឺជាទ



www.budinst.gov.kh www.elibraryofcambodia.org

បះបោរប្រឆាំងនឹងមហាក្សត្រស្របច្បាប់របស់ខ្លួនមែនទេ ?

- ពិតហើយ ពួកគេប្រឆាំងនឹងពួកអេស្ប៉ាញ ប៉ុន្តែ...

- នេះជាការបះបោរមែនរឺទេ ?

- បាទ ប៉ុន្តែវាក៏មានកាលៈទេសៈអនុគ្រោះដែរទាន ។ ជាកាលៈទេសៈអនុ...

- គ្មានរឿង" កាលៈទេសៈអនុគ្រោះ " ទេ នៅពេលណាដែលគេហ៊ានបះបោរប្រឆាំងនឹងអម្ចាស់របស់ខ្លួននោះ ។

- លើកលែងតែពេលណាដែលគេឈ្នះ ។

*តូរ៉ាណាកា* សំលឹងយ៉ាងមុតទៅរក *ប្លាក់ថន* រួចបន្ទាប់មកលោកក៏សើចឡើងខ្លាំង ។ លោកសើចផង និយាយទៅកាន់ *ហ្ស៊ីរ-ម៉ាត់ស៊ុ* ផង ។ បុរសនេះងក់ក្បាល ។

- ពិតហើយ លោកបរទេសដែលខ្ញុំហៅឈ្មោះមិនត្រូវ ។ ពិតហើយ ។ លោកបានលើកឡើងពីកាលៈទេសៈអនុគ្រោះតែមួយនេះ ។

បន្ទាប់ពីសើចកាច់កកាច់ស្រង់មួយសន្ទុះទៀត *តូរ៉ាណាកា* ក៏ឈប់នៅយ៉ាងម៉ឹងម៉ាត់ដូចពីមុនដដែល :

- តើលោកនឹងបានឈ្នះទេ ?

- *វ៉េ* !

*តូរ៉ាណាកា* និយាយបន្តទៀត ប៉ុន្តែបព្វជិត *អាល់វីតូ* ឥតមានបានបកឡើយ ។ លោកញញឹមយ៉ាងចំលែក ហើយក្រសែភ្នែកលោកនៅសំលឹងជាប់មកលើរូប *ប្លាក់ថន* ។ បន្ទាប់មកលោកដកដង្ហើមធំ ហើយនិយាយឡើង :

- លោកច្បាស់នៅក្នុងចិត្តហើយរឺ ?

- នេះជាសំនួររបស់គាត់ រឺក៏ជារបស់ព្រះតេជគុណ ?

- ជាសំនួររបស់គាត់ ។ រំពល់...គាត់សួរអ៊ីចឹង ។

- ពិតហើយ ។ ជំរាបគាត់ទៅ ថាខ្ញុំច្បាស់នៅក្នុងចិត្តបំផុត ។ តើខ្ញុំអាចពន្យល់ប្រាប់គាត់ថាមកពីហេតុអ្វីទេ ?



www.budinst.gov.kh www.elibraryofcambodia.org

បញ្ជិតងាកទៅនិយាយប្រាប់ *តូរ៉ាណាកា* យ៉ាងយូរ លើសពីពេលចាំបាច់ដែលត្រូវបក សំនូរមួយឃ្លារបស់ *ប្លាក់ថន* នេះណាស់ ។ តើអែងពិតជានៅនឹងនរដូចដែលអែងខំបង្ហាញខាង ក្រៅនេះមែនរឺ ? នេះជាសំនូរដែល *ប្លាក់ថន* ចង់សួរទៅរកបញ្ជិត *អាលវីតូ* ។ តើចំនុចណា ដែលនឹងធ្វើអោយអ្នែងធ្លាយបាន ? តើខ្ញុំនឹងបំផ្លាញអ្នែងបានដោយរបៀបណា ?

*តូរ៉ាណាកា* និយាយបណ្ដើរ ហូតយកផ្លិតពីក្នុងដៃអាវចេញមកក្រៅបណ្ដើរ ។

បញ្ជិត *អាលវីតូ* ក៏បន្តបកប្រែទៅទៀត ដោយនៅតែរក្សាសំលេងឥតស្និទ្ធស្នាល លាយដោយភាពចំអកដដែល :

- ពិតមែនហើយតែកុង ។ លោកអាចនិយាយប្រាប់ខ្ញុំបានថា តើហេតុអីបានជាលោក គិតថា លោកឈ្នះសង្គ្រាមនេះបាននោះ ។

*ប្លាក់ថន* នៅតែខិតខំបង្ហាញទុកចិត្តរបស់ខ្លួនដដែល ដោយគេមានអារម្មណ៍ថា បញ្ជិត ដែលនៅទល់មុខគេនេះប្រឹងប្រែងសង្កត់គេអោយចាញ់ច្រាបនៅពេលនេះ :

-បច្ចុប្បន្ននេះយើងធ្វើម្ចាស់លើផ្ទៃសមុទ្រនៅអឺរ៉ុបហើយ ! គឺមួយភាគធំនៃ សមុទ្រនៅអឺរ៉ុប- *ប្លាក់ថន* ប្រញាប់កែសំដីរបស់គេ ។ កុំរហន់ពេកអាវ៉ា ។ និយាយតែតាមត្រង់ រឺមួយកាឡៃតែបន្តិចបន្តួច ដូចជាអាយេស៊ុតនេះវាធ្វើអីចឹង ។ តែសំខាន់និយាយរឿងពិត-ពួក អង់គ្លេសយើងបានកំទេចការវាយលុកដ៏ធំនៃកងនាវាចរណ៍ដ៏ធំទាំងពីររបស់ប៉ាកទុយកាល់ និង អេស្ប៉ាញខ្ទេចទៅហើយ ។ ហើយមើលទៅពួកនេះគ្មានលទ្ធភាពនឹងបើកការវាយលុកជាថ្មីបាន ទៀតទេ ។ កោះដ៏តូចរបស់យើងខ្ញុំ គឺជាបន្ទាយមួយតែម្ដង ហើយអីលូវនេះគ្មានអ្វីអាចគំរាម កំហែងយើងបានទេ ។ សំពៅរបស់ពួកយើងធ្វើជាម្ចាស់នៅលើផ្ទៃសមុទ្រហើយ ។ សំពៅរបស់ យើងលឿនជាង ទំនើបជាង និងមានអាវុធច្រើនជាងសត្រូវ ។ ពួកអេស្ប៉ាញមិនអាចច្បាំងឈ្នះ ប្រទេសហូឡង់ផងក្នុងរយៈពេលហាសិបឆ្នាំនៃសង្គ្រាម ការបង្ហូរឈាម និងតុលាការសាសនា កន្លងមក ។ សម្ព័ន្ធមិត្តរបស់យើងបានផុតទុក្ខភ័យហើយនាពេលបច្ចុប្បន្ននេះ មិនតែប៉ុណ្ណោះគេ បានចំរើនខ្លាំងក្លា ហើយជាពិសេសគេបានធ្វើអោយចក្រភពអេស្ប៉ាញខ្សោះឈាមទៅហើយ ។ យើងនឹងឈ្នះ ពីព្រោះយើងធ្វើម្ចាស់លើសមុទ្រ និងពីព្រោះមហាក្សត្រអេស្ប៉ាញដែលងប់ទៅ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងភាពក្រអឺតក្រទមឥតបានការនោះ មិនព្រមអោយប្រជាជន ឯទៀតនោះមានសេរីភាពឡើយ ។

- លោកធ្វើម្ចាស់សមុទ្រមែនអ្ហី ? រួមទាំងសមុទ្ររបស់យើងផង រឺយ៉ាងម៉េច ? គឺសមុទ្រដែលនៅតាមបណ្តោយឆ្នេររបស់យើងនេះមែនទេ ?

- ទេ ពិតជាមិនមែនទេ *ត្វាំណាកា-សាយ៉ា* ។ ខ្ញុំនិយាយនេះមិនមែនមានន័យក្រអឺតក្រទមអីទេ ។ ខ្ញុំចង់និយាយតែពីសមុទ្រអឺរ៉ុបតែប៉ុណ្ណោះ ថ្វីត្បិតតែ..

- ល្អ ។ ខ្ញុំអរដែលលោកច្បាស់លើចំនុចនេះ ។ រួចលោកថាម៉េចអំបាញ់មិញនេះ ? ថ្វីត្បិតតែ...យ៉ាងម៉េច ?

*ថ្លាក់ថន* និយាយយ៉ាងច្បាស់ :

-ថ្វីត្បិតតែនៅលើលំហសមុទ្រទាំងអស់ យើងនឹងបោសសំអាតពួកសត្រូវយើងអោយរលីងម៉ត់នៅពេលបន្តិចទៀតខាងមុខនេះក្តី ។

- លោកនិយាយពាក្យ " សត្រូវ " ។ រឺមួយយើងជាសត្រូវដែរ ? រួចហើយអ៊ីចឹងមែនតើវាយ៉ាងម៉េច ? តើពួកលោកនឹងខិតខំកំទេចនាវាយើង និងសាបព្រោះវិនាសកម្មតាមបណ្តោយឆ្នេរយើងរឺយ៉ាងណា ?

- ខ្ញុំមិនដែលមានពេលណានឹកគិតថា លោកម្ចាស់នឹងក្លាយជាសត្រូវឡើយ ។

- តែខ្ញុំអាចក្លាយទៅជាសត្រូវយ៉ាងងាយបំផុត ។ ដល់ពេលនោះ តើយ៉ាងម៉េចទៅ ?

- បើសិនជាលោកម្ចាស់លើកទ័ពវៃនគរខ្ញុំ១ នឹងប្រយុទ្ធតបលោកម្ចាស់ ដើម្បីបង្ក្រាបលោកម្ចាស់ហើយ- *ថ្លាក់ថន* តបឡើង ។

-រួចចុះបើសិនជាអ្នកដឹកនាំលោក ប្រាប់លោកអោយមកច្បាំងនឹងយើងនៅទីនេះវិញ ?

- ខ្ញុំនឹងជំទាស់ ។ ជំទាស់យ៉ាងខ្លាំងក្លាបំផុត ។ ព្រះមហាក្សត្រិយានីរបស់យើងច្បាស់ជានឹងស្តាប់តាម ។ ព្រះនាង...

- ពួកលោកឯងត្រូវមហាក្សត្រិយានីគ្រប់គ្រងទៅវិញទេ ? មិនមែនក្សត្រាទេ ?

- ពិតហើយ លោកម្ចាស់ *ត្វាំណាកា* ។ ព្រះមហាក្សត្រិយានីយើងជាអង្គស្តេចប្រកប



www.budinst.gov.kh www.elibraryofcambodia.org

ដោយគតិបណ្ឌិតណាស់ ។ ព្រះនាងនឹងមិនអាចចេញបញ្ហាដោយឥតសមហេតុផលបែបនេះទេ។

- រួចចុះបើព្រះនាងសំរេចថាច្បាំងមែន ? រឺក៏អ្នកដឹកនាំរបស់លោកសំរេចយ៉ាងនេះមែន ?

- បើអីចឹងមែនខ្ញុំមានតែភាវនាធម៌ទេ ព្រោះទោះទៅតាមច្រកណាក៏ខ្ញុំនៅតែស្លាប់តែដដែលណឹង ។

*តូរ៉ាណាកា* នៅស្ងៀមមួយសន្ទុះ រួចពោលបន្ត

-តើលោកត្រូវចំនាយពេលប៉ុន្មានទើប មកដល់ទីនេះ ?

- ប្រហែលពីរឆ្នាំទាន ។ បើនិយាយអោយជាកំនត់តែម្តង គឺមួយឆ្នាំ ដប់មួយខែ និងពីរថ្ងៃ ។ បើនិយាយចំងាយសមុទ្រ គឺមានប្រហែលបួនពាន់គាវុធ ក្នុងមួយគាវុធមានបីម៉ៃ ។

បព្វជិត *អាលវីតូ* បកប្រែចប់ហើយ ក៏និយាយបន្ថែមយ៉ាងខ្លី ក្នុងពេលជាមួយនេះ *តូរ៉ាណាកា* បក់ផ្លិតមួយ ៗ បែបសញ្ជឹងគិតវែងឆ្ងាយ ។

- ខ្ញុំផ្ទៀងពេល និងចំងាយទៅតាមរបៀបស្រុកគេនេះ លោកមេបញ្ជាការតែកុង *ប្លាក់ថន*-បព្វជិតពោលទៅកាន់ *ប្លាក់ថន* យ៉ាងសុភាព ។

- សូមអរគុណព្រះតេជគុណ ។

រួច *តូរ៉ាណាកា* និយាយត្រង់មករកគេទៀត :

- តើលោកមកដល់កន្លែងនេះតាមរបៀបណា ? តាមផ្លូវណា ?

- តាមច្រកសមុទ្រ *ម៉ាសេឡង់* ទាន ។ បើសិនជាខ្ញុំនៅសល់ផែនទី និងកូនសៀវភៅរបស់ខ្ញុំនោះ ខ្ញុំនឹងបង្ហាញវាបានច្បាស់លាស់ ប៉ុន្តែគេលួចវាបាត់ទៅហើយ ។ មានអ្នកណាយកវាពីក្នុងសំពៅខ្ញុំទៅជាមួយទាំងសារអនុលោម និង លិខិតស្នាមផ្សេង ៗ ទាំងអស់របស់ខ្ញុំ ។ បើសិនជាលោកម្ចាស់ ...

*ប្លាក់ថន* ឈប់សំដីកណ្តាលទី ដោយឃើញ *តូរ៉ាណាកា* និយាយម៉ាត់ ៗ ទៅកាន់ *ហ្សី-ម៉ាត់ស៊ី* ដែលហាក់ដូចជាខ្មាយខ្វល់ណាស់ដែរ ។

- លោកថា ឯកសារទាំងអស់របស់លោកត្រូវគេយក...គេលួចមែនរឺ ?



www.budinst.gov.kh www.elibraryofcambodia.org

- ពិតមែនលោកម្ចាស់ ។

- បើសិនជាការនេះពិតមែន គឺជារឿងមួយអាក្រក់បំផុត ។ នៅទីប៉ុង រីជប៉ុននេះ ការលួចឆក់គឺជាអំពើមួយ ដែលយើងស្អប់ខ្ពើមជាទីបំផុត ។ បញ្ហានេះត្រូវធ្វើអង្កេតជាបន្ទាន់ ។ ដូចជាមិនជឿសោះដែលថា ជនជាតិជប៉ុនហ៊ានធ្វើបែបនេះ ថ្វីបើយើងមានចោរ និងចោរសមុទ្រជប៉ុនមួយចិបមួយចុបនៅទូទាំងប្រទេសក្តី ។

*ប្លាក់ថន* តប :

- ប្រហែលគេដូរកន្លែង ដើម្បីទុកវានៅកន្លែងណាគត់មត់ជាងក៏មិនដឹងទាន ។ ប៉ុន្តែរបស់ទាំងនេះមានតំលៃណាស់ លោកម្ចាស់ *តូរ៉ាណាកា* ។ គ្មានផែនទីសមុទ្រទេ ខ្ញុំដូចជាមនុស្សខ្វាក់ដើរក្នុងក្បួនព័ទ្ធអីចឹង ។ តើលោកម្ចាស់ចង់អោយខ្ញុំនិយាយពីរឿងដំណើរទេទាន ។

- ចង់ ប៉ុន្តែចាំពេលក្រោយ ។ ដំបូងប្រាប់ខ្ញុំមើលថា តើហេតុអ្វីលោកខំធ្វើដំណើរផ្លូវឆ្ងាយយ៉ាងនេះ ?

*ប្លាក់ថន* ខំទ្រាំសង្កត់ចិត្តកន្ទះរារបស់ខ្លួន ហើយនិយាយចំលើយខ្លួនឡើងវិញ :

- យើងខ្ញុំមករកជួញដូរដោយសន្តិវិធីទាន ។ ជួញដូរត្រលប់ទៅស្រុកវិញ ។ ធ្វើយ៉ាងនេះអោយលោកម្ចាស់មានបាន ហើយយើងខ្ញុំក៏អីចឹងដែរ ។ ហើយនឹង...

- លោកមានបាន ខ្ញុំមានបាន ? ក្នុងពីរនេះ មួយណាសំខាន់ជាងគេ ?

- ទាំងសងខាងលោកម្ចាស់ ។ រកស៊ីលក់ដូរត្រូវមានការស្មោះត្រង់ ។ យើងខ្ញុំយកផ្លូវរកស៊ីយូរអង្វែង ។ យើងខ្ញុំលក់ដូរថោកជាងពួកប៉កទុយកាល់ និងពួកអេស្ប៉ាញ ហើយសេវារបស់ពួកយើងខ្ញុំក៏មានគុណភាពល្អជាងទៀត ។ ឈ្មួញយើងខ្ញុំ...

សំលេងខ្លាំង១ នៅឯក្រៅបន្ទប់បានបង្អាក់ *ប្លាក់ថន* អោយឈប់លែងនិយាយ ។ *ហ៊ីរ្វូ-មាត់ស៊ី* ហើយនិងពួកអង្គរក្សពាក់កណ្តាលស្ទុះក្លែតទៅជិតមាត់ទ្វារ ឯពាក់កណ្តាលទៀតស្ទុះទៅអង្គុយពាំងមុខក្តារកំនល់ជិត ។ ពួកសាមូរ៉ៃ ដែលយាមទ្វារក្នុងក៏បានស្ថិតក្នុងស្ថានភាពត្រៀមប្រយុទ្ធហើយស្រេចដែរ ។

*តូរ៉ាណាកា* ឥតមានកំរើកខ្លួនឡើយ ។ លោកនិយាយទៅកាន់បព្វជិត *អាល់វីតូ* ។



www.budinst.gov.kh www.elibraryofcambodia.org

បព្វជិត *អាលវីកូ* ក៏និយាយទៅកាន់ *ប្លាក់ថន* ដោយសំលេងអាសន្នតែយ៉ាងនឹងនរ :

- លោកមេបញ្ជាការ *ប្លាក់ថន* សូមលោកមកខាងនេះ ដើម្បីនៅឆ្ងាយពីមាត់ទ្វារ ។ បើលោកស្រលាញ់ជីវិត សូមលោកកុំនិយាយស្តី និងកុំធ្វើកាយវិការរហ័សរហួនអ្វីទាំងអស់ ។

រួចលោកក៏ខិតទៅអង្គុយជិតទ្វារក្នុងខាងឆ្វេងទៅ ។

*ប្លាក់ថន* លំអោនខ្លួនគោរពយ៉ាងសមរម្យទៅរក *គូវ៉ាណាកា* ប៉ុន្តែ *គូវ៉ាណាកា* ឥតបាន មើលមកគេឡើយ ។ គេក៏ងើបដើរតំរង់ទៅរកបព្វជិត *អាលវីកូ* យ៉ាងប្រុងប្រយ័ត្ន ដោយនៅក្នុង អារម្មណ៍របស់គេ ១ គិតថា កិច្ចសន្ទនានេះ គឺជាការធ្លាក់ទឹកទាំងស្រុងតែម្តង ។

គេដាក់បង្គុយខ្លួនបណ្តើរ និយាយខ្សឹប ១ទៅរកបព្វជិត *អាលវីកូ* បណ្តើរ :

- ចុះមានរឿងអីហ្នឹង ?

ឆ្មាំដែលនៅជិត *ប្លាក់ថន* ក៏រើកខ្លួនយ៉ាងគួរអោយខ្លាចភ្លាម ប៉ុន្តែបព្វជិត *អាលវីកូ* និយាយយ៉ាងរហ័សទៅកាន់ពួកគេ រួចទើបលោកពោលទៅកាន់ *ប្លាក់ថន* :

- លើកក្រោយបើលោកហាមាត់និយាយ លោកនឹងអស់ជីវិតភ្លាម ។

បើអ្វេងស្លាប់កាន់តែឆាប់ពេលណា គឺកាន់តែល្អកាលហ្នឹង-បព្វជិត *អាលវីកូ* គិតនៅក្នុង ចិត្ត ។ ក្នុងកាយវិកាយ៉ាងយឺត ១ លោកទាញយកកន្សែងពីក្នុងដៃអាវ ហើយជូតញើសដែលនៅ សើមពេញដៃរបស់លោក ។ នៅក្នុងអំលុងពេលសួរទមិឡនេះ លោកត្រូវប្រើអស់ការហាត់រៀន របស់លោក ដើម្បីនៅនឹងនរ និងវាងវៃបាន ។ នេះជាការសន្ទនាមួយយ៉ាងលំបាកបំផុត ដែល បព្វជិត *អាលវីកូ* ត្រូវទទួលបកប្រែតាំងពីលោកកើតមក ។

លោកនឹកឃើញឡើងវិញពីសំដី កាលពីយប់មិញលរបស់គណៈសង្ឃរាជ ដែលបានមក ធ្វើអធិការកិច្ចនៅប្រទេសជប៉ុននេះ :

- លោកត្រូវតែមានវត្តមាននៅកន្លែងនោះរឺ ?

- *គូវ៉ាណាកា* បានស្នើរូបខ្ញុំជាពិសេសតែម្តង ។

- ខ្ញុំគិតថា នេះគឺជាប្រការគ្រោះថ្នាក់ណាស់ចំពោះរូបលោក ទាំងចំពោះពួកយើងទាំង អស់គ្នា ។ លោកគិតធ្វើពុតជាឈឺទៅអ្ហី ? បើលោកទៅ លោកត្រូវតែបកតាមសំដីអាចោរ



www.budinst.gov.kh www.elibraryofcambodia.org

សមុទ្រនោះហើយ ១ បើតាមសេចក្ដី រាយការណ៍ គឺវាជាបិសាចពិត ១ ហើយក្រលិចក្រ លុចជាងពួកជ្វីវ[៤៣] ទៅទៀត ។

-ជាការល្អ ខ្ញុំគួរមានមុខនៅទីនោះវិញទាន ។ យ៉ាងហោចណាស់ក៏ខ្ញុំអាចចាប់ចំនុចកុហករបស់ *ប្លាក់ថន* បានខ្លះ ១ដែរ ។

- រួចចុះយ៉ាងម៉េចវា បានជាវាមកដល់កន្លែងយើងដែរ ។ គេកំពុងតែនៅសុខ ១ វាមកភិរវឆានអស់តែម្រ៉ង ។ រួចវាមានសំពៅឯទៀតនៅឯលំហសមុទ្រមែនអ្វី ? រួចរឿងវាបញ្ជូនសំពៅទៅវៃពួកអេស្ប៉ាញនៅម៉ានីលនោះ តើជាការពិតទេ ? នេះមិនមែនខ្ញុំខ្វល់ពីវាសនាអាទិក្រុង របស់យកនេះ រឺខ្វល់ពីដែនអាណានិគមអេស្ប៉ាញនៅភីលីពីននោះទេ ប៉ុន្តែនាវាចរណ៍ខាំងនៅក្នុងសមុទ្រប៉ាស៊ីភិច គឺឡប់ធាតុតែម្រ៉ង មានពួកវាមែន គឺយើងនឹងមានផលវិបាកច្រើននៅអាស៊ី ។ ហើយបើអា *ប្លាក់ថន* អីគេហ្នឹងអាចបញ្ចុះបញ្ចូល *តួកំណាកា រឺអុីស៊ុដូ រឺ ដៃមីញ៉ូ* ខាំង ១ណាម្នាក់បាននោះ សភាពការណ៍នឹងយ៉ាប់មែន ។

- អីលូវនេះ *ប្លាក់ថន* មកដល់ហើយ ប៉ុន្តែសំនាងដែរដែលយើងមានប្រៀបនឹងសង្កត់វាបានទាន ។

- បើសិនជាខ្ញុំមិនដឹងរឿងសព្វគ្រប់ល្អិតល្អន់ទេនោះ ខ្ញុំប្រាកដជានឹកថា ពិតជាពួកអេស្ប៉ាញរឺពួកប្រង់ស៊ីស្កាន[៤៤] និងបេនីឌិចទិន[៤៥] ដែលជាដៃជើងពួកអេស្ប៉ាញនេះហើយដែលរុញពួកវាមកដល់ទីនេះ ដើម្បីបំផ្លាញយើងជាមិនខាន ។

- អាចពួកអស់នេះជាអ្នកធ្វើមែនក៏មិនដឹងទានប្រាស ។ គ្មានរឿងអ្វីដែលពួកសង្ឃនោះ

---

*(៤៣)-( Jews ) ប្រជាជនដើមនៃប្រទេសអុីស្រាអែល ដែលក្នុងជំនាន់ដើម (និងបច្ចុប្បន្ននេះទៅតាមក្រុមសង្គមនីមួយ ១) គេរមែងចាត់ទុកថា ពួកសំបូរល្បិចក្រលិចក្រលុច( ក.ប.អ) .*

*(៤៤) "Franciscan "និកាយមួយផ្នែកនៃគ្រិស្តសាសនាបង្កើតដោយសន្ត: ប្រាំងស៊ីស "Saint Francis " នាសតវត្ស ទី១៣ ( ក.អ.ប. )*

*(៤៥) " Benedictines " និកាយមួយផ្នែកនៃគ្រិស្តសាសនា ដែលបង្កើតឡើងដោយសន្ត:បេនេឌិច (Saint Benedict) នាដើមសតវត្សទី ៦ ( ក.អ.ប. )*



www.budinst.gov.kh www.elibraryofcambodia.org

ធ្វើមិនបានទេ អោយតែពួកវាអាចបំផ្លាញយើងបាន ។ តែអានេះគឺរឿងច្រលែនតែប៉ុណ្ណោះ ពីព្រោះវាធ្វើទៅធ្លាក់ទឹក ឯយើងធ្វើទៅបានជោគជ័យ ។ ពួកនេះគង់តែថ្ងៃណាមួយព្រះលោកនឹងបើកភ្នែកអោយពួកវាដឹងថា វាច្រលំផ្លូវជាមិនខាន ម្យ៉ាងទៀតអាអង់គ្លេស នេះវាអាច ទៅស្រុកដើម វិញមុនវាអាចធ្វើអ្វីជាឧបសគ្គដល់យើងផងក៏មិនដឹង ។ កូនសៀវភៅបង្ហាញច្បាស់ណាស់ថា វាជាអ្នកណា ។ វាគឺជាចោរសមុទ្រ ហើយជាមេពួកចោរសមុទ្រទៀតផង ។

- យកវាទៅអានជូនលោក *តូរ៉ាណាកា* ទៅ *ម៉ាតាំង* ។ អានអាត្រង់ដែលវានិយាយពីការប្លន់ភូមិ ដែលឥតមានអ្វីការពារតាំងពីនៅអាព្រិច រហូតមកដល់ស៊ីលី..ហើយនិង បញ្ជីប្លន់និងការកាប់សំលាប់ទាំងប៉ុន្មាននោះទៅ ។

- យើងគួររង់ចាំសិនទៅព្រះតេជគុណ ។ យើងនៅតែអាចយកកូនសៀវភៅនេះចេញនៅពេលណាក៏បានដែរ ។ វាអាចលៀនកន្ទុយដោយខ្លួនឯង ហើយពេលនោះ វានឹងដាក់ទោសវាដោយខ្លួនវាតែម្តងទាន ។

បព្វជិត *អាល់វីតូ* ជូតដៃរបស់លោកម្តងទៀត ។ លោកដឹងថា *ពួក់ថុន* សំលឹងមើលមកលើរូបលោកជាប់ ។ សូមព្រះជួយប្រណីទោសអ្វែងផងចុះ - លោកគិតនៅក្នុងចិត្ត - គ្រាន់តែសំដីអែងនិយាយប្រាប់ *តូរ៉ាណាកា* នេះ ជីវិតអែងអីលូវនេះចោកមិនបានមួយស្លឹងផងពិសេសវិញ្ញាណក្ខន្ធអែងនឹងប្រោសយ៉ាងណាក៏មិនរួចដែរ ។ អែងនឹងត្រូវឆ្កាងហើយ ។ នេះមិនចាំបាច់បង្ហាញកូនសៀវភៅអែងផង ។ តើគួរបញ្ជូនកូនសៀវភៅទាំងនេះអោយ *សេបាស្ទ្យ* ដើម្បីប្រគល់ទៅអោយ *មូរ៉ាវី*យ៉ាងណាអីចេះ ? រួចចុះបើ *តូរ៉ាណាកា* រកសំបុត្រស្លាមទាំងនេះមិនឃើញ តើគេនឹងធ្វើយ៉ាងណា ? ទេ មិនកើតទេ តែមិនបញ្ជូនទៅវិញ *មូរ៉ា*ច្បាស់ជាមានគ្រោះថ្នាក់ជាមិនខាន ។

ទ្វារដែលនៅឯដើមសាលរបើកឃ្វាំង ។ *ណាកា* និយាយឡើង :

- លោកម្ចាស់ *អ៊ីស៊ីដូ* សូមជួបលោកម្ចាស់ទាន ។ គាត់...គាត់...គាត់នៅឯរបៀងហើយសូមជួបលោកម្ចាស់ ។ គាត់ថាជួបភ្លាមនេះទាន ។

- អ្នកទាំងអស់គ្នាអង្គុយតាមកន្លែងរៀងខ្លួនទៅ !



www.budinst.gov.kh www.elibraryofcambodia.org

ពេល *តូវ៉ាណាកា* ចេញបញ្ជាហើយ ទាំងអស់គ្នាគោរពតាមភ្លាម ។ ប៉ុន្តែពួក *សាមូរ៉ៃ* នៅតែអង្គុយបែរមុខទៅរកមាត់ទ្វារដដែល ។ នៅពីមុខពួកគេ គឺ *ហ៊ូរ៉ា-មាត់ស៊ុ* ។ ដាវទាំងអស់សុទ្ធតែស្ថិតក្នុងសភាពប្រុងជើងការហើយជាស្រេច ។

- *ណាកា-សាន* ជំរាបលោកម្ចាស់ *អ៊ីស៊ីដូ* ទៅថា ទីកន្លែងនេះស្ងាត់មនីជានិច្ចវត្តមានរបស់លោក ។ ប្រាប់អោយគាត់ចូលមកចុះ ។

បុរសមាឌធំម្នាក់ដើរចូលមក ។ សាមូរ៉ៃ ដប់នាក់ដើរហែហមបុរសនេះ ។ ពួកគេមានឯកសណ្ឋានពណ៌ប្រផេះ ។ ប៉ុន្តែនៅពេលឆ្លងផុតខ្លោងទ្វារ ពួកគេក៏ឈប់ស្ងៀម ហើយនៅពេលដែល *អ៊ីស៊ីដូ* អោយសញ្ញាពួកគេក៏អង្គុយពែនភ្លែនចុះនៅកន្លែងនោះទៅ ។

អ្នកទាំងពីរគោរពគ្នាយ៉ាងសមរម្យ ។

បព្វជិត *អាលវីតូ* ទន្ទេញអរគុណព្រះ ដែលបានអោយលោកមានវត្តមាននៅពេលនេះ ។ ការប៉ះទង្គិចគ្នានៅពេលខាងមុខនេះ រវាងមេក្រុមប្រឆាំងគ្នាទាំងពីរនឹងប្រែទិសវិវត្តន៍នៃចក្រភពទាំងមូល ក៏ដូចជានឹងកំនត់ពីអនាគតនៃសាសនាកាតូលិច នៅជប៉ុនផងដែរ ។ ដោយហេតុនេះ គំរុយរឹពតិមានតិចតួចយ៉ាងណាក៏នឹងជួយក្រុម *យេស៊ូអ៊ីត* អោយជ្រើសរើសបានថា តើគេនឹងជួយអ្នកណានៅក្នុងជំលោះនេះ ។ *អ៊ីស៊ីដូ* ជាពុទ្ធសាសនិក-និកាយសេន ហើយជាអ្នកប្រឆាំងសាសនាកាតូលិចយ៉ាងមុតមាំ ។ *តូវ៉ាណាកា* ក៏ជាពុទ្ធសាសនិកនិកាយសេនដែរ ប៉ុន្តែជាមនុស្សមានសមានចិត្តចំពោះសាសនាកាតូលិច ថ្វីត្បិតតែយ៉ាងដូចនេះក្តី ក៏ពួកដៃមិញ៉ូគ្រិស្តសាសនិកភាគច្រើនគាំទ្រ *អ៊ីស៊ីដូ* ទេវិញ ដោយពួកគេខ្លាចឥទ្ធិពលរបស់ *តូវ៉ាណាកា* ហើយបព្វជិត *អាលវីតូ* យល់ថា ការខ្លាចរបស់ពួកគេ គឺមានមូលហេតុត្រឹមត្រូវ ។ ពួកដៃមិញ៉ូគ្រិស្តសាសនិក មានអារម្មណ៍គិតថា បើសិនជា *តូវ៉ាណាកា* អាចកំចាត់ឥទ្ធិពលរបស់ *អ៊ីស៊ីដូ* នៅក្នុងក្រុមប្រឹក្សាអាជ្ញានុសិទ្ធិបានមែននោះ *តូវ៉ាណាកា* ច្បាស់ជាឡោមយកអំនាចសំរាប់តែខ្លួនឯងម្នាក់ជាមិនខាន ។ ហើយនៅពេលដែល *តូវ៉ាណាកា* មានអំនាចពេញនៅក្នុងដៃហើយ លោកច្បាស់ជានឹងអនុវត្តអាជ្ញាបណ្តេញពួកបរទេសរបស់ *រ៉ាកូ* ហើយនិងបំបិទចោលសាសនាកាតូលិចជាមិនខាន ។ ផ្ទុយទៅវិញបើសិនជា *តូវ៉ាណាកា* ត្រូវបានកំចាត់ចេញវិញនោះ ការបន្តអំនាចដ៏



www.budinst.gov.kh www.elibraryofcambodia.org

ខ្សោយនឹងត្រូវបានធានាដល់កូនប្រុស របស់ *វិតតូ* ហើយសាសនាកាតូលិចច្បាស់ជានឹងរីកចំរើនជាមិនខាន ។

អាស្រ័យដោយការគាំទ្ររបស់ពួក *វៃមីញ៉ូ* គ្រិស្តសាសនិក និងក៏ដូចជា *វៃមីញ៉ូ* ឯទៀត ។ ដែលរមែងតែរេចុះរេឡើងនោះ គឺជាការលំបាកណាស់ដែលកំនត់អោយបានច្បាស់ ថាអ្នកណាខ្លាំងជាងអ្នកណានោះ ។ សូម្បីតែខ្លួនបព្វជិត *អាលវីតូ* ដែលជាជនជាតិអឺរ៉ុបតែម្នាក់គត់នៅក្នុងចក្រភពនេះ ដែលដឹងរឿងរ៉ាវច្រើនជាងគេបំផុតនោះ ក៏មិនអាចកំនត់បានច្បាស់ដែរថា បើសិនជាសង្គ្រាមផ្ទុះឡើង តើពួកវៃមីញ៉ូគ្រិស្តសាសនិក នឹងគាំទ្រខាងណា ហើយខាងណានឹងមានជ័យជំនះនោះ ។

បព្វជិត*អាលវីតូ* សំលឹងមើល *តូរ៉ាណាកា* ដែលងើបចេញពីក្តារកំនល់ ហើយដើរទៅរក *អ៊ីស៊ីដូ* ដោយឆ្លងកាត់រង្វង់កងការពាររបស់ខ្លួន :

- សូមស្វាគមន៍លោក *អ៊ីស៊ីដូ* ។ សូមអញ្ជើញអង្គុយកន្លែងនេះចុះ- *តូរ៉ាណាកា* ចង្អុលទៅម៉ក់តែមួយដែលនៅពីលើកំនល់ - ខ្ញុំរីករាយណាស់បើសិនជាលោកបានកន្លែងអង្គុយស្រួលបួលនោះ ។

- អរគុណណាស់លោក *តូរ៉ាណាកា* ។ ប៉ុន្តែខ្ញុំមិនអង្គុយកន្លែងនោះទេ ។

*អ៊ីស៊ីដូ កាស៊ូណារី* មានរាងស្តើង មុខមាំ និងរាងស្រអែម ។ លោកមានអាយុតិចជាង *តូរ៉ាណាកា* មួយឆ្នាំ ។ អ្នកទាំងពីរជាសត្រូវនឹងគ្នាចាស់ឆ្នាំមកហើយ ។ នៅក្នុងនិងជុំវិញអូសាកានេះ មានកងសាមូរ៉ៃ របស់ *អ៊ីស៊ីដូ* ប្រាំបីពាន់នាក់ កំពុងត្រៀមខ្លួនជានិច្ច ។

- អរគុណលោកណាស់ ប៉ុន្តែខ្ញុំមិនអង្គុយកន្លែងនោះទេ-*អ៊ីស៊ីដូ* និយាយសាជាថ្មី - ខ្ញុំនៅមិនសុខទេ បើខ្ញុំបានកន្លែងអង្គុយស្រួល ហើយលោកអត់នោះ មិនអីចឹង ? ថ្ងៃណាមួយខ្ញុំនឹងអង្គុយលើម៉ក់របស់លោក ប៉ុន្តែមិនមែនថ្ងៃនេះទេ ។

ចរន្តកំហឹងបានរត់ឆក់ពួកអាវក្អោតទាំងអស់គ្នា នៅពេលដែលពួកគេលឺសំដីពោរពេញទៅដោយការគំរាមកំហែងនេះ ប៉ុន្តែ *តូរ៉ាណាកា* នៅតែឆ្លើយតបយ៉ាងផ្អែមត្រជាក់ :

- លោកអញ្ជើញមកចំពេលល្អណាស់ ។ ខ្ញុំទើបតែសាកសួរអ្នកចុងស្រុកថ្មីម្នាក់ចប់



www.budinst.gov.kh www.elibraryofcambodia.org

អំបាញ់មិញនេះ ។ *ល្ហូត-សាន* សូមលោកប្រាប់គេអោយលើបឈរឡើង ។

បព្វជិតធ្វើតាមសំដីរបស់ *តូរ៉ាណាកា* ភ្លាម ។ ក្នុងអារម្មណ៍របស់លោក ១ ចាប់បាននូវចរន្តអរិភាពរបស់ *អ៊ីស៊ីដូ* យ៉ាងច្បាស់ ។ ក្រៅពីជាអ្នកប្រឆាំងដាច់ខាត នឹងគ្រិស្តសាសនា *អ៊ីស៊ីដូ* តែងតែជាអ្នកប្រឆាំងដាច់ខាតនឹងពួកអឺរ៉ុប ហើយគេតែងទាមទារអោយបិទទ្វារចក្រភពជប៉ុនមិនអោយពួកអឺរ៉ុបចូលមកបានឡើយ ។

*អ៊ីស៊ីដូ* សំលឹងមើល *ប្លាក់ថន* ដោយអាការៈខ្ញើមឆ្អើម :

- ខ្ញុំលឺគេថាវាអាក្រក់ណាស់ តែខ្ញុំមិននឹកស្មានថា វាអាក្រក់ដល់យ៉ាងនេះសោះ ។ គេនិយាយចចេកចចូចថា វាជាចោរសមុទ្រផង តើពិតទេ ?

- លោកនៅសង្ស័យថា មិនមែនទៀតអ្វី ? រួចវាជើងកុហកឈ្លុយថែមទៀត ។

- បើអ៊ីចឹង មុនពេលលោកដោតឆ្កាងវា សូមលោកទុកវាអោយខ្ញុំបានកន្លះថ្ងៃផង ។ ទាយាទប្រហែលជាសប្បាយចិត្តនឹងមើលវា នៅពេលដែលក្បាលវានៅលើស្មានៅឡើយ-រួច *អ៊ីស៊ីដូ* ផ្ទុះសំណើចយ៉ាងកំនាច :

- បើមិនអ៊ីចឹងទេ លោកអាចបង្ហាត់វាអោយចេះរាំដូចខ្លាឃ្មុំ ហើយនាំវាទៅបង្ហាញគេឯងទូទាំងប្រទេសទៅ វាណឹងហើយ " អាបិសាចទិសខាងកើត " នោះ

ខុសពីពួកប៉ក់ទុយកាល់ ដែលតែងមកទីនេះតាមភាគខាងត្បូង ហើយដោយហេតុនេះទើបមានឈ្មោះថា " ពួកចុងស្រុកភាគខាងត្បូង " នោះ *ប្លាក់ថន* ជាមនុស្សតែម្នាក់គត់ ដែលមកដល់ប្រទេសជប៉ុនតាមសមុទ្រទិសខាងកើត ។ ប៉ុន្តែការដែល *អ៊ីស៊ីដូ* អោយឈ្មោះ *ប្លាក់ថន* ថាជា " អាបិសាចទិសខាងកើត " នោះ គឺពិតជាការវាយបញ្ឆិតទៅលើរូប *តូរ៉ាណាកា* ដែលត្រួតត្រាខេត្តទាំងឡាយនៅបូព៌ាទិសទៅវិញទេ ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ *តូរ៉ាណាកា* នៅតែញញឹម ហើយធ្វើហាក់ដូចជាមិនយល់អ្វីពីការលេងមួយផ្លែនេះទៀតរបស់ *អ៊ីស៊ីដូ* ឡើយ ។ លោកនិយាយឡើង :

- លោកពិតជាប៉ិនក៏ប្លែងមែនលោក *អ៊ីស៊ីដូ* ។ តែខ្ញុំគិតថា ចាត់ការមនុស្សចុងស្រុកនេះកាន់តែឆាប់កាលណា កាន់តែល្អកាលណឹង ។ អានេះជាមនុស្សព្រោកប្រាជ្ញ ក្រអឺតក្រទម



www.budinst.gov.kh www.elibraryofcambodia.org

ឡូឡា ហើយដូចជាមិនគ្រប់ដប់យ៉ាងម៉េចទេ ។ និយាយរួមវាគ្មានបានការអី ហើយគ្មានរបៀបរបបអីទាំងអស់តែម្ដង ។ *ណាកា-សាន* អោយមនុស្សខ្លះនាំវាយកទៅឃុំជាមួយពួកអ្នកទោសធម្មតាទៅ ។

- លោកមេបញ្ជាការ-តៃកុង សូមលោកទៅតាមអ្នកប៉ុន្មាននាក់នោះទៅ ។

- ខ្ញុំទៅណា ?

បព្វជិត*អាលវីតូ* អេះអុញមួយរយៈ ។ លោករីករាយណាស់ដែលលោកបានឈ្នះក្នុងវិញ្ញាសានេះ ប៉ុន្តែគូប្រកួតរបស់លោកនេះ គឺជាមនុស្សក្លាហានម្នាក់ ហើយព្រលឹងរបស់គេអាចប្រោសអោយផុតបាន ។ លោកតប :

- លោកត្រូវគេឃុំខ្លួនហើយ ។

- ឃុំប៉ុន្មានពេលទៅ ?

- ខ្ញុំអត់ដឹងទេ ។ គឺរហូតដល់លោកម្ចាស់ *តូរ៉ាណាកា* សំរេចចិត្ត ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ១២

ក្នុងពេលដែល *តូរ៉ាណាកា* តាមសំលឹងមើល *ហ្គក់ថន* ដើរចេញពីសាលជំនុំលោកក៏បានដកចិត្តពីកិច្ចសន្ទនាដ៏គួរអោយជក់ចិត្តនេះ ដើម្បីផ្តោតអារម្មណ៍ទាំងអស់ទៅបញ្ហា *អ៊ីស៊ីដូ* ដែលនៅចំពោះមុខវិញនេះម្តង ។

*តូរ៉ាណាកា* សំរេចចិត្តមិនអោយបព្វជិត *អាលវីតូ* ដកខ្លួនទៅវិញទេ ដោយលោកដឹងថា វត្តមាននេះនឹងធ្វើអោយ *អ៊ីស៊ីដូ* មួហ្មងនៅក្នុងចិត្តជាមិនខាន ថ្វីត្បិតតែលោកដឹងថា វត្តមានជាបន្តរបស់បព្វជិតនេះ ក៏អាចជាគ្រោះថ្នាក់មួយចំពោះលោកយ៉ាងណាក្តី ។ ជនបរទេសនេះដឹងកាន់តែតិចកាលណា កាន់តែល្អកាលនោះ ។ មានមនុស្សដឹងលឺកាន់តែតិចក៏កាន់តែល្អ ។ តើឥទ្ធិពលរបស់ *ឈូតូ-សាន* ទៅលើពួកដៃមួព្វ៉ូគ្រិស្តសាសនិក នឹងគាំទ្រអញ ឬក៏ប្រឆាំងអញ ? *តូរ៉ាណាកា* ដណ្តឹងសួរនៅក្នុងចិត្ត ។ មកដល់ពេលនេះអញទុកចិត្តវា ប៉ុន្តែក៏មានពេលខ្លះដែលអញមិនអាចយល់បានពីមនុស្សចុងស្រុកនេះផងដែរទេ ។

*អ៊ីស៊ីដូ* មិនបាននិយាយការគួរសមជាប្រពៃណីនោះទេ ប៉ុន្តែលោកចាប់ចូលសាច់រឿងត្រង់តែម្តង :

- ខ្ញុំសូមសួរម្តងទៀត តើលោកមានចំលើយបែបណាចំពោះក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ?

- ខ្ញុំសូមឆ្លើយម្តងទៀត : ក្នុងឋានៈជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ខ្ញុំយល់ថាគ្មានចាំបាច់ត្រូវការចំលើយអ្វីទាំងអស់ ។ ខ្ញុំបានចងសាច់សារលោហិតកំប៉ិចកំប៉ុកមួយចំនួនតូចដែលគ្មានសារសំខាន់អ្វីឡើយទេ ។ ហើយនេះគ្មានចាំបាច់ទាមទារចំលើយទេ ។

- លោកបានភ្ជាប់ពាក្យ *ណាកា-សាន* ដែលជាកូនប្រុសរបស់លោកទៅនឹងកូនស្រីរបស់អម្ចាស់ *ម៉ាសាមូនេ* ។ លោកបានការចៅស្រីរបស់លោកជាមួយកូនប្រុស និង ជាទាយាទរបស់អម្ចាស់ *សាគាគី* ហើយចៅស្រីម្នាក់ទៀតទៅនឹងកូនប្រុសរបស់អម្ចាស់ *គីយ៉ាម៉ា* ។ និយាយរួម ការចងសាច់ចងឈាមទាំងនេះសុទ្ធតែបានធ្វើជាមួយពួកអម្ចាស់ រឺក្រុមគ្រួសារអម្ចាស់ ហេតុនេះវាមិនមែនជាការកំប៉ិកកំប៉ុកនោះទេ ហើយនេះ គឺផ្ទុយទៅនឹងបញ្ជារបស់លោកម្ចាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកម្ចាស់ *វ៉ាកូ* របស់យើងស្លាប់បានមួយឆ្នាំហើយ ។ ស្តាយណាស់ ។ មែនខ្ញុំសែនសោកស្តាយចំពោះមរណភាពបងថ្លៃរបស់ខ្ញុំនេះ ។ ខ្ញុំតែងតែបន់អោយគាត់នៅមានជីវិតរស់នៅដើម្បីដឹកនាំជោគវាសនារបស់ចក្រភពយើងជាប់រៀងរហូត ។

រួច *តូរ៉ាណាកា* ពោលបន្ថែមទៀត ដើម្បីបន្ថែមអំពិលទៅលើមុខរបួសផ្លូវចិត្តរបស់ *អ៊ីស៊ីដូ* :

- បើសិនជាបងថ្លៃខ្ញុំនៅរស់ គាត់ច្បាស់ជាឯកភាពនឹងការចងសម្ព័ន្ធមេត្រីសាច់សារលោហិតនេះជាមិនខាន ។ ការណែនាំរបស់គាត់ គឺទាក់ទិនទៅនឹងការចងសាច់ឈាមណាដែលគំរាមកំហែងដល់ការបន្តអំនាចរបស់ត្រកូលគាត់តែប៉ុណ្ណោះ ។ ខ្ញុំមិនបានគំរាមកំហែងត្រកូលគាត់ រឺទាយាទគាត់ដែលត្រូវជាក្មួយរបស់ខ្ញុំ គឺ *យែម៉ុន* នោះទេ ។ ខ្ញុំរីករាយនឹងតំនែងរបស់ខ្ញុំជាអម្ចាស់តំបន់*ក្វាន់តូ* នោះណាស់ទៅហើយ ។ ខ្ញុំមិនបានស្វះស្វែងពង្រាតដែនដីរបស់ខ្ញុំទេ ។ ខ្ញុំរស់នៅដោយសន្តិភាពជាមួយតំបន់ជិតខាងខ្ញុំ ហើយខ្ញុំតែងមានបំនងចង់អោយសន្តិភាពនេះនៅមានបន្តទៅទៀត ។ ខ្ញុំយកព្រះជាបន្ទាល់ថា ខ្ញុំនឹងមិនមែនជាអ្នករំលោភបំផ្លាញសន្តិភាពនេះមុនឡើយ ។

ជាងប្រាំមួយទសវត្សមកហើយ ដែលចក្រភពត្រូវហែកហួរដោយសង្គ្រាមក្នុងស្រុក ។ កាលពីសាមសិបឆ្នាំមុននេះ ដៃមីញ៉ូតូចតាចម្នាក់ឈ្មោះ *ក្ស៊ូដា* គាំទ្រដោយ *តូរ៉ាណាកា* បានដណ្តើមកាន់កាប់តំបន់ក្វាន់តូ ។ បន្ទាប់ពីនោះក្នុងអំលុងពេលពីរទសវត្សមកទៀត កងទ័ពរបស់ *ក្ស៊ូដា* បានវាយបង្ក្រាបជាចំនុះជាងពាក់កណ្តាលនៃប្រទេសជប៉ុន អាស្រ័យការសំលាប់យ៉ាងរង្គាល ហើយ*ក្ស៊ូដា* ក៏បានប្រកាសខ្លួនជាមហាឧបរាជ ប៉ុន្តែក៏នៅតែមិនទាន់មានអំនាចគ្រប់គ្រាន់ ដើម្បីសុំអោយព្រះចៅអធិរាជប្រទានគោរមងារជាអគ្គមហាសេនាបាន ទោះជា *ក្ស៊ូដា* ស្ថិតនៅក្នុងវង្សត្រកូល*ភូជីម៉ូតូ* ក្តី ។ រួចកាលពីដប់ប្រាំមួយឆ្នាំមុននេះ *ក្ស៊ូដា* ត្រូវមេទ័ពរបស់ខ្លួនម្នាក់ធ្វើឃាតស្លាប់ទៅ ហើយអំនាចរបស់លោកក៏ត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់មេទ័ពដ៏ល្បីល្បាញរបស់ខ្លួនម្នាក់ ដែលមានប្រភពចេញពីកសិករ គឺ *ណាកាមូរ៉ា* ។

ក្នុងរយៈពេលដ៏ខ្លីចំនួនបួនឆ្នាំ មេទ័ព *ណាកាមូរ៉ា* ដោយបានជំនួយពី*តូរ៉ាណាកា អ៊ីស៊ីដូ*



www.budinst.gov.kh www.elibraryofcambodia.org

និងដៃមីញ៉ូឯទៀតបានបំបាត់ចោលអ្នកបន្តពូជ *ក្ញូដៅ* ទាំងអស់ហើយបានដាក់ចក្រភពជប៉ុនទាំងមូលអោយនៅក្រោមការត្រួតត្រាផ្តាច់មុខរបស់ខ្លួន ។ នេះគឺជាលើកទីមួយក្នុងប្រវត្តិប្រទេសជប៉ុន ដែលមនុស្សតែម្នាក់អាចត្រួតត្រានគរទាំងមូលបាន ។ ក្នុងជ័យជំនះនេះ *ណាកាមូរ៉ា* បានទៅដល់ក្បូង ថ្វាយបង្គំព្រះចៅ *ភូ-ឌីចូ* ។ ដោយខ្លួនលោកមានពូជពង្សមកពីកសិករ លោកក៏ត្រូវបានទទួលការតែងតាំងជា *ក្វាមប៉ាគូ* គឺជាអគ្គទីប្រឹក្សា ហើយដែលនៅពេលក្រោយមកទៀតលោកបានផ្ទេរឋានៈនេះទៅកូនប្រុសរបស់លោក ដោយលោកកាន់តែឋានៈជា *តៃកូ* តែប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តីក៏ *ដៃមីញ៉ូ* ទាំងអស់ត្រូវតែលំអោនខ្លួនគោរពចំពោះមុខលោកដដែល សូម្បីតែ *តូរ៉ាណាកា* ក៏ដោយ ។ ហើយស្ទើរតែគ្មានអ្នកណាជឿបាន ក្នុងអំលុងពេលដប់ឆ្នាំនគរបានសុខសន្តិភាពរហូត ។ នៅឆ្នាំទៅមិញ *តៃកូ* ក៏បានទទួលមរណភាពទៅ ។

*តូរ៉ាណាកា* និយាយម្តងទៀត ៖

- ខ្ញុំយកព្រះជាបន្ទាល់ ខ្ញុំនឹងមិនមែនជាអ្នករំលោភបំផ្លាញសន្តិភាពមុនឡើយ ។

- ប៉ុន្តែលោកត្រៀមធ្វើសង្គ្រាមហើយមែនទេ ?

-មនុស្សឈ្លាសវៃត្រូវតែត្រៀមខ្លួនតទល់នឹងអំពើក្បត់ មិនអ៊ីចឹង? នៅតាមគ្រប់ខេត្តតែងមានមនុស្សអាក្រក់ជូជាតិជាមិនខាន ។ អាមនុស្សអាក្រក់ខ្លះនៅថ្នាក់ខ្ពស់ទៀតផង ។ យើងទាំងពីរនាក់សុទ្ធតែបានដឹងហើយទេតើ អំពីការគ្មានព្រំដែននៃអំពើក្បត់នៅក្នុងបេះដូងមនុស្សម្នាក់ ៗ នោះ មិនថាអ៊ីចឹង ? លោកម្ចាស់ *តៃកូ* បានទុកការឯកភាពជាកេរមរតករបស់លោកមកដល់ពួកយើង ប៉ុន្តែអីលូវនេះវាបែរជាលេចបូពាទិសរបស់ខ្ញុំ និងបស្ចិមទិសរបស់លោកទៅវិញ ។ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិក៏បែកខ្ញែកគ្នាទៅទៀត ។ ពួកដៃមីញ៉ូ ក៏មានទំនាស់គ្នា ។ ក្រុមប្រឹក្សាមិនអាចដឹកនាំតែកូនភូមិអង្កាច់អង្កោចមួយបានផង កុំថាឡើយដល់ចង់ទៅដឹកនាំចក្រភពនោះ ។ ហេតុនេះ កូនប្រុសរបស់លោកម្ចាស់ *តៃកូ* កាន់តែឆាប់ពេញវ័យកាលណា កាន់តែល្អកាលនោះ ។ កាន់តែមានអគ្គទីប្រឹក្សាឆាប់កាលណា កាន់តែល្អកាលនោះ ។

*អ៊ីស៊ីដូ* និយាយបៀសឡើង ៖

- រឺអគ្គមហាសេនាវិញអ្វី ?



www.budinst.gov.kh www.elibraryofcambodia.org

- អគ្គទីប្រឹក្សា រឺអគ្គមហាសេនា រឺតែកូ អំនាចវានៅតែដដែលហ្នឹង ។ តើគោរមងារវាសំខាន់អីទៅ ? អំនាចទេដែលជាប្រការសំខាន់បំផុតនោះ ។ *ក្លូដោ* មិនដែលបានក្លាយជាអគ្គមហាសេនា ហើយ*ណាកាមូរ៉ា* ពេញចិត្តណាស់ទៅហើយនឹង គោរមងារអគ្គទីប្រឹក្សាក្រោយមកទៀត គាត់មានឈ្មោះតែត្រឹម *តៃកូ*ផង ។ តែអ្វីដែលសំខាន់ គឺគាត់ជាអ្នកត្រួតត្រា ។ ដល់អីចឹងទៅអត់មានបញ្ហាអី ដែលថាគាត់មានប្រភពពីកសិករអីសោះតែម្តង ។ រួចចុះវាមានបញ្ហាអី ទំរាំគ្រួសារខ្ញុំជាគ្រួសារមានចំនាស់យូរលង់មកហើយនោះ ? រឿងកើតពីត្រកូលទាបត្រកូលខ្ពស់ មានបញ្ហាអីទៀត ? សំខាន់អីលូវនេះ គឺយើងជាមេទ័ព ជាស្តេចត្រាញ់ ហើយជាមនុស្សម្នាក់នៅក្នុងក្រុមប្រឹក្សាអាផ្វានុសិទ្ធិថែមទៀត ។

វាមានបញ្ហាច្រើន *អ៊ីស៊ីដូ* គិតនៅក្នុងចិត្ត ។ អែងដឹងច្បាស់ណាស់ ។ អញក៏ដឹងដែរ ។ *ដៃមីញ៉ូ* ម្នាក់ណាក៏ដឹង ។ សូម្បីតែលោកម្ចាស់តៃកូក៏ដឹងដែរ ។

- *យែនម៉ុន* មានអាយុប្រាំពីរឆ្នាំហើយ ។ ក្នុងប្រាំពីរឆ្នាំទៀត គេនឹងក្លាយទៅជាអគ្គទីប្រឹក្សាហើយ ។ ពីនេះទៅដល់រយៈពេលនោះ...

- គឺក្នុងរយៈពេលប្រាំបីឆ្នាំ លោកមេទ័ព*អ៊ីស៊ីដូ* ។ នេះគឺជាច្បាប់ជាប្រវត្តិរបស់នគរយើង ។ នៅពេលដែលក្មួយខ្ញុំអាយុបានដប់ប្រាំឆ្នាំហើយ វានឹងពេញវ័យ ហើយវានឹងទទួលស្នងអំនាចឪពុកវា . ក្នុងចន្លោះពេលនេះ សមាជិកទាំងប្រាំត្រូវដឹកនាំប្រទេសក្នុងនាម*យែនម៉ុន* ។ នេះគឺជាឆន្ទៈចុងក្រោយរបស់លោកម្ចាស់ ។

- ពិតហើយ ។ លោកម្ចាស់ថែមទាំងបញ្ជាហាមមិនអោយសមាជិកក្រុមប្រឹក្សាយកអ្នកណាជាចំនាប់ខ្មាំង ដើម្បីប្រឆាំងតទល់នឹងគ្នាឡើយ ។ លោកជំទាវ *អូជីបា* ដែលត្រូវជាម្តាយរបស់ទាយាទលោកម្ចាស់ អីលូវនេះជាចំនាប់ខ្មាំងនៅក្នុងបន្ទាយរបស់លោក ទៅងយេដូជាថ្នូរនឹងសន្តិសុខរបស់លោកនៅទីនេះ ។ នេះគឺជាការប្រឆាំងនឹងបណ្តាំរបស់លោកម្ចាស់ ។ លោកបានឯកភាពយល់ព្រមគោរពតាមកិច្ចសន្យានេះ ដូចជាសមាជិកក្រុមប្រឹក្សាឯទៀតដែរ ។ ហើយលោកថែមទាំងបានចុះហត្ថលេខាលើឯកសារនេះដោយឈាមលោកផ្ទាល់ថែមទៀតផង ។

*តូរ៉ាណាកា* ដកដង្ហើមធំ :



www.budinst.gov.kh www.elibraryofcambodia.org

-លោកជំទាវ *អូជីណា* បានទៅយេដូ ដើម្បីសួរសុខទុក្ខប្អូនស្រីតែមួយរបស់គាត់ដែលឆ្លងទន្លេ ។ ប្អូនស្រីរបស់លោកជំទាវ គឺជាប្រពន្ធរបស់កូនប្រុសខ្ញុំ ហើយដែលជាទាយាទរបស់ខ្ញុំទៅទៀត ។ នៅពេលដែលខ្ញុំនៅទីនេះ កូនប្រុសខ្ញុំមានភារកិច្ចនៅទទួលមើលកិច្ចការខុសត្រូវឯយេដូ ។ តើវាមានអីប្លែក ក្នុងរឿងដែលបងស្រីទៅសួរសុខទុក្ខប្អូនស្រីក្នុងស្ថានភាពនេះ ? នេះមិនតឹជាកិត្តិយសដ៏ធំធេងទេឬ ? ខ្ញុំប្រហែលជាបាន ចៅប្រុសដំបូងផងក៏មិនដឹង មិនថា អីចឹង ?

- លោកជំទាវ គឺជានារីដ៏សំខាន់បំផុតនៅក្នុងនគរ ។ លោកជំទាវមិនគួរស្ថិតនៅក្នុង... នៅក្នុង- *អ៊ីស៊ីដូ* ហៀបនិយាយថា " នៅក្នុងកណ្ដាប់ដៃខ្មាំង " ទៅហើយ ប៉ុន្តែលោកទប់មាត់ទាន់ -នៅក្នុងទីក្រុងមួយដែលលោកជំទាវមិនដែលធ្លាប់នៅនោះទេ

*អ៊ីស៊ីដូ* ឈប់មួយរយៈ រួចពោលបន្តទៀត :

- ក្រុមប្រឹក្សាមានបំនងអោយលោកចេញបញ្ជា អោយលោកជំទាវវិលត្រលប់មក *អូសាកា* វិញនៅថ្ងៃនេះ ។

*តូរ៉ាណាកា* វាងអន្ទាក់នេះ ដោយឆ្លើយឡើង :

- ខ្ញុំសូមនិយាយម្ដងទៀតថា លោកជំទាវ *អូជីណា* មិនមែនជាចំនាប់ខ្មាំងទេ ដោយហេតុនេះលោកជំទាវមិនមែនស្ថិតនៅក្រោមបញ្ជារបស់ខ្ញុំទេ ហើយតាំងពីដើមមកក៏មិនដែលដែរ ។

- បើអីចឹងខ្ញុំនិយាយតាមផ្លូវផ្សេងចុះ ។ តឹក្រុមប្រឹក្សាទាមទារអោយលោកជំទាវមានវត្តមាននៅទីនេះជាបន្ទាន់ ។

- អ្នកណាទាមទារ ?

- ខ្ញុំទាមទារ ។ អម្ចាស់ *ស៊ូគីយ៉ាម៉ា* អម្ចាស់ *អូណូស៊ី* អម្ចាស់តី *យ៉ាម៉ា* ក៏ទាមទារ ។ ពិសេសយើងបានឯកភាពគ្នាថា យើងនឹងនៅទីនេះទាំងអស់គ្នា រង់ចាំការវិលត្រលប់មកវិញរបស់លោកជំទាវ ។ នេះតឹជាហត្ថលេខារបស់យើងទាំងអស់គ្នា ។

*តូរ៉ាណាកា* ប្រែទឹកមុខស្នេកមួយរំពេច ។ តាំងពីដើមរៀងមកលោកតែងតែរៀបចំក្រុមប្រឹក្សា ដើម្បីធ្វើយ៉ាងណាអោយសំលេងឆ្នោតបែកបានពីរ រឺបីសំលេង ប៉ុន្តែលោកមិន



www.budinst.gov.kh www.elibraryofcambodia.org

ដែលបានជោគជ័យក្នុងការរកអោយបានគ្រប់សំលេងប្រឆាំងនឹង *អ៊ីស៊ីដូ* ឡើយ ។ *អ៊ីស៊ីដូ* ក៏អញ្ចឹងដែរ ។ បូនទល់មួយមានន័យថា ឯកោនិងមហន្តរាយ ។ ហេតុអីបានជា *អូណូស៊ី* ងាកទៅគាំទ្រ *អ៊ីស៊ីដូ* វិញអ៊ីចឹង ? រួចចុះ *តើយ៉ាម៉ា* ? គេទាំងពីរនាក់ គឺជាសត្រូវស្លាប់រស់នឹងគ្នាតាំងពីពេលគេចូលសាសនាបរទេស នេះម្ល៉េះ ។ រួចចុះតើ *អ៊ីស៊ីដូ* មានឥទ្ធិពលប៉ុនណាទៅលើពួកគេទាំងពីរនាក់នោះ ?

*អ៊ីស៊ីដូ* បានឃើញថាលោកបានបំបាក់គូសត្រូវរបស់ខ្លួនហើយ ។ ប៉ុន្តែលោកត្រូវដើរមួយជំហានទៀត ដើម្បីឈានទៅដល់ជ័យជំនះទាំងស្រុងបាន ។ ដោយហេតុនេះលោកចាប់ផ្តើមអនុវត្តផែនការមួយទៀត ដែលលោកបានឯកភាពគ្នាជាមួយ *អូណូស៊ី* ។

- ពួកយើងជាសមាជិកនៃក្រុមប្រឹក្សាទាំងអស់ បានឯកភាពគ្នាថា អីលូវនេះដល់ពេលហើយ ដែលយើងត្រូវតែចាត់ការអ្នកណាដែលមានផែនការដណ្តើមយកអំនាចរបស់លោក ម្ចាស់ហើយប៉ងសំលាប់ទាយាទលោកម្ចាស់នោះ ។ ជនក្បត់ត្រូវតែផ្តន្ទាទោស ។ ពួកវាត្រូវតែបណ្តើរអាក្រាសតាមផ្លូវជាមួយញាតិផៅប្រាំពីរសណ្តានរបស់ពួកវា ហើយពួកវានឹងត្រូវប្រហារជីវិតដូចជាពួកចោរប្លន់ធម្មតាជាមួយនឹងញាតិប្រាំពីរសណ្តានរបស់ពួកវានោះ ។ *តូជីម៉ូតូ តាកាស៊ីម៉ា* ត្រកូលទាប ត្រកូលខ្ពស់ គឺឥតមានលើកលែងទេ ។ សូម្បីតែ *មីណូវ៉ារ៉ា* ក៏ដោយ ។

ចរន្តកំហឹងបានរត់កាត់គ្រប់ពួក *សាមូរ៉ៃ* របស់ *តូរ៉ាណាកា* ដោយហេតុថា ការប្រមាថត្រកូលមួយដែលស្ទើរតែជាត្រកូលស្តេចដែរនោះ គឺជាទង្វើមួយដ៏ធ្ងន់ធ្ងរជាទីបំផុត ។ *សាមូរ៉ៃ អ៊ូសាគី* ដែលត្រូវជាចៅប្រុសារបស់ *តូរ៉ាណាកា* ស្ទុះក្រោកឈរឡើងទាំងមុខក្រហមងាំង ។ គេហូតដាវវែងរបស់គេឡើង ហើយស្ទុះទៅរក *អ៊ីស៊ីដូ* ត្រៀមនឹងកាត់ក្បាលរបស់មេទ័ពព្រហើននេះ ។

*អ៊ីស៊ីដូ* ឥតមានបញ្ចេញកាយវិការអ្វី ដើម្បីការពារខ្លួនឡើយ ។ លោកបានត្រៀមខ្លួនចំពោះយថាហេតុ នេះហើយជាស្រេច ។ អ្វីដែលកើតឡើងនៅពេលនេះ គឺលោកបានរៀបគំរោងហើយជាស្រេច ។ ហើយលោកបន់អោយតែហេតុការណ៍កើតឡើងតាមការ ស្មានរបស់លោកថែមទៀត ។ លោកបានបញ្ជាអោយមនុស្សរបស់លោក មិនលូកដៃធ្វើអន្តរាគមន៍អ្វីទាំង



www.budinst.gov.kh www.elibraryofcambodia.org

អស់ រហូតដល់ពេលលោកស្លាប់សិន ។ បើសិនជាខ្លួនលោក *អ៊ីស៊ីដូ* នេះត្រូវសំលាប់នៅកន្លែងនេះ ក្នុងពេលនេះដោយពួកសាមូរ៉ៃរបស់ *តូរ៉ាណាកា* កងទ័ពទាំងអស់ដែលនៅអូសាកានឹងមានសិទ្ធិរៃបុក ហើយសំលាប់ *តូរ៉ាណាកា* បានយ៉ាងងាយដោយឥតរវល់អ្វីទៀតពីរឿងអ្នកចំនាប់ខាំងឡើយ ។ ដល់អ៊ីចឹងទៅកូនរបស់ *តូរ៉ាណាកា* ច្បាស់ជាសំលាប់លោកជំទាវ *អូជីបា* ដើម្បីជាកិច្ចសងសឹក ហើយពេលនោះសមាជិកក្រុមប្រឹក្សាទាំងប៉ុន្មានច្បាស់ជារួមកំលាំងគ្នា ដើម្បីប្រឆាំងក្រុមយ៉ូស៊ី ដែលនឹងនៅឯកោ ហើយទីបំផុតនឹងត្រូវគេកំទេចចោល ។ នៅក្នុងករណីនេះទាយាទរបស់លោកម្ចាស់នឹងមានការធានាក្នុងការឡើងគ្រងអំនាច ហើយខ្លួនលោកបានបំពេញករណីយកិច្ចរបស់ខ្លួនយ៉ាងពេញលេញចំពោះលោកម្ចាស់ *រ៉ែកូ* ។

ប៉ុន្តែសន្ទុះដាវឥតវាត់មកសោះ ។ នៅនាទីចុងក្រោយនោះ *អ៊ូសាគី* បានទប់អារម្មណ៍ខ្លួនបាននឹងនរវិញ ហើយគេក៏ស៊កដាវទៅវិញទាំងញ័រទទ្រើត ។ គេក៏លុតជង្គង់ចុះយ៉ាងដាក់ខ្លួន ។

- សូមលោកម្ចាស់ *តូណារ៉ាកា* អភ័យទោសដល់ខ្ញុំបាទផង ។ ខ្ញុំបាទមិនអាចទ្រាំទ្រនូវការអាម៉ាស់ដោយ.......... ដោយសីពាក្យ......... ដោយគេពោលដាក់លោកម្ចាស់.............នូវ ពាក្យប្រមាថកាតទានយ៉ាងនេះបានទេ ។ ខ្ញុំបាទសូមលោកម្ចាស់អនុញ្ញាត អោយខ្ញុំបាទធ្វើ *សិប្បុកូ* ពេលនេះចុះ ដោយខ្ញុំបាទមិនអាចរស់ទ្រាំទ្រភាពអាម៉ាស់នេះបានទេ ។

ថ្វីត្បិតតែ *តូណារ៉ាកា* នៅស្ងៀមឥតកំរើក តែលោកត្រៀមជាស្រេច នឹងធ្វើអន្តរាគមន៍ដើម្បី គេចផ្លែដាវចេញ ហើយលោកក៏ដឹងដែរថា *ហ៊ីរូ-ម៉ាត់ស៊ី* និងអ្នកឯទៀត ក៏ត្រៀមនឹងធ្វើអន្តរាគមន៍ដូចគ្នានេះដែរ ហេតុនេះយ៉ាងច្រើនណាស់ *អ៊ីស៊ីដូ* ប្រហែលជានឹងមានរបួសតែប៉ុណ្ណោះ ។ លោកបានយល់ច្បាស់ណាស់ថា ហេតុអ្វីបានជាពេលនេះ អ៊ីស៊ីដូ មានរីកពារ និងសំដីព្រហើនហើយ មានលក្ខណៈបញ្ឆោះយ៉ាងនេះ ។ អញនឹងសងអ្វែងវិញនៅថ្ងៃក្រោយ អា *អ៊ីស៊ីដូ* ។ សងទាំងដើម សងទាំងការអោយធ្ងន់ជាមួយគ្នាតែម្តង- *តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។

*តូរ៉ាណាកា* បែរទៅរកយុវបុរស ។

- ហេតុអ្វីបានជាអ្វែងហ៊ានបកស្រាយសំដីលោកម្ចាស់ *អ៊ីស៊ីដូ* ថាជាការប្រមាថកាត



www.budinst.gov.kh www.elibraryofcambodia.org

ទានមកលើរូបខ្ញុំអីចឹង ។ អែងដឹងហើយថាលោកម្ចាស់ *អ៊ីស៊ិដូ* មិនមែនជាមនុស្សមិនដឹងច្បាប់ទំលាប់ឯណា ។ ហេតុអ្វីបានជាអែងហ៊ានស្ដាប់គេនិយាយពីរឿងមិនទាក់ទិនអ្វីដល់អែងសោះអីចឹង ។ យើងមិនព្រមអោយអែងធ្វើ *សិបពូគូ* ទេ ។ អោយអែងធ្វើ *សិបពូគូ* គឺជាកិត្តិយស ចំនែករូបអែងវិញ អែងគ្មានទាំងកិត្តិយសគ្មានទាំងស្ញ័យវិន័យ ។ អែងត្រូវដោតឆ្កាងនៅថ្ងៃនេះដូចពួកចោរបហារយអីចឹង។ ដាវរបស់អែងត្រូវតែបំបាក់ចោល ហើយយកទៅកប់នៅភូមិពូក *អេតា* ។ កូនប្រុសរបស់អែងក៏ត្រូវនៅក្នុងភូមិពូកអេតាដែរ ។ ក្បាលរបស់អែងនឹងត្រូវដោតលើអណ្ដោតទុកអោយអ្នកស្រុកមើលជាមួយនឹងប៉ាយដែលសរសេរថា " មនុស្សនេះច្រលំកើតមកជាសាមូរ៉ៃ ។ ឈ្មោះរបស់អែងវាលែងមានតទៅហើយ " ។

*អ៊ីសាគី* ប្រឹងទប់ដង្ហើមខ្លួនយ៉ាងញ័រចំប្រប់ ប៉ុន្តែញើសបានហូរចេញមកសស្រាក់ ហើយការខ្មាសអៀនបានមកទន្ទ្រានពេញដួងចិត្តរបស់គេ ។ យុវបុរសនេះ លំអោនខ្លួនស្ដាប់សំដីរបស់ *តូរ៉ាណាកា* ដែលកំនត់នូវវាសនារបស់ខ្លួន ក្នុងកាយវិការយ៉ាងស្ងាត់ស្ងៀម ។

*ហ៊ូរ៉ូ-ម៉ាត់ស៊ឺ* ដើរមកខាងមុខ ហើយកញ្ឆក់ហូតយកអាវុធទាំងពីរ ពីចង្កេះចៅប្រុសារបស់ខ្លួន រួចទើបពោលយ៉ាងម៉ឺងម៉ាត់ ទៅ *តូរ៉ាណាកា* :

- លោកម្ចាស់ *តូរ៉ាណាកា* ខ្ញុំសូមអនុញ្ញាតពីលោកម្ចាស់ អនុវត្តបញ្ជាលោកម្ចាស់នេះដោយផ្ទាល់ទាន ។

*តូរ៉ាណាកា* ងក់ក្បាល

យុវបុរស លំអោនខ្លួនគោរព *តូរ៉ាណាកា* ម្ដងទៀតជាលើកចុងក្រោយ រួចក៏ប្រុងប្រៀបក្រោកឈរឡើង ។ ប៉ុន្តែ *ហ៊ូរ៉ូ-ម៉ាត់ស៊ឺ* ជ្រមុជគេចុះវិញដោយពោលឡើង :

- ពួកសាមូរ៉ៃដើរ មនុស្សម្នាឯទៀតក៏ដើរដែរ ។ ប៉ុន្តែអ្ហែង មិនមែនជាសាមូរ៉ៃ ហើយក៏មិនមែនជាមនុស្ស ។ ហេតុនេះហើយអ្ហែងត្រូវវារទៅស្លាប់ទើបត្រូវ ។

អ៊ីសាគី ទទួលធ្វើតាមសំដី *ហ៊ូរ៉ូ-ម៉ាត់ស៊ឺ* យ៉ាងស្ងៀមស្ងាត់ឥតមានតបមួយម៉ឺនឡើយ ។

ថាមពលនៃស្ញ័យវិន័យ ហើយនិងទំហំនៃសេចក្ដីក្លាហាន របស់យុវបុរសនេះ ធ្វើអោយសាលទាំងមូល ប្រែជាមានភាពកក់ក្ដៅមួយរំពេច ។ វានឹងចាប់ជាតិជាសាមូរ៉ៃវិញ ជាមិនខាននេះគឺការគិតនៅក្នុងដួងចិត្តរបស់មនុស្សទាំងអស់គ្នា ដែលមានវត្តមាននៅក្នុងសាល ។



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ១៣

យប់នោះ *តូរ៉ាណាកា* សំរាន្តមិនលក់សោះតែម្តង ។ នេះគឺជាការកំរមួយ សំរាប់លោក ពីព្រោះធម្មតាលោករមែងលើកការងារបន្ទាន់បំផុតទុកសំរាប់ស្អែក ពីព្រោះលោកដឹងថា បើសិនជាលោកនៅរស់រានមានជីវិតរហូតដល់ថ្ងៃស្អែកនោះ លោកនឹងអាចដោះស្រាយវាបានយ៉ាងពេញសមត្ថភាពរបស់លោក ។ តាំងពីយូរយារណាស់មកហើយ លោកបានឃើញថាជំលោកយ៉ាងសុខស្រួល អាចផ្តល់ចំលើយបានចំពោះគ្រប់បញ្ហា ទោះស្មុគស្មាញយ៉ាងណាក្តី ។ ហើយបើដោះមិនរួចតើវាមានទៅសំខាន់អី ? ពីព្រោះជីវិតគ្រាន់តែជាតំនក់សន្សើមមួយតែប៉ុណ្ណោះ ។

ប៉ុន្តែនៅរាត្រីនេះ មានបញ្ហាចាក់ស្រេះជាច្រើន ដែលត្រូវពិចារណា ។

តើអញត្រូវធ្វើ យ៉ាងណាជាមួយ *អ៊ីស៊ីដូ* ?

ហេតុអ្វីបានជា *អ៊ីស៊ីដូ* ទៅចូលដៃជាមួយសត្រូវទៅវិញ ?

តើអញត្រូវប្រកាន់ជំហរយ៉ាងណា ជាមួយក្រុមប្រឹក្សា ?

តើពួកបព្វជិតគ្រិស្តសាសនិក បានចូលលូកលាន់ម្តងទៀតហើយរឺក៏អត់ ?

តើការប៉ុនប៉ងធ្វើឃាត នាពេលខាងមុខនឹងចេញមកពីខាងណា ?

តើគួរដោះស្រាយជាមួយ *យ៉ាប៊ូ*នៅពេលណា ?

តើបុរសចុងស្រុកនេះ និយាយការណ៍ពិតរឺទេ ?

ចំជាគួរអោយឆ្ងល់មែន ដែលបុរសចុងស្រុកនេះមកតាមសមុទ្រខាងកើតចំពេលនេះតែម្តង ។ តើវាជារបាលបិសាចទេដឹង ។ តើវាជា*កាម៉ា* ដែលនឹងដុតបំផ្លុះធុងរំសេវទេដឹង ?

*កាម៉ា* គឺជាពាក្យឥណ្ឌា ដែលជនជាតិជប៉ុនបានយកមកប្រើ ។ ជាផ្នែកមួយនៃទស្សនវិជ្ជាពុទ្ធសាសនា ដែលលើកឡើងពីវាសនាមនុស្សក្នុងជីវិតរស់នៅរបស់ខ្លួន ។ វាសនារបស់មនុស្សម្នាក់ៗ ត្រូវបានកំនត់ដោយសកម្មភាព ដែលគេបានធ្វើពីជាតិមុន ។ សកម្មភាពល្អ នឹងផ្តល់នូវតួនាទីល្អក្នុងជាតិនេះ ហើយសកម្មភាពអាក្រក់ នឹងផ្តល់តួនាទីមួយអាក្រក់ផងដែរ ។ ក៏ដូចជាទង្វើក្នុងជីវិតបច្ចុប្បន្ននេះ នឹងកំនត់ពីជាតិមុខផងដែរ ។ មនុស្សត្រូវកើតវិលវល់ក្នុងពិភព



www.budinst.gov.kh www.elibraryofcambodia.org

ទឹកភ្នែកនេះ រហូតដល់ពេលណាដែលគេបានឆ្លងកាត់ទុក្ខសោក និងការរៀនសូត្រច្រើនជាតិហើយ ទើបគេអាចឈានដល់និព្វាន ដែលលែងកើតទៀតបាន ។

ពិតជាការចំលែកមែនដែលព្រះសម្មាសម្ពុទ្ធជាម្ចាស វីព្រះអាទិទេពផ្សេង វីកាម៉ា បាននាំយក *អាន់ជីន-សាន* ទៅដល់ដែនដីរបស់ *យ៉ាប៊ូ* ។ ជាការចំលែកដែលបុរសនេះឡើងគោកចំភូមិរបស់ *អូរ៉ា* ប្រធានក្រុមបណ្តាញយកការណ៍តំបន់ *អ៊ីស៊ូ* ដែលបានទៅតាំងទីលំនៅ១ទីនោះកាលពីប៉ុន្មានឆ្នាំមុននេះដោយឥតធ្វើអោយ *វ៉ែតូ* និងអាស្វាយស៊ីដល់ឆ្អឹង *យ៉ាប៊ូ* នេះសង្ស័យបន្តិចណាសោះឡើយនេះទៅវិញ។ ជាការចំលែកដែល *ឈូតូ-សាន* មានមុខនៅ *អូសាកា*នេះដើម្បីបកប្រែ ព្រោះតាមចម្មតាគេនៅប្រចាំ ឯ *ណាកាសាគី*សោះ ។ មិនតែប៉ុណ្ណោះមានទាំងគណៈសង្ឃគ្រិស្តសាសនា ហើយនិងមេទ័ពធំ របស់ប៉កទុយកាល់ថែមទៀតផង ។ ជាការចំលែកថែមទៀតដែល *រ៉ូឌ្រិច* អាចដឹក *ហ្ស៊ី-ម៉ាត់ស៊ុ* ទៅកាន់ *អាន់ជីរ៉ូ* ទាន់ពេលវេលាដើម្បីចាប់មនុស្សនេះទាំងរស់ និងយកអាវុធទាំងអស់ជាវត្ថុរឹបបាន។ រួចវានៅមាន *កូស៊ីគី អូមី* នៅទីនោះទៀត ។ ឪពុករបស់ *អូមី* នឹងកាត់ក្បាល *យ៉ាប៊ូ*អោយអញភ្លាម បើសិនណាជាអញកំរើកកូនដៃអញតែបន្តិច ។

គិតទៅជីវិតមានសំរស់អស្ចារ្យមែន តែទន្ទឹមនេះវាក៏មានភាពគំសត់ស្រងេះស្រងោចណាស់ដែរ ។ គឺជាជីវិតដែលឆាបឆួលតែមួយភ្លែត គ្មានអតីតកាល គ្មានអនាគតកាល និងមានតែបច្ចុប្បន្នដ៏ស្ងើងល្ងើយ គ្មានព្រំដែនតែប៉ុណ្ណោះ ។

*តូរ៉ាណាកា* ដកដង្ហើមធំ ។ មានរឿងមួយដែលច្បាស់លាស់ នោះគឺបុរសចុងស្រុកនេះនឹងមិនត្រលប់ទៅវិញជាដាច់ខាត ។ ស្លាប់ក៏ដោយ រស់ក៏ដោយ ។ គេគឺជាចំនែកមួយនៃចក្រភពនេះរហូត ។

ត្រចៀករបស់លោកបានចាប់បានសូរជើងដើរ ដ៏ស្រាលសំដៅមករកបន្ទប់លោក ។ដាវរបស់លោកបានស្ថិតនៅក្នុងស្ថានភាពត្រៀមហើយស្រេច ។ រៀងរាល់យប់លោកតែងដូរបន្ទប់ដេក ដូរអ្នកយាម និងដូរពាក្យសំងាត់ ដើម្បីបង្ការពួកឃាតក ដែលតែងរង់ចាំឱកាសរបស់វា ។ សូរជើងឈប់នៅខាងក្រៅទ្វារ។ រួច *តូរ៉ាណាកា* លឺសូរសំលេងរបស់ *ហ្ស៊ី-ម៉ាត់ស៊ុ* ដែលចាប់



www.budinst.gov.kh www.elibraryofcambodia.org

ផ្ដើមដោយពាក្យសំងាត់ :

- បើសិនជាសច្ចធម៌លេចច្បាស់ហើយ ចាំបាច់ស្ទឹងស្មាធធ្វើអ្វីទៀត ?

*តូរ៉ាណាកា* តបវិញ :

- រួចចុះបើសច្ចធម៌ នៅលាក់កំបាំងនៅឡើយ ?

- សច្ចធម៌លេចចេញច្បាស់ហើយ ។

ចំលើយតបគឺត្រឹមត្រូវ ។ ពាក្យទាំងនេះត្រូវដកស្រង់ពីសំដីអាចារ្យពុទ្ធសាសនា*គង់ក្រា* ម្នាក់ នាម*សាក៊ិបៈ* ។

រហូតទាល់តែ *តូរ៉ាណាកា* ឃើញច្បាស់ថា ពិតជាទីប្រឹក្សារបស់លោកហើយ ទើបលោកលែងដាវរបស់លោក :

- អង្គុយចុះមក ។

- ខ្ញុំបាទលឺថា លោកម្ចាស់សំរាន្តមិនលក់ ហេតុនេះហើយទើបខ្ញុំបាទគិតថា លោកម្ចាស់ប្រហែលជាត្រូវការអ្វីហើយ ។

- អត់ទេ អរគុណលោក ។

*តូរ៉ាណាកា* សង្កេតឃើញស្នាមស្លក់ ដែលនៅតាមរង្វង់ភ្នែក របស់បុរសចំនាស់ ។ លោកនិយាយបន្ត :

- ខ្ញុំសប្បាយចិត្តណាស់ ដែលបានមិត្តចាស់មកសួរសុខទុក្ខយ៉ាងនេះ ។

- តើលោកម្ចាស់ច្បាស់ក្នុងចិត្តហើយថា លោកម្ចាស់មិនអីនោះ ?

- ច្បាស់ហើយ ។

- បើអីចឹង ខ្ញុំបាទសូមជំរាបលាលោកម្ចាស់សិនហើយ ។ ខ្ញុំបាទសូមអភ័យទោសដែលមករំខានលោកម្ចាស់ ។

- ទេ ! ទេ ! អង្គុយចុះមក ។ ខ្ញុំរីករាយណាស់ដែលលោកមកនេះ ។

បុរសចំនាស់ដាក់បង្គុយចុះក្បែរមាត់ទ្វារ ។

- ខ្ញុំបាទបានបន្ថែមអ្នកយាមរួចហើយទាន ។



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីនៅស្ងៀមមួយសន្ទុះ *ហ៊្សី-ម៉ាត់ស៊ី* បន្លឺឡើង .

- ពីរឿងអាចំកូតលុង អ្វីៗត្រូវបានធ្វើតាមបញ្ជារបស់លោកម្ចាស់ សព្វគ្រប់ហើយ ។ អ្វីៗទាំងអស់ ។

- អរគុណ ។

- ប្រពន្ធរបស់វា ........ ចៅស្រីរបស់ខ្ញុំបាទនោះ នៅពេលដែលលឺអាថ្វានោះ បានមកសុំខ្ញុំបាទ អោយអនុញ្ញាតអោយវាសំលាប់ខ្លួន តាមប្តីវា និងកូនវា ។ ខ្ញុំបាទ បានប្រកែកដោយប្រាប់វាអោយរង់ចាំសិន ដើម្បីសុំការអនុញ្ញាតពីលោកម្ចាស់ ។

បេះដូង ប្រមាត់របស់ *ហ៊្សី-ម៉ាត់ស៊ី* កំពុងរបេះរបោច នៅក្នុងពេលដែលលោកនិយាយទៅកាន់ *តូរ៉ាណាកា* ។ ឱជីវិត ! អីក៏ខ្លោចផ្សាម្ល៉េះ !

- លោកធ្វើនេះ ត្រឹមត្រូវហើយ ។

- ខ្ញុំបាទ ក៏សូមបញ្ចប់ជីវិតខ្ញុំបាទត្រឹមនេះចុះដែរទាន ។ អ្វីដែលវាបានធ្វើនាំអោយលោកម្ចាស់ មានគ្រោះថ្នាក់ដល់ជីវិត ប៉ុន្តែនេះ ក៏ជាកំហុសរបស់ខ្ញុំដែរ ។ ខ្ញុំបាទគួរតែស្គាល់ដឹងពីចរិតរបស់វា តែផ្ទុយទៅវិញ ខ្ញុំបាទធ្វើអោយលោកម្ចាស់ខកចិត្តស្រលះ ។

- លោកមិនអាចធ្វើ *សិបពូគូ* បានទេ ។

- សូមលោកម្ចាស់ អនុញ្ញាតអោយខ្ញុំបាទផងចុះទាន ។

- ទេ លោកនៅរស់មានផលប្រយោជន៍ជាង ។

- ខ្ញុំបាទ ទទួលគោរពតាមបញ្ជារបស់លោកម្ចាស់ ប៉ុន្តែសូមលោកម្ចាស់អភ័យទោសដល់ខ្ញុំបាទផងទាន ។

- ខ្ញុំលើកលែងហើយ ។

មួយស្របក់ក្រោយមក *តូរ៉ាណាកា* សួរឡើង :

- រឿងមនុស្សចុងស្រុកនោះ តើលោកយល់យ៉ាងណាដែរ ?

- មានចំនុចច្រើនណាស់ទាន ។ ទីមួយ : បើសិនជាថ្ងៃនេះលោកម្ចាស់មិននៅរង់ចាំអា



www.budinst.gov.kh www.elibraryofcambodia.org

មនុស្សចុងស្រុកនេះទេនោះ លោកម្ចាស់ច្បាស់ជាទៅបណ្ដើរស្ទាំងតាំងពីក្លឹបល្ខោន១ម្ល៉េះទៅហើយ។ *អ៊ីស៊ុីដូ* ពិតជាមិនអាចបំបាក់មុខលោកម្ចាស់ នៅក្នុងជំនួបដ៏ល្អើមនេះបានដែរ ។ ពេលនេះលោកម្ចាស់គ្មានជំរើសអ្វីក្រៅពី ប្រកាសសង្គ្រាមនឹងវាទេ នេះបើសិនជាលោកម្ចាស់អាចចេញផុតពីវិមាននេះ ត្រលប់ទៅដល់*រយេដូ*វិញ ។

- រួចចុះទីពីរ ?

- និងទីបី ទីសែសិបបី និងទីមួយរយសែសិបបី ខ្ញុំបាទមិនឆ្លាតឆ្លៃដូចលោកម្ចាស់ទេទាន ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ខ្ញុំបាទអាចមើលឃើញថា អ្វី១ដែលពួកចុងស្រុកភាគខាងត្បូង បានធ្វើអោយយើងជឿតាមនោះមិនមែនជាការពិតទេ ។

ពេលនេះ *ហ៊ូរ៉ូ-ម៉ាត់ស៊ុី* សប្បាយចិត្តណាស់ ដែលខ្លួនលោកបាននិយាយ ព្រោះវាជួយបន្ថយនូវការឈឺចាប់ ដែលកំពុងបេះបោចថ្លើមប្រមាត់របស់លោក ។ លោកបន្តទៀត :

- ប៉ុន្តែបើសិនជាមានគ្រិស្តសាសនាពីរ ដែលស្អប់គ្នាទូនគ្នាមែន ហើយបើសិនជាប្រទេសប៉ិកទុយកាល់ ជាផ្នែកមួយនៃប្រទេសអេស្ប៉ាញដែលធំជាង ហើយបើសិនជាប្រទេសរបស់បុរសចុងស្រុកនេះ ទោះជាមានឈ្មោះស្អីក៏ដោយ តែក៏ជាប្រទេសនោះដូចយើង ហើយធ្វើសង្គ្រាមប្រឆាំងប្រទេសទាំងពីរ ហើយឈ្នះមែននោះ ហើយនឹងអារឿង " បើ " ដែលសំខាន់ជាងគេបំផុតនោះគឺថា បើបុរសចុងស្រុកនេះនិយាយការពិត ហើយបព្វជិតនោះ បកបានត្រឹមត្រូវនោះ ....... ខ្ញុំបាទគិតថា លោកម្ចាស់ពិតជាអាចបូកបញ្ចូលអារឿង "បើ " ទាំងអស់នេះជាមួយគ្នា ដើម្បីឃើញសារជាតិវា និងលើកផែនការបានជាមិនខាន ។ ចំពោះខ្ញុំបាទវិញ ខ្ញុំបាទមិនអាចទៅរួចទេ សូមលោកម្ចាស់អធ្យាស្រ័យ ។ ខ្ញុំបាទ ជឿតែតាមភ្នែកខ្ញុំបាទដែលបានឃើញនៅឯ *អាន់ជីរ* និងនៅលើទូកធំតែប៉ុណ្ណោះទាន ។ គឺ *អាន់ជីន-សាន* ជាមនុស្សមានខួរក្បាល ពោរពេញដោយថាមពល ថ្វីបើរាងកាយវាខ្សោយក្តី ប៉ុន្តែអារឿងខ្សោយនេះទៀត ក៏ប្រហែលអាចមកពីការធ្វើដំណើរផ្លូវឆ្ងាយ ក៏មិនដឹង ។ ហើយវានោះ គឺជាស្តេចសមុទ្រតែម្តង ។ ខ្ញុំបាទអត់យល់អំពីរឿងនេះទេ ។ ហេតុអីបានជាវាជាមនុស្សមួយប៉ុណ្ណោះដែរ តែសុខចិត្តអោយគេបាញ់នោមដាក់កណ្តាលខ្នងអីចឹង ? ហេតុអ្វីបានជាវាទៅជួយជីវិត *យ៉ាប៊ូ* ដែលកន្ទួងមកធ្វើអាក្រក់ដាក់វាអីចឹង ?



www.budinst.gov.kh www.elibraryofcambodia.org

រួចម៉េចបានជាវាទៅជួយសង្គ្រោះអា *រ៉ូប៊ែច* ដែលជាជាតិ ប៉ិកទុយកាល់ សត្រូវរបស់វាទៅវិញ ? រួចក្បាលខ្ញុំបានឡើងក្រលកធាតុ ដូចស្រវឹងស្រាសាកេទៅហើយ ដើម្បីគ្រាន់តែពិចារណាពីស័ខ្ទរទាំងប៉ុន្មាននេះ ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* បង្អង់មួយរយៈ ។ លោកមានអារម្មណ៍ថា ខ្លួនលោកហេវហត់យ៉ាងខ្លាំង ៖

- ប៉ុន្តែខ្ញុំបាទគិតថា យើងគួរតែឃាត់ទុកវាអោយនៅលើដីគោកទៅ ។ ទាំងវា ទាំងពួកគ្នាវា បើសិនជាមានពួកវាមកតាម ។ ហើយសំលាប់ពួកវា កាន់តែឆាប់ពេលណាកាន់តែល្អពេលនោះ ។

- ចុះរឿង *យ៉ាប៊ូ* តើត្រូវគិតយ៉ាងម៉េចទៅវិញ ?

- បញ្ជាអោយវាធ្វើ*សិបពុគូ* យប់នេះតែម្តងទៅទាន ។

- ហេតុអី ?

- វាគ្មានច្បាប់ គ្មានទំលាប់អីសោះតែម្តង ។ លោកម្ចាស់បានទាយទុកជាមុនស្រេចទៅហើយថា តើវានឹងធ្វើអ្វី នៅពេលដែលទៅដល់ *អាន់ជិរ៉ូ* ។ ពេលនោះ វាហៀបតែនឹងលួចកម្មសិទ្ធិរបស់លោកម្ចាស់ទៅហើយ ។ រួចម្យ៉ាងទៀតអានេះកុហកំឈ្មុយតែម្តង ។ ស្អែកនេះ សូមលោកម្ចាស់កុំទទួលអោយវាជួបតាមការកំនត់អោយសោះទាន ។ សូមលោកម្ចាស់ចេញបញ្ជាអោយខ្ញុំបានចាត់ការវាអីលូវនេះទៅទាន។ យូរីឆាប់លោកម្ចាស់ ក៏គង់តែត្រូវសំលាប់វា ហេតុនេះល្អបំផុតត្រូវចាត់ការនៅទីនេះតែម្តង ព្រោះនៅទីនេះ វាគ្មានអណ្តាប់ណាម្នាក់នៅជិតវាទេ។ ខ្ញុំម្ចាស់ស្នើលោកម្ចាស់ កុំទុកអោយឱកាសល្អកន្លងទៅផុត ទាន ។

ស្នូរគោះទ្វារយ៉ាងស្រាល បានលាន់លឺឡើងនៅមាត់ទ្វារ ។

- *គូរ៉ាចាន់* ?

*គូរ៉ាណាកា* ញញឹមដូចតែសព្វដង ដែលគេបានលឺសំលេងពិសេសនេះ ។

- មានការអី *គីរី-សាន* ?

- ខ្ញុំសូមលោកម្ចាស់អភ័យទោស ដែលហ៊ានលើកតែមកដោយមិនបានសួរលោកម្ចាស់ជាមុន ។ តើខ្ញុំអាចចូលបានទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- បាទ បាន !

ទាំងពីរនាក់ លំអោនខ្លួនគោរពគបលោកស្រីវិញ ។ *គីរីស*ទទ្វារបន្ទប់ហើយរៀបចំចាក់តែ។ លោកស្រីមានអាយុហាសិបបីឆ្នាំ តែនៅមាំទាំនៅឡើយ ។ នៅពេលដែល *តូរ៉ាណាកា* បានអាយុប្រហែលម្ភៃឆ្នាំ លោកគឺជាចំនាប់ខ្មាំងរបស់ជនផ្ដាច់ការ *អ៊ីកាវ៉ា* ដែលជាម្ចាស់ខេត្ត *ស៊ូរុក*និង *តូតូមី* ហើយដែលត្រូវជាឪពុករបស់ *អ៊ីកាវ៉ាស៊ីគីយូ* សត្រូវរបស់ *យ៉ាប៊ូ* នាពេលបច្ចុប្បន្ននេះ ។សាមូរ៉ៃដែលទទួលបង្ហាញបែបបទរស់នៅដល់ *តូរ៉ាណាកា* នោះ ទើបបានយក *គីរីស៊ូបូ* ជាប្រពន្ធទីពីររបស់ខ្លួន ។ កាលនោះលោកស្រីមានអាយុដប់ប្រាំពីរឆ្នាំ ។ ទាំងសាមូរ៉ៃនោះ ទាំងអ្នកស្រី *គីរី*បានថែទាំ *តូរ៉ាណាកា*យ៉ាងយកចិត្តទុកដាក់ ព្រមទាំងផ្ដល់នូវដំបូន្មានល្អៗ ហើយនៅពេលដែល *តូរ៉ាណាកា* បានបះបោរប្រឆាំងនឹង *កាដ៉ាសាគី* ដោយបានទៅចូលរួមជាមួយ *គូរ៉ូដា* នោះអ្នកទាំងពីរបាននាំមនុស្សជាច្រើនទៅចូលរួមជាមួយនឹងលោក ហើយបានធ្វើសឹកយ៉ាងអង់អាចជាមួយ *តូរ៉ាណាកា*។ ក្រោយមកទៀតនៅក្នុងការប្រយុទ្ធដណ្ដើម យកទីក្រុងប្ដីរបស់អ្នកស្រី *គីរី*បានទទួលមរណភាពទៅ។ *តូរ៉ាណាកា* បានស្នើមតិអ្នកស្រី សូមអោយធ្វើជាប្រពន្ធចុងរបស់ខ្លួន ហើយអ្នកស្រីបានទទួលយល់ព្រមយ៉ាងស្ម័គ្រស្មោះ។ កាលនោះអ្នកស្រី អាយុដប់ប្រាំបួនឆ្នាំ *តូរ៉ាណាកា* អាយុម្ភៃបួន ។ ចាប់តាំងពីពេលនោះមក អ្នកស្រីគឺជាអ្នកចាត់ចែងការងារមេផ្ទះ នៅក្នុងវិមានរបស់ *តូរ៉ាណាកា* រហូតមក ។

អ្នកស្រីហុចពែងតែ ទៅអ្នកទាំងពីរ :

- នេះតែ ។ អីលូវនេះ ខ្ញុំចេញទៅវិញហើយ ។ តើលោកម្ចាស់ត្រូវការអោយខ្ញុំប្រាប់អ្នកនាង *សាស៊ូកូ*មកកំដរលោកម្ចាស់ទេ ?

- ទេ អរគុណច្រើនណាស់ ដែល *គីរី-សាន* គិតគូរដល់រូបខ្ញុំជាប់យ៉ាងនេះ ។ ពួកយើងនិយាយគ្នាបន្តិច ។ រួចហើយចូលគេងហើយ ។

- សូមគោរព *តូរ៉ា-សាម៉ា* ។

អ្នកស្រីលំអោនគោរព *តូរ៉ាណាកា* និង *ប៊្លូ-ម៉ាត់ស៊ឺ* ហើយចេញពីបន្ទប់ទៅ ។

អ្នកទាំងពីរគ្រេបតែយ៉ាងស្ងៀមស្ងាត់មួយសន្ទុះ ទើប *តូរ៉ាណាកា* ពោលឡើង :



www.budinst.gov.kh www.elibraryofcambodia.org

- រាល់ពេល ខ្ញុំស្តាយត្រង់តែរវាងខ្ញុំ នឹង *គិរិ-សាទ* គ្មានកូនប្រុសមួយគ្រាប់នឹងគេសោះតែប៉ុណ្ណោះ ។ គេហ៊ានទំងន់ម្តងដែរ តែរលូតបាត់ទៅ កាលនោះគឺកំពុងច្បាំងទៅ *ណាកាតូដេ* ។

- អូ ចំបាំងនោះអ្វី ?

- មែនហើយ ។

កាលនោះ គឺជាពេលបន្ទាប់ដែលមេផ្កាធំការ *ក្លូដេ*ត្រូវគេធ្វើឃាត ហើយជាពេលដែលមេទ័ព*ណាកាមូរ៉ា* អនាគត *រ៉ែកូ*កំពុងតែប្រឹងប្រែងក្តាប់អំនាចទាំងមូល ។ នាពេលនោះគឺជារយៈពេលនៃភាពមិនច្បាស់លាស់ដោយ *តូរ៉ាណាកា* ជាអ្នកគាំទ្រកូនប្រុសម្នាក់របស់ *ក្លូដេ* ដែលត្រូវឡើងស្នងឪពុកនោះ ។ ទ័ពរបស់ *ណាកាមូរ៉ា* បានប៉ះទង្គិចនឹងទ័ពរបស់ *តូរ៉ាណាកា* នៅក្បែរកូនភូមិមួយ ក្នុងតំបន់ *ណាកាតូដេ* ហើយទ័ពរបស់លោក *ណាកាមូរ៉ា* ត្រូវខូចខាត ហើយទទួលបរាជ័យទៅ ។ ប៉ុន្តែ *តូរ៉ាណាកា* បានដកទ័ពយ៉ាងឈ្លាសវៃដោយទ័ពជំនួយថ្មីដែលដឹកនាំដោយ *ហ៊ីរ៉ូ-ម៉ាត់ស៊ី*មកដល់ ។ នៅក្នុងសមរភូមិណាកាតូដេនេះ មានមនុស្សជាងប្រាំម៉ឺននាក់បានបាត់បង់ជីវិតក្នុងនោះមានមនុស្សរបស់ *តូរ៉ាណាកា* តែបន្តិចបន្តួចប៉ុណ្ណោះ ។ *តូរ៉ាណាកា* បាននាំទ័ពស្ទើរតែគ្មានខិតអ្វីទាំងអស់យកទៅខេត្តកំណើតរបស់លោក ដើម្បីត្រៀមធ្វើការប្រយុទ្ធជាថ្មី ។ *ណាកាតូដេ* គឺជាសមរភូមិតែមួយដែល *ណាកាមូរ៉ា* បានទទួលបរាជ័យ ហើយ *តូរ៉ាណាកា* ជាមេទ័ពតែមួយគត់ ដែលឈ្នះលើលោកបាន ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ី* និយាយឡើង :

- ខ្ញុំបាទ រីករាយណាស់ ដែលយើងមិនបានប៉ះគ្នាលើសមរភូមិ ។

- ពិតហើយ ។

- បើប៉ះពេលនោះ លោកម្ចាស់ពិតជាឈ្នះ ។

- ទេ ។ អម្ចាស់ *រ៉ែកូ* គឺជាមេទ័ព ដ៏មហិមា ដ៏វាងវៃ និងដ៏កំពូលបំផុត មិនដែលមាន ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ី* ញញឹម :

- ពិតមែនទាន លើកលែងតែលោកម្ចាស់ចេញ ។

- ទេ លោកច្រលំហើយ ។ ព្រោះតែខ្ញុំមិនអាចស្មើនឹងគាត់ទើបខ្ញុំក្លាយជាអណ្តាប់គាត់ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំស្តាយណាស់ ដែលគាត់បានទទួលមរណភាពទៅ ។

- ពិតហើយ ។

- ហើយ *ក្លូដោ* គាត់ជាមនុស្សល្អមួយដែរមែនទេ ? អីលូវនេះមនុស្សល្អជាច្រើនបានលាចាកលោកទៅហើយ ។

ដោយសភាវគតិ *ហ៊្វូ-ម៉ាត់ស៊ឺ* បង្វិលដាវរបស់ខ្លួន ហើយពោលបន្ត :

- លោកម្ចាស់ត្រូវចាត់ការ *អ៊ីស៊ីដូ* ហើយ ។ លោកម្ចាស់ធ្វើយ៉ាងនេះ នឹងបង្ខំពួក *ដៃមីញ៉ូ* ទាំងអស់អោយជ្រើសរើសថា តើពួកគេនៅខាងណា ។ ធ្វើយ៉ាងនេះបានវាដាច់ស្រេចទាន ។ ទោះជាយ៉ាងម៉េចយ៉ាងម៉ា ក៏យើងច្បាស់ជាឈ្នះសង្គ្រាមដែរ ។ ដល់ពេលនោះលោកម្ចាស់អាចរំសាយក្រុមប្រឹក្សា ហើយឡើងជាអគ្គមហាសេនាបានហើយទាន ។

*តូរ៉ាណាកា* ឆ្លើយតបយ៉ាងកំបុតកំបុយ :

- ខ្ញុំឥតស្វះស្វែងចង់បានកិត្តិយសនេះទេ ខ្ញុំបានប្រាប់លោកប៉ុន្មានសិបដងហើយតើ ?

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំបាទផងចុះទាន ។ខ្ញុំបាទដឹងហើយ ប៉ុន្តែរឿងនេះគឺពិតជាល្អសំរាប់ប្រទេសជប៉ុនទាំងមូលទាន ។

- នេះជាអំពើក្បត់ណា !

- ក្បត់អ្នកណា ? ក្បត់អម្ចាស់ *តៃកូ* ? គាត់ស្លាប់បាត់ទៅហើយ ។ ក្បត់នឹងបណ្តាំរបស់គាត់អ្វី? នេះគឺជាក្រដាសម៉ាសន្លឹកតែប៉ុណ្ណោះ ។ ក្បត់នឹង *យ៉ែទម៉ុទ* ដែលជាកូនក្មេងណឹង ? *យ៉ែទម៉ុទ*គឺជាកូនរបស់អ្នកស្រែម្នាក់ដែលបានជ្រែកអំនាចនិងមរតករបស់មេទ័ពម្នាក់តែប៉ុណ្ណោះ ។តាមពិតនេះត្រូវតែជាមរតករបស់ *ក្លូដោ* ទេតើ ។ ពិតហើយយើងធ្លាប់ជាសម្ព័ន្ធមិត្តរបស់ *ក្លូដោ* បន្ទាប់មកជាអណ្តាប់ *តៃកូ* ។ ប៉ុន្តែ អីលូវនេះអ្នកទាំងពីរស្លាប់បាត់ទៅហើយ ។

-បើសិនជាលោកជាសមាជិកម្នាក់នៃក្រុមប្រឹក្សាតើលោកនឹងមានយោបល់ដូចនេះទេ?

- ទេ ។ តែអីលូវនេះខ្ញុំបាទមិនមែនជាសមាជិកនៃក្រុមប្រឹក្សាឯណា ហើយខ្ញុំរីករាយណាស់ ។ អីលូវនេះខ្ញុំជាអណ្តាប់របស់លោកម្ចាស់តែប៉ុណ្ណោះ ។ ខ្ញុំបាទជ្រើសរើសផ្លូវរបស់ខ្ញុំបាទតាំងពីឆ្នាំទៅម្ល៉េះ ហើយខ្ញុំជ្រើសរើសនេះដោយស្ម័គ្រចិត្តឥតមានអ្នកណាបង្ខំខ្ញុំបាទទេទាន ។



www.budinst.gov.kh www.elibraryofcambodia.org

- ហេតុអី ?

សំនួរនេះ *តូរ៉ាណាកា* ឥតដែលបានសួរ *ហ្សិ-ម៉ាត់ស៊ុ* ម្តងណាឡើយពីមុនមក ។

- ពីព្រោះលោកម្ចាស់គឺជាកូនប្រុសដើមទ្រូងប្រាំហត្ថ ។ ពីព្រោះលោកម្ចាស់គឺជាក្រសែ *មីណូវ៉ាវ៉ា*ពីព្រោះលោកម្ចាស់ធ្វើការអ្វីដោយវាងវៃ ។អ្វីដែលលោកម្ចាស់បានពោលទៅកាន់ *អ៊ីស៊ីដូ* គឺត្រឹមត្រូវណាស់ : យើងមិនមែនជាប្រជាជនមួយដែលត្រូវដឹកនាំដោយគណៈកម្មាធិការនោះទេ ។ យើងត្រូវការអ្នកដឹកនាំម្នាក់ ។ ក្នុងចំនោមសមាជិកក្រុមប្រឹក្សាអាជ្ញានុសិទ្ធិទាំងប្រាំ តើខ្ញុំបាទត្រូវចុះចូលជាមួយអ្នកណា ? ជាមួយលោកម្ចាស់ *អូណូស៊ី* អ្វី ? ពិតហើយគាត់ជាមនុស្សវាងវៃ ហើយក៏ ជាមេទ័ពពូកែមួយ ប៉ុន្តែគាត់កាន់គ្រិស្តសាសនា អាយុគាត់ក៏ច្រើនណាស់ទៅហើយ ។ឃ្លង់ស៊ី ឡើងស្កុយ ហាសិបព្យាមជុំវិញខ្លួនទៅហើយ ។ ជាមួយលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* អ្វី ? គាត់គឺជា *ដៃមីញ៉ូ* ដ៏មានសម្បត្តិស្តុកស្តម្ភជាងគេបំផុតក្នុងប្រទេសនេះ ហើយក្រសែគាត់ក៏មានតាំងពីយូរយារមកហើយ ដូចក្រសែលោកម្ចាស់ដែរ ។ ប៉ុន្តែគាត់នេះជាមនុស្សរេតាមខ្យល់គ្មានសេចក្តីក្លាហានក្នុងខ្លួនបន្តិចណាសោះឡើយ ។ ហើយទាំងលោកម្ចាស់ ទាំងខ្ញុំបាទសុទ្ធតែដឹងពីមនុស្សនោះយ៉ាងច្បាស់ណាស់មកហើយ ។ លោកម្ចាស់ *គីយ៉ាម៉ា* ? គាត់ជាមនុស្សវាងវៃ ក្លាហានជាមេទ័ពពូកែ ហើយជាមិត្តចាស់ផង ។ ប៉ុន្តែគាត់ក៏ជាគ្រិស្តសាសនិកដែរ ហើយខ្ញុំបាទគិតថា នៅស្រុកយើងមានព្រះ មានទេវតាសំបូរហូរហៀរមិនចាំបាច់អីទៅធ្វើឈ្លើយគោរពតែព្រះមួយនោះទេ ។ *អ៊ីស៊ីដូ* ? ខ្ញុំបាទស្អប់អាអ្នកស្រែអត់ពូជ មេក្បត់នេះតាំងពីខ្ញុំបាទចាប់ស្គាល់វាតាំងពីដំបូងដៃម្ល៉េះ តែហេតុដែលខ្ញុំមិនសំលាប់វា គឺដោយសារវាជាឆ្កែរបស់អម្ចាស់ *តៃកូ* តែប៉ុណ្ណោះឯង ។

ទឹកមុខជ្រីវជ្រួញរបស់ *ហ្សិ-ម៉ាត់ស៊ុ* ឡើងញញឹមពព្រាយ :

- ដោយហេតុនេះទើបខ្ញុំបាទគ្មានជំរើសទៀតទេលោកម្ចាស់ *តូរ៉ាណាកា-ណូមីវ៉ាវ៉ា* ។

- រួចចុះបើខ្ញុំមិនធ្វើតាមមតិលោកវិញ ? រួចចុះបើសិនជាខ្ញុំញាក់ក្រុមប្រឹក្សា ញាក់ទាំង *អ៊ីស៊ីដូ* ហើយលើក *យែនមុំន* អោយឡើងកាន់អំនាចវិញ ?

- អ្វីដែលលោកម្ចាស់ធ្វើគឺត្រឹមត្រូវ និងវាងវៃទាំងអស់ ។ ប៉ុន្តែក្រុមប្រឹក្សាទាំងមូលគេចង់ឃើញលោកស្លាប់ណា ។ នេះគឺជាការពិត ។ ខ្ញុំបាទគាំទ្រគំនិតប្រកាសសង្គ្រាមភ្លាមទាន ។



www.budinst.gov.kh www.elibraryofcambodia.org

ភ្ញាម១នេះតែម្តង ។ មុនពួកគេអាចឯកោលោកម្ចាស់បានរឹអ្វីដែលច្បាស់ប្រាកដគឺមុនពេលដែលគេសំលាប់លោកម្ចាស់បាន ។

*គូរ៉ាណាកា*រំពឹងគិតពីសត្រូវរបស់លោក ។ សត្រូវលោកមានច្រើនហើយពួកគេសុទ្ធសឹងតែជាអ្នកមានវិទ្ធានុភាពទៀតផង ។

ដើម្បីត្រលប់ទៅដល់*យេដូ*វិញ លោកត្រូវចំនាយពេលបីអាទិត្យដោយធ្វើដំណើរតាមផ្លូវ*តូកៃដូ* ដែលសៀវតាមបណ្តោយឆ្នេរ ហើយដែលភ្ជាប់ទីក្រុង*អូសាកា* ទៅនឹងទីក្រុង*យេដូ*នេះ ។ យើងទៅតាមផ្លូវទឹកក៏រឹតតែមានគ្រោះថ្នាក់ ហើយនឹងចំនាយពេលកាន់តែច្រើនទៀត លើកលែង តែប្រើកេត្រាដែលរត់បញ្ច្រាសទឹក បញ្ច្រាសខ្យល់បាន ។

ខួរក្បាលរបស់ *គូរ៉ាណាកា*រំលឹកឡើងវិញពីផែនការ ដែលលោកបានគ្រោងឡើង :

- ខ្ញុំបានលឺជាសំងាត់កាលពីម្សិលនេះថា ម្តាយរបស់*អ៊ីស៊ីដូ* បានទៅលេងចៅរបស់គាត់នៅឯ *ណាកូយ៉ា* ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ី* ផ្តោតអារម្មណ៍យកចិត្តទុកដាក់ភ្លាម ។ *ណាកូយ៉ា*គឺជាទីក្រុងរដ្ឋមួយដ៏ធំ ហើយដែលមកទល់ពេលនេះឥតមានចុះចូលនឹងក្រុមណាមួយនៅឡើយទេ ។

*គូរ៉ាណាកា*និយាយបន្ត :

- គួរតែលោកតាមេវត្ត " អញ្ជើញ " លោកស្រីទៅមើលដើមសើរីចេញផ្កានៅឯវត្ត*យ៉ូជី*ផងដែរ ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ី*បន្ទរឡើង

- បាទ ។ អញ្ជើញភ្លាមនេះ ។ ខ្ញុំបាទ បញ្ជូនព្រាបនាំសារទៅ ។

វត្ត*យ៉ូជី*ល្បីល្បាញដោយសារបីចំនុច ។ ទីមួយ គឺរុក្ខវិថី ដែលអមដោយដើមសើរី ទីពីរ ប្រកាន់ខ្ជាប់វិន័យព្រះពុទ្ធសាសនា និកាយសេន និងទីបី គឺភក្តីភាពយ៉ាងខ្ជាប់ខ្ជួនចំពោះ*គូរ៉ាណាកា* ដែលកាលពីប៉ុន្មានឆ្នាំមុននេះ បានសាងវិហារនេះឡើង ។

- ផ្កាប្រហែលជាមិននៅក្រពុំទៀតទេ ប៉ុន្តែលោកស្រី នឹងទៅដល់ទីនោះនៅថ្ងៃស្អែក ។ ខ្ញុំបាទជឿថា លោកស្រីពិតជាចង់ស្នាក់នៅទីនោះ ពីរបីថ្ងៃជាមិនខានពីព្រោះកន្លែងនោះស្ងប់ស្ងាត់



www.budinst.gov.kh www.elibraryofcambodia.org

ល្អណាស់ ។ ចៅប្រុសរបស់គាត់ ត្រូវទៅកន្លែងនោះដែរីលោកម្ចាស់ ?

-. ទេ ! តែគាត់ម្នាក់បានហើយ ។ កុំអោយគេមើលឃើញថា "ការអញ្ជើញ"របស់លោក តាមេវត្ត វាចេញក្រឡាសាពេក ។ រឿងមួយទៀតបន្ទាប់ពីនេះ គឺផ្ញើសារពាក្យសំងាត់ទៅ *ស៊ូងារ៉ា* កូនរបស់ខ្ញុំ ប្រាប់ថាខ្ញុំនឹងចេញពី *អូសាកា*នៅពេលដែលក្រុមប្រឹក្សាបញ្ចប់សម័យប្រជុំនេះ គឺនៅ បួនថ្ងៃទៀត ។ផ្ញើសារនេះតាមនីរសារទៅហើយស្អែកផ្ញើសារបញ្ជាក់ទៀតតាមព្រាបនាំសារទៅ។

*ហ៊ីរូ-ម៉ាត់ស៊ី* បង្ហាញទឹកមុខ មិនឯកភាពភ្លាម :

- រួចហើយតើខ្ញុំបាទ អាចបញ្ជាអោយនាំទ័ពមួយម៉ឺននាក់មក *អូសាកា* ទេទាន ?

- ទេ មនុស្សនៅទីនេះគ្រប់គ្រាន់ហើយ ។ សូមអរគុណ ។ ខ្ញុំគិតចង់រកដេកពួនហើយ អីលូវនេះ ។

*ហ៊ីរូ-ម៉ាត់ស៊ី* ក្រោកឡើង ហើយពត់ដៃជើង ។ នៅពេលទៅដល់មាត់ទ្វារ លោកក៏ងាក បែរមកសួរ *តូរ៉ាណាហ្គា* :

- តើខ្ញុំបាទអាចអនុញ្ញាតអោយ *ភូជីកូ* ជាចៅស្រីរបស់ខ្ញុំបាទធ្វើអត្តឃាតបានទេ ?

- ទេ ។

- ប៉ុន្តែ *ភូជីកូ* ជាសាមូរ៉ៃទាន ។ លោកម្ចាស់អាចយល់បានហើយពីសន្តានចិត្ត ម្តាយ ចំពោះកូន ។ ហើយនេះគឺជាកូនប្រុសដំបូងរបស់វាផង ។

- *ភូជីកូ* អាចមានកូនច្រើនទៀត ។ នាងអាយុប៉ុន្មានហើយអីចេះ ? ដូចជាប្រាំបី-ប្រាំ បួនដណ្តប់ទេតើ ។ ចាំខ្ញុំរកប្តីមួយទៀតអោយនាង ។

*ហ៊ីរូ-ម៉ាត់ស៊ី* គ្រវីក្បាល :

- វាមិនព្រមយកអ្នកណាទៀតទេ ។ ខ្ញុំបាទស្គាល់វាច្បាស់ណាស់ទាន ។អីលូវនេះវាទាមទារតែរឿងធ្វើអត្តឃាត តាមប្តីវាតែប៉ុណ្ណឹង ។ សូមលោកម្ចាស់អនុញ្ញាតអោយវាចុះ ។

- សូមលោកប្រាប់ទៅចៅស្រីរបស់លោកផងថា ខ្ញុំមិនឯកភាពចំពោះការស្លាប់អត់ ប្រយោជន៍អីចឹងទេ ។ ខ្ញុំមិនអនុញ្ញាតទេ ។

នៅទីបំផុត *ហ៊ីរូ-ម៉ាត់ស៊ី* លំអោនខ្លួនដើម្បីសុំលា *តូរ៉ាណាហ្គា* ត្រលប់ទៅកន្លែងខ្លួនវិញ ។



www.budinst.gov.kh www.elibraryofcambodia.org

ពេលនោះ *តូរ៉ាណាកា* ក៏សួរឡើង :

- តើគួរអោយមនុស្សចុងស្រុកនេះ នៅក្នុងគុកប៉ុន្មានពេល ?

*ហ៊្សូ-ម៉ាត់ស៊ី* ឆ្លើយតបដោយឥតបែរក្រោយមកវិញទេ :

- នោះអាស្រ័យលើសមត្ថភាពទប់ទល់របស់វា ។

- អរគុណ ។ រាត្រីសួស្តី *ហ៊្សូ-ម៉ាត់ស៊ី* ។

នៅពេលដែលលោកដឹងច្បាស់ថា គ្មានអ្នកណានៅជិតលោកទៀតទេ *តូរ៉ាណាកា* ក៏និយាយឡើងយ៉ាងស្រាល១ :

- *គីរី-សាន* ?

ទ្វារបន្ទប់ខាងក្នុងរបើកឡើង ។ *គីរី* ដើរចូលមកលុតជង្គង់នៅចំពោះមុខ *តូរ៉ាណាកា* ។

- ផ្ញើសារមួយជាបន្ទាន់ទៅ*ស៊ូដារ៉ា* ។ ដាក់ថា " អ្វី១ស្រួលបួលទេ " ។ ផ្ញើតាមព្រាបនាំសារអាឿន១បំផុត ។ ប្រើព្រាបបីទៅ ហើយព្រលែងវាក្នុងពេលជាមួយគ្នានៅពេលព្រលឹមនេះ ។ ដល់ថ្ងៃត្រង់ផ្ញើអ៊ីចឹងទៀត ។ លឺទេ ?

- ចាស់ លោកម្ចាស់ ។

រួច*គីរី* ក៏ចាកចេញទៅ ។

ក្នុងព្រាបប៉ុន្មាននេះ យ៉ាងអន់ក៏មានព្រាបមួយទៅដល់ទីដៅដែរ -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ យ៉ាងហោចណាស់ ក៏បូនដែរដែលត្រូវធ្លាក់ដោយសារព្រួញ ដោយស្ទាំង រឺត្រូវពួកយកការណ៍ចាប់បាន ។ ប៉ុន្តែលើកលែងតែ*អ៊ីស៊ីដូ*ដឹងរូបមន្តពាក្យសំងាត់ បើមិនអ៊ីចឹងទេសារនេះគ្មានន័យអ្វីទាំងអស់សំរាប់វា ។

រូបមន្តសារសំងាត់នេះមានតែមនុស្សបួននាក់ទេដែលដឹងបាន ។ នោះគឺ*ណូប៊ូរូ* កូនប្រុសច្បងរបស់លោក *ស៊ូដារ៉ា* កូនប្រុសទីពីរ និងជាអ្នកស្នងលោក*គីរី* និងរូបលោក ។ សារដែលលោកផ្ញើទៅនេះនៅពេលដែលគេសំរាយ វាមានន័យថា "កុំរវល់នឹងសារឯទៀតអោយសោះចាត់ចែងដំណើរការផែនការទីប្រាំទៅ " តាមការកំនត់ជាមុន ផែនការទីប្រាំមានន័យថាត្រូវប្រមូលប្រមុខត្រកូល*យ៉ូស៊ី* ទាំងអស់ ហើយនិងទីប្រឹក្សាជំនិតជាទីទុកចិត្តបំផុតរបស់ពួកគេ អោយទៅជួបជុំគ្នា



www.budinst.gov.kh www.elibraryofcambodia.org

នៅឯ *យេដូ* ហើយគេណ្ឌកំលាំងរៀបចំសង្គ្រាមភ្លាម ។ពាក្យសំងាត់ដែលបើកសង្គ្រាមគឺ " ផ្ទៃមេឃក្រហម " ឃាតកម្មលើរូបលោក ចំនាប់រូបលោក និងធ្វើអោយ " ផ្ទៃមេឃក្រហម " កំរើកសកម្មភាព ហើយសង្គ្រាមនឹងផ្ទុះឡើងភ្លាម ។ នោះគឺ *ស៊ូដាក៊ា* នឹងបើកការ វាយលុកយ៉ាងប្តូរផ្តាច់ទៅលើក្រុងក្យូតូ ដោយប្រើកំលាំងទ័ពទាំងអស់ដើម្បីកាន់កាប់ទីក្រុងនេះ និងក្តាប់អោយបានព្រះចៅអធិរាជ ។ សកម្មភាពនេះនឹងត្តបផ្សំជាមួយផែនការសំងាត់មួយទៀតដែលត្រូវបានរៀបចំយ៉ាងល់អិតជាច្រើនឆ្នាំមកហើយ ។ នោះគឺជាផែនការកុបកម្មមួយ ដែលនឹងផ្ទុះឡើងនៅក្នុងខេត្តចំនួនហាសិប ។ រាល់មុខសញ្ញារាល់ច្រកចេញចូល រាល់ទីប្រជុំជន វិមាន និងស្ពាននានា ត្រូវបានកំនត់ជាយូរយារមកហើយ ។

នេះពិតជាគំរោងការមួយដ៏ល្អ - *តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ ប៉ុន្តែគំរោងការនឹងធ្លាក់ទឹក បើសិនជាអញមិនដឹកនាំ ។ *ស៊ូដាក៊ា* ពិតជាបរាជ័យបើវាទទួលធ្វើ ។ មិនមែនដោយវាខ្វះសេចក្តីក្លាហាន រឺគ្មានប្រាជ្ញា រឺដោយមានអំពើក្បត់នោះទេ ។ តែនេះសំខាន់ពីព្រោះ *ស៊ូដាក៊ា* មិនមានការចេះដឹង ហើយនិងបទពិសោធន៍គ្រប់គ្រាន់ ហើយក៏មិនអាចមានសមត្ថភាពអូសទាញពួក *ដៃមីញ៉ូ* ដែលនៅជាអព្យាក្រឹតនោះអោយតាមខ្លួនបាន ។

សង្គ្រាមរបស់ *តូរ៉ាណាកា* បានចាប់ផ្តើមតាំងពីលោកមានអាយុបានប្រាំមួយឆ្នាំ ហើយត្រូវគេទុកជាចំនាប់ខ្មាំងនៅក្នុងកន្លែងពួកសត្រូវម្ល៉េះ ។ រួចបន្ទាប់មកទៀតលោកត្រូវគេអនុញ្ញាតអោយរួចខ្លួន ប៉ុន្តែលោកត្រូវសត្រូវផ្សេងចាប់ឃុំឃាត់ខ្លួនជាចំនាប់ខ្មាំង រហូតដល់ពេលលោកបានអាយុដប់ពីរឆ្នាំ ។ ក្នុងអាយុដប់ពីរឆ្នាំនេះ លោកបានចេញដឹកនាំកងល្បាតដំបូងបង្អស់របស់លោក ហើយលោកបានទទួលជ័យជំនះក្នុងចំបាំងជាលើកដំបូងរបស់លោក ។

ការប្រយុទ្ធមានរាប់មិនអស់ ។ មិនដែលមានការប្រយុទ្ធណាមួយដែលអញត្រូវចាញ់នោះឡើយ ។ ប៉ុន្តែសត្រូវក៏រាប់មិនអស់ដែរ ។ អីលូវនេះពួកវាពួតដៃគ្នាហើយ ។

*ស៊ូដាក៊ា* ច្បាស់ជាបរាជ័យ ។ អ្នែងជាមនុស្សតែម្នាក់គត់ ដែលអាចដណ្តើមយកជ័យជំនះបាន តាមគំរោងការ " ផ្ទៃមេឃក្រហម " ។ អម្ចាស់ *តែតូ* ពិតជានឹងធ្វើបែបនេះដែរ ។ ប៉ុន្តែបើមិនអនុវត្ត " ផ្ទៃមេឃក្រហម " បាននោះ១ក៏រឹតតែប្រសើរណាស់ទៅទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ១៤

ចំពោះ*ប្លាក់ថន* នេះគឺជាពេលព្រឹកព្រលឹមមួយ ដែលហាក់បីដូចជានៅក្នុងឋាននរក ។ គេជាប់ដៃក្នុងការវាយប្រតាយគ្នាស្ទើរងាប់រស់ ជាមួយអ្នកទោសម្នាក់ទៀត ព្រោះតែរឿងបបរមួយចាន ។ អ្នកទាំងពីរស្រោតនទលគោកទាំងអស់គ្នា ។ នៅពេលណាដែលគេយកអ្នកទោសមកដាក់នៅក្នុងគុកឈើដ៏ធំ និងដែលនៅផ្ទាល់ដីនេះ គេរមែងប្រស្រាតខោអាវអ្នកទោសចេញ ។ មនុស្សស្លៀកខោអាវស៊ុកខ្លែងធំ ហើយខោអាវអាចលាក់អាវុធទៀតផង ។

គុកងងឹតព្រាល និងដ៏ថប់នេះ មានបណ្ដោយប្រហែល ម្ភៃម៉ែត និងទទឹងប្រហែលប្រាំម៉ែត ហើយពោរពេញទៅដោយពួកជប៉ុន ដែលបែកញើសរហាម និងស្រាតនទលគោកដូចគេយ៉ាងដូច្នោះដែរ ។ មានពន្លឺបន្តិចបន្តួចប៉ុណ្ណោះ ដែលចាំងចូលតាមចន្លោះក្ដារជញ្ជាំង និងពិដានគុក ។

*ប្លាក់ថន* ឈើចុកចាប់ស្ទើរឈរលែងបាន ។ ស្បែករបស់គេត្រូវរលាត់ឈើផ្សាបណ្ដោយមកពីក្រចកកំបាក់របស់បុរសនោះផង ពីអង្កាន់ក្ដារជញ្ជាំងផង ។ នៅទីបញ្ចប់គេយកក្បាលគេអុកចំមុខបុរសនោះ ហើយដៃរបស់គេច្បាមបំពង់កគូប្រយុទ្ធ ចាប់បោកក្បាលទៅនឹងជញ្ជាំងរហូតបុរសនោះលែងដឹងខ្លួន ។ បន្ទាប់មកគេត្រវែងរាងកាយស្លុកស្លឹងនោះចោល ហើយដើរជ្រែករវ៉ូងមនុស្សបែកញើសតយៀវនោះ សំដៅកន្លែងរបស់គេនៅឯជ្រុងជញ្ជាំង ហើយត្រៀមខ្លួនជាស្រេច ដើម្បីទប់ទល់នឹងការវាយលុកណាមួយជាថ្មីទៀត ។

កាលពីពេលព្រឹកព្រលឹមនេះ គឺជាម៉ោងចែករបបហូបចុក ។ អ្នកយាមបានដើរចែកបបរ ហើយនឹងទឹកតាមចន្លោះចរឹងទ្វារគុក ។ នេះគឺម្ហូប និងទឹក លើកដំបូងបង្អស់ ដែល*ប្លាក់ថន* ទទួលបានតាំងពីគេត្រូវវញាត់គុក ពីពេលព្រលប់ម្សិលមិញម្ល៉េះ ។ ការបន្តកន្ទុយទទួលទឹក និងម្ហូបគឺមានភាពស្ងប់ស្ងៀមយ៉ាងចំលែក ។ គ្មានវិន័យគឺឥតមានអ្នកណាម្នាក់បានហូបឡើយ ។ ហើយបន្ទាប់មកទៀត មានបុរសដូចស្វាម្នាក់ គ្មានកាត់សក់ គ្មានកោរមុខ សុទ្ធតែថៃ និងយ៉ាងតគ្រិចបំផុត បានដាល់គេមួយដៃចំត្រគាក ហើយឆក់យកបបរគេទៅ ក្នុងពេលដែលអ្នកឯទៀត ទាំងអស់ចាំសំលឹងមើលថា តើរឿងរ៉ាវវានឹងទៅជាយ៉ាងណានោះ ។ ប៉ុន្តែ*ប្លាក់ថន* ធ្លាប់ហាក់លោត



www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងរឿងទាត់ធាក់ រវាងពួកដើរសមុទ្រ រាប់សិបដងទៅហើយ ហេតុនេះការវាយឆ្អក់អំពាញ់មិញនោះ មិនអាចផ្តួលគេបានទេ ប៉ុន្តែគេធ្វើហាក់ដូចជាត្រូវធ្ងន់ រួចទើបងាកទាត់មួយជើងផាំងយ៉ាងអស់ទំហឹង ។ ហើយការប្រវាយប្រតប់ក៏បានចាប់ផ្តើមឡើង ។ អីលូវនេះ ពេលដែលគេកំពុងអង្គុយនៅនឹងកាច់ជ្រុងជញ្ជាំង គេសែនភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយឃើញបុរសម្នាក់បានហុចរបបបបរ និងទឹករបស់គេ ដែលគេគិតស្មានថាបាត់ទៅហើយនោះ មកអោយគេវិញ ។ *ភ្លាក់ផន* ទទួលយករបបខ្លួនបណ្តើរ អរគុណបុរសនោះបណ្តើរ ។

កាច់ជ្រុងជញ្ជាំង គឺជាកន្លែងជំរើសបំផុតហើយ ។ នៅនឹងដី ឈើក្តារមួយបន្ទះបានពុះគុកនេះជាពីរតាមបណ្តោយ ។ ក្នុងមួយផ្នែក១នេះ មានមនុស្សបីជួរ ។ ពីរជួរបែរមុខរកគ្នាដោយមានខ្នងទល់នឹងជញ្ជាំង រឺទល់នឹងបន្ទះក្តារ ហើយមួយជួរទៀតនៅចន្លោះកណ្តាល ។ នៅចន្លោះកណ្តាលនេះ មានតែមនុស្សចាស់ និងមនុស្សខ្សោយទេ ឯអ្នកខ្លាំង១នៅជួរក្រៅទាំងអស់ ។ នៅពេលណាដែលអ្នកជួរក្រៅត្រូវការសណ្តូកជើង គេត្រូវសណ្តូកលើពួកអ្នកនៅកណ្តាលនេះឯង ។

ពេលនេះ *ភ្លាក់ផន* ឃើញសាកសពពីរនាក់ដែលឡើងហើមប៉ោង និងមានសុទ្ធតែពងរុយទៅហើយ ។ ប៉ុន្តែពួកមនុស្សដ៏កំសោយ និងត្រដរខ្យល់ឯទៀតនោះ ហាក់មិនយកចិត្តទុកដាក់អ្វីឡើយ ។

នៅក្នុងបន្ទប់ដ៏សែនក្តៅដូចជាឡនេះ គេមើលមិនបានឃើញឆ្ងាយប៉ុន្មានទេ ។ កំដៅព្រះអាទិត្យបានដុតកំលោចលើជញ្ជាំងគុកតាំងពីពេលថ្ងៃរនេះម្ល៉េះ ។ ថ្វីត្បិតតែនៅទីនេះ មានធុងសំរាប់បន្ទោរបង់ក្តី ក៏ចំហួលក្លិនស្អៃលាមក ធ្វើអោយគេទ្រាំទ្រស្ទើរមិនបាន ដោយហេតុថាពួកអ្នកមានជំងឺ បានជុះនោមប្រឡាក់ទាំងខ្លួន ប្រឡាក់ទាំងកន្លែងដែលពួកគេដេកនោះអស់ទៅហើយ ។

យូរ១ម្តង ឆ្មាំគុកបើកទ្វារដែក ហើយហៅឈ្មោះអ្នកជាប់ឃុំនៅទីនេះអោយចេញទៅក្រៅ ។ អ្នកដែលមានឈ្មោះរមែងអោនខ្លួនគោរពមិត្តរួមគុកជាមួយខ្លួន រួចហើយទើបដើរចេញទៅ ។ ប៉ុន្តែកន្លែងទំនេរនេះ តែមួយភ្លែតក្រោយ ក៏មានអ្នកចំនួលថ្មីមកកាន់កាប់វិញភ្លាមដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

មើល១ទៅវាហាក់ដូចជាអ្នកជាប់គុកនៅទីនេះ បានសុខចិត្តទទួលយកវាសនារបស់ ខ្លួនទៅតាមយថាកម្មបែបនេះ ហើយពួកគេក៏ខំប្រឹងរស់នៅ ដោយសុខស្រួលឥតមានគុំកួនអ្វីជាមួយអ្នកជិតខាងរបស់ខ្លួនយ៉ាងនេះទៅ ។

បុរសម្នាក់ ដែលនៅជាប់នឹងជញ្ជាំង ចាប់ផ្តើមក្អួតចង្អោរ ។ បុរសនេះត្រូវគេទាញទៅជ្រុងកណ្តាលយ៉ាងរហ័ស ។ គេដួលនៅជ្រុងកណ្តាលនោះ ហើយប្រឹងត្រដរខ្យល់ក្រោមទំងន់ជើងរបស់អ្នកនៅជ្រុងខាង ដែលសណ្តូកពីលើនោះ ។

*ឡាក់ថន* ត្រូវបង្ខំចិត្តបិទភ្នែក និងខាំមាត់ជំនះលើចិត្តតក់ស្លុត និងការភ័យខ្លាចកន្លែងហ៊ុមព័ទ្ធបែបនេះ ។ អាកូនមីចោរ *តូភិណាកា* ។ អញប្រាថ្នាសូមអោយតែថ្ងៃណាមួយ អញបានញាត់អ្អែងចូលកន្លែងបែបនេះម្តងអ្នា !

អាកូនមីចោរម្រាយឆ្នាំគុក ។

យប់មិញ ពេលដែលឆ្មាំបានបញ្ជាគេអោយដោះខោអាវចេញនោះ *ឡាក់ថន* តដៃជាមួយពួកនោះ ទោះជាគេដឹងថា គេមិនអាចឈ្នះក្តី ប៉ុន្តែគេមិនអាចចាញ់ដោយទទេ១បានទេ ។ បន្ទាប់មករូបគេត្រូវពួកឆ្មាំញាត់បញ្ចូលបន្ទប់នេះ ។

នៅទីនេះ មានបន្ទប់ដូចនេះបួន ។ នេះជាគុកមួយដែលនៅជាយក្រុង អមព័ទ្ធដោយជញ្ជាំងថ្មខ្ពស់១ហើយមានផ្លូវក្រាលថ្មយ៉ាងស្អាត។ នៅក្រៅជញ្ជាំងថ្មមានទីធ្លាមួយហ៊ុមព័ទ្ធដោយខ្សែលួស ត្រូវបានគេរៀបចំឡើងនៅអែបនឹងមាត់ស្ទឹង ។ នៅលើទីធ្លានោះ មានឈើឆ្កាង ចំនួនប្រាំ ។ មនុស្សប្រុសបួននាក់ និងនារីម្នាក់ដែលមានខ្លួនអាក្រាតនទលគោក ត្រូវបានគេចងកដៃកជើងគ្រៀកជាប់នឹងឈើឆ្កាងនេះ ។ នៅពេលដែល*ឡាក់ថន* ដើរចូលមកក្នុងទីធ្លានេះ ជាមួយកងល្បាតសាមូរ៉ៃនោះ គេបានឃើញពួកពេជ្ឈឃាត ដែលប្រដាប់ដោយលំពែងដ៏វែង១នោះ បានបុសលំពែងខ្វែងគ្នាទំលាយដើមទ្រូងអ្នករងគ្រោះ ក្នុងពេលដែលអ្នកឈរមើលទាំងប៉ុន្មានស្រែកកញ្ជ្រៀវឡើង ។ រួចហើយគេកាត់សាកសពទាំងប្រាំទំលាក់ចុះ ហើយដាក់មនុស្សប្រាំនាក់ទៀតឡើងទៅលើឈើឆ្កាងនោះវិញ ក្នុងពេលជាមួយគ្នានេះ ពួកសាមូរ៉ៃ បានមកកាប់ចិញ្ច្រាំសាកសពទាំងប្រាំនេះនឹងដាវវែងរបស់ខ្លួនបណ្តើរ និយាយលេងសើចក្អាកក្អាយបណ្តើរ ។



www.budinst.gov.kh www.elibraryofcambodia.org

ពួកអាកូនមីចោរ ស្រែកឈាមរំបល់យក៍នេះ !

ដោយឥតមានអ្នកណាបានកត់សំគាល់ បុរសដែល *ប្លាក់ថន*បានវាយដួលនោះ បានភ្ញាក់ដឹងខ្លួនវិញហើយ ។ បុរសនេះនៅក្នុងជួរកណ្តាល ។ ឈាមនៅកកក្តាំងពេញមួយចំហៀងមុខរបស់វា ហើយច្រមុះវាត្រូវបាក់កំពិត ។ រំពេចនោះវាស្ទុះហក់រឹងទៅរក *ប្លាក់ថន* ដោយឥតរវីរវល់នឹងមនុស្សម្នាដែលនៅមុខផ្លូវរបស់ខ្លួនឡើយ ។

*ប្លាក់ថន* ក្រលេកឃើញគូប្រយុទ្ធរបស់ខ្លួន នៅនាទីចុងក្រោយតែប៉ុណ្ណោះ ។ គេរវៃទំងន់ដៃវៃមកនោះជាប់ ហើយដាល់ទៅវិញត្រូវចំចង្កេះរបស់ សត្រូវដួលចង្រ្កាងទៅលើរ៉ូងអ្នកទោសឯទៀត ។ អ្នកទោសម្នាក់ទៀតស្រែកឡូឡាប្រទេចផ្តាសាឡើង ហើយអ្នកទោសម្នាក់ទៀតមានមាឌធំចង្រ្កាងដូចក្របីឡើងក ក៏កាប់មួយដៃចំកញ្ចឹងក គូសត្រូវរបស់ *ប្លាក់ថន* លឺសូរផស ហើយបុរសនោះក៏បាក់ស្រ៊ុបតែម្តង បុរសក្របីឡើងកនោះច្បាមសក់ក្បាលសុទ្ធតែថៃរបស់បុរសរងគ្រោះទាញយកមកពិនិត្យ រួចទំលាក់វាទៅវិញ រួចគេសំលឹងមើលទៅ *ប្លាក់ថន* និយាយគ្រលរ១បីប្អូនម៉ាត់ ហើយសើចស្ញេញទាំងមាត់ក្រហ៊ុប ។

- អរគុណ !

*ប្លាក់ថន* និយាយបណ្តើរប្រឹងត្រដររកខ្យល់ដកដង្ហើមបណ្តើរ ។ គេអរដែរ ដែលគូសត្រូវរបស់គេមិនចេះស្ទៀតប្រយុទ្ធដោយដៃទទេដូចជា *មូរ៉ា* នោះ ។ គេចង្អុលខ្លួនគេ ហើយនិយាយឡើង :

- ខ្ញុំឈ្មោះ *អាន់ជីន-សាន* ។ រួចចុះអ្នែង ?

- អ្ហា ! *សូដេស៊ូ អាន់ជីន-សាន* !

រួចបុរសនោះ ចង្អុលខ្លួនឯង ហើយនិយាយទាំងដង្ហក់

- *មីទីគី* !

- *មីទីគី-សាន* ?

- *ហៃ* ! - រួចបុរសនោះក៏ព្រលែង ភាសាជប៉ុនមួយប្រាវថែមទៀត ។

*ប្លាក់ថន* ក្រញ៉ែងស្មាយ៉ាងនឿយណាយ :



www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

- *វ៉ាការី ម៉ារសេន* ! ខ្ញុំអត់ចេះភាសាជប៉ុនទេ ។

- អ្ហាំ ? *សូដេស៊ូ* !

បុរសក្របីឡើងកនេះក៏ងាកទៅនិយាយយ៉ាងខ្លីជាមួយអ្នកជិតខាងខ្លួន រួចគេញាក់ស្មាម្តងទៀត ។ *ភ្លាក់ថន*ក៏ញាក់តបវិញ ។ បន្ទាប់មកអ្នកទាំងពីរក៏លើកសាកសពនោះទៅដាក់ជាមួយសាកសពឯទៀតទៅ ។ នៅពេលដែលពួកគេទាំងពីរនាក់វិលមករកជ្រុងជញ្ជាំងរបស់ពួកគេនោះ គ្មានអ្នកណាម្នាក់ដណ្តើមយកកន្លែងរបស់គេឡើយ ។

អ្នកដែលនៅទីនេះ ជាភាគច្រើនកំពុងតែដេកលក់ រឺកំពុងតែខំប្រឹងធ្មេចភ្នែកដេក ។

*ភ្លាក់ថន* មានអារម្មណ៍ថា ខ្លួនគេឡើងស្ពុយគគ្រិច ហើយត្រជាក់ខ្យល់ម្តងៗទៅហើយ ។ កុំភ័យពេកអ្ហាំ - គេនិយាយលួងលោមនៅក្នុងចិត្ត - អ្ហែងមិនងាយងាប់តែប៉ុណ្ណឹងទេ..... តែ ...... តែ..... អញមិនអាចរស់នៅក្នុងរូងនរកនេះបានយូរទេ ។ មានមនុស្សខ្លាប់យ៉ាងនេះ ។ ឱព្រះអើយអោយខ្ញុំបានរួចចេញពីកន្លែងនេះទៅ យីហេតុម៉េចបានជាបន្ទប់នេះវាឃ្លេងឃ្លោងអ៊ីចឹង ? រួចនេះ *អារ៉ូត្រ៊ិច* ទេដឹង ? រួចម៉េចបានជាវាផុសពីណា មកពីក្រោមអ៊ីចឹង ? រួចម៉េចបានជាភ្នែកវាប្រែទៅជាងៀបអ៊ីចឹង ? ខ្ញុំដកដង្ហើមមិនរួចទេ ដកមិនរួចទេ ខ្ញុំត្រូវចេញពីទីនេះ ។ នែ៎ ! កុំដាក់អុសថែមទៀត ភ្លើងប៉ុណ្ណឹងវាគ្រប់គ្រាន់ណាស់ទៅហើយ ។ រួចចុះអ្ហែងធើអីនៅកន្លែងនេះដែរអាគ្រួក ? អញស្មានថា តែលែងអ្ហែងហើយតើ ។ អញស្មានថាអ្ហែងទៅដល់ភូមិវិញហើយៗអើនែ ! យើងមកដល់ភូមិវិញហើយតើ ! រួចម៉េចបានជាអញមកដល់ណឹងដែរ ? រួចហេតុអីបានជានៅលើឆ្នេរខ្សាច់ មានសុទ្ធតែឈាមយ៉ាងណឹង ? រួចចុះថ្លាងនេះ ? ពួកយើងនៅក្នុងថ្លាងទេតើ ? ទេ កុំបំពក់ភ្លើងថែមទៀត ។ ខ្ញុំងាប់អីឡូវហើយ ។ ឱព្រះអង្គអើយព្រះអង្គទេ ! .......ទេ ! ។

*ភ្លាក់ថន* ខំរើបំរាស់ពីភាពរវើរវាយ ប៉ុន្តែត្រចៀកគេនៅលាន់ខ្ទ័រ នឹងសំលេងអោយធម៌ដ៏ស្ងាត់ស្ងៀមមួយ ។ ក្នុងមួយរយៈនោះ*ភ្លាក់ថន* មិនដឹងថាតើគេភ្ញាក់ រឺ ក៏គេយល់សប្តិទេពិព្រោះត្រចៀកគេបានស្តាប់លឺដោយឥតព្រមជឿផងទេនូវ សំលេងសូត្រធម៌បង្សុកូលជាភាសាឡាតាំងម្តងទៀត ហើយភ្នែករបស់គេក៏មិនព្រមជឿនូវអ្វី ដែលគេបានឃើញនោះដែរ នោះគឺជា



www.budinst.gov.kh www.elibraryofcambodia.org

បុរសសញ្ជាតិអ៊ីរ៉ុបដ៏ស្គមស្រឌីត និងដ៏មានស្បែកជ្រីវជ្រួញម្នាក់ ដែលឈរនៅក្នុងជួរកណ្ដាល ប្រហែលប្រាំមួយប្រាំពីរម៉ែតពីខ្លួនគេ ហើយដែលកំពុងតែអោនសំលឹងមើលសាកសព។ តាចាស់ គ្រហុបធ្មេញមានសក់យ៉ាងវែងនិងយ៉ាងគគ្រិចមានអាវខ្មុកខ្មូរ ក្រចកដៃបាក់ ។ គាត់លើកដៃ ដែលដូចជាក្រញ៉ាំត្មាតឡើង ដើម្បីដាក់ឈើឆ្កាងពីលើសាកសព ។ ពន្លឺព្រះអាទិត្យបានចាំង ឆ្លុះលើរូបគាត់មួយស្របក់ បន្ទាប់មកតាចាស់ក៏បិទភ្នែកសាកសពហើយសូត្រធម៌រម៉ូវៗ រួច សព្វគ្រប់ហើយគាត់ក៏វេក្រសែភ្នែកមើលជុំវិញខ្លួន ក៏ប្រទះនឹងភ្នែករបស់ប្លាក់ថនដែលកំពុងជាប់ មករក ។

- ព្រះមាតាអើយ ឯ្អែងជាមនុស្សពិតមែនអ្វី ?

តាចាស់និយាយក្នុងសំលេងស្អកស្អា ជាភាសាអេស្ប៉ាញជនបទបណ្ដើរ ធ្វើសញ្ញាខ្វែង បណ្ដើរ ។

*ប្លាក់ថន* តបវិញជាភាសាអេស្ប៉ាញដែរ :

- ពិតហើយ ។ លោកជាអ្នកណា ?

តាចាស់រាវផ្លូវទាំងពពីមពពើមមករក*ប្លាក់ថន* ទាំងនិយាយរម៉ូវៗតែម្នាក់ឯង ។ អ្នក នៅទីនោះ ខ្លះក៏ញែកផ្លូវអោយដើរ ខ្លះអោយគាត់ដើរជាន់ ខ្លះអោយដើរវាំលង ដោយឥតមាន និយាយអ្វីមួយម៉ាត់សោះ ។ ពេលមកទល់មុខ*ប្លាក់ថន* គាត់សំលឹងចុះយ៉ាងពិនិត្យពិច័យ ហើយ ពោលថា :

- ឱព្រះមាតាអើយ លោកពិតជាមនុស្សទាំងសាច់ទាំងឈាមមែន ។ លោកជាអ្នក ណា ? ខ្ញុំបាទ......... ខ្ញុំបាទ........ឈ្មោះ *ព្រីយ៉ា ដូមិញ្ញូ ! ដូមិញ្ញូ* .........*ដូមិញ្ញូ* ........ នៃ និកាយរបស់សន្ទ: *ប្រង់ស៊ីស*........និយាយ..........

រួចបន្ទាប់មកតាចាស់ក៏និយាយច្របូកច្របល់ ជាភាសាជប៉ុនផង ឡាតាំងផង អេស្ប៉ាញផង រួចគាត់គ្រវៀងក្បាល ហើយយកដៃជូតស្លេស្មដែលស្រក់ទៅលើទ្រូងរបស់គាត់ :

- លោកពិតជា ពីសាច់ពីឈាមមែនអ្វី ?

*ប្លាក់ថន* សំរួលបង្គុយ ហើយតបម្ដងទៀត :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំមែនណឹងហើយ ។

តាចាស់ភាវនាធមិ ហើយទឹកភ្នែករបស់គាត់ហូរមករហាមកាត់ផែនថ្ពាល់ ។ គាត់ថើបព្រះឆ្លាងម្តងហើយម្តងទៀត ហើយបើកុំតែគ្មានកន្លែងទំនេរ ម្ល៉េះប្រហែលជាគាត់លុតជង្គង់ទៅហើយមើលទៅ ។ បុរសក្របីឡើងកអង្រួនបុរសម្នាក់ដែលនៅជិតនោះអោយភ្ញាក់ឡើង ហើយអ្នកទាំងពីរនាក់នេះក៏នាំគ្នាអង្គុយចោងហោងប្រជ្រៀតគ្នា ដើម្បីញែកកន្លែងមួយតូចល្មមសំរាប់បព្វជិតនេះអង្គុយចុះ ។

- ឱលោកអើយលោក ការបួងសួងរបស់ខ្ញុំសំរេចមែន ។ អំបាញ់..........អំបាញ់......អំបាញ់មិញ ខ្ញុំស្មានតែរវើរវាយទេលោក ហើយខ្ញុំស្មានតែលោកជាខ្មោចទេ ។ បាទថាខ្មោចមែន ។ ព្រោះខ្ញុំបាទទំលាប់ឃើញច្រើនដងហើយទាន ។ តើលោកមកដល់កន្លែងណឹងពីអង្កាល់ ? នៅក្នុងកន្លែងងងឹតពពើមអ៊ីចឹង ពិបាកមើលគ្នាណាស់ ហើយភ្នែកខ្ញុំវាយ៉ាប់ទៀត......ពីអង្កាល់ ?

- ម្សិលមិញ ។ ចុះលោក ?

- ខ្ញុំអត់ដឹងទេទាន ។ យូរហើយ ។ គេយកខ្ញុំមកដាក់កន្លែងនេះនៅខែកញ្ញា ក្នុងឆ្នាំមួយពាន់ប្រាំរយកៅសិបប្រាំបី ។

- អីលូវនេះ គឺខែ ឧសភា ឆ្នាំមួយពាន់ប្រាំមួយរយហើយ ។

- មួយពាន់ប្រាំមួយរយ ?

សំរែកគ្រងរខ្យល់បានមកកាត់ផ្តាច់កិច្ចសន្ទនានេះ ។ តាចាស់ស្ទុះងើបឡើង ហើយដើរវិលងមនុស្សម្នាដែលនៅដេករណ្តូករណែល ប្រៀបដូចជាពីងពាងមួយដោយពោលពាក្យកំលាអ្នកនេះ ស្ទាបអង្អែលអ្នកនោះ ។ គាត់និយាយភាសាជប៉ុនយ៉ាងស្ទាត់ ។ ប៉ុន្តែដោយគាត់មិនអាចរកអ្នកគ្រងរខ្យល់នោះឃើញ គាត់អោយធមិនៅកណ្តាលបន្ទប់នោះតែម្តងទៅ ។ អ្នកដែលជាប់ឃុំឃាំងក្នុងទីនេះទាំងប៉ុន្មាននៅបែបវាហ៊ី គ្មានអ្នកណាភ្ញាក់ផ្អើល គ្មានអ្នកណាយកចិត្តទុកដាក់អ្វីទាំងអស់ ។

- សូមលោកមកតាមខ្ញុំមក ។

ដោយឥតរង់ចាំចំលើយ តាចាស់ដើរពពីមពពើមកាត់តាមរវ៉ូងមនុស្សសំដៅទៅចុង



www.budinst.gov.kh www.elibraryofcambodia.org

បន្ទប់ ។ *ប្លាក់ថន* រេរានៅក្នុងចិត្ត ដោយគេមិនចង់ដើរចោលកន្លែងរបស់គេ ។ រួចគេក៏ងើបឡើង ហើយដើរតាមបព្វជិតនោះទៅ ។ ដើរបានដប់ជំហានគេងាកសំលឹងមើលទៅក្រោយវិញ ។ កន្លែងរបស់គេរលាយបាត់ស្រមោលហាក់ដូចជារូបគេមិនដែលបានទៅអង្គុយកន្លែងនោះឡើយ ។

*ប្លាក់ថន* ដើរកាត់ចុងបន្ទប់ពីម្ខាងទៅម្ខាង ។ នៅឯកាច់ជ្រុងបន្ទប់នោះមានកន្លែងទំនេរមួយស្ទើរមិនអាចជឿបាន ។ កន្លែងនេះល្មមអោយមនុស្សមាឌតូចម្នាក់ប្រះខ្លួនដេកបាន ។ នៅក្បែរនោះមានក្រឡ និងមានចង្កឹះពីរបី ហើយនិងពូកចំបើងកញ្ចាស់មួយ ។

បព្វជិត *ដូមិញកូ* ញែកមនុស្សម្នាដែលនៅទីនោះចូលទៅកន្លែងទំនេរនោះ ហើយធ្វើសញ្ញាអោយ *ប្លាក់ថន*តាមខ្លួន ។ ពួកជប៉ុនដែលនៅព័ទ្ធកន្លែងទំនេរនេះ សំលឹងមើល *ប្លាក់ថន* ដើរកាត់ពួកគេយ៉ាងស្ងៀមស្ងាត់ ។

- ពួកគេគឺជាសាវ័ករបស់ខ្ញុំ ។ ពួកគេសុទ្ធតែជាកូនរបស់ខ្ញុំនៅចំពោះមុខព្រះជាម្ចាស់ ។ ខ្ញុំបញ្ចុះបញ្ចូលពួកគេបានច្រើនណាស់នៅទីនេះ .........នេះគឺ *ជន* ហើយនេះគឺ *ម៉ាក* ហើយមួយនេះទៀតគឺ *មេកូសេឡាស*...........។

បព្វជិតឈប់និយាយបន្តិច ដើម្បីសំរួលដង្ហើម :

- ខ្ញុំហត់ណាស់ ។ ហត់ណាស់ ។ ខ្ញុំ........ខ្ញុំ ........ ខ្ញុំត្រូវ........

សំដីរបស់តាចាស់ អូសបន្លាយទៅៗ រួចគាត់ក៏លង់លក់ក្នុងដំនេកទៅ ។

នៅពេលព្រលប់គេបានមកចែកអាហារម្តងទៀត ។ នៅពេលដែល *ប្លាក់ថន*ប្រុងប្រៀបក្រោកឈរឡើងនោះ ជប៉ុនម្នាក់ដែលនៅជិតគេធ្វើសញ្ញាប្រាប់អោយគេនៅមួយកន្លែង ហើយបន្ទាប់មកគេទៅយកអាហារមួយចានពេញអោយ *ប្លាក់ថន* ។ បុរសម្នាក់ទៀតអង្រួនបព្វជិតយ៉ាងថ្នមៗ អោយគាត់ភ្ញាក់ឡើង ហើយជូនម្ហូបទទួលទាន ។

- *អ៊ីយេ* !

តាចាស់គ្រវីក្បាល ទាំងទឹកមុខញញឹម ហើយរុញចានទៅអោយបុរសនោះវិញ ។

- *អ៊ីយេ ផាផា-សាម៉ា* !

តាចាស់ក៏ព្រមទទួលទានអាហារ ហើយហូបបីបួនម៉ាត់ រួចក៏ងើបឡើងដោយលំបាក



www.budinst.gov.kh www.elibraryofcambodia.org

សន្ធាក់ឆ្អឹងប្រេសប្រស់ ។ គាត់ហុចចានអាហារទៅបុរសម្នាក់ដែលនៅជួរកណ្ដាល ។ បុរសនោះយកដៃរបស់បព្វជិត មកដាក់ផ្ទប់នឹងថ្ងាសរបស់ខ្លួន ហើយបព្វជិតនោះ ក៏សូត្រធម៌អោយមួយរយៈទៅ ។

- ខ្ញុំសប្បាយចិត្តណាស់ដែលឃើញអ្នកមកពីទីកន្លែងដូចគ្នាយ៉ាងនេះ ។

បព្វជិតនិយាយបណ្ដើរអង្គុយចុះជិត*ក្លាក់ថន* បណ្ដើរ ។ គាត់ចង្អុលទៅជ្រុងម្ខាងទៀតនៃបន្ទប់ឃុំឃាំងហើយពោលបន្ត :

- សាវ័កម្នាក់របស់ខ្ញុំ និយាយថា លោកបានប្រើពាក្យ "តៃកុង" "*អាន់ជីន*" តើលោកជាតៃកុងអ្វី ? តើមានពួកក្រុមនាវិក របស់លោកនៅទីនេះទេ ?

- ទេ ខ្ញុំតែម្នាក់ឯងគត់ ។ រួចចុះហេតុអី បានជាលោកមកនៅទីនេះដែរ ?

- បើសិនជាលោកមានតែម្នាក់ឯង តើលោកមកពីម៉ានីលមែនទេ ?

- ទេ ។ មុននេះ ខ្ញុំមិនដែលមកអាស៊ីម្ដងណាទេ ។

*ក្លាក់ថន* និយាយយ៉ាងប្រុងប្រយ័ត្ន ។ ភាសាអេស្ប៉ាញរបស់គេច្បាស់ល្អណាស់ ។

- នេះជាលើកទីមួយរបស់ខ្ញុំហើយ ។ ខ្ញុំទើបចេញដំណើរមកបរទេសលើកណឹង ។ ហេតុម៉េចបានជាលោកមកទីនេះ ?

- ពួក *យេស៊ុីត* វាដាក់ខ្ញុំនៅទីនេះ ។ ពួកអា*យេស៊ុីត* នឹងអារឿងកុហកដ៏ស្អុយគគ្រុករបស់ពួកវាណឹងណា ! លោកថាលោកចេញដំណើរមកបរទេស ។ លោកមិនមែនសញ្ជាតិអេស្ប៉ាញ ហើយក៏មិនមែនសញ្ជាតិប៉័កទុយកាល់ដែរ..... បព្វជិតនេះ សំលឹងមើល *ក្លាក់ថន* យ៉ាងសង្ស័យ ហើយខ្យល់ដង្ហើមយ៉ាងខ្មោះខ្មួររបស់ លោកបានរួបរឹតរាងកាយ*ក្លាក់ថន* ភ្លាមដែរ- តើសំពៅនោះ ជាសំពៅប៉័កទុយកាល់អ្វី ? ស្បថថា និយាយត្រង់ទៅមើល ដោយយកព្រះជាបន្ទាល់ ។

- អត់ទេ ។ សំពៅនោះមិនមែនរបស់ប៉័កទុយកាល់ទេ ។ ខ្ញុំសូមយកព្រះធ្វើជាបន្ទាល់ ។

- ឱព្រះមាតាអើយ សូមអរព្រះគុណហើយ ។ សូមលោកអភ័យទោសដល់ខ្ញុំផងណា ។



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំខ្វាចពេក .........ខ្ញុំ.........ខ្ញុំចាស់ហើយ១លូង់ខ្មៅ និងមានជំងឺទៀត ។ សំពៅនេះ ជារបស់អេស្ប៉ាញទេ រួចចុះវាមកពីខាងណាវិញ ? ខ្ញុំសប្បាយចិត្តម្ល៉េះទេ .......តើស្រុកកំណើតលោកនៅឯណាទៅ ? ពីតំបន់អេស្ប៉ាញអ្វី ? រឺអ្នកមកពី *ប្រេតែនបូ* ? រឺក៏មកពីផ្នែកដីដែលយើងត្រួតត្រានៅ អាឡឺម៉ង់ ? ឱលោកអើយលោក បាននិយាយភាសាកំណើតរបស់ខ្ញុំឡើងវិញនេះដូចជាសែនសុខម្ល៉េះទេ ។ តើលោកម្ចាស់លិចសំពៅដូចពួកយើង អ៊ីចឹងដែរមែនទេ ? លោកម្ចាស់ត្រូវគេបញ្ឆោត យកមកញាត់គុក ព្រោះពាក្យចោទមូលបង្កាច់ តែផ្ដេសផ្ដាសរបស់ពួកអាបិសាច *យេស៊ូអ៊ីត* នេះមែនទេ ? - ភ្នែករបស់បព្វជិតជះពន្លឺយ៉ាងមុត -អំបាញ់មិញលោកមានប្រសាសន៍ថា លោកមិនដែលមកអាស៊ីទេ មែនទេ ?

- បាទ មិនដែលទេ ។

- បើសិនជាលោកមិនដែលមកអាស៊ីមែន លោកនឹងដូចជាកូនក្មេងនៅកណ្ដាលព្រៃស្មសានអ៊ីចឹង ។ បាទមែនណា ! មានរឿងច្រើនណាស់ដែលត្រូវនិយាយតើលោកម្ចាស់មានដឹងទេថា ពួក*យេស៊ូអ៊ីត* ជាទូទៅគឺ ជាពួកឈ្មួញ ពួកជួញអាវុធ និងមេចងការទេ ? តើលោកម្ចាស់មានដឹងដែរទេថា ពួកវាក្ដាប់ជំនួញសូត្រនៅស្រុកនេះ ហើយនិងជំនួញរវាងស្រុកនេះនឹងស្រុកចិនទេ ? រួចដឹងពីជើងសំពៅខ្មៅប្រចាំឆ្នាំ ពោរពេញដោយទ្រព្យ មានតំលៃជាងមួយលានទេ ?

ពួកវានៅបានបង្ខំ *ប៉ាប* អោយផ្ដល់សិទ្ធិអំនាចទាំងស្រុងដល់ពួកវា នៅទ្វីបអាស៊ីនេះទៀត ទាំងពួកវា ទាំងផ្អែបិកទុយកាល់របស់ពួកវា ។ ខ្ញុំ នែ ! លោកម្ចាស់មានដឹងទេថានៅទីនេះ សាសនាដទៃទៀតត្រូវហាមឃាត់ទេ ? តាមពិតពួក*យេស៊ូអ៊ីត* រកស៊ីចំនេញកប់ក្ដោងសំរាប់ពួកវា ដែលជាប្រការមួយផ្ទុយនឹងបញ្ជារបស់*ប៉ាប* ផ្ទុយនឹងព្រះរាជបញ្ជាព្រះចៅ*ភីលីប* ហើយផ្ទុយនឹងច្បាប់របស់ស្រុកនេះទៀតផង ។ រួចលោកមានដឹងទេថា ពួកវាលួចបញ្ចូលអាវុធមកអោយពួកស្ដេច១កាន់គ្រិស្តសាសនា និងបំផុសពួកទាំងនេះ អោយធ្វើការបះបោរទេ ? ពួកវាលូកដៃ ចូលក្នុងរឿងនយោបាយ ហើយបញ្ចុកបញ្ចុះ អោយគេដណ្ដើមរាជ្យគ្នា ។ ពួកអាអស់នេះ មេកុហក មេបោកប្រាស់គេ ហើយមូលបង្កាច់ពួកយើងថែមទៀត ។ គណៈសង្ឃ



www.budinst.gov.kh www.elibraryofcambodia.org

របស់ពួកវាបាន ទាំងផ្ញើសារសំងាត់មួយទៅឧបរាជរបស់អេស្ប៉ាញនៅឯលូសុង ប្រទេសភីលីពីន ដើម្បីសុំអោយពួក *កុងគីស្តាឌ័រ* មកស្រុកនេះ ។ តាមពិតទៅពួកវាចង់អោយពួក អេស្ប៉ាញ ទន្រ្ទានស្រុកនេះ ដើម្បីបិទបាំងកំហុសឆ្គងរបស់ពួកប៉ុកទុយកាល់នេះ ។ អារឿងរ៉ាវយើង ទាំងប៉ុន្មាននេះ គឺមកតែពីពួកវាតែម្តង សូមលោកជឿខ្ញុំចុះទាន ។ គឺពួកអា*រយេស៊ុីត* នេះ ហើយដែលព្រួសពិសពុលដាក់ប្រទេស អេស្ប៉ាញ និង ព្រះចៅ*ភីលីប* របស់យើង ។ គឺការ កុហករបស់ពួកវានេះហើយ ដែលធ្វើអោយខ្ញុំ ធ្លាក់ខ្លួនមកដល់ទីនេះ ហើយបញ្ជិតម្ភៃប្រាំមួយ នាក់ទៀតត្រូវទទួលទារុណកម្មរហូតដល់ស្លាប់។ ពួកវាថាខ្ញុំកំពូជអ្នកស្រែ រូចខ្ញុំមិនយល់ដែរ ទាន..........ខ្ញុំចេះអានចេះសរសេរដែរតើ ។ ពីមុនខ្ញុំធ្លាប់ជាស្មៀនម្នាក់របស់លោកឧបរាជដែរ តើ ។ ពួកវាគិតថាពួកយើងជាពួកប្រង់ស៊ីស្កាំងនេះ គ្មានយល់អ្វីទាំងអស់ ............

និយាយដល់ត្រឹមនេះ តាចាស់ក៏តាំងនិយាយច្របូកច្របល់ ម្តងភាសាជប៉ុន ម្តងភាសា អេស្ប៉ាញ ម្តងជាភាសាឡាតាំង ចំនែក*ហ្វាក់ថង* វិញ ខួរក្បាលគេចាប់ផ្តើមកំរើក ហើយការចង់ ដឹងរបស់ គេក៏រឹតតែមានខ្លាំងក្លាថែមទៀត នៅពេលដែលគេលឺអ្វីៗដែលតាចាស់ទើបបាននិយាយ អំបាញ់មិញ។ កាំភ្លើងអី ? មានអី ? ជួញដូរអី ? សំពៅខ្មៅអី ? រឿងទន្រ្ទានអី ? មួយណានអី ? រួចយ៉ាងម៉េចរឿងពួកស្តេចគ្រិស្តសាសនិកពរីង ?

អ្នែងកំពុងតែបោកប្រាស់តាចាស់មានជំងឺនេះទេដឹង ? គេដល្លឹងសួរខ្លួនឯង ។ គាត់ កំពុងតែគិតថាអ្នែងជាមិត្ត មិនមែនជាសត្រូវទេ ។

ទេ អញអត់មានកុហកគាត់ឯណា ។

ក្រែងអ្នែង ចង់អោយគាត់យល់ច្រលំថា អ្នែងជាមិត្តគាត់ទេដឹង ?

អញបាននិយាយ ឆ្លើយនឹងគាត់ដោយត្រង់ទេតើ ។

អ្នែងគ្មាន ស្មគ្រផ្តល់ពតិមានអីទៅគាត់ទេ ?

គ្មានទេ ។

តើត្រឹមត្រូវទេ ?

ច្បាប់ទីមួយ ដើម្បីរស់នៅបានក្នុងទីកន្លែងខ្មាំង គឺគ្មានស្មគ្រផ្តល់ពតិមានអ្វីទាំងអស់ ។



www.budinst.gov.kh www.elibraryofcambodia.org

ការមូម៉ៅរបស់បព្វជិតនេះហាក់ដូចជាបានស្ងប់ទៅវិញហើយ ។ ពួកជប៉ុនទាំងប៉ុន្មានដែលនៅជិតនេះហាក់ដូចជារសាប់រសល់នៅក្នុងចិត្តណាស់ដែរ ។ បុរសម្នាក់ក៏ក្រោកឡើងទៅអង្រួនតាចាស់យ៉ាងថ្នម១ ហើយក៏និយាយទៅកាន់គាត់ ។ បន្តិចម្តង១ បព្វជិត*ដូមិញ្ញកូ*ក៏ចាប់ផ្តើមស្វាងឡើងវិញ ភ្នែករបស់គាត់ប្រែបានថ្លាជាងមុន ។ គាត់សំលឹងមើល*ប្លាក់ថន*ក្នុងក្រសែភ្នែកដ៏ដឹងគុណ ហើយគាត់ក៏និយាយជប៉ុនតបទៅបុរសដែលអង្រួនគាត់ និងបន្ទាប់មកនិយាយទៅអ្នកឯទៀតអោយឈប់ព្រួយបារម្ភទៅ ។ រួចហើយតាចាស់នេះ ក៏បែរងាកទៅនិយាយរក*ប្លាក់ថន*វិញ :

- សូមទោសណាលោក ពួកគេ.........ពួកគេស្មានថា.......... ស្មានថាខ្ញុំខឹង.......ខឹងនឹងលោក ។ ឱព្រះអើយ សូមករុណាកំហឹងដ៏លេលារបស់ខ្ញុំនេះផង ។ រឿងពួកអា*យេស្វីត*នេះ ខ្ញុំនិយាយប្រាប់លោកប៉ុន្មានក៏មិនអស់ដែរ ។

តាចាស់ជូតស្ទេស្មចេញពីដើមទ្រូងរបស់ខ្លួន ហើយមើលទៅទំនងដូចជាគាត់ខំទប់ចិត្តខ្លួនឯងសំបើមណាស់ ។ បព្វជិត *ដូមិញ្ញកូ* យកដៃរឹតដើមទ្រូងបង្អន់ការឈឺចាប់ :

- លោកមានប្រសាសន៍ថាម៉េច អំបាញ់មិញនេះ ? សំពៅលោករសាត់ខុសទិសអ្វី ?

- បាទ ថាអ៊ីចឹងក៏បានដែរ ។

*ប្លាក់ថន* ឆ្លើយតប ។ គេសំរួលជើងយ៉ាងប្រុងប្រយ័ត្ន ។ អ្នកឯទៀតដែលតាមសំលឹងមើលរូបគេ និងចាំស្តាប់គេទាំងនោះ នាំគ្នាប្រជ្រៀតថយក្រោយ ដើម្បីគេបានកន្លែងទូលាយបន្តិច បុរសម្នាក់ទៀតក្រោកឈរឡើង ហើយធ្វើសញ្ញាអោយ *ប្លាក់ថន* សណ្តូកដៃជើង ។

- អរគុណ ! - *ប្លាក់ថន* ឆ្លើយតប - អូមែន ! តើ " អរគុណ " ជប៉ុនថាម៉េច ?

- *ដូម៉ូ* ជួនកាលលោកអាចនិយាយថា *អារីកាតូ* ។ នារីត្រូវតែសុភាពអោយណាស់ទាន ។ នារី១ត្រូវនិយាយថា *អារីកាតូ កូស៊ៃម៉ាស៊ីតា* ។

*ប្លាក់ថន* ចង្អុលទៅបុរសដែលងើបឈរនោះ ។

- ម្នាក់នេះឈ្មោះអីទាន ?

- វាឈ្មោះ *គុងសាលេស* ។



www.budinst.gov.kh www.elibraryofcambodia.org

- រួចចុះឈ្មោះជប៉ុន ?

- អ្ហាស ? អូវាឈ្មោះ *អាកាបូ* ។ ប៉ុន្តែឈ្មោះហ្នឹងមានន័យថា " អ្នកលីសែង " តែប៉ុណ្ណឹងទាន ។ ពួកគេគ្មានឈ្មោះទេ ។ មានតែពួកសាមូរ៉ៃទេដែលមានឈ្មោះ ។

- តាថាម៉េច ?

- មានតែពួកសាមូរ៉ៃទេដែលមានឈ្មោះមានត្រកូល ។ នេះគឺច្បាប់នៅទីនេះទាន ។ អ្នកឯទៀតមានឈ្មោះតាមមុខរបរ ដែលពួកគេមាន ដូចជាអ្នកលីសែង អ្នកចាប់ត្រី អ្នកចុងភៅ ពេជ្ឈឃាត អ្នកស្រែអីចឹងទៅ ។ កូនប្រុស កូនស្រី ក៏ដូចតែគ្នា គេគ្រាន់តែហៅថាកូនស្រីបង កូនស្រីទីពីរ កូនប្រុសច្បង អីចឹងទៅ ។ ជួនកាលគេហៅអ្នកខ្លះថា " អ្នកស្ទូចត្រីនៅក្បែរដើមជ្រៃ " រឺ " អ្នកចាប់ត្រីក្អែកអន់ " ទៅ - តាចាស់ញាក់ស្មាហើយយកដៃខ្ទប់មាត់ស្ងាប - ជប៉ុនធម្មតាមិនមានសិទ្ធិមានឈ្មោះទេ ពួកស្រីពេស្យាដាក់ឈ្មោះខ្លួនឯង ដូចជាឈ្មោះ *ចន្ទ្រា ក់រង តាវា* ជាដើម ។ ស្តាប់ទៅចំលែកណាស់ទាន តែនេះគឺជាច្បាប់របស់ពួកគេអីចឹងតែម្តងទាន ។ ពួកយើងអោយឈ្មោះគ្រិស្តសាសនាទៅពួកគេ អោយពួកគេមានឈ្មោះខ្លួនឯងពិតប្រាកដ នៅពេលដែលយើងបញ្ចុះបញ្ចូលគេក្នុងសាសនា ហើយពួកយើងជួយស្រោចស្រង់ពួកគេពីអន្លង់ទុក្ខបានឃើញធម៌ព្រះ ........... ។

សំដីរបស់តាចាស់ អូសត្រដិតទៅៗ រួចគាត់ក៏សំរាន្តលង់លក់ទៅតែម្តង ។

*- ដូម៉ូ អាកាបូ-សាន !*

*ប្លាក់ថន* និយាយទៅកាន់បុរសនោះៗក៏ញញឹមតបវិញយ៉ាងអៀនប្រៀន ហើយលំអោនខ្លួនគោរព ។

បន្តិចក្រោយមកទៀត បព្វជិតចំនាស់ ក៏ភ្ញាក់ពីដំណេកវិញ ហើយក្រោយពីសូត្រធម៌យ៉ាងខ្លីគាត់ក៏បន្តសួរទៅ*ប្លាក់ថន* ទៀត :

- លោកនិយាយថា ទើបមកដល់កន្លែងនេះកាលពីម្សិលមិញហ្នឹងទេ ? តើលោកមានរឿងអីទៅ ?

*ប្លាក់ថន*តប :



www.budinst.gov.kh www.elibraryofcambodia.org

- ពេលយើងឡើងដីគោក មានអាយេស៊ូតម្នាក់នៅទីណុង ។ តែអំបាញ់មិញ គេជគុណនិយាយថា ពួកវាចោទខ្វាមទោសគេជគុណមែនអ្វី ? តើគេជគុណមានរឿងរ៉ាវអី ? ហើយសំពៅគេជគុណទៅណាទៅ ?

- សំពៅ ? លោកសួរពីរឿងសំពៅពួកយើងណឹងអ្វី ? លោកមកពីម៉ានីលដូចពួកយើងដែរអ្វី ? រឺមួយក៏......... អូស ខ្ញុំចំជាឆ្កួតមែន ។ ខ្ញុំនឹកឃើញ លោកថា លោកមកពីឆ្ងាយហើយមិនដែលស្គាល់អាស៊ីទេ ។ ហ៊ឹ ! ខ្ញុំសប្បាយចិត្តម្ល៉េះទេ ដែលបាននិយាយជាមួយមនុស្សមានអារ្យធម៌ដូចលោកនេះម្តងទៀតនោះ ហើយនិយាយជាភាសាកំនើតខ្ញុំទៅទៀត ។ ពុទ្ធោអើយ គិតទៅយូរពេលណាស់មកហើយ ។ ខ្ញុំឈឺក្បាលណាស់ ឈឺណាស់ សំពៅពួកខ្ញុំអ្វី ? យើងបានទៅដល់ផ្ទះវិញហើយ ។ យើងចេញពី *ម៉ានីល* ទៅ*អាកាពូលកូ*នៅក្នុងស្រុករបស់*ក័រតេស*នៅ *ម៉ិចស៊ិច* រួចយើងធ្វើដំណើរតាមដីគោកកាត់ម៉ាប្រទេសនេះ ទើបទៅដល់*វើរ៉ាគ្រូស* ។ នៅទីនោះយើងឡើងសំពៅ ឆ្លងកាត់សមុទ្រ អាត្លង់ទិច ហើយទីបំផុតទើបទៅដល់ផ្ទះ ។ ភូមិខ្ញុំនៅក្រៅក្រុង*ម៉ាទ្រីត* នៅតំបន់ភ្នំទាន ។ ភូមិខ្ញុំឈ្មោះ *សាន់តាវេរ៉ូនីកា* ។ ខ្ញុំចោលស្រុកកំនើតជាងសែសិបឆ្នាំហើយទាន ។ ខ្ញុំមកពិភពថ្មីនៅម៉ិចស៊ិច រួចទៅភីលីពីន ។ ខ្ញុំធ្វើដំណើរជាមួយពួក *កុងគីស្តាឌ័រ* ដ៏ជាញជ័យរបស់យើង ។ ខ្ញុំទៅ *លូសុង* ពេលដែលទ័ពយើងកំទេចស្តេចក្រៅសាសនាស្រុកនោះ ដែលមាននាមថា *លូម៉ាឡុង* ហើយយកលូសុងជាចំនុះ និងបញ្ចូលប្រទេសភីលីពីនទៅក្នុងផ្លូវធម៌របស់ព្រះជាអម្ចាស់ ។ មានពួកជប៉ុន ដែលចូលសាសនាយើងច្រើននាក់ណាស់ បានទៅជួយប្រយុទ្ធជាមួយពួកយើងតាំងពីពេលនោះម្ល៉េះទាន ពួកនេះពូកែប្រយុទ្ធណាស់ ។ កាលនោះ គឺនៅឆ្នាំ ១៥៧៥ ។ និកាយសាសនាពួកយើងនៅទីនោះរឹងមាំណាស់ទាន ។ ខ្ញុំមកជប៉ុនជិតពីរឆ្នាំហើយពេលដែលខ្ញុំហៀបនឹងត្រលប់ទៅភីលីពីនវិញ ពួក*យេស៊ូត*ក្បត់ពួកយើងបណ្តោយ ។

បព្វជិតនេះ ក៏ឈប់និយាយ ហើយបិទភ្នែកលង់លក់ក្នុងដំណេកទៅ ។ ក្រោយមកទៀតគាត់ភ្ញាក់ឡើង ហើយបន្តសាច់រឿងរបស់គាត់បន្តទៅទៀត ហាក់ដូចជាគាត់មិនបានសំរាន្តអ្វីសោះអីចឹង ដែលជាលក្ខណៈរបស់មនុស្សចាស់មួយចំនួនដូចរូបគាត់យ៉ាងនេះដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- សំពៅរបស់ខ្ញុំឈ្មោះ *សានកេលីប* ។ យើងដឹកគ្រឿងទេស មាស ប្រាក់ដែលមានតំលៃជាងមួយលានកន្លះ *ប៉ីស្វូស* ប្រាក់ ។ ពេលនោះមានព្យុះមួយដ៏ធំបានបក់ផាត់សំពៅយើងទៅក្បែរឆ្នេរតំបន់ *ស៊ីក្កូ*។នៅថ្ងៃទីបី សំពៅយើងត្រូវធ្លាយរយះជាពីរ ។ ពេលនោះយើងជញ្ជូនអីវ៉ែអីវ៉ាន់យើងចុះពីសំពៅស្ទើរអស់ហើយ ។ ពេលនោះស្រាប់តែមានបញ្ជាថា លោកម្ចាស់ *រ៉ែក្កូ* អោយរឹបអូសទ្រព្យសម្បត្តិយើងទាំងអស់ ព្រោះពូកយើងជាចោរសមុទ្រ ហើយនឹង..........

ភាពស្ងប់ស្ងាត់ដែលកើតមានឡើងមួយរំពេចនោះ ធ្វើអោយតាចាស់ឈប់និយាយភ្លាមដែរ ។

ទ្វារដែក នៃបន្ទប់ឃុំឃាំងរបើកឃ្វាំងឡើង ។

ឆ្មាំចាប់ផ្ដើមហៅឈ្មោះដែលមាននៅលើបញ្ជីមួយ ។ បុរសក្របីឡើងកដែលទើបបានក្លាយជាមិត្តរបស់ *ភ្នាក់ថន* នោះ ក៏មានឈ្មោះនឹងគេដែរ ។ គេដើរចេញទៅក្រៅដោយឥតងាកក្បាលមើលក្រោយឡើយ ។ *អាកាប៉ូ* ក៏មានឈ្មោះដែរ ។ គេលុតជង្គង់ចុះពីមុខបព្វជិតចំនាស់១ ធ្វើសញ្ញាខ្វែងពីលើ *អាកាប៉ូ* ហើយអោយធមិយ៉ាងរហ័ស ។ *អាកាប៉ូ* អានថើបរូបព្រះឆ្កាង ហើយក៏ដើរចេញទៅ ។

ទ្វារបន្ទប់ក៏បិទជិតទៅវិញ ។

*ភ្នាក់ថន* សួរទៅតាចាស់ :

- ពួកវានឹងត្រូវប្រហារជីវិតមែនទេ ?

- ហើងហើយ ។ ទុក្ខវេទនារបស់វាគឺចាប់ពីក្រៅទ្វារទៅ។ សូមព្រះជួយអោយវាបានស្លាប់ឆាប់ ហើយអោយវិញ្ញាណក្ខន្ធវាបានសោយសុខនៅឋានសួគ៌ផងចុះ ។

- តើបុរសហឹងបានប្រព្រឹត្តអំពើអ្វី ?

- វាបានបំពានច្បាប់ ។ ច្បាប់របស់ពួកវាណាលោក ។ ពួកជនជាតិជប៉ុន ជាប្រជាជនមួយសាមញ្ញណាស់ ហើយក៏តឹងតែងណាស់ដែរ ។ ពួកគេមានការផ្តន្ទាទោសតែមួយមុខគត់គឺស្លាប់។ ស្លាប់ដោយឆ្កាង ស្លាប់ដោយរឹតក រឺកាត់ក ។ ចំពោះអ្នកបង្កអគ្គីភ័យនោះ គឺការផ្តន្ទា



www.budinst.gov.kh www.elibraryofcambodia.org

ទោស ដោយដុតទាំងរស់ ។ ពួកនេះស្ទើរតែគ្មានការផ្តន្ទាទោសណាផ្សេងទៀតទេ មានដែរ ដូចការបំបរ បង់ចោល រឺនារីខ្លះត្រូវគេកាត់សក់ ។ តែ - តាចាស់ដកដង្ហើមធំ - តែ..... ភាគច្រើន គឺប្រហារជីវិតតែម្តង ។

- តេជគុណ ភ្លេចរឿងដាក់គុកហើយ ។

បព្វជិតចំនាស់បេះក្រមរពីលើដៃរបស់ខ្លួនបែបវាហ៏ :

- នេះមិនមែនជាទំរង់មួយនៃការផ្តន្ទាទោសទេ ។ ចំពោះពួកជប៉ុន គុកគឺជា កន្លែង ដែលគេដាក់មនុស្សជាបណ្តោះអាសន្ន រហូតដល់ពេលគេសំរេចវិនិច្ឆ័យថា យ៉ាងម៉េច១តែ ប៉ុណ្ណោះ ។ មានតែអ្នកបានប្រព្រឹត្តកំហុសទេ ដែលបានមកទីនេះ ។ មកជាបណ្តោះអាសន្ន ។

- និយាយអីចឹង ដូចគ្មានន័យអីទេហ៏ង ។ រួចចុះខ្លួនតេជគុណនោះ ? ក្រែងលោក នៅជាងមួយឆ្នាំ ជិតពីរឆ្នាំហើយតើ ។

- ថ្ងៃណាមួយពួកវានឹងអារកខ្ញុំដូចអ្នកឯទៀតអីចឹង ។ កន្លែងនេះគ្មានអីក្រៅតែជា កន្លែងសំរាកនៅចន្លោះឋាននរកលោកិយ ហើយនិងឋានសួគ៌តែប៉ុណ្ណោះ ។

- ខ្ញុំមិនជឿតេជគុណទេ ។

- កុំខ្លាច កូនប្រុស ។ នេះគឺជាឆន្ទៈរបស់ព្រះជាម្ចាស់ ។ ខ្ញុំនៅទីនេះស្រាប់ បើលោក ត្រូវការខមាទោសអីក៏បាន ហើយខ្ញុំក៏អាចអោយធម៌ដើម្បីអស់បាបបានដែរតើ ។ តើលោកត្រូវ ការធ្វើខមាទោសអីលូវនេះអ្វី ?

- ទេ ! ទេ ! អរគុណហើយ ។ មិនទាន់ដល់ពេលទេ ។

*ប្លាក់ថន* សំលឹងមើលទៅទ្វារដែក ហើយសួរឡើង :

- តើដែលមានអ្នកណាសាកល្បងរត់ចេញពីទីនេះទេ ?

- តើហេតុអីបានជាពួកវាចាំបាច់ធ្វើអីចឹង ? គ្មានកន្លែងណារត់ គ្មានកន្លែងណាពួន ទេ ។ ពួកអាផ្សាធរប្រិតប្រយ័ងណាស់ ។ អ្នកណាម្នាក់ដែលជួយលាក់អ្នកទោសដែលគេចខ្លួន រឺ ជួយអ្នកណាដែលប្រព្រឹត្តិបទឧក្រិដ្ឋ..............



www.budinst.gov.kh www.elibraryofcambodia.org

តាចាស់លើកដៃវាសតំរង់ទៅទ្វារ

- ..........*កុងសារលេស* រឺ *អាកាបូ* ដែលទើបចេញពីយើង អំបាញ់មិញនេះ ។ វាគឺជាមនុស្ស *កាកា* ។ វាប្រាប់ខ្ញុំថា..........

- ស្អីទៅមនុស្ស កាកា ?

- គឺជាអ្នកសែងគ្រែស្នែង រឺអគ្រើងដែលគេហៅថា *កាកា*នោះឯង ។ វាប្រាប់ខ្ញុំថា ដៃគូរបស់វាបានលួចយកកន្សែងសូតមួយពីភ្ញៀវ ហើយព្រោះតែវាមិនបានរាយការណ៍ពីរឿងលួចនេះ ទើបជីវិតវាត្រូវអស់ដែរ ។ លោកជឿខ្ញុំចុះទាន សាកល្បងលួចរត់ រឺជួយអ្នកណាអោយរត់គឺត្រូវអស់ជីវិតទាំងខ្លួនឯង និងទាំងគ្រួសារថែមទៀត ។ ពួកវាតឹងរឹងណាស់ទាន ។

- រួចអីចឹង ទាំងអស់គ្នាទៅអោយគេសំលាប់ដូចរង្វេងចៀមអីចឹង ?

- គ្មានជំរើសអីទៀតទេ ។ នេះជាឆន្ទៈរបស់ព្រះជាម្ចាស់ ។

កុំឆេះដុំ ហើយកុំស្លន់ស្លោអាវ៉ា -*ប្លាក់ថន* ព្រមានខ្លួនគេនៅក្នុងចិត្ត-ត្រូវតែអត់ធ្មត់។ ម្តែងអាចគិតរកផ្លូវដោះខ្លួនបាន ។ មិនមែនស្អីដែលបព្វជិតនេះ និយាយសុទ្ធតែជាការពិតនោះទេ ។ តានេះឡប់១ផង ។ រួចអ្នកណាមិនឡប់ បើនៅកន្លែងនេះយូរយារយ៉ាងនេះ ?

បព្វជិតពោលបន្តទៀត :

- អារឿងគុកនេះ គឺថ្មីថ្មោងណាស់សំរាប់ពួកគេ ។ *វ៉ែតូ* បានចាត់តាំងគុកឡើង កាលពីប៉ុន្មានឆ្នាំមុននោះ បើតាមពួកគេនិយាយ ។ មុនជំនាន់លោកស្រុកនេះមិនដែលមានគុកទេ ។ កាលពីមុនទៅពេលគេចាប់មនុស្សបាន មនុស្សនោះសារភាពទោសខ្លួន ហើយបន្ទាប់មក គេក៏ប្រហារជីវិតចោលទៅ ។

- រួចចុះ បើមនុស្សនោះមិនសារភាព ?

- ទាំងអស់គ្នាត្រូវតែសារភាពទាន........ សារភាពកាន់តែឆាប់កាលណា កាន់តែល្អពេលនោះ ។ វាដូចជានៅក្នុងស្រុកយើងអីចឹងដែរតើ នៅពេលណាដែលយើងត្រូវគេចាប់ខ្លួននោះ ។

បព្វជិតចំនាស់ ក៏លង់លក់នៅក្នុងដំណេកម្តងទៀត ទាំងមមើពោលរង៉ូវ១ ហើយអេះ



www.budinst.gov.kh www.elibraryofcambodia.org

ខ្វារមិនដាច់ ។ នៅពេលគាត់ភ្ញាក់ឡើង *ភ្លាក់ថន* ក៏ពោលទៅកាន់គាត់ :

- សូមតេជគុណប្រាប់ខ្ញុំមើល ថាហេតុអីបានជាពួក *យេស៊ុីត* ទុះបាញ់នេះយកសង្ឃមកដាក់ក្នុងគុកនេះវិញ ?

- ដូចជាគ្មានរឿងអីច្រើន នឹងនិយាយទេ ។ ក្រោយពីមនុស្សរបស់តៃកូ បានមករឹបអូសយកទ្រព្យសម្បត្តិយើងទាំងអស់មក លោកមេបញ្ជាការបានទាមទារទៅទីក្រុង ដើម្បីតវ៉ានឹងអំពើនេះព្រោះថាគ្មានហេតុផលដែលត្រូវរឹបអូសទ្រព្យសម្បត្តិយើងសោះ ។ យើងជាមិត្តនឹងគ្នា ហើយ *តៃកូ* ខ្លួនឯងបានស្នើអោយម៉ានីលដែល នៅក្រោមការគ្រប់គ្រងរបស់អេស្ប៉ាញ អោយធ្វើជំនួញត្រង់ជាមួយជប៉ុនតែម្តង ដើម្បីបំបែកការផ្តាច់មុខរបស់ប៉ុកទុយកាល់ ។ ហេតុនេះយើងគិតថា ការរឹបអូសនេះ គឺជាការភ័ន្តច្រលំទេ ។

ខ្ញុំក៏ធ្វើដំណើរទៅជាមួយលោកមេបញ្ជាការដែរ ។ ពួក *យេស៊ុីត* ហើយនៅក្នុងនេះមានអាម្នាក់ឈ្មោះ *ម៉ាកតាំងអាលវីតូ* បានស្នើសុំចរចាជំនួសយើង នៅឯក្យូដូជារាជធានីនោះ ។ ពួកអាពោះវៀនបត់ចន្ទាសនេះ ! គណៈសង្ឃនៃនិកាយយើង *ព្រីយ៉ាប្រាកង់សា* ស្ថិតនៅក្នុងរាជធានីដែរក្នុងឋានៈជាឯកអគ្គរាជទូត ។ ជាឯកអគ្គរាជទូតពេញច្បាប់ ពីប្រទេសអេស្ប៉ាញប្រចាំនៅនឹង *តៃកូ* ចំនួនប្រាំឆ្នាំមកហើយ ។ *តៃកូ* ខ្លួនឯងបានស្នើឧបរាជរបស់យើងនៅឯម៉ានីលអោយបញ្ជូនសង្ឃនិកាយ *ប្រង់ស៊ីស្កាំង* និងឯកអគ្គរាជទូតមកជប៉ុននេះ ។ ហើយពួកយើងគិតថាតេជគុណ *ព្រីយ៉ា* ជាមនុស្សទុកចិត្តបាន មិនមែនដូចពួក *យេស៊ុីត* ទេ ។

ក្រោយពីរង់ចាំរាប់ថ្ងៃមក យើងបានជួបជំជែកគ្នាម្តងជាមួយ *តៃកូ* ។ អាគាត់ណាស់មានតួចកញ្ជើប ហើយអាក្រក់ណាស់ទាន ។ យើងស្នើសុំសម្បត្តិទ្រព្យយើងវិញ ហើយនិងសំពៅមួយ ។ បើមិនបានសំពៅយើងស្នើដោយសារសំពៅណាមួយក៏បាន ហើយយើងសុខចិត្តចេញលុយ ។ កាលនោះយើងមានអារម្មណ៍ថា ជំនួបនោះបានប្រព្រឹត្តទៅល្អស្រួលបួលទេ ហើយ *តៃកូ* ក៏អោយយើងត្រលប់មករង់ចាំដំណឹងសិន ។ យើងក៏មកស្នាក់នៅវិហារ របស់ពួកយើងនៅឯក្យូដូនោះដើម្បីរង់ចាំ ហើយក្នុងពេលរង់ចាំដំណឹងប៉ុន្មានខែនេះ យើងក៏បន្តផ្សព្វផ្សាយសាសនាទៅទៀត ។ យើងចាត់ចែងសូត្រធម៌ជាចំហ មិនមែនដូចចោរកណ្តាលយប់របៀបពួក



www.budinst.gov.kh www.elibraryofcambodia.org

*យេស៊ុីត* នោះទេ ។ យើងស្លៀកពាក់ស្បង់របស់យើង មិនមែនស្លៀកពាក់បន្លំភ្នែកគេ ដូចពួកសង្ឃនៅស្រុកនេះទេ ។ យើងផ្សព្វផ្សាយធម៌ដល់ប្រជាជន ដល់អ្នកពិការ ដល់អ្នកមានជំងឺដំកាត់ មិនមែនដូចពួក*យេស៊ុីត* ដែលចាក់ចេកចាក់ស្ករ តែជាមួយពួកស្ដេច និងនាម៉ឺននោះទេ ។ សហគមន៍យើងពេលនោះ មានសមាជិកកើនឡើងជាលំដាប់ យើងមានពេទ្យព្យាបាលមនុស្សឃ្លង់ ។ យើងមានវិហាររបស់យើង ហើយអ្នកសុំចូលក៏ចេះតែកើនឡើង ។ យើងហៀបតែនឹងបញ្ចុះបញ្ចូលពួកស្ដេច នៅស្រុកនេះបានទៅហើយ ស្រាប់តែថ្ងៃមួយយើងត្រូវគេក្បត់បណ្ដោយ ។

ថ្ងៃមួយនៃ ខែមករា ពួកយើងដែលជាពួក*ប្រង់ស៊ីស្កាំង* ទាំងអស់ត្រូវគេនាំឡើងទៅតុលាការ ។ ហើយយើងត្រូវទទួលការចោទប្រកាន់មួយដោយមានត្រារបស់ *តៃកូ*ផ្ទាល់ថា ពួកយើងជាអ្នករំលោភច្បាប់របស់អ្នកស្រុកនេះ ថាពួកយើងជាអ្នកបង្កភាពវឹកវរ ហើយត្រូវប្រហារជីវិតដោយឆ្កាង ។ ពួកយើងមានគ្នាទាំងអស់សែសិបនាក់ ។ វិហាររបស់យើង ដែលនៅទូទាំងប្រទេស ត្រូវកំទេចចោល ហើយសហគមន៍យើងត្រូវរំលាយ ។ រំលាយតែពួកប្រង់ស៊ីស្កាំង មិនមែនរំលាយទាំងពួកយេស៊ុីតនោះឡើយ ។ តែពួកយើងគត់ទាន ! ពួកយើង ត្រូវគេចោទមូលបង្កាច់យ៉ាងអយុត្តិធម៌ ។ ពួកយេស៊ុីតបានទៅផ្លុំពិសដាក់ត្រចៀករបស់ *តៃកូ*ថា ពួកយើងជាពួក*កុងគីស្តាឌ័រ* ថាពួកយើងទន្ទ្រានដែនឆ្នេរសមុទ្រប្រទេសជប៉ុន រួចការពិតគឺពួក*យេស៊ុីត* នេះឯងដែលទៅលុតក្រាបអង្វរឧបរាជពួកយើងអោយបញ្ជូនទ័ពពីភីលីពីនមកទីនេះ ។ ខ្ញុំឃើញសំបុត្រនេះដោយភ្នែកខ្ញុំផ្ទាល់ ។ អ្នកផ្ញើសំបុត្រ គឺប្រធានគណៈសង្ឃរបស់ពួកវា ។ ពួកវាគឺជាពួកបិសាចដែលអះអាងថាបំរើព្រះវិហារ បំរើព្រះគ្រិស្ត តែតាមពិតទៅពួកវាបំរើផលប្រយោជន៍ពួកវាតែប៉ុណ្ណឹង ។ ពួកវាស្រេកឃ្លានណាស់អំនាច ទោះជាត្រូវធ្វើអ្វីក៏ដោយ ។ ពួកគេធ្វើហាក់ដូចជា ក្រហាមនិងលត់ដំណាស់ តែកំបាំងពីគេវិញ ពួកវារស់នៅដូចស្ដេច ហើយវេចញាត់ទ្រព្យសម្បត្តិមិនស្ទើរទេ ។ តាមពិតពួកវាច្រណែននឹងសហគមន៍របស់ពួកយើងតែប៉ុណ្ណឹងឯង ។ *ដៃមីញ៉ូ* ខេត្ត*ហ៊ីសិន* ឈ្មោះ *ហារីម៉ា គាដារ* ហើយដែលមានឈ្មោះ ក្នុងគ្រិស្តសាសនាថា *ដូមប្រាន់ស៊ីស្កូ* នោះ បានខំជួយពួកយើងដែរ ហើយដៃមីញ៉ូម្នាក់១គឺជាស្ដេចណា ។ *ដូមប្រាន់ស៊ីស្កូ* ជាសាសនិក*ប្រង់ស៊ីស្កាំង* តែទោះជាយ៉ាងណាក៏ឥតបានផលដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅទីបញ្ចប់ ពួកយើងម្ភៃប្រាំមួយនាក់ត្រូវគេយកទៅប្រហារជីវិត គឺប្រាំមួយនាក់ជាជនជាតិអេស្ប៉ាញ ដប់ប្រាំពីរនាក់ជាជនជាតិជប៉ុនដែលចូលនិកាយយើង ហើយនិងក្មេងប្រុសជំទង់បីនាក់ក្នុងសហគមន៍យើង ។ អូ ! លោកដឹងទេ ថាតើថ្ងៃនោះជំនឿបានលេចឡើងយ៉ាងណា ? ថ្ងៃនោះគឺជាថ្ងៃដ៏ត្រជាក់បំផុត នៃខែកុម្ភៈ ហើយ ក៏ជាឆ្នាំដ៏ជូរចត់ បំផុតដែរ ។ ឆ្នាំនោះមានការកើតរំជួយផែនដីផង មានខ្យល់ព្យុះ ទឹកជំនន់ ភ្លើងឆេះថែមទៀត ហើយសូម្បីតែវិមានដ៏ធំរបស់ មេមហាឃាតករ ឈ្មោះ *ភូជីមី* ក៏ត្រូវរលំដែរ ។

ទឹកមុខ របស់តាចាស់ប្រែជាស្លូតស្រពោន :

- អីចឹងហើយពួកអេស្ប៉ាញយើងប្រាំមួយនាក់ត្រូវទទួលមរណភាព សហគមន៍ និងព្រះវិហារយើងត្រូវរលាយខ្ចាត់ខ្ចាយ ហើយមន្ទីរពេទ្យក៏ត្រូវបិទទ្វារ ។ ខ្ញុំ..........ខ្ញុំគឺជាអ្នកដែលត្រូវយកទៅប្រហារជីវិតដែរ ប៉ុន្តែ..........ប៉ុន្តែ...........ខ្ញុំមិនមានសំណាងបានទទួល កិត្តិយសស្លាប់ដើម្បីព្រះធម៌សោះ។ ពួកវាបង្ខំអោយយើងដើរតាំងពីក្យូជូ មក*អូសាកា*នេះ ។ ពេលមកដល់ ពួកវាយកពួកយើងមួយចំនួនទុកក្នុងវិហារយើង ឯអ្នកដែលនៅសល់...........អ្នកដែលនៅសល់ត្រូវគេកាត់ត្រចៀកម្ខាង រួចគេបណ្ដើរតាមផ្លូវដូចជាពួកចោរហារយអីចឹង រួចបន្ទាប់មកគេនាំអ្នកទាំងនោះទៅទិសខាងលិច ។ ដើរអស់មួយខែទើបដល់ភ្នំ *នីស៊ីសាគិ* ដែលនៅចំនោតពីលើកំពង់ផែ *ណាកាសាគី* ហើយគេសំលាប់អ្នកទាំងនោះនៅកន្លែងនោះ ។ កាលនោះគេបញ្ជាខ្ញុំអោយវិលត្រលប់មក *អូសាកា* វិញ ទោះជាខ្ញុំអង្វរសាមូរ៉ៃនោះយ៉ាង ណាក៏ដោយ ។ មួយខែក្រោយព្រឹត្តិការណ៍នោះមក ពួកយើងត្រូវគេញាត់ចូលគុក ។ កាលនោះពួក យើងមានគ្នាបីនាក់ នេះបើតាមខ្ញុំចាំ តែខ្ញុំជាជនជាតិអេស្ប៉ាញតែម្នាក់គត់ ។ ពីរទៀតជាពួកជប៉ុនដែលចូលនិកាយយើង ។ ប៉ុន្មានថ្ងៃក្រោយមកពួកឆ្មាំបានហៅពួកគេទៅ ។ ប៉ុន្តែពួកវា មិនដែលហៅឈ្មោះខ្ញុំសោះ រឺមួយក៏នេះជាឆន្ទៈរបស់ព្រះជាម្ចាស់ក៏មិនដឹង រឺមួយក៏ពួកអា *យេស៊ូត៍* នេះទុកខ្ញុំអោយរស់នៅដើម្បីធ្វើទារុណកម្មខ្ញុំអោយលំបាកវេទនាក៏មិនដឹង ។ មិនមែនជាការងាយស្រួលទេការអត់ធ្មត់នេះ ។ លំបាកណាស់ទាន ............

បព្វជិតចំនាស់ក៏បិទភ្នែក ហើយស្ងូត្រធម៌បណ្ដើរ យំបណ្ដើរ រហូតដល់គាត់លង់លក់តែម្ដង ។



www.budinst.gov.kh www.elibraryofcambodia.org

ថ្វីត្បិតតែយប់បានមកដល់ ថ្វីត្បិតតែគេប្រឹងបិទភ្នែកយ៉ាងណាក្តី ក៏ *ប្លាក់ថន* ដេកមិនលក់សោះ ។ ស្បែករបស់គេញាក់ទទ្រើកក្រោមការខាំជញ្ជក់ឈាមរបស់ចៃ ។ រួចក្បាលរបស់គេឡើងវិជ្ជយព្រោះការភ័យខ្លាច ។

គេបានដឹងយ៉ាងសែនមហាច្បាស់ថា គេមិនអាចមានមធ្យោបាយអ្វីនឹងគេចចេញពីទីកន្លែងនេះឡើយ ។ គេដឹងថា ខ្លួនគេមិនអាចធ្វើអ្វីបានទាំងអស់ ហើយខ្លួនគេកំពុងតែត្រូវមច្ចុរាជតថ្លៃហើយ ។ នៅក្នុងស្បែងងឹតនៃរាត្រីកាល ភាពតក់ស្លុតបានមកទន្ទ្រានលុកលុយខ្លួនគេ ហើយជាលើកទីមួយនៅក្នុងជីវិតរបស់ខ្លួនគេចាប់ផ្តើមយំខ្សឹកខ្សួល ។

បព្វជិត អោនមកនិយាយខ្សឹប១ជាមួយ *ប្លាក់ថន* :

- យ៉ាងម៉េច កូនប្រុស ? មានរឿងអី ?

ទាំងដើមទ្រូងញាប់ញ័រ *ប្លាក់ថន* ពោលតបវិញ :

- អត់មានអីទេ ! អត់មានអីទេ ! អញ្ជើញសំរាន្តវិញចុះ ។

- គ្មានរឿងអីត្រូវខ្លាចទេ ។ ជីវិតរបស់យើងអាស្រ័យព្រះជាម្ចាស់លោកកំនត់ទេ ។

ក្រោយពីនិយាយឃ្លានេះហើយ បព្វជិតចំនាស់ ក៏គេងលក់បន្តទៀតទៅ ។

ភាពតក់ស្លុតបានចាកចេញពីរូប *ប្លាក់ថន* ហើយជំនួសដោយការភ័យខ្លាចមួយ ដែលអាចទ្រាំទ្របាន ។ ទោះជាយ៉ាងម៉េចយ៉ាងម៉ា អញនឹងចាកចេញពីទីនេះទាល់តែបានគេខំនិយាយកំលាខ្លួនឯង ដោយខំដាក់ចិត្តទាំងប៉ុន្មានអោយជឿលើការកុហករបស់ខ្លួនឯងនេះ ។

នាពេលព្រឹកព្រលឹមគេបានយកម្ហូប និង ទឹកមកចែកអោយអ្នកជាប់ឃុំជាថ្មី ។ ពេលនេះ *ប្លាក់ថន* មានកំលាំងកំហែងខ្លាំងជាងមុន ។ អ្ហែងចំជាទ្រើកមែន ដែលបណ្តោយខ្លួនអោយបាក់អារម្មណ៍យ៉ាងនេះ -គេបន្ទោសខ្លួនឯង - ទ្រើក ខ្សោយ ហើយគ្រោះថ្នាក់ថែមទៀត ។ អ្ហែងមិនត្រូវបាក់ទៀតទេ ។ បើអ្ហែងបាក់ អ្ហែងនឹងឆ្កួតលេលា ហើយស្លាប់ជាមិនខាន ។ ពួកគេនឹងដាក់អ្ហែងនៅជួរកណ្តាល ហើយអ្ហែងពិតជាស្លាប់ ។ ត្រូវប្រយ័ត្នប្រយែង អត់ធ្មត់ ហើយរក្សាខ្លួន ។

- ថ្ងៃនេះ តើលោកយ៉ាងម៉េចដែរទាន ?

- ស្រួលបួលទេតេជគុណ ! សូមអរគុណ ។ រួចតេជគុណយ៉ាងម៉េចដែរ ?



www.budinst.gov.kh www.elibraryofcambodia.org

- ល្អណាស់ ។ អរគុណ ។

- ឃ្លាណឹង បើចង់និយាយភាសាជប៉ុន ថាម៉េច ?

- *ដូម៉ូ កិនតី វេស៊ូ*

- *ដូម៉ូ កិនតី វេស៊ូ* ។ កាលពីម្សិលមិញ គេជគុណនិយាយពីរឿងសំពៅខ្មៅរបស់ពួកប៉កទុយកាល់ ។ តើសំពៅណឹងវាមានរាងយ៉ាងម៉េច ? តើគេជគុណដែលឃើញទេ ?

- ដែលឃើញទាន ។ នេះជាសំពៅធំជាងគេបំផុតលើពិភពលោក ។ ចំនុះវា មានប្រហែល ពីរពាន់តោន ។ គ្រាន់តែបើកបរវា គេត្រូវការមនុស្សប្រហែលពីររយនាក់ ហើយបើរាប់ទាំងនាវិក ទាំងអ្នកដំណើរ សំពៅនេះអាចដាក់បានមនុស្ស ប្រហែលមួយពាន់នាក់ ។ គេប្រាប់ខ្ញុំថា សំពៅនេះរត់ស្រួលណាស់បើបណ្តោយខ្យល់ តែរត់ទទឹងខ្យល់គឺយ៉ាប់ ។

- តើសំពៅនេះមានកាំភ្លើងធំប៉ុន្មានដើម ?

- ពីម្ភៃទៅសាបសិបដើមក្នុងបីជាន់ ។

បព្វជិត ដូមិញកូសប្បាយចិត្តណាស់នឹងឆ្លើយសំនួររបស់*ញាក់ថន* ដោយលោកនិយាយនិងបានបង្រៀនណែនាំ ឯ*ញាក់ថន* ក៏សប្បាយចិត្តស្តាប់ និងរៀនសូត្រផងដែរ ។ ការយល់ដឹងពីនេះបន្តិចពីនោះបន្តិចរបស់បព្វជិតចំនាស់ គឺពិតជាមានតំលៃកាត់ថ្លៃមិនបាន ។

គាត់បន្តទៀត :

- ទេ *ដូម៉ូ* មានន័យថាអរគុណ ឯ *ដូស្សូ* មានន័យថា សូមអញ្ជើញ ។ ទឹកគេថា *មីស៊ូ* ។ ម្យ៉ាងទៀត លោកត្រូវចាំជាប់នៅក្នុងចិត្តថា ពួកជប៉ុនយកចិត្តទុកដាក់ជាសំខាន់លើរកពានិងរបៀបរបបគួរសមនេះ ។ ហ៊ឺ ! បើសិនជាខ្ញុំមានក្រដាស មានទឹកខ្មៅ និងស្លាបក្កាន ! អូមែន ! គិតឃើញហើយ ! ខ្ញុំសរសេរពាក្យនៅលើដីនេះ ដើម្បីលោកងាយចងចាំ.........

- *ដូម៉ូ* !

*ញាក់ថន* ឆ្លើយតបទៅតាចាស់ ។ ក្រោយពីទន្ទេញចាំពាក្យ បីបួនម៉ាត់ទៀតហើយ គេក៏សួរបន្តទៅទៀត !

- តើពួក ប៉កទុយកាល់មកដល់ស្រុកនេះតាំងពីពេលណាមក ?



www.budinst.gov.kh www.elibraryofcambodia.org

- អូតាំងពីពេលដែលគេរកឃើញស្រុកនេះ នៅឆ្នាំ១៥៤២ម្ល៉េះទាន។ គឺឆ្នាំដែលខ្ញុំកើតតែម្តង កាលនោះមានមនុស្សបីនាក់ គឺ *ដាម៉ូតា ប៉ីសូតូ* និងម្នាក់ទៀតខ្ញុំមិនចាំឈ្មោះ ។ អ្នកបីនាក់នេះ គឺជាឈ្មួញ ប៉កទុយកាល់រកស៊ីតាមសំពៅចិនពីកំពង់ផែស្រុកសៀម ហើយសៀវតាមឆ្នេរសមុទ្រស្រុកចិន ។ តើលោកដែលបានទៅដល់ស្រុកសៀមទេ ?

- ទេ !

- ហ៊ឺ នៅអាស៊ីនេះមានកន្លែងមើលច្រើនណាស់ ។ ពួកអ្នកទាំងបីនាក់នេះដើររកស៊ីតែក៏ត្រូវព្យុះកំបុកត្បូងវាយផាត់ពីផ្លូវ ហើយមកដល់ *តានេកាស៊ីម៉ា* នៅ*គ្យូស៊ូ* ។ កាលនោះគឺជាលើកទីមួយហើយ ដែលមានជនជាតិអឺរ៉ុបបានជាន់ដីជប៉ុន ។ ហើយគេក៏ចាប់ទាក់ទងរកស៊ីចាប់ពីពេលនោះមក ។ ប៉ុន្មានឆ្នាំក្រោយមក *ប្រង់ស៊ីស សាវីយេ* ដែលជាអ្នកបង្កើតសហគមន៍យេស៊ុីតម្នាក់ក៏បានមកដល់ទីនេះ ។ កាលនោះ គឺនៅឆ្នាំ ១៥៤៩..............នេះគឺពិតជាឆ្នាំចង្រៃសំរាប់ប្រទេសជប៉ុនតែម្តង ។ តាមពិតគួរតែអ្នកណាម្នាក់ក្នុងនិកាយយើង ដែលមកដល់ទីនេះ។ បើសិនជាយ៉ាងនេះមែន ពួកយើងច្បាស់ជាគ្រប់គ្រងចក្រភពនេះបាត់ មិនមែនពួក ប៉កទុយកាល់ទេ ។ *ប្រង់ស៊ីស សាវីយេ* ស្លាប់ទៅនៅក្រោយនោះបីឆ្នាំ ។ ស្លាប់នៅស្រុកចិនតែ ម្នាក់ឯងគត់ គ្មានអ្នកណានឹកនាដល់ ............ មិនដឹងជាខ្ញុំបានប្រាប់លោកហើយរឺនៅទេថា ពួក *យេស៊ុីត* ធ្លាប់បានទៅរាជធានីរបស់ស្តេច ចក្រភពស្រុកចិន ដែលមានឈ្មោះថា *ប៉េកាំង* នោះ ? .........

.......ប៉ុន្តែលោកគួរតែទៅ *ម៉ានីល* ទៅប្រទេសភីលីពីនវិញ ពួកយើងមានព្រះវិហារ *កាតេដ្រាល់* ប្អូន មានពួក*កុងគីស្តាឌ័រ* ប្រហែលបីពាន់នាក់ និងទាហានជប៉ុនប្រហែលប្រាំមួយពាន់នាក់ពង្រាយទូទាំងទីកោះ ហើយមានអ្នកបួសរបស់យើងជាងបីរយនាក់............

ខួរក្បាលរបស់ *ប្លាក់ថន* ពោរពេញដោយហេតុការណ៍នានា និងពាក្យជប៉ុនជាឃ្លា១ ។ គេសួរបន្ថែមពីជីវភាពរស់នៅក្នុងប្រទេសជប៉ុន ពី*ដៃមីញ៉ូ* ពី*សាមូរ៉ៃ* ពីពាណិជ្ជកម្ម ពី*ណាកាសាគី* ពីសង្គ្រាម និងសន្តិភាព ពីពួក*យេស៊ុីត* ពួក*ប្រង់ស៊ីស្កាំង* ពីពួកប៉កទុយកាល់នៅអាស៊ី ពីពួកអេស្ប៉ាញនៅម៉ានីល ។ គេសួរបន្ថែមពីរឿងសំពៅខ្មៅ ដែលបើកបរចុះឡើងជារៀងរាល់ឆ្នាំរវាងប្រទេសជប៉ុន នឹងម៉ាកាវ ។ ក្នុងអំលុងពេលបីយប់បីថ្ងៃ *ប្លាក់ថន* អង្គុយជាមួយបព្វជិត



www.budinst.gov.kh www.elibraryofcambodia.org

*ដូមិញ្ញូ*ជាប់ ហើយសួរនិងស្តាប់នូវអ្វីដែលគេចង់ដឹង ។ ពេលយប់គេដេកទាំងមមើមមាយ ហើយនៅពេលភ្ញាក់ឡើងគេក៏សួរបន្តសំនួរបំពេញបន្ថែម លើការយល់ដឹងរបស់គេទៅទៀត ។

នៅថ្ងៃទីបួន ឆ្មាំបានស្រែកហៅឈ្មោះគេឡើង :

- *អាន់ជីន-សាន* !

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ១៥

នៅក្នុងភាពស្ងាត់ស្ងៀម គួរអោយព្រឺព្រួច *ប្លាក់ថន* ក្រោកឈរឡើង ។

- ខមាទោសមកកូនប្រុស ! ខមាទោសអោយរហ័ស !

- ខ្ញុំ.........ខ្ញុំ.........ខ្ញុំគិតថា...........ខ្ញុំ.........

*ប្លាក់ថន* ទើបដឹងថាខ្លួនគេកំពុងនិយាយភាសាអង់គ្លេស ។ គេខាំមាត់ជាប់ ហើយដើរចេញទៅ ។ បព្វជិតចំនាស់ ខំងើបឡើងទាំងញញ៉ីញញ័រ ដោយគិតថា *ប្លាក់ថន* កំពុងតែនិយាយភាសាហូឡង់ រឺអាឡឺម៉ង់ ។គាត់ស្រវាចាប់កដៃ *ប្លាក់ថន* ហើយដើរទាំងប៉ុងពៀចជាមួយគេ ។

-អោយលឿនមកលោក ។ខ្ញុំនឹងសូត្រចមិលាងបាបជូនលោក ។សូមអោយឆាប់ទៅទានដើម្បីវិញ្ញាណក្ខន្ធលោកបានទៅសុគតិភព ។ សូមតែលោកខមាទោសអំពើបាបពីពេល មុន និងពេលបច្ចុប្បន្ននេះចំពោះមុខព្រះទៅ.............

គេកាន់តែមកជិតដល់ទ្វារដែកហើយ ។ ផ្ទុយពីការស្មាន បព្វជិតចាប់ដៃ *ប្លាក់ថន*យ៉ាងរឹងប៉ែសតែម្តង ។

- លោកខមាទោសមក ។ ព្រះជាម្ចាស់ នឹងប្រោសប្រណីលោកជាមិនខាន............

*ប្លាក់ថន* មួលដៃគេចេញ ហើយនិយាយយ៉ាងកំបុតៗ ជាភាសាអេស្ប៉ាញ :

- តេជគុណទៅជាមួយព្រះចុះ !

ទ្វារគុកបិទទៅវិញក្តាំង ពីក្រោយខ្នងរបស់គេ ។

ថ្ងៃនេះចំជាត្រជាក់ផង និងសើមផងមែនទែនតែម្តង ។ ដុំពពកទាំងដុំៗ អណ្តែតក្បឿនៗក្រោមកំលាំងជំនោរអាគ្នេយ៍ ។

*ប្លាក់ថន* ដកដង្ហើមយ៉ាងវែងស្រូបយកខ្យល់បរិសុទ្ធ ហើយឈាមក៏ចាប់ផ្តើមរត់គ្រប់សរសៃសរសួងរបស់គេឡើងវិញ ។ ថាមពលនៃជីវិតបានត្រលប់មករកគេវិញហើយ ។

អ្នកទោសអាក្រាតជាច្រើននាក់ទៀត កំពុងតែនៅឯទីធ្លាជាមួយ អ្នកមុខអ្នកការម្នាក់ ពួកឆ្មាំខ្មាន់លំពែង ពួក*អេតា* និងពួកសាមូរ៉ៃមួយក្រុម ។ អ្នកមុខអ្នកការតំនាងតុលាការនេះពាក់គីម៉ូណូពណ៌ខ្មៅស្រគាំ ដៃស្មាឡើងកំប៉ោងដូចជាស្លាប នៅលើក្បាលមានមួកខ្មៅតូចមួយ ។



www.budinst.gov.kh www.elibraryofcambodia.org

បុរសនេះឈរនៅពីមុខអ្នកទោសដែលនៅមុខគេបង្អស់ ហើយអានសេចក្តីនៅលើសារមួយ ។ នៅពេលដែលគេអានចប់អ្នកទោសម្នាក់ៗ ក៏ដើរតាមឆ្មាំគុករបស់ខ្លួនសំដៅទៅទ្វារធំដែលបើកចេញទៅរកទីធ្លា ។ *ប្លាក់ថន*ដើរនៅខាងក្រោយគេ ។ ផ្ទុយពីអ្នកឯទៀតរូបគេត្រូវបានគេប្រគល់ខោស្នាប់ភ្លៅគីម៉ូណូអំបោះនិងស្បែកជើងឈើចងខ្សែដើម្បីស្បែកពាក់ ។ ហើយឆ្មាំរបស់គេគឺ ពួកសាមូរ៉ៃ ។

គេបានគិតនៅក្នុងចិត្តជាស្រេចថា នៅពេលណាគេឆ្លងទ្វារធំហើយ គេនឹងដាក់មេដាយយកមែនទែនតែម្តង ប៉ុន្តែនៅពេលដែលគេកាន់តែជិតទៅដល់ទ្វារពេលណា ពួកសាមូរ៉ៃកាន់តែមកប្រកៀកព័ទ្ធខ្លួនគេជុំឡើងៗ ហើយគេឈានផុតពីមាត់ទ្វារនៅក្នុងកណ្តាលរង្វង់ពួក សាមូរ៉ៃទាំងនេះ ។ មានមនុស្សជាច្រើននៅកកកុញត្រៀបត្រាងលើទីធ្លានេះ ។ មនុស្សម្នាក់ត្រូវគេចងហើយស្រេចទៅនឹងឈើឆ្កាង ហើយគេក៏ចាប់ផ្តើមលើកឈើឆ្កាងនេះឡើង ។ នៅសងខាងឈើឆ្កាងមាន*អេតា*នាក់កាន់លំពែងចាំងផ្លេកៗ នៅឈរអមហើយជាស្រេច ។

*ប្លាក់ថន* បន្ថយល្បឿនដើររបស់ខ្លួន ។ ពួកក្រុមសាមូរ៉ៃក៏មកអែបជាប់នឹងរូបគេហើយរុញអោយគេដើរលឿន ។ គេគិតយ៉ាងភាន់ភាំងថា បើសិនជាគេស្លាប់នាពេលអីលូវហើយស្លាប់យ៉ាងរហ័សនោះ គឺជាការប្រសើរណាស់ ។ ដោយហេតុនេះហើយ ទើបគេក្តាប់ដៃយ៉ាងណែនដើម្បីឆក់ដណ្តើមដាវណាដែលនៅជិតជាងគេ ប៉ុន្តែគេឥតមានឱកាសសោះ ដោយពួកសាមូរ៉ៃបានដើរផុតពីទីធ្លាសំដៅទៅរកផ្លូវ ដែលឆ្ពោះទៅរកទីក្រុង និងទៅរកវិមានទៅវិញ ។

ឃើញយ៉ាងនេះ *ប្លាក់ថន* សំរេចរង់ចាំទាំងស្ទើរមិនចង់ដកដង្ហើម ដើម្បីអោយប្រាកដនៅក្នុងចិត្តសិន ។ ក្រុមរបស់ពួកគេដើរជ្រែករង្វង់មនុស្ស ដែលនាំគ្នាញែកផ្លូវអោយនោះ ហើយចេញផុតពីរបងបរិវេណគុកដើរតាមផ្លូវតំរង់ទៅទីក្រុងវិញ ។ គ្មានការភាន់ច្រលំទៀតទេនៅពេលនេះ ។

*ប្លាក់ថន* មានអារម្មណ៍ដូចកើតឡើងម្តងទៀត ។

ពេលដែលគេផ្ទៀមបំពង់កល្មមនិយាយបានហើយ គេក៏សួរឡើង :

- តើយើងទៅណាហឹង ?

គេឥតខ្វល់ថាគេនិយាយភាសាអង់គ្លេសទេ ហើយក៏រឹតតែមិនខ្វល់ថាតើអ្នកទាំងនោះ



www.budinst.gov.kh www.elibraryofcambodia.org

យលើរីក៏មិនយល់ដែរ ។ ខួរក្បាលគេឡើងភ្លឺស្រលះថែស ហើយខ្លួនគេឡើងស្រាល ស្ញើកដូច សំលី ។ គេបន្តនិយាយទៅកាន់ពួក*សាមូរ៉ៃ*:

- ឱព្រះអើយព្រះ ។ បាននិយាយភាសាអង់គ្លេសឡើងវិញដូចអស្ចារ្យណាស់តែម្តង ។ ខ្ញុំស្មានថាខ្ញុំត្រូវស្លាប់ហើយ ។ នេះគឺជាជីវិតទីប្រាំបីរបស់ខ្ញុំហើយ ។ នែអាស់លាញ់អាប ឯងមាន ដឹងរឿងណឹងទេ ? អីលូវនេះខ្ញុំសល់តែម៉ាជីវិតទៀតទេ ។ តែកុំទៅខ្វល់ ។ តា*អាល់បានកាភ៉ុក* តែងនិយាយថា ពួកតៃកុងមានជីវិតដប់ណាំ !

ពួក*សាមូរ៉ៃ*ហាក់ដូចជាចេះតែមូម៉ៅឡើងៗ នឹងសំដីប៉ប៉ាច់ប៉ប៉ោចរបស់ *ប្លាក់ថន* ហើយដែលពួកគេស្តាប់មិនយល់សោះនេះ ។

អោយនឹងនអាវ៉ា -គេគិតនៅក្នុងចិត្ត - កុំធ្វើអោយពួកវាមូម៉ៅពើយ ។ រួចរំពេច នោះទើបគេចាប់ភ្លឹកសំគាល់ថា ពួកសាមូរ៉ៃទាំងអស់នេះស្លៀកពាក់ពណ៌ប្រផេះ ។ គឺជាក្រុម របស់អ៊ីស៊ីដូ ។ នៅមុនពេលដែលគេទទួលបញ្ជាអោយក្រោកឈរឡើង និងត្រូវគេនាំយក មកដាក់គុកនេះ គេបានសួរទៅបព្វជិតអាលវីតូ ពីឈ្មោះអ្នកដែលប្រឆាំង*តូរ៉ាណាកា* នោះ ។ អាលវីតូបានពោលថា " *អ៊ីស៊ីដូ* " ។ តើពួកអាវប្រផេះសុទ្ធតែជាមនុស្សរបស់*អ៊ីស៊ីដូ* អ្វី ? ដូច ពួកអាវសំបុរត្នោតទាំងអស់ជាមនុស្សរបស់ *តូរ៉ាណាកា*អីចឹង រឺយ៉ាងមេច ?

- តើអីលូវនេះពួកយើងទៅទីណាណឹង ? ទៅទីណុងមែនទេ ?

គេគេះមេក្រុម ហើយលើកដៃចង្អុលទៅវិមានដែលនៅខ្ពស់ត្រដែតពីលើទីក្រុងដោយ បន្ថែពាក្យថា :

- ទៅទីកន្លែងណុងអ្វី ? *វ៉ៃ*?

- *វ៉ៃ*!

មេក្រុមងក់ក្បាលទំពែករបស់ខ្លួន ។

តើ *អ៊ីស៊ីដូ* ត្រូវការអីពីអញអីចេះ ? - *ប្លាក់ថន*ផ្តើងសួរនៅក្នុងចិត្ត ។

មេក្រុមបត់ចេញ ដើរទៅតាមផ្លូវមួយ ដោយបែរខ្នងទៅកំពង់ផែ ។ ពេលនោះ *ប្លាក់ថន* ក្រលេកឃើញសំពៅ របស់ពួកប៉ិកទុយកាល់ក្លាម ។ គឺជាសំពៅធុនតូចដែលមានទង់



www.budinst.gov.kh www.elibraryofcambodia.org

ពណ៌ខៀវ និង ស បក់វិចទៅតាមជំនោរខ្យល់ ។ នៅថ្នាក់ជាន់លើនៃសំពៅមានកាណុងធំ ហើយនៅក្បាលនិងកន្សៃមានកាណុងមួយដើម១ទៀតផង ។ *អេរ៉ាស* ស៊ីវាយ៉ាងងាយ -ប្លាក់ថន គិតនៅក្នុងចិត្ត ។ រួចចុះពួកដើរសំពៅរបស់អញនោះ វាយ៉ាងម៉េចទៅហើយអ៊ីចេះ ? វាកំពុងធ្វើអីណាំ នៅឯភូមិនោះ ? ហ៊ឺ អញនឹកពួកវាដល់ហើយ............

តែល្ហើយកុំរវល់គិតរឿងតែផ្ដេសផ្ដាសគ្មានបានការនេះ វាគ្មានបានផលអ្វីក្រៅពីធ្វើអោយអ្ហែងទន់ជ្រាយនោះទេ ។ តា*អាល់បានកាភ៉ុក*តែងនិយាយប្រដៅថា :

- ទាល់តែអ្ហែងមានចិត្តមុតមាំទើបអាចរស់នៅជាមួយសមុទ្របានណាំ !

ហ៊ឺ គួរអាណិត *តាអាល់បាន* មែន ។ អស់យេៈពេលរាប់ឆ្នាំ តា*អាល់បានកាភ៉ុក* ប្រៀបបីដូចជាព្រះមួយអង្គ ។ គាត់មើលឃើញអ្វី១ទាំងអស់ ដឹងរឿងរ៉ាវ អ្វី១ទាំងអស់ ។ ប៉ុន្តែគាត់បានបាត់បង់ជីវិតនៅក្នុងភាពតក់ស្លុត ។ កាលនោះ *ប្លាក់ថន* ជាអ្នកបើកសំពៅមួយដែលមានចំនុះមួយរយតោន ហើយដឹកស្បៀង រំសេវ និងឈ្នួន ចេញពីកំពង់ផែ *ប៉ក់មូត* ទៅផ្គត់ផ្គង់អោយកងនាវាចរណ៍របស់*ដ្រេក*នៅ*ឡូវ* ហើយដែលកំពុងជាប់ដៃវៃប្រយុទ្ធ នឹងកងសំពៅខ្មាំង ដែលបើកតាមសមុទ្រ *ប៉ាដឺកាលេ* សំដៅទៅ *ឌុំងកឺក* ជាកន្លែងដែលពួកទ័ពអេស្ប៉ាញនៅរង់ចាំដើម្បីឡើងសំពៅទៅឈ្លានពានប្រទេសអង់គ្លេសនោះ ។

ពេលនោះកងសំពៅអេស្ប៉ាញត្រូវខ្ទេចខ្ទាំទាំងអស់ដោយសារខ្យល់ព្យុះ ទាំងដោយសារសំពៅចំបាំងដ៏លឿន និងងាយបត់បែនទាំងប៉ុន្មានដែល*ដ្រេក* និង*ហូវ៉ាក* បានសាងសង់ឡើងនេះផង ។

ក្នុងពេលដែល *ប្លាក់ថន*កំពុងជាប់ដៃប្រយុទ្ធនៅក្បែរសំពៅរបស់លោក ឧត្តមនាវី *ហូវ៉ាក* ឈ្មោះ *រីវិញ្ជ* នោះ ស្រាប់តែខ្យល់ដូរទិសមួយរំពេច ហើយគេត្រូវតែសំរេចជ្រើសរើសទិសដើម្បីបែរក្បាលសំពៅ ។ បើសិនជាគេបើកសំពៅបញ្ច្រាសខ្យល់ គេច្បាស់ជាអាចគេចផុតពីមុខកាណុងទាំងអស់នៃសំពៅសាន់តាគ្រូសដែលនៅពីមុខគេនោះ ហើយបើគេបត់បណ្ដោយខ្យល់តែនឹងដាច់ចេញពីក្រុមសំពៅរបស់គេ ដែលបានបត់ក្បាលទៅបញ្ឆិតតាមទិសខាងជើងជាស្រេចទៅហើយ១សំពៅរបស់គេនឹងនៅចំកណ្ដាលរង្វង់សំពៅខ្មាំងតែម្ដង ។



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងពេលនោះ *អាល់បានកាភ៊ដុក*ក៏ស្រែកឡើង :

- បត់បញ្ច្រាសខ្យល់ទៅខាងជើងភ្លាមទៅ !

*អាល់បានកាភ៊ដុក* នៅពេលនោះគឺជាអនុបញ្ជាការ ឯ*ប្លាក់ថន*គឺជាប្រធានចង្កូត ហើយជាអ្នកទទួលខុសត្រូវលើនាវានេះ ។

- បត់ភ្លាម !

*ប្លាក់ថន* ស្រែកបញ្ជាហើយគេកាន់ចង្កូតវឹបបែរក្បាលសំពៅទៅទិសខាងត្បូង ចូលចំកណ្តាលវ្យូងសំពៅខ្មាំងភ្លាមដោយគេដឹងថា បើគេបត់ក្បាលទៅទិសផ្សេងទៀតគេនឹងក្លាយទៅជាចំនី នៃគ្រាប់កាណុងរបស់សំពៅធំ ដែលកំពុងតំរង់មករកពួកគេនោះជាមិនខាន ។

ដោយហេតុនេះហើយទើបគេសំរេចបត់ក្បាលបណ្តោយខ្យល់ទៅទិសខាងត្បូងវិញ ។ កាណុងលើជាន់ទាំងបីនៃសំពៅសាន់តាត្រូសបានបាញ់រំលងផុតសំពៅរបស់គេ ហើយសំពៅ របស់*ប្លាក់ថន* ក៏បាញ់សងត្រូវសំពៅ*សាន់តាត្រូស* វិញដែរ ប៉ុន្តែនោះគឺគ្រាន់តែជាដូចជាស្រមោចខាំដំរីតែប៉ុណ្ណោះឯង ។ អីលូវនេះ*ប្លាក់ថន*ត្រូវគេចសំពៅនៅក្នុងចំនោមសំពៅខ្មាំងតែម្តង ។ សំនាងល្អសំពៅខ្មាំងទាំងពីរ ដែលនៅសងខាងសំពៅរបស់*ប្លាក់ថន*គតហ៊ានបាញ់ឡើយ ដោយពួកគេខ្លាចគ្រាប់ទៅត្រូវគ្នាឯង ។ នៅពេលដែលគេចេញផុតពីចំនោមសំពៅខ្មាំង ហើយនោះស្រាប់តែសំពៅ *ម៉ាគដឺឌីយ៉ូស* ដែលមានកាណុងបីថ្នាក់នោះ បានមកពារលើសំពៅរបស់គេតែម្តង ។ ដងក្តោងទាំងពីររបស់សំពៅដាច់ប៉ើងដូចជាផ្លែព្រួញ អូសទាំងមនុស្សដែលជាប់ នឹងក្តោងនោះទៅផង ។ ចំហៀងស្តាំ នៃជើងសំពៅ ត្រូវប៉ើងរយះរយាយ ហើយនៅលើសំពៅគេឃើញមានតែសាកសព និងមនុស្សកំពុងតែគ្រដរខ្យល់ពាសពេញ ។

*ប្លាក់ថន* ក្រលេកឃើញ*អាល់បានកាភ៊ដុក* ទៅផ្តេកនឹងជើងទំរកាណុងមួយ ដែលបែកបាក់ខ្ទេចខ្ទីទៅហើយ ។ រូបរាងគាត់កាន់តែតូចណាស់ទៅទៀត នៅពេលដែលជើងទាំងពីររបស់គាត់ដាច់បាត់ទៅហើយនោះ ។ គេត្រកងតា*អាល់បានកាភ៊ដុក* ដាក់លើភ្លៅ ។ ភ្នែកទាំងគូរបស់តាចាស់ស្ទើរតែធ្លាក់ចេញពីរង្វង់ភ្នែកទៅហើយ១សំរែកគាត់លាន់ឡើងស្ទើរស្រៀវឆ្អឹងខ្នង :

- ព្រះអង្គអើយព្រះអង្គ ! ខ្ញុំមិនចង់ស្លាប់ទេ ...........មិនចង់ស្លាប់ទេ ជួយខ្ញុំផង ជួយខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

ផង ជួយផង អីយ៉ូយ ! ឈឺណាស់លោកអើយ !

ពេលនោះ *ភ្លាក់ថន* ដឹងថាគេមានតែវិធីមួយគត់ដើម្បីជួយតា *អាល់បានកាវ៉ាដុក* ។ គេស្រវាយកចរឹងដែកមួយដែលនៅក្បែរ ហើយបុកចុះយ៉ាងអស់ទំហឹង.............

ប៉ុន្មានអាទិត្យក្រោយមកទើបគេបានប្រាប់ *អេលីស៊ី* ជាប្រពន្ធថា ឪពុកនាងស្លាប់បាត់ទៅហើយ ។ គេគ្រាន់តែប្រាប់នាងថា ឪពុកនាងត្រូវស្លាប់តែមួយប៉ព្រិចភ្នែកតែប៉ុណ្ណោះ តែគេឥតនិយាយប្រាប់នាងថា ឈាមឪពុកនាងនៅជាប់នឹងដៃរបស់គេ ឥតមានរលប់ឡើយ .......

អីលូវនេះ *ភ្លាក់ថន* និងពួក *សាមូរ៉ៃ* កំពុងដើរតាមផ្លូវមួយធំទូលាយ តែបត់បែនក្រមឹកក្រងក់ ។ តាមបណ្តោយផ្លូវនេះគ្មានហាងលក់ដូរទេ ប៉ុន្តែមានផ្ទះនៅជាប់ៗគ្នា ដោយមានរបងខ្ពស់ៗព័ទ្ធជុំវិញ ។ ទាំងផ្លូវ ទាំងផ្ទះ ទាំងរបង មានសភាពស្អាតបាតយ៉ាងអស្ចារ្យតែម្តង ។

ភាពស្អាតបាតនេះធ្វើអោយ *ភ្លាក់ថន* សឹងឆ្ងល់យ៉ាងខ្លាំង ពីព្រោះនៅក្នុងទីក្រុងឡុង៍ និងទីក្រុងផ្សេងៗទៀត ទាំងនៅប្រទេសអង់គ្លេស ទាំងនៅទ្វីបអឺរ៉ុបទាំងមូល អាចម៍ នោម សំរាម ត្រូវគេជះទៅលើថ្នល់ដើម្បីគេសំអាត រឺមួយក៏នៅតររហូតដល់ពេលដែលអ្នកដំណើរសេះ និងរទេះនានាទៅលែងរួច ទើបទីក្រុងទាំងនោះលាងសំអាតខ្លួនឯងតែម្តង ។

អ្នកសំអាតផ្លូវថ្នល់ទីក្រុងឡុងគឺពួកវ៉ូងជ្រូក ដែលគេបណ្តើរតាមដងផ្លូវសំខាន់ៗទាំពេលយប់ ។ ប៉ុន្តែជាទូទៅ គឺកណ្តុរ ឆ្កែឥតម្ចាស់ ឆ្មា និងអគ្គីភ័យទៅវិញទេ ។ ក្រៅពីនេះគឺរុយ ។

ប៉ុន្តែនៅ *អូសាកា* វិញ គឺខុសគ្នាឆ្ងាយណាស់ ។ រួចចុះពួកនេះវាធ្វើយ៉ាងម៉េច ? *ភ្លាក់ថន* ដណ្តឹងសួរនៅក្នុងចិត្ត ។ ផ្លូវគ្មានជង្ហុក គ្មានគំនរអាចម៍សេះ គ្មានស្នាមរទេះ ធ្វើអោយទ្រុឌទ្រោមគ្មានស្រមោលនៃភាពគគ្រិចគគ្រុកណាបន្តិចសោះ គឺមានតែដីដ៏ហាប់ណែន សើមៗ និង ស្អាតគ្មានសំរាមបន្តិចណាសោះ។ ទាំងផ្ទះឈើ ទាំងរបងឈើ គឺស្អាតភ្លឹង។ រួចចុះឯណាទៅ ពួកវ៉ូងស្មូម និងពួកពិការកំបាក់កំពុកនានា ដែលទៅកកកុញក្នុងទីក្រុងនានានៃពិភពគ្រិស្តសាសនានោះ ?

មនុស្សដែលពួកគេជួបសុទ្ធតែលំអោនខ្លួនគោរពយ៉ាងរាបសារ មានអ្នកខ្លះលុតជង្គង់តែម្តង ។ ពួក *កាកា* សែងគ្រែស្នែង រឺអង្រឹងស្នែងយ៉ាងរហ័សរហួនទៅតាមផ្លូវ ។ ពួកសាមូរ៉ៃខ្លះទៀតដែលសុទ្ធតែមានអាវពណ៌ប្រផេះនោះ ដើរលេងតាមបណ្តោយផ្លូវ ដោយឥតរវីរវល់នឹងអ្វី



www.budinst.gov.kh www.elibraryofcambodia.org

អស់ ។ គ្មានសាមូរ៉ៃណាម្នាក់ ដែលពាក់អាវពណ៌ត្នោតឡើយ ។

នៅពេលដែលពួកគេ ដើរតាមបណ្តោយផ្លូវមួយ ដែលមានសុទ្ធតែហាងលក់ទំនិញនោះ *ភ្លាក់ថន* ក៏ទន់ជង្គង់ដួលប្រួសទៅលើដី ។

ពួក*សាមូរ៉ៃ*ជួយគេអោយក្រោកឈរឡើង តែក្នុងមួយរយៈនោះគេមិនអាចដើរទៅមុខបានទេ ។

- *គូមេន ណាសៃ ដូស្វូ កាម៉ាក់ស៊ូ* ! ខ្ញុំសូមទោស សូមរង់ចាំមួយភ្លែត !

និយាយតបបណ្តើរ គេលុញសាច់ដុំកំភួនជើងរបស់គេដែលកំពុងរមួលក្រពើនោះបណ្តើរ ។ នៅក្នុងចិត្ត គេសែនដឹងគុណបព្វជិត *ដូមិញ្ញកូ* ដែលបានបង្ហាត់បង្រៀនគេយ៉ាងច្រើនដូចនេះ ។

មេក្រុមពួកសាមូរ៉ៃ ឈ្ងោកមើល*ភ្លាក់ថន* ហើយនិយាយជាភាសាជប៉ុនមួយប្រាវ ។

- *គូមេន ណាសៃ នីហុងគូកាហាណាសេម៉ាសេន* ! ខ្ញុំសូមទោស ខ្ញុំមិនចេះភាសាជប៉ុនទេ - *ភ្លាក់ថន* ឆ្លើយតបវិញយ៉ាងយឺតៗ តែយ៉ាងច្បាស់ៗ - *ដូស្វូ កាម៉ាក់ស៊ូ* !

- អ្ហា ! *ស្វូដេស៊ូ អាន់ជីន-សាន វ៉ាការីម៉ាស៊ូ* ។

បុរសជាមេយល់ពីអ្វីដែល*ភ្លាក់ថន*ចង់និយាយ ។ គេងាកទៅចេញបញ្ជាយ៉ាងខ្លី ហើយ*សាមូរ៉ៃ*ម្នាក់ក៏រត់រឹងចេញទៅ ។ បន្តិចក្រោយមកទើប*ភ្លាក់ថន*ក្រោកឡើង ហើយខំដើរទាំងខ្ញើចជើងទៅមុខ ប៉ុន្តែបុរសជាមេក្រុមនិយាយថា " *អ៊ីយេ* ! " ហើយធ្វើសញ្ញាអោយគេរង់ចាំ ។

បន្តិចក្រោយទៀតសាមូរ៉ៃអំបាញ់មិញត្រលប់មកវិញ ដោយនាំទាំងកៅអីស្នែង និងអ្នកសែងបួននាក់មកផង ។ សាមូរ៉ៃនោះពន្យល់ប្រាប់*ភ្លាក់ថន* ពីរបៀបអង្គុយកៅអីស្នែង និងរបៀបទប់ខ្លួនដោយតោងនឹងខ្សែមួយ ដែលចងភ្ជាប់ទៅនឹងដងស្នែងនោះ ។

ក្បួនដំណើរក៏ចាប់បន្តទៅទៀត ។ បន្តិចម្តងៗ*ភ្លាក់ថន*ដឹងថាគេមានកំលាំងប្រឹសៗឡើងវិញ ហើយគេក៏ចង់ចុះដើរវិញដែរ ប៉ុន្តែគេដឹងថាខ្លួនគេនៅខ្សោយណាស់ ។ អញត្រូវតែសំរាកមួយរយៈសិន - គេនឹកនៅក្នុងចិត្ត ។ អញបាក់បៀវមែនទែនហើយ ។ អញត្រូវការមុជទឹក និងរកអីទ្រាប់ក្រពះសិន ។ រកម្ហូបមែនទែនមកស៊ី ។



www.budinst.gov.kh www.elibraryofcambodia.org

អីលូវនេះពួកគេដើរតាមជណ្ដើរដ៏ទូលាយៗ ដែលភ្ជាប់ផ្លូវមួយទៅមួយទៀត ហើយគេទៅដល់សង្កាត់មួយ ដែលមានផ្ទះសង់ឃ្លាតៗពីគ្នា ហើយដែលអមដោយបុសព្រៃមួយ ។

នៅពេលដែលពួកគេចូលជ្រៅទៅក្នុងបុសព្រៃនោះហើយ មានពួកសាមូរ៉ៃអាវប្រផេះប្រហែលសាមសិបនាក់បានលេចចេញពីកែងផ្លូវដែលនៅខាងមុខពួកគេនោះ ។ ក្រុមទាំងពីរក៏ឈប់ ហើយក្រោយពីការគោរពគួរសមតាមទំនៀមទំលាប់រវាងក្រុមទាំងពីរនោះមក ភ្នែកមនុស្សទាំងអស់បានបែរទៅស្រោចលើរូប *ប្លាក់ថន* ។ ក្រោយពីការសាកសួរ និងឆ្លងឆ្លើយគ្នាទៅវិញទៅមករួចហើយ ក្រុមទាំងពីរក៏រៀបចំចាកចេញដំណើរទៀត ។ រំពេចនោះមេក្រុមសាមូរ៉ៃម្នាងទៀតហូតដាវចេញយ៉ាងព្រងើយ ហើយចាក់ទំលាយខ្លួនរបស់មេក្រុមពួកសាមូរ៉ៃដែលជូនដំណើរ *ប្លាក់ថន*នោះដួលច្រងាង ហើយក្នុងពេលនោះភ្លាម ពួកអ្នកមកថ្មីទាំងប៉ុន្មានក៏ហក់ដាក់ក្រុមសាមូរ៉ៃរបស់*ប្លាក់ថន* យ៉ាងរហ័ស។ ការវាយស្ទាក់នេះមានលក្ខណៈរហ័ស និងត្រូវបានរៀបចំយ៉ាងល្អមែន ។ គ្រាន់តែមួយប៉ព្រិចភ្នែកពួកសាមូរ៉ៃទាំងដប់នាក់ ដែលជូន*ប្លាក់ថន* មកនេះដួលស្លាប់អស់ភ្លាម គ្មានអ្នកណាមានឱកាសបានដកដាវផងទេ ។

ពួកអ្នកស្លែងទាំងប៉ុន្មាន លុតជង្គង់ជ្រមុជថ្ងាសផ្ទប់ទៅនឹងស្មៅទាំងញ័រចំប្រប់ ។ *ប្លាក់ថន*ឈរនៅក្បែរពួកនេះ ។ មេពួកសាមូរ៉ៃ ដែលជាមនុស្សមានមាឌក្រអាញ និងមានក្បាលពោះស្ញែលនោះបានបញ្ជូនមនុស្សអោយទៅចាំឃ្លាំមើលនៅឯចុងផ្លូវទាំងសងខាង ចំនែកអ្នកឯទៀតដើរប្រមូលសាកសព។ ក្នុងអំលុងពេលនេះ ពួកគេឥតមាន់រវីរវល់អ្វីនឹង *ប្លាក់ថន* សោះឡើយតែលុះនៅពេលដែល *ប្លាក់ថន* ចាប់ផ្ដើមថយក្រោយនោះ សំលេងបញ្ជាយ៉ាងមុតៗរបស់មេក្រុមនេះធ្វើអោយគេនៅស្ពឹងមួយកន្លែងតែម្ដង ។

ក្រោមសំលេងបញ្ជាមួយទៀតពួកក្រុមមកដល់ថ្មីនេះដោះអាវគីម៉ូណូពណ៌ប្រផេះរបស់ខ្លួនចេញភ្លាម ។ នៅពីក្នុងគីម៉ូណូពណ៌ប្រផេះនោះគឺជាអាវកណ្ដោចកណ្ដាច និងគីម៉ូណូកញ្ចាស់ៗតែប៉ុណ្ណោះ។ ទាំងអស់គ្នាក៏ទាញយកកន្សែងដែលគេចងនៅកនោះមករុំមុខភ្លាម។ បុរសម្នាក់ទៀតប្រមូលយកឯកសណ្ឋានពណ៌ប្រផេះទាំងប៉ុន្មាននោះ ហើយគេចចេញទៅតាមព្រៃបាត់ទៅ។

ពួកអាអស់នេះច្បាស់ជាចោរប្លន់ហើយ *ប្លាក់ថន* គិតនៅក្នុងចិត្ត ។ ពីព្រោះបើមិនអីចឹង



www.budinst.gov.kh www.elibraryofcambodia.org

ពួកវាមិនចាំបាច់រុំមុខទេ ? តើពួកនេះត្រូវការអី ចង់បានអីពីអញអីចេះ ?

ពួកចោរប្លន់ទាំងនេះដេកជ្រែកគ្នាយ៉ាងនឹងនរបណ្ដើរ សំលឹងមើល *ភ្ជាក់ថន* បណ្ដើរ ចំនែកឯដៃពួកគេកំពុងជូតដាវនៅលើខោអាវរបស់សាកសពទាំងនោះ ។

- *អាន់ជីន-សាន ? ហៃ !*

ភ្នែករបស់មេក្រុមដែលនៅពីលើក្រណាត់រុំមុខនោះ មានរាងមូលហើយមុត ។

*ភ្ជាក់ថន* តបវិញទាំងឡើងស្បែកគីង្គក់ :

- *ហៃ !*

បុរសនោះ ចង្អុលទៅដីដែលមានន័យច្បាស់ថា មិនអោយគេកំរើកទៅណាឡើយ :

- *វ៉ាការីម៉ាស៊ូកា ?*

- *ហៃ !*

ពួកគេសំលឹងមើល *ភ្ជាក់ថន* តាំងពីក្បាលរហូតដល់ចុងជើង ។ បន្តិចមកឆ្មាំផ្លូវម្នាក់របស់ពួកគេដែលលែងពាក់ឯកសណ្ឋានប្រផេះហើយ១បិទមុខដូចពួកគ្នាគេដែរនោះលេចចេញពីគុម្ពោតព្រៃម្ខាងដែលនៅប្រហែលមួយរយជំហានពីពួកគេ ។ ឆ្មាំនោះលើកដៃសញ្ញាហើយក៏គេចបាត់ទៅ ។

រំពេចនោះពួកអ្នកឯទៀតមកព័ទ្ធជុំវិញ *ភ្ជាក់ថន* ដើម្បីរៀបចំចេញដំណើរ ។មេក្រុមរបស់ពួកចោរសំលឹងមើលអ្នកសែងទាំងបួនដែលកំពុងតែញាក់ទទ្រើក ដូចជាខ្លែងនៅចំពោះមុខ ម្ចាស់ដ៏កំនាចអីចឹង ។ ក្រោមអំនាចនៃក្រសែភ្នែកអ្នកទាំងបួនរឹតតែផ្ទប់ក្បាលទៅនឹងស្មៅ ថែមទៀត ។

រួចមេក្រុមចោរនេះ គំហកបញ្ជាយ៉ាងកំបុត ។ អ្នកទាំបួនងើបក្បាលឡើងទាំងស្រលាំងកាំង ។ក្រោយពីលឺបញ្ជាដដែលនេះម្ដងទៀតអ្នកទាំងបួនលំអោនក្បាលគោរពរួចវារថយក្រោយបានឆ្ងាយបន្តិចហើយទាំងបួននាក់ក៏ងើបឡើងយ៉ាងស្រុះគ្នា ហើយរេរកែងជូនលោកយ៉ាងខ្ទឹតតែម្ដង ។

មេចោរញញឹម រួចហើយក៏ធ្វើសញ្ញាអោយ *ភ្ជាក់ថន* ដើរតាមពួកគេសំដៅទៅទីក្រុង ។ *ភ្ជាក់ថន* គ្មានជំរើសអ្វី ក្រៅពីធ្វើតាមពួកនេះទាំងអស់សង្ឃឹមតែប៉ុណ្ណោះ ។

ពួកគេដើរជិតដល់ចុងព្រៃទៅហើយ ស្រាប់តែក្បួនដំណើរឈប់ស្ងៀមមួយរំពេច ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពីមុខពួកគេមានលីសូរមាត់មនុស្សជជែកគ្នា ហើយបន្តិចក្រោយមកក្រុមសាមូរ៉ៃសាមសិប នាក់លេចចេញពីកែងផ្លូវបត់មក ។ ពួកនេះមានទាំងពួកអាវប្រផេះ មានទាំងពួកអាវពណ៌ត្នោត ប៉ុន្តែពួកអាវពណ៌ត្នោតជាអ្នកនាំមុខក្រុម ។ មេក្រុមរបស់ពួកគេនៅក្នុងកៅអីស្នែង នៅពីក្រោយ ពួកគេមានសេះពីរក្បាលតាមពីក្រោយ ។ពេលឃើញក្រុមរបស់ *ប្លាក់ថន* ពួកគេឈប់ងឹក ហើយ ត្រៀមប្រយុទ្ធមួយរំពេច ។ ក្រុមទាំងពីរសំលឹងសំលក់គ្នាស្ទើរស៊ីសាច់ ។ ពួកគេនៅឈរ ឆ្ងាយ ពីគ្នា ប្រហែលចិតសិបជំហានប៉ុណ្ណោះ ។ មេក្រុមចោរក៏ឈានដើរទៅមុខ ហើយនិយាយ ខ្លាំងៗ ទាំងកំហឹងទៅពួកសាមូរ៉ៃម្ខាងទៀតដោយលើកដៃចង្អុលទៅរក *ប្លាក់ថន* ហើយបន្ទាប់មកចង្អុល ទៅកន្លែងវាយស្លាក់អំបាញ់មិញ ។ បន្ទាប់មកគេហូតដាវចេញលើកឡើងផុតក្បាលយ៉ាងកំនាច។ តាមមើលទៅប្រហែលជាគេប្រាប់អោយពួកម្ខាងទៀតចៀសចេញពីផ្លូវរបស់ពួកគេហើយ ។

ពួកចោរទាំងអស់ហូតដាវរបស់ពួកគេចេញ ។ ក្រោមបញ្ជារបស់មេគេបុរសម្នាក់បាន ដើរទៅឈរពីក្រោយ *ប្លាក់ថន* ដោយយារដាវត្រៀមជាស្រេច ។ បន្ទាប់មកមេក្រុមចោរនៅបន្ត និយាយជាមួយមេក្រុមម្ខាងទៀត ដើម្បីអោយគេបើកផ្លូវអោយក្រុមខ្លួន ។

ទាំងពីរក្រុមនៅស្ងៀមមួយសន្ទុះ រួច *ប្លាក់ថន* ឃើញបុរសម្នាក់ចេញពីក្នុងគ្រែស្នែងមក ហើយគេក៏ស្គាល់បុរសនោះភ្លាម ។ នោះគឺ *កាស៊ុគិ យ៉ាប៊ូ* ។ យ៉ាប៊ូគំហកតបទៅមេចោរវិញ តែ បុរសនេះគ្រវីដាវទាំងកំហឹង ហើយបង្ខំអោយពួករបស់ *យ៉ាប៊ូ* ចៀសចេញពីផ្លូវ ។ រំពេចនោះ *យ៉ាប៊ូ* ចេញបញ្ជាយ៉ាងកំបុត ហើយហូតដាវឡើងយ៉ាងខ្ពស់ រត់សំរុកមករកពួកចោរទាំងជើងប៉ុងខ្ទើច ដោយស្រែកសន្ធាប់យ៉ាងលាន់ខ្ទ័រ ។ ពួកសាមូរ៉ៃរបស់ *យ៉ាប៊ូ* រត់តាមពីក្រោយ ចំនែកឯពួកអាវ ប្រផេះក៏រត់ពីក្រោយថែមទៀត ។

*ប្លាក់ថន* ផ្ទួលខ្លួនចុះក្រោមដើម្បីគេចពីផ្លែដាវ ដែលអាចកាត់គេជាពីរកំនាត់បាន។ រំពេចនោះមេក្រុមចោរ និងកូនចៅគេទាំងប៉ុន្មានប្រាសវឹងរត់ចូលព្រៃប្រោកទាំងអស់គ្នាតែម្តង។

ក្នុងមួយប៉ព្រិចភ្នែកនោះ ពួកសាមូរ៉ៃពណ៌ត្នោត និង ពណ៌ប្រផេះបានមកព័ទ្ធការពារ *ប្លាក់ថន* ជិត ។ *ប្លាក់ថន* ក៏ក្រោកឈរឡើងវិញ ។សាមូរ៉ៃមួយចំនួនរត់ដេញតាមពួកចោរនៅក្នុងព្រៃ មួយចំនួនពង្រាយគ្នានៅតាមដងផ្លូវ ដើម្បីការពារក្បួនរបស់ពួកគេ ។ *យ៉ាប៊ូ* ឈរនៅក្បែរមាត់ព្រៃ



www.budinst.gov.kh www.elibraryofcambodia.org

ហើយស្រែកបញ្ចោយ៉ាងដាច់ណាត់ រួចទើបគេដើរត្រលប់មកក្រោយវិញយ៉ាងយឺតៗបង្ហាញអោយឃើញភាពប៉ុងខ្ចៃរបស់ខ្លួនកាន់តែច្បាស់ឡើង ។

មកទល់មុខ *ប្លាក់ថន យ៉ាប៊ូ* ក៏និយាយឡើងទាំងដង្ហក់ :

- *សូដេស៊ូ អាន់ជីន-សាន* ។

- *សូដេស៊ូ កាស៊ីគី យ៉ាប៊ូ-សាន* ។

*ប្លាក់ថន*ឆ្លើយតបវិញរួចចង្អុលទៅទិសដែលពួកចោរទើបរត់ទៅនោះដោយនិយាយថា:

- *ដូម៉ូ* !

រួចគេលំអោនខ្លួនគោរពយ៉ាងគួរសមក្នុងឋានៈជាអ្នកស្មើគ្នា ហើយគេបន្តនិយាយភាសាជប៉ុនបណ្ដើរ នៅក្នុងពោះជូនពរបញ្ជិត *ដូមិញ៉ូ* ដែលជួយបង្អាក់គេបណ្ដើរ :

- ខ្ញុំសូមទោស ខ្ញុំមិនចេះភាសាជប៉ុនទេ ។

- *ហៃ* !

*យ៉ាប៊ូ* ឆ្លើយតប រួចនិយាយមួយប្រាវទៀត តែ *ប្លាក់ថន* ស្ដាប់មិនយល់ថា តើ *យ៉ាប៊ូ* ចង់និយាយពីអ្វីទេ ។ គេសួរទៅវិញ :

- *ឈូយ៉ាគូ កាស៊ីម៉ាស៊ូកា*? តើលោកមានអ្នកបកប្រែទេ ?

- *អ៊ីយេ អាន់ជីន-សាន* ។ *តូមេនណាសៃ* !

*ប្លាក់ថន* មានអារម្មណ៍ធូរស្រាលចិត្តជាងមុន ។ អីលូវនេះគេអាចនិយាយទាក់ទងបានដោយផ្ទាល់ហើយថ្វីត្បិតគេមិនទាន់ចេះពាក្យបានច្រើនក្ដីក៏ប៉ុន្តែនេះគឺជាការចាប់ផ្ដើមតែប៉ុណ្ណោះ ។

ធ្វើម៉េចមានអ្នកបកណាំ ? -*យ៉ាប៊ូ* គិតនៅក្នុងចិត្ត ។ អញចង់ដឹងណាស់ថាតើមានរឿងរ៉ាវអីកើតឡើងនៅពេលដែលឯងជួប *តូរ៉ាណាកា*នោះ ? តើតូរ៉ាណាកាសួរសំនួរអីខ្លះ ? ហើយតើឯងឆ្លើយអីខ្លះប្រាប់ *តូរ៉ាណាកា* វិញ ? តើឯងមាននិយាយអ្វីខ្លះពីរឿងភូមិ រឿងកាំភ្លើង រឿងអ៊ីរ៉ៃអ៊ីវ៉ាន់ រឿងសំពៅ រឿងវ្ញូឡាគ្រិចនោះ ? អញមហាចង់ដឹងពីរឿងដែលបាននិយាយ ពីរបៀបនិយាយ ក៏ដូចជាចង់ដឹងថា ប៉ុន្មានថ្ងៃនេះឯងទៅឯណា រួចវាយ៉ាងម៉េចបានជាឯងនៅទីនេះ ? បើសិនជាដឹងរឿងអស់នេះអញពិតជាដឹងថា តើ *តូរ៉ាណាកា* មានគំនិតយ៉ាងម៉េច ហើយតើគាត់គិត



www.budinst.gov.kh www.elibraryofcambodia.org

បែបណាជាមិនខាន ហើយអញអាចរៀបផែនការដើម្បីនិយាយជាមួយគាត់នៅថ្ងៃនេះ ជាមិនខាន ។ តែអីលូវនេះគ្មានច្រកអ្វីពិតសោះ ។

រួចម៉េចបានជា *តូរ៉ាណាកា* ជួប *អាន់ជីន-សាន* ឯងភ្លាម តែមិនជួបអញអីចឹង ។ ហេតុអីក៏គាត់គ្មានផ្ដាំផ្ញើពាក្យមួយម៉ាត់ណាសោះដល់អញតាំងពីឡើងគោកមករហូតដល់ថ្ងៃនេះអីចឹង ? ហេតុអីក៏គាត់រកអញនៅថ្ងៃនេះ ? ហេតុអីបានជាគាត់លើកថ្ងៃជួបគ្នាពីរដងហើយអីចឹង ? មកពីឯងមាននិយាយអីប្រាប់ *តូរ៉ាណាកា* រឺ ? រឺមួយក៏ជា *ហ្សឺ-ម៉ាត់ស៊ុ* ? រឺមួយក៏ដោយសារគាត់ខ្វល់ខ្វាយនៅក្នុងចិត្តពេក ?

ពិតហើយលោកម្ចាស់ *តូរ៉ាណាកា* លោកពិតជាមានរឿងរ៉ាវចាក់ស្រេះមែន ។ ឥទ្ធិពលរបស់ *អ៊ីស៊ីដូ* កំពុងតែរាតត្បាតទីដូចភ្លើងឆេះរាលទៅហើយ ។ ហើយតើលោកមានដឹងពីការក្បត់របស់លោកម្ចាស់ *អូណូស៊ី* ហើយរឺនៅ ? ហើយតើលោកមានដឹងទេថា *អ៊ីស៊ីដូ* យល់ព្រមប្រគល់ក្បាលអា *អ៊ីកាវ៉ា ស៊ីគីយូ* ហើយនិងខេត្តរបស់វាអោយមកខ្ញុំ បើសិនណាជាខ្ញុំយល់ព្រមចូលជាសំងាត់ថាជួយគាត់ទេ ?

ហេតុអីបានជា លោកចាត់គេអោយទៅហៅខ្ញុំនៅថ្ងៃនេះ ? រួចកាមីចិត្តល្អណាមួយដែលធ្វើអោយខ្ញុំមកតាមផ្លូវនេះ ហើយបានជួយស្រោចស្រង់ជីវិត របស់ *អាន់ជីន-សាន* យ៉ាងនេះ ? ប៉ុន្ដែ គឺគ្រាន់តែដើម្បីចុកឈាមតែប៉ុណ្ណឹង ព្រោះមិនអាចនិយាយផ្ទាល់ជាមួយវាបាន រឺរកពឹងអ្នកណាជួយបកក៏មិនបាន ដើម្បីរកឃើញចំនុចអាថ៌កំបាំងរបស់ តូរ៉ាណាកា ។ ហេតុអីបានជាលោកឯងយកវាទៅដាក់គុកអ្នកទោសអស់ជីវិតអីចឹង ? ហេតុអីបានជា *អ៊ីស៊ីដូ* យកវាចេញពីគុក ? ហេតុអីបានជាពួកចោរចង់ចាប់វាដើម្បីដូរយកលុយ ? អ្នកណាជាអ្នកលោះវាពីចោរ ? រួចហេតុអីបានជា *អាន់ជីន-សាន* មិនងាប់ ? អាចោរនោះអាចកាប់វាដាច់ជាពីរកំនាត់យ៉ាងងាយដូចបកចេកទេតើ ?

*យ៉ាប៊ូ* កត់សំគាល់ស្នាមស្លាក់យ៉ាងជ្រៅៗនៅលើផ្ទៃមុខរបស់ *ភ្ញាក់ផុន* ដែលកាលពីពេលជួបគ្នាដំបូងគេឥតមានទាល់តែសោះ ។ មើលទឹកមុខស្លេងហាក់ដូចជាស្លេងដាច់បាយពីអង្កាល់ណាមកអីចឹង - *យ៉ាប៊ូ* គិតនៅក្នុងចិត្ត ។ វាប្រៀបដូចជាឆ្កែអត់ម្ចាស់អីចឹង ។ តែមិនមែនជាឆ្កែ



www.budinst.gov.kh www.elibraryofcambodia.org

ណាមួយក្នុងចំនោមវ៉ុងស្តែនោះទេ ។ វាគឺជាមេរ៉ុងតែម្តង ។

មែនណា៎ ! តែកុង បើសិនជាមានអ្នកបកប្រែណាមួយគួរជាទីទុកចិត្តបាននៅពេលនេះ អញសុខចិត្តអោយមួយពាន់*កូគូ* ភ្លាម ។

អញនឹងក្លាយជាម្ចាស់ឯងមិនខាន ។ ឯងនឹងសង់សំពៅអោយអញ ឯងនឹងបង្រៀនមនុស្សរបស់អញ ។ ទោះជាយ៉ាងម៉េចយ៉ាងម៉ាអញត្រូវតែញាក់*តូរ៉ាណាកា* អោយបាន ។ បើមិនបានក៏គ្មានការអីដែរ ។ ដល់ជាតិក្រោយអញនឹងរៀបចំអោយបានល្អជាងនេះ ។

*យ៉ាប៊ូ* បន្លឺសំដីដោយលាយទាំងស្នាមញញឹមបន្តិចផង :

- អារិគ្គតូ ។ អ្វីដែលអ្នែងត្រូវការគឺកណ្តាប់ដៃដ៏ណែន ឆ្អឹងខ្នង១ និងខ្សែតីម្តងម្កាល ។ ដំបូងអញនាំអ្នែងទៅលោកម្ចាស់ *តូរ៉ាណាកា* ប៉ុន្តែមុនបង្អស់អ្នែងទៅមុជទឹកសិន ។ អ្នែងធុំក្លិនមែនទែន លោកម្ចាស់តែកុង !

*ប្លាក់ថន* ឥតយល់ថា *យ៉ាប៊ូ* និយាយអ្វីទេ ប៉ុន្តែគេមានអារម្មណ៍ពីភាពស្និទ្ធស្នាល នៅក្នុងសំដីរបស់ *យ៉ាប៊ូ* ហើយគេឃើញ*យ៉ាប៊ូ*ញញឹមថែមទៀតផង ។ គេញញឹមតបវិញ :

- *វ៉ាការីម៉ាសេន* ។ ខ្ញុំមិនយល់ទេ ។

- *វ៉ៃ អាន់ជីន-សាន* ។

*យ៉ាប៊ូ*ងាកទៅទិសដែលពួកចោររត់ទៅ ហើយក៏ក្តោបដៃប្រកូកហៅ ។ ភ្លាមនោះពួកអាវខ្មៅតក់រិលត្រលប់មកវិញភ្លាម ។ មេក្រុមពួកអាវប្រផេះស្រែកប្រាប់គ្នាគេអោយឈប់ដេញតាមពួកចោរទៀតដែរ ។ គ្មានចោរណាម្នាក់ត្រូវគេចាប់បានឡើយ ។

នៅពេលដែលមេក្រុមពួកអាវប្រផេះមកជួប *យ៉ាប៊ូ* ពួកគេទាំងពីរនាក់មានការជជែកប្រកែកគ្នាយ៉ាងច្រើន ហើយចង្អុលចុះឡើង១ម្តងទៅវិមាន ម្តងទៅទីក្រុងទំនងជាមិនឯកភាពគ្នា ។

នៅទីបញ្ចប់ *យ៉ាប៊ូ* លែងរវល់ស្តាប់អ្នកម្ខាងទៀត ។ គេដាក់ដៃនៅលើដងដាវ ហើយធ្វើសញ្ញាអោយ*ប្លាក់ថន*ឡើងត្រែស្នែង ។

- *អ៊ីយេ* - មេក្រុមពួកអាវប្រផេះបន្លឺឡើង ។

អ្នកទាំងពីរចាប់ផ្តើមសំលឹងស្ទាបស្ទង់គ្នាចុះឡើង ចំនែកឯក្រុមអាវពណ៌ខ្មៅ និងពណ៌



www.budinst.gov.kh www.elibraryofcambodia.org

ប្រផេះ ក៏រាងបែបរសាប់រសល់នៅមិនសុខដែរហើយ ។

- *អាន់ជីន-សាន វេស៊ូ ស៊ុនជីន តូរ៉ាណាកា-សាម៉ា*...........

*ប្លាក់ថុន*ស្តាប់បានពាក្យនេះមួយម៉ាត់ ពាក្យនោះមួយម៉ាត់ ។ *វ៉ាតាគូស៊ី* មានន័យថា " ខ្ញុំ " បូកថែមនឹងពាក្យ *ហ៊ីតាស៊ី* មានន័យថា " ពួកយើង " *ស៊ុនជីន* មានន័យថា " អ្នកទោស " រួចនឹកឃើញសំដីរបស់*រ៉ូទ្រិច* ទើបគេគ្រវីក្បាល ហើយនិយាយកាត់យ៉ាងមុត១ :

- *ស៊ុនជីន អ៊ីយេ ! វ៉ាតាគូស៊ី វ៉ា អាន់ជីន-សាន*

បុរសទាំងពីរសំលឹងមើលគេថ្នាំង ។

*ប្លាក់ថុន* និយាយបន្តទៅទៀតនៅក្នុងភាពស្ងប់ស្ងាត់នេះ ដោយប្រើភាសាជប៉ុន ដែលគេចេះបន្តិចបន្តួចនោះ ដោយឥតខ្វល់ពីវេយ្យាករណ៍ពីអីទាំងអស់ តែគេសង្ឃឹមថា អ្នកឯទៀតយល់គេមិនខាន :

- ខ្ញុំមិត្ត ។ អត់អ្នកទោសទេ ។ សូមយល់មិត្ត ។ សូមទោសមិត្តត្រូវការមុជទឹក ។ មុជទឹក ។ យល់ទេ ? ហៅ ។ ឃ្លាន ។ មុជទឹក ។

រួចគេចង្អុលទៅលើវិមាន :

-ទៅនោះអីលូវនេះ ។លោកម្ចាស់*តូរ៉ាណាកា*មួយលោកម្ចាស់*អ៊ីស៊ីដូ*ពីរ ។តស់ទៅភ្លាម ។

ដោយសង្កត់លើពាក្យ " *អ៊ីម៉ា* " ចុងក្រោយនេះគេដើរទៅទំរេតខ្លួនលើម៉ក់លើស្នែងជើងរបស់គេលូតហួសគ្រែស្នែងទៅទៀត ។

*យ៉ាប៊ូ* ផ្ទុះសំនើចខ្ចរខ្ចារអ្នកឯទៀតក៏សើចតាម ។ រួច*យ៉ាប៊ូ* ក៏លំអោនខ្លួនគោរពបែបចំអក

- *អ្ហ៎ា សូ អាន់ជីន-សាម៉ា* !

- *អ៊ីយេ យ៉ាប៊ូ-សាម៉ា* ! *អាន់ជីន-សាន* !

*ប្លាក់ថុន* កែសំដី*យ៉ាប៊ូ* យ៉ាងពេញចិត្ត ។ ពិតហើយអាកូនមីចោរអត់ពូជ ។ អីលូវនេះអញយល់ដឹងបន្តិចបន្តួចដែរហើយ ។ តែអញអត់ភ្លេចរឿងអ្ហែងទេ ។ បន្តិចទៀតអញនឹងដើរជាន់ផ្លូវអ្ហែងជាមិនខានទេ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ១៦

*តូរ៉ាណាកា*សន្ទឹទ្បើង :

- បើសិនជាលោកចង់យកអ្នកទោសខ្ញុំ ចេញពីអំនាចច្បាប់របស់ខ្ញុំយ៉ាងនេះ លោកគួរសួរខ្ញុំជាមុនសិនទើបល្អជាង ។

- អាមនុស្សចុងស្រុកនេះ នៅក្នុងគុកចម្ងតាជាមួយអ្នកទោសចម្លតាអង្កាច់អង្គោច ។ អឺចឹងហើយទើបខ្ញុំគិតថា លោកលែងរវីរវល់នឹងវាទៀតហើយនោះ ព្រោះបើមិនអឺចឹងទេខ្ញុំមិនទៅយកវាចេញពីគុកដែរ ។ ពិតហើយ ខ្ញុំមិនដែលមានគំនិតចង់ជ្រៀតជ្រែកការងារផ្ទាល់ខ្លួនរបស់លោកទេ ។

មើលពីក្រៅ *អ៊ីស៊ីដូ* នៅតែមានភាពនឹងនរ រាបសារដដែល ប៉ុន្តែនៅក្នុងចិត្តរបស់លោកវិញ គឺជាភ្នំភ្លើងដែលកំពុងពុះពោរ ។ លោកដឹងថា លោកបានចូលក្នុងអន្ទាក់របស់គេ ព្រោះតែលាក់ការណ៍មិនបានល្អ ។ ពិតណាស់ គេគួរតែសួរ *តូរ៉ាណាកា* ជាដំបូងសិន ។ ព្រោះនេះ គឺជាកិច្ចគួរសមរវាងគ្នានឹងគ្នា ។ ហើយបើសិនមិនបានសួរនោះ ក៏គ្មានបញ្ហាអ្វីដែរ បើសិនជាមកដល់ពេលនេះ លោកបានមនុស្សចុងស្រុកនេះ មកនៅក្នុងកណ្តាប់ដៃរបស់លោកនោះ ។ លោកអាចប្រគល់បុរសនេះត្រលប់ទៅវិញតាមចិត្តចង់ បើសិនជានៅពេលណាដែល *តូរ៉ាណាកា* ស្នើ ។ ប៉ុន្តែអារឿងដែលកូនចៅរបស់ *អ៊ីស៊ីដូ* ត្រូវគេស្ទាក់ និងសំលាប់បានយ៉ាងអាម៉ាស់ហើយនិងប្រការដែល *យ៉ាប៊ូ* ហើយនិងកូនចៅរបស់ *តូរ៉ាណាកា* អាចដណ្តើមមនុស្សចុងស្រុកនេះពីដៃកូនចៅរបស់លោកនោះ បានធ្វើអោយស្ថានភាពប្រែក្រលាស់ទាំងស្រុងតែម្តង ។ លោកបានបាក់មុខបាក់មាត់អស់ ហើយតាមពិតទៅយុទ្ធសាស្ត្ររបស់លោកដើម្បីបំផ្លាញ *តូរ៉ាណាកា* ជាសាធារណៈនោះ គឺធ្វើយ៉ាងណាអោយ *តូរ៉ាណាកា* បាក់មុខបាក់មាត់ ដូចស្ថានភាពរបស់លោកនាពេលបច្ចុប្បន្ននេះទៅវិញទេ ។

- ជាថ្មីម្តងទៀត ខ្ញុំសូមលោកអភ័យទោសផងចុះ !

*តូរ៉ាណាកា* ចោលភ្នែកសំលឹងមើលទៅ *បុរ៊ូ-ម៉ាត់ស៊ី* ។ ពាក្យសូមទោសនេះលាន់លឺ



www.budinst.gov.kh www.elibraryofcambodia.org

ដូចជាតន្ត្រីមួយនៅក្នុងត្រចៀកអ្នកទាំងពីរ ។ គេទាំងពីរដឹងច្បាស់ថា តើពាក្យប៉ុណ្ណេះ *អ៊ីស៊ីដូ* ត្រូវបង់ថ្លៃ នៅក្នុងចិត្តអស់ប៉ុន្មានទៅហើយ ។ ពួកគេស្ថិតនៅក្នុងរោងជំនុំ ។ តាមការឯកភាពគ្នាមុនគួសត្រូវទាំងពីរមានកងការពារយ៉ាងទុកចិត្តបំផុតក្នុងម្នាក់ៗត្រឹមប្រាំនាក់ប៉ុណ្ណោះ ។ អ្នកឯទៀតនៅរង់ចាំឯខាងក្រៅ ។ *យ៉ាប៊ូ* នៅរង់ចាំខាងក្រៅដែរ ឯបុរសចុងស្រុកក៏ត្រូវបានមុជទឹកសំអាតខ្លួនប្រាណរួចរាល់ហើយដែរ ។ ល្អ ! ល្អ ! *តូរ៉ាណាកា* គិតនៅក្នុងចិត្តយ៉ាងរីករាយប្រមាត់ ។ លោកពិចារណាមួយភ្លែតពី *យ៉ាប៊ូ* ហើយសំរេចថា មិនទាន់ជួបមនុស្សនេះនៅថ្ងៃនេះទេ ហើយទុកប្រលែងលេងដូចត្រីនៅលើជ្រុញសិនចុះ ។ ដោយហេតុនេះ លោកក៏បានអោយ *ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* ទៅប្រាប់ *យ៉ាប៊ូ* អោយត្រលប់ទៅកន្លែងវិញសិនចុះ រួចហើយលោកងាកមករក *អ៊ីស៊ីដូ*ម្តង :

- ខ្ញុំព្រមទទួលការសូមទោស របស់លោកហើយ ។ សំនាងដែរដែលគ្មានគ្រោះថ្នាក់អ្វីកើតឡើងនោះ ។

- អ៊ីចឹង ខ្ញុំអាចយកវាទៅជូនទាយាទមើលបានទេ ? គឺ......គឺ......គឺថា នៅពេលវាមានភាពសមរម្យហើយនោះ ។

- ពេលណាខ្ញុំរួចដៃជាមួយវាហើយ ខ្ញុំនឹងបញ្ជូនវាទៅភ្លាម

- តើខ្ញុំអាចសួរលោកថាអង្កាល់បានទេ ? ទាយាទរង់ចាំវានាពេលព្រឹកនេះឯង ។

- ទាំងលោក ទាំងខ្ញុំ គួតែកុំខ្វល់ពីរឿងណឹងពេក មែនទេលោក ? *វ៉ែយទម៉ុន* ទើបអាយុបានប្រាំពីរឆ្នាំទេ ហើយខ្ញុំជឿថា ក្មេងអាយុប្រាំពីរឆ្នាំត្រូវតែចេះរៀនអត់ធ្មត់ហើយ មិនអ៊ីចឹង ? ភាពអត់ធ្មត់គឺជាទំរង់មួយនៃវិន័យដែរ ហើយវាទាមទារការរឹតបាត់មែនទេ ? ចាំខ្ញុំទៅពន្យល់ពីរឿងភ័ន្តច្រលំទាំងប៉ុន្មាននេះខ្លួនខ្ញុំ ។ ព្រឹកនេះខ្ញុំត្រូវបង្រៀន *វ៉ែយទម៉ុន* អោយហែលទឹកផង ។

- មែន ?

- មែនណាំ ។ លោកក៏គួរតែរៀនហែលទឹកដែរហើយ លោក *អ៊ីស៊ីដូ* ។ នេះជាការហាត់ប្រាណមួយយ៉ាងល្អ ហើយនៅពេលមានសង្គ្រាមវារឹតតែមានប្រយោជន៍ទៅទៀត ។ ពួកសាមូរ៉ៃ



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំទាំងអស់សុទ្ធតែចេះហែលទឹក ព្រោះខ្ញុំតំរូវអោយទាំងអស់គ្នាត្រូវចេះអារឿងណឹង ។

- មនុស្សរបស់ខ្ញុំគេចំនាយពេលហាត់បាញ់ព្រួញ ជិះសេះ គុនដាវ និងបាញ់កាំភ្លើងវិញ ។

- ក្រៅពីរៀនហែលទឹក មនុស្សរបស់ខ្ញុំតែងកំនាព្យ រៀនឆ្លាក់អក្សរ រៀបចំផ្កា ហើយនឹងពិធី *ឆាណូយូ* ។ សាមូរ៉ៃត្រូវតែពូកែនៅក្នុងសិល្បៈសន្តិភាព ដើម្បីអាចខ្លាំងបាននៅក្នុងសិល្បៈសង្គ្រាម ។

*អ៊ីស៊ីដូ* បន្ទឹតបរិញ្ញដោយដឹងខ្លួនច្បាស់ថា អក្សររបស់លោកអាក្រក់ ហើយការយល់ដឹងរបស់លោកក៏មានកំរិតទៀតផង :

- ពួកខ្ញុំមួយភាគធំសុទ្ធតែគ្រាន់បើណាស់ទៅហើយក្នុងសិល្បៈអស់នេះ ។ សាមូរ៉ៃកើតមកសំរាប់ធ្វើសង្គ្រាម ហើយអារឿងសង្គ្រាមនេះខ្ញុំថ្លឹកណាស់ ។ រឿងនេះគឺជារឿងគ្រប់គ្រាន់ហើយនាពេលនេះ ។ រឿងណឹង ហើយនិងរឿងគោរពតាមឆន្ទៈចុងក្រោយរបស់លោកម្ចាស់ ។

- *វ័យនម៉ុន* ត្រូវរៀនហែលទឹក នៅយាមសេះណា !

ថ្ងៃ និង យប់ត្រូវចែកជាប្រាំមួយវេនស្មើ១គ្នា ។ ថ្ងៃចាប់ផ្តើម ពីយាមទន្សាយ គឺម៉ោងប្រាំព្រឹកទៅប្រាំពីរព្រឹក រួចយាមនាគពីប្រាំពីរទៅប្រាំបួនព្រឹក បន្ទាប់មកមានយាមពស់ .សេះ ពពែ.ស្វា . មាន់ . ឆ្កែ . ជ្រូក .កណ្តុរ . គោ . ហើយបញ្ចប់នៅយាម ខ្លា ពីម៉ោង៣ភ្លឺទៅប្រាំភ្លឺ ។

*តូរ៉ាណាកា* បន្ត :

- តើលោកចូលរួមរៀនហែលទឹកទេ ?

*អ៊ីស៊ីដូ* ឆ្លើយតបវិញយ៉ាងខ្សោយ :

- អរគុណលោកហើយ ប៉ុន្តែ ខ្ញុំចាស់ជ្រុលនឹងប្រែប្រួលទំលាប់ហើយ ។

- ខ្ញុំលឺថា មេក្រុមរបស់ពួកសាមូរ៉ៃលោកត្រូវទទួលបញ្ជាអោយធ្វើ *សិបពុគូ* មែនទេ ?

- វាត្រូវតែអីចឹងហើយ ។ ពួកចោរហារយប៉ុណ្ណឹង គួរតែចាប់បាន រឺយ៉ាងហោចណាស់



www.budinst.gov.kh www.elibraryofcambodia.org

ចាប់អោយបានម្នាក់ចុះ ។ ព្រោះបើចាប់បានម្នាក់ យើងច្បាស់ជាចាប់បានតែទាំងអស់ហ្នឹង ។

- ខ្ញុំឆ្ងល់ដល់ហើយដែលមានភាពរញ៉េរញ៉ៃនៅក្បែរវិមានយ៉ាងនេះ ។

- ខ្ញុំឯកភាពហើយ ។ ប្រហែលជាអ្នកចុងស្រុកនេះអាចនិយាយពីកិនភាគរបស់ពួកវាបានមើលទៅ ។

*តូរ៉ាណាកា* ផ្ទុះសំនើច :

- រួចចុះអ្នកចុងស្រុកនេះដឹងអីខ្លះទៅ ? ពួកចោរនេះច្បាស់ជាពួក*រ៉ូនីន*ហើយមែនទេ ? កូនចៅរបស់លោកមានពួក*រ៉ូនីន* កៀរនឹងជើង បើលោកស៊ើបពីពួកអស់នេះ ប្រហែលជាមានប្រយោជន៍ដ៏ច្រើនជាង មិនអីចឹង ?

- ការស្រាវជ្រាវអង្កេតកំពុងតែដំណើរការហើយ ។ អង្កេតតាមមុខសញ្ញាខុស១គ្នា ។

*អ៊ីស៊ីដូ* ធ្វើជាមិនដឹង មិនលឺពីពាក្យចាក់ចុចរឿង*រ៉ូនីន* នេះ ។ ពួកនេះគឺជាពួកសាមូរ៉ៃគ្មានម្ចាស់ ជាពួកស៊ីឈ្នួលច្បាំងដែលនៅក្រៅសង្គម ហើយដែលកន្លងមកនេះបានមកបំរើទាហានទាំងពាន់១ក្រោយពី *អ៊ីស៊ីដូ* បានបង្ហើបអោយដឹងថា ខ្លួនលោកក្នុងនាមទាយាទ និង មាតារបស់ទាយាទ នឹងទទួលការសុំដាក់ខ្លួនបំរើរបស់ពួកនេះ ហើយអ្វីដែលអស្ចារ្យទៀតនោះ គឺតែនឹងលើកលែងហើយនឹងបំភ្លេចចោលពីរឿងក្បត់រឹសកម្មភាពនានាពីអតីតកាលទាំងអស់ ហើយភក្តីភាពរបស់ពួកនេះនឹងត្រូវតែផ្តល់រង្វាន់ខាន់ខៅថែមទៀតផង ។ *អ៊ីស៊ីដូ* ដឹងច្បាស់ណាស់ថានេះគឺជាគំនិតដ៏ភ្លឺស្វាងមែនទែនតែម្តង ព្រោះគេនឹងទទួលពួកសាមូរ៉ៃដែលមានការរឹកហាត់ហើយនោះយ៉ាងច្រើនឥតគណនា ទន្ទឹមនេះគេច្បាស់ក្នុងចិត្តថាពួកនេះមានភក្តីភាពជាមួយគេជាទីបំផុត ដោយហេតុថាពួក*រ៉ូនីន* ដឹងខ្លួនឯងយ៉ាងច្បាស់ថា ពួកគេនឹងមិនបានជួបសំនាងបែបនេះម្តងទៀតទេ ។ ពួកអ្នកមិនសប្បាយចិត្តទាំងប៉ុន្មានបានមកចុះចូលនឹង *អ៊ីស៊ីដូ* ទាំងអស់ក្នុងនោះមួយភាគធំបានក្លាយខ្លួនទៅជា*រ៉ូនីន* ព្រោះតែការប្រមាថប្រមាថទន្ទ្រានទីរបស់ *តូរ៉ាណាកា* និងសម្ព័ន្ធមិត្តរបស់*តូរ៉ាណាកា* នោះឯង ។ ម្យ៉ាងទៀតប្រការនេះបានបន្ថយគ្រោះថ្នាក់គំរាមកំហែងមកលើចក្រភពផងដោយការថមថយចុះនូវចំនួនពួកចោរប្លន់ទាំងឡាយ ព្រោះថាការរស់នៅដែលពួកសាមូរ៉ៃក្លាយខ្លួនជា *រ៉ូនីន* អាចធ្វើបាននោះ គឺមានតែបួសជាសង្ឃ រឺក៏ធ្វើជាចោរប្លន់តែប៉ុណ្ណោះ ។



www.budinst.gov.kh www.elibraryofcambodia.org

សំលេង *អ៊ីស៊ីដូ* ដែលលាន់លឺឡើង គឺពោរពេញទៅដោយជាតិពិស :

- មានចំនុចច្រើនណាស់ដែលខ្ញុំយល់មិនបានលើរឿងស្នាក់វ៉ៃនេះ ។ មែនណា៎ ! ឧទាហរណ៍ ហេតុអីបានជាពួកចោរបួនទាំងនេះសាកចាប់អាមនុស្សចុងស្រុកទុកជាថ្នូរយកលុយ អ៊ីចឹង ? វាមានមនុស្សច្រើនណាស់នៅក្នុងក្រុងនេះ ដែលសំខាន់ជាងវាទៅទៀតផង ។ រួចអាចោរវាមិនថាអ៊ីចឹង ? វាថាទុកអោយគេយកលុយមកលោះវា ។ អ្នកណាទៅលោះវា ? តើអាមនុស្សចុងស្រុកនេះមានតំលៃប៉ុន្មានទៅ ? តែម៉ាកាក់ក៏គ្មានផង ។ រួចម៉េចបានជាពួកចោរវាដឹងថា អាមនុស្សចុងស្រុកនេះត្រូវមានមុខនៅកន្លែងនោះ ? ខ្ញុំទើបបញ្ជាកាលពីម្សិលនេះសោះ អោយនាំវាយកទៅអោយទាយាទមើល ព្រោះខ្ញុំគិតថា ទាយាទប្រហែលជាសប្បាយភ្នែកនឹងឃើញមនុស្សនេះតែប៉ុណ្ណោះ ។ យី ! សែនធ្ងល់មែនទែនតែម្តង ។

- មែន សែនឆ្ងល់មែន ។

*តូរ៉ាណាកា* បន្ទរតាម ។

- រួចវានៅមានអារឿងចៃដន្យដែលលោក *យ៉ាប៊ូ* នៅម្តុំ១ឈុងដែរ ទាំងជាមួយគ្នាលោកខ្លះ គ្នាខ្ញុំខ្លះ ចំត្រូវពេលគ្នាតែម្តង ។ គួរអោយឆ្ងល់មែនតែម្តង ។

- មែនគួរមែន ។ តែរឿង *យ៉ាប៊ូ* នៅកន្លែងនោះ គឺព្រោះខ្ញុំប្រើគេអោយទៅអញ្ជើញគាត់មក ហើយក្រុមលោកនៅទីនោះដែរ ព្រោះយើងឯកភាពគ្នាតាមសំនើរបស់លោកផ្ទាល់តែម្តងថា នៅពេលដែលខ្ញុំបំពេញការងារជាផ្លូវការនេះ ដើម្បីជាប្រការមួយល្អផង ដើម្បីលុបបំបាត់តំលាតគ្នារវាងលោកនឹងខ្ញុំផង នៅពេលពួកខ្ញុំទៅទីណាក៏ដោយក៏ក្រុមរបស់លោកនឹងជូនដំណើរទៅជាមួយដែរ ។

- អារឿងចំលែកមួយទៀតគឺថា ពួកអាចោរអស់នេះដែលមានការចាត់តាំងយ៉ាង ល្អ ហើយធ្វើមធំប៉ាននំលាប់ពួកមុនទាំងដប់នាក់ ដោយមិនទាន់ទាំងបានប្រយុទ្ធគ្នាផងនោះ បែរជាធ្វើកដូចពួកកូរ៉ែទៅវិញ នៅពេលដែលមនុស្សពួកយើងទៅដល់ ។ តាមពិត ពីរក្រុមនេះមានមនុស្សស្មើគ្នា ។ ហេតុអីបានជាពួកអាចោរនេះមិនវ៉ៃតទល់ វីក៏ចាប់អាមនុស្សចុងស្រុកឡើងទៅលើភ្នំភ្លាមទៅ តែបែរជានៅឈរ វេរាលើផ្លូវធំទៅវិមានធ្វើអ្វីទៅវិញ ? គួរឆ្ងល់



www.budinst.gov.kh www.elibraryofcambodia.org

មែន ។

- មែនទែនតែម្តង ។ ស្អែកនេះពេលខ្ញុំទៅបណ្តើរស្ទាំង ខ្ញុំច្បាស់ជាបន្ថែមកងការពារ របស់ខ្ញុំមួយជាពីរហើយ ។ ដូចជាយ៉ាប់ដែរណាដល់ដឹងថា មានពួកចោរនៅក្រវែល១ ជិតវិមាន យ៉ាងនេះ ។ អូមែន ! ប្រហែលលោកចូលចិត្តបាញ់សត្វដែរទេអ្វី ? រីមួយបង្ហោះស្ទាំងលោក ប្រនាំងសាកនឹងរបស់ខ្ញុំលមើលអ្វី ? ស្អែកនេះខ្ញុំទៅបរបាញ់នៅតាមភ្នំខាងជើងនេះ ។

- ទេ ! អរគុណហើយ ។ ស្អែកនេះខ្ញុំមានការរវល់ផង ។ ចាំខានស្អែកទៅអ្វី ? ខ្ញុំបាន បញ្ជាអោយកំលាំងខ្ញុំពីរម៉ឺននាក់ដើរបរព្រៃ និងវាលទាំងអស់នៅជុំវិញអូសាកានេះ ។ ក្នុងដប់ ថ្ងៃ គឺគ្មានចោរមួយគ្រាប់ណាទេក្នុងរង្វង់ម្តេលីនេះ ហើយនេះខ្ញុំហ៊ានធានា ។

*តូរ៉ាណាកា* ដឹងច្បាស់លាស់ណាស់ថា *អ៊ីស៊ីដូ* កំពុងតែយកលេសពីរឿងពួកចោរនេះ ដើម្បីបង្កើនចំនួនទ័ពរបស់ខ្លួននៅក្បែរ១នេះ ។ បើ *អ៊ីស៊ីដូ* និយាយថា ពីរម៉ឺនគឺពិតជាមានប្រាំម៉ឺន ជាមិនខាន ។ មាត់អង្គប់កំពុងតែបិទហើយ-*តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ ហេតុអីក៏របាសម្ល៉េះ? តើមានរឿងក្បត់អីថ្មីទៀតកើតឡើងហ៊ី ? ហេតុអីបានជា *អ៊ីស៊ីដូ* ដូចជាទុកចិត្តខ្លួនឯងម្ល៉េះ ?

- ល្អ ! ខានស្អែកក៏ខានស្អែកណាលោក *អ៊ីស៊ីដូ* ! លោកពិតជានឹងប្រាប់កូនចៅលោក អោយចេញពីតំបន់ដែលខ្ញុំបរបាញ់ជាមិនខាន មែនទេលោក ? ខ្ញុំមិនចង់អោយអ្នកណាគេមក រំខានខ្ញុំទេ ។

- កុំភ័យរឿងហ្នឹង ។ រួចចុះរឿងមនុស្សចុងស្រុក ?

- វាជាកម្មសិទ្ធិរបស់ខ្ញុំ ហើយនៅជាកម្មសិទ្ធិខ្ញុំជារៀងរហូត ។ ទាំងវា ទាំងសំពៅ របស់វា ។ តែលោកគង់តែបានវាទេ នៅពេលណាដែលខ្ញុំចប់ការងារជាមួយវា ។ រួចផុតពីហ្នឹង ទៅ លោកចង់យកវាទៅធ្វើម៉ុា ធ្វើផ្អកអីស្រេចតែចិត្តលោកចង់ចុះ ។

- អរគុណលោកហើយ ! ។ ខ្ញុំប្រហែលជាក្របែលវាហើយមើលទៅ !-*អ៊ីស៊ីដូ* បិទ ផ្លិត ហើយដាក់ចូលទៅក្នុងដៃអាវ ។ លោកបន្តទៀត :

- វាគ្មានសារសំខាន់អ្វីទេ ។ អ្វីដែលសំខាន់ ហើយអ្វីដែលជាមូលហេតុដែលខ្ញុំមករក លោកនេះ គឺ.... អូ ! ខ្ញុំភ្លេច ! និយាយអីចឹងខ្ញុំលឺថា ម្តាយរបស់ខ្ញុំបានទៅលេងវត្ត *យ៉ូដឺ* ផងអ្វី ?



www.budinst.gov.kh www.elibraryofcambodia.org

- មែនអ្វី ? ខ្ញុំគិតថា ខែនេះចង់យឺតបន្តិចហើយដើម្បីមើលសេរីចេញផ្កា ។ ព្រោះ ដូចជាវារីករសស់យូរណាស់ទៅហើយ មិនអ៊ីចឹង ?

- បាទ ខ្ញុំឯកភាព ។ ប៉ុន្តែបើអ៊ីចឹងហើយ ម្តាយខ្ញុំនៅតែចង់ទៅមើលទៀត ហេតុអីក៏ មើលមិនបាន ? ជាមួយមនុស្សចាស់មិនងាយនិយាយចូលគ្នាទេ គំនិតយល់ឃើញរបស់គាត់វា ផ្សេងពីយើង មែនទេ ? តែសុខភាពរបស់គាត់មិនសូវល្អប៉ុន្មានទេ អានេះធ្វើអោយខ្ញុំខ្វាយខ្វល់ មែនទែន ។ គាត់ទាល់តែប្រយ័ត្នខ្លួនណាស់... បន្តិច១គាត់ផ្តាសាយភ្លាម ។

- ម្តាយរបស់ខ្ញុំក៏តែអ៊ីចឹងដែរ ។ ជាមួយចាស់១ទាល់តែប្រយ័ត្នប្រយែងសុខភាពគាត់ អោយណាស់ ។

និយាយបណ្តើរ *តូរ៉ាណាកា* កំនត់ចងចាំនៅក្នុងខួរក្បាល ដើម្បីបញ្ជូនសារទៅសង្ឃរាជ វត្ត ដើម្បីរំលឹកលោកអោយប្រុងប្រយ័ត្នមែនទែនពីរឿងសុខភាពរបស់ម្តាយ *អ៊ីស៊ីដូ* ។ បើសិន ជាលោកតែយាយចាស់នេះស្លាប់នៅទីនោះ រឿងពិតជាកក្រើកមេឃរញ្ជួយដីជាមិនខាន ហើយរូប របស់លោក នឹងទទួលការអាម៉ាស់ពេញមួយចក្រភពជាមិនខាន ។ *ដៃមីញ៉ូ* ទាំងអស់នឹងកត់ សំគាល់ថា នៅក្នុងល្បែងអុកដើម្បីអំនាចនេះ រូបលោកបានយកស្ត្រីចំនាស់គ្មានអ្វីការពារខ្លួន ម្នាក់ ដែលជាម្តាយរបស់សត្រូវរបស់ខ្លួនមកប្រើជាកូនអុក តែដោយគ្មានការទទួលខុសលើរូប គាត់សោះឡើយ ។ អារឿងចំនាប់ខ្មាំងនេះ គឺជារឿងគ្រោះថ្នាក់ណាស់ ។

នៅពេលដែលលោកដឹងថា ម្តាយជាទីគោរពរបស់លោកបានទៅនៅរូងខ្លារបស់ *តូរ៉ាណាកា* នៅឯ *ណាកូយ៉ា* នោះ *អ៊ីស៊ីដូ* លោតឆ្កោរក្រមាល់តែម្តង ។ ក្បាលមួយចំនួនបានត្រូវ ជាច់ធ្លាក់ដល់ដី ។ លោកបានពន្លឿនផែនការដើម្បីកំទេច *តូរ៉ាណាកា* កាន់តែរហ័សថែមទៀត ហើយលោកបានប្តេជ្ញាចិត្តថា នៅពេលណាដែលសង្គ្រាមចាប់ផ្តើមភ្លាម លោកនឹងទន្ទ្រានយក *ណាកូយ៉ា* មុនគេដើម្បីកំទេច *ដៃមីញ៉ូកាសាម៉ាគី* ដែលបច្ចុប្បន្ននេះជាអ្នកឃុំគ្រងម្តាយរបស់ លោកនោះ ។ម្យ៉ាងទៀតសារផ្ទាល់ខ្លួនមួយត្រូវបានផ្ញើជូនទៅសង្ឃរាជវត្ត តាមរយៈអ្នក កណ្តាលម្នាក់ដោយបញ្ជាក់ថា បើសិនជាម្តាយរបស់លោកមិនត្រូវបានដោះលែងក្នុងរយៈពេល ម្ភៃបួនម៉ោងនេះទេ *ណាកា* កូនប្រុសរបស់ *តូរ៉ាណាកា* ដែលគេអាចចាប់បាននៅពេលណាក៏បាន



www.budinst.gov.kh www.elibraryofcambodia.org

ដែរនោះ ហើយនិងប្រពន្ធរបស់ *ណាកា* ណាមួយដែលគេចាប់បាន គឺនឹងភ្ជាក់ដំណេកវិញនៅក្នុងភូមិអ្នកឃុំឃាំងជាមិនខាន ។ ហើយអ្នកទាំងពីរនាក់នឹងត្រូវស៊ីផឹកអាស្រ័យដោយពួកតំលង់ទាំងនេះ ហើយកិច្ចការមួយចំនួនទៀតនឹងត្រូវបំរើដោយស្រីពេស្យារបស់ពួកតំលង់ទាំងនេះ ។ *អ៊ីស៊ីដូ* ដឹងច្បាស់ណាស់ថា នៅពេលដែលម្តាយរបស់លោកកំពុងស្ថិតនៅក្នុងអំនាចរបស់ *តូរ៉ាណាកា* យ៉ាងនេះ លោកត្រូវតែដោះស្រាយយ៉ាងប្រយ័ត្នប្រយែងបំផុត ប៉ុន្តែលោកក៏បានអោយសញ្ញាយ៉ាងច្បាស់ហើយថា បើគេមិនលែងម្តាយរបស់លោកវិញទេ ចក្រភពទាំងមូលនឹងក្រលាប់ចាក់មិនខាន ។

*អ៊ីស៊ីដូ* សួរទៅ *តូរ៉ាណាកា* យ៉ាងសំដីគួរសម :

- តើលោកយាយម្តាយរបស់លោកយ៉ាងម៉េចទៅហើយ ?

- គាត់ស្រួលបួលទេ សូមអរគុណលោក ។

*តូរ៉ាណាកា* បញ្ចេញអោយឃើញនូវការសប្បាយរីករាយរបស់លោក ម្យ៉ាងនៅពេលដែលលោកគិតពីម្តាយរបស់លោក និងម្យ៉ាងទៀតនៅពេលដែលលោកដឹងពីការឆ្លេះដុំយ៉ាងអស់សង្ឃឹមរបស់ *អ៊ីស៊ីដូ* ។ លោកពោលបន្តទៀត :

- គាត់នៅតែម៉ឺងអីចឹង ថ្វីបើសព្វថ្ងៃគាត់អាយុចិតសិបបួនឆ្នាំក្តី ។ ខ្ញុំបានត្រឹមជួចគាត់ពេលខ្ញុំអាយុប៉ុណ្ណឹងក៏ប្រសើរណាស់ទៅហើយ ។

អ្ហែងអាយុហាសិបប្រាំបីហើយ អា *តូរ៉ាណាកា* ប៉ុន្តែអ្ហែងគ្មានវាសនាមានអាយុដល់ហាសិបប្រាំបួនទេ -*អ៊ីស៊ីដូ* គិតប្តេជ្ញានៅក្នុងចិត្ត ។ លោកបន្លឺឡើង :

- សូមលោកផ្តាំសួរសុខទុក្ខលោកយាយផង ហើយខ្ញុំសូមជូនពរសូមគាត់មានអាយុយឺនយូរ ។ម្តងទៀត ខ្ញុំសូមអរគុណលោក ហើយខ្ញុំស្តាយណាស់ដែលបានធ្វើអោយលោកអំពល់ទុក្ខ ។

*អ៊ីស៊ីដូ* លំអោនខ្លួនយ៉ាងទាប រួចដោយខំប្រឹងទប់យ៉ាងលំបាកកុំអោយការរីករាយផ្ទុយចេញមកក្រៅបាននោះ លោកក៏ពោលបន្ថែម :

- អូ មែន ! អារឿងសំខាន់ដែលខ្ញុំចង់មកជួបលោកនេះ គឺថាជំនួបជាផ្លូវការចុង



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយរបស់ក្រុមប្រឹក្សាត្រូវលើកវិញ ។ អ៊ីចឹងហើយយប់នេះយើងឥតប្រជុំទេ ។

*តូរ៉ាណាកា* នៅតែញញឹមជាប់ ប៉ុន្តែនៅខាងក្នុងនោះគឺជាការរញ្ជួយចិត្តមួយដ៏សំបើម :

- អ៊ីចឹងអ្វី ? ហេតុអីទៅ ?

- លោក *គីយ៉ាម៉ា* មានជំងឺ ។ អីលូវនេះលោក *ស៊ូគីយ៉ាម៉ា* និងលោក *អូណូស៊ី* បានសំរេចចិត្តផ្អាកការប្រជុំ ។ ខ្ញុំក៏អ៊ីចឹងដែរ ។ អារឿងសំខាន់១យ៉ាងហ្នឹងពន្យារពេលប៉ុន្មានថ្ងៃក៏មិនអីដែរមែនទេ ?

- យើងអាចបើកការប្រជុំដោយគ្មានលោក *គីយ៉ាម៉ា* បានដែរតើ ។

ក្រសែភ្នែករបស់ *អ៊ីស៊ីដូ* ពោរពេញដោយភាពមាក់ងាយ :

- យើងបានសំរេចហើយថា យើងមិនគួរធ្វើបែបនេះទេ ។

- សំរេចជាផ្លូវការអ្វី ?

- នេះគ្រាទាំងបួនរបស់ពួកយើង ។

ចិត្តរបស់ *តូរ៉ាណាកា* កំពុងតែពុះពោរមែនទែន ។ ពេលវេលាកាន់តែអូសបន្លាយគ្រោះថ្នាក់ដែលគំរាមរូបលោកកាន់តែធំឡើងថែមទៀត ។ តើលោកអាចយកម្តាយ *អ៊ីស៊ីដូ* មកធ្វើជាថ្នូរនឹងការបើកសម័យប្រជុំនេះភ្លាមទេ ? ទេ ព្រោះទំរាំតែបញ្ជាទៅ មក គឺវាស៊ីពេលយូរហើយលោកអាចព្រលែងដុំសាច់ស្រវាយកស្រមោលក៏សឹងតែបាន ។ លោកសួរបន្ត :

- បើអ៊ីចឹង តើអង្កាល់ទៅទើបយើងប្រជុំ ?

- តាមខ្ញុំស្មាន លោក *គីយ៉ាម៉ា* ប្រហែលស្រួលខ្លួនវិញស្អែក រឺក៏ខានស្អែកនេះហើយ ។

- ល្អ ! ខ្ញុំនឹងបញ្ជូនគ្រូពេទ្យផ្ទាល់ខ្លួនរបស់ខ្ញុំទៅជួយមើលគាត់ ។

- ខ្ញុំជឿថា គាត់នឹងរីករាយណាស់ដែលលោកធ្វើយ៉ាងនេះ ។ តែគ្រូពេទ្យគាត់ហាមមិនអោយអ្នកណាទៅជួបគាត់ទេ ។ ជំងឺនេះអាចឆ្លងផង ។

- ជំងឺអីទៅ ?

- ខ្ញុំឥតដឹងដែរទេ លោក ។ នេះគេប្រាប់ខ្ញុំតែប៉ុណ្ណឹង ។



www.budinst.gov.kh www.elibraryofcambodia.org

- គ្រូពេទ្យជាអ្នកចុងស្រុកអ្វី ?

- ពិតហើយ ។ តាមខ្ញុំដឹង គឺជាមេគ្រូពេទ្យរបស់ពួកគ្រិស្តសាសនិក ។ ជាគ្រូពេទ្យបព្វជិតរបស់ដៃមីញ៉ូគ្រិស្តសាសនិក ។ គ្រូពេទ្យយើងមិនសូវពូកែទេចំពោះដៃមីញ៉ូសំខាន់យ៉ាងនេះ ។

សំដីរបស់ *អ៊ីស៊ីដូ* ពោរពេញដោយភាពចំអក ។

កង្វល់របស់ *តូរ៉ាណាកា* ចេះតែមានធំឡើងៗហើយ ។ បើសិនគ្រូពេទ្យជាជនជាតិជប៉ុននោះ មានរឿងច្រើនណាស់ដែលលោកអាចធ្វើបាន ។ ប៉ុន្តែជាមួយគ្រូពេទ្យគ្រិស្តសាសនិក...ហើយនេះគឺច្បាស់ជាពួកបព្វជិតយេស៊ុីត...បើសិនប្រឆាំងនឹងពួកវាណាម្នាក់រីកជ្រៀតជ្រែកចូលក្នុងការងាររបស់ពួកវាណាម្នាក់ គឺច្បាស់ជាធ្វើអោយពួកដៃមីញ៉ូគ្រិស្តសាសនិកទាំងអស់ឃ្លាតចេញពីរូបលោកភ្លាម ។ ហើយចំនុចនេះ លោកមិនប្រថុយស្បែកទេ ។ លោកដឹងថាមិត្តភាពរបស់លោកជាមួយ *ឈូតូ-សាន* ពិតជាមិនអាចជួយលោកទប់ទល់នឹងដៃមីញ៉ូគ្រិស្តសាសនិក *អូណូស៊ី* រឺ *គីយ៉ាម៉ា* បានឡើយ ។ រណសិរ្សឯកភាពមួយ គឺជាផលប្រយោជន៍របស់ពួកគ្រិស្តសាសនិក ។ បន្តិចទៀតលោកត្រូវតែទាក់ទងជាមួយពួកបព្វជិតចុងស្រុកទាំងនេះដើម្បីសំរុះសំរួល និងដើម្បីអោយដឹងពីថ្លៃនៃកិច្ចសហប្រតិបត្តិការរបស់ពួកគេ ។ បើសិនជា *អ៊ីស៊ីដូ* មាន *អូណូស៊ី* និង *គីយ៉ាម៉ា* នៅខាងខ្លួនពិតប្រាកដមែន ហើយបើពួកវាធ្វើសកម្មភាពស៊ីសង្វាក់គ្នានោះ ពួក *ដៃមីញ៉ូ* គ្រិស្តសាសនិកទាំងអស់ពិតជានឹងទៅតាមពួកវា ហើយអញពិតជាឯកោ-*តូរ៉ាណាកា* គិតនៅក្នុងចិត្ត - ពេលនោះអញនៅសល់ផ្លូវតែមួយគត់គឺ "ផ្ទៃមេឃក្រហម" តែប៉ុណ្ណោះ ។

- ខ្ញុំនឹងទៅសួរលោក *គីយ៉ាម៉ា* ខាងស្អែកនេះ ។

*តូរ៉ាណាកា* និយាយបែបនេះគឺដើម្បីកំនត់រយៈពេលមួយដែលត្រូវបញ្ចប់ភាពមិនច្បាស់លាស់នេះ ។

- ចុះអារឿងឆ្លងរោគនេះ ? ខ្ញុំពិតជាមិនអត់អោនអោយខ្លួនខ្ញុំទេ បើសិនជាមានរឿងអីកើតឡើងលើរូបលោកក្នុងពេលដែលលោកនៅ *អូសាកា* នេះ ។ លោកគឺជាភ្ញៀវរបស់



www.budinst.gov.kh www.elibraryofcambodia.org

យើង ខ្ញុំត្រូវទទួលផែនទាំលោក ។ ហេតុនេះខ្ញុំសូមទទូចថា លោកមិនត្រូវទៅទេ ។

- លោកអាចស្ងប់ស្ងៀមបានហើយ លោក *អ៊ីស៊ីដូ* ។ រោគឆ្លងដែលអាចកាច់ខ្ញុំបាននោះ មិនទាន់កើតនៅឡើយទេ ។ លោកភ្លេចពីរឿងសំដីគ្រូទាយហើយ រឺ ?

កាលពីប្រាំមួយឆ្នាំមុន នៅពេលដែលអ្នកទូតចិនមកជួបនឹង *ហ៊ីតេកូ* ដើម្បីដោះស្រាយរឿងសង្គ្រាមជប៉ុន-ចិន-កូរ៉េនោះ ហោរាដ៏ល្បីល្បាញម្នាក់បានមកជាមួយនឹងក្រុមនេះដែរ ។ ហោរានេះបានទាយរឿងរ៉ាវជាច្រើន ដែលក្រោយមកបានកើតមានឡើងមែន ។

នៅក្នុងពិធីជប់លៀងជាផ្លូវការដ៏ធំមួយ ដែលលោកបានរៀបចំឡើងនោះ *ហ៊ីតេកូ*បានសុំអោយហោរាទស្សន៍ទាយពីមរណភាពនៃទីប្រឹក្សារបស់លោកមួយចំនួន ។ ហោរាបានទាយថា *តូរ៉ាណាកា* នឹងស្លាប់ក្រោមផ្លែដាវនៅពេលមានអាយុពាក់កណ្ដាលមនុស្ស ចំណែកឯ *អ៊ីស៊ីដូ* ដែលជាអ្នកប្រាជ្ញប្រាប់ប្រទេសកូរ៉េដ៏ល្បីល្បាញនោះ នឹងស្លាប់ដោយគ្មានរោគាព្យាធិអ្វីទេ និងក្នុងអាយុចាស់ ជើងទាំងពីរនៅម៉ឺងជាប់ដី ហើយនឹងមានឈ្មោះខ្ចរខ្ចារ ។ ឯ *ហ៊ីតេកូ* ខ្លួនលោកនឹងស្លាប់នៅលើគ្រែអាយុចាស់ មានគេគោរពបូជា និងមានកូនប្រុសម្នាក់បន្តពូជ ។ ការទស្សន៍ទាយនេះ ធ្វើអោយ *ហ៊ីតេកូ* សប្បាយចិត្តជាពន់ពេក ព្រោះពេលនោះ លោកមិនទាន់មានកូនសោះ ហើយលោកក៏បានសំរេចចិត្តមិនសំលាប់ពួកទូតនេះ ដូចដែលលោកគិតពីពេលមុន ដែលលោកចង់សំលាប់ពួកនេះ ព្រោះអាកប្បកិរិយាក្រអឺតក្រទមនោះ ។ កាលនោះ អធិរាជស្រុកចិនមិនបានបញ្ជូនអ្នកការទូតមកចរចាពីរឿងសន្តិភាព ដូចដែលអម្ចាស់ *ហ៊ីតេកូ* គិតនោះឡើយ ប៉ុន្តែតាមរយៈអ្នកការទូតនេះ ទ្រង់បានស្នើសូមតែងតាំងអម្ចាស់ *ហ៊ីតេកូ* ជា" ព្រះមហាក្សត្រនៃប្រទេស *វ៉ា* " គឺជាឈ្មោះដែលចិនហៅប្រទេសជប៉ុននេះ ។ គឺដោយការរីករាយសប្បាយចិត្តរបស់ *ហ៊ីតេកូ* នេះ ហើយទើបអ្នកការទូតទាំងនោះបានវិលត្រលប់ទៅស្រុកវិញដោយរស់រានមានជីវិត មិនមែននៅក្នុងកញ្ចប់ដែលគេបានរៀបចំហើយជាស្រេចពីពេលមុននោះឡើយ ។ បន្ទាប់មក *ហ៊ីតេកូ* ក៏បានបន្តធ្វើសង្គ្រាមសាជាថ្មីប្រឆាំងនឹងប្រទេសចិន និងកូរ៉េដដែល ។

-ទេ លោកម្ចាស់ *តូរ៉ាណាកា* ខ្ញុំមិនភ្លេចទេ។ ប៉ុន្តែអារឿងឆ្លងរោគនេះមិនមែនស្រួលទេ ។ រួចម៉េចចាំបាច់ទៅរកអារឿងលំបាកធ្វើអ្វី? លោកអាចឆ្លងស្វាយដូចកូនប្រុសលោកឈ្មោះ



www.budinst.gov.kh www.elibraryofcambodia.org

*ល្អបួរ* ក៏តែបាន ។ អោយខ្ញុំសូមទោសណា ។ រីមិនអីចឹងទេលោកអាចកើតឃ្លង់ដូចលោក *អ្នុណុស៊ី* អីចឹង ។ មើល ! គាត់ក្មេងសោះ តែលំបាកយ៉ាប់យ៉ឺនណាស់ ។ មែនណា ! យ៉ាប់មែន ទែន ។

ក្នុងមួយភ្លែតនោះ *តូរ៉ាំណាកា* ដូចជាឃ្លេងឃ្លោងដែរ ។ លោកដឹងយ៉ាងច្បាស់ពីទំហំមហន្តរាយនៃជំងឺទាំងពីរនេះ ។ *ល្អបួរ* កូនប្រុសច្បងដែលនៅរស់របស់លោកបានកើតស្វាយតាំងពីនៅអាយុដប់ប្រាំពីរឆ្នាំ ពោលគឺ កាលពីដប់ឆ្នាំមុន ។ តាំងពីពេលនោះមក ឱសថគ្រប់បែបយ៉ាងរបស់ពេទ្យជប៉ុន ចិន កូរ៉េ គ្រិស្តសាសនិក មិនអាចធ្វើអោយជំងឺនេះធូរស្រាលបានឡើយ ។ បើសិនជាអញមានអំនាចទាំងស្រុង - *តូរ៉ាំណាកា* សន្សាំនៅក្នុងចិត្ត -ប្រហែលជាអញកំចាត់ជំងឺនេះបានជាមិនខាន ។ តើអារោគនេះមកពីស្រីមែនរឺអត់ ? រួចម៉េចបានជាស្រីមានរោគនេះ ? រួចធ្វើយ៉ាងម៉េចដើម្បីព្យាបាលវា ? តួរស្តាយ *ល្អបួរ* មែនទែន ។ បើសិនជាអ្អែងមិនកើតរោគនេះ អ្អែងអាចជាអ្នកទទួលស្នងតំនែងពីអញជាមិនខាន ព្រោះអ្អែងជាយុទ្ធជនដ៏ជាញជ័យ ជានាម៉ឺនពូកែជាង *ស៊ូដាក៏* ហើយថែមទាំងសំបូរល្បិចកលថែមទៀត ។ នេះប្រហែលជាតិមុនអ្អែងបានធ្វើអំពើអាក្រក់ហើយមើលទៅ បានជាជាតិនេះអ្អែងរងកម្មយ៉ាងនេះ ។

លោកឆ្លើយតបទៅ *អ៊ីស៊ីដូ* :

- អូពុទ្ធោអើយ ! ខ្ញុំមានតែបន់សូមរោគទាំងនេះកុំអោយកើតលើអ្នកណាម្នាក់ទៅវិញទេ ។

- ខ្ញុំឯកភាពហើយ !

*អ៊ីស៊ីដូ* ឆ្លើយតបដោយជឿជាក់ក្នុងចិត្តថា បើសិនជាអាចធ្វើបានមែន ច្បាស់ជា *តូរ៉ាំណាកា* បន់អោយរោគទាំងពីរនេះកើតលើខ្លួនលោកជាមិនខាន ។ *អ៊ីស៊ីដូ* លំអោនខ្លួនគោរពម្តងទៀត ហើយចាកចេញពីរោងជំនុំទៅ ។

អស់មួយរយៈមក ទើប *តូរ៉ាំណាកា* ទំលាយភាពស្ងប់ស្ងៀមដែលកើតមានឡើងក្រោយពី *អ៊ីស៊ីដូ* ដើរចេញទៅ :

- យ៉ាងម៉េចទៅ ?

*ហ៊ីរ៉ូម៉ាត់ស៊ឺ* តប :



www.budinst.gov.kh www.elibraryofcambodia.org

-ទោះជាលោកម្ចាស់នៅ រីចេញទៅអីលូវនេះ ក៏រឿងនៅតែដដែល នោះគឺអន្តរាយ ! ពីព្រោះពួកគេក្បត់លោកម្ចាស់ហើយៗ លោកម្ចាស់ត្រូវពួកគេឯកោហើយ ។ បើសិនជាលោកម្ចាស់បន្តនៅទីនេះដើម្បីការប្រជុំនេះ...ហើយមើលទៅទំរាំប្រជុំបានប្រហែលរាប់អាទិត្យហើយ.. ពេលនោះ *អ៊ីស៊ីដូ* ពិតជាអាចប្រមូលទ័ពវាដែលនៅជុំវិញ *អូសាកា* ទាំងប៉ុន្មានមកហើយ ។ ពេលនោះលោកម្ចាស់ពិតជាមិនអាចចេញរួចទេ ទោះជាលោកជំទាវ *អូជីបា* ដែលនៅ *យេដូ* នោះ ទៅជាយ៉ាងម៉េចក៏ដោយ ព្រោះវាច្បាស់ក្រលែតទៅហើយថា *អ៊ីស៊ីដូ* សុខចិត្តប្រថុយប្តូរគាត់នឹងលោកម្ចាស់ហើយ ។ម្យ៉ាងទៀតវាជាការច្បាស់ណាស់ដែលពួកគេក្បត់លោកម្ចាស់ហើយសមាជិកទាំងបួន នៃក្រុមប្រឹក្សាពិតជាចេញសេចក្តីសំរេចប្រឆាំងនឹងលោកម្ចាស់ជាមិនខាន ។ ក្នុងសំលេងបួនទល់នឹងមួយ ក្រុមប្រឹក្សាពិតជាផាត់លោកចេញ ។ បើសិនជាលោកម្ចាស់ចេញពីទីនេះ ពួកគេនឹងសំរេចចិត្តតែតាមអ្វីដែល *អ៊ីស៊ីដូ* បញ្ជាតែប៉ុណ្ណោះ ។ លោកម្ចាស់ត្រូវតែគោរពតាមសេចក្តីសំរេចបួនទល់នឹងមួយនេះ ព្រោះលោកម្ចាស់បានស្បថរួចហើយថា លោកម្ចាស់នឹងទទួលគោរពតាមបណ្តឹបលោកម្ចាស់ ហើយក្នុងឋានៈលោកម្ចាស់ជាសមាជិកទីប្រឹក្សា លោកម្ចាស់មិនអាចលេបពាក្យសម្បថរបស់លោកម្ចាស់បានទេ ។

- ខ្ញុំឯកភាពហើយ ។

ភាពស្ងៀមស្ងាត់បានកើតមានឡើងវិញដដែល ។

ក្រោយពីរង់ចាំទាំងក្តីកង្វល់អស់មួយរយៈមក *ហ៊ីរ៉ូ-ម៉ាស់ស៊ី*ក៏សួរឡើង :

- តើលោកម្ចាស់គិតធ្វើយ៉ាងម៉េចទាន ?

*តូរ៉ាណាហ្គា* ឆ្លើយតបទាំងក្នុងភាពរីករាយគួរអោយភ្ញាក់ផ្អើល :

- ដំបូងបង្អស់ខ្ញុំទៅហែលទឹក បន្ទាប់មកខ្ញុំនឹងជួបមនុស្សចុងស្រុកនោះ ។

☆ ☆ ☆

នារីម្នាក់ដើរកាត់សួនច្បារផ្ទាល់ខ្លួនរបស់ *តូរ៉ាណាហ្គា* យ៉ាងស្ងៀមស្ងាត់សំដៅទៅរកផ្ទះស្បូវមួយ ដែលត្រូវបានសាងសង់យ៉ាងស្អាតច្រលឹងក្រោមម្លប់ដើមឈើដ៏ត្រឈឹងត្រឈៃ ។ *គីម៉ូញូ* និង *អូប៊ី* ធ្វើអំពីសូត្ររបស់នាងមានលក្ខណៈសាមញ្ញ ប៉ុន្តែមានលេចឡើងនូវភាពស្រស់



www.budinst.gov.kh www.elibraryofcambodia.org

សង្ហាផ្ដាច់បំផុត ដែលគេរកបាននៅក្នុងប្រទេសចិន ។ នាងបួងសក់នាងតាមម៉ូតថ្មីបំផុតនៃទីក្រុងក្យូតូ គឺបួងសក់ខ្ពស់ទៅលើ ហើយទប់ដោយស្នៀតសក់ប្រាក់យ៉ាងវែងៗ ។ ឆត្រពណ៌ងងឹតស្រស់មួយបានបិទបាំងការពារសាច់ដ៏សរលោងដូចពងមាន់របស់នាង ។ នាងមានរាងតូចល្អិត -ប្រហែលជាមួយម៉ែតកន្លះ-ប៉ុន្តែសមរឹកសមរាងណាស់ ។ នៅជុំវិញកនាងមានខ្សែកមាសតូចស្ដើងមួយ ហើយនៅព្យួរនឹងខ្សែកនេះមានរូបព្រះឆ្លាក់មាសតូចមួយ ។

*គីរី* ឈររង់ចាំនាងនៅក្រោមសំយ៉ាបផ្ទះខ្ទមនេះ។ លោកស្រីអង្គុយយ៉ាងស្ងៀមក្រោមម្លប់ស្បូវ ហើយសំលឹងមើលនារីដែលដើរតំរង់មករកខ្លួនតាមថ្មាំងថ្ម ដែលគេបានដាក់តំរៀបយ៉ាងស្អាត មើលទៅហាក់ដូចជាថ្មទាំងនេះដុះចេញពីដីមកជាមួយស្មៅយ៉ាងដូច្នោះដែរ ។

ក្រោយពីលំអោនខ្លួនតបការគោរពរបស់នារីនោះហើយ *គីរី* ក៏បន្លឺឡើងដោយសំលេងរាប់អានដ៏ស្មោះស្ម័គ្រ :

- *កូដា មារីកូ -សាន* ! នាងកាន់តែល្អឡើងៗ ក្មេងឡើងៗតែម្ដង !

- សូមអោយជាការពិតមែនទៅចុះ !

*មារីកូ* ឆ្លើយតបទាំងញញឹម ។ នាងលុតជង្គង់ចុះនៅលើម៉ក់ ហើយជាស្វ័យប្រវត្តិនាងយកដៃវាសរៀបចំផ្នត់សំពត់រាវនាងយ៉ាងស្អាតបាត ។

- ជាការពិតមែនណា៎ ! និយាយអីចឹង យើងជួបគ្នាចុងក្រោយបំផុតពីអង្កាល់អីចេះ ? ពីរឆ្នាំអ្ហ៎ ? រឺក៏បីឆ្នាំទេអ្ហ៎ ? ម្ភៃឆ្នាំហើយៗ នាងដូចជាគ្មានផ្លាស់ប្ដូរអីសោះតែម្ដង ។ កាលយើងជួបគ្នាដំបូង ដូចជាកាលពីម្ភៃឆ្នាំមុនមែនទេ ? នាងនៅចាំទេ ? កាលនោះ គឺជានៅក្នុងពេលជប់លៀងរបស់លោកម្ចាស់ *កូដា* ហើយនាងទើបបានអាយុដប់បួនឆ្នាំ និងទើបតែរៀបការផង ។

- កាលនោះខ្ញុំខ្លាចគេខ្លាចឯងណាស់ ។

- ទេ នាងមិនចាញ់ប្រាបអ្នកណាទេ ។

- តាំងពីពេលនោះមកដល់អីលូវនេះ គឺដប់ប្រាំមួយឆ្នាំហើយ *គីរីស៊ូបូ-សាន* មិនមែនម្ភៃឆ្នាំទេ ។ ចាស់ ! ខ្ញុំនៅចាំរឿងនោះយ៉ាងច្បាស់ណាស់ ។

ចាំយ៉ាងច្បាស់ណាស់ ! *មារីកូ* គិតយ៉ាងរវើរវាយនៅក្នុងចិត្ត ។ នោះគឺជាថ្ងៃដែលបង



www.budinst.gov.kh www.elibraryofcambodia.org

ប្រុសខ្ញុំបានខ្សឹបប្រាប់ខ្ញុំថា លោកឪពុកនឹងសងសឹកលើ *កូរ៉ែដា* ហើយ ពេលគឺគាត់នឹងសំលាប់ *កូរ៉ែដា* ដែលជាអម្ចាស់របស់ខ្លួនហើយ ។

ចាស់ *គីរី-សាន* ។ ខ្ញុំនៅតែចាំយ៉ាងច្បាស់ថ្ងៃនោះ ឆ្នាំនោះ និងម៉ោងនោះ ។ នេះគឺជាការចាប់ផ្តើមនៃអំពើគក់ស្លុត ញាប់ញ័រគ្រប់បែបយ៉ាងហើយ ។ខ្ញុំមិនដែលសារភាពជាមួយអ្នកណាម្នាក់ថា ខ្ញុំបានដឹងជាមុននូវរឿងរ៉ាវដែលនឹងកើតមានឡើងនៅពេលនោះឡើយ ។ ខ្ញុំឥតបានប្រាប់ប្តីខ្ញុំ រឺក៏ប្រាប់ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ដែលជាឪពុកក្មេកខ្ញុំឡើយ ។ ហើយអ្នកទាំងពីរ គឺជាអណ្តាប់ដ៏ស្មោះត្រង់បំផុតរបស់ *កូរ៉ែដា* ។ ប៉ុន្តែតើអ្នកណាអាចស្មានបានថា អំពើក្បត់ត្រូវបានរៀបចំឡើងដោយមេទ័ពដ៏ចំនានបំផុតរបស់ *កូរ៉ែដា* នោះ ? អ្វីដែលជាកំហុសដ៏ធំ គឺខ្ញុំឥតបានប្រាប់ *កូរ៉ែដា* ដែលជាអម្ចាស់របស់ខ្ញុំអោយបានដឹងខ្លួនជាមុនសោះ ។ ខ្ញុំមិនបានបំពេញភារកិច្ចរបស់ខ្ញុំ ចំពោះអម្ចាស់ខ្ញុំ ចំពោះប្តីខ្ញុំ ចំពោះគ្រួសារប្តីខ្ញុំ ដែលពេលខ្ញុំរៀបការហើយនោះបានក្លាយទៅជាគ្រួសារតែមួយគត់របស់ខ្ញុំ។ ឱព្រះមាតាអើយ សូមអភ័យទោសដល់អំពើបាបនេះផង ។ ខ្ញុំរក្សាការណ៍សំងាត់នេះគឺដើម្បីរក្សាកិត្តិយសលោកឪពុកជាទីស្រលាញ់របស់ខ្ញុំ ដែលត្រូវគេជាន់ឈ្លីនោះ ។

*ម៉ារីកូ* និយាយម្តងទៀតយ៉ាងស្ងប់ស្ងាត់ :

- មកដល់អីលូវនេះបានដប់ប្រាំមួយឆ្នាំហើយ ។

- នៅឆ្នាំនោះ ខ្ញុំពពោះកូនលោកម្ចាស់ *តូរ៉ាណាកា* ផង ។

*គីរី* ឆ្លើយតប ហើយលោកស្រីគិតនៅក្នុងចិត្តថា បើសិនជាលោកម្ចាស់ *កូរ៉ែដា* មិនត្រូវឪពុករបស់ *ម៉ារីកូ* ក្បត់និងសំលាប់ទេនោះ *តូរ៉ាណាកា* មិនចាំបាច់ចេញធ្វើសង្គ្រាមនៅ*ណាកាកូដៅ* ទេ ហើយខ្លួនលោកស្រីក៏មិនបានកើតផ្កាសាយរហូតទាល់តែរលូតកូនដែរ ។ ប៉ុន្តែ-លោកស្រីដកដង្ហើមធំនៅក្នុងចិត្ត-ប៉ុន្តែនេះក៏ប្រហែលមកពីកាម៉ារបស់អញតែប៉ុណ្ណោះ ។

លោកស្រីបន្លឺសំដីទាំងស្លូតបូតបន្តទៀត :

- ហ៊ឺ *ម៉ារីកូ -សាន* ! រឿងនេះកន្លងទៅយូរណាស់ វាហាក់ដូចជាកាលពីជាតិមុនអីចឹង ។ តែនាងដូចជាមិនចេះចាស់សោះតែម្តង ។ ម៉េចបានជាខ្ញុំមិនបានមានមុខស្អាត និងសក់ល្អដូចនាងអីចឹង ? ដំណើរនាងក៏នៅតែស្រាលស្ទើរកដដែលថែមទៀត ។ តាមពិតចំលើយវាងាយ



www.budinst.gov.kh www.elibraryofcambodia.org

សោះ ! នេះមកពិខ្ញុំហួបច្រើនពេក ។

រួច *គីរី* សើចកក្អិក ។

- ចុះរឿងហ្នឹងមានសំខាន់អី ? លោកស្រីបានទទួលការស្រលាញ់ពេញចិត្តពីលោកម្ចាស់ *គូរ៉ាណាកា* មិនអីចឹង ? បានតែប៉ុណ្ណោះ គឺគ្រប់គ្រាន់ទៅហើយ ។ លោកស្រីជាមនុស្សឆ្លាតឆ្នៃ រាក់ទាក់ ហើយពេញទៅដោយសុភមង្គលទៅហើយ ។

- ខ្ញុំចង់បានស្តម ហើយនៅតែហួបបាននិងនៅតែលោកម្ចាស់ពេញចិត្តទាំងអស់ហ្នឹង ។ ចុះនាង ! នាងមិនមានសុភមង្គលទេអ្ហី ?

*ម៉ារីកូ* ឆ្លើយតប :

-ខ្ញុំគ្រាន់តែជាឧបករណ៍តូរ្យតន្ត្រី សំរាប់កំដរលោកម្ចាស់ *ប៊ុនកាឡូ* របស់ខ្ញុំតែប៉ុណ្ណោះ ។ បើលោកម្ចាស់ជាប្តីខ្ញុំមានសុភមង្គលខ្ញុំក៏មានសុភមង្គលដែរ ។ ការសប្បាយរីករាយរបស់គាត់គឺជាការរីករាយសប្បាយរបស់ខ្ញុំដែរ ។ ខ្ញុំមិនដូចតែលោកស្រីអីចឹងដែរ ?

- មែនហើយ តែវាមិនដូចគ្នាទេ ។

*គីរី* ឆ្លើយតបបណ្តើរ បក់ផ្លិតសូតរបស់លោកស្រីបណ្តើរ ។ ពន្លឺសូតដេញកាំរស្មីព្រះអាទិត្យព្រិចៗ។ ខ្ញុំសប្បាយចិត្តណាស់ ដែលខ្ញុំមិនមែនជារូបនាង *ម៉ារីកូ* ។ នាងជានារីរូបស្អាតមានប្រាជ្ញាវាងវៃ ក្លាហាន ហើយរៀនសូត្រចេះដឹងច្រើនមែន តែបើជាខ្ញុំវិញ ខ្ញុំមិនអាចទ្រាំទៅរស់នៅជាមួយបុរសរូបអាក្រក់ ជាទីសំអប់ ក្រអឺតក្រទម និងប៉ះដៃៗ ប៉ះជើងៗ យ៉ាងនេះអស់ដប់ប្រាំពីរឆ្នាំអីចឹងទេ ។ តែមួយថ្ងៃក៏ទ្រាំមិនបានផង ។ អាគាត់នេះខុសពី *ហ្ស៊ីរ៉ូ-ម៉ាត់ស៊ី* ជាឪពុកឆ្ងាយណាស់ ។ គាត់គឺជាមហាបុរសមែន។ តែ *ប៊ុនកាឡូ* វិញ ? យ៉ាងម៉េចបានជាឪល្អ បែរជាមានកូនអាក្រក់យ៉ាងហ្នឹង ? ហ៊ឺ ម៉ារីកូ ! ហេតុអីបានជានាងចេះតែទ្រាំទ្រការលំបាកវេទនាអស់រាប់ឆ្នាំយ៉ាងនេះ ? បើមើលតែមុខនាងគ្មានឃើញស្រមោលតិចតួចពីបណ្តាទុក្ខវេទនាទាំងនេះសោះ ។

លោកស្រីបន្ត :

- នាងគឺពិតជានារីម្នាក់ដ៏អស្ចារ្យមែន *តូដា ប៊ុនកាឡូ ម៉ារីកូ-សាន* ។



www.budinst.gov.kh www.elibraryofcambodia.org

- សូមអរគុណណាស់ លោកស្រី *គីរ៉ូប្ល តូស៊ិកូ -សាន* ។ ហ៊ឺ ! *គីរ៉ី-សាន* ! បានជួបលោកស្រីគួរអោយសប្បាយណាស់ ។

- ចុះនាង ? ហើយកូនប្រុសនាងយ៉ាងម៉េចទៅហើយ ?

- ល្អណាស់ ! ល្អណាស់ ! *សាបូជី* អាយុដប់ប្រាំឆ្នាំហើយ ។ វាមានមាឌធំ ហើយខ្លាំងដូចឪពុកវាអ៊ីចឹង ។ ហើយលោកម្ចាស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* អោយជីតាត់ទាំងអស់ទៅ *សាបូជី* ។ លោកស្រីមានដឹងថា វាជិតរៀបការទេ ?

- ទេ ។ ការជាមួយអ្នកណាណឹង ?

- កូនក្រមុំគឺជាចៅរបស់លោកម្ចាស់ *គីយ៉ាម៉ា* ។ លោកម្ចាស់ *តូរ៉ាណាកា* ជាអ្នកចាត់ចែងរៀបចំឡើងរឿងនេះទាំងអស់ ។ គេសក្តិសមនឹងគ្រួសាររបស់យើងហើយ ។ ខ្ញុំគ្រាន់តែបន់អោយតែកូនស្រីនោះចេះ....ចេះ...ចេះថៃទាំកូនខ្ញុំអោយបានល្អតែប៉ុណ្ណោះ ។ លោកស្រីមានដឹងទេថានាង...នាង...

*ម៉ារីកូ* សើចកក្អឹកដោយអាការៈអៀនប្រៀន រួចនាងពោលបន្ត :

- មែនតែម្តង ។ ខ្ញុំចាប់ដូចម៉ែក្មេកគេគ្រប់១គ្នាដែរហើយ ។ តែខ្ញុំគិតថា លោកស្រីច្បាស់ជាឯកភាពហើយ ថានាងនោះមិនទាន់មានពិសោធន៍អីទាំងអស់ ។

- នាងគង់មានពេលនឹងបង្ហាត់បង្ហាញកូនប្រសាទេ ។

- ចាស់ ខ្ញុំក៏សង្ឃឹមអីចឹងដែរ ។ ចាស់ មែន ខ្ញុំជាមនុស្សសំនាងដែរ ដោយគ្មានម៉ែក្មេកនឹងគេ ។ បើមានវិញ ខ្ញុំមិនដឹងថាគួរធ្វើយ៉ាងម៉េចដែរទេ ។

- នាងពិតជាធ្វើអោយកូនប្រសាស្រីស្រលាញ់នាង ហើយនាងពិតជាចេះបង្វឹកកូនប្រសាអោយចេះបែបបទដូចអ្នកនៅក្នុងផ្ទះនាងទាំងអស់អីចឹង ។

- សូមអោយទៅជាការពិតចុះ ។ និយាយអីចឹងប្តីរបស់ខ្ញុំបញ្ជូនខ្ញុំមកទីនេះ ។ លោកម្ចាស់ *តូរ៉ាណាកា* ត្រូវការជួបខ្ញុំមែនទេ ?

- ត្រូវហើយ ។ គាត់ត្រូវការអោយនាងមកជួយបកប្រែជូនគាត់ ។

*ម៉ារីកូ* ឡើងស្រលាំងកាំងតែម្តង ។



www.budinst.gov.kh www.elibraryofcambodia.org

- បកជាមួយអ្នកណា ?

- អ្នកចុងស្រុកថ្មី ?

- អីចឹង ? រួចចុះបព្វជិត *ល្អូត-សាន* នោះ ? គាត់ឈឺអ្វី ?

*គីរី* ឆ្លើយតបបណ្ដើរ លេងផ្លិតរបស់ខ្លួនបណ្ដើរ :

- ទេ ។ ពួកយើងបានត្រឹមតែទាយមើលតែប៉ុណ្ណឹង ។ ហេតុអីបានជាលោកម្ចាស់ *តូរ៉ាណាកា* ត្រូវការនាង ហើយមិនចង់អោយបព្វជិតនោះមកដូចកាលពីលើកទីមួយទៀតអីចឹង? ហេតុអីបានជាយើងត្រូវតែជាអ្នកទុកដាក់លុយកាក់ គិតគូរការចំណាយទាំងសព្វទាំងគ្រប់ បង្ហាត់បង្រៀនអ្នកបំរើ ឡើងផ្សារ ទិញតុទូតាំង ទាំងសព្វទាំងគ្រប់ ប៉ុន្តែប្ដីមិនដែលប្រាប់ប្រពន្ធពីកិច្ចការរបស់គេសោះ មែនទេ ?

- ហេតុណឹងហើយបានជាចិត្តពិភាល់របស់ស្រីសំខាន់ណាស់ ។

- ប្រហែលហើយមើលទៅ ។ តែបើតាមខ្ញុំស្មាន រឿងនេះ គឺពិតជារឿងសំខាន់ និងយ៉ាងសំងាត់ណាស់ ។ ហេតុនេះហើយ សូមនាងស្បថដោយយកព្រះត្រៃស្ដរបស់នាងជាបន្ទាល់ថា នាងនឹងមិននិយាយអ្វីទាំងអស់ពីជំនួបនេះទេ ។ មិនប្រាប់អ្នកណាទាំងអស់ ។

កំដៅដ៏ស្រទន់នៃបរិយាកាសបានរលាយបាត់បង់អស់មួយរំពេច ។

- ចាស៎ ។

*ម៉ារីកូ* ឆ្លើយយ៉ាងរសាប់រសល់ ។ នាងយល់យ៉ាងច្បាស់លាស់ថា *គីរី* ចង់អោយនាងលាក់ការណ៍នេះអោយជិតបំផុត ទោះជាប្ដីនាង ឪពុកនាង រឺអ្នកដែលនាងត្រូវខមាទោសក្ដី ។ ប្ដីនាងបានបញ្ជូននាងមកទីនេះ ប្រហែលតាមបញ្ជារបស់លោកម្ចាស់ *តូរ៉ាណាកា* ហើយ ប៉ុន្តែតើកាតព្វកិច្ចរបស់នាងចំពោះម្ចាស់ អាចធំជាងកាតព្វកិច្ចរបស់នាងចំពោះអ្នកទទួលខមាទោសនោះទេ ? តើនាងមិនអាចនិយាយអ្វីបានទាំងអស់ប្រាប់អ្នកទទួលខមាទោសនោះទើរ ? រួចហេតុអីបានជានាងត្រូវបកប្រែជំនួសបព្វជិត *ល្អូត-សាន* ទៅវិញ ? ជាថ្មីម្ដងទៀតនាងដឹងថា ខ្លួននាងត្រូវជ្រមុជចូលទាំងបង្ខំទៅក្នុងល្បិចកលនយោបាយ ដែលធ្វើអោយជីវិតរបស់នាងក្រលាប់ចាក់អស់រលីងនោះ ។ នៅក្នុងចិត្តរបស់នាង១បួងសួមអោយត្រកូលគ្រួសារនាងមិនមែនជា



www.budinst.gov.kh www.elibraryofcambodia.org

ព្រះកូល *ភូជីម៉ូតូ* ដ៏ចំនាស់នេះអោយសោះ ហើយនិងសូមកុំអោយនាងកើតឡើងមាននិស្ស័យក្នុងរឿងភាសា ដែលធ្វើអោយនាងអាចរៀនចេះបាននូវភាសាបរកទុយកាល់ និងឡាតាំងដូចពេលនេះ ។ រឺ បើល្អបំផុត សូមកុំអោយនាងកើតមកលើផែនដីនេះតែម្តង ។ ប៉ុន្តែ-នាង *ម៉ារីកូ* បន្តគិតនៅក្នុងចិត្ត - បើសិនជាអញមិនចាប់កំនើតទេ អញធ្វើម៉េចឃើញកូនប្រុសអញ ធ្វើម៉េចបានចេះដឹងពីធម៌របស់ព្រះគ្រិស្ត ?

នេះគឺជា *កាម៉ា* របស់អ្នែងណា *ម៉ារីកូ* ។

រូបនាងបន្លឺឡើង :

- ល្អណាស់ *តូរ៉ា -សាន* ! ខ្ញុំសូមស្បថដោយមានព្រះគ្រិស្តជាបន្ទាល់ ថាខ្ញុំមិននិយាយផ្សព្វផ្សាយទៅក្រៅនូវអ្វីដែលបាននិយាយនៅកន្លែងនេះ ក្នុងថ្ងៃនេះឡើយ ហើយក៏ដូចជាមិនផ្សព្វផ្សាយអ្វីៗ ទៀតនៅគ្រប់ពេលណាដែលខ្ញុំបកប្រែជូនលោកម្ចាស់ដែរ ។

- ខ្ញុំក៏គិតដែរថា នាងគួរផាត់ចេញនូវសញ្ចេតនាផ្ទាល់ខ្លួនរបស់នាងចេញ ដើម្បីបកប្រែអោយបានចំនូវអ្វីដែលបាននិយាយ ។ មនុស្សចុងស្រុកថ្មីនេះចំលែកណាស់ ហើយនិយាយពីរឿងប្លែកៗ ទៀតផង ។ ខ្ញុំគិតថា លោកម្ចាស់បានសំរេចជ្រើសរើសនាងក៏ពីព្រោះមូលហេតុពិសេសដែរណា ។

- លោកម្ចាស់ *តូរ៉ាណាកា* មានបំនងយ៉ាងណា ខ្ញុំធ្វើតាមយ៉ាងនោះ ។ លោកមិនចាំបាច់ព្រួយបារម្ភពីភក្តីភាពរបស់ខ្ញុំទេ ។

- គ្មានបញ្ហាអ្វីពីរឿងនេះទេ សូមនាងកុំបារម្ភ ។ សំដីខ្ញុំនិយាយអំបាញ់មិញគ្មានបំនងចង់អាក្រក់ទេ ។

ភ្លៀងរលឹមនិទាឃរដូវបានមកដល់ ហើយរោយរាយស្បែស្តើងរបស់ខ្លួនមួយភ្លែតទៅលើស្រទាប់ផ្កា ផ្លែ និងស្លឹកឈើ ធ្វើអោយទេសភាពកាន់តែរីកស្រស់បំព្រងទៅទៀត ។

-ខ្ញុំមានសំនូមពរមួយ *ម៉ារីកូ-សាន* ។ តើនាងអាចលាក់រូបឆ្លាងក្នុងអាវ *គីម៉ូណូ* របស់នាងសិនបានទេ ?

ម្រាមដៃរបស់ *ម៉ារីកូ* ច្បាមរូបឆ្លាងហាក់ដូចជាចង់ការពារជាប់ :



www.budinst.gov.kh www.elibraryofcambodia.org

- ហេតុអ្វី ? លោកម្ចាស់ *តូរ៉ាណាកា* មិនដែលជំទាស់នឹងការចូលសាសនារបស់ខ្ញុំទេ។ លោកម្ចាស់ *ហ៊ីរ៉ូ-ម៉ាក់ស៊ី* ដែលជាមេត្រកូលខ្ញុំក៏មិនដែលជំទាស់ដែរ ។ ប្តីខ្ញុំបានយល់ព្រមអោយខ្ញុំពាក់ផងដែរ ។

-ខ្ញុំដឹងហើយ ! តែរូបឆ្លាងនេះធ្វើអោយមនុស្សចុងស្រុកត្រលប់ធាតុភ្លាម ហើយលោកម្ចាស់ *តូរ៉ាណាកា* មិនចង់អោយវាត្រលប់ធាតុទេ ពាត់ចង់អោយវានៅជាធម្មតាហឹងណា !

☆ ☆ ☆

*ប្លាក់ថន* មិនដែលឃើញអ្នកណាមាឌតូចយ៉ាងនេះទេ ។ គេបន្លឺឡើង :

- *កូនីជី វ៉ា ! កូនីជី តូរ៉ាណាកា -សាម៉ា !*

គេលំអោនខ្លួនគោរពតាមបែបអ្នកវាំងអឺរ៉ុប ហើយងក់ក្បាលទៅរកកុមារម្នាក់ ដែលនៅលុតជង្គង់បើកភ្នែកធំៗ ក្បែរ *តូរ៉ាណាកា* ហើយនិងនារីចាស់ម្នាក់ដែលនៅពីក្រោយ ។ ពួកគេនៅលើរានហាលដែលព័ទ្ធជុំវិញផ្ទះខ្ទមនោះ ។ ផ្ទះខ្ទមនេះសង់ខ្ពស់ពីដីប្រហែលកន្លះម៉ែត មានដំបូលស្លឹក ហើយមានបន្ទប់តូចមួយតែប៉ុណ្ណោះ ។ ចង្ក្រានបាយនៅខាងក្រោយខ្ទមនោះ ។ នេះគឺជាផ្ទះសំរាប់តែធ្វើពិធីបុណ្យ *ឆា-ណូ-យូ* ហើយត្រូវសាងសង់ឡើងដោយគ្រឿងសំភារៈប្រណីតៗ និងដ៏កំរ ។ ដោយខ្ទមនេះសង់នៅដាច់ឆ្ងាយពីគេនោះ គេរមែងប្រើវាជាកន្លែងណាត់ជួបគ្នា និងកិច្ចសន្ទនាសំងាត់ផងដែរ ។

*ប្លាក់ថន* រៀបចំសំរូល គីម៉ូណូ របស់ខ្លួន ហើយអង្គុយចុះទៅលើម៉ក់មួយដែលគេដាក់ផ្ទាល់នឹងដីខ្សាច់ទល់មុខនឹងមនុស្សទាំងប៉ុន្មាននាក់នោះ ។

- *កូមេន ណាសៃ តូរ៉ាណាកា -សាម៉ា ។ នីហុង កូ កា ហាណាសេម៉ាសិន ។ ឈូយ៉ាគូ -កូ អ៊ីម៉ាស៊ូ កា ?*

- ខ្ញុំគឺជាអ្នកបកប្រែជូនលោកហើយ !

*ម៉ារីកូ* និយាយភាសាប៉ រកទុយកាល់យ៉ាងរអិល ។ នាងបន្តយ៉ាងលឿងឆ្លល់ទៀតថា :

- យី លោកចេះភាសាជប៉ុនផង ?

- ទេ អ្នកនាង ។ ខ្ញុំចេះតែប៉ុន្មានម៉ាត់ និងប៉ុន្មានឃ្លាតែប៉ុណ្ណោះ ។



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថុន* ឆ្លើយតបយ៉ាងភ្ញាក់ផ្អើល ។ គេរំពឹងថា បព្វជិត *អាល់វីកូ* នឹងមកធ្វើជាអ្នកបកប្រែនៅពេលនេះ ហើយ *តូរ៉េណាកូ* នឹងមានពួកសាមូរ៉ៃហែហមមកជាមួយមិនខាន ហើយដៃមីញ៉ូ *យ៉ាប៉ូ* ប្រហែលជាជូនដំណើរមកជាមួយផងដែរ ។ ប៉ុន្តែគ្មាន សាមូរ៉ៃណាមួយនៅក្បែរពួកគេនោះសោះទេ ថ្វីត្បិតតែមាន សាមូរ៉ៃច្រើននាក់ នៅឈរជុំវិញសួនច្បារនេះក៏ដោយ ។

- លោកម្ចាស់ *តូរ៉េណាកា* របស់ខ្ញុំសួរថា តើ.....ប៉ុន្តែដំបូងបង្អស់ខ្ញុំគួរតែសួរលោកសិនថា តើលោកចូលចិត្តនិយាយឡាតាំងជាងប៉ កទុយកាល់ រឺយ៉ាងម៉េច ?

- ស្រេចតែអ្នកនាងចូលចិត្តចុះ

ដូចជាអ្នកចេះដឹងឯទៀតៗដែរ *ប្លាក់ថុន* អាចអាន សរសេរ និងនិយាយភាសាឡាតាំងបាន ពីព្រោះភាសាឡាតាំង គឺជាភាសាទៃចំនេះដឹងតែមួយគត់នៅក្នុងភពអារ្យធម៌ ។

តើនារីនេះជាអ្នកណា ? តើនាងរៀនភាសាប៉ កទុយកាល់ស្ទាត់នេះពីណាមក ? រួចភាសាឡាតាំង ? មើលទៅគ្មានអ្នកណាក្រៅពីពួក *យេស៊ូត* ទេដែលបង្រៀននាង -*ប្លាក់ថុន* គិតនៅក្នុងចិត្ត -គិតទៅពួក យេស៊ូតឆ្លាតមែនទែនតែម្តង ។ របស់ដែលវាចាប់ធ្វើដំបូងបង្អស់ គឺកសាងសាលារៀនតែម្តង ។

កាលពីចិតសិបឆ្នាំមុន *អ៊ីញ៉ាចូស ឡូយ៉ូឡា* បានបង្កើតសមាគមព្រះយេស៊ូ ហើយអីឡូវនេះសាលារបស់សមាគមនេះ ដែលត្រូវបានគេចាត់ទុកជាសាលាឆើតបំផុតនៅក្នុងភពគ្រិស្តសាសនានោះ ត្រូវបានពង្រាយនៅទូទាំងពិភពលោក ហើយអំនាចរបស់ពួកគេអាចលើកស្ទួយពួកស្តេចអោយខ្ពស់ត្រដែតក៏បាន អោយរលំរលាយជាផេះក៏បាន ។ ពួកគេត្រូវបានសម្តេចប៉ាបជឿទុកចិត្តថែមទៀតផង ។

*ម៉ារីកូ* បន្លឺឡើង :

- អីចឹង យើងនិយាយ ប៉ កទុយកាល់ចុះ ។ លោកម្ចាស់ខ្ញុំចង់ដឹងថា តើលោករៀនពាក្យ " ប៉ុន្មានម៉ោត់ និងប៉ុន្មានឃ្លា " នេះពីណាមក ។

- នៅក្នុងគុកមានបព្វជិតម្នាក់ ។ គាត់ជាបព្វជិតនិកាយ *ប្រង់ស៊ីស្កាំង*។ គឺលោកនោះដែលបានបង្រៀនខ្ញុំ ។ បង្រៀនខ្ញុំអោយចេះពាក្យដូចជា ម្ហូប មិត្ត មុជទឹក ទៅមក ពិត ក្លែង



www.budinst.gov.kh www.elibraryofcambodia.org

ក្លាយ ខ្ញុំ លោក អរគុណ ចង់ មិនចង់ អ្នកទោស បាទ ទេ ជាដើម ។ តែស្ពាយណាស់ ដោយនេះគ្រាន់តែជាជំហានចាប់ផ្ដើមតែប៉ុណ្ណោះ ។ សូមអធ្យាស្រ័យជំរាបលោកម្ចាស់ *គូរ៉ាណាកា* ផងថាពេលនេះខ្ញុំត្រៀមខ្លួនបានស្រួលបួលជាងមុន ដើម្បីឆ្លើយនឹងសំនួររបស់លោក រឺដើម្បីជួយលោក ហើយខ្ញុំសប្បាយចិត្តណាស់ដែលបានចេញពីគុកនេះ ។ ជំរាបលោកផងថា ខ្ញុំសូមអរគុណ ។

*ភ្លាក់ផន* តាមសំលឹងមើល *ម៉ារីកូ* ជាប់ទៅពេលដែលនាងបែរខ្លួនទៅនិយាយជាមួយ *គូរ៉ាណាកា* នោះ ។ គេដឹងថា គេត្រូវនិយាយពាក្យសាមញ្ញ ល្អបំផុតនិយាយឃ្លាខ្លីៗ ហើយត្រូវតែប្រយ័ត្នអោយមែនទែន ពីព្រោះខុសពីបព្វជិត *អាល់វីតូ* ដែលបកតាមភ្លាមៗនោះ នារីនេះរង់ចាំទាល់តែគេនិយាយចប់ទើបសង្ខេបសេចក្ដី រឺពន្យល់ពីគំនិតគេតែម្ដង ដែលជាបញ្ហាទូទៅរបស់អ្នកបកប្រែទាំងអស់ លើកលែងតែអ្នកបកប្រែពូកែបំផុតនោះ ។ នេះមិនទាន់គិតដល់អ្នកបកប្រែ ដែលបណ្ដោយអោយបុគ្គលភាពរបស់ខ្លួនជះឥទ្ធិពលទៅលើអ្វីដែលបាននិយាយនោះផងទោះចង់ រឺមិនចង់ក្ដី ។

ការមុជទឹក ធ្វើសរសៃ ហើយនិងការសំរាកអស់រយៈពេលពីរម៉ោង បានធ្វើអោយគេមានកំលាំងកំហែងយ៉ាងច្រើន ។ គេបានផ្ដល់សំលៀកបំពាក់ថ្មី ហើយទីសំរាកត្រូវបានរៀបចំយ៉ាងស្អាត ធ្វើអោយគេមានអារម្មណ៍ដូចជានៅក្នុងសុបិន្ត ហើយគេតែងតែដណ្ដឹងសួរនៅក្នុងចិត្តថា តើរវាងនៅក្នុងគុក នឹងនៅទីកន្លែងដ៏ស្អាតប្រណីតនេះ មួយណាជាការមែនទែន មួយណាជាការយល់សប្ដិ ។

បន្ទាប់មក *ភ្លាក់ផន* បានរង់ចាំយ៉ាងអន្ទះសា ដោយសង្ឃឹមថា គេនឹងត្រូវនាំទៅជួប *គូរ៉ាណាកា* មិនខាន ។ នៅក្នុងចិត្តរបស់គេៗបានគ្រោងឡើងនូវអ្វីដែលត្រូវនិយាយ អ្វី ដែលត្រូវបើកកកាយ ពីរបៀបដើម្បីបកអាក្រាតបព្វជិត *អាល់វីតូ* ហើយដឹងពីររបៀបធ្វើយ៉ាងណាមានឥទ្ធិពលទៅលើ *គូរ៉ាណាកា* ហើយនិងទៅលើបព្វជិតនោះ ។ អ្វីៗដែលគេបានដឹងពី បព្វជិត *ដូមិញ្ញូ* អំពីពួកប៉ែកទុយកាល់ ពីនយោបាយជាមួយប្រទេសជប៉ុន ហើយនិងការរកស៊ីជួញដូរនោះមក គេអាចជួយ *គូរ៉ាណាកា* បានហើយៗគេសង្ឃឹមថា *គូរ៉ាណាកា* ពិតជាផ្ដល់នូវទ្រព្យ



www.budinst.gov.kh www.elibraryofcambodia.org

សម្បត្តិ ដែលគេបង់នោះមកអោយគេយ៉ាងងាយ ដើម្បីជាកិច្ចដឹងគុណ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

តែពេលនេះ ដោយគ្មានវត្ថុមានរបស់បព្វជិត *អាលវិក្ក* ដើម្បីទទួលថែមទៀតនោះ *ភ្ជាក់ថន* កាន់តែមានទំនុកចិត្តលើខ្លួនឯងថែមទៀត ។ អ្វីដែលអញត្រូវការ គឺរឿងលេងបន្តិច ហើយនិងការអត់ធ្មត់ប៉ុណ្ណោះ ។

*ភូវ៉ាណាកា* កំពុងតែស្តាប់យ៉ាងយកចិត្តទុកដាក់ នូវសំដីរបស់នារីបកប្រែ ប្រៀបដូចជាកូនក្រមុំកៅស៊ូនោះ ។

នាងនេះអញលើកតែដៃមួយរួចយ៉ាងធូរល្ហែង- *ភ្ជាក់ថន* គិតនៅក្នុងចិត្ត-នាងនេះអាយុប៉ុន្មានហើយអីចឹង ? ស្គាតខ្ចង់តែម្តង គ្មានទាស់កន្លែងណាសោះ ! នាងមានប្តីហើយ រឺនៅអីចេះ ? ឥតឃើញនាងពាក់ចិញ្ចៀនការទេ ។ គួរដែរ ។ នាងនេះឥតពាក់គ្រឿងអលង្ការអ្វីបន្តិចសោះតែម្តង ក្រៅតែពីស្នៀតសក់ប្រាក់នៅក្នុងផ្នួងសក់របស់នាង ។ នារីចាស់ដែលនៅអង្គុយពីក្រោយ *ភូវ៉ាណាកា* ក៏តែអីចឹង ។

*ភ្ជាក់ថន* ប្រឹងខំរកនឹកនៅក្នុងខួរក្បាលរបស់ខ្លួន ។ នារីទាំងពីរនាក់ទៀត នៅឯភូមិក៏មិនឃើញមានពាក់គ្រឿងអលង្ការអ្វីទាំងអស់ដែរ ហើយអ្នកនៅក្នុងផ្ទះ *មូវ៉ា* ក៏ឥតមានពាក់ដែរ ។ ហេតុអីអីចេះ ?

រួចចុះនារីចាស់នោះជាអ្នកណា ? ជាប្រពន្ធរបស់ *ភូវ៉ាណាកា* រឺ ? រឺមួយក៏ជាមេដោះក្មេងនេះទេ ? រួចអាល្អិតនេះកូន *ភូវ៉ាណាកា* រឺយ៉ាងម៉េច ? រឺមួយក៏ជាចៅទេ ? បព្វជិត *មូមិញ្ញូ* និយាយប្រាប់ថា ពួកជប៉ុនអាចមានប្រពន្ធតែមួយទេ តែគេអាចមានប្រពន្ធចុងប៉ុន្មានក៏បានដែរ ។

តើអ្នកបកប្រែនេះ ជាប្រពន្ធចុងរបស់ *ភូវ៉ាណាកា* ដែរទេ ?

រួចចុះបើបាននារីបែបនេះ នៅក្នុងគ្រែជាមួយវិញ តើយ៉ាងម៉េចដែរ ? តែមិនស្រួលច្បាស់ជាអញ្ជើតបាក់ឆ្អឹងអស់មិនខានទេ ។ ប៉ុន្តែប្រហែលជាមិនបាក់ទេ។ នៅប្រទេសអង់គ្លេសក៏មានស្រីខ្លះមាឌតូចដូចនាងដែរតើ តែក៏មិនដូចនាងនេះដែរ ។

កុមារដែលអង្គុយជិត *ភូវ៉ាណាកា* នោះ មានរាងល្អិត ភ្នែកបើកធំៗ ហើយអង្គុយយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

ព្រង់ខ្លួន ។ សក់ខ្មៅរបស់កុមារនេះ ត្រូវបានគេកួចចងជាកន្ទុយសេះយ៉ាងខ្លី ក្បាលរបស់គេមិនទាន់កោរនៅឡើយ ។ កុមារនេះបានបង្ហាញអោយឃើញនូវការចង់ដឹងឥតមានព្រំដែនរបស់ខ្លួន ហើយដោយឥតបានគិតថាខ្លួនធ្វើអ្វីផងនោះ *ប្លាក់ថន* ក៏មិចភ្នែកដាក់កុមារនោះ ។ កុមារនោះភ្ញាក់ព្រើត រួចក៏តាំងសើចក្អាកក្អាយ ហើយបញ្ឈប់ *ម៉ារីកូ* លែងអោយនិយាយទៀត ដោយចង្អុលទៅ *ប្លាក់ថន* បណ្ដើរ និយាយបណ្ដើរ ។

- លោកម្ចាស់ *តូរ៉ាណាកា* សួរថា ហេតុអ្វីបានជាលោកធ្វើអីចឹង ?

- ខ្ញុំចង់អោយនាងតូចនេះវាបានសប្បាយទេតើ ។ នេះជាកូនក្មេងដូចគេដូចឯងដែរ ហើយក្មេងនៅស្រុកខ្ញុំតែកាលណាធ្វើអីចឹងដាក់វា១ តែងតែសើចកក្អឹកហើយ ។ កូនប្រុសខ្ញុំអីលូវនេះអាយុស្រករក្មេងនេះដែរ ។ កូនប្រុសខ្ញុំអាយុប្រាំពីរឆ្នាំហើយ ។

- ទាយាទអម្ចាស់អាយុប្រាំពីរឆ្នាំហើយដែរ ។

ក្រោយពីនៅស្ងៀមបន្តិច *ម៉ារីកូ* ក៏បកប្រែសំដីរបស់ *ប្លាក់ថន* ប្រាប់អ្នកឯទៀត ។

- ទាយាទ ? មានន័យថា កុមារនេះជាកូនប្រុសតែមួយគត់របស់លោកម្ចាស់ *តូរ៉ាណាកា* អ្ហ៎ ? -*ប្លាក់ថន* សួរ ។

- លោកម្ចាស់ *តូរ៉ាណាកា* ណែនាំខ្ញុំសូមអោយជំរាបប្រាប់លោកថា ក្នុងពេលនេះ សូមលោកកំនត់ព្រំដែនរបស់លោកនៅត្រឹមតែឆ្លើយនឹងសំនួរដែលគេសួរលោកតែប៉ុណ្ណោះ បានហើយ ។

រួច *ម៉ារីកូ* បន្តទៀត :

- ខ្ញុំគិតថា បើសិនជាលោកតែកុង *ប្លាក់ថន* ចេះអត់ធ្មត់នោះ លោកនឹងមានឱកាសសួរនូវអ្វីដែលលោកចង់ដឹងជាមិនខាន ។

- ល្អណាស់ ។

-ដោយឈ្មោះលោកពិបាកហៅតាមសំឡេងជប៉ុនពេក ព្រោះភាសាយើងគ្មានសំឡេងនេះ តើលោកអនុញ្ញាតអោយខ្ញុំពេលបកជូនលោកម្ចាស់ *តូរ៉ាណាកា* ហៅឈ្មោះលោកជាភាសាជប៉ុនថា *អាន់ជីន-សាន* បានទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- បាទ ! បាទ !

រួច *ប្លាក់ថន* ហៀបបហាមាត់សួរបន្តទៀតទៅហើយ ប៉ុន្តែគេនឹកឃើញទាន់នូវពាក្យបណ្ដាំរបស់ *ម៉ារីកូ* ទើបគេខំសង្កត់ចិត្តនៅរង់ចាំយ៉ាងស្ងៀមស្ងាត់ទេវិញទៅ ។

- សូមអរគុណលោក ។ លោកម្ចាស់ខ្ញុំសួរថា តើលោកមានកូនផ្សេងទៀតទេ ?

- មានកូនស្រីមួយទៀត ។ នាងកើតមុនពេលខ្ញុំរៀបចេញពីប្រទេសអង់គ្លេសបន្តិច ។ ឥឡូវនេះកូនស្រីខ្ញុំអាយុប្រហែលពីរឆ្នាំហើយ ។

- លោកមានប្រពន្ធមួយ រឺមានច្រើន ?

- មួយ ។ នេះគឺជាទំនៀមទំលាប់របស់ពួកយើង ហើយក៏ដូចពួកអេស្ប៉ាញ និងប័កទុយកាល់ដែរ ។ ពួកយើងអត់មានប្រពន្ធចុងទេ ។ ពោលគឺប្រពន្ធចុងផ្លូវការ ។

- នោះគឺជាប្រពន្ធទីមួយរបស់លោកឬ ?

- បាទ !

- សូមទោស លោកអាយុប៉ុន្មានហើយ ?

- សាមសិបប្រាំមួយ ។

- នៅអង់គ្លេសលោករស់នៅកន្លែងណា ?

- នៅជាយ *ឆាតថាម* ។ នេះគឺជាកំពង់ផែតូចមួយក្បែរទីក្រុង *ឡុង* ។

- *ឡុង* គឺជាទីក្រុងសំខាន់ជាងគេឬ ?

- បាទ ។

- លោកម្ចាស់សួរថា តើលោកនិយាយភាសាអ្វីខ្លះ ?

- អង់គ្លេស . ប័កទុយកាល់ . អេស្ប៉ាញ . ហូឡង់ និងឡាតាំង ។

- ស្អីទៅហូឡង់នោះ ?

- នេះជាភាសាដែលគេនិយាយនៅអឺរ៉ុប ។ នៅប្រទេស ហូឡង់ ។ វាស្រដៀងគ្នា នឹងអាឡឺម៉ង់ដែរ ។

*ម៉ារីកូ* ជ្រួញចិញ្ចើម :



www.budinst.gov.kh www.elibraryofcambodia.org

- ហូឡង់ ជាភាសាក្រៅសាសនាមែនទេ ? អាឡឺម៉ង់ក៏អ៊ីចឹងដែរ មែនទេ ?

*ប្លាក់ថន* ឆ្លើយតបយ៉ាងប្រុងប្រយ័ត្ន :

- ប្រទេសទាំងពីរនេះ ជាប្រទេសមិនមែនកាតូលិចទេ ។

- ខ្ញុំសូមទោស នេះមិនមែនមានន័យថាក្រៅសាសនាទេអ្វី ?

- អត់ទេអ្នកនាង ។ គ្រិស្តសាសនាត្រូវបែកចេញជាសាសនាពីរដាច់គ្នា និងខុសគ្នា គឺនិកាយកាតូលិច និងនិកាយប្រូតេស្តង់ ។ គឺមានរបៀបបកស្រាយគ្រិស្តសាសនាពីរបែបខុសគ្នា ។ នៅជប៉ុនគឺនិកាយកាតូលិច ។ បច្ចុប្បន្ននិកាយទាំងពីរនោះ គឺជាសត្រូវនឹងគ្នាស៊ីសាច់ហុតឈាម ។

*ប្លាក់ថន* បានកត់សំគាល់ឃើញនូវការភ្ញាក់ផ្អើលរបស់ *ម៉ារីកូ* ហើយនិងមានអារម្មណ៍ថា *តូរ៉ាណាកា* កំពុងតែចាប់ផ្តើមមួម៉ៅហើយ ដោយលោកត្រូវនៅក្រៅកិច្ចសន្ទនានេះ ។ ប្រយ័ត្នប្រយែងអាក៏ -ប្លាក់ថន រំលឹកខ្លួនឯង ។ នាងនេះច្បាស់ជាកាតូលិចហើយ ។ និយាយយ៉ាងណាអោយចំសាច់រឿងវុី ! ហើយនិយាយពាក្យសាមញ្ញៗបានហើយ ។

គេបន្ទឹបន្តទៀត :

- លោកស្រី ! ប្រហែលជាលោកម្ចាស់ *តូរ៉ាណាកា* មិនមានបំណងជជែករឿងសាសនាទេ ព្រោះកាលពីពេលជួបគ្នាដំបូងនោះ យើងបាននិយាយរឿងនេះខ្លះហើយ ។

- លោកជាគ្រិស្តសាសនិកប្រូតេស្តង់មែនទេ ?

- មែន ។

- ហើយពួកគ្រិស្តសាសនិកកាតូលិច គឺជាសត្រូវរបស់លោកមែនទេ ?

- ភាគច្រើនពួកគេច្រើនចាត់ទុកខ្ញុំថាជាពួកបែកធ្មេង ហើយជាសត្រូវរបស់ពួកគេមែន ។

*ម៉ារីកូ* រាងអេះអុញបន្តិច រួចងាកទៅនិយាយប្រាប់ *តូរ៉ាណាកា* យ៉ាងយូរ ។

នៅឯជាយសួនច្បារមានកងការពារជាច្រើន ។ ហើយនៅឆ្ងាយពីនេះក៏មានច្រើន



www.budinst.gov.kh www.elibraryofcambodia.org

ណាស់ដែរ ។ ពួកគេគឺជាពួកពណិក្នោតទាំងអស់ ។ រួច *ប្លាក់ថន* កត់សំគាល់ឃើញពួកពណិប្រផេះចំនួនដប់នាក់ដែលអង្គុយយ៉ាងមានរបៀបរៀបរយក្រោមម្លប់ឈើមួយ ។ ភ្នែកគេសំលឹងមើលកុមារនោះជាប់ឥតដាក់ភ្នែក ។ តើនេះមានន័យយ៉ាងម៉េចណឹង ? គេដណ្តឹងសួរនៅក្នុងចិត្ត ។

*តូរ៉ាំណាកា* សួរបកទៅ *ម៉ារីកូ* វិញ រួចក៏និយាយត្រង់ទៅកាន់ *ប្លាក់ថន* ។

*ម៉ារីកូ* ចាប់ផ្តើមបកបន្តទៀត :

- លោកម្ចាស់របស់ខ្ញុំចង់ដឹងពីរូបលោក ពីគ្រួសាររបស់លោក ពីប្រទេសរបស់លោក។ រឿងមហាក្សត្រិយានី ពីអ្នកដឹកនាំមុនៗ ទំនៀមទំលាប់ និងប្រវត្តិស្រុកលោក ។ លោកម្ចាស់ក៏ចង់ដឹងពីប្រទេសផ្សេងៗទៀតដែរ ពិសេសប្រទេស ប៉កទុយកាល់ និង អេស្ប៉ាញ ។ លោកម្ចាស់ចង់ដឹងទាំងអស់ពីពិភពលោក ដែលលោករស់នៅនេះ ។ ពីសំពៅលោក ពីអាវុធ ម្ហូប ជំនួញជួញដូរ ។ ពីសង្គ្រាម និងសមរភូមិ ពីររបៀបបើកសំពៅ ពីការធ្វើដំណើររបស់លោក ។ លោកម្ចាស់ចង់យល់... ហេតុអីបានលោកសើច?

- ពីព្រោះគាត់ចង់ដឹងតែទាំងអស់តែម្តង ។ ចង់ដឹងអ្វីទាំងអស់ ដែលខ្ញុំដឹង ។

- ចាស់ ព្រោះនេះគឺពិតជាបំនងរបស់លោកម្ចាស់ខ្ញុំមែន ។ " ពិតជា " តើខ្ញុំប្រើពាក្យនេះត្រូវទេ ?

- ត្រូវហើយអ្នកនាង ។ ខ្ញុំសូមសរសើរយ៉ាងស្មោះចំពោះភាសា ប៉កទុយកាល់ យ៉ាងច្បាស់របស់អ្នកនាង ។

*ម៉ារីកូ* បក់ផ្លិតបន្តិចៗ ។

- សូមអរគុណលោកណាស់ ។ ពិតហើយ លោកម្ចាស់របស់ខ្ញុំចង់ដឹងការពិតពីសព្វបែបយ៉ាង ចង់ដឹងពីហេតុការណ៍នានា ហើយនិងយោបល់របស់លោកផង ។

- ខ្ញុំនឹងជំរាបជូនលោកដោយរីករាយបំផុត ។ តែអាចស៊ីពេលច្រើនណាស់ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកមានពេលគ្រប់គ្រាន់ ។

*ប្លាក់ថន* សំលឹងមើលទៅ *តូរ៉ាំណាកា* :



www.budinst.gov.kh www.elibraryofcambodia.org

- *រ៉ាកាវីម៉ាស៊ូ !*

- អោយខ្ញុំអធ្យាស្រ័យណាលោក ។ លោកម្ចាស់ខ្ញុំប្រាប់ថា លោកនិយាយមិនទាន់បានច្បាស់នៅឡើយទេ ។

រួច *ម៉ារីកូ* និយាយអោយ *ប្លាក់ថុន* ស្តាប់ និងថាតាមនាង ។ ក្រោយពី *ប្លាក់ថុន* ថ្លែងអំនរគុណចំពោះនាងមក នាងក៏ពោលបន្ថែមទៀត :

- ខ្ញុំគឺជាអ្នកស្រី *ម៉ារីកូ ប៊ុនតារ៉ូ* មិនមែនអ្នកនាងកញ្ញានោះទេ ។

- បាទអ្នកស្រី !

*ប្លាក់ថុន* ចោលភ្នែកទៅរក *តូរ៉ាណាកា :*

- តើគាត់ចង់អោយខ្ញុំចាប់និយាយពីត្រង់ណាទៅ ?

*ម៉ារីកូ* សួរទៅ *តូរ៉ាណាកា* ។ ស្នាមញញឹមយ៉ាងស្រាលបានរត់កាត់យ៉ាងរហ័សលើផ្ទៃមុខរបស់ *តូរ៉ាណាកា* ។ *ម៉ារីកូ* ងាកមកនិយាយ :

- លោកម្ចាស់និយាយថា ចាប់ពីដើមទីមក ។

*ប្លាក់ថុន* ដឹងថា នេះពិតជាការសាកល្បងមួយទៀតហើយ ។ តើគេត្រូវចាប់ផ្តើមពីអ្វីទៅ ? តើគេត្រូវនិយាយសំដៅទៅអ្នកណា ? ទៅ *តូរ៉ាណាកា* ? ទៅកុមារ ? រឺក៏ទៅនារីនោះ ? ពិតណាស់ហើយ បើនៅទីនេះមានសុទ្ធតែបុរសនោះ គេត្រូវផ្តោតសំដៅ *តូរ៉ាណាកា* ។ ចុះអីល្វូវនេះវិញ ? ហេតុអីបានជាមានវត្តមានក្មេង និងនារីនេះដែរ ? នេះគឺមានន័យអ្វីមួយហើយ ។

រួចគេក៏សំរេចថា ផ្តោតទៅលើកុមារ និងស្ត្រីនោះ ។

- កាលពីព្រេងនាយ ប្រទេសខ្ញុំត្រូវគ្រប់គ្រងដោយព្រះមហាក្សត្រមួយព្រះអង្គដែលមានព្រះខ័នទិព្វមួយឈ្មោះ *អ៊ិចស្កាលីបូ* ហើយព្រះរាជមហេសីរបស់ព្រះអង្គ គឺជាបវរកញ្ញាគ្មានពីរនៅលើដែនដី ។ ទីប្រឹក្សារបស់ព្រះអង្គ គឺជាគ្រូវេទមន្តម្នាក់ឈ្មោះ *ម៉ែលើន* ហើយព្រះមហាក្សត្រអង្គនោះ ព្រះនាមហៅថា អាកធូ...

*ប្លាក់ថុន* ចាប់ផ្តើមនិទានយ៉ាងមានទំនុកចិត្ត ដោយលើកឡើងពីរឿងព្រេងដែលឪពុកគេតែងតែនិយាយប្រាប់កាលពីគេនៅជាកុមារនៅឡើយ :



www.budinst.gov.kh www.elibraryofcambodia.org

- រាជធានីរបស់ព្រះបាទ*អាកថូ* ឈ្មោះ*កាមេឡូ* ហើយក្នុងពេលនោះគឺជាសម័យមួយពោរពេញដោយសុភមង្គលព្រោះគ្មានចំបាំង ភោគផលក៏សំបូរហូរហៀរហើយ........-រំពេចនោះ *ប្លាក់ផន* ទើបដឹងថា គេកំពុងធ្វើការមួយភ័ន្តច្រលំយ៉ាងធំ ។ សាច់រឿងដែលសំខាន់ គឺទាក់ទិនទៅនឹង *គ្វីនេវ៉េ* ហើយនិង *ឡង់សឺឡូ* គឺជាមហារាជនីកំផិត និងអណ្ដាប់ទ្រុស្តម្នាក់ ហើយនិង*ម៉កទ្រិត* កូនអត់ខាន់ស្លារបស់ព្រះបាទ *អាកថូ* ដែលបានបង្កសង្គ្រាមយ៉ាងថោកទាបប្រឆាំងនឹងបិតាឯង ហើយនឹងប្រការដែលត្រូវ*អាកថូ* សំលាប់បុត្រាឯងនេះ នៅក្នុងការប្រយុទ្ធ ហើយខ្លួនព្រះអង្គផ្ទាល់ ក៏ត្រូវរបួសធ្ងន់ធ្ងរដែរ ដោយសារ*ម៉កទ្រិត* ។

ឱព្រះអង្គអើយព្រះអង្គ ! ហេតុអីក៏អញស្ញើល្ញើពកថ្វាសបែបណឹងទៅវិញ ? តើ *គូវ៉ាណាកា* មិនដូចជាមហាក្សត្រទេអ្វី ? ហើយនោះមិនជាមហេសីទេអ្វី ? រួចហើងមិនមែន បុត្រាទេអ្វី ?

- លោកមិនស្រួលខ្លួនទី ?

- ទេ ! ទេ ! .......ខ្ញុំ.......ខ្ញុំ........សូមទោស..........គ្រាន់តែ...........គ្រាន់តែ.........

- លោកកំពុងនិយាយពីរឿងស្ដេចនោះ ហើយនិងភោគផលហូរហៀរណា ។

- បាទ ! .............គឺ..................គឺ.............គឺថា ដូចជានៅប្រទេសនានា ជាភាគច្រើនដែរ អតីតកាលរបស់យើងខ្ញុំ មានលាយឡំទៅដោយរឿងព្រេង និងរឿងនិទានសព្វបែបយ៉ាង ប៉ុន្តែអានេះមិនមែនជារឿងសំខាន់ទេ ។

*ប្លាក់ផន*និយាយពីនេះពីនោះ ដើម្បីចំនេញពេលគិតគូរ ហក់រករឿងថ្មីទៀត ។ *ម៉ារីកូ* សំលឹងមើល*ប្លាក់ផន*ទាំងងឿងឆ្ងល់ ។ *គូវ៉ាណាក*សំលក់*ប្លាក់ផន*ស្ទើរធ្លុះអង្គប្រាណ ឯកុមារនោះ ក៏ចាប់ផ្ដើមស្ទាបផងដែរ ។

- លោកនិយាយបន្តទៀតទៅ ។

- ខ្ញុំ.........ខ្ញុំ.....នែ៎

រួចខួរក្បាលរបស់គេហាក់ដូចជាជះពន្លឺភ្លែត ។ គេក៏និយាយឡើងយ៉ាងញាប់រន្ទាន់ :

- មើលទៅរឿងល្អបំផុតខ្ញុំគួរតែគូរផែនទីពិភពលោកជូនមើលវិញអ្នកស្រី ។ គូរផែនទី



www.budinst.gov.kh www.elibraryofcambodia.org

មួយត្រឹម ដែលយើងបានស្គាល់មកត្រឹមសព្វថ្ងៃនេះ ។ តើលោកស្រីយល់ព្រមទេ ?

នៅពេលដែល *ម៉ារីកូ* បកប្រែរួច *ក្លាក់ថន* មើលឃើញពន្លឺនៃការយកចិត្តទុកដាក់លេច ឡើងមួយភ្លែតនៅក្នុងក្រសែភ្នែករបស់ *តូរ៉ាណាកា* ប៉ុន្តែកុមារនិងនារីនោះនៅស្ងៀមស្ងាត់គ្មានប្រតិកម្មអ្វីទាំងអស់ ។ តើធ្វើម៉េចដើម្បីទាក់ទាញពីរនាក់នេះផងអីចេះ ?

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថាយល់ព្រម ។ ខ្ញុំនឹងប្រើគេអោយទៅយកក្រដាស ។

- សូមអរគុណ ប៉ុន្តែនៅពេលនេះមិនអីទេ ។ ចាំនៅពេលក្រោយ បើអ្នកស្រីអោយប្រដាប់ប្រដាគ្រប់គ្រាន់ ខ្ញុំនឹងគូរមួយទៀតអោយបានច្បាស់លាស់ជាង ។

*ក្លាក់ថន* ក្រោកចេញពីកន្លែងអង្គុយ ហើយលុតជង្គង់ចុះនៅលើដីខ្សាច់ ។ គេយកម្រាមដៃគូសវាសលើដីខ្សាច់ជាទំរង់ផែនទីមួយ ដោយបង្វិលក្បាលបកខាងខ្លួនគេដើម្បីអោយអ្នកឯទៀតមើលឃើញច្បាស់ ។ គេបន្ថឹបន្ត :

- ផែនដីមានរាងមូល ដូចជាផ្លែក្រូច ។ ប៉ុន្តែផែនទីនេះ ប្រៀបដូចជាសំបកផ្លែក្រូចដែលគេចៀរវាពីជើងមកត្បូង ហើយយកមកលាតសន្ធឹងនៅលើដីយ៉ាងដូច្នោះដែរ ។ ជនជាតិហូឡង់ ម្នាក់ឈ្មោះ *មែកាទ័រ* (Mercator ) បានរកឃើញវិធីនេះ កាលពីម្ភៃឆ្នាំមុន ។ អាស្រ័យវិធីនេះ គេអាចគូសផែនទីបានប្រាកដប្រជាជាងមុនច្រើនណាស់ ។ ហើយនេះក៏ជាផែនទីពិភពលោកលើកដំបូងដែលប្រាកដប្រជាផងដែរ ។ ខាងនេះគឺជា ខាងជើង និងខាងត្បូង ហើយខាងនេះ គឺជាខាងកើត និងខាងលិច ។ ជប៉ុននៅកន្លែងនេះ ឯប្រទេសខ្ញុំ នៅចុងម្ខាងនេះ ។ ម្តុំនេះគឺជាតំបន់ដែលគ្មានអ្នកណាដឹង គ្មានអ្នកណាទៅដល់នៅឡើយ ។

ដៃរបស់ *ក្លាក់ថន* វាសចោលតំបន់ខាងជើងទ្វីបអាមេរិចចាប់ពីឧត្តរទិសនៃប្រទេសមិចស៊ិច តំបន់អាមេរិចខាងត្បូង លើកលែងតែប្រទេសប៉េរូ ហើយនិងតំបន់តាមឆ្នេរសមុទ្រតំបន់ចាប់ពីភាគខាងកើត និងខាងជើងប្រទេស *ន័រវែស* តំបន់ចាប់ពីភាគខាងកើតតំបន់ *មូស្គូ* ទាំងទ្វីបអាស៊ី ភាគខាងក្នុងទ្វីបអាព្រិច. ភាគខាងត្បូងកោះជ្វា ហើយនិងចុងភាគអាមេរិចខាងត្បូង ។ គេបន្តទៅទៀត :

- យើងស្គាល់តែបណ្តោយឆ្នេរប៉ុណ្ណោះ ហើយស្គាល់នេះតែបន្តិចបន្តួចទេ ។ ពួកយើង



www.budinst.gov.kh www.elibraryofcambodia.org

សឹងតែងពិតឈឹងតែម្តង ពីភាគខាងក្នុងនៃទ្វីបអាមេរិច អាព្រិច និងអាស៊ីនេះ ។

និយាយដល់ត្រឹមនេះ *ភ្លាក់ថន* ក៏ឈប់សិន ដើម្បីអោយ *ម៉ារីកូ* បក ។ ពេលនេះ *ម៉ារីកូ* បកដូចជាធូរជាងមុន ហើយ *ភ្លាក់ថន* មានអារម្មណ៍ថា អ្នកទាំងបីនាក់ កំពុងតែចាប់អារម្មណ៍ខ្លាំងឡើង១ហើយ ។

កុមារតូចនោះ រំកិលខ្លួនចូលមកជិតជាងមុនហើយ ។

- លោកទាយាទ ចង់ដឹងថា តើពួកយើងនៅកន្លែងណាទៅ នៅលើផែនទីនេះ ?

- នៅកន្លែងនេះ ។ ហើយនេះគឺជាប្រទេស *ការ៉ែ* រឺស្រុកចិន បើតាមខ្ញុំស្មាន ។ តែខ្ញុំមិនដឹងថាចំងាយវាមានប៉ុន្មានទេ ។ គ្រាន់តែពីកន្លែងនេះមកដល់នេះ ខ្ញុំត្រូវប្រើពេលអស់ពីរឆ្នាំហើយ ។

*តូរ៉ាណាកា* និងនារីចាត់នោះប្រឹងដកកដើម្បីមើលអោយបានច្បាស់ ។

- លោកទាយាទ សួរថា ហេតុអីបានជានៅលើផែនទីនេះ ស្រុកយើងអីក៏តូចម្លេះ ?

- នេះគឺគ្រាន់តែជាខ្នាតទេ អ្នកស្រី ។ នៅលើទ្វីបនេះគឺដីថ្មី ។ កន្លែងនេះ ដល់មិចស៊ិច មានប្រហែលមួយពាន់គាវុធទៅហើយ១ ក្នុងមួយគាវុធមានបី ម៉ៃ ។ ហើយពីកន្លែងនេះមកដល់ *យេដូ* មានប្រហែលមួយរយគាវុធ ។

ភាពស្ងៀមស្ងាត់បានកើតមានឡើងបន្ទាប់ពី *ភ្លាក់ថន* បញ្ចប់សំដីរបស់ខ្លួនបន្តិច ក្រោយមកទើបពួកគេចាប់ផ្តើមជជែកគ្នាមួយសន្ទុះ ។

- លោកម្ចាស់ *តូរ៉ាណាកា* មានបំនងចង់អោយលោកបង្ហាញនៅលើផែនទីនេះថា តើលោកមកដល់ជប៉ុនតាមណា ។

- មកតាមនេះ ។ នេះគឺជាច្រកសមុទ្រ *ម៉ាសេឡង់* ដែលនៅចុងអាមេរិចខាងត្បូងនេះ ។ កន្លែងនេះមានឈ្មោះអ៊ីចឹង គឺគេហៅតាមឈ្មោះអ្នកដើរសំពៅប៉័កទុយកាល់ម្នាក់ ដែលរកឃើញច្រកនេះកាលពីប៉ែតសិបឆ្នាំមុន ។ ចាប់ពីពេលនោះមកពួកប៉័កទុយកាល់ និងពួកអេស្ប៉ាញបានរក្សាការសំងាត់ពីច្រកនេះ ដើម្បីពួកវាប្រើផ្តាច់មុខ ។ ពួកយើងខ្ញុំ គឺជាអ្នកក្រៅទីមួយ ដែលឆ្លងកាត់ច្រកនេះ ។ នេះដោយសារខ្ញុំមានកូនសៀវភៅសំងាត់របស់ពួកវា អាណឹង



www.budinst.gov.kh www.elibraryofcambodia.org

ដូចជាផែនទីម៉ាបែបដែរ តែអ៊ីចឹងហើយខ្ញុំត្រូវរង់ចាំប្រាំមួយខែ ទើបឆ្លងបានដោយខ្យល់បក់ខ្លាំងពេក ។

*ម៉ារីកូ* បកសំដីរបស់ *ក្លាក់ថុន* ។ *តូរ៉ាណាកា* សំលឹងមើលទៅលើ ។ ទឹកមុខរបស់លោកបង្ហាញនូវការមិនជឿទៅលើអ្វី ដែល *ក្លាក់ថុន* បាននិយាយឡើយ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកច្រលំហើយ ។ ពួកអ្នកចុង.......ប៉ុកទុយកាល់មកពីទិសខាងត្បូងវិញទេតើ ។ ទិសណុងទើបជាផ្លូវរបស់ពួកគេ ។ ជាផ្លូវតែមួយគត់ ។

- បាទ ជាការពិតហើយ ដែលពួកប៉ុកទុយកាល់ចូលចិត្តផ្លូវនោះ ។ គឺការបើកវាងតាមជ្រោយនៃសង្ឃឹមល្អ (Cape of Good Hope) ។ នេះគឺពួកវាមានបន្ទាយប៉ុន្មានជណ្តប់នៅតាមបណ្តោយឆ្នេរ អាព្រិច ឥណ្ឌា និងកោះគ្រឿងទេស សំរាប់ពួកវាបន្ថែមស្បៀង ហើយជ្រកពេលរដូវរងា ។ ម្យ៉ាងទៀតកងសំពៅចំបាំងរបស់ពួកវាធ្វើល្បាត និងធ្វើភ្លើង ធ្វើព្យុះនៅលើដែនសមុទ្រនោះ ។ តែពួកអេស្ប៉ាញប្រើច្រកសមុទ្រ *ម៉ាសេឡង់* ដើម្បីទៅកាន់ដែនដីអាណានិគមរបស់ពួកវានៅអាមេរិច នៅក្នុងមហាសមុទ្រ ប៉ាស៊ីភិច ហើយនិងភីលីពីន ។ បើពុំនោះទេ ពួកវាដើរកាត់កន្លែងនេះ គឺដីសន្ទះ (isthmus) ប៉ាណាម៉ា ដើម្បីបំព្រួញការធ្វើដំណើររាប់ខែ ។ ចំពោះពួកយើងខ្ញុំការឆ្លងកាត់តាមច្រក *ម៉ាសេឡង់* គឺធានាសន្តិសុខជាង បើមិនអ៊ីចឹងទេ យើងត្រូវគ្រាប់កាណុងបន្ទាយពួកប៉ុកទុយកាល់ តែទាំងអស់ហ្នឹង ។ សូមអ្នកស្រី ជំរាបលោកម្ចាស់ *តូរ៉ាណាកា* ផងថា អីលូវនេះខ្ញុំស្គាល់ទីតាំងរបស់ពួកវាមួយចំនួនហើយ ។ ភាគច្រើនពួកវាប្រើទ័ពជប៉ុនទៀតផង.............

រួច *ក្លាក់ថុន* ពោលបន្ថែមទៀត យ៉ាងមាំទាំ :

- បព្វជិត ដែលផ្តល់ពត៌មានទាំងនេះអោយខ្ញុំពេលនៅក្នុងគុក គឺជាជនជាតិ អេស្ប៉ាញ ហើយលោកស្អប់ទាំងពួកប៉ុកទុយកាល់ ស្អប់ទាំងពួក *យេស៊ូត* ថែមទៀតផង ។

*ក្លាក់ថុន* ក្រលេកឃើញប្រតិកម្មលេចចេញយ៉ាងរហ័សនៅលើផ្ទៃមុខរបស់ *ម៉ារីកូ* ហើយ *តូរ៉ាណាកា* ក៏មានប្រតិកម្មដូចគ្នាដែរ នៅពេលដែលនាងបកប្រែចប់ ។ កុំអាលបង្ហំនាង ។ ទៅតាមសំរួលអារ៉ា -គេគិតនៅក្នុងចិត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

- ទ័ពជប៉ុន ? លោកចង់និយាយថា ពួកសាមូរ៉ៃអ្ហី ?

- ខ្ញុំគិតថា នោះគឺពួក *រ៉ូនីន* ទាន ។

- លោកនិយាយថា ផែនទី " សំងាត់ " មែនទេ ? លោកម្ចាស់ខ្ញុំចង់ដឹងថា តើធ្វើម្ដេចលោកយកបាន ?

- មានមនុស្សម្នាក់ឈ្មោះ *ពីទែ ស៊ុយដៃហូរ* មកពីហូឡង់ បានធ្លាប់ធ្វើជាលេខាធិការផ្ទាល់របស់សម្ដេចសង្ឃរាជនៅ *កូអ៊ា* (Goa ) ដែលជារាជធានីរបស់ពួកប៉កទុយកាល់ នៅក្នុងតំបន់ប្រទេសឥណ្ឌាដែលពួកវាកាន់កាប់ ។ លោកម្ចាស់បានជ្រាបរួចហើយ ថាពួកប៉កទុយកាល់ចង់ប្រើកំលាំងទ័ពដើម្បីត្រួតត្រាលើទ្វីបនេះ ។ ដោយសម្ដេចសង្ឃរាជ *កូអ៊ា* នេះ ក៏មានឋានៈ ជាឧបរាជប៉កទុយកាល់ថែមទៀតនោះ ឯកសារទាំងអស់ត្រូវឆ្លងកាត់ដៃ របស់លេខាធិការផ្ទាល់នេះ ។ ប៉ុន្មានឆ្នាំក្រោយមក បុរសនេះក៏ទទួលបានកូនសៀវភៅសំងាត់របស់ពួកវាមួយចំនួនដែលដូចជាផែនទីមួយដែរនោះ ហើយក៏លួចចំលងវាទុក ។ ពតិមានទាំងនេះ បើកការសំងាត់នៃច្រកសមុទ្រ *ម៉ាសេឡង់* ពន្យល់ពីរបៀបវាងតាមជ្រោយនៃក្ដីសង្ឃឹមល្អ ប្រាប់ពីបាតសមុទ្រ និងថ្មប៉ប្រះទឹកពីម៉ាកាវមកជប៉ុននេះ ។ កូនសៀវភៅដែលខ្ញុំមាន និយាយពីច្រកសមុទ្រ *ម៉ាសេឡង់*។ មុនពេលដែលវាបាត់ពីក្នុងសំពៅខ្ញុំនោះ ខ្ញុំទុកវាជាមួយក្រដាសផ្សេងៗរបស់ខ្ញុំនោះឯង ។ កូនសៀវភៅនេះ គឺដូចជាព្រលឹងរបស់ខ្ញុំតែម្ដង ហើយវាក៏អាចមានតំលៃយ៉ាងធំធេងដែរសំរាប់លោកម្ចាស់ *តូរ៉ាណាកា* ។

- លោកម្ចាស់ខ្ញុំបានមានប្រសាសន៍ថា លោកបានចេញបញ្ជាអោយគេស៊ើបសួររកហើយ ។ សូមលោកនិយាយបន្តទៅទៀតចុះ ។

- នៅពេលដែល *ស៊ុយដៃហូរ* ត្រលប់ទៅហូឡង់វិញ វាបានលក់កូនសៀវភៅទាំងនោះទៅពួកឈ្មួញនៃក្រុមហ៊ុនបូព៌ាឥណ្ឌា ដែលជាក្រុមហ៊ុនទទួលផ្ដាច់មុខក្នុងសង្វែងស្រាវជ្រាវមជ្ឈិមបូព៌ានោះ ។

*ម៉ារីកូ* សំលឹងមើល *ប្លាក់ថន* ដោយក្រសែភ្នែកត្រជាក់ស្រេប ។

- មនុស្សនេះគឺជាចោរបុរសស៊ីឈ្នួលរឺ ?



www.budinst.gov.kh www.elibraryofcambodia.org

- ជាការពិត គឺគេបានទទួលលុយចំពោះផែនទីមែន ។ នេះគឺជាទំលាប់របស់ពួកគេ ជារបៀបដែលគេផ្តល់រង្វាន់ ។ គឺគេមិនអោយឋានៈ វីជីនោះទេ គឺតែលុយមួយមុខគត់ ។ ហូឡង់ គឺជាសាធារណរដ្ឋ ។ អ្នកស្រីក៏ដឹងហើយថា ប្រទេសរបស់ខ្ញុំ ហើយនិងប្រទេសហូឡង់ ដែលជាសម្ព័ន្ធមិត្តនឹងគ្នានោះ កំពុងច្បាំងរាប់ឆ្នាំមកហើយនឹងប្រទេសអេស្ប៉ាញ និង ប៉ុកទុយកាល់ ។ អ្នកស្រីច្បាស់ជាយល់ហើយថា នៅក្នុងសង្គ្រាមគឺជារឿងងាប់រស់តែម្តង ដែលត្រូវរកអោយឃើញការណ៍សំងាត់របស់សត្រូវនោះ ។

ម៉ារីកូ ងាកខ្លួន ហើយក៏បកសំដីរបស់ *ប្លាក់ថន* យ៉ាងយូរ ។

- លោកម្ចាស់ខ្ញុំ សួរថា ហេតុអ្វីបានជាគណៈសង្ឃនោះយកសត្រូវមកធ្វើការជាមួយខ្លួនអីចឹង ?

- *ពីរ៉េ* និយាយថា គណៈសង្ឃដែលជា *យេស៊ូត* នេះ យកចិត្តទុកដាក់តែពីរឿងជួញដូរតែប៉ុណ្ណោះ ។ *ពីរ៉េ* ជាអ្នកជួយធ្វើអោយចំនួលពួកនេះកើនមួយជាពីរ ដោយហេតុនេះហើយទើបពួកនោះ " ថ្នាក់ថ្នម " គេណាស់ ។ *ពីរ៉េ* គឺជាឈ្មួញម្នាក់ដ៏ឆ្លាត ហើយម្យ៉ាងទៀតនៅក្នុងរឿងជួញដូរនេះ ពួកហូឡង់ពូកែជាងពួកប៉ុកទុយកាល់ឆ្ងាយណាស់ ។ ដោយហេតុនេះហើយទើបគេមិនសូវតឹងតែងជាមួយគាត់ទេ ។ នៅមានរឿងមួយទៀតដែលខ្ញុំចង់ប្រាប់ គឺថា ពួកមនុស្សដែលមានភ្នែកខៀវ និងសក់ទង់ដែង ដូចពួកអាឡឺម៉ង់ និងពួកអឺរ៉ុបផ្សេងទៀត គឺជាកាតូលិច................

*ប្លាក់ថន* រង់ចាំ *ម៉ារីកូ* បកប្រែចប់ហើយ ទើបពោលបន្ថែមយ៉ាងប្រយ័ត្នប្រយែង :

- *ពីរ៉េ ស៊ុយដែហ្វូរ* គឺជាមេចារកម្មរបស់ហូឡង់នៅអាស៊ី ។ ជាយុទ្ធជនម្នាក់នៃប្រទេសហូឡង់ ។ គាត់បានចាត់តាំងគ្នាគាត់មួយចំនួនអោយដើរតាមសំពៅ ប៉ុកទុយកាល់ ។ សូមអ្នកស្រីជំរាបលោកម្ចាស់ *តូរ៉ាណាកា* ផងថាបើគ្មានការជួញដូរជាមួយជប៉ុនទេ ចក្រភពប៉ុកទុយកាល់ នៅឥណ្ឌារស់មិនបានយូរទេ ។

ក្នុងពេលដែល *ម៉ារីកូ* និយាយភ្លែករបស់ *តូរ៉ាណាកា* នៅតែសំលឹងជាប់ទៅលើផែនទី ។ ពេលនាងនិយាយចប់ ក៏លោកគ្មានប្រតិកម្មអ្វីដែរ ។ *ប្លាក់ថន* ជញ្ជឹងសួរនៅក្នុងចិត្តថា តើ *ម៉ារីកូ*



www.budinst.gov.kh www.elibraryofcambodia.org

បានបកទាំងស្រុងនូវអ្វីដែលគេបាននិយាយ រឺក៏អត់ទេ ។

*ម៉ារីកូ* ងាកមកនិយាយជាមួយ *ភ្ញាក់ផ្អើន* វិញម្តង :

- លោកម្ចាស់ខ្ញុំចង់បានផែនទីពិភពលោក ជាលំអិតមួយនៅលើក្រដាស ។ កាន់តែឆាប់កាន់តែល្អ ។ សូមកុំភ្លេចបញ្ជាក់បន្ទាយរបស់ពួកប៉កទុយកាល់ទាំងអស់ ហើយនិងចំនួនពួក *វ៉ារីន* ដែលមាននៅតាមបន្ទាយទាំងនោះផង ។ លោកម្ចាស់មានប្រសាសន៍ថា សូមលោកបន្តនិយាយទៀតចុះ ។

*ភ្ញាក់ផ្អើន* បានដឹងថា ខ្លួនគេបានបោះជំហានយ៉ាងវែងទៅមុខហើយ ។ ប៉ុន្តែនៅពេលដែលឃើញកុមារនោះស្ងាប គេក៏សំរេចដូរសាច់រឿងនិយាយម្តង តែដោយផ្តោតទៅលើគោលដៅតែមួយដដែល :

- ពិភពលោកយើងនេះ មិនមែនសុទ្ធតែដូចយើងស្មាននោះទេ ។ ឧទាហរណ៍នៅខាងត្បូងនៃខ្សែបន្ទាត់ ដែលយើងហៅថា អេក្វាទ័រនេះ រដូវប្តូរគ្នាទាំងស្រុង ។ បើយើងនៅក្នុងរដូវក្តៅ ពួកគេខាងនោះ មានរដូវរងារទៅវិញ ។

- ម៉េចបានជាវាអ៊ីចឹង ?

- ខ្ញុំមិនដឹងដែរ តែនេះគឺជាការពិត ។ អីលូវនេះផ្លូវសំរាប់មកជប៉ុន គឺអាចមកតាមច្រកភាគខាងត្បូងទាំងពីរណើង ។ ពួកយើងដែលជាអង់គ្លេសនោះបានស្វាករុករកផ្លូវឧត្តរទិសមួយទៀត គឺថា រឺមួយរកផ្លូវភាគអីសាន តំបន់ ស៊ីបេរី រឺមួយផ្នែកពាយ័ព្យ នៃទ្វីបអាមេរិច ។ ខ្ញុំបានឡើងទៅភាគឧត្តរយ៉ាងឆ្ងាយ ។ នៅកន្លែងនោះដីទាំងមូលមានតែទឹកកក និងព្រិលជាប់ហើយត្រជាក់ទាល់តែមែនទែន គឺថា បើសិនជាយើងមិនពាក់ស្រោមដៃធ្វើពីរោមសត្វទេ ដៃយើងកកមួយរំពេច ។ មនុស្សដែលរស់នៅទីនោះ ត្រូវគេអោយឈ្មោះថាជាពួក *ឡាប៉ុង* ។ ពួកគេស្លៀកខោអាវធ្វើពីរោមសត្វ ។ ពួកប្រុសៗដើរបរបាញ់ ហើយកិច្ចការផ្សេងៗទៀតស្រីៗជាអ្នកទទួលរ៉ាប់រងទាំងអស់ ។ មួយផ្នែកនៃកិច្ចការស្រីៗ គឺដេរខោអាវនេះឯង ។ ចង់ធ្វើកិច្ចការនេះ ពួកគេត្រូវខាំបន្ទន់ស្បែកសិនទើបដេរវាបាន ។

*ម៉ារីកូ* លាន់សំនើចឡើង ។



www.budinst.gov.kh www.elibraryofcambodia.org

*ក្វាក់ថន* ញញឹមតបទៅរកនាង នៅក្នុងទំនុកចិត្តមួយមាំទាំជាងមុន ។

- នេះគឺជាការពិតណាអ្នកស្រី ។ នេះគឺ *ហុងកូ* !

- *សូវើរ៉ា ហុងកូ តេស៊ូកា* ?

ស្អីទៅដែលជាការពិតនោះ ? នេះគឺជាសំនួរវន្ទាន់របស់លោក *ត្វូរ៉ាណាកា* ។

និយាយបណ្តើរ សើចបណ្តើរ *ម៉ារីកូ* ក៏បកប្រែសំដីរបស់ *ក្វាក់ថន* ។ ទាំងអស់គ្នាចាប់ផ្តើមសើចក្អាកក្អាយផងដែរ ។ *ក្វាក់ថន* និយាយបន្ត :

- ខ្ញុំបានរស់នៅជាមួយពួកនេះ អស់ជិតមួយឆ្នាំ ។ កាលនោះសំពៅពួកយើងជាប់ក្នុងទឹកកក ហើយត្រូវរង់ចាំពេលវារលាយទៅវិញ ។ អ្នកស្រុកកន្លែងនោះហូបត្រី ភេ ហើយជួនកាលខ្លាឃ្មុំស និងត្រីបាឡែន។ ហើយគេហូបនៅ ។ ម្ហូបដែលគេចាត់ទុកថា ប្រណីតបំផុត គឺសាច់បីជាន់នៅរបស់ត្រីបាឡែន ។

- *អាន់ជីន-សាន* ចេះតែនិយាយហើយ !

- ពិតណាស់អ្នកស្រី ។ ពួកគេរស់នៅក្នុងផ្ទះតូច១ មូល១ ធ្វើពីដុំព្រិលទាំងអស់ ហើយពួកគេមិនដែលមុជទឹកទេ ។

*ម៉ារីកូ* ភ្ញាក់ដូចគេចោល :

- ថាម៉េច ? មិនដែលមុជទឹកសោះ ?

*ក្វាក់ថន* ងក់ក្បាល ហើយសំរេចថាមិនចាំបាច់ប្រាប់ *ម៉ារីកូ* ថា ការមុជទឹកគឺការកំរមួយកំរជាងនៅប៉ែកទុយកាល់ និងអេស្ប៉ាញ ដែលជាប្រទេសក្តៅទៅទៀត ។

នៅពេលដែល *ម៉ារីកូ* បកប្រែហើយ *ត្វូរ៉ាណាកា* គ្រវីក្បាល ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា នេះគឺជាការបំផ្លើសពេកហើយ ។ គ្មានអ្នកណារស់នៅបានដោយគ្មានមុជទឹកនោះឡើយ ។ ទោះជាប្រជាជននោះ គ្មានអារ្យធម៌បន្តិចបន្តួចណាក៏ដោយ ។

- នេះគឺជាការពិតណា ។ *ហុងកូ* !

*ក្វាក់ថន* ឆ្លើយតបយ៉ាងទឹងទរ បន្ទាប់មកទៀតគេលើកដៃឡើងស្បថថា :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំសូមស្បថនៅចំពោះមុខព្រះ និងចំពោះមុខព្រលឹងរបស់ខ្ញុំ ខ្ញុំសូមស្បថថា ទាំងអស់នេះគឺជាការពិត ។

*ម៉ារីកូ* សំលឹងមើល *ភ្លាក់ថុន* យ៉ាងស្មៀមស្ងាត់មួយសន្ទុះ ទើបសួរទៀត :

- ទាំងអស់អ្វី ?

- ទាំងអស់ហ្នឹង ។ លោកម្ចាស់ *តូរ៉ាណាកា*ចង់បានការពិត តើខ្ញុំចាំបាច់អីទៅកុហកនោះ ? ជីវិតរបស់ខ្ញុំក្នុងកណ្តាប់ដៃរបស់លោក ។ ចង់ដឹងថាពិតរឺមិនពិតស្រួលទេ..........អូ ! ទេ....... និយាយតាមត្រង់ទៅចង់ដឹងថា ពិតរឺមិនពិតនោះ មិនមែនជាការងាយទេ ។ អ្នកស្រីត្រូវអញ្ជើញទៅដល់កន្លែងទាំងនោះ ហើយមើលអោយឃើញនឹងភ្នែករបស់អ្នកស្រីផ្ទាល់ ។ ហើយពូកបិកទុយកាល់ និងពួកអេស្ប៉ាញ ដែលជាសត្រូវនឹងខ្ញុំច្បាស់ជាមិនគាំទ្រខ្ញុំទេ ។ ប៉ុន្តែលោកម្ចាស់ *តូរ៉ាណាកា* ចង់បានការពិត ហេតុនេះលោកអាចទុកចិត្តថា អ្វីៗដែលខ្ញុំបានជំរាបលោកនេះគឺឥតមានកុហកលោកឡើយ ។

*ម៉ារីកូ* សញ្ជឹងគិតមួយស្របក់រួចទើបចាប់ផ្តើមបកប្រែយ៉ាងល្អិតល្អន់ នូវសំដីរបស់ *ភ្លាក់ថុន* ។ រួចរាល់ហើយ ទើបនាងបន្លឺបន្តទៀត :

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា មិនគួរអោយជឿសោះដែលថាមនុស្សអាចរស់បានដោយមិនមុជទឹកនោះ ។

- ពិតហើយ តែកន្លែងនោះ គឺជាតំបន់ត្រជាក់ ។ ទំលាប់គេ គឺខុសពីអ្នកស្រី រឺពី ខ្ញុំ ។ ឧទាហរណ៍ នៅស្រុកខ្ញុំទាំងអស់គ្នាជឿថា ការមុជទឹកគឺធ្វើអោយប៉ះពាល់ដល់សុខភាព ។ ជីដូនខ្ញុំឈ្មោះ *ប្រាន់នី យ៉ាកូបា* ធ្លាប់ប្រដៅថា " គេមុជទឹកម្តងនៅពេលកើត និងម្តងទៀតពេលទៅបរលោកតែប៉ុណ្ណោះ " ។

- ដូចជាពិបាកជឿមែនតែម្តង ។

-ទំលាប់មួយចំនួនរបស់អ្នកស្រុកនេះ ក៏ពិបាកនឹងជឿណាស់ដែរ ។ ហើយជាការពិតណាស់ដែលថា ខ្ញុំបានមកដល់ស្រុកនេះតែមួយរយៈពេលដ៏ខ្លីប៉ុណ្ណោះ ប៉ុន្តែខ្ញុំបានមុជទឹកច្រើនជាងប៉ុន្មានឆ្នាំមុនទៅទៀត ។ តែខ្ញុំទទួលស្គាល់ថា ខ្ញុំមានអារម្មណ៍ស្រួលបួលជាងមុន ហើយខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

លែងគិតថា ការមុជទឹកនាំអោយមានគ្រោះថ្នាក់ទៀតហើយ ។ អ៊ីចឹងហើយខ្ញុំបានច់
នៅពេលដែលបានមកដល់ទីនេះ មែនទេ ?

ក្រោយពីស្ងៀមបន្តិចមក *ម៉ារីកូ* ក៏ឆ្លើយថា " ចាស់ "ហើយក៏បកប្រែទៅ *រ្*
*គីរី* បន្ទឹទ្បើង :

- វាដូចជាចំលែកអស្ចារ្យមែន ។ មែនទេ ?

*តូរ៉ាណាកា* សួរទៅ *ម៉ារីកូ* វិញ :

- តើនាងយល់យ៉ាងណាដែរ ពីមនុស្សនេះ ?

- ខ្ញុំគិតថា មនុស្សនេះនិយាយការពិតហើយលោកម្ចាស់ រឺថា ខ្ញុំជឿថា
និយាយការពិត ។ មើលទៅប្រហែលជាមនុស្សនេះមានតំលៃខ្ពស់សំរាប់លោកម្ចាស់
ពួកយើងមានការយល់ដឹងតែបន្តិចបន្តួចប៉ុណ្ណោះពីពិភពក្រៅ ។ ប៉ុន្តែចំពោះលោកម្ចា
មានតំលៃរឺទេនោះ ខ្ញុំមិនដឹងដែរ ។ មើលទៅមនុស្សនេះ ដូចទើបចុះមកពីលើមេឃ
មកពីបាតសមុទ្រអ៊ីចឹង ។ បើសិនមនុស្សនេះជាសត្រូវ នឹងពួកប៉កទុយកាល់ ហើយនិ
មែននោះ និងបើសិនជាមនុស្សនេះនិយាយត្រង់មែន ប្រហែលគេមានផលប្រយោ
ណាស់សំរាប់លោកម្ចាស់ ចាស់ !

*គីរីសន្ទូរតាម* :

- ខ្ញុំឯកភាពហើយ ។

- តើក្មួយយល់យ៉ាងម៉េចដែរ *យ៉ែបម៉ុន-សាម៉ា* ?

- ខ្ញុំអ្នីពូ ? ខ្ញុំគិតថាមនុស្សនេះ មានរូបរាងអាក្រក់ណាស់ ហើយខ្ញុំមិនចូលចិ
សោះ អាសក់ពណ៌លឿង និងភ្នែកឆ្មារបស់វានេះ ។ វាមិនដូចមនុស្សសោះទេ ។ ខ្ញុំស
ណាស់ដែលខ្ញុំមិនបានកើតមកជាអ្នកចុងស្រុកដូចវា តែកើតជាសាមូរ៉ៃដូចឪពុកខ្ញុំនេះ
ទៅហែលទឹកទៀតអ្វី លោកពូ ?

- ចាំស្អែក *យ៉ែបម៉ុន* !

*តូរ៉ាណាកា* ឆ្លើយតបទាំងមួម៉ៅ ដោយលោកមិនអាចនិយាយឆ្លើយឆ្លងដោយ



www.budinst.gov.kh www.elibraryofcambodia.org

មួយ *ភ្លាក់ថន* បាន ។

នៅពេលដែលពួកគេកំពុងជជែកគ្នានោះ *ភ្លាក់ថន* សំរេចថា ពេលរបស់គេមកដល់ហើយ ។ នៅពេលនោះ *ម៉ារីកូ* ងាកមករកគេម្តងទៀត :

- លោកម្ចាស់ខ្ញុំ សួរថា ហេតុអីបានជាលោកទៅខាងឧត្តរនោះ ?

- ខ្ញុំគឺជាតែកុងសំពៅ ហើយពួកយើងស្វះស្វែងរុករកផ្លូវមួយទៀត តាមច្រកអីសាន ។ ខ្ញុំដឹងថា មានរឿងច្រើនណាស់ដែលខ្ញុំនិយាយទៅ ច្បាស់ជាអ្នកស្រីឃើញដូចជារឿងកំប្លុកកំប្លែងអីចឹង ..........

រួច *ភ្លាក់ថន* ក៏ចាប់ផ្តើមចូលសាច់រឿង :

- ឧទាហរណ៍ ដូចកាលពីចិតសិបឆ្នាំមុន ស្តេចអេស្ប៉ាញ និងប៉កទុយកាល់ បានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាផ្លូវការមួយ ដែលបែងចែកកម្មសិទ្ធិនៅឯពិភពថ្មី ហើយនិងពិភពដែលមិនទាន់រុករកឯទៀត រវាងក្សត្រទាំងពីរអង្គនេះ ។ ដោយប្រទេសនេះស្ថិតនៅក្នុងខ្សែកាត់ប៉កទុយកាល់នោះ ជាផ្លូវការប្រទេសនេះគឺជារបស់ ប៉កទុយកាល់ ។ មានន័យថា លោកម្ចាស់ *តូរ៉ាណាកា* អ្នកស្រី មនុស្សទាំងអស់ រួមទាំងវិមាន និងអ្វីៗទាំងអស់នៅលើទឹកដីនេះ គឺត្រូវបានប្រគល់ទៅអោយ ប៉កទុយកាល់ហើយ ។

- ទេ *អាន់ជីន-សាន* ។ អោយខ្ញុំសូមទោស ។ នេះគឺចំជាលេលាហើយ ។

- ខ្ញុំទទួលស្គាល់ថា ភាពក្រអឺតក្រទម របស់ពួកវាគឺពិតជាមិនអាចជឿបានមែន ។ តែនេះគឺជាការពិតណា ។

*ម៉ារីកូ* បកប្រែភ្លាមទៅ *តូរ៉ាណាកា* ។ ពេលចប់ហើយ *តូរ៉ាណាកា* ក៏ផ្ទុះសំណើចយ៉ាងក្អាកក្អាយ ។

-លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា លោកក៏អាចពុះចែកជាមួយព្រះចៅស្រុកចិនបានដែរមែនទេ ?

*ភ្លាក់ថន* តបដោយប្រុងប្រយ័ត្ន ព្រោះគេដឹងថាគេកំពុងដើរក្នុងទីកន្លែងគ្រោះថ្នាក់ហើយ :



www.budinst.gov.kh www.elibraryofcambodia.org

- សូមជំរាបលោកម្ចាស់ *គូរ៉ាណាកា* ផង ថារឿងនេះមិនដូចគ្នាទេ ។ នេះគឺជាសំនៅ នៅក្នុងឯកសារជាផ្លូវច្បាប់ ដែលផ្តល់អោយស្តេចទាំងពីរអង្គនេះ នូវសិទ្ធិប្រកាសយកទឹកដីមិន មែនកាតូលិចទាំងអស់ ដែលរកឃើញដោយពលរដ្ឋរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ គេមានសិទ្ធិ ផាត់ចោលរដ្ឋាភិបាលដែលមានស្រាប់ ហើយប្តូរជំនួសវិញ ដោយពួកកាតូលិចក៏បាន ។

ម្រាមដៃរបស់*ប្លាក់ថន* គូសនៅលើផែនទីនូវខ្សែបន្ទាត់មួយពីជើងទៅត្បូង ហើយដែល ពុះប្រទេសប្រេស៊ីលជាពីរ ហើយគេនិយាយបន្តទៅទៀត :

- អ្វី១ ដែលនៅខាងកើតនៃខ្សែបន្ទាត់នេះ គឺជារបស់ប្រទេសប៉កទុយកាល់ អ្វី១ ដែល នៅខាងលិច គឺជារបស់ប្រទេស អេស្ប៉ាញ ។ លោក*ប្រេដ្ឋូ កាប្រាល់* រកឃើញប្រទេស ប្រេស៊ីល នៅឆ្នាំ ១៥០០ អីចឹងហើយទើបអីលូវនេះប្រេស៊ីលជាកម្មសិទ្ធិរបស់ប៉កទុយកាល់ ហើយពួក ប៉កទុយកាល់ បានលុបបំបាត់ចោលនូវវប្បធម៌ម្ចាស់ស្រុក ហើយនិងមេដឹកនាំស្របច្បាប់របស់ពួក គេ ។ ប៉កទុយកាល់ អីលូវនេះក្លាយជាអ្នកមានអាស្រ័យដោយមាស និងរ៉ែ ដែលពួកគេយកពី ក្នុងអណ្តូងរ៉ែ និងដែលប្លន់ពីក្នុងវិហាររបស់អ្នកស្រុកនោះមក ។ ចំនែកមួយភាគទៀត នៃទ្វីបអា មេរិច ដែលរកឃើញក្រោយ១មកទៀតនោះ គឺជារបស់អេស្ប៉ាញ ហើយនៅពេលនេះ ដូច ជាមិចស៊ិច ប៉េរ៉ូ ហើយនិងស្ទើរតែភាគខាងត្បូងទាំង មូលនៃទ្វីបអាមេរិចនេះ ។ ពួកវាបានល្អួស បំបាត់ប្រជាជាតិ *អាំងកា* (Incas ) លុបវប្បធម៌ របស់គេ ហើយរាប់សែននាក់ត្រូវ ពួកវាចាប់ធ្វើទាសករ។ ពួក*កុងគីស្តាឌ័រ* មានកាំភ្លើងទំនើប១ ឯពួកអ្នកស្រុកគ្មានសោះ ។ ពួក បព្វជិតរមែងមកជាមួយពួក*កុងគីស្តាឌ័រ* ហើយមិនយូរមិនឆាប់ ពួកស្តេច១មួយចំនួន ក៏ចូល សាសនា ។ នៅពេលនោះពួកគេក៏ចាប់ប្រើការខ្វែងគ្នានេះ ។ ស្តេច នឹងស្តេចចាប់ទាស់គ្នា ហើយ នគរទាំងមូលនឹងត្រូវពួកគេលេបយកម្តងមួយ១ ។ អីលូវនេះ ប្រទេសអេស្ប៉ាញ គឺជាប្រទេស អ្នកមានបំផុតនៅក្នុងលោកនេះ អាស្រ័យដោយមាសពួក*អាំងកា* និងពួកមិចស៊ិចដែលពួកគេប្លន់ បាន ហើយបញ្ជូនទៅស្រុកនោះ ។

*ម៉ារីកូ* បានប្រែទៅជាមាំទាវិញម្តង ។ នាងបានយល់យ៉ាងច្បាស់នូវមេរៀន ដែល*ប្លាក់ ថន*ចង់បង្រៀននេះ ។ *គូរ៉ាណាកា* ក៏យល់ដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកមសន័ថា នេះគឺពិតជាការដំដែកធ្លាដោយឥតបានផលមែន។ ហេតុអ្វីបានជាពួកនោះបានប្រកាសសិទ្ធិបែបនេះ ?

*ប្លាក់ថន* ឆ្លើយតបវិញយ៉ាងម៉ឺងម៉ាត់ :

- មិនមែនពួកគេនោះទេ ។ គឺស្តេច*ប៉ាប* ដែលផ្តល់សិទ្ធិនេះដល់ពួកគេជាថ្នូរនឹងការផ្សព្វផ្សាយគ្រិស្តសាសនា ។

*ម៉ារីកូ* ឧទានឡើង :

- ខ្ញុំមិនជឿទេ !

- សូមអ្នកស្រី បកសំដីដែលខ្ញុំនិយាយអំបាញ់មិញនេះទៅ ។ នេះគឺ *ហុងកូ* ។

*ម៉ារីកូ* ទទួលធ្វើតាមដោយបង្ហាញចេញយ៉ាងច្បាស់នូវភាពច្របូកច្របល់នៅក្នុងចិត្តរបស់នាង ។ រួចនាង ក៏ងាកមករក*ប្លាក់ថន*វិញ :

- លោកម្ចាស់ខ្ញុំ..........លោកម្ចាស់ខ្ញុំ............. មានប្រសាសន៍ថា លោកមានបំណងចាក់ចុចអោយលោកម្ចាស់ខ្ញុំ មានទំនាស់ជាមួយសត្រូវ របស់លោកតែប៉ុណ្ណោះ ។ ឯណាទៅដែលជាការពិតនោះ ? សូមលោកយកជីវិតលោកជាបន្ទាល់ណា ។

*ប្លាក់ថន* ចាប់ផ្តើមនិយាយបណ្តើរ នៅក្នុងពោះអរគុណបណ្តើរដល់តា *អាល់បានកាក់ឌុក* ដែលបានញាត់ហេតុការណ៍យ៉ាងច្រើនទៅក្នុងក្បាលរបស់គេ នៅពេលដែលគេនៅជាយុវជនហើយនិងបព្វជិត *ដូមិញកូ* ដែលបាននិយាយប្រាប់គេពីមោទនភាព និងផ្នត់គំនិតរបស់ជនជាតិជប៉ុន :

- សម្តេច*ប៉ាប អាឡិចសង់* ទី៦ បានចាប់ផ្តើមគូសខ្សែបែងចែកពិភពលោកបង្គស់នៅ ឆ្នាំ ១៤៩៣ ។ នៅឆ្នាំ ១៥០៦ សម្តេច*ប៉ាប ជូល្យូស* ទី២ បានប្រទានសច្ចាប័នលើវិសោធនកម្មនៅក្នុងសន្ធិសញ្ញា *តូដេស៊ីឡាស* ដែលចុះហត្ថលេខាដោយប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយកាល់នៅឆ្នាំ១៤៩៤ ហើយដែលកែខ្សែបែងចែកនោះបន្តិចបន្តួច ។ សម្តេច*ប៉ាប ក្លេម៉ង់* ទី៧ បានប្រទានសច្ចាប័នលើសន្ធិសញ្ញា *សារ៉ាកូស* ឆ្នាំ១៥២៩ ដែលគូសខ្សែថ្មីមួយទៀត ។ នៅកន្លែងនេះ......



www.budinst.gov.kh www.elibraryofcambodia.org

ម្រាមដៃរបស់ *ភ្លាក់ថន* គូសខ្សែរយៈបណ្ដោយមួយ ដែលកាត់ជាយខាងត្បូង នៃប្រទេសជប៉ុន :

- ខ្សែបន្ទាត់នេះ បានផ្ដល់ទៅអោយប្រទេសប៉កទុយកាល់ នូវសិទ្ធិផ្ដាច់មុខ ទៅលើប្រទេសជប៉ុន និងប្រទេសទាំងប៉ុន្មាននោះទៀត គឺរាប់ពីប្រទេសចិន ជប៉ុន រហូតដល់ អាព្រិចដូចដែលខ្ញុំបានជំរាបអំបាញ់មិញអ៊ីចឹង ។ គឺជាប្រទេសដែលអាចធ្វើអាជីវកម្មផ្ដាច់មុខតាមគ្រប់មធ្យោបាយទាំងអស់ដែលមាន ជាថ្នូរនឹងការពង្វាតនិកាយកាតូលិច ។

រួច *ភ្លាក់ថន* ឈប់ជាថ្មីម្ដងទៀត ដើម្បីទុកឱកាសអោយ *ម៉ារីកូ* បកប្រែ ។ *ម៉ារីកូ* ពេលនេះអេះអុញដោយអារម្មណ៏ច្របូកច្របល់ ហើយ *ភ្លាក់ថន* អាចដឹងបានថា *ភូរ៉ាណាកា* ចាប់ផ្ដើមមួម៉ៅឡើងហើយ ដោយលោកត្រូវរង់ចាំបំនកប្រែរបស់ *ម៉ារីកូ* ។

*ម៉ារីកូ* ខំមាត់សង្កត់ចិត្តបកប្រែនូវអ្វី ដែល *ភ្លាក់ថន* និយាយ ។ រួចនាងបន្តស្ដាប់ *ភ្លាក់ថន* បន្តទៀត ដោយសែនស្អប់នូវអ្វីដែលនាងបានលឺនៅពេលនេះ ។ តើពិតជាអ៊ីចឹងមែនរឺ ? នាងដណ្ដឹងសួរនៅក្នុងចិត្ត ។ តើសម្ដេចសង្ឃមានបន្ទូលយ៉ាងណឹងមែនរឺអី ? ប្រគល់ប្រទេសយើងអោយប៉កទុយកាល់ ? នេះគឺជាការកុហកទេ ។ តែថាកុហកម៉េចនឹងកើតបើតែកុងនេះស្បថដោយយកព្រះយេស៊ូជាបន្ទាល់ដែរនោះ ។

នាងចាប់ផ្ដើមបកបន្តនៅពេល *ភ្លាក់ថន* និយាយចប់ :

- តែកុងនិយាយថា នៅ.........នៅ.......នៅពេលដែលសេចក្ដីសំរេចទាំងនេះត្រូវបានប្រកាន់យក ដោយគណៈសង្ឃនោះពិភពរបស់ពួកគេ រួមទាំងប្រទេសរបស់ *អាន់ជីន-សាន* ផងសុទ្ធតែជាប្រទេសកាន់គ្រិស្តសាសនា និកាយកាតូលិច ។ ពេលនោះមិនទាន់មានចែកនិកាយនៅឡើយទេ ។ អ៊ីចឹងហើយ ទើប.........ទើប.........ទើបសេចក្ដីសំរេច របស់សម្ដេចប៉ាបនេះ មានអានុភាពទៅលើ........លើ.......លើគ្រប់ប្រទេសជាតិទាំងអស់ ។ តែទោះជាយ៉ាងនេះក្ដី ក៏តែកុងនេះនិយាយថា ថ្វីត្បិតតែ ប៉កទុយកាល់ មានសិទ្ធិផ្ដាច់មុខ ក្នុងការធ្វើអាជីវកម្មលើប្រទេសជប៉ុនក្ដី ក៏ពួកអេស្ប៉ាញ និង ប៉កទុយកាល់ ឈ្លោះគ្នាមិនចេះចប់ដែរនៅលើបញ្ហាកម្មសិទ្ធិនេះ ពីព្រោះតែជំនួញដ៏ធំរវាងប្រទេសយើង និងប្រទេសចិន ។



www.budinst.gov.kh www.elibraryofcambodia.org

- តើនាងយល់យ៉ាងម៉េចដែរ *គីរី-សាន* ?

*តូរ៉ាណាកា* បែរទៅសួរ *គីរី-សាន* ? នៅក្នុងអារម្មណ៍របស់លោក ដំណឹងនេះគឺជាទីភ្ញាក់ផ្អើលបំផុត ហើយក៏ដូចជាចំពោះអ្នកឯទៀតដែលនៅទីនេះដែរ ។ មានតែកុមារនោះទេដែលលេងផ្លិតបែបវាហី ។

*គីរី* ឆ្លើយតប :

- មនុស្សនេះជឿថា ខ្លួននិយាយការណ៍ពិត ។ នេះបើតាមខ្ញុំមើល ។ តែធ្វើម៉េចថារឿងទាំងអស់នេះ រឺមួយភាគនៃរឿងនេះ ជាការណ៍ពិតនោះ ?

- តើយើងបញ្ជាក់រឿងនេះបែបម៉េច *ម៉ារីកូ-សាន* ?

*តូរ៉ាណាកា* សួរទៅ *ម៉ារីកូ* ។ លោកក៏មានការភ្ញាក់ផ្អើលដូច *ម៉ារីកូ*ដែរ ។ ប៉ុន្តែទន្ទឹមនោះលោកក៏រីករាយនៅក្នុងចិត្តណាស់ដែរ ចំពោះប្រការដែលលោកបានសំរេចចិត្តជ្រើសរើសនាងអោយមកបកប្រែនៅពេលនេះ ។

*ម៉ារីកូ* តប :

- បើសិនខ្ញុំជាលោកម្ចាស់វិញ ខ្ញុំនឹងសួរបញ្ជាក់ព្រះតេជគុណ ឈូតូ-សាន ហើយ១ខ្ញុំនឹងបញ្ជូនមនុស្សម្នាក់ ដែលជាអណ្តាប់ជាទីទុកចិត្តអោយចេញទៅស្រុកក្រៅជាមួយ *អាន់ជីន-សាន* ដើម្បីមើលអោយច្បាស់ថា តើពិតរឺមិនពិត ។

*គីរី*សន្ទនាតាម :

- ទោះជាបព្វជិតនោះមិនគាំទ្រសំដីដែល *អាន់ជីន-សាន* និយាយក្តី ក៏មិនមានន័យជាកុហកដែរ មែនទេ ?

នៅក្នុងចិត្ត *គីរី* សែនសប្បាយចិត្តដោយនាងជាអ្នកស្នើអោយ *តូរ៉ាណាកា* យក *ម៉ារីកូ* ជាអ្នកបកប្រែជំនួស *ឈូតូ-សាន* នោះ ។ នាងដឹងថា *ម៉ារីកូ* ជាមនុស្សគួរទុកចិត្តបាន ហើយម្យ៉ាងទៀតនោះ ពេលណាដែលនាងស្បថហើយ នាងពិតជាមិននិយាយអ្វីទាំងអស់ ទោះជាពួកសង្ឃកាតូលិចឈ្លេចសួរយ៉ាងណាក៏ដោយ ។ ពួកឧត្យាតនេះ ដឹងកាន់តែតិច កាន់តែល្អ -*គីរី* គិតនៅក្នុងចិត្ត ។ ហើយបុរសចុងស្រុកនេះ ពិតជាចេះដឹងច្រើនមែន ។



www.budinst.gov.kh www.elibraryofcambodia.org

*គីរី* ចោលភ្នែកទៅឃើញកុមារនោះស្ងាបម្តងទៀត ។ ចំនុចនេះធ្វើអោយអ្នកស្រីសប្បាយចិត្តណាស់ ។ ក្មេងនេះ ដឹងកាន់តែតិច កាន់តែល្អ ។ រួចអ្នកស្រីបន្ថឺឡើង :

- ហេតុអ្វី មិនប្រើគេទៅហៅប្រធានសង្ឃគ្រិស្តសាសនា ហើយសួរគេពីហេតុការណ៍ទាំងអស់នេះសាកមើល ? ចាំមើលថាតើលោកនោះឆ្លើយថាម៉េច ? យ៉ាងម៉េចៗ មើលតែទឹកមុខពួកវាដឹងភ្លាមហើយ ។

*តូរ៉ាណាកា* ងក់ក្បាល ប៉ុន្តែ ក្រសែភ្នែករបស់លោកនៅផ្តោតជាប់លើ *ម៉ារីកូ* :

- នាងស្គាល់ពួកចុងស្រុក ភាគខាងត្បូងច្បាស់ណាស់ *ម៉ារីកូ-សាន* ។ តើដីការបស់សម្តេចថាបត្រូវពួកវាទទួលគោរពតាមមែនទេ ?

- ពិតណាស់ហើយលោកម្ចាស់ ។

- ដីការបស់សម្តេច *ថាប* ត្រូវគេចាត់ទុកដូចបន្ទូលរបស់ព្រះមែនទេ ?

- ចាស់ ។

- តើពួកគ្រិស្តសាសនិកកាតូលិច គោរពតាមសំដីរបស់សម្តេច *ថាប* មែនទេ ?

- ចាស់ ។

- ពួកគ្រិស្តសាសនិកជប៉ុនយើង ក៏អីចឹងដែរអ្ហី ?

- ខ្ញុំគិតថាអីចឹងដែរ ចាស់ ។

- នាង ក៏អីចឹងដែរ មែនទេ ?

ភ្នែករបស់ *ម៉ារីកូ* ប្រែជារឹងមុត :

- ចាស់លោកម្ចាស់ ។ នេះបើមានដីកាផ្ទាល់ពីសម្តេច *ថាប* មកខ្ញុំ ។ ប៉ុន្តែបើគ្មានបញ្ហានេះទេ ខ្ញុំស្តាប់តែលោកម្ចាស់ មេត្រកូលគ្រួសារខ្ញុំ ហើយនឹងប្តីខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំជាជនជាតិជប៉ុន ។ ពិតហើយខ្ញុំជាគ្រិស្តសាសនិក ប៉ុន្តែដំបូងបង្អស់ ខ្ញុំគឺជាសាមូរ៉ៃ ។

- អីចឹងល្អហើយ ដែលសម្តេច *ថាប* ស្ថិតនៅនោះនៅឆ្ងាយពីឆ្នេរសមុទ្រ របស់យើង ។ *តូរ៉ាណាកា* សញ្ជឹងគិតមួយសន្ទុះទើបសំរេចថា តើត្រូវដោះស្រាយរឿងបុរសចុងស្រុកនេះបែបណា ។



www.budinst.gov.kh www.elibraryofcambodia.org

- ប្រាប់ទៅវាផងថា.............

សំដីរបស់លោកនៅតាំងទ្រឹងកណ្តាលឃ្លា ។ ភ្នែករបស់មនុស្សទាំងអស់នៅទីនោះ បែរ បោលទៅរកស្ត្រីចំនាស់ម្នាក់ កំពុងតែដើរសំដៅមករកពួកគេ ។ ស្ត្រីចំនាស់នោះ មានសំលៀក បំពាក់ជាថ្ងូនជី ។ សាមូរ៉ៃអារវពលិប្រផេះបួននាក់អមដំណើរស្ត្រីនោះ ។ ពួកគេឈប់នៅពីចំងាយ ហើយស្ត្រីនោះបន្តដំណើរចូលមកតែម្នាក់ឯង ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ១៧

ទាំងអស់គ្នាលំអោនខ្លួនគោរពយ៉ាងទាប ។ *តូរ៉ាណាកា* កត់សំគាល់ថា បុរសចុងស្រុកនោះបានធ្វើតាមលោកទាំងស្រុង ហើយក៏មិនងើបឈរ វិតាមសំលឹងភ្នែរជាទំលាប់របស់ពួកចុងស្រុកទាំងអស់គ្នា លើកលែងតែបព្វជិត *ឈូតូ-សាន* នោះឡើយ ។ បុរសតែកុងនេះ បៀមសូត្របានរប៉ះមែន -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ ខួរក្បាលរបស់លោកនៅលាន់រណ្តំ ដោយអ្វីដែលលោកទើបបានលឺអំបាញ់មិញនេះ ។ សំនួររាប់ពាន់ រាប់ម៉ឺនបានហ៊ុមព័ទ្ធលោក ប៉ុន្តែលោកបានរុញច្រានវាទៅម្ខាងនៅពេលនេះ ដើម្បីផ្តោតលើគ្រោះថ្នាក់ចំពោះមុខវិញ ។

*គិរី* ប្រញាប់ប្រញាល់រុញម៉ក់របស់ខ្លួន ទៅជូនស្ត្រីចំនាស់នេះ ហើយនិងជួយអោយគាត់ដាក់បង្អួយចុះ ។ រួចរាល់ហើយ លោកស្រីគ្រលប់ទៅលុតជង្គង់នៅពីក្រោយយ៉ាងស្ងៀមស្ងាត់ ។

- អរគុណណាស់ *គិរីឈូបូ-សាន* !

ស្ត្រីចំនាស់បន្លឺសំដីបណ្តើរលំអោនខ្លួនគោរពតបបណ្តើរ ។ ស្ត្រីនេះមាននាមថា *យ៉ូដូកូ* ។ លោកជំទាវ គឺជាប្រពន្ធរបស់អម្ចាស់ *តៃកូ* ហើយក្រោយពី *តៃកូ* ទទួលមរណភាពមកលោកជំទាវបានចូលផ្នួស :

- ខ្ញុំសូមទោស ដែលមកទីនេះដោយគ្មានការអញ្ជើញ និងបានផ្តាច់ការជជែកពិភាក្សារបស់លោកណាំ លោកម្ចាស់ *តូរ៉ាណាកា* ។

- លោកជំទាវតែងត្រូវបានទទួល នូវកិច្ចស្វាគមន៍ ហើយទីកន្លែងនេះបើកចំហជានិច្ច *យ៉ូដូកូ-សាម៉ា* ។

- អរគុណ ! ចាស់ សូមអរគុណ !

លោកជំទាវ ចោលភ្នែកសំលឹងទៅ*ប្លាក់ថន* ហើយឈ្ងោកមើលដើម្បីសំលឹងអោយបានច្បាស់ :

- ខ្ញុំគិតថា ខ្ញុំបានកាត់ផ្តាច់កិច្ចសន្ទនារបស់លោកហើយ ។ ខ្ញុំមើលមិនច្បាស់សោះថាអ្នកណានេះ ? គាត់ជាអ្នកចុងស្រុកអ្វី ? ភ្នែកខ្ញុំកាន់តែយ៉ាប់ទៅៗហើយ ។ គាត់នេះមិនមែន



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ូតូ-សាន* ទេ មែនទេ ?

*តូរ៉ាណាកា* ឆ្លើយតប :

- មិនមែនទេ គេគឺជាអ្នកចុងស្រុកថ្មី ។

*យ៉ូដូតូ* អោនសំលឹងជិតបន្តិចទៀត :

- អីចឹងទេ ! សូមប្រាប់ទៅគាត់ផង ថាខ្ញុំមើលមិនសូវច្បាស់ទេ ហេតុនេះកុំប្រកាន់ថាខ្ញុំឈ្លើយអី ។

*ម៉ារីកូ* ធ្វើតាមសំដីរបស់ស្ត្រីចំនាស់ រួចទើបងាកមកបកសំដីរបស់ *ភ្ញាក់ថុន* វិញម្តង :

- គាត់និយាយថា នៅស្រុករបស់គាត់ មានមនុស្សច្រើនដែលមើលមិនបានឆ្ងាយអីចឹងដែរ *យ៉ូដូតូ-សាម៉ា* ប៉ុន្តែពួកគេពាក់វ៉ែនតា ។ គាត់សួរថា តើពួកយើងមានវ៉ែនតាវីអត់ ។ ខ្ញុំប្រាប់គាត់ថា មានខ្លះដែរដោយយើងបានពីពួកចុងស្រុកខាងត្បូង ។ ខ្ញុំបានប្រាប់ថា លោកស្រីពីមុន ក៏ពាក់វ៉ែនតាដែរ តែអីលូវនេះឈប់ហើយ ។

- ចាស់ ព្រោះខ្ញុំស្រលាញ់ភាពស្រអាប់ ដែលនៅជុំវិញខ្ញុំនេះ ។ ពិតណាស់ខ្ញុំមិនចង់ឃើញនូវអ្វីៗដែលមាននៅក្នុងពេលបច្ចុប្បន្ននេះទេ ។

រួចលោកជំទាវ ក៏បែរខ្លួនធ្វើហាក់ដូចជាទើបឃើញកុមារនេះ ។

- យី កូន ! កូននៅទីនេះទេអ្វី ? ម៉ែខំតែដើររកកូន ។ ម៉ែសប្បាយចិត្តណាស់ ដែលឃើញ *ក្វាមប៉ាតូ* នេះ ។

*វ៉ៃយនម៉ុន* មុខឡើងគ្រហាញ ហើយលំអោនខ្លួនគោរពស្ត្រីចំនាស់ :

- អរគុណម៉ែធំ ។ ម៉ែធំគួរតែមកស្តាប់អ្នកចុងស្រុកនេះ ។ គាត់គូរផែនទីប្រាប់យើង ហើយគាត់និយាយរឿង កំប្លុកកំប្លែងច្រើនណាស់ ពីពួកមនុស្សដែល មិនដែលមុជទឹកសោះ ម៉ាជីវិតរបស់ខ្លួន ។ រួចពួកនោះរស់នៅក្នុងផ្ទះព្រិល ហើយពាក់ស្បែកសត្វដូចពួក *កាមី* អាក្រក់អីចឹង ។

ទឹកមុខរបស់ *យ៉ូដូតូ* បង្ហាញឡើងនូវភាពមាក់ងាយយ៉ាងច្បាស់ :

- ម៉ែគិតថា ពួកនេះមកកាន់តែតិចពេលណា កាន់តែល្អពេលនោះ ។ ម៉ែមិនយល់ពួកនេះសោះតែម្តង ហើយពួកវាធុំសាបអាក្រក់អាក្រីតែម្តង ។ ម៉ែមិនយល់សោះថា ហេតុអីអម្ចាស់



www.budinst.gov.kh www.elibraryofcambodia.org

*វ៉េតូ* ដែលជាឪពុកលោកកូន ទ្រាំទទួលពូកនេះអោយនៅបាន ។ តែមើលទៅ មកពីគាត់ជាមនុស្សប្រុសហើយមើលទៅ ។ លោកកូន ក៏ជាមនុស្សប្រុសដើមទ្រូងប្រាំហត្ថដូចឪពុកលោកកូនដែរ ហើយកូនប្រុសរមែងមានអំនត់ជាងមនុស្សស្រីអន់ខ្សោយ ។ ម្យ៉ាងទៀតលោកកូន ក៏មានគ្រូយ៉ាងចំនានទៀតផង............

ភ្នែករបស់ស្ត្រីចំនាស់ សំលឹងមើលទៅ *តូរ៉ាណាកា* :

- លោកម្ចាស់ *តូរ៉ាណាកា* ជាមនុស្សមានអំនត់ជាងអ្នកណាទាំងអស់នៅក្នុងចក្រភពនេះ ។

*តូរ៉ាណាកា* ឆ្លើយតប :

- ចិត្តអំនត់ គឺជាការចាំបាច់សំរាប់បុរស ហើយជាការងាប់រស់សំរាប់អ្នកដឹកនាំ ។ ហើយការស្រេកឃ្លាន ទូរចំនេះដឹង ក៏ជាគុណសម្បត្តិដ៏ប្រសើរមួយផងដែរ មែនទេ *យែនមុំន-សាម៉ា ?* ហើយចំនេះវិជ្ជាមកពីកន្លែងចំលែក១ណាស់ ។

*យែនមុំន* និយាយឡើង :

- មែនហើយពូ ! ពិតមែន ! លោកពូមានយោបល់ត្រូវណាស់ មែនទេម៉ែធំ ?

- ចាស់ ! ចាស់ ! ម៉ែឯកភាពហើយ ។ តែម៉ែសប្បាយចិត្តណាស់ដែលម៉ែជាស្រី ហើយមិនចាំបាច់ខ្វល់ខ្វាយពីរឿងអស់នេះ ។

និយាយបណ្តើរ *យ៉ូម៉ូកូ* អោបកុមារដែលមកអង្គុយជិតខ្លួនបណ្តើរ :

- អូមែនហើយកូនប្រុស ហេតុអីបានជាមិមកទីនេះ ? គឺ មករក *ក្វាមប៉ាតូ* ណា៎ ។ ហេតុអី ? ពីព្រោះ *ក្វាមប៉ាតូ* ហួសពេលស្រស់ស្រូប ហើយថែមទាំងហួសពេលរៀនសរសេរមេរៀនទៀត ។

- ខ្ញុំស្អប់សរសេរមេរៀនណាស់ ហើយខ្ញុំចង់ទៅហែលទឹកវិញ ។

*តូរ៉ាណាកា* ពោលឡើងនៅក្នុងភាពម៉ឺងម៉ាត់ :

- ពេលដែលពូមានអាយុប្រហែលក្មួយឯង ពូក៏ស្អប់ការរៀនអក្សរអីចឹងដែរ ។ ប៉ុន្តែនៅពេលពូមានអាយុម្ភៃឆ្នាំ ពូត្រូវតែឈប់ធ្វើសង្គ្រាម ហើយត្រលប់ទៅសាលាវិញ ។ ហើយអារឿង



www.budinst.gov.kh www.elibraryofcambodia.org

ណុងពូរីតតែស្អប់លើសដើមទៅទៀត ។

- ត្រលប់ទៅសាលាវិញមែនអ្ហីលោកពូ ?ចេញហើយចូលវិញ ? អីយ៉ូយប៉ាប់ម្ល៉េះទេ !

- អ្នកដឹកនាំត្រូវតែចេះសរសេរអោយបានផ្ចិត *យែនមុំន-សាម៉ា* ។ មិនមែនគ្រាន់តែចេះសរសេរយ៉ាងច្បាស់ប៉ុណ្ណោះទេ តែយ៉ាងល្អទៀត ពិសេស*ក្វាមជាំតូ* ត្រូវតែលើសគេ ។ បើមិនអីចឹងទេ តើ *ក្វាមជាំតូ* សរសេរទៅព្រះចៅរីទៅមហា *វ៉េមីញ៉ូ* ទាំងឡាយយ៉ាងម៉េចទៅ ? អ្នកដឹកនាំត្រូវធ្វើកិច្ចការលំបាកយ៉ាងច្រើន ។

*យែនមុំន* ជ្រួញចិញ្ចើម ធ្វើទឹកមុខស្មើម :

- បាទពូ ! ធ្វើ*ក្វាមជាំតូ* ពិតជាលំបាកមែន ។ ខ្ញុំគិតទៅរៀនអីល្អវលើងគ្រាន់បើជាងចាំដល់អាយុម្ភៃឆ្នាំ ព្រោះដល់ពេលណុង ក្មួយនឹងមានការងាររដ្ឋសំខាន់ៗច្រើនណាស់ ។

ទាំងអស់គ្នា សែនមោទនភាពចំពោះ *យែនមុំន* ។ *យូ៉ដូកូ* ពោលឡើង :

- កូនពិតជាមានគំនិតចាស់ទុំមែន ។

- ពិតមែនម៉ែធំ ។ កូនមានគំនិតចាស់ទុំដូចពុកអីចឹង ។ ម៉ែខ្ញុំតែងតែនិយាយអីចឹងដែរ ។ រួចចុះពេលណាបានម៉ែខ្ញុំមក ?

*យូ៉ដូកូ* សំលឹងមើលទៅ *តូរ៉ាណាកា* :

- ជិតមកហើយកូន ។

- ខ្ញុំសង្ឃឹមថា ឆាប់ៗនេះជាមិនខាន ។

*តូរ៉ាណាកា* ឆ្លើយបន្ទរភ្លាម ។ *តូរ៉ាណាកា* ដឹងថា គឺ *អ៊ីស៊ីដូ* បានបញ្ជូន*យូ៉ដូកូ* អោយមកយក*យែនមុំន* ទៅវិញ។ លោកបាននាំ*យែនមុំន* ហើយនិងកងការពារមកស្ទួនច្បារនេះ ដោយផ្ទាល់ ដើម្បីធ្វើអោយសត្រូវរបស់លោកឆេះជុំតែប៉ុណ្ណោះ ។ ទន្ទឹមនោះលោកក៏មានបំនងចង់បង្ហាញជនបរទេសនេះ ដល់ទាយាទ កាត់មុខ *អ៊ីស៊ីដូ* ថែមទៀតផង ។

*យូ៉ដូកូ* និយាយឡើង :

- ខ្ញុំឡើយហត់ណាស់ដែលមានភារៈទទួលមើលការខុសត្រូវលើកូនប្រុសមួយនេះ ។ បើបានលោកជំទាវ *អូជីបា*ត្រលប់មក *អូសាកា* វិញនោះគឺជាការប្រសើរណាស់ព្រោះខ្ញុំអាចត្រលប់



www.budinst.gov.kh www.elibraryofcambodia.org

ទៅវត្តវិញបានហើយ ? តើ *អូជីជា* យ៉ាងម៉េចហើយ ? ហើយជំទាវ *កិនជីកូ* យ៉ាង ម៉េចដែរ?

- ពួកគេទាំងពីរនាក់មានសុខភាពល្អជាទេ ។

*តូក៉ាណាកា* ឆ្លើយតបទាំងសប្បាយរីករាយ ។ កាលពីប្រាំបួនឆ្នាំមុន នៅក្នុងការបង្ហាញពីមិត្តភាពមួយខុសពីធម្មតា អម្ចាស់តែកូបាននិយាយនឹងរូបលោកផ្ទាល់ អោយរៀបការជាមួយនឹង កិនជីកូ ដែលត្រូវជាប្អូនស្រីរបស់លោកជំទាវ *អូជីជា* ។ លោកជំទាវ *អូជីជា* គឺជាប្រពន្ធចុងសំនព្វបំផុតរបស់ *តែកូ* ។

កាលនោះ តែកូ និយាយទៅកាន់លោកថា :

- ធ្វើយ៉ាងនេះ ត្រកូលរបស់យើងនឹងផ្សារភ្ជាប់គ្នាជាវៀងរហូតមែនទេ ?

*តូក៉ាណាកា* ឆ្លើយតបយ៉ាងគោរព :

- បាទបាទ ។ ខ្ញុំបាទសូមទទួលគោរពតាម ថ្វីត្បិតតែខ្ញុំបាទមិនសក្តិសមនឹងទទួលកិត្តិយសបែបនេះក៏ដោយ ។

លោកមានបំនងចង់បានខ្សែទំនាក់ទំនងមួយជាមួយ *តែកូ* ប៉ុន្តែលោកក៏ដឹងដែរថា ថ្វីត្បិតតែជំទាវធំ *យ៉ូដូកូ* អាចយល់ព្រមក្តី ក៏ *អូជីជា* ដែលស្អប់រូបលោកស្រាប់ផងនោះ ពិតជានឹងប្រើឥទ្ធិពលរបស់នាង ទៅលើ *តែកូ*នោះ ដើម្បីរាំងមិនអោយមានអាពាហ៍ពិពាហ៍នេះឡើយ ។ម្យ៉ាងទៀត យកប្អូនស្រីរបស់ *អូជីជា* មកធ្វើជាប្រពន្ធ ក៏មិនមែនជាការមួយឈ្លាសវៃណាស់ដែរទេ ពីព្រោះវានឹងធ្វើអោយ *អូជីជា* មានឥទ្ធិពលយ៉ាងធំធេងមកលើរូបលោកជាមិនខាន ហើយជាពិសេសកំនប់ទ្រព្យទាំងប៉ុន្មានរបស់លោកអាចធ្លាក់ក្នុងកណ្តាប់ដៃ របស់ជំទាវនេះ ប៉ុន្តែបើសិនជា *កិនជីកូ* រៀបការជាមួយកូនប្រុសរបស់លោកគឺ *ស៊ូជាក៉ា* វិញនោះ ក្នុងឋានៈជាមេគ្រួសារខ្លួនលោកគឺពិតជាអាចក្តាប់អំនាចបានទាំងស្រុងជាមិនខាន ។ ពេលនោះ លោកត្រូវប្រើគ្រប់ការវាងវៃរបស់លោកទើបសំរេចអោយ *កិនជីកូ* រៀបការជាមួយកូនប្រុសរបស់លោកបាន ហើយអីឡូវនេះ *កិនជីកូ* គឺជារបស់មួយដ៏មានតំលៃបំផុត សំរាប់លោកតទប់ជាមួយជំទាវ *អូជីជា* ពីព្រោះលោកជំទាវស្រលាញ់ប្អូនស្រីខ្លួនណាស់ ។

- កូនប្រសាស្រីខ្ញុំមិនទាន់កើតកូននៅឡើយទេ ។ តាមត្រូវគឺ ចាប់ឈើពោះពីម្សិលមិញ



www.budinst.gov.kh www.elibraryofcambodia.org

ទៅហើយ ។ តែខ្ញុំគិតថា លោកជំទាវ *អូជីតា* នឹងធ្វើដំណើរមកវិញភ្លាម នៅពេលណាដែលអស់គ្រោះថ្នាក់ហើយនោះ ។

- *កិនជីកូ* អីលូវនេះមានកូនស្រីបីហើយ លើកនេះគួរចងដៃចៅប្រុសមួយជូនលោកហើយមែនទេ ? ចាំខ្ញុំបន់ស្រន់ សូមអោយលោកបានចៅប្រុសមួយនឹងគេផងចុះ ។

- សូមអរគុណ ។

*តូរ៉ាណាកា* តបដោយចិត្តស្រលាញ់រាប់អានយ៉ាងស្មោះស្ម័គ្រ ព្រោះលោកដឹងថា លោកជំទាវគិតយ៉ាងម៉េច និយាយយ៉ាងហ្នឹង មិនមែនចិត្តទេវទត្តមាត់ជាទេវតានោះឡើយ ថ្វីត្បិតតែរូបលោក គឺជាគ្រោះថ្នាក់មួយសំរាប់ត្រកូលលោកជំទាវក្តី ។

- ខ្ញុំលឺថា នាង *សាស៊ូកូ* របស់លោក មានទំងន់ហើយមែនទេ ?

- បាទ ខ្ញុំមានសំនាងអីចឹងមែន ។

ចំហាយក្តៅភាយរត់កាត់អង្គប្រាណរបស់ *តូរ៉ាណាកា* នៅពេលដែលលោកគិតពីប្រពន្ធចុងថ្មីបំផុតរបស់លោក ពីយុវភាព ពីថាមពល ហើយនិងភាពកក់ក្តៅរបស់នាង ។ អញប្រហែលជាបានកូនប្រុសហើយ -លោក *តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ បើបានកូនប្រុសមែន គឺពិតជាល្អណាស់ ។ ដប់ប្រាំពីរឆ្នាំ គឺពិតជាអាយុសមរម្យ ដើម្បីមានកូនដំបូងហើយ ។

- លោកពិតជាព្រះប្រទានពរមែន ។

កូនចិត្តច្រនែនតូចមួយ បានរត់កាត់អារម្មណ៍របស់លោកជំទាវ ។ វាហាក់ដូចជាអយុត្តិធម៌ណាស់ ដែល *តូរ៉ាណាកា* មានកូនប្រុសប្រាំនាក់នៅរស់ មានកូនស្រីមួយ ហើយនិងចៅស្រីប្រាំនាក់ទៅហើយ ។ បន្តិចទៀតកូនរបស់ *សាស៊ូកូ* នឹងកើតមកទៀត ហើយនៅប៉ុន្មានឆ្នាំខាងមុខ និងនៅមានប្រពន្ធចុងយ៉ាងច្រើននៅក្នុងផ្ទះរបស់លោកយ៉ាងនេះ *តូរ៉ាណាកា* ពិតជាបង្កើតបានកូនប្រុសយ៉ាងច្រើនទៀត ។ អីលូវនេះលោកជំទាវបានផ្តោតក្តីសង្ឃឹមតែមួយគត់ទៅលើក្មេងអាយុប្រាំពីរឆ្នាំនេះ ។ ជាក្មេងដែលលោកជំទាវចាត់ទុកដូចជាកូនបង្កើតរបស់លោកជំទាវ ថ្វីត្បិតតែវាជាកូនរបស់ *អូជីតា* ក្តី ។ ពិតហើយ វាដូចជាកូនរបស់ខ្ញុំ -លោកជំទាវគិតនៅក្នុងចិត្ត ។ គិតកាលពីដើម ខ្ញុំសែនស្អប់ *អូជីតា* ម្ល៉េះទេ ............



www.budinst.gov.kh www.elibraryofcambodia.org

លោកជំទាវទើបប្រទះឃើញក្រសែភ្នែករបស់អ្នកឯទៀត ដែលបាញ់ចំរុះមកលើរូបលោកជំទាវ ធ្វើអោយលោកជំទាវសែនភ្ញាក់ផ្អើល :

- មានការណ៍អីហ្នឹង ?

*ហែនម៉ុន* ជ្រួញចិញ្ចើម

- ខ្ញុំសួរថា យើងទៅរៀនអីល្ងូរហ្នឹងអ្វីម៉ែធំ ? ខ្ញុំសួរពីរដងហើយ ។

- ម៉ែសូមទោសណាកូនប្រុស ។ ម៉ែរវល់ភ្លឹករឿងផ្សេង ។ តែចាស់ទៅវាអីចឹងហើយ ។ បាន ! បាន ! មកអីចឹង !

*គិរី* ជួយលោកជំទាវអោយងើបឡើង ឯ *ហែនម៉ុន* រត់ទៅមុនជាស្រេច ។ ពួកអាវប្រផេះក៏បានក្រោករៀបចំខ្លួនហើយជាស្រេច ហើយសាមូរ៉ៃម្នាក់ បានលើក*ហែនម៉ុន* យ៉ាងថ្នាក់ថ្នមដាក់លើស្មារបស់ខ្លួន ។

សាមូរ៉ៃបួននាក់ទៀតដែលជូនជំទាវ *យ៉ូដូកូ* មកនោះ នៅឈរដាច់ពីគ្នា ។

- លោក*តូរ៉ាណាកា* ដើរជាមួយខ្ញុំបន្តិចបានទេ ? ខ្ញុំត្រូវការអ្នកដៃខ្លាំងអីចឹងគ្រាន់នឹងទប់ខ្លួន ។

*តូរ៉ាណាកា* ក្រោកឈរឡើងយ៉ាងរហ័ស ស្ទើរមិនអាចជឿបាន ។ លោកជំទាវឈោងទៅកាន់ដៃរបស់លោកបណ្តើរ ពោលបណ្តើរ :

- មែន ខ្ញុំត្រូវការដៃខ្លាំងអីចឹង ។ *ហែនម៉ុន* ក៏ត្រូវការ ។ នគរនេះ ក៏ត្រូវការ ។

*តូរ៉ាណាកា* ឆ្លើយតប :

- ខ្ញុំតែងតែត្រៀមខ្លួនបំរើលោកជំទាវជានិច្ចហើយទេតើ ។

នៅពេលដែលអ្នកទាំងពីរចេញឆ្ងាយពីអ្នកឯទៀត ហើយជំទាវ *យ៉ូដូកូ* បន្លឺយ៉ាងស្ងប់ស្ងៀម :

- សូមលោកទៅជាអាជ្ញានុសិទ្ធិ តែម្នាក់លោកទៅ ។ សូមលោកក្តាប់អំនាចយកសំរាប់តែលោកម្នាក់ ហើយដឹកនាំប្រទេសរហូតដល់ *ហែនម៉ុន* ពេញវ័យទៅចុះ ។

- បណ្តាំរបស់អម្ចាស់ *តៃកូ* ហាមផ្តាច់រឿងនេះ ..........ទោះជាក្នុងរឿងនេះ ខ្ញុំចង់ក្តី ។



www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្តែខ្ញុំឥតចង់ធ្វើអាជ្ញានុសិទ្ធិនេះទេ ។ ក្របខ័ណ្ឌដែលអម្ចាស់ *វ៉ាកូ* បានដាក់គឺផាត់ចេញអារឿង អាជ្ញានុសិទ្ធិ តែម្នាក់ឯងនេះហើយ។ ខ្ញុំក៏មិនស្វះស្វែងរកអំនាចអីដែរ ។ គឺមិនដែលសោះ ។

លោកជំទាវឆ្លើយតបដោយប្រើឈ្មោះក្រៅ ដែលលោកជំទាវធ្លាប់ហៅពីយូរយារណាស់មកហើយ :

- *តូកា-ចាន់* ! រវាងលោក នឹងខ្ញុំគ្មានរឿងអ្វីដែលជាអាថ៌កំបាំងប៉ុន្មានទេ ។ បើសិនជាលោកមានបំនង លោកច្បាស់ជាធ្វើបានក្នុងរឿងនេះ ។ ទុកអោយខ្ញុំនិយាយជាមួយជំទាវ *អូជីបា* ។ សូមលោកក្តាប់អំនាចសំរាប់មួយជីវិតរបស់លោកទៅចុះ ។ សូមលោកក្លាយទៅជាអគ្គមហាសេនា និង ............

- លោកជំទាវ អ្វីដែលលោកជំទាវ កំពុងនិយាយនេះ គឺជាការក្បត់ណា ។

ខ្ញុំ........មិន.......ស្វះស្វែង......ធ្វើជា....អគ្គ....មហា....សេនា.....ទេ ។

- ចាស់ ខ្ញុំដឹងហើយ ។ ប៉ុន្តែ សូមលោកស្តាប់ខ្ញុំសិន ។ សូមលោកឡើងជាអគ្គមហាសេនា ហើយតែងតាំង *វ៉ៃមុន* ជាទាយាទផ្ទាល់របស់លោកទៅ ។ លោកលឺទេ ? ជាទាយាទផ្ទាល់ ។ *វ៉ៃមុន* ថ្ងៃក្រោយនឹងអាចឡើងជាអគ្គមហាសេនាបន្តពីលោក ព្រោះនេះ គឺជាខ្សែពំនូកត្រកូលទេតើ ។ ត្រកូល *ភូជីម៉ូតូ* តាមរយៈលោកជំទាវ *អូជីបា* និង ជីតាវា *ក្លូដោ* រហូតដល់សម័យដើមឯណោះ ។

*តូកាណាកា* សំលឹងមើលចំលោកជំទាវ *យ៉ូមូតូ* :

- តើលោកជំទាវជឿថា ពួកដៃមីញ៉ូឯទៀតឯកភាពតាមអីចឹងអ្វី ? ម្យ៉ាងទៀតតើព្រះចៅយល់ព្រមតែងតាំងឋានៈអគ្គមហាសេនានេះអ្វី ?

- ទេ បើសិនជារឿងនេះជារឿង *វ៉ៃមុន* នោះ ។ ប៉ុន្តែបើលោកឡើងជាអគ្គមហាសេនាមុនហើយ។លោកយក *វ៉ៃមុន* ជាកូនធម៌នោះ។ លោកនឹងអាចធ្វើអោយពួកគេទាំងអស់គ្នាឯកភាពតាមហើយ ។ លោកជំទាវ *អូជីបា* និងខ្ញុំនឹងគាំទ្រលោកយ៉ាងពេញទំហឹង ។

*តូកាណាកា* សួរទៅវិញទាំងស្រលាំងកាំង :

- លោកជំទាវ *អូជីបា* ឯកភាពក្នុងរឿងនេះដែរ ?



www.budinst.gov.kh www.elibraryofcambodia.org

- ទេ ។ យើងទាំងពីរនាក់មិនដែលជជែកគ្នាពីរឿងនេះទេ ។ នេះគឺជាគំនិតខ្ញុំតែប៉ុណ្ណោះ ។ តែនាងពិតជាយល់ព្រម ។ ខ្ញុំហ៊ានធានាក្នុងរឿងនេះ ។ ហ៊ានធានាមុនតែម្តង ។

- រឿងនេះនិយាយនាំតែខាតទឹកមាត់ទេលោកជំទាវ ។

- លោកច្បាស់ជាអាចចាត់ចែងរឿងនេះបាន ។ រាល់ថ្ងៃខ្ញុំភ័យព្រួយនឹងពាក្យដែលគេខ្សឹបខ្សៀវគ្នានេះណាស់ ។ គេខ្សឹបខ្សៀវពីរឿងចំបាំង ពីរឿងចូលខាងនេះ ខាងនោះ ហើយនិងសត្វត្បរខ្មៅងងឹតដែលចាប់ផ្តើមឡើងវិញទៀតនោះ ។ បើសិនជាសង្គ្រាមឆាបឆេះជាថ្មីនោះវានឹងគ្មានពេលរលត់ទៅវិញទេ ហើយ *យែនមុំន* ពិតជាត្រូវឆេះរោលរាលជាមិនខាន ។

- បាន ខ្ញុំក៏យល់ឃើញយ៉ាងនេះដែរ ។ ពិតមែនហើយ បើសង្គ្រាមឆេះឡើងវិញម្តងទៀត គឺវានឹងមិនរលត់ជារៀងរហូត ។

- អ៊ីចឹងសូមលោកជណ្តើមយកអំនាចទៅ ។ ធ្វើទៅតាមបំណងរបស់លោកទៅ ។ ធ្វើអីអ្នកណាធ្វើទៅ ។ ធ្វើរបៀបណាធ្វើទៅ ។ *យែនមុំន* គឺជាក្មេងបានការម្នាក់ ។ ខ្ញុំដឹងថា លោកស្រលាញ់វា ។ វាមានខួរក្បាលដូចឪពុកវាអ៊ីចឹង ហើយបើបានលោកណែនាំវាទៀតនោះ យើងទាំងអស់គ្នាពិតជាបានចំនេញ ។ *យែនមុំន* គួរតែបានឡើងស្នងកេរឪពុកវា ។

- ខ្ញុំមិនប្រឆាំងនឹងវាទេ ហើយក៏មិនជំទាស់នឹងការស្នងអំនាចរបស់វាដែរ ។ ខ្ញុំបាននិយាយរឿងនេះច្រើនដងហើយទេតើ ។

- *យែនមុំន* ពិតជាត្រូវរលំ បើសិនជាលោកមិនគាំទ្រវាអោយបានខ្លាំងក្លាទេនោះ ។

*តួរ៉ាណាកា* ឆ្លើយតប :

- ខ្ញុំពិតជាគាំទ្រវា ។ គាំទ្រអស់ទំហឹង ។ នេះគឺជាប្រការដែលខ្ញុំបានឯកភាពជាមួយអម្ចាស់ *វ៉ាគូ* ។

*យ៉ូម៉ុគូ* ដកដង្ហើមធំ ហើយទាញក្អិតអាវរបស់ខ្លួន :

- ឆ្នាំងចំនាស់ខ្ញុំនេះវងាហើយ ។ គិតទៅមានរឿងច្រើនមែន ។ មានទាំងរឿងសំងាត់ រឿងចំបាំងរាំងជល់ រឿងក្បត់ រឿងស្លាប់ រឿងឈ្នះចាញ់ ។ ខ្ញុំគ្រាន់តែជាស្ត្រីម្នាក់តែប៉ុណ្ណោះ ។ ហើយជាស្ត្រីឯកោមែនទែន ។ ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំបានថ្វាយខ្លួនដល់ព្រះពុទ្ធ



www.budinst.gov.kh www.elibraryofcambodia.org

ជាម្ចាស់ ។ អីឡូវនេះ ចិត្តគំនិតខ្ញុំបូជាចំពោះព្រះអង្គស្ទើរតែទាំងអស់ទៅហើយ ។ ជាតិក្រោយក៏អ៊ីចឹងដែរ ។ តែក្នុងជាតិនេះខ្ញុំត្រូវតែការពារកូនខ្ញុំ ហើយខ្ញុំត្រូវនិយាយរឿងទាំងអស់នេះដល់លោក ។ ខ្ញុំសង្ឃឹមថា លោកពិតជាអត់អោនចំពោះការព្រហើនរបស់ខ្ញុំទេបាទមិនខាន ។

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

- ខ្ញុំតែងតែរីករាយណាស់ដែលបានលោកជំទាវផ្ដល់មតិនោះ ។

- អរគុណលោក ។

ដងខ្លួនរបស់លោកជំទាវឡើងត្រង់ជាងមុនបន្តិច :

- សូមលោកស្ដាប់ខ្ញុំណា ដរាបណាខ្ញុំនៅរស់ ទាំង *វ៉ែនមុ៊ន* ទាំងជំទាវ *អូជីជា* នឹងមិនប្រឆាំងលោកជាដាច់ខាត ។

- បាទ ។

- បើអ៊ីចឹងលោកយល់យ៉ាងម៉េចដែរ ដែលខ្ញុំស្នើនោះ ?

- លោកម្ចាស់បានហាមផ្ដាច់រឿងនេះ ។ ខ្ញុំមិនអាចក្បត់នឹងសម្បថរបស់ខ្ញុំបានទេ ។

អ្នកទាំងពីរបន្តដំណើរទៅទៀតយ៉ាងស្ងៀមស្ងាត់ ។ រួចលោកជំទាវក៏ដកដង្ហើមធំហើយបន្លឺឡើង :

- បើអ៊ីចឹងម៉េចក៏មិនយកនាងធ្វើជាប្រពន្ធទៅ ?

- *អូជីជា* ?

- រួចចុះវាយ៉ាងម៉េច ? បើនិយាយពីជំរើសនយោបាយ នាងគឺពិតជាត្រូវចំណាស់ទៅហើយ ។ ចំជាជំរើសឯកតែម្ដងសំរាប់រូបលោក ។ នាងមានរូបស្អាតនៅក្មេងខ្លាំង ហើយឈាមជ័រនាងក៏ល្អផុតគេទៅទៀត ។ មួយផ្នែកគឺជាឈាមត្រកូល *ភូជីម៉ូតូ* មួយផ្នែកគឺជា *មីណូវ៉ាក់* ។ ពេលនេះលោកក៏មិនទាន់មានប្រពន្ធជាផ្លូវការនៅឡើយដែរ ។ បើអ៊ីចឹងទេ ម៉េចមិនយកនាងតែម្ដងទៅ ? បើធ្វើអ៊ីចឹងវាអស់មានអារឿងស្នងអំនាចទៀតហើយៗ នគរក៏មិនត្រូវហែកហួដោយសារសង្គ្រាមដែរ ។ លោកក៏ពិតជានឹងមានកូនប្រុសទៀតជាមួយនាងមិនខាន ។ *វ៉ែនមុ៊ន* នឹងស្នងអំនាចពីលោក រួចបន្ទាប់មកកូនរបស់ *វ៉ែនមុ៊ន* រឺក៏កូនប្រុសផ្សេងទៀតរបស់ *អូជីជា* ។ លោកក៏អាចក្លាយទៅជាអគ្គមហាសេនា ។ លោកមានទាំងអំនាចនគរ



www.budinst.gov.kh www.elibraryofcambodia.org

មានទាំងអំនាចជាឪពុក ដោយហេតុនេះលោកអាចអប់រំ *ប៉ែនមុ៊ន* ទៅតាមបែបបទលោកបាន ។ លោកនឹងទទួល *ប៉ែនមុ៊ន* ជាផ្លូវការ ហើយ *ប៉ែនមុ៊ន* នឹងក្លាយទៅជាកូនរបស់លោកដូចកូនឯទៀតៗ របស់លោកដែរ ។ ហេតុនេះ ហេតុអីក៏មិនរៀបការជាមួយជំទាវ *អូជីណា* ទៅ ?

ពីព្រោះនាងគឺជាឆ្មាព្រៃ នាងគឺជាខ្លាញ្ជីប្រកបដោយល្បិចកល តែមានមុខនិងរូបរាងកាយទេពអប្សរ ព្រោះនាងរមែងចាត់ខ្លួនជាមហារាជនី ហើយធ្វើរិកដូចជាមហារាជនីអ៊ីចឹង - *តូកុំណាកា* គិតនៅក្នុងចិត្ត ។ អ្នែងមិនអាចទុកចិត្តនាងបានទេ ទោះជានាងមកដេកនៅលើគ្រែជាមួយក្តី ។ នាងអាចថ្នាក់ថ្នមបបោសអង្អែលអ្នែង តែនាងក៏អាចយកស្លៀតសក់នាងចាក់ទំលុះភ្នែករបស់អ្នែងបានដែរ ។ ឱព្រះអើយ អ្នកណាក៏បានដែរ កុំតែនាងនោះ ! ទោះជាការតែឈ្មោះក៏អញមិនព្រមដែរ ។ រឿងរ៉ាវរ៉ាច្រើនហួស នេះបើមិនគិតពីរឿងដែលកាលពីដប់មួយឆ្នាំមុនជំទាវនេះស្អប់ចងគំនុំនឹងអញ ហើយតាមឈ្នានីសអញអោយរលត់រលាយផង ។

កាលនោះ នាងទើបតែអាយុបានដប់ប្រាំពីរឆ្នាំសោះ តែនាងប្តេជ្ញាយ៉ាងមាំតាមបំផ្លាញអញស្រេចទៅហើយ ។ កាលនោះនាងក្មេងល្អក់ មើលពីក្រៅមិនខុសអ្វីពីផ្កាក្រពុំ នាពេលព្រឹកព្រហាមនោះទេ តែខាងក្នុងវិញគឺជាដែកថែបដែលមានព្រលឹងមិនចេះចាញ់ ។ គ្រាន់តែមួយភ្លែតសោះ នាងចេះធ្វើអោយអម្ចាស់ *តៃកូ* ឈ្លក់ងប់នឹងនាងលើសអ្នកឯទៀតទាំងអស់ ។ តាមពិតទៅនាងធ្វើអោយ *តៃកូ* ជាក់ចង្គូមតាំងពីពេលដែល *តៃកូ* យករូបនាងពេលនាងនៅអាយុដប់ប្រាំពីរឆ្នាំម្ល៉េះ ។ ពិតណាស់ តាំងពីអាយុដប់ប្រាំពីរម្ល៉េះនាងដឹងថា តើនាងស្វែងរកអ្វី ហើយស្វែងរកដោយរបៀបណា ។ ហើយបន្ទាប់មកទៀត ក្នុងចំនោមនារីទាំងអស់ដែល *តៃកូ* យកជាប្រពន្ធ នាងគឺជានារីតែម្នាក់គត់ដែលមានកូន ហើយកូនប្រុសទៅទៀត ។ តើអម្ចាស់ *តៃកូ* មានប្រពន្ធប៉ុន្មានអ៊ីចេះ ? មិនតិចជាងមួយរយទេ ហើយក្នុងមួយរយនេះទៀត មានគ្រប់អាយុ មានគ្រប់ឋានៈ ។ តាំងពីព្រះអង្គម្ចាស់ក្សត្រី រហូតដល់នារីកំដរភ្ញៀវថ្នាក់ទាបបំផុត ។ ហើយគ្មានអ្នកណាមួយមានទំងន់សោះ លើកលែងតែពេលលោកម្ចាស់លែង រឺបណ្តេញចេញទើបបានមានកូនជាមួយបុរសឯទៀត ។ គឺពិតជាគ្មានអ្នកណាមួយមានទំងន់ជាមួយអម្ចាស់ *តៃកូ* សោះ លើកលែងតែ *អូជីណា* មួយគត់ ។



www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្តែនាងបង្កើតកូនប្រុសនៅពេលដែល *វែក្ង* អាយុហាសិបបីឆ្នាំទៅហើយ។ កូននោះមានសុខភាពយ៉ាប់យ៉ឺន ហើយស្លាប់ទៅវិញយ៉ាងឆាប់ ធ្វើអោយ *វែក្ង* ស្ទើរឆ្កួត ។ រួចបួនឆ្នាំក្រោយមកទៀត នាងមានទំងន់ ហើយបង្កើតបានកូនប្រុសមួយទៀត ដែលមានសុខភាពល្អ ធ្វើអោយ *វែក្ង* សែនរីករាយនៅក្នុងចិត្ត ។ ពេលនោះនាងទើបអាយុបានម្ភៃមួយឆ្នាំប៉ុណ្ណោះ ។

តើអម្ចាស់ *វែក្ង* ជាឪពុក *វែយទមុ័ន* រឺក៏អត់ ? តើយើងនឹងដឹងការពិតនៅថ្ងៃណាមួយបានទេ ? ច្បាស់ជាគ្មានបែបនេះទេ តែបើអញដឹងវិញអស់ប៉ុន្មានក៏អស់ទៅចុះ ។

គិតទៅគឺជាការចំលែកមួយដែលអម្ចាស់ *វែក្ង* ដ៏ឆ្លាតវាងវៃនៅក្នុងសព្វបញ្ហាបែរមកជាល្ងង់ដប់គត់ជាមួយ *អូជីតា* ទៅវិញ ។ តែបើថាងប់ទាល់តែលែងមានវិចារណញ្ញាណវិញទើបត្រូវ ។ ជាការចំលែកទៅទៀតដែលក្នុងចំនោមអ្នកត្រូវជាម្ដាយក្មេងដែលត្រូវឡើងស្នងអំនាចពី *តូក៍ណាកា* គឺជាជំទាវ *អូជីតា* ដែលឪពុក ម្ដាយ និងឪពុកក្មេកត្រូវស្លាប់ដោយសារអម្ចាស់ *វែក្ង* ទៅវិញ ។

តើជំទាវ *អូជីតា* អាចមានល្បិចទៅដេកជាមួយប្រុសម្នាក់ទៀត ដើម្បីបានកូនហើយបន្ទាប់មកកំចាត់មនុស្សនោះចោល ដើម្បីការពារសន្តិសុខខ្លួននាងទេ ? មិនមែនធ្វើបែបនេះតែម្ដងនោះទេ តែពីរដងរឺ ?

តើនាងអាចមានល្បិចដ៏ថោកទាបបែបនេះទេ ? អាច ពិតជាអាច !

រៀបការជាមួយ *អូជីតា* អ្វី ? ទេ ដាច់ខាតទេ !

*តូក៍ណាកា* ពោលឡើង :

- ខ្ញុំមានកិត្តិយសណាស់ ! ដែលលោកជំទាវលើកសំនើបែបនេះ ។

- លោកជាកូនប្រុសដើមទ្រូងប្រាំហត្ថ *តូក៍-ចាន់* ។ លោកពិតជាអាចក្ដាប់នារីបែបនេះយ៉ាងងាយ ។ លោកគឺជាមនុស្សតែមួយគត់នៅក្នុងនគរនេះ ដែលអាចធ្វើយ៉ាងនេះបាន ។ នាងគឺពិតជាដៃគូមួយដ៏ល្អសំរាប់លោក ។ គ្រាន់តែមើលនាងតស៊ូដើម្បីការពារផលប្រយោជន៍កូននាងនៅពេលនេះក៏អាចយល់បានហើយ ។ ហើយនេះនាងជាស្រីទន់ខ្សោយគ្មានអំនាចនៅក្នុងដៃផង ។ នាងពិតជាសក្តិសមជាប្រពន្ធរបស់លោកណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំគិតថា នាងប្រហែលជាមិនដែលគិតដល់បញ្ហានេះផងទេ ។

- រួចចុះបើនាងគិតដល់វិញ ?

- ខ្ញុំក៏ចង់ដឹងដែរ ។ ដឹងជាសំងាត់ ។ មែនណា នោះគឺពិតជាកិត្តិយសមួយកាត់ថ្លៃមិនបានទេចំពោះខ្ញុំ ។

- មនុស្សជាច្រើនណាស់ជឿថា មានតែលោកម្ចាស់គត់ដែលអាចឈរពាំងមិនអោយ *វ៉ែយនម៉ុន* ឡើងស្នងអំនាចបាន ។

- មនុស្សច្រើននាក់ជាមនុស្សឆ្កួត ។

- ពិតហើយ តែលោកមិនមែនជាមនុស្សបែបនោះទេ *តូរ៉ាណាកា -សាម៉ា* ។ ជំទាវ *អូជីបា* ក៏អីចឹងដែរ ។

លោកជំទាវក៏យ៉ាងដូច្នោះដែរ -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ១៨

នៅកណ្ដាលយប់ស្ងាត់ ឃាតកបានលោតផ្លោះកំផែងចូលទៅក្នុងសួនច្បារ ។ ខ្លួនបុរសនេះ បន្លំបាត់ក្នុងស្បែងងងឹតដែលធ្វើអោយគេពិបាកនឹងឃើញណាស់ ។ បុរសនេះស្លៀកពាក់ខោអាវរឹបដងខ្លួន ហើយ *ភាប៊ី* របស់គេក៏មានពណ៌ខ្មៅដែរ ។ នៅលើក្បាលគេមានស្រោមមុខ និងស្រោមក្បាលពណ៌ខ្មៅ ។

បុរសនេះមានឧល្លិត ហើយគេរត់ដោយគ្មានសូរសំលេងអ្វីទាំងអស់សំដៅទៅកំផែងថ្មខាងក្នុងមួយជាន់ទៀតនោះ ។ នៅជើងកំផែងដ៏ចោត បុរសនេះឈប់ង៉ឹកក្បាម ។ ហាសិបម៉ែតពីបុរសនេះ បុរសអាវពណ៌ត្នោតពីរនាក់នៅឈរយាមច្រកទ្វារធំ ។ ដោយគ្មានសូរអ្វីទាំងអស់ និងយ៉ាងប៉ិនប្រសប់ បុរសនេះគ្រវែងទំពក់ដែលរុំនឹងក្រនាត់ ហើយដែលមានខ្សែសូតស្តើងចងបន្លាយនោះ ឡើងទៅលើ ។ ពេលដែលទំពក់បានថ្លក់ជាប់នឹងចង្អែកថ្មហើយ បុរសក៏ឡើងទៅលើ ហើយក៏កំសៀកខ្លួនចូលទៅក្នុងតាមច្រកទ្វារមួយបាត់ទៅ ។

របៀងនេះមានសភាពស្ងប់ស្ងាត់ ហើយត្រូវបំភ្លឺដោយពន្លឺទៀន ។ បុរសរត់ចុះទៅតាមរបៀងដោយគ្មានសឺរបជើងបន្តិចណាឡើយ ។ បន្ទាប់មកគេក៏បើកទ្វារមួយទៀត ដែលនាំគេចេញទៅខាងក្រៅ ។ បន្ទាប់ពីចោលទំពក់យ៉ាងប៉ិនប្រសប់ម្តងទៀត និងការហក់យោងខ្លួនឡើងមួយភ្លែតនោះមក បុរសនេះបានទៅដល់របៀងមួយទៀតដែលនៅជាន់លើ ។ ថ្វីត្បិតតែអ្នកយាមដែលឈរនៅតាមជ្រុងកំផែងទាំងប៉ុន្មានមានការប្រុងប្រយ័ត្នយ៉ាងណាក្តី ក៏ពួកគេឥតបានលឺសឺរបអ្វីបន្តិចណាសោះ ។ នៅពេលដែលក្រុមល្បាតរបស់ពួកអាវត្នោតមួយក្រុមដើរពិនិត្យសភាពការណ៍យ៉ាងស្ងៀមស្ងាត់នោះ បុរសនេះក៏ផ្ទឹបខ្លួនជាប់ទៅនឹងកន្លៀតថ្មមួយ ។ លុះក្រុមល្បាតដើរផុតហើយ បុរសនេះក៏កំសៀកខ្លួនតាមរបៀងនេះបន្តដំណើរទៅមុខទៀត ។ នៅកាច់ជ្រុងរបៀងគេឈប់ផ្ទៀងភ្នែកសំលឹងមើលសព្វទិសទីជាមុនសិន ។ នៅឯចុងរបៀងមានទ្វារមួយដែលមាន សាមូរ៉ៃ ម្នាក់យាមនៅទីនោះ ។ ពន្លឺទៀនរេរាំយ៉ាងស្ងៀមស្ងាត់ ។ សាមូរ៉ៃ ជាឆ្មាំនេះអង្គុយពែនភ្លែន ហើយផ្អែកខ្នងទៅនឹងជញ្ជាំង ។ បន្តិចក្រោយមកឆ្មាំនេះក៏ពត់ខ្លួន ហើយស្វាបឡើង ។ ធ្វើកាយវិការនេះនាំអោយឆ្មាំបិទភ្នែកមួយពេលយ៉ាងខ្លី តែក៏គ្រប់គ្រាន់ដើម្បីអោយ



www.budinst.gov.kh www.elibraryofcambodia.org

បុរសបិទមុខនេះស្ទុះហក់ទៅមុខបានហើយ ។ ជាសន្ទុះយ៉ាងលឿន និងគ្មានសូរ ។ ដៃរបស់បុរសនេះកួចខ្សែសូត ហើយពាក់ទៅលើកឆ្នាំយ៉ាងរហ័ស ។ បន្ទាប់មកគេក៏កន្ត្រាក់រឹតខ្សែយ៉ាងខ្លាំង។ ឆ្មាំប្រឹងយកម្រាមដៃមកច្បាមសាកល្បងទាញខ្សែមច្ចុរាជនេះចេញ ប៉ុន្តែខ្លួនគេទធាក់ត្រជាក់ខ្យល់ជាស្រេច ។ មួយកាំបិតយ៉ាងប៉ិនប្រសប់ចំកន្លែងបេះដៃផុតមួយទៀត ឆ្មាំបានក្លាយទៅជាសាកសពមួយរំពេច ។

បុរសបិទមុខបើកទ្វារយ៉ាងថ្នមៗ ។ សាលាជំនុំគ្មានមនុស្សម្នាក់ណាឡើយ ហើយទ្វារខាងក្នុងទាំងប៉ុន្មានក៏គ្មានអ្នកណាយាមដែរ ។ គេរុញសាកសពចូលក្នុងសាលាជំនុំ ហើយបិទទ្វារភ្ជិតទៅវិញ ។ ដោយគ្មានអល់អែកអ្វីសោះ គេដើរកាត់សាលាជំនុំតំរង់ទៅទ្វារដែលនៅខាងឆ្វេងដៃ ។ នោះគឺជាទ្វារឈើយ៉ាងក្រាស់មួយ ។

នៅពេលដែលកាំបិតស្នៀតត្រូវហូតកាន់នៅនឹងដៃស្តាំហើយ បុរសនោះក៏គោះទ្វារយ៉ាងថ្នមៗ ដោយបន្លឺឡើងនូវពាក្យសំងាត់សំរាប់អ្នកយាម :

- កាលពីសម័យព្រះចៅអធិរាជ *ស៊ីក៏កាក៏.....*

នៅឯម្ខាងទ្វារ សូរដាវដែលគេដកចេញពីស្រោមបានលាន់លឺឡើងទន្ទឹមនឹងចំលើយតប :

- មានបុរសដ៏វាងវៃម្នាក់ឈ្មោះ *អេនរ៉ាគូ-ជិ.....*

- ដែលបានសរសេរស៊ូត្រាទាំងសាមសិបជំពូង.....ខ្ញុំមានសារប្រញាប់ជូនដល់លោកម្ចាស់ *តូរ៉ាណាកា* ។

ទ្វារបើកឡើងឃ្វាំង ហើយឃាតកក៏ហក់ចូលទៅយ៉ាងលឿន ។ កាំបិតស្នៀតបានចាក់ចំបំពង់ក សាមូរ៉ៃ ទីមួយក្រោមចង្កាបន្តិច ហើយវាត់យ៉ាងរហ័សទៅ សាមូរ៉ៃ ទីពីរ ចំកន្លែងដដែល ។ គេមួលកាំបិតបន្តិច ហើយដកកាំបិតមកវិញ ។ ឆ្មាំទាំងពីរដាច់ខ្យល់ទាំងជំហរភ្លាម ។ ឃាតកចាប់ទប់ឆ្មាំម្នាក់ ហើយដាក់សាកសពនេះយ៉ាងថ្នមៗ ។ ឆ្មាំម្នាក់ទៀតរលំគ្រេង ប៉ុន្តែដោយគ្មានសូរសំលេងអ្វីទាំងអស់ ។ ឈាមហូរចេញកខក់ពីសាកសពទាំងពីរ ហើយខ្លួនប្រាណរបស់ឆ្មាំទាំងពីរនៅតែកន្ត្រាក់ញ័ររទទ្រើកនៅឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

ឃាតកបន្តដំណើរយ៉ាងប្រញាប់ប្រញាល់ទៅតាមរបៀងក្នុង ដែលមានពន្លឺបំភ្លឺយ៉ាងខ្សោយ ។ រំពេចនោះ ទ្វារបន្ទប់មួយរបើកឡើង ធ្វើអោយឃាតកឈប់ថ្នាំង ងាកសំលឹងទៅរកប្រភពសំលេងជាថៃដន្យនេះ ។

ដប់ជំហានពីនេះ *គីរី* ឈរបើកភ្នែកក្រលោតសំលឹងមករកឃាតកមួយនេះ ។ នៅលើដៃរបស់លោកស្រីមានថាសមួយផង ។

ក្នុងមួយប៉ប្រិចភ្នែក បុរសបិទមុខសំគាល់ឃើញថា ពែងទាំងពីរដែលនៅលើថាសមិនទាន់ត្រូវបានគេប្រើនៅឡើយ ម្ហូបក៏មិនទាន់ត្រូវបានគេប៉ះ ។ ប៉ាន់តែមានផ្សែងហុយទ្រលោម ។ ទៀនមួយទៀត ត្រូវបានដោតនៅក្បែរប៉ាន់នេះ ។

ថាសធ្លាក់ទៅលើកំរាលលាន់សូរប្រាវ ។ ដៃរបស់ *គីរី* លូកទៅក្នុងអូប៊ី ហើយហូតចេញកាំបិតស្នៀតមួយមក ។ លោកស្រីហក់ទៅរកឃាតកដោយប្រឹងស្រែកអោយសញ្ញាអាសន្ន ប៉ុន្តែលោកស្រីស្រែកមិនចេញសោះ ។ បុរសបិទមុខរត់តំរង់ទៅចុងរបៀងយ៉ាងប្រញាប់ប្រញាល់ ជួនជានៅពេលទ្វារដែលនៅចុងរបៀងក៏របើកឡើង ហើយសាមូរ៉ៃម្នាក់ដែលនៅមិនទាន់អស់ងងុយផងភ្ញាក់ផ្អើលអើតសំលឹងចេញមកក្រៅ ។

ឃាតកស្ទុះទៅរកទ្វារចុងក្រោយនេះ ហើយទំលាយក្រដាសពាសទ្វារមួយដែលនៅខាងស្តាំរបស់ខ្លួន ។ ចំពេលនេះ គីរីបន្លឺសំរែកចេញបានហើយៗ សញ្ញាអាសន្នក៏បានបន្លឺឡើង ។ ទោះជាយ៉ាងនេះក្តី ក៏ឃាតករត់កាត់ទីងងឹតដោយគ្មានអល់អែកអ្វីទាំងអស់ ហាក់ដូចជាគេទុកចិត្តខ្លួនគេទាំងស្រុងតែម្តង ។ គេរត់កាត់បន្ទប់មុខ ហក់រំលងក្រុមនារីដែលទើបភ្ញាក់ឡើងទាំងគ្រទីគ្រទា ។ នៅទីបំផុតគេបានមកដល់របៀងចុងក្រោយ ។ ទីនេះងងឹតឈឹង ប៉ុន្តែឃាតកបានរាវរកឃើញទ្វារដែលគេស្វែងរកក្នុងរយៈពេលយ៉ាងខ្លី ។ គេបើកទ្វារឃ្លាំង ហើយហក់ចូលទៅរកស្រមោលមនុស្សម្នាក់ដែលនៅដេកលើកន្ទេល ។ ប៉ុន្តែដៃរបស់គេត្រូវខ្ទាស់ជាប់កណ្តាលអាកាស ហើយគេក៏ដួលប្រួសទាំងប្រពាយប្រតប់ជាមួយស្រមោលមនុស្សនោះ ។ ឃាតកទប់ការវាយលុកយ៉ាងប៉ិនប្រសប់ រើខ្លួនចេញ ហើយហក់ចូលទៅចាក់ម្តងទៀត តែស្រមោលនោះគេចយ៉ាងរហ័ស ធ្វើអោយឃាតកជាប់ជើងនឹងភួយ ហើយដួលទាំងជំហរ ។ គេត្រវាសភួយទៅ



www.budinst.gov.kh www.elibraryofcambodia.org

ម្ខាងហើយហក់ទៅរកស្រមោលមនុស្សនេះម្តងទៀត ប៉ុន្តែស្រមោលនេះរមៀលខ្លួនទៅម្ខាងយ៉ាងរហ័ស ហើយទាត់មួយជើងសងចំកណ្តាលមុខ ធ្វើអោយបុរសជាឃាតកបែករំពិលអំពែកព្រាត ។ ឆ្លៀតឱកាសនោះ ស្រមោលមនុស្សបានរត់ទៅម្ខាងប្រុងប្រៀបការពារខ្លួនហើយជាស្រេច ។

បន្ទាប់មកពួក *សាមូរ៉ៃ* បានលេចមុខព្រោងព្រាតនៅឯមាត់ទ្វារ ។ ក្នុងចំនោមអ្នកទាំងនេះ មានខ្លះកាន់គោមចំភ្លឺមកជាមួយផង ។ *ណាកា* ដែលស្លៀកតែខោស្លាប់ភ្លៅមួយ ហើយនិងមានសក់កន្ទ្រើងនោះ បានស្ទុះមកនៅចំចន្លោះរវាង *ភ្ជាក់ផន* ហើយនិងឃាតកដោយលើកដាវត្រៀមហើយជាស្រេច :

-ចុះសាវភាពភ្លាម !

ឃាតកញ្ជាក់ជន្លមួយខ្ទាច់ រួចក៏ស្រែកឡើង :

- *អមិភាក:* !

បន្ទាប់មកឃាតកក៏បង្វែរចុងកាំបិតមករកខ្លួន ហើយផ្ទប់ដៃទាំងពីរបុះកាំបិតចំលុះចុងដង្ហើមរបស់ខ្លួនមួយរំពេច ។ ឈាមបាញ់ចេញច្រាវហើយបុរសក៏ស្លុតជង្គង់គ្រិបទៅនឹងក្តារ ។ ផ្ទៃដាវរបស់ *ណាកា* វាត់ឆ្ងាច់មើលស្ទើរមិនទាន់ ហើយក្បាលរបស់ឃាតកក៏រមៀលទៅលើក្តារភ្លាមដែរ ។

នៅក្នុងសភាពស្ងាត់ស្ងៀម *ណាកា* រើសយកក្បាលឡើង ហើយទាញក្រនាត់រុំមុខចេញនេះជាមនុស្សដ៏សាមញ្ញម្នាក់ ហើយភ្នែកនៅបើកប្រិចៗ នៅឡើយ ។ *ណាកា* កាន់កំប៉ោយសក់ហើយលើកក្បាលបង្ហាញអ្នកឯទៀត :

-មានអ្នកណាស្គាល់វាទេ ?

គ្មានអ្នកណាមានចំលើយសោះឡើយ ។ *ណាកា* ស្ពោះដាក់មុខរបស់ឃាតក ហើយក៏បោះក្បាលទាំងកំហឹងទៅកូនចៅរបស់ខ្លួន ។ បន្ទាប់មកគេក៏កន្ទ្រាក់ខោអាវខ្មៅ ដែលនៅលើសាកសពឃាតករ ហើយចាប់លើកដៃស្តាំបុរសនេះឡើង ។ ទីបំផុតគេក៏រកឃើញអ្វីដែលគេស្វែងរក ។ នោះគឺជាអក្សរចិន ដែលត្រូវបានសាក់យ៉ាងល្អិតនៅលើកំភួនដៃ ហើយដែលមាន



www.budinst.gov.kh www.elibraryofcambodia.org

ន័យថា " *អមិតា* "(*) ។

- អ្នកណាជាប្រធានក្រុមយាម ?

- ខ្ញុំបាទ ទាន !

មុខរបស់មេក្រុមយាមឡើងសដូចជាក្រដាស។ *ណាកា* ស្ទុះទៅរកបុរសនេះ ក្នុងពេលដែលអ្នកនៅទីកន្លែងនោះទាំងប៉ុន្មានថយក្រោយៗ ទៅក្រោយ ។ បុរសនាយក្រុមឥតមានងាកគេចពីផ្លែដាវរបស់ *ណាកា* ដែលវាត់យ៉ាងអស់ទំហឹង និងយ៉ាងសាហាវមករកខ្លួនឡើយ ។ សន្ទុះដាវបានកាត់ដាច់ក្បាល ស្មាមួយចំហៀង និងដៃម្ខាងទៅបាត់ ។ រួចរាល់ហើយ *ណាកា* ងាកទៅរកនាយក្រុមម្នាក់ទៀត :

- *ហាយ៉ាប៊ូសា-សាន* ! បញ្ជាអោយពួកអ្នកយាមវេននេះចេញទៅទីធ្លាទាំងអស់គ្នា។ វេនថ្មីនេះបន្ថែមអ្នកយាមមួយជាពីរទៅ ។ អូសខ្មោចចេញពីកន្លែងនេះផង ។ អ្នកឯទៀត គឺ.....

*ណាកា* ឈប់កណ្ដាលឃ្លា នៅពេលដែលឃើញលោកស្រី *គិរី* អើតតាមមាត់ទ្វារ ។ ដៃរបស់លោកស្រីនៅតែកាន់កូនកាំបិតស្នៀតនៅឡើយ ។ លោកស្រីសំលឹងមើលសាកសពទាំងពីររួចសំលឹងទៅកាន់ *ក្លាក់ថន* ដោយបន្លឺសំនួរឡើង :

- *អាន់ជិន -សាន* មិនមានរបួសទេអ្វី ?

*ណាកា* ងាកទៅសំលឹងមើលបុរសដែលកំពុងឈរជ្រងោពីមុខខ្លួន ហើយដែលកំពុងដកដង្ហើមយ៉ាងលំបាកនោះ ។ គេមិនអាចមើលអោយដឹងថា តើ *ក្លាក់ថន* មានរបួស រឺក៏ឃើញឈាមសោះឡើយ ។ ទឹកមុខរបស់ *ក្លាក់ថន* ពោរពេញទៅដោយភាពងោកងុយ និងបង្ហាញទឹកមុខរបស់មនុស្សម្នាក់ដែលទើបគេចផុតពីក្រញ៉ាំមច្ចុរាជទាំងប្រផិតប្រផើយ ។ ជាទឹកមុខដ៏ស្លេកស្លាំង តែមិនមែនជាទឹកមុខមនុស្សកំសាកញីនោះឡើយ :

- តែកុងមានត្រូវរបួសទេ ?

- ខ្ញុំស្ដាប់មិនយល់ទេ ។

---

*(*) : នាមព្រះធ្យានិពុទ្ធ ដែលពួកពុទ្ធសាសនិកខាងមហាយានកំនត់ " អមិតាភៈ រឺ អមិតា រឺ អមិតាយុស រឺ អមីដា...." ។*



www.budinst.gov.kh www.elibraryofcambodia.org

*ណាកា* ដើរទៅជិត បើកចំហតីម៉ូណូសំរាប់គេងដើម្បីអោយដឹងច្បាស់ថា តើ *ភ្លាក់ផន* មានរបួសអីក៏អត់ ។ រំពេចនោះគេក៏ឃើញ *ភ្លាក់ផន* ត្រវីក្បាល ហើយនិយាយឡើង :

- អូ ! យល់ហើយ អីល្ងូវនេះ ! ទេ អត់មានរបួសទេ ។

*ណាកា* ឆ្លើយតប :

- ល្អ !

រួចគេក៏ងាកទៅរកលោកស្រី *គីរី* វិញ :

- មើលទៅគាត់គ្មានរបួសអីទេ *គីរីស៊ូប៊ូ-សាន* ។

នៅពេលដែលឃើញ *ភ្លាក់ផន* ចង្អុលទៅសាកសពឃាតក ហើយនិយាយប៉ប៉ាច់នោះ *ណាកា* ក៏និយាយទៅវិញ :

- ខ្ញុំមិនដឹងថា លោកចង់និយាយពីអីទេ ។ *អាន់ជិន-សាន* លោកនៅទីនេះហើយ ។

រួចគេក៏ងាកទៅបញ្ជាបុរសម្នាក់ដែលនៅក្បែរនោះ ។

- ទៅយកម្ហូបម្ហាខ្លះមកជូនគាត់ ហើយបើគាត់ចង់ផឹកយកស្រាមកជូនគាត់ផង ។

លោកស្រី *គីរី* សួរទៅកាន់ *ណាកា* :

- ឃាតកមានសាក់ថា " *អមិតា* " មែនទេ ?

- បាទ មែនហើយលោកស្រី ។

- បិសាច ! ចំជាបិសាចមែន !

- ពិតជាអីចឹងមែនហើយលោកស្រី ។

*ណាកា* លំអោនខ្លួនគោរពលោកស្រី *គីរី* រួចងាកទៅរកកូនទាហានរបស់ខ្លួនម្នាក់ដែលកំពុងតែនៅស្ងន់ស្ងោនៅឡើយ :

- អ្នែងមកតាមខ្ញុំ ហើយយូរក្បាលវាមកផង !

រួចគេក៏ដើរចេញយ៉ាងរហ័សរហួន ទាំងជញ្ជឹងសួរនៅក្នុងចិត្តថា តើគេត្រូវប្រាប់ឪពុករបស់គេយ៉ាងដូចម្ដេច ? ឱព្រះអង្គអើយព្រះអង្គ !

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* និយាយយ៉ាងកំបុត១ :

- វាគឺជាពួក *វ៉ូនីន* លោកមិនងាយស៊ើបពីវាឡើយ *ហ៊្សូ ម៉ាត់ស៊ី-សាន* ។

- បាទទាន តែគឺ *អ៊ីស៊ីដូ* ដែលទទួលខុសត្រូវក្នុងរឿងនេះ ។ វាធ្វើអីចឹង គឺវាគ្មានគិតពីរឿងកិត្តិយសអ្វីទាំងអស់ ។ វាប្រើសុទ្ធតែអាពួកឃាតកថោកទាបទាំងអស់នេះ ។ សូមលោកម្ចាស់អោយខ្ញុំបាទប្រមូលទ័ពយើងភ្លាមទៅទាន ។ ខ្ញុំចាត់ការរឿងនេះអោយវាដាច់ស្រលះតែម្តងទៅទាន ។

- ទេ !

ភ្នែករបស់ *តូរ៉ាណាកា* ងាកទៅរក *ណាកា* វិញម្តង :

- ឯងច្បាស់ហើយអ្វី ថា *អាន់ជីន - សាន* អត់មានរបួសទេនោះ ?

- បាទ ច្បាស់ហើយលោកម្ចាស់ ។

- *ហ៊្សូ-ម៉ាត់ស៊ី-សាន* ! លោកត្រូវដកងារពួកអ្នកយាមវេននេះទាំងអស់គ្នា ព្រោះពួកវាបំពេញភារកិច្ចខ្លួនឯងមិនបាន ។ ពួកវាគ្មានសិទ្ធិធ្វើ *សិបពូគូ* ទេ ។ ពួកវាត្រូវរស់នៅដោយមានភាពអាម៉ាស់នេះ នៅជាប់នឹងថ្ងាសពួកវាមាំអាយ៉ុស ។ អោយវាទៅជាទាហានថ្នាក់ទាបបំផុត ។ អាអ្នកយាមដែលគេសំលាប់បាននោះ ត្រូវតែអូសជើងកាត់បន្ទាយ និងកាត់ក្រុងយកទៅចោលនៅឯកន្លែងពិឃាតមនុស្សទៅ ។ ទុកអោយឆ្កែចាត់ចែងវាចុះ ។

ពេលនេះ *តូរ៉ាណាកា* ចោលភ្នែកសំលឹងមើល *ណាកា* ជាកូនប្រុសរបស់លោកម្តង ។ កាលពីព្រលប់នេះ ដំណឹងបន្ទាន់ត្រូវបាននាំមកពីវត្ត *យ៉ូដូ* នៅ *ណាកូយ៉ា* ស្តីពីការគំរាមកំហែងរបស់ *អ៊ីស៊ីដូ* ទៅលើ *ណាកា* ។ ពេលនោះ *តូរ៉ាណាកា* បានបញ្ជាអោយកូនរបស់លោកនៅត្រឹមទីកន្លែងជុំវិញខ្លួនលោក ហើយជានិច្ចកាលមានកងការពារនៅអមជាប់ ។ សមាជិកក្រុមគ្រួសាររបស់លោក ដែលបានមករស់នៅក្នុងវិមាន *អូសាកា* គឺលោកស្រី *គីរី* និង *សាស៊ូកូ* ក៏ត្រូវបានយាមការពារយ៉ាងមធ្យ័តណាស់ដែរ ។ សារដែលទទួលបានពីលោកតាមេវត្តបានបន្ថែមថា ជាការល្អគេគួរតែលែងម្តាយរបស់ *អ៊ីស៊ីដូ* ហើយបញ្ជូនមកទីក្រុងវិញជាមួយស្រីបំរើទាំងអស់របស់លោកស្រីវិញ ព្រោះដូចជាសារបានបញ្ជាក់ហើយថា : "អាត្មាមិនហ៊ានប្រថុយយកជីវិតកូនប្រុស



www.budinst.gov.kh www.elibraryofcambodia.org

ដ៏អង់អាចរបស់លោកមកលលេងទទេៗនោះទេ អ្វីដែលអាក្រក់ណាស់ទៅទៀត គឺសុខ
របស់លោកស្រីមិនល្អទាល់តែសោះ ។ គាត់មានកើតជំងឺផ្តាសាយយ៉ាងធ្ងន់ធ្ងរ ។ យកល្អ
អោយលោកស្រីទទួលមរណភាពនៅក្នុងផ្ទះរបស់លោកស្រីផ្ទាល់ ជាជាងនៅក្នុងវត្តនេះ " ។

*តូរ៉ាណាកា* បន្លឺសំលេងយ៉ាងត្រជាក់ស្រេង និងយ៉ាងជូរចត់ :

- *ណាកា- សាន* ! អ្នែងក៏ទទួលខុសត្រូវផងដែរ ចំពោះប្រការដែលពួកឃាតក
ក្នុងទីនេះរួច ។ *សាមូរ៉ៃ* ទាំងអស់ត្រូវតែទទួលខុសត្រូវ ទោះជាក្នុងវេនយាមក្តីផុតវេនយា
ទោះកំពុងដេកលក់ រឺមិនទាន់ដេកលក់ក្តី ។ ប្រាក់បំនាច់ប្រចាំឆ្នាំរបស់អ្នែងនឹងកាត់បន្ថយ
កណ្តាល ។

*ណាកា* សែនភ្ញាក់ផ្អើលនឹងទណ្ឌកម្មដ៏ស្រាលនេះ !

- ប្របាទម្ចាស់ ! សូមលោកម្ចាស់ទំលាក់បុណ្យស័ក្តិរបស់ខ្ញុំផងចុះ ។ ខ្ញុំមិនអាច
នៅក្នុងក្តីអាម៉ាស់បែបនេះទេ ។ កង្វះខាតនេះក៏ជាកំហុសរបស់ខ្ញុំផងដែរទាន ។

-បើសិនជាអញចង់ទំលាក់បុណ្យស័ក្តិអ្នែង អញធ្វើហើយ ។ អ្នែងត្រូវទៅ *យេដូ* 
យប់នេះភ្លាម ជាមួយទាហានម្នែនាក់ ដើម្បីរាយការណ៍ប្រាប់បងរបស់អ្នែង ។ ទៅអោយ
*យេដូ* អោយបានយ៉ាងរហ័សបំផុត ។ ទៅចុះ !

*ណាកា* លំអោនខ្លួនគោរព ហើយដើរចេញទៅទាំងមុខស្លេកស្លាំង ។ *តូរ៉ាណាកា*
ងាកមកនិយាយជាមួយ *ហ៊ីរ៉ូ-ម៉ាត់ស៊ឹ* ទាំងសំដីម៉ាត់ៗផងដែរ :

- បន្ថែមកងការពារខ្ញុំមួយជាប្ងន ។ លុបចោលការបរបាញ់របស់ខ្ញុំនៅថ្ងៃនេះ និង
ស្អែកចោលទៅ ។ ប្រជុំក្រុមអាផ្ទានុសិទ្ធិហើយបានមួយថ្ងៃ ខ្ញុំនឹងចេញពី *អូសាកា* ភ្លាម ។ លេ
ត្រូវរៀបចំកិច្ចការអោយរហ័សអស់ជាស្រេច ហើយមុនដល់ថ្ងៃកំនត់នេះ ខ្ញុំនឹងនៅទីនេះ ។
មិនជួបអ្នកណាដែលខ្ញុំមិនបានអញ្ជើញទេ ។ តែម្នាក់ក៏គ្មានដែរ ។

និយាយរួច លោកធ្វើសញ្ញាទាំងកំហឹងអោយអ្នកទាំងអស់គ្នាថយចេញ :

- ពួកអ្នែងទាំងអស់គ្នា ចេញទៅក្រៅចុះ ។ *ហ៊ីរ៉ូ -ម៉ាត់ស៊ឹ* លោកនៅទីនេះហើយ
ទាំងអស់គ្នាចេញពីបន្ទប់យ៉ាងស្ងៀមស្ងាត់ ។ *ហ៊ីរ៉ូ-ម៉ាត់ស៊ឹ* សែនរីករាយនៅក្នុងចិត្ត ចំពោះប្រ



www.budinst.gov.kh www.elibraryofcambodia.org

ដែលគ្មានអ្នកណាម្នាក់នៅដើម្បីមើលឃើញភាពអាម៉ាស់របស់លោក ព្រោះថាក្នុងឋានៈជាមេបញ្ជាការកងអង្គរក្ស លោកគឺជាអ្នកទទួលកំហុសដ៏ធ្ងន់បំផុត :

- ខ្ញុំបាទ គ្មានពាក្យអ្វីនិយាយទៀតទេទាន ។ គ្មានសោះឡើយ ។

*តូរ៉ាណាកា* ហាក់ដូចជាភ្លឹកនៅក្នុងការសញ្ជឹងគិត ។ នៅលើមុខលោកគ្មានស្នាមកំហឹងបន្តិចបន្តួចណានៅសេសសល់ទៀតឡើយ :

- បើសិនជាលោកត្រូវការប្រើពួកក្រុមសំងាត់ *អមិតា-គុង* តើលោកធ្វើយ៉ាងម៉េចដើម្បីរកពួកវាឃើញ ? តើលោកទាក់ទងពួកវាតាមរបៀបណា ?

- ខ្ញុំបាទមិនដឹងទេលោកម្ចាស់ ។

- អ្នកណាដឹង ?

- *កាស៊ុគី យ៉ាប៊ូ* !

*តូរ៉ាណាកា* ចោលភ្នែកសំលឹងទៅក្រៅតាមចន្លោះបង្អួច ។ ពន្លឺព្រាល១នៃពេលព្រឹកព្រលឹមកំពុងស្ថិតនៅលាយឡំក្នុងស្បែងមឹតនាបូព៌ាទិសនៅឡើយ :

- ព្រលឹមនេះនាំ *យ៉ាប៊ូ* មកជួបខ្ញុំ ។

- លោកម្ចាស់យល់ថា វាជាអ្នកទទួលខុសត្រូវក្នុងរឿងនេះរឺ ?

*តូរ៉ាណាកា* ឥតឆ្លើយតបនឹងសំនួរនេះឡើយ ដោយអារម្មណ៍របស់លោកកំពុងតែលង់លក់នៅក្នុងការគិតគូរយ៉ាងជ្រាលជ្រៅ ។

នៅទីបំផុត មេទ័ពចំនាស់លែងទ្រាំទ្រនឹងភាពស្ងាត់ស្ងៀមនេះលែងបានតទៅទៀត :

- លោកម្ចាស់ សូមអោយខ្ញុំបាទចេញផុតពីមុខមាត់របស់លោកម្ចាស់ទៅចុះ ។ ខ្ញុំខ្មាសគេណាស់ ដែលធ្វេះធ្វោយការងារបែបនេះ.....

*តូរ៉ាណាកា* និយាយកាត់ :

- ចង់បង្ការការប៉ុនប៉ងទាំងនេះទៅមិនរួចទេ ។

- បាទទាន ។ ប៉ុន្តែយ៉ាងហោចណាស់ក៏យើងគួរស្ទាក់វាបាននៅឯខាងក្រៅនោះ មិន



www.budinst.gov.kh www.elibraryofcambodia.org

ត្រូវបណ្តោយអោយវាមកដល់កៀកខ្លួនលោកម្ចាស់អីចឹងទេ ។

- ខ្ញុំឯកភាព ។ តែខ្ញុំមិនចាត់ថាលោកជាអ្នកទទួលខុសត្រូវទេ ។

- តែគឺខ្ញុំបាទខ្លួនឯងដែលដាក់កំហុសខ្លួនឯងលោកម្ចាស់ ! ព្រោះខ្ញុំបាទគឺជាអ្នកទទួលខុសត្រូវលើសន្តិសុខរបស់លោកម្ចាស់ រហូតដល់ពេលដែលលោកម្ចាស់ត្រលប់ទៅដល់យេដូវិញ។ ទៅមុខទៀតនឹងកាន់តែមានការប៉ុនប៉ងធ្វើឃាតលើរូបលោកម្ចាស់កាន់តែច្រើនឡើងៗ ជាមិនខាន ។ ម្យ៉ាងទៀតអ្នកយកការណ៍យើងក៏បានរាយការណ៍ពីកំនើនចលនាទ័ពផងដែរ ។ *អ៊ីស៊ីដូ* កំពុងកេណ្ឌទ័ពហើយទាន ។

*តូរ៉ាណាកា* និយាយបែបវាហ៊ី :

- ពិតហើយ ។ បន្ទាប់ពី *យ៉ាប៊ូ* ខ្ញុំចង់ជួប *ឈូតូ-សាន* រួចជួប *ម៉ារីកូ-សាន* បន្ថែមកងការពារ *អាន់ជីន-សាន* មួយជាពីរផង ។

- សារដែលបានមកដល់កាលពីយប់មិញនេះ បានអោយដឹងថា លោកម្ចាស់ *អូណូស៊ី* កំពុងតែប្រើមនុស្សជាងមួយសែននាក់អោយពង្រឹងបន្ទាយរបស់ខ្លួន ។

សំលេងរបស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* ពោរពេញទៅដោយភាពកង្វល់ចំពោះសន្តិសុខរបស់លោក *តូរ៉ាណាកា* ។ ប៉ុន្តែសំលេងរបស់លោក *តូរ៉ាណាកា* នៅតែរក្សាភាពសោះអង្កើយដដែល :

- ខ្ញុំបាទដូចជាលែងយល់លោកម្ចាស់អស់រលីងហើយនេះ ! ខ្ញុំបាទត្រូវតែជំរាបលោកម្ចាស់ថា លោកម្ចាស់នឹងបាត់បង់អ្វីៗទាំងអស់យ៉ាងឆោតបំផុត ។ ពិតណាស់ទាន គឺយ៉ាងឆោតមែនណា ! ហើយខ្ញុំបាទមិនខ្លាចទេ ទោះជាត្រូវដាច់ក្បាលធ្លាក់ដល់ដីក៏ដោយ ក៏ការពិតវានៅតែជាការពិតដដែល ។ បើសិនជា *គីយ៉ាម៉ា* និង *អូណូស៊ី* បោះឆ្នោតខាង *អ៊ីស៊ីដូ* នោះ លោកម្ចាស់ប្រាកដជាត្រូវគេធីបទៅម្ខាងជាមិនខាន ។ លោកម្ចាស់នឹងត្រូវទុកដូចជាមនុស្សស្លាប់បាត់ទៅហើយ ។ ប្រការដែលលោកម្ចាស់មកទីនេះ គឺពិតជាការប្រថុយស្បែកមែនទែន ហើយលោកម្ចាស់បានចាញ់ហើយអីលូវនេះ ! សូមលោកម្ចាស់គេចខ្លួនទៅទាន់នៅមានឱកាស ព្រោះយ៉ាងហោចណាស់ក៏លោកម្ចាស់នៅសល់ក្បាលជាប់ នឹងស្មាលោកម្ចាស់នៅឡើយដែរ ។

- ព្រោះថ្នាក់មិនទាន់មាននៅឡើយទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ចុះការប៉ងធ្វើឃាតយប់មិញនេះ មិនបានបង្ហាញអ្វីជូនលោកម្ចាស់ទេរឺ ? បើសិនជាលោកម្ចាស់មិនដូរបន្ទប់ម្តងទៀតទេ ប្រហែលជាពេលនេះលោកម្ចាស់ស្លាប់បាត់ទៅហើយ ។

*តូរ៉ាណាកា* តប :

- ពិតហើយ រឺក៏អាចជាមិនពិតដែរក៏បាន ។ យប់នេះក៏ដូចជាយប់ម្សិលមានផ្កាំស្ទេកស្កះនៅមុខបន្ទប់របស់ខ្ញុំ ។ រួចយប់នេះលោកក៏ត្រូវវេនយាមផងដែរ ។ ឃាតកមួយណាក៏មិនអាចចូលជិតខ្ញុំបានដែរ ។ សូម្បីតែអាមួយនេះដែលបានរៀបចំយ៉ាងល្អក្តី ។ មិនឃើញវាស្គាល់ផ្លូវយ៉ាងច្បាស់ទេអ្វី សូម្បីតែពាក្យសំងាត់ក៏វាដឹងដែរមែនទេ? *គីរី* បានប្រាប់ថា នាងបានលឺវាប្រើពាក្យសំងាត់នេះណា ។ ហេតុនេះបានជាខ្ញុំគិតថា វាដឹងច្បាស់ណាស់ថា តើខ្ញុំនៅក្នុងបន្ទប់ណាមួយនោះ ។ ខ្ញុំមិនមែនជាមុខសញ្ញារបស់វាទេ ។ គឺ *អាន់ជីន-សាន* ដែលជាជុំសាច់ត្រូវត្រូវបាក់នោះ ។

- អាចុងស្រុកណុង ?

- ណឹងហើយ ។

ក្រោយពីការបើកកកាយនូវរឿងរ៉ាវដ៏អស្ចារ្យ កាលពីព្រឹកមិញនេះមក *តូរ៉ាណាកា* ដឹងច្បាស់ណាស់ថា បុរសចុងស្រុកនេះពិតជានឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់យ៉ាងច្រើនជាមិនខាន ។ ជាការច្បាស់ណាស់ដែលថា ចំពោះអ្នកមួយចំនួន *អាន់ជីន-សាន* មានជីវិតរស់នៅគឺពិតជាមហាគ្រោះថ្នាក់ ។ ប៉ុន្តែលោកមិននឹកស្មានថា ការវាយប្រហារនេះនឹងត្រូវធ្វើឡើងនៅក្នុងទីតាំងរបស់លោក ហើយនិងយ៉ាងរហ័សបែបនេះសោះ ។ តើអ្នកណាក្បត់អញអ៊ីចេះ ? លោកបានផាត់ចេញនូវលទ្ធភាពក្បត់ដែលមានលេចចេញពី *គីរី* រឺពី *មារិកូ* ។ ប៉ុន្តែទាំងក្នុងវិមាន ទាំងក្នុងសួនច្បារ សុទ្ធតែមានកន្លែងសំងាត់ដើម្បីយកការណ៍ជានិច្ច ។ អញនៅក្នុងជំរំខ្មាំង -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត- ហើយបើក្នុងទីនេះអញមានអ្នកយកការណ៍របស់អញម្នាក់ *អ៊ីស៊ីដូ* និងអ្នកឯទៀតពិតជាមានម្តែជាមិនខាន ។ មើលទៅរឿងនេះ គឺមកពីពួកយកការណ៍ទេមើល.ទៅ ។

- បង្កើនកងការពារ *អាន់ជីន - សាន* មួយជាពីរទៅ ។ ចំពោះខ្ញុំវាមានតំលៃស្មើនឹង



www.budinst.gov.kh www.elibraryofcambodia.org

មនុស្សរាប់ពាន់នាក់ណាំ ។

ព្រឹកមិញនេះ ក្រោយពីជំទាវ *យ៉ូរ៉ូកូ* បានចាកចេញទៅ *តូរ៉ាណាកា* បានវិ
មកផ្ទះតែវិញ ។ ទើបតែនៅពេលនោះទេ ដែលលោកបានកត់សំគាល់ពីភាពហេវហត់
កាយ ពីភាពថមថយផ្នែកឆន្ទៈ ហើយនិងពន្លឺភ្នែកដ៏ត្រចះត្រចង់របស់ *ប្លាក់ថន* ។ ដោ
នេះ ទើបលោកបានខិតខំរំងាប់ចិត្តពុះកញ្ជ្រោល ដែលចង់ដឹងរឿងច្រើនទៀតនោះ 
អនុញ្ញាតអោយ *ប្លាក់ថន* ចេញទៅដោយប្រាប់ថា នឹងបន្តទៅថ្ងៃស្អែកទៀត ។ *អាន់*
ត្រូវបានប្រគល់អោយ *គីរី* ជាអ្នកទទួលបីបាច់ថែទាំ ដោយតំរូវអោយទៅរកគ្រូពេទ្
កំលាំងហើយបើសិនជា *ប្លាក់ថន* ចង់ត្រូវរៀបចំម្ហូបរបស់ពួកអ្នកចុងស្រុកអោយថែមទៀ
មិនតែប៉ុណ្ណោះ *ប្លាក់ថន* ត្រូវបានគេយកមកសំរាកនៅក្នុងបន្ទប់មួយដែល *តូរ៉ាណាកា*
សំរាក នៅទីនោះថែមទៀតផង ។

ពេលនោះ *តូរ៉ាណាកា* បានណែនាំ *គីរី* ដោយផ្ទាល់ថា :

-អ្វីដែលអូនយល់ថាជាការចាំបាច់សូមអូនផ្តល់អោយវាទាំងអស់ទៅចុះ *គីរី*-
ខ្ញុំត្រូវការអោយវារឹងមាំទាំឡើងវិញយ៉ាងរហ័ស ហើយទាំងចិត្តទាំងប្រាណបានស្រ
បំផុត ។

រួច *អាន់ជីសាន* ក៏មានសំនួមពរ សូមគេដោះលែងសង្ឃមួយអង្គនោះនៅថ្ងៃ
ដែរ ដោយហេតុថា សង្ឃនោះចាស់ ហើយអាពាធទៀតផង ។ *តូរ៉ាណាកា* បានប្រាប់ទេ
លោកនឹងពិចារណាមើលសំនួមពរនេះ រួចលោកបានអោយ *ប្លាក់ថន* ត្រលប់ទៅវិញដោ
និយាយប្រាប់ថា លោកបានបញ្ជូនពួកសាមូរ៉ៃទៅមន្ទីរគុក ហើយអោយនាំយកសង
ឡើយ ។ ចំពោះ *តូរ៉ាណាកា* សង្ឃនោះក៏មានតំលៃមិនចាញ់ *ប្លាក់ថន* ប៉ុន្មានទេ ទាំងចំ
លោក ទាំងចំពោះ *អ៊ីស៊ីដូ* ។

*តូរ៉ាណាកា* បានដឹងពីវត្តមានរបស់សង្ឃអង្គនេះ ជាយូរយារមកហើយ។ ថែម
ថា សង្ឃនេះមានសញ្ជាតិអេស្ប៉ាញ ហើយជាសត្រូវនឹងពួកប៉កទុយកាល់ ទៀតផង ។ ប៉ុ
នេះត្រូវបានចាប់ដាក់គុកដោយបញ្ជារបស់ *តែតូ* ពោលគឺលោកជាអ្នកទោសរបស់ *តែតូ*



www.budinst.gov.kh www.elibraryofcambodia.org

ទៀត *អូសាកា* នេះ មិនមែនស្ថិតនៅក្រោមដែនអំនាចច្បាប់របស់ *តូយ៉ូណាកា* ឡើយ ។ ដោយហេតុនេះ ការបញ្ជូន *អាន់ជីន-សាន* ទៅគុកនោះគឺមិនមែនជាការចៃដន្យទេ ។ម្យ៉ាងដើម្បីរំងាប់ចិត្ត *អ៊ីស៊ីដូ* អោយយល់ថាមនុស្សចុងស្រុកនេះគ្មានបានការ គ្មានតំលៃអ្វីទាំងអស់ ម្យ៉ាងទៀតដើម្បីអោយតៃកុង ដ៏រហ័សរហួននេះ អាចឆ្លៀតស្រូបយកចំនេះដឹងរបស់សង្ឃនេះផង ។

ការប៉ុនប៉ងទាំងកំរោលយកជីវិតរបស់ *អាន់ជីន-សាន* នៅក្នុងគុកត្រូវបរាជ័យ ហើយចាប់ពីពេលនោះមក រនាំងការពារមួយត្រូវបានចាត់តាំងឡើងនៅជុំវិញខ្លួនគេ ។ *តូយ៉ូណាកា* បានអោយរង្វាន់ដល់ចារបុរសជាអណ្ដាប់របស់លោកឈ្មោះ *មីទី គុី* ដែលជាបុរសស្ដែង ដោយបានយកមនុស្សនេះចេញពីគុក ហើយនឹងផ្ដល់អ្នកស្នេងប្អូនទាក់របស់លោកផ្ទាល់ដល់បុរសនេះថែមទៀត ។ មិនតែប៉ុណ្ណោះ *មីទី គុី* មានសិទ្ធិគំនកូនចៅក្នុងការធ្វើអាជីវកម្មនៅលើមួយកំនាត់ផ្លូវនៃវិថី *តូកៃដូ* ដែលជាផ្លូវសំខាន់តភ្ជាប់ទីក្រុង យេដូ និង អូសាកា ពោលគឺជាកំនាត់ផ្លូវដែលស្ថិតនៅក្រោមដែនអំនាចរបស់ *តូយ៉ូណាកា* នោះឯង ។ *មីទីគុី* ត្រូវបានគេនាំចេញពី *អូសាកា* ជាសំងាត់នៅថ្ងៃទីមួយ ដែលគេរួចចេញពីគុកនោះម្ល៉េះ ។ បន្ទាប់ពីថ្ងៃមានរឿងនៅក្នុងគុកនោះមក អ្នកយកការណ៍ផ្សេងៗទៀត បានបញ្ជូនពត៌មានមកប្រាប់ *តូយ៉ូណាកា* ថា លោកសង្ឃ និង *ប្លាក់ថន* បានក្លាយជាមិត្តនឹងគ្នាយ៉ាងល្អ ។ លោកសង្ឃជាអ្នកនិយាយ ឯ *ប្លាក់ថន* ជាអ្នកសួរសំនួរ និង ស្ដាប់ ។

ចំពោះប្រការដែល *អ៊ីស៊ីដូ* មានអ្នកយកការណ៍របស់ខ្លួននៅក្នុងគុកដែរនោះ មិនធ្វើអោយ *តូយ៉ូណាកា* ខ្វល់ប៉ុន្មានទេ ។ *អាន់ជីន-សាន* មានគេការពារ និង មានសុវត្ថិភាពគ្រប់គ្រាន់ ។ រួចស្រាប់តែ *អ៊ីស៊ីដូ* សំរេចយក *អាន់ជីន-សាន* ចេញពីគុកដោយឥតមានព្រាងទុកសំដៅដកបុរសនេះទៅដាក់ក្រោមឥទ្ធិពលមនុស្សផ្សេងទៅវិញ ។

*តូយ៉ូណាកា* រំលឹកឡើងវិញពីការសប្បាយចិត្តដែលរូបលោកនឹង *ម៉ារីូ-ម៉ាត់ស៊ី* មានមុខនៅពេលដែលលោករៀបចំ " ការពួនស្ទាក់ " ជាបន្ទាន់នោះ ។ តាមពិតទៅ " ពួកចោរ *រ៉ូនីន* " គឺគ្មានពួកណាក្រៅពីពួកក្រុមសាមូរ៉ៃ ជើងឆើតរបស់លោកដែលត្រូវបំបែកជាក្រុមតូចៗ ជាច់ៗ



www.budinst.gov.kh www.elibraryofcambodia.org

ពីគ្នា ហើយដែលកំពុងមានវត្តមាននៅក្នុង និងជុំវិញទីក្រុង អូសាកានោះឡើយ ។ លោកបាន រៀបចំផែនការដើម្បីធ្វើយ៉ាងណាអោយ *យ៉ាប៊ូ* លេចមុខចំពេលនោះហើយចេញមុខ "សង្គ្រោះ" ។ កាលនោះអ្នកទាំងពីរសើចឡើងរលាក់ខ្លួន ដោយ *យ៉ាប៊ូ* ត្រូវដើរតួជាអាយ៉ងម្តងទៀតក្នុងផែន ការបំបាក់មុខ *អ៊ីស៊ីដូ* នេះ ។

អ្វីៗក៏ត្រូវបានសំរេចយ៉ាងល្អ ។ រហូតមកដល់ថ្ងៃនេះ ។

ថ្ងៃនេះ *សាមូរ៉ៃ* ដែលលោកបានបញ្ជូនទៅយកសង្ឃនោះ បានវិលត្រលប់មកវិញ ដោយដៃទទេស្អាត ។

- សង្ឃនោះសុគតបាត់ទៅហើយទាន- បុរសនោះរាយការណ៍ -នៅពេលដែលគេ ហៅព្រះនាម លោកឥតបានចេញមកខាងក្រៅទេ ។ អ្នកទោសដែលនៅជុំវិញលោកបានប្រាប់ ថា នៅពេលដែលឆ្មាំគុកហៅព្រះនាមលោកៗ ដួលតូងតែម្តង ។ ពេលខ្ញុំបានទៅថ្វាវលោកឡើង លោកសុគតបាត់ទៅហើយ ។ សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំបាទផងទាន លោកម្ចាស់ អោយខ្ញុំបាទទៅនាំលោកមក ហើយខ្ញុំបាទនាំមកមិនបាន ។ ខ្ញុំបាទមិនដឹងថា លោកម្ចាស់ ចង់បានព្រះកេសលោក រឺចង់បានសាកសពទាំងមូលទេ ព្រោះលោកជាអ្នកចុងស្រុក អ៊ីចឹងហើយ ទើបខ្ញុំបាទយកសាកសពទាំងមូល ទាំងក្បាលនៅជាប់ស្មានោះមកជូនលោកម្ចាស់សិនទាន ។ ពួកអ្នកទោសមួយចំនួនដែលនៅជុំវិញលោកនិយាយថា ពួកវាគឺជាសាវ័ករបស់លោក ហើយ ពួកវាចង់រាំងរាមិនអោយខ្ញុំបាទយកសាកសពចេញទេទាន ។ ខ្ញុំបាទក៏បានសំលាប់ចោលអស់ ប៉ុន្មាននាក់ទៅ ទើបយកសពនេះមកបាន ។ អីលូវនេះសពនេះនៅឯទីធ្លាទាន ។

ហេតុអីបានជាសង្ឃនេះសុគតអ៊ីចឹង ? -*តូរ៉ាណាកា* ដណ្តឹងសួរនៅក្នុងចិត្ត ។ រំពេច នោះលោកប្រទះឃើញក្រសែភ្នែករបស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* ដែលសំលឹងមករកលោកនោះពោរពេញ ទៅដោយសំនួរ :

- យ៉ាងម៉េច *ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* ?

- ខ្ញុំចង់ដឹងថា អ្នកណាចង់អោយតែគុងនេះស្លាប់ ?

- ពួកគ្រិស្តសាសនិក ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

*កាស៊ីគី* *យ៉ាប៊ូ* ដើរពីក្រោយ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* តាមបណ្តោយរបៀង ។ បរិយាកាសនាពេលព្រឹកព្រលឹមធ្វើអោយគេមានអារម្មណ៍យ៉ាងធំធេងមហិមា ។ ជំនោរខ្យល់រំភើយបាននាំមកនូវរសជាតិអំបិលដ៏គួរអោយឆ្ងាញ់ ហើយដែលធ្វើអោយ *យ៉ាប៊ូ* រំលឹកដល់ *មីស៊ីម៉ា* ទីក្រុងដែលគេធ្លាប់រស់នៅ ។ គេសប្បាយចិត្តណាស់ ដែលនៅទីបញ្ចប់គេអាចចួលជួប *តូរ៉ាណាកា* ហើយបញ្ចប់នូវការរង់ចាំដ៏យូរលង់របស់ខ្លួន ។ ព្រឹកព្រលឹមមិញនេះ *យ៉ាប៊ូ* បានមុជទឹក ហើយស្លៀក ពាក់យ៉ាងផ្ចិតផ្ចង់ ។ សំបុត្រចុងក្រោយត្រូវបានសរសេរហើយជាស្រេចសំរាប់ប្រពន្ធ និងម្តាយរបស់គេ ចំនែកឯបណ្តាំចុងក្រោយត្រូវបានបិទអាច់ល័ក្ខរួចរាល់ហើយជាស្រេច ដើម្បីបង្ការថាកិច្ចសន្ទនាអាចត្រលប់មកប្រឆាំងនឹងរូបគេវិញ ។ ថ្ងៃនេះគេស្ទៀតដាវរបស់ជាងដែឯក *មូរ៉ា សាម៉ា* ជាប់នៅនឹងខ្លួន ។

អ្នកទាំងពីរបត់មួយកែងទៀតទើប *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ច្រានទ្វារពាសដែកមួយ ហើយនាំ *យ៉ាប៊ូ* ឡើងតាមជណ្តើរថ្មមួយដែលនាំទៅភាគកណ្តាលនៃវិមាននេះ ។ នៅតាមនេះមានអ្នកយាមជាច្រើននាក់ដែលធ្វើអោយ *យ៉ាប៊ូ* ហិតក្លិនគ្រោះថ្នាក់បានភ្លាមមួយរំពេច ។

ជណ្តើរព័ទ្ធពេនជាគួចខ្សែងឡើងទៅលើ ។ នៅជាន់លើបំផុតដែលជាទីតាំងមានកិច្ចការពារយ៉ាងម៉ាំទាំនោះ អ្នកយាមបានបើកទ្វារដែកជូនដល់អ្នកទាំងពីរ ។ ពួកគេបានចេញមកដល់សើននៃវិមានហើយ ។ តើ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ត្រូវគេបញ្ជាអោយច្រានអញទំលាក់មួយអញត្រូវទទួលបញ្ជាអោយលោកទំលាក់ខ្លួនពីលើនេះ ? -*យ៉ាប៊ូ* ដណ្តឹងសួរយ៉ាងនឹងនរនៅក្នុងចិត្តដោយឥតមានគក់ស្លុតអ្វីបន្តិចសោះឡើយ ។

តែ *យ៉ាប៊ូ* សៃនភ្ញាក់ផ្អើលដោយគេប្រទះឃើញ *តូរ៉ាណាកា* មានវត្តមាននៅទីនោះដែរ ។ ហើយដែលរឹតតែមិនអាចជឿបាននោះគឺ *តូរ៉ាណាកា* ខ្លួនឯងបានក្រោកឡើង ហើយដើរមកទទួលរូបគេយ៉ាងរាក់ទាក់ និងយ៉ាងគួរសមបំផុត ។ តាមពិតទៅ ទោះដេកយល់សប្តិក៏ *យ៉ាប៊ូ* មិនជឿថា *តូរ៉ាណាកា* សំដែងអាកាៈបែបនេះឡើយ ព្រោះតាមពិតទៅ *តូរ៉ាណាកា* គឺជាអម្ចាស់ត្រួតលើប្រាំបីខេត្ត ចំនែកឯខ្លួនគេវិញគឺគ្រាន់តែជាអម្ចាស់ នៃតំបន់ *អ៊ីស៊ូ* មួយតែប៉ុណ្ណោះ ។ មិកអង្គុយត្រូវគេរៀបចំយ៉ាងម៉ត់ចត់ ។ ប៉ាន់តែមួយនៅសំងំក្នុងស្រោមមួយធ្វើអំពី



www.budinst.gov.kh www.elibraryofcambodia.org

សូត ។ នារីម្នាក់មានមុខជ្រុង សំរស់មធ្យម តែមានសំលៀកបំពាក់ដ៏មានតំលៃ លំអោនខ្លួនយ៉ាងទាបជាកិច្ចគោរព ។ នាងឈ្មោះ *សាស៊ូកូ* ហើយនាងជាប្រពន្ធចុងទីប្រាំពីរ របស់លោក *តូរ៉ាណាកា* ។ នាងជាប្រពន្ធក្មេងបំផុត ហើយនាងកំពុងពពោះផង ។

- រីករាយណាស់ដែលបានជួបលោក *កាស៊ីគី យ៉ាប៊ូ-សាន* ។ ខ្ញុំស្តាយណាស់ដែលអោយលោកនៅរង់ចាំយ៉ាងយូរបែបនេះ ។

អីលូវនេះ *យ៉ាប៊ូ* ជឿជាក់យ៉ាងច្បាស់នៅក្នុងចិត្តហើយថា *តូរ៉ាណាកា* បានសំរេចចិត្តយកក្បាលរបស់គេអោយទាល់តែបាន ទោះជាតាមរបៀបណាក៏ដោយ ។ ព្រោះជាធម្មតាសត្រូវរបស់យើងកាន់តែគួរសមណាស់នៅពេលដែលវាមានគំរោង រឺពេលដែលវាកំពុងគ្រោងបំផ្លាញយើងនោះ ។ គេហូតដាវទាំងពីររបស់គេចេញ ហើយដាក់ទៅលើកំរាលឥដ្ឋ ហើយដកខ្លួនឆ្ងាយពីអាវុធទាំងពីរនេះ ដើម្បីទៅអង្គុយនៅលើកន្លែងកិត្តិយសដែលរៀបចំហើយជាស្រេច ។

- ខ្ញុំគិតថា អង្គុយគយគន់មើលព្រះអាទិត្យរះ គឺពិតជាគួរអោយចាប់ចិត្តមែន *យ៉ាប៊ូ-សាន* ។ ខ្ញុំគិតថា ទិដ្ឋភាពទីកន្លែងនេះពិតជាល្អត្រកាលហើយ ។ ពិតជាល្អត្រកាលជាងមើលពីលើប៉មធំរបស់ទាយាទទៅទៀត មែនទេ ?

- បាទ ពិតជាល្អត្រកាលមែន ។

*យ៉ាប៊ូ* ឆ្លើយតបយ៉ាងរហ័សដោយឥតស្ទាក់ស្ទើរ ។ នេះជាលើកទីមួយហើយដែលគេបានឡើងមកជាន់យ៉ាងខ្ពស់នៃវិមានបែបនេះ ហើយគេក៏ជឿជាក់ថា សំដីរបស់ *តូរ៉ាណាកា* អំពី " ទាយាទ " នោះ មានន័យថា ការចរចាជាសំងាត់រវាងរូបគេ នឹង *អ៊ីស៊ីដូ* ត្រូវបានគេដឹងហើយ ។ *យ៉ាប៊ូ* បន្តទៀត :

- ខ្ញុំបាទមានកិត្តិយសណាស់ ដែលបានលោកម្ចាស់អនុញ្ញាតអោយមកចូលរួមក្នុងឱកាសនេះ ។

នៅក្រោមក្រសែភ្នែករបស់អ្នកទាំងពីរ គឺជាទីក្រុងដែលកំពុងលង់លក់ក្នុងនិទ្រានៅឡើយ ព្រមទាំងកំពង់ផែ ហើយនិងកោះទាំងឡាយ ។ ពន្លឺដែលចេះតែភ្លឺឡើង ៗ នៅឯខាងកើតនោះកំពុងតែចាប់ផ្តើមចិញ្ច្រាំបំបែកដុំពពក ដោយកំទេចក្រហមជាំរបស់ខ្លួនហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- នេះគឺជាអ្នកផ្ទះរបស់ខ្ញុំឈ្មោះ *សាស៊ូកូ* ។ *សាស៊ូកូ* ! នេះគឺជាសម្ព័ន្ធមិត្តរបស់ខ្ញុំ គឺលោកម្ចាស់*កាស៊ុគី យ៉ាប៊ូ* ដ៏ល្បីល្បាញនៃតំបន់*អ៊ីស៊ូ* នោះឯង ។ លោកគឺជាដៃមីញ្ជូ ដែលនាំមនុស្សចុងស្រុក និងសំពៅកំនប់មកអោយយើងនោះឯង !

*សាស៊ូកូ* លំអោនខ្លួនគោរព ព្រមទាំងពោលពាក្យស្ញើចសរសើរមិនដាច់ពីមាត់ផង ។ *យ៉ាប៊ូ* លំអោនខ្លួនគោរព ហើយនាងក៏លំអោនខ្លួនសងវិញម្តងទៀត រួចនាងក៏ចាក់តែហុចជូនទៅ *យ៉ាប៊ូ* ជាដំបូងគេ ប៉ុន្តែ*យ៉ាប៊ូ* បានប្រកែកយ៉ាងសុភាពរាបសាទាមទារជូនទៅ*តូរ៉ាណាកា* នូវពែងកិត្តិយសដំបូងនេះ ។ ក្រោយពីការជូនគ្នាចុះឡើងជាកិច្ចគួរសមនោះមក *យ៉ាប៊ូ* ក៏ទទួលយកពែងកិត្តិយសនេះក្នុងឋានៈខ្លួនជាភ្ញៀវ ។ *ប៊្លូ-ម៉ាត់ស៊ី* ទទួលយកពែងទីពីរ ។ ម្រាមដៃធំអឹងរបស់លោកកាន់ពែងព័រសីឡែនយ៉ាងលំបាក ឯដៃម្ខាងទៀតនៅតែក្តាប់ដាវរបស់លោកត្រឹមពាក់កណ្តាលស្រោម ។ *តូរ៉ាណាកា* ទទួលយកពែងទីបី ហើយបន្ទាប់ពីចិបតែបន្តិចមកអ្នកទាំងបីក៏ព្រលែងខ្លួននៅក្នុងធម្មជាតិ បណ្តោយអោយព្រលឹងខ្លួនហោះហើរទៅតាមអរុណរះកណ្តាលនភាល័យដ៏ស្ងប់ស្ងៀមឈឹងនេះ ។

សត្វរំពេហើរស្រែកខ្សៀវខ្សា ។ សំលេងអ៊ូអររបស់ទីក្រុងក៏ចាប់ផ្តើមលាន់លឺឡើង ។ ទិវាថ្មីមួយទៀតបានចាប់ផ្តើមហើយ ។

អ្នកស្រី *សាស៊ូកូ* ដកដង្ហើមធំប្រកបដោយទឹកភ្នែករលីងរលោង :

- នៅអង្គុយយ៉ាងខ្ពស់សំលឹងមើលទេសភាពទាំងនេះ ធ្វើអោយមានអារម្មណ៍ដូចជាទេវតាមួយអង្គអីចឹងដែរ មែនទេ ? ស្តាយណាស់ដែលសំរស់ទាំងនេះនឹងរលាយបាត់ជារៀងរហូត មែនទេលោកម្ចាស់ ? គួរអោយស្តាយណាស់ មែនទេ ?

- មែនហើយ- *តូរ៉ាណាកា* តប ។

នៅពេលដែលព្រះអាទិត្យលេចឡើងបានពាក់កណ្តាលហើយនោះ *សាស៊ូកូ* ក៏លំអោនខ្លួនគោរពលាចេញទៅ ។ ប៉ុន្តែអ្វីដែលធ្វើអោយ*យ៉ាប៊ូ* ភ្ញាក់ផ្អើលបំផុតនោះ គឺកងការពារក៏បានចាកចេញទៅដែរ ។ អីលូវនេះពួកគេនៅតែឯងហើយ ។ ពួកគេទាំងបីនាក់ ។

*តូរ៉ាណាកា* ក៏ចាប់ផ្តើមនិយាយ :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំសប្បាយចិត្តណាស់ ដែលបានទទួលជំនូនរបស់លោក *យ៉ាំប៉ូ-សាន* ។ នេះបានចំជាទូលាយមែន ដែលលោកអោយខ្ញុំទាំងសំពៅ ទាំងអីវ៉ាន់យ៉ាងនេះ ។

*យ៉ាំប៉ូ* ឆ្លើយតបទាំងអារម្មណ៍នៅដក់ជាប់នៅឡើយលើទិដ្ឋភាពពេលអរុណរះនេះ :

- អ្វីដែលខ្ញុំបាទមាន គឺជារបស់លោកម្ចាស់ហើយ ។

និយាយបណ្ដើរ *យ៉ាំប៉ូ* គិតក្នុងចិត្តបណ្ដើរ ។ អញសូមអោយតែមានពេលច្រើនជាងនេះទៅទៀតចុះ ។ *តូរ៉ាណាកា* ចំជាឡូយមែនតែម្ដង ។ យ៉ាងម៉េចយ៉ាងម៉ាបានអោយអញឃើញវិសាលភាពដ៏ធំធេងជាលើកចុងក្រោយម្ដងទៀតដែរ ។ រួចគេបន្ត :

- សូមអរគុណណាស់ចំពោះអរុណោទ័យនេះ ។

- បាទ- *តូរ៉ាណាកា* ឆ្លើយតប-នេះគឺខ្ញុំត្រូវជូនអីវិញទៅលោកហើយ ។ ខ្ញុំរីករាយណាស់ ដែលលោកពេញចិត្តនឹងជំនូនខ្ញុំ ដូចខ្ញុំពេញចិត្តនឹងជំនូនលោកអីចឹងដែរ ។

ភាពស្ងៀមស្ងាត់បានស្ថិតមាននៅមួយរយៈ ។

- *យ៉ាំប៉ូ-សាន* ។ តើលោកដឹងអីខ្លះទៅពីក្រុម *អាមីតា-កុង* ទេ ?

- ខ្ញុំបាទគ្រាន់តែដឹងដូចគេដូចឯងដឹងអីចឹងទេទាន ។ នេះជាសមាគមសំងាត់ក្នុងមួយតួបដំបន់នាក់ ។ ក្នុងម៉ាកខ្លែងមានមេមួយ និងកូនក្រុមមិនលើសពីប្រាំបួននាក់ដាច់ខាត ។ ប្រាំបួននាក់នេះមានស្រី មានប្រុស ។ ពួកវាសុទ្ធតែបានស្បថស្បែដោយយកព្រះជាបន្ទាល់ ថាពួកវាប្ដេជ្ញាគោរពបញ្ជាដាច់ខាត ហើយស្ម័គ្រស្លាប់ឥតរួញរា ព្រមទាំងរក្សាបរិសុទ្ធភាពឥតប្រលាក់ប្រលូសសោះឡើយ ។ ពួកវាប្ដេជ្ញាបូជាជីវិតដើម្បីរីកបាត់ ពត់លត់ដំខ្លួនពួកវាអោយក្លាយទៅជាឧបករណ៍ដ៏សុក្រិតសំរាប់តែរឿងសំលាប់តែមួយមុខគត់ ។ សំលាប់នៅពេលណាដែលមានបញ្ជារបស់មេពួកវាតែប៉ុណ្ណោះ ហើយបើសិនជាពួកវាបរាជ័យក្នុងការសំលាប់មនុស្ស ដែលជាមុខសញ្ញា ទោះជាប្រុសក្ដី ស្រីក្ដី រឺក្មេងក្ដី ពួកវានឹងសំលាប់ខ្លួនភ្លាមមួយរំពេច ។ ពួកវាជាសាសនិកងប់ដែលយល់ថា ពួកវាឈានពីជីវិតនេះទៅដល់និព្វានត្រង់តែម្ដង ។ តាំងពីដើមរៀងមក គ្មានអ្នកណាដែលចាប់បានពួកវាទាំងរស់សោះឡើយ ។

*យ៉ាំប៉ូ* បានដឹងរួចមកហើយ ពីរឿងការប៉ុនប៉ងធ្វើឃាតលើរូបលោក *តូរ៉ាណាកា* នេះ ។



www.budinst.gov.kh www.elibraryofcambodia.org

ទីក្រុង*អូសាកា* ទាំងមូលក៏បានដឹងដែរ ។ ទាំងអស់ថែមទាំងដឹងទៀតថា អម្ចាស់លើខេត្តទាំងប្រាំបីនេះបានរស់នៅយ៉ាងសុខសាន្តក្នុងសំណាញ់ដែកថែបដ៏រឹងមាំ ដែលគ្មានអ្នកណាចូលចុះឡើយ ។

- ពួកវាយូរ ១ សំលាប់ម្តង ។ ហើយពួកវាលាក់ការណ៍ជិតឈឹងតែម្តង ។ គ្មានអ្នកណាអាចតាមសង្ស័យពួកវាបានទេ ព្រោះគ្មានអ្នកណាដឹងថា ពួកវាជាអ្នកណារស់នៅឯណា រឺហាត់នៅឯណាឡើយ ។

- បើលោកត្រូវការប្រើពួកវា តើលោកធ្វើម៉េចទៅ ?

- ខ្ញុំបាទទៅខ្សិបនៅបីកន្លែង ។ នៅវត្ត*ហ៊ីណាន* នៅខ្លោងទ្វារវិហារ*អមិកា* និងនៅវត្ត *យូជី* ។ ក្នុងអំលុងពេលដប់ថ្ងៃ បើគេយល់ថា លោកជាអ្នកជួលត្រឹមត្រូវគួរទទួលបាន ពួកវាមកទាក់ទងតាមរយៈអ្នកកណ្តាលណាមួយ ។ ពួកវាធ្វើអ្វី ១ សុទ្ធតែលាក់ការណ៍យ៉ាងម៉ត់ចត់ ហើយក្រិចក្រវៀនណាស់ ដោយហេតុនេះហើយទោះជាលោកចង់ក្បត់ពួកវា រឺចង់ចាប់ពួកវា គឺមិនបានតែម្តង ។ ក្នុងថ្ងៃទីដប់ពួកគេនឹងប្រាប់ពីតំលៃជាលោហធាតុប្រាក់ ។ ថ្លៃប៉ុន្មាន ១ គឺអាស្រ័យលើឋានៈតួនាទីរបស់ដែលត្រូវសំលាប់ ។ រឿងតថ្លៃគឺគ្មានទេ ពួកវាទារថ្លៃប៉ុន្មានលោកត្រូវបង់ប៉ុណ្ណឹង ។ ពួកវាគ្រាន់តែសន្យាថា ក្នុងអំលុងពេលដប់ថ្ងៃកូនក្រុមរបស់ពួកវាម្នាក់នឹងសាកល្បងធ្វើឃាតអោយបាន ។ រឿងដែលគេនិយាយដំណាលត១គ្នា គឺថា បើសិនជាការសំលាប់មនុស្សបានជោគជ័យហើយ ឃាតកត្រូវវិលត្រលប់ទៅវិហារវិញ ហើយធ្វើពិធីអត្តឃាតតាមទំនៀមទំលាប់របស់ពួកគេហើយ ។

- បើអីចឹងលោកគិតថា យើងមិនអាចរកឃើញថាអ្នកណាជាអ្នកចេញលុយអោយមានការវៃលុកយប់មិញនេះទេ មែនទេ ?

- ពិតហើយទាន ។

- តើអាចមានការប៉ងសំលាប់បែបនេះទៀតទេ ?

- អាចមាន អាចមាន ។ ពួកវាចុះកិច្ចសន្យាម្តងសំរាប់ធ្វើការតែម្តងទេ ។ ប៉ុន្តែលោកម្ចាស់ពិតជាមានការវាងវៃក្នុងការពង្រឹងសន្តិសុខ របស់លោកម្ចាស់ជាមិនខាន ។ សន្តិសុខក្នុង



www.budinst.gov.kh www.elibraryofcambodia.org

ចំនោមពួកសាមូរ៉ៃរបស់លោកម្ចាស់ ក៏ដូចជាសន្តិសុខក្នុងចំនោមប្រពន្ធ ១ របស់លោកម្ចាស់។ ពួកនារី *អាមីតា* តែងទទួលការរ៉ុកហាត់ក្នុងការប្រើថ្នាំពុល ប្រើកាំបិត និងខ្សែរឹតក នេះបើតាមគេនិយាយទាន ។

- តើលោកដែលធ្លាប់ប្រើពួកវាទេ ?

- ទេ !

- ក្រែងឪពុកលោកធ្លាប់អ្វី ?

- ខ្ញុំបាទមិនដឹងដែរទាន គឺខ្ញុំបាទមិនច្បាស់ដែរទេ ។ គេបានប្រាប់ខ្ញុំបាទថា អម្ចាស់ *កែតូ* បានស្នើអោយឪពុកខ្ញុំបាទទាក់ទងពួកនេះម្តងដែរ ។

-តើការវ៉ៃប្រហារនោះបានជោគជ័យទេ ?

- អ្វី ១ ដែលអម្ចាស់ *កែតូ* ធ្វើសុទ្ធតែបានជោគជ័យទាំងអស់ទាន ។ បើមិនជោគជ័យរបៀបនេះ ក៏ជោគជ័យរបៀបនោះដែរ ។

*យ៉ាប៊ូ* មានអារម្មណ៍ហាក់ដូចជាមានមនុស្សនៅពីក្រោយខ្លួន ។ គេគិតថា ប្រាកដជាពួកការពារដែលលបវិលមកវិញយ៉ាងស្ងាត់ ១ ហើយ ។ នៅក្នុងចិត្តគេស្ទង់ប្រមាណចំងាយរវាងខ្លួនគេនឹងអាវុធរបស់គេ ។ តើអញគួរប្រថុយសំលាប់ *តូរ៉ាណាកា* សាកមើលរឺយ៉ាងម៉េច ? *យ៉ាប៊ូ* ដណ្តឹងសួរនៅក្នុងចិត្តម្តងទៀត ។ ពីមុនអញបានសំរេចចិត្តអីចឹង តែអីលូវនេះអញបែរជាមិនច្បាស់នៅក្នុងចិត្តទៅវិញ ។ អញប្តូរហើយ ។ តែតើហេតុអីទៅ ?

*តូរ៉ាណាកា* បន្លឺសំនួរបន្ត :

- តើលោកត្រូវបង់ប៉ុន្មាន ដើម្បីយកក្បាលរបស់ខ្ញុំ ?

- ទោះជាយកប្រាក់ម៉ាអាស៊ីនេះមកក៏ដោយ ក៏មិនអាចទាក់ទាញខ្ញុំបាទអោយប្រើពួកវាធ្វើការនេះដែរទាន ។

- ចុះបើជាអ្នកផ្សេងវិញ តើគេត្រូវបង់ថ្លៃប៉ុន្មាន ?

- ពីរម៉ឺន*កូកូ* ប្រាំម៉ឺន ដប់ម៉ឺន រឺក៏ច្រើនជាងនេះទៀតផងក៏មិនដឹង ខ្ញុំបាទមិនដឹងទេទាន ។



www.budinst.gov.kh www.elibraryofcambodia.org

- ដើម្បីក្លាយខ្លួនទៅជាអគ្គមហាសេនា តើលោកហ៊ានចំនាយដប់ម៉ឺន*កូកូ* ទេ ? ម្យ៉ាងទៀតសែស្រឡាយលោកបន្តមកពីត្រកូល*តាកាស៊ីមា*ដែរតើ មែនទេ ?

*យ៉ាំប៊ូ* ឆ្លើយតបក្នុងក្តីមោទនៈ :

- ខ្ញុំបាទមិនចំនាយអ្វីទាំងអស់ ។ ប្រាក់គឺជារឿងក្រខ្វក់មួយ ។ វាជាល្បែងសំរាប់ស្រី១ប្រលែងលេង រឺសំរាប់ពួកអាត្មាតអ្នករកស៊ីជួញដូរតែប៉ុណ្ណោះ ។ ប៉ុន្តែបើសិនជាអាចនោះ ហើយខ្ញុំដឹងថារឿងនេះវាមិនអាចទៅបានទេ នោះ ខ្ញុំសុខចិត្តដូរជីវិតខ្ញុំ ជីវិតប្រពន្ធខ្ញុំ ម៉ែខ្ញុំ និងពូជខ្ញុំទាំងអស់ លើកលែងតែកូនប្រុសខ្ញុំម្នាក់ ហើយនិងជីវិតសាមូរ៉ៃខ្ញុំម៉ាត់បន់*អ៊ីស៊ូ* ព្រមទាំងប្រពន្ធនិងកូនវាទាំងអស់ អោយតែខ្ញុំបាទបានធ្វើអគ្គមហាសេនាតែមួយថ្ងៃចុះ ។

- រួចចុះដើម្បីខេត្តទាំងប្រាំបី តើលោកហ៊ានចំនាយអីទៅ ?

- ដូចអំបាញ់មិញនេះដែរ លើកលែងតែជីវិតប្រពន្ធខ្ញុំ ម៉ែខ្ញុំ និងកូនប្រុសរបស់ខ្ញុំ ។

- ចុះដើម្បីខេត្ត*ស៊ូរូកា* ?

*យ៉ាំប៊ូ* ឆ្លើយតបដោយទឹកមុខមាក់ងាយ :

- គ្មានអ្វីទាំងអស់ ។ *អ៊ីកាវ៉ា ស៊ីគីយូ* គ្មានតំលៃតាក់តូចណាទេ ។ បើសិនជាជាតិនេះខ្ញុំយកក្បាលវា និងពូជត្រកូលវាមិនបានទេ ជាតិក្រោយខ្ញុំនឹងយកអោយទាល់តែបាន ។ ខ្ញុំបាញ់នោមច្រាសក្បាលវា និងកូនចៅរបស់វារាប់ពាន់ជាតិ ។

- រួចចុះបើសិនជាខ្ញុំប្រគល់វាជូនលោកវិញ ? រួចប្រគល់ខេត្ត *ស៊ូរូកា* ទាំងមូល រឺអាចថែមទាំងខេត្ត*តូតូមី* ដែលនៅជាប់គ្នានោះផងវិញ ?

*យ៉ាំប៊ូ* ចាប់ផ្តើមឡើយណាយនឹងល្បែងឆ្លាប្រលែងកណ្តុរ ហើយនិងការនិយាយពីរឿងក្រុម*អមិកា* នេះហើយ :

- លោកម្ចាស់បានសំរេចថា កាត់ក្បាលខ្ញុំបាទមែនទេ ? ល្អណាស់ ។ ខ្ញុំបាទត្រៀមខ្លួនជាស្រេចហើយទាន ។ សូមអរគុណលោកម្ចាស់ចំពោះអនុគ្រោះនេះ ប៉ុន្តែខ្ញុំមិនចង់ធ្វើអោយខូចសំរស់ទាំងនេះ ព្រោះតែការនិយាយបូរបាច់វែងអន្លាយនោះទេ ។ សូមលោកម្ចាស់ចាត់ការមកចុះ ។



www.budinst.gov.kh www.elibraryofcambodia.org

- ប៉ុន្តែខ្ញុំមានដែលសំរេចថា កាត់ក្បាលលោកពីអង្គាល់ *យ៉ាប៊ូ-សាទ* ? តើហេតុអ្វីបានជាលោកមានគំនិតបែបនេះ ? តើពួកសត្រូវបានបញ្ចូលពិសពុលតាមត្រចៀករបស់លោកទេដឹង ? រឺមួយជា *អ៊ីស៊ីដូ* ? ក្រែងលោកជាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធរបស់ខ្ញុំអ្វី ? តើលោកគិតថា ខ្ញុំនាំលោកមកកំសាន្តនៅកន្លែងនេះដោយគ្មានអ្នកការពារអីចឹងអ្វី បើសិនជាខ្ញុំចាត់លោកជាសត្រូវនោះ ?

*យ៉ាប៊ូ* ងាកមើលក្រោយយ៉ាងយឺត ។ គេរំពឹងថា នឹងប្រទះឃើញពួកសាមូរ៉ៃឈរយាមដាវជាស្រេចនៅពីក្រោយខ្លួនគេ ។ តែគ្មានសាមូរ៉ៃណាម្នាក់សោះឡើយ ។ *យ៉ាប៊ូ* ងាកមករក *តូរ៉ាណាកា* វិញ :

- ខ្ញុំមិនយល់ទេនេះ ។

- ខ្ញុំអញ្ជើញលោកមកទីនេះ ដើម្បីជជែកគ្នាតែពីរនាក់ ។ ហើយដើម្បីមើលអរុណរះផងដែរ ។ តើលោកចង់គ្រប់គ្រងខេត្ត *អ៊ីស៊ូ ស៊ូរូកា* និង *តូតូមី* ទេ បើសិនជាខ្ញុំមិនចាញ់សង្គ្រាមនេះ ?

សេចក្តីសង្ឃឹមរបស់ *យ៉ាប៊ូ* រីកធំឡើងហើយ :

- បាទចង់ ! ចង់ណាស់ទាន !

- តើលោកព្រមចំនុះធ្វើជាអណ្តាប់ខ្ញុំទេ? តើលោកព្រមទទួលខ្ញុំជាអម្ចាស់របស់លោកទេ ?

*យ៉ាប៊ូ* ឆ្លើយតបដោយឥតស្ទាក់ស្ទើរសោះឡើយ :

-ដាច់ខាតគឺទេ ។ បើជាសម្ព័ន្ធមិត្ត គឺយល់ព្រម ។ ទទួលលោកម្ចាស់ជាមេដឹកនាំ គឺយល់ព្រម ។ ទាបជាងលោកម្ចាស់គឺយល់ព្រម ។ យកជីវិតរបស់ខ្ញុំបាទ និង អ្វីៗ ដែលខ្ញុំបាទមានទៅខាងលោកម្ចាស់ គឺយល់ព្រម ។ ប៉ុន្តែ *អ៊ីស៊ូ* គឺជាទឹកដីខ្ញុំបាទ ។ ខ្ញុំបាទជាដៃមីញ៉ូនៃតំបន់ *អ៊ីស៊ូ* ហើយដាច់ខាតខ្ញុំបាទមិនប្រគល់អំនាចនេះ ទៅអោយអ្នកណាដាច់ខាត ។ ខ្ញុំបាទបានស្បថរឿងនេះនៅចំពោះមុខឪពុកខ្ញុំបាទ និងបន្ទាប់មកចំពោះមុខអម្ចាស់ *រ៉ៃកូ* ដែលបានទទួលស្គាល់គំនត្រកូលរបស់ខ្ញុំបាទនៅលើតំបន់នេះ ។ លោកម្ចាស់ *រ៉ៃកូ* គឺជាម្ចាស់តែមួយគត់របស់យើង ហើយខ្ញុំបាទបានស្បថថា នឹងមិនមានម្ចាស់ណាផ្សេងទៀតទេ រហូតដល់ទាយាទ



www.budinst.gov.kh www.elibraryofcambodia.org

អម្ចាស់ *តែកូ* ពេញវ័យ ។

*ហ៊្សី-មាត់ស៊ី* បង្វិលដាវមួយក្រឹកនៅក្នុងដៃ ។ ហេតុអីបានជាលោកម្ចាស់ *តូរ៉ាណាកា* មិនព្រមអោយអញចាត់ការអោយវារួចស្រលះតែម្តងទៅ ? ក្រែងឯកភាពគ្នាថាអីចឹងអ្ហី ? រួចម៉េចចាំបាច់និយាយវាងចុះវាងឡើងនាំខាតទឹកមាត់ធ្វើអី ? អញឡើងចុកខ្នងស្ទើរស្លាប់ទៅហើយ ។

*តូរ៉ាណាកា* យកដៃអេះក្តោងច្រមុះរបស់ខ្លួន :

- តើ *អ៊ីស៊ីដូ* សុខចិត្តប្រគល់អីដល់លោក ?

- ក្បាលរបស់ *ស៊ីតូយ៉ូ* ។ នៅពេលណាដែលក្បាលលោកម្ចាស់ដាច់ហើយ ។ ហើយនិងខេត្តរបស់វា ។

- ជាថ្នូរនឹងអី ?

- ដើម្បីគាំទ្រគាត់នៅពេលដែលសង្គ្រាមផ្ទុះឡើង ។ ពេលនោះខ្ញុំត្រូវវាយលុកឆ្លងជំនីរខាងត្បូងរបស់លោក ។

- តើលោកយល់ព្រមហើយអ្ហី ?

- លោកម្ចាស់ដឹងហើយថា ខ្ញុំបាទគ្រាន់បើជាងប៉ុណ្ណឹងដែរទាន ។

អ្នកយកការណ៍របស់ *តូរ៉ាណាកា* ដែលនៅបង្គប់ជុំវិញ *អ៊ីស៊ីដូ* បានអោយការណ៍ថាអ្នកទាំងពីរបានព្រមព្រៀងគ្នាលើលក្ខខណ្ឌនេះហើយ ។ មានរួមបញ្ចូលទាំងការកិច្ចធ្វើឃាតកូនប្រុសទាំងបីរបស់លោកថែមទៀតផង គឺ *ណូបូរូ ស៊ូដារ៉ា* និង *ណាកា* :

-គ្មានថ្នូរអីទៀតទេ ? គ្រាន់តែជួយគាំទ្រប៉ុណ្ណឹងអ្ហី ?

*យ៉ាប៊ូ* ឆ្លើយតបយ៉ាងប្រុងប្រយ័ត្ន :

- គាំទ្រតាមគ្រប់មធ្យោបាយដែលខ្ញុំបាទមាន ។

- រួមបញ្ចូលទាំងការធ្វើឃាតផងមែនទេ ?

- នៅពេលដែលសង្គ្រាមផ្ទុះឡើង ខ្ញុំបាទមានបំនងប្រើកំលាំងទាំងអស់ ដើម្បីធ្វើសង្គ្រាម ។ ដើម្បីសម្ព័ន្ធមិត្តរបស់ខ្ញុំបាទ ។ ទោះជាដោយរបៀបណាក៏ដោយ ខ្ញុំបាទអាចធានា



www.budinst.gov.kh www.elibraryofcambodia.org

អោយសម្ព័ន្ធមិត្តរបស់ខ្ញុំបានទទួលជ័យជំនះ ។ ក្នុងពេលដែល *វ៉េយទម៉ុន* មិនទាន់ពេញវ័យ យើងត្រូវការអាជ្ញានុសិទ្ធិតែម្នាក់ប៉ុណ្ណោះ ។ សង្គ្រាមរវាងលោកម្ចាស់នឹង *អ៊ីស៊ីដូ* មិនអាចចៀសបានទេ ។ នេះគឺជាផ្លូវតែមួយគត់ ។

*យ៉ាហ៊ូ* ប្រឹងស្វែងយល់ពីគំនិតរបស់ *តូរ៉ាណាកា* ។ គេប្រមាថ *តូរ៉ាណាកា* នៅលើភាពមិនដាច់ស្រេចនេះ ហើយគេរមែងគិតថា ខ្លួនគេពិតជាគ្រាន់បើជាង *តូរ៉ាណាកា* ហើយ *តូរ៉ាណាកា* នឹងត្រូវការ ការគាំទ្ររបស់គេ ។ នៅចុងបញ្ចប់គេពិតជាឈ្នះ *តូរ៉ាណាកា* ។ ប៉ុន្តែក្នុងចន្លោះពេលនេះតើត្រូវធើអី ? - *យ៉ាហ៊ូ* ដណ្តឹងសួរនៅក្នុងចិត្ត ។ គេស្តាយណាស់ដែល *យូរីកូ* ប្រពន្ធរបស់គេមិនបាននៅជិតដើម្បីផ្តល់មតិថា តើត្រូវធ្វើអ្វីនោះ ។ *យ៉ាហ៊ូ* បន្តទៀតដោយប្រថុយមួយចានទឹកមួយចានគោកតែម្តង :

- ខ្ញុំបាទពិតជាមានតំលៃច្រើនចំពោះលោកម្ចាស់ ។ ខ្ញុំបាទអាចជួយអោយលោកម្ចាស់ក្លាយជាអ្នកអាជ្ញានុសិទ្ធិតែម្នាក់ឯងគត់បាន ។

- ហេតុអ្វីបានជាខ្ញុំចង់ក្លាយទៅជាអ្នកអាជ្ញានុសិទ្ធិតែម្នាក់ឯងនោះ ?

*យ៉ាហ៊ូ* នៅតែនិយាយបន្ត :

- បើសិនជា *អ៊ីស៊ីដូ* បើកការវាយលុក ខ្ញុំបាទអាចជួយលោកម្ចាស់អោយប្រាមប្រាបគាត់បាន ។ នៅពេលណាដែលគាត់សំរេចបំផ្លាញសន្តិភាពហើយនោះ ។

- ជួយបែបណា ?

*យ៉ាហ៊ូ* និយាយរ៉ាយរ៉ាប់ប្រាប់ *តូរ៉ាណាកា* អំពីផែនការរបស់ខ្លួន អំពីរឿងកាំភ្លើង ។ *ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* ភ្ញាក់ច្រលោតដូចជាន់ដុំភ្លើងអីចឹង :

- ថាម៉េច ? ម៉ាអង្គភាពប្រាំរយសាមូរ៉ៃ ប្រដាប់ដោយកាំភ្លើងអ្វី ?

- បាទ ។ ហើយសូមគិតមើល តើកំលាំងកាំភ្លើងនោះវាយ៉ាងណាទៅ ។ ឯខ្មាន់កាំភ្លើងក៏សុទ្ធតែជាពួកជើងអើតទាំងអស់ ហើយពួកវាធ្វើសកម្មភាពដូចមនុស្សតែម្នាក់អីចឹង ។ កាណុងរាំងម្តេដើមក៏ដូចគ្នាអីចឹងដែរ ។

*ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* ឆ្លើយតប :



www.budinst.gov.kh www.elibraryofcambodia.org

- នេះជាផែនការអន់ណាស់ ។ គួរអោយឆ្អើមតែម្តង ។ លោកឯងលាក់ការណ៍បែប

នេះជិតអ្វី ? តែយើងចាប់ផ្តើមកំរើក ខ្មាំងក៏វាកំរើកដែរ ។ ដល់អីចឹងវាងាយអីនឹងចប់ ? ម្យ៉ាង

ទៀតអារឿងនេះគ្មានអ្វីជាផ្លែផ្កាសោះ ហើយរឹតតែគ្មានអនាគតទៅទៀត ។

*យ៉ាប៊ូ* និយាយតបវិញ :

- ក្រែងយើងទាំងអស់គ្នាមិនសុទ្ធតែទាក់ទិនទៅនឹងសង្គ្រាមខាងមុខនេះទេអ្វី *ហ្ស៊ី-មាត់ស៊ឺ* ? ក្រែងយើងទាំងអស់គ្នាសុទ្ធតែខ្វាយខ្វល់នឹងសន្តិសុខរបស់លោកម្ចាស់ទេអ្វី ?

- ពិតហើយ ។

- អ្វីដែលសំខាន់ គឺលោកម្ចាស់ *តូរ៉ាណាកា* ត្រូវឈ្នះការប្រយុទ្ធដ៏ធំតែមួយប៉ុណ្ណោះ ។ ប្រការនោះនឹងអាចអោយលោកម្ចាស់កាត់ក្បាលសត្រូវរបស់លោកម្ចាស់ទាំងអស់បាន...ហើយ និងអំនាចថែមទៀត ។ ខ្ញុំយល់ថា យុទ្ធសាស្ត្រនេះនឹងអាចអោយលោកម្ចាស់ដណ្តើមយកជ័យជំនះបាន ។

- ខ្ញុំថាអត់ ។ នេះជាផែនការដ៏គួរអោយឆ្អើម ហើយគ្មានកិត្តិយសអីបន្តិចបន្តួចណាសោះ ។

*យ៉ាប៊ូ* ងាកបែរខ្លួនទៅរក *តូរ៉ាណាកា* វិញ :

- សម័យថ្មីទាមទារការយល់ដឹងច្បាស់លាស់អំពីអត្ថន័យនៃពាក្យកិត្តិយសទាន ។ សត្រូវពេមួយបានហើរលែងក្បាលរបស់ពួកគេ ដោយបញ្ចេញសំលេងខ្សៀវខ្សារ ។

*តូរ៉ាណាកា* សួរតបទៅវិញ :

- តើ *អ៊ីស៊ីដូ* មានមតិយ៉ាងម៉េចទេអំពីផែនការរបស់លោក ?

- ខ្ញុំបាទមិនបានជជែកផែនការនេះជាមួយគាត់ទេ ។

- ហេតុអី ? បើលោកយល់ថា ផែនការនេះមានតំលៃចំពោះខ្ញុំក៏ពិតជាវាមានតំលៃចំពោះវាផងដែរ ។ អាចថាមានតំលៃជាងផងក៏មិនដឹង ។

- លោកម្ចាស់បានផ្តល់អនុគ្រោះដល់ខ្ញុំបាទ ។ លោកម្ចាស់មិនមែនមនុស្សសំរេចដូចជា *អ៊ីស៊ីដូ* នោះទេ ។ លោកម្ចាស់ជាមនុស្សវាងវៃបំផុត ជាមេដឹកនាំដ៏មានបទពិសោធន៍បំផុតនៅ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងចក្រភពនេះ ។

តើអ្វីដែលជាមូលហេតុពិតប្រាកដរបស់វាទៅ ? *តូរ៉ាណាកា* ដណ្តឹងសួរនៅក្នុងចិត្ត ។ រឺមួយអ្ហែងបាននិយាយប្រាប់*អ៊ីស៊ីដូ*ដែរទេអ្ហី ?

- បើសិនជាផែនការនេះត្រូវអនុវត្ត ទ័ពពាក់កណ្តាលគឺជារបស់លោកនិងពាក់កណ្តាលគឺជារបស់ខ្ញុំអ្ហី ?

- យល់ព្រម ។ តែខ្ញុំបាទជាមេបញ្ជាការ ។

- បើអីចឹងមនុស្សដែលខ្ញុំចាត់តាំងនឹងជាមេបញ្ជាការរងអ្ហី ?

- យល់ព្រម ។ ខ្ញុំបាទត្រូវការ *អាន់ជីន-សាន* ដើម្បីរីកហាត់ទ័ពខ្ញុំសំរាប់ប្រើកាំភ្លើងនិងប្រើកាណុង ។

- តែមនុស្សនេះនឹងស្ថិតនៅជាកម្មសិទ្ធិរបស់ខ្ញុំជាអចិន្ត្រៃយ៍ ហើយលោកត្រូវថ្លាក់ថ្នមវាដូចជាលោកថ្លាក់ថ្នមទាយាទអីចឹង តើលោកព្រមទេ ? លោកត្រូវទទួលខុសត្រូវទាំងស្រុងលើរូបវា ហើយលោកប្រព្រឹត្តអ្វី ៗ ជាមួយវាតាមខ្ញុំប្រាប់ តើលោកព្រមទេ ?

- យល់ព្រម ។

*តូរ៉ាណាកា* សំលឹងមើលពពកដែលមានពណ៌ក្រហមក្រមៅមួយសន្ទុះ ។ ផែនការនេះគ្មានន័យអ្វីទាំងអស់-លោកគិតនៅក្នុងចិត្ត ។ អញត្រូវប្រកាស " ផ្ទៃមេឃក្រហម " ដោយខ្លួនអញ ហើយនាំទ័ពអញទាំងអស់វាយលុក*ក្យូតូ*ភ្លាម ។ ដប់ម៉ឺនទល់នឹងកំលាំងលើសនេះដប់ដង...

- តើអ្នកណានឹងធ្វើជាអ្នកបកប្រែ ? ខ្ញុំមិនអាចចាត់តាំង*តូដា យារីកូ-សាន* ម៉ាហ្សូត នោះទេ ។

- តែប៉ុន្មានអាទិត្យក៏មិនបានដែរអ្ហីទាន ? ខ្ញុំនឹងចាត់ចែងអោយមនុស្សចុងស្រុកនេះរៀនភាសាយើងទាន ។

- នេះស៊ីមិនតិចឆ្នាំទេ ។ ពួកចុងស្រុកដែលអាចនិយាយបានស្រួលបួល មានតែពួកសង្ឃគ្រិស្តសាសនាតែប៉ុណ្ណោះ មែនទេ ? ហើយនេះពួកវាប្រើពេលរាប់ឆ្នាំ ។ *ឈូតូ-សាន* មករស់នៅស្រុកយើងនេះប៉ុន្មានឆ្នាំហើយ ? សាមសិបឆ្នាំ ! យ៉ាងនេះពិតជា*អាន់ជីន-សាន* រៀន



www.budinst.gov.kh www.elibraryofcambodia.org

មិនបានលឿនតាមចិត្តរបស់យើងទេ ក៏ដូចជាយើងមិនអាចរៀនភាសាចំកួតរបស់ពួកវាអីចឹង ។

- ពិតមែនហើយទាន ។ តែខ្ញុំបាទសន្យាថា *អាន់ជីន-សាន* នឹងរៀនចេះបានរហ័សទាន ។

រួច *យ៉ាប៊ូ* ក៏រាយរ៉ាប់ដល់ *តូរ៉ាណាកា* នូវផែនការដែល *អូមី* បានជូនយោបល់ប្រៀបបីដូចជាគំនិតខ្លួនគេផ្ទាល់អីចឹង ។

- អារឿងនេះដូចជាគ្រោះថ្នាក់ណាស់ ។

-តែនេះអាចអោយវារៀនឆាប់ចេះទាន ។ រួចម្យ៉ាងទៀតវានឹងសាំងផង ។

ក្រោយពីស្ងៀមមួយសន្ទុះ *តូរ៉ាណាកា* សួរបន្តទៀត :

- តើលោកធ្វើយ៉ាងណា ដើម្បីរក្សាការណ៍សំងាត់បានម៉ាក្នុងរយៈពេលវឹកទ័ពនេះ ?

- *អ៊ីស៊ូ* គឺជាឧបទ្វីប ហេតុនេះសន្តិសុខគឺធានាបានគំរិតខ្ពស់ណាស់ទាន ។ ខ្ញុំបាទនឹងរៀបចំមូលដ្ឋាននៅក្បែរ *អាន់ជីរ៉ូ* នៅភាគខាងត្បូងបំផុត ហើយឆ្ងាយពី *មីស៊ីម៉ា* និងពីព្រំដែនខេត្ត ដើម្បីធានាសន្តិសុខអោយបានខ្ពស់ទាន ។

- ល្អ ។ យើងនឹងចាត់តាំងខ្សែរយៈព្រាបនាំសារពី *អាន់ជីរ៉ូ* មក *អូសាកា* និង *យេដូ* នេះតែម្រ៉ង ។

- ល្អណាស់ ។ ខ្ញុំបាទត្រូវការតែប្រាំ រឺប្រាំមួយខែតែប៉ុណ្ណោះ ហើយ...

*ហ៊ីរ៉ូ-ម៉ាត់ស៊ី* និយាយចំអកកាត់ :

- យើងនៅបានប្រាំមួយថ្ងៃទៀត គឺវាសំនាងណាស់ទៅហើយ *យ៉ាប៊ូ-សាន* ។ តើលោកចង់និយាយថា បណ្តាញយកការណ៍ដ៏ល្បីល្បាញរបស់លោកត្រូវតែបោសកំទេចហើយអ្ហី ? លោកពិតជាទទួលរបាយការណ៍ដែរមែនទេ ? តើ *អ៊ីស៊ីដូ* មិនកំពុងកេណ្ឌទ័ពទេអ្ហី ? តើ *អូណូស៊ី* មិនកំពុងកេណ្ឌទ័ពទេអ្ហី ? តើយើងមិនកំពុងតែជាប់ស្នេញនៅក្នុងទីនេះទេអ្ហី ?

*យ៉ាប៊ូ* នៅស្ងៀមឥតមានឆ្លើយតបឡើយ ។

*តូរ៉ាណាកា* ក៏សួរទៅ *យ៉ាប៊ូ* ឡើង :

- យ៉ាងម៉េច ?



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៊ូ* ឆ្លើយតប ៖

- របាយការណ៍បានប្រាប់ពីហេតុការណ៍ទាំងអស់នេះមែន ហើយច្រើនជាងនេះទៀតផង ។ តែបើប្រាំមួយថ្ងៃនោះគឺប្រាំមួយថ្ងៃហើយ ១ នេះគឺជា*កាម៉ា* ។ តែខ្ញុំបាទជឿថា លោកម្ចាស់ពិតជាវាងវៃ មិនមែនបណ្តោយខ្លួនអោយជាប់ជុំចនៅទីនេះទេ ។ រីកលោកម្ចាស់មិនឆោតអ្វីទៅបង្កសង្គ្រាមរហ័សពេកដែរ ។

- បើខ្ញុំឯកភាពនឹងផែនការរបស់លោក តើលោកនឹងព្រមទទួលខ្ញុំជាមេដឹកនាំលោកទេ ?

- យល់ព្រម ។ ហើយនៅពេលដែលលោកម្ចាស់ឈ្នះ ខ្ញុំបាទនឹងមានកិត្តិយសបានទទួលខេត្ត*ស៊ូរ៉ុកា* និង *តូតូមី* ជាដែនដីក្រោមការត្រួតត្រារបស់ខ្ញុំបាទជារៀងរហូតមែនទេលោកម្ចាស់ ?

- រឿងខេត្ត*តូតូមី*គឺអាស្រ័យលើជោគជ័យនៃផែនការរបស់លោក ។

- យល់ព្រម ។

- លោកទទួលគោរពខ្ញុំទេ ? លោកហ៊ានយកកិត្តិយសជាបន្ទាល់ទេ ?

- យល់ព្រម ។ ដោយយកវិន័យ*ប៊ូស៊ីដូ* យកព្រះជាម្ចាស់ យកជីវិតម៉ែខ្ញុំបាទ ប្រពន្ធខ្ញុំបាទ និង ពូជអំបូរខ្ញុំបាទជាបន្ទាល់ទាន ។

*តូរ៉ាណាកា* បន្លឺឡើង ៖

- ល្អណាស់ ។ មក ! យើងនោមលើកិច្ចព្រមព្រៀងនេះ

*តូរ៉ាណាកា* ងើបឡើងហើយដើរទៅជ្រុងកំផែង ហើយហក់ឡើងលើបង្កាន់ដៃជញ្ជាំង ។ សួនច្បារផ្ទៃខាងក្នុងស្ថិតនៅប្រហែលជាងម្ភៃម៉ែតនៅខាងក្រោម ។ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ស្ទើរលែងហ៊ានដកដង្ហើម ដោយស្រឡាំងកាំងនឹងសេចក្តីក្លាហានហួសហេតុរបស់អម្ចាស់ខ្លួន ។ លោកឃើញ *តូរ៉ាណាកា* បែរខ្លួន ហើយធ្វើសញ្ញាអោយ*យ៉ាប៊ូ* ឡើងមកឈរក្បែរខ្លួន ។ *យ៉ាប៊ូ* ធ្វើតាមបញ្ជានេះ ។ នៅទីកន្លែងនេះគ្រាន់តែប៉ះតែបន្តិចក៏គេអាចបញ្ជូនអ្នកទាំងពីរនេះទៅគាល់យមរាជបានដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* បន្ទូរតិម្ទូណ្ហខ្លួន បង្អិលស្បែស្លាប់ភ្លៅ ។ *យ៉ាប៊ូ* ក៏ធ្វើយ៉ាងដូច្នេះដែរ ។ គេបាញ់នោមដំណាលគ្នា បញ្ចូលទឹកនោមជាមួយគ្នាអោយស្រោចស្រពសួនច្បារដែលនៅឯខាងក្រោមនោះ ។

ក្រោយពីការបន្ទូរខ្លួនហើយ *តូរ៉ាណាកា* បន្ថឹទ្បើង :

- កិច្ចព្រមព្រៀងចុងក្រោយដែលខ្ញុំបានភ្ជាប់របៀបនេះ គឺធ្វើជាមួយអម្ចាស់ *វ៉ែតកូ* តែម្តង ។ កាលនោះគឺនៅពេលដែលគាត់សំរេចប្រគល់ *ក្វាន់តូ* និង ខេត្តប្រាំបីមកអោយជាដែនដីខ្ញុំគ្រប់គ្រង ។ កាលនោះគឺតំបន់ ទាំងនោះត្រូវកាន់កាប់ដោយពួក *ហូចូ* នៅឡើយ ។ ហេតុនេះខ្ញុំត្រូវប្រាមប្រាបយកសិន ។ នោះគឺជាសំបុកទប់ទល់ចុងក្រោយបំផុតរបស់សត្រូវ ។ ពិតហើយ ខ្ញុំក៏មិនត្រូវទាមទារដែនដីដែលខ្ញុំត្រួតត្រាបន្តត្រកូលមកវិញដែរ គឺ *អ៊ីម៉ាកាវ៉ា អូវ៉ារី* និង *អ៊ីសេ* ។ ទោះជាយ៉ាងនេះក្តីខ្ញុំក៏បានយល់ព្រម ហើយយើងបានបាញ់នោមទទួលស្គាល់កិច្ចព្រមព្រៀងនេះ ។

*តូរ៉ាណាកា* ឈរលើបង្កាន់ដៃយ៉ាងបែបវាហី ហើយសំរូលស្បែស្លាប់ភ្លៅយ៉ាង ស្រួលប្រែបបីដូចលោកកំពុងឈរលើសួនច្បារនៅខាងក្រោមនេះអីចឹង មិនមែនឈរទុំដូចខ្លែងយ៉ាងខ្ពស់បែបនោះឡើយ ។ លោកបន្តសំដីទៅទៀត :

- នោះគឺជាកិច្ចព្រមព្រៀងមួយយ៉ាងល្អសំរាប់យើងទាំងពីរនាក់ ។ យើងវ៉ៃឈ្នះ *ហូចូ* ហើយកាត់ក្បាលបានជាងប្រាំពាន់ទៀតក្នុងរយៈពេលមួយឆ្នាំ ។ ទាំង *ហូចូ* ទាំងបក្ខពួកវាត្រូវយើងកំទេចម៉ត់ ។ មើលទៅលោកប្រហែលយល់ត្រូវមែន *កាស៊ីគី យ៉ាប៊ូ-សាន* ។ ប្រហែលជាលោកអាចជួយខ្ញុំ ដូចកាលខ្ញុំជួយអម្ចាស់ *វ៉ែតកូ* អីចឹង ។ បើគ្មានខ្ញុំ អម្ចាស់ *វ៉ែតកូ* នឹងមិនក្លាយជាអម្ចាស់ *វ៉ែតកូ* ឡើយ ។

-ខ្ញុំបាទអាចជួយលោកម្ចាស់អោយក្លាយទៅជាអ្នកអាជ្ញានុសិទ្ធិតែម្នាក់ឯង *តូរ៉ាណាកា-សាមា* តែមិនមែនជាអគ្គមហាសេនាទេ ។

- ពិតណាស់ហើយ ។ នេះជាកិត្តិយសតែមួយគត់ដែលខ្ញុំមិនចង់ស្វះស្វែងបាន ទោះជាសត្រូវនិយាយយ៉ាងណាក៏ដោយ ។



www.budinst.gov.kh www.elibraryofcambodia.org

*គូរ៉ាណាកា* លោតចុះមកលើអិដ្ឋវិញយ៉ាងចូវល្អែង ។ លោកងាកក្រោយបែរទៅ មើល *យ៉ាប៊ូ* ដែលកំពុងតែឈរសំរូលសំលៀកបំពាក់នៅលើបង្កាន់ដៃនៅឡើយ ។ លោកស្ទើរតែស្ទុះទៅរុញ *យ៉ាប៊ូ* ទំលាក់ទៅក្រោមព្រោះតែភាពព្រហើនរបស់មនុស្សនេះ ប៉ុន្តែលោកខំទ្រាំអត់ដាក់បង្គុយចុះ ហើយដើរខ្យល់យ៉ាងខ្លាំង :

- អើ អីចឹងទៅដូចជាចូរបន្តិច ។ រួចយ៉ាងម៉េចហើយដៃដែកមិនបន្ទូរចេញនឹងគេខែអ្វី ?

- ហត់ណាស់លោកម្ចាស់ ! ហត់ណាស់ ។

មេទ័ពចំនាស់ក្រោកឡើង ហើយទៅបន្ទោរបង់នឹងគេពីលើកំផែងនោះដែរ ប៉ុន្តែលោកមិនឈរនៅកន្លែងដែល *គូរ៉ាណាកា* និង *យ៉ាប៊ូ* នៅឈរអំបាញ់មិញនោះទេ ។ *ហ៊ីរ៉ូ- ម៉ាត់ស៊ុ* ក៏សប្បាយចិត្តណាស់ដែរ ដែលលោកមិនបានភ្ជាប់កិច្ចព្រមព្រៀងជាមួយ *យ៉ាប៊ូ* នោះ ។ បើសិនជាមាន នេះគឺកិច្ចព្រមព្រៀងតែមួយគត់ដែលអញនឹងមិនអនុវត្តតាមដាច់ខាត ។ ដាច់ខាតតែម្តង ។

-*យ៉ាប៊ូ-សាន* ។ ទាំងអស់នេះត្រូវលាក់ការណ៍អោយបានជិត ។ ខ្ញុំគិតថា លោកត្រូវតែចេញដំណើរក្នុងពីរថ្ងៃខាងមុខនេះ ។

- បាទ ។ ទៅជាមួយមនុស្សចុងស្រុក និង ជាមួយកាំភ្លើង រឺ *គូរ៉ាណាកា* សាម៉ា ?

- ណឹងហើយ ។ លោកនឹងធ្វើដំណើរតាមផ្លូវទឹក ។

រួច *គូរ៉ាណាកា* ងាកបែរអោយបញ្ជាទៅ *ហ៊ីរ៉ូ-ម៉ាត់ស៊ុ* :

- រៀបចំទូកធំ !

*ហ៊ីរ៉ូ-ម៉ាត់ស៊ុ* ឆ្លើយតបដោយទាំងសំដែងទឹកមុខមិនឯកភាពផង :

- ទូកត្រៀមហើយស្រេច ។ កាំភ្លើង និងរំសេវនៅមិនទាន់រើចេញនៅឡើយទេ ។

- ល្អ ។

បានការហើយអាវ៉ា ! -*យ៉ាប៊ូ* ស្ទើរស្រែកសំរែកនេះចេញមកក្រៅ ។ អ្អែងយកបានកាំភ្លើងយកបាន *អាន់ជីន-សាន* និងអ្វី ១ ទាំងអស់មកវិញហើយ ។ អ្អែងបានពេលប្រាំមួយខែ ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* នឹងមិនបើកឆាកសង្គ្រាមរហ័សពេកទេ ។ ទោះជា*អ៊ីស៊ីដូ* សំរេចធ្វើឃាត *តូរ៉ាណាកា* ក្នុងប៉ុន្មានថ្ងៃខាងមុខនេះទៀតក៏ដោយ ក៏ក្មេងនៅតែបានរបស់របរទាំងអស់ណឹងដដែល ។ ឱព្រះអង្គអើយ ! សូមជួយការពារ*តូរ៉ាណាកា* ទំរាំខ្ញុំបានដល់សមុទ្រផង ។

- សូមអរគុណលោកម្ចាស់ !

សំដីអរគុណរបស់*យ៉ាប៊ូ* ពេលនេះ គឺពិតជាចេញពីក្រអៅបេះដូងដ៏ពិត ១ ។ គេនិយាយ បន្តទៀត :

- ខ្ញុំសូមធានាថា គ្មានសម្ព័ន្ធមិត្តណាស្មោះត្រង់ជាងនេះទៀតទេ ។

នៅពេលដែល*យ៉ាប៊ូ* ចាកចេញទៅហើយ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ងាកមករក *តូរ៉ាណាកា* ផាំង :

- នេះគឺជាការប្រព្រឹត្តមួយយ៉ាងអាក្រក់បំផុត ។ ខ្ញុំបាទសែនអាម៉ាស់នឹងកិច្ចព្រមព្រៀងនេះ ។ ខ្ញុំបាទសែនអាម៉ាស់ ដែលមតិរបស់ខ្ញុំគ្មានតំលៃអ្វីបន្តិចសោះ ។ ខ្ញុំបាទពិតជាគ្មានផលប្រយោជន៍អ្វីដល់លោកម្ចាស់ទៀតទេ ហើយខ្ញុំបាទក៏ឡើយណាស់ដែរ ។ អាដៃមីញ៉ូកំប៉ិកកំប៉ុកនេះវាបង្វិលលោកដូចអាប៉េងអីចឹង ។ ហេតុអីបានជាវាធ្វើមធំប៉ាន់ប្រើដាវរបស់*មូរ៉ា សាម៉ា* នៅមុខលោកម្ចាស់អីចឹង ?

*តូរ៉ាណាកា* ឆ្លើយតប :

- ខ្ញុំក៏កត់សំគាល់ឃើញដែរ ។

- ខ្ញុំបាទយល់ថា ព្រះធ្វើអោយលោកម្ចាស់វង្វេងហើយទាន ។ លោកម្ចាស់ធ្វើមិនដឹងមិនលឺនៅចំពោះការប្រមាថបែបនេះ ។ មិនតែប៉ុណ្ណោះលោកម្ចាស់អោយវាមកក្មេងក្លាងនៅពីមុខលោកម្ចាស់ទៅទៀត ។ លោកម្ចាស់បានបើកដៃអោយ *អ៊ីស៊ីដូ* មកបំបាក់មុខលោកម្ចាស់ជាចំហ ។ លោកម្ចាស់ខាយ៉ាងខ្ញុំបាទ និងពួកយើងទាំងអស់គ្នាមិនអោយការពារលោកម្ចាស់ ។ លោកម្ចាស់មិនព្រមអោយចៅស្រីរបស់ខ្ញុំបាទ ដែលជានារីពូជសាមូរ៉ៃមួយដែរនោះ ទទួលបានការស្លាប់មួយដោយកិត្តិយស និងដោយស្ងប់ចិត្តទេ ។ លោកម្ចាស់បានបាត់បង់អំនាចនៅក្នុងក្រុមប្រឹក្សា សត្រូវលោកម្ចាស់កំពុងតែតាមលោកម្ចាស់ ហើយឥឡូវនេះលោកម្ចាស់ភ្ជាប់កិច្ច



www.budinst.gov.kh www.elibraryofcambodia.org

ព្រមព្រៀងជាផ្លូវការមួយដ៏ឆ្គើមបំផុតដែលខ្ញុំមិនដែលលឺសោះ ។ ហើយលោកម្ចាស់ធ្វើកិច្ចព្រមព្រៀងនេះជាមួយអាមនុស្សដែលស្គាល់តែអំពើថោកទាប ជាតិពិស និងអំពើក្បត់ដូចជាឪវាតែអ៊ីចឹង ។

កំហឹងធ្វើអោយ *ហ្គី-មាត់ស៊ី* ឡើងញ័រខ្លួន ។ *តូរ៉ាណាកា* ឥតឆ្លើយតបមួយម៉ាត់សោះ ។ លោកអង្គុយយ៉ាងស្ងៀមស្ងាត់ ហើយសំលឹងមើលទៅមេទ័ពចំនាស់ ហាក់ដូចជា *ហ្គី-មាត់ស៊ី* ឥតមាននិយាយអ្វីមួយម៉ាត់សោះ ។

- ឱ ទេវតា អ្នកតា អារក្សអើយ ! -*ហ្គី-មាត់ស៊ី* ច្រលោតឡើង-ខ្ញុំបាទសូរលោកម្ចាស់ ហើយខ្ញុំបាទស្រែកដាក់ និងប្រមាថលោកម្ចាស់ប៉ុណ្ណឹងហើយ លោកម្ចាស់នៅតែសំលឹងមើលខ្ញុំប៉ុណ្ណឹង ។ អីលូវនេះរឺមួយលោកម្ចាស់ឡប់ស្មារតី រឺមួយក៏ខ្ញុំបាទ ។ ហើយខ្ញុំបាទសូមលោកម្ចាស់អនុញ្ញាតអោយខ្ញុំបាទធ្វើ *សិបពូគូ* ទៅ ហើយបើលោកម្ចាស់មិនព្រមអនុញ្ញាតអោយខ្ញុំបាទបានស្ងប់បែបនេះទេ ខ្ញុំបាទសូមកោរក្បាលបួសចុះទាន ។ ធ្វើអីក៏បានដែរអោយតែអោយខ្ញុំបាទចេញទៅចុះទាន ។

- លោកគ្មានធ្វើអ្វីទាំងអស់ តែលោកចាត់អោយគេទៅហៅ *ស៊ូគូ-សាន* មកជួបខ្ញុំ !

រួច *តូរ៉ាណាកា* ក៏សើចយ៉ាងក្អាកក្អាយឡើង ។



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ១៩

បព្វជិត *អាល់វីត្ត* ជិះសេះនាំមុខក្រុម *រយេស៊ុត* របស់លោកចុះពីលើវិមាន ដែលស្ថិតនៅលើកូនភ្នំមកវិញហើយ ។ ក្រុម *រយេស៊ុត* ដែលតែងអមដំណើរលោកនេះស្លៀកពាក់ដូចជាសង្ឃពុទ្ធសាសនាដែរ ខុសគ្នាតែផ្កាំ ហើយនិងព្រះឆ្លាងដែលនៅលើដើមទ្រូងរបស់ខ្លួនតែប៉ុណ្ណោះ ។ អ្នកជិះសេះអមបព្វជិត *អាល់វីត្ត* ទាំងអស់នេះមានចំនួនសែសិបនាក់ ។ ពួកគេសុទ្ធតែជនជាតិជប៉ុន ជាកុលបុត្រនៃពួកសាមូរ៉ៃ គ្រិស្តសាសនិក ហើយជាសង្ឃ ចេញពីសាលាធម៌នៅ*ណាកាសាគី* ។ ទាំងអស់គ្នាសុទ្ធតែចេះជិះសេះយ៉ាងថ្នឹក ហើយមានវិន័យយ៉ាងល្អមិនខុសអ្វីពីពួក *សាមូរ៉ៃ* ដែលតែងតែហែហម *ដៃមីញ៉ូ* ឯទៀត ៗ នោះឡើយ ។

ពួកគេធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់កាត់តាមព្រៃ និងតាមដងផ្លូវនានានៃទីក្រុង ដោយឥតរវីរវល់នឹងកំដៅព្រះអាទិត្យដ៏កក់ក្ដៅនោះឡើយ ដើម្បីឆ្ពោះទៅទីបេសកកម្មរបស់ពួក *រយេស៊ុត* ដែលជាផ្ទះថ្មដ៏ធំមួយសង់បែបអឺរ៉ុបនៅក្បែរកំពង់ផែនោះ ។ ទីបេសកកម្មរួមមានទាំងបន្ទប់មាស ប្រាក់ ឃ្លាំង ទំនិញ ដែលគេប្តូរ រឺលក់សូត្រសំរាប់ទីក្រុងអូសាកាទាំងមូលផងដែរ ។

ក្បួនដំណើរឆ្លងកាត់ទ្វារដែកដ៏ធំនៃរបងថ្មដ៏ខ្ពស់កាត់លានក្រាលថ្ម ហើយមកឈប់នៅក្បែរទ្វារធំមួយ ។ អ្នកបំរើបានមករង់ចាំជួយបព្វជិត *អាល់វីត្ត* ចុះពីលើខ្នងសេះហើយជាស្រេច ។ លោកចុះពីលើសេះយ៉ាងរហ័ស ហើយបោះបង្ហៀរសេះទៅអ្នកបំរើ ។ ក្រចាប់ចាក់សេះរបស់លោកលាន់ខ្ទរនៅពេលដែលលោកដើរកាត់អគារធំ រួចបត់ទៅតាមចំហៀង ។ បន្ទាប់ពីដើរហួសវិហារតូចមួយមក លោកចុះតាមខ្លោងទ្វារមួយទៀតទើបទៅដល់សួនច្បារខាងក្នុងបំផុត ។ ទ្វារបន្ទប់មុខនៅបើកចំហនៅឡើយ ។ ដល់កន្លែងនេះ បព្វជិត *អាល់វីត្ត* ប្រឹងបណ្តេញភាពខ្វល់ខ្វាយអោយចេញអស់ពីក្នុងអារម្មណ៍ រួចក្រោយពីរៀបចំទឹកមុខរួចរាល់ហើយលោកក៏ដើរចូលទៅ ។

- គាត់នៅម្នាក់ឯងទេអ្វី ? –បព្វជិត *អាល់វីត្ត* សួរ ។

បព្វជិត *សុលឌី* ឆ្លើយតប :



www.budinst.gov.kh www.elibraryofcambodia.org

- ទេ ! គាត់មានគ្នាណា *ម៉ាកតាំង* ។

បព្វជិត*សុលឌី* ជាមនុស្សមាឌតូច រីកពាចម្មតា ស្គមបួត មុខសុទ្ធតែស្នាកអុតពាស ពេញ ។ លោកមានដើមកំនើតពីទីក្រុងណាប (Naple) ហើយលោកធ្លាប់ធ្វើជាលេខាធិការ របស់គណៈអធិការសង្ឃ ប្រហែលសាមសិបឆ្នាំមកហើយ ក្នុងនេះគឺម្ភៃប្រាំឆ្នាំនៅអាស៊ី ។

បព្វជិត*សុលឌី*បន្តទៀត :

- លោកមេបញ្ជាការ *វ៉ាភីវ៉ា* កំពុងតែនៅជាមួយលោក ។ ប៉ុន្តែព្រះតេជគុណមាន ដីកាថា បើលោកមកដល់អោយចូលតែម្តងទៅ ។ មានរឿងអីមិនស្រួលអ្វី *ម៉ាកតាំង* ?

- អត់មានអីទេ ។

បព្វជិត*សុលឌី*បែរទៅសំរូលស្លាបក្ខានបណ្តើរ និយាយរអ៊ូរទាំ ១បណ្តើរ :

- អត់ទេ ! អត់ទេ ! ខ្ញុំគង់តែដឹងទេ !

- ពិតជាអីចឹង ។

*អាលវីតូ* ឆ្លើយតបដោយទឹកចិត្តរាប់អាន ចំពោះបព្វជិតចំនាស់ ។ លោកដើរតំរង់រក ទ្វារមួយដែលនៅឯចុង ។

បព្វជិត*សុលឌី*ស្រែកសួរពីក្រោយខ្នងលោកមកទៀត :

- មានជួប *អ៊ីញ៉ូតីលីស* ទៀតទេ ?

*អាលវីតូ* ឥតឆ្លើយតបនឹងសំនួរនេះឡើយ ។ លោកគោះទ្វារឡើង ។

- អញ្ជើញចូល ។

*កាឡូ ដៃឡាក្វា* ជាគណៈអធិការសង្ឃនៅអាស៊ី និង ជាអ្នកតំនាងផ្ទាល់របស់គណៈ សង្ឃ*យេស៊ូក* ។ លោកជា*យេស៊ូក*ច្បងគេ ហើយក៏ជាមនុស្សដ៏មានអំនាចបំផុតនៅអាស៊ីនេះ ផង។ លោកនៅថែមជាមនុស្សមាឌធំជាងគេបំផុតផងដែរ ។ លោកមានកំពស់ជាងពីរម៉ែត ហើយកំលាំងលោកក៏ពិបាករកគូប្រៀបណាស់ ។ ស្បង់របស់លោកពណ៌ស្វាទុំ ឈើឆ្កាងរបស់ លោកត្រូវឆ្លាក់យ៉ាងស្អាត និងយ៉ាងរស់រវើក ។ បច្ចុប្បន្ននេះលោកមានអាយុហុកសិបឆ្នាំ ហើយ ។ លោកមានដើមកំណើតនៅ*ណាប៉ូលីតាំង*(Neapolitan) ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលក្រលេកឃើញបព្វជិត *ម៉ាកតាំង អាលវីតូ* បព្វជិត *វ៉ៃឡាក្វា* ក៏ឧទានឡើង ជាភាសាបិកទុយកាល់ ដោយសំនៀងដ៏ពិរោះនៃភាសាអ៊ីតាលី :

- អូ *ម៉ាកតាំង* ទេអ្ហ៎ ! ចូលមក ! ចូលមក ! ត្រូវការស្រាទេ ? តើលោកមានជួប *អ៊ីញ៉ូគីលីស* ទេ ?

- អត់ទេព្រះតេជគុណ ។ ជួបតែ *តូរ៉ាណាកា* ប៉ុណ្ណោះ ។

- អាក្រក់ទេ ?

- ពិតហើយទាន ?

-ដាក់ស្រាបន្តិចអ្ហ៎ ?

- អរព្រះគុណណាស់ទាន ។

*វ៉ៃរ៉ា* លូកមាត់សួរម្តង :

- អាក្រក់ប៉ុនណាទៅ ?

មេទ័ពក្នុងអាយុប្រហែលសាមសិបប្រាំឆ្នាំនេះអង្គុយលើកៅអីស្បែកមួយ ដែលមានបង្អែកដ៏ខ្ពស់នៅក្បែរចង្រ្កានភ្លើងកំដៅ ។ អ្វី ១ ដែលលេចចេញមកគឺជាមោទនភាពនៃស្តេចឥន្ទ្រីមួយហើយតាមពិតលោកគួរមានមោទនភាពមែន ព្រោះឆ្នាំនេះលោកទទួលជាមេបញ្ជាការនៃសំពៅ*ណាវ ដែលគ្រាតូ* ដែលជាសំពៅខ្មៅឆ្នាំនេះ ។ លោកមានរាងស្គមខ្ពស់ ហើយសមជាអ្នកមានអំនាចណាស់ ។

- ខ្ញុំគិតថា គឺពិតជាអាក្រក់មែនទែនតែម្រ៉ងណារលោកមេបញ្ជាការ ។ តួយ៉ាងដូចជា *តូរ៉ាណាកា* និយាយថារឿងជំនួញដូរឆ្នាំនេះអាចរង់ចាំសិនអីចឹងជាដើម ។

*វ៉ៃរ៉ា* ឆ្លើយតបផ្ទុង :

- វាច្បាស់ណាស់ថា អារឿងជំនួញដូរគ្មានអ្នកណារង់ចាំបានទេ ។ ខ្ញុំក៏ចាំមិនបានដែរ ។ ពេលជំនោរក្រោយនេះខ្ញុំត្រូវចេញដំណើរហើយ ។

- លោកមិនទាន់បានច្បាប់ផងទេ ។ ខ្ញុំក្រែងតែលោកត្រូវរង់ចាំទេ ។

- ខ្ញុំស្មានថា រឿងរ៉ាវអ្វី១ ដោះស្រាយរួចរាល់ហើយ តាំងពីប៉ុន្មានខែមកម្ល៉េះ ។



www.budinst.gov.kh www.elibraryofcambodia.org

ដូច *កែរីរ៉ា* ក៏តាំងចាប់ប្រទេចផ្ដាសាច្បាប់ជប៉ុន ដែលតំរូវអោយនាវាដើរសមុទ្រទាំងអស់ ទាំងបរទេស ទាំងជប៉ុន ត្រូវមានលិខិតអនុញ្ញាតសំរាប់ចូល និងសំរាប់ចេញពីផែ ។

*កែរីរ៉ា* បន្តទៀត :

- កុំទៅរវល់ស្ដាប់តាមក្រឹត្យក្រមពួកអាអ្នកស្រុកអាយអស់នេះ ។ ក្រែងលោកឯងនិយាយថា ជំនួបនេះគឺគ្រាន់តែដូចធម្មតា ដើម្បីយកលិខិតអនុញ្ញាតតែប៉ុណ្ណោះទេអី ?

- វាល់ដងវាអីចឹងមែន ។ តែលើកនេះ គឺខ្ញុំស្មានខុសហើយ ។ យកល្អចាំខ្ញុំពន្យល់អោយ....

-ខ្ញុំត្រូវត្រលប់ទៅ *ម៉ាកាវ* ជាបន្ទាន់ដើម្បីរៀបចំសំពៅខ្មៅ ។ ពួកយើងបានទទួលទិញសូត្រល្អបំផុតនៅឯផ្សារណាត់ *កង់តុង* អស់តំលៃមួយលាន *ឌុយកាត* ហើយ។ យើងត្រូវដឹកមាសចិនប្រហែលជាងបីតោនទៀត ។ ខ្ញុំគិតថា ខ្ញុំបានជំរាបពួកគេជគុណទាំងអស់គ្នាហើយថា ទៅឆ្នាំនេះគឺយើងប្រមូលលុយដែលមានទាំងប៉ុន្មានទៅ *ម៉ាកាវ* នៅ *ម៉ាឡាកា* និង *គូវ៉ា* បូករួមនឹងលុយពួកឈ្មួញនៅ *ម៉ាកាវ* លុយពួកបព្វជិតតាមក្រុងនានាដែលខ្ចីពីគេពីឯង ហើយនិងលុយពួកគេជគុណនៅទីនេះផង ។

*ដែឡាកា* ឆ្លើយតបយ៉ាងកំបុតកំបុយទៅវិញ :

-ពួកយើងសុទ្ធតែដឹងពីសារសំខាន់នៃបញ្ហានេះ ហើយពួកយើងក៏ខ្វល់ដូចជាលោកដែរតើ ។

*អាលវីតូ* បន្លឺសំលេងឡើង :

-ខ្ញុំសោកស្ដាយណាស់លោកមេបញ្ជាការ ។ ប៉ុន្តែ *តូរ៉ាណាកា* គឺជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសិទ្ធិ ហេតុនេះជាទំលាប់យើងមិនអាចរំលងគាត់ទេ ។ ធម្មតាគាត់មិនដែលសាំញ៉ាំច្រើនទឹងរឿងជួញដូរ រឺច្បាប់ផែរបស់លោកទេ ។ តែលើកនេះ បើកឆាកឡើងគាត់និយាយថាគាត់មិនគាំទ្រអារឿងធ្វើឃាតនោះ ។

*កែរីរ៉ា* តបផាំង :

-ចុះអ្នកណាគាំទ្រ ?



www.budinst.gov.kh www.elibraryofcambodia.org

*ដែឡាក្វា* សួរភ្លាម ៖

-*គូរ៉ាណាកា* និយាយពីរឿងអីណឹងម៉ាកតាំង ? ជាល្បិចរបស់វាទៀត រឺយ៉ាំងម៉េច ? ធ្វើឃាត ? រួចចុះអារឿងណឹងវាមានទាក់ទងអីនឹងពួកយើង ?

- *គូរ៉ាណាកា* និយាយថា ៈ" ហេតុអីបានជាពួកគ្រិស្តសាសនិកអស់លោកចង់ធ្វើឃាតតែកុងដែលជាអ្នកទោសរបស់ខ្ញុំ អីចឹង ? " ។

- ថាម៉េច ?

-*គូរ៉ាណាកា* ជឿថា ការប៉ងធ្វើឃាតពីយប់ម្សិលមិញនោះ គឺសំដៅអា*អ៊ីញូគីលើស* មិនមែនសំដៅលើគាត់ទេ ។ គាត់បាននិយាយថា កាលពីនៅក្នុងគុកមានគេប៉ងសំលាប់ *អ៊ីញូគីលើស* នេះម្តងហើយ ។

ក្រសែភ្នែករបស់ *អាល់វីតូ* ផ្តោតជាប់ទៅលើរូបមេទ័ព ។

*វ៉េរីរ៉ា* និយាយឡើង ៖

-តេជគុណចង់ចោទខ្ញុំរឿងអីណឹង ? ប៉ងធ្វើឃាត ? ខ្ញុំណឹង ? នៅក្នុងវិមានអូសាកានេះ ? នេះលើកទីមួយដែលខ្ញុំមកដល់ជប៉ុននោះ ។

- លោកប្រកែកថា លោកមិនដឹងអ្វីទាំងអស់អ្វី ?

*វ៉េរីរ៉ា* ឆ្លើយយ៉ាងត្រជាក់ស្រេង ៖

-ខ្ញុំមិនប្រកែកទេ ថាបើពួកអាបែកឆ្វេងនេះងាប់កាន់តែឆាប់ពេលណា គឺកាន់តែល្អពេលនោះ ។ បើសិនជាពួកហូឡង់ និង ពួកអង់គ្លេសចាប់ផ្តើមមកកកូរកកាយនៅអាស៊ីដែរនោះ ពួកយើងពិតគឺជាចង្រៃធំហើយ ។ ពួកយើងទាំងអស់គ្នាណឹងណា !

*អាល់វីតូ* និយាយតប ៖

-យើងកំពុងតែចង្រៃហើយតើ ។ *គូរ៉ាណាកា* បាននិយាយថា គាត់បានដឹងពីអា*អ៊ីញូគីលើស* ថាសិទ្ធិផ្តាច់មុខរបស់ប៉ាកទុយកាល់ ក្នុងរឿងជួញដូរជាមួយស្រុកចិននោះបាននាំអោយចំនេញដល់គេ ហើយថាពួកប៉ាកទុយកាល់យើងកោររឿងថ្លៃសូត ដែលពួកយើងទិញនៅឯស្រុកចិនដោយតំលៃថោក ៗនោះ ។ *គូរ៉ាណាកា* ប្រាប់ខ្ញុំថា " ដោយហេតុតែរវាងប្រទេសជប៉ុននឹង ប្រទេសចិនមាន



www.budinst.gov.kh www.elibraryofcambodia.org

អារិភាពនឹងគ្នាមិនអាចជួញដូរដោយត្រង់បាន ហើយមានតែពួកប៉ិកទុយកាល់តែមួយគត់ ដែល
ការអនុញ្ញាតអោយធ្វើការជួញដូរនេះ ហេតុនេះការចោទប្រកាន់របស់តៃកុង ដែលថាយើ
ខ្សែលើនោះ ត្រូវតែយើងឆ្លើយបំភ្លឺដោយលាយលក្ខណ៍អក្សរ " ។ *តូរ៉ាណាកា* នៅបាន "
ព្រះតេជគុណគណៈអធិការសង្ឃ សូមអោយបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនូវរបាយ
មួយស្តីពីអត្រាប្តូរប្រាក់ រវាងសាច់ប្រាក់នឹងសូត សូតនឹងប្រាក់ មាសនឹងប្រាក់ ។ គាត់និ
ទៀតថាគាត់មិនជំទាស់អ្វីដែលយើងយកចំនេញកប៉ាល់ក្តោងនោះទេ តែនេះត្រូវយកពីពួកចិន

-ព្រះតេជគុណត្រូវជំទាស់នឹងពាក្យក្រអឺតក្រទមនេះ-*ភែរីរ៉ា* និយាយ ។

- ជំទាស់ គឺពិបាកណាស់ ។

- បើអីចឹងធ្វើរបាយការណ៍បន្តទៅ !

*ដៃឡាក្វា* តប :

- ធ្វើបែបនេះ គឺធ្វើអោយមានគ្រោះថ្នាក់ដល់ស្ថានភាពយើងទាំងមូល ព្រោះ
យើងនៅទីនេះ គឺឈរលើមូលដ្ឋាននៃទំនុកចិត្តគ្នា ។

-ព្រះតេជគុណជឿពួកអាគយនេះដែរ ? គ្មានអីជឿពួកវាបានទេ ។ រឿងចំនេញ
យើងត្រូវលាក់អោយបានជិតមែនទែន ។ យីអាកូនមីចោរម្រាយ *អ៊ីញ្ញាតីលីស* នេះ !

-ខ្ញុំសូមជំរាបថា *ប្លាក់ថន* ហាក់ដូចជាដឹងរឿងរ៉ាវច្បាស់លាស់ណាស់ ។

*អាល់វីតូ* និយាយបណ្តើរ សំលឹងទៅបព្វជិត *ដៃឡាក្វា* បណ្តើរ ។

គណៈអធិការសង្ឃនៅស្ងៀម ឥតនិយាយស្តីអ្វីតបនឹងសំដីរបស់ *អាល់វីតូ* ឡើយ

*ភែរីរ៉ា* ធ្វើជាមិនឃើញកន្ទុយភ្នែករវាងបព្វជិតទាំងពីរឡើយ តែនៅក្នុងចិត្តគេជ
សួរថា តើអ្នកទាំងពីរនេះដឹងរឿងអ្វីខ្លះទៅ ។

-តើអាគយនោះវាមាននិយាយអ្វីទៀតទេ ? -*ភែរីរ៉ា* សួរបន្ត ។

-*តូរ៉ាណាកា* សូមអោយខ្ញុំផ្តល់ទៅគាត់នៅវេលាថ្ងៃត្រង់ស្អែកនូវផែនទីពិភពលោ
ដែលបង្ហាញពីគំនូសបែងចែករវាងប្រទេសប៉ិកទុយកាល់ នឹង អេស្ប៉ាញ ព្រះនាមរបស់
ដែលបានឯកភាពលើកិច្ចព្រមព្រៀង ហើយនិងថ្ងៃ ខែ និងព្រឹត្តិការណ៍ទាំងនេះ ។ គាត់នៅជ



www.budinst.gov.kh www.elibraryofcambodia.org

" ស្ពៃ " ទៀតថា ក្នុងរយៈពេលបីថ្ងៃ យើងធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយ ពន្យល់ពីការ " ប្រាមប្រាប " របស់យើងនៅឯពិភពថ្មី ហើយនិងចំនួនមាស និងប្រាក់ដែលយើងដឹកយកទៅប្រទេសប័កទុយកាល់ និងអេស្ប៉ាញ ។ កន្លែងនេះ *តូរ៉ាណាកា* ប្រើសំដីអាតែកុងតែម្តង ព្រោះគាត់ប្រើពាក្យ " ប្លន់ " ។ គាត់ស្នើអោយយើងគូសផែនទីមួយទៀតបង្ហាញពីដែនចក្រភពរបស់អេស្ប៉ាញ និង ប័កទុយកាល់ កាលពីមួយរយឆ្នាំមុន ពីហាសិបឆ្នាំមុន និងអីលូវនេះ រួមទាំងទីតាំងពិតប្រាកដរបស់មូលដ្ឋានរបស់យើងទាំងប៉ុន្មាន តាំងពីជ្រោយ *មាឡាកា* ទៅដល់ *គូវ៉ា* ។ *តូរ៉ាណាកា* ហៅឈ្មោះកន្លែងទាំងនេះចំ ១ តែម្តង ព្រោះមានសរសេរនៅលើក្រដាសមួយសន្លឹក ។ គាត់ទាមទារអោយយើងបញ្ជាក់ពីចំនួនពួកជប៉ុនស៊ីឈ្នួលច្បាំង ដែលយើងប្រើប្រាស់នៅតាមមូលដ្ឋាននីមួយ ១ ទៀតផង ។

ទាំង *ដែឡាក្វា* ទាំង *រ៉ៃភីរ៉ា* និយាយលែងចេញតែម្តង ។

បន្តិចក្រោយមក *រ៉ៃភីរ៉ា* ក៏គ្រហឹមឡើង :

- រឿងនេះត្រូវតែប្រកែក ។

*ដែឡាក្វា* និយាយតប :

- ជាមួយតូរ៉ាណាកា គេមិនអាចប្រកែកបានទេ ។

-ខ្ញុំគិតថា ព្រះតេជគុណអោយសារសំខាន់ទៅវាខ្លាំងពេកហើយ- *រ៉ៃភីរ៉ា* បន្តសំដីរបស់ខ្លួន-ចំពោះខ្ញុំ អាម្សៀរ *តូរ៉ាណាកា* នេះវាដូចតែស្តេចផ្តាច់ការឯទៀត ១ អីចឹង វាគ្រាន់តែជាមេឃាតកក្រៅសាសនាម្នាក់តែប៉ុណ្ណោះ ហេតុនេះគ្មានអ្វីត្រូវខ្លាចវានោះទេ ។ ប្រកែកនឹងសំនើនេះទៅ ។ គ្មានសំពៅខ្មៅយើងនេះទេ សេដ្ឋកិច្ចពួកវាទាំងអស់នឹងបះជើងមិនខាន ។ ពួកវាច្បាស់ជាមកអង្វរលន់តួសុំសូតចិនរបស់យើងជាមិនខាន ។ គ្មានសូត គ្មាន*គីម៉ូណូ* ។ ពួកវាត្រូវការជំនួញរបស់ពួកយើង ។ យី ! អារំបល់យក៏ *តូរ៉ាណាកា* នេះ ! ម្យ៉ាងទៀតយើងអាចធ្វើជំនួញជាមួយស្តេចគ្រិស្តសាសនិកបានដែរតើ ។ ពួកវាឈ្មោះអីអញ្ចេះ ? អូ មែនហើយគឺ *អូណូស៊ី* និង *គិយ៉ាម៉ា* ។ ក្រៅពីនេះនៅមានពួកស្តេចគ្រិស្តសាសនិក ឯទៀតនៅ*ក្យូស្យូ*ផងដែរ។ ម្យ៉ាងទៀតយើងមាន*ណាកាសាគី* ។ នៅកន្លែងនោះយើងមានប្រៀបខ្លាំង ហើយរឿងជួញដូរ



www.budinst.gov.kh www.elibraryofcambodia.org

ក៏កាត់តែតាម*ណាកាសាគី*តែប៉ុណ្ណឹង ។

- យើងមិនអាចធ្វើអីចឹងបានទេលោកមេបញ្ជាការ-*វៃឡាកា* តប-នេះគឺជាទស្សនកិច្ចលើកទីមួយរបស់លោកនៅជប៉ុន ហេតុនេះហើយទើបលោកមិនយល់ពីបញ្ហារបស់ពួកយើងដែលនៅទីនេះ ។ ពិតហើយថា ពួកវាត្រូវការយើង តែយើងត្រូវការពួកវាជាង ។ គ្មានការអនុគ្រោះរបស់*តូរ៉ាណាកា* និង*អ៊ីស៊ីដូ* ទេ យើងពិតជាបាត់ឥទ្ធិពលលើពួកស្តេចគ្រិស្តសាសនិក យើងពិតជាបាត់*ណាកាសាគី*ហើយនិងអ្វី ៗ ទាំងអស់ ដែលយើងបានកសាងឡើងក្នុងហាសិបឆ្នាំនេះ ។ តើលោកពិតជាមានបានលូកដៃចូលក្នុងរឿងប៉ុនប៉ងសំលាប់អាតៃកុងចង្រៃនោះមែនទេ ?

-ខ្ញុំបាននិយាយជាច់ហប្រាប់*រ៉ូឌ្រិច*ហើយនិងអ្នកឯទៀត១ថា អា*អ៊ិញគីលីស*នោះគឺជាមេចោរសមុទ្រដ៏គ្រោះថ្នាក់ ដែលនឹងនាំចំលងរឿងដល់គេគ្រប់គ្នាជាមិនខាន អីចឹងហើយត្រូវចាត់ការវាអោយបាន ទោះតាមមធ្យោបាយណាក៏ដោយ ។ ព្រះតេជគុណក៏និយាយក្នុងន័យបែបនេះដែរតើ គ្រាន់តែភាសាខុសគ្នាតែប៉ុណ្ណោះ ។ ព្រះតេជគុណ*អាល់វីតូ*ក៏និយាយបែបនេះ។ កាលពីម្សិលម៉្ងៃយើងមិនលើកបញ្ហានេះជាមួយ*អូណូស៊ី* និង *គីយ៉ាម៉ា* ទេអ្វី ? ព្រះតេជគុណមិនថាអាតៃកុងនោះជាមនុស្សគ្រោះថ្នាក់មែនទេ ?

-មែនហើយ តែ...

-ព្រះតេជគុណ ! ខ្ញុំសូមទោស តែនៅពេលខ្លះវាជាការមួយចាំបាច់ដែលទាហានត្រូវទទួលបំពេញភារកិច្ចរបស់ព្រះជាម្ចាស់តាមបែបណា ដែលល្អបំផុត ដែលខ្លួនអាចធ្វើទៅបាន ។ ខ្ញុំ គួរតែជំរាបព្រះតេជគុណថា ខ្ញុំខឹងស្ទើរដាច់ក្បាលដាច់កន្ទុយនឹងអា*រ៉ូឌ្រិច* ដែលវាមិនបង្កអោយមានជា " គ្រោះថ្នាក់ " អីនៅពេលមានព្យុះនោះសោះ ។ ក្នុងមនុស្សទាំងអស់ អា*រ៉ូឌ្រិច*ត្រូវដឹងរឿងនេះច្បាស់ជាងគេ ។ តែមិនអីចឹងទេ ព្រះអង្គអើយ ព្រះអង្គ ! មើលទៅមើល ថាតើអា*អ៊ិញគីលីស* វាធ្វើអីខ្លះដល់អា*រ៉ូឌ្រិច* ? អាចំកួតនោះបែរជាដឹងគុណអា*អ៊ិញគីលីស* មិនភ្លេចព្រោះបានជួយជីវិតវាទៅវិញ ។ អានេះគ្មានដឹងថា អាតៃកុងនោះវាលេងល្បិច ដើម្បីធ្វើអោយអា*រ៉ូឌ្រិច*ជឿទុកចិត្តវាអីសោះ ។ អា*រ៉ូឌ្រិច*នេះវាភ្លើអីក៏ភ្លើ របួតដល់ថ្នាក់អោយអា*អ៊ិញគីលីស*



www.budinst.gov.kh www.elibraryofcambodia.org

កាន់ចង្កូតជំនួសខ្លួនវា របហូតដល់វិះអស់ជីវិតទៅទៀតអីចឹង ? ហើយអារឿងការប៉ុនប៉ង សំលាប់នៅក្នុងវិមាននោះក៏អីចឹងដែរ អ្នកណាដឹងថាវាយ៉ាងម៉េច? ជួនកាលវាអាចតែជាបញ្ហារបស់អ្នកស្រុកអោយតែប៉ុណ្ណឹង ។ អានេះជួនកាលវាជាល្បិចពួកអាតយអស់ណឹង ។ខ្ញុំអត់អ៊ីនឹងរឿងពួកវាចង់សំលាប់តៃកុងនោះទេតែ ព្រះគេជគុណាទុកចិត្តចុះថា ខ្ញុំចាត់ការវាទាល់តែបានហ្នឹង ។

បព្វជិត *អាល់វីតូ* ចិបស្រារបស់លោកបណ្តើរ និយាយបណ្តើរ :

-*តូវ៉ាណាកា* និយាយថា គាត់នឹងបញ្ជូន *ប្លាក់ថន* ទៅ *អ៊ីស៊ូ* ហើយ ។

*កែរីវ៉ា* សួរឡើង :

-ទៅឧបទ្វីបខាងកើតណឹងអ្ហ៎ ?

- ណឹងហើយ ។

- តាមដីគោក រឺផ្លូវទឹក ?

- តាមផ្លូវទឹក ។

- ល្អ ។ ខ្ញុំមិនគួរនិយាយទេ ប៉ុន្តែពួកវាត្រូវស្លាប់តែទាំងអស់ណឹង ដោយខ្យល់ព្យុះអី១ មួយហើយ ។

*អាល់វីតូ* និយាយដោយសំលេងត្រជាក់ស្រេង ។

-ខ្ញុំ ក៏មិនគួរនិយាយដែរ ប៉ុន្តែ *តូវ៉ាណាកា* បាននិយាយជាមួយខ្ញុំហើយ ។ ខ្ញុំសូត្រសំដីរបស់គាត់អោយលោកស្តាប់ចុះ ។ *តូវ៉ាណាកា* និយាយថា :" ខ្ញុំបានចាត់អង្គរក្សផ្ទាល់របស់ខ្ញុំទៅចាំការពារតៃកុងនេះ ។ សូម *ល្វូតូ-សាន* ជ្រាបថា បើសិនជាតៃកុងនេះមានគ្រោះថ្នាក់អីការធ្វើអង្កេតមួយនឹងត្រូវធ្វើឡើងដោយប្រើអស់នូវអំនាចរបស់ខ្ញុំ និងរបស់ក្រុមប្រឹក្សាអាជ្ញាធុសិទ្ធិ ហើយបើសិនជាស៊ើបទៅដឹងថា គ្រិស្តសាសនិកណាមួយជាអ្នកទទួលខុសត្រូវរឺក៏អ្នកណាមួយដែលមានទំនាក់ទំនងជាប្រយោលក្តីជាមួយគ្រិស្តសាសនិកជាអ្នកទទួលខុសត្រូវនោះ ។អាចបញ្ញត្តិស្តីពីការបណ្តេញចេញពីស្រុក ត្រូវយកមកពិនិត្យសាជាថ្មីវិញ ហើយអាចវិហារ សាលារៀន កន្លែងសំរាករបស់ផ្នែកគ្រិស្តសាសនាទាំងអស់ត្រូវបិទចោលតែម្តង "។



www.budinst.gov.kh www.elibraryofcambodia.org

*វ៉ែឡាក្វា* ឧទានឡើង :

-ឱ ព្រះអង្គអើយ យ៉ាងម៉េចយ៉ាងម៉ាកុំអោយមានរឿងបែបនេះកើតឡើងអោយសោះលោក ។

*កែរីរ៉ា* និយាយតបក្នុងសំលេងចំអក :

-វាប្រូវទេ !

- លោកយល់ច្រលំហើយលោកមេបញ្ជាការ ។ *តូរ៉ាណាកា* ជាមនុស្សវាងវៃមិនចាញ់ *ម៉ាក្យាវែល*(*) ទេ ហើយឥតប្រណីមិនចាញ់ *អាទីឡា*(**) របស់ជនជាតិហ៊ុន (Hun) នោះដែរ។

រួចបព្វជិត *អាលវីតូ* ងាកបែរទៅរក *វ៉ែឡាក្វា* វិញ :

-បើមានរឿងអីកើតឡើងដល់អា *អ៊ិញ្ញាគីលីស* នោះ វាជាការងាយបំផុតដែលអោយយើងទទួលថ្មបាក់នោះ ។

- ពិតជាអ៊ីចឹង ។

*កែរីរ៉ា* បន្លឺឡើងទាំងកំហឹង :

-រឺមួយយើងចាត់ការអាប្រភពរឿងតែម្ដងទៅ ? ចាត់ការ *តូរ៉ាណាកា* បណ្ដោយទៅ។

*វ៉ែឡាក្វា* ឆ្លើយតប :

- ពេលនេះមិនមែនជាពេលនិយាយលេងសើចនោះទេ ។

-អ្វីដែលយើងធ្វើបានយ៉ាងត្រចះត្រចង់នៅឥណ្ឌា នៅម៉ាឡាយូ ប្រេស៊ីល ប៉េរូមិចស៊ិច និងកន្លែងផ្សេង ៗទៀតនោះ ពិតជាធ្វើនៅទីនេះកើត ។ខ្ញុំផ្ទាល់ធ្លាប់ចាត់ការរឿងនេះ មិនដឹងជាប៉ុន្មានដងទេនៅម៉ាឡាយូនិង *ក្វាំ* ហើយខ្ញុំមានតែពួកអាតយស៊ីឈ្នួលច្បាំងជាជំនួយតែប៉ុណ្ណោះ ។ នេះខ្ញុំគ្មានឥទ្ធិពលនិងការចេះដឹងដូចព្រះតេជគុណផង ។ យើងប្រើពួកស្ដេច

---

*(*)- ម៉ាក្យាវែល(Machiavelli) ជាអ្នកនយោបាយ ជាស្មេរ និងជាទស្សនវិទូអ៊ីតាលី( ១៤៦៩-១៥២៧) ។នៅក្នុងស្នាដៃដ៏ល្បីល្បាញរបស់លោកឈ្មោះ " អ្នកដឹកនាំ " (ThePrince) លោកបានលើក ឡើងពីសិល្បៈនៃការដឹកនាំប្រទេសរបស់ស្ដេចផែនដី ដែលផ្អែកលើភាពប្រាកដនិយម ។*

*(**) -ស្ដេចជនជាតិហ៊ុន ដ៏សាហាវម្នាក់ ( ៣៩៥-៤៥៣ )*



www.budinst.gov.kh www.elibraryofcambodia.org

គ្រិស្តសាសនិកទៅណា ។ យើងជួយអ្នកណាមួយអោយចាត់ការ *តូរ៉ាណាកា* ទៅបើអាគាត់ណើង វាជាបញ្ហានោះ ។ ពួកកុងតីស្តាឌ័រតែប៉ុន្មាននាក់ គឺគ្រប់គ្រាន់ណាស់ទៅហើយ ។ បំបែកដើម្បីសោយរាជ្យណាំតេជគុណ ។ ខ្ញុំនឹងទាក់ទងជាមួយ *តីយ៉ាម៉ា* ។ តេជគុណ *អាល់វីតូ* បើសិន ជាតេជគុណជួយបក...

-លោកមិនអាចប្រៀបពួកជប៉ុនទៅនឹងពួកឥណ្ឌា រឺពួកល្ងង់ជូជាតិ *អាំងកា* (Inca)នោះទេ (*) ។ នៅទីនេះលោកមិនអាចប្រើល្បិច បំបែកដើម្បីសោយរាជ្យបានទេ ។ ប្រជាជាតិជប៉ុនមិនដូចប្រជាជាតិគេឯទៀត ៗនោះទេ ។ មិនដូចសោះតែម្តង ។

សំលេងរបស់ *វ៉ៃឡាកា* ពោរពេញទៅដោយភាពនឿយណាយ ។ លោកបន្តពោលទៀតថា :

-លោកមេបញ្ជាការ ខ្ញុំសូមស្នើដល់លោកជាផ្លូវការតែម្តងថា កុំលូកដៃចូលក្នុងរឿងនយោបាយផ្ទៃក្នុងរបស់ស្រុកនេះអោយសោះ ។

- ខ្ញុំយល់ព្រមហើយ ។ អ្វី ៗដែលខ្ញុំបាននិយាយសូមកុំទុកនៅក្នុងចិត្តអី ។ ឱ ចំជាល្ងង់មែនដែលនិយាយត្រង់ ៗបែបនេះ ។ តែសំនាងដែរដោយរដូវនេះសំបូរព្យុះនោះ ។

- បើសិនជាមានព្យុះមែននោះ គឺព្រះជាអ្នកសំរេច ។ ប៉ុន្តែជាចំខាតលោកមិនត្រូវទៅប្រហារតែកុងទេណា ។

- មែន ?

- មែន ។ ហើយលោកក៏មិនត្រូវបញ្ជាអោយអ្នកណាផ្សេងធ្វើដែរ ។

-ខ្ញុំបានស្បថនៅចំពោះមុខព្រះភ័ក្ត្រព្រះរាជាយើងថា ខ្ញុំនឹងកំទេចសត្រូវទាំងអស់របស់ព្រះអង្គ ។ អា*អ៊ិញគិលិស* ជាសត្រូវនឹងប្រទេសជាតិយើង ។ វាជាឈ្លើង ជាចោរសមុទ្រជាទមិឡ ។ បើសិនជាខ្ញុំសំរេចថាចាត់ការវានេះគឺជារឿងផ្ទាល់របស់ខ្ញុំ។ ខ្ញុំគឺមេបញ្ជាការសំពៅខ្មៅនៅឆ្នាំនេះ ពោលគឺជាចៅហ្វាយលើតំបន់ *ម៉ាកាវ* ហើយមានអំនាចទាំងស្រុង ក្រោមតែ

(*)- *ជនជាតិមួយនៅទ្វីបអាមេរិច ដែលត្រូវរលត់ដោយការឈ្លានពានប៉ែកខុយកាល់* ។



www.budinst.gov.kh www.elibraryofcambodia.org

ស្តេចផែនដីមួយព្រះអង្គគត់នៅលើដែនទឹកកន្លែងនេះ ។ ហើយបើខ្ញុំចង់ចាត់ការ អា*អ៊ីញ៉ាតៀស៊ីស*
*វិគូវ៉ាណាកា*រីអ្នកណា១ផ្សេងទៀតនោះ ខ្ញុំនឹងចាត់ការហើយ ។

- អីចឹងលោកមិនធ្វើផុយនឹងបញ្ហាខ្ញុំទៅហើយ ។ លោកមិនខ្វាចខ្ញុំបណ្តេញចេញក្រៅសាសនាទេអី ។

-បញ្ហានេះមិននៅក្រោមអំនាចរបស់ព្រះតេជគុណទេ ។ នេះជារឿងអាណាចក្រមិនមែនរឿងសាសនាទេ ។

- ស្តាយណាស់ដែលតួនាទីរបស់ព្រះវិហារ នៅទីនេះជំពាក់ជំពិនយ៉ាងស្អិតល្អួតនឹងរឿងនយោបាយ ហើយនិងរឿងជួញដូរសូត ។ អីចឹងហើយអ្វី ១ សុទ្ធតែប៉ះពាល់ដល់សន្តិសុខរបស់ព្រះវិហារតែទាំងអស់ហ្នឹង ។ ដរាបណាខ្ញុំនៅមានជីវិតគ្មានអ្នកណាម្នាក់មកធ្វើអោយអនាគតរបស់ព្រះវិហារនៅទីនេះរងគ្រោះថ្នាក់បានទេ ។

- សូមអរគុណ ដែលព្រះតេជគុណនិយាយច្បាស់លាស់យ៉ាងនេះ ។ ខ្ញុំនឹងខំប្រឹងប្រែងស្វែងយល់ថែមទៀតពីបញ្ហាពួកជប៉ុននេះ ។

-ខ្ញុំអង្វរសូមអោយលោកប្រឹងស្វែងយល់អោយមែនទែន ។ គ្រិស្តសាសនាត្រូវតែអនុញ្ញាតអោយមាននៅក្នុងស្រុកនេះបាន ក៏ពីព្រោះតែពួកដៃមីញ៉ូជឿថា បើសិនជាពួកវាបណ្តេញពួកយើងលែងអោយនៅក្នុងស្រុកនេះ ហើយបំបិទជំនឿនេះ សំពៅខ្មៅនឹងលែងមកទៀតជារៀងរហូត ។ ពួកវាត្រូវការពួកយើងជាពួកយេស៊ុីត ហើយពួកយើងក៏មាន ឥទ្ធិពលខ្លះ១ ក៏ពីព្រោះតែមានតែពួកយើងគត់ ដែលនិយាយភាសាជប៉ុន និង ប៉កទុកកាល់ ហេតុនេះពួកយើងអាចបកប្រែ និង អាចជួយទាក់ទងអោយពួកវានៅក្នុងរឿងជួញដូរបាន ។ តែបើនិយាយពីរឿងជំនឿវិញ ខ្ញុំមិនគិតថានេះជារឿងពិតទេ ។ ខ្ញុំជឿថា អារឿងជួញដូរនេះនៅតែបន្តទៅទៀត ទោះជាជំហរពួកយើងនិងឥទ្ធិពលរបស់ព្រះវិហារទៅជាយ៉ាងណាក៏ដោយ ពីព្រោះពួកឈ្មួញប៉កទុយកាល់ រវល់នឹងផលប្រយោជន៍បុគ្គលច្រើនជាងជោគជ័យ របស់ព្រះជាម្ចាស់ ។

-រីមួយក៏ជាផលប្រយោជន៍បុគ្គលរបស់ពួកបព្វជិត ដែលចង់បង្ខំអោយចូលទៅកំពង់



www.budinst.gov.kh www.elibraryofcambodia.org

ផែណាដែលខ្លួនកំនត់ អោយជូញដូរជាមួយដៃមីញ៉ូណាដែលខ្លួនចូលចិត្ត ទោះជាប្រថុយប្រថានយ៉ាងណាក្តី ។ អារឿងណឹងច្បាស់ដូចថ្ងៃអីចឹង ។

- លោកភ្លេចថា លោកកំពុងនិយាយពីអីហើយ លោកមេបញ្ជាការ ។

- ខ្ញុំមិនភ្លេចទេថា កាលពីឆ្នាំទៅសំពៅខ្មៅបានត្រូវបាត់បង់ ក្នុងចន្លោះរវាងស្រុកនេះនឹងម៉ាកាវ ។ បាត់ទាំងមនុស្ស ទាំងមាសជាងពីររយតោន ហើយនិងអីវ៉ែអីវ៉ាន់ផ្សេងអស់រាប់ពាន់លានបើគិតជាដុំប្រាក់ នេះគឺព្រោះតែគេបានពន្យារពេលវាដោយឥតចាំបាច់អ្វីសោះរហូតដល់រដូវព្យុះ ។ ហើយអ្នកណាជាអ្នកស្នើពន្យារនេះ ? គឺព្រះតេជគុណផ្ទាល់ដែលស្នើនោះ ។ ព្រះតេជគុណមានដឹងទេថា គ្រាន់តែអារឿងសំពៅលិចពីឆ្នាំទៅនោះ ម្នាក់ ១ ចង់រលាយខ្លួនទៅហើយ តាំងពីជប៉ុននេះរហូតដល់*គូវ៉ា*ឯណោះ ។

-ការពន្យារពេលនោះ គឺជាការចាំបាច់ ពីព្រោះតែមរណភាពរបស់ *វ៉ាតូ* និងបញ្ហាផ្ទៃក្នុងទាក់ទងនឹងការស្នងអំនាច ។

- ខ្ញុំក៏មិនភ្លេចដែរទេ កាលពីបីឆ្នាំមុន ព្រះតេជគុណបានស្នើអោយឧបរាជនៅ*គូវ៉ា* អោយផ្អាកសំពៅខ្មៅ ហើយបញ្ជូនវាមកតែនៅពេលណា ដែលលោកប្រាប់ទៅផែណាមួយដែលលោកកំនត់ ហើយកាលនោះលោកឧបរាជមិនព្រមស្តាប់ព្រះតេជគុណ ដោយលោកចាត់ថានេះជាការលូកជ្រៀតជ្រែកការងារដ៏យ៉ាងព្រហើនមួយ ។

- កាលនោះ គឺដើម្បីពត់ *វ៉ាតូ* ធ្វើអោយវាមានវិបត្តិសេដ្ឋកិច្ចក្នុងពេលវាកំពុងធ្វើចំបាំងយ៉ាងលេលាជាមួយចិន និងកូរ៉េ ។ ពីព្រោះវាបានសំលាប់ទុក្ករបុគ្គលនៅ*ណាកាសាគី* ពីព្រោះវាហ៊ានប៉ះនឹងព្រះវិហារ និងពីព្រោះវាបានចេញច្បាប់បណ្តេញពួកយើងទាំងអស់ចេញពីប្រទេសជប៉ុន ។ បើសិនជានៅពេលនោះពួកលោកសហការជាមួយយើង ធ្វើតាមមតិយើង ម៉ាប្រទេសជប៉ុននេះ នឹងក្លាយជាកាតូលិចតែម៉ាស្រករមនុស្សតែប៉ុណ្ណោះ ។ មើល ! តើអ្វីដែលជាសំខាន់ជាង ? ជំនួញ រឺការជួយស្រោចស្រង់អាត្ម័នមនុស្ស ?

- អាត្ម័នមនុស្សវាសំខាន់ ។ តែបើព្រះតេជគុណ បានបំភ្លឺខ្ញុំអោយយល់ពីការងារពួកអាតយហើយនោះ ទុកអោយខ្ញុំចាត់ចែងការងារពួកអាតយនេះអោយចំសាច់រឿង ។ មកដល់



www.budinst.gov.kh www.elibraryofcambodia.org

សព្វថ្ងៃនេះ គឺជុំប្រាក់ពួកអាតយដែលទាក់ទាញយកបានសូត និងមាសចិននោះ ។ លុយចំនេញដ៏សន្ធឹកសន្ធាប់ ដែលយើងបានមកហើយ ដែលយើងដឹកយកទៅម៉ាឡាកា និង*ក្វាំ* រួចយកទៅលីស្បោន គឺដើម្បីគាំទ្រចក្រភពរបស់យើងនៅអាស៊ីទាំងមូល ហើយនិងដើម្បីចិញ្ចឹមរាល់បន្ទាយ រាល់បេសកកម្ម រាល់សង្វែង រាល់ព្រះវិហារ ហើយនិងរ៉ាប់រង បើមិនទាំងអស់ក៏មួយភាគធំដែរនូវសកម្មភាពទាំងឡាយរបស់យើងនៅអឺរ៉ុប ហើយដែលខាឃាំងពួកអាបែកឆ្វេងអស់នេះកុំអោយមកដល់អាស៊ី និងកុំអោយពួកវាមកកាត់មុខកាត់មាត់យើងបាន ។ បើសិនជាយើងទប់ពួកវាមិនជាប់ទេ ពួកវាពិតជាមានទុនគ្រប់គ្រាន់ ដើម្បីកំទេចទាំងយើង កំទេចទាំងសាសនាយើងមិនខាន ។ មើល ! តើអ្វីទៅដែលជាសំខាន់ជាង ? គ្រិស្តសាសនាអេស្ប៉ាញ ប៉កទុយកាល់ និងអ៊ីតាលី រឺគ្រិស្តសាសនា អាតយ ?

*ដែឡាក្វា* សំលឹងមើលមេទ័ពនេះដោយក្រសែភ្នែកយ៉ាងមុត :

-ខ្ញុំសូមនិយាយម្តងទៀត គឺលោក-មិន-ត្រូវ-ជ្រៀត-ជ្រែក-ក្នុង-នយោបាយ-ផ្ទៃ-ក្នុង-ស្រុក-នេះ-ដាច់-ខាត ។

រមើកធ្យូងមួយដុំបានផ្ទុះ ហើយខ្ទាតធ្លាក់ទៅលើកំរាលព្រំ ។ *ភែរីរ៉ា* ដែលនៅជិតកន្លែងនោះជាងគេ ក៏លើកជើងទាត់វាចេញទៅ ។

-រួចចុះបើព្រះតេជគុណពត់...ពត់ខ្ញុំបាន តើតេជគុណចង់ចាត់ការយ៉ាងម៉េចជាមួយអាទមិឡនោះ ? រួចចុះ*តូរ៉ាណាកា* ?

*ដែឡាក្វា* អង្គុយចុះ ដោយលោកជឿថា លោកបានឈ្នះហើយ :

-អីលូវនេះខ្ញុំមិនទាន់ដឹងនៅឡើយទេ ។ តែគំនិតដែលថាចង់កំចាត់*តូរ៉ាណាកា* នោះគួរអោយអស់សំណើចណាស់ ។ វាមានសមានចិត្តនឹងពួកយើង ហើយក៏គាំទ្រគំនិតបង្កើនការជួញដូរទៀតផង...

សំលេង*ដែឡាក្វា* ចុះទាបជាងមុន :

- ហើយនិងការមានបានរបស់លោកផង ។

*ភែរីរ៉ា* តបវិញក្នុងកំហឹងដែលឆាបឆេះឡើងជាថ្មី :



www.budinst.gov.kh www.elibraryofcambodia.org

-ការមានបានរបស់ពួកយើងខ្ញុំ គឺសំរាប់បំពេញការងារព្រះជាម្ចាស់របស់យើង លោកដឹងច្បាស់ហើយទេតើ ។

*ដែឡាក្វា* ចាក់ស្រាដោយអាការៈប៉ក់ល្ងើយ ហើយហុចទៅ*កែរីវ៉ា* ដើម្បីលួងលោមបុរសនេះអោយត្រជាក់ចិត្ត :

-មក៍ ! គ្មានប្រយោជន៏អ្វីដែលយើងត្រូវឈ្លោះគ្នាពីរឿងនេះទេ ។ រឿងអាទមិឡនេះគឺពិតជាយ៉ាប់ហើយ ។ តែឈ្លោះប្រកែកគ្នា គឺគ្មានបានផលអ្វីទាំងអស់ ។ ពួកយើងត្រូវការមតិលោក ត្រូវការការគិតគូររបស់លោក ហើយនិងកំលាំងរបស់លោក ។ ជឿខ្ញុំចុះ *តូរ៉ាណាកា* គឺជារឿងងាប់រស់សំរាប់ពួកយើង ។ បើសិនជាគ្មានវា ដើម្បីទប់ពួកសមាជិកក្រុមប្រឹក្សាអាជ្ញាធុសិទ្ធិឯទៀតនោះទេ នគរនេះពិតជាធ្លាក់ចុះក្នុងភាពវឹកវរទៀតជាមិនខាន ។

*អាលវីតូ* បន្ទរតាម :

- ប្រាកដណាស់លោកមេបញ្ជាការ ។ តែខ្ញុំឆ្ងល់ណាស់ថា តើហេតុអ្វីបានជាមកដល់ពេលនេះហើយ *តូរ៉ាណាកា* នៅតែស្ថិតនៅក្នុងវិមាន ហើយយល់ព្រមលើកពេលប្រជុំរបស់ក្រុមប្រឹក្សាអីចឹង ?បើថាពួកនោះបង្ខិលគាត់បាន គឺមិនជឿសោះហើយ ។ ទោះជាយ៉ាងណាក៏គាត់ដឹងថា *អូសាកា* គឺជារូងខ្លា រូងនាគ តែចូលហើយមិនងាយចេញវិញបានទេ ។ គាត់គួរចាកចេញពីទីនេះតាំងពីប៉ុន្មានថ្ងៃមុនម្ល៉េះ ។

*កែរីវ៉ា* សួរឡើង :

- បើ*តូរ៉ាណាកា* ជាចំនុចងាប់រស់ ហេតុអីទៅគាំទ្រ*អូណូស៊ី* និង*គីយ៉ាម៉ា* ទៅវិញ ? ក្រែងអាពីរនាក់ហ្នឹងចូលខាង *អ៊ីស៊ីដូ* ប្រឆាំងនឹង*តូរ៉ាណាកា* អ្វី ? រួចហេតុអីក៏ពួកព្រះតេជគុណមិនជួយយោបល់ខ្ញុំអោយធ្វើអីចឹងទៅ ? យើងទើបពិភាក្សាជាមួយគ្នាពីម្សិលម៉្ងៃតើ !

- ពេលនោះពួកគេមកប្រាប់យើង ពីការសំរេចចិត្តរបស់ពួកគេ ។ ពួកយើងឥតបានពិភាក្សាអ្វីទេ ។

-តែពេលនោះព្រះតេជគុណគួរមានមតិដែរ ។ បើរឿងវាសំខាន់យ៉ាងនេះ ហេតុអីក៏មិនប្រាប់ពួកនោះកុំអោយធ្វើ ? ហើយបើពួកនោះនៅតែចង់ជំនះទៀត ព្រះតេជគុណអាចគំរាម



www.budinst.gov.kh www.elibraryofcambodia.org

បណ្តេញវាក្រៅសាសនាបានដែរតើ ?

*ដែឡាក្វា* ដកដង្ហើមធំ :

- ខ្ញុំបន់អោយតែវាងាយដូចមាត់លោកនិយាយទេ ។ នៅជប៉ុន ការគិតគូរមិនមែនបែបនេះទេ ។ ពួកវាស្អប់បំផុតរឿងលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់ពួកវា ។ សូម្បីតែនៅពេលដែលពួកយើងមានសំនើអ្វី ១ ក៏ត្រូវប្រយ័ត្នប្រយែងមែនទែនដែរ ។

*វ៉េកីរ៉ា* ទាញយកពែងប្រាក់មកចាក់ស្រាបណ្តើរ រំងាប់កំហឹងដែលមាននៅក្នុងខ្លួនបណ្តើរ ដោយគេដឹងច្បាស់ថា គេត្រូវការពួក*យេស៊ូត* មកនៅខាងខ្លួន ។ បើគ្មានពួកនេះជួយបកប្រែទេ រូបគេនឹងតែលតោលបាត់បង្អែកជាមិនខាន ។ អ្វែងត្រូវធ្វើយ៉ាងណាអោយដំណើរជើងនេះបានប្រកបដោយជោគជ័យណា-*វ៉េកីរ៉ា* គិតនៅក្នុងចិត្ត ។ អ្វែងធ្វើទាហាន បង្ហូរឈាម បង្ហូរញើសជប់មួយឆ្នាំហើយដើម្បីបំរើស្តេច ទំរាំបានត្រូវតែងតាំងជាមេបញ្ជាការសំពៅខ្មៅប្រចាំឆ្នាំនេះ ។ ហើយនេះសំរាប់តែមួយឆ្នាំនេះឯង ។ ខាន់ខៅបានកំនត់រួចហើយ ។ អ្វែងនឹងបានសូតមួយភាគដប់ ហើយនិងមួយភាគដប់នៃមាស ប្រាក់ និងប្រាក់ចំនេញដែលបានទៀត គឺអ្វែងក្លាយទៅជាអ្នកមានម៉ាអាយ៉ូស មិនមែនតែម៉ាអាយ៉ូសទេគឺសាមសិបអាយ៉ូសផង បើសិនជាអ្វែងមានអាយុប៉ុណ្ណឹងហើយនេះ គឺតែមួយជើងគត់ ។ អោយតែមួយជើងនេះបានជោគជ័យ ។

ដៃរបស់*វ៉េកីរ៉ា* លូកទៅចាប់ដងដាវ ដែលពាសទៅដោយក្បាច់ប្រាក់ដ៏ស្អាតរបស់ខ្លួន

- សំពៅខ្មៅរបស់ខ្ញុំត្រូវតែចេញពី*ម៉ាកាវ* មក*ណាកាសាគី* តាមពេលកំនត់ត្រឹមត្រូវ រួចនៅរដូវមូសុង ខែវិច្ឆិកាសំពៅខ្ញុំនឹងទៅ *គួរ៉ា* រួចទៅស្រុកតែម្តងហើយនេះគឺជាសំពៅមហាសាលបំផុតក្នុងប្រវត្តិសាស្ត្រ ។ អារឿងណឹងគឺត្រូវតែអឺចឹង ។

វាត្រូវតែអឺចឹង ទោះជាអញត្រូវដុតម៉ាស្រុកជប៉ុន ម៉ាម៉ាកាវ ម៉ាស្រុកចិនក៏ដោយ-*វ៉េកីរ៉ា* បន្ថែមនៅក្នុងពោះ ។

*ដែឡាក្វា* បន្តតាមដោយស្ងៀមស្ងាត់ :

-យើងបន់ស្រន់សូមតែលោកបានជោគជ័យទេ ។ ពួកយើងយល់ច្បាស់ណាស់ពីសារសំខាន់នៃដំណើររបស់លោក ។



www.budinst.gov.kh www.elibraryofcambodia.org

-បើអ៊ីចឹង តើព្រះតេជគុណមានយោបល់យ៉ាងម៉េចដែរ ? ខ្ញុំដាច់ជើងហើយបើគ្មានលិខិតធ្វើដំណើរចេញពីផែទេនោះ ។ តើយើងអាចរំលងក្រុមប្រឹក្សាអាជ្ញាធរសិទ្ធិបានទេ ? តើមាន ផ្លូវអ្វីផ្សេងទៀតទេ ?

*ដែឡាក្កា* គ្រវីក្បាល :

- មើល *ម៉ាកតាំង* ? អែងជាអ្នកឯកទេសក្នុងរឿងជួញដូរស្រាប់ ។

*ម៉ាកតាំង អាលវីត្ត* ឆ្លើយឡើង :

-អត់ទេ ។ ធ្វើយ៉ាងម៉េចក៏មិនកើតដែរ ។

មួយរយៈនេះ លោកបានស្តាប់ទាំងមិនពេញចិត្តនូវការប្រកែកគ្នារវាងអ្នកទាំងពីរ ។ នេះបានចំជាព្រហើន ក្រអឺតក្រទម វើរីកមែនអាកូនមីចោរនេះ-លោកគិតនៅក្នុងចិត្ត ។ ប៉ុន្តែបើសិនជាគ្មានមនុស្សដូចអស់នេះទេ ព្រះវិហារប្រហែលជារលត់រលាយនៅស្រុកនេះតាំងពីយូរណាស់មកហើយ ។ លោកពោលបន្តទៀត :

-ខ្ញុំគិតថា ក្នុងមួយថ្ងៃពីរទៀតអ្វី១នឹងត្រូវរួចរាល់ហើយលោកមេបញ្ជាការ ។ យ៉ាងយូរបំផុតមួយអាទិត្យ ។អីលូវនេះ *តួរ៉ាណាកា* កំពុងដោះស្រាយរឿងពិសេស ។ ខ្ញុំជឿថាអ្វី១នឹងស្រួលបួលវិញហើយ ។

-ខ្ញុំចាំម៉ាអាទិត្យទៀតចុះ ។ អត់លើសពីណឹងទេ ។

សំលេងពោរពេញដោយការគំរាមកំហែងរបស់ *វ៉ែកវីរ៉ា* លាន់ឡើងគួរអោយស្រៀវឆ្អឹងខ្នង

-ធើម៉េចចាប់អាទមិឡាណុងបាន ។ ខ្ញុំនឹងធ្វើអោយវាក្អួតរឿងពិតចេញមិនខាន ។ តើ *តួរ៉ាណាកា* មាននិយាយអីពីរឿងកងនាវាចរណ៍នោះទេ ? នាវាចរណ៍ខ្លាំងណា ?

- អត់មានទេ ។

- ខ្ញុំចង់ដឹងការពិតណាស់ ។ ពីព្រោះនៅលើសមុទ្រ សំពៅខ្ញុំដែលផ្ទុកច្រើនយ៉ាងនេះមិនខុសអីពីមេជ្រូកសំអៀចនោះទេ ។ សំពៅយើងនេះជាសំពៅធំជាងគេបំផុតក្នុងពិភពលោក តែខ្ញុំគ្មានសំពៅការពារអមដំណើរទេ អ៊ីចឹងសំពៅចំបាំងតែម៉ាគ្រឿងវីក៏អាសំពៅ *អេរ៉ាស* ចោលម្រាមវានេះក៏ចាត់ការបានយ៉ាងធូរល្ហុយ ។ យកល្អអា *អ៊ិញ្ញគីលីស* មិនត្រូវចុះសំពៅវិញទាំងកាណុង ទាំងអ្នកបាញ់ ទាំងវិសេវនោះដែរ... ។

*វ៉ែកវីរ៉ា* គ្រេបស្រាបឆ្លើយទើបបន្តទៀត ។

-អង្កាល់ទើបគេបញ្ជូនអា *អ៊ិញ្ញគីលីស* ទៅ *អ៊ីស៊ូ* ?



www.budinst.gov.kh www.elibraryofcambodia.org

*អាលវីតូ* តប :

-*តូរ៉ាណាកា* អត់និយាយទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ឆាប់ៗនេះហើយ ។

- ថ្ងៃនេះអ្វី ?

- ខ្ញុំមិនដឹងដែរ ។ អីលូវនេះក្រុមប្រឹក្សាអាជ្ញានុសិទ្ធិសំរេចនឹងបើកការប្រជុំក្នុងបួនថ្ងៃទៀត អីចឹងហើយខ្ញុំគិតថា ប្រហែលជាក្រោយសម័យប្រជុំនេះ ។

*ដៃឡាក្វា* និយាយឡើងយ៉ាងធូនំពាប់ :

- *ប្លាក់ថន* មិនត្រូវប៉ះពាល់ទេ ។ ទាំងវា ទាំង *តូរ៉ាណាកា* ។

*វ៉ៃរីវ៉ា* ក្រោកឈរឡើង :

-ខ្ញុំត្រលប់ទៅសំពៅវិញហើយ ។ ព្រះតេជគុណអញ្ជើញទៅបាយល្ងាចជាមួយខ្ញុំអ្វី? អញ្ជើញទាំងពីរតែម្ដង ! ពេលព្រលប់ណា ។ នៅសំពៅមានម្ហូបឆ្ងាញ់ ហើយស្រាធុនលេខមួយទៀតផង ។

*ដៃឡាក្វា* តបទាំងញញឹម :

-សូមអរគុណ ។ មានអីទៅសាកម្ហូប និងស្រាលោកម្ដងទៀតចុះ ។

*អាលវីតូ* បន្ថឺឡើង :

-នៅពេលណាដែលខ្ញុំបានបណ្ដាំរបស់ *តូរ៉ាណាកា* ខ្ញុំនឹងជំរាបលោកភ្លាម ។

- អរគុណ ។

នៅពេលដែល *វ៉ៃរីវ៉ា* ចេញទៅបាត់ និងនៅពេល *ដៃឡាក្វា* ច្បាស់ថា គ្មានអ្នកណាលឺកិច្ចសន្ទនាទេនោះ ទើបលោកសួរទៅ *អាលវីតូ* ទាំងព្រួយបារម្ភ :

- *ម៉ាកតាំង* !តើ *តូរ៉ាណាកា* មាននិយាយអីទៀតទេ ?

-គាត់អោយយើងធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរពីរឿងជំនួញអាវុធហើយនិងសំនើពួក *កុងតីស្តាឌ័រ* ។

- អាកូនមីចោរ...

- *តូរ៉ាណាកា* ថ្ងៃនេះរាក់ទាក់ស្និទ្ធស្នាលណាស់ តែ...តែ...តែខ្ញុំមិនដែលឃើញគាត់បែបនេះទេ តាំងពីដើមរៀងមក ។

- មើល ! សំដីវាថាម៉េចខ្លះ ?

- នេះគឺសំដីរបស់ *តូរ៉ាណាកា* : " ខ្ញុំដឹងថា អតីតគណៈសង្ឃរបស់ *លូតូ-សាន*



www.budinst.gov.kh www.elibraryofcambodia.org

គឺព្រះតេជគុណ *ដាគុណាបា* បានសរសេរលិខិតទៅអភិបាលក្រុង *ម៉ាការ កូវ៉ា* ហើយនិងឧបរាជ អេស្ប៉ាញនៅ *ម៉ានីល* ឈ្មោះ *ដុងស៊ីស្កូ-អ៊ី-វីវេរ៉ា* កាលពីខែកក្កដាឆ្នាំ១៥៩៨ ស្នើកងទ័ព អេស្ប៉ាញប៉ុន្មានរយនាក់អោយវាយលុកជប៉ុនដើម្បីគាំទ្រពួក *វែងមីញ៉ូ* គ្រិស្តសាសនិក ដែលសហការជាមួយគណៈសង្ឃ លោកប៉ុនប៉ងផ្តួលរំលំអម្ចាស់របស់ខ្ញុំ គឺ *តែកូ។ វែងមីញ៉ូ* ទាំងនោះឈ្មោះអ្វីខ្លះ ? តើជាការពិតទេ ដែលគេមិនបានបញ្ជូនទាហានមកមែន តែគេបានបញ្ជូនអាវុធជាច្រើន ពី *ម៉ាការ* មក *ណាកាសាគី* ដោយប្រើព្រះវិហារជាឃ្លាំងបិទបាំងនោះ? តើជាការពិតទេ ដែលឯកអគ្គរាជទូតមកពី *កូវ៉ា* ក្នុងខែមីនា រឺមេសា ឆ្នាំ ១៥៩០ បានចាប់អាវុធទាំងនេះ ហើយបញ្ជូនចេញជាសំងាត់ពី *ណាកាសាគី* ទៅ *ម៉ាការ* វិញតាមសំពៅ *សាន់តាគ្រូស* នោះ ?

រំលឹកសំដី *តូរ៉ាណាកា* រូចបញ្ឈិត *អាល់វីតូ* យកដៃជូតញើសដែលនៅនឹងថ្ពាសរបស់ខ្លួនចេញ ។

- *តូរ៉ាណាកា* មាននិយាយអីទៀតទេ ?

- ដូចជាគ្មានអីសំខាន់ទៀតទេ ។ ខ្ញុំមិនទាំងមានពេលពន្យល់គាត់ផង.....គាត់អោយខ្ញុំចេញមកតែម្តង ។ គាត់អោយខ្ញុំចេញមកយ៉ាងគួរសមទេ តែអានេះក៏ដូចជាបណ្តេញដែរ ។

- រួចចុះអា *អ៊ិញគីលិស* ឧត្បាតនេះ វាបានពត៌មានទាំងហ្នឹងពីណាមក ?

- ខ្ញុំបន់អោយតែដឹងដែរហ្នឹង ។

- ទាំងថ្ងៃ ខែ ទាំងឈ្មោះ លោកពិតជាមិនច្រលំមែន ? *តូរ៉ាណាកា* ពិតជានិយាយអ៊ីចឹងមែន ?

- ខ្ញុំមិនច្រលំទេទាន ។ ឈ្មោះទាំងអស់សរសេរនៅលើក្រដាសមួយសន្លឹក ។ *តូរ៉ាណាកា* ថែមទាំងបង្ហាញអោយខ្ញុំមើលទៀត ។

- ជាអក្សររបស់ *ប្លាក់ថន* អ្វី ?

- អត់ទេទាន ។ ឈ្មោះទាំងអស់សរសេរជាភាសាជប៉ុនទេ ។

-យើងត្រូវស៊ើបសួររកមើលថា តើអ្នកណាជាអ្នកបកប្រែអោយ *តូរ៉ាណាកា* ? អាអ្នកបកនោះ គឺពិតជាពួកែមែន ។ ច្បាស់ជាមិនមែនពួកយើងទេ មែនទេ ? មិនមែនតេជ



www.budinst.gov.kh www.elibraryofcambodia.org

គុណ *ម៉ានុយអែល* ទេ មែនទេ ?

សំដឹបពួជិត *ដៃឡាក្វា* ពោរពេញទៅដោយការជូរចត់ ។ *អេម៉ានុយអែល* គឺជាឈ្មោះក្នុងគ្រិស្តសាសនារបស់ *ម៉ាសាម៉ាទូ ជីរ៉ូ* ដែលជាកូនរបស់ *សាមូរ៉ៃ* គ្រិស្តសាសនិកម្នាក់ ហើយដែលបានទទួលការអប់រំពីពួក *យេស៊ូត* តាំងពីនៅកុមារភាពម្ល៉េះ ។ អាស្រ័យដោយស្មារតីវាងវៃ និងទឹកចិត្តអំនត់ព្យាយាម លោកត្រូវបានជ្រើសតាំងអោយចូលរៀននៅសាលាធម៌ដើម្បីបានក្លាយជាបព្វជិតដំបូងគេបង្អស់ ។ *ជីរ៉ូ* រស់នៅជាមួយសមាគមព្រះយេស៊ូអស់ម្ភៃឆ្នាំ រួចស្រាប់តែដោយគ្មានមូលហេតុអ្វីទាំងអស់លោកបានចាកចេញពីសមាគមនេះ នៅមុនពេលដែលលោកចូលជាបព្វជិតពេញសិទ្ធិ ហើយលោកបានក្លាយទៅជាអ្នកប្រឆាំងនឹងព្រះវិហារដ៏ខ្លាំងក្លាជាងគេបំផុតទៅវិញ ។

*អាល់វីតូ* តបឡើង :

- អត់ទេ ។ *ម៉ានុយអែល* នៅឯ *ត្សូស៊ូ* នៅឡើយទេ ហើយវាក៏ជាសត្រូវប្ដូរផ្ដាច់នឹង *តូរ៉ាណាកា* ផងដែរ ហេតុនេះគ្មានរឿងអីវាត្រូវជួយ *តូរ៉ាណាកា* នោះទេ ។ សំនាងដែរដែលវាមិនជំពាក់ជំពិនក្នុងរឿងសំងាត់នយោបាយអីទាំងអស់ ។ តាមពិតទៅអ្នកបកប្រែ គឺលោកស្រី *ម៉ារីយ៉ា* ទេ ។

*ម៉ារីយ៉ា* គឺជាឈ្មោះក្នុងគ្រិស្តសាសនារបស់ *តូដា ម៉ារីកូ* ។

- *តូរ៉ាណាកា* ប្រាប់លោកអ្វី ?

- អត់ទេព្រះតេជគុណ ។ តែខ្ញុំបានដឹងថា នាងបានទៅវិមាន ហើយគេបានឃើញនាងជាមួយ *អ៊ិញគីលីស* នោះ ។

- លោកច្បាស់ហើយណឹង ?

- ពត៌មានរបស់ខ្ញុំសុទ្ធតែត្រឹមត្រូវហើយទាន ។

*ដៃឡាក្វា* ឧទានឡើង :

- ល្អ ! នេះប្រហែលជាព្រះមិនបិទផ្លូវយើងហើយ ។ ចាត់អោយគេទៅហៅនាងមក ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំបានជួបនាងហើយទាន ។ ខ្ញុំធ្វើជាជួបនាងដោយចៃដន្យ ។ នាងនៅតែប្រិមប្រិយ នៅតែផ្អែមល្ហែម នៅតែស្រគត់ស្រគំ ពីមុនយ៉ាងម៉េចអីលូវនេះក៏តែប៉ុណ្ណឹង ។ ខ្ញុំមិនទាន់បានសួរនាងផង នាងនិយាយយ៉ាងច្បាស់លាស់មកកាន់ខ្ញុំមុនទៅហើយថា : "ចាស៎ ! ចក្រភព គឺជាទឹកដីនៃអាថិកំបាំង ហើយមានរឿងមួយចំនួនគេតែងមានទំលាប់រក្សាវាជាអាថិកំបាំងអីចឹង ។ ក្រែងនៅប៊ីកទុយកាល់ និងសមាគមព្រះយេស៊ូក៏មានលក្ខណៈដូចគ្នាដែរតើ មែនទេ ? "

- លោកជាអ្នកទទួលលាងបាប និងស្ដាប់ខមាទោសនាងណា៎ !

- ពិតហើយ តែនាងនឹងមិននិយាយអ្វីទាំងអស់ ។

- ហេតុអី ?

- នាងពិតជាត្រូវគេព្រមានជាមុន ហើយនិងហាមឃាត់មិនអោយនិយាយពីអ្វីដែលកើតមានឡើងនៅពេលនោះ និងអ្វីដែលត្រូវបាននិយាយហើយ ។ ខ្ញុំស្គាល់ពួកនេះច្បាស់ណាស់ ។ ក្នុងបញ្ហាអីចឹង១ ឥទ្ធិពលរបស់ *គូរ៉ាណាកា* ពិតជាខ្លាំងក្លាជាងពួកយើងហើយ ។

- ជំនឿសាសនារបស់នាងខ្សោយយ៉ាងណឹងមែន ? តើការប្រៀនប្រដៅរបស់យើងចំពោះនាងវាគ្មានបានការអីសោះតែម្ដងទៅអ្វី ? ច្បាស់ជាមិនមែនទេ ។ នាងគោរពសាសនាហើយព្យាយាមជាងនារីណាទាំងអស់ដែលខ្ញុំបានជួប ។ ថ្ងៃណាមួយនាងអាចក្លាយទៅជាដូនជីជាមិនខាន ហើយអាចក្លាយជាសង្ឃរាជព្រះវិហារជប៉ុនដំបូងគេផង ។

- ពិតហើយ ។ ប៉ុន្តែនាងពិតជាមិននិយាយអីទាំងអស់នៅពេលនេះ ។

- ព្រះវិហារកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ។ អារឿងនេះសំខាន់ណាស់ ។ អាចនិយាយថាសំខាន់ហួស ។ នាងពិតជាយល់ពីចំនុចនេះ ។ នាងវាងវៃណាស់ ហេតុនេះច្បាស់ជាយល់ពីសារសំខាន់នៃបញ្ហានេះជាមិនខាន ។

- ខ្ញុំសូមអង្វរព្រះតេជគុណ សូមកុំយកជំនឿសាសនារបស់នាងមកសាកល្បងបែបនេះ ។ សាករបៀបនេះ យើងពិតជាខាតមិនខាន ។ នាងក៏បានប្រាប់ខ្ញុំជាមុនហើយដែរ ។ ហើយសំដីនាងច្បាស់លាស់ជាងទឹកខ្មៅលើក្រដាសទៅទៀត ។

- ជូនកាលល្អដែរ ដែលយើងសាកល្បងនាងនោះ ។ នេះដើម្បីវិញ្ញាណក្ខន្ធនាងបានរួច



www.budinst.gov.kh www.elibraryofcambodia.org

បាបផង ។

- រឿងនេះស្រេចតែព្រះតេជគុណទេ ដែលត្រូវសំរេចថាសាក រឺមិនសាកនោះ ។ ខ្ញុំបារម្ភថា នាងពិតជាគោរពតាម *តូកំណាកា* ហើយមិនមែនពួកយើងទេ ។

- ចាំខ្ញុំគិតមើលពីរឿង *ម៉ារីយ៉ា* នេះ ។ ណឹងហើយ ចាំខ្ញុំគិតមើលសិន ។

ក្រសែភ្នែករបស់បព្វជិត *វ៉ែឡាក្វា* សំលឹងមើលទៅរងើកភ្លើងដែលកំពុងឆេះនៅ ចង្ក្រាន ។ គួរអោយអាណិត *មារីយ៉ា* ដែរ ។ *អាស៊ុក្វូតីលើស* ចង្រៃវាយកំ ! អីលូវនេះតើ យើងធ្វើយ៉ាងម៉េចដើម្បីគេចពីអន្ទាក់នេះបាន ? តើលាក់អារឿងកាំភ្លើងនេះយ៉ាងម៉េច ជិត ? ចុះហេតុអីបានជាគណៈសង្ឃ *ដាតុនបា* ដែលមានបទពិសោធន៍ជាក់ស្តែងជាងប្រាំពី ហើយនៅម៉ាកាវ និង ជប៉ុនមកធ្វើការភាន់ច្រលំយ៉ាងនេះទៅវិញ ?

ហេតុអី ? ក្រសែភ្នែករបស់ *វ៉ែឡាក្វា* ហាក់ដូចជាប្រឹងសួរទៅអណ្តាតភ្លើង ដែ កំពុងឆាបឆេះភ្លឹបភ្លែត១ ក្នុងចង្ក្រាន ។

តាមពិតចំលើយងាយសោះ -បព្វជិត *វ៉ែឡាក្វា* គិតនៅក្នុងចិត្ត ។ ព្រោះអ្វី១ វាងា ពេក ។ រឺមួយអ្វែងស្ងួនស្ងោ រឺមួយអ្វែងភ្លេចពីរស្មីធម៌ព្រះ រឺមួយអ្វែងមោទនភាពហួស មួយអ្វែងក្រអឺតក្រទមពេក ។ អ្នកណាមិនធ្លាក់ក្នុងស្ថានភាពបែបនេះ បើសិនជាស្ថិតនៅ បរិយាកាសដូចគ្នានោះ ? ត្រូវ *វ៉ែកូ* ទទួលទាំងព្រលឹមអុរ ក្នុងកិត្តិយសតគ្រឹកគគ្រេង ហាក់ដូច *វ៉ែកូ* ប្រុងប្រៀបតែនឹងចូលសាសនា រួចភ្ញាក់ឡើងនៅកណ្តាលអធ្រាត្រដោយទទួលអាជ្ញាប *វ៉ែកូ* ដដែលនេះ អោយអ្នកបួសគ្រិស្តសាសនិកទាំងអស់ចេញផុតពីប្រទេសជប៉ុនជារៀងរ ក្នុងរយៈពេលម្ភៃថ្ងៃ បើមិនយ៉ាងដូច្នោះទេត្រូវសំលាប់ចោលទាំងអស់ ។ អាក្រក់ជាងនេះ ទៀត គឺបញ្ជាដែលកំនត់អោយជនជាតិជប៉ុន ដែលចូលគ្រិស្តសាសនាទូទាំងប្រទេសជប៉ុនអោ បោះបង់ចោលសាសនានេះ បើមិនយ៉ាងដូច្នោះទេ នឹងត្រូវនិរទេស រឺប្រហារជីវិតបង់ ។

ដោយការអស់សង្ឃឹម ទើបព្រះតេជគុណប្រធានគណៈសង្ឃបានស្ទុះស្ទាញជំរុញអោ ពួក *ដែមីញ៉ូ* គ្រិស្តសាសនិកនៅតំបន់ត្យូស៊ូ រួមទាំង *អូណូស៊ី មីសាគី គីម៉ាយ៉ា* និង *បារីម៉ា* តំបន់ណាកាសាគីផង អោយងើបឡើងធ្វើការបះបោរដើម្បីការពារព្រះវិហារ ទន្ទឹមនោះលោ



www.budinst.gov.kh www.elibraryofcambodia.org

បានផ្ញើសារយ៉ាងប្រញាប់ប្រញាល់ ស្នើសុំពួក *កុងគីស្តាឌ័រ* អោយមកជួយពួកបះបោរ ។

រវើកនៅផែះផេសផស់ក្នុងចង្រ្កាន។ ពិតណាស់ ! ទាំងអស់នេះគឺជាការពិត។ បើសិនជាកាលនោះអញបានដឹង រឺបើសិនជា *ដាគុនហា* សួរយោបល់អញមុនវាផ្សេងទៅហើយ ។ តែបន្ទោសលោកម៉េចនឹងកើត ? ផ្ញើសំបុត្រពីជប៉ុនទំរាំដល់ *ក្វាំ* ស៊ីពេល ៦ខែ ទៅហើយ។ ត្រលប់មកវិញស៊ីពេលអស់ប្រាំមួយខែទៀតឯណោះ។ពេលនោះអញទទួលសំបុត្ររបស់ឧបរាជ នៅ *ក្វាំ* តែងតាំងអញជាឯកអគ្គរាជទូត តែទំរាំមកដល់ម៉ាកាវ ក៏ស៊ីពេលរាប់ខែទៅហើយ។ ពេលនោះ *ដាគុនហា* ស្លាប់បាត់ទៅហើយ។ សង្ឃគ្រិស្តសាសនាត្រូវបាមឃាត់មិនអោយចូលជប៉ុនឡើយ បើហ៊ានបំពានត្រូវមានទោសប្រហារជីវិត ។

ដាគុនហា ស្លាប់ តែកាំភ្លើងបានបញ្ជូនរួចទៅហើយ ។

កន្លងពីនោះបានដប់អាទិត្យ ទើបមានដំណឹងថា គេមិនបិទព្រះវិហារវិញ ហើយអាជ្ញាអោយបណ្តេញបព្វជិតគ្រិស្តសាសនិកនោះ ក៏មិនបានអនុវត្តទេដែរ។ ព្រះវិហារប្រហែលហាសិបត្រូវដុតចោល មានតែព្រះវិហារនៅ *ភាកាឃ៉ាម៉ា* ទេ ដែលត្រូវកំទេចមិត់នោះ។ កាលនោះគេបានអោយដឹងថា ថ្វីត្បិតតែអាជ្ញារបស់ *តៃកូ* នៅតែជាធរមានក្តី ក៏ *តៃកូ* យល់ព្រមអោយអ្វីៗនៅដូចក្នុងស្ថានភាពមុនដដែល បើសិនណាជាពួកបព្វជិតគ្រិស្តសាសនិកទាំងអស់ យល់ព្រមបញ្ចូលសាសនាកុំចំហពេក និងអោយមានអាកប្បកិរិយាសមរម្យ ។ ទន្ទឹមនោះមិនត្រូវមានការគោរពបូជាជាសាធារណៈពេក ហើយក៏ត្រូវឃាត់ពួកគ្រិស្តសាសនិកទាំងអស់ មិនអោយដុត បំផ្លាញវត្តព្រះពុទ្ធសាសនាឡើយ ។

គឺក្រោយពីទទួលដំណឹងទាំងនេះទេ ទើប *ផែឡាក្វា* នឹកឃើញពីរឿងកាំភ្លើងដែលព្រះតេជគុណ *ដាគុនហា* ស្នើសុំ ហើយដែលកំពុងលាក់នៅក្នុងឃ្លាំងអីវ៉ាន់របស់ពួក *យេស៊ូត* នៅឯណា *កាសាគី* នោះ ។

កាលនោះអញថ្កូចរស់នៅលើរទេះភ្លើងអស់រាប់អាទិត្យ - *ផែឡាក្វា* រំលឹកនៅក្នុងចិត្ត ។ ទំរាំតែលួចបញ្ជូនកាំភ្លើងទៅម៉ាកាវវិញ មួយថ្ងៃៗនឹកភ័យតែបែកការណ៍ ។ តែទោះជាចប់រឿងរ៉ាវក្តី ក៏អញមិនដែលបានស្ងប់ចិត្តសោះ ទោះជាអញចង់ រឺប្រឹងសូត្រធម៌យ៉ាងណាក្តី ។

តើ *អាគិញ្ញគីលីស* មេឧត្បាតនេះ ដឹងប៉ុនណាទៅ ?



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងរយៈពេលជាងមួយម៉ោង ដែលបព្វជិត *វ៉េឡាក្វា* អង្គុយឥតកំរើកនៅលើកៅ បង្អែកខ្ពស់របស់លោក ភ្នែកសំលឹងជាប់ទៅចង្ក្រានភ្លើង ។ *អាល់វីតូ* នៅឈររង់ចាំយ៉ាងអត់ធ្ កែរ្សរទូដាក់សៀវភៅ ដៃទាំងពីរអោបដាក់លើពោះ ។ ពន្លឺព្រះអាទិត្យរត់រេរាំនៅលើរូបព្រះឆ្ ធ្វើអំពីប្រាក់មួយ ដែលព្យួរនៅលើជញ្ជាំងពីក្រោយខ្នងរបស់ *វ៉េឡាក្វា* ។ នៅលើជញ្ជាំងមួ ទៀតមានរូបគំនូរប្រេងមួយដែលគូរដោយជាងគំនូរក្រុង *វ៉ឺនីស* ឈ្មោះ*ទីត្យាន* ហើយដែ *វ៉េឡាក្វា* បានទិញនៅ *ប៉ាឌូអា* កាលក្នុងវ័យយុវជន នៅពេលដែលឪពុកលោកបញ្ជូន លោក រៀនច្បាប់នៅទីនោះ ។ ជញ្ជាំងមួយជ្រុងទៀតមានសុទ្ធតែសៀវភៅ និងគម្ពី *ប៊ីប* របស់លោ ជាភាសាឡាតាំង ប៉័កទុយកាល់ អ៊ីតាលី និងអេស្ប៉ាញ ។ ហើយនៅលើធ្នើរពីរផ្សេងទៀត ម សៀវភៅជាភាសាជប៉ុន ដែលពួក*យេស្វិត* បានបកពីឡាតាំង ហើយដែលត្រូវបានបោះពុម្ពដោ មាស៊ីនបោះពុម្ពរបស់ក្រុម *យេស្វិត* ដែលនាំមកយ៉ាងលំបាកលំបិន និងដោយអស់សោហ៊ុ យ៉ាងច្រើនពី *ក្វាំ* មក ។ នៅមានសៀវភៅដែលបកប្រែពីជប៉ុនទៅជាភាសាឡាតាំងថែមទៀ ដើម្បីប្រឹងប្រែងអប់រំជនជាតិជប៉ុនដែលចូលសាសនាអោយចេះភាសានេះ ។ ក្រៅពីនេះ ម គូនសៀវភៅពីរដែលកាត់ថ្លៃមិនបាន ។ មួយគឺសៀវភៅវេយ្យាករណ៍ប៉័កទុយកាល់-ជប៉ុនដំបូ បង្អស់ដែលត្រូវបានបោះពុម្ពផ្សាយកាលពីប្រាំមួយឆ្នាំមុន ហើយដែលជាលទ្ធផលនៃការប្រឹ ប្រែងមួយជីវិតរបស់តេជគុណ *សង់សូអាល់វ៉ារេស* និងក្រុមរបស់លោក ។ សៀវភៅមួយទៀ គឺ ជាវចនានុក្រមប៉័កទុយកាល់ -ឡាតាំង -ជប៉ុន ដែលទើបបានបោះពុម្ពផ្សាយកាលពីឆ្នាំម ដោយប្រើអក្សរឡាតាំង និង *ហ៊ីរ៉ាកាណា* ។ នេះជាវចនានុក្រមភាសាជប៉ុនដំបូងបំផុត ដែលប្រ បានរៀបចំឡើង ហើយដែលបព្វជិត *វ៉េឡាក្វា* បានបញ្ជាអោយគេរៀបចំតាំងពីម្ភៃឆ្នាំម ម្ល៉េះ។

បព្វជិត *អាល់វីតូ* ឈោងចាប់យកសៀវភៅនេះ ហើយយកវាមកអង្អែលដោយទឹ ចិត្តស្រលាញ់យ៉ាងជ្រាលជ្រៅ ។ លោកដឹងថា នេះគឺជារតនវត្ថុដ៏មានតំលៃបំផុតនៅលើលោ នេះ ។ ក្នុងរយៈពេលដប់ប្រាំឆ្នាំដែលលោកបានប្រឹងប្រែងចងក្រងវចនានុក្រមនេះឡើង វចនានុក្រមដែលមានពាក្យពន្យល់ល្អិតល្អន់ ហើយនេះក៏ជាវណ្ណកម្មមួយមិនចាញ់វណ្ណកម្មរបស់



www.budinst.gov.kh www.elibraryofcambodia.org

បព្វជិត *សង់សូអាល់វ៉ាលេស* ដែរ ។ បព្វជិត *អាល់វីតូ* ដឹងយ៉ាងច្បាស់ថា បើសិនជាឈ្មោះរបស់លោកត្រូវគេរំលឹកជារៀងរហូតនោះ គឺក៏ដោយសារតែសៀវភៅនេះនិងព្រះតេជគុណ *វ៉ៃឡាញ៉ា* តែប៉ុណ្ណោះ ។ បព្វជិត *អាល់វីតូ* នៅចាំមិនភ្លេចទេ នៅពេលដែលលោកបានជួបជាមួយព្រះតេជគុណគណៈអធិការសង្ឃនេះ នៅលើកទីមួយ :

- អែងចង់ចេញពីប្រទេសប៉ក់ទុយកាល់ ហើយដាក់ខ្លួនបំរើធម៌ព្រះមែនអ្វី ?

- បាទ មែន ។ សូមព្រះតេជគុណជួយខ្ញុំផង ។

- អែងអាយុប៉ុន្មានហើយ ?

- ខ្ញុំមិនដឹងដែរ ព្រះតេជគុណ.... ប្រហែលដប់ រឺម៉ាដណ្តប់ឆ្នាំអីប៉ុណ្ណឹង តែខ្ញុំអានបានសរសេរបាន ព្រោះបានបព្វជិតឯទៀតជួយបង្ហាត់បង្ហាញខ្ញុំ ។ ខ្ញុំជាក្មេងកំព្រាគ្មានញាតិផៅអ្វីទាំងអស់ ខ្ញុំគ្មានជាប់ជំពាក់នឹងអ្នកណាទេ ។

រួច *វ៉ៃឡាញ៉ា* បាននាំលោកទៅ *កូវ៉ា* រួចមក *ណាកាសាគី* ជាកន្លែងលោកបានចូលរៀនសាលាធម៌របស់សមាគមព្រះយេស៊ូ ។ លោកគឺជាជនជាតិអឺរ៉ុបក្មេងជាងគេបំផុតនៅអាស៊ី ។ លោកមានសំនាងរៀនភាសាឆាប់ចេះស្ទាត់ ហើយលោកក៏បានត្រូវគេទុកចិត្តតែងតាំងជាអ្នកបកប្រែ និងជាទីប្រឹក្សាពាណិជ្ជកម្ម ។ ដំបូងលោកធ្វើការជាមួយ *ហារីម៉ា គាដាអូ* ជា *ដៃមីញ៉ូ* នៅ *ហ៊ីសិន* ក្នុងតំបន់ *គូស៊ូ* ដែលត្រួតទាំង *ណាកាសាគី* ផងនោះ ។ រួចបន្ទាប់មកទៀត លោកបានទៅធ្វើការជាមួយ *តៃកូ* ផ្ទាល់តែម្តង ។

នៅទីបំផុត *វ៉ៃឡាញ៉ា* ក្រោកឈរពត់ខ្លួនបន្តិច ហើយដើរទៅមាត់បង្អួច ។ ពន្លឺព្រះអាទិត្យចាំងផ្ទេកៗនៅលើក្បឿងពណ៌មាស និងដែលមានរាងងខ្ចីតនៃដំបូលសើនរបស់វិមាន ។ នេះជាវិមានបិសាចតែម្តង - *វ៉ៃឡាញ៉ា* គិតនៅក្នុងចិត្ត ។ តើវិមាននេះអាចស្ថិតនៅបានប៉ុន្មានឆ្នាំទៅ ? កាលនោះ គឺកាលពីដប់ប្រាំឆ្នាំមុន.........ទេ គឺដប់ប្រាំពីរឆ្នាំមុន ដែល *តៃកូ* បានយកមនុស្សសែសិបម៉ឺននាក់មកជីក និងសាងសង់វិមាននេះ ។ ប្រទេសទាំងមូលត្រូវរឹងខ្សោះ ហើយវិមានដ៏ធំសំបើមនេះ ត្រូវសាងសង់ហើយតែក្នុងរយៈពេលពីរឆ្នាំតែប៉ុណ្ណោះ។ អាគាត់ *តៃកូ* នេះចំជាអស្ចារ្យមែន ! ពួកជនជាតិជប៉ុននេះក៏ចំជាអស្ចារ្យមែន ! ហើយអីលូវនេះវិមាន *អូសាកា*



www.budinst.gov.kh www.elibraryofcambodia.org

ឈរជ្រងោ គ្មានអ្វីមកកំទេចបានឡើយ លើកលែងតែកណ្ដាប់ដៃរបស់ព្រះជាម្ចាស់ ។ គ្មានអ្វីទប់នឹងមហិទ្ធិរិទ្ធិរបស់ព្រះអង្គបានទេ ។ ឱព្រះអង្គអើយ សូមជួយខ្ញុំអោយធ្វើអោយសំរេចនូវឆន្ទៈរបស់ព្រះអង្គផងចុះ ។

នៅទីបញ្ចប់ *ដៃឡាក្កា* និយាយក្នុងសំដីយ៉ាងម៉ឹងម៉ាត់ ដូចជាដំណើរចុះឡើងរបស់លោកផងដែរ :

- *ម៉ាកតាំង* ! អីលូវនេះមើលទៅយើងមានការធ្វើហើយ ។ ក្នុងរឿងអាតែកុងអង់គ្លេសនេះ បើយើងមិនការពារវាទេ វាអាចត្រូវគេសំលាប់បាន ហើយពេលនោះយើងអាចបាត់ការអនុគ្រោះរបស់ *គូរ៉ាំណាកា* ។បើយើងចេះការពារនោះ គង់តែដល់ពេលណាមួយវាចងកខ្លួនវាទេ ។ តែតើយើងហ៊ានរង់ចាំទេ ? វត្តមានរបស់វា គឺជាការគំរាមកំហែងមួយដល់យើងទៅហើយ នេះមិនទាន់គិតថាទំរាំដល់ថ្ងៃដែលវាចងកនោះ មិនដឹងជាវានាំចង្រៃអីខ្លះផង ។ រឺមួយយើងអាចជួយ *គូរ៉ាំណាកា* អោយចាត់ការវាចោលបានទេ ? រឺមួយយើងអាចបញ្ចុះបញ្ចូលវាអោយចូលនិកាយយើងបានទេ ?

*អាល់វីតូ* ស្ទើរមិនជឿត្រចៀករបស់ខ្លួន ។ ភ្នែករបស់លោកព្រិចញាប់ទទ្រើក :

- ព្រះតេជគុណថាម៉េច ?

- អាតែកុងនោះ ជាមនុស្សឆ្លាតណាស់ ហើយវាដឹងរឿងរ៉ាវច្រើនពីនិកាយកាតូលិចយើង ។ តាមពិតទៅពួកអង់គ្លេសក៏នៅមានជំនឿលើនិកាយកាតូលិចនៅឡើយដែរទេ នៅក្នុងដួងចិត្តរបស់ពួកវា ។ ចំលើយងាយណាស់បើសិនជាព្រះរាជា រឺ ព្រះរាជនីរបស់ពួកវាជាកាតូលិច មិនមែនប្រូតេស្តង់ដូចសព្វថ្ងៃនោះ ពួកអង់គ្លេសនេះវាមិនទៅខ្វល់អីពីរឿងសាសនានោះទេ ។ ពួកវាពុលនឹងប្រឆាំងយើងក្នុងពេលនេះ តែនេះក៏មកតែពីរឿងកងសំពៅយើងតែប៉ុណ្ណោះឯង ។ *ញ៉ាក់ផុន* អាចមានផ្លូវចូលសាសនាបាន ។ បើបានយ៉ាងដូចនេះ គឺពិតជាដំណោះស្រាយមួយយ៉ាងល្អបំផុត ។ ល្អទាំងចំពោះធម៌ព្រះ ល្អ ទាំងចំពោះវិញ្ញាណក្ខន្ធអាទមិឡនោះ ។

បន្ទាប់មកទៀត គឺ *គូរ៉ាំណាកា* ។ យើងនឹងអោយផែនទីដែលគាត់ទាមទារនោះបាន ។ ត្រូវពន្យល់គាត់អំពី " ដែនឥទ្ធិពល " ។ ហើយនេះមិនខុសទេ ។ តើអាខ្មៅរំបែងចែកនោះមិន



www.budinst.gov.kh www.elibraryofcambodia.org

មែនសំរាប់បែងចែកឥទ្ធិពលរវាងពួកប៉ិកទុយកាល់យើង និងពួកអេស្ប៉ាញជាមិត្តយើងនោះអី ? ប្រាប់គាត់ថា ចំពោះរឿងសំខាន់ផ្សេង១ទៀតខ្ញុំនឹងបកស្រាយបំភ្លឺទៅគាត់ពេលណាខ្ញុំរៀបចំរួចរាល់ ព្រោះខ្ញុំត្រូវទៅស្រាវជ្រាវមើលនៅឯម៉ាកាវឯណោះ ។ ហេតុនេះ សូមគាត់ទុកពេលល្មមសមគួរអោយខ្ញុំផង ។ ទន្ទឹមនេះ លោកត្រូវប្រាប់ទៅ *តូរ៉ាណាកា* ថា សំពៅខ្មៅនឹងមកដល់ទីនេះបីអាទិត្យមុនពេលកំនត់ ហើយលើកនេះដឹកសូត និងមាសច្រើនជាងឆ្នាំណា១ទាំងអស់ ហើយថាមុខទំនិញរបស់យើងទាំងនេះ....

*ផែរ៉្ឡាក្វា* សញ្ជឹងគិតមួយសន្ទុះទើបពោលបន្ត :

- ....ថា យ៉ាងតិចណាស់ក៏សាមសិបភាគរយនៃមុខទំនិញរបស់យើងទាំងអស់នឹងត្រូវជាកំលក់តាមរយៈពួកឈ្មួញរបស់ *តូរ៉ាណាកា* ។

- ព្រះតេជគុណ *វ៉ៃរីក៍* ពិតជាមិនចូលចិត្តចេញដំណើរឆាប់ពេក ហើយក៏មិនចូលចិត្ត..

- រឿងលិខិតអនុញ្ញាតអោយចេញពីផែសំរាប់ *វ៉ៃរីក៍* គឺជាភារកិច្ចដែលលោកទទួលខុសត្រូវ ។ លោកទៅជួប *តូរ៉ាណាកា* ប្រាប់ចំលើយរបស់ខ្ញុំទៅ ។ ធ្វើយ៉ាងណាអោយ *តូរ៉ាណាកា* ឃើញថា ការងាររបស់យើងរហ័ស និងមានប្រសិទ្ធិភាពមែន អាតាប៉ុនេះចេះសរសើរតែរឿងណឹងមួយទេ ។ កាលណា *វ៉ៃរីក៍* បានលិខិតអនុញ្ញាតរហ័សវានឹងយល់ព្រមមកទីនេះឆាប់ជាងរាល់ដងជាមិនខាន ។ ចំនែកអារឿងម៉ូយលក់វាមានទៅសំខាន់អី សំរាប់បញ្ហាការសំពៅនោះ? អ្នកណាទទួលលក់ក៏តែដូចគ្នាដែរ ព្រោះវានៅតែបានទទួលភាគហ៊ុនរបស់វាដដែលទេតើ ។

- តែរាល់ដង លោកម្ចាស់ *អូលូស៊ី គីយ៉ាម៉ា* និង *យាវីម៉ា* តែងបែងចែកម៉ូយលក់នេះរវាងពួកគាត់ ។ បើធ្វើតាមតេជគុណអីចឹង ខ្ញុំមិនដឹងថា តើពួកគាត់ឯកភាពរឺអត់ទេ ។

- ដោះស្រាយបញ្ហាណឹងតាមដំណើរវាទៅ ។ *តូរ៉ាណាកា* ត្រូវតែយល់ព្រមលើការពន្យារពេលនេះ ដើម្បីជាសម្បទាន ។ សម្បទានតែមួយគត់ដែល *តូរ៉ាណាកា* ត្រូវការគឺអំនាចឥទ្ធិពលនិងលុយកាក់ ។ ក្រៅពីនេះ តើយើងអាចអោយអីទៅគាត់ ? យើងមិនអាចប្រគល់ពួកដៃមីញ៉ូគ្រិស្តសាសនិកទៅ *តូរ៉ាណាកា* បានទេ ។ យើង......

- យើងមិនទាន់ដល់ពេលប្រគល់ទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ទោះជាយើងអាចធ្វើអ៊ីចឹងបានក្តីក៏យើងមិនទាន់ច្បាស់ថា តើយើងគួរធ្វើអ៊ីចឹង រឺយើងចង់ដើរតាមផ្លូវហ្នឹងនៅឡើយទេ ។ *អូល្លូស៊ី* និង *គីយ៉ាម៉ា* គឺជាសត្រូវស្លាប់រស់នឹងគ្នា តែពួកគេទាំងពីរនាក់រួមដៃប្រឆាំង *តូរ៉ាណាកា* ពីព្រោះពួកគេជឿថា បើ *តូរ៉ាណាកា* ក្តាប់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិបាន *តូរ៉ាណាកា* ពិតជាកំចាត់ព្រះវិហារយើងនិងពួកគេជាមិនខាន ។

- *តូរ៉ាណាកា* នឹងគាំទ្រព្រះវិហារ ឯ *អ៊ីស៊ីដូ* ទើបពិតជាសត្រូវរបស់យើង -*អាលវីតូ* និយាយតប ។

- ខ្ញុំមិនទាន់ទុកចិត្តដូចលោកទេ *អាលវីតូ* ។ យើងមិនត្រូវភ្លេចទេថា ដោយសារតែ *អូល្លូស៊ី* និង *គីយ៉ាម៉ា* ជាគ្រិស្តសាសនិកហ្នឹងហើយ ទើបកូនចៅគេរាប់ម៉ឺននាក់បានក្លាយទៅជាគ្រិស្តសាសនិកដែរនោះ ។ យើងមិនអាចប្រមាថពួកគេបានទេ ។ សម្បទានតែមួយគត់ដែលយើងអាចធ្វើបានជាមួយ *តូរ៉ាណាកា* គឺរឿងជួញដូរតែប៉ុណ្ណោះ ។ *តូរ៉ាណាកា* ងប់នឹងរឿងជួញដូរ តែគាត់មិនដែលលូកដៃចូលដោយផ្ទាល់ទេ ។ អ៊ីចឹងហើយ សម្បទានដែលខ្ញុំលើកឡើងនេះអាចទាក់ទាញ *តូរ៉ាណាកា* អោយយល់ព្រមលើការទុកពេលអោយយើងឆ្លើយបាន ហើយជួនកាលយើងអាចពន្យារពេលបានរហូតក៏សឹងតែបាន ។ លោកដឹងហើយថា ពួកជប៉ុនចូលចិត្តដំណោះស្រាយបែបនេះណាស់ ។ គឺថា ព្រនង់យារពីលើក្បាលរៀងខ្លួន តែម្នាក់ៗធ្វើដូចជាមិនដឹងអីសោះតែម្តង ។ មិនអ៊ីចឹង ?

- តាមមតិខ្ញុំ ប្រការដែល *អូល្លូស៊ី* និង *គីយ៉ាម៉ា* ងាកបែរមកប្រឆាំងនឹង *តូរ៉ាណាកា* នៅពេលនេះ គឺមិនវាងវៃផ្នែកនយោបាយសោះតែម្តង ។ ពួកគេគួរទុកច្រកដកថយទើបសម ។ ខ្ញុំគិតថា បើយើងស្នើពួកគេអោយវិលែកទៅតូរ៉ាណាកាម្តេប្រាំកាតរយអោយស្មើគ្នារវាង *អូល្លូស៊ី គីយ៉ាម៉ា ហារីម៉ា* និង *តូរ៉ាណាកា* តែម្តងនោះប្រហែលជាអាចជួយសំរួលប្រការដែលពួកនោះចូលដៃជា " បណ្តោះអាសន្ន " ជាមួយ *អ៊ីស៊ីដូ* បាន ។

- ចុះអ៊ីចឹង បើ *អ៊ីស៊ីដូ* ដឹងវាលែងទុកចិត្តពួកនោះ ហើយវាកាន់តែស្អប់ពួកយើងណាស់ទៅទៀត ។

- អីលូវនេះ *អ៊ីស៊ីដូ* ស្អប់យើងដល់ឆ្អឹងទៅហើយ ។ *អ៊ីស៊ីដូ* ក៏មិនទុកចិត្តដៃមីញ៉ូទាំង



www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

នោះ ដូចពួកនោះមិនទុកចិត្ត *អ៊ីស៊ីដូ* ដែរ ។តែរឿងពួកនេះចូលដៃគ្នាប្រឆាំង *តូកាំណាកា* ។យើងក៏មិនទាន់ដឹងថាមកពីហេតុអីដែរ ។ បើសិនជាយើងបានការឯកភាពរបស់ *អូណូស៊ី* និង *គីយ៉ាម៉ា* ហើយនោះ យើងឥតមានកាន់ជើង *អ៊ីស៊ីដូ* រឺ *តូកាំណាកា* សោះទេ ។ ជាសំខាន់យើងអាចប្រាប់ *តូកាំណាកា* អំពីជំហររបស់ *អូណូស៊ី* និង *គីយ៉ាម៉ា* បាន ។

*ដៃឡាក្វា* ពិចារណាពីចំនុចខ្លាំង និងចំនុចខ្សោយនៃផែនការនេះ រួចនៅទីបំផុតលោកពោលឡើង :

- ល្អណាស់ ។ ចាត់ការតាមបែបណឹងទៅ ។ ចំនែករឿងអាទមិឡនោះ សូមលោកប្រគល់កូនសៀវភៅរបស់វាទៅ *តូកាំណាកា* ថ្ងៃនេះចុះ ។ លោកត្រលប់ទៅជួប *តូកាំណាកា* ភ្លាមហើយប្រាប់គាត់ថា គេទើបបញ្ជូនកូនសៀវភៅនេះមកជាសំងាត់ដល់យើង ។

- ចុះអោយខ្ញុំប្រាប់ *តូកាំណាកា* ថាម៉េច ពីរឿងដល់ថ្ងៃនេះទើបប្រគល់កូនសៀវភៅដល់គាត់នោះ ?

- មិនបាច់ពន្យល់បកស្រាយអ្វីទាំងអស់ និយាយតែតាមការពិតទៅបានហើយ ។ ថាសៀវភៅ *រ៉ូឌ្រិច* យកមក តែពួកយើងទាំងអស់គ្នាឥតមានអ្នកណាដឹងថា ក្នុងកញ្ចប់ភិ្ជតអាច់ល័ខនេះមានកូនសៀវភៅដែលបាត់នោះឡើយ ។ ម្យ៉ាងទៀតយើងរវល់តែពីរឿងអាទមិឡនោះពេក យើងទុកកញ្ចប់នោះចោលពីរថ្ងៃទទេដោយឥតបានបើកវា ។ កូនសៀវភៅនេះជាភស្តុតាងបញ្ជាក់ថា *ប្លាក់ថន* ជាចោរសមុទ្រ ជាចោរប្លន់ ហើយជាមនុស្សក្បត់ ។ សំដីរបស់អា *ប្លាក់ថន* នេះផ្ទាល់នឹងរុញវាអោយជាប់ជុចរណ្តៅកវីលែងរួចរហូត ហើយនេះគឺពិតជាព្រះផ្តន្ទាវាហើយ ។ និយាយប្រាប់ *តូកាំណាកា* តាមត្រង់ទៅគឺថា *មូរ៉ា* បានប្រគល់វាទៅអោយបព្វជិត *សេបាស្ទា* ក៏បានបញ្ជូនកូនសៀវភៅនេះ មកយើងដោយគិតថា យើងនឹងដឹងថាតើត្រូវប្រើប្រាស់កូនសៀវភៅនេះតាមបែបណាហើយ ។ និយាយអីចឹង ទាំង *មូរ៉ា* ទាំង *សេបាស្ទ* នឹងរួចខ្លួនហើយ ។ យើងគួរបញ្ជូនព្រាបនាំសារទៅប្រាប់ *មូរ៉ា* ថាតើយើងបានចាត់ចែងការងារយ៉ាងម៉េចៗហើយ ។ ខ្ញុំជឿថា *តូកាំណាកា* នឹងយល់បានថា យើងគិតគួរផលប្រយោជន៍របស់គាត់ធំជាង *យ៉ាប៊ូ* ទៅទៀ ។ តើ *តូកាំណាកា* មានដឹងថា *យ៉ាប៊ូ* បានធ្វើការព្រមព្រៀងជាមួយ *អ៊ីស៊ីដូ* ទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំគិតថា គាត់ពិតជាដឹង ប៉ុន្តែអីល្ងូវនេះមានពាក្យចចាមអារ៉ាមថា *តូរ៉ាណាកា* និង *យ៉ាប៊ូ* ក្លាយទៅជាមិត្តនឹងគ្នាហើយ ។

-ខ្ញុំមិនទុកចិត្តអាមនុស្សបិសាចបែបណឹងទេ ។

- ខ្ញុំជឿថា *តូរ៉ាណាកា* ពិតជាមិនទុកចិត្ត *យ៉ាប៊ូ* ទេ។ ហើយក៏មិនជឿថា *យ៉ាប៊ូ* បានធ្វើកិច្ចសន្យាអីជាមួយ *តូរ៉ាណាកា* ដែរ ។

សំលេងឡូឡានៅខាងក្រៅបានកាត់ផ្តាច់ការសន្ទនារបស់អ្នកទាំងពីរ រួចទ្វារបន្ទប់ក៏របើកឃ្វាំងឡើង ។ បព្វជិតមួយអង្គ ជើងទទេបានដើរចូលមកដោយកៀសបព្វជិត *សុលឌី* ទៅម្ខាង :

- សូមចំរើនពរ ។ សូមព្រះជាម្ចាស់ប្រណីទោសដល់បាបកម្មរបស់ពួកឯងផងទៅចុះ ។

សំលេងរបស់បព្វជិតដែលទើបចូលមកនេះ ពោរពេញដោយអរិភាព ។ *ដៃឡាញ៉ូ* ភ្ញាក់ដូចជាន់ក្បាលពស់វែក :

- តេជគុណ *ប៉េរេស ?* តេជគុណមកធ្វើអីនៅទីនេះ ?

- ខ្ញុំវិលត្រលប់មកស្រុកនេះ ដើម្បីផ្សព្វផ្សាយធម៌ព្រះជាថ្មីម្តងទៀត ។

- ប៉ុន្តែអាជ្ញានគរនេះ បានហាមមិនអោយតេជគុណមកជាន់នគរនេះវិញទេ ។ បើមិនអីចឹងទេព្រះតេជគុណនឹងត្រូវប្រហារជីវិតព្រោះរឿងបំផុសបំផុលប្រជាជន ។ លោកបានគេចរួចពីការប្រហារជីវិតនៅ *ណាកាសាគី* ម្តង ដោយសារសំនាងគុណបុណ្យលោកជួយ ហើយពួកគេបានបញ្ជាអោយតេជគុណ.....

- នេះគឺជាបំនងរបស់ព្រះ ហើយអាជ្ញារបស់អាខ្មោចតៃហោងនោះគ្មានទាក់ទងអីនឹងខ្ញុំទេ ។ ខ្ញុំមកទីនេះ ដើម្បីផ្សព្វផ្សាយសំដីរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ ។

បព្វជិត *ប៉េរេស* ជាសង្ឃសញ្ជាតិអេស្ប៉ាញ ។ លោកមានរាងទាបទ្រនាប់ ។ លោកចោលភ្នែកសំលឹងទៅ *អាលវីតូ* ហើយសួរឡើង :

- យ៉ាងមេចហើយអារឿងជួញដូរនោះ ?



www.budinst.gov.kh www.elibraryofcambodia.org

*អាល់វីតូ* ឆ្លើយតបយ៉ាងត្រជាក់ស្រេង :

- ហេតុតែប្រទេសអេស្ប៉ាញមានវាសនាល្អនៅឡើយ ទើបការជួញដូររបស់ពួកយើងខ្ញុំកាក់កបល្អណាស់ ។

- ខ្ញុំមិនដែលបានសល់ពេលទៅគិតគូរផ្នែកគណនេយ្យសោះ ព្រោះរវល់តែរឿងផ្លូវធម៌ពេក ។

*វ៉ៃឡាក្កា* និយាយបន្តតាមយ៉ាងកំបុត :

- អីចឹងល្អហើយ ។ ប៉ុន្តែបើរវល់ផ្លូវធម៌ ត្រូវរវល់តាមដីការបស់ *ប៉ាប* គឺថាក្រៅពីប្រទេសជប៉ុន ។ នេះជាខេត្តផ្តាច់មុខរបស់ពួកយើង ។ ហើយនេះក៏ជាដែនដីរបស់ប៉័កទុយកាល់ផងដែរ ។ មិនមែនរបស់អេស្ប៉ាញទេ ។ ខ្ញុំសូមរំលឹកតេជគុណថា *ប៉ាប* បីអង្គហើយដែលបានចេញដីកាមិនអោយមាននិកាយណាមកតាំងទីនៅជប៉ុននោះឡើយ លើកលែងតែនិកាយពួកយើងមួយគត់ ។ ព្រះរាជា *ភីលីប* ក៏បានចេញរាជអាជ្ញាដូចគ្នានេះដែរ ។

- សន្យាំដង្ហើមខ្លះទៅតេជគុណ ។ ការងារធម៌វាធំលើសច្បាប់នគរ ច្បាប់អីៗទាំងអស់នៅលើដែនដីនេះ ។ ខ្ញុំមកវិញហើយៗ ខ្ញុំនឹងបើកទ្វារវិហារចំហតែម្តង មិនតែប៉ុណ្ណោះខ្ញុំបំផុសមហាជនអោយក្រោកឡើងអោយប្រឆាំងនឹងអ្វីដែលផ្ទុយនឹងធម៌ព្រះថែមទៀតផង ។

- តើតេជគុណចង់អោយគេព្រមានប៉ុន្មានដងទៀតទៅ ? នៅក្នុងប្រទេសជប៉ុន ព្រះអង្គមិនអាចធ្វើបានតាមចិត្តដូចពួក *អាំងកា* ដែលជាមនុស្សព្រៃគ្មានប្រវត្តិសាស្ត្រ គ្មានវប្បធម៌នោះបានទេ ។ ខ្ញុំសូមហាមឃាត់មិនអោយតេជគុណទេសនាធម៌នៅក្នុងនគរទេ ហើយព្រះតេជគុណត្រូវតែគោរពតាមដីការបស់ *ប៉ាប* ។

-យើងត្រូវបញ្ចូលពួកក្រៅសាសនាទាំងនេះ អោយចូលសាសនាយើង ។ សូមស្តាប់ខ្ញុំតេជគុណ! នៅឯម៉ានីលមានបព្វជិតរបស់ខ្ញុំជាងរយនាក់ទៀត ដែលកំពុងរង់ចាំឡើងសំពៅមកទីនេះ ។ ពួកគេសុទ្ធតែជនជាតិអេស្ប៉ាញយ៉ាងជំរើស ហើយបើយើងត្រូវការ យើងនៅមានពួក *កុងគីស្តាឌ័រ* ដ៏ជាញជ័យរបស់យើងសន្ទឹកសន្ទាប់ ដើម្បីការពារពួកយើង ។ ពួកយើងនឹងទេសនាធម៌ជាចំហ យើងស្លៀកស្បង់យើងជាចំហ មិនមែនបន្លែបន្លំគេដូចពួក *យេស៊ុីត* នោះទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកមិនត្រូវក្រលុកអាថ្វាចរទេ បើមិនយ៉ាងដូច្នេះទេ លោកនឹងធ្វើអោយព្រះវិហាររលំរលាយជាមិនខាន ។

-ខ្ញុំប្រាប់លោកហើយទេតើ ថាពួកយើងត្រលប់មកជប៉ុនវិញហើយ១ មកដើម្បីនៅ ។ យើងនឹងផ្សព្វផ្សាយព្រះធម៌ ទោះជាពួកលោកចង់ខាយ៉ាំងយ៉ាងណាក៏ដោយ ទោះជាមានអាជ្ញាមានដីការបស់ស្តេច របស់ *ហ៊ីប* អីក៏ដោយ ។

និយាយចប់បព្វជិតក៏ដើរចេញទៅវិញដោយទាំងកន្ត្រាក់ទ្វារតាមក្រោយលាន់សូរខ្លាំងផង ។

ដោយកំហឹងពុះពារ *ដៃឡាក្វា* ចាក់ស្រាពេញមួយកែវ ។ តំនក់ស្រាស្រក់ប្រលាក់ពាសពេញតុដំរលោងរបស់លោក :

- ពួកអាកូនមីចោរអេស្ប៉ាញនេះនឹងធ្វើអោយយើងរលត់រលាយតែទាំងអស់គ្នាហ្នឹង ។

រួចលោកលើកកែវឡើងក្រេបសុរាយ៉ាងយឺត១ ដើម្បីរំងាប់ភាពច្របូកច្របល់របស់លោក ។ នៅទីបញ្ចប់លោកបន្លឺឡើង :

- *ម៉ាកតាំង* ចាត់ពួកយើងខ្លះទៅតាមឃ្លាំអាសង្សចំកូតណឹងផង ។ យកល្អលោកត្រូវប្រាប់ *អូណូស៊ី* និង *គីយ៉ាម៉ា* តែម្តងទៅ ។ ខ្ញុំមិនបាច់ប្រាប់ថារឿងរ៉ាវនឹងទៅជាយ៉ាងណាទេ បើអាខ្មោចហ្នឹងវាចេញមុខជាសាធារណៈនោះ ។

- បាទ តេជគុណ ! .

ពេលទៅដល់មាត់ទ្វារ *អាល់វីតូ* រាងអេះអុញបន្តិច ទើបងាកមកវិញ :

-ដំបូង *ព្វាក់ផន* អីលូវនេះ *ប៉េរេស* ។ ដូចជាចៃដន្យខ្លាំងពេក ។ ពាមមើលប្រហែលជាពួកអេស្ប៉ាញដឹងពីរឿង *ព្វាក់ផន* ហើយបណ្តោយវាអោយមកដល់នេះដើម្បីក្រលុកពួកយើងទេដឹង ?

- អាចអីចឹង តែអាចមិនមែនដែរ ។

*ដៃឡាក្វា* ក្រេបស្រាបង្ហើយ រួចដាក់កែវចុះយ៉ាងថ្នម១ :

- ទោះជាក្នុងករណីណាក៏ដោយ អាស្រ័យដោយគុណបុណ្យព្រះជាម្ចាស់ និងចំនាត់ចំនែងការទាន់ពេល គ្មានពួកវាណាមួយអាចប៉ះពាល់ព្រះវិហារបានទេ....ទោះជាក្នុងតំលៃប៉ុន្មានណាក៏ដោយ ។



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២០

អញអោយប្រកាច់ងាប់ដូចពួកអេស្ប៉ាញទៅចុះ បើអានេះគេមិនហៅថា ជីវិតទេនោះ !

*ភ្លាក់ថន* កំពុងដេកផ្កាប់មុខយ៉ាងសែនសុខ ។ ខ្លួនប្រាណរបស់គេពាក់កណ្តាលត្រូវគ្របដណ្តប់ដោយគីម៉ូណូអំបោះមួយ ឯក្បាលគេកើយលើដៃ ។ នារីម្នាក់កំពុងឈ្លីខ្នងរបស់ *ភ្លាក់ថន* ធ្វើអោយសាច់ដុំ សៃប្រក និងអារម្មណ៍របស់គេមានអារម្មណ៍យ៉ាងសុខស្រួល ។ នារីម្នាក់ទៀតកំពុងចាក់ស្រាសាកេទៅក្នុងពែងព័រស៊ីឡែនមួយ ។ ស្ត្រីម្នាក់ទៀតនៅរង់ចាំយ៉ាងស្ងប់ស្ងៀម ។ នៅលើដៃនាងមានថាសខ្មុកម្រ័ក្សណ៍មួយដែលមានត្រីចៀនតាមបែបបីកទុយកាល់មួយកូនខេងផបស្រាសាកេមួយ និងចង្កឹះពីរបីគូ ។

- *ណោន គេស៊ូកា អាន់ជីន-សាន ?* ស្ដីណឹងលោកម្ចាស់តែកុង ? តើលោកមានប្រសាសន៍ថាម៉េច ?

- ខ្ញុំបកជាភាសា *នីហុង-កូ* មិនបានទេ *ក៏កូ-សាន* ។

*ភ្លាក់ថន* និយាយទាំងញញឹមទៅនារីដែលសួរគេបណ្តើរ ហុចស្រាសាកេមកគេបណ្តើរនោះ ។ រួចគេក៏ចង្អុលទៅពែង ដោយសួរឡើងថា :

- អានេះហៅថាម៉េច ? *ណាម៉ែ កា ?*

- *សាបាស៊ូគី* ។

នាងនិយាយឡើងបីដង ហើយ *ភ្លាក់ថន* ក៏ថាតាមទាំងបីដង ។ នារីម្នាក់ទៀតឈ្មោះ *អាសា* ក៏ហុចត្រីទៅ *ភ្លាក់ថន* តែ *ភ្លាក់ថន* គ្រវីក្បាល :

- *អ៊ីយេ ! ដូម៉ូ !*

ដោយគេមិនចេះពាក្យ " អីលូវនេះខ្ញុំឆ្អែតហើយ " នោះ គេក៏សាកនិយាយឃ្លា " អីលូវនេះអត់ឃ្លានទេ " វិញ ។

- អូ ! *អ៊ីម៉ា បាកា៍ បោតេ រ៉ា អូកា៍ទូ* ។



www.budinst.gov.kh www.elibraryofcambodia.org

*អាសា* និយាយឡើងដើម្បីតំរូវ *ប្លាក់ថន១* ក៏និយាយតាមប៉ុន្មានសា ធ្វើអោយ ទៀតសើចក្អាកក្អាយកាច់កកាច់ស្រង់ ព្រោះតែសំនៀងមិនសូវច្បាស់របស់គេ ។

អញមិនដែលរៀនភាសានេះទេ-*ប្លាក់ថន* គិតនៅក្នុងចិត្ត ។ សំនៀងសូររបស់ ដូចអីពាក់តូចណាទៅនឹងភាសាអង់គ្លេស វីឡាតាំង វីរអេស្ប៉ាញសោះ ។

*អាសា* ហុចថាសមកម្តងទៀត :

- *អាន់ជីន -សាន ?*

*ប្លាក់ថន* គ្រវីក្បាលហើយយកដៃស្ទាបពោះជាសញ្ញា ប៉ុន្តែគេយល់ព្រមទទួលយ សាគេមកផឹក ។ *សូណូ* នារីដែលឈ្លីខ្នងគេនោះក៏ឈប់ស្ងៀម ប៉ុន្តែ *ប្លាក់ថន* បានយកដៃនាង ដាក់លើកញ្ចឹងក ហើយធ្វើសញ្ញាប្រាប់ថា ខ្លួនបានសុខស្រួលណាស់ ។ *សូណូ* យល់បាន ហើយ នាងក៏ចាប់ផ្តើមឈ្លីបន្តទៀត ។

ជារាល់ពេលនៅពេលណាដែលស្រាអស់ពីពែងរបស់គេ នារីអ្នកបំរើក៏ចាក់បំពេ ភ្លាម ។ តាមសំរួលវិ៊-គេគិតនៅក្នុងចិត្ត- នេះជាដបទីបីហើយ១ដើងអញចាប់ក្តៅភាយ១ ដែរ ។

នារីទាំងបី *អាសា សូណូ* និង *រ៉ាកូ* បានមកដល់តាំងពីព្រលឹមស្រាង១ដោយនាំយក តែដែលបព្វជិត *ដូមិញ៉ាកូ* បានប្រាប់គេថា នេះគឺជាភេសជ្ជៈជាតិរបស់ចិននិងជប៉ុននោះម មួយផង ។ ក្រោយពីមានការប៉ងធ្វើឃាតមក *ប្លាក់ថន* ដេកមមើមមាយ ប៉ុន្តែតែ បានស្តារថាមពលរបស់គេវិញយ៉ាងរហ័ស ។ នារីទាំងនេះក៏បានយកមកជាមួយនូវកន្សែង មានក្លិនក្រអូបបន្តិច១ទៀតផង ។ នៅពេលដែល *ប្លាក់ថន* នៅងើមង៉ាមព្រោះមិនដឹងរបេ ប្រើនោះ *រ៉ាកូ* ដែលជាប្រធានគេបានបង្ហាញ *ប្លាក់ថន* ពីរបៀបប្រើកន្សែងនេះដើម្បីជូត និងដៃ ។

បន្ទាប់មកនារីទាំងបី និងសាមូរ៉ៃបួននាក់ដែលទទួលការពារបានជូន *ប្លាក់ថន* ក កន្លែងទឹកចំហុយដែលនៅឯចុងម្ខាងនៃវិមាននេះ ។ ពួកគេបានប្រគល់ *ប្លាក់ថន* ទៅ ទទួលខុសត្រូវនៅកន្លែងនោះ ហើយនៅក្នុងពេលដែលពួកគេមុជទឹកអោយ *ប្លាក់ថន* កាត់អ



www.budinst.gov.kh www.elibraryofcambodia.org

គាង កាត់សក់ ឈ្លីសរសៃ គងការពារទាំងបួននេះនៅអង្គុយបែកញើសជោកដោយឥតរអ៊ូរទាំ រី កំរើកសោះឡើយ ។

ក្រោយពីសំអាតខ្លួនប្រណរូច *ប្លាក់ថន* មានអារម្មណ៍ដូចរស់ឡើងវិញជាថ្មីម្តងទៀត។ ពួកគេបានប្រគល់អោយ *ប្លាក់ថន* នូវគីម៉ូណូត្រឹមជង្គង់ថ្មីមួយធ្វើអំពីអំបោះ ហើយនិង *តាប៊ិ* មួយថ្មី ស្រលាងផងដែរ ។ នារីទាំងបីនៅរង់ចាំគេនៅខាងក្រៅ ដដែល ។ ពួកគេបាននាំ *ប្លាក់ថន* ទៅបន្ទប់មួយទៀតដែលមាន *គិរី* និង *ម៉ារីកូ* នៅរង់ចាំទីនោះ។ *ម៉ារីកូ* បានជូនដំណឹងដល់រូបគេថា លោកម្ចាស់ *តូរ៉ាណាកា* បានសំរេចបញ្ជូន *អាន់ជីន-សាន* ទៅខេត្តមួយរបស់លោក ដើម្បីស្តារកំលាំងក្នុងប៉ុន្មានថ្ងៃទៀតនេះ ហើយលោកម្ចាស់ *តូរ៉ាណាកា* សែនសប្បាយចិត្តនឹង *អាន់ជីន-សាន* ហេតុនេះរូបគេមិនត្រូវខ្វាយខ្វល់ពីរឿងអ្វីទៀតទេ ព្រោះគេស្ថិតនៅក្រោមការថែទាំរបស់លោកម្ចាស់ហើយ ។ សូម *អាន់ជីន -សាន* រៀបចំតួរផែនទីចុះ។ អីវ៉ៃ អីវ៉ាន់ សំរាប់តួរត្រូវបាន *ម៉ារីកូ* យកមកផ្តល់អោយជាស្រេច។ បន្តិចទៀតនេះនឹងមានជំនួបជាមួយលោកម្ចាស់ម្តងទៀត ហើយលោកម្ចាស់បានសន្យាថា នឹងអនុញ្ញាតអោយនាងឆ្លើយប្រាប់នៅលើរាល់សំនួរដែល *អាន់ជីន-សាន* លើកឡើង ។ នាងបានប្រាប់ទៀតថា លោកម្ចាស់ *តូរ៉ាណាកា* មានបំណងយ៉ាងទទូចចង់អោយ *អាន់ជីន-សាន* រៀនភាសាជប៉ុន ដូចដែលលោកស្រេកឃ្លានចង់ដឹងពីពិភពខាងក្រៅ ពីការដើរសមុទ្រ និង ពីផ្លូវសមុទ្រយ៉ាងដូច្នោះដែរ ។

បន្ទាប់មក *ប្លាក់ថន* ត្រូវគេនាំទៅជួបគ្រូពេទ្យ ។ ផ្ទុយពីពួក *សាមូរ៉ៃ* លោកគ្រូពេទ្យនេះគាត់សក់ហោតិល ហើយគ្មានទុកកន្ទុយសេះអ្វីឡើយ ។

ជាធម្មតា *ប្លាក់ថន* ស្អប់គ្រូពេទ្យផង ខ្លាចគ្រូពេទ្យផង ។ ប៉ុន្តែគ្រូពេទ្យដែលគេជួបនេះសុភាពរាបសា ហើយស្អាតភ្លឹងស្មើរមិនអាចជឿបាន ។ គ្រូពេទ្យអឺរ៉ុបភាគច្រើនមានពុកមាត់ស្រមូមស្រមាម គំរោះគំរើយ និងកខ្វក់ដូចគេអីចឹង ។ គ្រូពេទ្យនេះ ស្ទាបគេយ៉ាងប្រយ័ត្នប្រយែង គោះគេយ៉ាងថ្នមៗ ហើយបន្ទាប់មកកាន់កដៃគេដើម្បីស្ទង់ជីពចរ ពិនិត្យភ្នែក មាត់និងត្រចៀក គោះខ្នង និងជង្គង់យ៉ាងស្រាលៗហើយស្ទាបពិនិត្យបាតជើងរបស់គេថែមទៀត ។ បើសិនជាគ្រូពេទ្យអឺរ៉ុបវិញ អ្វីដែលគេត្រូវការ គឺពិនិត្យអណ្តាត ហើយសួរថា "ឈឺកន្លែងណា ?"



www.budinst.gov.kh www.elibraryofcambodia.org

បន្ទាប់មកដោះបង្ហូរឈាមអាក្រក់ចេញ និងអោយថ្នាំបញ្ចុះសំអាតពោះវៀន តែប៉ុណ្ណឹង ។

*ប្លាក់ថន* ស្អប់បំផុតអារឿងដោះឈាម និងបញ្ចុះនេះ ព្រោះម្តងណាក៏ដោយវាមានរ៉េ រឿងយ៉ាប់ជាងតែប៉ុណ្ណោះ ។ ប៉ុន្តែគ្រូពេទ្យនេះ គ្មានកាំបិត គ្មានចានត្រងឈាម រឺក៏មានក្លិ ជាតិថ្នាំបញ្ចុះសោះទេ ដោយហេតុនេះបេះដូងរបស់*ប្លាក់ថន* ក៏ចាប់ដើរស្រួលឡើងវិញ ហើយ អារម្មណ៍តែលែងសូវជ្រួលបន្តិច ។

ម្រាមដៃគ្រូពេទ្យស្ទាបចុះស្ទាបឡើងដោយអាការៈយឺតផ្លូវ នូវស្នាមសំលាកមួយ ដែលមាននៅលើចង្កេះរបស់*ប្លាក់ថន* ១ធ្វើសំលេងកាំភ្លើងប្រាប់ ព្រោះកាលពីប៉ុន្មានឆ្នាំមុននេះ គ្រាប់កាំភ្លើងមួយគ្រាប់បានទុកស្នាមរបួសនៅកន្លែងនេះ ។ លោកគ្រូពេទ្យក៏និយាយថា " អ្ហា ! *ស្វ តេ ស្ទ៊*" ហើយងក់ក្បាល ហើយបន្តចុចយ៉ាងថ្នម១ទៅទៀត នៅលើក្រលៀន និងចុងដង្ហើម ។ នៅទីបញ្ចប់លោកគ្រូពេទ្យនិយាយទៅកាន់ *វ៉ាក្វា* ក៏ងក់ក្បាលលំអោនខ្លួនគោរព ហើយនិយាយ អរគុណគ្រូពេទ្យ ។

- *អ៊ុជី បាន ?*

*ប្លាក់ថន* សួរឡើងដោយគេចង់ដឹងថា គេមានសុខភាពស្រួលបួលជាទេ ។

- *ហៃ អាន់ជីន-សាន* ។

- *ហុង តូ កា ?......*

- *ហុង តូ !*

គិតទៅពាក្យ *ហុង តូ* ( ពិត ) គឺជាពាក្យសំខាន់មែន -*ប្លាក់ថន* គិតនៅក្នុងចិត្ត-រួចតេ បន្លឺឡើង :

- *ដូម៉ូ* ! លោកគ្រូពេទ្យ-*សាន* ។

- *ដូ អ៊ិតាស៊ីម៉ាស៊ិតេ* -លោកគ្រូពេទ្យ តបដោយលំអោនខ្លួនតប -មិនអីទេ មិន កំបាច់រំលឹកទេ ។

*ប្លាក់ថន* លំអោនខ្លួនតបវិញ ។ រួចទើបពួកនារី១ នាំគេមកបន្ទប់នេះ ។ ទើបតែនៅ ពេលដែលផ្កាប់មុខដេកបន្ទូរតិម៉ូណូ ហើយនារីឈ្មោះ *សូណូ* ចាប់ផ្តើមឈ្លីឆ្អឹងខ្នងគេទេ ទើបបាន



www.budinst.gov.kh www.elibraryofcambodia.org

តែចាប់ភ្លឹកថា ពេលដែលលោកគ្រូពេទ្យពិនិត្យគេនោះ រូបគេនៅអាក្រាតចំពោះមុខគ្រូពេទ្យ មុខនារី១ មុខពួកសាមូរ៉ៃ ហើយគេហាក់ឥតចាប់ភ្លឹក រឺមានអារម្មណ៍ខ្មាសអៀនអ្វីសោះ ។

- *ណាន រេស៊ូ កា* ? -*រ៉ាកូ* សួរឡើង -មានរឿងអីរ៉ី ? ហេតុអីបានជាលោកម្ចាស់សើច?

*រ៉ាកូ* មានធ្មេញសដូចភ្លុក ។ រោមចិញ្ចើមនាង ត្រូវដកចេញអស់ ហើយគូសជំនួសវិញជារាងចំនិតព្រះខែ ។ សក់ខ្មៅរលើបរបស់នាងត្រូវបួងឡើងខ្ពស់ទៅលើ ។ នាងពាក់អាវគីម៉ូណូពណ៌ផ្កាឈូក ហើយនិងរឹបខ្លួនដោយ អូប៊ីមួយពណ៌ខៀវក្រម៉ៅ ។

- ពីព្រោះខ្ញុំសប្បាយចិត្តណា *រ៉ាកូ-សាន* ។ ប៉ុន្តែ តើខ្ញុំនិយាយប្រាប់នាងថាយ៉ាងម៉េច? តើខ្ញុំប្រាប់នាងយ៉ាងម៉េចថា ខ្ញុំសើចព្រោះខ្ញុំសប្បាយចិត្ត ហើយនេះជាលើកទីមួយចាប់តាំងពីខ្ញុំចេញពីផ្ទះមក ដែលខ្ញុំធូរក្បាលលែងតឹងទៀត ។ ពីព្រោះខ្លងខ្ញុំវាស្រួលសន្ទឹក ។ ពីព្រោះ *តូរ៉ាណាកា-សាម៉ា* ស្តាប់តាមខ្ញុំ ហើយខ្ញុំលេងអាពួកទេវតាកាច់ *យេស៊ូត* និងពួកអាស្វាយស៊ី ប៉ាកទុយកាល់បានមួយចានហើយ ។

រួច *ប្លាក់ថន* ក៏ស្ទុះក្រោកឡើងភឹង ចងរឹតគីម៉ូណូរបស់ខ្លួន ហើយក៏ចាប់ផ្តើមលោតរាំចង្វាក់ *ហានផែប* ដោយច្រៀងចំរៀងអ្នកដើរសមុទ្រ យ៉ាងរឡេរឡូ ដើម្បីបញ្ចេញភាពសប្បាយរបស់គេ ។

*រ៉ាកូ* និងអ្នកឯទៀតឡើងស្រលាំងកាំង ភាន់ភាំងស្មារតីអស់រលីង ។ ទ្វារបន្ទប់របើកឡើងឃ្វាំង ហើយពួកឆ្មាំ ដែលចូលមកដល់ក៏នៅច្រហមាត់ធ្ងុងទាំងអស់គ្នាដែរ ។ *ប្លាក់ថន* លោតរាំបណ្តើរ ស្រែកច្រៀងឡេឡូបណ្តើរ លុះត្រាតែគេទ្រាំលែងបានទៀតទើបគេអោបពោះសើចទាំងដួលត្រាំងទៅលើកំរាល ។ នារី១នាំគ្នាទះដៃ ហើយបន្ទាប់មក *រ៉ាកូ* ក៏សាកល្បងរាំតាម *ប្លាក់ថន* ប៉ុន្តែ នាងរាំមិនកើតសោះដោយនាងត្រូវរំខាននឹងជាយគីម៉ូណូរបស់នាង ។ នារីឯទៀតនាំគ្នាក្រោកឈរឡើង ហើយអង្វង *ប្លាក់ថន* អោយជួយបង្ហាត់ពីក្បាច់រាំនេះដល់នាង ។ *ប្លាក់ថន* ក៏ក្រោកឡើងម្តងទៀត ហើយចាប់រាំជាថ្មី ឯពួកនារីទាំងបីនាក់ នាំគ្នាឈរជាជួរតាមសំលឹងមើលជើងរបស់ *ប្លាក់ថន* ដៃទាំងពីរសើយជាយគីម៉ូណូរបស់ខ្លួន ។ប៉ុន្តែពួកនាងរាំមិនកើតឡើយ ហើយបន្តិចមកពួកគេនាំគ្នាដេកបណ្តើរ សើចក្អាកក្អាយបណ្តើរ បក់ផ្លិតបណ្តើរ ។



www.budinst.gov.kh www.elibraryofcambodia.org

វំពេចក្លាមនោះ ពួកឆ្មាំប្រែក្លាយជាម៉ឹងម៉ាត់ ហើយនាំគ្នាលំអោនខ្លួនយ៉ាងទាប ។ *ណាកា* នៅឈរថ្ងាំងនៅមាត់ទ្វារ អមដោយ*គីរី* និង *ម៉ារីកូ* ហើយនិងពួកអង្គរក្សជាអចិ[illegible] របស់លោក ។ នារីទាំងអស់លុតជង្គង់ចុះ ដាក់បាតដៃទៅលើកំរាល ហើយលំអោនខ្លួន[illegible] ប៉ុន្តែ នៅលើមុខរបស់ពួកនាងស្លាមក្លាកក្លាយនៅមានជាប់នៅឡើយ ហើយក៏គតបង្ហាញ[illegible] ភ័យខ្លាចអ្វីផងដែរ ។ ប្លាក់ថន ក៏លំអោនខ្លួនគោរពយ៉ាងគួរសមផងដែរ គ្រាន់តែមិនទាបដូ[illegible] នារី១ពេក ។ គេបន្លឺឡើង :

- *កូនីជីវ៉ា តូរ៉ាណាកា-សាម៉ា* ។

- *កូនីជីវ៉ា អាន់ជីន-សាន* ។

ក្រោយពីឆ្លើយតបរួចហើយ *តូរ៉ាណាកា* ក៏សួរឡើង *ម៉ារីកូ*បកប្រែបន្ត :

- លោកម្ចាស់ខ្ញុំសួរថា តើលោកកំពុងធ្វើអីហ្នឹង ?

- នេះគ្រាន់តែជាចង្វាក់រាំមួយប៉ុណ្ណោះ -*ប្លាក់ថន* តបដោយមានអារម្មណ៍ថា ខ្លួន ដូចជាល្ងាក់ល្ងើហួស -របាំនេះឈ្មោះ *ហានផែប* ។ នេះគឺជារបៀបរាំរបស់ពួកអ្នកដើរសមុ[illegible] ហើយពួកយើងច្រៀងចំរៀងសមុទ្រ ក្នុង......ក្នុង......ពេលជាមួយគ្នាផង ។ អំបាញ់មិញ[illegible] ខ្ញុំ.....ខ្ញុំ...សប្បាយចិត្តពេក ។ ប្រហែលមកពីស្រាសាកេហើយមើលទៅ ។ ខ្ញុំសូមទោស សង្ឃឹមថា ខ្ញុំមិនរំខានលោកម្ចាស់*តូរ៉ាណាកា-សាម៉ា* ទេ ។

*ម៉ារីកូ*បកប្រែ រួចនាងងាកមកនិយាយបន្ត :

លោកម្ចាស់របស់ខ្ញុំមានប្រសាសន៍ថា លោកចង់ឃើញរបាំនេះ ហើយចង់ស្តាប់ចំរៀ[illegible] វាផង ។

- អីល្ងូវហ្នឹង ?

- ពិតជាអីល្ងូវហ្នឹងមែន ។

*តូរ៉ាណាកា* អង្គុយពែនភ្នែននៅលើកំរាល ហើយអ្នកដែលហែហមលោក ក៏ពង្រាយ វិញបន្ទប់ ហើយសំលឹងមើល *ប្លាក់ថន* ដោយក្តីរង់ចាំ ។

សមមុខហើយអាឡប់-*ប្លាក់ថន* រអ៊ូនៅក្នុងពោះ ។អាហ្នឹងហើយដែលគេថាមិនប្រយ[illegible]



www.budinst.gov.kh www.elibraryofcambodia.org

ខ្លួន ។ អីលូវនេះអ្នែងត្រូវតែធ្វើបង្ហាញគេហើយ១ អ្នែងដឹងហើយថា សំលេងអ្នែងពេលនេះ ដូចស្គរកំបែក ហើយរបៀបរាំប្រហែលតែស្វាលេងចាហ៊ីតែប៉ុណ្ណឹង ។

ទោះជាយ៉ាងនេះក្តីក៏ *ភ្លាក់ថន* រិតខោអាវខ្លួន ហើយក៏ចាប់ផ្តើមភ្លាមដោយញាក់ផងបង្វិលខ្លួនផង លោតរន្ទាន់ផង ហើយចំរៀងរបស់គេ ក៏លាន់ឡើងក្នុងសំលេងលាន់ខ្ទ័រ និងរីករាយ ។

ស្ងាត់ឈឹងនៅក្នុងបន្ទប់ ។

- លោកម្ចាស់ខ្ញុំនិយាយថា ម៉ាជីវិតរបស់លោក១ មិនដែលឃើញរបៀបរាំអីចឹងទេ ។

- *អារីកាតូ កូស៊ីអេម៉ាស៊ីតា* ។

*ភ្លាក់ថន* ឆ្លើយតបទាំងបែកញើសជោក ម្យ៉ាងមកពីការប្រឹងរាំ ម្យ៉ាងមកពីភាពរសាប់រសល់របស់គេ ។ បន្ទាប់មក *តូរ៉ាណាកា* ដាក់អាវុធរបស់ខ្លួនទៅម្ខាង សើយគីម៉ូណូរបស់លោកមកត្រឹមចង្កេះ ហើយដើរមកឈរអែបនឹង *ភ្លាក់ថន* ។

*ម៉ារីកូ* បកប្រែប្រាប់ថា :

- លោកម្ចាស់ *តូរ៉ាណាកា* នឹងរាំរបាំរបស់លោក ។

- អ្ហាស ?

- លោកម្ចាស់របស់ខ្ញុំប្រាប់ថា សូមលោកជួយបង្រៀនគាត់ផង ។

ហើយ *ភ្លាក់ថន* ក៏ចាប់ផ្តើមបង្រៀនឡើង ។ ដំបូងគេបង្រៀនពីក្បាច់បាត ពោលគឺជំហានដើរ ហើយគេសាចុះសាឡើង ។ *តូរ៉ាណាកា* រៀនចេះយ៉ាងឆាប់រហ័ស ដែលធ្វើអោយ *ភ្លាក់ថន* ភ្ញាក់ផ្អើល និងស្ងើចសរសើរចំពោះការប៉ិនប្រសប់របស់បុរសចំនាស់ក្បាលពោះកំប៉ោងតូចទទយនេះយ៉ាងខ្លាំង ។

បន្ទាប់មក *ភ្លាក់ថន* ចាប់ផ្តើមច្រៀង និងរាំមែនទែន ។ *តូរ៉ាណាកា* ខំប្រឹងធ្វើតាម *ភ្លាក់ថន*ទាំងរឹង១ ក្រោមស្នូរទះដៃរបស់អ្នកដែលនៅទីនោះទាំងអស់ ។ បន្តិចក្រោយមក *តូរ៉ាណាកា* បោះគីម៉ូណូខ្លួនចោល អោបដៃ ហើយចាប់ផ្តើមរាំយ៉ាងចាស់ដៃមិនចាញ់ *ភ្លាក់ថន*ឡើយ ។ *ភ្លាក់ថន* ក៏បោះគីម៉ូណូរបស់ខ្លួនចោល ហើយស្រែកច្រៀងកាន់តែខ្លាំងឡើង១ដោយជំនក់ខ្យល់ ។ នៅទីបញ្ចប់ *ភ្លាក់ថន* លោតបង្វិលខ្លួនយ៉ាងរហ័សរហួន ហើយឈប់ស្ងៀម ។ រួចគេលំអោនខ្លួនគោរព



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* និងទះដៃសរសើរ ទាំងអស់គ្នាក៏ទះដៃបន្ទរឡើងចំពោះលោកម្ចាស់របស់ មើលទៅទំនងដូចជារីករាយណាស់ ។

*តូរ៉ាណាកា* ក៏អង្គុយចុះនៅកណ្ដាលបន្ទប់ ។ ដង្ហើមរបស់លោកនៅរត់យ៉ាងស្មើ រំពេចនោះ *រ៉ូកូ* ក៏ស្ទុះទៅបក់ជូនលោក ឯអ្នកខ្លះទៀតស្ទុះទៅរើសយកគីម៉ូណូ ។ ប៉ុន្តែ*តូ* បានរុញគីម៉ូណូរបស់ខ្លួនទៅអោយ *ប្លាក់ថន* ហើយលោកយក គីម៉ូណូសាមញ្ញមកពាក់វិញ

*ម៉ារីកូ* ក៏បកប្រែឡើង :

- លោកម្ចាស់របស់ខ្ញុំនិយាយថា លោកសប្បាយចិត្តណាស់ បើសិនជាលោកទទួ គីម៉ូណូនេះ ទុកជាជំនូន ។

រួចនាងនិយាយបន្ថែម :

- នៅក្នុងប្រទេសនេះ គេចាត់ទុកដូចជាកិត្តិយសខ្ពង់ខ្ពស់ ដែលទទួលបានគីម៉ូណ ជាកញ្ចាស់កំពុកយ៉ាងណាក្ដី ពីលោកម្ចាស់របស់គេនោះ ។

*-អារីកាតូ កូស៊ីអេម៉ាស៊ីតា តូរ៉ាណាកា-សាម៉ា* ។

*ប្លាក់ថន* លំអោនខ្លួនគោរពយ៉ាងទាប រួចនិយាយទៅកាន់ *ម៉ារីកូ* :

- ខ្ញុំយល់ណាស់នូវកិត្តិយសដែលខ្ញុំទទួលបាននេះ *ម៉ារីកូ-សាន* ។ សូមអ្នក អរគុណលោកម្ចាស់*តូរ៉ាណាកា* ដោយប្រើពាក្យបានត្រឹមត្រូវផង ព្រោះខ្ញុំមិនទាន់ចេះនិយ ឡើយ ។ សូមជំរាបលោកថា ខ្ញុំនឹងថែរក្សាគីម៉ូណូនេះដូចគ្រាប់ភ្នែករបស់ខ្ញុំ ពិសេសខ្ញុំ រក្សានូវកិត្តិយសដ៏ធំធេងដែលលោកបានផ្ដល់អោយខ្ញុំ អាស្រ័យការមករាំជាមួយនឹងខ្ញុំនេះ

ភាពរីករាយបានបង្ហាញយ៉ាងច្បាស់ នៅលើផ្ទៃមុខ*តូរ៉ាណាកា* ក្រោយពី *ម៉ារីកូ* ប្រែចប់ ។

ដោយអាការៈគោរព*គីរី* និងនារីប៉ុន្មាននាក់ទៀតបានជួយ *ប្លាក់ថន* ពាក់អាវ របស់ម្ចាស់ខ្លួន និងប្រាប់ *ប្លាក់ថន* អំពីរបៀបចងខ្សែក្រវាត់ ។ គីម៉ូណូធ្វើអំពីសូតពណ៌ និងមាន សញ្ញាក្រហមក្រម៉ៅទាំងប្រាំ ។ ខ្សែក្រវាត់ធ្វើអំពីសូតពណ៌សរលោង ។

- លោកម្ចាស់*តូរ៉ាណាកា* មានប្រសាសន៍ថា លោកចូលចិត្តចង្វាក់រាំនេះណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

ណាមួយលោកប្រហែលជានឹងបង្ហាញចង្វាក់ភ័ររបស់ពួកយើងខ្លះជូនលោក ។ លោកម្ចាស់មានបំនងចង់អោយលោករៀនភាសាជប៉ុនបានរហ័ស ។ រហ័សកាលណាល្អកាលនោះ ។

- ខ្ញុំក៏មានបំនងយ៉ាងនេះដែរ ។

មាត់និយាយយ៉ាងដូចនេះមែន ប៉ុន្តែនៅក្នុងចិត្ត*ប្លាក់ថន* កំពុងគិតថា : " អញចូលចិត្តស្លៀកពាក់ខោអាវអញ ស៊ីម្ហូបអញនៅក្នុងបន្ទប់អញលើសំពៅអញ ដោយមានកាណុងញាត់គ្រាប់ កាំភ្លើងខ្លីអញនៅនឹងចង្កេះនោះវិញទេ " ។ រួចគេនិយាយបន្ត :

-សូមលោកស្រី សួរលោកម្ចាស់*តូរ៉ាណាកា* មើលថាតើពេលណាទើបលោកសងសំពៅមកខ្ញុំវិញ ?

- លោកថាម៉េច ?

- សំពៅខ្ញុំណាំអ្នកស្រី ។ សូមសួរលោកមើលថា តើពេលណាគាត់សងសំពៅខ្ញុំវិញ ។ ទាំងពូកនាវិកខ្ញុំផង ។ អីវ៉ែអីវ៉ាន់អី១ត្រូវគេសាងចេញអស់ហើយ ក្នុងនោះមានទាំងប្រាក់ពីរម៉ឺនឱយកាតថែមទៀតផងនៅក្នុងទូដែក ។ ខ្ញុំជឿថា លោកម្ចាស់ច្បាស់ជាយល់ ហើយថាពួកយើងជាអ្នករកស៊ី ហើយថ្វីត្បិតតែយើងសែនពេញចិត្ត នឹងការរាក់ទាក់ទទួលរបស់លោកម្ចាស់យ៉ាងណាក្តី ក៏ពួកយើងមានបំនងចង់យកទំនិញ ដែលយើងយកមកជាមួយនេះដើម្បីជួញដូរ ហើយព្រលប់ទៅស្រុកវិញ ។ ទំរាំតែទៅដល់ស្រុកវិញនោះ យើងត្រូវប្រើពេលមិនតិចជាងដប់ប្រាំបីខែទេ ។

- លោកម្ចាស់ខ្ញុំនិយាយថា លោកមិនបាច់ព្រួយបារម្ភទេ ។ អ្វី១នឹងត្រូវដោះស្រាយក្នុងពេលឆាប់បំផុតដែលអាចធ្វើបាន ។ ដំបូងបង្អស់លោកត្រូវតែស្តារកំលាំង និងសុខភាពឡើងវិញ ។ ព្រលប់នេះលោកត្រូវចេញដំណើរហើយ ។

- អ្នកស្រីថាម៉េច ?

-លោកម្ចាស់*តូរ៉ាណាកា* មានប្រសាសន៍ថា លោកនឹងចេញដំណើរនៅពេលព្រលប់នេះ ។ តើខ្ញុំនិយាយមិនត្រូវរឺ ?

- ទេ ! ទេ ! អត់ទេ *ម៉ារីកូ-សាន* ។ ប៉ុន្តែកាលពីជាងមួយម៉ោងពីរនេះ លោកស្រី



www.budinst.gov.kh www.elibraryofcambodia.org

ប្រាប់ខ្ញុំថា ខ្ញុំនឹងចេញដំណើរក្នុងប៉ុន្មានថ្ងៃទៀតឯណោះ ។

- ចាស់មែន ។ ប៉ុន្តែអីលូវនេះលោកម្ចាស់មានប្រសាសន៍ថា លោកត្រូវចេញដំណើរ យប់នេះ ។

រួច *ម៉ារីកូ* បកប្រែសំដីឆ្លើយឆ្លងទាំងនេះទៅ *តូរ៉ាណាកា* ១ក៏និយាយតបមកវិញ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកចេញដំណើរនៅយប់នេះ គឺល្អជាងស្រួ ជាង។ លោកមិនចាំបាច់ខ្វល់ខ្វាយអ្វីទេ *អាន់ជីន-សាន* ព្រោះលោកស្ថិតនៅក្រោមការការពា ផ្ទាល់របស់លោកម្ចាស់ហើយ ។ លោកម្ចាស់ក៏បានបញ្ជូនលោកស្រី *គីរីស៊ូ* ទៅ *យេដូ* ផងដែរ ដើម្ រៀបចំការវិលត្រលប់របស់លោកម្ចាស់ ។ លោកនឹងត្រូវរួមដំណើរជាមួយលោកស្រីណា ។

- សូមអរគុណលោកម្ចាស់ជំនួសខ្ញុំផង ។ ម្យ៉ាងទៀតតើលោកម្ចាស់អាច....អាច..... បើសិនជាលោកម្ចាស់មានលទ្ធភាព ខ្ញុំមានសំណូមពរសូមដោះលែងបព្វជិត *ដូមិញ្ញកូ*បានទេ មនុស្សនេះមានការចេះដឹងជ្រៅជ្រះណាស់ ។

*ម៉ារីកូ*បកប្រែសំនូមពរនេះទៅ *តូរ៉ាណាកា* ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកស្តាយណាស់ ដោយមនុស្សនោះបានស្លាប់បា ទៅហើយ ។ គ្រាន់តែលោកស្នើកាលពីម្សិលមិញនេះភ្លាម លោកម្ចាស់បានចាត់អោយគេទៅ ដោះបព្វជិតនោះជាបន្ទាន់ ប៉ុន្តែលោកស្លាប់បាត់ទៅហើយ ។

*ប្លាក់ថន*សែនស្រណោះកាំងនឹងសំដីនេះ :

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គាត់ស្លាប់នៅពេលដែលគេហៅឈ្មោះលោក ។

- ហ៊ឺ ! ចំជាអាណោចអាធ័មមែន !

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា ការរស់ និងការស្លាប់ គឺជារឿងតែមួយប៉ុណ្ណោះ ។ ព្រលឹងរបស់បព្វជិតនោះ នឹងវិលវល់ចំនួនសែសិបថ្ងៃ ហើយបន្ទាប់មក នឹងចាប់កំណើតជាថ្មីទៀត ហើយ ។ បើអីចឹងចាំបាច់កើតទុក្ខធ្វើអ្វី ? នោះគឺជាក្រិត្យក្រមធម្មជាតិណា ។

នាងរៀបនិយាយបន្ថែមអ្វីមួយ ប៉ុន្តែនាងក៏ផ្លាស់ប្តូរគំនិតទៅវិញ :

- ពុទ្ធសាសនិកជឿថា ពួកយើងត្រូវកើតចុះកើតឡើងច្រើនដងណាស់ *អាន់ជីន-សាន*។



www.budinst.gov.kh www.elibraryofcambodia.org

រហូតដល់ទីបំផុតយើងបានក្លាយជាសុក្រឹតហើយនោះ ទើបយើងអាចទៅដល់និញ្វានបាន ។

*ភ្លាក់ថន* ប្រឹងកំចាត់ភាពទុក្ខព្រួយចេញពីខ្លួន ហើយផ្ដោតការយកចិត្តទុកដាក់របស់ខ្លួនទៅ *តូរ៉ាណាកា* និងបច្ចុប្បន្នកាលនេះវិញ ។

- តើខ្ញុំអាចមានសំនួមពរមួយពីរឿងពូកនាវិកខ្ញុំដែល.....

*ភ្លាក់ថន* ឈប់ទ្រឹងកណ្ដាលទី ដោយឃើញ *តូរ៉ាណាកា* ចោលភ្នែកសំលឹងមើលទៅទីផ្សេង ។ យុវសាមូរ៉ៃម្នាក់ដើរចូលយ៉ាងរហ័សរហួនមកក្នុងបន្ទប់ លំអោនខ្លួនគោរព *តូរ៉ាណាកា* ហើយរង់ចាំយ៉ាងស្ងាត់ស្ងៀម ។

*តូរ៉ាណាកា* សួរឡើង :

- *ណាន ចា ?*

*ភ្លាក់ថន* មិនអាចស្ដាប់បានថា តើគេកំពុងនិយាយអ្វីនោះទេ គ្រាន់តែគេស្ដាប់បានហៅស្សនាមរបស់បព្វជិត *អាល់វីតូ* ថា " *ឈូតូ* " តែប៉ុណ្ណោះ ។ គេឃើញតូរ៉ាណាកាវាស់ភ្នែកមកមើលរូបគេមួយខ្ទាច់ ហើយស្នាមញញឹមយ៉ាងស្រាលមួយ បានលេចឡើងនៅលើមុខលោក ។ *ភ្លាក់ថន* ដណ្ដឹងសួរខ្លួនឯងថាតើ *តូរ៉ាណាកា* ចាត់គេទៅហៅបព្វជិត *អាល់វីតូ* មកព្រោះតែអ្វីដែលគេបាននិយាយប្រាប់នោះរឺយ៉ាងណា ។ បើអីចឹងមែនល្អហើយ -គេគិតនៅក្នុងចិត្ត -បើអីចឹងមែន បព្វជិត *អាល់វីតូ* ច្បាស់ជាកប់អាច់ហើយម្ដងនេះ ។ តើអាគាត់ណឹងវ៉េរូចរឺមិនរួច ? ប៉ុន្តែទោះជាក្នុងចិត្តកញ្ជ្រោលយ៉ាងណាក្ដី ក៏ *ភ្លាក់ថន* ឥតមានលើកសំនួរនេះទៅ *តូរ៉ាណាកា* ឡើយ ។

*តូរ៉ាណាក* និយាយយ៉ាងកំបុត :

- *ការេ នី ម៉ាត់ស៊ឺ យ៉ូនី ។*

- *តឺ យ៉ូអ៊ឺ !*

សាមូរ៉ៃនោះលំអោនខ្លួនគោរព ហើយក៏រលាំងរលះចេញទៅ ។ *តូរ៉ាណាកា* ក៏ងាកមករក *ភ្លាក់ថន* វិញម្ដង :

- *ណាន ចា អាន់ជីន-សាន*

*ម៉ារីកូ* ក៏បន្តបកប្រែទៅទៀត :



www.budinst.gov.kh www.elibraryofcambodia.org

- លោកមានប្រសាសន៍ថាម៉េចអំបាញ់មិញនេះចាស់ ? អំពីរឿងនាវិករបស់លោ
យ៉ាងម៉េច ?

- បាទ គឺថា តើលោកម្ចាស់*តូរ៉ាណាកា-សាម៉ា* អាចទទួលយកពួកនាវិករបស់ខ្ញុំ ទាំ
អស់អោយនៅក្រោមកិច្ចការពារផ្ទាល់របស់លោកផងបានទេ ? តើលោកម្ចាស់អាចជួយប្រា
អោយគេមើលថែទាំពួកវាអោយបានល្អស្រួលបួលផងបានទេ ? តើពួកនោះនឹងត្រូវបញ្ជូនទេ
យេដូដែរ រឺយ៉ាងម៉េច ?

*ម៉ារីកូ* សួរទៅ *តូរ៉ាណាកា* ១ស្រវាំទាញយកដាវរបស់ខ្លួនមកសៀតនៅនឹងចង្កេះអា
គឺម៉ូណូរបស់ខ្លួន ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកបានចាត់ចែងរឿងនេះរួចរាល់អស់ហើយ ។
លោកមិនចាំបាច់ខ្វល់ពីរឿងពួកគេ រឺពីរឿងសំពៅរបស់លោកឡើយ ។

- សំពៅខ្ញុំល្អស្រួលបួលមែនអ្ហ៎ ? មានគេថែទាំវាមែនអ្ហ៎ ?

- ចាស់ ! លោកម្ចាស់មានប្រសាសន៍ថា សំពៅរបស់លោកគេយកទៅទុកនៅ*យេដូ*មុន
ហើយ ។

*តូរ៉ាណាកា* ក្រោកឈរឡើង ។ ទាំងអស់គ្នាលំអោនខ្លួនគោរព រួចស្រាប់តែ*ប្លាក់ថន*
និយាយឡើងទៀត :

- រឿងចុងក្រោយគឺ.......

រួច*ប្លាក់ថន*ឈប់ស្ងៀមមួយរំពេច ទាំងប្រទេចផ្កាសាខ្លួនឯងនៅក្នុងពោះ ព្រោះគេទើប
រឹងខ្លួនថា គេខ្វះសុជីវធម៌យ៉ាងសំបើម ។ *តូរ៉ាណាកា* បានបង្ហាញយ៉ាងច្បាស់ថាកិច្ចសន្ទនាត្រូវ
វានបញ្ចប់ហើយ១ទាំងអស់គ្នាបានចាប់ផ្ដើមលំអោនខ្លួនទៅហើយ ប៉ុន្តែសំដីរបស់*ប្លាក់ថន* បាន
ធ្វើអោយគេនៅគាំងកណ្ដាលទី មិនដឹងថាតើត្រូវលំអោនខ្លួន រឺត្រូវចាំ រឺត្រូវសាឡើងវិញ ។

- *ណាកន ចា អាន់ជីន-សាន* ?

សំដីរបស់*តូរ៉ាណាកា* កំបុត១ហើយលែងមានភាពស្និទ្ធស្នាលដូចមុនទៀតហើយ ដោយ
រលោកផ្ទាល់ក៏ត្រូវបន្ទច់បង្អាក់ទាំងកណ្ដាលទីផងដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- *គូមេន ណាសែ* ខ្ញុំស្តាយណាស់ *តូរ៉ាណាកា-សាម៉ា* ។ ខ្ញុំអត់មានបំនងចង់ធ្វើល្មើយបែបនេះទេ ។ ខ្ញុំគ្រាន់តែចង់សួរថា តើលោកស្រី *ម៉ារីកូ* អាចនៅនិយាយជាមួយខ្ញុំបានបន្តិចទៀតទេ មុនពេលដែលខ្ញុំចេញដំណើរនេះ ? ព្រោះនេះអាចជួយខ្ញុំបានច្រើនណាស់ ។

នាងសួរទៅ*តូរ៉ាណាកា* ។

*តូរ៉ាណាកា* គ្រហឹមចំលើយយល់ព្រមយ៉ាងកំបុត ហើយក៏ដើរចេញទៅដោយមាន*គីរី*និងកងការពារជាប់ពីក្រោយផង ។

អាកូនមីចោរអត់ពូជនេះ -*ប្លាក់ថន* ជេរប្រទេចខ្លួនឯង --ម្តេងថ្ងៃក្រោយត្រូវប្រយ័ត្នប្រយែងអោយមែនទែន ។ គេលើកដៃអាវជូតថ្ពាសរបស់គេ ។ ពេលនេះទើបគេឃើញទឹកមុខ*ម៉ារីកូ* ដែលបានបង្ហាញនូវភាពស្លន់ស្លោឥតឧបមា ។ *រ៉ូកូ* ស្ទុះហុចកូនកន្សែងមួយទៅ*ប្លាក់ថន*ភ្លាម ។ អីលូវនេះទើបគេចាប់ភ្លឹកថា គេកំពុងពាក់អាវរបស់ " លោកម្ចាស់ " ហេតុនេះគេមិនត្រូវយកដៃអាវ " លោកម្ចាស់ " ទៅជូតថ្ពាសបានទេ ។ ឱព្រះអើយព្រះ អញខុសទៀតហើយ ។ មើលទៅអញរៀនមិនចេះទេ ! មិនចេះតែរហូតណឹង ។

- *អាន់ជីន-សាន* ?

*រ៉ូកូ* ហៅ*ប្លាក់ថន*បណ្តើរ ហុចស្រាសាកេមកបណ្តើរ ។

*ប្លាក់ថន*អរគុណ *រ៉ូកូ* ហើយក្រេបពែងស្រាផឹកអស់ភ្លាម ។ *រ៉ូកូ* ក៏ចាក់បំពេញពែងវិញ ។ នៅលើថ្ពាសមនុស្សទាំងអស់ *ប្លាក់ថន* ក្រលេកឃើញតំនក់ញើសស្រាល១ ។

- *គូមេន ណាសែ* !

*ប្លាក់ថន* ថ្លែងអំណរគុណ ដល់មនុស្សទាំងអស់ដែលនៅក្នុងបន្ទប់ រួចទើបគេហុចពែងស្រាទៅ *ម៉ារីកូ* :

- ខ្ញុំមិនដឹងថានេះជាល្បីអាក្រក់ទេ តែតើអ្នកស្រីពិសាសាកេទេ ?តើគេអនុញ្ញាតទេ? រឺមួយក៏ត្រូវបោកថ្ពាសនៅនឹងកំរាល ?

*ម៉ារីកូ* ផ្ទុះសំនើចឡើង :

- ចាស៎ នេះគឺជាការគួរសមណាស់ហើយ១លោកក៏មិនចាំបាច់បោកថ្ពាសអីដែរ ។ គ្មាន



www.budinst.gov.kh www.elibraryofcambodia.org

អ្វីចាំបាច់លោកត្រូវសូមទោសខ្ញុំទេ លោកមេបញ្ជាការ ។ បុរសមិនសូមទោសនារីទេ ។ ស្ដីដែលបុរសធ្វើ គឺត្រឹមត្រូវជានិច្ច ។ នេះជាអ្វីដែលពួកយើងជានារី១ត្រូវចងចាំ និងជឿជាក់ ។

រួច *ម៉ារីកូ* ងាកទៅនិយាយប្រាប់នារីឯទៀត ពីអ្វីដែលនាងនិយាយនេះ ។

អ្នកឯទៀតងក់ក្បាលឯកភាពយ៉ាងស្ងៀមស្ងាត់ ។ រួចទើបនាងងាកមករក *ធ្លាក់ថនវិញ*

- លោកមិនអាចយល់បានពីរឿងទាំងនេះទេ *អាន់ជីន-សាន* - *ម៉ារីកូ*ឈោងទៅយកពែងសាកេ ក្រេបសុរាមួយក្ដឹក រួចប្រគល់ពែងទៅ *ធ្លាក់ថនវិញ* :

- សូមអរគុណលោកណាស់ ចាស់ ! ខ្ញុំមិនហូបសាកេទៀតទេនៅពេលនេះ ។ វាឆាប់ធ្វើអោយខ្ញុំស្រវឹងណាស់ ។ ប៉ុន្តែខ្ញុំឃើញលោករៀនបានរហ័សណាស់ ។ ខ្ញុំគិតថា លោកប្រហែលជា ហត់នឿយណាស់ហើយមើលទៅដើម្បីរៀនបានប៉ុណ្ណេះ ។ តែសូមលោកកុំបារម្ភអី ។ លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា លោកមានសម្បទានអស្ចារ្យពិសេសលើសគេតែម្ដង ។ បើសិនជាលោកមិនសប្បាយចិត្តបំផុតនឹងរូបលោកលោកទេ លោកមិនជូនគីម៉ូណូនេះទេ ។

- តើគាត់អោយគេទៅហៅ *ឈូតូ-សាន* អ្វី ?

- បព្វជិត *អាល់វីតូ* ?

- បាទ

-លោកគួរតែសួរសំនួរនេះចំពោះលោកម្ចាស់ *អាន់ជីន-សាន* ។ លោកម្ចាស់ឥតបានប្រាប់ខ្ញុំពីរឿងនេះទេ ។ ហេតុនេះ ល្អបំផុតនារីមិនត្រូវចេះដឹងរវីខ្វាយខ្វល់អីពីរឿងកិច្ចការនយោបាយឡើយ ។

- អូ ! *សូ តេស៊ូកា* ? ខ្ញុំបន់អោយតែស្រី១ស្រុកខ្ញុំ....ឆ្លាតឆ្លុំដូចគ្នាអីចឹងដែរទេ ។

*ម៉ារីកូ* អង្គុយបក់ផ្លិតបណ្ដើរ និយាយបន្តបណ្ដើរ :

- របាំលោកល្អណាស់ *អាន់ជីន-សាន* ។ តើនារីស្រុកលោករាំរបៀបណឹងដែរ រឺយ៉ាងម៉េច ?

- ទេ ។ តែមនុស្សប្រុសទេ ។ នេះជារបាំសំរាប់មនុស្សប្រុស ។ ជារបាំរបស់ពួកអ្នកដើរសំពៅ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកថាមានបំនងចង់សួរសំនួរខ្លះដល់ខ្ញុំ តើលោកអនុញ្ញាតអោយខ្ញុំសួរសំនួរខ្លះដល់លោកមុនបានទេ ?

- ច្បាស់ជាបាន ។ សូមអ្នកស្រីសួរមកចុះ ។

- តើប្រពន្ធរបស់លោករាងរៅយ៉ាងម៉េចដែរ ?

-ប្រពន្ធរបស់ខ្ញុំ អាយុម្ភៃប្រាំបួនឆ្នាំ ។ បើប្រៀបធៀបនឹងអ្នកស្រី រាងមានឧធំឆ្ងាយណាស់ ។ ខ្ញុំមានកំពស់មួយម៉ែតប៉ែតសិបប្រាំ ប្រពន្ធខ្ញុំកំពស់មួយម៉ែតចិបសិបពីរ ។ អ្នកស្រីមានកំពស់ត្រឹមមួយម៉ែតហាសិបតែប៉ុណ្ណោះ ។ គឺអ្នកស្រីខ្ពស់ប្រហែលត្រឹមកប្រពន្ធខ្ញុំប៉ុណ្ណោះ ។ មាឌប្រពន្ធខ្ញុំក៏ធំទៅតាមកំពស់នេះដែរ ។ សក់នាងពណ៌....ពណ៌.....

*ប្លាក់ថន* ចង្អុលទៅរទូតឈើសែត ។ ភ្នែកអ្នកទាំងអស់គ្នាបាញ់សំលឹងតាមម្រាមដៃរបស់*ប្លាក់ថន* រួចទើបងាកមករករូបគេវិញ ។

- ពណ៌ណុង គ្រាន់តែក្រមៅបន្តិច មិនលឿងច្រាលតែម្តងទេ ។ ភ្នែកនាងពណ៌ខៀវតែខៀវដិតជាងភ្នែកខ្ញុំទៅទៀត ។ សក់នាងវែង ហើយភាគច្រើននាងមិនបួងទេ ។

*ម៉ារីកូ* បកស់ដីរបស់*ប្លាក់ថន* ប្រាប់ទៅអ្នកឯទៀត ដែលប្រឹងស្តាប់ស្ទើរអត់ដង្ហើម ។ ពួក គេសំលឹងមើលរទូតឈើសែត សំលឹងមើល*ប្លាក់ថន* ។ សូម្បីតែពួកអង្គរក្សសាមូរ៉ៃក៏ប្រឹងស្តាប់ យ៉ាងយកចិត្តទុកដាក់ណាស់ដែរ ។ *រ៉ាកូ* លើកសំនួរឡើង

- រ៉ាកូសួរថា តើប្រពន្ធលោកមានរាងកាយដូចពួកយើងដែរអ្វី ?

- បាទដូចគ្នា ។ គ្រាន់តែចង្កេះនាងធំជាង ។ ដើមទ្រូងនាងក៏អ៊ីចឹងដែរ ។ និយាយជារួមទៅនារីស្រុកខ្ញុំមានសាច់ជាង ដើមទ្រូងធំជាង ។

- តើបុរសនារីស្រុកលោក សុទ្ធតែមានមាឌធំៗជាងពួកយើងអ៊ីចឹងអ្វី ?

- ជារួមធំជាង ។ តែក៏មានអ្នកខ្លះមាឌតូចដូចជាអ្នកនៅទីនេះអ៊ីចឹងដែរ ។ ខ្ញុំគិតថាមាឌល្អិតបែបនេះ គឺល្អណាស់ ។

*អាសា* និយាយសួរម្តង ។

- *អាសា* និយាយពីរឿងគ្រែ ។ តើនារីស្រុកលោកផ្ទឹមជាមួយនារីស្រុកនេះយ៉ាងម៉េច



www.budinst.gov.kh www.elibraryofcambodia.org

ដែរ ?

- សូមទោស ខ្ញុំមិនយល់ទេ ។

- អូស ! ចាស់ អោយខ្ញុំសូមទោសទៅចុះ ។ រឿងគ្រែ គឺរឿងស្និទ្ធស្នាល ។ និយាយពីរឿងគ្រែ គឺនិយាយពីការរួមរក្សដោយរាងកាយរវាងបុរស នឹងនារី ។ ប្រើពាក្យគ្រែល្អជាងរួមសង្វាសមែនទេលោក ?

*ប្លាក់ថន* ខំបិទបាំងភាពរសាប់រសល់របស់ខ្លួន ហើយឆ្លើយឡើង :

- ខ្ញុំ....តែ....តែ....ទើបបាន....បាន......សាករឿង.....គ្រែ....នេះតែម្ដងគត់ ។ កាលនោះ....តែ....តែ....នៅឯភូមិឯណោះ ។ ហើយ....ខ្ញុំចាំមិនសូវច្បាស់ដែរទេ ដោយ....តែ.... កាលនោះខ្ញុំបាក់បៀហេវហត់ព្រោះការធ្វើដំណើរពេក....ខ្ញុំ......ខ្ញុំ.....ដូចយល់សប្ដិបន្តិច ដូចមែនទែនបន្តិច ។ ។ តែ....តែ....ខ្ញុំហាក់ដូចជាពេញចិត្តណាស់ដែរ ។

*ម៉ារីក្លូ*ជ្រួញចិញ្ចើម :

- តាំងពីលោកមកដល់ស្រុកនេះ លោកទើបបានរួមដំណេកម្ដងទេ ?

- បាទ ។

- លោកពិតជាស្ងះស្ងាប់ហើយមែនទេ ? នារីប៉ុន្មាននាក់នេះពិតជាសប្បាយចិត្តរួមដំណេកជាមួយលោកណាស់ *អាន់ជីន-សាន* ។ លោកយកមួយណាក៏បាន រឺយកទាំអស់ក៏បាន ។

- អ្នកស្រីថាម៉េច ?

- មែនណាលោក ។ បើលោកមិនត្រូវការពួកបីនាក់នេះទេ ក៏លោកមិនបាច់ខ្វល់ដែរ ពួកគេមិនអាក់អន់ចិត្តអីដែរ ។ លោកគ្រាន់តែចង់បាននារីបែបណាមក ពួកយើងនឹងដោះស្រាយជូនភ្លាម ។

- សូមអរគុណហើយ តែពេលនេះខ្ញុំមិនទាន់ចង់បានទេ ។

- លោកច្បាស់ហើយណឹងអ្ហី ? សូមលោកអភ័យទោសផង ប៉ុន្តែ *គីរីស៊ូ-សាន* បានណែនាំច្បាស់លាស់ណាស់ ថាត្រូវថែទាំ និងស្តារសុខភាពរបស់លោក ។ តើលោកមានសុខភាពម៉េចនឹងកើត បើមិនបានរួមដំណេកនោះ ? នេះជារឿងសំខាន់ណាស់ សំរាប់មនុស្សប្រុសមែន



www.budinst.gov.kh www.elibraryofcambodia.org

ទៅលោក ? មែនណា ពិតជាសំខាន់ណាស់ ។

- សូមអរគុណណាស់អ្នកស្រី ។ តែ.... តែខ្ញុំ....ចាំពេលក្រោយចុះបាទ ។

*ប្លាក់ថន* ឆ្លើយទាំងភ័ន្តភាំងនឹងការនិយាយយ៉ាងត្រង់ៗយ៉ាងនេះ ។

- លោកមានពេលវេលាច្រើនណាស់ ។ ចាំបន្តិចទៀតយើងនិយាយរឿងនេះម្តងទៀតក៏បាន ។ យើងមានពេលច្រើនដើម្បីជជែកគ្នា បើសិនជាលោកចង់ជជែក ។ ពេលនេះលោកមានពេលយ៉ាងតិចក៏បួនចួបដែរ ។ ទាល់តែដល់ថ្ងៃលិចឯណោះទើបលោកត្រូវចេញដំណើរ ។

- សូមអរគុណ ។

- ពួកគេទាំងអស់គ្នាសុទ្ធតែចង់សំរួលអោយលោក *អាន់ជីន-សាន* ។ អូមែន ! រឺមួយ......រឺមួយ......លោកត្រូវការក្មេងប្រុសវិញ ?

- ថាម៉េច ?

- ក្មេងប្រុសណា ។ អារឿងនេះ ងាយដូចបកចេកបើសិនជាលោកត្រូវការ ។

ការញញឹមរបស់ *ម៉ារីកូ* ឥតមានក្លែងក្លាយសោះឡើយ សំលេងនាងក៏មានលក្ខណៈធម្មតា ។

- និយាយលេង រឺនិយាយមែនហ្នឹង ?

- មែនណា*អាន់ជីន-សាន* ។ រួចមានរឿងអីហ្នឹង ? ខ្ញុំគ្រាន់តែនិយាយថា បើសិនជាលោកចង់ ពួកគេនឹងបញ្ជូនក្មេងប្រុសម្នាក់មកភ្លាម ។

ឈាមឡើងច្រាលពេញមុខរបស់*ប្លាក់ថន* ។

- ខ្ញុំមិនត្រូវការទេ ។ តើខ្ញុំវាដូចជាពួកអាលេងកូនជីងហ្នឹងណាស់ទៅអ្វី ?

សំលេងរបស់ *ប្លាក់ថន* ឡើងលាន់ខ្ទរពេញបន្ទប់ ។ ទាំងអស់គ្នាបែរជាស្រលាំងកាំងសំលឹងផ្ទាំងមើល*ប្លាក់ថន* ។ *ម៉ារីកូ* អោនខ្លួនដាក់ថ្វាសនាងទៅជាប់នឹងកំរាល :

- សូមលោកអភ័យទោសដល់ខ្ញុំផងចុះ ដែលខ្ញុំបានធ្វើការភ័ន្តច្រលំយ៉ាងធ្ងន់ធ្ងរបែបនេះ ។ ខ្ញុំចង់អោយលោកមានការសប្បាយរីករាយ តែខ្ញុំបែរជាប្រមាថលោកទៅវិញ ។ ខ្ញុំមិនដែលនិយាយជាមួយ......ជាមួយជនបរទេសណាក្រៅតែពីបព្វជិតម្នាក់គត់ ដោយហេតុនេះហើយ



www.budinst.gov.kh www.elibraryofcambodia.org

ទើបខ្ញុំមិនដឹង.....មិនដឹងពីរបៀបរបបរបស់លោកក្នុងរឿងណឹងទេ ។ គេមិនដែលបង្រៀនខ្ញុំពីរឿងអស់នេះទេ *អាន់ជីន-សាន* ។ លោកបព្វជិតមិនដែលនិយាយដល់រឿងនេះទេ ។ នៅស្រុកនេះជូនកាលបុរស១ ត្រូវការក្មេងប្រុសម្តងម្កាលដែរ.....ពួកបព្វជិតក៏អីចឹង ។ ហេតុនេះហើយទើបខ្ញុំល្ងីល្ងើ គិតថាទំលាប់របស់លោកដូចជាទំលាប់របស់ពួកយើងដែរ ។

-ខ្ញុំមិនមែនជាបព្វជិតទេហើយរឿងណឹងក៏មិនមែនជាទំលាប់ជាទូទៅរបស់ពួកខ្ញុំដែរ។

មេពួកសាមូរ៉ៃឈ្មោះ *កាស៊ូ វ៉ាញ* សំលឹងមើលហេតុការណ៍ទាំងកំហឹងក្រេវក្រោធ ។ លោកមានភារៈទទួលមើលសន្តិសុខរបស់បុរសចុងស្រុកនេះ ហើយនិងទទួលថែទាំសុខភាពមនុស្សនេះផង ។ លោកក៏បានមើលឃើញផ្ទាល់នឹងភ្នែក នូវការរាប់អានដ៏អស្ចារ្យ របស់លោកម្ចាស់*តូរ៉ាណាកា* ជាមួយបុរសចុងស្រុកនេះ ហើយពេលនេះបុរសចុងស្រុកកំពុងតែបង្ហាញភាពច្រលោតខឹងមែនទែនតែម្តង ។ ពិតជាពួកស្រី១ភ្លីភ្លើអស់នេះនិយាយប៉ះពាល់អីធ្ងន់ដល់អ្នកទោសដ៏សំខាន់នេះហើយ ។ *កាស៊ូ* សួរទៅ *ម៉ារីកូ* ទាំងកំហឹង :

- រួចគាត់មានរឿងអី ?

*ម៉ារីកូ* ពន្យល់ពីសំដីដែលបានឆ្លើយឆ្លងគ្នាអំបាញ់មិញនេះរួចនាងពោលបន្ថែមទៀតថា

- ខ្ញុំដូចជាមិនយល់សោះតែម្តង មិនដឹងជារឿងអី ធ្វើអោយគាត់មួម៉ៅអីចឹង ?

*កាស៊ូ* អេះក្បាល ដោយស្ទើរមិនជឿខ្លួនឯង :

- គ្រាន់តែនាងស្នើក្មេងប្រុសភ្លាម គាត់ដូចជ្រូកពុលភ្លាមមែន ?

- ចាស់ ។

- សូមទោសណា តែតើនាងនិយាយបានគួរសមទេ ? រឺមួយនាងប្រើពាក្យមិនត្រូវទេដឹង ?

- ទេ ! ទេ ! *កាស៊ូ-សាន*..... ខ្ញុំច្បាស់ណាស់ ។ ខ្ញុំវង្វេងក្បុងហើយ ។ ខ្ញុំជាអ្នកនាំរឿងមែន ។

- ច្បាស់ជាមកពីរឿងផ្សេងទេដឹង ? រឿងអីណាំ ?

- អត់ទេ *កាស៊ូ-សាន* តែរឿងមួយហ្នឹង ។



www.budinst.gov.kh www.elibraryofcambodia.org

*កាស៊ូ-ភិញ* បន្ទឺឡើងទាំងតឹងទ្រូង :

- ខ្ញុំរកយល់មិនបានទេ ពួកអាចុងស្រុកអស់នេះ ។ អីលូវនេះធ្វើម៉េចជួយលួងវាអោយឈប់ខឹងទៅ ទើបពួកយើងបានសុខទាំងអស់គ្នា *ម៉ារីកូ-សាន* ។ នេះប្រហែលជាវាខានដំណេកយូរហើយទេដឹង ? នែ ! -*កាស៊ូ*បញ្ជាទៅ *ស៊ូណូ* -នាងយកសាកេមកទៀត សាកេក្តៅណាហើយយកកន្សែងមកផង ។ វាកួចងទៅឈ្លីកអោយយក្សណឹងទៅ ។

នារីបំរើស្ទុះស្ទាញធ្វើតាមបញ្ជាភ្លាម ។

រំពេចនោះ *កាស៊ូ-ភិញ* នឹកឃើញរឿងមួយ :

- រឺមួយក៏វាមិនកើតការទេដឹង ? រឿងដំណេកនៅឯភូមិនោះដូចជាមិនច្បាស់លាស់សោះមែនទេ ? រឺមួយវាឆេះដុំព្រោះវា " មិនកើតការ " ហើយដល់នាងលើករឿងនេះ វាឆេះដុំបណ្តោយទៅ ?

- សូមទោសខ្ញុំមិនយល់បែបណឹងទេ ។ លោកគ្រូពេទ្យនិយាយថា គាត់ល្អទាំងអស់ ។

- បើគាត់ " មិនកើតការ " មែន អានេះវាងាយយល់ទេ មែនទេ ? បើសិនជាខ្ញុំវិញខ្ញុំក៏ស្រែកបែកអាកាសដែរ ។ មែនណា ! សួរវាមើលទៅ ។

*ម៉ារីកូ* ធ្វើតាមសំដីរបស់*កាស៊ូ-ភិញ*ភ្លាម ។ គ្រាន់តែសំនួរចប់ *កាស៊ូ-ភិញ* ឡើងញាក់សាច់ ដោយឃើញមុខរបស់*ញាក់ថន* ឡើងក្រហមងាំងម្តងទៀត ទន្ទឹមនឹងសំលេងប្រទេចផ្តាសាដែលលាន់ឡើងពេញបន្ទប់ ។

សំលេង*ម៉ារីកូ* លាន់ឡើងស្តាប់មិនចង់លឺ :

- គាត់.....គាត់.....គាត់ថា " ទេ " ។

- និយាយម៉ាប្រាវមិញណឹង គ្រាន់តែថា " ទេ " អីចឹង ?

- ទេ ! តែពួកអស់នេះតែកាលណាខឹងមូម៉ៅ ប្រើពាក្យចំអេសចំអាសណាស់ ។

ម្តងនេះ *កាស៊ូ-ភិញ* ចាប់ផ្តើមបែកញើសស្រាក់ ព្រោះរូបលោកជាអ្នកដើមហេតុវិញម្តង :

- ជួយលួងគាត់ផង !



www.budinst.gov.kh www.elibraryofcambodia.org

វំពេចនោះ *កាស៊ូ-វ៉ាញ* ឈប់ង៉ក់ ។ *ហ្ស៊ីរ៉ូម៉ាត់ស៊ី* កំពុងដើរមករកពួកគេទាំងអស់គ្នាពីជ្រុងម្ខាងមក ។

- សូមទោសទាន !

*កាស៊ូ-វ៉ាញ* បន្ទឹពាក្យឡើងក្នុងអារម្មណ៍តឹងតែង និងដោយខំប្រឹងទប់សំលេងរបស់ខ្លួនកុំអោយញ័រ ពីព្រោះកណ្តាប់ដៃដែក ដែលធម្មតាជាមនុស្សប្រកាន់វិន័យបំផុតនោះ បានក្លាយជាដីរិចុះប្រេងក្នុងមួយអាទិត្យកន្លងមកនេះ ហើយនៅថ្ងៃនេះគឺដល់បន្ទុកតែម្តង ។ ទ័ពដប់នាក់ត្រូវបានទំលាក់សក្តិ ព្រោះសំលៀកបំពាក់រយីករយាក ពួកគូបយាមទាំងអស់ត្រូវបណ្តើរអាក្រោសយ៉ាងអាម៉ាស់ពេញមួយវិមាន សាមូរ៉ៃពីរនាក់ត្រូវបញ្ជាអោយធ្វើសិបពូគូ ព្រោះមកដូរវេនយាមយឺត ហើយអ្នកប្រមូលលាមកយប់១បួននាក់ត្រូវបោះទំលាក់ពីលើកំផែងវិមាន ពីព្រោះបានធ្វើអោយធុងលាមកកំពុបនៅក្នុងសួនច្បារវិមាន ។

- វ៉ាស្រួលបួលទេ *ម៉ារីកូ-សាន* ?

សំដីរបស់កណ្តាប់ដៃដែក ពោរពេញដោយការមួម៉ង ។ *កាស៊ូ-វ៉ាញ* ជឿជាក់ថានារីពត្លីពត្លីដែលនាំបង្ករឿងរ៉ាវអស់នេះ ច្បាស់ជានិយាយតាមត្រង់តែទាំងអស់ ហើយអ្នកនៅទីនេះទាំងប៉ុន្មានច្បាស់ជាកំបុតក្បាល ទាំងអស់ជាមិនខាន ។

ប៉ុន្តែ *កាស៊ូ-វ៉ាញ* ធូរទ្រូងខ្សាក នៅពេលដែលលឺ *ម៉ារីកូ* និយាយថា :

- ចាស់ លោកម្ចាស់ ! អ្វី១បានស្រួលបួលទេ ចាស់ ។

- នាងត្រូវលោកម្ចាស់បញ្ជាអោយចាកចេញដំណើរជាមួយ *អ៊ីរីស៊ូបូ-សាន* ។

- ចាស់ លោកម្ចាស់ ។

នៅពេលដែល *ហ្ស៊ីរ៉ូម៉ាត់ស៊ី* ចេញទៅ *ម៉ារីកូ* ខំសញ្ជឹងគិតថា ហេតុអ្វីគេបញ្ជូននាងអោយចេញឆ្ងាយពីទីនេះ ។ តើដើម្បីគ្រាន់តែបកប្រែអោយ *អ៊ីរី* ក្នុងពេលធ្វើដំណើរជាមួយមនុស្សចុងស្រុកនេះប៉ុណ្ណឹងទេអ្វី ? នេះដូចជាមិនសំខាន់ណាស់ណាទេ ។តើប្រពន្ធរបស់ *តូរ៉ាណាកា* ប៉ុន្មាននាក់ទៀតចេញដំណើរដែរឬយ៉ាងណា ? បើសិនជាទៅ តើនេះមិនជាការប្រថុយប្រថានសំរាប់សាស៊ីកូក្នុងការធ្វើដំណើរតាមសមុទ្រទេអ្វី ? តើអញទៅជាមួយ *អ៊ីរី* តែម្នាក់ឯង រឺមួយយកប្តីអញទៅ



www.budinst.gov.kh www.elibraryofcambodia.org

ជាមួយដែរ? បើសិនជាគាត់នៅ-ហើយគាត់ប្រាកដជានៅ ព្រោះនេះជាភារកិច្ចរបស់គាត់ចំពោះលោកម្ចាស់-តើបានអ្នកណាជួយមើលថែទាំគាត់ ? ហេតុអីបានជាយើងត្រូវធ្វើដំណើរតាមទូក? តើផ្លូវ *តូរ៉េកដូ* លែងធានាសន្តិសុខហើយរឺ តើ *អ៊ីស៊ីដូ* នឹងប៉ះពាល់ពួកយើងរឺ ? មើលទៅច្បាស់ជាវាប៉ានហើយ ព្រោះពួកយើងគឺពិតជាចំនាប់ដ៏មានតំលៃ : *សាស៊ីកូ គីវស៊ីបូ* និងអ្នកឯទៀតៗ ។ បែបអីចឹងហើយ ទើបពួកយើងត្រូវដើរតាមសមុទ្រនោះ ។

តាំងពីដើមមក *ម៉ារីកូ* ស្អប់សមុទ្រណាស់ ។ គ្រាន់តែឃើញក៏នាងឈឺបាត់ទៅហើយ ។ តែបើអញត្រូវអស់អាយុ គឺត្រូវតែអស់ ហើយអ្វីៗក៏ចប់ត្រឹមណឹង ។ នេះគឺកាម៉ា ។ នាងក៏បង្វិលអារម្មណ៍របស់នាងអោយលែងរវល់ នឹងរឿងព្រហ្មលិខិតទៀត ហើយផ្តោតមកលើមនុស្សចុងស្រុកខុសបែបខុសបទនេះ ហើយគ្មានបាននាំអ្វីក្រៅតែពីរឿងរ៉ាវជាប់ដល់រូបនាងតែប៉ុណ្ណោះ ។

នៅពេលដែលកណ្តាប់ដៃដែក ចាំងខ្លួនបាត់នឹងជ្រុងរបៀងហើយ ទើប *កាស៊ូ-វ៉ាញូ* ប៉ានងើបក្បាលឡើង ។ ហើយទាំងអស់គ្នាក៏ដកដង្ហើមបន្ធូរទ្រូងលាន់សូរឃ្សូរ ។ *អាសា* បានវិលត្រលប់មកវិញដោយមានទាំងស្រាសាកេមកជាមួយផង ។ នៅពីក្រោយនាងគឺសូណូ ដែលកាន់កន្សែងក្តៅមកជាមួយផងដែរ ។

ពួកគេតាមសំលឹងមើលអាកប្បកិរិយារបស់ *ប្លាក់ថន* នៅក្នុងពេលដែលនារីៗ រៀបចំផ្គាប់ចិត្ត ។ ពួកគេឃើញ *ប្លាក់ថន* នៅតែមានទឹកមុខមាំ ហើយគេទទួលសាកេដោយសោះអង្គើយនិង ពោលពាក្យអរគុណយ៉ាងត្រជាក់ស្រេងនៅពេលទទួលកន្សែងក្តៅ ។

*ម៉ារីកូ* និយាយទៅកាន់ *កាស៊ូ-វ៉ាញូ*

- តាមខ្ញុំមើល មនុស្សចុងស្រុកនេះមិនចូលចិត្តនិយាយរឿងដំណេកទេ ។ គាត់ជាមនុស្សចុងស្រុកប្រភេទថ្មី ដែលទើបមកដល់ស្រុកយើងជាលើកដំបូងបង្អស់ ហេតុនេះយើងត្រូវស្ទាបស្ទង់គេសិន ។

- ខ្ញុំឯកភាពហើយ - *កាស៊ូ-វ៉ាញូ* តប - វាគួរសមណាស់ដែរដំបូង ដល់ពេលយើងនិយាយរឿងណឹងទើបវាឆេះដុំតែម្រ៉ង ។

និយាយបណ្តើរ *កាស៊ូ-វ៉ាញូ* សំលក់អាសាបណ្តើរ ។ *អាសា* ក៏លំអោនក្បាលយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

ទាបស្មើរផល់កំភាល ។

- ខ្ញុំសូមទោស ។ លោកម្ចាស់ *កាស៊ូវ៉ាញូ-សាន* មានប្រសាសន៍ត្រូវណាស់ ។ នេះជាកំហុសរបស់ខ្ញុំទាំងស្រុង ចាស់ ។

- ពិតហើយ ខ្ញុំត្រូវរាយការណ៍រឿងនេះជូនលោកស្រី *គីរីស៊ូបូ-សាន* ។

- មែន ?

*ម៉ារីកូ* ផ្តល់មតិយ៉ាងប៉ិនប្រសប់

- ខ្ញុំគិតថា គួរប្រាប់ម្ចាស់ស្រីអោយប្រុងប្រយ័ត្នផងដែរ កុំនិយាយពីរឿងដំណេកអីទាំងអស់ជាមួយមនុស្សនេះ ។ លោក*កាស៊ូវ៉ាញូ-សាន*ចំជាវាងវៃមែន ចាស់ ។ តែបើគិត១ទៅ *អាសា* គឺជាឧបករណ៍ហេងមួយដែលជួយលោកស្រី*គីរីស៊ូបូ* និងអាចទាំងលោកម្ចាស់*តូរ៉ាណាកា*ផងអោយចេញផុតពីស្ថានភាពដ៏អាក្រក់មួយបាន ។ សូមលោកគិតមើល បើកាលពីម្សិលមិញ*គីរីស៊ូបូ-សាន* សួរពីបញ្ហានេះដោយខ្លួនឯងផ្ទាល់នៅចំពោះមុខ *តូរ៉ាណាកា* តើរឿងរ៉ាវនឹងទៅជាយ៉ាងណា បើមនុស្សចុងស្រុកបញ្ចេញអាកប្បកិរិយាបែបនេះ នៅចំពោះមុខលោកម្ចាស់ ?

*កាស៊ូ-វ៉ាញូ* គ្រញ៉ែងខ្លួន :

- ឈាមច្បាស់ជាក្រាលដីហើយ ។ នាងនិយាយត្រូវណាស់ *ម៉ារីកូ-សាន* ។ គួរតែអរគុណ *អាសា*ទើបត្រូវ ។ ខ្ញុំនឹងពន្យល់លោកស្រី *គីរីស៊ូបូ-សាន* ថាគាត់ហេងហើយ ។

*ម៉ារីកូ* ចាក់ស្រា ហើយលើកហុចទៅ*ប្លាក់ថន* ១គ្រវីក្បាល :

- ទេសូមអរគុណ ។

- ខ្ញុំសូមលោកអភ័យទោស ចំពោះប្រការដែលខ្ញុំល្ងីល្ងើមិនដឹងខ្យល់នេះ ។ លោកចង់សួរចំនួនខ្លះផល់ខ្ញុំមែនទេ ?

កន្លងមកនេះ *ប្លាក់ថន* បានត្រឹមអង្គុយមើលពួកអ្នកទាំងប៉ុន្មាននាក់ជជែកគ្នា ។ គេសែនមួម៉ៅ ដោយគេមិនអាចយល់ថា អ្នកទាំងនោះនិយាយពីអ្វីសោះ ។

- បាទ ។ នាងនិយាយថា ការលេងកូនជីង គឺជារឿងមួយធម្មតានៅស្រុកនេះអ្វី ?

- អ្វីដែលទាក់ទិនទៅនឹងរឿងដំណេក គឺជារឿងធម្មតាទាំងអស់ - *ម៉ារីកូ* ឆ្លើយតប



www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងអំនួតជំរុញម្យ៉ាងដោយកង្វះរបៀបរបបរបស់*ភ្លាក់ថុន* និងម្យ៉ាងដោយសំនួរដែលនាងចាត់ជាសំនួរដ៏ល្ងីល្ងើបំផុតនេះ ។ លោកម្ចាស់*គូរ៉ាណាកា* បានប្រាប់អោយនាងជួយផ្តល់ពត៌មាននានាដែលមិនមានចរិតនយោបាយអោយទៅ*ភ្លាក់ថុន* ប៉ុន្តែនាងត្រូវរាយការណ៍ជូនលោកនូវអ្វី១ដែលបានដឹងដែកទាំងអស់ ។ នាងបន្តទៀត :

- ចាស់ រឿងដំណោកគឺជារឿងធម្មតា។ ហើយរឿងមនុស្សប្រុសម្នាក់ រួមរក្សជាមួយមនុស្សប្រុសម្នាក់ទៀត រឺក្មេងប្រុសម្នាក់ តើរឿងនេះវាមិនទៅទាក់ទាមអ្នកណាផ្សេងក្រៅតែពីគេពីរនាក់នោះ ? តើរឿងនេះវានាំអោយប៉ះពាល់អីទៅ ? គ្មានទេ !

រួចនាងក៏បន្ទន់សំលេងមកវិញ :

- ប៉ុន្តែបើសិនលោកយល់ថា.....

-ការលេងកូនជឹង គឺជាបាបកម្មធ្ងន់ធ្ងរណាស់ ហើយអ្នកដែលប្រព្រឹត្តគឺជាសំរាមមនុស្សតែម្តង។

*ភ្លាក់ថុន* និយាយសង្កត់*ម៉ារីកូ* ជាប់ ដោយសារតែនាហហ៊ានប្រមាថខ្លួនគេថា ស្ថិតនៅក្នុងចំណោមពួកប្រភេទមនុស្សទាំងនោះ ។ ម្ចាស់ថ្លៃអើយ រួចវាយ៉ាងម៉េច បានជានាងយល់ថាអញជាមនុស្សបែបណឹង ? តែខំទប់អោយនឹងនរឡើងអាវ៉ា ! -*ភ្លាក់ថុន* ព្រមានខ្លួនឯងនៅក្នុងចិត្ត - កុំធ្វើឯងមើលតែអ្នកមហាត្រឹមត្រូវពេកនោះ។ រួចម្យ៉ាងទៀត ហេតុអីក៏អ្អែងស្អប់ពួកលេងកូនជឹងខ្លាំងម្ល៉េះ ? តើអារឿងនេះមិនមកតែពីពួកអ្នកដើរសមុទ្រ រាប់ខែហើយបើមិនដោះស្រាយតាមផ្លូវនេះទេតើមានអ្នកណាទ្រាំបាន ? តើអានេះមិនបណ្តាលមកពីអ្អែងក៏ធ្លាប់ចង់សាកម្តង១ដែរ ទេអ្វី ? រឺមួយក៏ពីកាលនៅក្មេងអ្អែងត្រូវប្រយុទ្ធដើម្បីការពាររូបខ្លួនអ្អែងទេដឹង ? ហើយម្តងនោះអ្អែង ត្រូវគេចាប់ជាប់រឺតែត្រូវគេរំលោភបានទៅទៀត បើកុំតែអ្អែងរើរួច ហើយប៉ុះមួយកាំបិតសំលាប់អាកូនមីចោរនោះទៅ ។ កាលនោះអ្អែងមានអាយុទើបបាន ដប់ពីរឆ្នាំហើយបុរសនោះគឺជាអ្នក រងគ្រោះទីមួយនៅលើបញ្ជី ដ៏វែងរបស់អ្អែង.......

*ភ្លាក់ថុន* និយាយបន្តទៅទៀត :

- នេះគឺជាអំពើបាប ហើយវាផ្ទុយទៅនឹងក្រឹត្យក្រមរបស់ព្រះ និងមនុស្សលោកទៀត



www.budinst.gov.kh www.elibraryofcambodia.org

ផង ។

*ម៉ារីកូ* តបវិញយ៉ាងជូរចត់ ដោយមិនពេញចិត្តនឹងភាពច្រងេងច្រងាងរបស់*ព្វាក់ថន* :

- នេះជាពាក្យគ្រិស្តសាសនាសំរាប់អនុវត្តលើរឿងផ្សេងៗទៀតតែប៉ុណ្ណោះ ។ អំពើបាប ? តើរឿងនេះមានកន្លែងណាដែលជាអំពើបាប ?

- នាងគួរតែដឹងហើយ ។ ក្រែងនាងជាកាតូលិចដែរមែនទេ ? នាងត្រូវបានពួក*យេស៊ុីត*អប់រំដែរមែនទេ ?

- ព្រះគ្រូបានអប់រំខ្ញុំអោយចេះនិយាយ និងសរសេរភាសាឡាតាំង និងប៉ិកទុយកាល់ ។ ខ្ញុំមិនដឹងថា លោកចង់និយាយពាក្យកាតូលិចនេះ ក្នុងន័យយ៉ាងណាទេ តែខ្ញុំគឺជាអ្នកកាន់គ្រិស្តសាសនា ហើយកាន់នេះជិតដប់ឆ្នាំហើយៗក៏គេមិនដែលនិយាយពីរឿងដំណេកដែរ ។ ខ្ញុំមិនដែលមើលសៀវភៅអស់លោកនិយាយពីរឿងដំណេកទេ បានមើលតែសៀវភៅធម៌តែប៉ុណ្ណឹង ។ តើរឿងដំណេកជាអំពើបាបដែរ ? រួចយ៉ាងម៉េចបានជាវាទៅជាអ៊ីចឹងទៅវិញ ? តើហេតុអ្វីបានជាអ្វីៗដែលអាចផ្តល់ការសប្បាយរីករាយដល់មនុស្សលោក ប្រែទៅជាអំពើបាបទៅវិញ ?

- ទៅសួរបព្វជិត*អាល់វីតូ* ទៅ !

ខ្ញុំចង់សួរណាស់ទៅហើយ !- *ម៉ារីកូ* គិតទាំងជ្រួលច្របល់នៅក្នុងចិត្ត - តែខ្ញុំត្រូវទទួលបញ្ជាយ៉ាងដាច់ណាត់ មិនអោយយករឿងដែលបាននិយាយនៅកន្លែងនេះទៅពិភាក្សាជាមួយអ្នកណាក្រៅពីជាមួយ*គីរី*និងលោកម្ចាស់*តូរ៉ាណាកា* ឡើយ ។ ខ្ញុំបានបន់ព្រះ និងព្រះមាតាសូមអោយជួយខ្ញុំដែរ តែគ្មានចំលើយអ្វីទាំងអស់ ។ ខ្ញុំដឹងតែម្យ៉ាងទេ គឺថាតាំងពីលោកឯងមកដល់កន្លែងនេះពេលណាមក គឺឃើញតែរឿងរ៉ាវរហូត ។ ខ្ញុំគ្មានបានអ្វីក្រៅតែពីរឿងរ៉ាវទេ...នាងបន្តទៀត :

- បើរឿងនេះជាអំពើបាបដូចលោកថាមែន ហេតុអីក៏មានសង្ឃយើងគគោកប្រព្រឹត្តរឿងនេះ ? មាននិកាយពុទ្ធសាសនាខ្លះបានណែនាំអោយប្រព្រឹត្តវាទៀតផង ។ នេះគឺពិតជាពេលវេលាមួយដែលមនុស្សលោកអាចខិតទៅជិតឋានសួគ៌បានដោយពិតប្រាកដ ។ មានបព្វជិតជាច្រើននាក់បានត្រូវគេដឹងថា ចូលចិត្តប្រព្រឹត្តអំពើបែបនេះដែរ ។ តើពួកគេជាពួកបិសាចអ្វី ? គឺពិតជាមិនមែនទេ ! ហេតុអីក៏ពួកគេមិនអាចសប្បាយក្នុងផ្លូវធម្មតាបានទៅពេលដែលពួកគេ



www.budinst.gov.kh www.elibraryofcambodia.org

មិនអាចប៉ះពាល់នារីបានទៅហើយនោះ ? នេះគឺចំជាផ្ដេសផ្ដាសមែនដែលនិយាយថា រឿងដំណេកទាំងអស់សុទ្ធតែជាអំពើបាប និងជាអំពើដែលព្រះផ្ដន្ទានោះ ។

- រឿងកូនជឹង គឺជាអំពើថោកទាប ហើយផ្ទុយនឹងក្រឹត្យក្រមទាំងអស់ ។ នាងសាកសួរបព្វជិតប្រដៅចមិរបស់នាងទៅមើល !

លោកឯងហ្នឹងហើយដែលជាមនុស្សថោកទាប -*ម៉ារីកូ* ស្រែកជំទាលនៅក្នុងពោះ ។ ហេតុអីបានជាលោកឯងច្រងេងច្រងាងគ្មានសណ្ដាប់ធ្នាប់ និងល្ងីល្ងើមិនដឹងខ្ទាក់យ៉ាងហ្នឹង ? លោកឯងថារឿងហ្នឹងខុសនឹងព្រះ ? ចំជាភ្លីភ្លើមែន ! ខុសនឹងព្រះលោកឯងទេដឹង ? លោកឯងអះអាងថា កាន់គ្រិស្តសាសនា តែមើលសព្វ១ទៅលោកឯងពិតជាមិនមែនទេ ។ លោកឯងគឺជាមនុស្សកុហកបោកប្រាសតែប៉ុណ្ណោះ ។ ប្រហែលជាលោកឯងដឹងរឿងអស្ចារ្យជាច្រើន ហើយប្រហែលជាលោកឯងធ្លាប់បានទៅកន្លែងប្លែក១ជាច្រើនមែន តែលោកឯងពិតជាមិនមែនគ្រិស្តសាសនិកទេ ។ តើលោកឯងត្រូវ*សាតង់* បញ្ជូនមកទេដឹង ? អំពើបាប ? ចំជាផ្ដេសផ្ដាសមែន ! លោកឯងនេះលោតច្រលោតពីរឿងធម្មតា ហើយអាកប្បកិរិយាលោកឯងហាក់ដូចជា មនុស្សលេលាអីចឹង ។ លោកឯងក្រលុកពួកបព្វជិត នាំកង្វល់ដល់លោកម្ចាស់*តូរ៉ាណាកា* នាំពួកយើងបែកបាក់គ្នា នាំការសង្ស័យដល់ជំនឿរបស់យើង មិនតែប៉ុណ្ណោះធ្វើអោយពួកយើងវង្វេងវង្វាន់ពីរឿងអ្វីដែលពិត និងអ្វីដែលមិនពិត ព្រោះលោកឯងដឹងច្បាស់ថា ពួកយើងមិនអាចរកស្ដុតាងបានភ្លាម១ឡើយ ។

ខ្ញុំចង់ប្រាប់លោកថា ខ្ញុំស្អប់លោកឯង ហើយខ្ញុំស្អប់ពួកអ្នកចុងស្រុកទាំងអស់ ។ ពិតណាស់ហើយពួកចុងស្រុកទាំងនេះ បានធ្វើអោយជីវិតខ្ញុំក្រលាប់ចាក់អស់ហើយ ។ ពួកវាស្អប់ឪពុកខ្ញុំដែលមិនព្រមទុកចិត្តពួកវា ហើយបានស្នើជាចំហដល់*តូរ៉ូដា* អោយបណ្ដេញពួកនេះចេញអស់ពីទឹកដីរបស់យើង ។ មិនគឺពួកវានេះហើយដែលបានបញ្ចុះបញ្ចូលលោកម្ចាស់ *តូរ៉ូដា* អោយស្អប់ឪពុកខ្ញុំ ដែលជាមេទ័ពជំនិតបំផុត និងជាមនុស្សដែលបានជួយ*តូរ៉ូដា* ច្រើនលើសពីមេទ័ពណាកាមូរ៉ា រីលោកម្ចាស់*តូរ៉ាណាកា* ទៀតផងនោះ ។ មិនគឺពួកចុងស្រុកនេះទេអ្វីដែលជាដើមហេតុនាំអោយ*តូរ៉ូដា* ប្រមាថកាតទានឪពុកខ្ញុំ ធ្វើអោយឪពុកខ្ញុំវង្វេងវង្វាន់ស្មារតីអស់នាំទាំងការ



www.budinst.gov.kh www.elibraryofcambodia.org

លំបាកដល់ខ្ញុំទៀតនោះ ?

ពិតណាស់ គឺពួកនេះហើយដែលជាដើមភ្លើង ហើយបានបង្ករឿងលើសពីនេះទៅទៀត ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏វាសនាខ្ញុំស្ថិតនៅលើព្រះជាម្ចាស់ជាអ្នកសំរេចតែប៉ុណ្ណោះ ។

*ម៉ារីកូ* និយាយទៅកាន់ *ភ្វាក់ថន* :

- ខ្ញុំសូមអភ័យទោស ចំពោះភាពមិនសមរម្យរបស់ខ្ញុំ ។ លោកខឹងនេះគឺពិតជាត្រឹមត្រូវហើយ ។ ខ្ញុំគ្រាន់តែជានារីពត្បីពភ្លើមួយតែប៉ុណ្ណោះ ។ សូម *អាន់ដឺន-សាន* រក្សាខន្តីនិងអភ័យទោសដល់ការល្ងង់ខ្លៅរបស់ខ្ញុំផង ។

កំហឹងរបស់ *ភ្វាក់ថន* ចាប់ផ្តើមរសាយចេញភ្លាមមួយរំពេច ។ តើមនុស្សប្រុសណាមួយអាចនៅខឹងបានយូរទៀត បើសិនជានារីម្នាក់ទទួលសារភាពថាខ្លួននាងជាអ្នកខុស ហើយប្រុសជាអ្នកត្រូវនោះ ? គេចាប់ផ្តើមនិយាយបន្ទន់សំលេងតបវិញ :

- ខ្ញុំក៏សូមអភ័យទោសផងដែរ *ម៉ារីកូ-សាន* ។ ប៉ុន្តែចំពោះពួកយើង កាលណាគេនិយាយថាជាអ្នកលេងកូនជឹង គឺពិតជាការប្រមាថមួយដ៏ធ្ងន់ធ្ងរបំផុតហើយ ។

តាមពិតទៅ ពួកលោកឯងមិនគ្រាន់តែមិនដឹងខ្យល់ ល្ងាក់ល្ងើតែប៉ុណ្ណោះទេ តែលោកឯងថែមទាំងថោកទាប ច្រលើសបើស គ្មានដឹងច្បាប់ទំលាប់អ្វីទាំងអស់ថែមទៀត -ម៉ារីកូគិតនៅក្នុងចិត្ត ។ តែជាមួយមនុស្សចុងស្រុក តើមានអីហួសពីណឹងទៅទៀត ? នាងឆ្លើយតបទៅ *ភ្វាក់ថន* វិញ :

- ចាស់ ! ពិតមែនណា៎ ! លោកនិយាយត្រូវណាស់ ។ ខ្ញុំគ្មានបំនងប៉ះពាល់ *អាន់ដឺន-សាន* ទេ សូមលោកអភ័យទោសដល់ខ្ញុំផង ចាស់ ។

*ម៉ារីកូ* ដកដង្ហើមធំ ហើយសំដីនាងឡើងផ្អែម និងយ៉ាងស្រទន់ គឺថា ទោះជាប្តីកំពុងច្រលោតខឹង រឹម្ចមៅយ៉ាងណា ក៏ត្រូវតែចុះចាញ់ផងដែរ :

- ចាស់ នេះគឺជាកំហុសរបស់ខ្ញុំទាំងស្រុងមែនណា៎ ។ សូមអភ័យទោស ចាស់ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

ព្រះអាទិត្យលិចប៉ប្រះជើងមេឃទៅហើយ តែបព្វជិត *អាលវីតូ* នៅតែរង់ចាំក្នុងសាលាជំនុំនៅឡើយ ។ កូនសៀវភៅដែលនៅក្នុងដៃរបស់លោកហាក់ដូចជាធ្ងន់ពាប់តែម្តង ។

អា *ក្លាក់ថន* ចង្រៃយក៏នេះ!បព្វជិត *អាលវីតូ* ប្រទេចផ្តាសានៅក្នុងពោះ ។ នេះគឺជាលើកទីមួយហើយដែល *តូរ៉ាណាកា* ទុកអោយលោកនៅរង់ចាំយ៉ាងនេះ ។ នេះគឺជាលើកទីមួយហើយដែលលោកត្រូវរង់ចាំ *វ៉ែមីក្លូ* ទោះជា *តែគូ* ក៏មិនដែលយ៉ាងដូច្នោះដែរ ។ក្នុងរយៈពេលប្រាំបីឆ្នាំចុងក្រោយនៃអំនាចរបស់ *តែគូ* លោកត្រូវបានគេផ្តល់ឯកសិទ្ធិយ៉ាងធំសំបើម ស្ទើរមិនអាចជឿបាន ពោលគឺលោកអាចចូលជួប *តែគូ* បានភ្លាមៗនៅគ្រប់ពេលវេលាដូចជាបច្ចុប្បន្នជាមួយ *តូរ៉ាណាកា* សព្វដងយ៉ាងដូច្នោះដែរ ។ ប៉ុន្តែឯកសិទ្ធិជាមួយ *តែគូ* គឺត្រូវបានមកដោយសារលោកចេះភាសាជប៉ុនយ៉ាងស្ទាត់ហើយនិងភាពវាងវៃរបស់លោកនៅក្នុងរឿងជួញដូរ ។ ចំនេះដឹងរបស់លោកស្តីពីគន្លឹះក្នុងជំនួញដូរអន្តរជាតិបានជួយបង្កើនសម្បត្តិមហាសាលរបស់ *តែគូ* យ៉ាងរហ័ស ។ ថ្វីត្បិតតែ *តែគូ* អានអក្សរស្ទើរមិនដាច់ក្តី ក៏ការយល់ដឹងលើផ្នែកភាសារបស់លោកគឺទូលំទូលាយ ហើយចំនេះដឹងផ្នែកនយោបាយរបស់លោកគឺធំធេង ។ ដោយហេតុនេះបព្វជិត *អាលវីតូ* មានការរីករាយណាស់ដែលបាននៅអែបអម្ចាស់ *តែគូ* ដើម្បីរៀនតាមនិង ដើម្បីបង្រៀនទទ្ទឹមនឹងកូនចិត្តសង្ឃឹមថាអាចបញ្ចុះបញ្ចូល *តែគូ* អោយចូលសាសនាគ្រិស្តថែមទៀតផង ។ ចំនុចចុងក្រោយនេះគឺជាមុខងារជាពិសេស ដែលគណៈអធិការសង្ឃ *វ៉ៃឡាក្កា* បានបំពាក់បំប៉នយ៉ាងម៉ត់ចត់អាស្រ័យការជ្រើសរើសគ្រូអ្នកបង្ហាត់ពូកែៗបំផុតក្នុងចំនោមពួក *យេស៊ុីត* និងពួកជំនួញបំកទុយកាល់នៅអាស៊ីនេះ ។ *អាលវីតូ* ក៏បានក្លាយទៅជាមនុស្សទំនុកចិត្តរបស់ *តែគូ* ក្នុងចំណោមមនុស្សទំនុកចិត្តទាំងបួននាក់ និងជាមនុស្សទំនុកចិត្តសញ្ជាតិបរទេសតែម្នាក់គត់ ដែលបានឃើញឃ្លាំងសម្បត្តិមហាសាលផ្ទាល់ខ្លួនរបស់ *តែគូ* ។

នៅចំងាយពីសាលាជំនុំប៉ុន្មានរយជំហាន គឺជាប៉មធំនៃវិមាន និងជាឃ្លាំងសម្បត្តិមហាសាល ។ ប៉មនេះមានប្រាំពីរជាន់ និងមានទ្វារចូល និងកន្លែងការពារខ្ជាត់ខ្ជែង ។ នៅជាន់ទីបួនមានបន្ទប់ប្រាំពីរឃាំងដោយទ្វារដែកទាំងអស់ ។ បន្ទប់នីមួយៗពោរពាសទៅដោយកាសមាស និងដុំមាស ។ នៅជាន់លើទៀត គឺជាបន្ទប់ពោរពេសដោយកាសប្រាក់ និងដុំ ប្រាក់ ។ ជាន់



www.budinst.gov.kh www.elibraryofcambodia.org

លើមួយទៀត មានក្រនាត់សូតកំរ១ មានពែង ប៉ាន់ ចានចរណៃ ដាវ និងអាវក្រោះ ។ នេះគឺសម្បត្តិមហាសាលនៃចក្រភពនេះ ។

បើតាមការប៉ាន់ស្មានរបស់យើងពេលនេះ - បព្វជិត *អាល់វីតូ* គិតនៅក្នុងចិត្ត-តំលៃនៃសម្បត្តិមហាសាលទាំងនេះ មិនតិចជាងហាសិបលានឌុយកាតទេ ពោលគឺស្មើនឹងចំនួលជាងមួយឆ្នាំរបស់ចក្រភពអេស្ប៉ាញ ចក្រភពប៉ក់ទុយកាល់ និងអឺរ៉ុបទាំងមូលបូកបញ្ចូលគ្នាទៅទៀត។ នេះគឺពិតជាសម្បត្តិមហាសាលបុគ្គលច្រើនជាងគេបំផុតនៅក្នុងលោកនេះហើយ ។

តើនេះគឺជាតំលៃដែលត្រូវបានរឺ ?បព្វជិត *អាល់វីតូ* វិភាគនៅក្នុងចិត្ត ។ អ្នកណាត្រួតត្រាវិមាន *អូសាកា* នឹងមិនក្លាយទៅជាម្ចាស់សម្បត្តិមហាសាលនេះរឺទេអី?ហើយបើអីចឹងទ្រព្យសម្បត្តិទាំងនេះ នឹងមិនផ្តល់ដល់ជននោះនូវអំនាចលើទឹកដីនេះទេរឺអ្វី? មិនតែនគរទាំង មូលត្រូវខ្សោះខ្លួនក្នុងការកសាងវិមាន *អូសាកា* អោយក្លាយទៅជាវិមានមួយដែលគ្មានអ្នកណាបំពានបាន ដើម្បីការពារមាសទាំងនេះ រហូតដល់ពេលដែល *យែនមុំន* ដល់វ័យអាចគ្រប់គ្រងនគរ នេះបានទេអ្វី ?

គ្រាន់តែមួយភាគរយនៃទ្រព្យសម្បត្តិនេះ យើងអាចកសាងព្រះវិហារបាននៅគ្រប់ក្រុងនិមួយ១និងកន្លែងប្រដៅធម៌នៅគ្រប់ភូមិមួយនគរនេះ។ នេះបើសិនជាយើងអាចក្តាប់បានទ្រព្យសម្បត្តិនេះ និងប្រើទ្រព្យសម្បត្តិនេះជាផលប្រយោជន៍ថ្វាយព្រះ ។

អម្ចាស់ *តែកូ* ជាមនុស្សស្រលាញ់អំនាច ។ ហើយលោកក៏ស្រលាញ់មាសផងដែរព្រោះមាសផ្តល់នូវអំនាចលើមនុស្សឯទៀត។ សម្បត្តិមហាសាលនេះគឺជាកន្លែងផ្លែផ្កានៃការគ្រប់គ្រងអំនាចផ្តាច់ការដប់ប្រាំមួយឆ្នាំ ជាសួយសារអាករ ដែល *ដៃមីញ៉ូ* ទាំងអស់ត្រូវយកមកជូនជារៀងឆ្នាំផង ជាផលដែលប្រមូលនៅក្នុងដែនដីដែលលោកត្រួតត្រាផង ។ តាមរយៈ សិទ្ធិ ជាជ័យភព្វតែកូមានអំនាចត្រួតត្រាដោយផ្ទាល់នូវទឹកដីមួយភាគបួននៃនគរ។ ចំនួលប្រចាំឆ្នាំផ្ទាល់ខ្លួនរបស់ *តែកូ* គឺលើសពីប្រាំលានកូគូ ។ហើយព្រោះតែតែកូបានសិទ្ធិប្រទានពីព្រះចៅអធិរាជ អោយទទួលតួនាទីជាស្តេចត្រាញ់លើទូទាំងប្រទេសជប៉ុនផងនោះ លោកក៏ជាអ្នកកាន់កាប់ប្រាក់ចំនួលទាំងអស់នៃដែនដីនគរនេះផងដែរ ។ *តែកូ* គតទារពន្ធពីអ្នកណាម្នាក់ឡើយប៉ុន្តែ *ដៃមីញ៉ូ* កសិករសិប្បករឈ្មួញពួកអ្នកចុងស្រុកទាំងអស់រួមទាំងពួក *អេតា* សុទ្ធតែបានរួមបង់វិភាគទានយ៉ាងស្ម័គ្រចិត្ត និង



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងចំនួនយ៉ាងច្រើន ។ បង់ដើម្បីសន្តិសុខផ្ទាល់ខ្លួន ។

ហេតុនេះនៅពេលណាដែលសម្បត្តិទ្រព្យទាំងនេះ នៅគង់វង្ស វិមានអូសាកានៅគង់វង្ស ហើយ *វ៉ៃយទម៉ុន* នៅតែជាអ្នកគ្រប់គ្រងដោយពិតប្រាកដ-បព្វជិត *អាលវីតូ* គិតនៅក្នុងចិត្ត-*វ៉ៃយទម៉ុន* ពិតជាអាចគ្រប់គ្រងអំនាចបាននៅពេលពេញវ័យ ទោះជា *តូរ៉ាណាកា* រឺ *អ៊ីស៊ីដូ* រឺអ្នកណាផ្សេងទៀតចង់រារាំងក្តី ។

គឺចំជាសិយមែន ដែលតែកូបានទទួលមរណភាពទៅ ។ ទោះជាអាតាត់នេះមានកំហុសយ៉ាងណាក្តីក៏យើងធ្លាប់ស្គាល់ខ្មោចព្រាយនេះហើយដែរ ។ បើសិយមែនទែនគឺ *ក្លូរ៉ដា* ត្រូវតែសំលាប់ទៅវិញនោះទេព្រោះគាត់នោះទើបជាមិត្តពិតប្រាកដរបស់យើង។ តែគាត់ស្លាប់ទៅហើយ ។ *តែកូ* ក៏អ៊ីចឹង ។ ហើយឥឡូវនេះយើងត្រូវពត់ទមិឡថ្មីទៀតគឺ *តូរ៉ាណាកា* និង *អ៊ីស៊ីដូ* ។

*អាលវីតូ* នៅចាំយ៉ាងច្បាស់នូវយប់ដែល *តែកូ* ទទួលមរណភាពនោះ ។លោកត្រូវបាន *តែកូ* អញ្ជើញកំដររួមជាមួយ *យ៉ូដូកូ-សាម៉ា* ប្រពន្ធរបស់ *តែកូ*និងជំទាវ *អូជីបា* ដែលត្រូវជាប្រពន្ធចុង *តែកូ* និងជាម្តាយរបស់ *វ៉ៃយទម៉ុន*។ពួកគេបាននៅអង្គុយកំដរយ៉ាងយូរនៅក្នុងរាត្រីដ៏វែង នៃរដូវផ្ការីក ។

រួចតែកូ ក៏ត្រដរខ្យល់ ហើយដកចង្ហាមាន់ដាច់ខ្យល់ផុតទៅ ។

- ព្រលឹងលោកចេញផុតហើយ ឥឡូវនេះព្រះជាម្ចាស់ថែរក្សាលោកវិញម្តង !

*អាលវីតូ* បន្លឺពាក្យឡើងក្រោយពីបានពិនិត្យច្បាស់លាស់ហើយ ។ រួចលោកធ្វើសញ្ញាខ្វែងលើសាកសព និងសូត្របង្សុកូលយ៉ាងខ្លី ។

*យ៉ូដូកូ* និយាយក្នុងសំនោកយ៉ាងស្ងៀមស្ងាត់ :

- សូមព្រះពុទ្ធជាម្ចាស់ថែរក្សាអម្ចាស់របស់ខ្ញុំ និងឆាប់អោយលោកចាប់ជាតិមកវិញបានរហ័សដើម្បីក្តាប់ចក្រភពនេះម្តងទៀត ។

លោកជំទាវ *យ៉ូដូកូ* គឺជានារីដ៏ល្អម្នាក់ ជាសាមូរ៉ៃត្រកូលខ្ពស់ និងជាភរិយាដ៏ស្មោះត្រង់ និងជាទីប្រឹក្សាដ៏ជាទីទុកចិត្តអស់រយៈពេល សែសិបបួនឆ្នាំ នៃអាយុហាសិបប្រាំបួនឆ្នាំរបស់លោកជំទាវ ។ ក្នុងតួនាទីរបស់លោកជំទាវ១បានបិទភ្នែករបស់សពហើយនិង ចំអាសសព ។ រួចស្រេចបាច់ហើយ លោកជំទាវអោនគោរពសពបីដង ទើបចាកចេញពីទីនោះទៅ ។



www.budinst.gov.kh www.elibraryofcambodia.org

មរណភាពរបស់អម្ចាស់ *វ៉ាត់កូ* ឥតមានលំបាកវេទនាអ្វីសោះ ។ អម្ចាស់ *វ៉ាត់កូ*មានជំងឺរាប់ខែមកហើយ១យប់នេះអ្នកណាក៏ដឹងថា ជារាត្រីចុងក្រោយដែរ ។ កាលពីប៉ុន្មានម៉ោងមុននេះ លោកបានបើកភ្នែក ហើយញញឹមដាក់ជំទាវ *អូជីកា* និងយ៉ូដូ។ រួចលោកក៏និយាយខ្សាវៗឡើងៈ

- សូមជួយស្ដាប់ណា នេះគឺជាកំនាព្យមរណភាពរបស់ខ្ញុំ :

*ជីវិតប្រៀបដូចជាសន្សើម*

*ទាំងពេលចាប់ផ្ដើម ពេលចាកគត*

*វិមានអូសាកា និងចក្រភព*

*នេះគ្រាន់ជាសប្តិនៅក្នុងសប្តិ* ។

រួចគឺជាស្នាមញញឹមដ៏ស្រទន់មួយ របស់មេផ្ដាច់ការចំពោះប្រពន្ធទាំងពីរ និងចំពោះ បព្វជិត *អាល់វ៉ីតូ* ។

- សូមអ្នកទាំងអស់គ្នាជួយថែទាំកូនប្រុសរបស់ខ្ញុំផង ។

ជាមួយនឹងបណ្ដាំចុងក្រោយនេះ ភ្នែករបស់ *វ៉ាត់កូ* ក៏នៅល្អក់ទ្រឹងជារៀងរហូត ។

បព្វជិត *អាល់វ៉ីតូ* នៅទឹកឃើញពីអារម្មណ៍រំភើបរបស់លោកចំពោះកំនាព្យចុងក្រោយ ដែលពិតជាបុគ្គលិកលក្ខណៈរបស់ *វ៉ាត់កូ* ពិតៗ ។ កាលនោះនៅក្នុងចិត្តលោកពោរពេញដោយក្ដីសង្ឃឹម ដោយហេតុថា *វ៉ាត់កូ* បានអញ្ជើញរូបលោក ដោយហេតុនេះនៅរយៈពេលចុងក្រោយបំផុតនេះ ស្ដេចត្រាញ់នៃចក្រភពជប៉ុនពិតជាយល់ព្រមចូលសាសនា ហើយទទួលធមិចុងក្រោយជាមិនខាន ។ ប៉ុន្តែរឿងរ៉ាវមិនដូចដែលលោកគិតទុកជាមុនសោះ ។

- លោកម្ចាស់បានបាត់បង់នគរសួគ៌តែរហូតហើយ !

បព្វជិត *អាល់វ៉ីតូ* និយាយរង៉ូវៗយ៉ាងក្រៀមក្រំ ។ លោកតែងតែកោតសរសើរ *វ៉ាត់កូ* ក្នុង តួនាទីជាមេទ័ព និងជាអ្នកនយោបាយដ៏ចំនានម្នាក់ ។

ជំទាវ *អូជីកា* បន្លឺសំនូរឡើង :

- រួចចុះវាយ៉ាងម៉េចទៅវិញ បើសិនជានគរសួគ៌របស់លោកនៅទាល់ត្រឹមជញ្ជាំងអ្នកចុងស្រុកនោះ ?



www.budinst.gov.kh www.elibraryofcambodia.org

- លោកជំទាវមានប្រសាសន៍ថាម៉េច ?

បព្វជិតស្ញើរតែមិនជឿត្រចៀករបស់លោក  នៅពេលដែលលឺសូរស័ព្ទពោរពេញទៅដោយភាពស្ងប់ ដែលលោកមិនដែលនឹកស្មានដល់យ៉ាងនេះ ។ លោកបានស្គាល់ជំទាវ *អូជីបា* ជិតម្ភៃឆ្នាំមកហើយ គឺតាំងពីលោកជំទាវអាយុបានដប់ប្រាំឆ្នាំ គឺនៅពេលដែល *វ៉ៃកូ* បានយកលោកជំទាវជាប្រពន្ធចុងភ្លាមម្ល៉េះ។ លោកជំទាវរមែងមានចរិតសុភាពរាបសារក់រនិយាយស្តី ហើយជានិច្ចកាលតែងតែញញឹមយ៉ាងផ្អែមត្រជាក់ ពោរពេញដោយសុភមង្គល ។ ប៉ុន្តែពេល នេះ......

- ខ្ញុំនិយាយថា : ˝ រួចចុះវាយ៉ាងម៉េចទៅវិញ បើសិនជានគរសួគ៌របស់លោកនៅទាល់ត្រឹមជញ្ជាំងអ្នកចុងស្រុកនោះ ? ˝

- សូមព្រះជាម្ចាស់សណ្តោសប្រោសប្រណីលោកជំទាវផងចុះ ! ប្តីលោកជំទាវទើបផុតដង្ហើមអំបាញ់មិញសោះ......

-ម្ចាស់ប្តីរបស់ខ្ញុំស្លាប់  ឥទ្ធិពលរបស់លោកទៅលើគាត់ក៏ស្លាប់ទៅជាមួយផងដែរមែនទេ ? គាត់ចង់អោយលោកមកទីនេះ។ ល្អ ! នេះជាសិទ្ធិរបស់គាត់។ ប៉ុន្តែអីលូវនេះគាត់នៅ ឯបរលោកហើយលែងបញ្ជានៅកន្លែងនេះទៀតហើយ ។អីលូវនេះគឺខ្ញុំជាអ្នកបញ្ជា។ លោកបព្វជិតឯងស្អុយណាស់  ហើយនាំតែខូចបរិយាកាសគេទេ។ អីលូវនេះសូមលោកឯងចេញពី វិមាននេះភ្លាម ហើយទុកអោយគេបានស្ងប់ស្ងាត់ផង ។

ពន្លឺភ្លើងទៀនរេរាំនៅលើរង្វង់មុខរបស់ជំទាវ *អូជីបា* ។ លោកស្រីគឺរាប់ស្ថិតនៅក្នុងចំនោមនារីដ៏ស្អាត១បំផុតក្នុងនគរនេះ  ។ ដោយសភាវគតិបព្វជិត *អាលវីតូ*  ធ្វើសញ្ញាខ្វែងហាក់ដូចចង់បណ្តេញបិសាចចេញពីក្នុងខ្លួនលោកជំទាវយ៉ាងដូច្នោះដែរ ។

សំនើចរបស់លោកជំទាវលាន់ឡើងគួរអោយព្រឺឆ្អឹងខ្នង ។

- ទៅអោយផុតពីមុខពីមាត់ទៅ ! ហើយកុំមកវិញអោយសោះ ។ ពេលវេលារបស់លោកឯងគឺចប់ហើយ ។

- លោកជំទាវក៏យ៉ាងដូច្នោះដែរ។ ជីវិតរបស់ខ្ញុំស្រេចតែព្រះជាម្ចាស់កំនត់។ លោកជំទាវគួរតែស្តាប់តាមព្រះជាម្ចាស់ទៅ ក្រែងបានដល់ផ្លូវសួគ៌នឹងគេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ថាម៉េច ? ជីវិតលោកស្រេចតែព្រះជាម្ចាស់កំនត់ ? ព្រះគ្រិស្តសាសនាណឹងមែនទេ? ចំពោះរូបលោកប្រហែលជាអីចឹងមែន ! រឺប្រហែលជាមិនមែនទេក៏មិនដឹង ? នែ លោកបព្វជិត តើលោកធ្វើយ៉ាងម៉េចទៅ បើនៅពេលដែលលោកឯងស្លាប់ទៅទើបលោកដឹងថាគ្មានព្រះ គ្មានឋាននរក ហើយឋានសួគ៌ អមតៈរបស់លោកឯងគ្រាន់តែជាសប្តិនៅក្នុងសប្តិនោះ ?

បព្វជិត *អាលវីតូ* បន្លឺឡើង :

- ខ្ញុំជឿ ! ខ្ញុំជឿថាមានព្រះ ! ពាក្យសន្យាព្រះគ្រិស្តគឺជាការពិត ។ ជាការពិត ! ជាការពិត ! ! ខ្ញុំជឿ !

- *ណោន ចា ណូគូ-សាន* ?

ក្នុងរយៈពេលយ៉ាងខ្លីបព្វជិត*អាលវីតូ*លឺតែភាសាជប៉ុនដែលគ្មានន័យអ្វីទាំងអស់ចំពោះលោក ។

*តូរ៉ាណាកា* កំពុងឈរនៅឯមាត់ទ្វារ ហ៊ុមព័ទ្ធទៅដោយអង្គរក្សរបស់លោក ។

បព្វជិត *អាលវីតូ* ខំប្រឹងប្រមែប្រមូលស្មារតីមកវិញ ហើយលំអោនខ្លួនគោរពទាំងបែកញើសជោកខ្នង និងមុខ :

- ខ្ញុំសូមអភ័យទោសដែលមកទីនេះដោយគ្មានការអញ្ជើញ ។ ខ្ញុំ....ខ្ញុំ..... កំពុងមមើមមាយទាំងថ្ងៃ ។ ខ្ញុំកំពុងរំលឹកពីវាសនារបស់ខ្ញុំដែលបានឃើញរឿងរ៉ាវជាច្រើននៅក្នុងប្រទេសជប៉ុននេះ ។ មួយជីវិតរបស់ខ្ញុំ ហាក់ដូចជានៅទីនេះតែម្តង គឺគ្មានកន្លែងណាទៀតទេ ។

- នេះគឺជាសំនាងរបស់ពួកយើងទេ *ណូគូ-សាន* !

*តូរ៉ាណាកា* ដើរចូលមកក្នុងបន្ទប់ដោយអាការៈប៉ក់ស្ងើយ ។ មកដល់ក្តារកំនល់លោកអង្គុយនៅលើម៉ក់សាមញ្ញមួយ ។ ពួកអង្គរក្សរៀបចំខ្លួនអង្គុយជារបាំងការពារយ៉ាងស្ងៀមស្ងាត់ ។

- លោកមកដល់ គឺនៅឆ្នាំ*គិនសូ* ទីបីមែនទេ ?

- អត់ទេលោកម្ចាស់ គឺឆ្នាំទីបួន គឺឆ្នាំជូតទាន ។

*អាលវីតូ* តបដោយប្រើឈ្មោះឆ្នាំតាមជប៉ុន ដែលលោកត្រូវចំនាយពេលរាប់ខែដើម្បីស្វែងយល់បាន ។ ឆ្នាំទាំងអស់ត្រូវបានរាប់តាមឆ្នាំណាមួយ ជាពិសេសដែលព្រះចៅអធិរាជបាន



www.budinst.gov.kh www.elibraryofcambodia.org

ជ្រើសរើស ។ មហន្តរាយមួយ រឺលោកអ្វីមួយអាចបញ្ចប់យុគមួយ រឺចាប់ផ្តើមយុគថ្មីមួយទៅតាមព្រះទ័យព្រះចៅ ។ ហោរាត្រូវបានបញ្ជាអោយជ្រើសរើសឈ្មោះប្រផ្នូលល្អណាមួយនៅក្នុងក្បួនគម្ពីរចិនដើម្បីចាប់ផ្តើមយុគថ្មីមួយ ដែលអាចមានរយៈពេលតែមួយឆ្នាំរឺហាសិបឆ្នាំ។ *ភិនសូ* មានន័យថា "ទេវគុណធម៌"។ កាលមុនឆ្នាំនោះ គឺមានរលកសមុទ្រយ៉ាងធំបានបក់បោកមកលើនគរធ្វើអោយមនុស្សជាងពីរសែននាក់ត្រូវបាត់បង់ជីវិត។ឆ្នាំនិមួយៗត្រូវបានអោយឈ្មោះ និងអោយលេខដូចជាម៉ោងពេលប្រចាំថ្ងៃដែរ ជូត, ឆ្លូវ,ខាល,ថោះ .......។ ឆ្នាំទីមួយនៃសម័យ *ភិនសូ* គឺជាឆ្នាំរកា ហើយឆ្នាំ ១៥៧៦ ដែលជាឆ្នាំទីបួន ត្រូវគ្នានឹងឆ្នាំជូត ។

- គិតទៅក្នុងម្តេបួនឆ្នាំនេះ មានរឿងរ៉ាវច្រើនណាស់មែនទេ ?

- ពិតមែនហើយទាន ។

- ពិតមែន ។ ការឡើងរបស់ *ក្លូវ៉ា* និងមរណភាពរបស់គាត់ ។ ការឡើងរបស់តៃកូនិងមរណភាពរបស់គាត់ ។ រួចចុះអ៊ីលូវ ?

សំលេងរបស់ *កូរ៉ាណាកា* បោកផ្ទប់នឹងជញ្ជាំងលាន់ខ្ទរ ។

- នេះគឺវាសនាលោកជាអ្នកកំនត់ ។

ពាក្យ " វាសនា "របស់ *អាល់វីតូ* អាចបកស្រាយជាព្រះយេស៊ូក៏បាន ជាព្រះពុទ្ធក៏បាន។

-ទាំងលោកម្ចាស់ *ក្លូវ៉ា* ទាំងលោកម្ចាស់ *តៃកូ* មិនដែលជឿព្រះយេស៊ូ រឺវាសនាអ្វីទេ។

- ក្រែងព្រះពុទ្ធបានថែងហើយទេតើ ថាផ្លូវទៅនិព្វានមានច្រើនបែប ។

- ហ៊ឺ ! *ល្វូតូ-សាន* លោកចំជាមនុស្សវាងវៃមែន។ ហេតុអីបានជាមនុស្សនៅក្មេងដូចលោកវាងវៃម្ល៉េះ ?

- ខ្ញុំសូមអោយពិតមែនទៅចុះទាន។ បើយ៉ាងនេះមែនខ្ញុំអាចនឹងជួយបានការងារច្រើនជាមិនខាន ។

- លោកចង់ជួបខ្ញុំអ្វី ?

- បាទ។ ខ្ញុំគិតថា រឿងនេះមានសារសំខាន់គួរសមដែរ ទើបខ្ញុំមកដោយគ្មានការអញ្ជើញនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

*អាល់វីតូ* ហូតយកកូនសៀវភៅរបស់*ប្លាក់ថន* ចេញមក ហើយដាក់លើកំរាលនៅពីមុខរបស់ខ្លួន ។ រួចលោកពន្យល់*តូរ៉ាណាកា* ទៅតាមសំដីដែលគណៈអធិការសង្ឃ *វ៉ៃឡាក្វា* បានប្រាប់។ លោកឃើញទឹកមុខរបស់ *តូរ៉ាណាកា* ប្រែទៅជាមាំហើយប្រការនេះធ្វើអោយលោករីករាយនៅក្នុងចិត្តយ៉ាងខ្លាំង ។

- គឺជាភស្តុតាងនូវអំពើចោរសមុទ្ររបស់វ៉ាវី ?

- ពិតមែនហើយទាន ។ កូនសៀវភៅមានទាំងបញ្ជាពិតប្រាកដរបស់ពួកវ៉ាផង ក្នុងនោះមានទាំងឃ្លានិយាយថា " បើសិនចាំបាច់ត្រូវឡើងគោកដោយប្រើកំលាំងបាយ ហើយកាន់កាប់យកទឹកដីទាំងអស់ដែលទៅដល់ វីបានរកឃើញ " ថែមទៀតផង ។ បើសិនជាលោកចង់ ខ្ញុំអាចបកប្រែឃ្លាសំខាន់ៗជូនបានទាន ។

*តូរ៉ាណាកា* តប :

- បកទាំងអស់តែម្តងទៅ ។ បកអោយឆាប់ ។

- នៅមានរឿងមួយទៀតដែលគណៈអធិកាសង្ឃចង់ជំរាបលោកអោយបានជ្រាប ។

រួចបព្វជិត *អាល់វីតូ* រ៉ាយរ៉ាប់ប្រាប់*តូរ៉ាណាកា* នូវរឿងរ៉ាវទាំងអស់ស្តីពីផែនទីរបាយការណ៍និងសំពៅខ្មៅ ដូចដែលបានពិគ្រោះគ្នា ហើយលោកសែនរីករាយនៅក្នុងចិត្តនៅពេលដែលឃើញប្រតិកម្មល្អរបស់*តូរ៉ាណាកា* ។

- ល្អណាស់។ លោកច្បាស់ថា សំពៅខ្មៅពិតជាឆាប់មកដល់ជាងរាល់ឆ្នាំមែនអ្វី ? ច្បាស់ប្រាកដមែនណា ?

- ពិតណាស់ទាន ។

*អាល់វីតូ* ឆ្លើយតបយ៉ាងជឿជាក់នៅក្នុងចិត្ត។ ឱព្រះជាម្ចាស់អើយសូមអោយរឿងរ៉ាវអ្វីៗកើតឡើងតាមបំនងប្រាថ្នាទៅចុះ ។

- ល្អ ! សូមជំរាបទៅគណៈរបស់លោកផងថាខ្ញុំសង្ឃឹមថា នឹងបានអានរបាយការណ៍ក្នុងពេលឆាប់ៗនេះជាមិនខាន។ មែនណា ? តាមខ្ញុំស្មានមើលទៅប្រហែលជាត្រូវរង់ចាំរាប់ខែដែរ ទំរាំគណៈរបស់លោកបានពតិមានច្បាស់លាស់មែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

-គណៈរបស់ខ្ញុំបាននិយាយថា គាត់នឹងរៀបចំរបាយការណ៍អោយបានឆាប់បំផុត យើងខ្ញុំនឹងបញ្ជូនផែនទីតាមតំរូវការរបស់លោក ។ តើលោកម្ចាស់អាចអោយលោកមេបញ្ជាការបានលិខិតអនុញ្ញាតចេញពីផែបានរហ័សទេទាន ។

- លោកសន្យាថា សំពៅនឹងមកឆាប់ជាងសព្វដងមែនរឺ ?

- គ្មានមនុស្សណាម្នាក់អាចធានារឿងខ្យល់ រឿងព្យុះ និងរឿងសមុទ្របានទេទាន ។ ប៉ុន្តែសំពៅនឹងចេញពីម៉ាកាវឆាប់ជាងសព្វឆ្នាំ ។

- លោកនឹងបានលិខិតចេញផែមុនពេលថ្ងៃលិចនេះ ។ តើនៅមានបញ្ហាអីទៀតទេ ? ព្រោះចាប់ពីពេលនេះទៅខ្ញុំនឹងជាប់រវល់ ប្រហែលបីថ្ងៃទាល់តែក្រុមប្រឹក្សាអាជ្ញាអនុសិទ្ធិបិទប្រជុំឯណោះ ។

- គ្មានអីទៀតទេទាន ។ សូមអរគុណលោកម្ចាស់ ។ ខ្ញុំសូមបួងសួងសូមលោកបានសុខសប្បាយជារៀងរហូតទាន ។

រួច *អាលវីតូ* លំអោនខ្លួនគោរព ហើយរង់ចាំ *តូរ៉ាណាកា* អោយសញ្ញាលោកលាចេញមកវិញ ។ *តូរ៉ាណាកា* បែរធ្វើសញ្ញាអោយអង្គរក្សរបស់លោកថយចេញទៅវិញ ។

នេះគឺជាលើកទីមួយហើយ ដែលអាលវីតូឃើញ *វ៉ែមីញ៉ូ* គ្មានអង្គរក្សនោះ ។

*តូរ៉ាណាកា* ទះកន្ទែងមួយនៅក្បែរខ្លួនលើក្តារកំទល់ ដោយពោលឡើង :

- អញ្ជើញលោកមកអង្គុយកន្លែងនេះមក *ឈូតូ-សាន* !

*អាលវីតូ* មិនដែលបានអង្គុយលើក្តារកំទល់ម្តងណាឡើយទេ។ តើនេះជាសញ្ញានៃទំនុកចិត្ត រឺជាការកាត់ទោស ?

*តូរ៉ាណាកា* និយាយ :

- សង្គ្រាមផ្ទុះឡើងហើយ ។

- ពិតមែនហើយទាន ។

*អាលវីតូ* ទទឹមនោះលោកគិតនៅក្នុងចិត្តថាសង្គ្រាមនឹងមិនមានថ្ងៃណាបញ្ចប់ទេ ។

- អ្វីដែលគួរអោយឆ្ងល់ គឺពួកគ្រិស្តសាសនិក *អូណូស៊ី និងគីយ៉ាម៉ា* បែរមកប្រឆាំងនឹង



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំទៅវិញ ។

- ខ្ញុំមិនអាចឆ្លើយជំនួស *វ៉ៃមីញ៉ូ* ណាមួយបានទេទាន ។

- មានរឿងចចេចចចូចច្រើនណាស់ លោកមានដឹងទេ ? ពីរឿងអ្នកពីរនាក់នេះ និងពីរឿងពួក *វ៉ៃមីញ៉ូ* គ្រិស្តសាសនិកឯទៀត១ផង ។

- មនុស្សវាងវៃរមែងទុកផលប្រយោជន៍នគរជាចំបងទាន ។

- ពិតហើយ ។ ប៉ុន្តែចង់រឺមិនចង់ អីលូវនេះនគរត្រូវបែងចែកជាពីរហើយ ។ គឺផ្នែកខាងខ្ញុំ និងខាង *អ៊ីស៊ីដូ*។ ដោយហេតុនេះផលប្រយោជន៍ចក្រភពទាំងមូលត្រូវនៅខាងខ្ញុំរឺខាង *អ៊ីស៊ីដូ* ។ គ្មានផ្លូវកណ្តាលទេ ។ តើផលប្រយោជន៍របស់ពួកគ្រិស្តសាសនិកនៅខាងណា ?

- នៅខាងសន្តិភាពទាន ។ គ្រិស្តសាសនា មិនមែនមនោគមន៍នយោបាយទេទាន ។

-គណៈសង្ឃរបស់លោក គឺជាប្រធានព្រះវិហារទាំងអស់នៅទីនេះ ។ខ្ញុំលឺលោកនិយាយអីចឹង ហេតុនេះលោកអាចនិយាយក្នុងនាមគណៈសង្ឃលោកបានហើយ ។

- ពួកយើងត្រូវហាមឃាត់មិនអោយលូកដៃចូលក្នុងនយោបាយរបស់ស្រុកលោកទេ ។

សំលេង *តូរ៉ាណាកា* កាន់តែតឹងឡើង :

- តើលោកស្មានថា *អ៊ីស៊ីដូ* នឹងអនុគ្រោះដល់ពួកលោកអ្វី ? វាប្រឆាំងដាច់ខាតនឹងសាសនារបស់លោក ។ ខ្ញុំតែងតែអនុគ្រោះដល់ពួកលោកជានិច្ច ។ *អ៊ីស៊ីដូ* វាចង់តែអនុវត្តបញ្ញត្តិបណ្តេញរបស់ *វ៉ៃកូ* ហើយបិទទ្វារនគរ លែងអោយពួកចុងស្រុកណាម្នាក់ចូលបានទៀត ។ ឯខ្ញុំវិញ ខ្ញុំចង់បើកទូលាយពាណិជ្ជកម្មវិញទេ ។

- យើងខ្ញុំមិនត្រួតត្រាលើ *វ៉ៃមីញ៉ូ* គ្រិស្តសាសនិកណាមួយទេទាន ។

- បើអីចឹង តើខ្ញុំត្រូវធ្វើយ៉ាងម៉េចដើម្បីមានឥទ្ធិពលទៅលើពួកទាំងនោះបាន ?

- ខ្ញុំគ្មានការយល់ដឹងបានជ្រៅជ្រះល្អមនឹងជូនមតិទៅលោកបានទេ ។

- ខ្ញុំដឹងថា សំលាញ់ឯងមានការយល់ដឹងល្អមនឹងយល់ថា បើសិនជា *គីយ៉ាម៉ា* និង *អូណូស៊ី* ចូលដៃជាមួយ *អ៊ីស៊ីដូ* ហើយនិងវ៉ៃងវាដើម្បីប្រឆាំងនឹងខ្ញុំនោះ ពួក *វ៉ៃមីញ៉ូ* គ្រិស្តសាសនិកទាំងអស់នឹងដើរតាមពួកវាភ្លាម ។ ដល់ពេលនោះបើមានម្នាក់គាំទ្រខ្ញុំ *អ៊ីស៊ីដូ* នឹងមានម្ភៃនាក់គាំ



www.budinst.gov.kh www.elibraryofcambodia.org

ទ្រវាជាមិនខាន ។

- បើសិនជាសង្គ្រាមផ្ទុះឡើងមែន ខ្ញុំសូមបួងសួងសុំអោយលោកបានឈ្នះលើសត្រូវរបស់លោក ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

- បើតៃម្លៃ ខ្ញុំមួយនោះ អ្វីដែលខ្ញុំត្រូវការ គឺលើសពីការបន់ស្រន់នេះទៅទៀត ។

- តើគ្មានផ្លូវណាបញ្ចៀសសង្គ្រាមបានទេអ្វី ? តែពេលណាផ្ទុះសង្គ្រាមហើយគឺវាមិនងាយចប់ទេ ។

- ខ្ញុំក៏ជឿយ៉ាងនេះដែរ ។ នៅពេលនោះអ្នកចាញ់គឺទាំងអស់គ្នា ទាំងពួកយើង ទាំងពួកចុងស្រុកទាំងព្រះវិហារ ។ប៉ុន្តែបើនៅពេលនេះពួក *វៃមីញ៉ូ* គ្រិស្តសាសនិកនៅខាងខ្ញុំជាចំហនោះនឹងគ្មានសង្គ្រាមឡើយ ។ មហិច្ឆតា របស់ *អ៊ីស៊ីដូ* ពិតជានឹងត្រូវបង្ក្រាបបានជារៀងរហូត ។ ទោះជា *អ៊ីស៊ីដូ* ចង់តថ្លៃ រឺហ៊ានបះបោរ ក៏ក្រុមប្រឹក្សាអាជ្ញាអនុសិទ្ធិ អាចធ្វើបវាបានយ៉ាងងាយ ។

*អាលវីតូ* មានអារម្មណ៍ថា ខ្សែអន្ទាក់កំពុងតែរឹតបំពង់ករបស់ខ្លួនបន្តិចម្តង១ហើយ ។

- ពួកយើងមកទីនេះ គឺមកផ្សព្វផ្សាយធម៌តែប៉ុណ្ណោះ មិនមែនមកលូកលាន់ក្នុងរឿងនយោបាយ របស់លោកទេទាន ។

-គណៈសង្ឃលោកមុនបានផ្តល់ការគាំទ្ររបស់ពួក *វៃមីញ៉ូ* គ្រិស្តសាសនិកនៅ *គូស៊ូ* ដល់អម្ចាស់ *រ៉ាកូ* នៅមុនដែលយើងប្រាមប្រាបតំបន់នោះបាន ។

-នោះគឺជាការខុសឆ្គងមួយហើយ ដែលលោកធ្វើអ៊ីចឹង ។ លោកគ្មានការអនុញ្ញាតពីព្រះវិហារ រឺពី *វៃមីញ៉ូ* ណាអោយធ្វើអ៊ីចឹងទេទាន ។

- កាលណោះគណៈសង្ឃបានអោយសំពៅប៉ុកទុយកាល់ជួយ *រ៉ាកូ* ដឹកជញ្ជូនទ័ពទៅ *គូស៊ូ* ព្រមទាំងផ្តល់ទ័ពប៉ុកទុយកាល់និងកាំភ្លើងថែមទៀតផង ។ លោកនៅថែមទាំងជួយយើងនៅពេលច្បាំងជាមួយចិន និងកូរ៉េថែមទៀត ។

- នេះក៏អ៊ីចឹងដែរទាន លោកធ្វើនេះគឺគ្មានការអនុញ្ញាតពីព្រះវិហារទេ ។

- បន្តិចទៀតអ្នកណាក៏ត្រូវជ្រើសរើសខាងណាមួយដែរ *ឈូតូ-សាន* ។ ក្នុងពេលបន្តិចទៀត យ៉ាងខ្លីខាងមុខនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

*អាល់វីតូ* បាក់ស្បៀវរឹងខ្លួននឹងពាក្យគំរាមនេះ ។

- ខ្ញុំតែងរង់ចាំបំរើលោកជានិច្ចទាន ។

- បើសិនជាខ្ញុំចាញ់ តើលោកស្លាប់ជាមួយខ្ញុំទេ ? តើលោកនឹងធ្វើ*ស៊ិនស៊ី* ទេ ? តើលោកព្រមតាមខ្ញុំរហូតដល់មរណភាពទេ ?

- ជីវិតរបស់ខ្ញុំ គឺព្រះជាអ្នកកំនត់ ឯការស្លាប់វិញក៏អ៊ីចឹងដែរ ។

- ឱ មែន ! ព្រះគ្រិស្តរបស់លោក !

*តូរ៉ាណាកា* បង្វិលដាវរបស់លោកបន្តិច រួចបន្តទៀត :

- បើ *អូណូស៊ី* និង *គីយ៉ាម៉ា* មកខាងខ្ញុំ ក្នុងសែសិបថ្ងៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនឹងលុបអាជ្ញារបស់ *វែកូ* ស្តីពីការបណ្តេញពួកបរទេសភ្លាម ។

តើអញអាចបោះជំហានដល់ត្រឹមណា ? *អាល់វីតូ* ដណ្តឹងសួរនៅក្នុងចិត្តទាំងអស់សង្ឃឹម ។ ដល់ត្រឹមណាទៅ ?

- ពួកយើងខ្ញុំមិនអាចមានឥទ្ធិពលទៅលើអ្នកទាំងនោះ ដូចលោកស្មាននោះទេ ។

- ប៉ុន្តែគណៈសង្ឃរបស់លោកអាចបញ្ជាពួកនោះបាន ។ បញ្ជាពួកនោះទៅ ! *អ៊ីស៊ីដូ* នឹងក្បត់ពួកលោក ហើយនិងពួកអស់នោះផងដែរ ។ ខ្ញុំស្គាល់ *អ៊ីស៊ីដូ* ច្បាស់ណាស់ ។ ជំទាវ *អូជីបា* ក៏តែអ៊ីចឹង ។ មិនគឺជំទាវណើងទេអ្ហី ដែលញុះញង់ទាយាទអោយប្រឆាំងនឹងពួកលោកនោះ?

ពិតហើយ *អាល់វីតូ* ស្រែកនៅក្នុងចិត្ត ។ ប៉ុន្តែ *អូណូស៊ី* និង *គីយ៉ាម៉ា* បានទទួលជាសំងាត់នូវលិខិតសន្យាសរសេរដោយដៃ *អ៊ីស៊ីដូ* ផ្ទាល់ថា យល់ព្រមអោយពួកគេនេះជាអ្នកជ្រើសរើសគ្រូបាធ្យាយរបស់ *យែនម៉ុន* ក្នុងចំនោមនោះយ៉ាងតិចក៏មានគ្រូជាគ្រិស្តសាសនិកម្នាក់ផងដែរ ។ ហើយទាំង *អូណូស៊ី* ទាំង *គីយ៉ាម៉ា* សុទ្ធតែជឿថា អ្ហែងក៏នឹងក្បត់ព្រះវិហារដែរនៅពេលណាដែលអ្ហែងចាត់ការ *អ៊ីស៊ីដូ* រួច ។

- ព្រះតេជគុណគណៈអធិការសង្ឃមិនអាចបញ្ជាពួកនោះបានទេទាន ។ ធ្វើយ៉ាងនេះគឺពិតជាការលូកដៃចូលយ៉ាងធ្ងន់ធ្ងរទៅក្នុងរឿងនយោបាយរបស់នគរនេះហើយ ។

- *អូណូស៊ី* និង *គីយ៉ាម៉ា* ទៅខាងខ្ញុំ ក្នុងសែសិបថ្ងៃ អាជ្ញា *វែកូ* នឹងត្រូវលុបចោលភ្លាម ។



www.budinst.gov.kh www.elibraryofcambodia.org

ហើយក៏គ្មានសង្ឃចំកួតណាមករញ៉េរញ៉ៃទៀតទេ ។ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនឹងហាមឃាត់ពួកនោះមិនអោយចូលស្រុកនេះទេ ។

- លោកមានប្រសាសន៍ថាម៉េច ?

-គឺមានតែលោកនិងក្រុមលោកតែមួយគត់ ដែលអាចធ្វើសកម្មភាព ក្នុងនគរនេះបាន ។ គ្មាននិកាយផ្សេងទៀតទេ ។ គ្មានពួកស្បង់ខ្មៅសំអុយទេ ។ លោកចង់កាត់ក្បាលពួកវាក៏តែបានដែរអោយតែលោកចង់ ។

អាគ្គីន *អាល់វីតូ* ទាំងមូល ស្រែកអោយមានស្មារតីប្រុងប្រយ័ត្ន ។ *តូរ៉ាណាកា* មិនដែលនិយាយចេញអស់ដូចថ្ងៃនេះទេ ។ ដើរខុសមួយជំហានអ្នែងអាចប៉ះពាល់គាត់ ហើយ *តូរ៉ាណាកា* នឹងក្លាយជាសត្រូវព្រះវិហារជារៀងរហូត ។

ត្រូវគិតពីសំនើរបស់ *តូរ៉ាណាកា* វិញ ! មានសិទ្ធិផ្សាយតែសាសនាយើងមួយគត់នៅទូទាំងចក្រភពជាប្រការមួយយ៉ាងល្អបំផុត ដើម្បីធានាសុខភាពនៃព្រះវិហារ ហើយនិងសន្តិសុខព្រះវិហារក្នុងដំណាក់កាលរីកចំរើនលូតលាស់នេះ ។ ជាប្រការមួយដែលកាត់ថ្លៃមិនបាន ។ ជាប្រការមួយដែលគ្មានអ្នកណាអាចផ្តល់អោយបាន ទោះជាប៉ាបក៏ដោយ លើកលែងតែ *តូរ៉ាណាកា* ម្នាក់គត់ ។ បើសិនជា *គីយ៉ាម៉ា* និង *អូណូស៊ី* គាំទ្រ *តូរ៉ាណាកា* ជាចំហ *តូរ៉ាណាកា* អាចកំទេច *អ៊ីស៊ីដូ* ហើយក្តាប់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិយ៉ាងងាយ ។

គ្មានពេលណា ដែលបព្វជិត *អាល់វីតូ* នឹកថា *តូរ៉ាណាកា* ត្រង់ៗ យ៉ាងនេះទេ ។ ហើយក៏មិននឹកគិតថា *តូរ៉ាណាកា* យល់ព្រមលើរឿងយ៉ាងច្រើនបែបនេះសោះ ។ តើ *អូណូស៊ី* និង *គីយ៉ាម៉ា* អាចប្រែប្រួលគំនិតវិញបានទេ ? ពីរនាក់នេះស្អប់គ្នាណាស់ ។ គឺដោយមានហេតុដែលមានតែពីរនាក់ដឹងតែប៉ុណ្ណោះ ដែលពួកគេរួមគ្នាប្រឆាំង *តូរ៉ាណាកា* ។ តើមកពីហេតុអ្វីទៅ ? ហើយតើមានអ្វីដែលអាចអោយពួកនេះក្បត់ *អ៊ីស៊ីដូ* បាន ?

- ខ្ញុំមិនមានសមត្ថភាពអីនឹងឆ្លើយជូនលោក រឺក៏និយាយពីរឿងនេះទេទាន ។ ការងាររបស់យើងខ្ញុំ គឺដើម្បីសង្គ្រោះព្រលឹងមនុស្សតែប៉ុណ្ណោះ ។

- ខ្ញុំលឺថា កូនប្រុសខ្ញុំឈ្មោះ *ណាកា* មានបំនងចូលសាសនាលោកមែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

តើ*តូរ៉ាណាកា* និយាយគំរាមកំហែង រឺក៏ចង់បញ្ចូនកូនមែន ? *អាលវីតូ* ដណ្ដឹងសួរខ្លួនឯង ។ តើ*តូរ៉ាណាកា* ចង់អោយកូនចូលសាសនាមែនអ្វី ? បើមែនចំជាអស្ចារ្យណាស់ ។ តែរឺមួយ*តូរ៉ាណាកា* ចង់និយាយថា " បើលោកឯងមិនព្រមសហការទេ ខ្ញុំនឹងប្រាប់វាអោយឈប់មានទំនាក់ទំនងនឹងសាសនាលោកឯងទៀត " វិញទេ ?

*អាលវីតូ* និយាយតបវិញ :

- កូនប្រុសរបស់លោកមានទស្សនៈទូលំទូលាយខាងផ្នែកសាសនាណាស់ទាន ។

នៅពេលនេះទើប*អាលវីតូ* មើលឃើញស្ថានភាពទំនាស់ ដែល*តូរ៉ាណាកា* ត្រូវប្រឈមមុខ ។ អាគាត់នេះជាប់ជុចហើយ ។ អីចឹងហើយបានជាវាមកចរចាជាមួយពួកយើង *អាលវីតូ* គិតយ៉ាងរីករាយនៅក្នុងចិត្ត ។ វាត្រូវតែប្រឹងទ្រោលហើយ ! ទោះជាយើងតំរូវអីក៏វាត្រូវតែយល់ព្រមដែរ នេះបើសិនណាជាយើងចង់ចរចាជាមួយវា ។ អីលូវនេះទើបវាត្រូវទទួលស្គាល់ថា ពួកដៃមីញ៉ូគ្រិស្តសាសនិកមានតួនាទី អាចធ្វើអោយជញ្ជីងបះទៅខាងណាក៏បានដែរ ។ អីលូវនេះយើងចង់ទារអីក៏បានដែរ ! តើពួកយើងចង់បានអីលើសពីនេះទៀត ? លើកលែងតែ...

ដោយចេតនា បព្វជិត*អាលវីតូ* ចោលភ្នែកទៅសំលឹងមើលកូនសៀវភៅដែលលោកបានដាក់នៅចំពោះមុខ*តូរ៉ាណាកា* ។ លោកសំលឹងមើលដៃរបស់ *តូរ៉ាណាកា* ដែលលូកយកកូនសៀវភៅទុកយ៉ាងស្រួលនៅក្នុងថង់ដៃអាវគីម៉ូណូរបស់លោក ។ រួច*តូរ៉ាណាកា* ក៏បន្លឺឡើងក្នុងសំលេងមួយយ៉ាងប្លែក និងយ៉ាងឡើយហត់ :

- អូមែន ! *ឈូតូ-សាន* ។ នៅមានអ្នកចុងស្រុកថ្មីទៀត គឺចោរសមុទ្រនោះ ។ វាជាសត្រូវនៃប្រទេសរបស់លោក ។ បន្តិចទៀតក្រុមពួកវាមកដល់ទីនេះក្នុងចំនួនយ៉ាងច្រើនមែនទេ ? យើងអាចលើកទឹកចិត្តអោយពួកនេះមក រឺធ្វើមិនអោយពួកវាមកជាន់ទីនេះបាន ។ ដូចចោរសមុទ្រម្នាក់នេះអីចឹង ។

អីលូវនេះបព្វជិត *អាលវីតូ* ដឹងថា លោកទទួលសព្វគ្រប់ហើយ ។ តើអញគួរសុំអោយគេកាត់ក្បាលអា*ប្លាក់ថន* ដាក់ថាសប្រាក់មកជូនអញ ដើម្បីប្រថាប់កិច្ចព្រមព្រៀងនេះ ដូចកាលកាត់ក្បាលសន្តិជន*ឡឺបាបទិស* ទេ ?



www.budinst.gov.kh www.elibraryofcambodia.org

តើអញគួរសុំកសាងវិហារធំមួយនៅយេដូ រឺក៏សង់មួយនៅក្នុងកំពែងវិមាន អូសាកានេះវិញ ? ជាលើកទីមួយ ដែលបព្វជិត *អាលវីតូ* មានអារម្មណ៍ដូចជានាវាដែលជាច់ចង្អូតនៅក្នុងលំហនៃអំនាច ។

អ្វីដែលបានស្នើមកនេះ គឺគ្រប់គ្រាន់ណាស់ទៅហើយ ! យើងមិនត្រូវការអ្វីទៀតទេ។ ឱ បើសិនជាអញជាអ្នកទទួលចរចារឿងនេះវិញណ៎ ! បើក្នុងរឿងនេះអញមានសិទ្ធិសំរេចតែម្នាក់អញនេះ អញច្បាស់ជាប្រថុយមួយចានហើយ ។ បើ *អូណូស៊ី* និង *គីយ៉ាម៉ា* មិនឯកភាពតាមអញបណ្តេញវាក្រៅសាសនាភ្លាម ព្រោះនេះដើម្បីព្រះវិហារទាំងមូល ។ ព្រលឹងពីរដូរនឹងព្រលឹងរាប់ម៉ឺន រាប់សែន រាប់លាននាក់ ។ បើសិនជារូបអញមែន អញយល់ថាល្មមលេងគ្នាបាន ។ តែអញមិនអាចសំរេចរឿងអ្វីបានទាំងអស់ ហើយលោកឯងក៏បានដឹងហើយ ។ អញគ្រាន់តែជាអ្នកនាំសារ ហើយមួយភាគនៃសាររបស់អញនេះ ..

- ខ្ញុំត្រូវការជំនួយណា *ឈូតូ-សាន* ! ត្រូវការនៅពេលនេះតែម្តង !

- អ្វីដែលខ្ញុំអាចធ្វើបាន ខ្ញុំនឹងធ្វើ *តូរ៉ាណាកា-សាម៉ា* ។ ខ្ញុំសូមសន្យានឹងលោក ។

*តូរ៉ាណាកា* និយាយបញ្ចប់ :

-ខ្ញុំនឹងរង់ចាំសែសិបថ្ងៃអីចឹង ។ មែនហើយ ! សែសិបថ្ងៃ !

*អាលវីតូ* លំអោនខ្លួនគោរព ។ លោកកត់សំគាល់ឃើញថា *តូរ៉ាណាកា* បានគោរពតបវិញទាបជាងរាល់សព្វដង ហើយថែមទាំងជារបៀបផ្លូវការទៀតផង គឺប្រហែលនឹងពេលដែលលោកគោរព *រ៉ែគូ* អីចឹងដែរ ។ បព្វជិត *អាលវីតូ* ក្រោកឡើងទាំងញ័រចំប្រប់រួចក៏ដើរចេញទៅតាមរបៀងនៅខាងក្រៅ ។ ជំហានរបស់លោកកាន់តែញាប់ឡើង ១ ។

ពេលដែលបព្វជិត *អាលវីតូ* ដើរកាត់សួនច្បារដែលនៅទីក្រោមនោះ *តូរ៉ាណាកា* តាមសំលឹងមើលលោកដោយឥតដាក់ភ្នែកឡើយ ។ ទ្វារបន្ទប់របើកឡើង ប៉ុន្តែតូរ៉ាណាកាដេញអង្គរក្សរបស់លោក ដោយទុកអោយលោកនៅតែម្នាក់ឯង ហើយអ្នកណាហ៊ានល្មើសបញ្ជានឹងត្រូវប្រហារជីវិត ។ ភ្នែករបស់ *តូរ៉ាណាកា* នៅតែតាមសំលឹងជាប់បព្វជិត *អាលវីតូ* ដែលឆ្លងកាត់ទ្វារដែកទីលានធំ រហូតដល់រូបលោកបាំងបាត់នឹងកំផែងខ្ពាត់ខ្វែងនៅក្នុងវិមានទៅ ។

រួចនៅក្នុងសភាពស្ងៀមស្ងាត់តែម្នាក់ឯងនេះ *តូរ៉ាណាកា* ចាប់ផ្តើមញញឹមឡើង ។ បន្ទាប់មកលោកលើកដាយគីម៉ូណូរបស់លោកឡើង ហើយចាប់ផ្តើមរាំ ។ នោះគឺក្បាច់រាំ *ហានផែប* ។



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ២១

ក្រោយពេលព្រលប់បន្តិច *គីរី* ចុះដណ្ដើរទាំងកន្ទះរា ដោយមាននារីអ្នកបំរើពីរនាក់អមជាមួយផង ។ លោកជំទាវដើរតំរង់ស្ពែងបាំងវាំងននមួយដែលនៅក្បែរខ្លមសួនច្បារ ។ អាវក្រៅដ៏ធំស៊ុលឃុលមួយត្រូវបានលោកជំទាវពាក់ពីលើអាវគីម៉ូណូ ធ្វើដំណើរ ធ្វើអោយរូបរាងលោកជំទាវកាន់តែបានមាឌុថែមទៀត ។ លោកជំទាវនៅបានពាក់មួកហាមធំមួយ ហើយដែលលោកជំទាវបានព័ទ្ធខ្សែចងជាប់នៅនឹងចង្កា ។

នៅឯរានហាល ជំទាវ*សាស៊ូកូ* បាននៅឈររង់ចាំជូនដំណើរជំទាវ *គីរី* យ៉ាងអត់ធ្មត់ជាមួយនឹង *មារីកូ* ។ *ប្លាក់ថន* នៅឈរផ្អែកនឹងជញ្ជាំងកំផែងក្បែរទ្វារពាសដែក ។ គេពាក់គីម៉ូណូរបស់ពួកអាវប្រផេះ និងស្បែកជើងទ័ព ។ ផុតពីទ្វារពាសដែកពួកសាមូរ៉ៃជាគងការពារចំនួនហុកសិបនាក់បានឈរជាជួរយ៉ាងល្អស្អាតហើយស្រេចនៅលើទីធ្លា ។ ពួកទាំងនោះប្រដាប់ដោយអាវុធយ៉ាងសំបូរបែប ហើយក្នុងមនុស្សបីនាក់មានម្នាក់កាន់ចន្លុះ ។ នៅនឹងមុខគេ *យ៉ាប៊ូ* កំពុងឈរជជែកគ្នាជាមួយនឹង *ប៊ុនតារ៉ូ* ដែលជាប្ដីរបស់ *មារីកូ* ។ *ប៊ុនតារ៉ូ* ជាមនុស្សទាបកន្ទាល់ ហើយមានកខ្លីកញ្ជ្រឹប ។ អ្នកទាំងពីរសុទ្ធតែពាក់អាវក្រោះ និងមានស្ពាយបំពង់ព្រួញនៅនឹងស្មា ។ *ប៊ុនតារ៉ូ* ពាក់មួកដែកសំរាប់ធ្វើសឹក ហើយដែលមានបណ្ដុះស្លែងផង ។ អ្នកស្លែង និងអ្នកលីសែងរបស់របរនៅអង្គុយចោងហោងយ៉ាងអត់ធ្មត់ និងយ៉ាងមានវិន័យនៅក្បែរអីវ៉ៃអីវ៉ាន់មួយគំនរ ។

គន្ធពិដោរនៃរដូវផ្ការីក បានរសាត់អណ្ដែតមកតាមជំនោរខ្យល់ ប៉ុន្តែគ្មាននរណាម្នាក់ចាប់ភ្លឹកពីចំនុចនេះឡើយ លើកលែងតែ*ប្លាក់ថន* ចេញ ។ ហើយទោះជាយ៉ាងនេះក្ដី ក៏*ប្លាក់ថន*នៅតែមានអារម្មណ៍ដឹងបានពីបរិយាកាសតឹងតែង ដែលនៅហ៊ុមព័ទ្ធពួកគេទាំងអស់គ្នានេះដដែល ។ ម្យ៉ាងទៀតគេក៏មានអារម្មណ៍ផងដែរថា ក្នុងចំនោមមនុស្សទាំងអស់នេះ គេជាមនុស្សតែម្នាក់គត់ដែលគ្មានអាវុធនឹងគេ ។

*គីរី* ទ្រោបទៅលើរានហាល ហើយនិយាយឡើង :

- នាងមិនគួរនៅរង់ចាំកន្លែងត្រជាក់យ៉ាងណឹងទេ *សាស៊ូកូ-សាន* ។ នាងនឹងផ្ដាសាយមិនខាន ! អីលូវនេះនាងត្រូវគិតគូរពីរឿងកូនហើយ ។ យប់រដូវនេះនៅសើមនៅឡើយទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំមិនត្រជាក់ទេ*គីរី-សាន* ។ យប់នេះល្អណាស់ ហើយធ្វើអោយខ្ញុំកាន់តែសប្បាយចិត្តវិញទេ ។

- អ៊ី ១ ស្រួលបួលទេអ៊ី ?

- ចាស ! អ៊ី ១ ល្អស្រួលបួលទាំងអស់ ។

- ខ្ញុំមិនចង់ចេញដំណើរទាល់តែសោះ ។ មែនណា ខ្ញុំស្អប់មែនតែម្តង ។

- គ្មានរឿងអ្វីដែលត្រូវខ្វល់ខ្វាយនោះទេ ! -*មារីកូ* និយាយយ៉ាងមានទំនុកចិត្តបណ្តើរដើរមកចូលរួមជាមួយអ្នកទាំងពីរបណ្តើរ ។ នាងពាក់មួកបាមធំដែរ គ្រាន់តែពណ៌ភ្លឺ ជាង ។ នាងពោលបន្ត :

-លោកជំទាវពិតជាសប្បាយចិត្តបានទៅយេដូវិញនេះ ។ លោកម្ចាស់របស់យើងនឹងទៅតាមយើងប៉ុន្មានថ្ងៃនេះទៀតហើយ ។

- នរណាដឹងថាថ្ងៃស្អែកទៅជាយ៉ាងម៉េច *មារីកូ-សាន* ?

- ថ្ងៃស្អែកអាស្រ័យលើព្រះជាអ្នកកំនត់ ។

*សាស៊ូកូ* និយាយបន្តឡើង :

- ថ្ងៃស្អែកគឺជាថ្ងៃល្អ ហើយបើមិនមែនជាថ្ងៃល្អទេ គឺពិតជាមិនមែនថ្ងៃល្អហើយ ។ ចាំបាច់ខ្វល់ខ្វាយពីថ្ងៃស្អែកធ្វើអ្វី ? គឺបច្ចុប្បន្ននេះហើយដែលល្អផ្តាច់គេនោះ ។ លោកជំទាវស្អាតណាស់ *គីរី-សាន* ហើយពួកយើងទាំងអស់គ្នាពិតជានឹកលោកជំទាវ ។ នឹកទាំងនាងផងដែរ *មារីកូ-សាន...*

*សាស៊ូកូ* ឈប់សិន ហើយងាកបែរទៅមើល*ប៊ុនតារ៉ូ* ដែលកំពុងស្រែកសន្ធាប់ទាំងកំហឹងដាក់សាមូរ៉ៃម្នាក់ ដែលធ្វើអោយជ្រុះចន្លុះ ។

យ៉ាប៊ូ ដែលមានថ្នាក់ខ្ពស់ជាង*ប៊ុនតារ៉ូ* នោះ ក៏មានភារៈជាអ្នកទទួលខុសត្រូវលើក្បួននេះ។ នៅពេលដែលឃើញជំទាវ*គីរី* ចុះមកដល់ *យ៉ាប៊ូ* ក៏ដើរកាត់ទ្វារប្រកបដោយអាការៈយ៉ាងហ៊ឹកហ៉ាក់ ដោយមាន*ប៊ុនតារ៉ូ* ដើរតាមជាប់ពីក្រោយផង ។ លោកជំទាវ*គីរី* ក៏លំអោនខ្លួនគោរពយ៉ាងរចល់ :



www.budinst.gov.kh www.elibraryofcambodia.org

- អូ ! លោកម្ចាស់*យ៉ាប៊ូ* ! លោកម្ចាស់*ប៊ុនតារ៉ូ* ! ខ្ញុំសូមអភ័យទោសដែលបានធ្វើអោយអស់លោកនៅរង់ចាំយ៉ាងនេះ ។ ដំបូងលោកម្ចាស់*តូរ៉ាណាកា* សំរេចចុះមកជាមួយដែរ តែទីបំផុតគាត់ក៏សំរេចថាអត់វិញ ។ គាត់ប្រាប់ថាអោយពួកយើងចេញដំណើរពេលអីលូវនេះចុះ ។ សូមលោកអភ័យទោសផងចាស ។

- បាទគ្មានបញ្ហាអ្វីទេលោកជំទាវ ។

ចំពោះ*យ៉ាប៊ូ* ចេញផុតពីវិមាន*អូសាកា* គ្រលប់ទៅ*អ៊ីស៊ូ* កាន់តែឆាប់កាលណាកាន់តែល្អពេលនោះ។ គេនៅតែស្ទើរមិនជឿថា គេអាចចេញពីទីនេះដោយមានក្បាលនៅជាប់នឹងស្មា ដោយបានអ្នកចុងស្រុក ដោយបានកាំភ្លើង និងដោយបានអ្វីសព្វគ្រប់ទាំងអស់នោះឡើយ ។ គេបានផ្ញើសារប្រញាប់តាមព្រាបនាំសារទៅដល់ប្រពន្ធរបស់គេនៅឯ*យេដូ* ដើម្បីអោយច្បាស់ថាអ្វីៗត្រូវបានរៀបចំស្រេចបាច់អស់ ហើយនៅឯមីស៊ីម៉ាទីក្រុងរបស់គេ ។ សារប្រញាប់ឯទៀតត្រូវបានបញ្ជូន ទៅអោយ*អូមី* នៅឯភូមិ*អាន់ជិរ៉ូ* ផងដែរ ។

*យ៉ាប៊ូ* និយាយបន្ត :

- លោកជំទាវរៀបចំស្រេចបាច់ហើយរឺ ?

*គីរី* មានទឹកភ្នែករលីងរលោងហើយស្រេច :

- ចាំខ្ញុំសំរួលដង្ហើមបន្តិចសិន ហើយខ្ញុំនឹងចូលក្នុងស្នែងហើយ ។ ហ៊ឺ ! ខ្ញុំមិនចង់ចេញដំណើរទៅសោះ !

លោកជំទាវចោលភ្នែកសំលឹងរកមើល*ប្លាក់ថន* ហើយទីបំផុតក៏គ្រលេកឃើញនៅក្បែរកន្លែងងងឹតព្រាល ១ ។ លោកជំទាវក៏សួរភ្លាម :

- អ្នកណាជាអ្នកទទួលខុសត្រូវលើអាន់*ជីន-សាន* រហូតដល់ពេលឡើងទូក ?

*ប៊ុនតារ៉ូ*ឆ្លើយតបក្នុងភាសាស្ទាបស្ទង់ :

- ខ្ញុំបានបញ្ជាអោយវាដើរអែបនឹងស្នែងប្រពន្ធខ្ញុំ ។ បើប្រពន្ធខ្ញុំមិនអាចមើលវាកើតទេនោះ ខ្ញុំនឹងទទួលកិច្ចការនេះ ។

- លោកម្ចាស់*យ៉ាប៊ូ* លោកគួរជូនដំណើរជំទាវ*សាស៊ូកូ*...



www.budinst.gov.kh www.elibraryofcambodia.org

- អ្នកយាម !

សំលេងអោយអាសន្នលាន់ចេញពីថ្នាក្រៅ ។ *ប៊ុនតារ៉ូ* និង*យ៉ាប៊ូ* ស្ទុះចេញទៅភ្លាម ដោយមានពួកកងសេនាតាមប្រកិតពីក្រោយ និងមានមួយចំនួនទៀតស្ទុះចេញមកពីក្នុង ។

នៅតាមចន្លោះកំផែងវិមានទាំងពីរ *អ៊ីស៊ីដូ* កំពុងតែដើរតំរង់មក ។ នៅពីក្រោយ *អ៊ីស៊ីដូ* មានពួកអាវប្រផេះប្រហែលពីររយនាក់មកជាមួយផង ។ មកដល់ទីធ្លាខាងក្រៅខាងមុខទ្វារធំ *អ៊ីស៊ីដូ* ក៏ឈប់នៅទីនោះ ។ ថ្វីត្បិតតែមនុស្សទាំងពីរក្រុមមិនមានអាកប្បកិរិយាប្រឡូសរ៉ាយនឹងគ្នា ថ្វីត្បិតតែគ្មានអ្នកណាម្នាក់ដាក់ដៃខ្លួនទៅលើដងដាវ ប៉ុន្តែម្នាក់ៗត្រៀមខ្លួនហើយជាស្រេច ។

*អ៊ីស៊ីដូ* អោនខ្លួនគោរពក្នុងអាការៈធ្វើរឹកធ្វើរាង :

- រាត្រីនេះចំជាល្អមែន លោកម្ចាស់ *យ៉ាប៊ូ !*

- បាទ ! បាទ ! ពិតជាល្អមែន ។

*អ៊ីស៊ីដូ* ងក់ក្បាលគោរពជាការគួរសមខាងក្រៅទៅរក*ប៊ុនតារ៉ូ* ១ក៏ងក់ក្បាលសងមកវិញជាសំបកក្រៅដូចគ្នានេះដែរ ។ អ្នកទាំងពីរនេះគឺជាមេទ័ពជំនិតរបស់អម្ចាស់ *តូរ៉ាណាហ្គា* ។ *ប៊ុនតារ៉ូ* ជាមេទ័ពកងពលមួយនៅក្នុងចំប៉ាំងនៅតូរ៉េ ឯ*អ៊ីស៊ីដូ* គឺជាមេបញ្ជាការរួម ។ ទាំងពីរនាក់បានចោទគ្នាទៅវិញទៅមកពីរឿងក្បត់ ។ នៅពេលនោះ បើសិនជាគ្មានអន្តរាគមន៍ដោយផ្ទាល់ និងបញ្ជាដាច់ណាត់របស់អម្ចាស់ *តូរ៉ាណាហ្គា* ទេ ប្រហែលជាមានរឿងឈាមដាបផែនដីជាមិនខាន ។

*អ៊ីស៊ីដូ* សង្កេតវាយតំលៃពួកអាវត្នោត ។ រួចក្រសែភ្នែករបស់លោកក៏ប្រទះឃើញ *ប្លាក់ថន* ១ក៏លំអោនខ្លួនគោរព ។ លោកក៏លំអោនគោរពសងវិញ។ តាមមាត់ទ្វារកំផែងលោកក៏បាន ឃើញនារីទាំងបី និងស្មេចផងដែរ ។ បន្ទាប់មកលោកក៏ងាកមើលទៅ*យ៉ាប៊ូ*វិញ :

- លោកគ្រាន់តែរៀបចំក្បួនពិធីការជូនលោកជំទាវ *គីរីស៊ីបូ* សោះប៉ុន្តែការរៀបចំរបស់ពួកលោកដូចទៅធ្វើសង្គ្រាមអ៊ីចឹង ។

- នេះគឺជាបញ្ជារបស់ *ហ្ស៊ីរ៉ូ-ម៉ាត់ស៊ី-សាន* ។ ព្រោះមានរឿងពួកឃាតករ *អាមីតា*..

*យ៉ាប៊ូ* បញ្ឈប់សំដីនៅកណ្ដាលទី ដោយ*ប៊ុនតារ៉ូ* បានបោះជំហានយ៉ាងឃ្លើននៅឈរជ្រែងនៅចំកណ្ដាលមាត់ទ្វារ :



www.budinst.gov.kh www.elibraryofcambodia.org

- ពួកយើងតែងតែត្រៀមប្រយុទ្ធជានិច្ច ។ ទោះមានអាវក្រោះ រឺអត់អាវក្រោះក្តី។ ពួកយើងហ៊ានមួយតដប់ ហើយបើជាពួកស៊ីខ្មឹម(*) ពួកយើងហ៊ានត ដល់ហាសិបនាក់ផង ។ ពួក យើងមិនគ្រលប់ក្រោយរត់ចោលកន្លែងប្រយុទ្ធ ដូចពួកអាកំសាកញីនោះទេ ។ ហើយពួកយើងក៏ មិនដែលទុកអោយគ្នាយើងត្រូវគេរោមរ៉ៃនោះដែរ ។

ភាពញញឹមរបស់*អ៊ីស៊ីដូ* ពោរពេញទៅដោយភាពមាក់ងាយ ហើយសំដីរបស់លោក ប្រៀបបីដូចជាម្ទុលពិស :

- មែនអ្ហី ?ប្រហែលបន្តិចទៀតលោកនឹងមានឱកាសជាមិនខាន។ ឱកាសបានប្រយុទ្ធ ជាមួយនឹងកូនប្រុសដើមទ្រូងប្រាំហត្ថពិតប្រាកដ មិនមែនពួកស៊ីខ្មឹមទេ ។

- បន្តិចទៀតហ្នឹងអង្កាល់ទៅ ? ម៉េចមិនយប់នេះតែម្ដងទៅ ? នៅកន្លែងនេះ បណ្ដោយទៅ ?

*យ៉ាប៊ូ* កំសៀកខ្លួនយ៉ាងប្រុងប្រយ័ត្នទៅក្នុងចន្លោះអ្នកទាំងពីរ ។ គេធ្លាប់បានទៅប្រ យុទ្ធនៅកូរ៉េដែរ ហើយគេដឹងពីការពិតពីមនុស្សទាំងពីរនេះ ។ គឺជាមនុស្សដែលគេមិនអាចទុក ចិត្តបាន ទាំង*ប៊ុនគារ៉ូ* ទាំង*អ៊ីស៊ីដូ* ។ គេនិយាយសំរួលបរិយាកាសឡើងវិញ :

- មិនមែនយប់នេះទេ ។ ព្រោះយប់នេះ យើងស្ថិតនៅក្នុងចំនោមគ្នាជាមិត្ត *ប៊ុនគារ៉ូ-សាន* ។

ចំពោះ*យ៉ាប៊ូ* គឺជាប្រការសំខាន់ណាស់ ដែលត្រូវបញ្ចៀសអោយបានការប៉ះទង្គិច ដែលអាចរាំងផ្លូវគេមិនអោយចេញពីវិមាននេះបានជារៀងរហូត ។ គេនិយាយម្ដងទៀត :

- យើងស្ថិតនៅក្នុងចំនោមគ្នាជាមិត្ត *ប៊ុនគារ៉ូ-សាន* ។

- មិត្តណា ? ខ្ញុំស្គាល់មិត្តណាស់ !

រួច*ប៊ុនគារ៉ូ* ងាកទៅរក*អ៊ីស៊ីដូ* ផាំង :

- រួចអាកូនប្រុសដើមទ្រូងប្រាំហត្ថនោះនៅឯណា ? អាកូនប្រុសពិតប្រាកដ ដែល

---

(*) *ពួកកូរ៉េ (ក.អ.ប.)*



www.budinst.gov.kh www.elibraryofcambodia.org

លោកឯងនិយាយអំបាញ់មិញនោះ *អ៊ិស៊ីដូ-សាន* ? អ្នាស ? អាកូនប្រុសណុងប៉ុន្មាននាក់ ? អោយវាលូនចេញពីរន្ធមកឈរមុខខ្ញុំសាកលមើល ? ខ្ញុំគឺ *តូដា ប៊ុនតារ៉ូ* អម្ចាស់តំបន់*សាកូរ៉ា* !អោយពួកវាមកសាកមើល បើពួកវាក្លាហានមែននោះ !

*អ៊ិស៊ីដូ* សំលក់សំលឹង*ប៊ុនតារ៉ូ* សឹងស្ទុះទៅស៊ីសាច់ ។

យ៉ាប៊ូនិយាយ :

- នេះមិនជាពេលប្រយុទ្ធទេ ប៊ុនតារ៉ូ-សាន ។ មិត្តក៏ដោយ...

- មិត្ត ? ឯណា ? នៅនឹងជុំអាច់ណឹងអ្ហី ?

និយាយចប់ *ប៊ុនតារ៉ូ* ខាកទាំងល្មើមទៅលើដីថែមទៀត

សាមូរ៉ៃអាវប្រផេះម្នាក់លូកដៃកាន់ដងដាវរបស់ខ្លួនភ្លាម ។ រំពេចនោះពួកអាវខ្មៅតដប់នាក់ក៏មានកាយវិការតាមនេះភ្លាម ហើយក្នុងមួយភ្លែតនោះជាបន្ថមកទៀត ពួកអាវប្រផេះហាសិបនាក់ក៏លូកដាវខ្លួនដែ។ អីលូវនេះទាំងអស់គ្នារង់ចាំ*អ៊ិស៊ីដូ*ដកដាវចេញជាសញ្ញាវាយលុកតែប៉ុណ្ណោះ។

ក្នុងពេលដ៏តឹងតែងនេះ *ហ៊ីរ៉ូ-មាត់ស៊ី* ក៏បានលេចមុខចេញតាមសួនច្បារ ហើយដើរកាត់ខ្លោងទ្វារចេញមកដល់ទីធ្លាក្រៅនេះដែរ ។ ដៃរបស់លោកកាន់ដាវផ្តាច់ជីវិត ដោយមានផ្លែពាក់កណ្តាលហូតចេញពីស្រោមហើយស្រេច ។

នៅពេលមកដល់អ្នកទាំងពីរ *ហ៊ីរ៉ូ-មាត់ស៊ី* ក៏និយាយឡើងយ៉ាងនឹងនរ :

- កូនប្រុស ជូនកាលម្តែងអាចរកបានមិត្តនៅក្នុងតំនរអាច់បានដែរ ។

ដៃទាំងអស់បានលែងដងដាវភ្លាម ។ សាមូរ៉ៃទាំងពីរក្រុមក៏បន្ធូរខ្សែធ្នូរបស់ខ្លួនដែរ ។ *ហ៊ីរ៉ូ-មាត់ស៊ី* និយាយបន្ត :

- យើងមានមិត្តពេញមាវិមាននេះ ។ ពេញទីក្រុងអូសាកាថែមទៀតផង ។ នេះជាការពិតណា ។ ព្រោះលោកម្ចាស់*តូរ៉ាណាកា*របស់យើងតែងមានប្រសាសន៍យ៉ាងនេះ ។

នៅក្នុងក្រសែភ្នែកកូនប្រុសតែមួយគត់ដែលនៅរស់នេះ *ហ៊ីរ៉ូ-មាត់ស៊ី* ឃើញគំលានឈាមយ៉ាងច្បាស់ ។ នៅពេលដែល*អ៊ិស៊ីដូ* ដើរតំរង់មកនោះ*ហ៊ីរ៉ូ-មាត់ស៊ី* បានត្រៀមស្ថានភាពប្រយុទ្ធជាស្រេចនៅទីធ្លាក្នុង ហើយនៅពេលដែលស្ថានភាពគ្រោះថ្នាក់បានកន្លងផុតទៅលោកបានរំកិលខ្លួនយ៉ាងស្ងៀមស្ងាត់ដូចជាឆ្មានៅក្នុងទីងងឹតវិញ ។ ពេលនេះលោកសំលឹងយ៉ាងមុតចំ ភ្នែករបស់កូនលោក :



www.budinst.gov.kh www.elibraryofcambodia.org

-មែនទេកូនប្រុស ?

ដោយខំសង្កត់ចិត្តយ៉ាងសំបើមអស្ចារ្យ *ប៊ុនតារ៉ូ* ងក់ក្បាល ហើយថយក្រោយមួយជំហាន ប៉ុន្តែគេនៅតែពាំងច្រកទ្វារដដែល ។

*ហ៊្សី-មាត់ស៊ី* ក៏បែរទៅរក *អ៊ីស៊ីដូ* ម្តង :

- ពួកយើងឥតមានផែនការជួបលោកយប់នេះសោះ *អ៊ីស៊ីដូ-សាន* ។

- ខ្ញុំចង់មកសំដែងការគួរសមចំពោះជំទាវ *គីរីស៊ូបូ* ។ មុននេះបន្តិចខ្ញុំឥតបានដឹងសោះថា មានគេចង់ចេញពីវិមាននេះ ។

-បើអីចឹងកូនប្រុសខ្ញុំវាមិននិយាយត្រូវហើយ ? តើយើងត្រូវភ័យថា យើងមិនមែននៅជាមួយមិត្តទេអ្វី ? តើយើងជាចំនាប់ដែលត្រូវអង្វរសុំការសន្តោសប្រោសប្រណីអីចឹងអ្វី ?

- មិនមែនអីចឹងទេ ! ប៉ុន្តែលោក *តូរ៉ាណាកា* នឹងខ្ញុំបានឯកភាពគ្នាលើពិធីការនៅក្នុងរយៈពេលទស្សនកិច្ចរបស់លោក ។ ការមកដល់ រឺការចេញដំណើររបស់ឥស្សរជនជាន់ខ្ពស់ត្រូវតែជូនដំណឹងមុនមួយថ្ងៃ ដើម្បីខ្ញុំអាចរៀបចំបានសមរម្យ ។

- នេះគឺជាការសំរេចចិត្តភ្លាម ៗរបស់លោកម្ចាស់ *តូរ៉ាណាកា* ។ លោកគិតថាគ្រាន់តែបញ្ជូនប្រពន្ធរបស់លោកម្នាក់ទៅយេដូវិញនោះ មិនមែនជារឿងសំខាន់ណាស់ណារហូតដល់ទៅរំខានលោកឡើយ ។ ពិតហើយលោកម្ចាស់ *តូរ៉ាណាកា* មិនទាន់រៀបចំការចេញដំណើររបស់ខ្លួនលោកផ្ទាល់នៅឡើយទេ ។

- ពេលចេញដំណើរបានកំណត់ហើយរឺនៅ ?

- កំនត់ហើយ ។ គឺនៅថ្ងៃដែលក្រុមប្រឹក្សាអាជ្ញានុសិទ្ធិបិទសម័យប្រជុំ ។ លោកនឹងត្រូវគេជូនដំណឹងតាមកាលវេលាត្រឹមត្រូវដូចការកំនត់ក្នុងពិធីសារ ។

- ល្អណាស់ ។ តាមពិតសម័យប្រជុំអាចនឹងត្រូវលើកពេលទៀតផង ព្រោះលោកម្ចាស់ *គីយ៉ាម៉ា* មានជំងឺកាន់តែដាបទៅហើយ ។

- តើសម័យប្រជុំត្រូវលើកពេល រឺក៏អត់ ?

- ខ្ញុំគ្រាន់តែនិយាយថា វាអាចតែប៉ុណ្ណោះ ។ យើងសង្ឃឹមថា ជាប្រការមួយគួរជាទី



www.budinst.gov.kh www.elibraryofcambodia.org

រីករាយណាស់ ដែលបានលោកម្ចាស់ *តូរ៉ាណាកា* មកនៅយូរជាមួយពួកយើងយ៉ាងនេះមែនទេ? តើលោកម្ចាស់ *តូរ៉ាណាកា* នឹងទៅបរបាញ់ជាមួយខ្ញុំនៅថ្ងៃស្អែកនេះទេ ?

- ខ្ញុំបាទមានសំនូមពរអោយលោកម្ចាស់ខ្ញុំលុបចោលកម្មវិធីបរបាញ់ទាំងអស់ រហូតដល់ថ្ងៃប្រជុំ ព្រោះខ្ញុំគិតថា វាមិនធានាសន្តិសុខប៉ុន្មានទេ ។ ខ្ញុំលែងចាត់តំបន់ម្តុំនេះថាជាតំបន់សុវត្ថិភាពទៀតហើយ ។ បើពួកឃាតកតំរក់អាចឆ្លងកាត់ពួកឆ្មាំរបស់លោកយ៉ាងងាយបែបនេះទៅហើយ នៅក្រៅកំផែងវិមានវារឹតតែងាយក្នុងការប្រើល្បិចចោកទាបនេះទៅទៀត ។

*អ៊ីស៊ីដូ* ធ្វើជាមិនដឹងចំពោះសំដីប្រមាថនេះ។ ការប្រមាថមិននាំអ្វីក្រៅពីបញ្ចេះកំហឹងកូនទ័ពរបស់លោក ហើយអីលូវនេះក៏មិនទាន់ដល់ពេលដែលលោកត្រូវបញ្ចេះឆ្លួនទៅឡើយ ។ អំបាញ់មិញនេះលោកចូរថ្វេងសន្និកនៅពេលដែល *ហ៊ីរ៉ូ-មាំត់ស៊ឺ* ធ្វើអន្តរាគមន៍នេះ ដោយលោកវិះទប់ខ្លួនលែងបានទៅហើយ ។ រូបភាពក្បាលរបស់ *ប៊ុនតារ៉ូ* ដាច់ធ្លាក់ទៅលើដីនោះ កំពុងតែទន្រានអារម្មណ៍របស់លោក ។ លោកនិយាយតបនឹង *ហ៊ីរ៉ូ-មាំត់ស៊ឺ* វិញ :

- លោកបានដឹងហើយតើ ថាបញ្ហាការល្បាតទាំងប៉ុន្មាននៅយប់នោះសុទ្ធតែទទួលបញ្ជាអោយទៅបរលោកទាំងអស់ហើយ ។ ស្តាយដែរដែលពួក *អាមិតា* ដឹងតែច្បាប់របស់ក្រុមពួកវាតែប៉ុណ្ណោះ តែពួកវាគង់តែត្រូវបោសសំអាតតែទាំងអស់ណឹង ។ ក្នុងពេលខាងមុខដ៏ខ្លីនេះក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនឹងសំរេចចាត់ការពួកវាជាមិនខាន ។ អីលូវនេះតើខ្ញុំអាចទៅសំដែងការគួរសមចំពោះលោកជំទាវ *គីរី ស៊ូបូ* បានទេ ?

និយាយរួច *អ៊ីស៊ីដូ* ក៏បោះជំហានដើរទៅមុខ ។ អង្គរក្សការពារទាំងប៉ុន្មានរបស់លោកក៏ដើរជាប់តាមក្រោយ ។ ប៉ុន្តែទាំងអស់គ្នាឈប់ង៉ក់ភ្លាម ។ ដៃរបស់ *ប៊ុនតារ៉ូ* កំពុងកាន់ធ្នូមួយដើម ហើយថ្វីបើផ្លែព្រួញកំពុងតំរង់ចុះក្រោមក្តី ក៏ខ្សែធ្នូត្រូវបានយឹតយ៉ាងតឹងហើយស្រេច:

- ពួកអាវប្រផេះមិនអនុញ្ញាតអោយឆ្លងទ្វារនេះទេ ។ នេះបានឯកភាពគ្នាក្នុងពិធីសារហើយ ។

- ខ្ញុំគឺជាអភិបាលនៃវិមានអូសាកា និងជាមេបញ្ជាការលើក្រុមអង្គរក្សរបស់ទាយាទ! ខ្ញុំមានសិទ្ធិទៅកន្លែងណាក៏បានដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

ជាថ្មីម្តងទៀត *ហ៊ីរ៉ូ-មាំត់ស៊ី* ម្ចាស់ការជាប់លើសភាពការណ៍ :

- ពិតណាស់ហើយ លោកគឺជាមេបញ្ជាការលើក្រុមអង្គរក្សរបស់ទាយាទ ហើយលោកមានសិទ្ធិទៅទីណាក៏បាន ។ ប៉ុន្តែមនុស្សតែប្រាំនាក់ប៉ុណ្ណោះមានសិទ្ធិតាមលោកឆ្លងខ្លោងទ្វារនេះ ។ ក្រែងនេះគឺជាការឯកភាពគ្នារវាងលោកនឹងលោកម្ចាស់ខ្ញុំនៅពេល ដែលលោកម្ចាស់ខ្ញុំស្នាក់នៅទីនេះអ្ហ៎ ?

- ប្រាំ រឺហាសិបវាមានទៅខុសអី ? ការប្រមាថបែបនេះមិនអាច...

- ប្រមាថ ? កូនប្រុសរបស់ខ្ញុំគ្មានបំនងអ្វីនឹងប្រមាថលោកសោះទេ ។ វាគ្រាន់តែធ្វើតាមបញ្ជា ដែលបានឯកភាពគ្នារវាងលោកម្ចាស់វា នឹង រូបលោកតែប៉ុណ្ណោះ ។ តែប្រាំនាក់ទេ ! ប្រាំនាក់ !

សំដីរបស់ *ហ៊ីរ៉ូ-មាំត់ស៊ី* គឺជាបញ្ជាផងដែរ ។ រួច *ហ៊ីរ៉ូ-មាំត់ស៊ី* បែរខ្នងដាក់ *អ៊ីស៊ីដូ* ហើយសំលឹងមើលទៅកូនប្រុសរបស់លោក :

- លោកម្ចាស់ *អ៊ីស៊ីដូ* មកសំដែងការគួសមចំពោះលោកជំទាវ *គីរីស៊ូបូ* យ៉ាងនេះ គឺជាការផ្តល់កិត្តិយសដល់ពួកយើងណាស់ ។

ដាវរបស់មេទ័ពចំនាស់ល្បឿនចេញពីស្រោមប្រហែលជាងពីរថ្នាប់ស្រេចទៅហើយ ។ គ្មានអ្នកណាម្នាក់ច្បាស់នៅក្នុងចិត្តថា តើសំរាប់រៃទៅរក *អ៊ីស៊ីដូ* បើសិនជាការប្រយុទ្ធផ្ទុះឡើង រឺក៏សំរាប់កាត់ផ្តាច់ក្បាលរបស់ *ប៊ុនតារ៉ូ* បើសិនជាបុរសនេះតំរង់ធ្នូឡើងនោះឡើយ ។ ទាំងអស់គ្នាសុទ្ធតែដឹងថា រវាងឪពុកនឹងកូនគ្មានសញ្ចេតនាស្រលាញ់គ្នាបន្តិចបន្តួចណាឡើយ តែទាំងពីរនាក់គោរពល្បិចកន្ទុយខ្មៀនរបស់គ្នារៀង ១ ខ្លួន ។ *ហ៊ីរ៉ូ-មាំត់ស៊ី* និយាយបន្ត :

-ម៉េចទៅអាកូន ? តើអ្ហែងចង់និយាយអីទៀតជាមួយលោកមេបញ្ជាការ និងអង្គរក្សទាយាទនោះ ?

ញើសហូរសស្រាក់លើផ្ទៃមុខរបស់ *ប៊ុនតារ៉ូ* ។ បន្តិចក្រោយមកបុរសនេះថយចេញទៅម្ខាង ហើយបន្ធូរខ្សែធ្នូរបស់ខ្លួនវិញ ។ ប៉ុន្តែព្រួញនៅតែស្ថិតនៅលើខ្សែធ្នូនៅឡើយ ។ជាច្រើនលើកមកហើយ ដែល *អ៊ីស៊ីដូ* បានឃើញ *ប៊ុនតារ៉ូ* ប្រកួតប្រជែងបាញ់ធ្នូ ដោយមានវង់បាញ់



www.budinst.gov.kh www.elibraryofcambodia.org

ចំងាយពីររយជំហាន ។ *ប៊ុនតារ៉ូ* បាញ់ព្រួញប្រាំមួយនៅពេលដែលព្រួញទីមួយមិនទាន់ដល់វង់បាញ់ផង ។ ហើយព្រួញទាំងប្រាំមួយសុទ្ធតែចំរង្វង់ខ្មៅទាំងអស់ ។ លោកពេញចិត្តណាស់នឹងបញ្ជាអោយបើកការវាយលុក ហើយនិងកំទេចឪពុក និងកូនទាំងពីរនាក់នេះ ក៏ដូចជាអ្នកឯទៀតផងដែរ ។ ប៉ុន្តែលោកដឹងថា ចាប់ផ្តើមប្រយុទ្ធជាមួយពួកនេះ គឺពិតជាអំពើលេលាតែម្តង ព្រោះសត្រូវធំរបស់លោកគឺ *តូរ៉ាណាកា* ឯណោះទេ ។ ម្យ៉ាងទៀត នៅពេលដែលសង្គ្រាមផ្ទុះឡើង *ហ៊ីរ៉ូ-មាត់ស៊ី* អាចបោះបង់ចោល *តូរ៉ាណាកា* មករួមដៃជាមួយលោកវិញផងក៏មិនដឹង ។ ជំទាវ *អូជីបា* បាននិយាយហើយថា នៅពេលដែលកាលៈទេសៈមកដល់ លោកជំទាវនឹងទាក់ទងជាមួយតាចាស់កណ្តាប់ដៃដែកនេះជាមិនខាន ។ លោកជំទាវបានស្បថស្បែថា កណ្តាប់ដៃដែកពិតជាមិនក្បត់ទាយាទឡើយ ហើយលោកជំទាវពិតជាអូសទាញមនុស្សនេះបាន រឺប្រហែលជាអាចប្រើមនុស្សនេះអោយធ្វើឃាត *តូរ៉ាណាកា* ក៏បាន ដើម្បីចៀសវាងការប្រឈមមុខជាចំហ ។ តើលោកជំទាវក្តាប់ការណ៍សំងាត់អី ក្តាប់ការយល់ដឹងអ្វី ទើបមានឥទ្ធិពលលើកណ្តាប់ដៃដែកបាន? *អ៊ីស៊ីដូ* ដណ្តឹងសួរនៅក្នុងចិត្ត ។ លោកបានបញ្ជាអោយគេជំលៀសជំទាវ *អូជីបា* ចេញអោយផុតពីយេដូ មុនពេលដែលក្រុមប្រឹក្សាអាជ្ញានុសិទ្ធិប្រជុំ ព្រោះថាជីវិតរបស់ជំទាវ *អូជីបា* ថ្លៃមិនស្មើនឹងស្រូវមួយគ្រាប់ឡើយ នៅពេលណាដែល *តូរ៉ាណាកា* ត្រូវទំលាក់ពីតំនែងនោះ ហើយរឿងទំលាក់នេះសមាជិកក្រុមប្រឹក្សាទាំងអស់បានឯកភាពគ្នាហើយជាស្រេច ។ ទំលាក់ពីតំនែងនិង *សិបពូគូ* ជាបន្ទាន់ បើជាចាំបាច់ត្រូវប្រើកំលាំងថែមទៀតផង ។ ហេតុនេះបើជំទាវ *អូជីបា* បានគេចផុតពីយេដូ នោះគឺជាប្រការល្អ ។ បើគេចមិនរួចទេក៏គ្មានការអ្វីដែរ *យ៉ែនម៉ុន* នឹងឡើងក្តាប់អំនាចប្រាំបីឆ្នាំខាងមុខនេះ ។

*អ៊ីស៊ីដូ* ដើរកាត់ខ្លោងទ្វារចូលទៅសួនខាងក្នុងដោយមាន *ហ៊ីរ៉ូ-មាត់ស៊ី* និង *យ៉ាប៊ូ* ដើរតាមពីក្រោយផង ។ អង្គរក្សប្រាំនាក់ចូលទៅជាមួយផងដែរ ។ *អ៊ីស៊ីដូ* លំអោនខ្លួនគោរពនិងជូនពរជំទាវ *គីរ* ហើយដោយឃើញថា អ្វីៗរៀបរយទេនោះលោកក៏ត្រលប់ទៅវិញជាមួយអង្គរក្សទាំងអស់របស់លោកទៅ ។

*ហ៊ីរ៉ូ-មាត់ស៊ី* និយាយទាំងកំហឹង :



www.budinst.gov.kh www.elibraryofcambodia.org

- លោកអាចចេញដំណើរទៅបានហើយ *យ៉ាប៊ូ-សាន* ។ អាខ្មោចស៊ីពៃនេះវាលែងមករករឿងទៀតហើយ ។

- បាទ ខ្ញុំចេញដំណើរអីលូវនេះហើយ ។

*គិរី* យកកន្សែងផ្ចិតញើសដែលនៅលើថ្ងាសរបស់ខ្លួនបណ្ដើរ និយាយបណ្ដើរ ។

-វានេះចំជាបិសាចមែន ! ជាកាមីអាក្រក់តែម្ដង ! ខ្ញុំបារម្ភចំពោះលោកម្ចាស់ណាស់ ។

តំណក់ទឹកភ្នែកស្រក់ចុះពីរង្វង់ភ្នែករបស់លោកជំទាវ :

- ខ្ញុំមិនចង់ចេញដំណើរទៅសោះ

*ហ៊ីរ៉ូ-ម៉ាត់ស៊ុ* បន្លឺឡើង :

- គ្មានអ្វីអាក្រក់អាចប៉ះពាល់លោកម្ចាស់*តូរ៉ាណាកា* បានទេ ខ្ញុំសូមសន្យាជាមួយលោកជំទាវ ។ លោកជំទាវគួរចេញដំណើរទៅហើយ ។ ចេញទៅភ្លាមនេះ ។

*គិរី* ប្រឹងទប់ភាពខ្សឹកខ្សួលរបស់ខ្លួន ហើយលើកស្បៃក្រាសដែលធ្លាក់តាមហាមមួកដ៏ធំរបស់លោកស្រីឡើង :

-*យ៉ាប៊ូ-សាម៉ា* សូមលោកអធ្យាស្រ័យជូនជំទាវ *សាស៊ូកូ* ចូលទៅក្នុងវិញផងបានទេ?

- បាទ បានលោកជំទាវ ។

ជំទាវសាស៊ូកូ លំអោនខ្លួនគោរពហើយដើរចេញទៅដោយមាន*យ៉ាប៊ូ* តាមពីក្រោយផង។ នៅពេលដែលឡើងជិតដល់កាំជណ្ដើរខាងលើ លោកជំទាវក៏រអិលជើងហើយដួលប្រួសតែម្ដង ។

*គិរី* ស្រែកឡើងភ្លាត់សំលេង :

- ប្រយ័ត្នពោះ ? នាងមានត្រូវរបួសទេ ?

ភ្នែកទាំងអស់បាញ់ស្រោចទៅរក*សាស៊ូកូ* ។ *មារីកូ* ស្ទុះទៅរកជួយ ប៉ុន្តែ*យ៉ាប៊ូ* បានលើកនាងអោយក្រោកឈរវិញបាត់ទៅហើយ ។ នាងឥតត្រូវរបួសអ្វីទេ គ្រាន់តែឈឺចុកចាប់បន្តិចតែប៉ុណ្ណោះ ។ នាងនិយាយទាំងដង្ហក់ ១ :

- ខ្ញុំឥតមានអីទេ មិនបាច់ខ្វល់ទេ ។ ខ្ញុំចំជាល្ងាក់ល្ងើមែន ។

ឃើញថាជំទាវ*សាស៊ូកូ* ស្រួលបួលហើយ *យ៉ាប៊ូ* ក៏ដើរចេញទៅធ្លាក្រៅ ដើម្បីរៀបចំ



www.budinst.gov.kh www.elibraryofcambodia.org

ការចេញដំណើរជាបន្ទាន់ ។

*មារីកូ* ក៏ត្រលប់មកកាន់ខ្លោងទ្វារវិញដែរ ។ *ប្លាក់ថន* កំពុងឈរស្ងាបនៅឯក្នុងសួនច្បារ ។

-មានរឿងអីហ្នឹង- *មារីកូ* សួរ ។

- អត់មានអីទេ ។

ក្រោយពីឈប់ស្ងៀមបន្តិច *ប្លាក់ថន* ក៏សួរទៅវិញ :

- ជំទាវ *គីរីស្ទីប* ស្រែកអីអំបាញ់មិញ ?

*មារីកូ* និយាយពន្យល់ប្រាប់រឿងរ៉ាវដល់ *ប្លាក់ថន* ហើយបន្ថែម :

- ពួកយើងខ្លាចថា ការដួលនេះអាចប៉ះពាល់ដល់កូនក្នុងពោះណា៎ ។

- កូនរបស់ *តូរ៉ាណាកា-សាមាំ* អ្ហ៎ ?

- ចាស ។

និយាយចប់ *មារីកូ* ងាកបែរក្រោយសំលឹងមើលទៅស្ពែង ។ ស្រមោល *គីរី* ដែលលើកស្បៃមួយឡើងនោះ ចាំងឆ្លុះតាមស្បៃស្តើងដែលបិទជិតស្ពែងនោះ ។ គួរអោយអាណិតមែន- *មារីកូ* គិតនៅក្នុងចិត្តដោយនាងយល់ថា *គីរី* ចូលស្ពែងមុន ដើម្បីកុំអោយគេឃើញទឹកភ្នែករបស់លោកជំទាវ ។ បើអញជាជំទាវ *គីរី* វិញ ក៏អញច្បាស់ជាតក់ស្លុតដែរនៅពេលចាកចេញពីលោកម្ចាស់អញយ៉ាងនេះ ។

រួចភ្លែក *មារីកូ* ងាកទៅមើល *សាស៊ូកូ* ដែលបក់ដៃលានៅឯរានហាល រួចហើយនាងក៏ដើរចូលទៅក្នុងទៅ ។ ទ្វារដែកដែលបិទតាមក្រោយជំទាវ *សាស៊ូកូ* លាន់ប្រៀបបីដូចជាជួងមរណៈ ។ តើពួកយើងនឹងជួបគេវិញទេ ?

*ប្លាក់ថន* សួរបន្ត :

- តើ *អ៊ុស៊ុជូ* មានការអី ?

- គាត់...គាត់...ខ្ញុំមិនដឹងពាក្យអោយចំតែម្តងទេ ។ គឺថា គាត់អង្កេត មកធ្វើការពិនិត្យដោយមិនជូនដំណឹងជាមុនឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- ហេតុអី ?

ដោយមិនចង់ប្រាប់ពីមូលហេតុពិតប្រាកដ *មារីកូ* និយាយថា :

- គាត់ជាមេបញ្ជាការនៃវិមាននេះ ។

*យ៉ាប៊ូ* ស្រែកចេញបញ្ជាទៅឯក្បាលក្បួន ហើយចេញដំណើរទៅ ។ *មារីកូ* ក៏ចូលទៅក្នុង ស្នែងដោយទុករនាំងនៅចំហមួយបន្ទោះ ។ *ប៊ុនតារ៉ូ* ធ្វើសញ្ញាប្រាប់ *ប្លាក់ថន* អោយដើរក្បែរនោះ ។ *ប្លាក់ថន* ធ្វើតាមបញ្ជាភ្លាម ។

ពួកគេរង់ចាំអោយស្នែងជំទាវគីរីចេញទៅមុន ។ *ប្លាក់ថន* សំលឹងមើលស្រមោលព្រាល ១ ដែលបាំងស្បែជិតរបស់ *គីរី* នៅក្នុងស្នែង ។ សំលេងខ្សឹកខ្សួលស្រាល ១ នៅលាន់លឺនៅឡើយ ។ នារីអ្នកបំរើទាំងពីរនាក់ គឺ *អាសា* និង *សូណូ* ដើរកៀកស្នែងទាំងញ័រចំប្រប់ ។ រួច *ប្លាក់ថន* ងាកក្រោយសំលឹងមើលជាចុងក្រោយ ។ *ហ៊ីរ៉ូ-មាត់ស៊ុ* ឈរច្រត់លើដាវតែម្នាក់ឯងនៅក្បែរកូនខ្ទម ។ រួចទិដ្ឋភាពសួនច្បារត្រូវរលាយបាត់នៅពេលដែលសាមូរ៉ៃរុញទ្វារដែកយ៉ាងមាំបិទ ហើយរុញរនុកឈើយ៉ាងធំខ្ទាស់ជាប់ ។ អីលូវនេះនៅលើផ្លូវគ្មានកងការពារទៀតទេ ។ ពួកគេឡើងលើកំផែងទាំងអស់ ។

*ប្លាក់ថន* សួរទៅ *មារីកូ* ។

- មានរឿងអីណឹង ? មើលទៅដូចពួកគេត្រូវខ្ទាំងព័ទ្ធអីចឹង ។ ពួកអាវត្នោតទល់នឹងពួកអាវប្រផេះ ។ ពួកនេះត្រៀមមានរឿងអីផ្ទុះឡើងអ្អី ? រឿងបន្ថែមទៀតអ្អី ?

- សូមទោស ធម្មតាទេតែពេលយប់គេត្រូវតែបិទទ្វារយ៉ាងនេះហើយ ។

នៅពេលដែលស្នែងចាប់ចេញដំណើរ *ប្លាក់ថន* ក៏ដើរប្រកៀកទៅជាមួយផងដែរ ។ *ប៊ុនតារ៉ូ* ហើយនិងពួកសាមូរ៉ៃ ដែលនៅសល់សំរាប់បិទកន្ទុយក្បួននោះក៏ដើរតាមពីក្រោយ ។ *ប្លាក់ថន* សំលឹងមើលស្នែងដែលនៅពីមុខ ដំណើរយោលយោករបស់អ្នកស្នែង ហើយនិងស្រមោលព្រាល១ ដែលនៅក្នុងស្នែងនោះ ។ នៅក្នុងអារម្មណ៍របស់គេ គឺសែនច្របូកច្របល់ ថ្វីបើនៅខាងក្រៅគេប្រឹងខំលាក់យ៉ាងណាក្តី ។ នៅពេលដែលជំទាវ *គីរីស៊ូបូ* ស្រែកវ៉ាសឡើងនោះ ភ្នែករបស់



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថុន* បានចោលទៅមើលជំទាវ *គីរី* ភ្លាម ក្នុងពេលដែលភ្នែករបស់មនុស្សទាំងអស់គ្នាចោលសំលឹងទៅរកជំទាវក្មេងដែលដួលនៅលើជណ្តើរនោះ ។ *ប្លាក់ថុន* ក៏ប្រុងចោលភ្នែកមើលទៅតាមទិសដែលជំទាវ *សាស៊ូក* ដួលនោះដែរ ប៉ុន្តែគេឃើញជំទាវ *គីរី* ស្ទុះឡើងក្នុងល្បឿនយ៉ាងលឿនចូលទៅក្នុងខ្ទម ដែលនៅក្បែរនោះ ។ ដំបូងគេស្មានថាគេភាន់ច្រលំ ព្រោះនៅក្នុងពេលយប់បែបនេះអាវក្រៅខ្មៅ គឺម៉ូណូខ្មៅ មួកខ្មៅ និងស្បែខ្មៅបានធ្វើអោយលោកជំទាវស្ទើរលាយខ្លួនបាត់ក្នុងស្បៃរាត្រី ។ គេសំលឹងមើលស្រមោលដែលចូលបាត់មួយភ្លែត ហើយក៏លេចចេញមកវិញដោយស្ទុះទៅចូលផ្តុកក្នុងស្នែង និងដោយរូតរនាំងជិតឈើង ។ ក្នុងមួយរយៈពេលខ្លី ភ្នែកអ្នកទាំងពីរបានប៉ះគ្នា ។ គឺជា *តូរ៉ាណាកា* ។

☆☆☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ២២

ក្បួនតូចដែលហែហមស្តេចទាំងពីរនោះ បានដើរយ៉ាងយឺត ៗ បត់បែនតាមបន្ទាយនិងកន្លែងឆែកឆេររាប់មិនអស់ ។ រាល់ពេល គឺជាការលំអោនគោរពគួរសមការពិនិត្យសំបុត្រស្នាមយ៉ាងម៉ត់ចត់ ហើយពួកអាវប្រផេះ ព្រមទាំងមេបញ្ជាការថ្មីមួយក្រុមទៀត បានមកប្តូរវេនហែហមជំនួស រួចក្បួនក៏បន្តដំណើរទៅមុខទៀត ។ នៅកន្លែងឆែកឆេរនីមួយ ៗ *ប្លាក់ថន* តាមស់លឹងដោយក្តីព្រួយបារម្ភកាន់តែធំឡើងៗ នៅរាល់ពេល ដែលមេបញ្ជាការប៉ុសយាមដើរទៅជិតរទេះស្តេចរបស់ជំទាវ *គីរីស្ទីក* ដើម្បីពិនិត្យស្រមោលដែលឆ្លុះតាមវាំងននស្តេចដែលបិទជិតនោះ ។ ប៉ុន្តែជារៀងរាល់ពេលមេបញ្ជាការប៉ុស រមែងលំអោនខ្លួនគោរពយ៉ាងគួរសម ចំពោះស្រមោលព្រាលៗ ដែលកំពុងបញ្ចេញសំលេងខ្សឹកខ្សួលតិចៗ ពីក្នុងស្តេចហើយទើបញ្ជប់ធ្វើសញ្ញាអោយក្បួនបន្តដំណើរទៅមុខទៀត ។

តើមានអ្នកណាខ្លះដែលដឹងរឿងនេះ- *ប្លាក់ថន* ដណ្តឹងសួរទាំងរចល់នៅក្នុងចិត្ត ។ នារីអ្នកបំរើពិតជាដឹង បើមិនអីចឹងទេមិនមែនពួកនាងឡើងញ័រចំប្រប់បែបនេះឡើយ ។ *ហ៊្វី-ម៉ាត់ស៊ី* ប្រាកដជាដឹងដែរហើយច្បាស់ណាស់ ដែល*សាស៊ូក្គ* ដឹងរឿងនេះព្រោះនាងជានុយបញ្ឆោតទៅហើយនោះ ។ ចុះ *ម៉ារីក្គ* ? ប្រហែលអត់ទេ។ *យ៉ាប៊ូ* ? *តូរ៉ាណាកា* ប្រហែលមិនទុកចិត្តអាគាត់ណឹងទេ ។ រួចចុះអាគ្រូញ *ប៊ុនគាវ៉ូ* ? ពិតជាវាមិនដឹងម៉ុងអីទាំងអស់ ។

ពិតណាស់ហើយ នេះគឺជាការសាកល្បងរត់ដោះខ្លួនយ៉ាងសំងាត់បំផុត ។ ប៉ុន្តែហេតុអ្វីបានជា *តូរ៉ាណាកា* ប្រថុយស្បែកខ្លួននៅខាងក្រៅវិមានធ្វើអ្វី ? នៅខាងក្នុងមានសន្តិសុខគ្រប់គ្រាន់ហើយតើ ? រួចចុះយ៉ាងម៉េចចាំបាច់លាក់ការណ៍ម្ល៉េះ ? តើ *តូរ៉ាណាកា* ចង់គេចពីអ្នកណា? ពី *អ៊ីស៊ីដូ* រឺពីពួកឃាតក ? រឺពីអ្នកណាម្នាក់នៅក្នុងវិមាននេះ ? ប្រហែលជាគេចពីទាំងអស់ណឹង។ នៅក្នុងចិត្ត *ប្លាក់ថន* បន់ស្រូមអោយតែពួកគេបានទៅដល់ទូកធំ និងចេញឆ្ងាយទៅក្នុងលំហសមុទ្រ ។ បើសិនជា *តូរ៉ាណាកា* ត្រូវគេបើកមុខបាននោះឈាមនឹងដាបពោះដីរហើយ ។ នោះពិតជាការប្រយុទ្ធងាប់រស់មួយដ៏កក្រើកមេឃកក្រើកដី គ្មានការប្រណីអាសូរអ្វីទាំងអស់ ។ ខ្លួនអញគ្មានអាវុធសោះ ហើយទោះជាអញមានកាំភ្លើងខ្លីមួយគូ រឺកាណុងតូចម្តៃដើម និងកូន



www.budinst.gov.kh www.elibraryofcambodia.org

ចៅរាប់រយគ្គី ក៏ពួកអាវប្រផេះនៅតែកំទេចអញបានដដែល ។ អញគ្មានកន្លែងសំរាប់រត់ កន្លែងលាសំរាប់ពួនសោះ ។

- លោកហត់ទេ *អាន់ជីន-សាន* ? - *មារីកូ* បន្ទឺពាក្យសួរយ៉ាងស្រទន់-បើសិនជាលោកត្រូវការ លោកអាចអង្គុយលើស្លែង ហើយខ្ញុំដើរជំនិញម្ដងក៏បានដែរ ។

- អរគុណ !

*ធ្លាក់ផន* ឆ្លើយតបយ៉ាងគំបុត ដោយគេកំពុងតែស្ដាយស្បែកជើងវែងរបស់គេ ព្រោះស្បែកជើងដែលគេកំពុងពាក់នេះ ហាក់ដូចជាមិនស្រួលសោះ ។ គេបន្តនិយាយ :

- ជើងខ្ញុំមិនអីទេ ខ្ញុំគ្រាន់តែបន់សូមអោយយើងបានសុខឯលំហសមុទ្រតែប៉ុណ្ណោះ ។

- តើយើងពិតជាបានសុខនៅឯលំហសមុទ្រអ្វី ?

- ជួនកាលក៏បានសុខដែរអ្នកស្រី ។ តែមិនមែនសុខគ្រប់ពេលនោះទេ ។

*ធ្លាក់ផន* ស្ដាប់លឺសំដីរបស់ *មារីកូ* ល្មើយៗតែប៉ុណ្ណោះ ដោយអារម្មណ៍របស់គេកំពុងនៅច្របូកច្របល់អំពីរឿង *តូរ៉ាណាកា* នៅឡើយ ។ ឱ ព្រះអើយព្រះ សូមកុំអោយអញធ្វើអ្វីដែលអាចក្បត់ *តូរ៉ាណាកា* អោយសោះ ។ បើមិនអីចឹងទេ គឺពិតជាអាសន្នធំហើយ ។ បើសិនជាអញមិនបានឃើញ*តូរ៉ាណាកា* ទេនោះ រឿងរ៉ាវបែបវាងាយទេវិញទេ ។ អានេះហើយដែលគេហៅថា ស័យ ។ អារឿងបន្តិចបន្តួចសោះ តែអាចបំផ្លាញផែនការមួយ ដែលត្រូវបានរៀបចំយ៉ាងស្អាត និងអនុវត្តទៅយ៉ាងល្អបំផុតបាន ។ យាយចាស់ *គីរីស៊ូប៊ូ* ពិតជាសំដែងល្ខោនល្អមែន ។ នារីមួយដែលក្មេងនោះក៏មិនអន់ដែរ ។ អានេះបើកុំតែអញមិនដឹងថាតើ *គីរីស៊ូប៊ូ* ស្រែកពីរឿងអីកុំអីអញ ក៏ចាញ់ល្បិចនេះដូចគេដូចឯងទៅហើយ ។ ចំជាស័យមែនដែលអញមើលឃើញ *តូរ៉ាណាកា* យ៉ាងច្បាស់បែបនេះ ។ ទោះជា*តូរ៉ាណាកា* ពាក់សក់ លាបម្សៅ និងស្លៀកពាក់ដូចជា*គីរីស៊ូប៊ូ* ក្ដី តែ *តូរ៉ាណាកា* នៅតែជា *តូរ៉ាណាកា* ដដែល ។

នៅប៉ុសត្រួតពិនិត្យមួយទៀត បញ្ជាការប៉ុសបានដើរមកជិតស្លែងលើសពីអ្នកធម្មតា ប៉ុន្តែអ្នកបំរើទាំងពីរបានចេញទៅលំអោនខ្លួនគោរពបុរសនេះ ប៉ុន្តែទន្ទឹមនេះបានពាំងផ្លូវមិនអោយបុរសនេះខិតចូលទៅជិតស្លែងពេកផង ។ បញ្ជាការនេះក៏សំលឹងពិនិត្យពិច័យ *ធ្លាក់ផន*



www.budinst.gov.kh www.elibraryofcambodia.org

[illegible] ហើយ[illegible]ចេញទៅនិយាយជាមួយ *មារីកូ* ១គ្រវីក្បាលហើយឆ្លើយតបវិញ ។ នៅទីបញ្ចប់ បុរសនោះនិយាយរញ៉ាំរញ៉ូវបណ្ដើរ ដើរទៅរក *យ៉ាប៊ូ* ឯក្បាលក្បួនបណ្ដើរ ។ ទៅដល់ហើយគេក៏ហុចសំបុត្រស្នាមទៅ *យ៉ាប៊ូ* ហើយធ្វើសញ្ញាអនុញ្ញាតអោយក្បួនចេញដំណើរបន្តទៅទៀត ។

*ប្លាក់ថន* ក៏សួរទៅ *មារីកូ* :

- តើអាគាត់នោះនិយាយអ្វីខ្លះ ?

- គាត់ឆ្ងល់ថាលោកមកពីណា ? ផ្ទះលោកនៅឯណា ?

- ប៉ុន្តែអ្នកស្រីគ្រវីក្បាល អានេះមិនមែនជាចំលើយឯណា ?

- ចាសសូមទោស ! គាត់នោះចង់ដឹងថា តើជីដូនជីតាសាច់ញាតិលោកមានទាក់ទងនឹងពួកបិសាច ពួក *កាមី* ដែលរស់នៅជាយដែនខាងជើងស្រុកចិននោះរឺក៏អត់ ។ តាំងពីដើមរហូតដល់ពេលថ្មី១នេះ យើងតែងគិតថា ក្រៅពីចក្រភពជប៉ុនមានតែស្រុកចិនមួយទៀតប៉ុណ្ណោះដែលជានគរអារ្យធម៌ ។ ស្រុកចិនគឺធំធេងណាស់ប្រៀបដូចជាពិភពលោកអ៊ីចឹង ។

រួច *មារីកូ* ក៏បញ្ចប់ឃ្លាត្រឹមនេះ ។ តាមពិតបញ្ជាការប៉ុសបានសួរនាងថា តើ *ប្លាក់ថន* មានពូជអំបូរបន្តពី *ហារិមភាំកៃរី* ដែលជាកាមីទទួលចិញ្ចឹមថៃទាំឆ្មានោះរឺក៏អត់ ។ នាងក៏បានឆ្លើយថា មិនមែនទេ ប៉ុន្តែនៅក្នុងចិត្តនាងសែនរង្កៀសចិត្តនឹងភាពច្រលើសបើសរបស់បញ្ជាការនេះ ដោយហេតុថាប្លាក់ថនមិនធុំក្លិនអាក្រក់ដូចជា *ឈូតូ-សាន* រឺគណៈអធិការសង្ឃរីពួកចុងស្រុកឯទៀត ១នោះឡើយ ។ អីលូវនេះក្លិនគេស្រាលជាងមុនឆ្ងាយណាស់ ។

*ប្លាក់ថន* ក៏ដឹងថា *មារីកូ* មិននិយាយប្រាប់គេតាមត្រង់ដែរ ។អញបន់អោយតែចេះភាសាក្លែមល្បោយរបស់ពួកវាទេ-គេគិតនៅក្នុងចិត្ត-ហើយបើល្អបំផុតបន់អោយតែអញបានឡើងលើសំពៅអេរ៉ាសមរបស់អញ មានស្រា មានគ្រាប់ មានរំសេវ ជូញដូរអីវ៉ាន់អីវ៉ាន់របស់អញ ហើយចេញផុតពីអាស្រុកចម្លែងនេះត្រលប់ទៅស្រុកអញវិញតែប៉ុណ្ណោះ ។ តើអង្កាល់ទៅ ទើបរឿងនេះក្លាយទៅជាការពិត ? *តូរ៉ាណាកា* ថាបន្តិចទៀត ។ តើជឿអាតាត់ណឹងបានទេ ? តើវាធ្វើម៉េចទើបនាំសំពៅទៅយេដូបាន ? តើសណ្ដោងអ្វី ? រឺមួយក៏ពួកប៉ុកទុយកាល់បើក ? រួច *រ៉ូឌ្រីក*



www.budinst.gov.kh www.elibraryofcambodia.org

វាយ៉ាងម៉េចទៅហើយអីចេះ ? តើជើងវារលេះរលួយរឺអត់ ? ដល់ពេលនេះវាអាចដឹងបានថា តើវាអាចរស់នៅដោយមានជើងពីរ រឺជើងមួយ រឺមួយក៏ត្រូវស្លាប់ ។ ឱ ព្រះអើយព្រះ ជួយខ្ញុំយ៉ាងម៉េចយ៉ាងម៉ាកុំអោយមានរបួស និងអោយគេចផុតពីដៃពួកពេទ្យទៅចុះ ! ហើយនិងពួកបព្វជិតផង !

កន្លែងប៉ុសត្រួតពិនិត្យមួយទៀត ។ *ប្លាក់ថន* សែនឆ្ងល់ថា ហេតុយ៉ាងម៉េចបានជាម្នាក់ៗចេះនៅរក្សាបានភាពគួរសម និងភាពអត់ធ្មត់ ចេះលំអោនខ្លួនដាក់គ្នាទៅវិញទៅមកហុចសំបុត្រស្នាមចុះឡើងៗទាំងញញឹម គ្មានសញ្ញាអ្វីបញ្ជាក់ថា ពួកគេមានអរិភាពនឹងគ្នាសោះអីចឹង ? ពួកនេះចំជាខុសឆ្ងាយពីពួកយើងមែន ។ *ប្លាក់ថន* ចោលភ្នែកសំលឹងមើលមុខរបស់ *ម៉ារីកូ* ដែលលេចចេញតាមចន្លោះស្បៃមូករបស់នាង ។ គេគិតថានាងមានរូបសម្បត្តិស្អាតណាស់ហើយគេក៏ពេញចិត្តណាស់ដែរ ដែលបានដោះស្រាយរឿង ដែលនាងភាន់ច្រលំកាលពីព្រឹកមិញនោះ ។ ក្រោយពីយល់ព្រមទទួលការសូមទោសរបស់ *ម៉ារីកូ*ហើយ *ប្លាក់ថន* ក៏បានសួរនាងពីរឿង *យេដូ* ពីទំនៀមទំលាប់ជប៉ុនពី *អ៊ីស៊ីដូ* និងពីវិមាននេះ ។ គេបានចៀសវាងមិននិយាយពីរឿងដំណេកឡើយ ។ អ្វីដែលគេបានសួរ *ម៉ារីកូ* បាននិយាយយ៉ាងក្បោះក្បាយពន្យល់ ប៉ុន្តែនាងក៏បានចៀសវាងមិននិយាយពីរឿងអ្វី ដែលទាក់ទងដល់នយោបាយឡើយ ពោលគឺជាចំលើយផ្តល់ពត៌មានគ្រប់គ្រាន់តែស្អាតចែស ។ បន្ទាប់មកទៀត *ម៉ារីកូ* និងនារីអ្នកបំរើ ក៏បានចេញទៅរៀបចំខ្លួនចេញដំណើរ ដោយទុកតែ *ប្លាក់ថន* នៅជាមួយពួកកងការពារនេះទៅ ។

ប្រការដែលមានគេនៅជិតខ្លួនរាល់ពេលវេលាយ៉ាងនេះ ធ្វើអោយ *ប្លាក់ថន* សែនមួម៉ៅបំផុត ។ គិតទៅពេលណាក៏មានមនុស្សនៅក្បែរដែររឺ ! - *ប្លាក់ថន* គិតនៅក្នុងចិត្ត - ពួកវាដូចជាច្រើនហួស មើលតែស្រមោចទៅហើយ ។ ធ្វើម៉េចបានទ្វារមួយមានសោចាក់គ្រាន់តែបានស្ងប់ចិត្តម្តង ។ តែសោនៅខាងអញ មិនមែននៅខាងពួកនោះទេ ។

អីលូវនេះនៅពេលដែលដើរកាត់វិមានអូសាកាទើបគេចាប់ភ្លឹកថា គេនឹងទទួល *តូរ៉ាណាកា*នៅក្នុងអាណាចក្ររបស់គេតែម្តង ។ នោះគឺសមុទ្រ ហើយខ្លួនគេផ្ទាល់គឺជាព្រះរាជា ។



www.budinst.gov.kh www.elibraryofcambodia.org

យើងមានពេលច្រើន ដើម្បីនិយាយគ្នា *មារីកូ*នឹងជួយបកប្រែ ហើយអ៊ីៗ នឹងត្រូវដោះស្រាយជ្រះស្រលះជាមិនខាន ។ នោះគឺកិច្ចព្រមព្រៀងពាណិជ្ជកម្ម រឿងសំពៅ ការសងប្រាក់មកអោយយើងវិញ ហើយបើ*តូរ៉ាណាកា* ចង់គាត់ក៏អាចទិញកាំភ្លើងនិងរំសេវក៏បាន ។ អញអាចធ្វើការសំរុះសំរួល ដើម្បីឆ្នាំក្រោយអញអាចដឹកសូតម៉ាសំពៅមកក៏បាន ។ បញ្ជិត*ដូមិញូកូ* ស្លាប់យ៉ាងវេទនាមែន តែអញនឹងប្រើអោយបានល្អបំផុតនូវពតិមានដែលគាត់បានផ្តល់អោយអញនេះ ។ បើអញបានសំពៅអេរ៉ាសអញមកវិញអញនឹងបើកវាឡើងដល់កង់តុង ដោយកំទេចចោលអោយអស់របាំងរបស់ពួកប៉កទុយកាល់និងពួកចិន ។ អោយតែសងសំពៅអញមកវិញ អញនឹងក្លាយជាអ្នកមានភ្លាម ។ មានជាងអាតាប៉ិ *វេជក* ផង ។ ពេលអញត្រលប់ទៅស្រុកវិញ អញដើរប្រមូលពួកដើរសំពៅជើងចាស់ទាំងអស់ដើម្បីមកក្តាប់ជំនួញនៅទូទាំងអាស៊ីនេះតែម្តង ។ បើគ្មានសូតម៉ាការនឹងដាច់ខ្យល់ស្លាប់ភ្លាម ។ បើគ្មានម៉ាការ ម៉ាឡាកាក៏ងាប់ រួចដល់វេនកូវ៉ាម្តង ។ ដល់ពេលនោះពួកយើងអាចមួរចក្រភពប៉កទុយកាល់ដូចមួរកំភាលអ៊ីចឹង ។

រួចគេឆ្លងកាត់ប៉ុសត្រួតពិនិត្យមួយទៀត រួចទើបបត់តាមផ្លូវកែងមួយ ។ នៅពីមុខពួកគេ គឺរនាំងដែកចុងក្រោយនិងទ្វារចុងក្រោយនៃវិមាន ។ ផុតពីនេះទៅ គឺស្នាមបើកបិទចុងក្រោយនិងស្នាមភ្លោះចុងក្រោយ ។ ចន្លុះរាប់សិប ដែលនៅពីមុខក្បួនបានធ្វើអោយរាត្រីនេះប្រែជាក្រហមដាស ។

រួច*អ៊ីស៊ីដូ*ក៏ដើរចេញមកពីក្នុងទីងងឹតមួយ ។

ពួកអាវត្នោតក្រលេកឃើញ*អ៊ីស៊ីដូ* ព្រមៗគ្នាតែម្តង ។ ចរន្តអរិភាពបានរត់កាត់ពួកគេទាំងអស់គ្នាភ្លាមមួយរំពេច ។ *ប៊ុនតារ៉ូ* ស្ទុះយ៉ាងប្រញាប់ប្រញាល់ទៅឯក្បាលក្បួន ។ *ប្លាក់ថន* រអ៊ូឡើង :

- អាកូនមីចោរអត់ពូជនេះ រមាស់ដៃចង់តែកាប់ភ្លាតែម្រ៉ង !

- សូមទោស ! លោកនិយាយថាម៉េច ?

-អឺ...ខ្ញុំនិយាយថា...ប្តីអ្នកស្រីចង់តែ...គឺថា...*អ៊ីស៊ីដូ*ធ្វើអោយប្តីអ្នកស្រីនេះជុំតែម្តង ។

*មារីកូ* ឥតមានឆ្លើយតបឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

យ៉ាប៊ូធ្វើសញ្ញាបញ្ឈប់ក្បួន ហើយហុចលិខិតបើកផ្លូវបែបវាហើទៅបញ្ជាការប្រចាំច្រកទ្វារ រួចទើបដើរសំដៅទៅ *អ៊ីស៊ីដូ* :

- ខ្ញុំមិននឹកស្មានថា ជួបលោកនៅកន្លែងនេះទៀតសោះ ។ ឆ្នាំរបស់លោកស្ថិតណាស់ ។

- សូមអរគុណ ។

ឆ្លើយបណ្តើរ ភ្នែក *អ៊ីស៊ីដូ* សំលឹងមើលមុខ *ប៊ុនតារ៉ូ* ហើយនិងស្នែងបិទជិតដែលនៅពីក្រោយ *ប៊ុនតារ៉ូ* បណ្តើរ ។

- រែកនេះតែម្តងនោះ គឺគ្រប់គ្រាន់-*ប៊ុនតារ៉ូ* និយាយ-ពីរដង គឺវាណាស់ទៅហើយ ។ តើពេលនេះវាយ៉ាងម៉េច ? ពេលសង្គ្រាមអ្វី ? ធ្វើរបៀបនេះគឺប្រមាថមែនទែនតែម្តង ។

- នេះមិនមែនក្នុងបំនងប្រមាថកាតទានអ្វីទេ *ប៊ុនតារ៉ូ-សាន* ។ តែដោយសាររឿងឃាតកនោះហើយ ទើបខ្ញុំបញ្ជាអោយពង្រឹងសន្តិសុខថែមទៀត ។

*អ៊ីស៊ីដូ* សំលឹងមើល *ប្លាក់ថន* មួយខ្ទាច់ ដោយក្នុងចិត្តលោកកំពុងដណ្តឹងសួរថា តើលោកគួរអោយមនុស្សនេះចេញពីវិមាន រឺឃាត់វាទុកតាមការទាមទាររបស់ *អូណូស៊ី* និង *គីយ៉ាមា* ? រួចលោកសំលឹងមើលទៅ *ប៊ុនតារ៉ូ* ម្តងទៀត ។ អាអាច់ !-*អ៊ីស៊ីដូ* គិតនៅក្នុងចិត្ត - ក្បាលអ្នែងច្បាស់ជាបាននៅលើឈើអណ្តោតបន្តិចទៀតហើយ ។ រួចចុះវាយ៉ាងម៉េចបានជាស្រីល្អស្អាតច្រលឹងដូច *មារីកូ* នេះសុខចិត្តនៅធ្វើជាប្រពន្ធអាមនុស្សដូចស្វាបែបអ្នែងយ៉ាងនេះ ?

បញ្ជាការថ្មីពិនិត្យយ៉ាងម៉ត់ចត់អ្នកអមដំណើរដើម្បីច្បាស់ថាតើវាស៊ីគ្នានឹងសំបុត្របើក ផ្លូវរឺទេ ក្រោយពីចប់សព្វគ្រប់ហើយ បុរសនេះក៏ដើរទៅក្បាលក្បួន ហើយនិយាយឡើង :

-អ្វីៗបានរៀបរយហើយ *យ៉ាប៊ូ-សាមា* ។ លោកមិនចាំបាច់ត្រូវការលិខិតបើកផ្លូវនេះទេ ពួកយើងទុកវានៅទីនេះហើយ ។

- បាទ !

រួច *យ៉ាប៊ូងាក* ទៅរក *អ៊ីស៊ីដូ* :

- ចាំក្រោយជួបគ្នា !

*អ៊ីស៊ីដូ* ដកហ្វតសារមួយរមូរចេញពីក្នុងដៃអាវរបស់ខ្លួនបណ្តើរ និយាយឡើងបណ្តើរ:



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំចង់ស្នើជំទាវ *គីរីស៊ូប៊ូ* សូមអោយលោកជំទាវយកសារនេះទៅយេដូផងបានទេ ? គឺយកទៅអោយក្មួយស្រីរបស់ខ្ញុំ ដោយហេតុថា ខ្ញុំមិនទាន់ងាយបានទៅយេដូទេ ។

- បាទបាន !

រួច *យ៉ាប៊ូ* ហុចដៃទៅទទួលយកសារ ប៉ុន្តែ *អ៊ីស៊ីដូ* គ្រវីក្បាល :

- លោកមិនបាច់ខ្វល់ទេ យ៉ាប៊ូ-សាន ។ ខ្ញុំនឹងទៅសួរលោកជំទាវខ្លួនខ្ញុំក៏បានដែរ ។

រួច *អ៊ីស៊ីដូ* ក៏ដើរតំរង់ទៅរកស្លែងតែម្តង ។ នារីអ្នកបំរើទាំងពីរសំដែងការគួរសមពាំងចំពីមុខស្លែង ។ *អាសា* លើកដៃឡើង :

- សូមលោកម្ចាស់ប្រគល់សារមកនាងខ្ញុំចាស ! ម្ចាស់ស្រីខ្ញុំ...

- ទេ !

ទាំង *អ៊ីស៊ីដូ* ទាំងអ្នកឯទៀតដែលនៅជុំវិញ ពួកគេសែនចំលែកចិត្តដោយឃើញនារីអ្នកបំរើទាំងពីរនៅតែឈរពាំងពីមុខស្លែងដដែល ។

- តែគឺម្ចាស់ស្រី បាន...

*អ៊ីស៊ីដូ* ស្រែកបញ្ជាឡើង :

- ចៀសចេញ !

នារីអ្នកបំរើទាំងពីរដកខ្លួនថយទាំងញ័រចំប្រប់ ។

*អ៊ីស៊ីដូ* លំអោនខ្លួនគោរពស្លែងដែលនៅតែបិទជិតនៅឡើយ :

-*គីរីស៊ូប៊ូ-សាន* ។ តើលោកជំទាវអាចនាំយកសាររបស់ខ្ញុំទៅយេដូផងបានទេ ? ទៅក្មួយស្រីរបស់ខ្ញុំបាទ ។

រវាងភាពខ្សឹកខ្សួល ហើយនិងស្រមោលដែលងក់ក្បាលយល់ព្រមនោះ ហាក់បីដូចជាមានភាពទីទើមួយរយៈផងដែរ ។

- សូមអរគុណបាទ ។

និយាយចប់ *អ៊ីស៊ីដូ* ហុចសារទៅជិតដល់រនាំងដែលបិទស្លែងតែម្តង ។

ស្នូរខ្សឹកខ្សួលចប់ភ្លាមមួយរំពេច ។ មកដល់ពេលនេះទើប *ព្លាក់ថន* ដឹងថា *តូរ៉ាណាកា*



www.budinst.gov.kh www.elibraryofcambodia.org

ជាប់អន្ទាក់ហើយ ។ ការគួរសមតំរូវអោយ *តូរ៉ាណាកា* ទទួលយកសារដោយផ្ទាល់ដៃ ហើយនៅពេលនោះដៃនេះនឹងប្រាប់ការពិតជាមិនខាន ។

ទាំងអស់គ្នារង់ចាំដៃដែលនឹងលូកចេញមក ។

- *គីរីស៊ុប្ញ-សាន ?*

គ្មានចលនាអ្វីទាំងអស់ ។ *អ៊ីស៊ីដូ* ក៏បោះជំហានទៅមុខ ហើយកៀសរនាំងចេញ ។ ទន្ទឹមគ្នានេះ *ប្លាក់ថន* ក៏ស្រែករោទិ៍ឡើង ហើយរាំកញ្ឆក់កញ្ឆែងហាក់បីដូចជាមនុស្សឆ្កួត ធ្វើអោយទាំង *អ៊ីស៊ីដូ* ទាំងអ្នកឯទៀតងាកបែរមើលទៅរូបគេទាំងភាន់ភាំង ។

ក្នុងមួយប៉ប្រិចភ្នែកនោះ មុខរបស់ *តូរ៉ាណាកា* ត្រូវបានបង្ហាញច្បាស់ពីក្រោយខ្នងរបស់ *អ៊ីស៊ីដូ* ។ *ប្លាក់ថននឹង* យ៉ាងច្បាស់ណាស់ថា ពីម្តេចជំហាន *តូរ៉ាណាកា* អាចបន្លំខ្លួនធ្វើជាជំទាវ *គីរីស៊ុប្ញ* បាន ប៉ុន្តែនៅតែប្រាំជំហានដូចពេលនេះ គឺពិតជាមិនកើតឡើយទោះជា *តូរ៉ាណាកា* ទំលាក់ស្បៃមូកយ៉ាងណាក៏ដោយ ។ ហើយនៅក្នុងមួយវិនាទីដ៏សែនយូរ មុនពេលដែល *តូរ៉ាណាកា* ទាញរនាំងបិទទៅវិញនោះ *ប្លាក់ថន* ដឹងថា *យ៉ាប៊ូ* បានមើលស្គាល់ *តូរ៉ាណាកា* *មារីកូ* ក៏ច្បាស់ជាឃើញដែរ ព្រមទាំង *ប៊ុនតារ៉ូ* និងពួកសាមូរ៉ៃមួយចំនួនក៏ប្រហែលជាអាចមើលស្គាល់ដែរហើយ ។ គេបោះជំហានទៅមុខឆក់យកសារពីដៃ *អ៊ីស៊ីដូ* ហើយរុញចូលទៅក្នុងស្នែងតាមប្រលោះរនាំង រួចទើបងាកមកនិយាយទាំងតតាក់តតុបថា :

-នៅក្នុងនគររបស់ខ្ញុំ គឺជាការចង្រៃធំណាស់ដែលត្រកូលព្រះមហាក្សត្រជូនសារដោយផ្ទាល់ដៃដូចជាមនុស្សអារាត់អារាយនោះ...ចង្រៃណាស់ ...

ទាំងអស់នេះបានកើតឡើងយ៉ាងរហ័ស និងយ៉ាងចៃដន្យ ទើបដាវរបស់ *អ៊ីស៊ីដូ* ឥតមានកំរើកបន្តិច ។ រហូតដល់ពេលដែល *ប្លាក់ថន* លុំអោនខ្លួន ហើយបន្តលោតវក់វីប្រៀបដូចជាខ្មោចចូល ទើបខួរក្បាលរបស់លោកចាប់ផ្តើមធ្វើការឡើងវិញ ហើយផ្លែដាវត្រូវបានដកហូតចេញពីស្រោម ហើយវាត់យ៉ាងរហ័សតំរង់ទៅរកបំពង់ករបស់ *ប្លាក់ថន* ។

ក្រសែភ្នែកអស់សង្ឃឹមរបស់ *ប្លាក់ថន* បានប៉ះប្រទះនឹងក្រសែភ្នែក *មារីកូ* :

- ព្រះអើយជួយខ្ញុំផង ! ចង្រៃណាស់ ! ចង្រៃណាស់ !



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* ស្រែករ៉ាសឡើង ។ ផ្លែដាវឈប់ង៉ិក់នៅត្រឹមមួយសរសៃសក់ពីបំពង់ករបស់ *ប្លាក់ថន* ។ *ម៉ារីកូ* ស្ទុះចេញពីក្នុងស្នែង ហើយក៏ចាប់ផ្តើមនិយាយពន្យល់ *អ៊ីស៊ីដូ* ពីសំដីដែល *ប្លាក់ថន* បាននិយាយអំបាញ់មិញ ។ *អ៊ីស៊ីដូ* ទំលាក់ដាវរបស់ខ្លួនចុះបន្តិចស្តាប់ការពន្យល់មួយស្របក់ ហើយក៏ស្រែកសន្ធាប់ដាក់ម៉ារីកូ ទាំងកំហឹង រួចទះប្លាក់ថនមួយកំផ្លៀងលាន់សូរផាំង ។

កំហឹងរបស់ *ប្លាក់ថន* ពេលនេះ មិនខុសអ្វីពីភ្លើងដែលផ្ទុះចេញមកឡើយ ។ គេក្តាប់កណ្តាប់ដៃដ៏ធំមាំរបស់ខ្លួន ហើយស្ទុះទៅរក *អ៊ីស៊ីដូ* ភ្លាម ។

ក្នុងនាទីពេលនោះ បើសិនជា *យ៉ាប៊ូ* មិនរហ័សចាប់ដៃរបស់ *អ៊ីស៊ីដូ* ដែលកាន់ដាវនោះទេ ក្បាលរបស់ *ប្លាក់ថន* ពិតជារមៀលធ្លាក់ទៅលើដីបាត់ជាមិនខាន ។ មួយវិនាទីក្រោយមកទៀត *ប៊ុនតារ៉ូ* ក៏ហក់ទៅចាប់ *ប្លាក់ថន* ដែលកំពុងច្បាមបំពង់ករបស់ *អ៊ីស៊ីដូ* ប៉ុន្តែទាល់តែមានពួកអាវខ្មៅតបូននាក់ទៀតទើបគេអាចផ្តាច់ *ប្លាក់ថន* ចេញបាន ។ រួច *ប៊ុនតារ៉ូ* ក៏យារបាតដៃកាប់កញ្ជឹងក *ប្លាក់ថន* មួយផ្ទុងយ៉ាងខ្លាំង ធ្វើអោយរូបគេឡើងស្រងល់ភ្លាម ។ ពួកអាវប្រផេះក៏ស្ទុះឡើងមកខាងមុខ ដើម្បីការពារចៅហ្វាយរបស់ខ្លួន ប៉ុន្តែពួកអាវខ្មៅតបានព័ទ្ធ *ប្លាក់ថន* និងស្នែងជុំវិញហើយជាស្រេច ។ ទាំងសងខាងហាក់ដូចជានៅទ្រឹងនៅឡើយ ហើយសំរែកទាំងចេតនារបស់ *ម៉ារីកូ* និងនារីអ្នកបំរើទាំងពីររឹតតែនាំអោយមានភាពអល់អែក កាន់តែខ្លាំងឡើងថែមទៀត ។

*យ៉ាប៊ូ* ចាប់ផ្តើមនិយាយលួងលោម *អ៊ីស៊ីដូ* ។ *ម៉ារីកូ* និយាយពន្យល់សាចុះសាឡើងទាំងទឹកភ្នែក និងក្នុងអាការៈបែបស្លន់ស្លោថា អ្នកចុងស្រុកចំកួតនេះមានបំណងគ្រាន់តែចង់ជួយសង្គ្រោះ *អ៊ីស៊ីដូ* ដែលខ្លួនស្មានថាជាព្រះអង្គម្ចាស់នោះអោយផុតពីកាមីអាក្រក់តែប៉ុណ្ណោះ ។ រួចនាងពោលបន្ត :

- ពួកនេះដូចជាយើងដែរ ការទះកំផ្លៀង គឺជាការប្រមាថធ្ងន់ធ្ងរណាស់លោកម្ចាស់ ។ អ៊ីចឹងហើយទើបគេនេះឡើងដូចជ្រូកពុលអ៊ីចឹងនោះ ។ គាត់នេះជាអ្នកចុងស្រុក មិនសូវដឹងខ្យល់អីមែនលោកម្ចាស់ ប៉ុន្តែនៅស្រុករបស់គាត់ ៗ គឺជាដៃមីញ៉ូម្នាក់ដែរ ហើយគាត់គ្មានបំណងអ្វីក្រៅតែពីចង់ជួយលោកម្ចាស់តែប៉ុណ្ណោះ ។

*អ៊ីស៊ីដូ* និយាយឡូឡាបែកពពុះមាត់ ហើយទាត់ *ប្លាក់ថន* មួយជើងទៀត នៅពេល



www.budinst.gov.kh www.elibraryofcambodia.org

ដែល បុរសនោះដើរមករកខ្លួន ។ *ប្លាក់ថន* ស្តាប់ស្នូរចលនាទាំងនេះ ទាំងក្នុងអារម្មណ៍ស្ងប់ស្ងៀម ។ ភ្នែករបស់គេភ្លឺស្រលះពួកអាវប្រផេះ ដែលនៅជុំវិញពួកគេមានចំនួនលើសពួកអាវខ្មៅតម្លៃដង ។ ដាវទាំងអស់ត្រូវហូតចេញពីស្រោម ប៉ុន្តែក៏គ្មានអ្នកណាម្នាក់ស្លាប់នៅឡើយដែរ ពេលគឺ អ្នកទាំងអស់គ្នាកំពុងនៅរង់ចាំយ៉ាងមានវិន័យ ។

*ប្លាក់ថន* បានឃើញថា ទាំងអស់គ្នាសុទ្ធតែផ្តោតអារម្មណ៍មកលើរូបគេតែម្នាក់តែប៉ុណ្ណោះ ប៉ុន្តែពេលនេះគេដឹងថាគេមានសម្ព័ន្ធមិត្តហើយ ។

*អ៊ីស៊ីដូ* ស្រែកសន្ធាប់បណ្តើរ ដើរតំរង់មកកាន់តែជិត *ប្លាក់ថន* បណ្តើរ ។ ពួកអាវខ្មៅតក៏កាន់តែចូលមកកៀកផងដែរ ។ ប៉ុន្តែនៅពេលដែលកណ្តាប់ដៃ *អ៊ីស៊ីដូ* វាយមករកខ្លួនគេនោះ *ប្លាក់ថន* ឥតបានគេចដូចអ្នកផងគិតស្មាននោះឡើយ ។ គេទទួលយកកណ្តាប់ដៃនេះ ហើយដួលប្លូសទៅដីរួចក៏ងើបឡើងវិញជាបន្ទាន់ ។ គេដើរចេញបណ្តើរសើចកាច់កកាច់ស្រង់បណ្តើរ ដូចខ្មោចចូលបណ្តើរ ។ បន្ទាប់មកគេក៏ចាប់ផ្តើមរាំចង្វាក់ " ហានផៃប " ។ ព្រះតេជគុណ *ដូមិញ្ញូ* បាននិយាយប្រាប់គេថា ពួកជប៉ុនមានជំនឿថា ភាពចំកួតលេលាគឺត្រូវបង្កឡើងដោយកាមីដោយហេតុនេះមនុស្សឆ្កួតប្រៀបបីដូចជាកូនក្មេងនិងមនុស្សចាស់ជរាយ៉ាងដូច្នោះដែរ គឺគេមិនសូវប្រកាន់ទេ ហើយជួនកាលថែមទាំងគេផ្តល់អភ័យឯកសិទ្ធិមួយចំនួនណានោះទៀតផង ។ ដោយហេតុនេះគេចេះតែបន្តឡូករាំញាក់ទទ្រើកទទ្រើក ព្រមទាំងនិយាយទៅកាន់ *មារីកូ* ក្នុងលំនាំជាបទចំរៀងផង :

- ជួយផង...ខ្ញុំត្រូវការអោយជួយផង ព្រះម្ចាស់ថ្លៃអើយ...ខ្ញុំមិនអាចបន្តឆាកល្ខោនបែបនេះបានយូរទេ...ជួយផង...

មកដល់ពេលនេះ ទើប *មារីកូ* យល់បានពីល្បិចរបស់ *ប្លាក់ថន* ។ នាងស្រែកឡើង :

- គាត់ឆ្កួតហើយ ! គាត់ខ្មោចចូលហើយ !

- មែនហើយ ! មែនហើយ !

*យ៉ាប៊ូ* និយាយបន្ទរតាម ។ នៅក្នុងអារម្មណ៍របស់គេ ១ នៅមិនទាន់បាត់ស្រលាំងកាំងនឹងប្រការដែលគេប្រទះឃើញ *តូរ៉ាណាកា* នៅឡើយ ។ ពេលនេះទៀតសោត គេក៏មិនដឹងថា តើ



www.budinst.gov.kh www.elibraryofcambodia.org

*អាន់ជីន-សាន* ធ្វើជាឆ្កួតរឺឆ្កួតមែនទែននៅឡើយ ។

ចំពោះ *មារីកូ* នាងដូចជាឡប់សតិហើយព្រោះនាងមិនដឹងថា តើនាងត្រូវធ្វើយ៉ាងណា? *អាន់ជីន-សាន* បានជួយជីវិតលោកម្ចាស់ *តូរ៉ាណាកា* ប៉ុន្តែហេតុអីបានជាបុរសនេះដឹង ?

មុខរបស់ *ប្លាក់ថន* គ្មានឈាមមួយតំនក់ លើកលែងតែស្នាមកំផ្លៀងដែលនៅក្រហមជាំតែប៉ុណ្ណោះ ។គេចេះតែលោតរាំឥតឈប់ឈរដើម្បីរង់ចាំជំនួយ ប៉ុន្តែគ្មានជំនួយអ្វីមករំដោះគេពីក្នុងស្ថានភាពនេះសោះ នៅក្នុងពោះ *ប្លាក់ថន* ជេរប្រទេចទាំង *យ៉ាកូ* ទាំង *ប៊ុនតារ៉ូ* ដែលនៅឈរយ៉ាងកំសាក ហើយនិងបញ្ចោរទាំង *មារីកូ* ដែលល្ងាក់ល្ងើគ្មានយល់ការអ្វីទាំងអស់ ។ រួចគេក៏ឈប់លោតរាំ លំអោនខ្លួនគោរព រួចដើរផង រាំតិចៗផង សំដៅទៅច្រកទ្វារបន្ទាយវិមាន ដោយស្រែកឡើងថា :

- តាមខ្ញុំមក ! តាមខ្ញុំមក !

ពួកអាវប្រផេះរាំងផ្លូវ *ប្លាក់ថន* ជាប់ ។ គេធ្វើជាខឹងច្រលោត ហើយគ្រហឹមស្រែកសន្ធាប់អោយពួកទាំងនោះបើកផ្លូវអោយខ្លួន រួចក៏សើចកាច់កកាច់ស្រង់បន្តទៅទៀត ។

*អ៊ីស៊ីដូ* កញ្ឆក់យកធ្នូ និងព្រួញមកកាន់នៅនឹងដៃ ។ ពួកអាវប្រផេះដែលនៅរាំងផ្លូវនាំគ្នាចៀសចេញអស់ ហើយ *ប្លាក់ថន* ក៏បានទៅជិតខ្លោងទ្វារហើយដែរ ។ នៅទីនោះគេងាកក្រលប់ក្រោយទាំងអស់សង្ឃឹមដោយដឹងថា គេគ្មានកន្លែងណារត់គេចបានឡើយ ។ គេក៏ចាប់ផ្តើមរាំកញ្ឆក់កញ្ឆេងឡើងវិញ ។

*អ៊ីស៊ីដូ* យឺតធ្នូឡើង ។ សំដីលោកម៉ាត់ ១ :

- វាឆ្កួតហើយ ! វាជាឆ្កែឆ្កួត ។ ឆ្កែឆ្កួតត្រូវតែចាត់ការចោល !

ភ្លាមនោះ *មារីកូ* ស្ទុះចេញពីកន្លែងកៀកស្មែង *តូរ៉ាណាកា* តំរង់ទៅរកប្លាក់ថន :

- សូមលោកម្ចាស់ *អ៊ីស៊ីដូ* កុំព្រួយបារម្ភអីចាស ។ លោកម្ចាស់មិនបាច់ខ្វល់បារម្ភអ្វីទាំងអស់ នេះគឺគាត់គ្រាន់តែឆ្កួតមួយពេល ១ តែប៉ុណ្ណោះ ចាំនាងខ្ញុំ...

នៅពេលដែលនាងចូលកាន់តែជិតទើបនាងកាន់តែឃើញសភាពហេវហត់របស់ *ប្លាក់ថន* ហើយនិងស្នាមសើចដូចមនុស្សចំកួតពិត ១ ដែលធ្វើអោយរូបនាងស្រៀវឆ្អឹងខ្នងទាំង



www.budinst.gov.kh www.elibraryofcambodia.org

អចេតនា ។ នាងនិយាយទាំងរហ័ស :

- ខ្ញុំអាចជួយលោកបានហើយ *អាន់ជីន-សាន* ។ យើងត្រូវ...ត្រូវ...សាកដើរកាត់តាមខ្លោងទ្វារនេះ ។ ខ្ញុំនឹងដើរតាមពីក្រោយលោក ។ សូមលោកកុំបារម្ភអោយសោះ វាមិនបាញ់យើងទេ ។ អីលូវនេះលោកអាចឈប់លោតរាំបានហើយ ។

*ប្លាក់ថន* ឈប់រាំមួយរំពេច ហើយបែរខ្លួនដើរយ៉ាងស្ងៀមស្ងាត់ឆ្លងតាមស្ពាន ។ *មារីកូ* ដើរពីក្រោយមួយជំហាន ដោយគិតថា ព្រួញប្រាកដជានឹងត្រូវបាញ់មកជាមិនខាន ។

ភ្នែករាប់ពាន់កំពុងតាមសំលឹងយក្សចំកួត និងនារីទាបល្អិតដែលកំពុងដើរឆ្លងស្ពាន ។

មកដល់ពេលនេះទើប *យ៉ាប៊ូ* ភ្ញាក់អារម្មណ៍ឡើង :

- បើលោកចង់សំលាប់វា សូមលោកទុកអោយខ្ញុំចាត់ការវាចុះ *អ៊ីស៊ីដូ-សាមា* ។ ឋានៈរបស់លោកមិនសមនឹងរវល់លើកដៃសំលាប់វានោះទេ ។ មេទ័ពមិនចាំបាច់សំលាប់មនុស្សដោយដៃខ្លួនឯងទេ ។ ទុកអោយអ្នកផ្សេងធ្វើជំនួសចុះទាន ។

រួច *យ៉ាប៊ូ* ក៏ដើរមកជិត *អ៊ីស៊ីដូ* ហើយបន្ទាបសំលេង :

- ទុកជីវិតវាចុះទាន ។ វាឆ្កួតដោយសារលោកទះវាអំបាញ់មិញនេះតែប៉ុណ្ណោះ ។ នៅស្រុកវា ។ ក៏ជាដៃមីញ៉ូម្នាក់ដែរណា ។ ដល់លោកទះវាយ៉ាងនេះ ទើបវាឆ្កួតបណ្តោយទៅ ។ សូមលោកជឿខ្ញុំចុះ វានៅរស់មានប្រយោជន៍ដល់យើងច្រើនជាងវាស្លាប់ទាន ។

- ថាម៉េច ?

-វាមានតំលៃជាងពេលណាជីវិតវានៅគង់វង្ស ។ សូមលោកទុកចិត្តខ្ញុំចុះ ។ លោកចង់អោយវាស្លាប់ថ្ងៃណាក៏បានដែរ ។ តែពេលនេះយើងត្រូវការអោយវារស់ ។

នៅលើផ្ទៃមុខរបស់ *យ៉ាប៊ូ* *អ៊ីស៊ីដូ* ប្រទះឃើញនូវភាពអស់សង្ឃឹមនិងការពិត ។ លោកដាក់ធ្នូចុះវិញ ។

- ល្អ ។ ប៉ុន្តែនៅថ្ងៃណាមួយ ខ្ញុំចង់បានវាទាំងរស់ ។ ខ្ញុំចង់ព្យួរជើងវាពីលើអន្លង់ម្តង ។

*យ៉ាប៊ូ* លេបទឹកមាត់ក្អឹក ហើយលំអោនខ្លួនគោរពយ៉ាងស្រាល រួចទើបធ្វើសញ្ញាយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

រចលអោយក្បួនចេញដំណើរជាបន្ទាន់ ដោយខ្លាចអ៊ិស៊ិដូ នឹកឃើញពីរឿងស្នេងនិងពីជំទាវ " *គីរីស៊ូប៉ូ* " ។

*ប៊ុនកាវ៉ូ* ដោយធ្វើជាអាការៈគោរពផងនោះ ក៏ចាប់ផ្ដើមនាំពួកអាវក្ដោតចេញដំណើរភ្លាម ។ បុរសនេះឥតងឿងឆ្ងល់អ្វីនឹងប្រការដែលលេចរូប*តូរ៉ាណាកា* មកនៅក្នុងកណ្ដាលចំនោមពួកគេនេះឡើយ គេដឹងតែម្យ៉ាងថា *តូរ៉ាណាកា* លោកម្ចាស់របស់គេកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ហើយគ្មានអ្វីការពារទាំងអស់ ។ គេមើលឃើញ*អ៊ិស៊ិដូ* ឥតដកក្រសែភ្នែកចេញពី*មារីកូ* និង*អាន់ជីន-សាន* សោះឡើយ ។ ទោះជាយ៉ាងនេះក្ដី ក៏គេនៅតែលំអោនខ្លួនគោរព*អ៊ិស៊ិដូ* ម្ដងទៀតជាការគួរសម ហើយដើរកិតពីក្រោយស្នេងរបស់*តូរ៉ាណាកា* ដើម្បីការពារក្រែងមានព្រួញណាបាញ់ពីក្រោយទៅលើលោកម្ចាស់របស់គេ នៅពេលណាដែលការប្រយុទ្ធផ្ទុះឡើងនោះ ។

ក្បួនកាន់តែខិតទៅជិតដល់ខ្លោងទ្វារហើយ ។ *យ៉ាប៊ូ* ដឹកនាំកងការពារបិទកន្ទុយក្បួនវិញម្ដង ។ ក្នុងគ្រប់វិនាទី គេរំពឹងថាក្បួននឹងត្រូវបញ្ឈប់ជាមិនខាន ។ ព្រោះគេគិតថា វាមិនលែងអីដែលពួកអាវប្រផេះខ្លះអាចប្រទះភ្នែកឃើញ*តូរ៉ាណាកា* ឡើយ ។ តើពួកវានឹងប្រាប់*អ៊ិស៊ិដូ* នៅពេលណា ? តើ*អ៊ិស៊ិដូ* នឹងគិតថាអញជាអ្នករួមគំនិតនៅក្នុងការលបគេចនេះទេ ? តើប្រការនេះនឹងធ្វើអោយគំរោងការអញរលត់រលាយវិទេ ?

នៅពេលឆ្លងស្ពានបានពាក់កណ្ដាលហើយ *មារីកូ* ក៏ងាកបែរទៅក្រោយមួយភ្លែត :

- ពួកគេមកតាមយើងហើយ*អាន់ជីន-សាន* ។ ពួកគេឆ្លងផុតខ្លោងទ្វារហើយ ១កំពុងដើរតាមស្ពានមកហើយ ។ ទាំងក្បួន ទាំងស្នេង ។

*ប្លាក់ថន* ឥតឆ្លើយ រឺងាកមើលទៅក្រោយឡើយ ។ គេត្រូវប្រើអស់កំលាំង កាយចិត្តដើម្បីនៅឈរលើជើងទាំងពីររបស់ខ្លួនបាន ។ ស្បែកជើងរបស់គេរបូតបាត់ ។ មុខគេឡើងក្ដៅដោយស្នាមម្រាមដៃ ក្បាលគេឈឺស្ទើរបែក ។ កងល្បាតចុងក្រោយបានបណ្ដោយអោយគេដើរឆ្លងរនាំងដែកដោយឥតសួរនាំអ្វីទាំងអស់ ។ ពួកគេក៏អត់ឃាត់ដំណើរ*មារីកូ* ដែរ ។ ហើយទាំង ក្បួនទាំងស្នេងក៏បានចេញផុតពីកំផែងវិមានអូសាកា ។

*ប្លាក់ថន* ដើរនាំមុខចុះតាមកូនភ្នំ ឆ្លងកាត់វាលមួយហើយឆ្លងកាត់ស្ពានមួយទៀតដែលនៅឆ្ងាយពីវិមាន ។ នៅពេលដែលគេមកដល់តំបន់មានព្រៃឈើកំបាំងបាត់ពីវិមានហើយនោះគេក៏ដួលសន្លប់បាត់ស្មារតីមួយរំពេច ។



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២៣

*អាន់ជីន-សាន* ! *អាន់ជីន-សាន* !

*ប្លាក់ថន* គ្រេបស្រាសាកេចិប ១ ដែល *មារីកូ* បញ្ជូកគេទាំងនៅរវើរវាយនៅឡើយ ។ ក្បួនដំណើរនៅឈប់ស្ងៀមកណ្តាលផ្លូវ ដោយមានពួកអាវខ្មៅតនៅឈរព័ទ្ធយ៉ាងណែនណាន់តាន់ តាប់ជុំវិញស្នែងចាំងរនាំងជិត ។ ពួកអាវប្រផេះដែលជូនដំណើរក្បួននោះនៅឈរពីខាងមុខ និងពីខាងក្រោយក្បួន ។ ក្រោយពីបានបញ្ជាយ៉ាងតឹងរឹងដល់កងការពាររបស់ខ្លួនមិនអោយអ្នកណាម្នាក់ចូលជិតស្នែងរបស់ " ជំទាវ *គីរីស៊ូបូ-សាន* " មក *ប៊ុនតារ៉ូ* ក៏ប្រញាប់ប្រញាល់ដើរទៅជិត *មារីកូ* :

- ម៉េចទៅ *អាន់ជីន-សាន* ? មិនអីទេអ្ហី ។

- ចាស ! ចាស ! ខ្ញុំមើលទៅប្រហែលជាមិនអីទេ ។

ដើម្បីដោះដៃចេញពីពួកអាវប្រផេះ *យ៉ាប៊ូ* ដែលទើបមកក្បែរ *ប្លាក់ថន* ដែរនោះ ក៏និយាយបែបវាហ៊ីទៅកាន់មេបញ្ជាកាពួកអាវប្រផេះឡើង :

- យើងអាចបន្តដំណើរទៅទៀតបានហើយលោកមេបញ្ជាការ ។ យើងទុកមនុស្សខ្លះអោយនៅជាមួយ *មារីកូ* ចុះ ហើយនៅពេលណាដែលមនុស្សចុងស្រុកនេះបានស្រួលបួលហើយ ពួកគេអាចទៅតាមក្រោយយើងបានហើយ ! ។

- លោកសូមអធ្យាស្រ័យផងចុះ *យ៉ាប៊ូ-សាន* ។ ពួកយើងត្រូវតែរង់ចាំ ។ ខ្ញុំមានភារកិច្ចជូនដំណើរអស់លោកទៅដល់ទូកធំដោយសុវត្ថិភាព ។ ហេតុនេះទើរនៅត្រូវតែជាមួយគ្នាទាន ។

ទាំងអស់គ្នាចោលភ្នែកសំលឹងទៅ *ប្លាក់ថន* ដែលឈ្លក់នឹងស្រាសាកេ ហើយដែលនិយាយទាំងស្អក ១ ទៅកាន់ *មារីកូ* :

- ពួកយើងរួចខ្លួនហើយអ្ហី ? មានអ្នកខ្លះដែលដឹងថា ...

- អីលូវនេះពួកយើងឥតមានបញ្ហាអ្វីទៀតទេ ។



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* ឆ្លើយកាត់សំដីប្លាក់ថនទាំងចេតនា ។ នាងអង្គុយជិត *ប្លាក់ថន* ដោយបែរខ្នងទៅរកមេបញ្ជាការពួកអាវប្រផេះ ។ នាងនិយាយបន្តបណ្តើរ ធ្វើភ្នែកជាសញ្ញាប្រាប់ *ប្លាក់ថន* អោយប្រុងប្រយ័ត្នខ្លួនបណ្តើរ :

- លោកបានសុខស្រួលហើយ *អាន់ជីន-សាន* ។ លោកមិនបាច់ខ្វល់បារម្ភពីអ្វីទាំងអស់ ។ លោកយល់ហើយរឺនៅ ? អំបាញ់មិញនេះរោគចាស់របស់លោករើឡើងវិញតែប៉ុណ្ណោះ ។ អីលូវនេះលោកមើលជុំវិញខ្លួនលោកទៅមើល ។ លោកបានសុខស្រួលហើយនៅពេលនេះ ។

*ប្លាក់ថន* ចោលភ្នែកក្រលេកឃើញមេបញ្ជាការ និងកងទ័ពអាវប្រផេះរបស់ *អ៊ីស៊ីម៉ូ* ក៏យល់ពីស្ថានភាពភ្លាម ។ គេធ្វើតាមអ្វីដែល *ម៉ារីកូ* ប្រាប់គេ ហើយអាស្រ័យដោយមានស្រាជាជំនួយផង កំលាំងកំហែងរបស់គេបានម្រមូលផ្តុំមកវិញយ៉ាងរហ័ស ។ គេនិយាយទៅកាន់ *ម៉ារីកូ*:

- សូមអ្នកស្រីអភ័យទោស ។ ខ្ញុំគិតថា អំបាញ់មិញខ្ញុំស្លន់ស្លោពេក ។ ប្រហែលខ្ញុំកាន់តែអាយុច្រើនហើយ ។ ខ្ញុំឧស្សាហ៍ឡប់ណាស់ ហើយរួចទៅ ខ្ញុំអត់មានចាំអីតែទាំងអស់ហ្នឹង ។ ម្យ៉ាងទៀតនិយាយភាសាប៉ិកទុយកាល់ គឺចំជាហត់នឿយមែនទែន ។

រួច *ប្លាក់ថន* និយាយឡាតាំងម្តង :

- អ្នកស្រីយល់ទេ ?

- ចាស់ យល់ច្បាស់ណាស់ ។

- ភាសានេះ " ងាយ " ទេ ?

- ប្រហែលដែរ ។

*ម៉ារីកូ* ចាប់ផ្តើមធូរស្រាលនៅក្នុងចិត្តឡើងវិញ នៅពេលឃើញថា *ប្លាក់ថន* យល់ពីតំរូវការនៃការប្រុងប្រយ័ត្ន រហូតដល់និយាយភាសាឡាតាំង ដែលជាភាសាមួយដ៏សែនលំបាកចំពោះជនជាតិជប៉ុន ។ អាចនិយាយថា ក្នុងមួយចក្រភពនេះមានជនជាតិជប៉ុនតែប៉ុន្មាននាក់ប៉ុណ្ណោះដែលចេះភាសាឡាតាំងនេះ ហើយពួកអ្នកទាំងនោះ គឺជាអ្នកដែលពួក *យេស៊ុិត* បង្រៀន និងភាគច្រើនជាអ្នកដែលបានថ្វាយខ្លួនដល់ព្រះជាម្ចាស់ទៀតផង ។ នាងគឺជានារីម្នាក់គត់នៅក្នុងចក្រភពនេះដែលអាចនិយាយ អាន និងសរសេរភាសាឡាតាំង និងប៉ិកទុយកាល់បាន ។



www.budinst.gov.kh www.elibraryofcambodia.org

*មារីកូ* និយាយបន្ត :

- ភាសាទាំងពីរនេះពិបាកដូចគ្នា ហើយសុទ្ធតែមានគ្រោះថ្នាក់ដូចគ្នា ។

- អ្នកណាខ្លះដឹងរឿង " គ្រោះថ្នាក់ " នេះ ?

- ប្តីខ្ញុំ និងម្នាក់ដែលជូនដំណើរពួកយើងនេះ ។

- អ្នកស្រីច្បាស់ហើយណឹង ?

- ពួកអ្នកទាំងពីរនេះបានបង្ហាញអោយដឹងហើយទេតើ ។

មេបញ្ជាការពួកអាវប្រផេះឈរច្រាស់ច្រាល់ រួចនិយាយទៅកាន់ *មារីកូ* ។

- បុរសនេះសួរថា តើលោកជាមនុស្សមានគ្រោះថ្នាក់ទេ ហើយនឹងថាតើគួរចងដៃចងជើងលោកវឺអត់ ។ ខ្ញុំបានប្រាប់ទៅវិញថា មិនអីទេ ព្រោះលោកបានជាវិញហើយ ។

*ប្លាក់ថន* បកទៅនិយាយភាសាប៉កទុយកាលវិញ :

- ពិតហើយ ។ ខ្ញុំតែងវើដំងឺនេះញឹកញាប់ ។ បើមានអ្នកណាវើមុខខ្ញុំ ១ ឡប់ភ្លាម ។ ខ្ញុំសូមទោស ។ ពេលឡប់ម្តង១ ខ្ញុំឥតចាំអីទាំងអស់ ហើយក៏មិនដឹងថាខ្លួនធ្វើអីផងដែរ ។ នេះធ្វើម៉េច បើលេខខ្ញុំវាត្រូវអ៊ីចឹងទៅហើយនោះ ។

នៅពេលកំពុងនិយាយនេះ *ប្លាក់ថន* សង្កេតឃើញមុខមេបញ្ជាការប្រឹងសំលឹងមើលបបូរមាត់របស់គេ ដើម្បីយល់បានពីអ្វីដែលគេនិយាយនេះ ។ អាកូនមីចោរអត់ពូជ-*ប្លាក់ថន* គិតនៅក្នុងចិត្ត-អ្នែងលេចគូថកណ្តាលវាលហើយអ្ហា !មួយរយអញស៊ីតែមួយរៀលទេ បើអែងណឹងមិនចេះភាសាប៉កទុយកាល់នោះ ។

នារីអ្នកបំរើឈ្មោះ*សូណូ* អោនក្បាលទៅជិតស្មែង ដែលមានរនាំងបាំងជិត ដើម្បីត្រងត្រាប់ស្តាប់មួយសន្ទុះ ទើបនាងដើរមករក *មារីកូ* វិញ :

-សូមអភ័យទោស *មារីកូ-សាម៉ា* ប៉ុន្តែម្ចាស់របស់ខ្ញុំសួរថា តើបុរសចំកួតអំបាញ់នេះបានស្រួលបួលល្មមនឹងបន្តដំណើរទៅមុខទៀតបានហើយវឺនៅ ? ម្ចាស់ស្រីខ្ញុំស្នើសួរថា តើលោកស្រីអាចអោយបុរសនេះអង្គុយលើស្នែងលោកស្រីបានទេ ព្រោះយើងត្រូវប្រញាប់ចេញដំណើរក្នុងពេលជំនោរសមុទ្រនេះចាស ។ ម្ចាស់ស្រីខ្ញុំកាន់តែខ្វល់ខ្វាយក្នុងចិត្តថែមទៀត ពេល



www.budinst.gov.kh www.elibraryofcambodia.org

ដែលឃើញបុរសចំកួតនេះបង្កនាំអោយមានបញ្ហាច្រើនយ៉ាងនេះ ។ ប៉ុន្តែម្ចាស់ស្រីខ្ញុំក៏ដឹងដែរថា អំពើលេលាទាំងឡាយតែងតែបង្កឡើងដោយព្រះ ដោយហេតុនេះម្ចាស់ស្រីខ្ញុំនឹងបួងសួងអោយគាត់ឆាប់ជាសះស្បើយ ហើយនៅពេលដល់ទូកធំម្ចាស់ស្រីខ្ញុំនឹងផ្តល់ថ្នាំផ្ទាល់របស់ខ្លួន ដើម្បីជួយព្យាបាលគាត់ ។

*ម៉ារីកូ* បកប្រែទៅអោយ *ប្លាក់ថន* ១ឆ្លើយ :

- បាទ ខ្ញុំស្រួលបួលវិញហើយអីលូវនេះ ។

*ប្លាក់ថន* ក្រោកឈរឡើងទាំងជើងញ័រទទ្រើតនៅឡើយ ។ *យ៉ាប៊ូ* ស្រែកចេញបញ្ជា ។

- *យ៉ាប៊ូ-សាន* និយាយថា លោកត្រូវអង្គុយនៅក្នុងស្នែង *អាន់ជីន-សាន* ។

ពេលដែល *ប្លាក់ថន* ប្រកែក *ម៉ារីកូ-សាន* ក៏ញញឹមយ៉ាងស្រស់ :

- ខ្ញុំពិតជាមាំមួនមែនណា សូមលោកកុំបារម្ភអី ។ ខ្ញុំនឹងដើរអែបស្នែងលោក ហេតុ នេះបើលោកចង់ដេកគ្នា លោកនៅតែដេកបានដដែលទេតើ ។

នៅពេលដែលគេជួយ *ប្លាក់ថន* ចូលអង្គុយក្នុងស្នែងហើយ ក្បួនក៏បន្តដំណើរទៅមុខទៀតភ្លាម ។ សង្វាក់យោលយោកនៃស្នែងមានលក្ខណៈដូចគ្នា នឹងថ្នាំជួយរំងាប់អារម្មណ៍ម្យ៉ាងដែរ ។ *ប្លាក់ថន* ដេកផ្អែកសន្ទឹងសន្ធៃនឹងបង្អែកស្នែង ហើយរង់ចាំពេលដែលបញ្ហាការពួកអាវ ប្រផេះរត់ទៅខាងក្បាលក្បួនវិញនោះទើប...

- នែ អាគាត់ណឹងក៏ចេះភាសាប៉ុកទុយកាល់ដែរណា ។

នាងនិយាយខ្សឹប ១តបវិញក្នុងស្ថានភាពនឹងនរ :

- ចាស ។ ហើយខ្ញុំគិតថា វាចេះភាសាឡាតាំងខ្លះ ៗ ថែមទៀតផង ។

ក្រោយពីដើរបានមួយសន្ទុះ នាងក៏បន្តនិយាយទៅទៀត :

-និយាយមែនទែនទៅលោក គឺជាបុរសមួយអង់អាចណាស់ ។ ខ្ញុំសូមអរគុណលោកដែលបានជួយសង្គ្រោះគាត់អំបាញ់មិញនេះ ។

- ប៉ុន្តែលោកស្រីបានបង្ហាញភាពអង់អាចច្រើនជាងនេះទៅទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

-ចាសទេ ប៉ុន្តែព្រះជាម្ចាស់បានដាក់ជើងខ្ញុំនៅចំដំណើរផ្លូវនេះ ហើយធ្វើអោយខ្ញុំក្លាយជាមនុស្សបានការបន្តិចបន្តួចទៅ ។ ខ្ញុំសូមអរគុណលោកម្តងទៀតចាស ។

នៅពេលយប់ ទីក្រុងមិនខុសអ្វីពីឧទ្យានសួគ៌នោះទេ ។ ផ្ទះធំ ៗ មានគោមចំរុះពណ៌ជាច្រើនព្យួរបំភ្លឺនៅលើខ្លោងទ្វារ និងនៅក្នុងសួនច្បារ ។ សូម្បីតែផ្ទះអ្នកក្រក៏មានពន្លឺចាំងឆ្លុះពីក្នុងតាមក្រដាសស្តើងដែលពាសទ្វារ និងបង្អួចនោះផងដែរ ។ ពន្លឺទាំងនេះបានជួយបំភ្លឺអ្នកថ្មើរជើង អ្នកកាកា និងពួកសាមូរ៉ៃ ដែលដើរ រឺជិះសេះតាមបណ្តោយផ្លូវនេះ ។

- យើងប្រើប្រេង រឺទៀនដើម្បីដុតបំភ្លឺផ្ទះ ប៉ុន្តែនៅពេលយប់កាន់តែជ្រៅទៅនោះមនុស្សភាគច្រើនចូលសំរាកហើយ ។

*មារីកូ* និយាយពន្យល់ក្នុងពេលដែលពួកគេដើរតាមផ្លូវថ្នល់ ដែលបត់បែនចុះឡើងនៅក្នុងក្រុង ។ ក្បួនទៅដល់ទីណា អ្នកថ្មើរជើងទាំងអស់តែងលំអោនខ្លួនគោរព ហើយអ្នកដែលក្រីក្រតោកយ៉ាកបំផុតតែងតែលុតជង្គង់លំអោនខ្លួនគោរពរហូតដល់ពេលដែលក្បួនទៅផុតតែម្តង ។ នៅឯនាយ ទឹកសមុទ្រដេញពន្លឺព្រាត ៗ ក្រោមពន្លឺខែ ។

-ពួកយើងក៏អីចឹងដែរ ។ តើពួកអ្នកស្រីដាំស្លរបៀបយ៉ាងណា ? គេប្រើឡអុសដែរអ្វី?

*ប្លាក់ថន* ប្រមូលកំលាំងបានវិញយ៉ាងឆាប់រហ័ស ។ ជើងរបស់គេលែងធ្ងន់ពាប់ដូចសំណទៀតហើយ ។*មារីកូ* បានប្រកែកមិនព្រមអង្គុយលើស្នែងវិញទេ ដោយហេតុនេះគេក៏បន្តអង្គុយនៅលើស្នែងយ៉ាងសុខស្រួលទៀតទៅ ។ សំលេងរបស់*មារីកូ* រឹតតែធ្វើអោយអារម្មណ៍សុខស្រួលនេះមានភាពសុក្រឹតថែមទៀត ។

- ពួកយើងប្រើធ្យូង ហើយពួកយើងមិនហូបម្ហូបដូចពួកលោកទេ ហើយម្ហូបពួកយើងសាមញ្ញជាង ។ គឺមានតែបាយ ត្រីបន្តិចបន្តួច ភាគច្រើនជាត្រីឆៅ រឺពេលខ្លះចៀន ហើយផ្ទាប់ជាមួយបន្លែបន្ទុកបន្តិចទៅ ។ ពេលខ្លះក៏មានសំលបន្តិចទៅ ។ គ្មានសាច់ទេ មិនតែម្តង ។ ពួកយើងជាជនជាតិមួយដែលហូបយ៉ាងសាមញ្ញ ហើយយើងត្រូវតែសាមញ្ញយ៉ាងនេះ ព្រោះយើងមានមនុស្សច្រើន ហើយដីមួយភាគប្រាំនៃនគរនេះតែប៉ុណ្ណោះដែលអាចដាំដុះបាន ។ ការហូបចុកតិច និងសាមញ្ញ គឺជាគុណធម៌មួយសំរាប់ប្រជាជនយើង ទោះជាយើងមានម្ហូបសំបូរយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

ណាក្តី ។

- អ្នកស្រីពិតជាអង់អាចមែន ។ ខ្ញុំសូមអរគុណ ។ ខ្ញុំដឹងថា ព្រួញមិនត្រូវបានបាញ់ចេញ ក៏ដោយសារអ្នកស្រីយកខ្លួនរបស់អ្នកស្រីពាំងតែប៉ុណ្ណោះ ។

- មិនមែនទេ លោកមេបញ្ជាការសំពៅ ។ នេះគឺជាព្រហ្មលិខិតទេ ។

- អ្នកស្រីពិតជាអង់អាច ហើយពិតជាល្អស្អាតថែមទៀតផង ។

*មារីកូ* បន្តដំណើរយ៉ាងស្ងៀមស្ងាត់មួយស្របក់ ។ តាំងពីដើមមក មិនដែលមានអ្នកណានិយាយថាអញល្អស្អាតសោះ-នាងគិតនៅក្នុងចិត្ត-មិនដែលមានម្តង ។ រួចនាងនិយាយតបទៅវិញ :

- ខ្ញុំមិនមែនជាអ្នកអង់អាច ហើយក៏មិនមែនល្អស្អាតដែរ ។ ដាវទើបល្អស្អាត ។ កិត្តិយសទើបល្អស្អាត ។

- សេចក្តីក្លាហាន គឺល្អស្អាត ហើយអ្នកស្រីពោរពេញដោយសេចក្តីក្លាហានមែន ។

*មារីកូ* ឥតមានឆ្លើយតបឡើយ ។ នាងរំលឹកឡើងវិញពីអ្វី ដែលបានកើតមានឡើងតាំងពីពេលព្រឹកមិញនេះ ។ តើហេតុអ្វីបានជាមនុស្សនេះអាចជាមនុស្សអង់អាចផង សំពីកផងជាមនុស្សស្លូតបូតផង សាហាវផង ជាមនុស្សគួរជាទីស្រលាញ់ផង និងគួរស្អប់ផង ក្នុងពេលតែមួយយ៉ាងនេះ ? *អាន់ជីន-សាន* គឺពិតជាអង់អាចរកអ្វីប្រៀបពុំបាន នៅពេលដែលគេបំបែកអារម្មណ៍*អ៊ីស៊ីដូ* ចេញពីស្នែង ហើយក៏ពិតជាវាងវៃអស្ចារ្យ នៅពេលដែលគេធ្វើជាឆ្កួតនាំ*តូរ៉ាណាកា* គេចផុតពីអន្ទាក់យ៉ាងនេះ ។ *តូរ៉ាណាកា* ក៏ពិតជាវាងវៃក្នុងការជ្រើសរើសមធ្យោបាយនេះដើម្បីគេចខ្លួន ។

នាងឆ្លើយតបទៅ*ប្លាក់ថន*វិញ :

-ចាសពិតហើយ សេចក្តីក្លាហាន គឺពិតជាល្អស្អាត ហើយលោកពោរពេញដោយសេចក្តីក្លាហាន ។

រួចនាងបែរទៅនិយាយភាសាប៉័រទុយកាល់វិញ :

- និយាយឡាតាំងគឺពិតជាយ៉ាប់មែនតែម្តង ។



www.budinst.gov.kh www.elibraryofcambodia.org

- អ្នកស្រីរៀនឡាតាំងនៅសាលាអ្វី ?

- ទេ *អាន់ជីន-សាន* ។ ខ្ញុំរៀនភាសានេះក្រោយពីខ្ញុំឈប់រៀននៅសាលាទេ ។ ក្រោយពីពេលខ្ញុំរៀបការហើយ ខ្ញុំបានទៅរស់នៅភាគខាងជើងយូរពេលក្រែលដែរ ។ កាលនោះខ្ញុំរស់នៅតែម្នាក់ឯង ជាមួយអ្នកភូមិ និងអ្នកបំរើតែប៉ុណ្ណោះ ។ ហើយសៀវភៅដែលខ្ញុំមានទាំងប៉ុន្មាន គឺជាសៀវភៅវេយ្យាករណ៍ និងសៀវភៅធម៌ជាភាសាប៊កទុយកាល់ និងឡាតាំងតែប៉ុណ្ណោះ ។ រៀនភាសាបរទេស គឺធ្វើអោយខ្ញុំមិនសូវអផ្សុក ហើយមិនឃើញថា ពេលវេលាយូរពេកផង ។ គិតទៅនេះគឺជាសំនាងរបស់ខ្ញុំម្យ៉ាងដែរ ។

- កាលនោះប្ដីរបស់អ្នកស្រីនៅឯណា ?

- គាត់ទៅធ្វើសង្គ្រាម ។

- អ្នកស្រីនៅម្នាក់ឯងយូរពេលទេ ?

- ពួកយើងតែងនិយាយថា ពេលវេលាមិនអាចវាស់បានទេ ។ ពេលវេលាប្រៀបបីដូចជាអ័ព្ទ ជាពន្លឺ ជាទឹកភ្លៀក ជាខ្យល់ព្យុះ ជាថ្ងៃអស្ដង្គត ។ រឺជាដុំសិលាក៏បាន ។

-នេះគឺពិតជាសំដីមួយដ៏វាងវៃមែន ។ អ្នកស្រីនិយាយភាសាប៊កទុយកាល់បានល្អណាស់ ។ ហើយភាសាឡាតាំងរបស់អ្នកស្រីល្អជាងខ្ញុំផង ។

-អណ្ដាតលោកពោរពេញដោយទឹកឃ្មុំតែម្ដង *អាន់ជីន-សាន* ។

- នេះគឺ *ហុងតូ* ណា ។

- *ហុងតូ* គឺជាពាក្យពិរោះមែន ។ ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំនិយាយភាសាបរទេសបានល្អ ។ នេះគឺមកពីឪពុកខ្ញុំចង់អោយខ្ញុំរៀនភាសាទាំងនេះ ។

- ហេតុអ្វី ?

- គាត់យល់ថា ចង់រកស៊ីជាមួយខ្មោច ត្រូវស្គាល់ខ្មោចអោយច្បាស់សិន ។

- គាត់គឺពិតជាមនុស្សវាងវៃមែន ។

- ចាសទេ គាត់មិនមែនជាវាងវៃទេ ។

- ហេតុអ្វី ?



www.budinst.gov.kh www.elibraryofcambodia.org

- ចាំថ្ងៃណាមួយខ្ញុំនឹងនិយាយរឿងនេះជំរាបលោក ។ នេះជារឿងកំសត់ទេ ។

- ហេតុអ្វីបានជាអ្នកស្រីទៅនៅទីឆ្ងាយយូរពេលយ៉ាងនេះ ។

- ហេតុអ្វីក៏លោកមិនសំរាកទៅ ? យើងត្រូវធ្វើដំណើរផ្លូវឆ្ងាយណាស់ ។

- តើអ្នកស្រីចង់ជិះស្លែងម្តងអ្វី ?

រួច *ប្លាក់ថន* ក៏ងើបឡើង ប៉ុន្តែ *មារីកូ* គ្រវីក្បាល :

- ចាសទេ ! អរគុណលោកហើយ ។ សូមលោកនៅអង្គុយលើស្លែងចុះ ។ ខ្ញុំចូលចិត្តដើរជាង ។

- អីចឹងក៏បាន ។ ប៉ុន្តែអ្នកស្រីចង់ជជែកគ្នាទៀតទេអ្វី ?

- បើសិនជាលោកចង់ យើងអាចបន្តជជែកគ្នាបាន ។ តើលោកចង់ដឹងពីរឿងអីទៅ ?

- ហេតុអ្វីបានជាអ្នកស្រីនៅតែម្នាក់ឯងក្នុងរយៈពេលមួយយ៉ាងយូរបែបនេះ ?

- គឺប្តីខ្ញុំបញ្ជូនខ្ញុំទៅទីនោះ ព្រោះវត្តមានរបស់ខ្ញុំបានប៉ះពាល់កិត្តិយសរបស់គាត់ ។ គាត់ធ្វើនោះគឺត្រឹមត្រូវ ។ ហើយគាត់ទុកកិត្តិយសអោយខ្ញុំ ដោយមិនលែងខ្ញុំ ក្រោយមកទៀតគាត់ទទួលយកខ្ញុំ និងកូនប្រុសរបស់ខ្ញុំមកវិញ ។

*មារីកូ* ងាកសំលឹងទៅ *ប្លាក់ថន* :

- អីលូវនេះកូនប្រុសខ្ញុំអាយុដប់ប្រាំឆ្នាំហើយ ។ ខ្ញុំជាស្រីចាស់ហើយណា ។

- ខ្ញុំមិនជឿអ្នកស្រីទេ ។

- នេះគឺ *ហុងតូ* ណា !

- អ្នកស្រីអាយុប៉ុន្មាននៅពេលរៀបការ ?

- ពេលនោះខ្ញុំអាយុច្រើនហើយ *អាន់ជីន-សាន* ។ ច្រើនណាស់ ។

- ពួកយើងតែងនិយាយថា :" អាយុប្រៀបបីដូចជាដុំទឹកកក ជាសុរិយាអស្តង្គត រឺជួនកាលជាផ្ទាំងសីលា " ។

*មារីកូ* សើចកក្អឹក ។ នាងពិតជាល្អស្រស់មែន- *ប្លាក់ថន* គិត ។ គេពោលបន្ត :

- ចំពោះអ្នកស្រី អាយុច្រើននេះរឹតតែធ្វើអោយអ្នកស្រីលេចសំរស់ឡើងថែមទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

- ចំពោះនារី អាយុច្រើនមិនមែនជាលំអទេ *អាន់ជីន-សាន* ។

- អ្នកស្រីជាមនុស្សវាងវៃ ហើយមានសំរស់ស្អាតណាស់ ។

- នៅស្រុកនេះមិនមែនជាប្រការមួយល្អទេ ដែលត្រូវកត់សំគាល់ពីប្រពន្ធរបស់បុរសម្នាក់ទៀតនោះ ។ ប្រពៃណីរបស់យើងតឹងតែងណាស់ ។ ជាឧទាហរណ៍ បើសិនជាគេឃើញនារីមានប្ដីម្នាក់នៅក្នុងបន្ទប់បិទទ្វារជិតជាមួយបុរសម្នាក់ផ្សេងទៀត ទោះជាគ្រាន់តែនិយាយគ្នាលេងក្ដី គឺប្ដី រឺបងថ្លៃ រឺឪពុកម្ដាយក្មេកមានសិទ្ធិសំលាប់នារីនោះចោលភ្លាម ។ បើសិនជានារីនោះមិនទាន់មានប្ដីទេ នេះឪពុករបស់នាងមានសិទ្ធិសំរេចធ្វើយ៉ាងម៉េចក៏បានដែរ ។

- នេះមិនយុត្តិធម៌ទេ រឺក៏ថាគ្មានអារ្យធម៌អីសោះក៏បានដែរ ។

និយាយរួច ទើប *ឮក់ថន* ស្ដាយសំដីរបស់ខ្លួនជាក្រោយ ។

- ពួកយើងយល់ថា ពួកយើងគឺពិតជាមានអារ្យធម៌ណាស់ *អាន់ជីន-សាន* ។ ក្រឹត្យក្រមរបស់យើង គឺពិតជាវាងវៃ ។ ការពិត នេះគឺជាប្រការមួយការពារនារីផងដែរ ។ ភារកិច្ចរបស់នារី គឺផ្ដោតទៅលើប្ដីរបស់ខ្លួន ។ អោយតែលោកចេះអត់ធ្មត់ លោកនឹងឃើញថា តើពួកយើងជាពួកជនជាតិមានអារ្យធម៌យ៉ាងណា ជឿនលឿនដល់ណា ។ បុរសអាចមានប្រពន្ធជាផ្លូវការតែមួយទេ ពិតមែនតែគេអាចមានប្រពន្ធចុងច្រើនក្ដី ។ ប៉ុន្តែនៅទីនេះ នារី ១ មានសេរីភាពច្រើនជាងនារី ១អេស្ប៉ាញ រឺប៉័កទុយកាល់ទៅទៀត នេះបើតាមគេប្រាប់ខ្ញុំ ។ ពួកយើងអាចដើរទៅណានៅពេលណាតាមចិត្តចង់ ។ ពួកយើងអាចលែងប្ដីបាន បើសិនជាយើងចង់ ។ ពួកយើងជាម្ចាស់លើទ្រព្យសម្បត្តិ លើកម្មសិទ្ធិលើខ្លួនប្រាណ និងចិត្តគំនិតរបស់យើង ។ បើសិនជាពួកយើងចង់ ពួកយើងអាចមានអំនាចយ៉ាងធំធេងក៏បាន ។ នៅក្នុងផ្ទះរបស់លោក តើអ្នកណាជាអ្នកថែទាំទ្រព្យសម្បត្តិ និងប្រាក់កាសរបស់លោក ?

- ច្បាស់ហើយ គឺខ្ញុំ ។

-នៅទីនេះ គឺប្រពន្ធជាអ្នកមើលថែទាំគ្រប់សព្វគ្រប់យ៉ាង ។ ប្រាក់មិនមែនជារឿងសំខាន់ទេចំពោះសាមូរ៉ៃ ។ រឿងនេះ គឺជារឿងកំប៉ិកកំប៉ុកសំរាប់កូនប្រុសដើមទ្រូងប្រាំហត្ថ ។ ខ្ញុំជាអ្នកចាត់ចែងកិច្ចការសព្វគ្រប់របស់ប្ដីខ្ញុំ ។ ប្ដីខ្ញុំជាអ្នកសំរេចគ្រប់បែបយ៉ាង ។ ខ្ញុំជាអ្នក



www.budinst.gov.kh www.elibraryofcambodia.org

អនុវត្តចិត្តគំនិតរបស់គាត់ និងជាអ្នករ៉ាប់រងទទួលខុសត្រូវ ។ ដល់អ៊ីចឹងទៅ គាត់គ្មានជាប់ដៃជាប់ជើងក្នុងការបំពេញភារកិច្ចរបស់គាត់ចំពោះអម្ចាស់របស់គាត់ឡើយ ។ ហើយនេះគឺជាភារកិច្ចរបស់គាត់ ។ អូមែន *អាន់ជីន-សាន* មុនពេលដែលលោករិះគន់ លោកត្រូវតែចេះមានការអត់ធ្មត់សិន ។

- ខ្ញុំនិយាយអំបាញ់មិញនេះ មិនមែនខ្ញុំចង់មានគំនិតរិះគន់នោះទេ អ្នកស្រី ។ នេះគឺអ្វីដែលពួកយើងយល់ឃើញពីតំលៃនៃជីវិត ។ ពួកយើងយល់ឃើញថា គ្មានអ្នកណាម្នាក់អាចត្រូវគេសំលាប់យ៉ាងងាយ ៗ នោះទេ លើកលែងតែតុលាការស្របច្បាប់បានកំនត់តែប៉ុណ្ណោះ ។

- លោកនិយាយរឿងច្រើនណាស់ ដែលខ្ញុំមិនអាចយល់បាន *អាន់ជីន-សាន* ។ ប៉ុន្តែអំបាញ់មិញក្រែងលោកនិយាយថា " មិនយុត្តិធម៌ និងគ្មានអារ្យធម៌ " អ៊ីចឹងមែនទេ ?

- បាទមែនហើយ ។

- ណឹងមិនមែនជាការរិះគន់ទេអ្វី ? គឺជាការមិនសមរម្យទេ ដែលធ្វើការរិះគន់ដោយគ្មានការយល់ដឹងនោះ ។ លោកត្រូវដឹងថា អារ្យធម៌យើង វប្បធម៌យើងមានចំនាស់រាប់ពាន់ឆ្នាំហើយ ។ គ្រាន់តែឯកសារកត់ត្រារបស់យើងមានចំនាស់បីពាន់ឆ្នាំរួចទៅហើយ ។ ពិតណាស់ពួកយើងគឺជាប្រជាជន ដែលមានប្រវត្តិយូរលង់មកហើយ ។ យូរប្រហែលប្រទេសចិនដែរ ។ តើវប្បធម៌របស់លោកមានចំនាស់ប៉ុន្មានពេលមកហើយ ។

- មិនយូរប៉ុន្មានទេអ្នកស្រី ។

- ព្រះចៅអធិរាជយើងសព្វថ្ងៃ ព្រះនាម *កូ-ទីចូ* គឺជាព្រះចៅទីមួយរយប្រាំពីរនៃសន្តតិវង្ស-*គេណូ* ។ សូម្បីតែប្រទេសចិន ក៏មិនអាចអះអាងថា មានប្រវត្តិបែបនេះឡើយ ។ តើព្រះរាជានៅក្នុងប្រទេសលោកសោយរាជ្យបានប៉ុន្មានគំនហើយ ?

-ក្សត្រីយានីរបស់យើង គឺជាគំនទីបី នៃសន្តតិវង្ស*ទូដ័រ* ប៉ុន្តែព្រះនាងមានព្រះជន្មាយុច្រើនណាស់ទៅហើយ១គ្មានព្រះរាជបុត្រាបុត្រីថែមទៀត ។ ហេតុនេះព្រះនាងគឺជាអ្នកចុងក្រោយហើយ ។

- ព្រះអធិរាជយើង គឺជាអ្នកគំនទីមួយរយប្រាំពីរណាំ *អាន់ជីន-សាន* ! គឺតាំងពីជំនាន់ព្រះម្លេះ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងសំដីរបស់ *មារីកូ* ពោរពេញទៅដោយមោទនភាព ។

- បើអ្នកស្រីយល់យ៉ាងនេះ តើអ្នកស្រីអាចនិយាយថា អ្នកស្រីជាអ្នកកាតូលិចម៉េច នឹងកើត ?

- ខ្ញុំកាន់សាសនានេះ ទើបបានដប់ឆ្នាំប៉ុណ្ណោះ គឺប្រហែលដូចជាលោកនេននៅឡើយ ។ ថ្វីបើខ្ញុំមានជំនឿលើព្រះគ្រិស្ត តែព្រះចៅអធិរាជរបស់ខ្ញុំ គឺនៅដាច់ចេញពីបញ្ហាទាំងនេះ ពិតមែន ហើយខ្ញុំជាកាតូលិច ប៉ុន្តែដំបូងបង្អស់ខ្ញុំជាជនជាតិជប៉ុន ។

តើនេះជាកូនសោសំរាប់ពួកអ្នកឯងទាំងអស់នេះរឺ ? គឺដំបូងបង្អស់ពួកឯង ជាជនជាតិជប៉ុនមែនទេ ? *ប្លាក់ថន* ដណ្តឹងសួរក្នុងចិត្ត ។ ទំនៀមទំលាប់ពួកវាចំជាលេលាមែន ! តើប្រាក់គ្មានន័យអ្វីទាំងអស់ចំពោះកូនប្រុសដើមទ្រូងប្រាំហត្ថមែនអ្វី ? អ៊ីចឹងហើយបានជា *តូរ៉ាណាកា* បានបង្ហាញអាកប្បកិរិយាមាក់ងាយម្ល៉េះ នៅពេលដែលអញនិយាយពីរឿងលុយនៅពេលជួបគ្នាដំបូងនោះ ។ មួយរយប្រាំពីរតំន ? មិនអាចទេ ។ សំលាប់ ចោលភ្លាម បើគ្រាន់តែនៅក្នុងបន្ទប់បិទជិតជាចម្លតាជាមួយនារី ?ព្រៃផ្សៃមែន! ពួកវាជំរុញ និងសរសើរឃាតកម្មតែម្តង ។ អ៊ីចឹងមិនដូច *វ៉ុទ្រិច* និយាយទេអ្វី ? មិនដូច *អូមី-សាន* និយាយទេអ្វី ? វាមិនសំលាប់អ្នកស្រែមួយនោះយ៉ាងធូរល្ហុយទេអ្វី ? ឱ ព្រះអើយ !អញភ្លេចគិតពីអា *អូមី* ប៉ុន្មានថ្ងៃ ហើយ ។ ភ្លេចទាំងភូមិ ភ្លេចទាំងអន្លង់ រឺភ្លេចពីរឿងអញលុតជង្គង់ពីមុខវាទៅហើយ ។ តែណ្ហើយ កុំអាលគិតពីរឿងវា ។ ស្តាប់នារីនេះសិន ត្រូវចេះអត់ធ្មត់ដូចនារីនេះនិយាយអ៊ីចឹង ។ ត្រូវសួរនាងអោយបានច្រើន ព្រោះនាងអាចផ្តល់មធ្យោបាយ ដែលអាចអូសទាញ *តូរ៉ាណាកា* អោយដើរតាមផែនការឯងបាន ។ អីលូវនេះ *តូរ៉ាណាកា* ជំពាក់គុណអ្នែងយ៉ាងធ្ងន់ធ្ងរទៅហើយ ព្រោះអ្នែងបានជួយគាត់ ។ គាត់ដឹងរឿងនេះច្បាស់ណាស់ ហើយអ្នកឯទៀតក៏បានដឹងដែរ ។

ក្បួនដើរបត់បែនតាមទីក្រុងសំដៅតំរង់ទៅសមុទ្រ ។ ពេលប្រទះឃើញ *យ៉ាប៊ូ* នៅឯខាងមុខអារម្មណ៍របស់ *ប្លាក់ថន* ក៏រំលឹកឃើញភ្លាមពីសំរែករបស់ *ពីតែស៊ូន* ។ គេខំនិយាយតិច១ទៅកាន់ខ្លួនគេ :

- ដោះម្តងមួយ ១អារ៉ា !



www.budinst.gov.kh www.elibraryofcambodia.org

*មារិក្ក* បន្តនិយាយចាក់ចុចទៅទៀត :

- ពិតហើយ គឺពិតជាការលំបាកចំពោះលោក ។ ពិភពរបស់ពួកយើង គឺពិតជាខុសប្លែកពីពិភពរបស់លោក ។ ពិតជាខុសឆ្ងាយ តែនេះជាពិភពពោរពេញដោយគតិបណ្ឌិត ។

ក្រសែភ្នែករបស់ *មារិក្ក* ប្រទះឃើញស្រមោលរបស់ *តូរ៉ាណាកា* ស្ទុង១ទៅក្នុងស្នែង ហើយនាងសែនរីករាយ ដែលអម្ចាស់របស់នាងបានគេចខ្លួនយ៉ាងនេះ ។ តើអញត្រូវពន្យល់មនុស្សចុងស្រុកនេះបែបណា ដើម្បីយល់ពីពួកយើងបាន ? តើត្រូវអរគុណពីភាពអង់អាចរបស់មនុស្សនេះយ៉ាងម៉េច ?

នាងនិយាយបន្ត :

- ខ្ញុំនឹងនិយាយរឿងមួយជូនលោក *អាន់ជីន-សាន* ។ នៅពេលខ្ញុំនៅជាក្មេងនៅឡើយ ឪពុកខ្ញុំគឺជាមេទ័ពនៃដៃមីញ៉ូម្នាក់ឈ្មោះ *ក្លូរ៉ូដា* ។ កាលនោះលោកម្ចាស់ *ក្លូរ៉ូដា* មិនទាន់ជាអ្នកក្តាប់អំនាចទាំងមូលនោះទេ ប៉ុន្តែគឺគាត់កំពុងប្រយុទ្ធដើម្បីក្តោបអំនាច ។ ឪពុកខ្ញុំបានអញ្ជើញ *ក្លូរ៉ូដា* និងអណ្តាប់១ ទាំងប៉ុន្មានរបស់លោកមកជប់លៀង ។ កាលនោះឪពុកខ្ញុំឥតគិតថា យើងមានលុយរឺអត់ដើម្បីទិញម្ហូប ទិញស្រាសាកេ ទិញគ្រឿងចានក្បាន ទិញ *តាតាមី* ដើម្បីអោយសក្តិសមនឹងពិធីការទេ ។ សូម្បីតែនឹកឃើញក៏គ្មានផង ។ និយាយអីចឹងលោកគិតថា ម្តាយខ្ញុំជានារីមេផ្ទះស់គិះហើយ ។ តែគឺមិនមែនអីចឹងទេ ។ លុយកាក់ប្រាក់ចំនូលបន្តិចបន្តួចរបស់ឪពុកខ្ញុំត្រូវបានចែកចាយដល់សាមូរ៉ៃជាអណ្តាប់របស់គាត់ ហើយថ្វីត្បិតតែឪពុកខ្ញុំមានទ្រព្យសម្បត្តិល្មមនឹងចិញ្ចឹមទ័ពតែបួនពាន់នាក់ក្តី ក៏ម្តាយខ្ញុំសុខចិត្តបេះពីមាត់ ពីក លើកពីនេះដាក់ឯនោះ ដើម្បីអាចអោយឪពុកខ្ញុំអាចចិញ្ចឹមបានដល់ទៅប្រាំពាន់បីរយនាក់ ដើម្បីធ្វើសង្គ្រាម ក្នុងបំនងលើកកិត្តិយសឪពុកខ្ញុំ និងដើម្បីជ្រោងកិត្តិយសរបស់អម្ចាស់គាត់ ។ ពួកយើងក្នុងគ្រួសារវិញ គឺទាំងម្តាយខ្ញុំ ប្រពន្ធចុងទាំងប៉ុន្មានរបស់ឪពុកខ្ញុំ បងប្អូនប្រុសស្រីទាំងអស់របស់ខ្ញុំ គឺសុខចិត្តហូបអត់ ហូបឃ្លាន ។ ប៉ុន្តែប្រការនេះមិនមែនជាការសំខាន់ទេ អ្វីដែលសំខាន់គឺឪពុកខ្ញុំនិងទ័ពរបស់គាត់មានអាវុធល្អបំផុត មានសេះល្អបំផុតក្នុងការធ្វើសង្គ្រាមដើម្បី អម្ចាស់របស់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org

ចាស នៅពេលនោះយើងគ្មានលុយគ្រប់គ្រាន់ ដើម្បីរៀបចំពិធីជប់លៀងនោះឡើយ ។ ពេលនោះម្តាយខ្ញុំបានទៅរកអ្នករកស៊ីធ្វើសក់លក់ ដើម្បីលក់សក់របស់គាត់ ។ ខ្ញុំចាំច្បាស់ណាស់ កាលនោះសក់របស់គាត់ខ្មៅរលោង ហើយធ្លាក់ហៀរដល់កែងជើង ។ ជាងធ្វើសក់បានកាត់សក់គាត់នៅថ្ងៃនោះ ហើយប្រគល់សក់ក្លែងក្លាយដ៏ថោកមួយទៅគាត់វិញ ។ អាស្រ័យដោយថ្លៃលក់សក់នេះ គាត់អាចទិញរបស់របរដែលចាំបាច់ទាំងអស់ ហើយជួយរក្សាកិត្តិយសរបស់ឪពុកខ្ញុំបាន។ នេះជាភារកិច្ចរបស់គាត់ក្នុងការរ៉ាប់រងការចំនាយ ហើយរ៉ាប់រងបានមែន ។ គឺគាត់បានបំពេញករណីយកិច្ចរបស់គាត់ ។ ចំពោះយើង ករណីយកិច្ចគឺជាប្រការសំខាន់បំផុតលើសគេ ។

- នៅពេលដែលឪពុកអ្នកស្រីដឹងរឿងនេះ តើគាត់ថាម៉េចទៅ ?

- មានថាម៉េច ក្រៅពីអរគុណម្តាយខ្ញុំ ?. នេះគឺករណីយកិច្ចរបស់ម្តាយខ្ញុំ ក្នុងការរកលុយ ក្នុងការថែរក្សាកិត្តិយសឪពុកខ្ញុំ ។

- ម្តាយរបស់អ្នកស្រីពិតជាស្នេហាឪពុករបស់អ្នកស្រីណាស់មែនទេ ?

- ស្នេហា គឺជាពាក្យគ្រិស្តសាសនាទេ *អាន់ជីន-សាន* ។ នេះជាគំនិត ជាគតិគ្រិស្តសាសនាតែប៉ុណ្ណោះ ។ យើងគ្មានពាក្យស៊ីគ្នានឹងពាក្យ " ស្នេហា " នេះទេ ។ ករណីយកិច្ច ភក្តីភាព កិត្តិយស ការគោរព ចំនង់ នេះគឺជាពាក្យដែលយើងមាន ហើយជាពាក្យគ្រប់គ្រាន់សំរាប់ពួកយើង ។

នាងសំលឹងមើល *ប្លាក់ថន* យ៉ាងមុត ហើយទោះជានៅក្នុងចិត្តនាងនៅតែរង្កៀសចិត្តនឹងពាក្យសំដីបះពាល់របស់ *ប្លាក់ថន* ក្តី ក៏នាងនឹកឃើញផងដែរពីខណៈដែលបុរសនេះបានជួយ *តូរ៉ាណាកា* ហើយបើគ្មានបុរសនេះទេ ពួកគេប្រាកដជាស្លាប់បាត់ទៅហើយនៅពេលនេះ ។

នៅពេលដែលឃើញថា គ្មានអ្នកណានៅជិតពួកគេទាំងពីរនាក់នោះទេ *មារីកូ* ក៏និយាយខ្សឹបៗទៅកាន់ *ប្លាក់ថន* :

- ហេតុអ្វីបានជាលោកធ្វើដូចពេលអំបាញ់មិញនេះអ៊ីចឹង ?

- ខ្ញុំមិនដឹងដែរ ។ ប្រហែលមកពី...

រូច *ប្លាក់ថន* ឈប់នៅត្រឹមនេះ ។ មានមូលហេតុច្រើន ដែលគេអាចពន្យល់បាន។ ជួនកាលប្រហែលមកពី *តូរ៉ាណាកា* អស់ផ្លូវហើយ ១ ខ្ញុំមិនចង់អោយគាត់ងាប់...ប្រហែលមកពីបើសិនជាគេដឹងថា *តូរ៉ាណាកា* ពួកយើងទាំងអស់គ្នាច្បាស់ជាអាសន្នធំហើយ .....ប្រហែលមកពីខ្ញុំដឹងថា មានតែខ្ញុំម្នាក់គត់ដែលដឹងអាថិកំបាំងនេះ ហេតុនេះខ្ញុំត្រូវតែប្រថុយ ... ប្រហែលមកពី



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំមិនចង់ស្លាប់ ព្រោះខ្ញុំមានការងារច្រើនដែលត្រូវធ្វើ ហើយ*គូរ៉ាណេកា* ជាមនុស្សតែមួយគត់ដែលអាចសងសំពៅ និងសេរីភាពមកខ្ញុំវិញបាន...

ប៉ុន្តែទោះជាយ៉ាងនេះគឺ *ប្លាក់ថុន* ក៏ពន្យល់ *មារីកូ* ជាភាសាឡាតាំងថា :

- ពីព្រោះព្រះបាននិយាយថា អ្វីដែលជារបស់*សេសា*(*) ត្រូវជូនទៅ*សេសា*វិញ ។

- ចាស់ មែនហើយ ។

រួច *មារីកូ* និយាយបង្ហើបឃ្លាជាភាសាឡាតាំងវិញ :

- ហើយអ្វីដែលជារបស់ព្រះ ត្រូវថ្វាយទៅព្រះវិញ ។ ព្រះគឺជាព្រះ ឯព្រះចៅអធិរាជរបស់យើង គឺជាសែស្រឡាយរបស់ព្រះ ។ នេះគឺអ្វីដែលខ្ញុំចង់និយាយ ។ *សេសា* គឺ*សេសា* ហើយគេត្រូវគោរពត្រឹមតែដូចជា*សេសា*តែប៉ុណ្ណោះ ។

ឥលូវនេះ សមុទ្រនៅត្រឹមប្រហែលកន្លះគីឡូម៉ែតទៀតពីពួកគេតែប៉ុណ្ណោះ ។ *ប្លាក់ថុន* ឃើញមានទូកជាច្រើន ។ សំពៅបីកទុយកាល់មានឆេះភ្លើងបំភ្លឺផ្លូវជាស្រេច ។ សំពៅនេះតូរដែរ មានតែកាណុងម្តៃដើមអញយកឈ្នះបានយ៉ាងងាយ ។ គេងាកទៅសំលឹងមើល *មារីកូ* ។ នារីនេះពិតជាចំលែកមែន ហើយគ្រួសារក៏រឹតតែចំលែកណាស់ទៅទៀត ។ ហេតុអ្វីបានជានាងអាចនាំអោយប៉ះពាល់ដល់កិត្តិយសអាស្នាក្រិស*ប៊ុនតារ៉ូ* នេះវិញ ។ ហេតុអ្វីបានជានាងទ្រាំដេកជាមួយអាមនុស្សបែបណឹងកើត ? តើអ្វីទៅជារឿងដែលនាងថាជាការ " កំសត់ " នោះ ?

គេសួរទៅ *មារីកូ* ដោយខំរក្សាពាក្យយ៉ាងថ្នម :

- អ្នកស្រី ! ម្តាយអ្នកស្រីពិតជានារីម្នាក់ដ៏គំរណាស់ ដែលគាត់ធ្វើយ៉ាងនេះ ។

- ចាស ព្រោះតែយ៉ាងនេះ ទើបគាត់រស់នៅជារៀងរហូត ។ ឥលូវនេះម្តាយខ្ញុំបានក្លាយទៅជាតួអង្គនៃរឿងនិទានទៅហើយ ។ គាត់ជាសាមូរ៉ៃដូចឪពុកខ្ញុំដែរ ។

- ខ្ញុំគិតថា មានតែមនុស្សប្រុសទេទើបជាសាមូរ៉ៃបាន ។

- ទេ ! ទេ ! *អាន់ជីន-សាន* ! បុរសនិងស្ត្រីជាសាមូរ៉ៃដូចគ្នា ជាអ្នកប្រយុទ្ធដែលមានភារកិច្ចទទួលខុសត្រូវចំពោះមុខអម្ចាស់របស់ខ្លួនដូចគ្នា ។ ម្តាយខ្ញុំគឺជាសាមូរ៉ៃសុទ្ធសាធករណីយកិច្ចរបស់គាត់ចំពោះឪពុកខ្ញុំគឺលើសអ្វី១ទាំងអស់ ។

- ឥលូវនេះគាត់រស់នៅជាមួយអ្នកស្រីរឺ ?

---

*(*) Caesar :រដ្ឋបុរសនៃចក្រភពរ៉ូមដ៏ល្បីល្បាញ(ឆ្នាំ ១០១ដល់ឆ្នាំ ៤៤ មុនគ.ស) ។ (ក.អ.ប)*



www.budinst.gov.kh www.elibraryofcambodia.org

- ទេ *អាន់ជីន-សាន* ។ ទេ ! ក៏ដូចជាឪពុកខ្ញុំ បងប្អូនប្រុសស្រីខ្ញុំ រឺគ្រួសារខ្ញុំដែរ ។ ខ្ញុំគឺជាអ្នកបន្តពូជចុងក្រោយនៃត្រកូលនេះហើយ ។

- តើមានមហន្តរាយអ្វីកើតឡើងអ្វី ?

*មារីកូ* មានអារម្មណ៍ហាក់ដូចជាឡើយណាយមួយរំពេច ។ អញឡើយណាយនឹងនិយាយភាសាឡាតាំង និងប៉កទុយកាល់ ឡើយណាយនឹងធ្វើជាអ្នកបង្រៀនគេណាស់-នាងគិតនៅក្នុងចិត្ត - អញមិនមែនជាគ្រូទេ ។ អញគ្រាន់តែជាស្ត្រីម្នាក់ដែលស្គាល់ពីករណីយកិច្ចរបស់ខ្លួន ហើយដែលចង់បំពេញករណីយកិច្ចនេះយ៉ាងស្ងាត់ស្ងៀមតែប៉ុណ្ណោះ ។

- អាចនិយាយថា ជាមហន្តរាយក៏តែបានដែរ *អាន់ជីន-សាន* ។ ចាំថ្ងៃណាមួយ ខ្ញុំនឹងនិយាយប្រាប់លោកអំពីរឿងនេះ ។

*រួច មារីកូ* ដើរលឿនជាងមុន សំដៅខិតទៅជិតស្ពែងមួយទៀត ។ នារីបំរើទាំងពីរញញឹមដាក់នាងទាំងរអើល ៗ ។ *សូណូ* សួរឡើង :

- តើយើងត្រូវធ្វើដំណើរឆ្ងាយទៀត រឺយ៉ាងម៉េច *មារីកូ-សាន* ?

*មារីកូ* និយាយកំលាអ្នកទាំងពីរ :

- ខ្ញុំគិតថា ប្រហែលជាមិនឆ្ងាយពេកទេ ។

មេបញ្ជាការពូកអាវប្រផេះស្រាប់តែលេចមុខពីក្នុងទីងងឹតនៅក្បែរមួយចំហៀងទៀតនៃស្ពែង ។ *មារីកូ* ដណ្តឹងសួរខ្លួនឯងថា តើអ្វីដែលនាងបាននិយាយជជែកគ្នាជាមួយ *អាន់ជីន-សាន* នោះ មានអ្វីខ្លះដែលគេអាចស្តាប់លឺទៅ ?

មេបញ្ជាការនេះសួរទៅ *មារីកូ* :

- អ្នកស្រីត្រូវការគាកាទេ *មារីកូ-សាន* ? តើអ្នកស្រីអស់កំលាំងហើយរឺនៅ ?

- ទេ សូមអរគុណលោកហើយ ។ ខ្ញុំឥតមានអស់កំលាំងទេ ។

និយាយបណ្តើរ *មារីកូ* បង្អង់ជើងបណ្តើរ ដើម្បីអូសទាញមេបញ្ជាការពូកអាវប្រផេះនេះអោយចេញពីស្ពែង ។ បុរសនេះសួរបន្តទៀត :

- មនុស្សចុងស្រុកនោះបានស្រួលបួលហើយរឺនៅ ? វាមិនរំខានអ្នកស្រីទេ ?

- អត់អីទេ ។ គាត់នៅស្ងៀមហើយអីលូវនេះ ។

- ចុះអ្នកស្រីនិយាយអីខ្លះជាមួយវាអំបាញ់មិញនេះ ?

- ទាំងសព្វទាំងគ្រប់ណឹង ។ ខ្ញុំពន្យល់ប្រាប់គាត់ពីច្បាប់ ពីទំនៀមទំលាប់ខ្លះៗរបស់



www.budinst.gov.kh www.elibraryofcambodia.org

ស្រុកយើងដល់គាត់ណា ។

រូច *មារីកូ* ធ្វើសញ្ញាទៅលើសើនវិមាន ដែលនៅហាក់ដូចអណ្តែតពីលើរេហាស៍ ហើយនិយាយតទៅទៀត :

- លោកម្ចាស់ *តូរ៉ាណាកា* បានបញ្ជាអោយខ្ញុំជួយពន្យល់ណែនាំគាត់ ។

- អូមែន ! លោកម្ចាស់ *តូរ៉ាណាកា*-មេបញ្ជាការងាកសំលឹងមើលទៅវិមានមួយភ្លែត រួចទើបបែរទៅសំលឹងមើល *ប្លាក់ថន* វិញម្តង-អ្នកស្រីប្រាប់ខ្ញុំបានទេថា ហេតុអីបានជាលោកម្ចាស់ *តូរ៉ាណាកា* យកចិត្តទុកដាក់លើវាខ្លាំងម្ល៉េះ ?

- ខ្ញុំមិនដឹងដែរ ។ តែខ្ញុំស្មានថា ក្រែងលោកគាត់នេះជាមនុស្សចំលែកទេដឹង ។

ពួកគេបត់ចេញទៅតាមផ្លូវមួយទៀតដែលអមដោយផ្ទះ ដែលមានសួនច្បារធ្វើជារបង ។ នៅលើផ្លូវនេះមានមនុស្សតែប៉ុន្មាននាក់ប៉ុណ្ណោះ ។ ផុតពីនេះទៅគឺផែនិងសមុទ្រ ។ ដងក្តោងទូកនិងសំពៅលូតផុតដំបូលផ្ទះទាំងឡាយហើយអាកាសធាតុធំពាប់ដោយក្លិនសារ៉ាយ ។ មេបញ្ជាការពួកអាវប្រផេះបន្តសំនួរ :

- ចុះអ្នកស្រីមាននិយាយពីរឿងអីទៀតទេ ?

- ពួកនេះមានទស្សនៈចំលែកណាស់ ។ ពួកគេពេលណាក៏គិតតែរឿងលុយដែរ ។

- មានគេនិយាយថា ម៉ាស្រុកពួកវានេះ គឺមានសុទ្ធតែពួកឈ្មួញចោរសមុទ្រហើយគ្មានសាមូរ៉ៃម្នាក់ទេ ។ ចុះបើអីចឹង តើលោកម្ចាស់ *តូរ៉ាណាកា* ចង់បានអីពីវា ?

- ខ្ញុំស្តាយណាស់ ខ្ញុំឥតដឹងអីទាំងអស់ ។

-មានគេនិយាយទៀតថាវាជាគ្រិស្តសាសនិក ហើយវាក៏អះអាងថាវាជាគ្រិស្តសាសនិកផងដែរ ។ តើមែនទេ ?

- មិនមែនគ្រិស្តសាសនិកបែបពួកយើងទេ លោកមេបញ្ជាការ ។ លោកជាគ្រិស្តសាសនិកដែរអ្ហី ?

- ម្ចាស់របស់ខ្ញុំគឺជាគ្រិស្តសាសនិក អីចឹងហើយខ្ញុំក៏ជាគ្រិស្តសាសនិកដែរ ។ ម្ចាស់ខ្ញុំគឺលោក *គីយ៉ាម៉ា* ។

-ខ្ញុំមានកិត្តិយសបានស្គាល់លោកម្ចាស់ *គីយ៉ាម៉ា* ច្បាស់ណាស់ ។ លោកបានផ្តល់កិត្តិយសយ៉ាងសំបើមដល់ប្តីខ្ញុំ ដោយលោកសុខចិត្តភ្ជាប់ពាក្យចៅស្រី របស់លោកជាមួយនឹងកូនប្រុសខ្ញុំ ។



www.budinst.gov.kh www.elibraryofcambodia.org

- បាទ ខ្ញុំបានដឹងពីរឿងនេះដែរ អ្នកស្រី *ភូដា* ។

- តើលោកម្ចាស់ *គីយ៉ាម៉ា* បានធូរស្រាលបន្តិចទេ ? តាមខ្ញុំដឹង គ្រូពេទ្យមិនអនុញ្ញាត អោយអ្នកណាជួបលោកម្ចាស់ *គីយ៉ាម៉ា* ទេ មែនទេ ?

- ខ្ញុំមិនដែលបានជួបលោកម្ចាស់ប៉ុន្មានអាទិត្យហើយ ។ ពួកយើងទាំងអស់គ្នានេះគ្មានអ្នកណាម្នាក់បានជួបលោកទេ ។ ប្រហែលជារោគប៉េសចិនក៏មិនដឹង ។ សូមព្រះអង្គជាម្ចាស់ជួយថែរក្សាលោកម្ចាស់ និងដាក់បណ្តាសាពួកអាចិនចង្រៃយក៏នេះផង -បុរសនេះចោលភ្នែកទៅ *ប្លាក់ថន* មួយខ្ទាច់-គ្រូពេទ្យនិយាយថា ពួកអាចុងស្រុកអស់នេះបាននាំចំលងរោគប៉េសទៅចិនទៅម៉ាកាវ រួចបន្ទាប់មកស្រុកយើងនេះ ។

*ម៉ារីកូ* តបជាភាសាឡាតាំង :

- វាសនារបស់យើងស្រេចលើព្រះជាអ្នកកំនត់ទេ ។

- ពិតមែនហើយ *អាមែន !*

មេបញ្ជាការឆ្លើយតបជាភាសាឡាតាំងជាស្វ័យប្រវត្តិ ដោយឥតចាប់ភ្លឹកថាខ្លួនចូលក្នុងអន្ទាក់របស់ *ម៉ារីកូ* ដែលចង់សាកមើលថា តើខ្លួនចេះភាសាឡាតាំង រឺអត់នោះឡើយ ។

*ប្លាក់ថន* ក៏បានកត់សំគាល់កំហុសរបស់បុរសជាមេបញ្ជាការនេះដែរ ។ គេប្រទះឃើញនូវពន្លឺកំហឹងដែលបានលេចឡើងនៅលើផ្ទៃមុខរបស់បុរសនេះ ហើយគេលឺបុរសនេះនិយាយរង្វើរៗទៅកាន់ *ម៉ារីកូ* ដែលបន្ទាប់មកឡើងមុខក្រហម ហើយឈប់លែងបន្តដំណើរទៅមុខទៀត។ គេក៏ចុះពីលើស្នែង ហើយដើរទៅរកអ្នកទាំងពីរ ។

- បើមេបញ្ជាការចេះនិយាយភាសាឡាតាំងដែរនោះ គឺពិតដូចជាលោកដាក់ទានដល់ខ្ញុំអីចឹង បើសិនជាលោកយល់ព្រមនិយាយភាសានេះជាមួយខ្ញុំមួយភ្លែត ។ ខ្ញុំស្រេកឃ្លានចង់ស្គាល់ពីមហាប្រទេសនេះណាស់ ។

- បាន ខ្ញុំពិតជាចេះភាសារបស់លោកមែន ។

- ភាសាឡាតាំង មិនមែនជាភាសាកំនើតរបស់ខ្ញុំទេ លោកមេបញ្ជាការ ។ ប៉ុន្តែនេះគឺជាភាសាសាសនា និងជាភាសាដែលអ្នកចេះដឹងនិយមប្រើនៅក្នុងពិភពរបស់ខ្ញុំ ។ លោក



www.budinst.gov.kh www.elibraryofcambodia.org

និយាយភាសានេះបានល្អណាស់ ។ តើលោករៀនភាសានេះពីអង្កាល់ ? រៀនតាមអី ?

ក្បួនដំណើរបានដើរហួសអ្នកទាំងបី ហើយទាំងពួកអាវប្រផេះ ទាំងពួកអាវខ្មៅ សុទ្ធតែតាមសំលឹងមើលពួកគេគ្រប់ៗគ្នា ។ *ប៊ុនតារ៉ូ* ដែលដើរកិតៗស្នែង *តូរ៉ាណាកា* នោះ ក៏បញ្ឈប់ដំណើរ ហើយងាកបែរមកក្រោយ ។ ក្នុងស្ថានភាពនេះ បុរសមេបញ្ជាការអាវប្រផេះរាងបែបអេះអុញ ហើយក៏បន្តដំណើរទៅមុខទៀតទៅ ។ *ម៉ារីកូ* សែនរីករាយចំពោះប្រការដែល *ប្លាក់ថន* បានចុះមកជាមួយនាង ហើយអ្នកទាំងបីក៏បន្តដំណើរយ៉ាងស្ងៀមស្ងាត់មួយរយៈទៅមុខទៀត ទើប *ប្លាក់ថន* សួរឡើង :

- លោកមេបញ្ជាការនិយាយភាសាឡាតាំងឡើងរ៉ាវតែម្តង មែនទេ ?

- ចាស់ ពិតមែន ។

រួចនាងងាកបែរទៅសួរបុរសនោះ :

- តើលោករៀនភាសានេះនៅក្នុងសាលាធម៌មែនទេ ?

- រួចចុះលោកវិញ និយាយមិនរ៉ាវទេអ្វី ?

ចំលើយរបស់បុរសមេបញ្ជាការមានភាពត្រជាក់ស្រេង ហើយដោយឥតមានយកចិត្តទុកដាក់អ្វីបន្តិចបន្តួចដល់ *ម៉ារីកូ* ឡើយ ។ នៅក្នុងអនុស្សាវរីយ៍របស់ខ្លួន បុរសនេះសែនស្អប់សាលាធម៌នៅម៉ាការ ដែល *តឺយ៉ាំម៉ា* បានបញ្ជូនខ្លួនអោយទៅរៀនភាសានេះតាំងពីនៅកុមារភាពនោះជាពន់ពេក :

- អីលូវនេះ បើយើងអាចនិយាយគ្នាផ្ទាល់បានហើយយ៉ាងនេះ សូមលោកនិយាយត្រង់មកមើល ថាហេតុអ្វីបានជាលោកសួរទៅស្ត្រីនេះថា : "មានអ្នកណាខ្លះ " ទៀតដែលដឹង..." តើអ្នកណាខ្លះទៀតដឹងពីរឿងអីទៅ ?

- ខ្ញុំនឹកមិនឃើញទេ ។ អារម្មណ៍ខ្ញុំវើវវាយណាស់អីលូវនេះ ។

- វើវវាយ ? ចុះហេតុអ្វីបានជាលោកនិយាយថា " អ្វីដែលជារបស់ *សេសា* ត្រូវជូនទៅ *សេសា* វិញ " យ៉ាងនេះ ?

- នេះជាការនិយាយសើចលេងទេតើ ។ ខ្ញុំជជែកលេងជាមួយអ្នកស្រីខាងនេះ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

អ្នកស្រីបាននិយាយរឿងល្អជាច្រើន ប៉ុន្តែមានពេលខ្លះពិបាកយល់មែនទែន ។

- ពិតហើយ មានរឿងច្រើនណាស់ដែលត្រូវស្វែងយល់ ។ ហេតុអ្វី ស្រាប់តែពេលមកដល់ខ្លោងទ្វារ លោកប្រែទៅជាឆ្កួតឡប់សតិយ៉ាងហ្នឹង ហើយហេតុអ្វីបានជាលោកឆាប់ជាយ៉ាងនេះ ?

- នេះគឺករុណាធម៌របស់ព្រះណា !

ពួកគេដើរទៅក្បែរស្មែងជាថ្មីម្តងទៀត ។ បុរសមេបញ្ជាការសែនមួម៉ៅនៅក្នុងចិត្តដោយខ្លួនត្រូវជាប់អន្ទាក់របស់ *ម៉ារីកូ* យ៉ាងងាយៗបែបនេះ ។ លោកម្ចាស់ *គីយ៉ាម៉ា* បានប្រាប់គេជាមុនថែមទៀតផង ថានារីនេះឈ្លាសវៃណាស់ :" ឯងមិនត្រូវភ្លេចទេថា អារឿងក្បត់គឺជាសាច់ ជាឈាម ជាដង្ហើមរបស់មីស្រីនេះ ហើយអាចោរសមុទ្រនោះ គឺព្រលឹងសាតង់ នៅសណ្ឋិតក្នុងខ្លួនវា។ ចាំគយគន់ ចាំស្តាប់ ហើយត្រូវចាំសព្វចាំគ្រប់ ។ ជូនកាលមីស្រីនោះអាចធ្វើអោយបែកការណ៍អ្វីមួយ ហើយអាចក្លាយជាសាក្សីសំខាន់ក្នុងការប្រឆាំង *តូក័ណាកា* នៅក្នុងក្រុមប្រឹក្សាអាជ្ញានុសិទ្ធិក៏តែថាបាន ។ នៅពេលដែលពួកពូនស្ទាក់បើកឆាកប្រយុទ្ធ ឯងត្រូវសំលាប់អាចោរសមុទ្រនោះភ្លាម " ។

ផ្លែព្រួញហោះជ្រែកកាត់ស្បៃរាត្រីដូចតំនក់ទឹកភ្លៀង ។ ផ្លែព្រួញទីមួយបានមកដោតឈិបចាក់ទំលាយបំពង់ករបស់បុរសមេបញ្ជាការពួកអាវប្រផេះនេះតែម្តង ។ នៅពេលដែលបំពង់ករបស់ខ្លួនឡើងក្តៅស្ទើរឆេះ ហើយនៅពេលដែលចង្កូមមច្ចុរាជកំពុងតែហាត្របាក់ខ្លួននោះអារម្មណ៍ចុងក្រោយរបស់គេ គឺការភ្ញាក់ផ្អើលនិយាយមិនដល់ ពីព្រោះកន្លែងពួនស្ទាក់មិនមែននៅកន្លែងនេះទេ តែគឺនៅឯកំពង់ផែ ហើយការវាយលុកមិនមែនសំដៅលើរូបពួកគេនោះទេ តែគឺ ផ្តោតជាសំខាន់លើអាចោរសមុទ្រមួយតែប៉ុណ្ណោះ ។

ផ្លែព្រួញមួយទៀតបានមកដោតជាប់នឹងបង្គោលស្មែងនិតក្បាល *ព្លាក់ថន* តែប្រហែលមួយធឹងតែប៉ុណ្ណោះ ។ព្រួញពីរទៀតបានបុកទំលុះរនាំងស្មែងរបស់*គីរីស៊ីបូ* ដែលនៅខាងមុខបន្តិចហើយព្រួញមួយទៀតបានចាក់ទំលុះដើមទ្រូងរបស់នារីអ្នកបំរើម្នាក់ឈ្មោះ *អាសា* ។ ពេលដែល *អាសា* លាន់សំរែកឡើងនោះ អ្នកសែងស្មែងក៏ទំលាក់ស្មែងចុះ ហើយដាក់មេដាយកប់បាត់ទៅ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងភាពងងឹត ។ *ពួក់ថន* ចាប់ *ម៉ារីកូ* អូសទៅជ្រកពួនក្បែរស្នែងដែលក្រលាប់ចោលនោះមួយរំពេច ចំនែកឯពួកអាវប្រផេះ និងអាវខ្មៅតបែកគ្នារញ៉ាយ ។ ព្រួញធ្លាក់ស្រោចដូចគ្រាប់ភ្លៀងលើស្នែងទាំងពីរ ។ កន្លែងដែល *ម៉ារីកូ* ឈរនៅអំបាញ់មិញនោះ ត្រូវព្រួញមួយដោតឈិបនៅនឹងដី ។ *ប៊ុនតារ៉ូ* យកខ្លួនរបស់គេពាំងស្នែងរបស់ *តូរ៉ាណាកា* ជាប់ ។ ព្រួញមួយបានមកដោតជាប់ពីក្រោយអាវក្រោះធ្វើពីឫស្សី និងសំនាញ់ដែករបស់គេ ។ ពេលដែលស្ងប់ព្រួញ *ប៊ុនតារ៉ូ* ស្ទុះទៅកន្ត្រាក់រនាំងស្នែងភ្លើចឡើងយ៉ាងអស់ទំហឹង ។ ព្រួញមួយបានដោតជាប់ដើមទ្រូង និងមួយទៀតជាប់នឹងចង្កេះរបស់ *តូរ៉ាណាកា*។ ប៉ុន្តែលោកឥតត្រូវរបួសបន្តិចឡើយ ដោយអាវក្រោះការពារដែលលោកបានពាក់ពីក្រោមអាវគីម៉ូណូរបស់លោក ។ លោកកន្ត្រាក់ព្រួញចេញ ហើយដោះមួកហាមធំ និងសក់ក្លែងក្លាយដែលលោកពាក់នោះចោល ។ ភ្នែក *ប៊ុនតារ៉ូ* ប្រឹងសំលឹងទំលុះសែ្បរាត្រីដើម្បីរកមើលសត្រូវ ដៃកាន់ធ្នូទាញបន្តឹងហើយជាស្រេច ក្នុងពេលដែល *តូរ៉ាណាកា* កៀសរនាំងស្នែង ហើយលូកទាញយកដាវដែលលោកលាក់នៅខាងក្រៅស្នែងនោះចេញមកក្រៅ ។ *ម៉ារីកូ* ប្រុងស្ទុះចេញទៅជួយ *តូរ៉ាណាកា* ទៅហើយ ប៉ុន្តែ *ពួក់ថន* លូកដៃទាញនាងមកក្រោយជាមួយនឹងសំរែកអោយប្រុងប្រយ័ត្ន ក្នុងពេលដែលភ្លៀងព្រួញបាចសាចមកលើស្នែងទាំងពីរជាថ្មីម្តងទៀត ។ ពួកអាវខ្មៅតពីរនាក់ និងពួកអាវប្រផេះម្នាក់ត្រូវព្រួញដួលគ្មោលមួយរំពេច ។ ព្រួញមួយទៀតបានឆ្លូតជាប់សើស្បែកថ្ពាល់របស់*ពួក់ថន* ហើយព្រួញមួយទៀតបានដោតគីម៉ូណូរបស់គេជាប់ទៅនឹងដី ។ នារីអ្នកបំរើម្នាក់ទៀតឈ្មោះ *សូណូ* នៅអែបជាប់នឹង *អាសា* ដែលកំពុងរមួលខ្លួនដោយការឈឺចាប់ តែបានខាំមាត់យ៉ាងក្លាហាន ឥតមានបញ្ចេញសំរែកមួយម៉ាត់សោះឡើយ ។ *យ៉ាប៊ូ* ស្រែកចេញបញ្ចោចង្អុលទៅទិសមួយ ហើយស្ទុះហក់ទៅមុខភ្លាម ។ ស្រមោលមនុស្សនៅស្ទុងៗលើដំបូលផ្ទះ ។ ភ្លៀងព្រួញបានស្រោចមកលើស្នែងជាលើកចុងក្រោយ តែ *ប៊ុនតារ៉ូ* បាននាំទ័ពរបស់ខ្លួនពាំងការពារ *តូរ៉ាណាកា* ជាប់ ។ បុរសម្នាក់ត្រូវព្រួញដួលប្រួស ។ ព្រួញមួយទៀតបានមកចាក់ជ្រៀតចូលតាមចន្លោះអាវក្រោះនៅត្រង់ស្មារបស់ *ប៊ុនតារ៉ូ* ដែលជាហេតុធ្វើអោយបុរសនោះគ្រហឹមលាន់ព្រោះការឈឺចាប់ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏*យ៉ាប៊ូ* នៅតែនាំមុខកូនទ័ពរបស់ខ្លួនរុលរហូតទៅដល់ជញ្ជាំងដើម្បីចូលវាយលុកពួកសត្រូវ ប៉ុន្តែពួកនេះបានគេចខ្លួនបាត់



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងទីងងឹត ប្រៀបបីដូចជាបិសាច ហើយទាំងពួកអារក្មោត ទាំងពួកអារប្រផេះ សុទ្ធតែដឹងយ៉ាងច្បាស់ថា ទោះជាពួកគេប្រឹងដេញតាមយ៉ាងណាក្តីក៏ពួកគេមិនអាចដេញតាមពួកនេះប្រកបដោយលទ្ធផលល្អឡើយ ។

ក្រោយពីស្ថានភាពមានសន្តិសុខឡើងវិញហើយ *ភ្លាក់ផន* ក៏ក្រោកឡើង ហើយជួយលើក *មារីកូ* អោយបានឈរត្រង់ខ្លួនឡើងវិញ ។ នាងគ្មានត្រូវរបួសអ្វីទេ ប៉ុន្តែខ្លួននាងនៅញ័រចំប្រប់នៅឡើយ ។

- អរគុណ ។

នាងនិយាយទៅកាន់ *ភ្លាក់ផន* ហើយក៏ប្រញាប់ប្រញាល់ស្ទុះទៅឈរបាំង *តូរ៉ាណាកា* កុំអោយពួកអារប្រផេះឃើញ ។ *ប៊ុនតារ៉ូ* ស្រែកបញ្ជាអោយកូនចៅរបស់ខ្លួនពន្លត់ចន្លុះដែលនៅជិត១ស្ទើងទាំងអស់ ប៉ុន្តែគឺយឺតពេលណាស់ទៅហើយ ។ បុរសអារប្រផេះម្នាក់ក្រលេកឃើញហើយលាន់មាត់ឡើង :

- *តូរ៉ាណាកា !*

ទោះជាសំដីភ្ញាក់ផ្អើលត្រូវបាននិយាយឡើងយ៉ាងស្រាលក្តី ក៏វាបានលឺពេញត្រចៀករបស់គ្រប់១គ្នាមួយរំពេច ។

នៅក្នុងពន្លឺភ្លឹបភ្លែតនៃចន្លុះ មុខ *តូរ៉ាណាកា* ដែលផាត់ម្សៅ និងដែលដាមប្រតេកប្រតាកដោយញើស មិនខុសអ្វីពីមុខតុក្កតានោះឡើយ ។

មេក្រុមពួកអារប្រផេះម្នាក់លំអោនខ្លួនគោរពយ៉ាងប្រញាប់ប្រញាល់ ។ គេមិនយល់សោះតែម្តងថា ហេតុអ្វីបានជាសត្រូវរបស់លោកម្ចាស់របស់គេមកនៅជ្រងោ១ខាងក្រៅវិមានយ៉ាងដូច្នេះ :

- សូមលោកម្ចាស់ *តូរ៉ាណាកា* នៅរង់ចាំទីនេះហើយទាន ។

រួចបុរសនេះងាកទៅបញ្ជាកូនក្រុមរបស់ខ្លួន :

- ទៅរាយការណ៍ជូនលោកម្ចាស់ *អ៊ីស៊ីដូ* ភ្លាម ។

បុរសនេះទទួលបញ្ជា ហើយស្ទុះរត់ចេញទៅភ្លាម ។



www.budinst.gov.kh www.elibraryofcambodia.org

- ឃាត់វាភ្លាម !

*តូក៉ាណាកា* ចេញបញ្ជាយ៉ាងនឹងនរ ។ *ប៊ុនតារ៉ូ* បង្ហោះផ្លែព្រួញពីរផ្លែភ្លាម ។ បុរសនោះដួលប្រួសដាច់ខ្យល់មួយរំពេច ។ ឃើញយ៉ាងដូច្នេះ បុរសជាមេក្រុមនេះហូតដាវវែងរបស់ខ្លួន ហើយស្រែកសន្ធាប់ស្ទុះទៅរក *តូក៉ាណាកា* ប៉ុន្តែ *ប៊ុនតារ៉ូ*បានត្រៀមខ្លួនជាស្រេចហើយ ។ គេរងដាវរបស់បុរសមេក្រុមពួកអាវប្រផេះបានយ៉ាងងាយ ។ ក៏ពេលជាមួយគ្នានេះ ពួកអាវប្រផេះនិងពួកអាវខ្មោត ដែលនៅលាយឡំគ្នានោះក៏ហូតដាវចេញរៀង១ខ្លួន ហើយដកខ្លួនវាតទីកន្លែងភ្លាមដែរ ។ មួយដង្ហើមក្រោយមក ដងផ្លូវនេះបានក្លាយជាសមរភូមិយ៉ាងទ្រហឹងអឺងអាប់ ។ *ប៊ុនតារ៉ូ* និងបុរសជាមេក្រុមនៅតែប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ ដោយអ្នកទាំងពីរមានកិរិតគុនដាវប្រហាក់ប្រហែលគ្នា ។ រំពេចនោះ បុរសអាវប្រផេះម្នាក់ដកខ្លួនចេញផុតពីរង្វង់ប្រយុទ្ធ ហើយស្ទុះតំរង់ទៅរក *តូក៉ាណាកា* ភ្លាម ប៉ុន្តែ *ម៉ារីកូ* បានស្ទុះទៅយកចន្លុះមួយដែលនៅជ្រុះក្បែរនោះ ហើយរត់ទៅរក*ប៊ុនតារ៉ូ* ហើយរុកភ្លើងចន្លុះទៅរកមុខមេក្រុមពួកអាវប្រផេះនោះយ៉ាងរហ័ស ។ មួយប៉ប្រិចភ្នែកដែលបុរសនោះញ្ញោចគេចពីភ្លើងចន្លុះនោះ គ្រប់គ្រាន់នឹងអោយ *ប៊ុនតារ៉ូ* វាត់មួយដាវកាត់ផ្តាច់បុរសនោះជាពីរកំនាត់ភ្លាម ។ ទំនេរដៃហើយ *ប៊ុនតារ៉ូ* ស្ទុះហក់ទៅកាប់បុរសម្នាក់ទៀតដែលបោលតំរង់ទៅរក *តូក៉ាណាកា* នោះស្លាប់ភ្លាមមួយរំពេច ។ បុរសអាវប្រផេះម្នាក់ទៀតដែលស្ទុះមកដែរនោះ ក៏ត្រូវដាវរបស់ *ប៊ុនតារ៉ូ* ដាច់ពាក់កណ្តាលខ្លួនផងដែរ ។ *ម៉ារីកូ* ដើរថយទៅក្រោយយ៉ាងប្រយ័ត្នប្រយែង ដើម្បីកុំអោយទើសទែងដៃប្តីរបស់នាង ។ នៅក្នុងដៃនាង នៅពេលនោះមានដាវមួយទៀតផង ។ ក្រសែភ្នែករបស់នាងនៅតែផ្តោតជាប់លើ *តូក៉ាណាកា* និង *ប៊ុនតារ៉ូ* ។ .

បុរសអាវប្រផេះបួននាក់ទៀត រួមកំលាំងគ្នាស្ទុះទៅរក *ព្វាក់ថន* ដែលកំពុងឈរថ្មាំងនៅក្បែរស្នែង ប៉ុន្តែ *យ៉ាប៊ូ* និងបុរសអាវត្នោតក៏ស្ទុះទៅទប់ ហើយឆាកប្រយុទ្ធក៏បានផ្ទុះឡើងយ៉ាងស៊ីសាច់ស៊ីឈាម ។ *ព្វាក់ថន* អោនរើសយកចន្លុះមួយ ហើយប្រើវាដូចជាព្រនង់ដើម្បីរុញសត្រូវអោយចេញឆ្ងាយពីខ្លួន ។ មួយសន្ទុះក្រោយមក *យ៉ាប៊ូ* សំលាប់បានម្នាក់ និងធ្វើអោយរបួសម្នាក់ទៀត ហើយពួកអាវត្នោតបួននាក់ទៀតក៏បានស្ទុះមកបង្ហើយពួកអាវប្រផេះពីរនាក់



www.budinst.gov.kh www.elibraryofcambodia.org

ផ្សេងទៀតទៅ ។ ដោយគ្មានបង្អែបង្អង់ *យ៉ាប៊ូ* ហើយនិងសាមូរ៉ៃម្នាក់ទៀតដែលមានរបួសទៅហើយនោះ ហក់ចូលទៅក្នុងរង្វង់ប្រយុទ្ធទៀតភ្លាម ដើម្បីការពារ *តូរ៉ាណាកា ប្លាក់ថន* ស្ទុះទៅយកលំពែងកាំបិតមួយមកកាន់ ហើយឈរនៅក្បែរ *តូរ៉ាណាកា* ដែលនៅឈរយ៉ាងស្ងៀមស្ងាត់ដោយគ្មានអារម្មណ៍ភ្ញាក់ផ្អើលអ្វីទាំងអស់ ។

ពួកអាវប្រផេះដែលនៅសល់ បានប្រឹងប្រយុទ្ធយ៉ាងក្លាហាន ។ បុរសអាវប្រផេះបួននាក់ រួមកំលាំងគ្នាហក់ទៅរក *តូរ៉ាណាកា* ម្តងទៀត តែពួកអាវត្នោតបានទប់ជាប់ ហើយវាយបកទៅវិញផ្ទួនៗ រំពេចនោះ បុរសអាវប្រផេះម្នាក់ដែលមានរាងចំនាស់ជាងគេស្រែកបញ្ជាអោយសាមូរ៉ៃបីនាក់ដកខ្លួនរត់ទៅរកជំនួយ ឯអ្នកនៅសល់ទាំងប៉ុន្មាននៅបិទផ្លូវការពារអ្នកទាំងបីនេះ ។ បុរសអាវប្រផេះបីនាក់ស្ទុះរឹងរត់ទៅក្រោយ ហើយថ្វីត្បិតតែពួកអាវត្នោតប្រឹងដេញយ៉ាងណា និងទោះជាម្នាក់ត្រូវ *ប៊ុនតារ៉ូ* បាញ់ស្លាប់ក្តី ក៏បុរសពីរនាក់ទៀតនៅតែគេចខ្លួនបានក្នុងកណ្តាលរាត្រីងងឹតនោះ ។

ពួកអាវប្រផេះដែលនៅសល់ទាំងប៉ុន្មានស្លាប់ទាំងអស់ ។

☆ ☆ ☆

ពួកគេធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់តាមផ្លូវស្ងាត់ជ្រងំតូចមួយ កាត់តំរង់ទៅរកកំពង់ផែ និងទូកធំ ។ ពួកគេមានគ្នាទាំងអស់ដប់នាក់ : *តូរ៉ាណាកា* ជាអ្នកនាំមុខ តាមពីក្រោយដោយ *យ៉ាប៊ូ ម៉ារីកូ ប្លាក់ថន* និងសាមូរ៉ៃប្រាំមួយនាក់ទៀត ។ អ្នកជូនដំណើរឯទៀតស្ថិតក្រោមបញ្ជារបស់ *ប៊ុនតារ៉ូ* ធ្វើដំណើរតាមផ្លូវធំទាំងស្នែង ទាំងអឺរ៉ៃអឺវ៉ាន់ ដូចតាមការគ្រោងទុក សំដៅឆ្ពោះទៅរកទូកធំផងដែរ ។ នៅក្នុងស្នែងមួយនោះគេបានដាក់សាកសពរបស់ *អាសា* ។ នៅក្នុងពេលកំពុងប្រយុទ្ធគ្នា *ប្លាក់ថន* បានដកយកព្រួញចេញពីទ្រូងរបស់នាង ។ *តូរ៉ាណាកា* មើលឃើញឈាមបាញ់ចេញតាមមុខរបួសដូចចំពួយទឹក ហើយនិងតាមសំលឹងមើលដោយងឿងឆ្ងល់នូវអាការៈដែល *ប្លាក់ថន* បបោសអង្អែល *អាសា* ផ្ទុយពីទំលាប់នៅក្នុងស្រុក ដែលទុកអោយមនុស្សស្លាប់យ៉ាងស្ងប់ស្ងៀម និងយ៉ាងថ្លៃថ្នូរទៅវិញ ហើយនៅពេលឆាកប្រយុទ្ធស្ងប់ស្ងាត់ទៅ លោកឃើញ *ប្លាក់ថន* ដាក់សាកសព *អាសា* យ៉ាងថ្នមៗទៅក្នុងស្នែង ។ *អាសា* ពិតជាក្លាហានអង់អាចមែន



www.budinst.gov.kh www.elibraryofcambodia.org

ទែន នាងឥតផ្លូវមួយម៉ាត់ណាសោះ គឺគ្រាន់តែសំលឹងមើល *ភ្លក់ផន* រហូតដល់ពេលដាច់ដង្ហើម តែប៉ុណ្ណោះ ។ *តូរ៉ាណាកា* បានបញ្ជាអោយទុកសាកសព *អាសា* នៅក្នុងស្នែងបិទវាំង ហើយនិងដាក់សាមូរ៉ៃរបួសម្នាក់ទៀតនៅក្នុងស្នែងមួយទៀត ដើម្បីបន្លំភ្នែកអ្នកផង ។

ក្នុងចំនោមពួកពាក់អាវពណ៌ត្នោតចំនួនហាសិបនាក់ ដែលជូនដំណើរចេញពីវិមាននោះ មានដប់ប្រាំនាក់ត្រូវស្លាប់ ហើយដប់មួយនាក់ទៀតត្រូវរបួសជាទំងន់ ។ អ្នករបួសទាំងនេះបានផ្តាច់ជីវិតខ្លួនយ៉ាងរហ័ស ។ បីនាក់ដោយដៃខ្លួនគេផ្ទាល់ ប្រាំបីនាក់ទៀតបានស្នើអោយ *ប៊ុនតារ៉ូ* ជួយធ្វើការងារនេះដល់ខ្លួន ។ រួចរាល់ស្រេចបាច់ហើយ *ប៊ុនតារ៉ូ* ប្រមូលអ្នកដែលនៅសល់ទាំងប៉ុន្មាន ដើរអមស្នែងបន្តដំណើរតាមផ្លូវធំបន្តទៅទៀត ។ នៅលើទីលានប្រយុទ្ធ ពួកអាវប្រផេះសែសិបប្រាំបីនាក់នៅដេកស្លាប់ស្តូកស្តឹងទាំងអស់ ។

ផ្តាច់ខ្លួនពីក្រុមធំយ៉ាងនេះ *តូរ៉ាណាកា* ដឹងច្បាស់ណាស់ថា ខ្លួនលោកប្រថុយប្រថាននឹងគ្រោះថ្នាក់មែនទែន តែទោះជាយ៉ាងនេះក្តី ក៏លោកនៅតែសប្បាយរីករាយនៅក្នុងចិត្តដែរ ។ អ្វី១បានដំណើរការបានល្អណាស់ - លោកគិតទៅក្នុងចិត្ត - បើយោងទៅលើដំណើរប្រែប្រួលនៃរឿងហេងស៊ុយកន្លងមកនេះ ។ គិតទៅជីវិតចំជាចំលែកអស្ចារ្យមែន ! ដំបូងអញគិតថា គឺជាប្រផ្នូលអាក្រក់តែម្តងដែលតែកុងនេះឃើញអញប្តូរកន្លែងជាមួយ *គីរី* ។ ក្រោយមកទៀតវាបានជួយអញហើយធ្វើដូចជាមនុស្សឆ្កួតពិត១តែម្តង ។ ដោយប្រការនេះហើយដែលធ្វើអោយអញគេចរួចពី *អ៊ីស៊ីដូ* បាន ។ តែអញមិនស្មានបានថានឹងជួប *អ៊ីស៊ីដូ* នៅខ្លោងទ្វារកំផែងសោះ ព្រោះអញប៉ាន់ថា *អ៊ីស៊ីដូ* នឹងមកពិនិត្យតែនៅពេលចេញដំណើរតែប៉ុណ្ណោះ ។ ហេតុអីបានជា *អ៊ីស៊ីដូ* មានវត្តមាន នៅខ្លោងទ្វារកំផែងនេះ ? *អ៊ីស៊ីដូ* មិនមែនជាមនុស្សប្រយ័ត្នប្រយែងដល់ថ្នាក់នេះឡើយ ។ តើអ្នក ណាផ្តល់មតិទៅវា ? *គីយ៉ាម៉ា* ? *អូណូស៊ី* ? រឺមួយក៏ *យ៉ូដូកូ* ? អាចជា *យ៉ូដូកូ* ដែរ ព្រោះនារីអាច ឆាប់សង្ស័យលើរឿងល្បិចបែប១នេះណាស់ ។

នោះគឺពិតជាផែនការដ៏ល្អិតល្អន់ ដែលត្រូវបានត្រៀមរៀបចំច្រើនអាទិត្យមកហើយ ដោយ *តូរ៉ាណាកា* ប៉ាន់ដឹងថា *អ៊ីស៊ីដូ* ប្រាកដជាប្រឹងប្រែងឃាត់រូបលោកអោយនៅក្នុងវិមាន ហើយនិងបំផុសសមាជិកក្រុមប្រឹក្សាអាជ្ញានុសិទ្ធិឯទៀតអោយប្រឆាំងនឹងរូបលោក ជាមិនខាន



www.budinst.gov.kh www.elibraryofcambodia.org

ដោយវិធីសន្សាគ្រប់បែបយ៉ាងដល់អ្នកណាដែលព្រមរួមដៃនឹងខ្លួន ។ *អ៊ីស៊ីដូ* ពិតជានឹងធ្វើបែបនេះ ថ្វីបើជំទាវ *អូជីតា* ស្ថិតនៅជាចំនាប់នៅឯយេដូក្ដី ហើយគេនឹងបង្ខាំងរូបលោករហូតដល់ថ្ងៃដែលក្រុមប្រឹក្សាអាជ្ញានុសិទ្ធិបើកសម័យប្រជុំ ដែលនៅពេលនោះពួកគេនឹងដកហូតសិទ្ធិរបស់លោក ហើយនិងសំរេចពីវាសនារបស់លោក ។

- ប៉ុន្តែពួកវានៅតែអាចដកហូតមុខតំនែងរបស់លោកម្ចាស់តែដដែលហ្នឹង !

នេះគឺឧទ្ទានរបស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* កាលពីយប់ម្សិលមិញ នៅពេលដែល *តូរ៉ាណាកា* ពន្យល់ពីផែនការរបស់លោក និងពីហេតុអ្វីលោកត្រូវបង្ខំចិត្តធ្វើបែបនេះ ។ កណ្ដាប់ដៃដែកនិយាយបន្ត :

- ទោះបីជាលោកម្ចាស់អាចគេចចេញផុតក្ដី ក៏ពួកនេះនៅតែអាចដកហូតមុខតំនែងលោកម្ចាស់ពីក្រោយខ្នងលោកម្ចាស់យ៉ាងងាយ ដូចជាគេនឹងធ្វើនៅពេលមានវត្តមានរបស់លោកម្ចាស់ដដែល ។ ដល់ពេលនោះ លោកម្ចាស់ត្រូវតែធ្វើ *សិបពុគូ* នៅពេលណាដែលពួកវាចេញបញ្ជា ហើយពួកវាច្បាស់ជាចេញបញ្ជានេះ ។

- ពិតហើយ *-តូរ៉ាណាកា* ឆ្លើយតប -ក្នុងឋានៈជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិខ្ញុំត្រូវតែធ្វើតាមពួកវា បើសិនជាអ្នកទាំងបួនបោះឆ្នោតប្រឆាំងនឹងខ្ញុំ ។ ប៉ុន្តែ....

*តូរ៉ាណាកា* លូកយកក្រមួរសារមួយចេញពីក្នុងដៃអាវរបស់ខ្លួន ហុចទៅ *ហ៊ីរ៉ូ-ម៉ាត់ស៊ី :*

- នេះគឺពាក្យសុំលាលែងចេញពីក្រុមប្រឹក្សាអាជ្ញានុសិទ្ធិរបស់ខ្ញុំ ។ លោកត្រូវប្រគល់វាទៅ *អ៊ីស៊ីដូ* នៅពេលណាដែលគេបានដឹងពីការគេចខ្លួនរបស់ខ្ញុំហើយ ។

- លោកម្ចាស់មានប្រសាសន៍ថាម៉េច ?

- បើសិនជាខ្ញុំលាលែង ខ្ញុំឥតមានជាប់អ្វីនឹងពាក្យសម្បថរបស់ខ្ញុំទៀតទេ ។ អម្ចាស់ *តៃកូ* ក៏ឥតបានហាមឃាត់ខ្ញុំមិនអោយលាលែងពីតំនែងដែរ មែនទេ ? ហើយប្រគល់វានេះទៅ *អ៊ីស៊ីដូ* ផងដែរ ។

*តូរ៉ាណាកា* ហុចត្រាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិទៅអោយ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ទុក ។

- ប៉ុន្តែលោកម្ចាស់នឹងត្រូវឯកោ ហើយមិនខុសអ្វីពីត្រូវគេកាត់ទោសហើយដែរទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកយល់ច្រលំហើយ ។ ចាំស្ដាប់ខ្ញុំណា ! បណ្ដាំរបស់អម្ចាស់ *វ៉ាគូ* គឺត្រូវមាន សមាជិកក្រុមប្រឹក្សាចំនួនប្រាំនាក់ ដើម្បីគ្រប់គ្រងប្រទេស ។ អីលូវនេះមានតែបួនប៉ុណ្ណោះ ។ ដើម្បីអោយស្របច្បាប់ ដើម្បីអាចដឹកនាំប្រទេសក្នុងនាមព្រះចៅបាន ពួកវាទាំងបួនត្រូវបោះឆ្នោត រឺចាត់តាំងសមាជិកថ្មីម្នាក់បន្ថែមទៀតជាទីប្រាំមែនទេ ? *អ៊ីស៊ីដូ គីយ៉ាមៅ អូណូស៊ី* និង *ស៊ូគីយ៉ាម៉ា* ត្រូវតែឯកភាពជាមួយគ្នាមែនទេ ? ព្រោះសមាជិកថ្មីនៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ត្រូវតែទទួលបានការឯកភាពពីអ្នកចាស់ទាំងបួន មិនអីចឹង ? អីលូវលោកគិតសាកទៅមើល តើពួកនេះនឹងយល់ព្រមចែករំលែកអំនាចពួកវាជាមួយអ្នកណា ? អ្នាស ? ហើយនៅពេលដែលពួកវាជជែកគ្នា ពិភាក្សាគ្នា....

-ពួកយើងត្រៀមរៀបចំសង្គ្រាម ហើយលោកម្ចាស់ក៏លែងជាប់សម្បថអ្វីទៀតដែរ ។ លោកម្ចាស់អាចចាក់ទឹកឃ្មុំនៅកន្លែងនោះបន្តិច បន្តក់ពិសនៅកន្លែងនោះបន្តិច ហើយពួកអាត្មាតអស់នេះនឹងហែកហួគ្នាស៊ីជាមិនខាន *-ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* និយាយកាត់ទាំងរហ័ន-លោកម្ចាស់ *យ៉ូស៊ី តូរ៉ាណាកា-ណូ-មីណូរ៉ាកា* លោកគឺជាមនុស្សក្នុងចំនោមមនុស្ស ។ ខ្ញុំប៉ាននកាត់ក្បាលចោល បើសិនណាលោកម្ចាស់មិនមែនជាមនុស្សវាងវៃជាងគេបំផុតនៅក្នុងនគរនេះទេនោះ ។

ពិតណាស់ នេះជាផែនការមួយយ៉ាងល្អ *-តូរ៉ាណាកា* គិតនៅក្នុងចិត្ត-ហើយគ្រប់គ្នាសុទ្ធតែបានបំពេញមុខនាទីរបស់ខ្លួនយ៉ាងល្អប្រសើរ : *ហ៊ីរ៉ូ-ម៉ាត់ស៊ឺ គីរី* និង *សាស៊ូកូ* បណ្ដូលចិត្តអញ ។ អីលូវនេះពួកគេត្រូវជាប់នៅក្នុងវិមាន ហើយនឹងត្រូវនៅជាប់ទីនោះរហូត រឺមួយពួកគេនឹងទទួលការអនុញ្ញាតអោយចាកចេញ ។ ប៉ុន្តែអញយល់ថា ពួកនេះមិនទទួលបានការអនុញ្ញាតអោយចាកចេញពីវិមានឡើយ ។

បាត់បង់ពួកនេះ គឺជាការមួយគួរអោយសោកស្ដាយមែនទែន ។

*តូរ៉ាណាកា* នាំក្រុមរបស់ខ្លួនដើរដោយឥតមានបង្អែបង្អង់ឡើយ ។ លោកដើរយ៉ាងញាប់ ។ នេះគឺជាដំណើរដែលលោកបានប្រើក្នុងពេលបរបាញ់ ហើយជាដំណើរដែលលោកអាចប្រកាន់យកក្នុងពីរថ្ងៃមួយយប់ពេញក៏បាន បើសិនជាចាំបាច់ ។

ពួកគេឆ្លងកាត់ផ្លូវថ្មលស្ងាត់ជ្រងំមួយ ហើយតំរង់ទៅរកច្រកផ្លូវតូចមួយ ។ *តូរ៉ាណាកា*



www.budinst.gov.kh www.elibraryofcambodia.org

ដឹងច្បាស់ថា ដំណឹងអាសន្នបែបនេះនឹងទៅដល់ *អ៊ីស៊ីដូ* ក្នុងពេលបន្តិចនេះ ហើយពេលនោះចលនាទ័ពនឹងកំរើកសកម្មភាពដើម្បីដេញតាមរូបលោកជាមិនខាន ។ ប៉ុន្តែអីលូវនេះអញនៅសល់ពេល នៅឡើយទេ -លោកគិតនៅក្នុងចិត្ត ។

តើអ្នកណាជាអ្នកចេញបញ្ជាអោយមានការប្រយុទ្ធអំបាញ់មិញនេះ ? ជា *គីយ៉ាម៉ា* រឺអូណូស៊ុ ? រឺមួយជាពួកប៉ក់ទុយកាល់ ? រឺមួយជាពួកបព្វជិតគ្រិស្តសាសនា ?

*តូរ៉ាណាកា* ងាកមើលទៅក្រោយដើម្បីរកមើលបុរសតៃកុង ។ លោកឃើញថា ទាំង *ប្លាក់ថន* ទាំង *ម៉ារីកូ* នៅតែបន្តដំណើរបាននៅឡើយ ថ្វីបើអ្នកទាំងពីរហេវហត់យ៉ាងណាក្តី ។ នៅឯជើងមេឃ រូបរាងវិមាននិងសើនខ្ពស់ៗ បង្ហាញរូបរាងរបស់ខ្លួនព្រាលៗ ។ យប់នេះគឺជាយប់ទីពីរហើយ ដែលអញរិះតែនឹងអស់ជីវិតនៅ ក្នុងវិមាននេះ -លោកគិតនៅក្នុងចិត្ត ។ តើវិមាននេះពិតជានឹងក្លាយជាសត្រូវរបស់អញមែនរឺ? អម្ចាស់ *វ៉ែតូ* តែងនិយាយប្រាប់អញជាញឹកញយថា : " ដរាបណាវិមានអូសាកានៅតែឈររឹងមាំនៅឡើយនោះ ពូជអម្បូររបស់ខ្ញុំ នឹងមិនរលត់រលាយហើយ *តូរ៉ាណាកា មីណូវ៉ារ៉ា* លោកនឹងមានឈ្មោះចារឹកនៅលើកំផែងនៃវិមាននេះ ។ អូសាកាគឺជាផ្ទះរបស់លោកហើយ " ។

តើអម្ចាស់ *វ៉ែតូ* មកសណ្ឋិតនៅក្នុងខ្លួន *យ៉ែនម៉ុន* រឺ ? តែទោះជាលោកមកសណ្ឋិតរឺមិនសណ្ឋិតក្តី ក៏ *យ៉ែនម៉ុន* ជាទាយាទស្របច្បាប់ផងដែរ ។

*តូរ៉ាណាកា* ប្រឹងដកភ្នែកចេញពីវិមាន ហើយនាំក្រុមរបស់ខ្លួនបត់តាមកែងផ្លូវមួយទៀត ដើម្បីដើរតាមច្រកផ្លូវតូចៗ ជាច្រើន និងដ៏ក្រវែចក្រវៀន ។ នៅទីបំផុតលោកបានឈប់នៅពីមុខទ្វារដ៏សំរឹកមួយ ដែលមានឆ្លាក់រូបត្រីជាប់នឹងសន្លឹកទ្វារ ។ លោកគោះទ្វារតាមសញ្ញាសំងាត់ ។ ទ្វាររបើកភ្លាម ហើយសាមូរ៉ៃសើងមម៉ើងម្នាក់ក៏ចេញមកលំអោនខ្លួនគោរព :

- លោកម្ចាស់ ?

- នាំពួកឯងមកតាមខ្ញុំភ្លាម !

និយាយរួច *តូរ៉ាណាកា* បន្តដំណើរទៅទៀតភ្លាម ។

- ទទួលបញ្ជាដោយរីករាយទាន !



www.budinst.gov.kh www.elibraryofcambodia.org

សាមូរ៉ៃនេះឥតស្លៀកពាក់ឯកសណ្ឋានរបស់ពួកអាវខ្មៅតទេ ប៉ុន្តែគេពាក់ខោអាវកញ្ចាស់ៗរបស់ រ៉ូនីន ទៅវិញ ។ តាមពិតបុរសនេះស្ថិតនៅក្នុងកងកំលាំងពិសេសជើងឆើត ដែល តូរ៉ាណាកា បានលបបញ្ជូនចូលក្នុងទីក្រុងអូសាកា ដើម្បីបង្ការភាពអាសន្នបែបនេះជាដើម ។ រំពេចនោះ មនុស្សដប់ប្រាំនាក់ដែលស្លៀកពាក់ខោអាវដូចៗគ្នា តែប្រដាប់ដោយអាវុធគ្រប់គ្រាន់ បានចេញពីក្នុងផ្ទះទៅតាមក្បួនដំណើររបស់ តូរ៉ាណាកា ភ្លាម ។ ក្នុងវិន័យយ៉ាងថ្លៃថ្នូរ និងយ៉ាងស្ទាត់ជំនាញ ពួកនេះរំលែកគ្នាដើម្បីចែកជាកំលាំងនាំមុខ និងកំលាំងការពារផ្នែកក្រោយយ៉ាងរហ័ស ចំនែកឯសាមូរ៉ៃម្នាក់ទៀតរត់ទៅអោយសញ្ញាអាសន្នដល់កំលាំងបង្កប់ផ្សេងៗទៀត ។ ក្នុងរយៈពេលមួយយ៉ាងខ្លីប៉ុណ្ណោះ តូរ៉ាណាកា មានទ័ពហាសិបនាក់មកហែហមលោកភ្លាម ។ សាមូរ៉ៃមួយរយនាក់ទៀតដើរការពារឆ្នឹងជំនីក្បួនរបស់លោកទាំងសងខាង ។ បើសិនជាលោកត្រូវការនៅពេលព្រឹកព្រលឹមនេះ លោកនឹងមានកំលាំងបន្ថែមមួយពាន់នាក់ទៀតដែលត្រៀមខ្លួនហើយជាស្រេច ។ ក្នុងស្ថានភាពនេះ លោកបន្ធូរអារម្មណ៍ ហើយបង្អង់ល្បឿនជើងរបស់លោក ដោយលោកដឹងថា ទាំង ពួក់ថុន ទាំង ម៉ារីកូ សុទ្ធតែហត់ឡើយមែនទែនហើយៗលោកចង់អោយអ្នកទាំងពីរនៅរក្សាបានកំលាំងមាំមួនរបស់ពួកគេ ។

☆ ☆ ☆

តូរ៉ាណាកា ឈរនៅក្នុងទីងងឹតនៃឃ្លាំងទំនិញ ហើយប្រឹងពិនិត្យសភាពការណ៍នៅលើទូកធំ នៅលើផែ និងនៅលើឆ្នេរសមុទ្រ ។យ៉ាប៊ូ ហើយនិងសាមូរ៉ៃម្នាក់នៅពីក្រោយលោក ។អ្នកឯទៀតកំពុងឈរជារបាំងយ៉ាងញឹកនៅចុងច្រកផ្លូវប្រមាណប្រហែលមួយរយជំហានពីទីនេះ ។

នៅប្រហែលប៉ុន្មានរយជំហានពីកន្លែងដែលលោកឈរ តូរ៉ាណាកា ឃើញពួកអាវប្រផេះប្រហែលមួយរយនាក់កំពុងឈរយាមក្បែរជណ្តើរឡើងទៅលើទូក ។ ពួកនេះឈរនៅម្ខាងនៃដីវាលស្រលះមួយ ដែលអាចអោយពួកគេគេចផុតពីវាលវ៉ាយលុកជាថែជន្យទាំងឡាយ ។ ដងថែវត្រូវលើកដាក់បណ្តោយទូក ហើយ តូរ៉ាណាកា មើលឃើញពួកនាវិក និងពួកយុទ្ធជនមួយ ចំនួន កំពុងដើរចុះដើរឡើងស្ទុងៗនៅលើទូកធំនោះផង ។

តូរ៉ាណាកា និយាយខ្សឹបៗទៅកាន់ យ៉ាប៊ូ :



www.budinst.gov.kh www.elibraryofcambodia.org

- តើពួកនេះ ជាពួកយើងរឺពួកគេ ?

- ឆ្ងាយយ៉ាងនេះមើលមិនច្បាស់ទេទាន ។

ជំនោរសមុទ្រឡើងខ្ពស់ណាស់ទៅហើយ ។ រំលងហួសពីទូកធំទៅ ទូកនេសាទពេលយប់ចេញចូលឥតអាក់ ដោយប្រើគោមរបស់ខ្លួនសំរាប់បំភ្លឺផ្លូវផង សំរាប់ចាប់ត្រីផង ។ នៅតាមបណ្តោយឆ្នេរនៅទិសខាងជើង មានទូកនេសាទតូចៗកំពុងនេសាទក្បែរៗច្រាំង ។ នៅប្រហែលជាប្រាំរយជំហាននៅទិសខាងត្បូង សំពៅ សាន់តា ថេរេសា របស់ពួកប៉ិកទុយកាល់កំពុងនៅចតជាប់នឹងផែថ្មមួយ ។ ក្រោមពន្លឺចន្លុះ ក្រុមអ្នកលីសែងកំពុងជញ្ជូនបាវ និងធុងនានាឡើងលើសំពៅនេះ ។ នៅក្បែរសំពៅនេះ មានពួកអាវប្រផេះជាច្រើនកំពុងល្បាត ។ នេះគឺជាការធម្មតាពីព្រោះតាមច្បាប់ រាល់ទូក សំពៅប៉ិកទុយកាល់ និងបរទេសទាំងអស់ដែលចូលចតកំពង់ផែជប៉ុន ត្រូវស្ថិតនៅក្រោមការឃ្លាំពិនិត្យជាអន្ត្រែយ៍ ។ គឺមាននៅតែ *ណាកាសាគី* ទេ ដែលទូកសំពៅប៉ិកទុយកាល់អាចចេញចូលដោយសេរីបាននោះ ។

បើសិនជាយើងអាចពង្រឹងសន្តិសុខនៅកន្លែងនេះបាន យើងពិតជាធ្មេចភ្នែកដេកលក់ដោយលែងបារម្ភពីអ្វីហើយ -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ ប៉ុន្តែតើយើងអាចខាឃាំងពួកវាទន្ទឹមនឹងរកស៊ីជួញដូរកាន់តែច្រើនឡើងៗជាមួយស្រុកចិនបានទេ ? អានេះហើយគឺជាអន្ទាក់ដែលពួកចុងស្រុកភាគខាងត្បូងទាក់យើងបាន ហើយដែលយើងពិបាករកច្រកចេញនោះ ។ រឺថារកច្រកចេញមិនងាយបាន នៅពេលណាដែលពួកដៃមីញ៉ូគ្រិស្តសាសនិកនៅតែក្តាប់ *គ្យូស៊ូ* ហើយនៅពេលណាដែលយើងនៅតែត្រូវការពួកបព្វជិតនោះ ។ អ្វីដែលយើងអាចធ្វើបាន គឺត្រឹមតែធ្វើដូចអម្ចាស់ *តៃកូ* បានធ្វើអីចឹង ។ អោយពួកចុងស្រុកបន្តិចទៅ រួចធ្វើដូចជាចង់យកវិញ លេងល្បិចខ្លះ មែនខ្លះ ទន្ទឹមនឹងដឹងច្បាស់នៅក្នុងចិត្តថា បើគ្មានការជួញដូរជាមួយពួកស្រុកចិនទេជីវភាពរស់នៅពិតជាមហាយ៉ាប់ជាមិនខាន ។

សាមូរ៉ៃដែលនៅពីក្រោយនិយាយខ្សឹប :

- បើសិនជាលោកម្ចាស់អនុញ្ញាត ខ្ញុំនឹងវាយលុកពួកវាភ្លាមទាន ។

- យើងមិនគួរវៃលុកភ្លាមទេ -*យ៉ាប៊ូ* ផ្តល់យោបល់-យើងមិនដឹងថាមានពួកយើងនៅ



www.budinst.gov.kh www.elibraryofcambodia.org

លើទូក រឺក៏អត់ទេ ។ ម្យ៉ាងទៀតនៅជុំវិញទីកន្លែងនេះមានមនុស្សរាប់ពាន់នៅសំងំពួនផងក៏មិនដឹង ។ ពួកអស់នោះ.....

*យ៉ាប៊ូ* លើកដៃចង្អុលទៅរ៉ូងពួកអារប្រផេះដែលនៅល្បាតក្បែរសំពៅប៉កទុយកាល់ :

- ពួកអស់នោះ អាចប្រកាសសញ្ញាអាសន្នបានទាន ។ ពួកយើងមិនទាន់យកទូកចេញទៅលំហសមុទ្រផង ពួកវាខ្ទប់យើងជាស្រេច ។ ម្យ៉ាងទៀត យើងត្រូវការកំលាំងតិចណាស់ក៏ដប់ដងលើសកំលាំងដែលយើងមានឥឡូវនេះដែរ ។

សាមូរ៉ៃនោះតវិញ :

- ប៉ុន្តែលោកមេទ័ព *អ៊ីស៊ីដូ* ពិតជានឹងដឹងរឿងរ៉ាវក្នុងពេលឆាប់ ៗ នេះជាមិនខាន ។ នៅពេលនោះ យើងនឹងមានសត្រូវរោមយើងនៅ *អូសាកា* នេះ ច្រើនជាងរុយរោមខ្មោចលើសមរភូមិទៅទៀត ។ រួមទាំងពួកការពារឆ្អឹងជំនីយើងផង ខ្ញុំបាទមានមនុស្សមួយរយហាសិបនាក់ដែរទាន ។ ប៉ុណ្ណឹងគឺគ្រប់គ្រាន់ហើយ ។

- តែមិនគ្រប់គ្រាន់ដើម្បីធានាសុវត្ថិភាពទេ ។ ហើយរឹតតែមិនគ្រប់គ្រាន់ទៅទៀត បើសិនជាពួកយើងមិនបានត្រៀមជងចែវហើយស្រេចទេនោះ ។ យកល្អយើងគួរបំបែកការប្រុងប្រយ័ត្នរបស់ពួកវាសិន គឺធ្វើយ៉ាងណាដើម្បីទាញពួកអារប្រផេះដែលយាមទូក និងដែលនៅបំពួនខ្លួននោះអោយចេញឆ្ងាយសិន ។ ថែមទាំងពួកអាអស់នោះផង.....

*យ៉ាប៊ូ* ចង្អុលទៅពួកល្បាតដែលនៅក្បែរសំពៅពួកប៉កទុយកាល់ ។

*តូរ៉ាណាកា* សួរឡើង :

- តើបំបែកការប្រុងប្រយ័ត្នរបស់ពួកវាយ៉ាងម៉េចទៅ ?

- ដុតផ្ទះតាមបណ្តោយផ្លូវទៅ !

- មិនកើតទេ !

សាមូរ៉ៃនោះឧទានឡើងទាំងស្រលាំងកាំង និងយ៉ាងភ្ញាក់ផ្អើល ។ ដុតផ្ទះគឺជាទោសឧក្រិដ្ឋដែលត្រូវកាត់ទោសប្រហារជីវិតដោយការដុតទាំងរស់ និងជាសាធារណៈនូវមួយពូជនៃអ្នកដែលបានប្រព្រឹត្តអំពើនេះ ។ ការផ្តន្ទាទោសនេះ គឺជាការផ្តន្ទាទោសក៏តឹងតែង និងធ្ងន់ធ្ងរ ពី



www.budinst.gov.kh www.elibraryofcambodia.org

ព្រោះអគ្គិភ័យគឺជាភយន្តរាយដ៏ធំបំផុតសំរាប់ភូមិ សំរាប់ឃុំ រឺសំរាប់ទីក្រុងនៅក្នុងចក្រភពនេះ ។ សំភារៈសំនង់របស់ជនជាតិជប៉ុនមានតែឈើនិងក្រដាសតែប៉ុណ្ណោះ លើកលែងតែគ្រឿងរឺដំបូលចេញ ។ ដោយហេតុនេះ ផ្ទះនីមួយៗ ឃ្លាំងនីមួយៗ ខ្ទមនីមួយៗ និងគ្រប់កន្លែងទាំងអស់ គឺមិនខុសពីអ្វីពីប្រនេះចង្កៀងនោះឡើយ ។

សាមូរ៉ៃនិយាយម្តងហើយ ម្តងទៀត :

- មិនកើតទេ ! មិនកើតទេ !

*យ៉ាប៊ូ* សួរត្រលប់ទៅវិញ :

- អីល្ងូវគិតមើល ! តើអ្វីដែលសំខាន់ជាង ? ការខូចខាតផ្ទះពីរបីផ្លូវ រឺមួយមរណភាពរបស់លោកម្ចាស់ ?

- តែដុតហើយ ភ្លើងនឹងរាលជាមិនខាន *យ៉ាប៊ូ-សាន* យើងមិនអាចដុតក្រុង *អូសាកា* ទាំងមូលនេះបានទេ ។ នៅក្នុងក្រុងនេះ មានមនុស្សមួយលាននាក់ រឺច្រើនជាងនេះផងដែលរស់នៅ ។

- ណឹងជាចំលើយ នឹងសំនួររបស់ខ្ញុំអ្វី ?

សាមូរ៉ៃនោះបែរមុខយ៉ាងស្លេកស្លាំងរបស់ខ្លួនទៅរក *តូរ៉ាណាកា* :

- លោកម្ចាស់ ! ខ្ញុំបាទនឹងទទួលធ្វើតាមបញ្ជារបស់លោកម្ចាស់ទាំងអស់ ។ តើលោកម្ចាស់ចង់អោយខ្ញុំបាទធ្វើយ៉ាងនេះរឺទាន ?

*តូរ៉ាណាកា* សំលឹងមើល *យ៉ាប៊ូ* ។

*យ៉ាប៊ូ* គ្រវីម្រាមដៃចង្អុលដោយអាការៈមាក់ងាយទីក្រុង :

- កាលពីពីរឆ្នាំមុន ពាក់កណ្តាលទីក្រុងនេះឆេះខ្ទេចជាផេះ ហើយមើលអីល្ងូវទៅមើល ! កាលពីប្រាំឆ្នាំមុន គឺជាមហាអគ្គិភ័យ ។ មានមនុស្សប៉ុន្មានសែននាក់ដែលស្លាប់នៅពេលនោះ ? តើចាំបាច់ទៅខ្វល់ខ្វាយពីរឿងនេះធ្វើអី ? ពួកវាគ្រាន់តែជាម្ចាស់ហាងទំនិញ ជាឈ្មួញ ជាជាង និងជា អេតា តែប៉ុណ្ណឹង ។

មួយរយៈពេលមកហើយ ដែល *តូរ៉ាណាកា* កំពុងស្ទង់ខ្យល់ ។ ជំនោរតិចៗបែបនេះនឹង



www.budinst.gov.kh www.elibraryofcambodia.org

មិនធ្វើអោយភ្លើងរាលដាលបានទេ ។ តែបេងស័យទេ ។ លោតែធ្លាក់ខ្យល់មកវិញនោះ ទីក្រុងទាំងមូលនឹងក្លាយជាធំនីភ្លើងមិនខាន លើកលែងតែវិមានមួយគត់ដែលអាចនៅគង់មត់ ។ ហ៊ី បើសិនជាភ្លើងអាចឆេះទាំងវិមានទៀតនោះ អញគ្មានអល់អែកអីបន្តិចសោះហើយ ។

លោកបែរត្រលប់ក្រោយ ហើយដើរទៅរកអ្នកឯទៀតដែលនៅរង់ចាំឯខាងក្រោយនោះ :

- *ម៉ារីកូ-សាន !* នាងនាំតែកុង និងសាមូរ៉ៃប្រាំមួយនាក់ទៅទូកធំ ។ ត្រូវធ្វើដូចជាភ័យស្លន់ស្លោណាស់អ៊ីចឹង ។ ប្រាប់ពួកអាវប្រផេះថាមានគេពួនស្ទាក់វ៉ៃ ហើយមិនដឹងថាជាពួកចោរ រឺពួក រ៉ូនីន ទេ ។ នាងប្រាប់ពួកនោះថា នាងមិនច្បាស់ថាជាពួកណាទេ ដែលពួនស្ទាក់នោះ ។ ប្រាប់ពួកវាពីទីកន្លែងដែលកើតហេតុអម្បាញ់មិញនេះ ហើយថា នាងត្រូវមេបញ្ជាការកងអាវប្រផេះដែលអមដំណើរក្បួននោះចាត់អោយមកជាបន្ទាន់ ដើម្បីអោយពួកនោះទៅជួយភ្លាម ។ ថាការប្រយុទ្ធគ្នានៅតែបន្តតក្រឹកគគ្រេងណាស់ ហើយថា *គីរីស៊ូបូ* ប្រហែលជាស្លាប់ហើយ រឺយ៉ាងហោចណាស់ក៏របួសដែរ ។ បើសិនជានាងចេះសំដែង ពួកវាមួយភាគធំច្បាស់ជាចេញពីទីនេះភ្លាម ។

- ខ្ញុំយល់យ៉ាងច្បាស់ណាស់លោកម្ចាស់ ។

- រួចកិច្ចការនេះហើយ ទោះជាពួកអាវប្រផេះសំរេចយ៉ាងម៉េចក៏ដោយនាងត្រូវឡើងទៅលើទូកជាមួយតែកុង ។ បើពួកទូកយើងនៅលើនោះ បើទូកស្រួលបួលទេនោះ នាងត្រូវត្រលប់មកជណ្តើរកៀនទូក ហើយធ្វើជាសន្ទប់ទៅ ។ នេះគឺជាសញ្ញា ។ នាងត្រូវធ្វើនៅមាត់ជណ្តើរទូកណា !

រួច *តូរ៉ាណាកា* ងាកមើលទៅ *បួក់ថន :*

- និយាយប្រាប់គាត់ពីអ្វីដែលនាងត្រូវធ្វើ ប៉ុន្តែមិនបាច់និយាយពីផែនការនាងសន្លប់ទេ ។

រួចលោកក៏ដើរទៅចេញបញ្ជាដល់ក្រុមរបស់លោក ព្រមទាំងការណែនាំជាពិសេសដល់ពួកសាមូរ៉ៃទាំងប្រាំមួយនាក់ដែលត្រូវឡើងទូកនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលដែល *តូរ៉ាណាកា* ចាត់ចែងការរួចរាល់ហើយ *យ៉ាប៊ូ* ទាញលោកទៅឆ្ងាយដាច់ពីគេ ៖

- ហេតុអ្វីបានជាលោកម្ចាស់បញ្ជូនអាចុងស្រុកនេះទៅធ្វើអី ? ទុកវាអោយនៅទីនេះមានសុវត្ថិភាពជាង ។ ជាពិសេសសំរាប់លោកម្ចាស់ ។

- គឺសំរាប់គាត់ទេវិញទេ *យ៉ាប៊ូ-សាន* ។ មិនមែនសំរាប់ខ្ញុំទេ ។ មនុស្សនេះជានុយបញ្ឆោតមួយដ៏មានប្រយោជន៍ណា ។

- ដុតផ្ទះ គឺផ្ដល់សុវត្ថិភាពជាង លោកម្ចាស់ ។

- ពិតហើយ ។

ទន្ទឹមនឹងចំលើយ *តូរ៉ាណាកា* គិតថា គឺជាប្រការល្អដែលបាន *យ៉ាប៊ូ* នៅខាងលោក ជាជាងនៅខាង *អ៊ីស៊ីដូ* ។ ហេងដែរ ដែលកាលពីម្សិលមិញអញមិនបញ្ជាអោយវាលោតចុះពីលើកំផែងមកនោះ ។

- លោកម្ចាស់ ?

- មានការអី *ម៉ារីកូ-សាន* ?

- ខ្ញុំសូមលោកម្ចាស់អធ្យាស្រ័យ ប៉ុន្តែ *អាន់ជីន-សាន* សួរថា តើត្រូវធ្វើយ៉ាងម៉េចទៅបើសិនពួកសត្រូវកាន់កាប់ទូកនោះ ?

- នាងប្រាប់គាត់ថា បើគាត់យល់ថាប្រមាត់គាត់តូចទេ គាត់មិនចាំបាច់ទៅទេ ។ នៅពេលដែល *ម៉ារីកូ* បកសំដីរបស់ *តូរ៉ាណាកា* ហើយ កំហឹងរបស់ *ប្លាក់ថន* ពុះពោរមួយរំពេច ប៉ុន្តែគេខំរំងាប់ចិត្តរបស់ខ្លួនទេវិញ ៖

- ជំរាបលោកម្ចាស់ *តូរ៉ាណាកា* ថាផែនការរបស់លោកមិនមែនល្អសំរាប់អ្នកស្រីទេ ។ អ្នកស្រីត្រូវនៅទីនេះហើយ ។ បើសិនជាស្ថានការណ៍ស្រួលបួលនោះ ខ្ញុំអាចអោយសញ្ញាក៏បានដែរ ។

*ម៉ារីកូ* និយាយតបវិញយ៉ាងម៉ឺងម៉ាត់ ៖

- ខ្ញុំមិនអាចធ្វើយ៉ាងនេះបានទេ *អាន់ជីន-សាន* ។ ព្រោះនេះមិនមែនជាបញ្ជារបស់



www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់ខ្ញុំឡើយ ។ ផែនការអ្វីដែលលោកម្ចាស់ខ្ញុំលើកឡើង គឺល្អវាងវៃណាស់ ។

ពេលនេះ *ក្លាក់ថន* ដឹងថា គេមិនចាំបាច់និយាយពន្យល់ហេតុផលអ្វីទៀតទេ ។ ពូកអាអស់នេះចំជាពូកស្រែកឈោម និងក្មេងក្មាងមែនតែម្តង -គេគិតនៅក្នុងចិត្ត ។ តែទោះជាយ៉ាងណាក្តី ក៏ត្រូវទទួលស្គាល់ថា ពូកអាអស់នេះអង់អាចក្លាហានមែន ។ ក្លាហានទាំងស្រី ទាំងប្រុសតែម្តង ។

នៅក្នុងឆាកប្រយុទ្ធកន្លែងពួនស្ទាក់អម្បាញ់មិញនេះ *ក្លាក់ថន* បានតាមសំលឹងមើល *ម៉ារីកូ* ដែលកាន់ដាវមួយយ៉ាងវែង ស្ទើរប្រហែលមួយជំហររបស់នាងដែរ ។ នាងបានប្រើដាវយ៉ាងប៉ិនប្រសប់ ដើម្បីការពារយ៉ាងប្តូរផ្តាច់អាយុជីវិតរបស់ *តូរ៉ាណាកា* ។ ពិតមែនតែ *ប៊ុនតារ៉ូ* ជាអ្នកសំលាប់អ្នកវាយលុកមែន តែគឺ *ម៉ារីកូ* ជាអ្នកបង្កឱកាសនេះ អាស្រ័យដោយនាងបានធ្វើអោយបុរសនោះញ្ញោចផយក្រោយ ។ ឈាមនៅជាប់នឹងអាវគីម៉ូណូនាងដែលរហែកជាដុំៗនោះនៅឡើយ ។ មុខរបស់នាងប្រលាក់ប្រលូស ។

នៅពេលដែលឆាកប្រយុទ្ធចប់ និងនៅតាមផ្លូវតំរង់ទៅរកផែ *ក្លាក់ថន* ក៏បានសួរនាង :

- តើអ្នកស្រីរៀនគុនដាវពីណាមក ?

- លោកគួរដឹងហើយថា នារីសាមូរ៉ៃទាំងអស់សុទ្ធតែត្រូវបានរីកវ៉ឺនតាំងពីតូចៗមកអោយចេះប្រើកាំបិត ដើម្បីការពារកិត្តិយសរបស់ខ្លួន និងកិត្តិយសរបស់អម្ចាស់ខ្លួន ។ ប៉ុន្តែមាននារីមួយចំនួនមិនជាច្រើនប៉ុន្មានទេ ដែលត្រូវគេបង្រៀនអោយចេះគុនដាវនិងគុនលំពែងទៀតផង *អាន់ជីន-សាន* ព្រោះមានឪពុកខ្លះយល់ថា កូនស្រីក៏ដូចជាកូនប្រុសដែរ ត្រូវតែត្រៀមខ្លួនប្រយុទ្ធដើម្បីអម្ចាស់ខ្លួនជានិច្ច ។ លោកដឹងទេ ជួនកាលមាននារីខ្លះចូលចិត្តធ្វើការប្រយុទ្ធជាងអ្នកឯទៀត ហើយពួកនេះតែងតែចូលរួមក្នុងសមរភូមិជាមួយប្តីខ្លួន រឺឪពុកខ្លួនទៀតផង ។ ម្តាយខ្ញុំស្ថិតក្នុងចំនោមនារីប្រភេទនេះ ។ ហើយឪពុកម្តាយខ្ញុំបានសំរេចអោយខ្ញុំត្រូវតែរៀនគុនដាវ និងគុនលំពែងទៅ ។

នៅពេលដែលសំលឹងមើល *ម៉ារីកូ ក្លាក់ថន* ដឹងថា គេនឹងប្រឹងអស់ពីសមត្ថភាព ដើម្បីការពារមិនអោយ *ម៉ារីកូ* ជួបគ្រោះថ្នាក់អ្វីទាំងអស់ :



www.budinst.gov.kh www.elibraryofcambodia.org

- ទុកអោយខ្ញុំទៅជាមួយពួកសាមូរ៉ៃបានហើយ *ម៉ារីកូ-សាន* ។ អ្នកស្រីនៅទីនេះចុះ ខ្ញុំសូមអង្វរ ។

- មិនកើតទេ *អាន់ជីន-សាន* ។

- បើអីចឹងអោយខ្ញុំសុំកាំបិតខ្លីមួយមក ។ អូទេ ! យកល្អសុំអោយពីរមក ។

*ម៉ារីកូ* លើកសំនើនេះទៅ *តូរ៉ាណាកា* ១យល់ព្រមភ្លាម ។ *ប្លាក់ថន* ស៊កកាំបិតមួយទៅក្នុងខ្សែក្រវាត់ក្រនាត់ និងមួយទៀតគេចងនឹងកំភួនដៃ ដោយដាក់ដងចុះក្រោម និងដោយប្រើក្រនាត់សូត្រដែលគេហែកពីជាយគីម៉ូណូរបស់គេ ។

- លោកម្ចាស់របស់ខ្ញុំសួរថា តើពួកអង់គ្លេសទាំងអស់សុទ្ធតែលាក់កាំបិតនៅក្នុងដៃអាវអីចឹងវី ?

- ទេ តែភាគច្រើននៃអ្នកជើរសមុទ្រតែងធ្វើយ៉ាងនេះ ។

- នៅនគរនេះមិនដែលឃើញរបៀបនេះទេ ។ ពួកប៉កទុយកាល់ក៏មិនដែលដាក់អាវុធបែបនេះដែរ ។

- កន្លែងដែលល្អបំផុតសំរាប់កូនកាំបិត គឺស្បែកជើងកវែង ។ ពេលនោះគេអាចប្រើវាយ៉ាងរហ័ស និងយ៉ាងមានប្រសិទ្ធភាពបំផុត បើសិនជាមានការចាំបាច់ ។

*ប្លាក់ថន* កត់សំគាល់នូវក្រសែភ្នែកយកចិត្តទុកដាក់របស់ *តូរ៉ាណាកា* និង *យ៉ាប៊ូ* នៅពេលដែល *ម៉ារីកូ* បកសំដីដែលគេនិយាយអម្បាញ់មិញនេះ ហើយគេមានអារម្មណ៍ថា អ្នកទាំងពីរមិន ចូលចិត្តឃើញគេមានអាវុធជាប់នឹងខ្លួនឡើយ ។

រួចគេក៏ចាប់ផ្តើមគិតពិចារណាពី *តូរ៉ាណាកា* ទៀត ។ ក្រោយពីកំចាត់ការពូនស្នាក់និងសំលាប់ពួកអាវប្រផេះអស់ហើយ *តូរ៉ាណាកា* បានថ្លែងអំនរគុណរូបគេតាមរយៈ *ម៉ារីកូ* និងនៅចំពោះមុខពួកអាវត្នោតទាំងអស់នូវ " ភក្តីភាព " ដែល *ប្លាក់ថន* បានបង្ហាញ ។ តែប៉ុណ្ណឹងគឺចប់គ្មានពាក្យសន្យា គ្មានកិច្ចព្រមព្រៀង គ្មានរង្វាន់ខាន់ខៅអ្វីទាំងអស់ ។ ប៉ុន្តែ *ប្លាក់ថន* ដឹងថារបស់ទាំងអស់នេះនឹងមានមកនៅពេលក្រោយទៀត ។ សង្ឃចំនាស់បានប្រាប់គេហើយថា ភក្តីភាពជារបស់តែមួយគត់ដែលពួកគេផ្តល់រង្វាន់ :



www.budinst.gov.kh www.elibraryofcambodia.org

- ភក្តីភាព និងករណីយកិច្ចណាលោក ។ នេះគឺសក្ការៈរបស់ពួកនេះ ។ នេះជា *ប៊ូស៊ីដូ* របស់ពួកវា ។ ពួកយើង១ស្លាប់ដើម្បីព្រះធម៌ ឯពួកអស់នេះរិញសុខចិត្តស្លាប់ដូចឆ្កែដើម្បីម្ចាស់របស់ពួកវា ។ សូមលោកចាំកុំភ្លេចណា ពួកវាគឺជាសត្វតែម្តងមិនមែនមនុស្សទេ ។

តាមពិតពួកនេះមិនមែនជាសត្វទេ-*ប្លាក់ថន* គិតនៅក្នុងចិត្ត ។ ហើយអ្វីដែលគេជគុណ *ដូមិញ្ញូ* និយាយ គឺខុសទេ ។

គេនិយាយប្រាប់ទៅ *ម៉ារីកូ :*

- យើងត្រូវការអោយសញ្ញា ដើម្បីអោយដឹងថា សំពៅថានាសុវត្ថិភាពរឺក៏អត់ ។

*ម៉ារីកូ* បកប្រែដោយធ្វើជាមិនដឹងអ្វីទាំងអស់ :

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា យុទ្ធជនយើងម្នាក់នឹងទទួលផ្តល់សញ្ញានេះ ។

- ខ្ញុំនៅតែយល់ថា វាគ្មានអ្វីថ្លៃថ្នូរសោះ ដែលត្រូវបញ្ជូននារីទៅធ្វើកិច្ចការមនុស្សប្រុសយ៉ាងនេះ ។

- សូមលោករក្សាភាពអត់ធ្មត់ទៅ *អាន់ជីន-សាន* ។ ចំពោះពួកយើងគ្មានការខុសគ្នារវាងបុរសនឹងនារីទេ ។ ក្នុងឋានៈជាសាមូរ៉ៃ នារីគឺស្មើនឹងបុរស ។ នៅក្នុងផែនការនេះ នារីអាចបំពេញការងារល្អជាងបុរសផង ។

*តូរ៉ាណាកា* និយាយមួយឃ្លាយ៉ាងខ្លីទៅ *ម៉ារីកូ* ។

- តើលោកត្រៀមរៀបចំហើយរឺនៅ *អាន់ជីន-សាន ?* យើងត្រូវចេញទៅអីលូវនេះ ។

- ផែនការនេះសែនយ៉ាប់ ហើយសែនគ្រោះថ្នាក់ ហើយខ្ញុំធុញនឹងរកស៊ីធ្វើនុយអោយគេណាស់ តែទោះជាយ៉ាងម៉េចក៏ដោយ ខ្ញុំនៅតែទៅអីចឹង ។

*ម៉ារីកូ* សើចកក្អឹក រួចលំអោនខ្លួនគោរព *តូរ៉ាណាកា* ហើយរត់ចេញទៅភ្លាម ។ *ប្លាក់ថន* ហើយនិងសាមូរ៉ៃទាំងប្រាំមួយនាក់រត់តាមពីក្រោយនាង ។

*ម៉ារីកូ* រត់យ៉ាងលឿន ហើយទាល់តែដល់ផ្លូវកែងបត់ចេញទៅឆ្នេរសមុទ្រឯណោះ



www.budinst.gov.kh www.elibraryofcambodia.org

ទើប *ប្លាក់ថន* រត់តាមនាងទាន់ ។ *ប្លាក់ថន* មានអារម្មណ៍ដូចជាអាក្រាតនននលគោកតែម្តង ។ គ្រាន់តែពួកគេលេចមុខនៅលើទីវាល ពួកអាវប្រផេះក៏បានក្រលេកឃើញពួកគេភ្លាម ហើយស្ទុះមករកពួកគេយ៉ាងប្រញាប់ប្រញាល់ ។ តែមួយប៉ប្រិចភ្នែកពួកអាវប្រផេះបានព័ទ្ធពួកគេជុំជិត ។ *ម៉ារីកូ* និយាយយ៉ាងញាប់ស្មេរជាមួយពួកអាវប្រផេះ ។ រួច *ប្លាក់ថន* ក៏ចូលប្រឹុបន្ថែមដោយនិយាយប៉កទុយកាល់ អង់គ្លេស និងហូឡង់ ច្រលូកច្រលំគ្នា ធ្វើសញ្ញាអោយពួកគេប្រញាប់ឡើង ហើយគេក៏ដើរទាំងទ្រេតទ្រោតទៅកាន់ជណ្តើរដែលឡើងពីចំហៀងទូកធំ ។ គេខំប្រឹងសំលឹងមើលទៅក្នុងទូកដែរ ប៉ុន្តែគេមើលមិនឃើញច្បាស់សោះ ក្រៅតែពីក្បាលមនុស្សស្កុង១ជាច្រើនដែលអើតចុះមក ។ គេសំលឹងក្បាលគោររបស់ពួកសាមូរ៉ៃ និងពួកនាវិកជាច្រើន ប៉ុន្តែគេមិនអាចមើលឃើញថា គីម៉ូណូរបស់ពួកនេះមានពណ៌អ្វីទេ ។

នៅពីក្រោយ សាមូរ៉ៃម្នាក់និយាយទៅរក *ប្លាក់ថន* ១បែរខ្លួនមកវិញ ធ្វើសញ្ញាថាខ្លួនស្តាប់មិនយល់ទេ និងបញ្ជាក់អោយពួកនោះប្រញាប់ទៅកន្លែងកើតហេតុភ្លាម :

- ទៅកន្លែងនោះភ្លាម ! អោយវាលឿនឡើង អាពួកប្រកាច់យកអ៊ីអស់នេះ ! *វាការីម៉ាស៊ូ កា ?* គេកំពុងតែកាប់គ្នាឯនោះ ម៉េចក៏មិនប្រញាប់ទៅ ?

*ម៉ារីកូ* និយាយបែកពពុះមាត់ដើម្បីធ្វើអោយមេកងពួកអាវប្រផេះជឿតាមខ្លួន ។ បុរសនេះក៏ដើរទៅជិតទូក ហើយស្រែកចេញបញ្ជាឡើង ។ រំពេចនោះពួកអាវប្រផេះជាងមួយរយនាក់ស្ទុះចេញពីក្នុងទូកធំមកភ្លាម ។ ពួកអាវប្រផេះមួយចំនួនតូចត្រូវបានបញ្ជូនទៅខាងជើងដើម្បីទទួលអ្នករបួស រីបើចាំបាច់ផ្តល់ជំនួយគាំទ្រដល់ពួកគេ ។ សាមូរ៉ៃម្នាក់ទៀតត្រូវគេបញ្ជូនទៅសុំជំនួយពីពួកអាវប្រផេះដែលកំពុងចាំយាមសំពៅពួកប៉កទុយកាល់ ។ ដោយទុកទាហានតែដប់នាក់អោយឈរយាមមាត់ជណ្តើរចុះទូកនោះ មេបញ្ជាការនេះនាំមនុស្សទាំងអស់រត់ទៅរកផ្លូវដែលតំរង់ទៅរកទីក្រុងនោះមួយរំពេច ។

*ម៉ារីកូ* ស្ទុះទៅរក *ប្លាក់ថន* ហើយសួរឡើង :

- បើតាមលោកមើល តើទូកនេះស្រួលបួលឬទេ ?

- បាទ !



www.budinst.gov.kh www.elibraryofcambodia.org

រួច *ប្លាក់ថន* ប្រឹងអស់ទំហឹងតោងខ្សែជណ្ដើរហក់ឡើងទៅលើទូក ។ *ម៉ារីកូ* និងពួកអាវខ្មៅតពីរនាក់ក៏ឡើងតាមក្រោយជាបន្តបន្ទាប់ ។ ពួកអាវប្រផេះបួននាក់នៅយាមឯលើកឹងដកខ្សែ និងពីរនាក់ទៀតនៅយាមឯក្បាលទូក ។ ពួកនេះសុទ្ធតែប្រដាប់ដោយព្រួញ ធ្នូ និងដាវទាំងអស់ ។

*ម៉ារីកូ* សួរទៅនាវិកម្នាក់ ។ បុរសនោះឆ្លើយតបវិញយ៉ាងគោរព ។

នាងក៏បែរទៅនិយាយប្រាប់ *ប្លាក់ថន :*

-ពួកគេត្រូវបានគេជួលមកដើរទូកនេះ ដើម្បីជូនជំទាវ *គិរីស៊ូបូ-សាន* ទៅយេដូ ។

- សួរគាត់មើល ថា....

រួច *ប្លាក់ថន* ក៏ឈប់កណ្ដាលទី ដោយគេទើបមើលស្គាល់បុរសទាបកន្ទើម្នាក់ដែលគេបានតែងតាំងជាមេបញ្ជាការទូកក្រោយពេលខ្យល់ព្យុះនោះ ។

- *កូនបារ៉ា* មេបញ្ជាការ-សាន ! រាត្រីសួស្ដី ។

- *កូនបារ៉ា អាន់ជីន-សាន ! វ៉ាតាស៊ី អ៊ីយេ* មេបញ្ជាការ-*សាន អ៊ីម៉ា* ។

បុរសមេបញ្ជាការឆ្លើយតបទាំងញញឹមពព្រាយ រួចក៏ចង្អុលទៅនាវិកម្នាក់ដែលឈរនៅក្បែរកឹង ដោយនិយាយប្រាប់ថា :

- *អ៊ីម៉ាស៊ូ* មេបញ្ជាការ-សាន ។

- អា្ហ *សូតិស៊ូ ? បាឡូរ៉ា* បញ្ជាការ-សាន ។

*ប្លាក់ថន* និយាយទៅកាន់បុរសនោះ រួចទើបលំអោនខ្លួនគោរព ។ ទន្ទឹមនេះគេបន្ទាបសំលេងនិយាយទៅកាន់ *ម៉ារីកូ :*

-*ម៉ារីកូ-សាន* សូមរកមើលថា តើនៅខាងក្រោមទូកមានពួកអាវប្រផេះឯទៀតៗទេ ?

មុនដែល *ម៉ារីកូ* ហើបមាត់នោះ មេបញ្ជាការនោះបានគោរពសងវិញហើយនិយាយទៅកាន់នាវិកកន្ទើនោះ។ បុរសនោះក៏ឆ្លើយតបយ៉ាងយូរ ។ នាវិកមួយចំនួនទៀតនិយាយផងងក់ក្បាលជាសញ្ញាឯកភាពលើសំដីរបស់នាវិកនោះផង ។ ទាំងបញ្ជាការទាំងអ្នកឯទៀតដែលនៅ


www.budinst.gov.kh www.elibraryofcambodia.org

លើទូក សុទ្ធតែបានបង្ហាញការកោតសរសើរយ៉ាងខ្លាំង ។

រួចហើយលោកមេបញ្ជាការក៏ស្រែកឡើង :

- *អា សូតិស៊ូ អាន់ជីន-សាន* ! គោរព !

មនុស្សទាំងអស់ដែលនៅលើទូក នាំគ្នាលំអោនខ្លួនគោរព *ប្លាក់ផន* ទាំងអស់លើក លែងតែពួកសាមូរ៉ៃប៉ុន្មាននាក់នោះចេញ ។

*ម៉ារីកូ* និយាយទៅកាន់ *ប្លាក់ផន* :

- នាវិកនេះនិយាយប្រាប់លោកមេបញ្ជាការថា លោកបានជួយទូកអោយរួចពីគ្រោះថ្នាក់នៅក្នុងពេលដែលមានព្យុះយ៉ាងខ្លាំង ។ លោកឥតដែលបាននិយាយពីរឿងព្យុះ រឺពីរឿងធ្វើដំណើរនេះប្រាប់ពួកយើងសោះ ។

- តាមពិតទៅវាគ្មានអ្វីដែលត្រូវនិយាយផង ។ នេះគ្រាន់តែព្យុះមួយដូចព្យុះឯទៀត១សព្វដងតែប៉ុណ្ណោះ ។ សូមអ្នកស្រីអធ្យាស្រ័យ ជំរាបទៅលោកមេបញ្ជាការផង ថាខ្ញុំសូមអរគុណគាត់ ហើយនិងខ្ញុំរីករាយណាស់ដែលបានឡើងទូកនេះម្តងទៀត ។ សូមសួរគាត់ផងថា តើទូកអាចចេញដំណើរបានភ្លាមទេ នៅពេលណាដែលអ្នកឯទៀតមកដល់នោះ ។

រួច *ប្លាក់ផន* និយាយបន្ទាបសំលេងបន្តិច :

- រកមើលផង ថាតើមានសល់ពួកអាវប្រផេះនៅខាងក្រោមទេ ?

*ម៉ារីកូ* ធ្វើតាមភ្លាម ។

បុរសជាមេបញ្ជាការដើរមកជិតអ្នកទាំងពីរ ហើយម៉ារីកូក៏សួរពត៌មានបន្ថែមពីនេះពីនោះមួយស្របក់ ទើបនាងងាកមករក *ប្លាក់ផន* វិញ :

- *អាន់ជីន-សាន* លោកមេបញ្ជាការសូមអរគុណលោកដែលបានជួយសង្គ្រោះទូករបស់លោក ហើយលោកថា ទូកត្រៀមរៀបចំអស់ហើយ ។

រួចនាងបន្ទាបសំលេង :

- ចំពោះរឿងពួកឯទៀតនោះ គាត់អត់ដឹងអ្វីទាំងអស់ ។

*ប្លាក់ផន* ចោលភ្នែកសំលឹងមើលទៅច្រាំង ។ គ្មានសញ្ញាអ្វីដែលបញ្ជាក់ថា *ប៊ុនតារ៉ូ* រី



www.budinst.gov.kh www.elibraryofcambodia.org

ក្រុមទិសខាងជើងបានមកដល់សោះ ។ សាមូរ៉ៃម្នាក់ដែលបញ្ជូនទៅរកជំនួយបន្ថែមពីសំពៅ *សាន់តា ថេរេសា* នៅមិនទាន់ទៅដល់ទិសដៅ ហើយក៏មិនទាន់មានអ្នកណាប្រទះភ្នែកឃើញនៅឡើយដែរ ។

ដោយមិនអាចទ្រាំរង់ចាំយូរបាន *ប្លាក់ថន* ក៏សួរឡើង :

- អីលូវនេះធ្វើយ៉ាងម៉េចទៀត ?

*ម៉ារីកូ* នៅទីទើរ មិនដឹងសំរេចបែបណានៅឡើយ ។

ប្លាក់ថនសំលឹងមើលទៅសំពៅពួកប៉ក់ទុយកាល់ :

- ម្នាក់នោះជិតទៅដល់អីលូវហើយ !

- ជិតដល់អី ?

*ប្លាក់ថន* លើកដៃចង្អុលប្រាប់ *ម៉ារីកូ* :

- អាមួយនោះ....សាមូរ៉ៃម្នាក់នោះណា !

- សាមូរ៉ៃមួយណា ? ខ្ញុំសូមទោស ខ្ញុំមិនអាចមើលបានឆ្ងាយយ៉ាងណឹងទេ *អាន់ជីនសាន* ។ ខ្ញុំអាចមើលឃើញអ្វីៗទាំងអស់ដែលនៅលើសំពៅ លើកលែងតែពួកអាវប្រផេះដែលនៅពីមុខសំពៅនោះ ខ្ញុំមើលឃើញតែព្រិលៗប៉ុណ្ណោះ ។ លោកនិយាយពីសាមូរ៉ៃណាមួយ ?

*ប្លាក់ថន* ប្តូរទៅនិយាយជាភាសាឡាតាំងវិញម្តង :

-អីលូវបុរសនោះនៅប្រហែលហាសិបជំហានពីសំពៅតែប៉ុណ្ណោះ ។ អីលូវនេះមានគេឃើញវាហើយ ។ ពេលនេះយើងត្រូវការជំនួយជាបន្ទាន់ណាស់ ។ អ្នកណាជាអ្នកអោយសញ្ញា ? ត្រូវអោយសញ្ញាពេលនេះជាបន្ទាន់ ។ រឿងនេះសំខាន់ណាស់

*ម៉ារីកូ* សួរជាភាសាប៉ក់ទុយកាល់វិញ :

- មានឃើញប្តីខ្ញុំទេ ?

*ប្លាក់ថន* គ្រវីក្បាល ។

- រវាងលោកម្ចាស់នឹងទូកនេះ មានពួកអាវប្រផេះដប់ប្រាំមួយនាក់រាំង ។ សូមព្រះជាម្ចាស់ជួយការពារលោកម្ចាស់ខ្ញុំផងចុះ ។



www.budinst.gov.kh www.elibraryofcambodia.org

ដោយបទំស្រទំរួច១នៅក្នុងពោះ ដើម្បីកុំអោយនាងធ្វើការសំរេចចិត្តដោយភាន់ច្រលំអោយសោះនោះ នាងក៏ដើរយ៉ាងហោះហត់ទៅឯក្បាលដណ្ដើរទូក ហើយធ្វើជាដួលសន្លប់ភ្លាមមួយរំពេច ។

ក្នុងស្ថានភាពបែបនេះ *ក្លាក់ថុន* ប្រែរជាស្រឡាំងកាំងតែម្ដង ។ គេឃើញក្បាលរបស់ *ម៉ារីកូ*ទង្គិចនឹងក្ដារទូកយ៉ាងខ្លាំង ។ គេស្ទុះទៅរក *ម៉ារីកូ* ទន្ទឹមនឹងពួកនាវិក ក៏ដូចទាំងពួកអាវពណ៌ប្រផេះដែលនៅកន្សៀ និងក្បាលទូក ពពាក់ពពូនមកផងដែរ ។ *ក្លាក់ថុន* លើកបីនាង ហើយដើរកាត់រ៉ូងមនុស្សសំដៅទៅកន្សៀ ។

- សុំទឹកបន្តិចមក ! ទឹក ហែ ?

ពួកនាវិកសំលឹងមើល *ក្លាក់ថុន* ធ្មាំង ដោយពួកគេមិនយល់ពីអ្វីដែល *ក្លាក់ថុន* ចង់និយាយ ។ *ក្លាក់ថុន* ខំប្រឹងនឹកទាំងអស់សង្ឃឹមពីពាក្យជប៉ុនដែលមានន័យថាទឹកនេះ ។

សង្ឃចំនាស់បានប្រាប់ពាក្យនេះដល់គេប្រហែលហាសិបដងហើយ ។ ឱព្រះអើយព្រះពាក្យអីអ៊ីចេះ ?

- អូមែនហើយ ! *មីស៊ូ ! មីស៊ូ ហៃ ?*

- អ្ហា ! *មីស៊ូ ! ហៃ អាន់ជីនសាន* ។

បុរសម្នាក់ក៏ស្ទុះចេញទៅរកទឹកភ្លាម ។

រំពេចនោះ សំលេងប្រកាសអាសន្នបានលាន់ឡើងមួយរំពេច ។

នៅលើឆ្នេរខ្សាច់ពួកសាមូរ៉ៃរបស់ *តូរ៉ាណាកា* សាមសិបនាក់ដែលមានសំលៀកបំពាក់បន្ទំជាពួក រ៉ូនីន បានលេចខ្លួនឡើងនៅឯដើមផ្លូវ ។ ពួកអាវប្រផេះដែលនៅខាងក្រោមបានមកប្រមូលគ្នានៅឯដណ្ដើរឡើងតាមចំហៀងទូក ចំនែកឯពួកដែលនៅលើគឹងកន្សៀ និងខាងក្បាលទូកក៏ខំជំទើតជើងដើម្បីមើលអោយឃើញច្បាស់ថែមទៀត ។ បុរសម្នាក់ស្រែកតំហាកចេញបញ្ជាឡើង ។ ពួកខ្មាន់ធ្នូតំលើងព្រួញភ្លាម ។ បន្ទាប់មក ទាំងសាមូរ៉ៃអាវប្រផេះ ទាំងសាមូរ៉ៃអាវត្នោត ក៏ស្ទុះចេញទៅឈរលើផែដើម្បីចាំតទប់នឹងសត្រូវ ឯសាមូរ៉ៃអាវត្នោតពីរនាក់ដែលនៅលើទូក ក៏ស្ទុះមួយទៅកន្សៀ មួយទៅក្បាលទូកភ្លាមដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- ឈប់ !

ប៉ុន្តែពួក វ៉ូនីន-សាមូរ៉ៃ ឥតស្តាប់បញ្ជានេះឡើយ ពួកគេបោលសំរុកចូលមកតែម្តង ផ្លែព្រួញមួយបានទៅដោតឈិបលើទ្រូងរបស់បុរសម្នាក់ដួលធ្លោលមួយរំពេច ។ រំពេចនោះបុរស អាវខ្មៅគក់វាត់មួយដាវសំលាប់ខ្ទាន់ធ្លូអាវប្រផេះនោះភ្លាម ប៉ុន្តែនៅពេលដែលគេវាត់ដាវទៅរក សាមូរ៉ៃម្នាក់ទៀតនោះ សាមូរ៉ៃនេះរងដាវជាប់យ៉ាងរហ័សទទឹមនឹងស្រែកប្រាប់ពួកខ្លួនអំពី ល្បិចបោកប្រាស់នេះ ។ បុរសអាវខ្មៅដែលនៅលើកឹងកន្សែ បានកាត់ដាច់ដៃរបស់ពួកអាវ ប្រផេះម្នាក់ ប៉ុន្តែបីនាក់បានវាយទប់ជាប់ ហើយដកខ្លួនថយទៅរកជណ្តើរ ។ ពួកនាវិកដែលនៅ លើទូកទាំងប៉ុន្មានរត់ប្រញាប់ ។ ការប្រយុទ្ធនៅឯលើផែឯនោះ ក៏ស៊ីសាច់ស៊ីឈាមវក់វីរណាស់ ដែរ ។ ដោយពួកអាវប្រផេះទាំងអស់បានបែរមកព្រួតវាយពួកអាវខ្មៅទាំងបួននាក់ ដើម្បីសងសឹក ចំពោះការបោកប្រាស់នេះ ព្រោះពួកគេដឹងថា បន្តិចទៀតពួកវាយលុកនឹងមករោមហែកពួក គេប្រញាប់ជាមិនខាន ។ បុរសម្នាក់មានអមតាងស្រមូម ដែលជាមេរបស់ពួកអាវប្រផេះ ប្រទះ ឃើញ *ប្លាក់ថន* និង *ម៉ារីកូ* ដែលនៅលើទូក ក៏ស្រែកសន្ធាប់ស្ទុះទៅភ្លាម :

- សំលាប់ពួកអាក្បត់អោយអស់ !

*ប្លាក់ថន* ឃើញថា ពួកអាវប្រផេះទាំងអស់គ្នាសំលក់សំលឹងមើល *ម៉ារីកូ* ដែលនៅតែ សន្លប់នៅឡើយនោះ ប្រកបដោយក្រសែភ្នែកយ៉ាងសាហាវស្ទើរស្រក់ឈាម ។ គេដឹងច្បាស់ លាស់ថា បើសិនជាគេមិនទទួលបានជំនួយក្នុងពេលឆាប់ៗនេះទេ ពួកគេទាំងពីរនាក់ប្រាកដជា ត្រូវស្លាប់ ព្រោះគេគ្មានរំពឹងពួកនាវិកទាំងនេះអាចជួយពួកគេបានឡើយ ព្រោះគេចាំច្បាស់ ណាស់ថា មានតែសាមូរ៉ៃទេទើបអាចប្រយុទ្ធជាមួយសាមូរ៉ៃបាន ។

*ប្លាក់ថន* ដកហូតយកកាំបិត ហើយយារគប់យ៉ាងអស់ទំហឹង ។ កាំបិតទៅដោតជាប់ បំពង់ករបស់បុរសជាមេពួកសាមូរ៉ៃនោះ ។ ពួកអាវប្រផេះពីរនាក់ទៀតយារដាវយ៉ាងខ្ពស់គំរង់ ទៅរក *ប្លាក់ថន* ដែលលូកដៃយកកាំបិតមួយទៀតមកឈរការពារក្បែរ *ម៉ារីកូ* ព្រោះគេមិនដាច់ចិត្ត ទុកនាងនៅតែម្នាក់ឯងដោយគ្មានអ្នកការពារនោះឡើយ ។ តាមកន្ទុយភ្នែករបស់ខ្លួន *ប្លាក់ថន* ឃើញថា កំលាំងរបស់ *តូរ៉ាណាកា* ស្ទើរមានជ័យជំនះទាំងស្រុងទៅហើយនៅលើផែ ។ មានពួក



www.budinst.gov.kh www.elibraryofcambodia.org

អាវប្រផេះតែបីនាក់ប៉ុណ្ណោះដែលនៅយាមឯមាត់ជណ្ដើរ ។ មានតែបីនាក់ប៉ុណ្ណោះដែលចាំទប់ទឹកជំនន់ ។ បើសិនជាគេទប់ទល់បានប្រហែលជិតមួយនាទីនោះ គឺគេនឹងបានរួចខ្លួនហើយ ។ ទាំង *ម៉ារីកូ* ក៏យ៉ាងដូច្នោះដែរ ។

ផ្លែដាវវាត់យ៉ាងរហ័សសំដៅបំពង់ករបស់គេ ធ្វើអោយគេហក់ គេចទៅក្រោយភ្លាម ។ បុរសអាវប្រផេះស្ទុះដេញតាម *ភ្លាក់ថន* ឯម្នាក់ទៀតមកឈរក្បែរ *ម៉ារីកូ* ហើយលើកដាវឡើងបំរុងកាប់ចុះ ។ ក្នុងមួយខណៈនោះ *ភ្លាក់ថន* ឃើញ *ម៉ារីកូ* ដឹងខ្លួនឡើង ហើយប្រមៀលខ្លួនយ៉ាងរហ័ស គេៀសជើងបុរសនោះដួលគ្រាំងទៅលើក្ដារទូក ។ រួច *ម៉ារីកូ* ក៏ងើបឡើងទាំងទ្រេតទ្រោត ដើរទៅយកដាវរបស់ខ្មោចសាមូរ៉ៃម្នាក់ ហើយក៏ហក់សន្ទាប់មករកបុរសអាវប្រផេះដែលដួលស្រទាងអម្បាញ់មិញនេះ ។ គូប្រយុទ្ធទាំងពីរប៉ះទង្គិចគ្នាយ៉ាងកក្រើកមេឃកក្រើកដី ប៉ុន្តែ *ភ្លាក់ថន* ដឹងយ៉ាងច្បាស់ថា ទោះជានាងប្រយុទ្ធយ៉ាងអង់អាចយ៉ាងណាក៏ នាងមិនអាចឈ្នះគេបានដែរ ដោយបុរសនោះខ្លាំងក្លាណាស់ ។ គេគេចពីផ្លែដាវដែលគូប្រយុទ្ធរបស់គេវាត់មកម្ដងទៀត ហើយវាយបកបង្ខំអោយបុរសថយក្រោយ រួចទើបគប់កាំបិតខ្លួនយ៉ាងអស់ទំហឹងសំដៅគូប្រយុទ្ធរបស់ *ម៉ារីកូ* ។ កាំបិតដោតកប់យ៉ាងជ្រៅចំកណ្ដាលខ្នងគូប្រយុទ្ធរបស់ *ម៉ារីកូ* ធ្វើអោយផ្លែដាវរបស់វាកាប់ត្រូវខ្យល់ទទេ ហើយបុរសនោះក៏ដួលដាច់ខ្យល់មួយ រំពេច ប៉ុន្តែនៅពេលនេះ *ភ្លាក់ថន* មិនខុសអ្វីពីឆ្កែទ័លច្រកនៅឯកឹងកន្សៀទូកនោះឡើយ ។ បុរសអាវប្រផេះម្នាក់កំពុងឡើងតាមជណ្ដើរដេញតាមគេ ឯបុរសអាវប្រផេះម្នាក់ទៀតដែលទើបឈ្នះការប្រយុទ្ធនៅឯក្បាលទូកនោះ ក៏រត់តាមបណ្ដោយទូកសំដៅមករករួបគេផងដែរ ។ ច្រកផ្លូវមានតែមួយគត់ គឺលោតចុះទឹក ។ *ភ្លាក់ថន* ក៏ស្ទុះរឹងទៅរកគែមទូក ប៉ុន្តែគេត្រូវដួលទាំងជំហរព្រោះជើងគេរអិលនឹងឈាមដែលនៅលើក្ដារនោះ ។

នៅឯកណ្ដាលទូកនោះវិញ បុរសម្នាក់ក៏កំពុងវាយលុកផ្ទួនៗរុញ *ម៉ារីកូ* អោយទ័លច្រកផងដែរ ។ នៅទីបញ្ចប់ ដាវនាងត្រូវបុរសនេះគាស់វាត់ប៉ើងចេញពីដៃ ។ នៅពេលដែលបុរសនេះប្រមូលកំលាំងដើម្បីវាត់ដាវជាចុងក្រោយ ពួក រ៉ូនីន-សាមូរ៉ៃ បានវាយលុកសំរេចឡើងទូកព្រាត ។ បុរសម្នាក់ហក់ទៅរកគូប្រយុទ្ធរបស់ *ម៉ារីកូ* ឯបុរសម្នាក់ទៀតយារធ្នូបាញ់



www.budinst.gov.kh www.elibraryofcambodia.org

តំរង់ទៅលើកឹងដែលនៅនឹងកន្សែងនោះ ។

ផ្លែព្រួញដោតឈើបចំកណ្ដាលខ្នងរបស់បុរសអាវប្រផេះ ធ្វើអោយវាដួលទាំងជំហរ ផ្លែដាវរត់ប្រផិត *ហ្គាក់ថន* ទៅជាប់ឆ្អឹងទៅនឹងតែមទូក ។ *ហ្គាក់ថន* ប្រឹងលូនចេញប៉ុន្តែបុរសនេះ អោបគេសង្កត់ជាប់ ហើយប្រឹងយកម្រាមដៃដើម្បីរុកភ្នែករបស់គេ ។ ព្រួញមួយទៀតបានមក ដោយជាប់ស្មារបស់សាមូរ៉ៃម្នាក់ទៀត ធ្វើអោយបុរសនេះលាន់សំរែកដោយការឈឺចាប់ និង ដោយកំហឹង ។ វាបោះដាវចោល ហើយប្រឹងដកព្រួញចេញ ។ ព្រួញទីបីធ្វើអោយវាវិលខ្លួនមួយ ជុំ ធ្លាយឈាមចេញតាមមាត់កខក់ ។ វាប្រឹងដើរទៅរក *ហ្គាក់ថន* ហើយក៏ដួលប្រួសទៅលើរូប គេបណ្ដោយ ក្នុងពេលដែលបុរសអាវប្រផេះចុងក្រោយម្នាក់កាន់កាំបិតខ្លីមួយនៅនឹងដៃស្ទុះទៅ ដល់ដែរ ។ វាលើកកាំបិតដើម្បីចាក់ *ហ្គាក់ថន* ដែលនៅស្រទាងនៅលើក្ដារកឹង ប៉ុន្តែដៃមនុស្ស ម្នាក់បានទប់កាំបិតនេះជាប់ ហើយក្បាលរបស់បុរសនេះក៏ប៉ើងដាច់ចេញពីកមើលមិនទាន់ ឃើញតែឈាមដែលបាញ់ចេញដូចជាចំពួយទឹក ។ សាកសពទាំងពីរត្រូវគេទាញចេញពីលើខ្លួន *ហ្គាក់ថន* ហើយគេបានជួយអោយ *ហ្គាក់ថន* ក្រោកឈរឡើង ។ នៅពេលដែលជូតឈាម ចេញពីមុខខ្លួនហើយនោះ *ហ្គាក់ថន* ក៏ប្រទះឃើញ *ម៉ារីកូ* ដែលនៅដេកស្ដូកស្ដឹងលើក្ដារទូក និងដោយមាន ពួក រ៉ូនីន-សាមូរ៉ៃ នៅព័ទ្ធនាងជុំវិញ ។ គេច្រានអ្នកជួយគេចេញ ហើយដើរ តំរង់ទៅរកនាង ប៉ុន្តែជើងគេលែងស្ដាប់បញ្ជាហើយៗគេក៏ដួលប្រួសទៅលើក្ដារតែម្ដង ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២៤

ប្រហែលជាដប់នាទីក្រោយមកទៀតទើប *ប្លាក់ថន* អាចក្រោកឈរដោយមិនបាច់មានគេជួយបាន។ ក្នុងរយៈពេលនេះ ពួក រ៉ូនីន-សាមូរ៉ៃ បាននាំគ្នាចាត់ចែងអ្នកត្រូវរបួសធ្ងន់ ហើយនិងបានជញ្ជូនសាកសពទាំងប៉ុន្មានទំលាក់ទៅក្នុងសមុទ្រទាំងអស់ ។ ពួកអាវខ្មៅតទាំងប្រាំមួយនាក់ដែលមកជាមួយ *ប្លាក់ថន* ស្លាប់ទាំងអស់ ។ ពួកអាវប្រផេះទាំងអស់ក៏គ្មានអ្នកណានៅមានជីវិតរស់រានបានដែរ។ សំពៅត្រូវបានលាងជូតសំអាតពួកនាវិកក៏ត្រូវបានបញ្ជូនទៅកាន់ផងចែវ ហើយមួយចំនួនទៀតត្រៀមស្រាវពួរដើម្បីត្រៀមចេញដំណើរភ្លាម១ ។ គេបានពន្លត់ភ្លើងចន្លុះចេញទាំងអស់ ។ សាមូរ៉ៃប៉ុន្មាននាក់ត្រូវបានបញ្ជូនចេញទៅទិសខាងជើងដើម្បីចាំទទួល *ប៊ុនតារ៉ូ* ។ កំលាំងធំរបស់ *តូរ៉ាណាកា* បានប្រញ៊ើកប្រញ៉ោលតំរង់ទៅទិសខាងត្បូង ហើយរៀបចំស្ថានភាពការពារយ៉ាងរឹងមាំមួយ ត្រង់ទំនប់រលកដែលនៅប្រហែលពីររយជំហានពីទូកធំដើម្បីតទប់នឹងពួករអាវប្រផេះជាងមួយរយនាក់ដែលនៅល្បាតសំពៅពួកប៉ុកទុយកាល់ ហើយដែលក្រោយពីបានឃើញឆាកប្រយុទ្ធអម្បាញ់មិញនេះក៏បានធ្វើដំណើរមកយ៉ាងលឿន ។

នៅពេលដែលមនុស្សទាំងអស់ នៅលើទូកត្រូវបានផែកឆេរយ៉ាងម៉ត់ចត់ហើយនោះ មេកងក៏ក្តោបដៃស្រែកប្រកូកទៅឯឆ្នេរខ្សាច់ ។ ភ្លាមនោះ ពួកសាមូរ៉ៃស្លៀកពាក់បន្លំជាពួករ៉ូនីន មួយចំនួនទៀតដែលនៅក្រោមបញ្ជារបស់ *យ៉ាប៊ូ* ក៏ស្ទុះចេញពីទីងងឹតហើយពង្រាយជាស្នែងក្របីការពារទាំងទិសខាងជើង និងខាងត្បូងហើយជាស្រេច ។ រួចរាល់ហើយ *តូរ៉ាណាកា* ក៏បង្ហាញមុខចេញ ហើយដើរមួយ១តែម្នាក់ឯងសំដៅជណ្តើរចំហៀងទូក ។ លោកបានបោះចោលគីម៉ូណូស្រីដែលលោកបានពាក់ហើយនិងជូតម្សៅ...



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org